# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៣២

បាលីប្រែ ៥២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# បរមត្ថជោតិកា អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# ខុទ្ទកបាឋ ធម្មបទគាថា ឧទាន

# បឋមភាគ

# ៣២

# បាលីប្រែ ៥២



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៣២

# សុត្តន្តបិដក

## ខុទ្ទកនិកាយ ខុទ្ទកបាឋៈ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

## ខុទ្ទកបាឋ

## សរណាគមន៍

[១] *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ជាគម្រប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ជាគម្រប់ពីរដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ជាគម្រប់ពីរដងផង ។ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរឭក ជាគម្រប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរឭក ជាគម្រប់បីដងផង ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរឭក ជាគម្រប់បីដងផង ។*

*សរណាគមន៍ ចប់*

# អដ្ឋកថា

# ខុទ្ទកនិកាយ

# ឈ្មោះ បរមត្ថជោតិកា

# ខុទ្ទកបាឋ:

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## ពាក្យប្រារព្ធ

និទ្ទេសនេះ ខ្ញុំសូមដល់ព្រះពុទ្ធជាសរណៈ សូមដល់ព្រះធម៌ជាសរណៈ សូមដល់ព្រះសង្ឃជាសរណៈ ។ សូម្បីវារៈទី ២ ទី ៣ ក៏ដូចគ្នា ។ ជានិទ្ទេស អធិប្បាយអំពីការដល់ព្រះរតនត្រ័យ ជាគោលខាងដើមនៃគម្ពីរខុទ្ទបាឋៈ ។

ឥឡូវនេះ ដើម្បីបើកផ្សារ បែក ធ្វើឲ្យងាយនូវអត្ថនៃបាលីនោះ ខ្ញុំនឹងពោលអធិប្បាយសេចក្ដីនេះ ដោយអដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះថា បរមត្ថជោតិកា ដោយពាក្យថា ខ្ញុំសូមនមស្ការព្រះរតនត្រ័យ ដែលឧត្ដមជាងវត្ថុទាំងឡាយ ដែលគួរនមស្ការហើយ និងធ្វើកិច្ចពណ៌នានៃខុទ្ទកបាឋៈ ។ កិច្ចពណ៌នានេះ ខ្ញុំ ជាអ្នកដឹងក្នុងសាសនាតិចតួច ធ្វើបានលំបាកក្រៃលែង ព្រោះខុទ្ទកបាឋៈមានអត្ថជ្រាលជ្រៅក៏ពិត តែព្រោះហេតុដែលការវិនិច្ឆ័យរបស់បុព្វាចារ្យមានជានិច្ច ដល់ថ្ងៃនេះ មួយអន្លើដោយនវង្គសត្ថុសាសនៈ ក៏នៅតាំងនៅ ដូចក្នុងកាលមុន ដូច្នោះ ខ្ញុំអាស្រ័យនវង្គសត្ថុសាសនៈ និងការវិនិច្ឆ័យរបស់បុព្វាចារ្យ

នេះ ទើបប្រាថ្នានឹងពណ៌នាសេចក្តី ដោយការគោរពយ៉ាងក្រៃលែងក្នុងព្រះសទ្ធម្ម មិនមែនបំណងលើកខ្លួន សង្កត់សង្កិនលោកឡើយ សូមលោកទាំងឡាយ តាំងចិត្តស្តាប់នូវកិច្ចពណ៌នាសេចក្តីនេះហោង ។

## **ការកំណត់ខុទ្ទកបាឋៈ**

ខ្ញុំបានពោលក្នុងពាក្យប្រារព្ធនោះថា នឹងធ្វើកិច្ចពណ៌នាសេចក្តីនៃខុទ្ទក-បាឋៈខ្លះ ។ ខ្ញុំចាំបាច់កំណត់ខុទ្ទកបាឋៈទាំងឡាយជាមុនហើយ ទើបនឹងធ្វើកិច្ចពណ៌នាអត្ថឯក្រោយ ឯកទេសចំណែកនីមួយៗ របស់ខុទ្ទកនិកាយ ឈ្មោះថា **ខុទ្ទក**។ ឯកទេសចំណែកនីមួយៗ របស់និកាយទាំង ៥ ឈ្មោះថា **ខុទ្ទកនិកាយ** ពោលដោយធម៌ និងដោយអត្ថ គម្ពីរទាំងនេះមាន ៥ និកាយ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ ឈ្មោះថា **និកាយ ៥** ។

បណ្តានិកាយទាំង ៥ នោះ ព្រះសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម ឈ្មោះថា **ទីឃនិកាយ** ដូចលោកពោលថា និកាយដែលរួបរួមព្រះសូត្រ ៣៤ ចែកជាវគ្គមាន៣ ឈ្មោះថា **ទីឃនិកាយ**។ អនុលោមទី១ ព្រះសូត្រ១៥២ មានមូលបរិយាយសូត្រជាដើម ឈ្មោះថា **មជ្ឈិមនិកាយ**។ ព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ឈ្មោះថា **សំយុត្តនិកាយ**។ ព្រះសូត្រ ៩៥៥៧ មានចិត្តបរិយាទានសូត្រជាដើម ឈ្មោះថា **អង្គុត្តរនិកាយ**។

ខុទ្ទកបាឋៈ ធម្មបទ ឧទាន ឥតិវុត្តកៈ សុត្តនិបាត វិមានវត្ថុ បេតវត្ថុ

ថេរគាថា ថេរីគាថា ជាតក និទ្ទេស បដិសម្ភិទាមគ្គ អបទាន ពុទ្ធវង្ស ចរិយាបិដក ពុទ្ធវចនៈ វៀរវិនយបិដក និងអភិធម្មបិដក ឬនិកាយ ៤ ឈ្មោះថា **ខុទ្ទកនិកាយ** ។

ហេតុអ្វី ទើបនិកាយនេះ លោកហៅថា **ខុទ្ទកនិកាយ** ហេតុជាទីប្រមូលមក ជាទីលំនៅនៃពួកធម៌តូចៗ ជាច្រើន ។ ពិតហើយ ការរួមគ្នា លោកហៅថា **និកាយ** ពោលដោយសាសនា និងដោយលោក ក្នុងសេចក្តីនេះ មានសាធកជាដើមយ៉ាងនេះ គឺម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាននេះ ដ៏វិចិត្រយ៉ាងណា ចិត្តណាដែលវិចិត្រយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញ សូម្បីនូវពួកធម៌មួយ ដទៃអំពីចិត្តនោះឡើយ ។ ពួកក្សត្របោណិក ពួកក្សត្រចិក្ខល្លិកា ។ ឯកទេសចំណែកមួយរបស់ខុទ្ទកនិកាយនោះ មានដូច្នេះ ពួកធម៌តូចៗ ដែលទាក់ទងក្នុងព្រះសុត្តន្តបិដកទាំងនេះ សំដៅយកទីដែលបើកផ្សារ ចែក ធ្វើឲ្យផ្សាយដោយអត្ថ ខុទ្ទកបាឋៈ ៩ ប្រភេទ គឺ សរណសិក្ខាបទ ទ្វត្តឹសាការ កុមារបញ្ហា ( សាមណេរបញ្ហា ) មង្គលសូត្រ រតនសូត្រ តិរោកុឌ្ឌសូត្រ និធិកណ្ឌសូត្រ និងមេត្តសូត្រ ជាចំណែកខាងដើមនៃពួកធម៌ទាំងនោះ ដោយអាចារ្យខាងក្រោយមក លើកឡើងប្រាប់បង្រៀន មិនជាពាក្យដែលព្រះមានព្រះភាគត្រាស់ ។ ពិតហើយ គាថាទាំងនេះ ព្រះមានមានព្រះភាគត្រាស់ថា

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។**

**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**

*កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណរវល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខ រឿយៗ ។*

*នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។*

*ឈ្មោះថា ជាបឋមពុទ្ធវចនៈទាំងអស់ ព្រោះជាព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ដែលឈ្មោះថា បឋមពុទ្ធតម្រាស់នោះ ក៏ព្រោះត្រាស់ដោយព្រះមនស មិនមែនទ្រង់បន្លឺព្រះវាចាត្រាស់ឡើយ ចំណែកព្រះគាថានេះថា*

**យទា ហវេ បាតុភវន្តិ ធម្មា**
**អាតាបិនោ ឈាយតោ ព្រាហ្មណស្ស**
**អថស្ស កង្ខា វបយន្តិ សព្វា**
**យតោ ខយំ បច្ចយានំ អវេទីតិ ។**

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមាន
ព្យាយាម ញុំាងកិលេសឲ្យក្តៅ អ្នកដុតបង់នូវ
កិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយ
ទាំងពួង របស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ក្នុង
កាលនោះ ព្រោះដឹងច្បាស់នូវធម៌ ព្រមទាំងហេតុ ។

ឈ្មោះថា ជាបឋមពុទ្ធតម្រាស់ ព្រោះជាព្រះតម្រាស់ដែលព្រះមានព្រះភាគទ្រង់បន្លឺព្រះវាចាត្រាស់ ។ ព្រោះដូច្នោះ ខុទ្ទកបាឋៈ ៩ ប្រភេទនេះ ឈ្មោះថា ជាគោលខាងដើមនៃពួកធម៌តូចៗ ទាំងនេះ យើងនឹងផ្តើមពណ៌នាសេចក្តីនៃខុទ្ទកបាឋៈនោះ តាំងអំពីនេះជាដើមទៅ ។

## និទានសោធនៈ

[១] វាចានេះថា **ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ** ជាពាក្យខាងដើមនៃពាក្យផ្តើមនោះ ខ្ញុំសូមពណ៌នាអត្ថនៃពាក្យផ្តើមនោះ ដូច្នេះថា ត្រៃសរណៈ អ្នកណាពោល ពោលក្នុងទីណា ពោលក្នុងកាលណា ពោលព្រោះហេតុអ្វី ។ ម្យ៉ាងទៀត ដែលមិនបានត្រាស់ខាងដើម ព្រោះហេតុអ្វី ទើបក្នុងទីនេះពោលថា ត្រាស់ជាប្រការដំបូង ចាំបាច់ត្រូវជម្រះពាក្យផ្តើមខាងដើម បន្ទាប់អំពីនេះទៅ ក្នុងពាក្យផ្តើម ក៏នឹងចង្អុលបង្ហាញរឿងព្រះពុទ្ធ រឿងការដល់សរណៈ និងរឿងបុគ្គលដែលដល់សរណៈ និងសម្តែងការដាច់ ការមិនដាច់នៃសរណគមន៍ ទាំងផល ទាំងសរណៈដែលគួរដល់ក្នុងសរណៈ ២ មាន **ធម្មំ សរណំ** ជាដើម ក៏ស្គាល់

ហើយថា មានន័យយ៉ាងនេះ និងអធិប្បាយហេតុក្នុងការកំណត់ដោយលំដាប់ និងប្រកាសត្រៃសរណៈនោះ ដោយឧបមាទាំងឡាយ ។

បណ្ដាគាថាទាំងនោះ គាថាដំបូង មានប្រស្នា ៥ ប្រការ គឺត្រៃសរណៈ បុគ្គលណាពោល ១ ពោលក្នុងទីណា ១ ពោលអំពីពេលណា ១ ពោលព្រោះហេតុអ្វី ១ ព្រះតថាគតមិនបានត្រាស់មកអំពីមុន ព្រោះហេតុអ្វី ទើបក្នុងទីនេះបានត្រាស់ជាដំបូង ។

នឹងវិសជ្ជនាប្រស្នាទាំង ៥ នោះថា ប្រស្នាថា អ្នកណាពោល ឆ្លើយថា ព្រះមានព្រះភាគត្រាស់ មិនមែនសាវក មិនមែនឥសីទាំងឡាយ មិនមែនទេវតាពោល ។

ប្រស្នាថា ពោលទីណា វិសជ្ជនាថា ត្រង់ឥសិបតនមិគទាយវ័ន ក្រុងពារាណសី ។

ប្រស្នាថា ពោលអំពីពេលណា ឆ្លើយថា កាលព្រះយសសម្រេចអរហត្តមួយអន្លើដោយសម្លាញ់ទាំងឡាយ កាលព្រះអរហន្ត ៦១ ធ្វើការសម្ដែងធម៌ក្នុងលោក ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ជនច្រើន ។

បញ្ហាថា ពោលព្រោះហេតុអ្វី ឆ្លើយថា ដើម្បីបព្វជ្ជា និងដើម្បីឧបសម្បទា ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រនោះ ភិក្ខុគប្បីកោរសក់ និងពុកមាត់ឲ្យជាដំបូង ហើយឲ្យស្លៀកសំពត់កាសាយៈទាំង-ឡាយ រួចឲ្យពាក់ចីវរឆៀងស្មាម្ខាងឲ្យថ្វាយបង្គំបាទាភិក្ខុទាំងឡាយ ហើយឲ្យអង្គុយប្រហោង ផ្គងអញ្ជលីឡើង រួចប្រាប់ថា អ្នកចូរពោលពាក្យយ៉ាងនេះថា

ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីរឭក ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីរឭក ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីរឭក ។

ប្រស្នាថា ព្រោះហេតុអ្វី ទើបក្នុងទីនេះ ត្រាស់ជាដំបូង វិសជ្ជនាថា ព្រោះទេវតា និងមនុស្សនាំគ្នាចូលកាន់សាសនា ជាឧបាសកខ្លះ ជាបព្វជិតខ្លះ ដោយផ្លូវនេះ ដូច្នោះ ទើបគួរដឹងថា នវង្គសត្ថុសាសនៈនេះ បុព្វាចារ្យទាំង-ឡាយបង្រួបបង្រួមក្នុងបិដកទាំង ៣ លើកឡើងកាន់ការប្រៀនប្រដៅ ទើបពោលថា ត្រាស់ជាដំបូងក្នុងខុទ្ទកបាឋៈនេះ ព្រោះជាផ្លូវចូលកាន់សាសនា ។

# ពណ៌នា ត្រៃសរណៈ

## អំពីពុទ្ធៈដោយអត្ថ

ឥឡូវនេះ ពាក្យណាខ្ញុំពោលថា នឹងចង្អុលបង្ហាញរឿងព្រះពុទ្ធ រឿងការដល់សរណៈ និងរឿងបុគ្គលដល់សរណៈ ក្នុងពាក្យនោះ សត្វពិសេសឈ្មោះថា **ពុទ្ធ** ព្រោះបញ្ញត្តអាស្រ័យខន្ធសន្តានដែលត្រូវអប់រំ ដោយការសម្រេចអនុត្តរវិមោក្ខដែលជានិមិត្តនៃព្រះញាណឯណា ដែលរារាំងមិនបាន ឬព្រោះបញ្ញត្តអាស្រ័យការត្រាស់ដឹងឯងក្រៃលែងនូវសច្ចៈ ដែលជាបទដ្ឋាននៃព្រះសព្វញ្ញុតញ្ញាណ ដូចដែលលោកពោលថា

ព្រះមានព្រះភាគអង្គណា ទ្រង់កើតឯង មិនមានអាចារ្យ ត្រាស់ដឹងសច្ចៈទាំងឡាយ ដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ឮមកក្នុងកាលមុន ព្រះអង្គទ្រង់ដល់នូវភាពជាសព្វញ្ញូ ក្នុងសច្ចៈទាំងនោះផង ទ្រង់

ដល់នូវភាពជាអ្នកស្គាត់ ក្នុងពលៈទាំងឡាយផង ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **ពុទ្ធ** ។ ការចង្អុលបង្ហាញរឿងព្រះពុទ្ធដោយអត្ថប៉ុណ្ណោះសិន ។

## អំពី ពុទ្ធៈ ដោយព្យញ្ជនៈ

បើពោលដោយព្យញ្ជនៈគប្បីជ្រាបដោយន័យជាដើមយ៉ាងនេះថា ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់ជាបុគ្គលត្រាស់ដឹង ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់ជាអ្នកដាស់ឲ្យភ្ញាក់ សមដូចលោកពោលថា

សំណួរត្រង់ពាក្យថា **ពុទ្ធ** ចុះឈ្មោះថា **ពុទ្ធ** ដោយអត្ថដូចម្តេច ។ ឈ្មោះថា **ព្រះពុទ្ធ** ព្រោះហេតុទ្រង់ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះហេតុទ្រង់ញុំាងពពួកសត្វឲ្យត្រាស់ដឹង ។ ឈ្មោះថា **ពុទ្ធ** ព្រោះព្រះអង្គដឹងធម៌ទាំងពួង ។ ឈ្មោះថា **ពុទ្ធ** ព្រោះព្រះអង្គឃើញធម៌ទាំងពួង ។ ឈ្មោះថា **ពុទ្ធ** ព្រោះព្រះអង្គដឹងច្បាស់ ។ ឈ្មោះថា **ពុទ្ធ** ព្រោះព្រះអង្គរីកហើយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះគេពោលថា ព្រះអង្គមានឧបក្កិលេសដកហើយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះហេតុទ្រង់ ប្រាសចាករាគៈ ដោយចំណែកមួយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះហេតុទ្រង់ប្រាសចាកទោសៈ ដោយចំណែកមួយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះហេតុទ្រង់ប្រាសចាកមោហៈ ដោយចំណែកមួយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះហេតុទ្រង់មានកិលេសចេញហើយដោយចំណែកមួយ ។ ឈ្មោះថា **ពុទ្ធ** ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។ ឈ្មោះថា **ពុទ្ធ** ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់

ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតដទៃក្រៅលែងជាង ។ ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់កម្ចាត់បង់សេចក្ដីល្ងង់ ព្រោះការបាននូវប្រាជ្ញា ។ ព្រះនាម **ពុទ្ធ** នុ៎ះ មិនមែនព្រះមាតាថ្វាយ មិនមែនព្រះបិតាថ្វាយ មិនមែនបងប្អូនប្រុសថ្វាយ មិនមែនបងប្អូនស្រីថ្វាយ មិនមែនពួកមិត្ត និងអមាត្យថ្វាយ មិនមែនពួកញាតិ និងសាលោហិតថ្វាយ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា **ពុទ្ធ** នុ៎ះ របស់ព្រះពុទ្ធទាំងឡាយមានព្រះភាគ ជាព្រះនាមកើតក្នុងទីបំផុតនៃវិមោក្ខប្បញ្ញត្តិថា **ពុទ្ធ** នេះ កើតព្រោះការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណ ទៀបគល់ពោធិព្រឹក្ស ហេតុនោះ ( លោកពោលថា ) **ពុទ្ធ** ។

ក្នុងបទថា **ពុទ្ធ** នុ៎ះ ឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា ត្រាស់ដឹងសច្ចៈទាំងឡាយ ដូចបុគ្គលដែលចុះមកក្នុងលោក ក៏ហៅថា អ្នកចុះមក( អវតារ ) ឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា ទ្រង់ដាស់ពួកសត្វឲ្យភ្ញាក់ ដូចខ្យល់ដែលធ្វើស្លឹកឈើឲ្យស្ងួត ក៏ហៅថា ស្លឹកឈើស្ងួត ។ ពាក្យថា ព្រោះព្រះអង្គដឹងធម៌ទាំងពួង លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** ព្រោះការដឹងដែលអាចដឹងបានគ្រប់យ៉ាង ។ ពាក្យថា ព្រោះព្រះអង្គឃើញធម៌ទាំងពួង លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** ព្រោះការដឹងដែលអាចដឹងធម៌បានគ្រប់យ៉ាង ។ ពាក្យថា ព្រោះព្រះអង្គដឹងច្បាស់ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** ព្រោះត្រាស់ដឹងឯង មិនមែនអ្នកដទៃធ្វើឲ្យត្រាស់ដឹង ។ ពាក្យថា ព្រោះព្រះអង្គរីកហើយ លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់រីក ព្រោះរីកដោយព្រះគុណ

*ច្រើនប្រការ ដូចផ្កាឈូករីក ។ ដោយពាក្យថា ព្រោះគេពោលថា ព្រះអង្គមានអាសវៈអស់ហើយជាដើម លោកអធិប្បាយថា ឈ្មោះថា* **ពុទ្ធ** *ព្រោះទ្រង់ភ្ញាក់ហើយ ព្រោះអស់កិលេស ដូចការដេកលក់គ្រប់យ៉ាង ដូចបុរសភ្ញាក់ ព្រោះអស់ការដេកលក់ ព្រោះទ្រង់លះធម៌ ដែលធ្វើការរួញរានៃចិត្តបាន ។ លោកពោលថា ព្រោះហេតុទ្រង់ទៅហើយកាន់ផ្លូវ ជាទីទៅនៃបុគ្គលម្នាក់ឯង ដូច្នេះ ក៏ដើម្បីសម្តែងថា ព្រះមានព្រះភាគ លោកហៅថា* **ពុទ្ធ** *ព្រោះទ្រង់យាងតាមឯកាយនមគ្គ ដូចបុរសដើរផ្លូវ គេក៏ហៅថា អ្នកដើរទៅ ព្រោះបរិយាយនៃអត្ថថា ទៅកាន់ផ្លូវត្រាស់ដឹង ។ ពាក្យថា ព្រោះហេតុទ្រង់ជាបុគ្គលឯក ត្រាស់ដឹងចំពោះសម្មាសម្ពោធិញ្ញាណ មិនមានគុណជាតដទៃក្រៃលែងជាង លោកអធិប្បាយថា ឈ្មោះថា* **ពុទ្ធ** *មិនមែន ព្រោះត្រាស់ដឹងដោយអ្នកដទៃ ដែលពិត ឈ្មោះថា* **ពុទ្ធ** *ព្រោះត្រាស់ដឹងក្រៃលែងនូវសម្មាសម្ពោធិដ៏កំពូល ដោយព្រះអង្គឯងប៉ុណ្ណោះ ។ ពាក្យថា ព្រោះទ្រង់កម្ចាត់បង់សេចក្តីល្ងង់ ព្រោះការបាននូវប្រាជ្ញា ជាពាក្យសម្តែងបរិយាយថា* **ពុទ្ធិ ពុទ្ធំ ពោធោ** ។ *ក្នុងពាក្យនោះ គប្បីជ្រាបអត្ថដែលអាចធ្វើ* **ពុទ្ធ** *សព្ទរបស់បទទាំងអស់ឲ្យសម្រេចសេចក្តី ដោយន័យយ៉ាងនេះថា លោកអធិប្បាយដើម្បីឲ្យដឹងថា* **ពុទ្ធ** *ព្រោះទ្រង់ប្រកបដោយព្រះគុណ គឺ* **ពុទ្ធិ** *ដូចគេតែងហៅថា សំពត់ខៀវ សំពត់ក្រហម ព្រោះប្រកបដោយពណ៌ខៀវ ពណ៌ក្រហម បន្ទាប់អំពីនោះ ពាក្យថា ព្រះនាមថា* **ពុទ្ធ** *នុ៎ះ ជាដើម លោកពោលក៏ដើម្បីឲ្យដឹងថា បញ្ញត្តនេះប្រព្រឹត្តទៅតាមអត្ថ គឺន័យសេចក្តី ។ ការ*

ចន្ទុលអំពីពុទ្ធដោយព្យញ្ជនៈមានដូចពោលមកនេះ ។

## អំពីការដល់សរណាគមន៍
## និងរឿងបុគ្គលដែលចូលដល់សរណាគមន៍

ឥឡូវនេះ នឹងចន្ទុលបង្ហាញក្នុងរឿងការដល់សរណាគមន៍ជាដើម ដូចតទៅនេះ ព្រះរតនត្រ័យ ឈ្មោះថា **សរណ** ព្រោះកម្ចាត់ អធិប្បាយថា សង្កត់សង្កិន ទម្លាយ នាំចេញ រម្ងត់ភ័យ គឺសេចក្ដីខ្លាច ការតក់ស្លុត ទុក្ខ ទុគ្គតិ ការសៅហ្មង ដោយការដល់សរណៈនោះឯងរបស់មនុស្សទាំងឡាយ ដែលដល់សរណគមន៍ ។ ម្យ៉ាងទៀត ព្រះពុទ្ធ ឈ្មោះថា **សរណ** ព្រោះកម្ចាត់ភ័យរបស់សត្វទាំងឡាយ ដោយការឲ្យចូលដល់វត្ថុដែលជាប្រយោជន៍ និងនាំចេញចាកវត្ថុដែលមិនជាប្រយោជន៍ ។ ព្រះធម៌ ឈ្មោះថា **សរណ** ព្រោះឲ្យសត្វឆ្លងកន្តារ គឺភព និងឲ្យនូវការស្រឡះនៃចិត្ត ។ ព្រះសង្ឃ ឈ្មោះថា **សរណ** ព្រោះធ្វើសក្ការៈ សូម្បីតិចតួច ឲ្យត្រឡប់បាននូវផលដ៏បរិបូណ៌ ព្រោះដូច្នោះ ទើបរតនត្រ័យនោះ ឈ្មោះថា **សរណ** ដោយបរិយាយដូចពោលមកនេះ ។

ចិត្តុប្បាទដែលការជ្រះថ្លា ក្នុងព្រះរតនត្រ័យនេះ និងការគោរពក្នុងព្រះ-រតនត្រ័យនោះ កម្ចាត់ ទម្លាយនូវកិលេសបាន ប្រព្រឹត្តទៅដោយអាការ គឺការមានព្រះរតនត្រ័យនោះជាខាងមុខ ឬមិនមានអ្នកដទៃជាបច្ច័យ ឈ្មោះថា **សរណាគមន៍។** សត្វដែលដល់ព្រមដោយចិត្តុប្បាទនោះ រមែងដល់ព្រះរតន-ត្រ័យនោះជាសរណៈ អធិប្បាយថា រមែងចូលដល់ព្រះរតនត្រ័យ ដោយ

*ចិត្តុប្បាទ ដែលមានប្រការដូចពោលហើយយ៉ាងនេះថា* **ឯស មេ សរណំ ឯស មេ បរាយណំ** *នេះជាសរណៈរបស់ខ្ញុំ នេះជាទីទៅខាងមុខរបស់ខ្ញុំ ។ បុគ្គលកាលចូលដល់ រមែងចូលដល់ដោយវិធីសមាទាន ដូចនាយពាណិជ្ជ ២ នាក់ ឈ្មោះតបុស្សៈ និងភល្លិកៈជាដើមថា* **ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ឧបាសកេ នោ ភគវា ធារេតុ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំង ២ សូមដល់នូវព្រះមានព្រះភាគ និងព្រះធម៌ជាសរណៈ សូមព្រះមានព្រះភាគ ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គទាំង ២ ថាជាឧបាសក ដូច្នេះក៏បាន ។*

*ចូលដល់ដោយវិធីយល់ព្រមធ្វើជាសិស្ស ដូចព្រះមហាកស្សបៈ[1] ជាដើមថា* **សត្ថា មេ ភន្តេ ភគវា សាវកោហមស្មិ** *បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ជាគ្រូរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ដូច្នេះក៏បាន ។*

*ចូលដល់ដោយវិធីបង្អោនខ្លួន ទៅក្នុងព្រះរតនត្រ័យនោះ ដូចព្រហ្មាយុព្រាហ្មណ៍ជាដើម តាមបាលីថា* **ឯវំ វុត្តេ ព្រហ្មាយុ ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ** *កាលបើឧត្តរមាណពពោលយ៉ាងនេះហើយ ព្រហ្មាយុព្រាហ្មណ៍ក៏ក្រោកអំពីអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះត្រង់ទីដែលព្រះមាន-*

---

*១- កស្សបៈ ក្នុងទីនេះ បានដល់ឧរុវេលកស្សបៈ*

ព្រះភាគគង់ បន្លឺនូវឧទានវាចាអស់វារៈ ៣ ដងថា សូមថ្វាយបង្គំ ព្រះមាន-ព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ... សូមថ្វាយបង្គំ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ដូច្នេះក៏បាន ។

ចូលដល់ដោយវិធីប្រគល់ខ្លួន ដូចយោគីបុគ្គលដែលខ្វល់ខ្វាយក្នុងកម្ម-ដ្ឋានក៏បាន ។

ចូលដល់ដោយវិស័យ និងដោយកិច្ចច្រើនវិធី ដូចជាដោយវិធីកម្ចាត់ឧបក្កិលេសដោយការដល់សរណគមន៍ ដូចព្រះអរិយបុគ្គលទាំងឡាយក៏បាន ។ អំពីការដល់សរណគមន៍ និងរឿងបុគ្គលដែលចូលដល់សរណ-គមន៍ដូចពោលមកនេះ ។

## អំពីសរណៈដាច់ មិនដាច់

## និងផលរបស់សរណគមន៍

ឥឡូវនេះ នឹងសម្តែងសរណគមន៍ដាច់ជាដើម ដែលខ្ញុំពោលថា នឹងសម្តែងសរណគមន៍ដាច់ និងមិនដាច់ មួយអន្លើដោយផល និងសរណៈដែលគួរដល់ ដូចតទៅនេះថា ការដាច់សរណគមន៍របស់បុគ្គលដែលដល់សរណ-គមន៍យ៉ាងនេះ មាន ២ យ៉ាង គឺមានទោស និងមិនមានទោស ការដាច់សរណគមន៍ព្រោះការស្លាប់ ឈ្មោះថា មិនមានទោស ការដាច់សរណគមន៍ព្រោះងាកទៅរាប់អានសាសនាដទៃ និងប្រព្រឹត្តខុសក្នុងព្រះសាស្តា ឈ្មោះថាមានទោស ។ ការដាច់ទាំង ២ នោះ រមែងមានដល់ពួកបុថុជ្ជនប៉ុណ្ណោះ សរណៈនៃបុថុជ្ជនទាំងនោះ រមែងឈ្មោះថា សៅហ្មង ព្រោះប្រព្រឹត្តទៅដោយ

ការមិនដឹង ការសង្ស័យ និងការដឹងខុស ព្រោះប្រព្រឹត្តមិនអើពើជាដើមក្នុងព្រះពុទ្ធគុណទាំងឡាយ ឯព្រះអរិយបុគ្គល មិនមានសរណៈដាច់ទៅឡើយ ឯការសៅហ្មងនៃសរណៈក៏មិនមាន ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ឧទ្ទិសខ្ទួនចំពោះគ្រូដទៃ ដោយហេតុឯណា ហេតុនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺថា ហេតុនុ៎ះមិនដែលមានឡើយ ។ ឯពួកបុថុជ្ជនមិនទាន់ដាច់សរណៈដរាបណា ដរាបនោះ ក៏នៅឈ្មោះថា ជាអ្នកមានសរណៈមិនដាច់ ការដាច់សរណៈនៃបុថុជ្ជនទាំងនោះរមែងមានទោស មានការសៅហ្មង និងឲ្យផលមិនគួរប្រាថ្នា ការដាច់សរណៈដែលមិនមានទោស ក៏មិនមានផល ព្រោះមិនមានវិបាក ។ ឯការមិនដាច់សរណៈ ពោលដោយផល ក៏រមែងឲ្យផលដែលគួរប្រាថ្នាតែម្យ៉ាង ដូចព្រះតម្រាស់ថា

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន ដូច្នេះ ។

ក្នុងសេចក្តីនោះ គប្បីជ្រាបអធិប្បាយនៃគាថាយ៉ាងនេះថា ជនពួកណាដល់នូវសរណៈ ដោយការកាត់ឧបក្កិលេសបានដោយសរណគមន៍ ជនពួកនោះ នឹងមិនទៅអបាយ ។ ឯជនក្រៅអំពីនោះ នឹងមិនទៅអបាយ ក៏ដោយការដល់សរណៈ ។

សម្តែងសរណៈដាច់មិនដាច់ និងផលមានប្រមាណប៉ុណ្ណោះ ។

# អំពីសរណៈដែលគួរដល់

ក្នុងការសម្ដែងសរណៈដែលគួរដល់ បុគ្គលអ្នកចោទសួរ ពោលថា ក្នុងពាក្យថា ខ្ញុំដល់ព្រះពុទ្ធជាសរណៈ បុគ្គលណាដល់ព្រះពុទ្ធជាសរណៈ បុគ្គលនោះ នឹងគប្បីដល់ព្រះពុទ្ធ ឬសរណៈទាំង ២ ពាក្យ ការពោលតែពាក្យ ១ ក៏ឥតប្រយោជន៍ ព្រោះហេតុអ្វី ព្រោះមានតែកិរិយា គឺការដល់មិនមានកម្ម ២ សេចក្ដីពិត អ្នកគិតខាងអក្ខរសាស្ត្រ មិនបំណាងកម្ម ២ ក្នុងសេចក្ដីនេះ ដូចក្នុងពាក្យថា **អជំ គាមំ នេតិ** ជាដើមដូច្នោះ ។

បើបុគ្គលអ្នកសួរពោលថា ការពោលពាក្យទាំង ២ មានតែប្រយោជន៍តែម្យ៉ាង ដូចក្នុងពាក្យថា **គច្ឆតេវ បុព្វំ ទិសំ គច្ឆតិ បច្ឆិមំ ទិសំ** អ្នកគិតអក្ខរសាស្ត្រមិនបំណាងយកយ៉ាងនោះទេ ព្រោះលោកមិនបំណាងយកថា ព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា សេចក្ដីពិត កាលបំណាងថា ព្រះពុទ្ធ និងសរណៈទាំងនោះ ជាតួហេតុស្មើៗ គ្នាហើយ បុគ្គលមានចិត្តអាក់អន់ ចូលគាល់ព្រះពុទ្ធ ក៏នឹងគប្បីឈ្មោះថា ដល់នូវព្រះពុទ្ធ ដល់នូវសរណៈ សរណៈនោះធ្វើឲ្យផ្សេងទៀតថា ព្រះពុទ្ធ ។ បុគ្គលនោះក៏ឈ្មោះថា ដល់នូវសរណៈទាំងអស់ ។

បើអ្នកសួរពោលថា លោកបំណាងយកភាពដែលព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា ព្រោះបាលីថា **ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ** សរណៈនោះឯងក្សេម ផុតភ័យ សរណៈនោះឧត្ដម មិនបំណាងដូច្នោះឡើយ ព្រោះក្នុងបទគាថានោះ មានតែព្រះពុទ្ធជាសរណៈ សេចក្ដីពិត ក្នុងបទគាថានោះ លោកបំណាងដល់ភាពដែលព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា

យ៉ាងនេះថា សរណៈក្សេមផង ឧត្តមផង ព្រោះពិចារណាដល់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមនោះ ក្នុងភាពជាសរណៈ ដែលរាប់បានថា កម្ចាត់ភ័យ ដល់បុគ្គលដែលដល់សរណគមន៍បានពិត ឯក្នុងបាលីបទេសដទៃ កាលមាន ការសម្ពន្ធដោយបុគ្គលដល់សរណគមន៍ លោកក៏មិនបំណងភាពដែលព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗ គ្នា ព្រោះមិនសម្រេចជាសរណគមន៍ ដូច្នោះ ទើបពាក្យនេះ សាធកមិនបាន ។

បើអ្នកសួរពោលថា គួរសំដៅយកភាពដែលព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗ គ្នា ព្រោះសម្រេចជាសរណគមន៍ កាលមានការសម្ពន្ធដោយបុគ្គលដែលដល់សរណគមន៍បាន ក្នុងបាលីនេះថា **ឯតំ សរណមាគម្ម សព្វ-ទុក្ខា បមុច្ចតិ** បុគ្គលអាស្រ័យសរណៈនោះ រមែងរួចផុតចាកទុក្ខទាំងពួង ដូច្នេះ មិនមែនដូច្នោះទេ ព្រោះជាប់ជំពាក់ដោយទោស ដែលពោលមកមុនហើយ ។ សេចក្តីពិត ក្នុងសេចក្តីនោះ គប្បីជាប់ជំពាក់ដោយទោសដែលពោលអំពីមុនថា កាលព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា បុគ្គលមានចិត្តអាក់អន់ អាស្រ័យសរណៈ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក៏គប្បីរួចផុតចាកទុក្ខបានទាំងអស់ទៅហើយ តែមិនជាប់ជំពាក់ដោយទោសក៏មិនមែន ដូច្នោះ ទើបពាក្យនោះលើកមកសាធកមិនបាន ។ គប្បីជ្រាបអធិប្បាយក្នុងសេចក្តីនោះយ៉ាងនេះថា សត្វទាំងឡាយកាលនឹងរួចផុតដោយអានុភាពរបស់ព្រះមានព្រះភាគ ដែលជាកល្យាណមិត្ត លោកក៏ពោលថា អាស្រ័យកល្យាណមិត្ត ទើបរួចផុតបាន ដូចក្នុងបាលីថា

ម្នាលអានន្ទ សត្វទាំងឡាយ មានជាតិជាធម្មតា រមែងរួចចាកជាតិ ក៏ព្រោះអាស្រ័យនឹងតថាគតជាមិត្តល្អ យ៉ាងណា ក្នុងទីនេះ បុគ្គល កាលរួចផុតដោយអានុភាពនៃសរណៈ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ លោកក៏ពោលថា បុគ្គលអាស្រ័យសរណៈនេះ រមែងរួចផុតចាកទុក្ខទាំងពួង ដូច្នេះ ក៏យ៉ាងនោះ ។

ភាពដែលព្រះពុទ្ធជាគមនីយក៏មិនត្រូវ ភាពដែលសរណៈជាគមនីយក៏មិនត្រូវ ភាពដែលព្រះពុទ្ធ និងសរណៈទាំង ២ ជាគមនីយក៏មិនត្រូវ ដោយប្រការទាំងពួងយ៉ាងនេះ គមនីយរបស់បុគ្គលដល់នូវសរណគមន៍ ដែលលោកអធិប្បាយថា ខ្ញុំដល់វត្ថុដែលគប្បីប្រាថ្នា គួរពោលដល់ បន្ទាប់អំពីនោះ ក៏គួរពោលយុត្តិ គឺប្រការដែលត្រូវក្នុងរឿងនេះ ដូច្នោះ ខ្ញុំនឹងពោលយុត្តិដូចតទៅនេះថា

ក្នុងយុត្តិនោះ ព្រះពុទ្ធប៉ុណ្ណោះជាគមនីយ តែដើម្បីសម្តែងអាការ គឺការដល់ពាក្យពោលដល់សរណៈនោះ មានពាក្យថា ខ្ញុំដល់ព្រះពុទ្ធ ជាសរណៈ ព្រះពុទ្ធអង្គនោះជាសរណៈរបស់ខ្ញុំ ព្រះពុទ្ធអង្គនោះជាបារាយណៈរបស់ខ្ញុំ ជាអ្នកកម្ចាត់ទុក្ខ ជាបុគ្គលទ្រទ្រង់នូវប្រយោជន៍ ខ្ញុំដល់ ខ្ញុំគប់រក ខ្ញុំសេព ខ្ញុំចូលជិតព្រះពុទ្ធអង្គនោះ ដោយបំណងដូចពោលមកនេះ ឬពោលថា ខ្ញុំដឹងយ៉ាងនេះ ពិតហើយ គតិជាប្រយោជន៍របស់ធាតុពួកណា សូម្បីការដឹង ក៏ជាប្រយោជន៍របស់ធាតុទាំងនោះ ។

បើអ្នកសួរ ពោលថា សេចក្តីនោះ មិនត្រូវ ព្រោះមិនប្រកប **ឥតិ** សព្ទ

ពាក្យចោទនោះក៏មិនត្រឹមត្រូវ យុត្តិដែលត្រឹមត្រូវក្នុងរឿងនោះគប្បីមានដូច្នេះថា បើសេចក្ដីក្នុងរឿងនោះគប្បីមានយ៉ាងនេះសោត បន្ទាប់អំពីនោះ ក៏គប្បីត្រូវប្រកប **ឥតិ** សព្ទ ដូចក្នុងប្រយោគទាំងឡាយជាដើមថា **អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ បជានាតិ** រមែងដឹងច្បាស់នូវរូបដែលមិនទៀងតាមសេចក្ដីពិតថា រូបមិនទៀង ដូច្នេះ ។ តែ **ឥតិ** សព្ទ លោកមិនប្រកបឡើយ ព្រោះដូច្នោះ ទើបការចោទសួរនោះមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះអត្ថនៃ **ឥតិ** សព្ទ មាននៅក្នុងខ្លួននោះហើយ អត្ថនៃ **ឥតិ** សព្ទក្នុងទីនេះក៏មានព្រម ដូចក្នុងប្រយោគទាំងឡាយជាដើមយ៉ាងនេះថា **យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ** បុគ្គលណាដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈ ដូច្នេះ តែមិនមែនត្រូវប្រកប **ឥតិ** ក្នុងទីគ្រប់អន្លើ ព្រោះមានការនៅព្រមក្នុងខ្លួនហើយ បណ្ឌិតគប្បីជ្រាបអត្ថនៃ **ឥតិ** សព្ទ សូម្បីមិនបានប្រកប ដូចប្រកបក្នុងទីនោះ ទាំងក្នុងទីដទៃដែលមានកំណើតយ៉ាងនេះ ព្រោះដូច្នោះ ទើប **ឥតិ** សព្ទ មិនមានទោស ។ បើអ្នកសួរ ពោលថា ពាក្យណាដែលអ្នកពោលថា ដើម្បីសម្ដែងអាការ គឺដល់ ទើបត្រូវពោលប្រារព្ធសរណៈ ដូច្នេះ ពាក្យនោះក៏មិនត្រឹមត្រូវ ព្រោះសរណៈប៉ុណ្ណោះ ជាគមនីយ គឺវត្ថុដែលគួរដល់ បានក្នុងបាលីជាដើមថា ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតបព្វជ្ជា ... ដោយត្រៃសរណគមន៍ទាំងឡាយនេះ ដូច្នេះពាក្យដែលខ្ញុំពោលនោះ មិនមែនមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះពាក្យនោះមានការនៅព្រមក្នុងខ្លួន ។ សេចក្ដីពិត អត្ថនៃ **ឥតិ** សព្ទនោះ ក៏មាន

ព្រមក្នុងពាក្យទាំងនោះឯង ព្រោះមិនប្រកប **ឥតិ** សព្ទ ដូចពាក្យមុន ក៏គប្បីឃើញដូចប្រកប **ឥតិ** សព្ទ ក្រៅអំពីនេះ ក៏គប្បីជាប់ជំពាក់ដោយទោស ដែលពោលមក អំពីមុននោះឯង ព្រោះដូច្នោះ គប្បីកាន់យកតាមដែលលោកប្រៀនប្រដៅប៉ុណ្ណោះ ។

សម្តែងវត្ថុដែលគួរដល់ ដូចពោលមកដូច្នេះ

## អំពីសរណៈ គឺព្រះធម៌ និងព្រះសង្ឃ

ឥឡូវនេះ នឹងពោលអធិប្បាយតទៅ ក្នុងពាក្យដែលខ្ញុំពោលទុកថា ក្នុងសរណៈទាំង ២ មាន **ធម្មំ សរណំ** ជាដើម ក៏ដឹងហើយថា មានន័យនេះដូចគ្នា ។ ន័យនៃការពណ៌នាអត្ថនេះ ខ្ញុំពោលក្នុងពាក្យនេះថា **ពុទ្ធំ សរណំ គច្ឆាមិ** ក៏គប្បីជ្រាបន័យនៃការពណ៌នាសេចក្តីនោះ ក្នុង ២ បទនេះថា **ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ។** ពិតហើយ ក្នុងសេចក្តីនោះ ពោលដោយអត្ថ និងព្យញ្ជនៈរបស់ព្រះធម៌ និងព្រះសង្ឃ ក៏មានត្រឹមតែការបន្តុលបង្ហាញប៉ុណ្ណោះ ដែលមិនដូចគ្នាក្រៅអំពីនោះក៏ដូចគ្នា ដូចដែលពោលមកហើយនោះឯង ព្រោះនឹងពោលអធិប្បាយចំពោះទីដែលមិនដូចគ្នា ក្នុងព្រះធម៌ និងព្រះសង្ឃនេះ ដូច្នេះ អាចារ្យមួយពួកពោលថា មគ្គ ផល និព្វាន ឈ្មោះថា ព្រះធម៌ ។ ខន្តិ ការពេញចិត្ត ឬមតិរបស់ពួកយើងថា មគ្គ និងវិរាគៈប៉ុណ្ណោះ ឈ្មោះថា ព្រះធម៌ក្នុងអត្ថនេះ ព្រោះទ្រទ្រង់បុគ្គលចម្រើនមគ្គផលនិងដែលធ្វើឲ្យជាក់ច្បាស់ព្រះនិព្វានហើយ ដោយមិនឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ និងធ្វើឲ្យស្រឡះចិត្តយ៉ាងក្រៃលែង សូមលើកយកអគ្គប្បសាទ-

សូត្រនោះឯងជាសាធក សមដូចព្រះមានព្រះភាគត្រាស់ក្នុងអគ្គប្បសាទសូត្រនោះយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាង ពួកសង្ខតធម៌ទាំងនោះ ។

ក្រុមរបស់បុគ្គលទាំងឡាយ ដែលដល់ព្រមដោយអរិយមគ្គ ៤ យ៉ាង និងដែលមានខន្ធសន្តានអប់រំក្រៃលែង ដោយសាមញ្ញផល ៤ ឈ្មោះថា ព្រះសង្ឃ ព្រោះរួមគ្នាដោយការរួមទិដ្ឋិ និងសីល សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកយល់សេចក្តីនោះដូចម្តេច ធម៌ទាំងឡាយដែលតថាគតត្រាស់ដឹងហើយ សម្តែងហើយ ដល់អ្នកទាំងឡាយ ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ម្នាលអានន្ទ អ្នកដែលឃើញភិក្ខុពីររូបមានវាទៈផ្សេងគ្នា ក្នុងធម៌ទាំងឡាយនេះដែរឬ ។

ពិតហើយ ព្រះសង្ឃដោយបរមត្ថ ដែលបុគ្គលគប្បីដល់ជាសរណៈ ក្នុងព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ថា ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគ ជាអាហុនេយ្យបុគ្គល ជាបាហុនេយ្យបុគ្គល ជាទក្ខិណេយ្យបុគ្គល ជាអញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ សរណគមន៍របស់បុគ្គលដែលដល់នូវសរណៈនោះ រមែងមិនដាច់ មិនសៅហ្មង

*ដោយការធ្វើការថ្វាយបង្គំជាដើមក្នុងភិក្ខុសង្ឃ ឬភិក្ខុនីសង្ឃពួកដទៃ ឬសង្ឃដែលមានព្រះពុទ្ធជាប្រធាន ឬសម្មតិសង្ឃ មានសង្ឃបចតុវគ្គជាដើម ឬក្នុងបុគ្គលណាមួយ ដែលបួសឧទ្ទិសចំពោះព្រះមានព្រះភាគ ការផ្សេងគ្នាក្នុងសង្ឃសរណៈ ដែលមានប្រមាណប៉ុណ្ណេះ ចំណែកវិធី គឺការដាច់ និងមិនដាច់ជាដើមនៃសរណគមន៍នេះ និងទី ២ ក្រៅអំពីដែលពោលហើយ គប្បីជ្រាបតាមន័យដែលពោលមកអំពីមុនហើយ កិច្ចពណ៌នាសេចក្តីក្នុងសរណៈ ២ ថា* **ធម្មំ សរណំ** *ជាដើម ដែលធ្លាប់ដឹងមកហើយ ក៏ន័យនេះដូចគ្នា ។*

*អំពីសរណៈ គឺព្រះធម៌ និងព្រះសង្ឃមានប្រមាណប៉ុណ្ណេះ*

## អធិប្បាយ ហេតុក្នុងការកំណត់តាមលំដាប់

*ក្នុងពាក្យនេះថា នឹងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់ ឥឡូវនេះនឹងអធិប្បាយហេតុ ក្នុងការកំណត់តាមលំដាប់ យ៉ាងនេះថា ក្នុងពាក្យដល់សរណៈទាំង ៣ នោះ លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង ព្រោះជាបុគ្គលប្រសើរជាងសត្វទាំងពួង ប្រកាសព្រះធម៌លំដាប់បន្ទាប់មក ព្រោះជាដែនកើតនៃព្រះពុទ្ធទាំងនោះ និងព្រោះជាធម៌ដែលព្រះពុទ្ធអង្គនោះ ទ្រង់នាំចេញទូន្មានហើយ ប្រកាសព្រះសង្ឃក្នុងលំដាប់ចុងក្រោយ ព្រោះជាបុគ្គលទ្រទ្រង់ទុកនូវព្រះធម៌នោះ និងព្រោះសេពព្រះសទ្ធម្ម ម្យ៉ាងទៀត លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង ព្រោះទ្រង់ប្រកបសត្វទាំងពួងទុកក្នុងហិតប្រយោជន៍ ប្រកាសព្រះធម៌ក្នុងលំដាប់បន្ទាប់ ព្រោះជាដែនកើតនៃព្រះពុទ្ធនោះ និងព្រោះជាធម្មហិតាយ គឺធម៌ដែលជាប្រយោជន៍ដល់សត្វទាំងពួង ប្រកាសព្រះសង្ឃ*

ក្នុងលំដាប់ចុងក្រោយ ព្រោះព្រះសង្ឃ ជាអ្នកបដិបត្តិដើម្បីសម្រេចហិត-ប្រយោជន៍ និងមានហិតប្រយោជន៍ដែលសម្រេចហើយ កំណត់ដោយភាពជាសរណ: ។

## ប្រកាសដោយឧបមា

ឥឡូវនេះ នឹងពោលអធិប្បាយពាក្យដែលនឹងប្រកាសព្រះសរណត្រ័យដោយឧបមាទាំងឡាយ ក្នុងពាក្យនោះ ព្រះពុទ្ធប្រៀបដូចព្រះចន្ទពេញវង់ ព្រះធម៌ប្រៀបដូចក្រុមនៃរស្មីរបស់ព្រះចន្ទ ព្រះសង្ឃប្រៀបដូចទ្វីបលោក ដែលស្កប់ស្កល់ដោយរស្មីរបស់ព្រះចន្ទពេញវង់ ដែលធ្វើឲ្យកើតឡើង ។ ព្រះពុទ្ធប្រៀបដូចព្រះអាទិត្យជះពន្លឺស្រទន់ ព្រះធម៌ដូចពោល ប្រៀបដូចសំណាញ់នៃរស្មីរបស់ព្រះអាទិត្យនោះ ព្រះសង្ឃប្រៀបដូចទ្វីបលោក ដែលព្រះអាទិត្យនោះកម្ចាត់ងងឹតហើយ ។ ព្រះពុទ្ធប្រៀបដូចអ្នកដុតព្រៃ ព្រះធម៌ជាគ្រឿងដុតព្រៃ គឺកិលេស ប្រៀបដូចភ្លើងដុតព្រៃ ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត ព្រោះដុតកិលេសបានហើយ ប្រៀបដូចភូមិភាគដែលជាខេត្ត ព្រោះដុតព្រៃអស់ហើយ ព្រះពុទ្ធប្រៀបដូចភ្លៀងធំ ព្រះធម៌ប្រៀបដូចទឹកភ្លៀង ព្រះសង្ឃអ្នករម្ងាប់ធូលី គឺកិលេស ប្រៀបដូចជនបទដែលរម្ងាប់លម្អងធូលី ព្រោះភ្លៀងធ្លាក់ ។ ព្រះពុទ្ធប្រៀបដូចសារថី ព្រះធម៌ប្រៀបដូចឧបាយក្នុងការទូន្មានសេះអាជានេយ្យ ព្រះសង្ឃប្រៀបដូចហ្វូងសេះអាជានេយ្យ ដែលទូន្មានល្អហើយ ។ ព្រះពុទ្ធ ប្រៀបដូចសល្លវេជ្ជ គឺពេទ្យវះ ព្រោះទ្រង់ដកព្រួញ គឺទិដ្ឋិបានអស់ ព្រះធម៌ ប្រៀបដូចឧបាយដែលដកព្រួញចេញបាន ព្រះសង្ឃ ជាអ្នកដកព្រួញ

គឺទិដ្ឋិចេញហើយ ប្រៀបដូចជនដែលត្រូវដកព្រួញចេញហើយ ។ម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចចក្ខុវេជ្ជ ព្រោះទ្រង់បកភ្នាសមោហៈចេញបានហើយ ព្រះធម៌ ប្រៀបដូចឧបាយជាគ្រឿងបកភ្នាសរបស់ភ្នែក ព្រះសង្ឃ ជាអ្នកមានភ្នាសបកចេញហើយ ជាអ្នកមានភ្នែក គឺញាណដ៏ស្រស់ថ្លា ប្រៀបដូចជនដែលបកភ្នែកហើយ មានភ្នែកស្រស់ថ្លា ។ ម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចពេទ្យដ៏ឈ្លាស ព្រោះទ្រង់អាចកម្ចាត់ព្យាធិ គឺកិលេស ព្រមទាំងអនុស័យចេញបាន ព្រះធម៌ ប្រៀបដូចភេសជ្ជៈ ដែលទ្រង់ផ្សំត្រឹមត្រូវហើយ ព្រះសង្ឃមានព្យាធិ គឺកិលេស និងអនុស័យរម្ងាប់ហើយ ប្រៀបដូចពួកជនដែលព្យាធិរម្ងាប់ហើយ ព្រោះការដាក់ថ្នាំ ។

ម្យ៉ាងទៀត ព្រះពុទ្ធ ប្រៀបដូចអ្នកចង្អុលផ្លូវ ព្រះធម៌ ប្រៀបដូចផ្លូវល្អ ឬផ្លូវដែលផុតភ័យ ព្រះសង្ឃ ប្រៀបដូចអ្នកដំណើរដល់ទីដែលផុតភ័យ ព្រះពុទ្ធ ប្រៀបដូចនាយទូកដែលល្អ ព្រះធម៌ ប្រៀបដូចទូក ព្រះសង្ឃប្រៀបដូចអ្នកដំណើរដល់ត្រើយ ។ ព្រះពុទ្ធ ប្រៀបដូចព្រៃហិមពាន្ត ព្រះធម៌ប្រៀបដូចឱសថ ដែលកើតក្នុងព្រៃហិមពាន្តនោះ ព្រះសង្ឃ ប្រៀបដូចបុគ្គលមិនមានរោគ ព្រោះប្រើថ្នាំ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកឲ្យទ្រព្យ ព្រះធម៌ប្រៀបដូចទ្រព្យ ព្រះសង្ឃ អ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជនដែលបានទ្រព្យតាមបំណង ។ ព្រះពុទ្ធ ប្រៀបដូចអ្នកចង្អុលកំណប់ទ្រព្យ ព្រះធម៌ ប្រៀបដូចកំណប់ទ្រព្យ ព្រះសង្ឃ ប្រៀបដូចជនដែលបានកំណប់ទ្រព្យ ។

ម្យ៉ាងទៀត ព្រះពុទ្ធជាវីរបុរស ប្រៀបដូចអ្នកឲ្យនូវការមិនមានភ័យ ព្រះ

ធម៌ ប្រៀបដូចមិនមានភ័យ ព្រះសង្ឃ អ្នកកន្ទងបង់នូវភ័យគ្រប់យ៉ាង ប្រៀបដូចជនដែលដល់នូវការមិនមានភ័យ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកលួងលោម ព្រះធម៌ ប្រៀបដូចការលួងលោម ព្រះសង្ឃ ប្រៀបដូចបុគ្គលដែលបានធូរស្បើយ ព្រោះការលួងលោម ។ ព្រះពុទ្ធ ប្រៀបដូចមិត្តល្អ ព្រះធម៌ ប្រៀបដូចពាក្យប្រៀនប្រដៅ ដែលជាហិតប្រយោជន៍ ព្រះសង្ឃ ប្រៀបដូចអ្នកជួបនូវប្រយោជន៍ខ្លួន ព្រោះប្រកបហិតប្រយោជន៍ ។ ព្រះពុទ្ធ ប្រៀបដូចអណ្តូងកើតទ្រព្យ ព្រះធម៌ ប្រៀបដូចទ្រព្យដែលជាសារៈ ព្រះសង្ឃ ប្រៀបដូចជនដែលប្រើទ្រព្យជាសារៈ ។ ព្រះពុទ្ធ ប្រៀបដូចអ្នកស្រោចស្រង់ព្រះកុមារ ព្រះធម៌ ប្រៀបដូចទឹកដែលស្រោចស្រង់លើព្រះសិរសា ព្រះសង្ឃជាអ្នកស្រោចស្រង់ល្អហើយដោយទឹក គឺព្រះសទ្ធម្ម ប្រៀបដូចពួកព្រះរាជកុមារដែលស្រង់ល្អហើយ ។ ព្រះពុទ្ធ ប្រៀបដូចជាងអ្នកធ្វើគ្រឿងអលង្ការ ព្រះធម៌ ប្រៀបដូចគ្រឿងអលង្ការ ព្រះសង្ឃដែលប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចពួកព្រះរាជឱរសដែលប្រដាប់ហើយ ។ ព្រះពុទ្ធ ប្រៀបដូចដើមចន្ទន៍ ព្រះធម៌ ប្រៀបដូចក្លិនដែលកើតអំពីដើមចន្ទន៍នោះ ព្រះសង្ឃ រម្ងាប់ការក្តៅក្រហាយបានឥតសេសសល់ ព្រោះឧបភោគ គឺប្រើប្រាស់ព្រះសទ្ធម្ម ប្រៀបដូចជនដែលរម្ងាប់ការក្តៅ ព្រោះប្រើលម្អិតខ្លឹមចន្ទន៍ ។ ព្រះពុទ្ធ ប្រៀបដូចបិតាប្រគល់មត៌កដោយធម៌ ព្រះធម៌ ប្រៀបដូចមត៌ក ព្រះសង្ឃអ្នកបន្តមត៌ក គឺព្រះសទ្ធម្ម ប្រៀបដូចពួកបុត្រដែលបន្តមត៌ក ។ ព្រះពុទ្ធ ប្រៀបដូចផ្កាបទុមដែលរីក ព្រះធម៌ ប្រៀបដូចទឹកដមដែលកើតអំពីផ្កាបទុមដែលរីកនោះ ព្រះសង្ឃ ប្រៀប

ដូចពួកកមរដែលស្រូបទឹមជមនោះ ។ គប្បីប្រកាសត្រៃសរណៈនោះ ដោយឧបមាទាំងឡាយ ដូចពោលមកនេះចុះ ។

មាតិកានៃកថាពណ៌នាសេចក្តីដែលលើកឡើងតាំងទុកខាងដើម ដោយ ៤ គាថាថា ត្រៃសរណៈអ្នកណាពោល ពោលក្នុងទីណា ពោលកាលណា ពោលព្រោះហេតុអ្វីជាដើម ក៏ឈ្មោះថា ប្រកាសហើយ ដោយអត្ថ ដោយកថាមានប្រមាណប៉ុណ្ណេះឯង ។

កថាពណ៌នា ត្រៃសរណៈ ចប់

# សុត្តន្តបិដក

## ខុទ្ទកបាឋ: សិក្ខាបទ ១០

[ ២ ] ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការសម្លាប់សត្វ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការកាន់យក នូវវត្ថុដែលគេមិនបានឲ្យ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការប្រព្រឹត្តនូវធម៌មិនប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការពោលនូវពាក្យកុហក ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរ

ចាកការបរិភោគនូវភោជនាហារក្នុងកាលខុស ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការរាំ ច្រៀង ប្រគំ និងការមើលល្បែងផ្សេងៗ ដែលជាសត្រូវដល់កុសលធម៌ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការទ្រទ្រង់ការប្រដាប់ និងការតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកសេនាសនៈដ៏ខ្ពស់ ( ហួសប្រមាណ ) និងសេនាសនៈដ៏ប្រសើរ ។ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកការកាន់យកនូវមាស និងប្រាក់ ។

សិក្ខាបទ ១០ ចប់

# អដ្ឋកថា

## ពណ៌នាសិក្ខាបទ

[ ២ ] កាលសម្តែងការចូលកាន់ព្រះសាសនា ដោយការដល់សរណគមន៍យ៉ាងនេះហើយ ដើម្បីពណ៌នាបាឋៈដែលពោលអំពីសិក្ខាបទ ដែលតាំងជានិក្ខេបបទ ដើម្បីសម្តែងសិក្ខាបទទាំងឡាយ ដែលឧបាសក ឬបព្វជិតអ្នកចូលមកកាន់ព្រះសាសនា គប្បីសិក្សាជាលំដាប់ដំបូង ឥឡូវនេះ ខ្ញុំនឹងពោលមាតិកាដូចតទៅនេះ

សិក្ខាបទទាំងនេះ បុគ្គលណាពោល ពោលទីណា ពោលអំពីពេលណា ពោលព្រោះហេតុអ្វី ចាំបាច់កំណត់ពោលធ្វើន័យនោះ ដោយការប្លែកនៃសិក្ខាបទទូទៅ ចាំបាច់កំណត់ពោលដែលជាបកតិវជ្ជផង និងបណ្ណត្តិវជ្ជផង ធ្វើនូវការចង្អុលបង្ហាញន័យទូទៅគ្រប់សិក្ខាបទ ដោយព្យញ្ជនៈ និងអត្ថរបស់បទទាំងឡាយ ។

តែក្នុងសិក្ខាបទ ៥ ខាងដើម គប្បីជ្រាបវិនិច្ឆ័យដោយប្រកាសការប្លែកគ្នានៃសិក្ខាបទទូទៅ ដោយភាពតែមួយ និងភាពផ្សេងគ្នាជាដើម តាំងអំពីបាណាតិបាតជាដើមទៅ ដោយអារម្មណ៍ ការសមាទាន និងការដាច់ ដោយការមានទោសច្រើន ដោយប្រយោគ អង្គ និងសមុដ្ឋាន ដោយវេទនា មូល និងកម្ម ដោយការវៀរ និងដោយផល ។

យុត្តិ គឺការត្រឹមត្រូវអំពីកិច្ចពណ៌នាសិក្ខាបទ ៥ ខាងដើម គប្បីនាំមកប្រើក្នុង ៥ សិក្ខាបទក្រោយ គប្បីពោលសិក្ខាបទមួយប្រការៗ គប្បីជ្រាបថា សិក្ខាបទមានដោយអាក្រក់ជាដើមផងដែរ ។

ក្នុងមាតិកា ១០ នោះ សិក្ខាបទ មានបាណាតិបាតាវេរមណីជាដើមនោះ ព្រះមានព្រះភាគមួយអង្គត្រាស់ មិនមែនសាវក ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ចេញអំពីក្រុងកបិលពស្តុដល់ក្រុងសាវត្ថី ទ្រង់ឲ្យរាហុលបព្វជ្ជាហើយ ក្នុងវត្តជេតពនអារាមរបស់អនាថបិណ្ឌិក នាក្រុងសាវត្ថី ត្រាស់សិក្ខាបទ ១០ នោះ ដើម្បីកំណត់សិក្ខាបទសម្រាប់សាមណេរទាំងឡាយ សមដូចលោកពោលពាក្យនេះថា

លំដាប់អំពីនោះមក ព្រះដ៏មានបុណ្យទ្រង់គង់ក្នុងក្រុងកបិលវត្ថុ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់យាងសំដៅទៅកាន់ចារិកឯក្រុងសាវត្ថី ទ្រង់ត្រាច់ទៅកាន់ចារិកដោយលំដាប់ៗ ហើយ ទ្រង់បានទៅដល់ក្រុងសាវត្ថីនោះ ។ តាមតំណាលក្នុងនិទានថា ព្រះដ៏មានបុណ្យទ្រង់គង់ក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។បេ។ គ្រាតពីនោះមក សាមណេរទាំងឡាយបានត្រិះរិះសេចក្តីនេះនឹងគ្នាថា សិក្ខាបទរបស់យើងទាំងឡាយមានប៉ុន្មានហ្ន៎ ម្យ៉ាងទៀត យើងទាំងឡាយ គួរសិក្សាក្នុងវិន័យដូចម្តេចខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានបុណ្យ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំងឡាយ ១០ ដល់សាមណេរទាំងឡាយ ម្យ៉ាងទៀត អនុញ្ញាតឲ្យសាមណេរទាំងឡាយ សិក្សាក្នុងសិក្ខាបទទាំងឡាយ ១០ នោះ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ១ ។បេ។ ចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាស និងប្រាក់ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសិក្ខាបទទាំង ១០ នេះដល់សាមណេរទាំងឡាយ ម្យ៉ាងទៀត អនុញ្ញាតឲ្យពួកសាមណេរសិក្សាក្នុងសិក្ខាបទទាំងឡាយ ១០ នេះ ដូច្នេះ ។

សិក្ខាបទទាំង ១០ នោះ គប្បីជ្រាបថា លោកលើកឡើងប្រៀនប្រដៅដោយគន្លងព្រះសូត្រថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ និងដោយគន្លងបាឋៈ ដែលលោកបានសម្តែងក្នុងសរណគមន៍យ៉ាងនេះថា **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ**

*ខ្ញុំសមាទានសិក្ខាបទ គឺចេតនាវៀរចាកសម្លាប់សត្វជាដើម គប្បីជ្រាបន័យដែលថា សិក្ខាបទទាំងនេះ អ្នកណាពោល ពោលទីណា ពោលអំពីពេលណា ពោលព្រោះហេតុអ្វី នឹងពោលន័យនេះប៉ុណ្ណោះសិន ។*

## ការប្លែកគ្នានៃសិក្ខាបទ

*បណ្តាសិក្ខាបទទាំងនោះ សិក្ខាបទទី ៤-៥ ពីរសិក្ខាបទខាងដើម ទូទៅដល់ឧបាសកផង សាមណេរផង ព្រោះជានិច្ចសីល តែបើពោលដោយឧបោសថ សីលរបស់ពួកឧបាសក វៀរសិក្ខាបទក្រោយបង្អស់ ព្រោះសិក្ខាបទទី ៧-៨ រួមចូលគ្នាតែមួយ សិក្ខាបទទាំងអស់ ក៏ទូទៅដល់សាមណេរទាំងឡាយ ចំណែកសិក្ខាបទក្រោយជាពិសេស សម្រាប់តែសាមណេរប៉ុណ្ណោះ គប្បីជ្រាបកំណត់ដោយការប្លែកគ្នានៃសិក្ខាបទទូទៅ ដូចពោលមក ដូច្នេះ គប្បីកំណត់បកតិវជ្ជៈ និងបណ្ណត្តិវជ្ជៈយ៉ាងនេះ គឺបណ្តាសិក្ខាបទទាំងនោះ សិក្ខាបទ ៥ ខាងដើម កំណត់ដោយចេតនា វៀរចាកបកតិវជ្ជៈរបស់បាណាតិបាតជាដើម ព្រោះមានកុសលចិត្តជាសមុដ្ឋាន ដោយចំណែកមួយ សិក្ខាបទក្រៅអំពីនោះ កំណត់ដោយចេតនា វៀរចាកបណ្ណត្តិវជ្ជៈ ។*

## ចង្អុលបង្ហាញបទទូទៅ

*ព្រោះហេតុដែលបណ្តាបទទាំងនោះ បទថា* **វេរមណី សិក្ខាបទំ សមាទិយាមិ** *ជាបទទូទៅទាំងអស់ ដូច្នោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនោះទូទៅ ទាំងដោយព្យញ្ជនៈ ទាំងដោយអត្ថដូចតទៅនេះ*

ក្នុងបទទាំងនោះ គប្បីជ្រាបដោយព្យញ្ជនៈមុន ឈ្មោះថា **វេរមណី** ព្រោះវៀរចាកពៀរ អធិប្បាយថា លះបង់ បន្ទោបង់នូវពៀរ គឺធ្វើឲ្យអស់ឲ្យដល់នូវការមិនមាន ។ ម្យ៉ាងទៀត បុគ្គលរមែងវៀរចាកពៀរដោយចេតនានោះ ហេតុនោះ ចេតនានោះ ឈ្មោះថា **វេរមណី** ព្រោះយក **វិ** អក្ខរៈជា **វេ** អក្ខរៈ ។ ដោយហេតុនោះឯង ទើបក្នុងពាក្យនេះ ពុទ្ធបរិស័ទសូធ្យជា ២ យ៉ាងថា **វេរមណីសិក្ខា បទំ** ឬ **វិរមណីសិក្ខា បទំ** ។ ឈ្មោះថា **សិក្ខា** ព្រោះបុគ្គលគប្បីសិក្សា ឈ្មោះថា **បទ** ព្រោះជាគ្រឿងដល់បទនៃសិក្ខា ។ បទនៃសិក្ខា ឈ្មោះថា **សិក្ខាបទ** អធិប្បាយថា ឧបាយជាគ្រឿងដល់សិក្ខា ។ ម្យ៉ាងទៀត លោកអធិប្បាយថា ជាមូល ជាទីអាស្រ័យ ជាទីតាំង ។ សិក្ខាបទ គឺចេតនាជាគ្រឿងវៀរ ឈ្មោះថា **វេរមណីសិក្ខាបទ** ឬ **វិរមណីសិក្ខាបទ** តាមន័យទី ២ ។ ខ្ញុំកាន់យកដោយប្រពៃ ឈ្មោះថា **សមាទិយាមិ** លោកអធិប្បាយថា ខ្ញុំកាន់យកដោយបំណងមិនកន្លងល្មើស ព្រោះជាបុគ្គលធ្វើសិក្ខាបទមិនឲ្យដាច់ មិនឲ្យធ្លុះ មិនឲ្យពព្រុសពពាល ។

តែកាលពោលដោយអត្ថ បទថា **វេរមណី** បានដល់ វិរតិ ប្រកបដោយចិត្តដែលជាកាមាវចរកុសល ។ វិរតិរបស់បុគ្គលដែលវៀរចាកបាណាតិបាត លោកពោលទុកក្នុងវិភង្គ ដោយន័យជាដើមយ៉ាងនេះថា ចេតនាវៀរចេតនាហាមឃាត់ វៀរផ្តាច់ វៀរបង់ មិនធ្វើ មិនប្រព្រឹត្ត មិនកន្លង មិនកន្លងល្មើសព្រំដែន ការទាញស្ពានដោយអរិយមគ្គ ឈ្មោះថា **សេតុ** អំពីបាណាតិបាត ក្នុងសម័យនោះឯណា ។ ធម្មតាវេរមណីនោះ ជាលោកុត្តរមានក៏ពិត

តែក្នុងទីនេះ ក៏គួរជាវេរមណីដែលប្រព្រឹត្តទៅដោយការសមាទាន ព្រោះបុគ្គលសមាទានពោលថា **សមាទិយាមិ** ព្រោះដូច្នោះ ទើបវេរមណីជាលោកុត្តរនោះ មិនមាន ខ្ញុំពោលថា វិរតិ ប្រកបដោយចិត្តដែលជាកាមាវចរកុសល ។

បទថា **សិក្ខា** បានដល់ សិក្ខា ៣ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា តែក្នុងទីនេះ សីល គឺសម្បត្តវិរតិ វិបស្សនាជាចំណែកលោកិយ រូបជ្ឈាន និងអរូបជ្ឈាន និងអរិយមគ្គ លោកបំណងថា សិក្ខា ក្នុងបទថា **សិក្ខា** នេះ ដូចលោកពោលថា

ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា ចិត្តជាកាមាវចរកុសល ប្រទាំដោយសោមនស្ស សម្បយុត្តដោយញាណ មានរូបជាអារម្មណ៍ក្តី ។បេ។ ក្នុងសម័យនោះ ការប៉ះពាល់ ក៏កើតមាន ។បេ។ ការមិនរាយមាយ ក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។

ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងរូបភព ។បេ។ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ។បេ។ ចូលកាន់បញ្ចមជ្ឈាន ។បេ។ ការមិនរាយមាយក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។

ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គលចម្រើនមគ្គ ដើម្បីកើតក្នុងអរូបភព ។បេ។ ចូលកាន់នេវសញ្ញានាសញ្ញា-

យតនជ្ឈាន ។បេ។ ការមិនរាយមាយក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។

ធម៌ទាំងឡាយដូចម្តេច ឈ្មោះថា សិក្ខា ។ ក្នុងសម័យណា បុគ្គលចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ។បេ។ ការមិនរាយមាយក៏កើតមាន ធម៌ទាំងឡាយនេះ ឈ្មោះថា **សិក្ខា** ។

បទ គឺឧបាយជាគ្រឿងដល់ ម្យ៉ាងទៀត ជាមូល ជាទីអាស្រ័យ ជាទីតាំងនៃសិក្ខាណាមួយ បណ្តាសិក្ខាទាំងនោះ ហេតុនោះ ទើបឈ្មោះថា សិក្ខាបទ សមដូចលោកពោលដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យសីល តាំងស៊ប់នៅក្នុងសីល កាលចម្រើននូវពោជ្ឈង្គ: ... យ៉ាងនេះជាដើម ។ គប្បីធ្វើការចង្អុលបង្ហាញដោយព្យញ្ជនៈ ដោយអត្ថ ដោយសាធារណៈ ដោយបទ ក្នុងបទទាំងនេះ ដោយប្រការដូច្នេះ ។

## ការពណ៌នាសិក្ខាបទ ៥ ខាងដើម

ពាក្យណាដែលខ្ញុំពោលថា ក្នុងសិក្ខាបទ ៥ ខាងដើម ចាំបាច់ចង្អុលបង្ហាញ ដោយប្រកាសការប្លែកគ្នា ។បេ។ គប្បីជ្រាបវិនិច្ឆ័យ ។បេ។ ក្នុងពាក្យនោះ ឥឡូវនេះ ខ្ញុំនឹងចង្អុលបង្ហាញដូច្នេះ ជាបឋមក្នុងពាក្យថា **បាណាតិ-បាតោ** នេះ បទថា **បាណោ** បានដល់ ការបន្តនៃខន្ធដែលទាក់ទងដោយជីវិតិន្ទ្រិយ ។ ន័យម្យ៉ាងទៀត បានដល់ សត្វដែលបណ្ឌិតអាស្រ័យការបន្តនៃខន្ធនោះបញ្ញត្ត ។ វធកចេតនា គឺចេតនាគិតនឹងសម្លាប់របស់បុគ្គលដែលមានសេចក្តីសម្គាល់ក្នុងសត្វមានជីវិតនោះ ថាជាសត្វមានជីវិត ជាសមុដ្ឋាននៃ

សេចក្ដីព្យាយាមដែលនឹងកាត់ជីវិតិន្ទ្រិយរបស់សត្វមានជីវិតនោះ ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **ပាណាតិបាត** ។

ក្នុងពាក្យថា **អទិន្នាទានំ** នេះ បទថា **អទិន្នំ** បានដល់ ទ្រព្យដែលមានម្ចាស់ហួងហែង ដែលម្ចាស់ទ្រព្យខ្លួនឯង កាលធ្វើតាមត្រូវការក៏មិនត្រូវទោស មិនត្រូវពាក្យតិះដៀល ថេយ្យចេតនារបស់បុគ្គល ដែលមានការសម្គាល់ក្នុងទ្រព្យដែលមានម្ចាស់រក្សាថា ជាទ្រព្យរបស់ម្ចាស់ទ្រព្យហួងហែង ជាសមុដ្ឋាននៃសេចក្ដីព្យាយាមនឹងលួចទ្រព្យនោះ ប្រព្រឹត្តទៅផ្លូវកាយទ្វារ និងវចីទ្វារ ទ្វារណាទីមួយនោះឯង ឈ្មោះថា **អទិន្នាទាន** ។

បទថា **អព្រហ្មចរិយំ** បានដល់ ការប្រព្រឹត្តមិនប្រសើរ ចេតនាជាហេតុល្មើសនូវឋានៈ គឺការសេពអសទ្ធម្ម ប្រព្រឹត្តទៅផ្លូវកាយទ្វារ ដោយការសេពមេថុន ឈ្មោះថា **អព្រហ្មចរិយៈ** ។

ក្នុងពាក្យថា **មុសាវាទោ** នេះ បទថា **មុសា** បានដល់ វចីបយោគ ឬកាយបយោគ ដែលធ្វើប្រយោជន៍របស់បុគ្គលដែលប្រាថ្នាឲ្យឃ្លាតសេចក្ដីពិតជាខាងមុខ មិច្ឆាចេតនា ចេតនាដែលគិតនឹងពោលខុស ធ្វើខុសរបស់បុគ្គលនោះ ដោយបំណងនឹងឲ្យអ្នកដទៃយល់ខុស ជាសមុដ្ឋាននៃកាយបយោគ និងវចីបយោគដែលធ្វើអ្នកដទៃឲ្យយល់ខុស ប្រព្រឹត្តទៅផ្លូវកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **មុសាវាទ** ។

ក្នុងពាក្យថា **សុរាមេរយមជ្ជប្បមាទដ្ឋានំ** នេះ បទថា **សុរា** បានដល់ សុរា ៥ យ៉ាង គឺសុរាធ្វើដោយម្សៅ សុរាធ្វើដោយនំ សុរាធ្វើដោយបាយ

សុរាធ្វើអំពីពូជនៃសុរា និងសុរាធ្វើដោយគ្រឿងផ្សំផ្សេងៗ ។

មេរ័យក៏មាន ៥ យ៉ាង គឺមេរ័យដែលធ្វើដោយផ្កា មេរ័យដែលធ្វើដោយផ្លែឈើ មេរ័យដែលធ្វើដោយទឹកអំពៅ មេរ័យដែលធ្វើដោយផ្កាស្រគំ មេរ័យដែលផ្សំដោយគ្រឿងផ្សំ ។ បទថា **មជ្ជំ** បានដល់ ទាំង ២ នោះឯង ឈ្មោះថា **មជ្ជ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្ដីស្រវឹង ឬវត្ថុដទៃណា ទោះជាអ្វីក៏ដោយ ដែលជាទីតាំងនៃសេចក្ដីស្រវឹង បុគ្គលស្រវឹង ប្រមាទដោយវត្ថុណា ដែលផឹកហើយ វត្ថុនេះក៏ហៅថា **មជ្ជ**។ បទថា **បទដ្ឋានំ** បានដល់ ចេតនាដែលបរិភោគមជ្ជៈនោះ លោកហៅថា **បមាទដ្ឋានំ** ព្រោះជាហេតុនៃការស្រវឹងដោយការប្រមាទ ចេតនាបរិភោគមជ្ជៈ គឺសុរា និងមេរ័យ ប្រព្រឹត្តទៅផ្លូវកាយទ្វារ ដោយបំណងនឹងបរិភោគ គប្បីជ្រាបថា សុរាមេរ័យ ជាទីតាំងនៃសេចក្ដីប្រមាទដោយប្រការណា គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទាំងនោះមុនរាប់តាំងអំពីបាណាតិបាតជាដើមទៅ ដោយប្រការដូច្នេះ ។

## វិនិច្ឆ័យសិក្ខាបទដូចគ្នា និងផ្សេងគ្នាជាដើម

ក្នុងពាក្យថា ដូចគ្នានិងផ្សេងគ្នាជាដើម ដោយសិក្ខាបទតែម្យ៉ាងដូចគ្នាតែផ្សេងគ្នាជាដើមនេះ អ្នកចោទសួរពោលថា បាណាតិបាត ឬសិក្ខាបទដែលមានអទិន្នាទានជាដើមតែមួយដូចគ្នា ព្រោះបុគ្គលដែលគប្បីសម្លាប់ ត្រូវសម្លាប់ប្រយោគ និងចេតនាជាដើមតែមួយដូចគ្នា ឬផ្សេងគ្នា ព្រោះមានបុគ្គលដែលត្រូវសម្លាប់ជាដើមផ្សេងគ្នា ឬមិនមែនទាំង ២ យ៉ាង ក៏ព្រោះហេតុអ្វី ទើបអ្នកចោទសួរពោលពាក្យនេះ បើសិក្ខាបទតែមួយដូចគ្នា ព្រោះបុគ្គលដែល

ត្រូវសម្លាប់ជាដើម ជាមនុស្សតែម្នាក់សោត កាលបើដូច្នោះ កាលណាបុគ្គលសម្លាប់ច្រើននាក់ សម្លាប់មនុស្សដែលត្រូវសម្លាប់តែម្នាក់ ឬបុគ្គលអ្នកសម្លាប់តែម្នាក់ សម្លាប់មនុស្សដែលត្រូវសម្លាប់ច្រើននាក់ មនុស្សដែលគប្បីត្រូវសម្លាប់ច្រើននាក់ ក៏នឹងត្រូវសម្លាប់ដោយប្រយោគមួយ មានសាហត្ថិកប្បយោគជាដើម ឬចេតនាតែម្យ៉ាង ក៏នឹងញុំាងប្រយោគរបស់បុគ្គលដែលចូលទៅកាត់ជីវិតិន្ទ្រិយរបស់បុគ្គល ដែលត្រូវសម្លាប់ច្រើននាក់ឲ្យតាំងឡើង កាលនោះ បាណាតិបាតក៏គប្បីមានតែមួយ តែបើសិក្ខាបទផ្សេងគ្នា ព្រោះអ្នកដែលត្រូវសម្លាប់ជាដើមផ្សេងគ្នាសោត កាលបើដូច្នោះ កាលណាអ្នកសម្លាប់តែម្នាក់ បើធ្វើប្រយោគមួយ ដើម្បីមនុស្សម្នាក់ ក៏រមែងសម្លាប់បុគ្គលដែលត្រូវសម្លាប់ច្រើននាក់ ឬអ្នកសម្លាប់ច្រើននាក់ កាលធ្វើច្រើនប្រយោគ ដើម្បីមនុស្សច្រើននាក់ មានទេវទត្ត យញ្ញទត្ត និងសោមទត្តជាដើម ក៏រមែងសម្លាប់បានចំពោះទេវទត្ត យញ្ញទត្ត ឬសោមទត្តម្នាក់ប៉ុណ្ណោះ ឬបុគ្គលដែលគប្បីត្រូវសម្លាប់តែម្នាក់ ត្រូវអ្នកសម្លាប់ សម្លាប់ដោយច្រើនប្រយោគ មានសហត្ថិកប្បយោគជាដើម ចេតនាច្រើនក៏នឹងញុំាងប្រយោគរបស់បុគ្គល ដែលចូលទៅកាត់ជីវិតិន្ទ្រិយរបស់បុគ្គលដែលត្រូវសម្លាប់ម្នាក់ប៉ុណ្ណោះ ឲ្យតាំងឡើង ។ កាលនោះ បាណាតិបាតក៏គប្បីមានច្រើនយ៉ាង សូម្បីពាក្យទាំង ២ នោះ ក៏មិនត្រឹមត្រូវ ។ សិក្ខាបទនឹងឈ្មោះថា តែមួយដូចគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ជាដើមនោះ មានតែម្នាក់ក៏មិនមែនសិក្ខាបទ ឈ្មោះថា ផ្សេងគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ជាដើម

នោះផ្សេងគ្នាក៏មិនមែន សេចក្តីពិត សិក្ខាបទតែមួយ នឹងផ្សេងគ្នា ក៏ដោយហេតុដទៃ ពាក្យនោះ គប្បីប្រើដល់បាណាតិបាត សិក្ខាបទក្រៅអំពីនោះ ក៏គប្បីប្រើយ៉ាងនោះ ។

ខ្ញុំនឹងលើកសេចក្តីនេះឡើងដូចតទៅនេះថា ដំបូង បាណាតិបាតនោះ ឈ្មោះថា តែមួយ ព្រោះបុគ្គលដែលគប្បីត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើមតែមួយដូចគ្នា ឈ្មោះថា ផ្សេងគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ជាដើមផ្សេងគ្នាក៏មិនមែន ដោយពិតនោះ បាណាតិបាត ឈ្មោះថា តែមួយដូចគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើមតែមួយដូចគ្នា ដោយចាត់ជាគូៗគ្នា ។ ទាំងឈ្មោះថា តែមួយដូចគ្នា ព្រោះបុគ្គលដែលត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើមទាំង ២ នោះ តែមួយដូចគ្នា ដោយចាត់ជាគូៗ គ្នា ឬឈ្មោះថា ផ្សេងគ្នា ព្រោះបុគ្គលដែលគប្បីត្រូវសម្លាប់ និងអ្នកសម្លាប់ជាដើមនោះជាមនុស្សម្នាក់ទៀត ក្រៅអំពីមនុស្សទាំង ២ នាក់នោះ ។

ពិតហើយ កាលមនុស្សអ្នកសម្លាប់ច្រើននាក់ សូម្បីសម្លាប់មនុស្សដែលត្រូវសម្លាប់ច្រើននាក់ ដោយប្រយោគច្រើនប្រយោគ មានសារត្ថបបយោគ មានការជីកស្រះជាដើម ឬដោយប្រយោគមួយ មានឱបាតខណនបយោគ គឺការជីកអណ្តូងជាដើម ក៏ជាបាណាតិបាត កាលបុគ្គលអ្នកសម្លាប់តែម្នាក់ សម្លាប់បុគ្គលដែលត្រូវសម្លាប់ច្រើននាក់ ដោយប្រយោគមួយ ឬច្រើនប្រយោគ ដោយចេតនាមួយ ដែលញុំាងប្រយោគនោះឲ្យតាំងឡើង ឬដោយច្រើនប្រយោគ ក៏ជាបាណាតិបាតច្រើនបាណាតិបាត ម្យ៉ាងទៀត កាលបុគ្គលអ្នកសម្លាប់ច្រើន

សូម្បីត្រូវសម្លាប់បុគ្គលដែលត្រូវសម្លាប់តែម្នាក់ ដោយប្រយោគច្រើន តាមដែលពោលហើយ ឬដោយប្រយោគមួយ ក៏ជាបាណាតិបាតច្រើន ក្នុងសិក្ខាបទ មានអទិន្នាទានជាដើម ក៏មានន័យដូច្នេះ គប្បីជ្រាបវិនិច្ឆ័យដោយភាពជាសិក្ខាបទតែមួយដូចគ្នា និងដូចគ្នា និងផ្សេងគ្នាជាដើម ដោយប្រការដូចពោលមកដូច្នេះ ។

បើពោលដោយអារម្មណ៍ ក្នុងសេចក្តីនេះ បាណាតិបាត មានជីវិតិន្ទ្រិយជាអារម្មណ៍ អទិន្នាទាន អព្រហ្មចរិយៈ និងសុរាមេរយមជ្ជប្បមាទដ្ឋាន មានសង្ខារ គឺបណ្តារូបធម៌ មានរូបាយតនៈជាដើមណាមួយជាអារម្មណ៍ មុសាវាទមានសត្វជាអារម្មណ៍ ព្រោះប្រារព្ធបុគ្គលនឹងពោលមុសាប្រព្រឹត្តទៅ អាចារ្យពួកខ្លះពោលថា សូម្បីអព្រហ្មចរិយៈក៏មានសត្វជាអារម្មណ៍ ម្យ៉ាងទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ក្នុងកាលដែលសត្វជាបុគ្គល ដែលគប្បីត្រូវលួចទៅ ប្រការមួយទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ក៏ដោយអំណាចសង្ខារ មិនមែនដោយអំណាចព្រះបញ្ញត្ត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអារម្មណ៍ ដូចពោលមកដូច្នេះ ។

កាលពោលដោយសមាទាន សិក្ខាបទទាំងនេះ មានបាណាតិបាតាវេរមណីសិក្ខាបទជាដើម សាមណេរសមាទានក្នុងសម្នាក់ភិក្ខុប៉ុណ្ណោះ ទើបឈ្មោះថា សមាទាន ចំណែកឧបាសក សមាទានឯងក្តី សមាទានក្នុងសម្នាក់របស់អ្នកដទៃក្តី ក៏ឈ្មោះថា សមាទានហើយ សមាទានរួមគ្នាក្តី ( រួមសិក្ខាបទចូលគ្នា ) សមាទានបែកគ្នាក្តី ( សមាទានរាយសិក្ខាបទមួយៗ ) ក៏ឈ្មោះថា

សមាទានហើយ តែផ្សេងគ្នាដូចម្ដេច បុគ្គលសមាទានរួមគ្នា ក៏មានវិរតិ ១ មានចេតនា ១ ប៉ុណ្ណោះ តែប្រាកដថា វិរតិ និងចេតនាទាំងនោះ មានដល់ ៥ ដោយអំណាចកិច្ច ។ ឯបុគ្គលដែលសមាទានបែកគ្នា គប្បីជ្រាបថា មានវិរតិ ៥ ចេតនា ៥ ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យដោយការសមាទានដោយប្រការដូច្នេះ ។

បើពោលដោយការដាច់ ក្នុងសេចក្ដីនេះ សម្រាប់សាមណេរទាំងឡាយ កាលសិក្ខាបទមួយដាច់ គ្រប់សិក្ខាបទក៏ដាច់ ព្រោះសិក្ខាបទទាំងនោះជាឋានៈ ជាទីតាំងនៃបារាជិករបស់សាមណេរទាំងនោះ ដោយសិក្ខាបទដែលសាមណេរកន្លងល្មើសនោះឯង មានកម្មជាប់តាមមក ។

តែសម្រាប់គ្រហស្ថ កាលសីលមួយដាច់ ក៏ដាច់មួយប៉ុណ្ណោះ ព្រោះសីលរបស់គ្រហស្ថមានអង្គ ៥ រមែងនឹងបរិបូណ៌ទៀត ដោយការសមាទានសីលប៉ុណ្ណោះ ។ តែអាចារ្យមួយពួកទៀតពោលថា បណ្ដាសីលដែលគ្រហស្ថសមាទាន ជាសិក្ខាបទមួយៗ កាលសីលណាមួយដាច់ ក៏ដាច់មួយប៉ុណ្ណោះ តែបណ្ដាសីលដែលគ្រហស្ថសមាទានរួមគ្នាយ៉ាងនេះថា **បញ្ចង្គសមន្នាគតំ សីលំ សមាទិយាមិ** ខ្ញុំសូមសមាទានសីល ដែលប្រកបដោយអង្គ ៥ ដូច្នេះ កាលសីលណាមួយដាច់ សីលដ៏សេស ក៏ដាច់ទាំងអស់ ។ ព្រោះហេតុអ្វី ព្រោះសីលដែលសមាទានមិនដាច់ ដ្បិតសីលដែលគ្រហស្ថកន្លងល្មើសនោះឯង ក៏មានចំណងកម្ម ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យដោយការដាច់ដោយប្រការដូច្នេះ ។

កាលពោលដោយទោសច្រើន បណ្តាសត្វមានជីវិត វៀរចាកគុណ មានសត្វតិរច្ឆានជាដើម បាណាតិបាត ឈ្មោះថា មានទោសតិច ក៏ព្រោះសត្វមានខ្លួនតូច ឈ្មោះថា មានទោសច្រើន ក៏ព្រោះថា សត្វមានខ្លួនធំ ។ ព្រោះហេតុអ្វី ព្រោះប្រយោគធំ គឺសេចក្តីព្យាយាមច្រើន ទោះបីមានបយោគស្មើគ្នា ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុធំ ចំណែកបណ្តាសត្វមានជីវិត ដែលមានគុណ មានមនុស្សជាដើម បាណាតិបាត ឈ្មោះថា មានទោសតិច ក៏ព្រោះមនុស្សមានគុណតិច ឈ្មោះថា មានទោសច្រើន ក៏ព្រោះមនុស្សមានគុណច្រើន តែបើមានខ្លួន និងគុណស្មើគ្នា ក៏គប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងសេចក្តីព្យាយាមទន់ខ្សោយ និងមានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ក្នុងសិក្ខាបទដ៏សេស ក៏មានន័យដូច្នេះ ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ សុរាមេរយមជ្ជប្បមាទដ្ឋានប៉ុណ្ណោះ ឈ្មោះថា មានទោសច្រើន បាណាតិបាតជាដើម មិនមែនមានទោសច្រើនឡើយ ព្រោះអ្វី ព្រោះធ្វើអន្តរាយដល់អរិយធម៌ ព្រោះធ្វើមនុស្សដែលកើតមកជាមនុស្សឲ្យក្លាយជាមនុស្សឆ្កួត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយការមានទោសច្រើន ដោយប្រការដូច្នេះ ។

កាលពោលដោយបយោគ ក្នុងសេចក្តីនេះ បាណាតិបាត មានប្រយោគ ៦ គឺសាហត្ថិកប្បយោគ អាណត្តិកប្បយោគ និស្សគ្គិយប្បយោគ ថាវរប្បយោគ វិជ្ជាមយប្បយោគ ឥទ្ធិមយប្បយោគ ។

បណ្តាបយោគទាំងនោះ ការប្រហារដោយកាយ ឬរបស់ដែលជាប់នឹង

កាយ ឈ្មោះថា សាហត្ថិកប្បយោគៗ នោះ ចែកជា ២ គឺសាហត្ថិកប្បយោគដោយចំពោះ និងសាហត្ថិកប្បយោគដោយមិនចំពោះ ។ ក្នុងសាហត្ថិកប្បយោគទាំង ២ នោះ សាហត្ថិកប្បយោគដោយចំពោះ បុគ្គលរមែងពាក់ព័ន្ធដោយកម្ម ព្រោះការស្លាប់របស់មនុស្សដែលទៅចំពោះប្រហារប៉ុណ្ណោះ ។ ក្នុងសាហត្ថិកប្បយោគមិនចំពោះយ៉ាងនេះថា បុគ្គលណាម្នាក់ក៏ដោយ ចូរស្លាប់ដូច្នេះ បុគ្គលរមែងជាប់ដោយកម្ម ព្រោះការស្លាប់របស់បុគ្គលណាម្នាក់ ព្រោះការប្រហារជាបច្ច័យ ។ ម្យ៉ាងទៀត ដោយសាហត្ថិកប្បយោគទាំង ២ បុគ្គលគ្រាន់តែត្រូវប្រហារស្លាប់ ឬស្លាប់ដោយរោគនោះខាងក្រោយ បុគ្គលក៏រមែងដល់នូវកម្មពន្ធ ខណៈដែលបុគ្គលត្រូវប្រហារប៉ុណ្ណោះ តែបើបុគ្គលប្រហារដោយបំណងនឹងឲ្យគេស្លាប់ តែគេមិនស្លាប់ដោយការប្រហារនោះ បែរជាគិតប្រហារបុគ្គលនោះទៀត បើក្នុងពេលក្រោយ គេស្លាប់ដោយការប្រហារដំបូងនោះ បុគ្គលក៏រមែងត្រូវកម្មពន្ធក្នុងវេលានោះប៉ុណ្ណោះ បើសត្វនោះស្លាប់ដោយការប្រហារលើកទី ២ ក៏មិនជាបាណាតិបាត បើបុគ្គលនោះស្លាប់ដោយសាហត្ថិកប្បយោគទាំង ២ បុគ្គលក៏ត្រូវកម្មពន្ធ ដោយការប្រហារដំបូងប៉ុណ្ណោះ បើបុគ្គលមិនស្លាប់ ដោយសាហត្ថិកប្បយោគទាំង ២ ក៏មិនជាបាណាតិបាតឡើយ ក្នុងប្រការដែលមនុស្សច្រើននាក់ប្រហារមនុស្សម្នាក់ ក៏ន័យនេះ ក្នុងសេចក្ដីនោះ កម្មពន្ធ រមែងមានដល់បុគ្គលដែលប្រហារបុគ្គលនោះស្លាប់ប៉ុណ្ណោះ ។

ការតាំងចិត្តប្រើឲ្យគេធ្វើ ឈ្មោះថា អាណត្តិកប្បយោគ ក្នុងអាណត្តិ-

កប្បយោគនោះ ក៏គប្បីជ្រាបកម្មពន្ធ ដោយន័យដែលបានពោលក្នុងសាហត្ថិកប្បយោគនោះឯង ក្នុងអាណត្តិកប្បយោគនោះ គប្បីជ្រាបថា មានកំណត់ ៦ យ៉ាង ។

អាណត្តិកប្បយោគ កំណត់ ៦ យ៉ាង គឺវត្ថុ ១ កាល ១ ឱកាស ១ អាវុធ ១ ឥរិយាបថ ១ កិរិយាវិសេស ១ ។ ក្នុងការកំណត់ ៦ នោះ សត្វមានជីវិត គប្បីចាំទុកថាជាវត្ថុ ។ ពេលព្រឹក ល្ងាច និងពេលនៅជាកំលោះ ក្រមុំ ពេលជាមនុស្សធំជាដើម គប្បីចាំទុកថាកាល ។ គាម និគម ព្រៃ ច្រក ឬផ្លូវបំបែក ដូចពោលមកនេះជាដើម គប្បីចាំទុកថា ឱកាស ។ អាវុធ គឺដាវ ធ្នូ ឬលំពែង ការឈរ ឬការអង្គុយ របស់អ្នកដែលត្រូវសម្លាប់ និងអ្នកសម្លាប់ ដូចពោលមកនេះជាដើម គប្បីចាំទុកថាជាឥរិយាបថ ។ ការចាក់ធ្លុះ ការកាត់ ការធ្វើឲ្យដាច់ ឬការបោចសក់ ដូចពោលមកជាដើម គប្បីចាំទុកថា កិរិយាវិសេស ។ បើបុគ្គលត្រូវគេប្រើឲ្យសម្លាប់បុគ្គលណា ធ្វើវត្ថុឲ្យឃ្លៀងឃ្លាត គឺសម្លាប់ខុសបុគ្គល សម្លាប់អ្នកដទៃក្រៅអំពីបុគ្គលនោះសោត អ្នកប្រើក៏មិនត្រូវកម្មពន្ធ បើបុគ្គលនោះមិនធ្វើវត្ថុឲ្យឃ្លៀងឃ្លាត សម្លាប់មិនខុសបុគ្គល ជនទាំង ២ ក៏ត្រូវកម្មពន្ធ គឺអ្នកប្រើត្រូវក្នុងខណៈប្រើ អ្នកដែលត្រូវប្រើត្រូវក្នុងខណៈសម្លាប់ ក្នុងការកំណត់ដទៃៗ មានកាលជាដើម ក៏មានន័យដូច្នេះ ។

ការលែងគ្រឿងប្រហារដោយកាយ ឬរបស់ដែលជាប់ដោយកាយ ដើម្បីធ្វើឲ្យស្លាប់ ឈ្មោះថា និស្សគ្គិយប្បយោគ ។ និស្សគ្គិយប្បយោគនោះក៏ចែក

ជា ២ ដូចគ្នា គឺនិស្សគ្គិយប្បយោគដោយចំពោះ និងមិនចំពោះ ក្នុងសេចក្តីនេះ កម្មពន្ធ គប្បីជ្រាបតាមន័យដែលពោលមកហើយខាងដើមនោះឯង ។

ការជីកអណ្តូង ការដាក់ក្តារចម្រូង ការប្រកបថ្នាំពិស និងគន្ទឹះយន្តជាដើម ដើម្បីធ្វើឲ្យសត្វស្លាប់ ឈ្មោះថា ថាវរប្បយោគ ថាវរប្បយោគនោះបែកជា ២ គឺថាវរប្បយោគចំពោះ និងមិនចំពោះ ។ ក្នុងសេចក្តីនេះ កម្មពន្ធគប្បីជ្រាបតាមន័យដែលពោលមកហើយខាងដើម តែការប្លែកគ្នា មានដូច្នេះ កាលអ្នកជីកជំឡូង ធ្វើអណ្តូងជាដើមក្បែរៗ ឬធ្វើអណ្តូងទទេក្តី របស់មនុស្សដទៃៗ បើបុគ្គលនោះស្លាប់ ព្រោះអណ្តូងនោះជាបច្ច័យ កម្មពន្ធក៏មានដល់អ្នកជីកជំឡូង ។ ម្យ៉ាងទៀត កាលមនុស្សទាំងនោះ ឬអ្នកដទៃលុបអណ្តូងនោះចោល ធ្វើផ្ទៃដីឲ្យរាប ឬបុគ្គលបោសធូលី គោយធូលីទៅ ឬអ្នកជីកជំឡូង ជីកជំឡូងធ្វើរណ្តៅ ឬកាលភ្លៀងធ្លាក់ បែកកក់ មនុស្សចុះទៅជាប់ស្លាប់ក្នុងកក់នោះ កម្មពន្ធមានដល់អ្នកជីកជំឡូងនោះឯង បើមនុស្សដែលបានជំឡូង ឬអ្នកដទៃធ្វើរណ្តៅនោះឲ្យទូលាយ ឬជ្រៅជាងមុន បុគ្គលចុះទៅស្លាប់ព្រោះរណ្តៅធំ ឬជ្រៅនោះ កម្មពន្ធក៏មានដល់មនុស្សទាំង ២ ហេតុទាំងឡាយ រមែងប្រៀបធៀបគ្នាបាននឹងការជីកជំឡូង យ៉ាងណា កាលមនុស្សលុបរណ្តៅឲ្យរាបក្នុងទីនោះ មនុស្សក៏ផុតចាកការធ្លាក់រណ្តៅ ក៏ដូច្នោះ ។

ក្នុងថាវរប្បយោគ មានការដាក់ក្តារចម្រូងជាដើម ក៏យ៉ាងនោះដូចគ្នា កម្មពន្ធតាមហេតុដែលកើត ក៏គប្បីជ្រាប ដរាបណាថាវរប្បយោគនោះនៅប្រព្រឹត្តទៅ ។

ការរាយវិជ្ជាអាគមដែលធ្វើឲ្យស្លាប់ ឈ្មោះថា វិជ្ជាមយប្បយោគ ។

ការធ្វើឫទ្ធិផ្សេងៗ ដែលកើតអំពីវិបាកកម្ម ដើម្បីធ្វើឲ្យបុគ្គលនោះស្លាប់ ដូចប្រើអាវុធ គឺចង្កូមជាដើម ខាំដោយចង្កូមជាដើម ឈ្មោះថា ឥទ្ធិមយប្បយោគ ។ ឯអទិន្នាទាន ក៏មានប្រយោគ គឺសាហត្ថិកប្បយោគ និងអាណត្តិកប្បយោគជាដើម ដែលប្រព្រឹត្តទៅដោយអំណាចថេយ្យាវហារ បសយ្ហាវហារ បដិច្ឆន្នាវហារ បរិកប្បាវហារ និងកុសាវហារ ប្រភេទនៃបយោគទាំងនោះ ក៏គប្បីជ្រាបដោយទំនងដែលពោលមកហើយនោះឯង សិក្ខាបទទាំង ៣ មានអព្រហ្មចរិយៈជាដើម ក៏បានចំពោះនូវសាហត្ថិកប្បយោគតែម្យ៉ាង ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យដោយបយោគ ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយអង្គ ក្នុងសេចក្ដីនេះ បាណាតិបាតមានអង្គ ៥ គឺបាណោ សត្វមានជីវិត ១ បាណសញ្ញី សម្គាល់ថាមានជីវិត ១ វធកចិត្តំ ចិត្តគិតនឹងសម្លាប់ ១ វាយមតិ ព្យាយាមនឹងសម្លាប់ ១ តេនមរណតិ សត្វស្លាប់ដោយព្យាយាមនោះ ។

អទិន្នាទានក៏មានអង្គ ៥ ដូចគ្នា គឺបរបរិគ្គហិតំ របស់មានម្ចាស់រក្សា ១ បរបរិគ្គហិតសញ្ញី សម្គាល់ថា របស់មានម្ចាស់ហួងហែង ១ ថេយ្យចិត្តំ មានចិត្តគិតនឹងលួច ១ វាយមតិ ព្យាយាមនឹងលួច ១ តេន អាទាតព្វំ អាទានំ គច្ឆតិ លួចបានមកដោយការព្យាយាមនោះ ១ ។

ចំណែកអព្រហ្មចរិយៈមានអង្គ ៤ គឺអជ្ឈាចរិយវត្ថុ វត្ថុដែលគប្បីកន្លង

លើស ១ សេវនចិត្តំ ចិត្តគិតនឹងសេព ១ បយោគំ សមាបជ្ជតិ ព្យាយាម នឹងចូលដល់ ១ សាទិយតិ ត្រេកអរ ១ ។

មុសាវាទមានអង្គ ៤ ដូចគ្នា គឺមុសា រឿងកុហក ១ វិសំវាទនចិត្តំ ចិត្តគិតនឹងពោលកុហក ១ វាយាមោ ព្យាយាមកើតអំពីចិត្តនោះ ១ បរវិសំ-វាទនំ និយាយកុហកចំពោះបុគ្គលដទៃ និងអ្នកដទៃដឹងរឿងកុហក ១ ។

សុរាមេរយមជ្ជប្បមាទដ្ឋាន ក៏មានអង្គ ៤ គឺ សុរាទីនំ អញ្ញតរំ របស់ស្រវឹង មានសុរាជាដើមណាមួយ ១ មទនីយបាតុកម្យតាចិត្តំ ចិត្តគិតចង់ផឹក ១ តជ្ជំ វាយាមំ អាបជ្ជតិ ការព្យាយាមកើតអំពីចិត្តនោះ ១ បីតេ ច បវិស្សតិ ផឹកចូលទៅក្នុងបំពង់ក ១ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអង្គ ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយសមុដ្ឋាន ក្នុងសេចក្តីនេះ បាណាតិបាត អទិន្នាទាន និងមុសាវាទ មានសមុដ្ឋាន ៣ គឺកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ ។ អព្រហ្មចរិយៈមានសមុដ្ឋាន ១ គឺកាយចិត្ត ។ សុរាមេរយមជ្ជប្ប-មាទដ្ឋាន មានសមុដ្ឋាន ២ គឺកាយ ១ ចិត្ត ១ ក្នុងសេចក្តីនេះ គប្បីជ្រាប វិនិច្ឆ័យដោយសមុដ្ឋាន ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយវេទនា ក្នុងសេចក្តីនេះ បាណាតិបាត ប្រកបដោយទុក្ខ-វេទនា អទិន្នាទាន ប្រកបដោយវេទនា ៣ ណាមួយ មុសាវាទក៏ដូចគ្នា សិក្ខា-បទ ២ ទៀត ប្រកបដោយសុខវេទនា និងអទុក្ខមសុខវេទនា ក្នុងសេចក្តី នេះ គប្បីជ្រាបវិនិច្ឆ័យដោយវេទនា ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយមូល ក្នុងសេចក្តីនេះ បាណាតិបាត មានទោសៈ និងមោហៈជាមូល អទិន្នាទាន និងមុសាវាទ មានលោភៈ និងមោហៈជាមូលក៏មាន មានទោសៈ និងមោហៈជាមូលក៏មាន ។ សិក្ខាបទ ២ ទៀត ក្រៅអំពីនេះ មានលោភៈ និងមោហៈជាមូល ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយមូល ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយកម្ម ក្នុងសេចក្តីនេះ បាណាតិបាត អទិន្នាទាន និងអព្រហ្មចរិយៈ ជាកាយកម្ម និងជាកម្មបថ មុសាវាទជាវចីកម្មតែម្យ៉ាងដែលកាច់បំបាក់នូវប្រយោជន៍ ក៏ជាកម្មបថ មុសាវាទក្រៅអំពីនេះ ជាកម្មតែម្យ៉ាង សុរាមេរយមជ្ជប្បមាទដ្ឋាន ជាកាយកម្មតែម្យ៉ាង ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយកម្មដូចពោលមក ដូច្នេះ ។

បើពោលដោយវិរតិ ក្នុងសេចក្តីនេះ អ្នកចោទសួរពោលថា បុគ្គលកាលវៀរបាណាតិបាតជាដើម វៀរអំពីណា ។ នឹងពោលចម្លើយបង្ហាញ ដូច្នេះ ជាបឋម បុគ្គលកាលវៀរ ដោយសមទានវិរតិ រមែងវៀរចាកអកុសលកម្ម មានបាណាតិបាតជាដើមរបស់ខ្លួនឯង ឬរបស់អ្នកដទៃ ។ សួរថា ប្រារព្ធអ្វី ។ ឆ្លើយថា ប្រារព្ធអកុសលកម្មដែលវៀរនោះឯង កាលវៀរដោយសម្បត្តវិរតិ រមែងវៀរចាកអកុសលកម្មដូចពោលហើយនោះឯង សួរថា ប្រារព្ធអ្វី ឆ្លើយថា ប្រារព្ធអារម្មណ៍នៃអកុសលកម្ម មានបាណាតិបាតជាដើម ដែលពោលហើយ ។ តែអាចារ្យពួកខ្លះពោលថា បុគ្គលប្រារព្ធសង្ខារទាំងឡាយ ដែលរាប់បានថា ទឹកស្រវឹង គឺសុរា និងមេរ័យ ទើបវៀរចាកទីតាំងនៃសេចក្តី

ប្រមាទ គឺការផឹកសុរា និងមេរ័យ ។ បុគ្គលប្រារព្ធបណ្ណាសត្វ និងសង្ខារ ចំពោះដែលខ្លួនគប្បីលួច នឹងគប្បីបំផ្លាញ ទើបវៀរចាកអទិន្នាទាន និង មុសាវាទ ។ ប្រារព្ធសត្វតែម្យ៉ាង ទើបវៀរចាកបាណាតិបាត និងអព្រហ្ម-ចរិយៈ ។ អាចារ្យក្រៅអំពីនោះ មានការឃើញយ៉ាងនេះថា កាលបើដូច្នោះ បុគ្គលកាលគិតយ៉ាងណាមួយ ក៏ធ្វើយ៉ាងណាមួយ លះវត្ថុណា ក៏មិនជីងវត្ថុ នោះ ដូច្នេះ កាលមិនត្រូវការយ៉ាងនោះ ទើបពោលថា បុគ្គលលះវត្ថុណា ក៏ ប្រារព្ធវត្ថុនោះ គឺអកុសលកម្ម មានបាណាតិបាតជាដើមរបស់ខ្លួននោះឯង ទើប វៀរ ។ ពាក្យនោះមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះវត្ថុនោះ មិនមានអារម្មណ៍ បច្ចុប្បន្ន និងមិនមានអារម្មណ៍ខាងក្រៅ ។ ពិតហើយ ក្នុងបាលីវិភង្គនៃសិក្ខា-បទទាំងឡាយ លោកសួរថា សិក្ខាបទទាំង ៥ ជាកុសលប៉ុន្មាន ។បេ។ ជា អរណៈប៉ុន្មាន ហើយក្នុងការឆ្លើយបញ្ហាដែលប្រព្រឹត្តទៅយ៉ាងនេះថា កុសល ទាំងឡាយ ប្រកបដោយសុខវេទនាក៏មាន ទើបពោលដល់ភាពជាធម៌ មាន អារម្មណ៍ជាបច្ចុប្បន្ន និងអារម្មណ៍ខាងក្រៅយ៉ាងនេះថា មានអារម្មណ៍ជាបច្ចុ-ប្បន្ន មានអារម្មណ៍ខាងក្រៅ ពាក្យនោះរមែងមិនត្រឹមត្រូវសម្រាប់បុគ្គលដែល ប្រារព្ធអកុសលធម៌ មានបាណាតិបាតជាដើមរបស់ខ្លួន ។ ក្នុងពាក្យថា បុគ្គល គិតម្យ៉ាង ធ្វើម្យ៉ាង នឹងលះវត្ថុណា ក៏មិនជីងវត្ថុនោះ សូមពោលចង្អុលបង្ហាញ ដូច្នេះ បុគ្គលកំពុងបដិបត្តិ ដោយធ្វើកិច្ចឲ្យសម្រេច ប្រាថ្នានឹងពោលថា គិត ម្យ៉ាង ធ្វើម្យ៉ាង ឬលះវត្ថុណា មិនជីងវត្ថុនោះ ដូច្នេះ រមែងមិនបាន ដូច លោកពោលថា

**អារកិត្វាន អមតំ ជហន្តោ សព្វទាបកេ**

**និទ្ទស្សនញ្ចេត្ថ ភវេ មគ្គដ្ឋោរិយបុគ្គលោ។**

ព្រះអរិយបុគ្គលតាំងនៅក្នុងមគ្គ ប្រកបអមតធម៌ ក៏លះ

បាបធម៌បានទាំងអស់ ជាឧទាហរណ៍ក្នុងសេចក្តីនេះ ។

គប្បីជ្រាបវិនិច្ឆ័យដោយវិរតិ ដោយប្រការដូចពោលមក ដូច្នេះ ។

បើពោលដោយផល បាបធម៌ មានបាណាតិបាតជាដើម ទាំងអស់នេះ រមែងឲ្យកើតផល គឺទុគ្គតិ និងឲ្យកើតវិបាកដែលមិនគួរប្រាថ្នា មិនគួរចង់បាន មិនគួរពេញចិត្តក្នុងសុគតិផង ឲ្យកើតផល មានការមិនក្មៀវក្លាជាដើម ក្នុងចំណែកខាងមុខ និងបច្ចុប្បន្ន ។ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយផល តាមន័យជាដើមយ៉ាងនេះថា វិបាករបស់បាណាតិបាតយ៉ាងស្រាលបំផុត កាលកើតជាមនុស្ស ក៏ធ្វើឲ្យជាអ្នកមានអាយុខ្លី ។

ប្រការមួយទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយសមុដ្ឋាន វេទនា មូល កម្ម និងផលរបស់ចេតនា វៀរចាកបាណាតិបាតជាដើម ក្នុងចេតនាវៀរនោះឲ្យយល់ដូច្នេះ ។ វេរមណីទាំងអស់នេះ តាំងឡើងដោយសមុដ្ឋាន ៤ គឺកាយ កាយចិត្ត វាចាចិត្ត កាយវាចាចិត្ត ។ ទាំងអស់នោះឯង ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មានអលោភៈ អទោសៈជាមូលក៏មាន មានអលោភៈ អទោសៈ អមោហៈជាមូលក៏មាន ក្នុងសេចក្តីនេះ វេរមណីទាំង ៤ ជាកាយកម្ម មុសាវាទាវេរមណី ជាវចីកម្ម តែក៏តាំងឡើងអំពីចិត្ត ក្នុងខណៈមគ្គចិត្ត វេរមណីទាំងពួងក៏ជាមនោកម្ម ។

**ចាណាតិបាតា វេរមណី** មានផលជាដើមយ៉ាងនេះ គឺមានអវយវៈតូចធំបរិបូណ៌ មានសម្បត្តិ គឺភាពខ្ពង់ខ្ពស់ មានសម្បត្តិ គឺភាពវាងវៃ មានជើងតាំងនៅរាបស្មើ ការស្អាត ស្រស់បស់ ល្អ ក្លាហាន មានកម្លាំងច្រើន មានវាចាពីរោះ ជាទីស្រឡាញ់របស់សត្វលោក ការមានវាចាមិនមានទោស ការមានបរិស័ទមិនបែកគ្នា ការមានសេចក្តីអង់អាច ការមានរូបមិនខ្វះខាត ភាពជាបុគ្គលមិនស្លាប់ព្រោះសត្រូវ ភាពជាបុគ្គលមានបរិវារច្រើន ភាពជាបុគ្គលមានរូបស្អាត ភាពជាបុគ្គលមានទ្រង់ទ្រាយល្អ ការមានរោគតិច ការមិនសោកស្តាយ ការមិនព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីពេញចិត្ត និងការមានអាយុវែង ។

**អទិន្នាទានា វេរមណី** មានផលជាដើមយ៉ាងនេះ គឺមានទ្រព្យច្រើន មានទ្រព្យ គឺធញ្ញជាតិច្រើន ស្តុកស្តម្ភដោយភោគៈ ការកើតភោគទ្រព្យដែលមិនទាន់កើត ភោគទ្រព្យដែលកើតហើយ នៅជាថាវរៈ បានភោគទ្រព្យតាមប្រាថ្នាយ៉ាងឆាប់រហ័ស មានភោគទ្រព្យមិនត្រូវភ័យអន្តរាយ គឺភ័យអំពីព្រះរាជា ចោរ ទឹក ភ្លើង ទាយាទដែលមិនស្រឡាញ់គ្នា បានទ្រព្យដែលមិនជាសាធារណៈ បានលោកុត្តរទ្រព្យ មិនស្គាល់ការមិនមាន និងរស់នៅជាសុខ ។

**អព្រហ្មចរិយា វេរមណី** មានផលជាដើមយ៉ាងនេះ គឺការមិនមានសត្រូវ ការជាទីស្រឡាញ់របស់បុគ្គលគ្រប់រូប ការបានបាយទឹក សំពត់ ទីដេកជាដើម ការដេកជាសប្បាយ ការភ្ញាក់សប្បាយ ការផុតភ័យក្នុងអបាយ ការមិនកើតជាស្រី ឬកើតជាមនុស្សមិនមានភេទ ការមិនក្រោធ ការធ្វើដោយគោរព

ភាពជាទីស្រឡាញ់នៃស្ត្រី និងបុរស មានឥន្ទ្រិយបរិបូណ៌ មានលក្ខណៈបរិបូណ៌ មិនមានសេចក្ដីសង្ស័យ ជាអ្នកខ្វល់ខ្វាយតិច នៅជាសុខ មិនមានភ័យអំពីទីណា មិនមានការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ។

**មុសាវាទា វេរមណី** មានផលយ៉ាងនេះ គឺមានឥន្ទ្រិយផូរផង់ ជាអ្នកមានវាចាពីរោះ ជាអ្នកមានធ្មេញរាបស្មើស្អាត ជាអ្នកមិនធាត់ពេក ជាអ្នកមិនស្គម ជាអ្នកមិនទាបពេក ជាអ្នកមិនខ្ពស់ពេក ជាអ្នកមានសម្ផស្សសប្បាយ មាត់មានក្លិនដូចផ្កាឧប្បល អ្នកនៅក្រោមបង្គាប់ ស្ដាប់ឱវាទល្អ មានវាចាដែលអ្នកដទៃជឿបាន មានអណ្ដាតទន់ក្រហម ដូចផ្កាកោមុទ និងឧប្បល ការមិនរាយមាយ ការមិនអណ្ដែតអណ្ដូងជាដើម ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** មានផលយ៉ាងនេះ គឺប្រាជ្ញាបានឆាប់រហ័សក្នុងករណីយកិច្ចទាំងពួង ទាំងអតីត អនាគត និងបច្ចុប្បន្ន ការមានសតិគ្រប់កាល មិនជាមនុស្សឆ្កួត ជាអ្នកមានញាណ មិនខ្ជិលច្រអូស មិនល្ងង់ មិន-គ មិនស្រវឹង មិនប្រមាទ មិនវង្វេង មិនភ័យខ្លាច មិនប្រណាំងវាសនា មិនសង្ស័យ មិនងឿងឆ្ងល់ ភាពជាអ្នកពោលពិត ភាពជាអ្នកពោលតែវាចាមិនស៊ីកសៀត មិនគ្រោតគ្រាត មិនឥតប្រយោជន៍ ជាអ្នកមិនខ្ជិលច្រអូសទាំងពេលយប់ និងពេលថ្ងៃ ជាអ្នកមានកតញ្ញូ ជាអ្នកមានកតវេទី ជាអ្នកមិនកំណាញ់ ជាអ្នកលះបង់ ជាអ្នកមានសីល ជាមនុស្សទៀងត្រង់ ជាអ្នកមិនក្រោធ ជាអ្នកមានហិរិ ជាអ្នកមានឱត្តប្បៈ ជាអ្នកមានសម្មាទិដ្ឋិ ជាអ្នកមានបញ្ញាច្រើន ជាអ្នកមានការដឹង ជាបណ្ឌិត ជាអ្នកឈ្លាសក្នុងវត្ថុដែលជា

*ប្រយោជន៍ និងមិនជាប្រយោជន៍ជាដើម ។ ក្នុងសេចក្ដីនេះ គប្បីជ្រាប វិនិច្ឆ័យដោយសមុដ្ឋាន វេទនា មូល កម្ម និងផល ដោយប្រការដូចពោល មក ដូច្នេះ ។*

## ពណ៌នាសិក្ខាបទ ៥ ខាងក្រោយ

*ពាក្យដែលខ្ញុំពោលថា យុត្តិអំពីពាក្យពណ៌នា ៥ សិក្ខាបទដើមនោះ គួរនាំមកប្រើក្នុង ៥ សិក្ខាបទក្រោយ គួរពោលជាសិក្ខាបទមួយៗ និងគួរ ជ្រាបថា សិក្ខាបទមានយ៉ាងអាក្រក់ជាដើមផង ឥឡូវនេះ នឹងពណ៌នាដូច តទៅនេះ ។ ពាក្យណា ក្នុងកិច្ចពណ៌នា ៥ សិក្ខាបទដើម រមែងយុត្តិ ពាក្យ នោះ រមែងគួរដល់ការពណ៌នានោះ មកប្រកបក្នុង ៥ សិក្ខាបទខាងក្រោយ ។ ក្នុងសេចក្ដីនេះ ប្រកបសេចក្ដីដូច្នេះថា បើពោលដោយអារម្មណ៍ ក្នុងសិក្ខាបទ មុនៗ សុរាមេរយមជ្ជប្បមាទដ្ឋាន មានសង្ខារ មានរូបាយតនៈណាមួយជាដើម ជាអារម្មណ៍ យ៉ាងណា ក្នុងទីនេះ វិកាលភោជនក៏ដូច្នោះ គប្បីជ្រាបសេចក្ដី ផ្សេងគ្នានៃអារម្មណ៍របស់សិក្ខាបទក្រោយ គ្រប់សិក្ខាបទដោយន័យនេះ ។*

*តែបើពោលដោយសមាទាន ៥ សិក្ខាបទខាងដើម ដែលសាមណេរ ឬឧបាសកសមាទាន រមែងឈ្មោះថា សមាទានហើយ យ៉ាងណា ៥ សិក្ខា- បទក្រោយនេះ ក៏ដូច្នោះ ។ បើពោលដោយអង្គ ការផ្សេងគ្នារបស់អង្គនៃ សិក្ខាបទ ៥ ខាងដើម មានបាណាតិបាតជាដើម បានពោលហើយក្នុងទីនោះ យ៉ាងណា ក្នុងទីនេះ ក៏ដូច្នោះ ។*

*វិកាលភោជន មានអង្គ ៤ គឺវិកាល ១ របស់ជាយាវកាលិក ១ ការ*

បរិភោគ ១ ភាពមិនជាមនុស្សឆ្កួត ១ ។ គប្បីជ្រាបការផ្សេងគ្នានៃអង្គរបស់សិក្ខាបទក្រៅអំពីនោះដោយទំនងនេះ ។

ម្យ៉ាងទៀត បើពោលដោយសមុដ្ឋាន ក្នុងទីនោះ សុរាមេរយមជ្ជប្បមាទដ្ឋានមានសមុដ្ឋាន ២ គឺកាយ ១ កាយចិត្ត ១ យ៉ាងណា ក្នុងទីនេះ វិកាលភោជន ក៏ដូច្នោះ គប្បីជ្រាបសមុដ្ឋានរបស់សិក្ខាបទ គ្រប់សិក្ខាបទដោយន័យដូច្នេះ ។

ម្យ៉ាងទៀត បើពោលដោយវេទនា ក្នុងទីនេះ អទិន្នាទាន ប្រកបដោយវេទនា ៣ យ៉ាងណាមួយ យ៉ាងណា ក្នុងទីនេះ វិកាលភោជន ក៏យ៉ាងនោះ គប្បីជ្រាបការប្រកបព្រម ដោយវេទនារបស់សិក្ខាបទ គ្រប់សិក្ខាបទ ដោយន័យនេះ ។

ម្យ៉ាងទៀត ក្នុងទីនោះ អព្រហ្មចរិយៈ មានលោភៈ និងមោហៈជាមូល យ៉ាងណា សូម្បីក្នុងទីនេះ វិកាលភោជន និងសិក្ខាបទ ២ ទៀត ក៏ដូច្នោះ គប្បីជ្រាបការផ្សេងគ្នានៃមូលរបស់សិក្ខាបទ គ្រប់សិក្ខាបទដោយន័យនេះ ។

ម្យ៉ាងទៀត ក្នុងទីនោះ បាណាតិបាតជាដើម ជាកាយកម្ម យ៉ាងណា សូម្បីក្នុងទីនេះ វិកាលភោជនជាដើមក៏ដូច្នោះ ។

ម្យ៉ាងទៀត **ជាតរូបរជតប្បដិគ្គហាណ** ជាកាយកម្មក៏មាន ជាវចីកម្មក៏មាន ដោយបរិយាយនៃការប្រព្រឹត្តទៅ និងការកើតតាមកាយទ្វារជាដើម មិនមែនកម្មបថ ។

ម្យ៉ាងទៀត បើពោលដោយវិរតិ ក្នុងទីនោះ បុគ្គលកាលវៀរ រមែងវៀរ

ចាកអកុសល មានបាណាតិបាតជាដើមរបស់ខ្លួន ឬរបស់អ្នកដទៃ យ៉ាងណា ក្នុងទីនេះ ក៏រមែងវៀរចាកអកុសល មានវិកាលភោជនជាដើម ក៏ដូច្នោះ ។

ម្យ៉ាងទៀត បើពោលដោយភាពជាកុសល ក៏តែមួយដូចគ្នា ។ ក្នុង ៥ វេរមណីខាងដើម មាន ៤ សមុដ្ឋាន គឺកាយ ១ កាយចិត្ត ១ វាចាចិត្ត ១ និងកាយវាចាចិត្ត ១ គ្រប់វេរមណីប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មានអលោភៈ អទោសៈជាមូលក៏មាន មានអលោភៈ អទោសៈ អមោហៈជាមូលក៏មាន និងគ្រប់វេរមណី ឲ្យកើតផលដែលគួរប្រាថ្នា មានប្រការផ្សេងៗ យ៉ាងណា ក្នុងទីនេះ ក៏ដូច្នោះ ទើបខ្ញុំពោលថា

យុត្តិអំពីកិច្ចពណ៌នា ៥ សិក្ខាបទខាងដើមនោះ គួរនាំមកប្រើក្នុង ៥ សិក្ខាបទក្រោយ គួរពោលសិក្ខាបទជាលំដាប់ៗ គួរជ្រាបថា សិក្ខាបទមានយ៉ាងអាក្រក់ជាដើមផងដែរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង ៥ សិក្ខាបទខាងក្រោយនោះ ។ ពាក្យថា **វិកាលភោជនំ** បានដល់ ការបរិភោគអាហារកន្លងកាលវេលាអំពីថ្ងៃត្រង់ ។ ពិតហើយ ការបរិភោគអាហារ បើកន្លងកាលថ្ងៃត្រង់នោះ គឺការបរិភោគអាហារកន្លងកាល ដែលទ្រង់អនុញ្ញាត ព្រោះដូច្នោះ ទើបលោកហៅថា វិកាលភោជន ចេតនាវៀរចាកការបរិភោគអាហារក្នុងវេលាវិកាលនោះ។ ក្នុងពាក្យថា **នច្ចគីតវាទិតវិសូកទស្សនំ** នេះ ការរាំណាមួយ ឈ្មោះថា **នច្ច** ការច្រៀងណាមួយ ឈ្មោះថា **គីត** ការប្រគំណាមួយ ឈ្មោះថា **វាទិត** ។ ការមើលវត្ថុជាសត្រូវ ព្រោះទម្លាយធម៌ចំណែកកុសល ដោយជាបច្ច័យ ធ្វើ

ឲ្យកើតកិលេស ឈ្មោះថា **វិសូកទស្សន** ឬការមើល ការឃើញដែលជាសត្រូវ ក៏ឈ្មោះថា **វិសូកទស្សន** ។ ការរាំផង ការច្រៀងផង ការប្រគំផង ការមើលវត្ថុដែលជាសត្រូវផង ឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សន** ។ វិសូកទស្សនៈក្នុងទីនេះ គប្បីកាន់យកតាមន័យ ដែលត្រាស់ក្នុងព្រហ្មជាលសូត្រ ។ ពិតហើយ ក្នុងព្រហ្មជាលសូត្រនោះ ព្រះមានព្រះភាគត្រាស់ថា

ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗ នូវការស្តាប់ និងការមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌មានសភាពយ៉ាងនេះ ។ ឯល្បែងដែលជាសត្រូវដល់កុសលធម៌នោះ តើដូចម្តេចខ្លះ ។ គឺល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ ចម្រៀងស្តេចការតៈ និងព្រះរាមជាដើមខ្លះ គងខ្លះ រគាំងខ្លះ ស្គរមានជ្រុង ៤ ខ្លះ រូបគំនូរខ្លះ ល្បែងដុំដែកខ្លះ ល្បែងរ៉ាវខ្លះ ល្បែងលាងឆ្អឹងខ្លះ ដំរីជល់គ្នាខ្លះ សេះប្រខាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ គោជល់គ្នាខ្លះ ពពែជល់គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុនដំបងខ្លះ ប្រដាល់ខ្លះ ចំបាប់ខ្លះ ទីសម្រាប់ច្បាំងគ្នាខ្លះ ទីសម្រាប់រៀបពលខ្លះ លំនៅកងទ័ពខ្លះ ទីមើលសេនាប្រកបដោយអង្គ ៤ ខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាស្តាប់ និងការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពដូច្នេះឯង ។

ម្យ៉ាងទៀត ការរាំ ការច្រៀង និងការប្រគំតាមដែលពោលមកហើយ

*ប៉ុណ្ណោះដែលជាសត្រូវ ឈ្មោះថា* **នច្ចគីតវាទិតវិសូក** *ការមើល ការរាំ ការច្រៀង ការប្រគំ ដែលជាសត្រូវទាំងនោះ ឈ្មោះថា* **នច្ចគីតវាទិត-វិសូកទស្សន** *ចេតនាវៀរចាកការរាំ ការច្រៀង និងប្រគំដែលជាសត្រូវនោះ កាលគួរនឹងពោលថា* **ទស្សនសវនា** *សូម្បីការស្តាប់ លោកក៏ហៅថាទស្សនៈ ដូចគ្នា ។ ការយល់ឃើញ សូម្បីមិនមែនប្រព្រឹត្តទៅតាមចក្ខុទ្វារ លោកក៏ហៅថា ទស្សនៈ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា* **សោ ច ហោតិ មិច្ឆាទិដ្ឋិកោ វិបរីតទស្សនោ** *បុគ្គលនោះ រមែងជាមិច្ឆាទិដ្ឋិ មានការឃើញខុស មានទស្សនៈវិបរិត ។ ឯការកន្លងល្មើសក្នុងសិក្ខាបទនេះ រមែងមានដល់បុគ្គលចូលទៅមើល ព្រោះចង់មើលប៉ុណ្ណោះ ឯបុគ្គលដើរទៅជួប ឬឃើញចំពោះ ( អារម្មណ៍ ) ដែលមកប្រាកដ ក្នុងឱកាសដែលឈរ អង្គុយដេក ក៏មានតែការសៅហ្មង មិនមែនកន្លងល្មើស ។ ក្នុងសិក្ខាបទនេះ ការច្រៀងដែលអាស្រ័យធម៌ ក៏មិនគួរ តែធម៌ដែលអាស្រ័យការច្រៀង គប្បីជ្រាបថា សមគួរ ។*

*ផ្កាជាដើម គប្បីប្រកបដោយការទ្រទ្រង់ តាមសមគួរក្នុងសិក្ខាបទនោះ ។ ពាក្យថា* **មាលា** *បានដល់ ផ្កាប្រភេទណាមួយ ។ ពាក្យថា* **វិលេបន** *បានដល់ របស់ណាមួយ ដែលគេបុកផ្សំដើម្បីលាប ក្រៅអំពីនោះ គ្រឿងក្រអូបមានលម្អិត និងផ្សែងអប់ជាដើមគ្រប់យ៉ាង ឈ្មោះថា គ្រឿងក្រអូប ។ គ្រឿងក្រអូបគ្រប់យ៉ាង ប្រើតាក់តែង ប្រដាប់ មិនគួរ តែប្រើជាថ្នាំ គួរ ។ គ្រឿងក្រអូបដែលគេនាំមកដើម្បីបូជា សម្រាប់បុគ្គលដែលទទួលទុក រមែង*

មិនគួរ ដោយបរិយាយណាមួយឡើយ ។ ទីដេកលើសខ្នាត លោកហៅថា **ឧច្ចាសយនំ** ទីដេកជាអកប្បិយ និងគ្រឿងកម្រាលដែលជាអកប្បិយ លោកហៅថា **មហាសយនំ** ទីដេកទាំង ២ យ៉ាងនោះ សម្រាប់បុគ្គលដែលទទួលរមែងមិនគួរ ទោះក្នុងបរិយាយណាមួយក៏ដោយ ។

បទថា **ជាតរូប** បានដល់ មាស ។ បទថា **រជត** បានដល់ កហាបណៈ គឺរបស់ណាមួយ មានមាសកលោហៈ មាសកឈើ និងមាសកជ័រជាដើមដែលគេចាយវាយក្នុងប្រទេសនោះៗ ។ មាស និងប្រាក់ទាំង ២ នោះ ឈ្មោះថា **ជាតរូបរជត** ។ ការទទួលយកមាស និងប្រាក់នោះ ឈ្មោះថា **បដិគ្គហ** គឺការទទួល ។ ការទទួលនោះ រមែងមិនគួរ ទោះបរិយាយណាក៏ដោយ ។ គប្បីជ្រាបសិក្ខាបទនីមួយៗ ដូចពោលមកដូច្នេះ ។

ទាំង ១០ សិក្ខាបទនេះ បុគ្គលសមាទានដោយឆន្ទៈ ឬវិរិយៈ ចិត្ត វិមំសាដែលថោកថយ ឈ្មោះថា **ហីន** ។ ដោយឆន្ទៈ វិរិយៈ ចិត្ត និងវិមំសាជាកណ្តាល ឈ្មោះថា **មជ្ឈិម** ។ ដោយឆន្ទៈ វិរិយៈ ចិត្ត វិមំសា យ៉ាងប្រណីត ឈ្មោះថា **បណីត** ។ ម្យ៉ាងទៀត សិក្ខាបទ ១០ នេះ សៅហ្មងដោយតណ្ហា ទិដ្ឋិ និងមានះ ឈ្មោះថា យ៉ាងអាក្រក់ ។ ដែលមិនសៅហ្មង ឈ្មោះថា កណ្តាល ។ ដែលបញ្ញាឧបត្ថម្ភក្នុងសិក្ខាបទនោះៗ ឈ្មោះថា យ៉ាងល្អ ។ ម្យ៉ាងទៀត សិក្ខាបទទាំងនេះ ដែលសមាទានដោយកុសលចិត្តជាញាណវិប្បយុត្ត ឈ្មោះថា យ៉ាងអាក្រក់ ។ ដែលសមាទានដោយកុសល-

ចិត្ត ជាញាណសម្បយុត្ត ជាសសង្ខារិក ឈ្មោះថា ជាកណ្តាល ។ ដែលសមាទានដោយកុសលចិត្តជាញាណសម្បយុត្ត អសង្ខារិក ឈ្មោះថា យ៉ាងល្អ ។ គប្បីជ្រាបសិក្ខាបទ មានយ៉ាងអាក្រក់ជាដើម ដូចពោលមកដូច្នេះ ។

មាតិកាឯណា ខ្ញុំលើកឡើងជាបទតាំងទុក ដើម្បីពណ៌នាបាឋៈនៃសិក្ខាបទដោយ ៦ គាថា មានពាក្យថា សិក្ខាបទនេះ បុគ្គលណាពោល ពោលទីណា ពោលក្នុងកាលណា ពោលព្រោះហេតុអ្វីជាដើម មាតិកានោះខ្ញុំប្រកាសដោយអត្ថ ដោយពាក្យមានប្រមាណប៉ុណ្ណោះឯង ។

## អធិប្បាយសិក្ខាបទ ចប់

# សុត្តន្តបិដក

## ខុទ្ទកបាឋៈ អាការ ៣២

[ ៣ ] ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ខួរក្នុងក្បាល ។

អាការ ៣២ ចប់

# អដ្ឋកថា

# ទុតិយសាការ

## សម្ពន្ធនៃបទ

[ ៣ ] កម្មដ្ឋាន គឺកាយគតាសតិនេះ ដែលពួកតិរ្ថិយទាំងពួង មិនធ្លាប់ឲ្យប្រព្រឹត្តទៅហើយ ក្រៅពុទ្ធកាល ដើម្បីការបរិសុទ្ធនៃអាសយញ្ញាណ និងដើម្បីចិត្តភាវនារបស់កុលបុត្រដែលមានបយោគដ៏បរិសុទ្ធ ដោយសិក្ខាបទ ១០ យ៉ាងនេះ ជាអ្នកតាំងនៅក្នុងសីល ព្រះមានព្រះភាគទ្រង់សរសើរដោយអាការដ៏ច្រើន ក្នុងព្រះសូត្រនោះ យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងដែលបុគ្គលបានចម្រើនហើយ បានសន្សំរឿយៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្វេគច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីក្សេមចាកយោគៈច្រើន តែងប្រព្រឹត្តទៅ ដើម្បីបាននូវសតិ និងសម្បជញ្ញៈ តែងប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ តែងប្រព្រឹត្តទៅ ដើម្បីនៅជាសុខ ក្នុងបច្ចុប្បន្ន តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា វិមុត្តិ និងផល ។ ធម៌មួយយ៉ាង គឺអ្វី ។ គឺកាយគតាសតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមិនបរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះឈ្មោះថា មិនបរិភោគនូវព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាបរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះ ទើបឈ្មោះថា បរិភោគនូវព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនបរិភោគ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុទាំងនោះ មិនបរិភោគដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាបរិភោគហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះបរិភោគដែរ ។

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិរបស់ពួកភិក្ខុណាសាបសូន្យហើយ ព្រះនិព្វានរបស់ពួកភិក្ខុនោះ ក៏ឈ្មោះថា សាបសូន្យដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិរបស់ពួកភិក្ខុណាមិនសាបសូន្យ ព្រះនិព្វានរបស់ពួកភិក្ខុនោះ ក៏ឈ្មោះថា មិនសាបសូន្យដែរ ។

ដូច្នេះហើយ ទ្រង់សម្តែងជាបព្វៈ ១៤ គឺអានាបានបព្វៈ ឥរិយាបថបព្វៈ

ចតុសម្បជញ្ញបព្វៈ បដិកូលមនសិការបព្វៈ ធាតុមនសិការបព្វៈ នវសីវ-ថិកាបព្វៈ មាន ៩ បព្វៈ ដោយន័យថា

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលបុគ្គលបាន ចម្រើន ដូចម្ដេច បានធ្វើឲ្យរឿយៗ ដូចម្ដេច ទើបមានផលច្រើន មាន អានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃ ក្ដី ... ដូច្នេះជាដើម ។

ឥឡូវនេះ និទ្ទេសនៃការចម្រើនកាយគតាសតិកម្មដ្ឋាននោះ មកដល់ តាមលំដាប់ហើយ ក្នុងនិទ្ទេសនោះ ខ្ញុំពោលជាវិបស្សនា ៣ បព្វៈ គឺឥរិ-យាបថបព្វៈ ចតុសម្បជញ្ញបព្វៈ ធាតុមនសិការបព្វៈ ពោលនវសីវថិកាបព្វៈ ជាអាទីនវានុបស្សនាក្នុងវិបស្សនាញាណ ឯសមាធិភាវនាក្នុងឧទ្ធុមាតិក-អសុភជាដើម ក្នុងនិទ្ទេសនោះ ដែលគប្បីប្រាថ្នា ខ្ញុំក៏ប្រកាសពិស្ដារហើយ ក្នុងអសុភភាវនានិទ្ទេស គម្ពីរវិសុទ្ធិមគ្គទាំងអស់ ។ ២ បព្វៈនេះ គឺអានា-បានបព្វៈ និងបដិកូលមនសិការបព្វៈ ក៏ពោលជាសមាធិហើយ ក្នុងនិទ្ទេសនោះ ក្នុង ២ បព្វៈនោះ អានាបានបព្វៈ ជាកម្មដ្ឋានមួយផ្នែកដោយពិត ដោយជា អានាបានសតិ ឯកម្មដ្ឋាន គឺទ្វត្តិំសាការនោះ ជាបរិយាយនៃភាវនាចំណែក មួយរបស់កាយគតាសតិ ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងសង្គ្រោះខួរក្នុង ក្បាល ដោយខួរក្នុងឆ្អឹង ក្នុងបាលីបទេសនោះៗ យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញច្បាស់ នូវកាយ នេះឯង ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះ

មក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ។បេ។ ទឹកមូត្រ ដូច្នេះ ។ ខ្ញុំផ្តើមហើយ កម្មដ្ឋាន គឺទ្វត្តឹសាការនោះ នឹងពណ៌នាសេចក្តីដូចតទៅនេះ

បណ្តាបទទាំងនោះ បទថា **អត្ថិ** ប្រែថា មាន ។ បទថា **ឥមស្មឹ** សេចក្តីថា ដែលពោលតាំងអំពីបាតជើងឡើងទៅ អំពីចុងសក់ចុះមក មានស្បែកស្រោបដោយជុំវិញ ពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ ។ បទថា **កាយេ** បានដល់ ក្នុងសរីរៈ ។ ពិតហើយ សរីរៈ ហៅថា កាយ ព្រោះសន្សំរបស់មិនស្អាត ឬព្រោះជាទីចម្រើនដុះដាលនៃសក់ជាដើម ដែលគួរខ្ពើម និងរបស់រោគរាប់រយ មានរោគភ្នែកជាដើម ។ បទថា **កេសា ។បេ។ មុត្តំ** គឺអាការ ៣២ មានសក់ជាដើមនេះ ក្នុងទ្វត្តឹសាការនេះ គប្បីជ្រាបការសម្ពន្ធសេចក្តីយ៉ាងនេះថា សក់នៅក្នុងកាយនេះ រោមមាននៅក្នុងកាយនេះជាដើម ។ ឈ្មោះថា ត្រាស់នូវអ្វី ដោយទ្វត្តឹសាការកម្មដ្ឋាននោះ ជាការត្រាស់ថា បុគ្គលណាម្នាក់ កាលពិចារណាដោយអាការគ្រប់យ៉ាង ក្នុងកលេវរកាយប្រមាណមួយព្យាមនេះ គឺប្រមាណប៉ុណ្ណោះ ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ពាសដោយស្បែកជុំវិញ តែងមិនឃើញអ្វីមួយ ទោះជាកែវមុក្តា កែវមណី កែវពិទូរ្យ ក្រស្នា ចន្ទន៍ ស្បូវភ្លាំង កប្បូរ ឬលម្អិតជាដើម សូម្បីទំហំតូចមួយ ថាស្អាត ដោយពិត រមែង

យើញកាយ មានសក់ រោមជាដើម ដែលមានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង មិនមានសិរីដែលគួរមើលឡើយ មានប្រការផ្សេងៗ ជាមិនស្អាតតែម្យ៉ាង ។

ពណ៌នាដោយការសម្ពន្ធនៃបទ

ក្នុងទ្វត្តឹសាការកម្មដ្ឋាននេះប៉ុណ្ណេះសិន

## អសុភភាវនា

គប្បីជ្រាបការពណ៌នាទ្វត្តឹសាការកម្មដ្ឋាននោះ ជាអសុភភាវនា ដូចតទៅ

ជាបឋម កុលបុត្រដែលផ្ដើមបំពេញកម្មដ្ឋាន ជាអ្នកតាំងនៅក្នុងសីល មានបាណាតិបាតវេរមណីសិក្ខាបទជាដើមយ៉ាងនេះហើយ មានប្រយោគដែលបរិសុទ្ធ បំណងប្រកបរឿយៗ នូវអនុយោគ គឺការបំពេញកម្មដ្ឋានចំណែកទ្វត្តឹសាការ ដើម្បីសម្រេចការបរិសុទ្ធនៃអាសយញ្ញាណ កុលបុត្រនោះ រមែងមានបលិពោធ ១០ ប្រការ គឺកង្វល់ដោយលំនៅ ១ ដោយត្រកូល ១ ដោយលាភ ១ ដោយគណៈ ១ ដោយការងារ ១ ដោយការដើរផ្លូវ ១ ដោយញាតិ ១ ដោយការរៀនគម្ពីរ ១ ដោយរោគ ១ ដោយឥទ្ធិឫទ្ធិ ឬដោយការកង្វល់ដោយកិត្តិយស ១ កាលបើដូច្នោះ កុលបុត្រនេះ ក៏ត្រូវកាត់កង្វល់ទាំង ១០ នោះចេញ ដោយវិធីយ៉ាងនេះ គឺដោយការលះនូវការជាប់ជំពាក់ក្នុងអាវាស ត្រកូល លាភ គណៈ ញាតិ និងកិត្តិយសចោល ដោយការមិនខ្វល់ខ្វាយក្នុងការងារ ការដើរផ្លូវ និងការរៀនគម្ពីរ ដោយការព្យាបាលរោគ កាលបើដូច្នោះ កុលបុត្រនេះ កាត់បលិពោធបានហើយ មិនកាត់ការត្រេកអរក្រៃលែងក្នុងនេក្ខម្មៈ កំណត់ការបដិបត្តិ ដុសខាត់ រហូតដល់ខាងចុង មិន

លះបង់អាចារ តាមព្រះវិន័យសូម្បីតិចតួច ក៏គប្បីចូលទៅរកអាចារ្យអ្នកឲ្យកម្មដ្ឋាន ដែលជាបុគ្គលប្រកបដោយអាគម គឺបរិយត្តិ អធិគម គឺបដិវេធ ឬប្រកបដោយគុណឯណាមួយ អំពីអាគម និងអធិគមនោះ ដោយវិធីដែលសមគួរដល់ព្រះវិន័យ និងគប្បីប្រាប់បំណងរបស់ខ្លួនដល់អាចារ្យនោះ ដែលខ្លួនធ្វើឲ្យលោកមានចិត្តត្រេកអរ ដោយវត្តសម្បទា ។ អាចារ្យនោះ គប្បីដឹងការផ្សេងគ្នានៃនិមិត្ត ដែលអាស្រ័យចរិយា និងអធិមុត្តិរបស់កុលបុត្រនោះ បើកម្មដ្ឋាននោះ ជារបស់សមគួរ កាលបើដូច្នោះ កុលបុត្រនោះបំណងនឹងនៅក្នុងវិហារដែលខ្លួននៅសោត បន្ទាប់អំពីនោះ ក៏គប្បីឲ្យកម្មដ្ឋានដោយសង្ខេប បើកុលបុត្រនោះ បំណងនៅក្នុងវិហារដទៃ ក៏គប្បីប្រាប់កម្មដ្ឋានពិស្តារ ព្រមទាំងប្រការដែលគួរធ្វើមុន ដោយប្រាប់ប្រការដែលគួរលះ និងប្រការដែលគួរកំណត់ដឹងជាដើម ព្រមទាំងប្រភេទចរិត ដោយប្រាប់កម្មដ្ឋានដែលសមគួរដល់រាគចរិតជាដើម កុលបុត្រនោះ កាលរៀនកម្មដ្ឋាន ព្រមទាំងប្រការដែលគួរធ្វើមុន មួយអន្លើដោយប្រភេទនោះហើយ លាអាចារ្យវៀរសេនាសនៈ ១៨ ប្រភេទដែលគួរវៀរដូច្នេះ គឺ

អាវាសធំ អាវាសថ្មី ( អាវាសដែលធ្វើមិនទាន់ហើយ ) អាវាសចាស់ ( អាវាសដែលទ្រុឌទ្រោម ) អាវាសជិតផ្លូវ អាវាសក្បែរត្រពាំងទឹក អាវាសដែលមានស្លឹកឈើ អាវាសមានផ្កាឈើ អាវាសមានផ្លែឈើ អាវាសដែលបុគ្គលទាំងឡាយប្រាថ្នា ( អាវាសដែលមនុស្សចូលចិត្តមក ) អាវាសជិតនគរ អាវាសជិតព្រៃឧស អាវាសជិតស្រែចម្ការ អាវាសដែលមានអារម្មណ៍

ជាសត្រូវ អាវាសក្បែរកំពង់ទឹក អាវាសជាប់ព្រំដែន អាវាសត្រង់ចន្លោះព្រំដែន អាវាសដែលជាអសប្បាយ អវាសដែលមិនបានកល្យាណមិត្ត បណ្ឌិតស្គាល់ទី ១៨ ប្រការនេះ ដូច្នេះហើយ គប្បីវៀរឲ្យឆ្ងាយ ដូចអ្នកដើរផ្លូវវៀរផ្លូវដែលមានភ័យចំពោះមុខ ដូច្នោះ ។ ហើយចូលទៅកាន់សេនាសនៈដែលប្រកបដោយអង្គ ៥ ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ចុះសេនាសនៈប្រកបដោយអង្គ ៥ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងលោកនេះ មិនឆ្ងាយពេក មិនជិតពេក ល្មមទៅមកស្រួល មិនកុះករដោយមនុស្សក្នុងវេលាថ្ងៃ មិនសូវមានសំឡេង មិនសូវគឹកកងក្នុងរាត្រី មិនសូវមានសម្ផស្សដោយរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំ ១ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ កើតឡើងដល់ភិក្ខុដែលនៅក្នុងសេនាសនៈនោះដោយមិនលំបាក ១ ពួកភិក្ខុជាថេរៈដែលនៅក្នុងសេនាសនៈនោះ ជាពហុស្សូតចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ១ ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះម្តងៗ ហើយសួរប្រឹក្សាថា បពិត្រលោកដ៏ចម្រើន រឿងនេះតើដូចម្តេច សេចក្តីអធិប្បាយនៃរឿងនេះ តើដូចម្តេច

១ លោកដ៏មានអាយុទាំងនោះ រមែងពន្យល់រឿង
ដែលមិនទាន់ច្បាស់លាស់ផង ធ្វើឲ្យងាយនូវរឿង
ដែលជ្រៅផង បន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌
ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យច្រើន
ប្រការផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេនាសនៈ
ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ។

ដូច្នេះហើយ ធ្វើកិច្ចគ្រប់យ៉ាងឲ្យសម្រេចហើយ ពិចារណាទោសក្នុងកាម ទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ធ្វើចិត្តឲ្យជ្រះថ្លា ដោយការរឭកដល់ ព្រះរតនត្រ័យ ដោយការៈដែលព្រះសម្ពុទ្ធត្រាស់ដឹងល្អហើយ ដោយការៈ ដែលព្រះធម៌ ជាធម៌ល្អ និងដោយការៈដែលព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ មិនលះឧគ្គហកោសល ៧ យ៉ាង ដែលលោកពោលយ៉ាងនេះថា

អ្នកប្រាជ្ញ ជាអ្នកឈ្លាសក្នុងឧបាយ ៧ គឺដោយវាចា
ដោយចិត្ត ដោយវណ្ណៈ ដោយសណ្ឋាន ដោយទិស
ដោយឱកាស និងដោយបរិច្ឆេទ និងមនសិការ-
កោសល ១០ យ៉ាង ដែលលោកពោលទុកយ៉ាងនេះ
គឺដោយលំដាប់ ដោយមិនលឿនពេក មិនយឺតពេក
ដោយការពារសេចក្តីរាយមាយ ដោយកន្លងបញ្ញត្ត
ដោយរំលងលំដាប់ ដោយអប្បនា និងសូត្រ ៣ ទើប
គួរផ្តើមចម្រើនទុត្តិសាការ ពិតហើយ ការចម្រើន

ទុត្តិសាការដោយអាការគ្រប់យ៉ាង រមែងសម្រេចដល់
អ្នកផ្ដើម ដូចពោលមកនេះ មិនមែនសម្រេចដោយ
ប្រការដទៃទេ ។

ក្នុងការចម្រើនទុត្តិសាការនោះ ភិក្ខុទទួលតចបញ្ចកកម្មដ្ឋានមុនខាងដើម ពោលដោយព្រះត្រៃបិដក កាលតចបញ្ចកកម្មដ្ឋានស្ទាត់ជំនាញហើយ ដោយអនុលោមតាមន័យថា **កេសា លោមា** ជាដើម ស្ទាត់ជំនាញហើយដោយបដិលោម តាមន័យថា **តចោ ទន្តា** ជាដើម គប្បីចម្រើនកន្ទះខែ ដោយវាចា ដើម្បីកាត់បង់នូវវិតក្កដែលរាយមាយទៅខាងក្រៅ ដោយអនុលោមនិងបដិលោមតាមន័យទាំង ២ នោះឯង ដើម្បីឲ្យស្ទាត់ក្នុងបាលី និងផ្លូវចិត្ត ដើម្បី កំណត់សភាវៈនៃចំណែករាងកាយជាអារម្មណ៍ ពិតហើយ ការចម្រើនផ្លូវវាចា នូវតចបញ្ចកកម្មដ្ឋាននោះ កាត់បង់នូវការរាយមាយទៅខាងក្រៅបានហើយ រមែងជាបច្ច័យដល់ការចម្រើនផ្លូវវាចា ព្រោះស្ទាត់ក្នុងបាលីហើយ ការចម្រើនផ្លូវចិត្ត រមែងជាបច្ច័យដល់ការកំណត់ពណ៌នៃអសុភ និងលក្ខណៈចំណែកណាមួយ កាលបើដូច្នោះ ដោយន័យនោះ ក៏គប្បីចម្រើនវក្កបញ្ចក-កម្មដ្ឋាន គឺពួកធម៌ ៥ មានវក្កំជាគម្រប់ ៥ អស់កន្ទះខែ បន្ទាប់អំពីនោះ សឹមចម្រើនតចបញ្ចកកម្មដ្ឋាន និងវក្កបញ្ចកកម្មដ្ឋានទាំង ២ នោះអស់កន្ទះខែ បន្ទាប់អំពីនោះ សឹមចម្រើនបប្ផាសបញ្ចកកម្មដ្ឋានកន្ទះខែទៀត បន្ទាប់អំពីនោះ ក៏ចម្រើនទាំង ៣ បញ្ចកៈ នេះប្រមាណកន្ទះខែ កាលបើដូច្នោះ ក៏គប្បីបន្ថែមមត្ថលុង្គដែលមិនបានត្រាស់ទុកខាងចុង ក្នុង ៣ ពួកនេះ ដើម្បីចម្រើន

រួមគ្នា ជាមួយអាការនៃបឋវីធាតុទាំងឡាយ ហើយចម្រើនមគ្គលុង្គិកន្ទះវែខ បន្ទាប់អំពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈកន្ទះវែខ មេទចក្កៈកន្ទះវែខ បន្ទាប់អំពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈរួមគ្នាជាមួយមេទចក្កៈកន្ទះវែខ មុត្តចក្កៈកន្ទះវែខ បន្ទាប់អំពីនោះ ក៏ចម្រើនទ្វត្តឹសាការទាំងអស់កន្ទះវែខ គប្បីចម្រើនកំណត់ដោយវណ្ណៈ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ចំនួន ៦ វែខ ដូចពោលមក ដូច្នេះ ។ សេចក្តីនេះ លោកពោលសំដៅដល់បុគ្គលដែលមានបញ្ញាថ្នាក់កណ្តាល ឯបុគ្គលដែលមានបញ្ញាទន់ខ្សោយគប្បីចម្រើន ដរាបដល់អស់ជីវិត បុគ្គលមានបញ្ញាមុតស្រួច ការចម្រើនរមែងសម្រេចបានក្នុងកាលមិនយូរឡើយ ។

## កោសា

ក្នុងសេចក្តីនេះ អ្នកចោទសួរពោលថា ភិក្ខុអ្នកចម្រើនកម្មដ្ឋាននេះ កំណត់ទ្វត្តឹសាការនេះដោយវណ្ណៈជាដើមដូចម្តេច សេចក្តីពិត ភិក្ខុអ្នកផ្តើមកម្មដ្ឋាន កាលចម្រើនទ្វត្តឹសាការ ដោយចែកជាតចបញ្ចកកម្មដ្ឋានជាដើម ដោយន័យថា មាននៅក្នុងកាយនេះ សក់ ដូច្នេះជាដើម រមែងកំណត់សក់ជារបស់ដូចដែលភិក្ខុនេះឃើញហើយពីមុន ដោយវណ្ណៈថា មានពណ៌ខ្មៅ កំណត់សក់ដែលមានរមូរវែង ដោយសណ្ឋានថា ដូចជងជញ្ជីង តែព្រោះហេតុក្នុងកាយនេះ ចាប់ពីពោះឡើងទៅលើ ហៅថា ទិសខាងលើ ទាបជាងពោះមកក្រោម ហៅថា ទិសខាងក្រោម ដូច្នោះ ទើបកំណត់ដោយទិសថា កើតក្នុងទិសខាងលើនៃកាយនេះ កំណត់ដោយឱកាសថា កើតត្រង់ស្បែក

ក្បាល ជុំវិញត្រចៀក និងដង-ក កំណត់សក់នោះថា សក់មិនដឹងថា អញកើតត្រង់ស្បែកក្បាល សូម្បីស្បែកក្បាល ក៏មិនដឹងថា សក់កើតត្រង់អញ ប្រៀបដូចស្មៅកុណ្ឌៈដែលកើតលើកំពូលដំបូក មិនដឹងថាអញកើតលើកំពូលដំបូក សូម្បីកំពូលដំបូក ក៏មិនដឹងថា ស្មៅកុណ្ឌៈកើតលើអញ ដូច្នោះ កំណត់ថា ពិតហើយ សក់ទាំងនេះ វៀរចាកការគិត និងការពិចារណាជាធម៌ មិនមានចេតនា ជាអព្យាកតៈ សោះសូន្យទទេ បដិកូលដោយក្លិន គួរខ្ពើមរអើមក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល កាលពោលដោយបរិច្ឆេទ ការកាត់ផ្តាច់ មាន ២ យ៉ាង គឺកាត់ផ្តាច់ដោយសភាគ និងកាត់ផ្តាច់ដោយវិសភាគ ក្នុងបរិច្ឆេទ ២ យ៉ាងនោះ កំណត់ដោយការផ្តាច់ ដោយសភាគយ៉ាងនេះថា សក់ត្រូវកាត់ផ្តាច់ខាងក្រោមត្រឹមផ្ទៃស្បែកដែលតាំងនៅ និងដោយគល់របស់ខ្លួនដែលចូលទៅក្នុងស្បែកនោះ ប្រមាណមួយចុងគ្រាប់ស្រូវ តាំងនៅខាងលើ កាត់ផ្តាច់ដោយអាកាស ទទឹងដោយសក់ផងគ្នា និងកំណត់ដោយការកាត់ផ្តាច់ ដោយវិសភាគយ៉ាងនេះថា សក់មិនមែនអាការ ៣១ ដ៏សេស អាការ ៣១ ដ៏សេស ក៏មិនមែនសក់ កំណត់សក់ដោយវណ្ណៈជាដើម ក៏មានប្រការដូចពោលមកយ៉ាងនេះ ។

## លោមា

ក្នុងអាការ ៣១ ដ៏សេស ការកំណត់រោមដែលភិក្ខុនេះធ្លាប់ឃើញហើយ ដោយវណ្ណៈ ដោយច្រើនមានពណ៌ខៀវ ដោយសណ្ឋាន មានសណ្ឋានដូចដងធ្នូ ឬមានសណ្ឋានដូចជក់ត្នោត-ង កំណត់ដោយទិសទាំង ២ កំណត់ដោយ

ឱកាសថា កើតត្រង់ស្បែកនៃសរីរៈដ៏សេស វៀរបាតដៃ-ជើង ។

ក្នុងអាការ ៣០ ដ៏សេសនោះ កំណត់ថា រោមមិនដឹងថា អញកើតត្រង់ស្បែកនៃសរីរៈ សូម្បីស្បែកនៃសរីរៈក៏មិនដឹងថា រោមកើតត្រង់អញ ប្រៀបដូចស្មៅទព្វៈដែលកើតត្រង់ស្រុកចាស់ រមែងមិនដឹងថា អញកើតត្រង់ស្រុកចាស់ សូម្បីស្រុកចាស់ក៏មិនដឹងថា ស្មៅទព្វៈកើតត្រង់អញ ដូច្នោះ ដ្បិតថា រោមទាំងនោះ វៀរការគិត និងការពិចារណា ជាធម៌មិនមានចេតនា ជាអព្យាកតៈ សោះសូន្យទទេ បដិកូលដោយក្លិនស្អុយ គួរខ្ពើមរអើមក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល កំណត់ដោយបរិច្ឆេទថា រោមខាងក្រោមខណ្ឌដោយផ្ទៃស្បែកដែលតាំងនៅ និងគល់របស់ខ្លួនដែលចូលទៅក្នុងស្បែកនោះប្រមាណមួយខ្ទួនចៃតាំងនៅ រោមខាងលើខណ្ឌដោយអាកាស ខាងទទឹងខណ្ឌដោយរោមផងគ្នា នេះជាការកំណត់រោមទាំងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់រោមដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## ឆខា

បន្ទាប់អំពីនេះទៅ ក៏កំណត់ថា បុគ្គលមានក្រចកគ្រប់គ្រាន់ក៏មាន ២០ ក្រចកទាំងអស់នោះ ដោយពណ៌ មានពណ៌ស ក្នុងឱកាសដែលផុតអំពីសាច់ មានពណ៌ក្រហមក្នុងឱកាសដែលជាប់សាច់ ដោយសណ្ឋាន មានសណ្ឋានដូចឱកាសដែលតាំងនៅ ដោយច្រើនមានសណ្ឋានដូចគ្រាប់ស្រគំ ឬមានសណ្ឋានដូចស្រកាត្រី ។ ដោយទិស តាំងនៅក្នុងទិសទាំង ២ ដោយឱកាស តាំងនៅ

ខាងចុងម្រាម ។

ក្នុងក្រចកនោះ កំណត់ថា ក្រចករមែងមិនដឹងថា អញតាំងនៅខាងចុងម្រាម សូម្បីម្រាមក៏មិនដឹងថា ក្រចកតាំងនៅត្រង់ចុងរបស់អញ ប្រៀបដូចគ្រាប់ស្រគំដែលពួកក្មេងអ្នកស្រុកដោតត្រង់ចុងកំណាត់ឈើ មិនដឹងថា អញត្រូវដោតត្រង់ចុងកំណាត់ឈើ សូម្បីចុងកំណាត់ឈើក៏មិនដឹងថា គ្រាប់ស្រគំត្រូវដោតត្រង់អញ ដូច្នោះ ដ្បិតថា ក្រចកទាំងនោះ វៀរចាកការគិត និងការពិចារណា ជាធម៌មិនមានចេតនា ។បេ។ មិនមែនបុគ្គល កំណត់ដោយបរិច្ឆេទថា ក្រចកខាងក្រោមត្រូវខណ្ឌដោយសាច់ម្រាមត្រង់គល់ ឬដោយទីដែលតាំងនៅត្រង់គល់នោះ ខាងលើខណ្ឌដោយឱកាសត្រង់ចុង ដោយស្បែកចុងសងខាងនៃម្រាមទាំងសងខាង នេះជាការកំណត់ក្រចកទាំងនោះ ដោយសភាគ ឯការកំណត់វិសភាគក៏ដូចគ្នានឹងសក់នោះឯង កំណត់ក្រចកដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## ធន្តា

បន្តអំពីនោះទៅ ក៏កំណត់ថា បុគ្គលមានធ្មេញគ្រប់បរិបូណ៌ ក៏មាន ៣២ ធ្មេញទាំងអស់នោះ ដោយពណ៌ ក៏មានពណ៌ស ដោយសណ្ឋាន ធ្មេញរបស់បុគ្គលដែលមានធ្មេញរាបស្មើ និងប្រាកដដូចផ្ទៃស័ង្ខដែលគេកាត់ និងដូចផ្កាពណ៌សក្រពុំដែលតម្រៀប ធ្មេញរបស់បុគ្គលដែលមិនរាបស្មើ មានសណ្ឋានផ្សេងៗ គ្នា ដូចលំដាប់តាំងលើអាសនៈសាលាចាស់ ។ ក្នុងចុងជួរធ្មេញសងខាងនៃធ្មេញទាំងនោះ ៨ ធ្មេញ ខាងក្រោមពីរ ខាងលើពីរ មានចុង ៤

មានគល់ ៤ មានសណ្ឋានដូចអាសន្ទិវែង ។ ៨ ធ្មេញ ដែលតាំងនៅតាមលំដាប់នោះ ក្នុងធ្មេញទាំងនោះ មានចុង ៣ មានឫស ៣ មានសណ្ឋានដូចមើមក្រចាប់ ៤ ធ្មេញ ខាងក្រោម ១ ខាងលើ ១ តាមលំដាប់នោះ ក្នុងធ្មេញទាំងនោះ មានចុង ២ មានឫស ២ មានសណ្ឋានដូចចន្ទល់រទេះ ធ្មេញចង្កូមមាន ៤ តាំងនៅតាមលំដាប់ ក្នុងធ្មេញទាំងនោះ ខាងក្រោម ១ ខាងលើ១ មានចុង ១ មានឫស ១ មានសណ្ឋានដូចផ្កាម្ទេះក្រពុំ បន្ទាប់អំពីនោះ ៨ ធ្មេញ ខាងក្រោម ៤ ខាងលើ ៤ ត្រង់កណ្តាលជួរធ្មេញទាំងសងខាង មានចុង ១ មានឫស ១ មានសណ្ឋានដូចគ្រាប់ឃ្លោក ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស ធ្មេញលើ តាំងនៅក្នុងឆ្អឹងថ្គាមលើ មានចុងចុះក្រោម ធ្មេញក្រោមតាំងនៅក្នុងឆ្អឹងថ្គាមក្រោម មានចុងឡើងលើ ។

ក្នុងធ្មេញនោះ ក៏កំណត់ថា ធ្មេញមិនដឹងថា អញតាំងនៅក្នុងឆ្អឹងថ្គាមខាងក្រោម តាំងនៅក្នុងឆ្អឹងថ្គាមខាងលើ ឆ្អឹងថ្គាមក្រោម ក៏មិនដឹងថា ធ្មេញតាំងនៅក្នុងអញ ឆ្អឹងថ្គាមលើក៏មិនដឹងថា ធ្មេញតាំងនៅក្នុងអញ ប្រៀបដូចសសរដែលបុរសកសាងតាំងឡើងក្នុងផ្ទៃថ្មខាងក្រោម ស៊កចូលក្នុងផ្ទៃថ្មខាងលើ រមែងមិនដឹងថា អញត្រូវគេតាំងទុកក្នុងផ្ទៃថ្មខាងក្រោម ត្រូវស៊កចូលក្នុងផ្ទៃថ្មខាងលើ ផ្ទៃថ្មខាងក្រោមក៏មិនដឹងថា សសរត្រូវគេតាំងទុកក្នុងអញ ផ្ទៃថ្មខាងលើក៏មិនដឹងថា សសរត្រូវគេស៊កចូលក្នុងអញ ដូច្នោះ ។ ដ្បិតថា ធ្មេញទាំងនោះ វៀរចាកការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គលកំណត់ដោយបរិច្ឆេទថា ធ្មេញក្រោម ខណ្ឌដោយរណ្តៅឆ្អឹងថ្គាម ស៊ក

ចូលក្នុងឆ្អឹងថ្គាមតាំងនៅ និងដោយឫសរបស់ខ្លួន ធ្មេញលើខណ្ឌដោយអាកាស ទទឹងកំណត់ដោយធ្មេញផងគ្នា នេះជាការកំណត់ធ្មេញទាំងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ធ្មេញដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## តចោ

បន្ទាប់អំពីនេះទៅ វត្ថុដែលបិទបាំងគំនរសាកសពផ្សេងៗ ខាងក្នុងសរីរៈឈ្មោះថា ស្បែក ។ ស្បែកមានពណ៌ស ស្បែកនោះប្រាកដដូចមានពណ៌ផ្សេងៗ មានពណ៌ខ្មៅ ពណ៌សជាដើម ព្រោះត្រូវជ្រលក់ដោយគ្រឿងជ្រលក់ស្បែកដូច្នោះ ក៏សនោះឯង ដោយពណ៌ដែលជាសភាគគ្នា ។ ការដែលស្បែកនោះមានពណ៌ស ប្រាកដដោយស្បែកដែលត្រូវភ្លើងរលាក និងត្រូវប្រហារដោយគ្រឿងប្រហារជាដើម ។ កំណត់ដោយសណ្ឋាន ដោយសង្ខេបថា មានសណ្ឋានដូចអាវ ដោយពិស្តារថា មានសណ្ឋានផ្សេងៗ ។ ពិតហើយ ស្បែកម្រាមជើងមានសណ្ឋានដូចសម្បុកដង្កូវនាង ស្បែកខ្នងជើង មានសណ្ឋានដូចស្រោមជើងដែលគេខ្ចប់ ស្បែកស្មង មានសណ្ឋានដូចស្លឹកត្នោតដែលគេខ្ចប់បាយ ស្បែកជើង មានសណ្ឋានដូចថង់វែង ដែលគេប្រចកអង្ករពេញ ស្បែកត្រគាកមានសណ្ឋានដូចសំពត់តម្រងទឹក ដែលមានទឹកពេញ ស្បែកខ្នងមានសណ្ឋានដូចបន្ទះស្បែកស្រោបខែល ស្បែកពោះមានសណ្ឋានដូចស្បែកដែលគេដាស់ស្នូកពិណ ។ ស្បែកទ្រូងមានសណ្ឋាន ៤ ជ្រុង ស្បែកដើមដៃទាំង ២ មានសណ្ឋានដូចស្បែកដែលគេរុំធ្នូ ស្បែកខ្នងដៃ មានសណ្ឋានដូចស្រោមកាំបិត-

គោរ ឬមានសណ្ឋានដូចស្រោមស្និត ស្បែកម្រាមដៃមានសណ្ឋានដូចស្រោមសោ ស្បែកកមានសណ្ឋានដូចអាវមានក ស្បែកមុខមានសណ្ឋានដូចសម្បុកដង្កូវ មានប្រហោងតូចធំ ស្បែកក្បាលមានសណ្ឋានដូចស្តោកបាត្រ ។

ព្រះយោគាវចរ កំណត់ស្បែកជាអារម្មណ៍ បញ្ជូនចិត្តចូលទៅវាងស្បែក និងសាច់ តាំងអំពីបបូរមាត់លើ កំណត់ស្បែកមុខជាលំដាប់ដំបូង បន្ទាប់អំពីនោះ កំណត់ស្បែកក្បាល ស្បែកកខាងក្រៅ បន្ទាប់អំពីនោះ គប្បីកំណត់ស្បែកដៃស្តាំ ដោយអនុលោម និងបដិលោម លំដាប់តមក គប្បីកំណត់ស្បែកដៃឆ្វេង ស្បែកខ្នង ស្បែកត្រគាក បន្ទាប់អំពីនោះ កំណត់ស្បែកខ្នងជើងស្តាំ ដោយអនុលោម និងបដិលោម ស្បែកខ្នងជើងឆ្វេង ស្បែកតម្រងបស្សាវៈ ស្បែកពោះតូច ស្បែកបេះដូង ស្បែកកផ្នែកខាងក្នុង បន្ទាប់អំពីនោះ ស្បែកចង្កាក្រោម ស្បែកបបូរមាត់ក្រោម កំណត់យ៉ាងនេះទៀត រហូតដល់បបូរមាត់លើ ។ កំណត់ដោយទិសថា កើតក្នុងទិសទាំង ២ កំណត់ដោយឱកាសថា រុំព័ទ្ធពេញសរីរៈតាំងនៅ ។

ក្នុងស្បែកនោះ ព្រះយោគាវចរកំណត់ថា ស្បែកមិនដឹងថា អញស្រោបសរីរៈដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ សូម្បីសរីរៈ ដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ ក៏មិនដឹងថា អញត្រូវបានស្បែកស្រោប ប្រៀបដូចហិប ដែលពាសដោយស្បែកស្រស់ៗ រមែងមិនដឹងថា អញស្រោបហិប ហិបក៏មិនដឹងថា អញត្រូវស្បែកស្រស់ស្រោប ដូច្នោះ ។ ព្រោះថា ស្បែកទាំងនោះ វៀរចាកការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គល ។

លោកពោលលម្អិតថា

**អាលុចម្មបដិច្ឆន្នោ នវទ្វារោ មហាវណោ**
**សមន្តតោ បគ្ឃរតិ អសុចិបូតិគន្ធិយោ ។**

រាងកាយនេះ ស្រោបដោយស្បែកស្រស់ មានទ្វារ ៩
មានមុខដំបៅច្រើន មិនស្អាត មានក្លិនស្អុយ រមែងហូរ
ចេញដោយជុំវិញ ។

កំណត់ដោយបរិច្ឆេទថា ស្បែកខាងក្រោមខណ្ឌដោយសាច់ ឬដែលតាំងនៅត្រង់សាច់នោះ ខាងលើខណ្ឌដោយសម្បុរថ្ងៃ នេះជាការកំណត់ស្បែកនោះដោយសភាគ ការកំណត់ដោយវិសភាគក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ ស្បែកដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះឯង ។

## មំសំ

បន្ទាប់អំពីនោះទៅ ក៏កំណត់សាច់ដែលមាន ៩០០ ដុំ ក្នុងសរីរៈ ដោយវណ្ណៈថា មានពណ៌ក្រហមដូចផ្កាចារ ដោយសណ្ឋាន មានសណ្ឋានផ្សេងៗគ្នា ពិតហើយ សាច់កំភួនជើងនៃសរីរៈនោះ មានសណ្ឋានដូចបាយដែលខ្ចប់ដោយស្លឹកត្នោត អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចផ្កាការកេតក្រពុំមិនទាន់រីកដូច្នេះក៏មាន សាច់ជើងមានសណ្ឋានដូចត្បាល់បាយ-អ សាច់ត្រគាកមានសណ្ឋានដូចឈើសម្រាប់គោះបន្ទះ សាច់ខ្នងមានសណ្ឋានដូចបន្ទះស្ករត្នោត សាច់ឆ្អឹងជំនីរទាំងសងខាងមានសណ្ឋានដូចដី ដែលគេបូកស្តើងៗ ក្នុងទីដែលគេធ្វើជង្រុកដែលត្បាញដោយឫស្សី សាច់ដោះមានសណ្ឋានដូចដុំដីដែល

សើមដែលគេធ្វើឲ្យមូល ហើយបោះទៅ សាច់ដៃទាំងសងខាង មានសណ្ឋានដូចកណ្ដុរធំដែលគេកាត់កន្ទុយ កាត់ក្បាល ពន្លាត់ស្បែកតាំងទុក ។ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចចង្កោមសាច់ ដូច្នេះក៏មាន សាច់ថ្គាល់មានសណ្ឋានដូចគ្រាប់ថ្នាំដែលគេដាក់ត្រង់ថ្គាល់ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចកន្ត្រៃ ដូច្នេះក៏មាន សាច់អណ្ដាតមានសណ្ឋានដូចត្របកឈូក សាច់ប្រមុះមានសណ្ឋានដូចទូដាក់សៀវភៅដែលគេផ្កាប់ សាច់ប្រឡង់ភ្នែកមានសណ្ឋានដូចផ្លែល្វាទុំពាក់កណ្ដាល សាច់ក្បាលមានសណ្ឋានដូចប្រេងដែលលាបខ្លះស្តើងៗ សម្រាប់អប់បាត្រ ព្រះយោគាវចរកំណត់សាច់ជាអារម្មណ៍ គប្បីកំណត់ចំណែកគ្រោតគ្រាតទាំងនេះឯងដោយសណ្ឋាន ដ្បិតថា ព្រះយោគាវចរកំណត់យ៉ាងនេះ សាច់ដែលល្អិតក៏នឹងប្រាកដដល់ញាណ កំណត់ដោយទិស សាច់កើតក្នុងទិសទាំង ២ ។ កំណត់ដោយឱកាស សាច់បូកលាបតាមឆ្អឹង ៣០០ កំណាត់ ដែលជាគ្រោងតាំងនៅ ។

ក្នុងសាច់នោះ ក៏កំណត់ថា សាច់ ៩០០ ដុំ រមែងមិនដឹងថា អញបូកលាបឆ្អឹង ៣០០ កំណាត់ សូម្បីឆ្អឹង ៣០០ កំណាត់ក៏មិនដឹងថា អញត្រូវសាច់ ៩០០ ដុំបូកលាប ប្រៀបដូចជញ្ជាំងផ្ទះដែលត្រូវបូកលាបដោយដី គ្រោតគ្រាតដី គ្រោតគ្រាតរមែងមិនដឹងថា អញបូកលាបជញ្ជាំងផ្ទះ សូម្បីជញ្ជាំងផ្ទះក៏មិនដឹងថា អញត្រូវដីបូកលាប ដ្បិតថា សាច់ទាំងនោះ វៀរចាកការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គល លោកពោលដោយពិស្តារថា

**នវបេសិសតា មំសា អនុលិត្តា ករេវរំ**
**នានាកិមិកុលាកិណ្ណំ មិឡ្ហត្ថានំវ បូតិកំ ។**

សាច់ ៩០០ ដុំ បូកលាបកលេវរកាយ ដែលពពាក់ពពូន ដោយហ្វូងដង្កូវប្រភេទផ្សេងៗ មានក្លិនស្អុយដូចលាមក ។

កំណត់ដោយបរិច្ឆេទថា សាច់ខាងក្រោម ខណ្ឌដោយឆ្អឹង ឬទីតាំងនៅនៃឆ្អឹងនោះ សាច់ខាងលើខណ្ឌដោយស្បែក សាច់ខាងទទឹងខណ្ឌដោយសាច់គ្នាឯង នេះជាការកំណត់អត្ថនោះដោយសភាគ ឯការកំណត់ដោយវិសភាគក៏ដូចគ្នានឹងសក់នោះឯង កំណត់អត្ថដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## ន្ហារុ

បន្ទាប់អំពីនេះទៅ នឹងកំណត់សរសៃ ៩០០ ក្នុងសរីរៈ ដោយវណ្ណៈមានពណ៌ស ។ អាចារ្យពួកខ្លះពោលថា មានពណ៌ដូចទឹកឃ្មុំ ។ ដោយសណ្ឋានមានសណ្ឋានផ្សេងៗ ពិតហើយ បណ្តាសរសៃ ៩០០ នោះ សរសៃធំៗ មានសណ្ឋានដូចផ្កាកន្ទួលៈក្រពុំ សរសៃតូចមានសណ្ឋានដូចខ្សែអន្ទាក់ដែលគេដាក់ជ្រូក សរសៃដែលតូចជាងនោះ ក៏មានសណ្ឋានដូចវល្លិផោមដែលតូចជាងនោះទៅទៀត មានសណ្ឋានដូចខ្សែពិណធំ របស់អ្នកសីហឡដែលតូចជាងនោះទៅទៀត មានសណ្ឋានដូចអំបោះដែលមានសរសៃធំ សរសៃត្រង់ខ្នងដៃខ្នងជើង មានសណ្ឋានដូចជើងបក្សី សរសៃក្បាលមានសណ្ឋានដូច

សំពត់ស្តើងៗ ដែលគ្របលើក្បាលរបស់ក្មេងអ្នកស្រុក សរសៃខ្ទង់មាន សណ្ឋានដូចសំណាញ់ចាប់ត្រីដែលសើមដោយទឹក ហើយបោកហាលថ្ងៃ សរសៃដែលទៅតាមអវយវៈតូចធំនោះៗ ក្នុងសរីរៈនេះមានសណ្ឋានដូចអាវសំណាញ់ ដែលពាក់ត្រង់សរីរៈ ដោយទិស សរសៃកើតក្នុងទិសទាំង ២ ។ បណ្តាសរសៃទាំងនោះ សរសៃធំ ឈ្មោះថា **កណ្ឌរ** មាន ៥ ចងតាំងអំពីគុម្ពត្រចៀកខាងស្តាំមកខាងមុខ និងខាងក្រោយដល់ខាងឆ្វេង ចងតាំងអំពីសៀតផ្កាខាងឆ្វេងមកខាងមុខ និងខាងក្រោយដល់ខាងស្តាំ ចងតាំងអំពីកញ្ចឹងក ខាងស្តាំមកខាងមុខ និងខាងក្រោយដល់ខាងឆ្វេង ចងតាំងអំពីកញ្ចឹងកខាងឆ្វេងមកខាងមុខ និងខាងក្រោយ ដល់ខាងស្តាំ ចងដៃខាងស្តាំមកខាងមុខ ៥ ខាងក្រោយ ៥ រួមជាសរសៃធំ ១០ ដែលឈ្មោះថា **កណ្ឌរៈ** ជា ១០ ចាក់ស្រេះពេញខ្លួន ។ ដៃខាងឆ្វេង ជើងខាងស្តាំ និងជើងខាងឆ្វេងក៏ដូចគ្នាយ៉ាងនោះ ។ រួមសេចក្តីថា សរសៃធំ ៦០ ដូចពោលមកទាំងនេះកំណត់ថា ជាគ្រឿងជួយទ្រទ្រង់សរីរៈ ជួយកំណត់សរីរៈក៏មាន កំណត់ដោយឱកាស សរសៃចងឆ្អឹងខាងក្នុងឆ្អឹងជាមួយនឹងស្បែក និងឆ្អឹងជាប់នឹងសាច់ តាំងនៅពេញសរីរៈ ។

ក្នុងសរសៃនោះ កំណត់ថា សរសៃរមែងមិនដឹងថា ឆ្អឹង ៣០០ កំណាត់ត្រូវអញចង សូម្បីឆ្អឹង ៣០០ កំណាត់ ក៏មិនដឹងថា អញត្រូវសរសៃចងប្រៀបដូចឈើរៀចៗ ត្រូវវល្លិចងលាម វល្លិរមែងមិនដឹងថា ឈើកោងត្រូវអញចង សូម្បីឈើកោងក៏មិនដឹងថា អញត្រូវវល្លិចង ដូច្នោះ ។ ដ្បិតថា

សរសៃទាំងនោះ វៀរចាកការគិត និងពិចារណាជាធម្មតា ។បេ។ មិនមែន បុគ្គល ។ លោកពោលសរុបថា

**នវ ន្ហារុសតា ហោន្តិ ព្យាមមត្តេ កលេវរេ**
**ពន្ធន្តិ អដ្ឋិសង្ឃាដំ អគារមិវ វល្លិយោ ។**

សរសៃ ៩០០ រមែងចងគ្រោងឆ្អឹងក្នុងសរីរៈ
ប្រមាណមួយព្យាម ដូចវល្លិចងផ្ទះ ដូច្នោះ ។

កំណត់ដោយបរិច្ឆេទថា សរសៃខាងក្រោម ខណ្ឌដោយឆ្អឹង ៣០០ កំណាត់ ឬទីតាំងនៅនៃឆ្អឹងនោះ សរសៃខាងលើខណ្ឌដោយស្បែក និងសាច់ ខាងទទឹងខណ្ឌដោយសរសៃគ្នាឯង នេះជាការកំណត់សរសៃទាំងនោះដោយ សភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់ សរសៃដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## អដ្ឋិ

បន្ទាប់អំពីនេះទៅ ក៏កំណត់ដោយវណ្ណៈថា ឆ្អឹងមានប្រភេទដែលលោក ពោលដោយន័យជាដើមយ៉ាងនេះថា ព្រោះលោកកាន់យកឆ្អឹងធ្មេញ ៣២ ចែក ទុកដោយឡែក ឆ្អឹងដ៏សេសក្នុងសរីរៈ គឺឆ្អឹងដៃ ៦៤ ឆ្អឹងជើង ៦៤ ឆ្អឹង ខ្ចីដែលជាប់សាច់ ៦៤ ឆ្អឹងកែងជើង ២ ឆ្អឹងកជើងម្ខាង ២ ឆ្អឹងស្មង ២ ឆ្អឹង ក្បាលជង្គង់ ១ ឆ្អឹងភ្លៅ ១ ឆ្អឹងចង្កេះ ២ ឆ្អឹងទ្រនង់ខ្នង ១៨ ឆ្អឹងជំនីរ ២៤ ឆ្អឹងទ្រូង ១៤ ឆ្អឹងជិតបេះដូង ១ ឆ្អឹងដងកាំបិត ២ ឆ្អឹងស្មាបប្រចៀវ ២ ឆ្អឹង ដើមដៃ ២ ឆ្អឹងចុងដើមដៃ ( ទ្វេអគ្គពាហត្ថិនិ ) ២ ឆ្អឹងក ៧ ឆ្អឹងចង្កា ២

ឆ្អឹងប្រមុះ ១ ឆ្អឹងក្អែក ២ ឆ្អឹងត្រចៀក ២ ឆ្អឹងថ្ពាស ១ ឆ្អឹងបង្អើយ ១ ឆ្អឹងលលាដ៍ក្បាល ៩ ឆ្អឹងទាំងអស់នោះឯងមានពណ៌ស ។

កំណត់ដោយសណ្ឋានថា ឆ្អឹងមានសណ្ឋានផ្សេងៗ គ្នា ។ ពិតហើយ បណ្តាឆ្អឹងទាំងនោះ ឆ្អឹងចុងម្រាមជើង មានសណ្ឋានដូចគ្រាប់ល្ពៅ បន្ទាប់អំពីនោះ ឆ្អឹងថ្នាំងកណ្តាលរបស់ម្រាមជើងមានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនពេញ ឆ្អឹងថ្នាំងខាងគល់មានសណ្ឋានដូចស្គរតូច អាចារ្យមួយពួកពោលថាមានសណ្ឋានដូចអង្កាំកន្ទុយក្ងោកក៏មាន ឆ្អឹងខ្នងជើងមានសណ្ឋានដូចគំនរឫសដើមកន្ទួលៈដែលគេជំ ឆ្អឹងកែងជើងមានសណ្ឋានដូចកំពីងត្នោតដែលមានគ្រាប់ ១ ឆ្អឹង-កជើងមានសណ្ឋានដូចផ្លែអង្គញ់ចងផ្ញោបគ្នា ឆ្អឹងស្មងតូចមានសណ្ឋានដូចដងធ្នូ ឆ្អឹងស្មងធំមានសណ្ឋានដូចសរសៃស្ងួត ព្រោះស្រេកឃ្លាន ឆ្អឹងស្មងដែលស៊កចូលក្នុង-កជើង មានសណ្ឋានដូចពន្លកដើមល្មើ ដែលបកសម្បកចេញ ឆ្អឹងស្មងដែលតាំងនៅក្នុងឆ្អឹងជង្គង់ មានសណ្ឋានដូចស្គរសម្ភោរ ឆ្អឹងក្បាលជង្គង់មានសណ្ឋានដូចពពុះទឹក ដែលកាត់មួយចំហៀង ឆ្អឹងភ្លៅមានសណ្ឋានដូចដងកាំបិត និងដងពូថៅដែលចាំងច្បោលៗ ឆ្អឹងភ្លៅដែលតាំងនៅក្នុងឆ្អឹងចង្កេះមានសណ្ឋានដូចដងស្នប់របស់ជាងមាស ។ ឱកាសដែលឆ្អឹងភ្លៅតាំងនៅក្នុងឆ្អឹងចង្កេះនោះ មានសណ្ឋានដូចផ្លែបុសនាគកាត់ខាងចុង ឆ្អឹងចង្កេះមាន ២ ក៏ជាប់គ្នាតែមួយ មានសណ្ឋានដូចចង្ក្រានដែលនាយស្មូនធ្មាំងធ្វើ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចខ្សែយរបស់តាបសដូច្នេះក៏មាន ។ ឆ្អឹងត្រគាកមានសណ្ឋានដូចសំណាកពស់ដែលគេផ្កាប់ ឆ្អឹងទ្រនង់ខ្នង ១៨ មាន

ប្រហោងតូច-ធំ ក្នុងទី ៧-៨ កន្លែង ខាងក្នុងមានសណ្ឋានដូចសំពត់ជូតក្បាល ដែលដាក់ត្រួតៗ គ្នា ខាងក្រៅមានសណ្ឋានដូចបំពង់មូល ឆ្អឹងទ្រនង់ខ្នងទាំងនោះមានបន្ទា ២-៣ ពក ដូចធ្មេញរណា ។ បណ្ដាឆ្អឹងជំនីរ ២៤ ចំណែកដែលបរិបូណ៌ មានសណ្ឋានដូចកណ្ដៀវអ្នកសីហឡ ដែលបរិបូណ៌ ចំណែកដែលមិនបរិបូណ៌មានសណ្ឋានដូចកណ្ដៀវអ្នកសីហឡ ដែលមិនបរិបូណ៌ អាចារ្យមួយពួកពោលថា ទាំងអស់នោះឯង មានសណ្ឋានដូចស្លាបទាំង ២ របស់មាន់សំឡីដែលដាច់ចេញ ដូច្នេះក៏មាន ឆ្អឹងដើមទ្រូង ១៤ កំណាត់មានសណ្ឋានដូចបន្ទះឈើ ដូចបន្ទះគ្រែស្នែងចាស់ៗ ឆ្អឹងបេះដូងមានសណ្ឋានដូចបន្ទះវែក ឆ្អឹងដងកាំបិត មានសណ្ឋានដូចកាំបិតលោហៈតូចៗ បណ្ដាឆ្អឹងដងកាំបិតទាំងនោះ ឆ្អឹងខាងក្រោមមានសណ្ឋានដូចអឡ្បចន្ទ ឆ្អឹងស្លាបប្រចៀវមានសណ្ឋានដូចមុខពូថៅ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចចបអ្នកសីឡហៈ ដែលកាត់ពាក់កណ្ដាល ដូច្នោះក៏មាន ឆ្អឹងដើមដៃមានសណ្ឋានដូចដងកញ្ចក់ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចដងកាំបិតធំដូច្នោះក៏មាន ឆ្អឹងចុងដើមដៃ មានសណ្ឋានដូចឫសត្នោតគូ ឆ្អឹងកដៃ មានសណ្ឋានដូចសំពត់ជូតក្បាល ដែលគេដាក់ភ្ជាប់រួមគ្នា ឆ្អឹងខ្នងដៃមានសណ្ឋានដូចគំនរឫសកន្ទួលដែលគេជំ ឆ្អឹងគល់នៃម្រាមដៃមានសណ្ឋានដូចស្គរតូច ឆ្អឹងថ្នាំងកណ្ដាល មានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនបរិបូណ៌ ឆ្អឹងម្រាមខាងចុងមានសណ្ឋានដូចគ្រាប់ល្មៀង ឆ្អឹងក ៧ មានសណ្ឋានដូចទំពាំងដែលគេចោះដាក់តម្រៀបគ្នា ឆ្អឹងចង្កាខាងក្រោម មានសណ្ឋានដូចខ្សែចងញញួរនៃជាងមាស

ឆ្អឹងចង្កាខាងលើ មានសណ្ឋានដូចឈើជម្រះ ៧ ឯឆ្អឹងប្រឡង់ភ្នែក និងក្ដោង ប្រមុះ មានសណ្ឋានដូចផ្លែត្នោតខ្ចីដែលមិនទាន់មានសាច់ ឆ្អឹងថ្ងាស មានសណ្ឋានដូចសម្បកស័ង្ខបែកដែលគេដាក់ផ្កាប់ ឆ្អឹងត្រចៀក មានសណ្ឋានដូចស្រោមកាំបិតកោររបស់ជាងកោរកាត់ បណ្ដាឆ្អឹងថ្ងាស និងឆ្អឹងគុម្ពត្រចៀក ឆ្អឹងក្នុងឱកាសដែលជាប់គ្នា ជាបន្ទះខាងលើ មានសណ្ឋានដូចចម្រៀកសំពត់ចាស់ដែលបិតផ្ទាំង ដែលពេញដោយទឹក ឆ្អឹងបង្ហើយមានសណ្ឋានដូចត្រឡោកដូង ដែលគេកាត់ទទឹងពីខាងមុខ ឆ្អឹងក្បាលមានសណ្ឋានដូចសម្បកឃ្លោកចាស់ដែលដាក់គេព្យួរ ។ ដោយទិសឆ្អឹងទាំងឡាយ កើតក្នុងទិសទាំង ២ ។

ដោយឱកាសឆ្អឹងទាំងឡាយ តាំងនៅពេញសរីរៈ មិនមានវៀរ តែដោយពិសេស ឆ្អឹងក្បាលតាំងនៅលើឆ្អឹង-ក ឆ្អឹង-កតាំងនៅលើឆ្អឹងទ្រនង់ខ្នង ឆ្អឹងទ្រនង់ខ្នងតាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះតាំងនៅលើឆ្អឹងភ្លៅ ឆ្អឹងភ្លៅតាំងនៅលើឆ្អឹងជង្គង់ ឆ្អឹងជង្គង់តាំងនៅលើឆ្អឹងស្មង ឆ្អឹងស្មងតាំងនៅលើឆ្អឹង-កជើង ឆ្អឹង-កជើងតាំងនៅលើឆ្អឹងខ្នងជើង ឆ្អឹងខ្នងជើងក៏លើកឆ្អឹង-កជើងឡើងតាំងទុក ឆ្អឹង-កជើងក៏ទ្រឆ្អឹងស្មង ។បេ។ ឆ្អឹង-កក៏ទ្រឆ្អឹងក្បាលតាំងឡើង គប្បីជ្រាបឆ្អឹងចំណែកដ៏សេស ដោយទំនងដូចពោលមក ដូច្នេះ ។

ក្នុងឆ្អឹងនោះ កំណត់ថា ឆ្អឹងក្បាល រមែងមិនដឹងថា អញតាំងនៅលើឆ្អឹង-ក ។បេ។ ឆ្អឹង-កជើងរមែងមិនដឹងថា អញតាំងនៅលើឆ្អឹងខ្នងជើង សូម្បីឆ្អឹងខ្នងជើងក៏មិនដឹងថា អញលើកឆ្អឹង-កជើងឡើងតាំងទុក ប្រៀបដូចបណ្ដា

ទព្វសម្ភារៈមានឥដ្ឋ និងបន្ទន់ ឥដ្ឋជាដើមខាងលើរមែងមិនដឹងថា អញតាំងនៅលើឥដ្ឋជាដើមខាងក្រោម ឥដ្ឋជាដើមត្រង់កណ្ដាលក៏មិនដឹងថា អញលើកឥដ្ឋជាដើមខាងលើតាំងទុក ដូច្នោះ ដ្បិតថា ឆ្អឹងទាំងនោះ វៀរការគិត និងការពិចារណាជាធម្មតា ។បេ។ មិនមែនបុគ្គល ។ ឆ្អឹង ៣០០ កំណាត់ដែលជាគ្រោងសរីរៈទាំងនេះ ដែលសរសៃ ៩០០ និងសាច់ ៩០០ ជុំ ចង និងបូកលាប ស្បែកស្រោបឲ្យជាប់គ្នាតែមួយ បូកលាបដោយឆវស្អិតទៅតាមបសាទទទួលរស ៧០០០ មានតំណក់ញើស ត្រងដោយរណ្ដៅរោម ៩៩០០០ មានត្រកូលដង្កូវ ៨០ ត្រកូល រាប់បានថាជាកាយតែម្យ៉ាង ដែលព្រះយោគាវចរ កាលពិចារណាដោយសភាវៈពិត រមែងមិនឃើញវត្ថុណាមួយដែលគួរចូលទៅប្រកាន់ តែនឹងឃើញសរីរៈនៃឆ្អឹងតែម្យ៉ាងដែលចងរឹតដោយសរសៃ ដេរដាសដោយសាកសពផ្សេងៗ កាលឃើញហើយ រមែងចូលដល់ភាពជាឱរសរបស់ព្រះទសពល ដូចព្រះតម្រាស់ថា

**បដិចាជិយត្ថីនិ មិតានិ កោជិយា**

**អនេកសន្ធិយមិតោ ន កេហិចិ**

**ពទ្ធោ នហារូហិ ជរាយ ចោទិតោ**

**អចេតនោ កដ្ឋកលិង្គរូបមោ ។**

ឆ្អឹងទាំងឡាយ តាំងចុងរៀងគ្នាក្នុងទី-តជាច្រើនអំពីកាយនេះ ដែលវត្ថុណាមួយ មិនបានចងទុក កាយនេះ សរសៃទាំងឡាយចងទុក ដែលជរាជាស់តឿនហើយ មិនមានចេតនា ឧបមាដូចអន្ទត់ឧស ។

កុណបំ កុណបេ ជាតំ អសុចិអសុចិម្ហិ ច
បូតិកាយម្ហិ បូតីនិ ទុគ្គន្ធេ ចាបិ ទុគ្គន្ធំ
ភេទនធម្មេហិ វយធម្មំ អជ្ឈិបុជេ អជ្ឈិបុជោ
និព្វត្តោ បូតិកាយម្ហិ តម្ហិ ច វិនេថច្ឆន្ទំ
ហោស្សថ បុត្តា ទសពលស្សាតិ ច ។

សាកសពកើតក្នុងសាកសព របស់ស្អុយកើតក្នុងរបស់មិនស្អាត របស់មានក្លិនមិនល្អ កើតក្នុងរបស់មានក្លិនមិនល្អ របស់បែកធ្លាយ កើតក្នុងរបស់ដែលប្រែប្រួលទៅ គំនរឆ្អឹងកើតក្នុងគំនរឆ្អឹង របស់ស្អុយកើតក្នុងកាយស្អុយ អ្នកទាំងឡាយ ចូរកម្ចាត់បង់នូវការពេញចិត្តក្នុងកាយស្អុយនេះចេញ ទើបឈ្មោះថា ជាបុត្ររបស់តថាគតទសពល ។

ដោយបរិច្ឆេទ ក៏កំណត់ថា ខាងក្នុងឆ្អឹងខណ្ឌដោយខួរក្នុងឆ្អឹង ខាងក្រៅខណ្ឌដោយសាច់ ត្រង់ចុង និងគល់ខណ្ឌដោយឆ្អឹងជាមួយគ្នា នេះជាការកំណត់ឆ្អឹងទាំងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ឆ្អឹងដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## អដ្ឋិមិញ្ជំ

តអំពីនេះទៅ នឹងកំណត់ខួរក្នុងឆ្អឹង ដែលនៅខាងក្នុងឆ្អឹងទាំងឡាយ មានប្រភេទតាមដែលពោលហើយក្នុងសរីរៈ ដោយពណ៌ មានពណ៌ស ដោយ

សណ្ឋាន ដូចឱកាសរបស់ខ្លួន គឺខួរក្នុងឆ្អឹងដែលនៅក្នុងឆ្អឹងទាំងឡាយ ដែលមានទំហំធំ មានសណ្ឋានដូចពន្លកផ្ដៅធំ ដែលគេស៊កក្នុងបំពង់ឫស្សី និងដើមបបុស ដែលមានទំហំធំ ខួរក្នុងឆ្អឹងដែលនៅក្នុងឆ្អឹងតូចៗ មានសណ្ឋានដូចពន្លកផ្ដៅ ដែលមានដើមតូច ដែលគេស៊កក្នុងបំពង់ឫស្សី និងដើមបបុសខ្នាតតូច ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស តាំងនៅក្នុងឆ្អឹងទាំងឡាយ ។

ខួរក្នុងឆ្អឹងទាំងនោះ ក៏កំណត់ថា ខួរក្នុងឆ្អឹងរមែងមិនដឹងថា អញនៅខាងក្នុងឆ្អឹង សូម្បីឆ្អឹងក៏មិនដឹងថា ខួរក្នុងឆ្អឹងនៅខាងក្នុងអញ ប្រៀបដូចទឹកដោះជូរ និងទឹកអំពៅនៅខាងក្នុងបំពង់ឫស្សី ឬដើមបបុស ដូច្នោះ រមែងមិនដឹងថា អញនៅខាងក្នុងឫស្សី ឬដើមបបុសជាដើម សូម្បីឫស្សី និងបបុសជាដើម ក៏មិនដឹងថា ទឹកដោះជូរ និងទឹកអំពៅនៅខាងក្នុងអញ ដូច្នោះ ពិតហើយធម៌ទាំងនេះ វៀរការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ខួរក្នុងឆ្អឹងខណ្ឌដោយផ្ទៃខាងក្នុងឆ្អឹងទាំងឡាយ និងដោយចំណែកនៃខួរក្នុងឆ្អឹង នេះជាការកំណត់ខួរក្នុងឆ្អឹងនោះដោយសភាគ ឯការកំណត់ដោយវិសភាគដូចគ្នានឹងសក់នោះឯង ។ កំណត់ខួរក្នុងឆ្អឹង ដោយវណ្ណៈជាដើមមានប្រការដូចពោលមក ដូច្នេះ ។

## វក្កំ

បន្ទាប់ពីនេះទៅ នឹងកំណត់វក្កៈ គឺទាច ដែលមាន ២ ដុំក្នុងសរីរៈ ដោយពណ៌ មានពណ៌ក្រហមខ្ចីដូចគ្រាប់រលួសផ្អុង ដោយសណ្ឋាន មានសណ្ឋាន

ដូចផ្លែអង្គញ់ជោតអំបោះរបស់ក្មេងអ្នកស្រុក អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចស្វាយពីរផ្លែដែលមានទងតែមួយ ដូច្នេះក៏មាន ដោយឱកាស ទាចនោះ ត្រូវសរសៃគ្រោតគ្រាត ដែលចេញមកអំពីប្រជុំក មានគល់តែមួយ ធ្លាក់មកបន្តិច ហើយបែកចេញជា ២ ចំណែក ចងរួបរឹតទុក ហើយព័ទ្ធសាច់បេះដូងតាំងនៅ ។

ក្នុងទាចនោះ ក៏កំណត់ថា ទាចមិនដឹងថា អញត្រូវសរសៃគ្រោតគ្រាតចង សូម្បីសរសៃគ្រោតគ្រាតក៏មិនដឹងថា អញចងទាច ប្រៀបដូចស្វាយ ២ ផ្លែជាប់ទងតែមួយ រមែងមិនដឹងថា អញត្រូវទងចង សូម្បីទង ក៏មិនដឹងថា អញចងស្វាយ ២ ផ្លែ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ដោយបរិច្ឆេទកំណត់ថា ទាច ខណ្ឌដោយចំណែកនៃទាច នេះជាការកំណត់ទាចនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់ដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## ហទយំ

បន្ទាប់អំពីនេះទៅ ក៏កំណត់ថា ហទយៈខាងក្នុងសរីរៈ ដោយពណ៌ មានពណ៌ក្រហម ដូចត្របកឈូកក្រហម ដោយសណ្ឋាន មានសណ្ឋាន ដូចផ្កាឈូកក្រពុំបកត្របកក្រៅចេញហើយ ដាក់សំយុង ។ បេះដូងនោះ ខាងក្នុងដូចផ្លែបុសនាគ កាត់កំពូលខាងលើ ខាងក្រៅរលីង ខាងក្នុងក៏ដូចខាងក្នុងនៃផ្លែននោងព្រៃ ។ បេះដូងរបស់អ្នកមានបញ្ញាច្រើន រីកបន្តិច របស់អ្នក

មានបញ្ញាខ្សោយក្រពុំតែម្យ៉ាង មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណាប្រព្រឹត្តទៅ លះបង់រូបនោះចេញទៅហើយ ។ ឈាមតាំងនៅខាងក្នុងប្រមាណកន្ទះទូកដៃ ខាងក្នុងបេះដូង ពោល គឺដុំសាច់ ចំណែកដ៏សេសឈាមនោះ របស់បុគ្គលរាគចរិត មានពណ៌ក្រហម របស់បុគ្គលទោសចរិតពណ៌ខ្មៅ របស់បុគ្គលមោហចរិត មានពណ៌ដូចទឹកលាងសាច់ របស់បុគ្គលវិតក្កចរិត មានពណ៌ដូចទឹកពពាយជ្រុង របស់បុគ្គលសទ្ធាចរិត មានពណ៌ដូចផ្កាកណិការ របស់បុគ្គលបញ្ញាចរិតថ្លា មិនល្អក់កករ ប្រាកដដូចជាពន្លឺនៃកែវមណីដោយកំណើត ដែលជម្រះហើយ ។ ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស តាំងនៅកណ្តាលដោះទាំង ២ ខាង ក្នុងសរីរៈ ។

ក្នុងបេះដូងនោះ កំណត់ថា បេះដូងមិនដឹងថា អញតាំងនៅពាក់កណ្តាលដោះទាំង ២ សូម្បីដោះក៏មិនដឹងថា បេះដូងតាំងនៅត្រង់ពាក់កណ្តាលអញ ប្រៀបដូចគន្លឹះតាំងនៅកណ្តាលសន្ទះបង្អួច និងសន្ទះទ្វារទាំង ២ រមែងមិនដឹងថា អញតាំងនៅត្រង់កណ្តាលសន្ទះបង្អួច និងទ្វារទាំង ២ សូម្បីសន្ទះបង្អួចនិងទ្វារ ក៏មិនដឹងថា គន្លឹះតាំងនៅកណ្តាលអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា បេះដូងខណ្ឌដោយចំណែកនៃបេះដូង នេះជាការកំណត់បេះដូងនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់បេះដូងដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## យកនំ

បន្ទអំពីនេះទៅ ក៏កំណត់ថា សាច់ ២ បន្ទុះ ដែលហៅថា ថ្លើមខាងក្នុង សរីរៈ ដោយវណ្ណៈ មានពណ៌ក្រហម ដូចពណ៌ត្របកខាងក្រៅ នៃឈូកក្រហម ដោយសណ្ឋាន មានគល់ ១ ចុងបែកជា ២ មានសណ្ឋាន ដូចផ្កាល្ហុសផ្អុង ។ ថ្លើមរបស់បុគ្គលអ្នកមានបញ្ញាទន់ខ្សោយ ផែកខាងចុងតែ ១ ហើយធំ របស់អ្នកមានបញ្ញាច្រើន មានផែក ២-៣ តែតូច ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស អាស្រ័យផ្អឹងជំនីរខាងស្តាំ តាំងនៅខាងក្រោមកន្សោមដោះទាំង ២ ។

ក្នុងថ្លើមនោះ កំណត់ថា ថ្លើមរមែងមិនដឹងថា អញអាស្រ័យផ្អឹងជំនីរខាងស្តាំតាំងនៅ សូម្បីកន្សោមដោះទាំង ២ និងផ្អឹងជំនីរខាងស្តាំ ក៏មិនដឹងថា ថ្លើមអាស្រ័យអញតាំងនៅ ប្រៀបដូចដុំសាច់ដែលព្យួរត្រង់ចំហៀងនៃថ្នាំងរមែងមិនដឹងថា អញព្យួរត្រង់ចំហៀងនៃថ្នាំង សូម្បីថ្នាំងក៏មិនដឹងថា ដុំសាច់ព្យួរក្នុងទីរបស់អញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខណ្ឌដោយចំណែកនៃថ្លើមជាមួយគ្នា នេះជាការកំណត់ថ្លើមដោយសភាគ ឯកំណត់ដោយវិសភាគ ដូចគ្នានឹងសក់នោះឯង ។ កំណត់ថ្លើមដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## កិលោមកំ

បន្ទាប់អំពីនេះទៅ ក៏កំណត់ថា ដោយពណ៌ភាវ មាន ២ យ៉ាង គឺភាវប្រភេទបិទ និងភាវប្រភេទមិនបិទ មានពណ៌ដូចសំពត់ទុកូលចាស់ ដោយ

សណ្ឋាន មានសណ្ឋានដូចឱកាសរបស់ខ្លួន ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស វាវប្រកេទបិទព័ទ្ធបេះដូង និងទាចតាំងនៅ វាវប្រកេទមិនបិទ ហ៊ុមសាច់ក្រោមស្បែកពេញសរីរៈតាំងនៅ ។

ក្នុងវាវនោះ កំណត់ថា វាវរមែងមិនដឹងថា អញស្រោបបេះដូង និងទាច និងស្រោបសាច់ខាងក្រោមស្បែកពេញសរីរៈ សូម្បីបេះដូងក្តី ទាចក្តី សាច់ទូទៅក្នុងសរីរៈក្តី ក៏មិនដឹងថា អញត្រូវវាវស្រោបឡើយ ប្រៀបដូចសាច់ដែលត្រូវសំពត់ទុកូលខ្ចប់ សំពត់ទុកូលក៏មិនដឹងថា អញខ្ចប់សាច់ សាច់ក៏មិនដឹងថា អញត្រូវសំពត់ទុកូលស្រោប ដូច្នោះ ។ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា វាវខាងក្រោមខណ្ឌដោយសាច់ ខាងលើខណ្ឌដោយស្បែក ខាងទទឹងខណ្ឌដោយចំណែកនៃវាវ នេះជាការកំណត់វាវនោះ ដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់វាវដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## ម៉ិហាក់

បន្ទាប់ពីនេះទៅ ក៏កំណត់ថា ដោយពណ៌ ក្រពះខាងក្នុងសរីរៈមានពណ៌ខៀវ មានពណ៌ដូចផ្កាកន្ទឹងក្រៀម ។ ដោយសណ្ឋាន ដោយច្រើនមានសណ្ឋានដូចអណ្តាតគោខ្មៅ មិនជាប់គ្នាប្រមាណ ៧ ធ្នាប់ ។ ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាសតាំងនៅខាងឆ្វេងបេះដូង អាស្រ័យខាងលើផ្ទៃពោះ កាលចេញមកខាងក្រៅ ព្រោះត្រូវប្រហារ ដោយគ្រឿងប្រហារ

សត្វក៏នឹងអស់ជីវិត ។

ក្នុងក្រពះនោះ ក៏កំណត់ថា ក្រពះមិនដឹងថា អញអាស្រ័យចំណែកខាងលើរបស់ផ្ទៃពោះ ចំណែកខាងលើរបស់ផ្ទៃពោះក៏មិនដឹងថា ក្រពះអាស្រ័យអញតាំងនៅ ប្រៀបដូចដុំលាមកគោ អាស្រ័យចំណែកខាងលើពោះតាំងនៅ រមែងមិនដឹងថា អញអាស្រ័យចំណែកខាងលើនៃពោះតាំងនៅ សូម្បីចំណែកខាងលើរបស់ពោះក៏មិនដឹងថា ដុំគោមយ័អាស្រ័យអញតាំងនៅ ដូច្នោះ ដ្បិតថា ធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ក្រពះខណ្ឌដោយចំណែកនៃក្រពះ នេះជាការកំណត់ក្រពះនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ក្រពះដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## បច្ឆាសំ

តអំពីនេះទៅ ក៏កំណត់ថា ដោយពណ៌ ស្អួតជាប្រភេទដុំសាច់ ៣២ ដុំ ខាងក្នុងសរីរៈ ពណ៌ក្រហម ដូចផ្លែល្វាស្រគាល ដោយសណ្ឋាន មានសណ្ឋានដូចទំដែលកាត់មិនស្មើ អាចារ្យមួយពួកពោលថា មានសណ្ឋានដូចគំនរផេដ្ឋដែលគេកធ្វើកំពែងដូច្នេះក៏មាន ។ ស្អួតមិនមានរស មិនមានឱជៈ ដូចគ្នានឹងចំបើងដែលសត្វទំពាហើយ ព្រោះត្រូវប៉ះខ្ទប់ដោយភ្លើងធាតុដែលកើតអំពីកម្មផ្សព្វផ្សាយឡើង ព្រោះមិនមានអាហារដែលទំពាស៊ី និងផឹក ។ ដោយទិសកើតក្នុងទិសខាងលើ ដោយឱកាស តាំងខាងលើ សំយុងគ្របបេះដូង និងប្លើមត្រង់ចន្លោះដោះទាំង ២ ។

ក្នុងសួតនោះ ក៏កំណត់ថា សួតមិនដឹងថា អញតាំងនៅសំយុងរវាង កន្សោមដោះទាំង ២ ខាងក្នុងសរីរៈ សូម្បីកន្សោមដោះទាំង ២ ក្នុងសរីរៈ ក៏មិនដឹងថា សួតសំយុងខាងក្នុងអញ ប្រៀបដូចសម្បុកសត្វដែលសំយុងនៅ ខាងក្នុងជង្រុកចាស់ រមែងមិនដឹងថា អញសំយុងនៅខាងក្នុងជង្រុកចាស់ ទោះ ជង្រុកចាស់ក៏មិនដឹងថា សម្បុកសត្វសំយុងនៅខាងក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល នេះ ជាការកំណត់សួតនោះដោយសភាគ ឯការកំណត់ដោយវិសភាគក៏ដូចគ្នានឹង សក់នោះឯង ។ កំណត់សួតដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## អន្តំ

អំពីនេះទៅ ក៏កំណត់ថា ដោយពណ៌ ពោះវៀនធំ មាន ២១ ផ្នត់ ពោះវៀនធំរបស់បុរសប្រមាណ ៣២ ហត្ថ របស់ស្ត្រីប្រមាណ ២៨ ហត្ថ មានពណ៌ស ដូចពណ៌នៃស្ករគ្រាប់ និងបាយ-អ ដោយសណ្ឋាន មាន សណ្ឋានដូចពស់ដែលគេកាត់ក្បាល ធ្វាយរង្វេលដាក់ក្នុងស្នូកឈាម ។ ដោយ ទិស កើតក្នុងទិសទាំង ២ ដោយឱកាស តាំងនៅខាងក្នុងសរីរៈដែលមាន បំពង់ក និងផ្លូវចេញនៃករីសជាទីបំផុត ព្រោះខាងលើជាប់ត្រង់បំពង់ក និង ខាងក្រោម ជាប់ត្រង់ទ្វារធំ ។

ក្នុងពោះវៀនធំទាំងនោះ ក៏កំណត់ថា ពោះវៀនធំ រមែងមិនដឹងថា អាត្មា អញតាំងនៅខាងក្នុងសរីរៈ សូម្បីសរីរៈក៏មិនដឹងថា ពោះវៀនធំតាំងនៅក្នុង

អញ ប្រៀបដូចខ្ទនពស់ដែលគេកាត់ក្បាលដាក់ក្នុងស្នូកឈាម រមែងមិនដឹងថា អញតាំងនៅក្នុងស្នូកឈាម សូម្បីស្នូកឈាមក៏មិនដឹងថា សរីរៈពស់ដែលមានក្បាលដាច់ តាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា ពោះវៀនធំខណ្ឌដោយចំណែកនៃពោះវៀនធំ ។ នេះជាការកំណត់ពោះវៀនធំដោយសភាគ ចំណែកការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។

## អន្តគុណំ

បន្ទាប់អំពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ពោះវៀនតូច នៅក្នុងចន្លោះពោះវៀនធំក្នុងសរីរៈ ពណ៌សដូចឫសចន្ទុលណី ដោយសណ្ឋាន មានសណ្ឋានដូចឫសចន្ទុលណីនោះឯង ។ អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចទឹកនោមគោ ដូច្នេះក៏មាន ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាសចងខាងចុងមាត់រន្ធេលពោះវៀនធំរួមគ្នា ដូចបន្ទះក្តារយន្តដែលចងខ្សែ ក្នុងកាលដែលមនុស្សធ្វើចប និងពូថៅជាដើម ទាញយន្តតាំងនៅ រវាងផ្នត់ពោះវៀនធំ ២១ ផ្នត់ ដូចខ្សែដែលគេចងចន្លាយខ្សែជូតជើង តាំងនៅក្នុងរវាងខ្សែជូតជើងប៉ុណ្ណោះ ។

ក្នុងពោះវៀនតូចនោះ ក៏កំណត់ថា ពោះវៀនតូចរមែងមិនដឹងថា អញចងពោះវៀនធំ ខាងក្នុងពោះវៀនធំ ២១ ផ្នត់ ពោះវៀនធំក៏មិនដឹងថា ពោះវៀនតូចចងអញ ប្រៀបដូចខ្សែតូចចងចន្លាយខ្សែធំជូតជើង រមែងមិនដឹងថា អញចងចន្លាយខ្សែជូតជើង សូម្បីខ្សែជូតជើងក៏មិនដឹងថា ខ្សែតូចចងអញ

ដូច្នោះ ។ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ពោះវៀនតូចខណ្ឌដោយចំណែកនៃពោះវៀនតូច នេះជាការកំណត់ពោះវៀនតូចនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ពោះវៀនតូចដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## ឧទរិយំ

បន្ទាប់អំពីនោះទៅ ក៏កំណត់ថា អាហារថ្មី ដោយពណ៌ មានពណ៌ដូចអាហារដែលលេបចូលទៅ ដោយសណ្ឋាន មានសណ្ឋានដូចអង្ករដែលចងធូរៗ ក្នុងសំពត់តម្រងទឹក ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស តាំងនៅក្នុងពោះ ធម្មតាពោះ ជាផ្ទៃនៃពោះវៀនធំ ដូចខ្យល់ដែលកើតឯង ត្រង់កណ្ដាលសំពត់សើម ដែលត្រូវប្របាច់ទាំងសងខាង ខាងក្រៅមានសភាពរលីង ខាងក្នុងប្រឡាក់ប្រឡូសដោយគំនរសាច់ស្អោកគ្រោក ដូចសំពត់ជូតរដូវ ដែលប្រឡាក់ប្រឡូស អាចារ្យពួកខ្លះពោលថា ដូចផ្ទៃកខាងក្នុងរបស់ផ្លែខ្នុរស្អុយ ដូច្នេះក៏មាន ។ ក្នុងពោះនោះ មានត្រកូលដង្កូវ ៣២ ត្រកូល យ៉ាងនេះ គឺត្រកូលតក្កោលកៈ មានទំហំប៉ុនផ្លែក្រវាញ កណ្ឌុប្បាទកៈ មានទំហំប៉ុនជន្លេន តាលហិរកៈ មានទំហំប៉ុនជក់ត្នោតជាដើម ដេរដាសប្រវាឡើងគ្នា នៅអាស្រ័យជាប្រចាំ កាលណាមិនមានអាហារ ទឹក និងបាយជាដើម ក៏វារចុះ វារឡើង ស្រែកយំទ្រហឹង ហើយជញ្ជក់សាច់បេះដូង ក្នុងកាលមនុស្សបរិភោគអាហារ មានបាយ និងទឹកចូលទៅ ក៏អើតក ស្ទុះស្ទា

ដំណើមអាហារ ២-៣ ដែលលេបទៅគ្រាដំបូង ផ្ទៃពោះក៏ក្លាយជាផ្ទះសម្រាប់កើតជាបង្គន់ ជារោងព្យាបាល និងជាព្រៃខ្មោចរបស់ជន្តុវទាំងនោះ ជាទីប្រៀបដូចក្នុងសារទរដូវ តំណក់ភ្លៀងគ្រោតគ្រាតធ្លាក់ចុះមកក្នុងអណ្ដូងស្មោកគ្រោកជិតទ្វារស្រុកពួកមនុស្សចណ្ឌាល សាកសពផ្សេងៗ មានបស្សាវៈ ឧច្ចារៈ កំណាត់ស្បែក ឆ្អឹង សរសៃ ទឹកមាត់ ទឹកសំបោរ និងឈាមជាដើម ត្រូវទឹកនាំមកបញ្ចូលគ្នាជាមួយភក់ និងទឹក ក៏មានជន្តុវត្រកូលតូច-ធំកើតឯងកន្លងទៅ ២-៣ ថ្ងៃ ក៏ក្ដៅដោយកម្ដៅថ្ងៃ ក៏បែកជាពពុះ ផុសឡើងខាងលើ មានពណ៌ខៀវចាស់ មិនគួរចូលទៅក្បែរ ឬសម្លឹងមើល មិនចាំបាច់ពោលដល់ការហិត ឬភ្លក់ យ៉ាងណា ទឹក និងបាយជាដើម មានប្រការផ្សេងៗ ក៏ដូច្នោះដូចគ្នា ។ កាលអញ្ច្រែ គឺធ្មេញ បុកល្អិតហើយ កាលដៃ គឺអណ្ដាតត្រឡប់ទៅមកហើយ ប្រឡាក់ប្រឡូសដោយទឹកមាត់ ប្រាសចាកការដល់ព្រមដោយពណ៌ ក្លិន រសជាដើម យ៉ាងណា ដូចកម្អួតឆ្កែក្នុងស្នូកបាយឆ្កែប្របល់គ្នាដោយទឹកប្រមាត់ ទឹកស្លេស្ម ដុតដោយកម្លាំងភ្លើងធាតុក្នុងពោះ និងកម្ដៅ មានជន្តុវត្រកូលតូច-ធំ ពពាក់ពពូនខាងលើ ក្លាយជាគំនរសំរាមមានក្លិនស្អុយ គួរខ្ពើមរអើមក្រៃលែង ។ ដែលស្ដាប់ហើយ ធ្វើមិនឲ្យចង់ផឹកទឹក បរិភោគបាយជាដើម កុំចាំបាច់ពោលដល់ការសម្លឹងមើលដោយចក្ខុ គឺបញ្ញាឡើយ ដែលជាទីទឹក និងបាយជាដើមធ្លាក់ទៅហើយ នឹងបែងជា ៥ ចំណែក គឺ ១ ចំណែកសត្វក្នុងពោះស៊ី ១ ចំណែកភ្លើងដុតរោល ១ ចំណែកក្លាយជាបស្សាវៈ ១ ចំណែកក្លាយជាឧច្ចារៈ ១ ចំណែកក្លាយជាឱជៈ

ទំនុកបម្រុងឈាម និងសាច់ ។

ក្នុងអាហារថ្មីនោះ ក៏កំណត់ថា អាហារថ្មី រមែងមិនដឹងថា អញនៅក្នុងពោះ ដែលមានក្លិនស្អុយគួរខ្ពើមក្រៃលែងនេះ សូម្បីពោះក៏មិនដឹងថា អាហារថ្មីនៅក្នុងអញ ប្រៀបដូចកម្ពុតត្លៃដែលនៅក្នុងស្នូក សូម្បីស្នូកក៏មិនដឹងថា កម្ពុតត្លៃ នៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ដឹងថា អាហារថ្មីខណ្ឌដោយចំណែកអាហារថ្មី នេះជាការកំណត់អាហារថ្មីនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់អាហារថ្មីដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## ករីសំ

តអំពីនេះទៅ ក៏កំណត់ថា អាហារចាស់ខាងក្នុងសរីរៈ ដោយច្រើន ដោយពណ៌ក៏ដូចអាហារដែលលេបចូលទៅ ដោយសណ្ឋាន ក៏មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងក្រោម ដោយឱកាស តាំងនៅក្នុងទីដែលអាហាររលាយ ហើយនៅអាស្រ័យ ធម្មតាប្រទេសដែលអាហាររលួសហើយនៅអាស្រ័យ ក៏ជាបទេសដូចខាងក្នុងបំពង់ឫស្សី និងបបុស កម្ពស់ប្រមាណ ៨ ធ្នាប់ នៅខាងចុងពោះវៀនធំ រវាងពោះតូច និងឆ្អឹងទ្រនង់ខ្នងខាងក្រោម ប្រៀបដូចទឹកភ្លៀងធ្លាក់ត្រង់ទីខាងលើ ហូរចុះទៅទីខាងក្រោមពេញហើយ ដក់នៅ យ៉ាងណា ទឹក និងបាយជាដើមណាមួយ ដែលធ្លាក់ចូលក្នុងលំនៅរបស់អាហារថ្មី កាលភ្លើងធាតុដុតឲ្យឆ្អិន បែកជាពពុះតូច-ធំ

ក្លាយជារបស់ល្អិតដូចម្សៅ ព្រោះភ្លើងធាតុធ្វើឲ្យល្អិត ហើយក៏ហូរទៅតាម បំពង់ពោះវៀនធំ ប្រជ្រៀតគ្នា តាំងនៅ ដូចដីពណ៌លឿងដែលគេញាត់ក្នុង បំពង់ឫស្សី និងដើមបបុស ក៏ដូច្នោះដូចគ្នា ។

ក្នុងអាហារចាស់នោះ ក៏កំណត់ថា អាហារចាស់រមែងមិនដឹងថា អញនៅ ក្នុងលំនៅរបស់អាហារ ដែលរលាយហើយ សូម្បីលំនៅរបស់អាហារ ដែល រលាយហើយ ក៏មិនដឹងថា អាហារចាស់នៅក្នុងអញ ប្រៀបដូចដីឥដ្ឋ ដែល គេប្របាច់ញាត់ក្នុងបំពង់ឫស្សី និងដើមបបុស រមែងមិនដឹងថា អញនៅក្នុង បំពង់ឫស្សី និងដើមបបុស សូម្បីបំពង់ឫស្សី និងដើមបបុស ក៏មិនដឹងថា ដីឥដ្ឋនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការ ពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា អាហារចាស់ ខណ្ឌដោយចំណែកនៃអាហារចាស់ នេះជាការកំណត់អាហារចាស់នោះដោយ សភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ អាហារចាស់ដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## មត្ថលុង្គំ

បន្ទាប់អំពីនេះទៅ ក៏កំណត់ដោយពណ៌ថា ខួរក្នុងលលាដ៍ក្បាល ក្នុង សរីរៈមានពណ៌សដូចផ្សិត ។ អាចារ្យពួកខ្លះពោលថា មានពណ៌ដូចទឹកដោះ ស្រស់ ដូច្នេះក៏មាន ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាសជាប្រភេទដុំខួរ ៤ ដុំ ដែលអាស្រ័យ ស្នាមសរសៃ ៤០០ ខាងក្នុងលលាដ៍ក្បាល រួមគ្នាតាំងនៅដូចដុំម្សៅ ៤ ដុំ

ដែលគេរួមគ្នាតាំងទុក ។

លលាដ៍ក្បាលនោះកំណត់ថា ខួរក្នុងក្បាល រមែងមិនដឹងថា អញនៅក្នុងលលាដ៍ក្បាល លលាដ៍ក្បាលក៏មិនដឹងថា ខួរក្នុងក្បាលនៅក្នុងអញ ប្រៀបដូចដុំម្សៅដែលគេដាក់ក្នុងសម្បកឃ្លោកចាស់ ឬទឹកដោះក្តៅ រមែងមិនដឹងថា អញនៅក្នុងសម្បកឃ្លោកចាស់ សូម្បីសម្បកឃ្លោកចាស់ ក៏មិនដឹងថា ដុំម្សៅ ឬទឹកដោះក្តៅនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខួរក្នុងក្បាល ខណ្ឌដោយចំណែកនៃខួរក្នុងក្បាល នេះជាការកំណត់ខួរក្នុងក្បាលនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ដូចគ្នានឹងសក់នោះឯង ។ កំណត់ខួរក្នុងក្បាលដោយពណ៌ជាដើម មានប្រការដូចពោលមកដូច្នេះ ។

# បិត្តំ

បន្ទាប់ពីនេះទៅ កំណត់ថា ប្រមាត់មាន ២ ប្រភេទ គឺប្រមាត់ក្នុងស្រោម និងប្រមាត់ក្រៅស្រោម មានពណ៌ដូចប្រេងស្រគំខាប់ អាចារ្យពួកខ្លះពោលថា ប្រមាត់ក្រៅស្រោម មានពណ៌ដូចផ្កាពិកុលក្រៀមដូច្នេះក៏មាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស ប្រមាត់ក្រៅស្រោម វៀរទីរបស់សក់ រោម ក្រចក ធ្មេញ ដែលផុតចាកសាច់ និងស្បែកដែលរឹង ឬក្រិន ប្រមាត់ជ្រួតពេញសរីរៈដ៏សេស ដូចតំណក់ប្រេង ផ្សាយទៅលើទឹក កាលប្រមាត់កម្រើកហើយ ភ្នែកក៏ទៅជាលឿង វិលមុខ ញ័រខ្លួន

និងកើតរមាស់ ។ ប្រមាត់ក្នុងស្រោមតាំងនៅក្នុងស្រោមប្រមាត់ ដូចផ្លែនោងព្រៃធំ អាស្រ័យសាច់បេះដូង តាំងនៅក្នុងចន្លោះបេះដូង និងសួត កាលកម្រើកហើយ សត្វទាំងឡាយនឹងទៅជាឆ្កួត មានចិត្តវិបល្លាស លះបង់នូវហិរិ និងឱត្តប្បៈ ធ្វើការដែលមិនគួរធ្វើ ពោលពាក្យដែលមិនគួរពោល គិតវត្ថុដែលមិនគួរគិត ។

ក្នុងប្រមាត់នោះ ក៏កំណត់ថា ប្រមាត់ឥតស្រោម រមែងមិនដឹងថា អញជ្រួតជ្រាបពេញសរីរៈ សូម្បីសរីរៈក៏មិនដឹងថា ប្រមាត់ក្រៅស្រោមជ្រួតជ្រាបក្នុងអញ ប្រៀបដូចប្រេងជ្រួតជ្រាបក្នុងទឹក រមែងមិនដឹងថា អញជ្រួតជ្រាបក្នុងទឹក សូម្បីទឹកក៏មិនដឹងថា ប្រេងជ្រួតជ្រាបក្នុងអញ ដូច្នោះ ប្រមាត់ក្នុងស្រោម រមែងមិនដឹងថា អញនៅក្នុងស្រោម សូម្បីស្រោមក៏មិនដឹងថា ប្រមាត់នៅក្នុងអញ ប្រៀបដូចទឹកភ្លៀងដែលនៅក្នុងកន្សោមនោងព្រៃ រមែងមិនដឹងថា អញនៅក្នុងកន្សោមនោងព្រៃ សូម្បីកន្សោមនោងព្រៃ ក៏មិនដឹងថា ទឹកភ្លៀងនៅក្នុងអញ ដូច្នោះ ។ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា ប្រមាត់ខណ្ឌដោយចំណែកនៃប្រមាត់ នេះជាការកំណត់ប្រមាត់នោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ប្រមាត់ដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## សេម្ហំ

បន្ទាប់អំពីនេះទៅ នឹងពោលអំពីសេម្ហៈ ដោយពណ៌ ស្លេស្មមានប្រមាណ

មួយបាត្រ[១] ខាងក្នុងសរីរៈ មានពណ៌ស ដូចពណ៌ក្នុងទឹកផ្លែល្វា ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស តាំងនៅក្នុងពោះ ក្នុងកាលលេបអាហារ មានទឹក និងភោជនជាដើម កាលទឹក និងភោជនជាដើមធ្លាក់ចុះ ក៏បែកចេញជា ២ ចំណែក ហើយបិទបាំងវិញ បើមានតិច ផ្ទៃពោះនឹងមានក្លិនដូចសាកសព គួរខ្ពើមរអើមក្រៃលែង ដូចបូសដែលទុំ ដូចពងមាន់ស្អុយ ប្រៀបដូចចកក្នុងទឹក កាលកំណាត់ឈើ ឬអំបែងធ្លាក់ចុះ ក៏ដាច់ចេញជា ២ ចំណែក ហើយត្រឡប់មកបិទបាំងផ្ទៃទឹកទៀត ដូច្នោះ ភើក្តី ស្វាបក្តី នឹងមានក្លិនស្អុយដូចសាកសព ស្អុយដោយក្លិនដែលផ្សាយឡើងក្នុងពោះនោះ បុគ្គលនោះក៏ត្រូវគេដេញគំហកថា ចេញទៅឯង ជះក្លិនស្អុយ ហើយកាលសេម្ហៈចម្រើនច្រើនឡើង ក៏ជួយរម្ងាប់ក្លិនស្អុយ តាំងនៅខាងក្នុងផ្ទៃពោះនោះឯង ដូចបន្ទះក្តារដែលបិទបង្គន់ ។

ក្នុងសេម្ហៈនោះ ក៏កំណត់ថា សេម្ហៈរមែងមិនដឹងថា អញនៅក្នុងផ្ទៃពោះ សូម្បីផ្ទៃពោះក៏មិនដឹងថា សេម្ហៈនៅក្នុងអញ ប្រៀបដូចជុំពពុះនៅលើអណ្តូងស្មោកគ្រោក រមែងមិនដឹងថា អញនៅក្នុងអណ្តូងស្មោកគ្រោក សូម្បីអណ្តូងស្មោកគ្រោកក៏មិនដឹងថា ជុំពពុះនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា សេម្ហៈខណ្ឌដោយចំណែកនៃសេម្ហៈ ។ នេះជាការកំណត់សេម្ហៈនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់សេម្ហៈដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

---

១- ឯកបត្ត ក្នុងទីខ្វះ លោកប្រែថា មួយកម្បង់

## បុព្វោ

បន្ទាប់ពីនេះទៅ ក៏កំណត់បុព្វោថា ដោយពណ៌ ខ្ទុះមានពណ៌ដូចស្លឹកឈើទុំ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសទាំង ២ ដោយឱកាស ធម្មតាឱកាសរបស់ទិសតាំងនៅជាប្រចាំមិនមាន និងតាំងនៅក្នុងតំណែងសរីរៈដែលខ្ទុះសន្សំ តាំងនៅ កាលត្រូវជន្លត់ បន្ទា ឬអណ្ដាតភ្លើងជាដើមក្ដី ប៉ះខ្ទប់ហើយ ក៏រងឈាម ឬកើតបូស ឬពកជាដើម ។ ក្នុងខ្ទុះនោះក៏កំណត់ថា ខ្ទុះរមែងមិនដឹងថា អញតាំងនៅក្នុងតំណែងដែលត្រូវជន្លត់ និងបន្ទាជាដើមប៉ះខ្ទប់ ឬក្នុងតំណែងដែលកើតបូស និងពកជាដើមក្នុងទីនោះៗ នៃសរីរៈ សូម្បីតំណែងនៃសរីរៈក៏មិនដឹងថា ខ្ទុះនៅក្នុងអញ ប្រៀបដូចជ័រឈើដែលហូរចេញ តាំងនៅក្នុងទីដែលត្រូវមុខពូថៅជាដើមចំពោះក្នុងទីនោះៗ នៃដើមឈើ រមែងមិនដឹងថា អញតាំងនៅក្នុងទីដែលត្រូវចំពោះរបស់ដើមឈើ សូម្បីទីដែលត្រូវចំពោះរបស់ដើមឈើ ក៏មិនដឹងថាជ័រឈើតាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ខ្ទុះខណ្ឌដោយចំណែកនៃខ្ទុះ នេះជាការកំណត់ខ្ទុះនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ខ្ទុះដោយវណ្ណៈជាដើមមានប្រការដូចពោលមក ដូច្នេះ ។

## លោហិតំ

បន្តបន្ទាប់អំពីនេះទៅ នឹងពោលអំពីលោហិត ឈាមមាន ២ យ៉ាង គឺឈាមខាប់ និងឈាមរាវ នឹងកំណត់ឈាមខាប់មុន ដោយពណ៌ មានពណ៌

ដូចទឹកល័ក្តខាប់ ឈាមរាវមានពណ៌ដូចទឹកល័ក្តថ្លា ។ ដោយសណ្ឋានឈាមគ្រប់យ៉ាងមានសណ្ឋានដូចឱកាសរបស់ខ្លួន ដោយទិស ឈាមខាប់កើតក្នុងទិសខាងលើ ឈាមរាវកើតក្នុងទិសទាំង ២ ដោយឱកាសឈាមរាវផ្សព្វផ្សាយទៅពេញសរីរៈគ្រប់ចំណែករបស់សត្វរស់ វៀរតែទីដែលសក់ រោម ក្រចក និងធ្មេញដែលផុតចាកសាច់ និងស្បែកដែលក្រិន និងស្ងួតប៉ុណ្ណោះ ឈាមខាប់ធ្វើចំណែកខ្លះនៃថ្លើមឲ្យពេញលេញ ហើយធ្វើតំណក់ឈាមឲ្យស្រក់ចុះម្តងបន្តិចៗ លើក្រពះ បេះដូង ថ្លើម និងសួត ប្រមាណពេញមួយទូកដៃ ។ ធ្វើក្រពះ បេះដូង ថ្លើម និងសួតឲ្យសើម កាលមិនធ្វើក្រពះ និងបេះដូងជាដើមឲ្យសើម សត្វទាំងឡាយក៏ស្រេកទឹក ។

ក្នុងឈាមក៏កំណត់ថា ឈាមរមែងមិនដឹងថា អញធ្វើក្រពះ និងបេះដូងជាដើមឲ្យសើម តាំងនៅចំណែកខាងក្រោមនៃថ្លើម សួម្បីត្រង់ចំណែករបស់ថ្លើម ក្រពះ និងបេះដូងជាដើម ក៏មិនដឹងថា ឈាមតាំងនៅក្នុងអញ ឬធ្វើអញឲ្យសើម តាំងនៅ ប្រៀបដូចទឹកដែលនៅក្នុងកាជនៈចាស់ៗ ធ្វើដុំដីជាដើមខាងក្រោមឲ្យសើម រមែងមិនដឹងថា អញតាំងនៅក្នុងកាជនៈចាស់ៗ ធ្វើដុំដីជាដើមខាងក្រោមឲ្យសើម សួម្បីកាជនៈចាស់ៗ ឬដុំដីជាដើមខាងក្រោម ក៏មិនដឹងថា ទឹកតាំងនៅក្នុងអញ ឬធ្វើអញឲ្យសើម តាំងនៅ ដូច្នោះ ដ្បិតថាធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ឈាមខណ្ឌដោយចំណែកនៃឈាម ។ នេះជាការកំណត់ឈាមនោះ ដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹង

សក់នោះឯង ។ កំណត់ឈាមដោយពណ៌ជាដើម មានប្រការដូចពោលមក
ដូច្នេះ ។

## សេទោ

បន្ទាប់ពីនេះទៅ ក៏កំណត់សេទោថា ញើសក្នុងសរីរៈ ដោយពណ៌ មាន
ពណ៌ដូចទឹកល្ងថ្លា ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស
កើតក្នុងទិសទាំង ២ ដោយឱកាស ធម្មតាញើស ហូរចេញជានិច្ចក៏មិនមែន
តែញើសមានសព្វកាល ឬក្នុងកាលណាសរីរៈក្តៅ ព្រោះពន្លឺថ្ងៃ និងរដូវ
ប្រែប្រួលជាដើម ពេលនោះ ញើសទើងហូរចេញគ្រប់រន្ធសក់ និងរន្ធរោម
ដូចទឹកក្នុងក្រអៅឈូក និងទងឈូកដែលកាត់មិនរាបស្មើលើកឡើងផុតទឹក
ដូច្នោះ ទើបព្រះយោគាវចរកំណត់ញើសនោះ ដោយសណ្ឋាន ដោយរន្ធសក់
និងរណ្តៅរោមទាំងនោះ បុព្វាចារ្យទាំងឡាយពោលថា ដែលព្រះយោគាវចរ
កំណត់យកញើសជាអារម្មណ៍ គប្បីមនសិការដាក់ចិត្តក្នុងញើស ដោយភាព
ដែលញើសធ្វើរន្ធសក់ និងរណ្តៅរោមឲ្យពេញ ហើយតាំងនៅ ។

ក្នុងញើសនោះកំណត់ថា ញើសរមែងមិនដឹងថា អញហូរចេញអំពីរន្ធ
សក់ និងរណ្តៅរោម សូម្បីរន្ធសក់ និងរណ្តៅរោម ក៏មិនដឹងថា ញើសហូរ
ចេញអំពីអញ ប្រៀបដូចទឹកដែលហូរចេញអំពីក្រអៅ និងទងឈូក រមែង
មិនដឹងថា អញហូរចេញអំពីក្រអៅឈូក និងទងឈូក សូម្បីក្រអៅឈូក និង
ទងឈូក ក៏មិនដឹងថា ទឹកហូរចេញអំពីអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ
វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ

កំណត់ថា ញើសខណ្ឌដោយចំណែកនៃញើស នេះជាការកំណត់ញើសនោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ញើសដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## មេទោ

បន្ទាប់អំពីនេះទៅ ក៏កំណត់មេទោ ដោយវណ្ណថា ខ្លាញ់ខាប់នៅក្នុងចន្លោះស្បែក និងសាច់ក្នុងសរីរៈ ដោយពណ៌ មានពណ៌ដូចរមៀតដែលពុស ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ពិតហើយ សម្រាប់បុគ្គលដែលមានខ្លួនធាត់ មានសេចក្ដីសុខ ខ្លាញ់ខាប់ដែលផ្សាយទៅក្នុងចន្លោះស្បែក និងសាច់ មានសណ្ឋានដូចសំពត់សម្បកឈើចាស់ជ្រលក់រមៀត សម្រាប់បុគ្គលដែលមានខ្លួនស្គម ខ្លាញ់ខាប់ អាស្រ័យសាច់កំភួនជើង សាច់ភ្លៅ សាច់អាស្រ័យឆ្អឹងខ្នង សាច់ខ្នង និងសាច់ផ្ទៃពោះប្រជុំគ្នា មានសណ្ឋានដូចសំពត់សម្បកឈើចាស់ជ្រលក់រមៀត ដែលគេប្រមូល ។ ដោយទិសកើតក្នុងទិសទាំង ២ ដោយឱកាស ខ្លាញ់ខាប់ សម្រាប់បុគ្គលធាត់ ផ្សាយទូទៅពេញសរីរៈ សម្រាប់បុគ្គលស្គម អាស្រ័យសាច់កំភួនជើងជាដើម គឺខ្លាញ់ស្អិត មិនមែនសង្គ្រោះដើម្បីជាខួរក្នុងឆ្អឹង មិនមែនដើម្បីជាប្រេងក្នុងពំនូតបាយ មិនមែនដើម្បីធ្វើជាប្រេងប្រទីប ព្រោះជារបស់គួរខ្ពើមរអើមក្រៃលែង ។

ក្នុងខ្លាញ់ខាប់នោះកំណត់ថា ខ្លាញ់ខាប់រមែងមិនដឹងថា អញអាស្រ័យពេញសរីរៈ ឬសាច់ដែលនឹងជាដើមតាំងនៅ សូម្បីសរីរៈទាំងមូល ឬសាច់

ដែលរឹងជាដើម ក៏មិនដឹងថា ខ្លាញ់ខាប់អាស្រ័យអញតាំងនៅ ប្រៀបដូចសំពត់សម្បកឈើចាស់ជ្រលក់រមៀត ដែលគេដាក់ផ្អែកគំនរសាច់ រមែងមិនដឹងថា អញគេដាក់ផ្អែកគំនរសាច់ សូម្បីគំនរសាច់ក៏មិនដឹងថា សំពត់សម្បកឈើចាស់ជ្រលក់រមៀត ដាក់ផ្អែកអញ ដូច្នោះ ។ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខ្លាញ់ខាប់ខាងក្រោមខណ្ឌដោយសាច់ ខាងលើខណ្ឌដោយស្បែក ជុំវិញខណ្ឌដោយចំណែកនៃខ្លាញ់ខាប់ នេះជាការកំណត់ខ្លាញ់ខាប់នោះដោយសភាគ ឯការកំណត់ដោយវិសភាគ ដូចគ្នានឹងសក់នោះឯង ។ កំណត់ខ្លាញ់ខាប់ដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## អស្សុ

លំដាប់អំពីនេះទៅ ក៏កំណត់ថា ដោយវណ្ណៈ ទឹកភ្នែកមានពណ៌ដូចប្រេងល្ងថ្លា ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស តាំងនៅក្នុងប្រឡង់ភ្នែក ។ ទឹកភ្នែកនោះ មិនមែនដក់នៅក្នុងប្រឡង់ភ្នែកគ្រប់កាល ដូចប្រមាត់ក្នុងស្រោមនោះឡើយ សេចក្តីនេះដូចម្តេច កាលណាសត្វទាំងឡាយកើតសោមនស្ស ក៏សើចសប្បាយ កើតទោមនស្សក៏ទ្រហោយំ ឬបរិភោគអាហារហឹរក៏ដូចគ្នា កាលណាភ្នែកទាំង ២ នៃសត្វទាំងនោះត្រូវផ្សែង ឬលម្អងធូលី និងកម្ទេចជាដើមប៉ះខ្ទប់ កាលនោះទឹកភ្នែកកើតឡើងព្រោះសោមនស្ស ទោមនស្ស និងអាហារក្តៅជាដើម ក៏នៅដក់ ហៀរចេញពេញប្រឡង់ភ្នែក បុព្វាចារ្យទាំងឡាយពោលថា ព្រះ

យោគាវចរកំណត់យកទឹកភ្នែកជាអារម្មណ៍ គប្បីមនសិការដាក់ចិត្តក្នុងទឹកភ្នែកដែលកំពុងដក់ពេញប្រឡង់ភ្នែកនោះឯង ។

ក្នុងទឹកភ្នែកនោះកំណត់ថា ទឹកភ្នែករមែងមិនដឹងថា អញដក់នៅក្នុងប្រឡង់ភ្នែក ប្រឡង់ភ្នែកមិនដឹងថា ទឹកភ្នែកដក់នៅក្នុងអញ ប្រៀបដូចទឹកដែលដក់នៅក្នុងប្រឡង់ផ្លែត្នោត ដែលកាត់ខាងចុង រមែងមិនដឹងថា អញដក់នៅក្នុងប្រឡង់ផ្លែត្នោតដែលកាត់ចុង សូម្បីប្រឡង់ផ្លែត្នោតដែលកាត់ចុង ក៏មិនដឹងថាទឹកដក់នៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ទឹកភ្នែកខណ្ឌដោយចំណែកនៃទឹកភ្នែក នេះជាការកំណត់ទឹកភ្នែកនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកភ្នែកដោយពណ៌ជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## វសា

តអំពីនោះទៅ ក៏កំណត់ខ្លាញ់រាវដោយពណ៌ថា ខ្លាញ់រាវ គឺខ្លាញ់ដែលរលាយ នៅក្នុងសរីរៈ មានពណ៌ដូចប្រេងដែលស្រោចក្នុងបាយក្តាំង ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស តាំងនៅត្រង់បាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ក្តោងច្រមុះ ថ្ងាស និងចុងស្មា តែខ្លាញ់រាវនោះ មិនមែនរលាយ តាំងនៅក្នុងឱកាសទាំងនោះគ្រប់កាលឡើយ ។ សេចក្តីនេះដូចម្តេច ។ កាលណាបទេសទាំងនោះក្តៅ ព្រោះកម្តៅភ្លើង ឬកម្តៅថ្ងៃ រដូវ និងធាតុដែលផ្ទុយគ្នា កាលនោះ

ខ្លាញ់រាវក៏រលាយ ជ្រួតជ្រាបទៅក្នុងបទេសទាំងនោះ ដូចទឹកសន្សើមក្នុងអណ្តូងទឹកដែលមានទឹកថ្លា ។ ក្នុងខ្លាញ់រាវ កំណត់ថា ខ្លាញ់រាវ រមែងមិនដឹងថា អញជ្រាបសើមនៅតាមបាតដៃជាដើម សូម្បីបាតដៃជាដើមក៏មិនដឹងថា ខ្លាញ់រាវជ្រាបអញ ដូចទឹកសន្សើមដែលជ្រាបក្នុងអណ្តូងទឹក រមែងមិនដឹងថា អញជ្រាបក្នុងអណ្តូងទឹក សូម្បីអណ្តូងទឹកក៏មិនដឹងថា ទឹកសន្សើមជ្រាបអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ខ្លាញ់រាវខណ្ឌដោយចំណែកនៃខ្លាញ់រាវ នេះជាការកំណត់ខ្លាញ់រាវនោះដោយសភាគ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង កំណត់ខ្លាញ់រាវជាដើម មានប្រការដូចពោលមកដូច្នេះ ។

## ខេឡោ

បន្ទាប់ពីនេះទៅ ក៏កំណត់ខេឡោដោយពណ៌ថា ទឹកមាត់ខាងក្នុងមាត់ក្នុងសរីរៈ ពណ៌សដូចពពុះទឹក ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចពពុះទឹកសមុទ្រដូច្នេះក៏មាន ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស ហូរចុះអំពីថ្ពាល់ទាំងសងខាង តាំងនៅត្រង់អណ្តាត តែទឹកមាត់នោះ មិនមែនសន្សំតាំងនៅត្រង់ថ្ពាល់នោះគ្រប់កាលឡើយ សេចក្តីនេះដូចម្តេច ។ កាលណា សត្វទាំងឡាយឃើញ ឬនឹកដល់អាហារ ដូច្នោះ ឬដាក់របស់ក្តៅ របស់ដែលមានរសល្វីង ហឹរ ប្រៃ និងជូរណាមួយក្នុងមាត់ និងកាលណាបេះដូងរបស់សត្វទាំងនោះមិនសប្បាយ ឬ

កើតការស្រេកឃ្លានឡើងក្នុងកាលខ្លះ កាលនោះ ទឹកមាត់នឹងហូរអំពីថ្ពាល់ទាំងសងខាងតាំងនៅត្រង់អណ្តាត តែត្រង់ចុងអណ្តាតទឹកមាត់នោះស្តើង ត្រង់គល់អណ្តាតក្រាស អំបុកក្តី អង្ករក្តី របស់ទំពាដទៃៗ ណាមួយ ដែលដាក់ចូលក្នុងមាត់ ដែលមិនទាន់រលាយទៅ ដូចទឹកក្នុងអណ្តូងដែលជីកលើខ្សាច់មាត់ស្ទឹង កាលនោះទឹកមាត់ នឹងអាចធ្វើរបស់ទំពាឲ្យសើម ។

ក្នុងទឹកមាត់នោះ កំណត់ថា ទឹកមាត់រមែងមិនដឹងថា អញហូរចេញអំពីថ្ពាល់ទាំង ២ តាំងនៅត្រង់អណ្តាត សូម្បីអណ្តាតក៏មិនដឹងថា ទឹកមាត់ហូរចេញអំពីថ្ពាល់ទាំង ២ តាំងនៅលើអញ ប្រៀបដូចទឹកដែលតាំងនៅក្នុងអណ្តូងដែលគេជីកលើច្នេរខ្សាច់ មាត់ស្ទឹង រមែងមិនដឹងថា អញតាំងនៅត្រង់អណ្តូង សូម្បីអណ្តូងក៏មិនដឹងថា ទឹកតាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹកមាត់ខណ្ឌដោយចំណែកនៃទឹកមាត់ នេះជាការកំណត់ទឹកមាត់នោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកមាត់ដោយពណ៌ជាដើម មានប្រការដូចពោលមកដូច្នេះ ។

## សិង្ឃាណិកា

បន្ទាប់អំពីនេះទៅ ក៏កំណត់សិង្ឃាណិកាដោយពណ៌ថា ទឹកសម្បោរមានពណ៌ដូចរំអិលត្នោតខ្ចី ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចពន្លកផ្តៅ ដែលគេដាក់ជាប់តគ្នា ចូលទៅ

ក្នុងរន្ធប្រមុះ ដូច្នេះក៏មាន ដោយទិសកើតក្នុងទិសខាងលើ ដោយឱកាស ដក់នៅពេញប្រមុះ តែទឹកសម្បោរនោះ មិនមែនសន្សំដក់នៅក្នុងរន្ធប្រមុះនោះ គ្រប់កាលឡើយ សេចក្តីនេះដូចម្តេច ។ បុរសខ្ចប់ទឹកដោះជូរក្នុងស្លឹកឈូក យកបន្លាចោះស្លឹកឈូកខាងក្រោម ពេលនោះ ដុំទឹកដោះជូរក៏ទឹងហូរចេញ អំពីប្រហោងនោះ ធ្លាក់ចុះទៅខាងក្រៅ យ៉ាងណា កាលណាសត្វទាំងឡាយ យំ ឬកើតធាតុកម្រើកដោយអាហារ និងរដូវដែលមិនត្រូវគ្នា កាលនោះ ខួរ ក្នុងក្បាលក៏ក្លាយជាស្លេស្មហូរចេញ អំពីខាងក្នុងក្បាល ធ្លាក់តាមពិតាន ដក់ នៅពេញប្រមុះដូច្នោះដូចគ្នា ។

ក្នុងទឹកសម្បោរនេះ កំណត់ថា ទឹកសម្បោរមិនដឹងថា អញដក់នៅក្នុង រន្ធប្រមុះ សូម្បីរន្ធប្រមុះក៏មិនដឹងថា ទឹកសម្បោរដក់នៅក្នុងអញ ប្រៀបដូច ទធិដែលគេដាក់ក្នុងសម្បកខ្យង រមែងមិនដឹងថា អញនៅក្នុងសម្បកខ្យង ទោះ សម្បកខ្យងក៏មិនដឹងថា ទឹកដោះជូរនៅក្នុងអញ ដូច្នោះ ព្រោះថា ធម៌ទាំងនេះ ប្រាសចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ទឹកសម្បោរខណ្ឌដោយចំណែកនៃទឹកសម្បោរ នេះជាការកំណត់ទឹក សម្បោរនោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់ នោះឯង ។ កំណត់ទឹកសម្បោរដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## លសិកា

លំដាប់អំពីនេះទៅ ក៏កំណត់ថា សាកសពដែលរអិលជាប្រេង ខាងក្នុង

ទី-តនៃសរីរៈខាងក្នុងសរីរៈ ឈ្មោះថា ទឹករំអិល ។ ដោយពណ៌ ទឹករំអិលនោះមានពណ៌ដូចជ័រកណិការ ដោយសណ្ឋានមានសណ្ឋានដូចអាកាសដែលតាំងនៅ ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាសឲ្យសម្រេចកិច្ច គឺធ្វើកិច្ចផ្សើមត្រង់ទី-តនៃធ្អឹងទាំងឡាយ តាំងនៅខាងក្នុងទី-ត ១៨០ កន្លែង ។ ក្នុងទឹករំអិលនោះ បុគ្គលណាមានទឹករំអិលតិច បុគ្គលនោះក្រោកឡើង អង្គុយចុះ ឈានទៅមុខ ឈានថយក្រោយ បត់ដៃ លាដៃ ធ្អឹងទាំងឡាយក៏នឹងលាន់ប្រសៗ ដើរទៅក៏ដូចធ្វើសំឡេងផ្ទាត់ម្រាមដៃ ធ្វើដំណើរទៅឆ្ងាយបានត្រឹមតែ ១ យោជន៍ ២ យោជន៍ វាយោធាតុក៏កម្រើក កាយក៏លំបាក ឯទឹករំអិលនៃបុគ្គលណាមានច្រើន ធ្អឹងទាំងឡាយរបស់បុគ្គលនោះ ក៏មិនលាន់ប្រសៗ ក្នុងខណៈក្រោកឡើង និងអង្គុយចុះជាដើម ធ្វើដំណើរបានយូរ វាយោធាតុក៏មិនកម្រើក កាយក៏មិនលំបាក ។

ក្នុងទឹករំអិលនោះ កំណត់ថា ទឹករំអិលរមែងមិនដឹងថា អញផ្សើមត្រង់ទី-ត ១៨០ កន្លែង សូម្បីទី-ត ១៨០ កន្លែងក៏មិនដឹងថា ទឹករំអិលផ្សើមអញ ប្រៀបដូចប្រេងបន្តក់ភ្លៅរថ រមែងមិនដឹងថា អញផ្សើមភ្លៅរថ ភ្លៅរថក៏មិនដឹងថា ប្រេងផ្សើមអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិតនិងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹករំអិលខណ្ឌដោយចំណែកនៃទឹករំអិលនោះ ដោយសភាគ ។ ឯការកំណត់ដោយវិសភាគ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ទឹករំអិលដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

# មុត្តំ

បន្ទបន្ទាប់អំពីនេះទៅ កំណត់ទឹកមូត្រដោយពណ៌ថា ទឹកមូត្រក្នុងសរីរៈ ដោយវណ្ណៈ មានពណ៌ដូចទឹកក្បុងសណ្ដែករាជមាស ដោយសណ្ឋាន មានសណ្ឋានដូចទឹកដែលនៅក្នុងក្អមទឹកដែលពេញ ដែលគេដាក់ផ្កាប់មាត់ ។ ដោយទិស កើតក្នុងទិស ខាងក្រោម ដោយឱកាស តាំងនៅក្នុងថ្លោកនោម ។ ថ្លោកនោម លោកហៅថា តម្រងបស្សាវៈ ដែលប្រៀបដូចទឹកស្មោកគ្រោករមែងចូលទៅក្នុងផ្ទាំង ដែលមិនមានមាត់ ដែលគេព្យួរនៅក្នុងអណ្ដូង ស្មោកគ្រោក ផ្លូវចូលទៅរបស់ទឹកស្មោកគ្រោកនោះមិនប្រាកដ យ៉ាងណា ទឹកមូត្រចូលទៅក្នុងសរីរៈ តែផ្លូវចូលទៅរបស់ទឹកមូត្រនោះ មិនប្រាកដ ផ្លូវចេញប៉ុណ្ណោះប្រាកដ ។

ក្នុងទឹកមូត្រនោះកំណត់ថា ទឹកមូត្រនោះមិនដឹងថា អញតាំងនៅក្នុងតម្រងបស្សាវៈ តម្រងបស្សាវៈក៏មិនដឹងថា ទឹកមូត្រតាំងនៅក្នុងអញ ប្រៀបដូចទឹកស្មោកគ្រោកក្នុងផ្ទាំងដែលមិនមានមាត់ ដែលគេដាក់ក្នុងអណ្ដូងស្មោកគ្រោករមែងមិនដឹងថា អញនៅក្នុងផ្ទាំងដែលមិនមានមាត់ សូម្បីផ្ទាំងក៏មិនដឹងថាទឹកស្មោកគ្រោកតាំងនៅក្នុងអញ ដូច្នោះ ដ្បិតថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ។បេ។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថាទឹកមូត្រខណ្ឌដោយតម្រងបស្សាវៈ និងដោយចំណែកនៃទឹកមូត្រ នេះជាការកំណត់ទឹកមូត្រនោះដោយសភាគ ។ ឯការកំណត់ដោយវិសភាគក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ទឹកមូត្រដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។ ព្រះយោគាវចរកំណត់ទ្វត្តឹសាការនេះ ដោយវណ្ណៈជាដើម

ដោយប្រការដូច្នេះ ។

ព្រោះអាស្រ័យការប្រកបរឿយៗ នូវភាវនា ការចម្រើនទ្វត្តឹសាការនោះៗ ទ្វត្តឹសាការ មានសក់ជាដើម ក៏រមែងស្ទាត់ជំនាញ ប្រាកដច្បាស់ក្នុងកោដ្ឋាស ដែលជាចំណែកៗ ដល់ព្រះយោគាវចរនោះ ដែលកំណត់ទ្វត្តឹសាការនេះ ដោយវណ្ណៈជាដើម ដោយប្រការដូច្នេះ ។ តាំងអំពីនេះទៅ កាលបុរសមានភ្នែកពិនិត្យមើលកម្រងផ្កានៃផ្កាទាំងឡាយ ដែលមាន ៣២ ពណ៌ ដែលដោតដោយអំបោះតែមួយ ផ្កាគ្រប់ផ្កា រមែងប្រាកដមិនមុន មិនក្រោយ យ៉ាងណា កាលព្រះយោគាវចរ ពិនិត្យពិច័យកាយនេះដោយសតិថា ក្នុងកាយនេះ មានសក់ជាដើម ធម៌ទាំងអស់នោះ រមែងប្រាកដមិនមុន មិនក្រោយដូច្នោះដូចគ្នា សតិដែលតាំងឡើងក្នុងសក់ទាំងឡាយដែលទឹកដល់ រមែងប្រព្រឹត្តទៅ រហូតដល់ទឹកមូត្រ តាំងអំពីនោះទៅ មនុស្ស និងសត្វតិរច្ឆានជាដើម ដែលដើរទៅមក និងលះអាការផស្សៈ ប្រាកដច្បាស់តែគំនរនៃកោដ្ឋាសជាចំណែកៗ ប៉ុណ្ណោះ ដល់ព្រះយោគាវចរនោះ ទឹក និងភោជនជាដើមដែលសត្វទាំងនោះលេបចូលទៅ ដូចទម្លាក់ទៅក្នុងគំនរកោដ្ឋាស ។

ក្នុងសេចក្ដីនេះ អ្នកចោទសួរពោលថា បើដូច្នោះ ព្រះយោគាវចរនេះគប្បីធ្វើអ្វី បន្ទាប់អំពីនោះទៅ ។ ការចង្អុលបង្ហាញដូច្នេះ និមិត្តទាំងនោះឯងដែលព្រះយោគាវចរគប្បីសេព គប្បីចម្រើន គប្បីធ្វើឲ្យច្រើន គប្បីកំណត់ដោយល្អ សួរថា ព្រះយោគាវចរនេះ សេព ចម្រើននិមិត្តនោះ ធ្វើឲ្យច្រើន កំណត់ឲ្យជាការកំណត់ ដោយល្អដូចម្ដេច ។ ឆ្លើយថា ព្រះយោគាវចរនេះ

សេពនិមិត្តត្រង់ទ្វត្តិសាការ មានសក់ជាដើមប្រាកដ ជាកោដ្ឋាសចំណែកនោះៗ រមែងចង គប់រក ចូលទៅអន្ទុយជិតដោយសតិ ឲ្យចិត្តទាញយកនូវបន្ទប់ គឺសតិ ឬធ្វើសតិដែលបានក្នុងនិមិត្តនោះឲ្យជុះដាល លោកហៅថា ចម្រើននិមិត្តនោះ ។ ពាក្យថា ធ្វើឲ្យច្រើន បានដល់ ធ្វើនិមិត្តនោះរឿយៗ ឲ្យប្រកបដោយសតិដែលវិតក្ក និងវិចារៈប៉ះខ្ទប់ហើយ ។ ពាក្យថា កំណត់ឲ្យជាការកំណត់ដោយល្អ បានដល់ និមិត្តដែលកំណត់ដោយល្អ មិនវិនាសទៅទៀត ដោយប្រការណា ព្រះយោគាវចររមែងកំណត់ចូលទៅទទួល ចូលទៅចងនិមិត្តនោះដោយសតិ ដោយប្រការនោះ ។

ម្យ៉ាងទៀត មនសិការកោសល ការឈ្លាសក្នុងមនសិការឯណា ដែលពោលអំពីមុន ១០ ប្រការយ៉ាងនេះ គឺដោយលំដាប់ ១ ដោយមិនរហ័សពេក ១ ដោយមិនយឺតពេក ១ ដោយការពារការរាយមាយ ១ ដោយកន្លងបញ្ញត្ត ១ ដោយរំលងលំដាប់ ១ ដោយលក្ខណៈ ១ សូត្រទាំងបី ១ ។ មនសិការកោសលនោះ គប្បីជ្រាបថា ព្រះយោគាវចរមនសិការដោយលំដាប់ ឈ្មោះថា សេព ។ មនសិការដោយមិនលឿនពេក ដោយមិនយឺតពេក ឈ្មោះថា ចម្រើន មនសិការដោយការពារការរាយមាយ ឈ្មោះថា ធ្វើឲ្យច្រើន មនសិការដោយកន្លងបញ្ញត្តិជាដើម ឈ្មោះថា កំណត់ឲ្យជាការកំណត់ដោយល្អ ។

ក្នុងសេចក្តីនេះ អ្នកចោទសួរថា ព្រះយោគាវចរនេះ មនសិការធម៌ទាំងនេះ ដោយមនសិការកោសល មានដោយលំដាប់ជាដើមដូចម្តេច ។ សូម

ពោលចន្លុលបន្លាញ ដូច្នេះ សេចក្ដីពិត ព្រះយោគាវចរនេះ កាលមនសិការសក់ហើយ បន្ទាប់អំពីនោះក៏មនសិការរោម មិនមនសិការក្រចក ។ ក្នុងអាការ គ្រប់យ៉ាងក៏មានន័យ ដូច្នេះ ព្រោះហេតុអ្វី ព្រោះថា ព្រះយោគាវចរ កាលមនសិការខុសលំដាប់ ចិត្តក៏លំបាក ធ្លាក់ចុះទៅអំពីទ្វត្តឹសាការភាវនា ចម្រើនភាវនាមិនសម្រេច ព្រោះមិនបាននូវអស្សាទ គឺសេចក្ដីត្រេកអរ ដែលគួរបានដោយភាវនាសម្បត្តិ ប្រៀបដូចបុរសមិនឈ្លាស ឡើងជណ្ដើរ ៣២ កាំ ខុសលំដាប់ ក៏លំបាកកាយ រមែងធ្លាក់ចុះ ឡើងជណ្ដើរមិនសម្រេច ដូច្នោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរសូម្បីមនសិការដោយលំដាប់ ក៏មិនមនសិការរហ័សពេកថា កេសា លោមា ។ ព្រោះថា ព្រះយោគាវចរកាលមនសិការរហ័សពេក ក៏មិនអាចកំណត់ពណ៌ និងសណ្ឋានជាដើម ដែលផុតចាកទ្វត្តឹ-សាការ បន្ទាប់អំពីនោះ ក៏មិនឈ្លាសក្នុងទ្វត្តឹសាការ និងកម្មដ្ឋានដែលវិនាសទៅ ប្រៀបដូចបុរសកំពុងដើរផ្លូវឆ្ងាយ មិនអាចកំណត់ផ្លូវរាបស្មើ ផ្លូវមិនរាបស្មើ ដើមឈើ ជន្លត់ រណ្ដៅ ផ្លូវបែកជា ២ ជាដើម ដែលផុតទៅអំពីផ្លូវ តអំពីនោះ ក៏មិនឈ្លាសក្នុងផ្លូវ ការដើរផ្លូវឆ្ងាយក៏នឹងអស់ទៅ ដូច្នោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរ មនសិការដោយមិនរហ័សពេក យ៉ាងណា ក៏មនសិការដោយមិនយឺតពេក ដូច្នោះ ព្រោះថា ព្រះយោគាវចរកាលមនសិការយឺតពេក ក៏មិនដល់នូវការសម្រេចទ្វត្តឹសាការភាវនា តែទឹកដល់នូវសេចក្ដីលំបាកដោយកាមវិតក្កជាដើមក្នុងចន្លោះ ព្រោះភាវនាដាច់ ប្រៀបដូចបុរសដើរ

ផ្លូវឆ្ងាយ ទើសទាក់នឹងដើមឈើ ភ្នំ និងអូរជាដើមក្នុងវង្វេងផ្លូវ ក៏មិនដល់ទី ដែលខ្លួនប្រាថ្នា តែនឹងដល់នូវសេចក្ដីលំបាកដោយសីហៈ និងខ្លាជាដើម ក្នុង វង្វេងផ្លូវនោះឯង ដូច្នោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរសូម្បីមនសិការដោយមិនយឺតពេក ក៏មនសិការ ដោយការពារនូវសេចក្ដីរាយមាយ ព្រះយោគាវចររមែងមនសិការដោយប្រការ ដែលមិនរាយមាយ ព្រោះការងារដទៃៗ មាននវកម្មជាដើម ព្រះយោគាវចរ ដែលមានចិត្តរាយមាយទៅខាងក្រៅ មានការត្រិះរិះនៃចិត្ត មិនតាំងមាំក្នុងទូត្ត- សាការ មានសក់ជាដើម ក៏មិនដល់នូវការសម្រេចនៃភាវនា នឹងដល់នូវសេចក្ដី លំបាកក្នុងវង្វេងផ្លូវនោះឯង ដូចសម្លាញ់របស់ព្រះពោធិសត្វ ដល់នូវសេចក្ដី លំបាក ក្នុងការធ្វើដំណើរទៅកាន់នគរតក្កសិលា ឯព្រះយោគាវចរដែលមាន ចិត្តមិនរាយមាយ មានការត្រិះរិះនៃចិត្តតាំងមាំក្នុងទូត្តិសាការ មានសក់ជាដើម ក៏ដល់នូវការសម្រេចនៃភាវនា ដូចព្រះពោធិសត្វ ដល់នូវសេចក្ដីសម្រេចនៃ រាជសម្បត្តិក្នុងនគរតក្កសិលា ។ ធម៌ទាំងនោះ រមែងប្រាកដដោយអសុភ ដោយពណ៌ ឬដោយភាពទទេ ដោយអំណាចបារមី ចរិយា និងការបង្អោន ចិត្តជឿដល់ព្រះយោគាវចរនោះ ដែលមនសិការដោយការពារការរាយមាយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរមនសិការធម៌ទាំងនោះដោយកន្លងបញ្ញត្ត ។ ពាក្យថា ដោយកន្លងបញ្ញត្ត បានដល់ មនសិការកន្លងនូវវោហារជាដើមយ៉ាង នេះថា កេសា លោមា ដោយជាអសុភជាដើម តាមដែលប្រាកដហើយ ។

មនសិការដូចម្តេច ប្រៀបដូចមនុស្សទាំងឡាយដែលចូលទៅអាស្រ័យក្នុងព្រៃ ធ្វើគ្រឿងសម្គាល់ ដោយកាច់បំបាក់មែកឈើជាដើម ដើម្បីចំណាំទីដែលមានទឹក ព្រោះជាទឹកដីដែលមិនធ្លាប់ស្គាល់ ទៅតាមសញ្ញានោះ រមែងបរិភោគនូវទឹកបាន ។ តែកាលណាថ្មីកក្នុងភូមិភាគហើយ បោះបង់ការដាក់ចិត្តក្នុងគ្រឿងចំណាំនោះ ទៅកាន់ទីដែលមានទឹក បរិភោគទឹកបាន យ៉ាងណាមិញ ព្រះយោគាវចរនេះក៏ដូច្នោះដូចគ្នា មនសិការធម៌ទាំងនោះ ដោយអាហារនោះៗ មានកេសា លោមាជាដើមហើយ កាលធម៌ទាំងនោះប្រាកដច្បាស់ ដោយអារម្មណ៍ មានអសុភជាដើមឯណានីមួយ ក៏កន្លងនូវអាហារនោះមនសិការដោយអារម្មណ៍ មានអសុភជាដើមនោះឯង ។

ក្នុងសេចក្តីនោះ បុគ្គលអ្នកសួរពោលថា ធម៌ទាំងនោះប្រាកដដោយភាពជាអសុភជាដើមដល់ព្រះយោគាវចរនោះដូចម្តេច ដោយវណ្ណៈដូចម្តេច ដោយភាពជារបស់ទទេដូចម្តេច ។ ម្យ៉ាងទៀត ព្រះយោគាវចរនោះ មនសិការធម៌ទាំងនេះដោយអសុភដូចម្តេច ដោយវណ្ណៈដូចម្តេច ឬដោយភាពទទេដូចម្តេចជាបឋម សក់ទាំងឡាយរមែងប្រាកដដល់ព្រះយោគាវចរនោះ ដោយអសុភជា ៥ ចំណែក គឺពណ៌ សណ្ឋាន ក្លិន ទីអាស្រ័យ និងឱកាស តាំងនៅព្រះយោគាវចរនេះក៏មនសិការធម៌ទាំងនេះ ជា ៥ ចំណែកនោះឯង ដោយអសុភ ។ សេចក្តីនេះដូចម្តេច ធម្មតាសក់ទាំងនេះ ដោយពណ៌មិនស្អាតជារបស់បដិកូល គួរខ្ពើមក្រៃលែង ។ ពិតហើយ មនុស្សទាំងឡាយឃើញសម្បកឈើ ឬអំបោះ ដែលមានពណ៌ដូចសក់ ដែលធ្លាក់ទៅក្នុងទឹក និង

បាយ ក្នុងពេលថ្ងៃ រមែងចោល ឬខ្ពើមទឹក និងបាយ សូម្បីជារបស់ពេញចិត្ត ដោយសម្គាល់ថា សក់ ។ សូម្បីដោយសណ្ឋានក៏មិនស្អាត ពិតហើយ មនុស្សទាំងឡាយប៉ះសម្បកឈើ ឬសរសៃអំបោះដែលមានសណ្ឋានដូចសក់ ដែលធ្លាក់ចូលទៅក្នុងទឹក ឬបាយក្នុងពេលយប់ រមែងចោល ឬខ្ពើមបាយ សូម្បីជារបស់ពេញចិត្ត ដោយសម្គាល់ថា សក់ ។ សូម្បីដោយក្លិនក៏មិនស្អាត ពិតហើយ សក់ទាំងឡាយដែលវៀរការតាក់តែង មានលាបប្រេងដោតផ្កា អប់ផ្សែងជាដើម ក្លិនគួររង្កៀសក្រៃលែង បុគ្គលហិតក្លិនសក់ដែលបោះចូលក្នុងភ្លើង ត្រូវបិទច្រមុះ បែរមុខចេញ ដោយទីលំនៅក៏មិនស្អាត ពិតហើយ សក់ទាំងនោះសន្សំហើយ ក៏ចម្រើនបរិបូណ៌ ដោយការហូរមកកកផ្តុំគ្នានៃប្រមាត់ ស្លេស្ម ខ្ទុះ និងឈាម ដូចដើមម្រះព្រៅជាដើមក្នុងគំនរសំរាម ដោយការហូរមក ប្រមូលផ្តុំនៃវត្ថុស្មោកគ្រោក របស់មនុស្សច្រើនប្រភេទ ។ សូម្បីដោយឱកាសក៏មិនស្អាត ។ ពិតហើយ សក់ទាំងនោះកើតក្នុងស្បែកទន់ដែលគ្របក្បាលរបស់មនុស្សទាំងឡាយ ខាងលើកំពូលនៃគំនរសាកសព ៣១ មានរោមជាដើម គួរខ្ពើមរអើមក្រៃលែង ដូចដើមម្រះព្រៅជាដើមក្នុងគំនរសំរាម ។ ក្នុងសាកសព ៣១ មានរោមជាដើម ក៏ន័យដូច្នេះ ។ ព្រះយោគាវចរមនសិការធម៌ទាំងនេះ ដែលប្រាកដដោយអសុក ដោយភាពជារបស់មិនស្អាតយ៉ាងនេះជាបឋម ។

បើធម៌ទាំងនេះ ប្រាកដដល់ព្រះយោគាវចរនោះ ដោយពណ៌ជាដើមនោះ សក់ទាំងឡាយក៏ប្រាកដជានីលកសិណ ។ រោម ធ្មេញ ក៏យ៉ាងនោះ រមែង

ប្រាកដដោយជាឱទាតកសិណ ។ ក្នុងទុត្តិសាការគ្រប់យ៉ាង ក៏មានន័យដូច្នេះ ។ ព្រះយោគាវចរនោះ រមែងមនសិការធម៌ទាំងនេះ ដោយជាកសិណនោះៗ ឯង ។ ធម៌ដែលប្រាកដដោយវណ្ណៈយ៉ាងនេះ ព្រះយោគាវចរក៏មនសិការ ដោយវណ្ណៈ បើធម៌ទាំងនោះប្រាកដដល់ព្រះយោគាវចរនោះ ដោយភាពជា របស់ទទេ កាលបើដូច្នោះ សក់ទាំងឡាយរមែងប្រាកដ ជាអាការប្រជុំដោយ វិនិព្ភោគរូប ដែលមានឱជៈជាគម្រប់ ៨ ដោយការកំណត់ បំបែកចេញពី ក្រុម ។ រោមជាដើមក៏ប្រាកដដល់ព្រះយោគាវចរ ដូចកាលសក់ប្រាកដ ។ ព្រះ យោគាវចរនោះ រមែងមនសិការធម៌ទាំងនេះយ៉ាងនោះដូចគ្នា ធម៌ដែលប្រាកដ ដោយភាពជារបស់ទទេយ៉ាងនេះ ក៏មនសិការដោយភាពជារបស់ទទេ ។

ព្រះយោគាវចរនេះ មនសិការយ៉ាងនេះ ឈ្មោះថា មនសិការធម៌ទាំង នោះដោយលំដាប់ ។ ពាក្យថា ដោយរំលងលំដាប់ អធិប្បាយថា ព្រះ យោគាវចររំលងសក់ដែលប្រាកដជាអសុភជាដើមណាមួយ ហើយមនសិការ រោម ជាអ្នកសម្ងឹងកណ្ដាលក្នុងសក់ទាំងឡាយ ហើយមនសិការរោមទាំង-ឡាយ កាលមនសិការក្នុងរោមទាំងឡាយ ក៏ឈ្មោះថា រំលងសក់ ប្រៀប ដូចឈ្លើងសម្ងឹងជាកណ្ដាលត្រង់បទេស ដែលខ្ជួនចាប់ដោយកន្ទុយ រំលង បទេសដទៃតាមមាត់ កាលទាមបទេសនោះ ក៏ឈ្មោះថា រំលងបទេសក្រៅ អំពីនេះ ដូច្នោះ ។ ក្នុងទុត្តិសាការគ្រប់យ៉ាង ក៏មានន័យដូច្នេះ ។ ធម៌ទាំង នោះ កាលប្រាកដដល់ព្រះយោគាវចរនោះ ដែលមនសិការដោយរំលង លំដាប់យ៉ាងនេះ រមែងប្រាកដមិនសេសសល់ឡើយ ថែមទាំងប្រាកដច្បាស់

ជាន់ទៀតផង ។

កាលបើដូច្នោះ ធម៌ពួកណាប្រាកដដោយភាពជារបស់មិនស្អាត ដល់ព្រះយោគាវចរណា ទាំងប្រាកដជា ប្រាកដច្បាស់ជាង ប្រៀបដូចស្វាដែលត្រូវព្រានដេញ លោតទៅក្នុងដើមត្នោត ៣២ ដើម មិនឈប់សូម្បីត្រឹមតែ ១ ដើម លោតទៅ កាលណាត្រឡប់ ក៏ហត់នឿយ កាលនោះ ទើបឈប់អាស្រ័យត្នោតដែលស្អាត ដែលបិទបាំងដោយស្លឹកត្នោតក្រាស់ដើមណាមួយ ប៉ុណ្ណោះ យ៉ាងណា ស្វា គឺចិត្តរបស់ព្រះយោគាវចរនោះ ក៏ដូច្នោះដូចគ្នា ដែលព្រះយោគាវចរនោះដេញទៅក្នុងកាយនេះ ដែលមានកោដ្ឋាស ៣២ គឺចំណែក មិនឈប់ សូម្បីតែចំណែកមួយ លោតទៅ កាលណាត្រឡប់ ព្រោះមិនមានសេចក្តីប្រាថ្នាក្នុងការស្ទុះទៅកាន់អារម្មណ៍ដ៏ច្រើនក៏ហត់នឿយ កាលនោះ ធម៌ណារបស់ព្រះយោគាវចរនោះស្ទាត់ជំនាញ ឬព្រោះសមដល់ចរិតជាងគេ ក្នុងចំណែក ៣២ មានសក់ជាដើម ឬជាអ្នកបានបំពេញបារមីមុនក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ ឈប់ដោយឧបចារសមាធិ កាលបើដូច្នោះ ព្រះយោគាវចរធ្វើនិមិត្តទាំងនោះឯងឲ្យដល់វិតក្ក រហូតដល់វិតក្កទល់ទ្រៀយៗ ក៏ធ្វើបឋមជ្ឈានឲ្យកើតឡើងតាមលំដាប់ តាំងនៅក្នុងបឋមជ្ឈានោះហើយ ផ្តើមវិបស្សនារមែងសម្រេចអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ រមែងប្រាកដដោយវណ្ណៈដល់ព្រះយោគាវចរណា ប្រៀបដូចស្វាត្រូវព្រានដេញទៅក្នុងព្រៃត្នោត ៣២ ដើម មិនឈប់ក្នុងដើមណាមួយ កាលណាត្រឡប់ក៏នឿយហត់ កាលនោះ ទើបឈប់អាស្រ័យ

ដើមត្នោតដែលស្អាត ដែលគ្របដណ្តប់ដោយស្លឹកត្នោតក្រាស់ណាមួយប៉ុណ្ណោះ យ៉ាងណា ស្វា គឺចិត្តរបស់ព្រះយោគាវចរនោះ ក៏ដូច្នោះ កាលព្រះយោគាវចរនោះឯង ដេញជាប់តាមទៅ ក្នុងកាយនេះ ដែលមានអាការ ៣២ មិនឈប់ក្នុងចំណែកណាមួយ លោតទៅ កាលណាត្រឡប់ ព្រោះមិនមានសេចក្តីប្រាថ្នា ស្ទុះទៅក្នុងអារម្មណ៍ដ៏ច្រើន ក៏នឿយហត់ កាលនោះ ធម៌ណារបស់ព្រះយោគាវចរនោះ ស្ទាត់ជំនាញហើយ ឬសមគួរដល់ចរិតថា ក្នុងអាការ ៣២ មានសក់ជាដើម ឬជាអ្នកបំពេញបារមីមកអំពីមុន ក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ ឈប់នៅក្នុងឧបចារសមាធិ កាលបើដូច្នោះ ព្រះយោគាវចរធ្វើនិមិត្តនោះឯងឲ្យដល់វិតក្ក ត្រូវវិតក្កទល់ទ្ររឿយៗ ក៏ធ្វើឲ្យកើតរូបាវចរជ្ឈានទាំង ៥ ដោយនីលកសិណ ឬដោយបីតកសិណតាមលំដាប់ និងតាំងនៅក្នុងរូបាវចរជ្ឈាននោះណាមួយ ផ្តើមចម្រើនវិបស្សនា ក៏សម្រេចអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ ប្រាកដដោយភាពជារបស់ទទេ ដល់ព្រះយោគាវចរណា ព្រះយោគាវចរនោះរមែងមនសិការដោយលក្ខណៈ កាលមនសិការដោយលក្ខណៈ រមែងសម្រេចឧបចារជ្ឈាន ដោយកំណត់ធាតុ ៤ ក្នុងធម៌ទាំងនោះ កាលបើដូច្នោះ កាលមនសិការ ក៏មនសិការធម៌ទាំងនោះដោយសូត្រទាំង ៣ គឺមិនទៀង ជាទុក្ខ ជាអនត្តា ។ នេះជាវិបស្សនាន័យរបស់ព្រះយោគាវចរនោះ ។ ព្រះយោគាវចរផ្តើមចម្រើនវិបស្សនានេះ និងបដិបត្តិ ទៅតាមលំដាប់ ក៏រមែងសម្រេចអរិយភូមិ ដូច្នេះ ។

ពាក្យណាខ្ញុំពោលថា ព្រះយោគាវចរនេះ មនសិការធម៌ទាំងនេះដូចម្តេច ពាក្យនោះ ខ្ញុំព្យាករហើយ ដោយកថាមានប្រមាណប៉ុណ្ណេះ ។ ម្យ៉ាងទៀត ពាក្យណាខ្ញុំពោលថា គប្បីជ្រាបការពណ៌នាបាឋៈនោះយ៉ាងនេះ ដោយភាវនាសេចក្តីនៃពាក្យនោះ ឈ្មោះថា ខ្ញុំប្រកាសហើយ ដូច្នេះ ។

## បកិណ្ណកន័យ

ឥឡូវនេះ គប្បីជ្រាបបកិណ្ណកន័យនេះ ដើម្បីភាពជំនាញ និងការឈ្លាសក្នុងទ្វត្តឹសាការនេះថា

**និមិត្តោ លក្ខណតោ ធាតុតោ សុញ្ញតោបិ ច**
**ខន្ធាទិតោ ច វិញ្ញេយ្យោ ទ្វត្តឹសាការនិច្ឆយោ ។**

គប្បីជ្រាបវិនិច្ឆ័យទ្វត្តឹសាការដោយនិមិត្ត លក្ខណៈ ធាតុ ភាពទទេ និងដោយខន្ធជាដើម ។

បណ្តាបកិណ្ណកៈនោះ ពាក្យថា ដោយនិមិត្ត សេចក្តីថា ទ្វត្តឹសាការនេះ មានប្រការដូចពោលមកហើយនេះ មាននិមិត្ត ១៦០ ដែលព្រះយោគាវចរអាចកំណត់ទ្វត្តឹសាការបានដោយកោដ្ឋាសដែលជាចំណែកៗ គឺសក់មាននិមិត្ត ៥ គឺពណ៌ សណ្ឋាន ទ្រង់ទ្រាយ ទិស ឱកាស ( ទីកើត ) និងបរិច្ឆេទ ក្នុងរោមជាដើម ក៏មានន័យដូច្នេះ ។

ពាក្យថា ដោយលក្ខណៈ សេចក្តីថា ក្នុងទ្វត្តឹសាការមានលក្ខណៈ ១២៨ ដែលព្រះយោគាវចរអាចធ្វើមនសិការទ្វត្តឹសាការបានដោយលក្ខណៈ គឺសក់មានលក្ខណៈ ៤ គឺលក្ខណៈរឹង ជ្រួតជ្រាប ក្តៅ និងបក់ផាត់ ក្នុងរោមជាដើម

ក៏មានន័យដូច្នេះ ។

ពាក្យថា ដោយធាតុ សេចក្តីថា ក្នុងទ្វត្តឹសាការធាតុទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់ក្នុងបាលីនេះថា **ចតុធាតុរោ ភិក្ខវេ អយំ បុរិស-បុគ្គលោ** ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលនេះ មានធាតុ ៤ ដូច្នេះ ។ ធាតុមាន ១២៨ ដែលព្រះយោគាវចរអាចកំណត់ទ្វត្តឹសាការបានដោយធាតុ ២ ក្នុងសក់មានធាតុ ៤ គឺចំណែកដែលរឹង ជាបឋវីធាតុ ចំណែកដែលជ្រួតជ្រាបជាអាបោធាតុ ចំណែកដែលក្តៅ ជាតេជោធាតុ ចំណែកដែលកម្រើក ជាវាយោធាតុ ក្នុងរោមជាដើមក៏យ៉ាងនេះ ។

ពាក្យថា ដោយភាពទទេ សេចក្តីថា ក្នុងទ្វត្តឹសាការ មានសុញ្ញតា ១២៨ ដែលព្រះយោគាវចរអាចពិចារណាឃើញទ្វត្តឹសការដោយភាពទទេ គឺក្នុងសក់មានសុញ្ញតា ៤ គឺបឋវីធាតុ ទទេចាកអាបោធាតុជាដើម អាបោធាតុជាដើមក៏យ៉ាងនោះ ទទេចាកបឋវីធាតុជាដើម ក្នុងរោមជាដើមក៏យ៉ាងនេះ ។

ពាក្យថា ដោយខន្ធជាដើម សេចក្តីថា ក្នុងទ្វត្តឹសាការ មានសក់ជាដើមលោកសង្គ្រោះដោយខន្ធជាដើម គប្បីជ្រាបវិនិច្ឆ័យដោយន័យជាដើមយ៉ាងនេះថា សក់ទាំងឡាយមានខន្ធប៉ុន្មាន មានអាយតនៈប៉ុន្មាន មានធាតុប៉ុន្មាន មានសច្ចៈប៉ុន្មាន មានសតិប្បដ្ឋានប៉ុន្មាន ។ កាយរមែងប្រាកដដូចគំនរសំរាម និងឈើចាស់ ព្រះយោគាវចរនោះពិចារណាយ៉ាងនេះ តាមដែលលោកពោលថា

**នត្ថិ សត្តោ នរោ បោសោ បុគ្គលោ នូបលព្ភតិ**
**សុញ្ញភូតោ អយំ កាយោ តិណាកដ្ឋសមូបមោ ។**

មិនមានសត្វ នរៈ បុរស មិនមែនបុគ្គល កាយនេះ
មានសភាពទទេ ប្រៀបដូចស្មៅ និងឈើ ។

ម្យ៉ាងទៀត ការត្រេកអរណា ដែលមិនមែនរបស់មនុស្ស ដែលលោកពោលយ៉ាងនេះថា

**សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស ភិក្ខុនោ**
**អមានុសី រតី ហោតិ សម្មា ធម្មំ វិបស្សតោ ។**

សេចក្ដីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែងមាន
ដល់ភិក្ខុអ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្តរម្ងាប់ អ្នក
ឃើញធម៌ដោយប្រពៃ ។

សេចក្ដីត្រេកអរនោះនៅមិនឆ្ងាយឡើយ ។ បន្ទាប់អំពីនោះ អមតៈ គឺបីតិ និងបាមោជ្ជណា ដែលសម្រេចមកអំពីវិបស្សនា ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា

**យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ**
**លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។**

ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធ
ទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ
រមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ
ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌
ទាំងឡាយ ។

*ព្រះយោគាវចរ កាលសោយបីតិ និងបាមោជ្ជ ដែលជាអមតៈនោះ មិនយូរឡើយ នឹងធ្វើឲ្យជាក់ច្បាស់នូវអមតៈ គឺព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ដែលអរិយជនសេពហើយ ដូច្នេះ ។*

*ទុតិសាការ ចប់*

# សុត្តន្តបិដក

## ខុទ្ទកបាឋៈ សាមណេរបញ្ហា

[ ៤ ] *ធម្មជាតឈ្មោះតែ ១ គឺអ្វី គឺសត្វទាំងអស់ តាំងនៅដោយអាហារ ។ ធម្មជាតឈ្មោះតែ ២ គឺអ្វី គឺនាម និងរូប ។ ធម្មជាតឈ្មោះតែ ៣ គឺអ្វី គឺវេទនា ៣ ។ ធម្មជាតឈ្មោះតែ ៤ គឺអ្វី គឺអរិយសច្ច ៤ ។ ធម្មជាតឈ្មោះតែ ៥ គឺអ្វី គឺឧបាទានក្ខន្ធ ៥ ។ ធម្មជាតឈ្មោះតែ ៦ គឺអ្វី គឺអាយតនៈខាងក្នុង ៦ ។ ធម្មជាតឈ្មោះតែ ៧ គឺអ្វី គឺពោជ្ឈង្គ ៧ ។ ធម្មជាតឈ្មោះតែ ៨ គឺអ្វី គឺអរិយមគ្គប្រកបដោយអង្គ ៨ ។ ធម្មជាតឈ្មោះតែ ៩ គឺអ្វី គឺសត្តាវាស ៩ ។ ធម្មជាតឈ្មោះតែ ១០ គឺអ្វី គឺបុគ្គលដែលហៅថា ព្រះអរហន្តប្រកបដោយអង្គ ១០ ។*

*សាមណេរបញ្ហា ចប់*

# អដ្ឋកថា

## កុមារបញ្ហា

[ ៤ ] ឥឡូវនេះ ដល់លំដាប់ពណ៌នាសេចក្តីរបស់កុមារបញ្ហាជាដើម យ៉ាងនេះថា អ្វីឈ្មោះថា ១ ខ្ញុំនឹងពោលអត្ថុប្បត្តិហេតុនៃកុមារបញ្ហាទាំងនោះ និងប្រយោជន៍នៃការដាក់បទតាំងទុកក្នុងទីនេះ ហើយពណ៌នាសេចក្តី និង អត្ថុប្បត្តិហេតុនៃកុមារបញ្ហាទាំងនោះ ។ ឈ្មោះថា **សោបាក** ជាព្រះមហា-សាវ័ករបស់ព្រះមានព្រះភាគ ។ ព្រះសោបាកៈនោះ សម្រេចជាព្រះអរហន្ត តាំងពីអាយុបាន ៧ ឆ្នាំអំពីកំណើត ។ ព្រះមានព្រះភាគ មានព្រះពុទ្ធបំណង នឹងទ្រង់អនុញ្ញាតឧបសម្បទា ដោយការព្យាករណ៍បញ្ហាដល់លោក ទ្រង់ ឃើញថា លោកអាចព្យាករបញ្ហាទាំងឡាយ ដែលទ្រង់បំណងហើយ ទើប ត្រាស់សួរបញ្ហាដោយន័យជាដើមយ៉ាងនេះថា អ្វីឈ្មោះថា ១ ។ លោកក៏ ព្យាករ និងធ្វើចិត្តរបស់ព្រះមានព្រះភាគ ឲ្យទ្រង់ត្រេកអរដោយការព្យាករណ៍ នោះ ។ ទុំះឯងបានជាឧបសម្បទារបស់ព្រះសោបាកៈនោះ ។

នេះជាហេតុកើតរឿងរបស់សាមណេរបញ្ហាទាំងនោះ ។

## ប្រយោជន៍នៃការតាំងបទ

ព្រោះហេតុដែលប្រកាសចិត្តភាវនា ដោយរឭកដល់ព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ដោយសរណគមន៍ ប្រកាសសីលភាវនា ដោយសិក្ខាបទ និង ប្រកាសកាយភាវនា ដោយទ្វត្តឹសាការ ដូច្នោះ ឥឡូវនេះ ទើបការព្យាករ បញ្ហាទាំងនេះ ជាប្រធានបទក្នុងទីនេះ ដើម្បីសម្តែងមុខ គឺបញ្ញាភាវនាដោយ

ប្រការផ្សេងៗ ឬព្រោះហេតុដែលសមាធិ មានសីលជាបទដ្ឋាន និងបញ្ញា មានសមាធិជាបទដ្ឋាន ដូចព្រះមានព្រះភាគត្រាស់ថា **សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ** នរជនមានបញ្ញាជាគ្រឿងរក្សាខ្លួន តាំងនៅក្នុងសីល ចម្រើននូវចិត្ត និងបញ្ញា ... ដូច្នេះ ទើបគួរជ្រាបថា កាលខ្ញុំសម្ដែងសីលដោយសិក្ខាបទទាំងឡាយ និងសមាធិដែលមានសីលនោះជាគោចរ ដោយទុត្តិសាការហើយ ទើបដាក់បញ្ហាព្យាករជាប្រធានក្នុងទីនេះ ដើម្បីសម្ដែងប្រភេទនៃបញ្ញា ដែលជាគ្រឿងពិនិត្យពិចារណាធម៌ផ្សេងៗ សម្រាប់បុគ្គល ដែលមានចិត្តតាំងមាំហើយ ។

នេះជាប្រយោជន៍នៃការដាក់បញ្ហាទាំងនោះជាប្រធានបទក្នុងទីនេះ ។

## អ្វីឈ្មោះថា ១

ឥឡូវនេះ នឹងពណ៌នាអត្ថនៃបញ្ហាទាំងនោះ ភិក្ខុកាលនឿយណាយដោយប្រពៃក្នុងធម៌ឯណាមួយ រមែងធ្វើទីបំផុតទុក្ខបានដោយលំដាប់ ។ម្យ៉ាងទៀត ព្រះសោបាកៈនេះ នឿយណាយក្នុងធម៌ណាមួយ ដែលធ្វើទីបំផុតទុក្ខហើយ ព្រះមានព្រះភាគ ទ្រង់សំដៅដល់ធម៌នោះ ទើបត្រាស់សួរបញ្ហាថា អ្វីឈ្មោះថា ១ ព្រះថេរៈទូលស្នងជាបុគ្គលាធិដ្ឋានថា សត្វទាំងពួងតាំងនៅបានដោយអាហារ ។ ក្នុងសេចក្ដីនេះ ព្រះសូត្រទាំងឡាយយ៉ាងនេះថា **កថញ្ច ភិក្ខវេ សម្មាសតិ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ** ម្នាលភិក្ខុទាំងឡាយ សម្មាសតិ តើដូចម្ដេច ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយក្នុងកាយ ដូច្នេះ ជាគ្រឿងសាធកក្នុងការកើតយុត្តិ ដោយការឆ្លើយ

យ៉ាងនេះ ។ ក្នុងពាក្យនេះ សត្វទាំងពួង លោកពោលថា តាំងនៅបាន ដោយអាហារណា អាហារនោះ ឬភាពដែលសត្វទាំងនោះតាំងនៅបានដោយ អាហារ គប្បីជ្រាបថា ព្រះថេរៈត្រូវត្រាស់សួរថា អ្វីឈ្មោះថា ១ ទូលចម្លើយ បង្ហាញហើយ ។ ពិតហើយ ក្នុងសេចក្តីនោះ ព្រះមានព្រះភាគទ្រង់បំណងថា ឈ្មោះថា ១ ក្នុងទីនេះ តែមិនបានត្រាស់ដើម្បីឲ្យដឹងថា ឈ្មោះថា ១ ដទៃ ក្នុងព្រះសាសនា ឬក្នុងលោកមិនមាន ។ សេចក្តីពិត ព្រះមានព្រះភាគ ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវ ប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន បាន ។

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ធុញទ្រាន់ ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹង នូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌មួយនេះឯង រមែងធ្វើនូវទីបំផុតនៃទុក្ខក្នុង បច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនុ៎ះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យ ហេតុនោះ ។

ក្នុងពាក្យថា **អាហារដ្ឋិតិកា** នេះ ព្រះថេរៈកាន់យកបច្ច័យ ដោយ **អាហារ** សព្វេ ហៅសត្វទាំងពួងដែលតាំងនៅបានដោយបច្ច័យថា តាំងនៅ

បានដោយអាហារ ដូចបច្ច័យ លោកហៅថា អាហារ ក្នុងប្រយោគជាដើមយ៉ាងនេះ សុកនិមិត្តរមែងមាន ការធ្វើទុកក្នុងចិត្តខុសទំនងនឹងការធ្វើឲ្យក្រាស់ក្រែលក្នុងសុកនិមិត្តនោះ នេះជាអាហារដែលញ៉ាំងកាមច្ឆន្ទៈមិនទាន់កើតឡើង ឲ្យកើតឡើង ... ដូច្នេះ តែកាលលោកពោលសំដៅយកអាហារ ៤ ក៏ពោលថា តាំងនៅបានដោយអាហារដូច្នេះ ។

ពាក្យថា **សព្វេ** ក៏គួរមិនពាល់ត្រូវ ដូចក្នុងប្រយោគជាដើមថា ពួកទេវតាជាអសញ្ញសត្វ មិនមានហេតុ មិនមានអាហារ មិនមានផស្សៈ មិនមានវេទនា ... ។

ក្នុងសេចក្តីនោះ មានពាក្យគប្បីចន្ទលបង្ហាញដូច្នេះថា កាលត្រូវពោលយ៉ាងនេះ ការដែលខន្ធទាំងឡាយ តាំងនៅបានដោយបច្ច័យ ក៏ត្រឹមត្រូវពិតព្រោះបាលីថា ពួកធម៌ប្រកបដោយបច្ច័យ តើដូចម្តេច ។ ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ... ដូច្នេះ តែភាពដែលសត្វទាំងឡាយ តាំងនៅបានដោយបច្ច័យ ពាក្យនេះ ប្រហែលជាមិនត្រឹមត្រូវពិតនោះឯង សេចក្តីនេះ មិនគួរឃើញយ៉ាងនេះ ។ ព្រោះហេតុអ្វី ។ ព្រោះពោលបង្រួបបង្រួមសម្រេចដល់ខន្ធក្នុងសត្វទាំងឡាយ ។ ពិតហើយ លោកពោលបង្រួបបង្រួមសម្រេចក្នុងសត្វទាំងឡាយហើយ ព្រោះអ្វី ។ ព្រោះលោកអាស្រ័យខន្ធប្បញ្ញត្តិ ។ សេចក្តីនេះដូចម្តេច ដូចឧបចារនៃស្រុកក្នុងផ្ទះ ឧបមាដូចកាលផ្ទះ ១-២ ខ្នង ឬ ៣ ខ្នងនៃស្រុក ត្រូវភ្លើងឆេះ ក៏ពោលសរុបសម្រេចដល់ស្រុកក្នុងផ្ទះយ៉ាងនេះថា ស្រុកត្រូវភ្លើងឆេះ ព្រោះអាស្រ័យផ្ទះ

*ច្រើនខ្នងបញ្ញត្ត យ៉ាងណា គប្បីជ្រាបថា ពោលរួមសេចក្ដីសម្រេចដល់ថា សត្វទាំងឡាយ តាំងនៅបានដោយអាហារ ក្នុងសត្វទាំងឡាយ ដែលតាំងនៅបានដោយអាហារ ព្រោះអត្ថថា ជាបច្ច័យក្នុងខន្ធទាំងឡាយដូច្នោះដូចគ្នា ។ តែបើពោលដោយបរមត្ថ គប្បីជ្រាបថា កាលខន្ធទាំងឡាយ កើត ចាស់ និងស្លាប់ ព្រះមានព្រះភាគកាលត្រាស់ថា ម្នាលភិក្ខុ អ្នកកើត ចាស់ និងស្លាប់គ្រប់ខណៈ ដូច្នេះ ។ ឈ្មោះថា ទ្រង់សម្ដែងថា ត្រាស់សរុបសេចក្ដីសម្រេចដល់ខន្ធក្នុងសត្វទាំងនោះ កាលណា សត្វទាំងពួង តាំងនៅបានដោយអាហារដែលហៅថា បច្ច័យឯណា អាហារនោះ ឬភាពដែលសត្វតាំងនៅបានដោយអាហារ គប្បីជ្រាបថា មាន ១ ព្រោះថា អាហារ ឬការដែលសត្វតាំងនៅបានដោយអាហារ រមែងជាឋានៈ ទីតាំងនៃនិព្វិទា ព្រោះជាហេតុនៃអនិច្ចតា ។ កាលនោះ ភិក្ខុនឿយណាយ ព្រោះឃើញអនិច្ចតាក្នុងសង្ខារទាំងឡាយដែលគេសម្គាល់ថា សត្វទាំងពួងនោះ រមែងជាអ្នកធ្វើទីបំផុតទុក្ខជាលំដាប់ រមែងសម្រេចបរមត្ថវិសុទ្ធិ ដូចដែលត្រាស់ថា*

**សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

*កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំង*
*ពួង មិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយ*
*ក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ដូច្នេះ ។*

*ក្នុងបញ្ហាដំបូងនេះ មានបាឋៈ ២ យ៉ាងថា* **ឯកំ នាម កឹ** *និង* **កិបហា ។**

ក្នុងបាឋៈទាំង ២ នោះ បាឋៈអ្នកសីហឡថា **កិហ** ដ្បិតថា អ្នកសីហឡទាំងនោះជំនួសដោយការពោលថា **កឹ** ក៏ពោលថា **កិហ** ។ អាចារ្យអ្នកសីហឡពួកខ្លះពោលថា ពាក្យថា **ហ** ជានិបាត បាឋៈរបស់ពួកអ្នកកាន់លទ្ធិខាងថេរវាទក៏យ៉ាងនេះដូចគ្នា ។ តែបាឋៈទាំង ២ មានសេចក្ដីតែមួយ ។ គាប់ចិត្តយ៉ាងណា ក៏គប្បីសូត្រ គប្បីពោលយ៉ាងនោះ ។ ឧបមាដូចទីខ្លះពោលថា **ទុខំ** និងទីខ្លះក៏ពោលថា **ទុក្ខំ** ក្នុងបាលីទាំងឡាយយ៉ាងនេះថា **សុខេន ផុដ្ឋោ អថ វា ទុខេន ទុក្ខំ ទោមនស្សំ បដិសំវេទេតិ** យ៉ាងណា ទីខ្លះក៏ថា **ឯកំ** ទីខ្លះក៏ថា **ឯកកំ** ក៏ដូច្នោះ តែក្នុងទីនេះ មានបាឋៈនេះតែម្យ៉ាងថា **ឯកំ នាម**។

## អ្វីឈ្មោះថា ២

ព្រះសាស្ដា ទ្រង់មានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍នេះយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើង ដូចន័យដំបូងថា អ្វីឈ្មោះថា ២ ព្រះថេរៈពោលដដែលថា **ទ្វេ** ទូលតបដោយទេសនាជាបុគ្គលាធិដ្ឋានថា គឺនាម និងរូប ។ បណ្ដានាម និងរូបនោះ រឿងដែលមិនមែនរូបទាំងអស់ លោកហៅថា នាម ព្រោះបង្អោនមុខកាន់អារម្មណ៍តែម្យ៉ាង ព្រោះជាហេតុបង្អោនចិត្តទៅតែម្យ៉ាង ។ តែក្នុងទីនេះ លោកបំណងយកធម៌ដែលមានអាសវៈប៉ុណ្ណោះ ព្រោះជាហេតុនៃនិព្វិទា គឺការនឿយណាយ ឯមហាភូតរូប ៤ និងរូបទាំងអស់ដែលអាស្រ័យមហាភូតរូបនោះ ប្រព្រឹត្តទៅលោកហៅថា រូប ព្រោះអត្ថថា បែកធ្លាយ រូបនោះ ក្នុងទីនេះ លោកបំណង

*យកទាំងអស់ តែព្រះថេរៈពោលក្នុងទីនេះថា ឈ្មោះថា ២ គឺនាម និងរូប ក៏ដោយបំណងនេះឯង មិនមែនពោលព្រោះមិនមានធម៌ ២ យ៉ាងដទៃ ដូចដែលត្រាស់ថា*

*ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ២ គឺអ្វី ។ គឺនាម ១ រូប ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយព្រោះអាស្រ័យហេតុនេះ ។*

*ក្នុងបញ្ហានេះ គប្បីជ្រាបថា ភិក្ខុលះអត្តទិដ្ឋិ គឺការឃើញថាខ្លួនបាន ដោយការឃើញត្រឹមតែនាមរូប ហើយកាលនឿយណាយដោយមុខ គឺការពិចារណាឃើញអនត្តា រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន រមែងសម្រេចបរមត្ថវិសុទ្ធបាន ដូចព្រះតម្រាស់ថា*

**សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

*កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ធម៌ទាំងពួង មិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនឿយ*

ណាយ ក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ដូច្នេះ ។

# អ្វីឈ្មោះថា ៣

ឥឡូវនេះ ព្រះសាស្ដា មានចិត្តដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើង ដូចន័យមុនថា អ្វីឈ្មោះថា ៣ ។ ព្រះថេរៈពោលជាដែលថា **តីណិ** ដើម្បីសម្ដែងសន្ធ្យាដែលសមគួរដល់លិង្គ គឺរបស់សព្វនៃការដែលគប្បីព្យាករទៀត ទើបទូលស្នងថា **តិស្សោ វេទនា** ។ ម្យ៉ាងទៀត ព្រះថេរៈគិតថា អញនឹងត្រឡប់ ពាក្យថា **តីណិ** របស់វេទនាដែលព្រះមានព្រះភាគត្រាស់ថា **តិស្សោ វេទនា** កាលសម្ដែង ទើបទូលស្នងដូច្នេះ ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងសេចក្ដីនេះដូចពោលមក ដូច្នេះ ដ្បិតថា ទេសនារបស់ពួកលោកដែលសម្រេចនូវទេសនាវិលាស ព្រោះការបែកធ្លាយនៃបដិសម្ភិទា មានកថាមុខជាច្រើន តែអាចារ្យពួកខ្លះពោលថា បទថា **តីណិ** នេះជាបទលើស ។ តែព្រះថេរៈពោលក្នុងទីនេះថា **តិស្សោ វេទនា** គឺវេទនា ៣ តាមន័យមុននោះឯង មិនមែនពោលព្រោះមិនមានធម៌ ៣ ដទៃ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៣ គឺអ្វីខ្លះ ។ គឺវេទនាទាំង ៣ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។

រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ញា ៣ ឧទ្ទេស ៣ វេយ្យាករណ៍ ៣ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

ក្នុងបញ្ហានេះ គប្បីជ្រាបថា ភិក្ខុលះសុខសញ្ញា ដោយការឃើញវេទនាទាំង ៣ ជាទុក្ខ ហើយនឿយណាយដោយមុខ គឺការពិចារណាឃើញទុក្ខតាមគន្លងព្រះសូត្រ ដែលត្រាស់ថា វេទនាឯណាមួយ វេទនាទាំងនោះ តថាគតពោលថាជាទុក្ខ ឬតាមគន្លងភាពជាទុក្ខ ព្រោះទុក្ខជាទុក្ខ ព្រោះប្រែប្រួល និងជាទុក្ខព្រោះបច្ច័យតាក់តែងយ៉ាងនេះថា

**យោ សុខំ ទុក្ខតោ ទក្ខិ ទុក្ខមទ្ទក្ខិ សល្លតោ**
**អទុក្ខមសុខំ សន្តំ អទ្ទក្ខិ នំ អនិច្ចតោ ។**

ភិក្ខុណា បានឃើញសុខវេទនាថាជាទុក្ខ បានឃើញទុក្ខវេទនាថាជាព្រួញ បានឃើញអទុក្ខមសុខវេទនាជាទីស្ងប់នោះ ថាជារបស់មិនទៀង ... ដូច្នេះ ។

រមែងជាបុគ្គលធ្វើទីបំផុតទុក្ខបាន រមែងសម្រេចបរមត្ថវិសុទ្ធិបាន ដូចព្រះតម្រាស់ថា

**សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំង

ពួន នាំមកនូវសេចក្តីទុក្ខដូច្នេះ កាលណោះ រមែងនឿយ
ណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ដូច្នេះ ។

# អ្វីឈ្មោះថា ៤

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍នេះ ដូច្នេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើង ដូចន័យមុនៗ ថា អ្វីឈ្មោះថា ៤ ក្នុងបញ្ហានេះ ក្នុងចំណែកព្យាករបញ្ហានេះ កន្លែងខ្លះ លោកបំណងយកអាហារ ៤ តាមន័យមុនៗ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ
។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤
គឺអ្វី ។ គឺអាហារទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ
ភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃ
ទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា
បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ
តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

កន្លែងខ្លះ ភិក្ខុមានចិត្តអប់រំហើយ ក្នុងគុណធម៌ទាំងឡាយណា រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ដោយលំដាប់ គុណធម៌ទាំងនោះ គឺសតិប្បដ្ឋាន ៤ ដូចជង្គលាភិក្ខុនីពោលថា

ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយ
ប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រ-

យោជន៍ដោយប្រពៃ ក្នុងធម៌ ៤ រមែងធ្វើនូវទីបំផុតនៃ
ទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៤ គឺអ្វី ។ គឺសតិប្បដ្ឋាន
៤ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អ
ដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ន
បាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា
បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនុ៎ះ
ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុ
នេះ ។

តែក្នុងទីនេះ ការកាត់កវតណ្ហាមាន ព្រោះត្រាស់ដឹងតាម និងចាក់ធ្លុះអរិយសច្ចទាំង ៤ ណា ព្រោះហេតុដែលអរិយសច្ច ៤ នោះ លោកបំណងយកហើយ ឬព្រោះហេតុដែលបញ្ហាកម្ម ដែលលោកព្យាករដោយបរិយាយនេះ ជាការព្យាករណ៍ល្អហើយទាំងអស់ ដូច្នោះ ព្រះថេរៈពោលដដែលថា **ចត្តារិ** ទើបទូលតបថា **អរិយសច្ចានិ** ។ ក្នុងពាក្យនោះ សព្ទថា **ចត្តារិ** ជាការកំណត់ដោយចំនួន ។ បទថា **អរិយសច្ចានិ** បានដល់ សច្ចៈដែលជាអរិយៈ អធិប្បាយថា មិនខុស មិនឃ្លៀងឃ្លាត ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះជារបស់ពិត
មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ព្រោះ
ហេតុនោះ បានជាតថាគត ហៅថា អរិយសច្ច ។

ម្យ៉ាងទៀត ព្រោះលោកអធិប្បាយថា ព្រោះជាសច្ចៈដែលមនុស្សលោក

និងទេវលោកគប្បីប្រព្រឹត្តទៅ គប្បីសម្រេច ។ ព្រោះប្រព្រឹត្តទៅក្នុងផ្លូវចម្រើន ដែលគេយល់ថា ឋានៈដែលគួរព្យាយាមខ្លះ ព្រោះមិនប្រព្រឹត្តទៅក្នុងផ្លូវដែលមិនចម្រើនខ្លះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវកទាំងឡាយ ដែលតែងដឹងថាជាព្រះអរិយៈ ព្រោះប្រកបដោយអរិយធម៌ គឺពោធិបក្ខិយធម៌ ៣៧ ប្រការ រមែងចាក់ធ្លុះអរិយសច្ចទាំងនេះ ព្រោះហេតុនោះ ទើបលោកហៅថា អរិយសច្ច ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ ។បេ។ អរិយសច្ចទាំង ៤ នេះ ព្រះអរិយៈទាំងឡាយ រមែងចាក់ធ្លុះនូវអរិយសច្ចៈទាំង ៤ នេះ ព្រោះហេតុនោះ ទើបហៅថា អរិយសច្ច ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា អរិយសច្ច ព្រោះជាសច្ចៈនៃព្រះមានព្រះភាគដែលជាអរិយៈ ដូចព្រះតម្រាស់ថា

ព្រះតថាគតជាអរិយបុគ្គល ក្នុងលោក ព្រមទាំងទេវលោក ។បេ។ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ព្រោះហេតុនោះ ( សច្ចៈ ៤ ដែលតថាគតសម្តែងហើយ ) ហៅថា អរិយសច្ច ។

ម្យ៉ាងទៀត ឈ្មោះថា អរិយសច្ច ព្រោះធ្វើឲ្យសម្រេចនូវភាពជាអរិយៈ ព្រោះអរិយសច្ចទាំងនោះ ទ្រង់ដឹងក្រៃលែងដោយព្រះអង្គឯងហើយ ដូចព្រះតម្រាស់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដែលមានឈ្មោះថា
អរហំសម្មាសម្ពុទ្ធ ព្រោះតថាគត បានត្រាស់ដឹងនូវ
អរិយសច្ច ៤ នេះ តាមសេចក្តីពិត ។

អត្ថនៃបទរបស់អរិយសច្ចទាំងនោះ មានដូច្នេះ ការកាត់ផ្តាច់នូវភវតណ្ហា រមែងមាន ព្រោះការត្រាស់ដឹងតាម និងការចាក់ធ្លុះអរិយសច្ចទាំងឡាយនេះ ដូចព្រះតម្រាស់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចនេះ តថាគតក្តី
អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ បានចាក់ធ្លុះ
ហើយ ។បេ។ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច
តថាគតក្តី អ្នកទាំងឡាយក្តី បានត្រាស់ដឹងហើយ
បានចាក់ធ្លុះហើយ ។ ភវតណ្ហាជាធម្មជាតនាំសត្វ
ឲ្យចូលទៅកាន់ភព បានផ្តាច់ផ្តិលអស់ហើយ ភព
ថ្មីទៀត ក្នុងកាលឥឡូវនេះ មិនមានឡើយ ។

## អ្វីឈ្មោះថា ៥

ព្រះសាស្តា មានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើង តាមន័យមុនៗ ថា អ្វីឈ្មោះថា ៥ ព្រះថេរៈពោលពាក្យដដែលថា **បញ្ច** ទើបទូលតបថា ឧបាទានក្ខន្ធ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **បញ្ច** ជាការកំណត់ចំនួន ។ ខន្ធទាំងឡាយ ដែលត្រូវឧបាទានឲ្យកើតមក ឬដែលធ្វើឧបាទានឲ្យកើត ឈ្មោះ

ថា ឧបាទានក្ខន្ធ ។ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណណាមួយ មាន អាសវៈ ដែលភិក្ខុគប្បីកាន់យក ពាក្យនេះ ជាឈ្មោះនៃឧបាទានក្ខន្ធទាំងនោះ ក្នុងទីនេះ ព្រះថេរៈពោលថា ឧបាទានក្ខន្ធ ៥ តាមន័យមុននោះឯង មិនមែន ព្រោះមិនមានធម៌ ៥ យ៉ាងដទៃ ដូចព្រះតម្រាស់ថា

*ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៥ គឺអ្វីខ្លះ ។ គឺឧបាទានក្ខន្ធទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគតពោលថា បញ្ហា ៥ ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។*

ក្នុងបញ្ហានេះ ភិក្ខុកាលពិចារណាដោយការកើត ការរលត់ជាអារម្មណ៍ បាននូវអមតៈ ដោយវិបស្សនាហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវអមតៈ គឺព្រះនិព្វានដោយលំដាប់ ដូចព្រះតម្រាស់ថា

**យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ**
**លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។**

*ភិក្ខុពិចារណាការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ*

រមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌ របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

## អ្វីឈ្មោះថា ៦

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យ ដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករណ៍នេះយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាឲ្យក្រៃលែង តាមន័យមុនថា អ្វីឈ្មោះថា ៦ ។ ព្រះថេរៈពោលពាក្យដដែលថា ៩ ទើបទូលតបថា អាយតនៈខាងក្នុង ។ ក្នុងពាក្យទាំងនោះ ពាក្យថា ៩ ជាការកំណត់ចំនួន ។ អាយតនៈទាំងឡាយដែលប្រកបខាងក្នុង ឬធ្វើខ្លួនឲ្យជាទីអាស្រ័យប្រព្រឹត្តទៅ ឈ្មោះថា **អជ្ឈត្តិក។** ឈ្មោះថា **អាយតន** ព្រោះបន្ត ឬព្រោះសាងនូវសេចក្តីចម្រើន ឬព្រោះនាំសង្សារទុក្ខមកអស់កាលយូរ ពាក្យនេះជាឈ្មោះរបស់ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនៈ ។ ក្នុងទីនេះ ព្រះថេរៈពោលថា អាយតនៈខាងក្នុង ៦ តាមន័យមុន មិនមែនពោលព្រោះមិនមានធម៌ ៦ ដទៃ ។ ដូចព្រះតម្រាស់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៦ គឺអ្វី ។ គឺអាយតនៈខាងក្នុងទាំង ៦ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណាដែលតថាគត

ពោលថា បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

ក្នុងបញ្ហានេះ ភិក្ខុពិចារណាអាយតនៈខាងក្នុង ៦ ដោយភាពជារបស់ទទេ តាមព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ស្រុកស្ងាត់នុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុងទាំង ៦ ដូច្នេះ ដោយភាពជារបស់ទទេ និងដោយភាពជារបស់បញ្ឆោត ព្រោះតាំងនៅយូរមិនបាន ដូចពពុះទឹក និងថ្ងៃបណ្ដើរកូន ដូច្នោះ ក៏នឿយណាយ ធ្វើទីបំផុតទុក្ខដោយលំដាប់ រមែងចូលដល់ទីដែលមច្ចុរាជមើលមិនឃើញ ដូចព្រះតម្រាស់ថា

**យថា បុព្ពុឡកំ បស្សេ យថា បស្សេ មរីចិកំ**
**ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។**

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រញថ្ងៃយ៉ាងណា ស្ដេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

## អ្វីឈ្មោះថា ៧

ព្រះសាស្ដា ជាបុគ្គលមានព្រះហឫទ័យ ដែលព្រះថេរៈធ្វើឲ្យត្រេកអរដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាឲ្យក្រៃលែងតាមន័យមុនថា អ្វីឈ្មោះថា ៧ ។ វិញ្ញាណដ្ឋិតិ ៧ ព្រះថេរៈពោលការព្យាករណ៍បញ្ហាធំក៏ពិត តែភិក្ខុមានចិត្តអប់រំល្អហើយ ក្នុងធម៌ពួកណា រមែងជាអ្នកធ្វើ

ទីបំផុតទុក្ខបាន ព្រះថេរៈកាលសម្តែងធម៌ទាំងនោះ ទើបទូលសួងថា ពោជ្ឈង្គ ៧ ។ ម្យ៉ាងទៀត សេចក្តីនេះ ព្រះមានព្រះភាគទ្រង់អនុមតិហើយ ដូចដែលត្រាស់ថា

ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនីជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាមនុស្ស មានប្រាជ្ញាច្រើនមែន ម្នាលគហបតីទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវសេចក្តីនុ៎ះ តថាគតក៏ដោះស្រាយសេចក្តីនោះយ៉ាងនោះ ដូចជាកជង្គលាភិក្ខុនីដែលដោះស្រាយដែរ ។

ជង្គលាភិក្ខុនីនោះព្យាករយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៧ គឺអ្វី ។ គឺពោជ្ឈង្គទាំង ៧ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧ ដូច្នេះ ពាក្យនុ៎ះ ព្រះដ៏មានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

សេចក្តីនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់អនុមតិហើយ ដោយប្រការដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **សត្ត** ជាការកំណត់ចំនួនដាច់ខាត មិនខ្វះមិនលើស ។ ពាក្យថា **ពោជ្ឈង្គ** នេះ ជាឈ្មោះរបស់ធម៌ មានសតិជាដើម ។

អត្ថនៃបទក្នុងពោជ្ឈង្គ ៧ នេះ មានដូច្នេះ ឈ្មោះថា **ពោធិ** ព្រោះវិគ្គហៈថា អរិយសាវករមែងត្រាស់ដឹងដោយធម្មសាមគ្គី ពោល គឺសតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ដែលជាបដិបក្ខចំពោះឧបទ្រវជាច្រើន មានការរួញរា ការរាយមាយ ការបញ្ឈប់ព្យាយាម ការព្យាយាម កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ និងការប្រកាន់ដោយឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិជាដើមដែលកើតឡើងក្នុងខណៈនៃមគ្គចិត្ត ឯលោកិយ និងលោកុត្តរនោះ លោកអធិប្បាយថា ក្រោកឡើងអំពីការដេកលក់ គឺសន្តានដែលមានកិលេស ឬចាក់ធ្លុះអរិយសច្ច ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ដូចដែលលោកពោលថា ទ្រង់ចម្រើនពោជ្ឈង្គ ៧ ត្រាស់ដឹងក្រៃលែងឯង នូវអនុត្តរសម្មាសម្ពោធិ ។

ម្យ៉ាងទៀត សូម្បីព្រះអរិយសាវក ក៏ឈ្មោះថា **ពោធិ** ព្រោះវិគ្គហៈថា ត្រាស់ដឹងដោយធម្មសាមគ្គីនេះ មានប្រការតាមដែលពោលមកហើយ ។ ដូច្នោះទើបឈ្មោះថា **ពោជ្ឈង្គ** ។ ព្រោះជាអង្គ គឺចំណែកនៃពោធិ ពោល គឺធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និងអង្គនៃមគ្គ ម្យ៉ាងទៀត ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃអរិយសាវក ដែលបានវោហារថា **ពោធិ** នោះ ដូចអង្គ គឺចំណែកនៃកងទ័ព និងអង្គ គឺចំណែកនៃរថជាដើម ដូច្នោះ ។

មួយប្រការទៀត គប្បីជ្រាបថា ពោជ្ឈង្គនៃពោជ្ឈង្គទាំងឡាយ ដោយវិធីដែលលោកពោលក្នុងគម្ពីរបដិសម្ភិទាយ៉ាងនេះថា

សំណួរត្រង់ពាក្យថា ពោជ្ឈង្គ តើពោជ្ឈង្គដោយអត្ថថាដូចម្តេច ។ ឈ្មោះ

ថា ពោជ្ឈង្គ ព្រោះហេតុប្រព្រឹត្តទៅព្រមក្នុងការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គព្រោះហេតុត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងចំពោះ ឈ្មោះថា ពោជ្ឈង្គ ព្រោះហេតុត្រាស់ដឹងព្រម[1] ព្រះយោគាវចរកាលចម្រើន ធ្វើឲ្យច្រើន នូវពោជ្ឈង្គទាំង ៧ នេះ យ៉ាងនេះ មិនយូរឡើយ នឹងជាបុគ្គលបាននូវគុណ មានការនឿយណាយ ដោយចំណែកមួយជាដើម ដោយហេតុនោះ ទើបត្រាស់ថា រមែងជាអ្នកធ្វើទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន សមដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ដែលបុគ្គល
ចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ រមែងប្រព្រឹត្តទៅ
ដើម្បីនឿយណាយដោយពិត ដើម្បីប្រាសចាករាគៈ
ដើម្បីរម្ងត់ ដើម្បីចូលទៅជិតរម្ងាប់ ដើម្បីដឹងច្បាស់
ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន ។

## អ្វីឈ្មោះថា ៨

ព្រះសាស្ដា ជាបុគ្គលមានចិត្តដែលព្រះថេរៈធ្វើឲ្យត្រេកអរ ដោយការព្យាករបញ្ហា ដូច្នេះហើយ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើងថា អ្វីឈ្មោះថា ៨ ព្រះថេរៈពោលលោកធម៌ ៨ ដោយការព្យាករណ៍ច្រើនបញ្ហាក៏ពិត តែភិក្ខុមានចិត្តអប់រំល្អហើយ ក្នុងធម៌ពួកណា រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ព្រះថេរៈកាលសម្ដែងធម៌ទាំងនោះ មិនបានពោលថា អង្គនៃអរិយមគ្គ ៨ ព្រោះ

១- សេចក្ដីពិស្ដារមានក្នុងបិដកលេខ ៧១ ទំព័រ ៦៤ ។

ធម្មតាមគ្គដែលផុតចាកអង្គ ៨ មិនមាន តែមគ្គមានត្រឹមអង្គ ៨ ប៉ុណ្ណោះ ដូច្នោះ កាលនឹងសម្រេចសេចក្តីនោះ ទើបទូលឆ្លើយដោយវិលាសនៃទេសនាថា អរិយមគ្គមានអង្គ ៨ អត្ថ និងទេសនាន័យនេះ ព្រះមានព្រះភាគ ទ្រង់អនុមតិហើយទាំងអស់ ដូចព្រះតម្រាស់ថា

ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនីជាអ្នកប្រាជ្ញ ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាមនុស្សមានប្រាជ្ញាច្រើនមែន ម្នាលគហបតីទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ ចូលមករកតថាគត ហើយសួរនូវសេចក្តីនុ៎ះ តថាគតក៏ដោះស្រាយសេចក្តីនោះយ៉ាងនោះ ដូចជាកជង្គលាភិក្ខុនី ដែលដោះស្រាយដែរ ។ ព្រះនាងកជង្គលាភិក្ខុនីនោះ ព្យាករទុកយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៨ គឺអ្វី ។ គឺអដ្ឋង្គិកមគ្គដ៏ប្រសើរទាំង ៨ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តចម្រើនល្អដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលព្រះដ៏មានព្រះភាគសម្តែងថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ដូច្នេះ ពាក្យនុ៎ះ ព្រះមានព្រះភាគសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

អត្ថ និងទេសនានុ័យនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់អនុមតិហើយ ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរិយោ** ប្រែថា ដែលបុគ្គលត្រូវការព្រះ-និព្វានគប្បីសម្រេច ។ ម្យ៉ាងទៀត មគ្គ គប្បីជ្រាបថា អរិយៈ ព្រោះប្រព្រឹត្តទៅឆ្ងាយចាកកិលេសទាំងឡាយ ព្រោះធ្វើឲ្យជាព្រះអរិយៈ និងព្រោះបានអរិយផល ។ អង្គនៃមគ្គនោះមាន ៨ ព្រោះហេតុនោះ ទើបមគ្គនោះ ឈ្មោះថា មានអង្គ ៨ មគ្គនេះ គប្បីជ្រាបថា គ្រាន់តែជាអង្គប៉ុណ្ណោះ ព្រោះមគ្គមានសភាពដែលបុគ្គលមិនគប្បីបាន ដោយចែកចេញជាអង្គ ដូចកងទ័ពមានអង្គ ៤ និងតន្ត្រីមានអង្គ ៥ ។ បុគ្គលរមែងស្វែងរកព្រះនិព្វានដោយផ្លូវនេះ ឬស្វែងរកឯង ឬសម្លាប់កិលេស ហេតុនោះ ទើបផ្លូវនេះ ឈ្មោះថា មគ្គ ។

ភិក្ខុកាលចម្រើនមគ្គ មានប្រភេទ ៨ និងមានអង្គ ៨ នេះ យ៉ាងនេះ រមែងទម្លាយអវិជ្ជា ធ្វើវិជ្ជាឲ្យកើត ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដោយហេតុនោះ ទើបលោកពោលថា ជាអ្នកធ្វើទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន សមដូចព្រះតម្រាស់ត្រាស់យ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ចុងគ្រាប់ស្រូវខ្សាយក្តី ចុងគ្រាប់ស្រូវដំណើបក្តី ដែលបុគ្គលរៀបចំត្រូវទំនង គឺធ្វើឲ្យមានចុងឡើងលើ បុគ្គលសង្កត់ដោយដៃ ឬជាន់ដោយជើង នឹងមុតដៃ ឬជើង នឹងធ្វើឈាមឲ្យផុលឡើងបាន ហេតុនេះ ទើបមាន រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ស្រូវបុគ្គលរៀបចំត្រូវទំនង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្ត

តម្កល់ត្រូវនឹងទម្លាយអវិជ្ជា នឹងធ្វើវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនេះទើបមាន ។

## អ្វីឈ្មោះថា ៩

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យ ដែលព្រះថេរៈធ្វើឲ្យត្រេកអរដោយការព្យាករណ៍បញ្ហានេះ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើងថា អ្វីឈ្មោះថា ៩ ។ ព្រះថេរៈពោលត្រូវថា **នវ** ទើបទូលឆ្លើយថា **សត្តាវាស** ។

ក្នុងពាក្យនោះ ពាក្យថា **នវ** ជាការកំណត់ចំនួន ពាក្យថា **សត្វ** បានដល់ សត្វមានជីវិតដែលលោកបញ្ញត្តអាស្រ័យខន្ធ ដែលទាក់ទងក្នុងជីវិតិន្ទ្រិយ ។ ពាក្យថា **អាវាស** បានដល់ ឈ្មោះថា **អាវាស** ព្រោះជាទីអាស្រ័យ ។ ទីអាស្រ័យរបស់សត្វទាំងឡាយ ឈ្មោះថា **សត្តាវាស** ឈ្មោះថា ជាគន្ថនៃទេសនា តែបើពោលដោយអត្ថ ពាក្យនេះជាឈ្មោះរបស់សត្វ ៩ ប្រភេទ ដូចលោកពោលថា

> ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជាសត្តាវាសទី ១ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់ព្រហ្មលោក ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា

ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាសត្តាវាសទី ៤ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វឥតសញ្ញា មិនដឹងច្បាស់ ( នូវអារម្មណ៍ ) ដូចពួកទេវតាជាអសញ្ញិសត្វ នេះជាសត្តាវាសទី ៥ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៦ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៧ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៨ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។បេ។ នេះជាសត្តាវាសទី ៩ ។

ក្នុងទីនេះ ព្រះថេរៈពោលថា សត្តាវាស ៩ តាមន័យមុនៗ នោះឯងមិនមែនពោលព្រោះមិនមានធម៌ ៩ ដទៃ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសទាំង ៩ ។ ម្នាលភិក្ខុទាំងឡាយកាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

ក្នុងបញ្ហានេះ ភិក្ខុលះការឃើញថា ទៀង ស្អាត សុខជាដើម ដោយញាតបរិញ្ញា ក្នុងសត្តាវាស ៩ ព្រោះបាលីថា ធម៌ ៩ គួរកំណត់ដឹង គឺ សត្តាវាស ៩ នឿយណាយដោយការឃើញត្រឹមតែជាគំនរសង្ខារសុទ្ធៗ ប្រាសចាកតម្រេក ដោយការឃើញអនិច្ចលក្ខណៈ ដោយតីរណបរិញ្ញា រួចផុតដោយការឃើញទុក្ខលក្ខណៈ ឃើញទីបំផុតដោយប្រពៃ ដោយការឃើញអនត្តលក្ខណៈ ត្រាស់ដឹងនូវភាពជាធម៌ប្រពៃ ដោយបហានបរិញ្ញា រមែងជាបុគ្គលធ្វើទីបំផុតទុក្ខបាន ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយ ដោយប្រពៃ ធុញទ្រាន់ដោយប្រពៃ រួចស្រឡះដោយប្រពៃ ឃើញនូវទីបំផុតដោយប្រពៃ ត្រាស់ដឹងនូវប្រយោជន៍ដោយប្រពៃ ក្នុងធម៌ ៩ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុង

បច្ចុប្បន្នបាន ។ ធម៌ ៩ គឺអ្វី ។ គឺសត្តាវាសទាំង ៩

ដូច្នេះ ។

## អ្វីឈ្មោះថា ១០

ព្រះសាស្តា ជាបុគ្គលមានព្រះហឫទ័យដែលព្រះថេរៈធ្វើឲ្យត្រេកអរដោយព្យាករនេះយ៉ាងនេះ ទើបត្រាស់សួរបញ្ហាក្រៃលែងឡើងទៀតថា អ្វីឈ្មោះថា ១០ ។ ក្នុងបញ្ហានេះ ព្រះមានព្រះភាគត្រាស់អកុសលកម្មបថ ១០ ក្នុងការព្យាករណ៍ទាំងឡាយ ក្រៅអំពីការព្យាករណ៍បញ្ហានេះ ដូចព្រះតម្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ធម៌ទាំង ១០ គឺអ្វី ។ គឺអកុសលកម្មបថទាំង ៩ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនឿយណាយដោយប្រពៃ ។បេ។ រមែងធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ដូច្នេះ ។

ពិតហើយ ទោះជាយ៉ាងនោះ ក្នុងទីនេះ ព្រោះហេតុដែលព្រះថេរៈ មិននាំខ្លួនឯងចូលទៅ បំណាងនឹងព្យាករនូវអរហត្ត ឬព្រោះហេតុដែលបញ្ហាកម្មដែលព្រះថេរៈព្យាករដោយបរិយាយនេះ ជាការព្យាករណ៍ល្អហើយ ដូច្នោះ

បុគ្គលដែលប្រកបដោយអង្គ ១០ ពួកណា លោកហៅថា ព្រះអរហន្ត ព្រះថេរៈ កាលសម្តែងការសម្រេចអង្គទាំង ១០ នោះ ទើបទូលដោយទេសនាជាបុគ្គលាធិដ្ឋានថា បុគ្គលដែលប្រកបដោយអង្គ ១០ លោកហៅថា ព្រះអរហន្ត ព្រោះក្នុងសេចក្តីនេះ បុគ្គលដែលប្រកបដោយអង្គ ១០ ពួកណា លោកហៅថា ព្រះអរហន្ត គប្បីជ្រាបថា អង្គទាំង ១០ នោះ ព្រះថេរៈត្រូវព្រះសាស្តាត្រាស់សួរថា អ្វីឈ្មោះថា ១០ ទើបទូលស្នងព្រះពុទ្ធដីកា ។ អង្គទាំង ១០ នោះ គប្បីជ្រាបដោយន័យដែលត្រាស់ក្នុងសូត្រទាំងឡាយជាដើមយ៉ាងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ត្រាស់ថា អសេក្ខៈ អសេក្ខៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអសេក្ខៈ តើដោយហេតុប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបដោយសម្មាទិដ្ឋិ ជាអសេក្ខៈ ប្រកបដោយសម្មាសង្កប្បៈ ជាអសេក្ខៈ ប្រកបដោយសម្មាវាចា ជាអសេក្ខៈ ប្រកបដោយសម្មាកម្មន្តៈ ជាអសេក្ខៈ ប្រកបដោយសម្មាអាជីវៈ ជាអសេក្ខៈ ប្រកបដោយសម្មា-វាយាមៈ ជាអសេក្ខៈ ប្រកបដោយសម្មាសតិ ជាអសេក្ខៈ ប្រកបដោយសម្មាសមាធិ ជាអសេក្ខៈ ប្រកបដោយសម្មាញាណ ជាអសេក្ខៈ ប្រកបដោយសម្មាវិមុត្តិ ជាអសេក្ខៈ ។ ម្នាលភិក្ខុ ( ភិក្ខុ ) ជាអសេក្ខៈយ៉ាង

នេះឯង ។

អដ្ឋកថាខុទ្ទកបាឋៈ

កុមារបញ្ហា ចប់

# សុត្តន្តបិដក

## ខុទ្ទកបាឋៈ មង្គលសូត្រ

[ ៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ទេវតា ១ អង្គ កាលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគលុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមាន ព្រះភាគដោយគាថា ។

[ ៦ ] ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នារក
សួស្តី បានគិតរកមង្គលទាំងឡាយ សូមព្រះអង្គសម្តែង
ប្រាប់នូវមង្គលដ៏ឧត្តម ។ ( ព្រះមានព្រះភាគទ្រង់
ត្រាស់ថា ) ការមិនសេពគប់ពាលជនទាំងឡាយ ១
ការសេពគប់បណ្ឌិតជនទាំងឡាយ ១ ការបូជាចំពោះ

បុគ្គលដែលគួរបូជាទាំងឡាយ ១ នេះជាមង្គលដ៏ឧត្តម ។ ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ ការតម្កល់ខ្លួនប្រពៃ ១ នេះជាមង្គលដ៏ឧត្តម ។ ភាវៈនៃបុគ្គលបានស្តាប់ បានរៀនច្រើន ១ សិល្បៈ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាប្រពៃ ១ វាចាដែលបុគ្គលពោលល្អ ១ នេះជាមង្គលដ៏ឧត្តម ។ ការបម្រើមាតាបិតា ១ សេចក្តីសង្គ្រោះដល់បុត្ត និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ នេះជាមង្គលដ៏ឧត្តម ។ ការបរិច្ចាគទាន ១ ការប្រព្រឹត្តធម៌ ១ សេចក្តីសង្គ្រោះញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ នេះជាមង្គលដ៏ឧត្តម ។ ការមិនត្រេកអរក្នុងបាប និងការវៀរចាកបាប ១ សេចក្តីសង្រួមចាកការផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទ ក្នុងធម៌ទាំងឡាយ ១ នេះជាមង្គលដ៏ឧត្តម ។ សេចក្តីគោរព ១ សេចក្តីឱនលំទោន ១ សេចក្តីត្រេកអរតាមមានតាមបាន ១ ភាពជាអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយ ១ ការស្តាប់នូវធម៌តាមកាល ១ នេះជាមង្គលដ៏ឧត្តម ។

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបាន ដោយងាយ ១ ការជួបប្រទះនូវសមណៈទាំងឡាយ ១ ការសន្ទនាទៅវិញ ទៅមកនូវធម៌តាមកាល ១ នេះជា មង្គលដ៏ឧត្តម ។ សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ ការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ច ទាំងឡាយ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ នេះជាមង្គលដ៏ឧត្តម ។ ចិត្តនៃបុគ្គលណាដែលលោក- ធម៌ទាំងឡាយ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ ការមិនមានសេចក្ដីសោក ១ ធូលី គឺរាគៈទៅប្រាស ហើយ ១ ចិត្តក្សេមក្សាន្ត ១ នេះជាមង្គលដ៏ឧត្តម ។ ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដី ក្នុងទីទាំងពួង នេះជាមង្គល ដ៏ឧត្តមរបស់ទេវតា និងមនុស្សទាំងឡាយនោះ ។

មង្គលសូត្រ ចប់

# អដ្ឋកថា

## មង្គលសូត្រ

## ប្រយោជន៍នៃនិក្ខេបបទ

[ ៥-៦ ] ឥឡូវនេះ ដល់លំដាប់ពណ៌នានៃមង្គលសូត្រ ដែលលើកឡើងជានិក្ខេបបទ បន្ទាប់លំដាប់អំពីកុមារបញ្ហា ។ ក្នុងទីនេះ ខ្ញុំនឹងពោលប្រយោជន៍នៃនិក្ខេបបទហើយ ទើបនឹងពណ៌នាអត្ថនៃមង្គលសូត្រនោះ ។ សេចក្ដីនេះដូចម្ដេច សេចក្ដីពិត ព្រះសូត្រនេះ ព្រះមានព្រះភាគ មិនបានត្រាស់តាមលំដាប់ តែខ្ញុំពោលដើម្បីសម្ដែងថា ការរាប់អានព្រះសាសនាដោយការដល់សរណៈ នឹងន័យតាមប្រភេទសីល សមាធិ បញ្ញា ទ្រង់សម្ដែងដោយសិក្ខាបទ ទូត្តិសាការ និងកុមារបញ្ហានេះ ទាំងអស់នោះក៏ជាមង្គលយ៉ាងក្រៃលែង ព្រោះបុគ្គលត្រូវការមង្គល ចាំបាច់ធ្វើព្យាយាមក្រៃលែងក្នុងមង្គលនោះៗ ឯង ។ ឯការរាប់អានព្រះសាសនាជាដើមនោះជាមង្គលនោះ បណ្ឌិតគប្បីជ្រាបតាមគន្ធព្រះសូត្រនេះ ។

នេះជាប្រយោជន៍នៃនិក្ខេបបទ ក្នុងមង្គលសូត្រនោះ ។

## បឋមមហាសង្គាយនា

ដើម្បីពណ៌នាអត្ថនៃមង្គលសូត្រនោះ ដែលលើកជានិក្ខេបបទយ៉ាងនេះ មានមាតិកា ដូច្នេះ ។

ខ្ញុំពោលវិធីយ៉ាងនេះថា ពាក្យនេះបុគ្គលណាពោល ពោលក្នុងកាលណា ពោលព្រោះហេតុអ្វី កាលនឹងពណ៌នាសេចក្ដីនៃបាឋៈ មាន **ឯវំ** ជាដើម

*ក៏ទឹងពោលសមុដ្ឋានដែលកើតមង្គល កំណត់មង្គលនោះហើយ ទឹងចង្អុលបង្ហាញនូវមង្គលនៃមង្គលសូត្រនោះ ។*

*ក្នុងមាតិកានោះ កន្លះគាថាដំបូងថា* **វុត្តំ យេន យទា យស្មា ជេតំ វត្វា ឥមំ វិធឹ** *លោកពោលសំដៅដល់ពាក្យ គឺ* **ឯវម្មេ សុតំ ។បេ។ ភគវន្តំ គាថាយ អជ្ឈភាសិ ។** *ពិតហើយ ព្រះសូត្រនេះ លោកពោលដោយស្តាប់បន្តៗ គ្នាមក ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាសយម្ភូ គឺត្រាស់ដឹងឯងមិនមានអាចារ្យ ព្រោះដូច្នោះ ពាក្យនេះ ទើបមិនមែនជាព្រះតម្រាស់របស់ព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ព្រោះហេតុដែលមានពាក្យពោលថា ពាក្យនេះអ្នកណាពោល ពោលកាលណា និងពោលព្រោះហេតុអ្វី ដូច្នោះ ទើបសូមពោលចង្អុលបង្ហាញ ។ ដូច្នេះ ពាក្យនេះ ព្រះអានន្ទពោល និងពោលក្នុងកាលធ្វើមហាសង្គាយនាលើកទី ១ ។*

*សេចក្តីពិត ការធ្វើមហាសង្គាយនាលើកទី ១ នេះ គួរជ្រាបមកតាំងអំពីដើម ដើម្បីភាពឈ្លាសវៃក្នុងនិទានវចនៈ គឺពាក្យខាងដើមនៃព្រះសូត្រទាំងពួង ដូចតទៅនេះ*

*កាលព្រះមានព្រះភាគ ជានាថនៃលោក ទ្រង់បំពេញពុទ្ធកិច្ច តាំងអំពីទ្រង់ប្រកាសធម្មចក្រ រហូតដល់ទ្រង់ប្រោសសុភទ្ទបរិញ្វជក ហើយទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលទៀបភ្លឺ ថ្ងៃវិសាខបុណ្ណមី ចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងសាលវ័នឧទ្យាន ដែលជាទីឈប់សម្រាករបស់មល្លក្សត្រ ជិតក្រុងកុសិនារា ព្រះមហាកស្សបដែលជាសង្ឃត្ថេររបស់*

ភិក្ខុប្រមាណ ៧ សែនរូប ដែលប្រជុំគ្នាក្នុងថ្ងៃចែកព្រះបរមសារីរិកធាតុរបស់ព្រះមានព្រះភាគ មករឭកដល់ពាក្យរបស់សុភទ្ទវុឌ្ឍបព្វជិតពោលក្នុងកាលព្រះមានព្រះភាគបរិនិព្វានបាន ៧ ថ្ងៃថា

អាវុសោទាំងឡាយ ណ្ហើយ អ្នកទាំងឡាយ កុំសោកសៅ
កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ
ព្រោះថា ពួកយើង មហាសមណៈនោះ តែងបៀតបៀនថា
អំពើនេះគួរ ដល់អ្នក អំពើនេះមិនគួរ ដល់អ្នក ឥឡូវនេះ
ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើនូវអំពើនោះ មិន
ប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន ដូច្នេះ ។

លោកត្រិះរិះថា ពួកភិក្ខុអាក្រក់យល់ថា បាវចនា គឺធម្មវិន័យ មានសាស្ដាកន្លងទៅហើយ បានចូលរួមជាបក្ខពួក ក៏នាំគ្នាញាំញីព្រះសទ្ធម្ម ឲ្យអន្តរធានទៅ ក្នុងកាលមិនយូរឡើយ សេចក្ដីនេះ រមែងប្រព្រឹត្តទៅបានដរាបណា ធម្មវិន័យនៅតាំងនៅដរាបនោះ បាវចនៈ គឺធម្មវិន័យ ក៏ឈ្មោះថាមិនមានសាស្ដានិព្វានទៅហើយឡើយ សមដូចព្រះមានព្រះភាគទ្រាស់ថា

ម្នាលអានន្ទ ធម៌ណាក្ដី វិន័យណាក្ដី ដែលតថាគត
សម្ដែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះ
អំណឹះឥតអំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាគ្រូ
របស់អ្នកទាំងឡាយ ដូច្នេះ ។

កុំដូច្នោះឡើយ យើងនឹងនាំគ្នាធ្វើសង្គាយនាធម្មវិន័យ ដោយវិធីដែល

ព្រះសាសនានេះគប្បីតាំងនៅយូរអង្វែង ។

ម្យ៉ាងទៀត ខ្ញុំកស្សប ដែលព្រះមានព្រះភាគ ទ្រង់អនុគ្រោះដោយសាធារណបរិភោគក្នុងចីវរត្រាស់ថា

កស្សប អ្នកនឹងទ្រទ្រង់សំពត់បង្សុកូល ដែលធ្វើដោយធ្មៃរបស់តថាគត ដែលតថាគតប្រើប្រាស់ ស្លៀកដណ្តប់ហើយឬ ដូច្នេះហើយ ទ្រង់អនុគ្រោះដោយអសាធារណបរិភោគក្នុងចីវរ និងដោយការទ្រង់លើកតម្កើង ប្រៀបធៀបព្រះអង្គក្នុងឧត្តរិមនុស្សធម្ម មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ជាប្រភេទ ដោយន័យជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សបប្រាថ្នាដរាបណា ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះដរាបនោះដែរ ដូច្នេះ ភាពជាអ្នកមិនមានបំណុលដទៃណាមួយ នឹងមានដល់អាត្មាអញនោះបាន ព្រះមានព្រះភាគទ្រង់ជ្រាបអាត្មាអញថា កស្សបនេះ នឹងជាអ្នកបន្តវង្សព្រះសទ្ធម្មរបស់តថាគត ដូច្នេះហើយ ទើបទ្រង់អនុគ្រោះដោយអសាធារណានុគ្រោះនេះ ដូចព្រះរាជាទ្រង់ជ្រាបព្រះឱរសដែលនឹងបន្តវង្សរបស់ព្រះអង្គ ហើយទ្រង់អនុគ្រោះដោយទ្រង់ប្រគល់គ្រឿងគ្រោះ និងឥស្សរិយយសរបស់ព្រះអង្គដូច្នោះ មិនមែនឬ ដូច្នេះ ទើបញុំាងសេចក្តី

*ឧស្សាហ៍ឲ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីប្រារព្ធសង្គាយនាព្រះធម៌ ព្រះវិន័យ ដូចដែលព្រះអានន្ទពោលថា*

*គ្រានោះឯង ព្រះមហាកស្សប ពោលនឹងភិក្ខុទាំងឡាយថា*

*លំដាប់នោះ ព្រះមហាកស្សបដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា អាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបាវានេះ រួចហើយនឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមផ្លូវឆ្ងាយជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន ៥០០ រូប ដូច្នេះ ។*

*សុភទ្ទកណ្ឌគួរពោលឲ្យពិស្ដារទាំងអស់ បន្ទាប់អំពីនោះ ព្រះមហាកស្សបពោលថា*

*ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនានូវធម៌ និងវិន័យ តំណាទៅមុខ អកុសលធម៌មុខជានឹងរុងរឿងឡើង កុសលធម៌មុខជានឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យ មុខជានឹងរុងរឿងឡើង វិន័យមុខជានឹងសាបសូន្យទៅ តំណាទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាធម្មវាទីនឹងថយកម្លាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកម្លាំងចុះ ដូច្នេះ ។*

ភិក្ខុទាំងឡាយពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ជ្រើសរើសភិក្ខុទាំងឡាយចុះ ។ ព្រះថេរៈវៀរភិក្ខុដែលជាបុថុជ្ជន សោតាបន្ន សកទាគាមី អនាគាមី និងព្រះខីណាស្រពសុក្ខវិបស្សកៈ ដែលទ្រទ្រង់ព្រះបរិយត្តិ គឺនវង្គសត្ថុសាសនៈទាំងអស់ ច្រើនរយ ច្រើនពាន់រូប ចម្រាញ់យកចំពោះភិក្ខុដែលជាព្រះអរហន្តប្រភេទតេវិជ្ជាជាដើម ដែលទ្រទ្រង់ព្រះបរិយត្តិ គឺព្រះត្រៃបិដកទាំងអស់ សម្រេចបដិសម្ភិទា មានអានុភាពជំក្រៃលែងដោយច្រើន ដែលព្រះមានព្រះភាគ ទ្រង់តែងតាំងក្នុងភាពជាឯតទគ្គៈ ដែលព្រះ-សង្គីតិកាចារ្យបំណងពោលថា គ្រានោះឯង ព្រះមហាកស្សបជ្រើសរើសព្រះអរហន្ត ៥០០ រូប ខ្វះ ១ ដូច្នេះ ។

សួរថា ហេតុអ្វី ទើបព្រះថេរៈឲ្យខ្វះមួយរូប ។ ឆ្លើយថា ដើម្បីទុកឱកាសដល់ព្រះអានន្ទត្ថេរ ព្រោះថា រួមព្រះអានន្ទផង វៀរព្រះអានន្ទផង ក៏មិនអាចធ្វើសង្គាយនាបាន ដ្បិតថា ព្រះអានន្ទជាព្រះសេក្ខៈ នៅមានកិច្ចធ្វើនៅឡើយ ដូច្នោះ ទើបមិនអាចរួមបាន ។ តែព្រោះនវង្គសត្ថុសាសនៈ មានសុត្តៈ និងគេយ្យៈជាដើមណាមួយ ដែលព្រះទសពលទ្រង់សម្តែងហើយ ឈ្មោះថាព្រះអានន្ទមិនបានទទួលចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ មិនមាន ដូច្នោះទើបមិនអាចវៀរបាន ។ បើព្រះអានន្ទជាសេក្ខៈ ក៏គួរ ព្រះថេរៈគប្បីជ្រើសរើសព្រោះជាអ្នកមានឧបការៈច្រើនចំពោះការសង្គាយនាធម៌ តែព្រោះហេតុអ្វី ទើបព្រះថេរៈមិនជ្រើសរើស ព្រោះចៀសវាងពាក្យតិះដៀល ។ សេចក្តីពិត ព្រះថេរៈមានការស្និទ្ធស្នាលពន់ពេកក្នុងព្រះអានន្ទ ។ ពិតហើយ សូម្បីព្រះអានន្ទ

មានសីសៈស្កូវហើយ ព្រះថេរៈក៏នៅទូន្មានលោក ដោយវាទៈថា កុមារ ដូចពាក្យថា កុមារម្នាក់នេះ មិនស្គាល់ប្រមាណសោះឡើយ ម្យ៉ាងទៀត ព្រះអានន្ទនេះកើតក្នុងសក្យត្រកូល ជាព្រះអនុជរបស់ព្រះតថាគត ជាឱរសរបស់ព្រះបិតុលា ។ ក្នុងការជ្រើសរើសព្រះអានន្ទ ភិក្ខុទាំងឡាយនឹងសម្គាល់ថា លោកលម្អៀងព្រោះស្រឡាញ់ គប្បីតិះដៀលថា ព្រះថេរៈ វៀរពួកភិក្ខុដែលដល់នូវអសេក្ខប្បដិសម្ភិទាចេញ ទៅជ្រើសរើសព្រះអានន្ទ ដែលសម្រេចសេក្ខប្បដិសម្ភិទា ។ ព្រះថេរៈ កាលចៀសវាងនូវពាក្យតិះដៀលនោះ គិតថា វៀរព្រះអានន្ទចេញ ក៏មិនអាចធ្វើសង្គាយនាបាន អញនឹងជ្រើសរើស លុះណាតែភិក្ខុទាំងឡាយអនុមតិប៉ុណ្ណោះ ដូច្នេះ ទើបមិនជ្រើសរើសឯង ។

គ្រានោះ ភិក្ខុទាំងឡាយនាំគ្នាសំណូមពរព្រះថេរៈ ដើម្បីជ្រើសរើសព្រះអានន្ទ ដូចព្រះអានន្ទពោលថា

> ភិក្ខុទាំងឡាយ បានប្រាប់ព្រះមហាកស្សបយ៉ាងនេះថា បពិត្រព្រះករុណាដ៏ចម្រើន ព្រះអានន្ទមានអាយុនេះ នៅជាសេក្ខបុគ្គលពិតមែន តែលោកមិនអាចនឹងលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ ធម៌ក្តី វិន័យក្តី ព្រះអានន្ទនេះ បានសិក្សារៀនសូត្រក្នុងសម្នាក់ព្រះមានព្រះភាគជាច្រើន បពិត្រព្រះករុណាដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសយកព្រះអានន្ទមានអាយុផង ដូច្នេះ ។

ទើបព្រះថេរៈមានចំនួន ៥០០ រូប រួមទាំងព្រះអានន្ទដែលព្រះថេរៈជ្រើសរើស ដោយអនុមតិរបស់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

លំដាប់នោះ ភិក្ខុដែលជាថេរៈទាំងឡាយប្រឹក្សាគ្នាថា យើងនឹងជួយគ្នាធ្វើសង្គាយនាធម៌ និងវិន័យ ទីណាហ្ន៎ បានសម្រេចថា ធ្វើក្នុងក្រុងរាជគ្រឹះដែលមានគោចរ និងអាហារច្រើន មានសេនាសនៈច្រើន បើដូច្នោះ យើងនៅចាំវស្សា នាំគ្នាសង្គាយនាក្នុងក្រុងរាជគ្រឹះ ភិក្ខុដែលមិនបានជ្រើសរើសមិនគប្បីនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ ហេតុអ្វី ទើបភិក្ខុដែលជាថេរៈបានសម្រេចដូច្នោះ ព្រោះលោកត្រិះរិះថា ការធ្វើសង្គាយនានេះ ជាថាវរកម្មរបស់យើងបុគ្គលដែលជាវិសភាគ គប្បីចូលមកក្នុងចំណោមសង្ឃ ហើយរើថាវរកម្មនោះចេញ ។ គ្រានោះ ទើបព្រះមហាកស្សបប្រកាសដោយញត្តិទុតិយកម្ម ។ ពាក្យប្រកាសនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសង្គីតិក្ខន្ធកៈនោះឯង ។

គ្រានោះ រាប់តាំងអំពីព្រះតថាគតបរិនិព្វាន កាលការលេងសាធុកីឡាកន្លងទៅ ៧ ថ្ងៃ ការបូជាព្រះធាតុកន្លងទៅ ៧ ថ្ងៃទៀត ព្រះមហាកស្សបដឹងថា ក្នុងកាលកន្លងទៅកន្លះខែហើយ នៅសល់មួយខែកន្លះ ក៏ដល់តិថីចូលវស្សា ទើបពោលថា អាវុសោទាំងឡាយ យើងនឹងនាំគ្នាទៅក្រុងរាជគ្រឹះ ក៏នាំពួកភិក្ខុពាក់កណ្តាលធ្វើដំណើរបែកទៅផ្លូវមួយ សូម្បីព្រះអនុរុទ្ធក៏នាំពួកភិក្ខុពាក់កណ្តាលបែកទៅផ្លូវមួយ ។ ឯព្រះអានន្ទត្រេកាន់បាត្រ និងចីវររបស់ព្រះមានព្រះភាគដែលពួកភិក្ខុចោមរោម បំណងនឹងទៅក្រុងសាវត្ថី ហើយ

សឹមទៅក្រុងរាជគ្រឹះ ក៏បែកផ្លូវ ធ្វើដំណើរទៅកាន់ក្រុងសាវត្ថី ។ ក្នុងទីដែលព្រះអានន្ទត្រូវទៅដល់ ក៏មានសំឡេងខ្សឹកខ្សួល យំរៀបរាប់ថា បពិត្រលោកម្ចាស់ឈ្មោះអានន្ទ លោកម្ចាស់ទុកព្រះសាស្តានៅឯណា មកហើយ ។ លុះព្រះថេរៈដល់ក្រុងសាវត្ថីតាមលំដាប់ ក៏មានសំឡេងយំសោកដ៏ធំ ដូចក្នុងគ្រាដែលព្រះមានព្រះភាគទ្រង់បរិនិព្វាន ។

បានឮថា សម័យនោះ ព្រះអានន្ទត្រូវលួងលោមមហាជននោះ ដោយធម្មីកថាដែលប្រកបដោយការមិនទៀងជាដើម ហើយទើបចូលទៅកាន់វត្តជេតពនវិហារ បើកទ្វារព្រះគន្ធកុដិ ដែលព្រះទសពលប្រថាប់ ហើយលើកគ្រែចេញ បោសសម្អាតព្រះគន្ធកុដិ បោលសំរាម គឺផ្កាក្រៀម នាំគ្រែចូលទៅតម្រៀបទុកដូចមុន បានធ្វើវត្តបដិបត្តិគ្រប់យ៉ាងដែលគួរធ្វើ ដូចក្នុងកាលព្រះមានព្រះភាគគង់ព្រះជន្មនៅ ។

ព្រះថេរៈសង្កត់ចិត្ត ឆាន់ថ្នាំបញ្ចុះលាយដោយទឹកដោះក្នុងថ្ងៃទី ២ ដើម្បីធ្វើកាយដែលមានភាពធ្ងន់ឲ្យស្រាល ព្រោះតាំងអំពីព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ត្រូវឈរច្រើន អង្គុយច្រើន ទើបអង្គុយតែក្នុងវិហារប៉ុណ្ណោះ ដែលលោកអាងដល់ ទើបពោលនឹងបុរសដែលសុភមាណពប្រើទៅ ដូច្នេះថា

> ម្នាលមាណព កាលនេះមិន គួរ ( ទៅទេ ) ដ្បិតថ្ងៃនេះ
> យើងបានផឹកថ្នាំខ្លះទៅហើយ បើដូច្នោះ ចាំយើងពិចា-
> រណានូវកាល និងសម័យសិនហើយ សឹមទៅក្នុងថ្ងៃ
> ស្អែក ដូច្នេះ ។

ថ្ងៃទី ២ ព្រះថេរៈមានព្រះបេតកត្ថេរជាបច្ឆាសមណៈ ត្រូវសុកមាណព សួរបញ្ហា ហើយបានពោលសូត្រទី ១០ ឈ្មោះសុកសូត្រក្នុងទីឃនិកាយ ។ គ្រានោះ ព្រះថេរៈឲ្យសុកមាណពជួយជួសជុលវត្តដែលបាក់បែក ក្នុងជេតពនវិហារ កាលទៀបនឹងចូលវស្សា ទើបទៅកាន់ក្រុងរាជគ្រឹះ ។ ព្រះមហាកស្សបត្ថេរ និងព្រះអនុរុទ្ធត្ថេរក៏យ៉ាងនោះ នាំពួកភិក្ខុទាំងអស់ទៅកាន់ក្រុងរាជគ្រឹះដូចគ្នា ។

សម័យនោះ ក្នុងក្រុងរាជគ្រឹះមានវត្តធំៗ ១៨ កន្លែង វត្តទាំងអស់មានសំរាម ដែលគេចោលចាត់រាត់រាយពេញទាំងអស់ ព្រោះក្នុងកាលព្រះមានព្រះភាគបរិនិព្វាន ភិក្ខុទាំងឡាយកាន់បាត្រចីវររបស់ខ្លួន បោះបង់វត្ត និងបរិវេណ និមន្តទៅអស់ កាលនោះ ព្រះថេរៈទាំងឡាយគិតគ្នាថា យើងនឹងនាំគ្នាជួសជុលវិហារដែលទ្រុឌទ្រោម មួយខែដំបូងនៃវស្សា ដើម្បីបូជាព្រះពុទ្ធតម្រាស់ និងដោះពាក្យតិះដៀលរបស់ពួកតិរ្ថិយ ដ្បិតថា ពួកតិរ្ថិយនាំគ្នាតិះដៀលថា ពួកសាវករបស់ព្រះគោតម កាលសាស្តានៅមានជីវិត ក៏នាំគ្នាទំនុកបម្រុង លុះព្រះសាស្តាបរិនិព្វានហើយ ក៏នាំគ្នាបោះបង់ទៅ ។ លោកអធិប្បាយថា ព្រះថេរៈទាំងឡាយគិតគ្នាដូច្នោះ ដើម្បីដោះពាក្យតិះដៀលរបស់ពួកតិរ្ថិយទាំងនោះ ។ សមដូចលោកពោលថា

គ្រានោះ ភិក្ខុទាំងឡាយជាថេរៈ មានសេចក្តីត្រិះរិះដូច្នេះ
ថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុល
សេនាសនៈ ដែលបែកបាក់ធ្លុះធ្លាយ ព្រះមានព្រះភាគ

ទ្រង់សរសើរហើយ ម្នាលអាវុសោ បើដូច្នោះ គួរតែយើងរាល់គ្នាជួសជុលសេនាសនៈ ដែលបែកបាក់ចុះ ធ្លាយ អស់ខែមួយដំបូងសិន ដល់មកខែកណ្ដាល យើងនឹងប្រជុំគ្នាធ្វើសង្គាយនានូវធម៌ និងវិន័យ ដូច្នេះ ។

ថ្ងៃទី ២ ព្រះថេរៈទាំងនោះ នាំគ្នាទៅឈរក្បែរទ្វារព្រះរាជនិវេសន៍ ព្រះបាទអជាតសត្រូវ ទ្រង់យាងមកថ្វាយបង្គំ ហើយបវារណាថា បពិត្រលោកម្ចាស់ ញោមអាចជួយអ្វីបានខ្លះ លោកម្ចាស់ទាំងឡាយត្រូវការអ្វី ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរសុំហត្ថកម្ម ដើម្បីធ្វើការជួសជុលវត្តធំៗ ១៨ កន្លែង ព្រះរាជាទ្រង់ទទួលថា សាធុ ហើយព្រះរាជទានមនុស្ស ដែលជាជាងមានថ្វីដៃ ។ ព្រះថេរៈទាំងឡាយឲ្យជួសជុលវិហារអស់ក្នុងមួយខែដំបូង បន្ទាប់មក ទើបក្រាបទូលព្រះរាជាថា សូមថ្វាយព្រះពរ ការជួសជុលវិហារស្រេចហើយ ឥឡូវនេះ ពួកអាត្មានឹងនាំគ្នាធ្វើសង្គាយនាធម៌ និងវិន័យ ។ ព្រះរាជាមានព្រះតម្រាស់ថា សាធុ សូមលោកម្ចាស់ ធ្វើដោយសប្បាយចិត្តចុះ អាណាចក្រសូមជាធុរៈរបស់ញោម ឯធម្មចក្រ ជាធុរៈរបស់លោកម្ចាស់ ហើយសូមប្រាប់មកចុះ តើឲ្យញោមជួយអ្វី ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរថា សូមមហារាជឲ្យសាងទីប្រជុំ សម្រាប់ភិក្ខុទាំងឡាយ ដែលជួយគ្នាធ្វើសង្គាយនាធម៌ ។ ត្រាស់សួរថា នឹងធ្វើត្រង់ណាលោកម្ចាស់ ។ ព្រះថេរៈប្រាប់ថា ធ្វើក្បែរទ្វារគុហាសត្តបណ្ណិ ក្បែរភ្នំវេភារៈ ទើបសមគួរមហាបពិត្រ ។ ព្រះបាទអជាតសត្តុទូលថា សាធុ ហើយឲ្យសាងមណ្ឌបធំ មាន

ជញ្ជាំងសសរ និងជណ្តើរ រៀបចំយ៉ាងល្អ វិចិត្រដោយផ្កា និងភ្ញីវល្លិច្រើនប្រភេទ ដូចវេស្សកម្មទេវបុត្រនិម្មិត មណ្ឌបធំនោះ មានពិតានមាស លម្អដោយកម្រងផ្កាច្រើនប្រភេទ ដែលដាក់សំយុង នៅត្រង់ផែនដី ក៏ពង្រាបឲ្យស្មើល្អ ។ លម្អដោយផ្កាបូជាច្រើនប្រភេទ ប្រៀបដូចផ្លូវដើរដែលប្រដាប់ដោយកម្រាលកែវមណីរ័តន៍ វិចិត្រដូចវិមានព្រហ្ម ឲ្យក្រាលអាសនៈដែលជាកប្បិយ ៥០០ ដែលមានតម្លៃកាត់ថ្លៃមិនបាន ក្នុងមហាមណ្ឌបនោះ សម្រាប់ភិក្ខុ ៥០០ រូប ឲ្យក្រាលអាសនៈព្រះថេរៈ បែរមុខទៅទិសខាងជើង បែរខ្នងទៅទិសខាងត្បូង ឲ្យក្រាលធម្មាសនៈដែលអន្កយសម្តែងធម៌ ដែលគួរជាអាសនៈសម្រាប់ព្រះមានព្រះភាគ ត្រង់កណ្តាលមណ្ឌប បែរមុខទៅទិសខាងកើត ដាក់ផ្លិតដែលមានជងរចនាអំពីភ្លុកលើធម្មាសនៈនោះ ហើយផ្ញើដល់ភិក្ខុសង្ឃឲ្យជ្រាបថា កិច្ចកម្មសម្រេចហើយ ។

ភិក្ខុទាំងឡាយ ពោលនឹងព្រះអានន្ទថា អាវុសោអានន្ទ ស្អែកនេះ ជាថ្ងៃប្រជុំសង្ឃ ខ្លួនអ្នកជាសេក្ខៈ មានកិច្ចដែលត្រូវធ្វើ ដោយហេតុនោះ ទើបអ្នកមិនគួរទៅប្រជុំ ចូរអ្នកកុំប្រមាទ ។ គ្រានោះ ព្រះអានន្ទត្រិះរិះថា ស្អែកនេះ ជាថ្ងៃប្រជុំ ការដែលអញជាសេក្ខៈទៅប្រជុំ មិនសមគួរឡើយ ដូច្នេះ ទើបព្យាយាមដោយកាយគតាសតិអស់រាត្រីដ៏យូរ ក្នុងកាលទៀបភ្លឺ ទើបចុះអំពីទីចង្ក្រម ចូលទៅកាន់វិហារ ពិចារណាដល់កាយ បំណងនឹងសិងសម្រាក ។ ជើងទាំង ២ ផុតផែនដី សីសៈមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តក៏មិនប្រកាន់មាំ រួចផុតចាកអាសវៈទាំងឡាយ ។

ពិតហើយ ព្រះអានន្ទនេះ ព្យាយាមខាងក្រៅដោយការចង្ក្រម មិនអាចធ្វើគុណវិសេសឲ្យកើតបាន ទើបត្រិះរិះថា ព្រះមានព្រះភាគបានត្រាស់នឹងអញមិនមែនឬថា អានន្ទ អ្នកមានបុណ្យធ្វើទុកហើយ ចូរប្រកបព្យាយាមរឿយៗ អ្នកនឹងជាបុគ្គលមិនមានអាសវៈបានដោយឆាប់រួសរាន់ ធម្មតា ព្រះសម្ពុទ្ធទាំងឡាយត្រាស់មិនដែលខុស អាត្មាអញប្រារព្ធព្យាយាមពេក ដោយហេតុនោះ ទើបចិត្តប្រព្រឹត្តទៅក្នុងការរាយមាយ ណ្ហើយចុះ អញនឹងប្រកបព្យាយាមតែល្មមប្រមាណ ទើបចុះអំពីទីចង្ក្រម ឈរក្នុងទីលាងជើងៗ ហើយក៏ចូលវិហារ អង្គុយលើគ្រែ គិតនឹងសម្រាកបន្តិច ក៏ទម្រេតកាយលើគ្រែ ជើងទាំង ២ ផុតដី ក្បាលមិនទាន់ដល់ខ្នើយ ក្នុងចន្លោះនោះ ចិត្តមិនប្រកាន់មាំ ក៏ផុតចាកអាសវៈទាំងឡាយ ។ អរហត្តរបស់ព្រះថេរៈវៀរចាកឥរិយាបថទាំង ៤ ដោយហេតុនោះ កាលសួរថា ក្នុងព្រះសាសនានេះ ភិក្ខុអង្គណា មិនអង្គុយ មិនដេក មិនឈរ មិនដើរ សម្រេចអរហត្ត ក៏គួរឆ្លើយថា គឺព្រះអានន្ទត្ថេរ ។

ក្នុងថ្ងៃទី ២ ភិក្ខុជាថេរៈទាំងឡាយឆាន់ភត្តាហារ ទុកដាក់បាត្រចីវរហើយ ក៏ប្រជុំគ្នាក្នុងធម្មសភា ឯព្រះអានន្ទត្ថេរបំណងនឹងឲ្យសង្ឃដឹងការសម្រេចអរហត្តរបស់ខ្លួន ទើបមិនទៅព្រមជាមួយភិក្ខុទាំងឡាយៗ កាលអង្គុយលើអាសនៈ ដែលសមគួរវៀងៗ ខ្លួន ក៏អង្គុយវៀរអាសនៈរបស់ព្រះអានន្ទត្ថេរ ក្នុងពេលនោះ កាលព្រះថេរៈពួកខ្លះសួរថា នុ៎ះអាសនៈរបស់អ្នកណា ក៏មានសំឡេងឆ្លើយថា របស់ព្រះអានន្ទ សួរថា ព្រះអានន្ទទៅណា សម័យនោះ

*ព្រះថេរៈត្រិះរិះថា ឥឡូវនេះ ជាកាលដែលអាត្មាអញគួរទៅ ។ ដូច្នេះ កាលសម្តែងអានុភាពរបស់ខ្លួន ទើបមុជចុះក្នុងផែនដី បង្ហាញខ្លួនលើអាសនៈនោះឯង អាចារ្យពួកខ្លះពោលថា មកតាមអាកាសក៏មាន ។*

*កាលព្រះអានន្ទអង្គុយស្រេចបាច់ ទើបព្រះមហាកស្សបត្ថេរប្រឹក្សានឹងភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ យើងនឹងសង្គាយនាអ្វីមុន តើធម៌ ឬវិន័យ ។*

*ភិក្ខុទាំងឡាយប្រាប់ថា បពិត្រមហាកស្សប ធម្មតាវិន័យជាអាយុរបស់សាសនា បើវិន័យតាំងនៅ សាសនាក៏ឈ្មោះថា តាំងនៅដែរ ព្រោះដូច្នោះ យើងនឹងសង្គាយនាវិន័យមុន ។ ព្រះថេរៈសួរថា ប្រគល់ឲ្យជាធុរៈដល់នរណាសង្គាយនាវិន័យហ្ន៎ ភិក្ខុទាំងឡាយប្រាប់ថា គឺព្រះឧបាលី ។ ព្រះថេរៈសួរជំទាស់ថា ព្រះអានន្ទមិនអាចឬ ភិក្ខុទាំងឡាយប្រាប់ថា មិនមែនមិនអាចទេ តែព្រះសម្មាសម្ពុទ្ធកាលគង់ព្រះជន្មនៅ អាស្រ័យការរៀនបរិយត្តិរបស់លោក ទើបទ្រង់ស្ថាបនាព្រះឧបាលី ទុកក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ស្រេចនឹងឧបាលី ដូច្នេះ ព្រោះដូច្នោះ យើងនឹងសួរព្រះឧបាលិត្ថេរសង្គាយនាវិន័យ ។ បន្ទាប់អំពីនោះ ទើបព្រះថេរៈសន្មតដោយខ្លួនឯង ដើម្បីសួរវិន័យ ឯព្រះឧបាលិត្ថេរក៏សន្មតខ្លួន ដើម្បីឆ្លើយវិន័យក្នុងសេចក្តីនោះ មានបាលីដូច្នេះថា គ្រានោះ ព្រះមហាកស្សបត្ថេរផ្សៀងសង្ឃថា*

**សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ ឧបាលី វិនិយំ បុច្ឆេយ្យំ** *អ្នកដ៏មានអាយុទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ បើ*

*សង្ឃីតិកម្មនេះ មានកាលសមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យ នឹងឧបាលិ ។ សូម្បីព្រះឧបាលីក៏ផ្ទៀងសង្ឃថា*

**សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន វិនយំ បុដ្ឋោ វិសជ្ជេយ្យំ** *បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្គីតិកម្មនេះ មានកាលសមគួរដល់សង្ឃហើយ លោកម្ចាស់កស្សបត្រូវសួរព្រះវិន័យចំពោះខ្ញុំ ខ្ញុំក៏ត្រូវដោះស្រាយក្នុងកាលឥឡូវនេះ ។*

*ឯព្រះឧបាលីកាលសន្មតខ្លួន ដោយខ្លួនឯងយ៉ាងនេះហើយ ក៏ក្រោកចាកអាសនៈ ដណ្តប់ចីវរ ថ្វាយបង្គំភិក្ខុដែលជាថេរៈ ហើយអង្គុយលើធម្មាសនៈ ចាប់ផ្លិតភ្លុក បន្ទាប់អំពីនោះ ទើបព្រះមហាកស្សបត្ថេរសួរវិន័យទាំងអស់តាំងអំពីបឋមបារាជិកជាដើមទៅ ជាមួយនឹងព្រះឧបាលិត្ថេរ ។ ព្រះឧបាលិត្ថេរ ក៏ឆ្លើយ ភិក្ខុទាំងអស់ ៥០០ រូប ក៏សូធ្យព្រមៗ គ្នា តាំងអំពីបឋមបារាជិកសិក្ខាបទ ព្រមទាំងនិទានទៅ សូម្បីសិក្ខាបទក្រៅអំពីនោះ ក៏សូធ្យទាំងអស់ ព្រោះហេតុនោះ គប្បីកាន់យករឿងទាំងអស់តាមអដ្ឋកថាព្រះវិន័យ ។ ព្រះឧបាលិត្ថេរកាលសង្គាយនាព្រះវិនយបិដកទាំងមូល ព្រមទាំងឧភតោវិភង្គ មួយអន្ទើដោយគម្ពីរខន្ធកៈ និងបរិវារ ដោយន័យនេះហើយ ក៏ដាក់ផ្លិតភ្លុក ចុះអំពីធម្មាសនៈ ថ្វាយបង្គំភិក្ខុចាស់ ហើយអង្គុយលើអាសនៈ ដែលសមគួរដល់ខ្លួន ។*

*ឯព្រះមហាកស្សបត្ថេរកាលសង្គាយនាវិន័យ ហើយបំណងនឹងសង្គាយនាព្រះធម៌ ទើបសួរភិក្ខុទាំងឡាយថា អ្នកទាំងឡាយ កាលនឹងសង្គាយនាធម៌*

នឹងប្រគល់ធុរៈដល់អ្នកណា ភិក្ខុទាំងឡាយប្រាប់ថា ជាធុរៈដល់ព្រះអានន្ទ គ្រានោះ ទើបព្រះមហាកស្សបផ្តៀងសង្ឃថា

**សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អានន្ទំ ធម្មំ បុច្ឆេយ្យំ** បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្ម មានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះអានន្ទដ៏មានអាយុ ។ គ្រានោះ ព្រះអានន្ទក៏ផ្តៀងសង្ឃថា

**សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន ធម្មំ បុដ្ឋោ វិសជ្ជេយ្យំ** បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរដល់សង្ឃហើយ លោកម្ចាស់មហាកស្សបនឹងសួរធម៌ចំពោះខ្ញុំ ខ្ញុំគប្បីឆ្លើយក្នុងកាលឥឡូវនេះ ដូច្នេះ ។

គ្រានោះ ព្រះអានន្ទក្រោកចាកអាសនៈ ដណ្តប់ចីវរឆៀងស្មាម្ខាង ថ្វាយបង្គំភិក្ខុចាស់ ហើយក៏អង្គុយលើធម្មាសនៈ កាន់ផ្លិតភ្លុក ។ លំដាប់នោះ ព្រះមហាកស្សបត្ថេរសួរធម៌ដល់ព្រះអានន្ទថា អានន្ទ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគត្រាស់ក្នុងទីណា ។ ឆ្លើយថា ត្រាស់ក្នុងដំណាក់ ក្នុងព្រះរាជ-ឧទ្យាន ឈ្មោះអម្ពលដ្ឋិកា ដែលនៅចន្លោះក្រុងរាជគ្រឹះ និងស្រុកនាលន្ទា ។ សួរថា ទ្រង់ប្រារព្ធអ្នកណា ។ ឆ្លើយថា ទ្រង់ប្រារព្ធសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។ គ្រានោះ ព្រះមហាកស្សបសួរព្រះអានន្ទដល់និទាននៃព្រហ្មជាលសូត្រ សួរដល់បុគ្គល ។ សួរថា អានន្ទ សាមញ្ញផលសូត្រទ្រង់ត្រាស់ក្នុងទីណា ។ ឆ្លើយថា ត្រង់ចម្ការស្វាយរបស់ពេទ្យជីវក ក្រុង

រាជគ្រឹះ ។ សួរថា ត្រាស់ជាមួយអ្នកណា ។ ឆ្លើយថា ជាមួយព្រះបាទអជាតសត្តុវេទេហិបុត្រ ។ លំដាប់នោះ ទើបព្រះមហាកស្សបសួរព្រះអានន្ទដល់និទាននៃសាមញ្ញផលសូត្រផង សួរដល់បុគ្គលផង ។ ព្រះមហាកស្សបសួរទាំង ៥ និកាយ ដោយឧបាយនេះឯង ។ ព្រះអានន្ទត្រូវសួរហើយសួរទៀត ក៏ឆ្លើយបានទាំងអស់ បឋមមហាសង្គីតិដំបូងនេះ ព្រះថេរៈ ៥០០ រូបនាំគ្នាធ្វើ ។ ដូចដែលលោកពោលថា

**សតេហិ បញ្ចហិ កតា តេន បញ្ចសតាតិ ច**
**ថេរេហេវ កតត្តា ច ថេរិកាតិ បវុច្ចតិ ។**

បឋមសង្គីតិ កាលធ្វើសង្គាយនាធំគ្រាដំបូង ដែលព្រះថេរៈ ៥០០ រូបនាំគ្នាធ្វើ ដោយហេតុនោះ ទើបលោកហៅថា **បញ្ចសតា** និងព្រោះភិក្ខុទាំងនោះ សុទ្ធតែជាព្រះថេរៈទាំងអស់ ទើបហៅថា **ថេរិកា** គឺលទ្ធិថេរវាទ ។

កាលបឋមមហាសង្គីតិនេះកំពុងប្រព្រឹត្តទៅ កាលព្រះអានន្ទ ដែលព្រះមហាកស្សប កាលសួរគម្ពីរទីឃនិកាយ និងគម្ពីរមជ្ឈិមនិកាយជាដើមអស់ហើយ កាលនឹងសួរគម្ពីរខុទ្ទកនិកាយតាមលំដាប់ ក្នុងចុងពាក្យដែលលោកសួរជាដើមយ៉ាងនេះថា អាវុសោ អានន្ទ មង្គលសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ក្នុងទីណា ដូច្នេះ ទើបសួរដល់និទានក្នុងពាក្យនេះថា សួរទាំងនិទានសួរទាំងបុគ្គល ។ ព្រះអានន្ទបំណងនឹងពោលនិទាននោះឲ្យពិស្តារថា ត្រាស់ដូចម្តេច អ្នកណាស្តាប់មក ស្តាប់ក្នុងកាលណា និងអ្នកណាពោល ពោលទីណា ពោលដល់អ្នកណា នឹងពោលសេចក្តីនោះឲ្យអស់ កាលនឹងសម្តែង

សេចក្តីនោះថា ត្រាស់យ៉ាងនេះ ខ្ញុំស្តាប់មក ស្តាប់មកសម័យមួយ ព្រះមានព្រះភាគត្រាស់ ត្រាស់ត្រង់ក្រុងសាវត្ថី ត្រាស់ដល់ទេវតា ដូច្នេះ ទើបពោលថា **ឯវម្មេ សុតំ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។បេ។ ភគវន្តំ គាថាយ អជ្ឈភាសិ ។** ពាក្យនេះ ព្រះអានន្ទពោលយ៉ាងនេះ ។ ឯពាក្យនោះ គប្បីជ្រាបថា លោកពោលក្នុងកាលធ្វើបឋមមហាសង្គីតិ ។

ឥឡូវនេះ នឹងអធិប្បាយក្នុងសេចក្តីនេះថា ត្រាស់ព្រោះហេតុអ្វី ។ ព្រោះហេតុដែលព្រះមហាកស្សបសួរដល់និទាន ដូច្នោះ ទើបលោកពោលនិទាននោះឲ្យពិស្តារតាំងអំពីដើម ម្យ៉ាងទៀត ព្រោះទេវតាខ្លះឃើញព្រះអានន្ទអង្គុយលើធម្មាសនៈ ចោមរោមដោយគណៈដែលជំនាញ ទើបកើតចិត្តគិតថា ព្រះអានន្ទនេះ ជាវេទេហមុនី សូម្បីដោយប្រក្រតី រាប់ត្រឹមតែនៅក្នុងសក្យត្រកូល ជាទាយាទរបស់ព្រះមានព្រះភាគ តែព្រះមានព្រះភាគទ្រង់សរសើរទុកក្នុងតំណែងឯតទគ្គៈដល់ទៅ ៥ ស្ថាន ជាអ្នកប្រកបដោយអច្ឆរិយអព្ភូតធម៌ ៤ ប្រការ ជាទីស្រឡាញ់ពេញចិត្តរបស់បរិស័ទ ៤ ឥឡូវនេះ ប្រហែលជាទាយាទដោយធម៌របស់ព្រះមានព្រះភាគ កើតជាពុទ្ធៈ ។

ដូច្នោះ ព្រះអានន្ទដឹងទូទៅ ដល់ការត្រិះរិះផ្លូវចិត្តរបស់ទេវតាទាំងនោះដោយចិត្តរបស់ខ្លួន អត់ធន់នឹងការសរសើរគុណដែលមិនមានពិតនោះមិនបាន ដើម្បីសម្តែងភាវៈដែលខ្លួនត្រឹមតែជាសាវក ទើបពោលថា **ឯវម្មេ សុតំ ឯកំ សមយំ ភគវា ។បេ។ អជ្ឈភាសិ ។** ក្នុងចន្លោះនេះ ព្រះអរហន្ត ៥០០

រូប និងទេវតាច្រើនពាន់ ក៏សរសើរព្រះអានន្ទថា សាធុ សាធុ មហាប្រឹថពី ក៏កម្រើកញាប់ញ័រ ភ្លៀងផ្កាច្រើនប្រភេទក៏រោយចុះមកអំពីអាកាស ការអស្ចារ្យដទៃក៏ប្រាកដច្រើន ទេវតាជាច្រើនកើតនូវសេចក្តីសង្វេគថា ពាក្យណា ខ្ញុំស្តាប់មកចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ពាក្យនោះ សូម្បីហេតុ-ការណ៍កន្លងផុតទៅក្រែកមកហើយ ក៏មកកើតបាន ។ ពាក្យនេះ ព្រះអានន្ទពោលក្នុងកាលធ្វើបឋមមហាសង្គីតិ គប្បីជ្រាបថា លោកពោលព្រោះហេតុនេះ ដោយប្រការដូច្នេះ ។ ដោយកិច្ចពណ៌នាមក មានប្រមាណប៉ុណ្ណេះ ក៏ឈ្មោះថា ប្រកាសអត្ថកន្ទះគាថានេះថា **វុត្តំ យេន យទា យស្មា ចេតំ វត្វា ឥមំ វិធឹ** ពោលវិធីនេះថា បុគ្គលណាពោល ពោលក្នុងកាលណា ពោលព្រោះហេតុអ្វី ។

## ពណ៌នាបាឋៈថា ឯវំ ជាដើម

ដើម្បីប្រកាសភាពដែលរួបរឹតដោយមាតិកាជាដើមយ៉ាងនេះថា **ឯវមិច្ចា-ទិបាឋស្ស អត្ថំ នានប្បការតោ** សេចក្តីនៃបាឋៈថា **ឯវំ** ជាដើម ដោយប្រការផ្សេងៗ ឥឡូវនេះ សូមអធិប្បាយដូច្នេះ សព្ទថា **ឯវំ** នេះ គប្បីឃើញថា

ប្រើក្នុងអត្ថទាំងឡាយ មានអត្ថជាដើមថា ឧបមា គឺប្រៀបធៀប ឧបទេស គឺណែនាំ សម្បហំសនៈ គឺលើកសរសើរ គរហណៈ គឺតិះដៀល វចនសម្បដិគ្គហណៈ គឺទទួលពាក្យ អាការ គឺអាការ និទស្សនៈ គឺឧទា-ហរណ៍ និងអវធារណៈ គឺរាំងសេចក្តីដទៃ ។

ពិតហើយ **ឯវំ** សព្ទនេះ ប្រើក្នុងការប្រៀបធៀប ដូចក្នុងប្រយោគជាដើមថា **ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ** កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ដូច្នេះ ។

ប្រើក្នុងអត្ថថា ណែនាំ ដូចក្នុងប្រយោគជាដើមថា **ឯវន្តេ អភិក្កមិតព្វំ ឯវំ បដិក្កមិតព្វំ** អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ ដូច្នេះ ។

ប្រើក្នុងអត្ថថា លើកសរសើរ ដូចក្នុងប្រយោគជាដើមថា **ឯវមេតំ ភគវា ឯវមេតំ សុគត** បពិត្រព្រះដ៏មានព្រះភាគ ហេតុនុ៎ះ យ៉ាងនេះហើយ បពិត្រព្រះសុគត ហេតុនុ៎ះ យ៉ាងនេះហើយ ដូច្នេះ ។

ប្រើក្នុងអត្ថថា តិះដៀល ដូចក្នុងប្រយោគជាដើមថា **ឯវមេវ បនាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស វណ្ណំ ភាសតិ** មេចង្រៃនេះធ្លាប់តែអ៊ីចឹងៗ ហ៊ានពោលសរសើរសមណៈត្រងោលក្នុងទីផ្តេសផ្តាស ដូច្នេះ ។

ប្រើក្នុងអត្ថថា ទទួលពាក្យ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទទួលពាក្យនៃព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះ ។

ប្រើក្នុងអត្ថថា អាការ ដូចក្នុងប្រយោគជាដើមថា **ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ** ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយក៏យ៉ាងនោះដែរ ដូច្នេះ ។

ប្រើក្នុងអត្ថថា ឧទាហរណ៍ ដូចក្នុងប្រយោគជាដើមថា **ឯហិ ត្វំ មាណវក**

**យេន សមណោ អានន្ទោ ។បេ។ អនុកម្បំ ឧបាទាយ** ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈឈ្មោះអានន្ទ លុះចូលទៅដល់ហើយ ចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំងនៅជាសុខសប្បាយ នឹងព្រះសមណៈ ឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ផ្តាំឲ្យសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយ ចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយ ឯងចូរនិមន្តថា សូមលោកម្ចាស់អានន្ទ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ដូច្នេះ ។

ប្រើក្នុងអត្ថថា រាវរកសេចក្តីដទៃ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **តំ កឹ មញ្ញថ កាលាមា ។បេ។ ឯវំ នោ ឯត្ថ ហោតិ** ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសល ព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោស ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះ ដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ

យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នោះដែរ ដូច្នេះ ។

តែក្នុងទីនេះ **ឯវំ** សព្ទ គប្បីឃើញថា ប្រើក្នុងអត្ថ គឺអាការ ឧទាហរណ៍ និងភាពាំងសេចក្ដីដទៃ ។

ក្នុងអត្ថទាំង ៣ នោះ ព្រះថេរៈសម្ដែងអត្ថនេះ ដោយ **ឯវំ** សព្ទ ដែលមានអត្ថជាអាការថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ល្អិតដោយន័យផ្សេងៗ ដែលកើតឡើង ដោយច្រើនអធ្យាស្រ័យសម្បូរដោយអត្ថ និងព្យញ្ជនៈ មានបាដិហារ្យផ្សេងៗ ជ្រាលជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ មកប៉ះខ្ទប់សោតៈ ល្មមសមគួរដល់ភាសារៀងៗ ខ្លួនរបស់សព្វសត្វទាំងឡាយ អ្នកណាអាចដឹងបាន ដោយប្រការទាំងពួង តែខ្ញុំសូម្បីប្រើកម្លាំងទាំងអស់ឲ្យកើតការចង់ស្ដាប់ បានស្ដាប់មកយ៉ាងនេះ គឺខ្ញុំក៏បានស្ដាប់មកហើយ ដោយអាការណាមួយ ។

ដោយ **ឯវំ** សព្ទ ដែលមានអត្ថជាឧទាហរណ៍ ព្រះថេរៈកាលដោះខ្លួនថា ខ្ញុំមិនមែនព្រះសយម្ភូ ព្រះសូត្រនេះ ខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ ទើបសម្ដែងព្រះសូត្រទាំងមូល ដែលគួរពោលក្នុងឥឡូវនេះថា **ឯវម្មេ សុតំ** គឺខ្ញុំបានស្ដាប់មកយ៉ាងនេះ ។

ដោយ **ឯវំ** សព្ទ ដែលមានសព្ទជា ភាពាំងសេចក្ដីដទៃ ព្រះថេរៈកាលសម្ដែងកម្លាំង គឺការចងចាំរបស់ខ្លួន ដែលគួរដល់ការៈ ដែលព្រះមានព្រះភាគទ្រង់សរសើរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អានន្ទ ជាកំពូលសាវករបស់តថាគតដែលជាពហុស្សុត មានគតិ មានសតិ មានធិតិ ពុទ្ធុបដ្ឋាក ដូច្នេះ

រមែងឲ្យកើតនូវការចង់ស្ដាប់ដល់សត្វទាំងឡាយ ដ្បិតថា ខ្ញុំស្ដាប់មកហើយយ៉ាងនេះ ពាក្យនោះ មិនខ្វះ មិនលើស ទោះជាដោយអត្ថ ឬព្យញ្ជនៈ បណ្ឌិតគប្បីឃើញយ៉ាងនេះប៉ុណ្ណោះ មិនគប្បីឃើញដទៃឡើយ ។

## អធិប្បាយសព្ទថា មេ

មានអត្ថ ៣ យ៉ាង ។ ពិតហើយ **មេ** សព្ទ មានអត្ថថា **មយា** ដែលខ្ញុំ ដូចក្នុងប្រយោគជាដើមថា **គាថាភិគីតម្មេអភោជនេយ្យំ** ភោជនដែលតថាគតពោលហើយដោយគាថា ( ច្រៀង ) ជាវត្ថុមិនគួរដល់ការបរិភោគទេ ។

មានអត្ថថា **មយ្ហំ** គឺដល់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមអង្វរ សូមព្រះមានព្រះភាគសម្ដែងធម៌ដោយសង្ខេបដល់ខ្ញុំ ។

មានអត្ថថា **មម** គឺរបស់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា **ធម្មទាយាទា មេ ភិក្ខវេ ភវថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌កចុះ តែក្នុងទីនេះ **មេ** សព្ទ រមែងពាល់ត្រូវក្នុងអត្ថទាំង ២ គឺ **មេ សុតំ** ប្រែថា ដែលខ្ញុំស្ដាប់មក និង **មម សុតំ** ការស្ដាប់របស់ខ្ញុំ ។

## អធិប្បាយបទថា សុតំ

**សុត** សព្ទនេះ មានឧបសគ្គ និងមិនមានឧបសគ្គ ផ្សេងគ្នាដោយច្រើនអត្ថ ដូចជាមានអត្ថថា ទៅ ប្រាកដ តម្រេក សន្សំ ខ្វល់ខ្វាយ សំឡេងដែលប្រាកដតាមសោតៈ និងដឹងតាមសោតទ្វារជាដើម ។ ពិតហើយ **សុត** សព្ទនោះ មានអត្ថថា ទៅ ដូចក្នុងប្រយោគជាដើមថា **សេនាយ បសុតោ** ទៅ

ហើយដោយសេនា ។

មានអត្ថថា ប្រាកដ ដូចក្នុងប្រយោគជាដើមថា **សុតធម្មស្ស បស្សតោ** បុគ្គលមានធម៌ស្តាប់ហើយ បានឃើញច្បាស់ ។

មានអត្ថថា តម្រេក ដូចក្នុងប្រយោគជាដើមថា **អវស្សុតា អវស្សុ-តស្ស** ( សុន្ទរីនន្ទាជាម្ចាស់ ) មានតម្រេក មិនគួរនឹងត្រេកអរឲ្យបុរសបុគ្គលដែលមានតម្រេក ... ដូច្នេះ ។

មានអត្ថថា សន្សំ ដូចក្នុងប្រយោគជាដើមថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** បុណ្យ ឈ្មោះថា បានសន្សំ មិនមែនតិចឡើយ ។

មានអត្ថថា ខ្វល់ខ្វាយ ដូចក្នុងប្រយោគជាដើមថា **យេ ឈានបសុតា ធីរា** អ្នកប្រាជ្ញពួកណា ជាអ្នកប្រកបរឿយៗ ( ខ្វល់ខ្វាយ ) ក្នុងឈាន ។

មានអត្ថថា សំឡេងដែលដឹងតាមត្រចៀក ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋំ សុតំ មុតំ** រូបដែលឃើញ សំឡេងដែលបានឮ អារម្មណ៍ដែលដឹង ។

មានអត្ថថា ដឹងតាមសោតទ្វារ ដូចក្នុងប្រយោគជាដើមថា **សុតធរោ សុតសន្និចយោ** ( ភិក្ខុក្នុងសាសនានេះ ) ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ។

តែក្នុងទីនេះ សព្ទថា **សុត** ព្រោះអត្ថថា ចូលទៅទ្រទ្រង់ ឬការទ្រទ្រង់ដោយវិថីវិញ្ញាណ មានសោតវិញ្ញាណជាប្រធាន ក្នុងពាក្យនោះ កាលណា **មេ** សព្ទ មានសេចក្តីថា **មយា** ប្រែថា ដែលខ្ញុំកាលនោះ ប្រកបសេចក្តីថា ដែលខ្ញុំស្តាប់មកហើយ គឺទ្រទ្រង់ចាំហើយដោយវិថីវិញ្ញាណ ដែលមាន

សោតវិញ្ញាណជាប្រធានយ៉ាងនេះ ។ កាលណា **មេ** សព្ទ មានសេចក្ដីថា **មម** គឺរបស់ខ្ញុំ កាលនោះក៏ប្រាកដសេចក្ដីថា ការស្ដាប់របស់ខ្ញុំ គឺការទ្រទ្រង់ចាំដោយវិថីវិញ្ញាណ ដែលមានសោតវិញ្ញាណជាប្រធាន ។

បណ្ដាបទទាំង ៣ នោះ ដូចពណ៌នាមកនេះ បទថា **ឯវំ** ជាបទចង្អុលដល់កិច្ច គឺនាទីរបស់សោតវិញ្ញាណ ។ បទថា **មយា** គឺបទដែលសម្ដែងដល់បុគ្គលដែលប្រកបសោតវិញ្ញាណដែលពោលហើយ ។ បទថា **សុតំ** ជាបទដែលចង្អុលដល់ការកាន់យកមិនខ្វះ មិនលើស និងមិនវិបរិត ព្រោះបដិសេធភាវៈ គឺការមិនបានស្ដាប់ ។

ន័យម្យ៉ាងទៀត បទថា **ឯវំ** ជាបទសម្ដែងដល់ភាវៈដែលចិត្ត មានចិត្តគិតនឹងស្ដាប់ជាដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយប្រការផ្សេងៗ ។ បទថា **មេ** ជាបទសម្ដែងដល់ខ្លួន ។ បទថា **សុតំ** ជាបទសម្ដែងដល់ធម៌ ។

ន័យម្យ៉ាងទៀត បទថា **ឯវំ** ជាបទចង្អុលបង្ហាញធម៌ដែលគួរចង្អុលបង្ហាញ ។ បទថា **មេ** ជាបទចង្អុលបង្ហាញតួបុគ្គល ។ បទថា **សុតំ** ជាបទចង្អុលបង្ហាញកិច្ចរបស់បុគ្គល ។

ន័យម្យ៉ាងទៀត បទថា **ឯវំ** អធិប្បាយដល់ប្រការផ្សេងៗ នៃវិថីចិត្តទាំងឡាយ ជាអាការបញ្ញត្តិ ។ សព្ទថា **មេ** អធិប្បាយដល់អ្នកធ្វើ ។ សព្ទថា **សុតំ** អធិប្បាយដល់វិស័យ ។

ម្យ៉ាងទៀត បទថា **ឯវំ** អធិប្បាយដល់កិច្ចរបស់បុគ្គល ។ សព្ទថា **សុតំ** អធិប្បាយដល់កិច្ចរបស់វិញ្ញាណ ។ សព្ទថា **មេ** អធិប្បាយដល់បុគ្គល

ដែលប្រកបដោយកិច្ចទាំង ២ ។

ន័យម្យ៉ាងទៀត បទថា **ឯវំ** សម្តែងដល់អាការៈ ។ សព្ទថា **មេ** សម្តែងដល់បុគ្គល ។ សព្ទថា **សុតំ** សម្តែងដល់កិច្ចរបស់បុគ្គលនោះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ឯវំ** និងពាក្យថា **មេ** ជាវិជ្ជមានប្បញ្ញត្តិ ព្រោះជាសច្ចិកត្ថបរមត្ថ ។ ពាក្យថា **សុតំ** ជាវិជ្ជមានប្បញ្ញត្តិ ។

ន័យម្យ៉ាងទៀត បទថា **ឯវំ** និង **មេ** ឈ្មោះថា ឧបាទាប្បញ្ញត្តិ ព្រោះពោលអាស្រ័យអារម្មណ៍នោះៗ ។ ពាក្យថា **សុតំ** ឈ្មោះថា ឧបនិធាប្បញ្ញត្តិ ព្រោះពោលអាងអារម្មណ៍ មានអារម្មណ៍ដែលឃើញហើយជាដើម ។

ក្នុងពាក្យទាំង ៣ នោះ ព្រះថេរៈសម្តែងមិនភ័ន្តច្រឡំ ដោយពាក្យថា **ឯវំ**។ ការមិនវង្វេងរឿងដែលស្តាប់មកដោយពាក្យថា **សុតំ** ម្យ៉ាងទៀត ព្រះថេរៈសម្តែងការដាក់ចិត្តដោយឧបាយ ដោយពាក្យថា **ឯវំ** ព្រោះមិនមានការចាក់ធ្លុះដោយប្រការផ្សេងៗ សម្រាប់បុគ្គលដែលដាក់ចិត្តដោយមិនមែនឧបាយ សម្តែងការមិនរាយមាយដោយពាក្យថា **សុតំ** ព្រោះមិនមានការស្តាប់ សម្រាប់បុគ្គលដែលមានចិត្តរាយមាយ ។ ពិតហើយ បុគ្គលដែលមានចិត្តរាយមាយ សូម្បីលោកពោលគ្រប់គ្រាន់គ្រប់យ៉ាង ក៏នឹងពោលថា ខ្ញុំមិនបានឮ សូមនិយាយម្តងទៀតចុះ ។ ក្នុងសេចក្តីនេះ បុគ្គលនឹងឲ្យសម្រេចការតាំងខ្លួនប្រពៃ និងភាពជាអ្នកធ្វើបុណ្យទុកមុន ក៏ដោយការដាក់ចិត្តដោយឧបាយ និងឲ្យសម្រេចការស្តាប់ធម៌របស់សប្បុរស និងការពឹងពាក់អាស្រ័យសប្បុរសដោយការមិនរាយមាយ ព្រះថេរៈសម្តែងការដល់ព្រម ដោយចក្រនៃធម៌ ២

ចំណុចខាងក្រោយរបស់ខ្លួន ដោយអាការដ៏ល្អ ដោយបទថា **ឯវំ** នេះ ។ សម្ដែងការដល់ព្រមដោយចក្រធម៌ ២ ខាងដើម ដោយសេចក្ដីព្យាយាមស្ដាប់ ដោយបទថា **សុតំ**។ ម្យ៉ាងទៀត ព្រះថេរៈសម្ដែងការបរិសុទ្ធនៃអជ្ឈាស្រ័យ និងបរិសុទ្ធនៃការព្យាយាមយ៉ាងនោះ គឺសម្ដែងការឈ្លាសវៃក្នុងអធិគម ដោយការបរិសុទ្ធនៃអជ្ឈាស្រ័យផង សម្ដែងការឈ្លាសក្នុងបរិយត្តិផង ដោយភាពបរិសុទ្ធនៃសេចក្ដីព្យាយាម ។

ម្យ៉ាងទៀត ព្រះថេរៈសម្ដែងការដល់ព្រមដោយអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្ដែងបដិវេធ មានប្រការផ្សេងៗ ដោយពាក្យថា **ឯវំ** នេះ ។ សម្ដែងការដល់ព្រម ដោយធម្មប្បដិ-សម្ភិទា និងនិរុត្តិប្បដិសម្ភិទា ដោយពាក្យដែលសម្ដែងបដិវេធ មានដោយប្រការដែលគួរស្ដាប់ ដោយពាក្យថា **សុតំ** នេះ ម្យ៉ាងទៀត ព្រះថេរៈកាលពោលពាក្យដែលសម្ដែងដល់ការដាក់ចិត្តដោយឧបាយនេះ ក៏ប្រកាសឲ្យដឹងថា ធម៌ទាំងនេះ ខ្ញុំសម្លឹងដោយចិត្ត ហើយចាក់ធ្លុះដោយទិដ្ឋិ ដោយពាក្យថា **ឯវំ**។ កាលពោលពាក្យដែលសម្ដែងដល់ការព្យាយាមស្ដាប់នេះ ក៏ប្រកាសឲ្យគេដឹងថា ធម៌ដ៏ច្រើន ខ្ញុំស្ដាប់ហើយ ទ្រទ្រង់ចាំហើយ រត់មាត់ហើយ ដោយពាក្យថា **សុតំ**។ ដើម្បីសម្ដែងការបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ឲ្យកើតការអើពើដើម្បីស្ដាប់ដោយពាក្យទាំង ២ នេះ ។

ម្យ៉ាងទៀត ព្រះអានន្ទ មិនតាំងធម៌ដែលព្រះតថាគតទ្រង់ប្រកាសហើយ ដើម្បីខ្លួន កន្លងនូវភូមិរបស់អសប្បុរស កាលប្ដេជ្ញាភាពជាសាវ័ក ទើបឈាន

ចុះកាន់ភូមិរបស់សប្បុរស ដោយពាក្យទាំងអស់ថា **ឯវំ មេ សុតំ** នេះ ។ម្យ៉ាងទៀត ព្រះថេរៈ ឈ្មោះថា លើកចិត្តចាកអសទ្ធម្ម តាំងចិត្តទុកក្នុងព្រះសទ្ធម្ម ។ ម្យ៉ាងទៀត កាលសម្ដែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ខ្ញុំស្ដាប់មកហើយដោយយកចិត្តទុកដាក់ ឈ្មោះថា ដោះនូវខ្លួន មានព្រះសាស្ដាជាបន្ទាល់ ជិតស្និទ្ធនឹងព្រះពុទ្ធតម្រាស់ តាំងបែបផែននៃធម៌ ។

ម្យ៉ាងទៀត ព្រះថេរៈមិនព្រមទទួលពាក្យថា **ឯវំ មេ សុតំ** ខ្លួនធ្វើឲ្យកើតឡើង កាលបើកនូវការស្ដាប់មកមុនបុគ្គលណាទាំងអស់ ទើបគួរជ្រាបថាលោក ឈ្មោះថា ទម្លាយនូវការមិនជឿ ធ្វើឲ្យកើតសទ្ធាសម្បទា ការដល់ព្រមដោយការជឿក្នុងព្រះធម៌នេះ ដល់ពពួកទេវតា និងមនុស្សថា ព្រះតម្រាស់នេះ ខ្ញុំទទួលមកចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគអង្គនោះ ដែលជាអ្នកក្លៀវក្លាដោយចតុវេសារជ្ជញ្ញាណ ជាអ្នកទ្រទ្រង់នូវកម្លាំង ១០ តាំងនៅក្នុងតំណែងដ៏ឧត្តម ជាអ្នកបន្លឺសីហនាទ ជាអ្នកទ្រទ្រង់នូវកំពូលរបស់សព្វសត្វទ្រង់ជាធំក្នុងធម៌ ទ្រង់ជាស្ដេចនៃធម៌ ទ្រង់ជាអធិបតីនៃធម៌ ទ្រង់មានធម៌ជាទីពឹងអាស្រ័យ ទ្រង់បន្វិលនូវចក្រដ៏ប្រសើរ គឺសទ្ធម្ម ទ្រង់ជាព្រះសម្មាសម្ពុទ្ធត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯង ក្នុងបទព្រះតម្រាស់នោះមិនគួរធ្វើសេចក្ដីសង្ស័យអល់អែកក្នុងអត្ថ ឬធម៌ បទ ឬព្យញ្ជនៈឡើយ ក្នុងសេចក្ដីនេះមានពាក្យពោលថា

**វិនាសយតិ អស្សទ្ធិយំ សទ្ធំ វឌ្ឍេតិ សាសនេ**

**ឯវមេ្ម សុតមិច្ចេវំ វទំ គោតមសាវកោ ។**

ព្រះអានន្ទ សាវករបស់ព្រះគោតម កាលពោលពាក្យថា **ឯវមេ្ម សុតំ** ឈ្មោះថា ទម្លាយអសទ្ធិយ គឺការមិនជឿ ដើម្បីបណ្ដុះនូវសទ្ធាក្នុងសាសនា ។

## អធិប្បាយបទថា ឯកំ-សមយំ

សព្ទថា **ឯកំ** សម្ដែងការកំណត់ចំនួន សព្ទថា **សមយំ** សម្ដែងកាលដែលកំណត់ ។ ពីរពាក្យថា **ឯកំ សមយំ** សម្ដែងកាលមិនពិតប្រាកដ ។ ក្នុងពាក្យនោះ **សមយ** សព្ទ មានអត្ថថា ព្រមព្រៀង ខណៈ កាល ប្រជុំ ហេតុ លទ្ធិ បានចំពោះ លះបង់ និងចាក់ធ្លុះ ។

ពិតហើយ **សមយ** សព្ទនោះ មានអត្ថថា ព្រមព្រៀង ដូចក្នុងប្រយោគជាដើមថា **អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ** បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យ ( កាលព្រមព្រៀង ) សិនហើយ សឹមទៅក្នុងថ្ងៃស្អែក ។

មានអត្ថថា ខណៈ ដូចក្នុងប្រយោគជាដើមថា **អយំ ភិក្ខវេ ឯកោវ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** ម្នាលភិក្ខុទាំងឡាយ នេះជាខណៈ និងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ដូច្នេះ ។

មានអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **ឧណ្ហសមយោ បរិឡាហសមយោ** សម័យក្ដៅ សម័យ ( កាល ) ស្អុះស្អាប់ ដូច្នេះ ។

មានអត្ថថា ប្រជុំ ដូចក្នុងប្រយោគជាដើមថា **មហាសមយោ បវនស្មឹ** ថ្ងៃនេះជាថ្ងៃប្រជុំធំ ក្នុងដងព្រៃធំ ។

*មានអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា* **សមយោបិ ខោ តេ ភទ្ទាលិ ។បេ។ សមយោ អប្បដិវិទ្ធោ អហោសិ ។** *ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តាដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជា* **ហេតុ** *ដែលអ្នកមិនបានដឹង ។*

*មានអត្ថថា លទ្ធិ ដូចក្នុងប្រយោគជាដើមថា* **តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិណ្ឌុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ** *សម័យនោះឯង បរិព្វាជកឈ្មោះឧគ្គាហមានះ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវទិដ្ឋិ ( លទ្ធិ ) ។*

*មានអត្ថថា បានចំពោះ ដូចក្នុងប្រយោគជាដើមថា*

**ទិដ្ឋេ ធម្មេ ច យោ អត្ថោ　យោ ចត្ថោ សម្បរាយិកោ**
**អត្ថាភិសមយា ធីរោ　បណ្ឌិតោតិ បវុច្ចតិ ។**

*បណ្ឌិត ជាអ្នកមិនប្រមាទ តែងបានចំពោះប្រយោជន៍ទាំងពីរ គឺប្រយោជន៍ណា ក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណា ដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ទាំងពីរនោះ ។*

*មានអត្ថថា លះបង់ ដូចក្នុងប្រយោគជាដើមថា* **សម្មា មានាភិ-សមយាអន្តមកាសិ ទុក្ខស្ស** *ធ្វើនូវទីបំផុតកងទុក្ខ ដោយហេតុដែលបាន លះបង់នូវមានះចោលដោយប្រពៃ ។*

*មានអត្ថថា ចាក់ធ្លុះ ដូចក្នុងប្រយោគជាដើមថា* **ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ** *ទុក្ខមានអត្ថថា បៀតបៀន មានបច្ច័យតាក់តែង ធ្វើឲ្យក្តៅក្រហាយ ប្រែប្រួល និងគួរចាក់ធ្លុះ។*

*តែក្នុងទីនេះ* **សមយ** *សព្ទនេះ មានអត្ថថា កាល ។ ដោយហេតុនោះ ទើបព្រះថេរៈសម្តែងថា* **ឯកំ សមយំ** *សម័យមួយ បណ្តាសម័យទាំងឡាយ ដែលហៅថា កាលជាដើមថា ឆ្នាំ រដូវ ខែ កន្លះខែ យប់ ថ្ងៃ ព្រឹក ពេល ថ្ងៃ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងព្រលឹម ។*

*លោកអធិប្បាយថា សម័យរបស់ព្រះមានព្រះភាគនេះ ដែលហៅថា កាល មានច្រើន ដែលប្រាកដក្រៃលែងក្នុងពួកទេវតា និងមនុស្សជាដើមយ៉ាងនេះ គឺសម័យទ្រង់ចូលកាន់ព្រះគភ៌ សម័យប្រសូត សម័យទ្រង់សង្វេគ សម័យទ្រង់ចេញបួស សម័យទ្រង់ធ្វើទុក្ករកិរិយា សម័យទ្រង់ឈ្នះមារ សម័យទ្រង់ត្រាស់ដឹង សម័យគង់ប្រថាប់ជាសុខក្នុងបច្ចុប្បន្ន សម័យទេសនា សម័យបរិនិព្វាន បណ្តាសម័យទាំងនោះ ព្រះថេរៈសម្តែងសម័យមួយ ពោល គឺ សម័យទេសនា ។*

*លោកអធិប្បាយថា បណ្តាសម័យទ្រង់ធ្វើកិច្ចដោយព្រះញាណ និងទ្រង់ធ្វើកិច្ចដោយព្រះករុណា ( បានដល់ ) សម័យទ្រង់ធ្វើកិច្ចដោយព្រះករុណានេះ*

បណ្តាសម័យទ្រង់បដិបត្តិ ដើម្បីជាប្រយោជន៍ចំពោះខ្លួន និងសម័យទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ( បានដល់ ) បណ្តាសម័យទ្រង់បដិបត្តិដើម្បីជាប្រយោជន៍ដល់អ្នកដទៃនេះ បណ្តាសម័យទ្រង់បដិបត្តិករណីយកិច្ចទាំង ២ ដល់បរិស័ទ ដែលប្រជុំគ្នា ( បានដល់ ) សម័យទ្រង់ពោលធម្មីកថានេះ បណ្តាសម័យទេសនា និងបដិបត្តិ ( បានដល់ ) សម័យទេសនានេះ បណ្តាសម័យទាំងនោះ ព្រះថេរៈសម្តែងថា **ឯកំ សមយំ** សម័យមួយ សំដៅយកសម័យណាមួយ ។

ក្នុងសេចក្តីនេះ បុគ្គលអ្នកសួរពោលថា ព្រោះហេតុអ្វី ទើបក្នុងព្រះសូត្រលោកធ្វើនិទ្ទេសជាទុតិយាវិភត្តិ មិនធ្វើដូចក្នុងអភិធម្មដែលធ្វើនិទ្ទេសជាសត្តមីវិភត្តថា **យស្មឹ សមយេ កាមាវចរំ** និងក្នុងសុត្តបទដទៃក្រៅអំពីអភិធម្មនេះថា **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ** និងដូចក្នុងវិន័យដែលធ្វើនិទ្ទេស ជាតតិយាវិភត្តិថា **តេន សមយេន ពុទ្ធោ ភគវា** ការពោលចន្លុលបង្ហាញ ដូច្នេះ ព្រោះក្នុងអភិធម្ម និងវិន័យនោះ **សមយ** សព្ទ មានអត្ថយ៉ាងនោះ ឯក្នុងព្រះសូត្រនេះ មានអត្ថដទៃ ។ សេចក្តីពិត បណ្តាបិដកទាំង ៣ នោះ ក្នុងអភិធម្មបិដក **សមយ** សព្ទ មានអត្ថថា កំណត់ការៈ ។ ពិតហើយ អធិករណៈ គឺ **សមយ** សព្ទ ដែលមានអត្ថថា កាលនិងមានអត្ថថា ប្រជុំ និងភាវៈនៃធម៌ មានផស្សៈជាដើមនោះ កំណត់បានដោយភាវៈនៃសម័យ គឺខណៈ ការព្រមព្រៀង និងហេតុនៃធម៌ទាំងឡាយមានផស្សៈជាដើម ដែលពោលហើយក្នុងអភិធម្មបិដក និងសុត្តបទដទៃនោះ

ព្រោះដូច្នោះ ទើបធ្វើនិទ្ទេសជាសត្តមីវិភត្តិ ក្នុងអភិធម្មបិដកនោះ ដើម្បីបញ្ជាក់អត្ថនោះ ។

ឯក្នុងព្រះវិនយបិដក **សមយ** សព្ទ មានអត្ថថា ហេតុ មានអត្ថថា ករណៈ ។ ពិតហើយ សម័យទ្រង់បញ្ញត្តសិក្ខាបទនោះ សូម្បីព្រះថេរៈ មានព្រះសារីបុត្រជាដើម គន់ដឹងបានដោយលំបាក ដោយសម័យនោះជាហេតុ និងជាករណៈ ។ ព្រះមានព្រះភាគ កាលទ្រង់បញ្ញត្តសិក្ខាបទទាំងឡាយ ទ្រង់ក៏សម្លឹងដល់ហេតុនៃការបញ្ញត្តិសិក្ខាបទ ទើបប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះ ទើបលោកធ្វើនិទ្ទេសជាតតិយាវិភត្តិទុកក្នុងវិនយបិដក ដើម្បីធ្វើបញ្ចាំងសេចក្ដីនោះ ។ ឯក្នុងសេចក្ដីនេះ និងបាឋៈនៃសុត្តន្តបិដក ដែលមានកំណើតដទៃៗ **សមយ** សព្ទ មានអត្ថថា អច្ចន្តសំយោគ គឺទុតិយាវិភត្តិ ដែលប្រែថា រហូត ពិតហើយ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងសូត្រនេះ ឬសូត្រដទៃអស់សម័យណា ក៏ប្រថាប់ដោយករុណាវិហាររហូតទៅ គឺរហូតសម័យនោះ ព្រោះដូច្នោះ ទើប **សមយ** សព្ទ គួរជ្រាបថា លោកធ្វើនិទ្ទេសជាទុតិយាវិភត្តិក្នុងសូត្រនេះ ដើម្បីធ្វើបញ្ចាំងសេចក្ដីនោះ ។ ក្នុងសេចក្ដីនេះ មានពាក្យពោលថា

**តំ តំ អត្ថមបេក្ខិត្វា ភុម្មេន ករណេន ច**
**អញ្ញត្រ សមយោ វុត្តោ ឧបយោគេន សោ ឥធ។**

លោកពិចារណាអត្ថនោះៗ ពោល **សមយ** សព្ទ ក្នុងបិដកដទៃដោយសត្តមីវិភត្តិ និងដោយតតិយាវិភត្តិ តែក្នុងសុត្តន្តបិដកនេះ **សមយ** សព្ទនោះ លោកពោលដោយទុតិយាវិភត្តិ ។

# អធិប្បាយបទថា ភគវា

*ពាក្យថា* **ភគវា** *នេះ ជាពាក្យហៅព្រះមានព្រះភាគអង្គនោះ ជាបុគ្គលវិសេសដោយគុណ ជាកំពូលនៃសត្វ ជាគ្រូ និងគួរគោរព ដូចលោកពោលថា*

**ភគវាតិ វចនំ សេដ្ឋំ ភគវាតិ វចនមុត្តមំ**

**គរុគារវយុត្តោ សោ ភគវា តេន វុច្ចតិ ។**

*ពាក្យថា* **ភគវា** *ជាពាក្យប្រសើរបំផុត*

*ពាក្យថា* **ភគវា** *ជាពាក្យឧត្តមបំផុត*

*ព្រះអង្គទ្រង់ជាគ្រូ និងគួរដល់ការគោរព*

*ដោយហេតុនោះ ទើបបណ្ឌិត ហៅថា* **ភគវា ។**

*សេចក្ដីពិត នាម គឺឈ្មោះមាន ៤ គឺ* **អាវត្ថិក** *ឈ្មោះតាមវ័យ* **លិង្គិក** *ឈ្មោះតាមភេទ* **នេមិត្តក** *ឈ្មោះតាមគុណ* **អធិច្ចសមុប្បន្ន** *ឈ្មោះដែលអណ្ដែតៗ ។ ឈ្មោះថា* **អធិច្ចសមុប្បន្ននាម** *លោកអធិប្បាយថា ជានាមដែលតាំងតាមការគាប់ចិត្ត ។ នាមទាំង ៤ នោះ នាមជាដើមយ៉ាងនោះថា កូនគោ គោបង្ហឹក គោបម្រើការ ឈ្មោះថា* **អាវត្ថិកនាម ។** *នាមជាដើមយ៉ាងនេះថា បុគ្គលមានឈើច្រត់ គឺមនុស្សចាស់ បុគ្គលមានឆត្រ គឺព្រះរាជា សត្វមានសិរ គឺក្ងោក សត្វមានប្រមោយ គឺដំរី ឈ្មោះថា* **លិង្គិកនាម ។** *នាមជាដើមយ៉ាងនេះថា អ្នកមានវិជ្ជា ៣ អ្នកមានអភិញ្ញា ៦ ឈ្មោះថា* **នេមិត្តកនាម ។** *នាមជាដើមយ៉ាងនេះថា អ្នកចម្រើនដោយសិរី អ្នកចម្រើនដោយទ្រព្យ ប្រព្រឹត្តទៅមិនសម្ដីងអត្ថនៃពាក្យ ឈ្មោះថា* **អធិច្ចសមុប្បន្ន-នាម ។** *ឯនាមថា* **ភគវា** *នេះ ជា* **នេមិត្តកនាម** *ដោយព្រះគុណ មិនមែន*

ព្រះនាងមហាមាយាពុទ្ធមាតាដាក់ឲ្យ មិនមែនព្រះបាទសុទ្ធោទនមហារាជពុទ្ធបិតាដាក់ឲ្យ មិនមែនព្រះញាតិ ៨៤០០០ អង្គដាក់ឲ្យ មិនមែនទេវតាពិសេស មានសក្កទេវរាជ ស្តេចសន្តុសិតដាក់ឲ្យ ដូចព្រះសារីបុត្រពោលថា ព្រះនាម **ភគវា** នុ៎ះ មិនមែនព្រះមាតាថ្វាយ ។បេ។ បញ្ញត្តិថា **ភគវា** នេះ កើតព្រោះការត្រាស់ដឹង ព្រមដោយការបានចំពោះនូវសព្វញ្ញុតញ្ញាណទៀបគល់ពោធិព្រឹក្ស ហេតុនោះ ( លោកពោលថា ) **ភគវា** ។ ដើម្បីប្រកាសគុណទាំងឡាយ ដែលជាគុណនេមិត្តកនាម ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថានេះថា

**ភគី ភជី ភាគី វិភត្តវា ឥតិ**

**អកាសិ ភគ្គន្តិ គរូតិ ភាគ្យវា**

**ពហូហិ ញាយេហិ សុភាវិតត្តនោ**

**ភវន្តគោ សោ ភគវាតិ វុច្ចតិ ។**

ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **ភគវា** ព្រោះទ្រង់ជាអ្នកមានភគៈ គឺជោគ ព្រោះទ្រង់ជាអ្នកសេពទីស្ងាត់ ព្រោះទ្រង់ជាអ្នកមានភាគ គឺចំណែកដែលគួរបានទទួលចតុប្បច្ច័យ ឬចំណែកនៃធម៌ ព្រោះទ្រង់ជាអ្នកចែកនូវធម៌ ព្រោះទ្រង់បានកាច់បំបាក់នូវបាបធម៌ ព្រោះទ្រង់ជាគ្រូ ព្រោះទ្រង់មានភាគ្យ គឺបុណ្យ ព្រោះទ្រង់អប់រំព្រះអង្គល្អហើយ ដោយញាយធម៌ដ៏ច្រើន ព្រោះទ្រង់ដល់នូវទីបំផុតភព ។

ភាពនៃព្រះគុណ បទថា **ភគវា** នោះ គប្បីឃើញតាមន័យដែលបាន ពោលហើយ ក្នុងនិទ្ទេសជាដើមនោះឯង ។

ម្យ៉ាងទៀត បរិយាយដទៃនៅមានទៀត ដូច្នេះថា

**ភាគ្យវា ភគ្គវា យុត្តោ ភគេហិ ច វិភត្តវា**

**ភត្តវា វន្តគមនោ ភវេសុ ភគវា តតោ ។**

ព្រះដ៏មានបុណ្យ ទ្រង់កាច់បំបាក់កិលេស ទ្រង់ប្រកប ដោយភគធម៌ ទ្រង់ចែកធម៌ ទ្រង់សេពនូវធម៌ ទ្រង់ខ្ជាក់ កិលេស ដែលជាហេតុទៅកាន់ភពទាំងឡាយបានហើយ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **ភគវា** ។

ក្នុងបទទាំងនោះ គប្បីជ្រាបថា លោកកាន់យកលក្ខណៈនៃនិរុត្តិសាស្ត្រ យ៉ាងនេះថា ចុះអក្ខរៈថ្មី ផ្លាស់អក្ខរៈជាដើម ឬកាន់យកលក្ខណៈ ការរួបរួម ក្នុងសព្ទ មាន **បិសោទរ** សព្ទជាដើម តាមន័យរបស់សព្ទសាស្ត្រ កាល គួរហៅថាព្រះ **ភាគ្យវា** ព្រោះទ្រង់មានភាគ្យ គឺបុណ្យបារមី មានទាន និង សីលជាដើមដ៏កំពូល ដែលឲ្យកើតសេចក្តីសុខ ទាំងលោកិយ និងលោកុត្តរ តែហៅក្លាយថា **ភគវា** ។ ម្យ៉ាងទៀត ព្រោះហេតុដែលទ្រង់កាច់បំបាក់ កិលេស ដែលធ្វើនូវសេចក្តីក្រវល់ក្រវាយរាប់សែនប្រភេទ គឺប្រភេទលោភៈ ទោសៈ មោហៈ ប្រភេទវិបរិតមនសិការ ប្រភេទអហិរិកៈ អនោត្តប្បៈ ប្រភេទកោធៈ ឧបនាហៈ ប្រភេទមក្ខៈ បលាសៈ ប្រភេទឥស្សា មច្ឆរិយៈ ប្រភេទសាឋេយ្យៈ ប្រភេទថម្ភៈ សារម្ភៈ ប្រភេទមានះ អតិមានះ ប្រភេទ

មទៈ បមាទៈ ប្រភេទតណ្ហា អវិជ្ជា ប្រភេទអកុសលមូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មលៈ ៣ វិសមៈ ៣ សញ្ញា ៣ វិតក្ក ៣ បបញ្ចធម៌ ៣ ប្រភេទវិបរិយេស ៤ អាសវៈ ៤ គន្ថៈ ៤ ឱឃៈ ៤ យោគៈ ៤ អគតិ ៤ តណ្ហុប្បាទ ៤ ចេតោខីលៈ ៥ វិនិពន្ធៈ ៥ នីវរណៈ ៥ អភិនន្ទៈ ៥ វិវាទ-មូល ៦ តណ្ហាកាយ ៦ អនុស័យ ៧ មិច្ឆត្តៈ ៨ តណ្ហាមូលកៈ ៩ អកុ-សលកម្មបថ ១០ ទិដ្ឋិគតៈ ៦២ តណ្ហាវិចរិត ១០៨ ឬពោលដោយសង្ខេប មារ ៥ គឺកិលេសមារ ខន្ធមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារ ដូច្នោះ កាលគួរហៅថា **ភគ្គវា** ក៏ហៅក្លាយថា **ភគវា** ព្រោះទ្រង់កាច់បំបាក់បង់ឧបទ្រវទាំងនោះបាន សេចក្តីនេះ លោកពោលថា

**ភគ្គរាគោ ភគ្គទោសោ ភគ្គមោហោ អនាសវោ**
**ភគ្គាស្ស បាបកា ធម្មា ភគវា តេន វុច្ចតិ ។**

ទ្រង់កាច់បំបាក់នូវរាគៈ ទោសៈ មោហៈ មាន
អាសវៈ ទ្រង់កាច់បំបាក់នូវបាបធម៌បានហើយ
ដោយហេតុនោះ ទើបលោកហៅថា **ភគវា**។

ការដល់ព្រមនៃព្រះរូបកាយរបស់ព្រះអង្គ ដែលទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយ ឈ្មោះថា លោកសម្តែងដោយភាពដែលទ្រង់មាន **ភាគ្យ** គឺបុណ្យ ការដល់ព្រមនៃព្រះធម្មកាយ ឈ្មោះថា លោកសម្តែងដោយភាពដែលទ្រង់កាច់បំបាក់ទោសៈបានហើយ ។ ភាពដែលសត្វលោក និងអ្នកជិតស្និទ្ធរាប់អានច្រើនក្តី ភាពជាបុគ្គលដែលគ្រហស្ថ និងបព្វជិតទាំងឡាយ ចូលមកគាល់

ក្តី ភាពជាបុគ្គលអាចជួយកម្ចាត់ទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្តដល់បុគ្គលដែលចូលមករកក្តី ភាពជាបុគ្គលធ្វើឧបការៈដោយអាមិសទាន និងធម្មទានក្តី ភាពជាអ្នកអាចក្នុងការប្រកបលោកិយសុខ និងលោកុត្តរសុខក្តី លោកសម្តែងដោយព្រះគុណ ២ យ៉ាងនោះ ។

ម្យ៉ាងទៀត ព្រោះ **ភគ** សព្ទក្នុងលោក ប្រព្រឹត្តទៅក្នុងធម៌ ៦ គឺ ឥស្សរិយៈ ធម្មៈ យស សិរី កាម បយត្ត ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់មានឥស្សរិយភាពជាធំ ក្នុងចិត្តរបស់ព្រះអង្គឯងដ៏កំពូល ឬទ្រង់មានឥស្សរិយបរិបូណ៌ ដោយអាការគ្រប់យ៉ាង ដែលសន្មតថាជាលោកិយ មាន អណិមា គឺធ្វើខ្លួនឲ្យតូច សង្ឃិមា គឺធ្វើខ្លួនឲ្យស្រាល ទ្រង់មានលោកុត្តរធម៌ក៏ដូចគ្នា ទ្រង់មានយសដ៏បរិសុទ្ធក្រៃលែង ដែលទ្រង់បានដោយព្រះគុណតាមសេចក្តីពិត ប្រាកដទូទៅក្នុងលោកទាំង ៣ ទ្រង់មានព្រះសិរីល្អ សព្វសព៌ាង្គ-កាយបរិបូណ៌ ដោយអាការគ្រប់យ៉ាង ទ្រង់អាចឲ្យទាក់ភ្នែក ទាក់ចិត្តដល់បុគ្គលខ្វល់ខ្វាយក្នុងការមើលព្រះរូបបាន ទ្រង់មានព្រះកាមដែលសំដៅដល់សេចក្តីសម្រេចនៃប្រយោជន៍ដែលទ្រង់បំណង ព្រោះប្រយោជន៍ណាមួយដែលទ្រង់បំណងហើយ ប្រាថ្នាហើយ ទោះជាប្រយោជន៍ខ្លួនក្តី ប្រយោជន៍អ្នកដទៃក្តី ប្រយោជន៍នោះៗ ក៏សម្រេច សមបំណងទាំងអស់ ហើយទ្រង់មានព្រះបរិយត្តិ ពោលគឺសម្មាវាយាមៈ ដែលជាហេតុកើតនូវភាពជាគ្រូរបស់សត្វលោកទាំងពួង ដូច្នោះ ទើបលោកហៅថា **ភគវា** ដោយអត្ថនេះថា ទ្រង់មានភគធម៌ ព្រោះភាពដែលទ្រង់ប្រកបដោយភគធម៌ទាំងនេះ ។

## អធិប្បាយបទថា វិភត្តវា

ម្យ៉ាងទៀត ព្រោះព្រះមានព្រះភាគ ទ្រង់ជាវិភត្តវា លោកអធិប្បាយថា ទ្រង់ចែក បើកផ្សារ សម្តែង នូវធម៌ទាំងពួងដោយប្រភេទ មានកុសលជាដើម ឬនូវធម៌ មានកុសលធម៌ជាដើម ដោយប្រភេទ មានខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ និងបដិច្ចសមុប្បាទជាដើម ឬនូវទុក្ខអរិយសច្ច ដោយអត្ថ គឺ បីឡនៈ សង្ខតៈ សន្តាបៈ វិបរិណាមៈ នូវសមុទយអរិយសច្ច ដោយអត្ថ គឺ អាយូហនៈ និទាន សំយោគ បលិពោធ នូវនិរោធអរិយសច្ច ដោយអត្ថ គឺ និស្សរណៈ វិវេក អសង្ខតៈ អមតៈ នូវមគ្គអរិយសច្ច ដោយអត្ថ គឺ និយ្យានិក ហេតុ ទស្សនៈ អធិបតេយ្យ ដូច្នោះ កាលគួរនឹងហៅថា **វិភត្តវា** តែហៅក្លាយថា **ភគវា**។

## អធិប្បាយបទថា ភត្តវា

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះមានព្រះភាគ ទ្រង់គប់រក ទ្រង់សេព ទ្រង់ធ្វើឲ្យច្រើន នូវធម៌ដែលជាទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ នូវកាយវិវេក ចិត្តវិវេក និងឧបធិវិវេក នូវសុញ្ញវិមោក្ខ អប្បណិហិតវិមោក្ខ អនិមិត្តវិមោក្ខ និងនូវឧត្តរិមនុស្សធម៌ដែលជាលោកិយផង លោកុត្តរដទៃៗផង ដូច្នោះ កាលគួរហៅថា **ភត្តវា** តែក៏ហៅក្លាយថា **ភគវា**។

## អធិប្បាយបទថា ភវេសុ វន្តគមន

ម្យ៉ាងទៀត ព្រោះការទៅ ពោល គឺតណ្ហាក្នុងភពទាំង ៣ ដែលទ្រង់ខ្ជាក់ចោលហើយ ដូច្នោះ កាលគួរនឹងហៅថា **ភវេសុវន្តគមន** តែលោកកាន់

យក **ភ** អក្ខរៈ អំពី **ភវ** សព្ទ **គ** អក្ខរៈ អំពី **គមន** សព្ទ **វ** អក្ខរៈ អំពី **វន្ត** សព្ទ ហើយធ្វើឲ្យជាទីឃៈ ហៅថា **ភគវា** ដូចក្នុងផ្លូវលោក កាលគួរនឹងហៅពេញៗ ថា **មេហានស្ស ខស្ស មាលា** តែអ្នកប្រាជ្ញលោកកាន់យក **មេ** អំពី **មេហានស្ស** កាន់យក **ខ** អំពី **ខស្ស** កាន់យក **លា** អំពី **មាលា** ក៏ហៅថា **មេខលា** ដូច្នោះឯង ។

ព្រះអានន្ទត្ថេរ កាលសម្តែងធម៌តាមដែលបានស្តាប់មក រៀនសូធ្យមក ទើបប្រកាសព្រះសរីរធម៌របស់ព្រះមានព្រះភាគ ឲ្យជាក់ច្បាស់ ដោយពាក្យថា **ឯវម្មេ សុតំ** ក្នុងព្រះសូត្រនេះ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ដោយប្រការដូច្នេះ ទើបព្រះថេរៈលួងលោមជនដែលមានចិត្តរាយមាយ ព្រោះមិនជួបព្រះមានព្រះភាគថា បាវចនៈ គឺធម៌ និងវិន័យនេះ ឈ្មោះថា មានសាស្តាកន្លងហើយ ក៏មិនមែន ធម៌ និងវិន័យនេះ ជាសាស្តារបស់អ្នកទាំងឡាយ ។

ពាក្យថា **ឯកំ សមយំ ភគវា** ព្រះថេរៈកាលសម្តែងភាពដែលព្រះមានព្រះភាគ មិនមានក្នុងសម័យនោះ ឈ្មោះថា សម្តែងបរិនិព្វាននៃព្រះរូបកាយ ។ ដោយពាក្យនោះ ព្រះថេរៈរមែងញុំាងជនដែលស្រវឹង មានស្រវឹងក្នុងជីវិតជាដើមឲ្យសង្វេគ ហើយញុំាងឧស្សាហ៍ក្នុងធម៌ឲ្យកើតដល់ជននោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងអរិយធម៌នេះយ៉ាងនោះ ទ្រទ្រង់នូវកម្លាំង ១០ មានព្រះកាយដូចពេជ្រ ក៏គង់ស្តេចបរិនិព្វាន ក្នុងសេចក្តីនោះ បុគ្គលដទៃណា គប្បីឲ្យកើតការប្រាថ្នាហួងហែងក្នុងជីវិតបាន ។

ព្រះថេរៈកាលពោលថា **ឯវំ** ឈ្មោះថា សម្តែងទេសនាសម្បត្តិ គឺការ

ដល់ព្រមនៃទេសនា កាលពោលពាក្យថា **មេ សុតំ** ឈ្មោះថា សម្តែងសាវកសម្បត្តិ ។ កាលពោលពាក្យថា **ឯកំ សមយំ** ឈ្មោះថា សម្តែងកាលសម្បត្តិ កាលពោលពាក្យថា **ភគវា** ឈ្មោះថា សម្តែងទេសកសម្បត្តិ គឺការដល់ព្រមនៃអ្នកសម្តែង ។

## អធិប្បាយបទថា សាវត្ថិយំ វិហរតិ

ពាក្យថា **សាវត្ថី** ក្នុងពាក្យថា **សាវត្ថិយំ វិហរតិ** នេះ បានដល់ នគរដែលជាលំនៅប្រចាំរបស់ឥសី ឈ្មោះ **សវត្ថៈ** ដូចពាក្យថា **កាកន្ទី មាកន្ទី** ដូច្នោះ ទើបលោកហៅថា **សាវត្ថី** ជា **ឥត្ថីលិង្គ** សព្ទ អ្នកប្រាជ្ញខាងអក្ខរសាស្ត្រពោលយ៉ាងនេះ ។ ឯអដ្ឋកថាចារ្យទាំងឡាយពោលថា គ្រឿងឧបភោគបរិភោគសម្រាប់មនុស្ស មានសព្វយ៉ាងក្នុងនគរនោះ ហេតុនោះ ទើបនគរនោះ ឈ្មោះថា **សាវត្ថី** ។ តែការប្រកបសព្ទ កាលត្រូវសួរថា មានរបស់ប៉ុន្មាន ទើបអាស្រ័យពាក្យថា មានគ្រប់យ៉ាង ប្រកបថា **សាវត្ថី** មានរបស់គ្រប់យ៉ាង ។

> គ្រឿងឧបករណ៍មានព្រម ក្នុងក្រុងសាវត្ថីសព្វកាល ព្រោះ
> ដូច្នោះ សំដៅដល់របស់គ្រប់យ៉ាង ទើបហៅថា **សាវត្ថី**។
> រាជធានីនៃដែនកោសល គួរជាទីត្រេកអរ គួរសរសើរ គួរ
> ចាប់ចិត្ត មិនស្ងាត់ចាកសំឡេង ១០ យ៉ាង ដល់ព្រម
> ដោយបាយ និងទឹក ។

ក្រុងសាវត្ថីរាជធានី ដល់នូវការចម្រើនបរិបូណ៌ ម៉ាំទាំ
រុងរឿង គួរជាទីត្រេកអរនៃចិត្ត ដូចក្រុងអាឡកមន្ទា-
ទេពធានីរបស់ពួកទេវតា ដូច្នោះ ។

ទៀបក្រុងសាវត្ថីនោះ ពាក្យនេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។

ពាក្យថា **វិហរតិ** នេះ ជាពាក្យសម្ដែងការដល់ព្រមដោយវិហារ បណ្ដាឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារបែបណានីមួយ ដោយមិនប្លែកគ្នា តែក្នុងព្រះសូត្រនេះ សម្ដែងការប្រកបព្រម ដោយឥរិយាបថវិហារ ក្នុងបណ្ដាឥរិយាបថ មានការឈរ ដើរ អង្គុយ ដេក ឥរិយាបថណានីមួយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទ្រង់ប្រថាប់ឈរក្ដី ទ្រង់យាងក្ដី ប្រថាប់អង្គុយក្ដី ផ្ទំក្ដី ក៏គប្បីជ្រាបថា **វិហរតិ** ទាំងអស់ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់កាត់នូវសេចក្ដីលំបាកនៃឥរិយាបថណាមួយ ដោយឥរិយាបថមួយទៀត ទ្រង់បរិហារអត្តភាពឲ្យប្រព្រឹត្តទៅមិនលំបាក ព្រោះដូច្នោះ ទើបហៅថា **វិហរតិ**។

## អធិប្បាយបទថា ជេតវនេ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ជេតវនេ** នេះ ដូច្នេះ ។ ព្រះរាជកុមារព្រះនាមថា **ជេត** ព្រោះឈ្នះជនដែលជាសត្រូវរបស់ខ្លួន ឬថា **ជេត** ព្រោះប្រសូតក្នុងកាលព្រះរាជាទ្រង់ឈ្នះសត្រូវ ឬឈ្មោះថា **ជេត** ព្រោះព្រះរាជាទ្រង់ដាក់ឈ្មោះយ៉ាងនេះ ដល់ព្រះរាជកុមារ ព្រោះមានព្រះរាជបំណងឲ្យជាមង្គល ។ ដែលឈ្មោះថា **វន** ព្រោះឲ្យគប់រក អធិប្បាយថា ឲ្យធ្វើនូវការ

*កក្តីដល់ខ្លួន ព្រោះការដល់ព្រមនៃខ្លួន គឺឲ្យកើតការស្រឡាញ់ក្នុងខ្លួន ។ មួយវិញទៀត ឈ្មោះថា* **វន** *ព្រោះស្រែកហៅ អធិប្បាយថា ហាក់បីដូចហៅសត្វទាំងឡាយថា សូមមកប្រើប្រាស់ខ្ញុំចុះ ។* **វន** *របស់ជេតរាជកុមារ ឈ្មោះថា* **ជេតវន** *។ ពិតហើយ ជេតវននោះដែលព្រះរាជកុមារព្រះនាមថា* **ជេត** *ដាំហើយថែរក្សា ។ ជេតរាជកុមារនោះ ជាម្ចាស់របស់ជេតវននោះ ព្រោះដូច្នោះ ទើបហៅថា* **ជេតវន** *។ ក្នុងជេតវននោះ ។*

## អធិប្បាយបទថា អនាថបិណ្ឌិកស្ស អារាមេ

*គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា* **អនាថបិណ្ឌិកស្ស អារាមេ** *នេះ ដូច្នេះថា គហបតីនោះ ឈ្មោះសុទត្តៈ ដោយឪពុកម្តាយដាក់ឈ្មោះឲ្យ ។ មួយវិញទៀត លោកបានឲ្យដុំបាយជាទានដល់មនុស្សអនាថាជាប្រចាំ ព្រោះលោកជាអ្នកប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ និងព្រោះជាអ្នកដល់ព្រមដោយគុណមានករុណាជាដើម ព្រោះលោកជាអ្នកស្តុកស្តម្ភដោយសម្បត្តិ ដែលគួរប្រាថ្នាគ្រប់យ៉ាង ដោយហេតុនោះ ទើបបានឈ្មោះថា* **អនាថបិណ្ឌិក** *។ បទេសដែលឈ្មោះថា* **អារាម** *ព្រោះជាទីដែលសត្វទាំងឡាយ ឬដោយចំពោះ គឺបព្វជិតទាំងឡាយនាំគ្នាមកត្រេកអរ អធិប្បាយថា បព្វជិតទាំងឡាយនាំគ្នាមកអំពីទីនោះៗ ត្រេកអរដោយមិនធុញទ្រាន់ ព្រោះជេតពននោះ ស្រស់ស្អាតដោយផ្កា ផ្លែឈើ ស្លឹកឈើខ្ចីជាដើម និងព្រោះដល់ព្រមដោយអង្គនៃសេនាសនៈ ៥ ប្រការ មានមិនឆ្ងាយពេក មិនជិតពេកជាដើម ។ មួយប្រការទៀត ឈ្មោះថា* **អារាម** *ព្រោះនាំបុគ្គលដែលទៅក្នុងទីនោះៗ មកខាង*

ក្នុងខ្លួន រួចត្រេកអរ ព្រោះសម្បត្តិដូចពោលមកហើយ ។ ពិតហើយ អារាម នោះ អនាថបិណ្ឌិកគហបតី ទិញអំពីព្រះហស្តរបស់ជេតរាជកុមារ ដោយ ប្រាក់ ១៨ កោដិ សាងសេនាសនៈអស់ ១៨ កោដិ ស្រេចហើយ ឆ្លងវិហារ អស់ប្រាក់ ១៨ កោដិ វេរថ្វាយភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយ បរិច្ចាគប្រាក់ ៥៤ កោដិ យ៉ាងនេះ ព្រោះដូច្នោះ ទើបហៅថា អារាមរបស់ អនាថបិណ្ឌិក ។ ក្នុងអារាមរបស់អនាថបិណ្ឌិកនោះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ជេតវនេ** ប្រារព្ធដល់ម្ចាស់ដើម ពាក្យថា **អនាថបិណ្ឌិកស្ស អារាមេ** ប្រារព្ធដល់ម្ចាស់ក្រោយ ។ មានពាក្យសួរថា ប្រារព្ធដល់វត្ថុជេតពន និងអារាមទាំងនោះ មានប្រយោជន៍អ្វី ។ សូមចម្លើយ បង្ហាញដូច្នេះថា ពោលដោយអធិការមុន ប្រយោជន៍ គឺការធ្វើនូវការកំណត់ ឆ្លើយនូវពាក្យដែលត្រាស់ក្នុងទីណាមួយ ជាការប្រកបបុគ្គលដែលត្រូវការ បុណ្យដទៃៗ ក្នុងការដល់ ( កាន់យក ) ជាបែបផែនណាមួយ ។ ពិតហើយ ក្នុងប្រយោជន៍ ២ យ៉ាងនោះ ទ្រព្យ ១៨ កោដិដែលបានអំពីការលក់ដី ក្នុង ការសាងប្រាសាទ មានទ្វារ និងខ្លោងទ្វារ ដើមឈើទាំងឡាយមានតម្លៃច្រើន កោដិ ជាបរិច្ចាគរបស់ជេតរាជកុមារ ។ ទ្រព្យ ៥៤ កោដិ ជាបរិច្ចាគរបស់ អនាថបិណ្ឌិកសេដ្ឋី ។ ដោយការប្រារព្ធដល់ជេតពន និងអារាមនោះ ព្រះ អានន្ទកាលសម្តែងបុគ្គលដែលត្រូវការបុណ្យ រមែងធ្វើបុណ្យទាំងឡាយយ៉ាង នេះ ក៏រមែងប្រកបបុគ្គលដែលត្រូវការបុណ្យដទៃៗ ក្នុងការកាន់យកជាបែប ផែនដោយប្រការណា ការប្រកបបុគ្គលដែលត្រូវការបុណ្យ ទុកក្នុងការកាន់

*យកជាបែបផែន ក៏គប្បីជ្រាបថា ជាប្រយោជន៍ក្នុងសេចក្ដីនេះ ដោយប្រការនោះ ។*

*ក្នុងសេចក្ដីនេះ អ្នកចោទសួរពោលថា បើព្រះមានព្រះភាគប្រថាប់នៅក្បែរក្រុងសាវត្ថីមុន ព្រះអានន្ទមិនគួរពោលថា ក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក តែបើប្រថាប់នៅក្នុងវត្តជេតពននោះ ក៏មិនគួរពោលថា ជិតក្រុងសាវត្ថី ព្រោះថា ព្រះមានព្រះភាគមិនអាចប្រថាប់ក្នុងទីទាំង ២ កន្លែងក្នុងពេលតែមួយបានឡើយ ។ សូមចន្លលបង្ហាញដូច្នេះថា ខ្ញុំពោលមកហើយមិនមែនឬថា ពាក្យថា* **សាវត្ថិយំ** *ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ព្រោះថា ប្រៀបដូចហ្វូងគោត្រាច់ទៅក្បែរស្ទឹងគង្គា និងយមុនាជាដើម គេក៏ហៅថា ត្រាច់ទៅជិតស្ទឹងគង្គា ត្រាច់ទៅជិតស្ទឹងយមុនា យ៉ាងណា ព្រះមានព្រះភាគកាលប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក ជិតក្រុងសាវត្ថី ក៏គប្បីជ្រាបថា ប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក ជិតក្រុងសាវត្ថី សូម្បីក្នុងព្រះសូត្រនេះ ក៏ដូច្នោះ ។ ពិតហើយ ពាក្យថា* **សាវត្ថី** *របស់ព្រះថេរៈ ក៏ដើម្បីសម្ដែងគោចរគាម ពាក្យដ៏សេស សម្ដែងទីនៅប្រចាំដែលសមគួរដល់បព្វជិត ។*

*ក្នុងពាក្យទាំង ២ នោះ ព្រះថេរៈសម្ដែងការអនុគ្រោះគ្រហស្ថរបស់ព្រះមានព្រះភាគ ដោយការប្រារព្ធក្រុងសាវត្ថី សម្ដែងការអនុគ្រោះបព្វជិត ដោយការប្រារព្ធវត្តជេតពនជាដើម ។ ម្យ៉ាងទៀត សម្ដែងការវៀរអត្តកិលមថានុយោគ ព្រោះកាន់យកបច្ច័យ ដោយពាក្យដើមសម្ដែងនូវឧបាយ វៀរកាម-*

សុខល្លិកានុយោគ ព្រោះលះវត្ថុកាមដោយពាក្យក្រោយ ។ម្យ៉ាងទៀត សម្តែងសេចក្តីព្យាយាមក្នុងទេសនាដោយពាក្យដើម សម្តែងការបង្អោនទៅក្នុងវិវេកដោយពាក្យក្រោយ សម្តែងការចូលទៅដោយករុណា ដោយពាក្យដើម និងសម្តែងការចូលទៅដោយបញ្ញា ដោយពាក្យក្រោយ ។ សម្តែងភាពដែលព្រះមានព្រះភាគ ទ្រង់បង្អោនទៅក្នុងការឲ្យសម្រេចហិតសុខ ដល់សត្វទាំង-ឡាយ ដោយពាក្យដើម សម្តែងភាពដែលទ្រង់មិនជាប់នៅក្នុងការបំពេញហិតសុខដល់អ្នកដទៃ ដោយពាក្យក្រោយ ។ សម្តែងការនៅជាផាសុក ដែលទ្រង់លះសុខ ប្រកបដោយធម៌ជានិមិត្ត ដោយពាក្យដើម សម្តែងការនៅជាផាសុក ដែលមានការប្រកបរឿយៗ នូវឧត្តរិមនុស្សធម៌ជានិមិត្ត ដោយពាក្យក្រោយ ។ សម្តែងភាពដែលទ្រង់មានឧបការៈច្រើន ដល់មនុស្សទាំងឡាយដោយពាក្យដើម ។ សម្តែងភាពដែលទ្រង់មានឧបការៈច្រើន ដល់ទេវតាទាំង-ឡាយ ដោយពាក្យក្រោយ ។ សម្តែងភាពដែលព្រះមានព្រះភាគ ទ្រង់កើតឡើងក្នុងលោក ចម្រើនក្នុងលោក ដោយពាក្យដើម សម្តែងភាពដែលលោកប្រឡាក់ប្រឡូសព្រះអង្គមិនបាន ដោយពាក្យក្រោយ មានបែបដូចពោលមកនេះជាដើម ។

ពាក្យថា **អជ** ប្រើក្នុងអត្ថថា មិនដាច់ខ្សែ សព្ទថា **ទោ** ជានិបាត ប្រើក្នុងអត្ថថា សម្តែងរឿងដទៃៗ ដោយពាក្យ ២ នោះ ។ ព្រះថេរៈសម្តែងថា រឿងដទៃៗ នេះ កើតឡើងក្នុងព្រះវិហាររបស់ព្រះមានព្រះភាគមិនដាច់ ។ រឿងនោះ គឺអ្វី គឺរឿងទេវតាមួយអង្គជាដើម ។ សព្ទថា **អញ្ញតរា** ក្នុងពាក្យថា

**អញ្ញតរា** *ប្រែថា ទេវតាមួយអង្គនោះ សម្ដែងការមិនពិតប្រាកដ ។ ពិតហើយ ទេវតានោះ មិនប្រាកដឈ្មោះ និងគោត្រ ព្រោះដូច្នោះ ទើបលោកពោលថា* **អញ្ញតរា** ។ *ទេវតា គឺទេវៈនោះឯង ពាក្យថា* **អញ្ញតរា** *នេះ សាធារណៈ ទូទៅដល់ស្ត្រី និងបុរស តែក្នុងទីនេះ បុរសប៉ុណ្ណោះ គឺទេវបុត្រ ។ ក្នុងពាក្យ ខ្លះ ទេវបុត្រ លោកពោលថា ទេវតា ដោយជាសាធារណនាម ។*

## អធិប្បាយ អភិក្កន្ត សព្ទ

*ក្នុងពាក្យថា* **អភិក្កន្តាយ រត្តិយា** *នេះ* **អភិក្កន្ត** *សព្ទ ប្រើក្នុងអត្ថ ទាំងឡាយ គឺអស់ទៅ ល្អ ស្អាត ត្រេកអរក្រៃលែងជាដើម ។*

*ក្នុងអត្ថទាំងនោះ ប្រើក្នុងអត្ថថា អស់ទៅ ដូចក្នុងប្រយោគជាដើមថា*

**អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខំ ។**

*បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ បឋម- យាម កន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ សម្ដែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។*

*ប្រើក្នុងអត្ថថា ល្អ ដូចក្នុងប្រយោគជាដើមថា*

**អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។**

បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះ ចាត់ថា ល្អ ជាងផង ប្រសើរជាងផង ។

ប្រើក្នុងអត្ថថា ស្អាត ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា

**កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ**

**អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា។**

អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ និងយស មានសម្បុរល្អ ( ស្អាត ) ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។

ប្រើក្នុងអត្ថថា ត្រេកអរក្រៃលែង ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម** បពិត្រគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រគោតមដ៏ចម្រើន ពីរោះណាស់ ។

ក្នុងព្រះសូត្រនេះ ប្រើក្នុងអត្ថថា អស់ទៅ អធិប្បាយថា បទថា **អភិក្កន្តាយ រត្តិយា** ប្រែថា កាលរាត្រីអស់ទៅហើយ ។

ក្នុងពាក្យថា **អភិក្កន្តវណ្ណា** នេះ **អភិក្កន្ត** សព្ទ ក្នុងអត្ថថា ស្អាត ។ **វណ្ណ** សព្ទ ប្រើក្នុងអត្ថថា ពណ៌សម្បុរ សរសើរ ពួកត្រកូល ហេតុ ទ្រង់ទ្រាយ ទំហំ រូបាយតនៈជាដើម ។

ប្រើក្នុងអត្ថថា ពណ៌សម្បុរ ដូចក្នុងប្រយោគជាដើមថា **សុវណ្ណវណ្ណោសិ ភគវា** បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គមានពណ៌សម្បុរដូចមាស ។

ប្រើក្នុងអត្ថថា សរសើរ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **កទា**

**សព្យញ្ជនា បន តេ គហបតិ ឥមេ សមណស្ស គោតមស្ស វណ្ណា** នែគហបតី ពាក្យសរសើរ ( គុណ ) ព្រះគោតមទាំងនេះ អ្នកចងក្រងពីពេលណា ។

ប្រើក្នុងអត្ថថា ពួកត្រកូល ដូចក្នុងប្រយោគជាដើមថា **ចត្តារោ មេ ភោ គោតម វណ្ណា** បពិត្រព្រះគោតមដ៏ចម្រើន ត្រកូលទាំង ៤ នេះ ។

ប្រើក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **អថ កេន នុ វណ្ណេន គន្ធថេនោតិ វុច្ចតិ** កាលបើដូច្នេះ ព្រោះហេតុអ្វីហ្ន៎ ទើបអ្នកពោលថាលួចក្លិន ។

ប្រើក្នុងអត្ថថា ទ្រង់ទ្រាយ ដូចក្នុងប្រយោគជាដើមថា **មហន្តំ ហត្ថិ-រាជវណ្ណំ អភិនិម្មិនិត្វា** និម្មិតសណ្ឋានជាស្តេចដំរីធំ ។

ប្រើក្នុងអត្ថថា ទំហំ ដូចក្នុងប្រយោគជាដើមថា **តយោ បត្តស្ស វណ្ណា** បាត្រ ៣ ខ្នាត ។

ប្រើក្នុងអត្ថថា រូបាយតនៈ ដូចក្នុងប្រយោគជាដើមថា **វណ្ណោ គន្ធោ រសោ ឱជា** រូប ក្លិន រស ឱជា ។

**វណ្ណ** សព្ទ ក្នុងសូត្រនេះ គប្បីប្រើក្នុងអត្ថថា ពណ៌សម្បុរ ដោយហេតុនោះ ទើបលោកអធិប្បាយថា បទថា **អភិក្កន្តវណ្ណា** ប្រែថា មានពណ៌សម្បុរគួរស្រឡាញ់ ។

## អធិប្បាយបទថា កេវលកប្បំ

**កេវល** សព្ទ ក្នុងបទថា **កេវលកប្បំ** នេះ មានអត្ថជាច្រើន ដូចជា

*មានអត្ថថា មិនមានចំណែកសល់ ដោយច្រើន មិនលាយឡំ មិនច្រើនពេក មាំទាំ មិនដាច់ដំពាក់ ។*

*ពិតហើយ* **កេវល** *សព្ទនោះ មានអត្ថថា មិនមានចំណែកសល់ ដូចក្នុងប្រយោគជាដើមថា* **កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ** *ទ្រង់□ ប្រកាសព្រហ្មចរិយៈ ដ៏ពេញបរិបូណ៌បរិសុទ□ាំងអស□*

*មានអត្ថថា ដោយច្រើន ដូចក្នុងប្រយោគជាដើមថា* **កេវលកប្បា ច អង្គមគធា បហូតំ ខាទនីយំ ភោជនីយំ អាទាយ អភិក្កមិតុកាមា ហោន្តិ** *ព្រោះថា ជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈ ទាំងអស់គ្នា ( ដោយច្រើន ) ប្រាថ្នានឹងនាំយក ខាទនីយភោជនីយាហារមានប្រមាណច្រើន ចូលមកបូជា ។*

*មានអត្ថថា មិនលាយឡំ ដូចក្នុងប្រយោគជាដើមថា* **កេវលស្ស ទុក្ខ-ក្ខន្ធស្ស សមុទយោ ហោតិ** *សេចក្តីកើតឡើងនៃកងទុក្ខសុទ្ធៗ ទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។*

*មានអត្ថថា មិនច្រើនពេក ដូចក្នុងប្រយោគជាដើមថា* **កេវលំ សទ្ធា-មត្តកំ នូន អយមាយស្មា** *ព្រោះអាស្រ័យនូវគុណធម៌ ត្រឹមតែសទ្ធាម្យ៉ាងដោយពិត ។*

*មានអត្ថថា មាំទាំ ដូចក្នុងប្រយោគជាដើមថា* **អាយស្មតោ ភន្តេ អនុរុទ្ធស្ស ពាហិយោ នាម សទ្ធិវិហារិកោ កេវលកប្បំ សង្ឃភេទាយ ឋិតោ** *បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិករបស់អនុរុទ្ធដ៏មានអាយុ ឈ្មោះវាហិយៈ នៅតែទទូចដើម្បីបំបែកសង្ឃ ឥតឈប់ឈរ ។*

មានអត្ថថា មិនជាប់ជំពាក់ ដូចក្នុងប្រយោគជាដើមថា **កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ** ម្នាលភិក្ខុទាំងឡាយ ( ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥ ) ហៅថា ជាឧត្តមបុរស មានគុណគ្រប់គ្រាន់ ( មិនជាប់ជំពាក់ ) ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ដូច្នេះ ។

តែក្នុងសូត្រនេះ **កេវល** សព្ទនោះ លោកបំណងយកអត្ថថា មិនមានចំណែកសេសសល់ ។

ចំណែក **កប្ប** សព្ទ មានអត្ថច្រើន ដូចជា ការជឿមាំ វោហារ កាល បញ្ញត្តិ តាក់តែង វិកប្ប លេស និងដោយជុំវិញ ។

ពិតហើយ **កប្ប** សព្ទនោះ មានអត្ថថា ជឿមាំ ដូចក្នុងប្រយោគជាដើមថា **ឱកប្បនីយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស** ពាក្យរបស់ព្រះគោតមដ៏ច្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ។

មានអត្ថថា វោហារ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលផ្លែឈើ ដោយសមណកប្ប ( វោហារ ) ៥ យ៉ាង ។

មានអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហារាមិ** តថាគតនេះឯង តែងនៅអស់កាលជានិច្ច ។

មានអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **ឥច្ចាយស្មា កប្បោ**

*កប្បមាណពដ៏មានអាយុទូលសួរថា ។*

*មានអត្ថថា តាក់តែង ដូចក្នុងប្រយោគជាដើមថា* **អលង្កតោ មាល្យ-ធរោ សុវត្ថោ សុកុណ្ឌលី កប្បិតកេសមស្សុ** *អស់មានខោអាវប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា សៀតផ្កាដណាប់ហើយ មានប្រដាប់ត្រចៀកល្អ មានសក់ និង ពុកចង្កាកាត់ឆៀលហើយ ។*

*មានអត្ថថា គួរ ដូចក្នុងប្រយោគជាដើមថា* **កប្បតិ ទ្វង្គុលកប្បោ** *កំណត់ដោយស្រមោល ព្រះអាទិត្យជ្រេទៅ ប្រមាណពីរធ្នាប់ធ្នូរ ។*

*មានអត្ថថា លេស ដូចក្នុងប្រយោគជាដើមថា* **អត្ថិ កប្បោ និប្បជ្ជិតុំ** *បើដូច្នោះ អាត្មាអញដេកសិន ។*

*មានអត្ថថា ដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា* **កេវលកប្បំ ជេតវនំ ឱភាសេត្វា** *ញុំាងវត្តជេតពនឲ្យភ្លឺស្វាងដោយជុំវិញ ។*

*តែក្នុងសូត្រនេះ* **កប្ប** *សព្ទនោះ លោកបំណងយកអត្ថថា ដោយជុំវិញ ដោយប្រការដែលក្នុងពាក្យថា* **កេវលកប្បំ ជេតវនំ** *នេះ គួរនឹងជ្រាបយ៉ាងនេះថា ញុំាងរស្មី ឲ្យភ្លឺពេញវត្តជេតពនដោយជុំវិញ មិនមានសេសសល់ឡើយ ។*

*បទថា* **ឱភាសេត្វា** *បានដល់ ផ្សាយដោយរស្មី អធិប្បាយថា រស្មីតែមួយ រុងរឿងតែម្យ៉ាង ដូចព្រះចន្ទ និងព្រះអាទិត្យ ។*

*បទថា* **យេន ភគវា តេនុបសង្កមិ** *ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ដោយប្រការដែលគប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា ព្រះ*

មានព្រះភាគប្រថាប់នៅក្នុងទីណា ទេវបុត្រក៏ចូលទៅគាល់ក្នុងទីនោះ ឬគប្បី ឃើញក្នុងពាក្យនេះយ៉ាងនេះថា ព្រះមានព្រះភាគ ដែលទេវតា និងមនុស្ស គប្បីចូលទៅគាល់ ដោយហេតុណា ទេវបុត្រក៏ចូលទៅគាល់ដោយហេតុនោះ ឯង ។ ព្រះមានព្រះភាគ ដែលទេវតា និងមនុស្សនាំគ្នាចូលទៅគាល់ ដោយ ហេតុណាមួយ ដោយបំណងនឹងសម្រេចគុណវិសេស មានប្រការផ្សេងៗ ដូចដើមឈើធំដែលចេញផ្លែជានិច្ច ដែលហ្វូងបក្សីនាំគ្នាចូលទៅ ដោយបំណង នឹងបរិភោគផ្លែឈើដែលមានរសឆ្ងាញ់ ដូច្នោះ ។ លោកអធិប្បាយថា បទ ថា **ឧបសង្កមិ** ប្រែថា ទៅហើយ ។ បទថា **ឧបសង្កមិត្វា** ជាពាក្យពោល ដល់ចុងក្រោយនៃការចូលទៅគាល់ ។ម្យ៉ាងទៀត លោកអធិប្បាយថា ទេវតាទៅយ៉ាងនោះហើយ បន្ទាប់អំពីនោះ ក៏ទៅកាន់ទីបន្ទាប់អំពីអាសនៈ ពោល គឺទីជិតព្រះមានព្រះភាគ ។ បទថា **ភគវន្តំ អភិវាទេត្វា** បានដល់ ថ្វាយបង្គំ នមស្ការព្រះមានព្រះភាគ ។

សព្ទថា **ឯកមន្តំ** ជាសព្ទនិទ្ទេស ធ្វើជាការនបុំសកលិង្គ លោកអធិប្បាយ ថា ឱកាសមួយ ចំណែកមួយ ។ ម្យ៉ាងទៀត ពាក្យនេះ ជាទុតិយាវិភត្តិ ចុះ ក្នុងអត្ថសត្តមីវិភត្តិ ។ សព្ទថា **អដ្ឋាសិ** បដិសេធឥរិយាបថអង្គុយជាដើម អធិប្បាយថា សម្រេចការឈរ គឺបានឈរហើយ ។

សួរថា ទេវតាទាំងនោះឈរដូចម្តេច ទើបឈ្មោះថា បានជាអ្នកឈរក្នុង ចំណែកម្ខាង ។ ឆ្លើយថា បុរាណាចារ្យពោលថា

**ន បច្ឆតោ ន បុរតោ ນាបិ អាសន្នទូរតោ**

**ន កច្ច នោបិ បជិវាតេ ន ចាបិ ឱណាតុណ្ណាតេ**

**ឥមេ ទោសេ វិវជ្ជេត្វា ឯកមន្តំ ឋិតា អហុ ។**

*មិនឈរខាងក្រោយ មិនឈរខាងមុខ មិនឈរជិត*

*មិនឈរឆ្ងាយ មិនឈរក្នុងទីសើម មិនឈរលើខ្យល់*

*មិនឈរទីទាប និងទីខ្ពស់ ឈរវៀរទោសទាំងនេះ*

*ឈ្មោះថា ឈរក្នុងចំណែកម្ខាង ដូច្នេះ ។*

*សួរថា ព្រោះហេតុអ្វី ទើបទេវតាឈរតែម្យ៉ាង មិនអង្គុយ ។ ឆ្លើយថា ព្រោះទេវតាបំណងត្រឡប់ទៅវិញដោយរហ័ស ពិតហើយ ទេវតាទាំងឡាយ អាស្រ័យអំណាចប្រយោជន៍ណាមួយ ទើបមកកាន់មនុស្សលោក ដូចបុរស អ្នកស្អាតមកចូលបង្គន់ ។ ដោយប្រក្រតី មនុស្សលោករមែងជារបស់បដិកូល ព្រោះជារបស់ស្អុយសម្រាប់ទេវតាទាំងនោះ តាំងអំពី ១០០ យោជន៍ ទេវតាទាំងឡាយ មិនអភិរម្យក្នុងមនុស្សលោកនោះឡើយ ដោយហេតុនោះ ទើបទេវតាអង្គនោះមិនអង្គុយ ព្រោះបំណងធ្វើកិច្ចដែលមក ហើយប្រញាប់ត្រឡប់ទៅ ។ មនុស្សទាំងឡាយ រមែងអង្គុយដើម្បីបន្ទោបង់សេចក្តីលំបាកនៃឥរិយាបថ មានដើរជាដើម យ៉ាងណា ការលំបាកនោះ សម្រាប់ទេវតាមិនមាន ព្រោះដូច្នោះ ទើបទេវតាមិនអង្គុយ ។*

*ម្យ៉ាងទៀត ព្រះមហាសាវកពួកណា ឈរចោមរោមព្រះមានព្រះភាគ ព្រះមានព្រះភាគក៏ទ្រង់រាប់អានព្រះមហាសាវកទាំងនោះ គឺទ្រង់ប្រថាប់ឈរដែរ ព្រោះហេតុនោះ ទើបទេវតាមិនអង្គុយ ។*

ម្យ៉ាងទៀត ទេវតាមិនអង្គុយ ក៏ព្រោះគោរពក្នុងព្រះមានព្រះភាគ ។ ពិតហើយ អាសនៈរមែងកើតដល់ទេវតាទាំងឡាយ ដែលបំណងនឹងអង្គុយ ទេវតាអង្គនេះមិនប្រាថ្នាអាសនៈទាំងនោះ មិនគិតសូម្បីតែអង្គុយ ទើបឈរក្នុងចំណែកម្ខាង ។

បទថា **ឯកមន្តំ ឋិតា ខោ សា ទេវតា** សេចក្ដីថា ទេវតាអង្គនោះឈរក្នុងទីសមគួរ នាចំណែកម្ខាង ដោយហេតុទាំងនេះយ៉ាងនេះហើយ ។ បទថា **ភគវន្តំ គាថាយ អជ្ឈភាសិ** សេចក្ដីថា បានទូលព្រះមានព្រះភាគដោយពាក្យកម្រងកែវ ដែលកំណត់ដោយអក្ខរបទ ។ ពោលដូចម្ដេច ពោលយ៉ាងនេះថា **ពហូ ទេវា មនុស្សា ច ។បេ។ ព្រូហិ មង្គលមុត្តមំ។**

## មូលហេតុកើតមង្គលប្បញ្ហា

ក្នុងកិច្ចពណ៌នាមង្គលសូត្រនោះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាថា កាលនឹងពណ៌នាសេចក្ដីនៃបាឋៈ មាន **ឯវំ** ជាដើម ដោយប្រការផ្សេងៗ និងពោលដល់សមុដ្ឋាន ដូច្នេះ ។ នេះជាឱកាសដែលនឹងពោលដល់សមុដ្ឋាននោះ ដូច្នោះ នឹងពោលដល់សមុដ្ឋាន មូលហេតុកើតមង្គលប្បញ្ហាជាមុន ហើយនឹងពណ៌នាអត្ថនៃបទគាថាទាំងនេះជាក្រោយ ។

បានឮថា ក្នុងជម្ពូទ្វីប មហាជនប្រជុំគ្នាក្នុងទីនោះៗ ក្នុងទីនោះៗ ដូចជាក្បែរទ្វារក្រុង សភានៃស្ថានរាជការជាដើម ប្រគល់ទ្រព្យ មាស ប្រាក់ ឲ្យគេនិទានរឿងផ្សេងៗ ដូចជា រឿងនាំនាងសិតាមកជាដើម ។ រឿងនីមួយៗ ពោលអស់ ៤ ខែទើបចប់ ។ ក្នុងទីនោះៗ មួយថ្ងៃៗ រឿងមង្គលប្បញ្ហាកើត

ឡើងថា អ្វីហ្ន៎ជាមង្គល វត្ថុដែលឃើញជាមង្គលឬ វត្ថុដែលបានឮជាមង្គល ឬ រឿងដែលដឹងជាមង្គលឬ នរណាហ្ន៎ស្គាល់មង្គល ដូច្នេះ ។

គ្រានោះ បុរសម្នាក់ ឈ្មោះទិដ្ឋមង្គលិក ជាអ្នករាប់អាន ជឿនូវការឃើញជាជាមង្គល ពោលថា ខ្ញុំស្គាល់មង្គល ។ វត្ថុដែលឃើញជាមង្គលក្នុងលោក រូបដែលសន្មតគ្នាថា ជាមង្គលក្រៃលែង ឈ្មោះថា **ទិដ្ឋ** ។ រូបដូចម្តេច បុគ្គលខ្លះ ក្នុងលោកនេះ ភ្ញាក់អំពីព្រលឹម ឃើញសត្វត្រចៀកកាំក្តី ឃើញដើមញ្ញៅជំទង់ក្តី ឃើញស្រីមានគភ៌ក្តី ឃើញក្មេងជំទង់តាក់តែងប្រដាប់កាយ ទូលក្អមទឹកដែលពេញក្តី ឃើញត្រីស្លិតក្រហមក្តី សេះអាជានេយ្យក្តី រថទឹមដោយសេះក្តី គោឈ្មោលក្តី គោញីក្តី គោក្រហមក្តី ឬថា ឃើញរូបដទៃណាបែបនោះ ដែលសន្មតគ្នាថា ជាមង្គលក្រៃលែង រូបដែលឃើញនេះ ហៅថា **ទិដ្ឋមង្គល** ។ បុគ្គលពួកខ្លះ ក៏រមែងទទួលពាក្យរបស់បុគ្គលនោះ ពួកខ្លះក៏មិនព្រមទទួល ពួកដែលមិនព្រមទទួល ក៏ជំទាស់នឹងបុគ្គលទាំងនោះ ។

គ្រានោះ បុរសម្នាក់ ឈ្មោះសុតមង្គលិកក៏ពោលថា អ្នកអើយ ឈ្មោះថា ភ្នែក រមែងឃើញរបស់ស្អាតខ្លះ របស់មិនស្អាតខ្លះ របស់ស្អាត និងមិនស្អាតខ្លះ របស់ពេញចិត្តខ្លះ របស់មិនពេញចិត្តខ្លះ បើរូបដែលបុគ្គលនោះឃើញគប្បីជាមង្គលសោត ក៏គប្បីជាមង្គលទាំងអស់ ព្រោះដូច្នោះ រូបដែលឃើញមិនជាមង្គលឡើយ សំឡេងដែលបានឮឯណោះទេតើ ជាមង្គល ។ សំឡេងដែលសន្មតថា ជាមង្គលក្រៃលែង ។ ឈ្មោះថា សុតៈ ដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ក្រោកឡើងអំពីព្រលឹម បានឮសំឡេងដូច្នេះថា ចម្រើនហើយ

ចម្រើនទៀត ពេញ ស ចិត្តល្អ សិរី ចម្រើនដោយសិរី ថ្ងៃនេះឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ ឬសំឡេងដែលសន្មតថា មង្គលឯណានីមួយ ។ សំឡេងដែលបានឮនេះ ហៅថា **សុតមង្គល** ។ ជនពួកខ្លះក៏រមែងទទួលពាក្យរបស់គាត់ ជនពួកខ្លះក៏មិនព្រមទទួល ពួកដែលមិនព្រមទទួល ក៏ជំទាស់ ។

គ្រានោះ បុរសម្នាក់ ឈ្មោះមុតមង្គលិក ពោលថា អ្នកអើយ តាមពិតនោះ ឈ្មោះថា ត្រចៀក រមែងបានឮសំឡេងល្អខ្លះ មិនល្អខ្លះ គាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះ បើសំឡេងដែលបុគ្គលនោះបានឮ ជាមង្គលសោត ក៏នឹងជាមង្គលទាំងអស់ទៅហើយ ព្រោះដូច្នោះ ទើបសំឡេងដែលបានឮ មិនជាមង្គលឡើយ តែវត្ថុដែលដឹងហើយឯណោះទេតើ ជាមង្គល ក្លិន រស និងផោដ្ឋព្វៈ វត្ថុដែលគប្បីពាល់ត្រូវ ឈ្មោះថា មុតៈ សេចក្ដីនេះ ដូចម្ដេច ។ បុគ្គលខ្លះក្រោកអំពីព្រលឹម ហិតក្លិនផ្កា មានផ្កាឈូកជាដើម ទំពាឈើស្ទន់សខ្លះ ចាប់ពាល់ផែនដីខ្លះ ចាប់ពាល់សន្ទូងពណ៌ខៀវខ្លះ អាចម៍គោស្រស់ខ្លះ អណ្ដើកខ្លះ ល្ងខ្លះ ផ្កាខ្លះ ផ្លែឈើខ្លះ លាបដោយដីសដោយប្រពៃខ្លះ ស្លៀកសំពត់សខ្លះ ជូតដោយសំពត់សខ្លះ ឬថា ហិតក្លិន លិទ្ធរស ពាល់ត្រូវផោដ្ឋព្វៈ ដែលសន្មតថា ជាមង្គលក្រៃលែងដទៃណាមួយបែបនោះ វត្ថុដូចពោលមកនេះ ហៅថា **មុតមង្គល** ។ ពួកខ្លះ ក៏រមែងទទួលពាក្យរបស់គាត់ ពួកខ្លះ ក៏មិនព្រមទទួល ។

ក្នុង ៣ ពួកនោះ ទិដ្ឋមង្គលិកបុរស មិនអាចធ្វើឲ្យសុតមង្គលិកបុរស និងមុតមង្គលិកបុរសយល់ព្រមបាន ទាំង ៣ ចំណែកនោះ ចំណែកនីមួយៗ

ក៏ធ្វើ ២ ចំណែកទៀត ឲ្យយល់ព្រមមិនបាន បណ្តាមនុស្សទាំងនោះ មនុស្សពួកណា ទទួលពាក្យរបស់ទិដ្ឋមង្គលិកបុរស ពួកនោះក៏ប្រកាន់ថា រូបដែលឃើញហើយប៉ុណ្ណោះជាមង្គល ។ ពួកណាវមែងទទួលពាក្យរបស់សុតមង្គលិកបុរស និងមុតមង្គលិកបុរស ពួកនោះក៏កាន់យកសំឡេងដែលបានឮប៉ុណ្ណោះជាមង្គល វត្ថុដែលបានដឹងប៉ុណ្ណោះជាមង្គល ។ រឿងមង្គលប្បញ្ហានេះ ប្រាកដពេញជម្ពូទ្វីប ដោយប្រការដូច្នេះ ។

គ្រានោះ មនុស្សពេញជម្ពូទ្វីប ប្រកាន់ជាពួកៗ នាំគ្នាគិតមង្គលទាំងឡាយថា អ្វីហ្ន៎ ជាមង្គល ។ អារក្ខទេវតានៃមនុស្សទាំងនោះ ស្តាប់រឿងនោះហើយក៏នាំគ្នាគិតមង្គលទាំងឡាយដូចគ្នា ។ ទាំងពួកភុម្មទេវតាជាសម្លាញ់នៃទេវតាទាំងនោះ ស្តាប់រឿងអំពីអារក្ខទេវតាទាំងនោះហើយ ក៏នាំគ្នាគិតមង្គលទាំងនោះដូចគ្នា ។ អាកាសដ្ឋកទេវតា ជាមិត្តរបស់ទេវតាទាំងនោះ ចាតុម្មហារាជិកទេវតាជាមិត្តរបស់អាកាសដ្ឋកទេវតាទាំងនោះ ដោយឧបាយនេះ ដរាបដល់អកនិដ្ឋទេវតាជាមិត្តរបស់សុទស្សីទេវតា ស្តាប់រឿងអំពីសុទស្សីទេវតាទាំងនោះហើយ ក៏កាន់យកជាពួកៗ នាំគ្នាគិតមង្គលទាំងឡាយ ដោយឧបាយយ៉ាងនេះ ការគិតមង្គលបានកើតគ្រប់ទីកន្លែង រហូតដល់ម៉ឺនចក្រវាល ។ ការគិតមង្គលកើតឡើងហើយ សូម្បីវិនិច្ឆ័យថា នេះជាមង្គល នេះជាមង្គល តែក៏មិនដាច់ស្រេច ទើបតាំងនៅអស់ ១២ ឆ្នាំ មនុស្សក្តី ទេវតាក្តី ព្រហ្មទាំងអស់ក្តី វៀរព្រះអរិយសាវក បែកគ្នាជា ៣ ពួក គឺទិដ្ឋមង្គលិក ១ ពួក សុតមង្គលិក ១ ពួក និងមុតមង្គលិក ១ ពួក សូម្បី ១ ពួកៗ ក៏មិនយល់ព្រមតាមការ

ពិតបានថា នេះប៉ុណ្ណោះ ជាមង្គល មង្គលកោលាហល គឺការជ្រួលច្របល់រឿងមង្គលកើតឡើងហើយក្នុងលោក ។

ឈ្មោះថា កោលាហលមាន ៥ គឺកប្បកោលាហល ១ ចក្កវត្តិកោលាហល ១ ពុទ្ធកោលាហល ១ មង្គលកោលាហល ១ មោនេយ្យកោលាហល ១ ។ បណ្ដាកោលាហលទាំង ៥ នោះ ពួកទេវតាជាន់កាមាវចរ ឱនក្បាលរម្សាយសក់ ទ្រហោយំ យកដៃជូតទឹកភ្នែក ស្លៀកសំពត់ពណ៌ក្រហម ទ្រទ្រង់ភេទចម្លែកៗ ក្រៃលែង ត្រាច់ទៅក្នុងទឹកដីមនុស្ស ស្រែកប្រកាសថា កន្លងទៅមួយសែនឆ្នាំទៀត កប្បនឹងប្រាកដ លោកនេះនឹងវិនាស មហាសមុទ្រនឹងរីងស្ងួត មហាប្រឹថពីនេះ និងស្ដេចភ្នំសិនេរុនឹងត្រូវភ្លើងឆេះ នឹងវិនាស លោកវិនាសនឹងមានដល់ព្រហ្មលោក ។ នៃអ្នកនិទ៌ុក្ខ សូមអ្នកទាំងឡាយនាំគ្នាចម្រើនមេត្តាចុះ ចូរនាំគ្នាចម្រើនករុណា មុទិតា ឧបេក្ខាចុះ អ្នកនិទ៌ុក្ខ ចូរបម្រើមាតាបិតា ចូរកោតក្រែងបុគ្គលជាធំក្នុងត្រកូល ជាអ្នកភ្ញាក់រឭកចុះ កុំប្រមាទឡើយ នេះ ឈ្មោះថា **កប្បកោលាហល** ។

ទេវតាជាន់កាមាវចរនោះឯង ត្រាច់ទៅក្នុងទឹកដីមនុស្ស ប្រកាសថា កន្លងទៅ ១០០ ឆ្នាំ ស្ដេចចក្រពត្តិ នឹងកើតឡើងក្នុងលោក នេះ ឈ្មោះថា **ចក្កវត្តិកោលាហល** ។ ឯទេវតាជាន់សុទ្ធាវាស ប្រដាប់ខ្លួនដោយអាភរណៈព្រហ្ម ជួតក្បាលដោយឆ្នួតព្រហ្ម កើតបីតិបាមោជ្ជ ពោលពុទ្ធគុណ ត្រាច់ទៅក្នុងទឹកដីមនុស្ស ប្រកាសថា កន្លងទៅ ១០០០ ឆ្នាំ ព្រះពុទ្ធនឹងកើតឡើងក្នុងលោក នេះ ឈ្មោះថា **ពុទ្ធកោលាហល** ។

ទេវតាជាន់សុទ្ធាវាសនោះឯង ដឹងចិត្តរបស់ពួកមនុស្ស ត្រាច់ទៅក្នុងទឹកដីមនុស្ស ប្រកាសថា កន្លងទៅ ១២ ឆ្នាំ ព្រះសម្មាសម្ពុទ្ធនឹងត្រាស់មង្គលនេះ ឈ្មោះថា **មង្គលកោលាហល** ។

ទេវតាជាន់សុទ្ធាវាសនោះឯង ត្រាច់ទៅក្នុងទឹកដីមនុស្ស ប្រកាសថា កន្លងទៅ ៧ ឆ្នាំ ភិក្ខុមួយរូប សមាគមជាមួយនឹងព្រះមានព្រះភាគ នឹងទូលសួរមោនេយ្យប្បដិបទា នេះ ឈ្មោះថា **មោនេយ្យកោលាហល** ។ បណ្តាកោលាហលទាំង ៥ នេះ មង្គលកោលាហលរបស់ទេវតា និងមនុស្សទាំងឡាយ កើតឡើងហើយក្នុងលោក ។

គ្រានោះ កាលទេវតា និងមនុស្សទាំងឡាយ នាំគ្នាសម្រេចមិនទាន់បាននូវមង្គលទាំងឡាយ កន្លងទៅ ១២ ឆ្នាំ ទេវតាជាន់តាវត្តិង្សក៏ប្រជុំគ្នា នាំគ្នាគិតយ៉ាងនេះថា មេផ្ទះ ក៏ជាម្ចាស់របស់មនុស្សក្នុងផ្ទះ មេស្រុក ក៏ជាប្រធានរបស់មនុស្សដែលនៅក្នុងស្រុក ព្រះរាជាជាប្រធានរបស់មនុស្សទាំងឡាយ សក្កទេវរាជអង្គនេះ ក៏ជាបុគ្គលប្រសើរបំផុតរបស់ពួកយើង គឺជាអធិបតីនៃទេវលោកទាំង ២ គឺចាតុម្មហារាជិកា និងតាវត្តិង្ស ដោយបុញ្ញ តេជៈ ឥស្សរិយបញ្ញា ។ ហេតុនេះ យើងគប្បីនាំគ្នាទៅទូលសេចក្តីនោះនឹងសក្កទេវរាជ ស្តេចទេវតាចុះ ។ ទេវតាទាំងនោះ ក៏នាំគ្នាទៅកាន់សម្នាក់ទេវរាជ ថ្វាយបង្គំសក្កទេវរាជដែលមានព្រះសរីរៈ មានសិរី ដោយអាភរណៈប្រចាំព្រះអង្គដែលសមគួរដល់ខណៈនោះ មានពួកទេពអប្សរ ២៥០ កោដិ[១] ប្រថាប់លើ

១- ក្នុងទីខ្លះ ពាក្យថា អឌ្ឍតេយ្យកោដិ នេះ លោកប្រែថា ២ កោដិកន្លះ ។

បណ្ឌុកម្ពលសិលាអាសនៈដ៏ប្រសើរ ខាងក្រោមដើមបារិច្ឆត្តកៈ ហើយឈរក្នុងទីសមគួរ នាចំណែកម្ខាង ទូលថា បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ សូមទ្រង់ប្រទាននូវព្រះវរោកាស សូមទ្រង់ជ្រាបចុះ ឥឡូវនេះ មង្គលបញ្ហាតាំងឡើងហើយ ជន ១ ពួកពោលថា រូបដែលឃើញជាមង្គល ១ ពួកពោលថា សំឡេងដែលបានឮជាមង្គល ១ ពួកពោលថា វត្ថុដែលដឹងហើយជាមង្គល បណ្ដាអ្នកទាំងនោះ ពួកទូលបង្គំ និងពួកជនដទៃ មិនទាន់បាននូវភាពត្រឹមត្រូវ សូមទ្រង់ព្រះមេត្តាព្យាករតាមសេចក្ដីពិតដល់ពួកទូលបង្គំផងចុះ ។ សក្កទេវរាជ ដោយប្រក្រតី ទ្រង់មានបញ្ញា ទើបត្រាស់ថា រឿងមង្គលនេះ កើតឡើងទីណាមុន ពួកទេវតាក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំស្ដាប់ពាក្យទេវតាចាតុម្មហារាជ បន្ទាប់អំពីនោះ ពួកទេវតាចាតុម្មហារាជ ស្ដាប់ពាក្យរបស់ពួកអាកាសដ្ឋកទេវតា ពួកអាកាសដ្ឋកទេវតា ស្ដាប់ពាក្យរបស់ពួកភុម្មទេវតា ពួកភុម្មទេវតាស្ដាប់ពាក្យរបស់ទេវតាដែលរក្សាមនុស្ស ទេវតាដែលរក្សាមនុស្សពោលថា រឿងមង្គលកើតឡើងក្នុងមនុស្សលោក ។

លំដាប់នោះ សក្កទេវរាជត្រាស់សួរស្ដេចទេវតាទាំងនោះថា ព្រះសម្ពុទ្ធប្រថាប់នៅទីណា ។ ទេវតាទាំងឡាយទូលថា ប្រថាប់នៅក្នុងមនុស្សលោក ព្រះឥន្ទ្រត្រាស់សួរថា បុគ្គលណាម្នាក់ បានទូលសួរព្រះមានព្រះភាគអង្គនោះហើយឬនៅ ពួកទេវតាទូលថា មិនមានទេ ព្រះអង្គ ។ ព្រះឥន្ទ្រត្រាស់ថា នែអ្នកនិទ្ទុក្ខ ហេតុអ្វីអ្នកទាំងឡាយបោះបង់គំនរភ្លើង ហើយមកសម្គាល់ក្នុងពន្លឺអំពិលអំពែក ហេតុអ្វី ទើបអ្នកទាំងឡាយរំលងព្រះមានព្រះភាគ ដែលទ្រង់

សម្តែងមង្គលមិនមានសេសសល់ មកសម្គាល់ខ្ញុំថា គួរសាកសួរ ណ្ហើយចុះ អ្នកនិទ្ទុក្ខទាំងឡាយ យើងនឹងសាកសួរព្រះមានព្រះភាគអង្គនោះ ពួកយើងនឹងបានការព្យាករណបញ្ហាដ៏មានសិរីពិត ទើបមានទេវាង្ការ ប្រើទេវបុត្រមួយអង្គថា អ្នកចូរទៅទូលសួរព្រះមានព្រះភាគចុះ ។ ទេវបុត្រអង្គនោះតាក់តែងគ្រឿងអលង្ការដ៏សមគួរដល់ខណៈ រុងរឿងដូចផ្លេកបន្ទោរ មានពួកទេវតាចោមរោម ទៅកាន់វត្តជេតពនមហាវិហារ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីសមគួរ នាចំណែកម្ខាង កាលសួរមង្គលបញ្ហា ទើបពោលជាគាថាថា **ពហូ ទេវា មនុស្សា ច** ជាដើម ។

នេះជាមូលហេតុនៃមង្គលបញ្ហា ។

## អធិប្បាយបទថា ពហូ ទេវា

ឥឡូវនេះ នឹងពណ៌នាអត្ថនៃបទគាថា ។ សព្ទថា **ពហូ** សម្តែងចំនួនមិនពិតប្រាកដ ព្រោះហេតុនោះ ទើបលោកអធិប្បាយថា ច្រើនរយ ច្រើនពាន់ច្រើនសែន ។ ឈ្មោះថា **ទេវ** ព្រោះលេង អធិប្បាយថា លេងជាមួយកាមគុណ ៥ ឬរុងរឿងដោយសិរីរបស់ខ្លួន ។ ន័យម្យ៉ាងទៀត បទថា **ទេវា** បានដល់ ទេវៈទាំង ៣ គឺ **សម្មតិទេវ ឧបបត្តិទេវ** និង **វិសុទ្ធិទេវ** ដូចលោកពោលថា

បទថា **ទេវា** បានដល់ ទេវៈ ៣ គឺសម្មតិទេវៈ ១ ឧបបត្តិទេវៈ ១ និងវិសុទ្ធិទេវៈ ១ ។

បណ្តាទេវៈទាំង ៣ នោះ ពួកព្រះរាជា ព្រះរាជកុមារ

និងព្រះទេពី លោកហៅថា សម្មតិទេព ។ ពួកទេព ឋិតនៅក្នុងចាតុម្មហារាជិកាឡើងទៅ លោកហៅថា ឧបបត្តិទេព ។ ពួកព្រះអរហន្តខីណាស្រពជាសាវ័ករបស់ ព្រះតថាគត និងពួកខីណាស្រពដែលជាព្រះបច្ចេកពុទ្ធ លោកហៅថា វិសុទ្ធិទេព ។

ក្នុងទេវៈទាំង ៣ នោះ ក្នុងសូត្រនេះ លោកបំណងយកឧបបត្តិទេព ។ ឈ្មោះថា **មនុស្សា** ព្រោះជាវង្សរបស់ព្រះបាទមនូ តែបុរាណពោលថា ឈ្មោះថា **មនុស្ស** ព្រោះជាអ្នកមានចិត្តខ្ពស់ ។ មនុស្សទាំងនោះមាន ៤ គឺអ្នកជម្ពូទ្វីប ១ អ្នកអមរគោយានទ្វីប ១ អ្នកឧត្តរកុរុទ្វីប ១ អ្នកបុព្វវិទេហទ្វីប ១ ។ ក្នុងសូត្រនេះ លោកបំណងយកអ្នកជម្ពូទ្វីប ឈ្មោះថា **មង្គលានិ** ព្រោះសត្វរុងរឿងដោយគុណទាំងនេះ អធិប្បាយថា សត្វដល់នូវការសម្រេច និងសេចក្តីចម្រើន ។

បទថា **អចិន្តយុំ** ប្រែថា គិតគ្នាហើយ ។ បទថា **អាកង្ខមានា** បានដល់ បំណង ប្រាថ្នា ត្រូវការ ។ បទថា **សោត្ថានំ** ប្រែថា សួស្តី លោកអធិប្បាយថា ភាពដែលធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងចំណែកខាងមុខគ្រប់យ៉ាង ស្អាតល្អ ។ បទថា **ព្រូហិ** បានដល់ សម្តែង ប្រកាស ប្រាប់ បើកផ្សារ ចែក ធ្វើឲ្យងាយ ។ បទថា **មង្គលំ** បានដល់ ហេតុនៃការសម្រេច ហេតុនៃសេចក្តីចម្រើន ហេតុនៃសម្បត្តិគ្រប់យ៉ាង ។ បទថា **ឧត្តមំ** បានដល់ វិសេសប្រសើរ នាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់លោកទាំងពួង

ដូចពោលមកនេះ ជាការពណ៌នាតាមលំដាប់បទនៃគាថាទាំងឡាយ ។

ឯសេចក្តីរួម មានដូច្នេះ ទេវបុត្រនោះឯង ឃើញទេវតាក្នុងម៉ឺនចក្រវាល ប្រជុំគ្នាក្នុងចក្រវាលនេះ ព្រោះចង់ស្តាប់មង្គលបញ្ហា នាំគ្នានិម្មិតអត្តភាពដ៏ល្អិត ១០ ខ្ទះ ២០ ខ្ទះ ៣០ ខ្ទះ ៤០ ខ្ទះ ៥០ ខ្ទះ ៦០ ខ្ទះ ៧០ ខ្ទះ ៨០ ខ្ទះ ។ ទំហំ ឱកាសចុងរោមទ្រាយ ១ ឈរជុំវិញព្រះមានព្រះភាគ ដែលប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ បញ្ចេញព្រះរស្មី គ្របសង្កត់ទេវតា មារ ព្រហ្មទាំងអស់ ដោយព្រះសិរី និងព្រះតេជះ ហើយទ្រង់ជ្រាបវិតក្កនៃចិត្តនៃពួកមនុស្សអ្នកជម្ពូទ្វីប ដែលមិនបានមកប្រជុំ ក្នុងសម័យនោះដោយចិត្តខ្លួនឯង ទើបពោលគាថា ដើម្បីដកនូវព្រួញ គឺសេចក្តីសង្ស័យរបស់ទេវតា និងមនុស្សទាំងពួងថា

ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នារកសួស្តី
បានគិតរកមង្គលទាំងឡាយ សូមព្រះអង្គសម្តែងប្រាប់
នូវមង្គលដ៏ឧត្តម ។

បពិត្រព្រះមានព្រះភាគ ទ្រង់ជាអ្នកដែលខ្ញុំព្រះអង្គទូលសួរហើយ ដោយអនុមតិរបស់ទេវតាទាំងនោះ និងដោយអនុគ្រោះមនុស្សទាំងឡាយ មង្គលឯណា ដែលជាឧត្តមមង្គល ព្រោះនាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់ខ្ញុំព្រះអង្គទាំងឡាយ សូមទ្រង់អាស្រ័យព្រះករុណាត្រាស់ប្រាប់មង្គលនោះដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។

# អធិប្បាយបទថា អសេវនា ច

ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យទេវបុត្រនោះយ៉ាងនេះហើយ ទើបត្រាស់ព្រះគាថាថា **អសេវនា ច ពាលានំ** ជាដើម ។ ក្នុងព្រះគាថានោះបទថា **អសេវនា** បានដល់ ការមិនគប់ មិនចូលទៅជិត ។

បទថា **ពាលានំ** សេចក្តីថា ឈ្មោះថា ពាល ព្រោះរស់នៅ ដកដង្ហើមបាន អធិប្បាយថា រស់នៅដោយត្រឹមតែដកដង្ហើមចេញ-ចូល មិនរស់នៅដោយការរស់នៅដោយបញ្ញា ។ នូវពាលទាំងនោះ ។

បទថា **បណ្ឌិតានំ** សេចក្តីថា ឈ្មោះថា បណ្ឌិត ព្រោះប្រព្រឹត្តទៅ អធិប្បាយថា ប្រព្រឹត្តទៅដោយគតិ គឺការដឹងក្នុងប្រយោជន៍ដែលជាបច្ចុប្បន្ន និងប្រយោជន៍ខាងមុខ ។ នូវបណ្ឌិតទាំងនោះ ។

បទថា **សេវនា** បានដល់ ការគប់រក ការចូលជិត ការមានបណ្ឌិតនោះជាសម្លាញ់ មានបណ្ឌិតនោះជាមិត្រ ការដល់ព្រមដោយបណ្ឌិតនោះ ។

បទថា **បូជា** បានដល់ ធ្វើសក្ការៈ គោរពរាប់អាន ក្រាបថ្វាយបង្គំ ។

បទថា **បូជនីយានំ** ប្រែថា បុគ្គលគួរបូជា ។

បទថា **ឯតម្មង្គលមុត្តមំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ប្រមូលការមិនសេពគប់បុគ្គលពាល ១ ការគប់រកបណ្ឌិត ១ ការបូជាដល់បុគ្គលដែលគួរបូជា ១ ទើបត្រាស់ថា **ឯតម្មង្គលមុត្តមំ** ។ លោកអធិប្បាយថា ពាក្យណាលោកសួរថា សូមត្រាស់ប្រាប់មង្គលដ៏ឧត្តមចុះ អ្នកចូរកាន់យកពាក្យនោះថាមង្គលដ៏ឧត្តមក្នុងសេចក្តីនោះមុន នេះជាពណ៌នាបទនៃគាថានោះ ។

ឯពណ៌នាអត្ថនៃបទនោះ គប្បីជ្រាបដូច្នេះ ព្រះមានព្រះភាគទ្រង់ស្តាប់

ពាក្យរបស់ទេវបុត្រនោះហើយ ទើបត្រាស់ព្រះគាថានេះថា **អសេវនា ច ពាលានំ** ជាដើម ។

ក្នុងគាថានោះ គាថាមាន ៤ គឺ **បុច្ឆិតគាថា អបុច្ឆិតគាថា សានុសន្ធិកគាថា អននុសន្ធិកគាថា** ។

បណ្តាគាថាទាំង ៤ នោះ គាថាដែលទ្រង់ត្រូវសួរហើយ ទើបត្រាស់ឈ្មោះថា **បុច្ឆិតគាថា** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **បុច្ឆាមិ តំ គោតម ភូរិបញ្ញ កថំករោ សាវកោ សាធុ ហោតិ** បពិត្រព្រះគោតម ទ្រង់មានព្រះបញ្ញាដូចផែនដី ខ្ញុំសូមក្រាបទូលសួរព្រះអង្គ ( បុគ្គលដែលចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្តី ឬក៏ពួកឧបាសកមានផ្ទះក្តី ) ប្រតិបត្តិដូចម្តេចទើបហៅថា សាវកល្អ ។ និងដូចប្រយោគថា **កថំ នុ ត្វំ មារិស ឱឃមតរិ** បពិត្រព្រះអង្គនិទ្ទុក្ខ ព្រះអង្គឆ្លងនូវអន្លង់ ដោយហេតុដូចម្តេចហ្ន៎ ។

គាថាដែលព្រះអង្គមិនត្រូវអ្នកដទៃសួរ ទ្រង់ត្រាស់ដោយព្រះអធ្យាស្រ័យរបស់ព្រះអង្គឯង ឈ្មោះថា **អបុច្ឆិតគាថា** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **យំ បរេ សុខតោ អាហុ តទរិយា អាហុ ទុក្ខតោ** ពួកជនពាលដទៃពោលនូវវត្ថុកាមណា ថាជាសុខ ព្រះអរិយៈទាំងឡាយ ពោលនូវវត្ថុកាមនោះ ថាជាទុក្ខ ។ គាថាទាំងអស់របស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា **សានុសន្ធិកគាថា** ព្រោះបាលីថា **សនិទានាហំ ភិក្ខវេ ធម្មំ ទេសេស្សាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌សមតាមហេតុ ដូច្នេះ ។ ដែលឈ្មោះថា **អននុសន្ធិកគាថា** គាថាមិនមានហេតុ មិនមានក្នុងសាសនានេះ បណ្តាគាថា

ទាំងនេះ ដូចពោលមកនេះ គាថានេះ ឈ្មោះថា **បុច្ឆិតគាថា** ព្រោះជាគាថា ដែលព្រះមានព្រះភាគត្រូវទេវបុត្រសួរហើយ ទើបត្រាស់តប ។ គាថានេះ ប្រាប់បុគ្គលដែលមិនគួរសេពគប់ ក្នុងបុគ្គលដែលគួរសេពគប់ និងមិនគួរសេពគប់ហើយ ទើបប្រាប់បុគ្គលដែលគួរសេពគប់ ប្រៀបដូចបុរសអ្នកឈ្លាសស្គាល់ផ្លូវផង ស្គាល់វត្ថុដែលមិនមែនផ្លូវផង ត្រូវគេសួរដល់ផ្លូវ ទើបប្រាប់ផ្លូវដែលគួរវៀរជាមុនហើយ ក្រោយមក ទើបប្រាប់ផ្លូវដែលគួរកាន់យកថា ក្នុងទីត្រង់នោះ មានផ្លូវបែកជា ២ ក្នុងផ្លូវបែកជា ២ នោះ ពួកអ្នកចូរវៀរបង់នូវផ្លូវខាងឆ្វេង ហើយកាន់យកផ្លូវខាងស្តាំ ដូច្នោះ ។ ព្រះមានព្រះភាគ ទ្រង់ដូចបុរសអ្នកឈ្លាសក្នុងផ្លូវ ដែលត្រាស់ថា

> ម្នាលតិស្សៈ ពាក្យថា បុរសអ្នកឈ្លាសក្នុងផ្លូវនេះ ជាឈ្មោះរបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ពិតហើយ តថាគតអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជាអ្នកឈ្លាសក្នុងលោកនេះ ជាអ្នកឈ្លាសក្នុងលោកដទៃ ឈ្លាសក្នុងទីកដីមច្ចុផង ឈ្លាសក្នុងទីកដីមិនមែនជារបស់មច្ចុផង ទ្រង់ឈ្លាសក្នុងការដឹងនូវអន្ទាក់នៃមារ និងមិនមែនអន្ទាក់នៃមារ ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ដល់បុគ្គលដែលមិនគួរសេពគប់ ទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាល ការសេពគប់បណ្ឌិតសេចក្តីពិត បុគ្គលពាលទាំងឡាយមិនគួរសេពគប់ មិនគួរចូលជិត ដូចផ្លូវ

ដែលគួរវៀរ បន្ទាប់អំពីនោះ ក៏គួរសេពគប់ គួរចូលជិត តែបណ្ឌិតដូចជាផ្លូវដែលគួរកាន់យក ។ អ្នកចោទសួរ ពោលថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់មង្គល ត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតមុន សេចក្តីនេះ ចង្អុលបង្ហាញដូច្នេះថា ព្រោះពួកទេវតា និងមនុស្សប្រកាន់នូវការឃើញ ថាជាមង្គល ក្នុងវត្ថុដែលឃើញហើយជាដើម ដោយការសេពគប់បុគ្គលពាល ទាំងការសេពគប់បុគ្គលពាលនោះ ក៏មិនជាមង្គល ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសមាគមជាមួយនឹងបុគ្គលដែលមិនមែនកល្យាណមិត្រ ដែលកាច់បំបាក់នូវប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ហើយទ្រង់សរសើរការសមាគមជាមួយនឹងកល្យាណមិត្រ ដែលឲ្យសម្រេចប្រយោជន៍ក្នុងលោកទាំង ២ ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតមុន ដល់ទេវតា និងមនុស្សទាំងនោះ ។

សត្វទាំងឡាយគ្រប់ប្រភេទ ដែលប្រកបដោយអកុសលកម្មបថ មានបាណាតិបាតជាដើម ឈ្មោះថា ពាល ក្នុងចំនួនពាល និងបណ្ឌិតនោះ ។ ពាលទាំងនោះនឹងដឹងបានដោយអាការទាំង ៣ ដូចព្រះមានព្រះភាគត្រាស់នៅក្នុងព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ មាន ៣ ។ ម្យ៉ាងទៀត គ្រូទាំង ៦ មានបូរណកស្សបជាដើម និងសត្វដទៃៗ ទាំងនោះ គឺទេវទត្ត កោកាលិកៈ កដមោតិកៈ តិស្សខណ្ឌាទេវីបុត្រ សមុទ្ទទត្តៈ ចិញ្ចមាណវិកា ជាដើម និងបងប្រុសរបស់ទីឃវិទៈ ក្នុងអតីតកាល គប្បីជ្រាបថាជាពាល ។

ពាលទាំងនោះ រមែងញុំាងខ្លួនឯង និងអ្នកដទៃដែលធ្វើតាមពាក្យរបស់

ខ្លួនឲ្យវិនាស ដោយទិដ្ឋិគតៈ គឺការឃើញដែលខ្លួនកាន់យកមិនល្អ ដូចផ្ទះដែលត្រូវភ្លើងឆេះ ដូចបងប្រុសរបស់ទីឃវិទៈ ធ្លាក់ចុះដេកផ្ងារ ដោយអត្តភាពប្រមាណ ៦០ យោជន៍ ឆេះនៅក្នុងមហានរកអស់ ៤ ពុទ្ធន្តរ និងដូចត្រកូល ៥០០ ដែលគាប់ចិត្តក្នុងទិដ្ឋិរបស់បងប្រុសនៃទីឃវិទៈនោះ ត្រកូលទាំងនោះនៅរួមជាសម្លាញ់របស់បងប្រុសនៃទីឃវិទៈនោះឯង ឆេះក្នុងមហានរក ដូច្នោះ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

> ម្នាលភិក្ខុទាំងឡាយ ភ្លើងតែងឆេះរាលអំពីផ្ទះបបុស ឬផ្ទះស្មៅ មកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូល មានសន្ទះទ្វារដ៏ជិតស្និទ្ធ មានបង្អួចបិទជិតបាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយ ណាមួយកើតឡើង ភ័យទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបទ្រពទាំង-ឡាយ ណាមួយកើតឡើង ឧបទ្រពទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបសគ្គទាំង-ឡាយ ណាមួយកើតឡើង ឧបសគ្គទាំងអស់នោះ តែងកើតអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ក៏ដូច្នោះដែរ ។

ម្យ៉ាងទៀត បុគ្គលពាលដូចត្រីស្អុយ បុគ្គលសេពគប់បុគ្គលពាលនោះ ដូចស្លឹកឈើដែលខ្ចប់ត្រីស្អុយ រមែងដល់នូវការៈដែលវិញ្ញូជនបោះបោល និងរង្កៀស សមដូចព្រះមានព្រះភាគត្រាស់ថា

**បូតិមច្ឆំ កុសគ្គេន យោ នរោ ឧបនយ្ហតិ**
**កុសាបិ បូតី វាយន្តិ ឯវំ ពាលូបសេវនា ។**

*ជនណាខ្ចប់នូវត្រីស្អុយដោយចុងស្បូវក្លាំង សូម្បីស្បូវក្លាំង ក៏មានក្លិនស្អុយផ្សាយចេញ ការគប់រកនូវបុគ្គលពាល (របស់ជននោះ) ក៏យ៉ាងនោះដែរ ។*

*ម្យ៉ាងទៀត កាលសក្កទេវរាជប្រទានពរដល់អកិត្តិបណ្ឌិត ក៏ពោលយ៉ាងនេះថា*

**ពាលំ ន បស្សេ ន សុណេ ន ច ពាលេន សំវសេ**
**ពាលេនល្លាបសល្លាបំ ន ករេ ន ច រោចយេ ។**

*បពិត្រសក្កៈជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល ។*

*សក្កទេវរាជត្រាស់សួរថា*

**កិន្នុ តេ អការំ ពាលោ វទ កស្សប ការណំ**
**កេន កស្សប ពាលស្ស ទស្សនំ នាភិកង្ខសិ ។**

*មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល ។*

អកិត្តិបណ្ឌិតឆ្លើយថា

**អនយំ នយតិ ទុម្មេធោ អធុរាយំ និយុញ្ជតិ**
**ទុន្នយោ សេយ្យសោ ហោតិ សម្មា វុត្តោ បកុប្បតិ**
**វិនយំ សោ ន ជានាតិ សាធុ តស្ស អទស្សនំ។**

បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ជាការប្រសើរ ( របស់បុគ្គលពាលនោះ ) បុគ្គលពាលបើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាលរមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះជាការប្រពៃ ។

ព្រះមានព្រះភាគ កាលទ្រង់តិះដៀល ការសេពគប់បុគ្គលពាល ដោយអាការទាំងពួងយ៉ាងនេះ ទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាល ជាមង្គល ឥឡូវនេះ កាលទ្រង់សរសើរ ការសេពគប់បណ្ឌិត ទើបត្រាស់ថា ការសេពគប់បណ្ឌិត ជាមង្គល ។

សត្វគ្រប់ប្រភេទ ដែលប្រកបដោយកុសលកម្មបថ ១០ មានចេតនាវៀរចាកបាណាតិបាតជាដើម ឈ្មោះថា បណ្ឌិត ។ ក្នុងពួកពាល និងបណ្ឌិតនោះ ។

បណ្ឌិតទាំងនោះ គប្បីដឹងបានដោយអាការ ៣ យ៉ាង ដូចព្រះមានព្រះភាគត្រាស់ក្នុងសូត្រថា ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ គឺលក្ខណៈ

របស់បណ្ឌិតមាន ៣ ។ ម្យ៉ាងទៀត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអសីតិ-មហាសាវក សាវកដទៃៗ របស់ព្រះតថាគត និងបណ្ឌិត មានសុនេត្តសាស្តា មហាគោវិន្ទសាស្តា វិធុរបណ្ឌិត សរភង្គតាបស ព្រះមហោសថ សុត្តសោម-បណ្ឌិត ព្រះបាទនិមិរាជ អយោឃរកុមារ និងអកិត្តិបណ្ឌិតជាដើម គប្បីជ្រាបថា ជាបណ្ឌិត ។

បណ្ឌិតទាំងនោះ ជាអ្នកអាចកម្ចាត់ភ័យឧបទ្រព និងឧបសគ្គបានគ្រប់យ៉ាង ដល់ពួកដែលធ្វើតាមពាក្យរបស់ខ្លួន ហាក់បីដូចការពារបានក្នុងវេលាមានភ័យ ហាក់បីដូចពន្លឺប្រទីបក្នុងពេលងងឹត ហាក់បីដូចបានបាយទឹកជាដើមក្នុងវេលាត្រូវទុក្ខ មានការស្រេកឃ្លានជាដើមគ្របសង្កត់ ។ ពិតហើយ អាស្រ័យតថាគត ពួកទេវតា និងមនុស្សរាប់មិនបាន ប្រមាណមិនអស់ នាំគ្នាសម្រេចធម៌ ជាទីអស់អាសវៈ តាំងនៅក្នុងព្រហ្មលោក តាំងនៅក្នុងទេវលោក កើតក្នុងសុគតិលោក ត្រកូល ៨០០០០ ត្រកូល ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះសារីបុត្រ និងទំនុកបម្រុងព្រះថេរៈដោយបច្ច័យ ៤ ទៅកើតក្នុងស្ថានសួគ៌ ។ ត្រកូលទាំងឡាយធ្វើចិត្តឲ្យជ្រះថ្លាក្នុងមហាសាវកទាំងពួង រាប់តាំងអំពីព្រះមហា-មោគ្គល្លាន ព្រះមហាកស្សបជាដើម ក៏យ៉ាងនោះដូចគ្នា ។ សាវកទាំងឡាយរបស់សុនេត្តសាស្តា ពួកខ្លះកើតក្នុងព្រហ្មលោក ពួកខ្លះក៏កើតជាសម្លាញ់របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។បេ។ ពួកខ្លះបានជាសម្លាញ់របស់គហបតីមហាសាល ។ ព្រះមានព្រះភាគ ក៏បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មិនមានភ័យកើតអំពីបណ្ឌិត មិនមានឧបទ្ទវអំពីបណ្ឌិត មិនមានឧបសគ្គអំពី

បណ្ឌិត ។

ម្យ៉ាងទៀត បណ្ឌិត ដូចរបស់ក្រអូប មានក្រស្នា និងផ្កាជាដើម បុគ្គលដែលសេពគប់បណ្ឌិត ក៏ដូចគ្នានឹងកញ្ចប់ស្លឹកឈើដែលខ្ចប់គ្រឿងក្រអូប មានក្រស្នា និងផ្កាជាដើម ដែលជួបនូវការៈ ដែលវិញ្ញូជនសរសើរ និងពេញចិត្ត ។ សូម្បីព្រះមានព្រះភាគក៏បានត្រាស់ដូច្នេះថា

**តគរំវ បលាសេន យោ នរោ ឧបនយ្ហតិ**
**បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា ។**

ជនណា ខ្ចប់ខ្ចីមក្រស្នាដោយស្លឹកឈើ សូម្បីស្លឹកឈើក៏មានក្លិនក្រអូបផ្សាយចេញ ការគប់រកអ្នកប្រាជ្ញ ( របស់ជននោះ ) ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត កាលសក្កទេវរាជប្រទានពរដល់អកិត្តិបណ្ឌិត ក៏ពោលថា

**ធីរំ បស្សេ សុណេ ធីរំ ធីរេន សហ សំវសេ**
**ធីរេនល្លាបសល្លាបំ តំ ករេ តញ្ច រោចយេ ។**

បើព្រះអង្គ នឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ ។

សក្កទេវរាជត្រាស់សួរថា

**កិន្នុ តេ អករំ ធីរោ វទ កស្សប ការណំ**

**កេន កស្សប ធីរស្ស ឧបសង្កមិ អភិកង្ខសិ ។**

*អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។*

*អកិត្តិបណ្ឌិតឆ្លើយថា*

**នយំ នយតិ មេធាវី អធុរាយំ ន យុញ្ជតិ**

**សុនយោ សេយ្យសោ ហោតិ សម្មា វុត្តោ ន កុប្បតិ**

**វិនយំ សោ បជានាតិ សាធុ តេន សមាគមោ ។**

*អ្នកប្រាជ្ញ រមែងណែនាំនូវហេតុដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ ( របស់អ្នកប្រាជ្ញនោះ ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។*

*ព្រះមានព្រះភាគ កាលទ្រង់សរសើរការគប់រកបណ្ឌិត ដោយធម៌ទាំងពួងយ៉ាងនេះ ទើបត្រាស់ថា ការសេពគប់បណ្ឌិតជាមង្គល ។*

*ឥឡូវនេះ កាលទ្រង់សរសើរការបូជាបុគ្គល ដែលចូលដល់ភាពជាបុគ្គលគួរបូជាដោយលំដាប់ ដោយការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតនោះ ទើបត្រាស់ថា* **បូជា ច បូជនីយានំ មង្គលំ** *។ ព្រះមានព្រះភាគ ឈ្មោះថា* **បូជនីយ** *ព្រោះទ្រង់វៀរចាកទោសគ្រប់យ៉ាង និង*

ព្រោះទ្រង់ប្រកបដោយគុណគ្រប់យ៉ាង ហើយខាងក្រោយអំពីនោះ គឺព្រះបច្ចេកពុទ្ធ ព្រះអរិយសាវកទាំងឡាយ ឈ្មោះថា **បូជនីយ** ។ ពិតហើយ ការបូជាបូជនីយបុគ្គលទាំងនោះ សូម្បីតិចតួច ក៏ជាប្រយោជន៍ នាំមកនូវសេចក្តីសុខអស់កាលយូរ ។ ក្នុងសេចក្តីនេះ មានរឿងនាយសុមនមាលាការ និងនាងមល្លិកាជាដើម ជាគំរូ ។ ក្នុងរឿងទាំង ២ នោះ សូមពោលតែមួយរឿង គ្រាន់ជាគំរូ ។

សេចក្តីថា ព្រឹកថ្ងៃមួយ ព្រះមានព្រះភាគទ្រង់ស្លៀកអន្តរវាសក ហើយកាន់បាត្រ និងចីវរ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ខណៈនោះ នាយមាលាការ ឈ្មោះសុមនមាលាការកំពុងដើរកាន់ផ្កា សម្រាប់ព្រះបាទពិម្ពិសារជាកំពូលនៃអ្នកមគធៈ បានឃើញព្រះមានព្រះភាគយាងចូលដល់ក្រុង ផូរផង់គួរជ្រះថ្លា ប្រដាប់ដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ប្រការ រុងរឿងដោយពុទ្ធសិរី កាលឃើញហើយ ក៏គិតថា ព្រះរាជាទ្រង់ទទួលផ្កាហើយ ក៏គប្បីប្រទានទ្រព្យ ១០០ ឬ ១០០០ នុ៎ះគ្រាន់តែជាសេចក្តីសុខក្នុងលោកនេះប៉ុណ្ណោះ តែការបូជាព្រះមានព្រះភាគ រមែងមានផលប្រមាណមិនបាន រាប់មិនអស់ នាំប្រយោជន៍ និងសេចក្តីសុខមកឲ្យអស់កាលយូរ ។ ណ្ហើយចុះ អញនឹងបូជាព្រះមានព្រះភាគ ដោយផ្កាទាំងនេះដូច្នេះ គាត់មានចិត្តជ្រះថ្លា ចាប់ផ្កាមួយក្តាប់បាចទៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។ ផ្កាទាំងឡាយទៅតាមអាកាស ប្រតិស្ឋានជាពិតានផ្កា នៅលើព្រះមានព្រះភាគ ។ នាយមាលាការឃើញអានុភាពនោះ ក៏មានចិត្តជ្រះថ្លា

ក្រៃលែងឡើង ទើបបាចផ្កាមួយក្ដាប់ទៀត សូម្បីផ្កាទាំងនោះ ក៏ទៅប្រតិស្ឋាន ជាពិតានផ្កា ។ នាយមាលាការបាចផ្កា ៨ ក្ដាប់យ៉ាងនេះ ផ្កាទាំងនោះ ក៏ទៅ ប្រតិស្ឋានជាផ្ទះកំពូលដែលជាវិការនៃផ្កា ។

ព្រះមានព្រះភាគ ប្រថាប់នៅក្នុងផ្ទះកំពូល មហាជនក៏ប្រជុំគ្នា ។ ព្រះ មានព្រះភាគទតឃើញនាយមាលាការ ក៏ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។ ព្រះ អានន្ទក៏ទូលសួរដល់ហេតុដែលទ្រង់ញញឹមដោយគិតថា ព្រះសម្ពុទ្ធទាំងឡាយ មិនមានហេតុ មិនមានបច្ច័យ ទ្រង់មិនញញឹមឲ្យប្រាកដឡើយ ។ ព្រះមាន ព្រះភាគត្រាស់ថា អានន្ទ នាយមាលាការនេះនឹងត្រាច់ទៅក្នុងទេវតា និង មនុស្សលោកអស់សែនកប្ប ដោយអានុភាពនៃការបូជានេះ ហើយក្នុងទីបំផុត ក៏នឹងបានជាព្រះបច្ចេកពុទ្ធ នាមថា សុមនិស្សរៈ ។ មានព្រះតម្រាស់ចប់ ក៏ត្រាស់ព្រះគាថានេះ ដើម្បីទ្រង់សម្ដែងធម្មកថាថា

**តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ**

**យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្ដៅក្រហាយ ឬដល់

នូវសេចក្ដីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា

កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

ចប់គាថា សត្វ ៨៤០០០ បានសម្រេចធម៌ ។ ការបូជាបូជនីយបុគ្គល ទាំងនោះ សូម្បីតិចតួច គប្បីជ្រាបថា មានប្រយោជន៍ និងសេចក្ដីសុខអស់ កាលយូរ ដោយប្រការដូច្នេះ ។

ការបូជានោះ ជាអាមិសបូជា នឹងពោលថ្មីក្នុងបដិបត្តិបូជា ព្រោះកុលបុត្រពួកណា បូជាព្រះមានព្រះភាគ ដោយទទួលសរណគមន៍ និងសិក្ខាបទ ដោយការសមាទានអដ្ឋង្គឧបោសថ និងដោយគុណទាំងឡាយរបស់ខ្លួន មានបារិសុទ្ធិសីល ៤ ជាដើម អ្នកណានឹងពណ៌នាផលនៃការបូជារបស់កុលបុត្រទាំងនោះបាន ដ្បិតថា កុលបុត្រទាំងនោះ លោកពោលថា បូជាព្រះតថាគតដោយការបូជាដ៏ឧត្តម ដូចព្រះមានព្រះភាគត្រាស់ថា

ម្នាលអានន្ទ បុគ្គលណាមួយ ទោះបីភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អានបូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ។

ការបូជាព្រះបច្ចេកពុទ្ធ និងអរិយសាវក នាំមកនូវប្រយោជន៍ និងសេចក្តីសុខ គប្បីជ្រាបតាមគន្លងនេះ ។

ម្យ៉ាងទៀត សម្រាប់គ្រហស្ថ គប្បីជ្រាបបូជនីយបុគ្គលក្នុងសេចក្តីនេះយ៉ាងនេះ គឺបុគ្គលចម្រើនបំផុត បងប្រុសក្តី បងស្រីក្តី ឈ្មោះថា បូជនីយបុគ្គលរបស់ប្អូន មាតាបិតា ជាបូជនីយបុគ្គលរបស់បុត្រ ប្តី ឪពុកក្មេក ម្តាយក្មេក ជាបូជនីយបុគ្គលរបស់ស្ត្រីទាំងឡាយ ដ្បិតថា ការបូជាបូជនីយបុគ្គលទាំងនោះ ជាមង្គលទាំងអស់ ព្រោះរាប់ថា ជាកុសលធម៌ និងព្រោះជាហេតុចម្រើនអាយុជាដើម ព្រះមានព្រះភាគមានព្រះពុទ្ធតម្រាស់ដូច្នេះថា

សត្វទាំងនោះ ក៏ជាអ្នកគោរពមាតា គោរពបិតា

គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នក
ប្រព្រឹត្តកោតក្រែង ត្រកូលរៀមច្បង ប្រព្រឹត្ត
សមាទាន នូវកុសលធម៌នេះ ក៏បានចម្រើនអាយុ
ចម្រើនពណ៌សម្បុរឡើងវិញ ដូច្នេះ ។

ឥឡូវនេះ ព្រោះខ្ញុំបានតាំងមាតិកាថា ពោលសម្ដានជាទីកើតមង្គល រួចកំណត់មង្គលនោះ និងចង្អុលបង្ហាញអត្ថនៃមង្គលនោះ ដូច្នោះ ទើបសូមចង្អុលបង្ហាញ ដូច្នេះ ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៣ មង្គល គឺការមិនសេពគប់បុគ្គលពាល ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជា ដោយប្រការដូច្នេះ ។ ក្នុងមង្គលទាំង ៣ នោះ គប្បីជ្រាបការមិនសេពគប់បុគ្គលពាល ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍របស់លោកទាំង ២ ព្រោះការពារភ័យ មានភ័យកើតអំពីបុគ្គលពាលជាបច្ច័យជាដើម ការគប់រកបណ្ឌិត និងការបូជាបុគ្គលដែលគួរបូជា ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃព្រះនិព្វាន និងសុគតិ ដោយន័យដែលពោលហើយ ក្នុងកិច្ចពណ៌នាបន្ថែម នៃផលរបស់ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជានោះឯង ។ តែខ្ញុំមិនសម្ដែងមាតិកា បន្ទាប់អំពីនេះទៅ នឹងកំណត់ប្រការដែលជាមង្គលទាំងនេះ ទើបចង្អុលបង្ហាញអត្ថដែលជាមាតិកានោះជាមង្គល ។

## អធិប្បាយបទថា អសេវនា ច ពាលានំ ចប់

# អធិប្បាយបទថា បដិរូបទេសវាសោ ច

ព្រះមានព្រះភាគ ត្រូវទេវបុត្រសូមនូវមង្គលតែម្យ៉ាងថា **ព្រូហិ មង្គលមុត្តមំ** សូមទ្រង់ត្រាស់ប្រាប់មង្គលដ៏ឧត្តម តែត្រាស់ដល់ ៣ មង្គល ដោយ ១ គាថា ប្រៀបដូចបុរសចិត្តទូលាយ ត្រូវគេសូមតែបន្តិចក៏ឲ្យច្រើនក្រៃលែងជាងនោះ ហើយទ្រង់ត្រាស់មង្គលជាច្រើនទៀត ដោយគាថាទាំងឡាយថា **បដិរូបទេសវាសោ** ច ជាដើម ក៏ព្រោះទេវតាទាំងឡាយចង់ស្តាប់ ព្រោះមង្គលទាំងឡាយមាន និងព្រោះមង្គលណាមួយ អនុកូលដល់សត្វណាមួយ ទ្រង់មានព្រះពុទ្ធបំណងនឹងប្រកបសត្វនោះៗ ក្នុងមង្គលនោះ ។ បណ្តាគាថានោះៗ នឹងពោលក្នុងគាថាដំបូងមុន ។ បទថា **បដិរូបោ** ប្រែថា សមគួរ ។ ឱកាសជាទីនៅអាស្រ័យរបស់សត្វទាំងឡាយគ្រប់កន្លែង ទោះជាគាមក្តី និគមក្តី នគរក្តី ជនបទក្តី ឈ្មោះថា ទេសៈ ។ ការនៅអាស្រ័យក្នុងទេសៈនោះ ឈ្មោះថា **វាសៈ** ។ បទថា **បុព្វេ** ប្រែថា អំពីមុន គឺក្នុងជាតិដែលកន្លងមកហើយ ។ ភាពជាអ្នកមានកុសលសន្សំហើយ ឈ្មោះថា ភាពជាអ្នកមានបុណ្យបានធ្វើហើយ ។ ចិត្ត ឬអត្តភាពទាំងមូល ឈ្មោះថា **អត្ត** ។ ការប្រកប គឺការតាំងសេចក្តីប្រាថ្នារបស់ខ្លួនប្រពៃ ។ លោកអធិប្បាយថា ការតាំងខ្លួនដោយប្រពៃ ឈ្មោះថា **សម្មាបណិធិ** ។ ពាក្យក្រៅអំពីនោះ មានន័យដូចពោលហើយនោះឯង នេះជាពណ៌នាបទ ក្នុងគាថាដំបូងនោះ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ក្នុងបទេសណា បរិស័ទ ៤ នៅចារិកនៅឡើយ នៅបំពេញបុញ្ញកិរិយាវត្ថុ មានទានជាដើមនៅឡើយទេ នវង្គសត្ថុសាសនៈនៅរុងរឿង បទេសនោះ ឈ្មោះថា **បដិរូបទេស** ការនៅ

អាស្រ័យក្នុងបដិរូបទេសនោះ ត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យដល់ការធ្វើបុណ្យនៃសត្វទាំងឡាយ ក្នុងសេចក្តីនេះ មានអ្នកប្រមង់ដែលចូលទៅកាន់កោះ សីហឡជាដើម ជាគំរូ ។

ន័យម្យ៉ាងទៀត បទេសជាទីត្រាស់ដឹងព្រះពោធិញ្ញាណ បទេសដែលទ្រង់ប្រកាសធម្មចក្រ បទេស គឺគល់ស្វាយរបស់នាយគណ្ឌៈ ដែលទ្រង់សម្តែងយមកបា្បដិហារ្យ ទម្លាយសេចក្តីស្រើងរបស់ពួកតិ្ថយទាំងពួង ត្រង់កណ្តាលបរិស័ទប្រមាណ ១២ យោជន៍ បទេសដែលទ្រង់ចុះអំពីទេវលោក ឬបទេសដទៃដែលជាទីនៅប្រថាប់របស់ព្រះពុទ្ធ មានក្រុងសាវត្ថី ក្រុងរាជគ្រឹះជាដើម បទេសនោះ ឈ្មោះថា **បដិរូបទេស** ការនៅអាស្រ័យក្នុងបដិរូបទេសនោះ ត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យដល់ការបានអនុត្តរិយៈ ៦ នៃសត្វទាំង-ឡាយ ។

ម្យ៉ាងទៀត ទិសបូព៌ តាំងអំពីជង្គលនិគម រហូតមកដល់មហាសាលាខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងចូលមកជាមជ្ឈិមជនបទ ។ ទិសអាគ្នេយ៍ តាំងអំពីស្ទឹងសល្លវតីមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិមជនបទ ទិសទក្សិណ តាំងអំពីសេតកណ្ណិកនិគមចូលមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិមជនបទ ។ ទិសខាងលិច តាំងអំពីថូនស្រុករបស់ព្រាហ្មណ៍ចូលមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិមជនបទ ។ ទិសឧត្តរ តាំងអំពីភ្នំឧសីរធជៈចូលមក ខាងក្រៅជាបច្ចន្តិមជនបទ ខាងក្នុងជាមជ្ឈិម-ជនបទ ។ នេះជាមជ្ឈិមប្រទេស ដែលមានបណ្តោយ ៣០០ យោជន៍ ទទឹង

២៥០ យោជន៍ ដោយជុំវិញ ៩០០ ។ មជ្ឈិមប្រទេសនេះ ឈ្មោះថា **បដិរូបទេស។**

ស្តេចចក្រពត្តិទាំងឡាយ ដែលគ្រងឥស្សរិយាធិបតីនៃទ្វីបធំទាំង ៤ ទ្វីបតូច ២ ពាន់ រមែងកើតក្នុងបដិរូបទេសនោះ ព្រះមហាសាវកទាំងឡាយមានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើមបំពេញបារមីមកមួយអសង្ខេយ្យ និងមួយសែនកប្ប ក៏កើតក្នុងបដិរូបទេសនោះ ព្រះបច្ចេកពុទ្ធទាំងឡាយបំពេញបារមីមក ២ អសង្ខេយ្យ និងមួយសែនកប្ប កើតក្នុងបដិរូបទេសនោះ ព្រះសម្មាសម្ពុទ្ធទាំងឡាយ បំពេញបារមីមក ៤ អសង្ខេយ្យ និងមួយសែនកប្បខ្លះ ៨ អសង្ខេយ្យ និងមួយសែនកប្បខ្លះ ១៦ អសង្ខេយ្យ និងមួយសែនកប្បខ្លះ ក៏ទ្រង់កើតឡើងក្នុងបដិរូបទេសនោះ បណ្តាបុគ្គលទាំងនោះ សត្វទាំងឡាយទទួលឱវាទរបស់ស្តេចចក្រពត្តិ តាំងនៅក្នុងសីល ៥ ហើយក៏មានស្ថានសួគ៌ជាទីទៅខាងមុខ តាំងនៅក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធក៏ដូចគ្នា ។ ឯសត្វទាំងឡាយ តាំងនៅក្នុងឱវាទរបស់ព្រះពុទ្ធ សាវករបស់ព្រះពុទ្ធ រមែងមានស្ថានសួគ៌ជាទីទៅខាងមុខ មានព្រះនិព្វានជាទីទៅខាងមុខ ព្រោះដូច្នោះ ការនៅក្នុងបដិរូបទេសនោះ ទើបត្រាស់ថា ជាមង្គល ព្រោះជាបច្ច័យនៃសម្បត្តិទាំងនេះ ។

ភាពជាអ្នកប្រារព្ធព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព សន្សំកុសលក្នុងជាតិដែលកន្លងមក ឈ្មោះថា ភាពជាអ្នកធ្វើបុណ្យក្នុងកាលមុន ។ ភាពជាអ្នកធ្វើបុណ្យក្នុងកាលមុននោះ ក៏ជាមង្គល ។ ព្រោះហេតុអ្វី ព្រោះធ្វើ

អធិប្បាយថា ភាពជាអ្នកបានធ្វើបុណ្យក្នុងកាលមុន រមែងឲ្យសម្រេចអរហត្ត កាលចប់គាថា ៤ បទ ដែលសម្ដែងចំពោះព្រះភក្ត្ររបស់ព្រះសម្ពុទ្ធ ព្រះ-បច្ចេកពុទ្ធ ឬដែលស្ដាប់ចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ។ មនុស្សណាបានសាងបារមី មានកុសលមូលក្រាស់មកអំពីមុន មនុស្សនោះធ្វើវិបស្សនាឲ្យកើតហើយ រមែងសម្រេចធម៌ដែលអស់អាសវៈ ដោយកុសល-មូលនោះឯង ដូចព្រះបាទមហាកប្បិន និងអគ្គមហេសី ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភាពជាអ្នកធ្វើបុណ្យក្នុងកាលមុន ជាមង្គល ។

បុគ្គលខ្លះ ក្នុងលោកនេះ រមែងធ្វើខ្លួនដែលទ្រុស្តសីល ឲ្យតាំងនៅក្នុងសីល ដែលមិនមានសទ្ធា ឲ្យតាំងនៅក្នុងសទ្ធាសម្បទា ខ្លួនដែលកំណាញ់ ឲ្យតាំងនៅក្នុងចាគសម្បទា ការតាំងខ្លួនដូចពោល ឈ្មោះថា តាំងខ្លួនប្រពៃ ។ ការតម្កល់ខ្លួនប្រពៃនេះ ហៅថា **អត្តសម្មាបណិធិ** ។ អត្តសម្មាបណិធិនេះឯងជាមង្គល ព្រោះហេតុអ្វី ព្រោះជាហេតុលះបង់នូវពៀរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងចំណែកខាងមុខ នឹងជួបនូវអានិសង្សច្រើនយ៉ាង ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៣ មង្គល គឺការនៅក្នុងបដិ-រូបទេស ១ ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ១ និងការតម្កល់ខ្លួនប្រពៃ ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល ក៏បានចង្អុលបង្ហាញក្នុងមង្គលទាំងអស់នោះហើយ ។

## អធិប្បាយបទថា បដិរូបទេសវាសោ ច ចប់

# អធិប្បាយ បទថា ពាហុសច្ចញ្ច

ឥឡូវនេះ ភាពជាពហូសូត ឈ្មោះថា **ពាហុសច្ច** ក្នុងបទនេះថា **ពាហុសច្ចញ្ច** ភាពឈ្លាសក្នុងការងាររហត្ថកម្មគ្រប់យ៉ាង ឈ្មោះថា សិប្បៈ ។ ការទូន្មានកាយ វាចា ចិត្ត ឈ្មោះថា **វិន័យ** ។ បទថា **សុសិក្ខិតោ** ប្រែថា ដែលសិក្សាដោយល្អហើយ ។ បទថា **សុភាសិតា** ប្រែថា ដែលគេពោលដោយល្អហើយ សព្ទថា **យា** សម្តែងការមិនពិតប្រាកដ ។ ពាក្យបន្ទឹខាងពាក្យសម្តី ឈ្មោះថា **វាចា** ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយទាំងអស់នោះឯង ។ នេះជាពណ៌នាបទក្នុងគាថាថា **ពាហុសច្ចញ្ច** នេះ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ភាពជាអ្នកទ្រទ្រង់ទុកនូវសត្ថុ-សាសនៈដែលទ្រង់ពណ៌នា ដោយន័យជាដើមយ៉ាងនេះថា ជាអ្នកទ្រទ្រង់នូវសុតៈ សន្សំសុតៈ និងពាក្យថា ភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ មានសុតៈច្រើន គឺសុតៈ គេយ្យៈ វេយ្យាករណៈជាដើម ឈ្មោះថា **ភាពជាពហុស្សូត** ។ ភាពជាពហូសូតនោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុលះអកុសល និងជួបនូវកុសល ព្រោះជាហេតុធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចតាមលំដាប់ សមដូចព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា

> ម្នាលភិក្ខុទាំងឡាយ អរិយសាវក មានការចេះដឹង ទុកជាអវត្ថុ រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើដែលមានទោស ចម្រើននូវអំពើដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ក៏យ៉ាងនោះដែរដូច្នេះ ។
>
> ដូចព្រះតម្រាស់មួយទៀតថា

ទើបស្តាប់ធម៌ លុះស្តាប់ហើយ ទើបទ្រទ្រង់នូវធម៌ពិចារណា នូវសេចក្តី នៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ កាលបើពិចារណានូវសេចក្តីហើយ ក៏ចូលចិត្តនូវធម៌ និងគំនិត កាលមានសេចក្តីចូលចិត្តនូវធម៌ និងគំនិតហើយ ក៏មានឆន្ទៈកើតឡើង លុះមានឆន្ទៈកើតឡើងហើយ ក៏ប្រឹងប្រែង លុះប្រឹងប្រែងហើយ ក៏ត្រិះរិះ លុះត្រិះរិះហើយ ក៏តម្កល់ ( នូវសេចក្តីព្យាយាមដើម្បីមគ្គ ) ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចៈដោយនាមកាយផង បានចាក់ធ្លុះ ឃើញច្បាស់នូវបរមត្ថសច្ចៈនោះដោយបញ្ញាផង ។

ម្យ៉ាងទៀត ពាហុសច្ចៈរបស់គ្រហស្ថឯណា មិនមានទោស នុ៎ះក៏គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំង ២ ។

សិប្បៈរបស់គ្រហស្ថ និងសិប្បៈរបស់បព្វជិត ឈ្មោះថា **សិប្បៈ** ។ បណ្តាសិប្បៈទាំង ២ នោះ កិច្ចកម្ម មានការងារជាងកែវមណី ជាងមាសជាដើម ដែលវៀរចាកការប្រទូស្តជីវិតសត្វដទៃ វៀរចាកអកុសល ឈ្មោះថា **អគារិកសិប្បៈ** គឺសិប្បៈរបស់គ្រហស្ថ ។ អគារិកសិប្បៈនោះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ក្នុងលោកនេះ ។

ការធ្វើសមណបរិក្ខារ មានការបោក និងដេរចីវរជាដើម ដែលព្រះមានព្រះភាគសរសើរក្នុងទីនោះៗ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ កិច្ច

ទាំងឡាយណាមួយ ធំ ឬតូច របស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូស ក្នុងកិច្ចទាំងនោះ ។ និងដែលត្រាស់ថា ជានាថ-ករណធម៌ ឈ្មោះថា **អគារិកសិប្បៈ** គឺសិប្បៈរបស់បព្វជិត ។ សិប្បៈរបស់បព្វជិតនោះ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំង ២ ដល់ខ្លួនឯង និងដល់អ្នកដទៃ ។

វិន័យរបស់គ្រហស្ថ និងវិន័យរបស់បព្វជិត ឈ្មោះថា **វិន័យ** ។ បណ្ដាវិន័យទាំង ២ នោះ ការវៀរអកុសលកម្មបថ ១០ ឈ្មោះថា វិន័យរបស់គ្រហស្ថ ។ វិន័យរបស់គ្រហស្ថនោះ គ្រហស្ថសិក្សាល្អហើយក្នុងវិន័យនោះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ និងសេចក្ដីសុខក្នុងលោកទាំង ២ ដោយការមិនប៉ះពាល់នូវសង្កិលេស និងការកំណត់គុណគឺអាចារៈ ។

ការមិនត្រូវអាបត្តិ ៧ កង ឈ្មោះថា វិន័យរបស់បព្វជិត ។ សូម្បីវិន័យរបស់បព្វជិតនោះ ដែលបព្វជិតសិក្សាល្អហើយ ដោយន័យដែលពោលមកហើយ ឬបារិសុទ្ធិសីល ៤ ឈ្មោះថា វិន័យរបស់បព្វជិត វិន័យរបស់បព្វជិតនោះ ដែលបព្វជិតសិក្សាល្អហើយ ដោយការសិក្សាដោយប្រការដែលតាំងនៅក្នុងចតុប្បារិសុទ្ធិសីលនោះហើយ សម្រេចនូវអរហត្តបាន គប្បីជ្រាបថា ជាមង្គល ព្រោះហេតុជួបនូវសុខ ទាំងលោកិយ ទាំងលោកុត្តរ ។

វាចាដែលវៀរចាកទោស មានមុសាវាទជាដើម ឈ្មោះថា **វាចាសុភាសិត** ដូចដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយ

អង្គ ៤ ជាវាចាសុភាសិត ឬវាចាដែលចរចាមិនផ្តេសផ្តាស ឈ្មោះថា វាចាសុភាសិត ដូចព្រះមានព្រះភាគត្រាស់ថា

**សុភាសិតំ ឧត្តមមាហុ សន្តោ ធម្មំ ភណេ នអធម្មំ តំ ទុតិយំ**
**បិយំ ភណេ នអប្បិយំ តំ តតិយំ សច្ចំ ភណេ នាលិកន្តំ ចតុត្ថំ។**

ពួកសប្បុរសបានពោលនូវវាចាជាសុភាសិតដ៏ឧត្តម ( នោះជាទី ១ ) ពោលនូវវាចាជាធម៌ មិនពោលនូវវាចាមិនមែនជាធម៌ នោះជាទី ២ ពោលវាចាគួរស្រឡាញ់ មិនពោលវាចាដែលមិនគួរស្រឡាញ់ នោះជាទី ៣ ពោលពាក្យពិត មិនពោលពាក្យឡេះឡោះ នោះជាទី ៤ ។

វាចាសុភាសិតនេះ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ក្នុងលោកទាំង ២ តែព្រោះវាចាសុភាសិតនេះទាក់ទងក្នុងវិន័យ ដូច្នោះ ទោះបីមិនសង្គ្រោះវាចាសុភាសិតនោះដោយវិនយសព្ទ ក៏គប្បីជ្រាបថា ជាវិន័យ ។ កាលបើដូច្នោះ វាចា មានការសម្តែងធម៌ដល់បុគ្គលដទៃជាដើម គប្បីជ្រាបថា ជាវាចាសុភាសិតក្នុងទីនេះ ។ សេចក្តីពិត វាចាសុភាសិត ត្រាស់ថា ជាមង្គល ក៏ព្រោះជាហេតុជួបនូវសុខក្នុងលោកទាំង ២ និងព្រះនិព្វានរបស់សត្វទាំងឡាយ ដូចការនៅក្នុងបដិរូបទេស ដូច្នោះ ។

សមដូចព្រះវង្គីសត្ថេរពោលថា

**យំ ពុទ្ធោ ភាសតិ វាចំ ខេមំ និព្វានបត្តិយា**
**ទុក្ខស្សន្តកិរិយាយ សា វេ វាចានមុត្តមំ។**

ព្រះពុទ្ធទ្រង់ត្រាស់នូវព្រះវាចាណា ជាគ្រឿងក្សេម ដើម្បីដល់នូវព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ វាចានោះឯង ឈ្មោះថា ជាវាចាដ៏ឧត្តម ។

ព្រះសម្ពុទ្ធត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺពាហុសច្ចៈ ១ សិប្បៈ ១ វិន័យដែលសិក្សាល្អហើយ ១ និងវាចាសុភាសិត ១ ដោយប្រការដូច្នេះ ។ ការដែលមង្គលនោះជាមង្គល ក៏បានចង្អុលបង្ហាញក្នុងមង្គលនោះទាំងអស់ ។

**អធិប្បាយបទថា ពាហុសច្ចញ្ចជាដើម ចប់**

# អធិប្បាយបទថា មាតាបិតុឧបដ្ឋានំ

ឥឡូវនេះ នឹងពណ៌នាក្នុងគាថានេះថា **មាតាបិតុឧបដ្ឋានំ ។** មាតា និងបិតា ហេតុនោះ ឈ្មោះថា មាតា និងបិតា ។ បទថា **ឧបដ្ឋានំ** ប្រែថា ការទំនុកបម្រុង ។ កូនទាំងឡាយផង ភរិយាទាំងឡាយផង ឈ្មោះថា បុត្រ និងភរិយា ការសង្គ្រោះ ឈ្មោះថា សង្គហៈ ។ ការងារ គឺកិច្ចកម្ម ដែលតិះដៀលមិនបាន ឈ្មោះថា មិនច្របូកច្របល់ ។ ពាក្យដ៏សេស មានន័យដូចពោលហើយទាំងអស់នោះឯង នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ស្ត្រីដែលញ៉ាំងបុត្រឲ្យកើត ឈ្មោះថា មាតា បិតាក៏ដូចគ្នា ។ ការធ្វើឧបការៈដោយការលាងជើង គក់ច្របាច់ ដុសក្អែល ងូតទឹកឲ្យ និងការជូនបច្ច័យ ៤ ឈ្មោះថា ទំនុកបម្រុង ។ ក្នុងការ

ទំនុកបម្រុងនោះ ព្រោះមាតាបិតាមានឧបការៈច្រើន ប្រាថ្នាប្រយោជន៍អនុគ្រោះដល់កូនទាំងឡាយ មាតាបិតាទាំងឡាយណា សម្លឹងឃើញកូនទាំងឡាយលេងនៅខាងក្រៅ ដើរមក មានខ្លួនប្រឡាក់ធូលី ក៏ជូតធូលីឲ្យ ថើបក្បាលបបោសអង្អែល ស្រឡាញ់ អាណិត ។ កូនទាំងឡាយប្រើក្បាលទូលមាតាបិតា អស់ ១០០ ឆ្នាំ ក៏មិនអាចធ្វើបដិការៈសងនូវគុណរបស់មាតាបិតានោះបាន និងព្រោះហេតុដែលមាតាបិតានោះ ជាអ្នកទំនុកបម្រុង បង្ហាញលោកនេះ សន្មតថាជាព្រហ្ម សន្មតថាជាបុព្វាចារ្យ ដូច្នោះ ការទំនុកបម្រុងមាតាបិតានោះ រមែងនាំមកនូវការសរសើរក្នុងលោកនេះ ការលះលោកទៅហើយ ក៏នាំមកនូវសេចក្តីសុខក្នុងស្ថានសួគ៌ ដោយហេតុនោះ ទើបត្រាស់ថាជាមង្គល សមដូចព្រះមានព្រះភាគត្រាស់ថា

មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្តី បុព្វាចារ្យក្តី
អាហុនេយ្យៈក្តី ( សុទ្ធតែ ) ជាអ្នកអនុគ្រោះដល់ពួកសត្វ
គឺកូន ។ ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរនមស្ការ គួរធ្វើ
សក្ការៈដល់មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់
គ្រឿងដេក គ្រឿងអប់ គ្រឿងជូតទឹក និងទឹកសម្រាប់លាង
ជើង ។ ព្រោះការដែលបានទំនុកបម្រុងមាតាបិតានោះហើយ
បានជាអ្នកប្រាជ្ញទាំងឡាយ សរសើរនូវបុគ្គលនោះ ក្នុង
លោកនេះឯង បុគ្គលនោះ លុះលះលោកនេះទៅហើយ
រមែងរីករាយក្នុងឋានសួគ៌ ។

ន័យម្យ៉ាងទៀត កិច្ចកម្ម ៥ យ៉ាង មានការចិញ្ចឹម ធ្វើកិច្ចរបស់លោក និងការតាំងវង្សត្រកូលជាដើម ឈ្មោះថា ការបម្រើ ។ ការបម្រើនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន ៥ យ៉ាង មានការហាមមិនឲ្យធ្វើបាបជាដើម ។ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាង គឺកូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀត ឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ។ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ ដូច្នេះ គឺហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្តឹងភរិយាស្វាមីសមគួរឲ្យ ១ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១ ។

ម្យ៉ាងទៀត បុគ្គលណាទំនុកបម្រុងមាតាបិតា ដោយឲ្យកើតការជ្រះថ្លាក្នុងវត្ថុ គឺរតនៈទាំង ៣ ដោយឲ្យដល់ព្រមដោយសីល ដោយឲ្យបព្វជ្ជា បុគ្គល

នេះជាកំពូលនៃបុគ្គល ដែលទំនុកបម្រុងមាតាបិតា ។ ការទំនុកបម្រុងមាតាបិតារបស់បុគ្គលនោះ ជាការតបស្នងសងឧបការគុណដែលមាតាបិតាធ្វើមកហើយ ត្រាស់ថាជាមង្គល ព្រោះជាបទដ្ឋាននៃប្រយោជន៍ទាំងឡាយ ក្នុងបច្ចុប្បន្នផង ក្នុងចំណែកខាងមុខផងដ៏ច្រើន ។

បុត្រក្តី ធីតាក្តី ដែលកើតអំពីខ្លួន រាប់ថា ជាបុត្រទាំងអស់ ក្នុងពាក្យថា **បុត្តទារស្ស** នេះ ។ បទថា **ទារា** បានដល់ ភរិយា ២០ ពួក ពួកណាមួយ ។ បុត្រ និងភរិយា ឈ្មោះថា **បុត្តទារ ។** នូវបុត្រ និងភរិយានោះ ។ បទថា **សង្គហោ** បានដល់ ធ្វើការឧបការៈដោយការសរសើរជាដើម ។ ការឧបការៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន មានភាពជាអ្នកចាត់ការងារល្អជាដើម ។ សេចក្តីពិត ព្រះមានព្រះភាគទ្រង់សង្គ្រោះបុត្រ និងភរិយា ដែលទ្រង់លើកឡើងសម្តែងថា ទិសខាងលិច គប្បីជ្រាបថា គឺបុត្រ និងភរិយាផងដែរ ។ ទើប **ភរិយា** សព្ទ ត្រាស់ដូច្នេះថា

ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺដោយការរាប់អានជាភរិយាពេញទី ១ ដោយមិនមើលងាយ ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ ដោយប្រគល់ឲ្យជាធំ ( ក្នុងការផ្ទះ ) ១ ដោយការឲ្យគ្រឿងតែងខ្លួន ១ ។ ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ដែលស្វាមីទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមី

ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ គឺចាត់ចែងការងារ
ដោយល្អ ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ១
មិនប្រព្រឹត្តក្បត់ចិត្ត ១ ថែទាំទ្រព្យដែលស្វាមីរកបានមក ១
ឈ្លាស មិនខ្ជិលច្រអូស ក្នុងកិច្ចសព្វគ្រប់ ១ ។

ម្យ៉ាងទៀត បទថា **សង្គហោ** បានដល់ ការសង្គ្រោះដោយទាន បិយ-វាចា អត្ថចរិយា ។ សេចក្ដីនេះដូចម្ដេច ការឲ្យស្បៀងអាហារក្នុងថ្ងៃឧបោសថ ការឲ្យលេងបុណ្យនក្ខត្តឫក្ស ធ្វើមង្គល ក្នុងថ្ងៃមង្គល ការទូន្មានប្រៀនប្រដៅក្នុងប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងលោកខាងមុខ ការសង្គ្រោះនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន ព្រោះជាហេតុនៃប្រយោជន៍ខាងមុខ និងព្រោះជាហេតុនៃភាពជាបុគ្គល ដែលទេវតាទាំងឡាយនមស្ការ ដូចសក្កទេវរាជត្រាស់ថា

**យេ គហដ្ឋា បុញ្ញករា សីលវន្តោ ឧបាសកា**
**ធម្មេន ទារំ បោសេន្តិ តេ នមស្សាមិ មាតលិ។**

ពួកគ្រហស្ថណា ជាអ្នកធ្វើបុណ្យ ជាឧបាសកមានសីល
ចិញ្ចឹមកូន ប្រពន្ធ ដោយធម៌ ម្នាលមាតលិ ខ្ញុំក៏ថ្វាយ
បង្គំចំពោះពួកគ្រហស្ថនោះដែរ ។

ការងារទាំងឡាយ មានកសិកម្ម គោរក្ខកម្ម និងវាណិជ្ជកម្មជាដើម វៀរចាកភាវៈច្របូកច្របល់ មានការកន្លងកាល ការធ្វើមិនសមគួរ និងការធ្វើធូរថយជាដើម ព្រោះជាអ្នកស្គាល់កាល ព្រោះជាអ្នកធ្វើសមគួរ ព្រោះជាអ្នកមិន

ខ្ជិលច្រអូស និងព្រោះមិនគួរវិនាស ព្រោះដល់ព្រមដោយការព្យាយាមប្រឹងប្រែង ឈ្មោះថា ការងារមិនច្របូកច្របល់ ។ ការងារមិនច្របូកច្របល់ទាំងនោះ ដែលបុគ្គលប្រកបបានយ៉ាងនេះ ព្រោះខ្លួន បុត្រ ភរិយា ឬទាសកម្មករ ដែលជាអ្នកឈ្លាស ត្រាស់ថា ជាមង្គល ព្រោះជាហេតុឲ្យបានទ្រព្យ ស្រូវ និងសេចក្ដីចម្រើនក្នុងបច្ចុប្បន្ន ។ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

បុគ្គលមានការងារសមតាមកាល មានធុរៈ ( មិនទម្លាក់ចោល ) ជាអ្នកតស៊ូ រមែងបាននូវទ្រព្យ ។ និងពុទ្ធដីកាមួយកន្លែងទៀតថា

> បុគ្គលដេកក្នុងវេលាថ្ងៃ ជាប្រក្រតី មិនក្រោកឡើងពីយប់ ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយ តែងកន្លងហួសមនុស្សដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះ ត្រជាក់ណាស់ ក្ដៅណាស់ ល្ងាចណាស់ ។ ជនណាមួយ ធ្វើនូវកិច្ចរបស់បុរស មិនអើពើនូវត្រជាក់ និងក្ដៅ ក្រៃលែងជាងស្មៅ ( ទៅទៀត ) ជននោះ រមែងមិនសាបសូន្យចាកសេចក្ដីសុខឡើយ ។

និងមួយកន្លែងទៀតថា

> កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឲ្យជាគំនរ ដូចជាឃ្មុំដូច្នោះឯង ។ ភោគៈទាំងឡាយតែងដល់នូវការពូនជាគំនរដូចជាដំបូកដែលកណ្ដៀរកពូនដូច្នោះឯង យ៉ាងនេះជាដើម ។

*ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺការបម្រើមាតា ១ បម្រើបិតា ១ ការសង្គ្រោះបុត្រភរិយា ១ និងការងារមិនច្របូកច្របល់ ១ ឬ ៥ មង្គល ព្រោះចែកការសង្គ្រោះបុត្រ និងភរិយាជា ២ ឬ ៣ មង្គល ព្រោះរួមការបម្រើមាតា និងបិតាចូលតែមួយ ។ ភាពដែលមង្គលទាំងនេះជាមង្គល បានចង្អុលបង្ហាញក្នុងមង្គលនោះៗ ហើយនោះឯង ។*

**អធិប្បាយបទថា មាតាបិតុបដ្ឋានំ ចប់**

## អធិប្បាយបទថា ទានញ្ច

*ឥឡូវនេះ នឹងពណ៌នាក្នុងគាថានេះថា* **ទានញ្ច។** *ឈ្មោះថា* **ទាន** *ព្រោះគេឲ្យដោយវត្ថុនេះ លោកអធិប្បាយថា គេប្រគល់ទ្រព្យដែលមានរបស់ខ្លួនឲ្យដល់អ្នកដទៃ ។ ការប្រព្រឹត្តធម៌ ឬការប្រព្រឹត្តដែលមិនប្រាសចាកធម៌ ឈ្មោះថា* **ធម្មចរិយា។** *ឈ្មោះថា* **ញាតិ** *ព្រោះបុគ្គលណាក៏ដឹងថា នេះជាគ្នារបស់យើង ។ ការមិនមានទោស ឈ្មោះថា* **អនវជ្ជ** *លោកអធិប្បាយថា បុគ្គលណាម្នាក់ និន្ទាមិនបាន តិះដៀលមិនបាន ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ នេះជាពណ៌នាបទ ។*

*ឯពណ៌នាអត្ថ គប្បីជ្រាបដូច្នេះ ចេតនាជាហេតុបរិច្ចាគវត្ថុ ១០ មានបាយជាដើម ដែលមានការដឹងល្អជាប្រធានចំពោះអ្នកដទៃ ឬការមិនមានលោភៈដែលប្រកបដោយចាគចេតនានោះ ឈ្មោះថា* **ទាន ។**

*ពិតហើយ បុគ្គលរមែងប្រគល់វត្ថុនោះឲ្យដល់អ្នកដទៃ ដោយការមិនលោភ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា ឈ្មោះថា* **ទាន** *ព្រោះបុគ្គលឲ្យដោយវត្ថុនេះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅខាងមុខ មានភាពជាបុគ្គលដែលជនច្រើនស្រឡាញ់ និងពេញចិត្តជាដើម ។ ក្នុងរឿងទាននេះ គប្បីរឭកដល់សូត្រទាំងឡាយជាដើមយ៉ាងនេះថា ម្នាលសីហៈ ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ។*

*មួយ៉ាងទៀត ឈ្មោះថា* **ទាន** *មាន ២ គឺអាមិសទាន និងធម្មទាន ក្នុងទានទាំង ២ នោះ អាមិសទានបានពោលមកហើយនោះឯង ។ ឯការសម្តែងធម៌ដែលព្រះសម្មាសម្ពុទ្ធប្រកាសហើយ ដែលនាំមកនូវការអស់ទុក្ខ និងសុខក្នុងលោកនេះ និងលោកខាងមុខ ព្រោះប្រាថ្នាឲ្យជាប្រយោជន៍ដល់អ្នកដទៃ ឈ្មោះថា* **ធម្មទាន** *។ មួយ៉ាងទៀត បណ្តាទានទាំង ២ នេះ ធម្មទាននេះតែម្យ៉ាង ជាកំពូលនៃទានទាំងពួង ដូចព្រះមានព្រះភាគត្រាស់ថា*

**សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ**
**សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

*ធម្មទាន ឈ្នះអាមិសទានទាំងពួង ធម្មរស ឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។*

*ក្នុងព្រះសូត្រ និងគាថានោះ ដែលត្រាស់ភាពដែលអាមិសទានជាមង្គល*

ប៉ុណ្ណោះ ចំណែកធម្មទានត្រាស់ថា ជាមង្គល ព្រោះជាបទដ្ឋាននៃគុណទាំង-ឡាយ មានភាពជាអ្នកជ្រាបនូវអត្ថជាដើម សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្ដែងធម៌ដល់បុគ្គលដទៃ តាមសមគួរដល់ការចេះដឹង សមគួរដល់ការសិក្សាដោយពិស្ដារ យ៉ាងណាៗ ភិក្ខុនោះ ក៏ដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះ យ៉ាងនោះៗ ដូច្នេះជាដើម ។

ការប្រព្រឹត្តកុសលកម្មបថ ១០ ឈ្មោះថា **ធម្មចរិយា** ដូចព្រះមានព្រះភាគត្រាស់យ៉ាងនេះជាដើមថា ម្នាលគហបតីទាំងឡាយ ការប្រព្រឹត្តធម៌ ការប្រព្រឹត្តស្មើមាន ៣ យ៉ាង ។ ការប្រព្រឹត្តធម៌នោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុចូលដល់ស្ថានសួគ៌ទេវលោក សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា

ម្នាលគហបតិទាំងឡាយ ព្រោះសេចក្ដីប្រព្រឹត្តស្មើ គឺប្រព្រឹត្តធម៌ ជាហេតុយ៉ាងនេះឯង បានជាពួកសត្វខ្លះ ក្នុងលោកនេះ ដល់បែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោកយ៉ាងនេះ ដូច្នេះ ។

ជនដែលជាប់ខ្សែស្រឡាយខាងមាតា ឬបិតា រហូតដល់ ៧ ជួរ ឈ្មោះថា **ញាតិ** ។ ការសង្គ្រោះញាតិទាំងនោះ បុគ្គលដែលត្រូវវិនាសភោគៈ ត្រូវវិនាសដោយជំងឺគ្របសង្កត់ហើយ មករកខ្លួនដោយអាហារ និងគ្រឿងស្លៀក

*ដណ្តប់ មានស្រូវជាដើមតាមកម្លាំង ត្រាស់ថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសដែលជាបច្ចុប្បន្ន មានការសរសើរជាដើម និងជាចំណែកខាងមុខ មានទៅសុគតិជាដើម ។ កិច្ចកម្មដែលជាសុចរិត ដោយកាយ វាចា ចិត្ត មានការសមាទានអដ្ឋង្គឧបោសថ ការធ្វើសេចក្តីខ្វល់ខ្វាយ ការដាំដើមឈើធ្វើសួន ដាំដើមឈើធ្វើព្រៃ និងសាងស្ពានជាដើម ឈ្មោះថា ការងារមិនមានទោស ។ ការងារមិនមានទោសទាំងនោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុឲ្យជួបនូវប្រយោជន៍ និងសេចក្តីសុខច្រើនប្រការ ។ គប្បីរឭកដល់ព្រះសូត្រទាំងឡាយ មានសូត្រជាដើមយ៉ាងនេះថា*

> *ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា ដូច្នេះ ។*

*ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានោះ ៤ មង្គល គឺទាន ១ ធម្មចរិយា ១ ការសង្គ្រោះញាតិ ១ ការងារមិនមានទោស ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល ក៏បានចង្អុលបង្ហាញហើយ ក្នុងមង្គលទាំងនោះឯង ។*

**អធិប្បាយបទថា ទានញ្ច ចប់**

# អធិប្បាយបទថា អារតី

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា **អារតី វិរតី** នេះ ។ ឈ្មោះថា **អារមណា** ព្រោះលះបង់ ។ ឈ្មោះថា **វិរមណា** ព្រោះវៀរ ។ ម្យ៉ាងទៀត ចេតនា ឈ្មោះថា **វិរតិ** ព្រោះជាគ្រឿងដែលសត្វវៀរចាក ។ បទថា **ចាចា** បានដល់ បាបអកុសល ។ ឈ្មោះថា **មជ្ជ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្តីស្រវឹង ។ ការផឹកមជ្ជៈ ឈ្មោះថា **មជ្ជបាន**។ សង្រួមចាកមជ្ជបានៈនោះ ។ ការសង្រួម ឈ្មោះថា **សំយម**។ ការមិនប្រមាទ ឈ្មោះថា **អប្បមាទ** ។ បទថា **ធម្មេសុ** បានដល់ ក្នុងកុសលទាំងឡាយ ។ ពាក្យដ៏សេស មានន័យដូចពោលមកទាំងអស់ហើយនោះឯង នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ការមិនត្រេកអរក្រៃលែងផ្លូវចិត្តតែម្យ៉ាងរបស់បុគ្គលដែលឃើញទោសក្នុងបាប ឈ្មោះថា **អារតិ**។ ការវៀរចាកតាមកាយ វាចា ដោយកម្ម និងទ្វារ ឈ្មោះថា **វិរតិ**។

ធម្មតាវិរតិនោះមាន ៣ គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទ-វិរតិ ១ ។ បណ្តាវិរតិទាំង ៣ នោះ វិរតិចេតនា វៀរចាកវត្ថុដែលជួបឯណារបស់កុលបុត្រ ក្នុងន័យជាដើមយ៉ាងនេះថា ការដែលអាត្មាអញសម្លាប់សត្វ ឬលួចទ្រព្យជាដើមនេះ កាលនឹកដល់ជាតិ ត្រកូល ឬគោត្ររបស់ខ្លួន ក៏មិនសមគួរដល់អាត្មាអញឡើយ វិរតិចេតនានេះ ឈ្មោះថា **សម្បត្តវិរតិ**។ កុល-បុត្តមិនធ្វើបាប មានបាណាតិបាតជាដើម តាំងអំពីប្រព្រឹត្តវិរតិឯណា វិរតិនោះ ប្រព្រឹត្តទៅដោយសមាទានសិក្ខាបទ ឈ្មោះថា **សមាទានវិរតិ**។ ពៀរនិងភ័យ ៥ របស់ព្រះអរិយសាវករម្ងាប់ទៅ តាំងអំពីប្រព្រឹត្តវិរតិណា វិរតិ

នោះ ប្រកបដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ** ។ បាបអកុសលនោះ មាន ៤ យ៉ាង ពោល គឺកម្មក្កិលេសដែលព្រះមានព្រះភាគត្រាស់ពិស្តារ យ៉ាងនេះថា

ម្នាលគហបតិបុត្ត ការធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ( សម្លាប់សត្វ ) ជាកម្មក្កិលេស ១ ការកាន់យកទ្រព្យដែលម្ចាស់គេមិនឲ្យ ជាកម្មក្កិលេស ១ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាកម្មក្កិលេស ១ ការនិយាយពាក្យកុហក ជាកម្មក្កិលេស ១ កម្មក្កិលេស ៤ ប្រការនេះ ដែលអរិយសាវកនោះ បានលះបង់ហើយ ដូច្នេះហើយ ទ្រង់សង្ខេបដោយគាថាយ៉ាងនេះថា

**បាណាតិបាតោ អទិន្នាទានំ មុសាវាទោ ច បវុច្ចតិ**
**បរទារគមនញ្ចេវ នប្បសំសន្តិ បណ្ឌិតា ។**

ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ និយាយកុហក ១ សេពកិរិយាបុគ្គលដទៃ ១ ហៅថា ( កម្មក្កិលេស ) បណ្ឌិតទាំងឡាយ មិនសរសើរឡើយ ។

ការវៀរចាកបាបអកុសលនោះ ការវៀរទាំងអស់នេះ ត្រាស់ថាជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសច្រើនប្រការ មានការលះភ័យ វៀរដែលជាបច្ចុប្បន្ន និងប្រព្រឹត្តទៅខាងមុខជាដើម ។

ក្នុងសេចក្តីនេះ គប្បីរឭកដល់ព្រះសូត្រទាំងឡាយ ដោយន័យជាដើមថា

ម្នាលគហបតិបុត្ត អរិយសាវក វៀរជាសមុច្ឆេទនូវបាណាតិបាត ។

និងពណ៌នានូវការសង្រួមក្នុងការផឹកទឹកស្រវឹង ពាក្យនេះជាឈ្មោះរបស់ចេតនា វៀរចាកទីតាំងនៃសេចក្តីប្រមាទ គឺការផឹកគ្រឿងស្រវឹង គឺសុរា និងមេរ័យ ដែលពោលអំពីមុនហើយ ។ ព្រោះហេតុដែលបុគ្គលផឹកទឹកស្រវឹង រមែងមិនដឹងអត្ថ មិនដឹងធម៌ រមែងធ្វើអន្តរាយដល់មាតា ធ្វើអន្តរាយដល់បិតា សូម្បីដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត រមែងជួបនូវការតិះដៀលក្នុងភពបច្ចុប្បន្ន ជួបនូវទុគ្គតិក្នុងភពខាងមុខ និងជួបនូវភាពឆ្កួតក្នុងភពតៗ ទៅ ។ ឯការសង្រួមចាកការផឹកទឹកស្រវឹង រមែងសម្រេចការរម្ងាប់ទោសទាំងនោះ និងការដល់ព្រមដោយគុណដែលផ្ទុយគ្នានឹងទោសនោះ ដូច្នោះ ការសង្រួមក្នុងការផឹកទឹកស្រវឹងនេះ គប្បីជ្រាបថា ជាមង្គល ។

ការនៅមិនប្រាសចាកសតិ ក្នុងកុសលធម៌ទាំងឡាយ ដោយអត្ថ គប្បីជ្រាបដោយជាបដិបក្ខចំពោះសេចក្តីប្រមាទ ដែលលោកពោលក្នុងបាលីថា

> ការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុងការចម្រើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្តីធ្វេសប្រហែស មានសភាពយ៉ាងនេះណា នេះហៅថា សេចក្តីប្រមាទ ។

*ឈ្មោះថា ការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ការមិនប្រមាទក្នុងកុសលធម៌នោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុ ជួបនូវកុសលច្រើនប្រការ និងព្រោះជាហេតុសម្រេចអមតធម៌ ។ ក្នុងសេចក្តីនោះ គប្បីរឭកដល់ពាក្យទូន្មានរបស់ព្រះសាស្តាជាដើមយ៉ាងនេះថា បុគ្គលមិនប្រមាទ បុគ្គលមានសេចក្តីព្យាយាម និងពុទ្ធវចនៈមួយទៀតថា សេចក្តីមិនប្រមាទ ជាផ្លូវមិនស្លាប់ ដូច្នេះ ។*

*ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៣ មង្គល គឺការវៀរចាកបាប ១ ការសង្រួមចាកការផឹកទឹកស្រវឹង ១ ការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ១ ដោយប្រការដូច្នេះ ។ ភាពដែលជាមង្គលទាំងនោះជាមង្គលក៏បានចង្អុលបង្ហាញហើយក្នុងមង្គលនោះទាំងអស់ ដូច្នេះ ។*

**អធិប្បាយបទថា អារតី ចប់**

# អធិប្បាយបទថា គារវោ ច

*ឥឡូវនេះ នឹងពណ៌នាក្នុងគាថា* **គារវោ ច** *ដូច្នេះ ។ បទថា* **គារវោ** *បានដល់ ភាពជាអ្នកធ្ងន់ ។ បទថា* **និវាតោ** *បានដល់ ភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ។ បទថា* **សន្តុដ្ឋិ** *ប្រែថា ការសន្តោស ។ ការដឹងឧបការគុណដែលលោកធ្វើទុក ឈ្មោះថា* **កតញ្ញុតា** *។ បទថា* **កាលេន** *ប្រែថា ខណៈឬសម័យ ។ ការស្តាប់ធម៌ ឈ្មោះថា* **ធម្មស្សវនំ** *។ ពាក្យដ៏សេស មាន*

ន័យដូចពោលមកហើយនោះឯង នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ សេចក្តីគោរព ការធ្វើសេចក្តីគោរព ភាពជាបុគ្គលមានសេចក្តីគោរពតាមសមគួរក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវ័ករបស់ព្រះតថាគត អាចារ្យ ឧបជ្ឈាយ៍ មាតាបិតា បងប្រុស បងស្រីជាដើម ជាបុគ្គលគួរប្រកបដោយសេចក្តីគោរព ឈ្មោះថា **គារវ** ។ គារវៈនេះ ព្រោះហេតុដែលជាហេតុនៃការទៅសុគតិជាដើម ដូចព្រះតម្រាស់ថា

ធ្វើសេចក្តីគោរព ដល់បុគ្គលដែលគួរគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាដល់បុគ្គលដែលគួរបូជា ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

និងដូចព្រះពុទ្ធតម្រាស់មួយទៀតយ៉ាងនេះថា

បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៧ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពព្រះសាស្តា ១ ... ដូច្នេះជាដើម ទើបត្រាស់ថា ជាមង្គល ។

ភាពជាអ្នកមានចិត្តដាក់ទាប ភាពជាបុគ្គលមានការប្រព្រឹត្តមិនបំប៉ោងខ្លួន ឈ្មោះថា ការប្រព្រឹត្តបន្ទាបខ្លួន ។ បុគ្គលប្រកបដោយភាពជាអ្នកបន្ទាបខ្លួនឯណា កម្ចាត់នូវមានះបាន កម្ចាត់នូវការរឹងត្អឹងបាន ដូចសំពត់ជូតជើង ដូចគោឧសភបាក់ស្នែង និងដូចពស់ដកចង្កូមហើយ រមែងជាអ្នកល្អិតល្អន់ទន់ភ្លន់ ស្រស់បស់ដោយសេចក្តីសុខ ភាពជាបុគ្គលបន្ទាប់ខ្លួននេះ ជា

**និទាន** និទាតនេះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុបាននូវគុណ មានយស ជាដើម ។ ម្យ៉ាងទៀត ត្រាស់ថា ជាអ្នកបន្ទាបខ្លួន មិនរឹងត្អឹង បុគ្គលបែប នោះ រមែងបានយស ដូច្នេះជាដើម ។

ការសន្តោសដោយបច្ច័យតាមមានតាមបាន ឈ្មោះថា **សន្តុដ្ឋី**។ សន្តោស នោះមាន ១២ យ៉ាង គឺក្នុងចីវរ ៣ យ៉ាង គឺយថាលាភសន្តោស សន្តោស តាមដែលបាន យថាពលសន្តោស សន្តោសតាមកម្លាំង យថាសារុប្បសន្តោស សន្តោសតាមសមគួរ ក្នុងបិណ្ឌបាតជាដើមក៏យ៉ាងនេះ ។

នឹងពណ៌នាប្រភេទនៃសន្តោសនោះ ដូច្នេះ ។ ភិក្ខុក្នុងធម្មវិន័យនេះ បាន ចីវរល្អក្តី មិនល្អក្តី ភិក្ខុនោះ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះ ប៉ុណ្ណោះ មិនប្រាថ្នាចីវរដទៃ កាលបានក៏មិនទទួលនេះ ឈ្មោះថា យថា-លាភសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុអាពាធ កាលដណ្តប់ចីវរធ្ងន់ រមែងមានខ្លួនកោងចុះ ឬ លំបាក ទើបលោកប្តូរចីវរនោះជាមួយភិក្ខុដែលយល់ចិត្តគ្នា ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅដោយចីវរនោះ ក៏ឈ្មោះថា សន្តោស នេះឈ្មោះថា យថា-ពលសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យដែលប្រណីត លោកបានចីវរ មាន ចីវរល្អជាដើមណាមួយ ដែលមានតម្លៃច្រើន គិតថា ចីវរនេះសមគួរដល់ព្រះ ថេរៈ ដែលជាអ្នកបួសយូរ និងភិក្ខុដែលជាពហុស្សុត ទើបប្រគេនដល់ភិក្ខុ ទាំងនោះ ខ្លួនឯងក៏ជ្រើសរើសយកសេសសំពត់អំពីគំនរសំរាម ឬបាកទីដទៃ

*ណាមួយ ធ្វើសង្ឃាដីគ្រង ក៏នៅតែជាអ្នកសន្តោសនោះឯង នេះឈ្មោះថា* **យថាសារុប្បសន្តោស** *ក្នុងចីវររបស់ភិក្ខុនោះ ។*

*ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះបានបិណ្ឌបាតសៅហ្មងក្តី ប្រណីតក្តី ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ មិនបំណងបិណ្ឌបាតដទៃ ។ កាលបានក៏មិនទទួល នេះឈ្មោះថា* **យថាលាភសន្តោស** *ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។*

*ម្យ៉ាងទៀត ភិក្ខុអាពាធឆាន់បិណ្ឌបាតសៅហ្មង រោគនឹងកម្រើកឡើងធ្ងន់ ទើបលោកប្រគេនបិណ្ឌបាតនោះដល់ភិក្ខុដែលគាប់ចិត្ត ឆាន់សប្បិ ទឹកឃ្មុំ និងទឹកដោះស្រស់ជាដើមអំពីដៃរបស់ភិក្ខុនោះ ធ្វើសមណធម៌ ក៏នៅតែជាអ្នកសន្តោស នេះជា* **យថាពលសន្តោស** *ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។*

*ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដ៏ប្រណីត គិតថា បិណ្ឌបាតនេះ សមគួរដល់ព្រះថេរៈដែលជាអ្នកបួសយូរ សូម្បីដល់សព្រហ្មចារីដទៃ ដែលវៀរបិណ្ឌបាតប្រណីតចេញ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅមិនបាន ទើបប្រគេនដល់ភិក្ខុទាំងនោះ ខ្លួនឯងត្រាច់បិណ្ឌបាត ឆាន់អាហារដែលលាយគ្នា ក៏នៅតែជាអ្នកសន្តោស នេះឈ្មោះថា* **យថាសរុប្បសន្តោស** *ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។*

*ម្យ៉ាងទៀត សេនាសនៈមកដល់ភិក្ខុក្នុងធម្មវិន័យនេះ លោកក៏សន្តោសដោយសេនាសនៈនោះឯង ។ មិនព្រមទទួលសេនាសនៈដទៃដែលមកដល់ល្អជាង នេះឈ្មោះថា* **យថាលាភសន្តោស** *ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។*

ម្យ៉ាងទៀត ភិក្ខុអាពាធនៅក្នុងសេនាសនៈដែលមិនត្រូវខ្យល់ រមែងទ្រុឌទ្រោមយ៉ាងក្រៃលែង ដោយរោគប្រមាត់ជាដើម ទើបលោកប្រគេនសេនាសនៈដល់ភិក្ខុដែលត្រូវគ្នា ហើយនៅក្នុងសេនាសនៈដែលត្រជាក់ មានខ្យល់ដែលដល់លំដាប់ភិក្ខុនោះ ធ្វើសមណធម៌ ក៏នៅឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត មិនព្រមទទួលសេនាសនៈដែលល្អ ដែលមកដល់ គិតថា សេនាសនៈល្អ ជាទីតាំងនៃសេចក្តីប្រមាទ កាលភិក្ខុអង្គុយក្នុងសេនាសនៈនោះ ថីនមិទ្ធៈរមែងគ្របសង្កត់ កាលនិទ្រា ហើយភ្ញាក់ឡើង កាមវិតក្ករមែងផ្សាយឡើង ទើបលោកបដិសេធសេនាសនៈនោះៗ នៅតែក្នុងទីវាល គល់ឈើ និងកុដិដែលប្រក់ដោយស្មៅទីណាទីមួយ ក៏នៅតែជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះបានភេសជ្ជៈ មិនថា ផ្លែសម៉ ឬផ្លែកន្ទួតព្រៃ លោកក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភេសជ្ជៈនោះ ។ មិនប្រាថ្នាភេសជ្ជៈដទៃ មានសប្បិ ទឹកឃ្មុំ ទឹកអំពៅជាដើមដែលបានហើយ កាលបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុអាពាធត្រូវការប្រេង តែបានទឹកអំពៅ លោកក៏ប្រគេនទឹកអំពៅនោះដល់ភិក្ខុដែលគាប់ចិត្ត តែធ្វើថ្នាំដោយប្រេងអំពីដៃរបស់ភិក្ខុនោះ

ធ្វើសមណធម៌ ក៏នៅតែជាអ្នកសន្ដោស នេះឈ្មោះថា **យថាពលសន្ដោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ដាក់សម៉ត្រាំទឹកមូត្រ ក្នុងភាជនៈមួយ ដាក់របស់មានរសឆ្ងាញ់ ៤ យ៉ាង ក្នុងភាជនៈមួយ កាលត្រូវភិក្ខុសព្រហ្មចារីប្រាប់ថា លោកម្ចាស់ត្រូវការរបស់ណា សូមកាន់យកចុះ បើអាពាធរបស់ភិក្ខុនោះរម្ងាប់ទៅដោយសម៉ត្រាំទឹកមូត្រ និងមធុរសេ គឺទាំង ២ យ៉ាងនោះណាមួយសោត កាលបើដូច្នោះ លោកគិតថា ធម្មតាសម៉ត្រាំដោយមូត្រ ព្រះពុទ្ធជាដើមទ្រង់សរសើរហើយ ហើយព្រះសម្ពុទ្ធត្រាស់ថា បព្វជ្ជាអាស្រ័យទឹកមូត្រជាភេសជ្ជៈ គប្បីធ្វើនូវឧស្សាហ៍ក្នុងមុត្តភេសជ្ជៈនោះ ដរាបដល់អស់ជីវិត បដិសេធវត្ថុ មានរសឆ្ងាញ់ជាភេសជ្ជៈ ធ្វើភេសជ្ជៈដោយសម៉ត្រាំដោយទឹកមូត្រ ក៏ជាអ្នកសន្ដោសយ៉ាងក្រៃលែង នេះឈ្មោះថា **យថាសារុប្ប-សន្ដោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

សន្ដោសទាំងអស់នោះ មានប្រភេទយ៉ាងនេះ ក៏ហៅថា **សន្តុដ្ឋី** សន្តុដ្ឋីនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវការលះបាបធម៌ទាំងឡាយ មានការប្រាថ្នាលើសចំណែក ការប្រាថ្នាច្រើន និងការប្រាថ្នាលាមកជាដើម ព្រោះជាហេតុនៃសុគតិ ព្រោះជាគ្រឿងអប់រំអរិយមគ្គ និងព្រោះជាហេតុនៃភាពជាអ្នកនៅបានសប្បាយក្នុងទិសទាំង ៤ ដូចព្រះមានព្រះភាគត្រាស់ថា

**ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ**
**សន្តុស្សមានោ ឥតរីតរេន ។**

បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនលំបាក
ត្រេកអរដោយបរិក្ខារ តាមមាន តាមបាន ... ។

ការស្គាល់ឧបការគុណដែលបុគ្គលណាម្នាក់ធ្វើមកហើយ ទោះច្រើន ឬ តិច ដោយការរឭកដល់រឿយៗ ឈ្មោះថា **កតញ្ញុតា**។ ម្យ៉ាងទៀត បុណ្យទាំងឡាយនោះឯង មានឧបការៈច្រើនដល់សត្វទាំងឡាយ ព្រោះការពារទុក្ខមានទុក្ខក្នុងនរកជាដើមបាន ។ ដូច្នោះ ការរឭកដល់ឧបការៈនៃបុណ្យទាំង-នោះ គប្បីជ្រាបថា ជាកតញ្ញុតា ។ កតញ្ញុតា ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេស មានប្រការផ្សេងៗ មានភាពជាបុគ្គលដែលសប្បុរសសរសើរជាដើម ទាំងព្រះមានព្រះភាគក៏ត្រាស់ថា បុគ្គលជាបុព្វការី ១ បុគ្គលជាកតញ្ញូកតវេទី ១ បុគ្គល ២ ពួកនេះ រកបានដោយក្រក្នុងលោក ។

ការស្តាប់ធម៌ ដើម្បីបន្ទោបង់នូវវិតក្ក ក្នុងកាលដែលចិត្តប្រកបដោយឧទ្ធច្ចៈ ឬចិត្តត្រូវវិតក្កទាំងឡាយ មានកាមវិតក្កជាដើមណាមួយគ្របសង្កត់ ឈ្មោះថា ការស្តាប់ធម៌តាមកាល ។ អាចារ្យពួកខ្លះពោលថា ការស្តាប់ធម៌រៀងរាល់ ៥ ថ្ងៃម្តង ឈ្មោះថា ស្តាប់ធម៌តាមកាល ដូចដែលលោកពោលថា ព្រះអនុរុទ្ធក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត យើងខ្ញុំព្រះអង្គតែងអង្គុយប្រជុំគ្នា ដោយធម្មីកថាពេញមួយយប់ រាល់ថ្ងៃទី ៥ ។

ម្យ៉ាងទៀត ក្នុងកាលណា ភិក្ខុចូលទៅរកកល្យាណមិត្តហើយ អាចស្តាប់ធម៌ បន្ទោបង់នូវសេចក្តីសង្ស័យរបស់ខ្លួនចេញបាន ការស្តាប់ធម៌ក្នុង

កាលនោះ ក៏គប្បីជ្រាបថា ការស្តាប់ធម៌តាមកាល ដូចព្រះមានព្រះភាគ ត្រាស់ថា បានចូលទៅសាកសួរពិគ្រោះនឹងគ្រូ ឬសព្រហ្មចារីបុគ្គលទាំងនោះ តាមកាលដ៏គួរ ... ។ ការស្តាប់ធម៌តាមកាលនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសច្រើនប្រការ មានការលះនីវរណៈ បាននូវ អានិសង្ស ៤ នឹងសម្រេចធម៌ដែលជាទីអស់អាសវៈជាដើម សមដូចព្រះ មានព្រះភាគត្រាស់ដូច្នេះថា

ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកធ្វើឲ្យ ជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងអស់ ផ្ទៀង សោតប្រសាទស្តាប់ធម៌ សម័យនោះ នីវរណធម៌ទាំង ៥ មិនមានដល់ភិក្ខុនោះឡើយ ។

និងត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំងឡាយ ៤ ប្រការ នៃធម៌ ដែលចូលទៅកាន់ត្រចៀករឿយៗ ជាធម៌ដែល បុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះ ដោយទិដ្ឋិ គឺបញ្ញា រមែងកើតប្រាកដ ។

និងត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ កាល ( នៃកុសលធម៌ ) ៤ យ៉ាងនេះ កាលបើបុគ្គលចម្រើនដោយប្រពៃ ឲ្យប្រព្រឹត្ត ទៅដោយប្រពៃ រមែងឲ្យដល់នូវការអស់ទៅនៃអាសវៈ

ដោយលំដាប់ ។ កាល ៤ យ៉ាង តើដូចម្ដេចខ្លះ ។

គឺការស្ដាប់ធម៌តាមកាល ១ ... យ៉ាងនេះជាដើម ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៥ មង្គល គឺ សេចក្ដីគោរព ១ ការបន្ទាបខ្លួន ១ សន្ដោស ១ កតញ្ញុតា ១ និងការស្ដាប់ធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល ក៏បានចង្អុលបង្ហាញហើយ ក្នុងមង្គលទាំងនោះឯង ។

**អធិប្បាយគាថា បទថា គារវោ ច ចប់**

## អធិប្បាយបទថា ខន្តិ ច

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា **ខន្តិ ច** នេះ ការអត់ធន់ ឈ្មោះថា **ខន្តិ**។ ឈ្មោះថា **សុវចៈ** ព្រោះប្រដៅងាយ ព្រោះជាបុគ្គលកាន់យកចំណែកខាងស្ដាំ ។ កម្មរបស់បុគ្គលប្រដៅងាយ ឈ្មោះថា **សោវចស្សំ**។ ភាវៈនៃកម្មរបស់បុគ្គលប្រដៅងាយ ឈ្មោះថា **សោវចស្សតា**។ ឈ្មោះថា សមណៈ ព្រោះរម្ងាប់កិលេសទាំងឡាយបាន ។ បទថា **ទស្សនំ** បានដល់ ការសម្លឹងមើល ។ ការសន្ទនា ឈ្មោះថា **ធម្មសាកច្ឆា**។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្ដី គប្បីជ្រាបដូច្នេះថា **អធិវាសនខន្តិ** ឈ្មោះថា ខន្តី ភិក្ខុដែលប្រកបដោយខន្តីនោះហើយ រមែងមិនមានអាការខុសប្រក្រតី ជាអ្នក

ហាក់ដូចមិនបានឮពាក្យជេរដោយអក្កោសវត្ថុ ១០ និងដូចមិនឃើញបុគ្គល ដែលបៀតបៀន ដោយការសម្លាប់ និងការចងជាដើម ដូចខន្តិវាទីតាបស ដូច្នោះ ។ ដូចព្រះមានព្រះភាគត្រាស់ថា

**អហុ អតីតមទ្ធានេ សមណោ ខន្តិទីបនោ**
**តំ ខន្តិយា យេវ ឋិតំ កាសិរាជា អឆេទយិ ។**

*សមណៈជាអ្នកសម្តែងនូវខន្តី មានហើយក្នុងអតីត-កាល ព្រះបាទកាសី ទ្រង់ត្រាស់ឲ្យចោរឃាតកបុរស សម្លាប់សមណៈនោះ អ្នកតាំងនៅក្នុងខន្តី ។*

ឬរមែងដាក់ចិត្តថា បុគ្គលនោះធ្វើល្អហើយ ព្រោះមិនមានការត្រេកអរ ក្រៃលែងជាងនោះ ដូចព្រះបុណ្ណត្ថេរ ដូច្នោះ ដែលលោកក្រាបទូលថា

*បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនា-បរន្តជនបទ នឹងជេរគំរាមខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុង ហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អ ណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញ ដោយបាតដៃ ... ដូច្នេះ ។*

ភិក្ខុប្រកបដោយខន្តីនោះហើយ រមែងជាបុគ្គលដែលសូម្បីតែឥសីទាំង-ឡាយក៏សរសើរ ដូចសរភង្គឥសីពោលថា

**កោធំ វធិត្វា ន កទាចិ សោចតិ មក្ខប្បហានំ**

**ឥសយោ វណ្ណយន្តិ សព្ពេសំ វុត្តំ ជរុសំ ខមេថ ឯតំ ខន្តឹ ឧត្តមមាហុ សន្តោ ។**

បុគ្គលសម្លាប់សេចក្តីក្រោធ រមែងមិនក្រៀមក្រំក្នុងកាលណាមួយឡើយ ឥសីទាំងឡាយ រមែងសរសើរនូវការលះបង់នូវសេចក្តីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ ពួកសប្បុរសពោលនូវសេចក្តីអត់ធន់នុ៎ះ ថាជាគុណជាតិដ៏ឧត្តម ។

រមែងជាបុគ្គលដែលទេវតាទាំងឡាយ គប្បីសរសើរ ដូចសក្កទេវរាជត្រាស់ថា

**យោ ហវេ ពលវា សន្តោ ទុព្វលស្ស តិតិក្ខតិ**
**តមាហុ បរមំ ខន្តឹ និច្ចំ ខមតិ ទុព្វលោ ។**

ជនណាមានកម្លាំង ជាអ្នកស្ងប់ ហើយអត់ឱនចំពោះបុគ្គលមានកម្លាំងខ្សោយ បណ្ឌិតទាំងឡាយសរសើរជននោះ ថាជាអ្នកមានសេចក្តីអត់ទ្រាំដ៏ក្រៃលែង ព្រោះថា បុគ្គលមានកម្លាំងថយ តែងអត់សង្កត់ជានិច្ច ។

រមែងជាបុគ្គលដែលព្រះពុទ្ធទាំងឡាយ គប្បីសរសើរ ដូចព្រះមានព្រះភាគត្រាស់ថា

**អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ**

**ខន្តិពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។**

*បុគ្គលណា មិនប្រទូស្ត អត់សង្កត់ពាក្យជេរផង*
*ការបៀតបៀន និងការចងផងបាន ទើបតថាគត*
*ហៅបុគ្គលដែលមានខន្តិជាពល មានខន្តិជាវេហ៍ពល*
*នោះឯង ថាជាព្រាហ្មណ៍ ។*

ខន្តីនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវគុណទាំងនោះ និងគុណដទៃៗ ដែលទ្រង់សរសើរក្នុងទីនេះ ។

កាលត្រូវសព្រហ្មចារី ប្រៀនប្រដៅក៏មិនដល់នូវការរាយមាយ និងអង្គុយស្ងៀម ឬគិតដល់គុណ និងទោស ដាក់នូវការអើពើ សេចក្តីគោរព និងការមានចិត្តធ្លាក់ទៅ ជាទីទៅខាងមុខយ៉ាងក្រៃលែង ហើយបន្ទឹពាក្យថា **សាធុ** ដូច្នេះ ឈ្មោះថា **សោវចស្សតា** គឺការប្រដៅងាយ ។ **សោវចស្សតា** នោះ ត្រាស់ថា ជាមង្គល ព្រោះជាហេតុបានឱវាទ និងអនុសាសនីអំពីសម្នាក់សព្រហ្មចារីទាំងឡាយ និងព្រោះជាហេតុលះទោស និងសម្រេចនូវគុណ ។

ការចូលទៅរកការទំនុកបម្រុង ការរឭក ការស្តាប់ និងការឃើញអ្នកបួសទាំងឡាយ ដែលស្ងប់រម្ងាប់កិលេស ហើយអប់រំកាយ វាចា ចិត្ត និងបញ្ញាហើយ ប្រកបដោយសេចក្តីស្ងប់ដ៏ឧត្តម ឈ្មោះថា ការឃើញសមណៈទាំងឡាយ ។ ការឃើញសមណៈទាំងឡាយ លោកពោលថា ទស្សនៈ ដោយទេសនាយ៉ាងទាប ។ ការឃើញសមណៈនោះ គប្បីជ្រាបថា ជាមង្គល ។ ព្រោះហេតុអ្វី ព្រោះមានឧបការៈច្រើន ពិតហើយ ព្រះមាន

ព្រះភាគត្រាស់ជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការជួបប្រទះនូវភិក្ខុទាំងនោះថា មានឧបការៈច្រើន ព្រោះបុណ្យឯណា ដែលកុលបុត្រអ្នកប្រាថ្នាប្រយោជន៍ ឃើញភិក្ខុទាំងឡាយដែលមានសីល មកដល់ទ្វារផ្ទះបើទេយ្យធម៌មាន ក៏គប្បីរាប់អាន ដោយទេយ្យធម៌តាមកម្លាំង បើមិនមានគប្បីថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន កាលការថ្វាយបង្គំដោយបញ្ចង្គប្រតិ-ស្ឋានមិនដល់ព្រម ក៏គប្បីផ្គងអញ្ជលីនមស្ការ បើនមស្ការមិនដល់ព្រម ក៏គប្បីមានចិត្តជ្រះថ្លា សម្លឹងមើលដោយចក្ខុជាទីស្រឡាញ់ ដោយបុណ្យ មានការសម្លឹងមើលជាមូលយ៉ាងនេះ រោគ ឬទោស កន្ទុយថ្លែន ឬពក នឹងមិនមានក្នុងចក្ខុអស់ពាន់ជាតិ ចក្ខុទាំង ២ ក៏នឹងផូរផង់ មានសិរី មានពណ៌ ៥ ដូចបន្ទះកែវមណីដែលបើកក្នុងរតនវិមាន បុគ្គលនោះ នឹងបានសម្បត្តិក្នុងទេវតានិងមនុស្សប្រមាណសែនកប្ប កាលកើតជាមនុស្ស ក៏ជាអ្នកមានបញ្ញា គប្បីសោយវិបាកសម្បត្តិបែបនេះ ដោយបុណ្យដែលសម្រេចមកអំពីការឃើញសមណៈ ដែលបុគ្គលនោះ ប្រព្រឹត្តមកដោយប្រពៃ មិនគួរអស្ចារ្យឡើយសូម្បីសត្វតិរច្ឆាន បណ្ឌិតទាំងឡាយ ក៏ពណ៌នាវិបាកសម្បត្តិ នៃការឃើញសមណៈ ដោយត្រឹមតែធ្វើសទ្ធាឲ្យកើតហើយតែម្យ៉ាងយ៉ាងនេះ ក្នុងបាលី-បទេសណា បាលីបទេសនោះ មានដូច្នេះ

សត្វទីទុយ អាស្រ័យវេទិយកបព៌ត មកអស់កាលយូរ ទីទុយនេះសុខពិតហ្ន៎ ឃើញព្រះពុទ្ធដ៏ប្រសើរ ដែលក្រោកឡើងអំពីព្រលឹម ៗ ទីទុយធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត និងភិក្ខុសង្ឃ ដែលជាអគ្គបុគ្គល មិនទៅទុគ្គតិអស់

សែនកប្ប ទីទុយនោះចុតិអំពីទេវលោក កាលកុសលកម្ម ជាស់តឿនហើយ នឹងបានជាព្រះបច្ចេកពុទ្ធ ជាអនន្តញ្ញាណ ប្រាកដនាមថា សោមនស្ស ដូច្នេះ ។

ក្នុងវេលាព្រលប់ ឬក្នុងវេលាទៀបភ្លឺ ភិក្ខុខាងព្រះសូត្រ ២ រូប រមែងសន្ទនានូវព្រះសូត្រដល់គ្នានិងគ្នា ភិក្ខុចាំណែកខាងវិន័យ ក៏សន្ទនាព្រះវិន័យ ភិក្ខុខាងអភិធម្ម ក៏សន្ទនាខាងព្រះអភិធម្ម ភិក្ខុខាងជាតក ក៏សន្ទនាខាងជាតក ខាងអដ្ឋកថា ក៏សន្ទនាខាងអដ្ឋកថា ឬសន្ទនាគ្នាក្នុងកាលនោះៗ ដើម្បីជម្រះចិត្តដែលត្រូវសេចក្តីរាយមាយគ្របសង្កត់ និងការសង្ស័យដឹកនាំទៅ ការសន្ទនាតាមកាលនេះ ឈ្មោះថា សន្ទនាធម៌តាមកាល ការសន្ទនាធម៌តាមកាលនោះត្រាស់ថា ជាមង្គល ព្រោះជាហេតុនៃគុណទាំងឡាយ មានការឈ្លាសក្នុងអាគម គឺនិកាយទាំង ៥ ជាដើម ។

ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺការអត់ធន់ ១ ភាពជាអ្នកប្រដៅងាយ ១ ការឃើញសមណៈ ១ ការសន្ទនាធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនោះជាមង្គល បានចង្អុលបង្ហាញហើយ ក្នុងមង្គលទាំងអស់ហើយនោះឯង ។

**អធិប្បាយថាបទថា ខន្តិ ច ចប់**

## អធិប្បាយបទថា តបោ ច

ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា **តបោ ច** នេះ ។ ឈ្មោះថា **តប**

*ព្រោះដុតនូវបាបធម៌ ។ ការប្រព្រឹត្តដូចព្រហ្ម ឬការប្រព្រឹត្តរបស់ព្រហ្ម ឈ្មោះថា* **ព្រហ្មចរិយ** *លោកអធិប្បាយថា ការប្រព្រឹត្តដ៏ប្រសើរ ការឃើញអរិយសច្ចទាំងឡាយ ឈ្មោះថា* **អរិយសច្ចាន ទស្សនំ** ។ *អាចារ្យពួកខ្លះពោលថា* **អរិយសច្ចានិ ទស្សនំ** *ដូច្នេះក៏មាន ។ ឈ្មោះថា* **និព្វាន** *ព្រោះចេញចាកតណ្ហាជាគ្រឿងជោតក្រង ។ ការធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា* **សច្ឆិកិរិយា** ។ *ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា* **និព្វានសច្ឆិកិរិយា** ។ *ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។ នេះជាពណ៌នាបទ ។*

*ឯពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះថា ឥន្ទ្រិយសំវរៈ ឈ្មោះថា* **តប** *ព្រោះដុតអភិជ្ឈា និងទោមនស្សជាដើម ឬសេចក្តីព្យាយាម ឈ្មោះថា* **តប** *ព្រោះដុតការខ្ជិលច្រអូស បុគ្គលប្រកបដោយតបៈទាំងនោះ លោកហៅថា* **អាតាបី** *តបៈនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុលះអភិជ្ឈាជាដើម និងបានឈានជាដើម ។*

*ឈ្មោះថា* **ព្រហ្មចរិយ** *ជាឈ្មោះនៃមេថុនវិរតិ សមណធម៌ សាសនា និងមគ្គ ។ ពិតហើយ មេថុនវិរតិ លោកហៅថា* **ព្រហ្មចរិយ** *ដូចក្នុងប្រយោគជាដើមថា* **អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ** *លះបង់អព្រហ្មចរិយៈហើយ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ។ សមណធម៌ ហៅថា* **ព្រហ្មចរិយ** *ដូចក្នុងប្រយោគជាដើមថា* **ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ** *ម្នាលអាវុសោ លោកមានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគរបស់យើងដែរឬ ។*

សាសនា ហៅថា **ព្រហ្មចរិយ** ដូចក្នុងប្រយោគយ៉ាងនេះជាដើមថា **ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ** ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា ... ដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។

មគ្គ ហៅថា **ព្រហ្មចរិយ** ដូចក្នុងប្រយោគយ៉ាងនេះជាដើមថា **អយមេវ ខោ ភិក្ខុ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ សេយ្យថីទំ សម្មាទិដ្ឋិ** ម្នាលភិក្ខុ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ហៅថា **ព្រហ្មចរិយ** ។ មគ្គទាំង ៨ តើដូចម្ដេច ។ គឺសម្មាទិដ្ឋិ ១ ... ។ តែក្នុងទីនេះ ព្រហ្មចរិយៈគ្រប់យ៉ាងមិនមានសេសសល់ រមែងគួរ ព្រោះមគ្គ លោកសង្គ្រោះដោយអរិយសច្ចានទស្សនៈខាងមុខហើយ ។ ព្រហ្មចរិយៈនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុជួបនូវផលវិសេសច្រើនប្រការ ខ្ពស់ឡើងៗ ។

ការឃើញមគ្គ ដោយត្រាស់ដឹងអរិយសច្ច ៤ ដែលពោលហើយ ក្នុងកុមារបញ្ហា ឈ្មោះថា **អរិយសច្ចានទស្សន** ។ អរិយសច្ចានទស្សនៈនោះត្រាស់ថា ជាមង្គល ព្រោះជាហេតុកន្លងបង់នូវទុក្ខក្នុងសង្សារវដ្ដ ។

អរហត្តផល លោកបំណងយកថា និព្វានក្នុងទីនេះ ។ ឈ្មោះថា **និព្វានសច្ឆិកិរិយា** គឺធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ពិតហើយ អរហត្តផលនោះ លោកពោលថា និព្វាន ព្រោះចេញចាកតណ្ហា ដែលតែងហៅថា **វាន** ព្រោះ

*ដោតក្រងទុកក្នុងគតិ ៥ ។ ការដល់ ឬការពិចារណានិព្វាននោះ ហៅថា* **សច្ឆិកិរិយា** *តែការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានក្រៅពីនេះ សម្រេចបាន ដោយការឃើញអរិយសច្ច ៤ នោះឯង ដោយហេតុនោះ ការឃើញអរិយ-សច្ចនោះ ទើបលោកមិនបំណងយកក្នុងទីនេះ ។ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនាំមកនូវជាសុខ ក្នុងបច្ចុ-ប្បន្នជាដើម ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺតបៈ ១ ព្រហ្មចរិយៈ ១ អរិយសច្ចានទស្សនៈ ១ និងនិព្វានសច្ឆិកិរិយា ១ ដោយប្រការដូច្នេះ ។ ការដែលមង្គលទាំងនោះ ជាមង្គល បានចង្អុលបង្ហាញ ក្នុងមង្គលទាំងនោះឯង ។*

**អធិប្បាយបទថា តបោ ច ចប់**

# អធិប្បាយបទថា ផុដ្ឋស្ស លោកធម្មេហិ

*ឥឡូវនេះ នឹងពណ៌នាក្នុងគាថាថា* **ផុដ្ឋស្ស លោកធម្មេហិ** *នេះ ។ បទថា* **ផុដ្ឋស្ស** *បានដល់ ពាល់ត្រូវហើយ ប៉ះពាល់ហើយ ប្រសព្វហើយ ។ ធម៌ទាំងឡាយក្នុងលោក ឈ្មោះថា* **លោកធម្មា** *។ លោកអធិប្បាយថា ធម៌ទាំងឡាយនឹងមិនវិលត្រឡប់ដរាបណា លោកធម៌នៅប្រព្រឹត្តទៅដរាបនោះ ។ បទថា* **ចិត្តំ** *បានដល់ មនោ មានសៈ ។ បទថា* **យស្ស** *បានដល់ របស់ភិក្ខុថ្មី ភិក្ខុកណ្តាល ឬភិក្ខុជាថេរៈ ។ បទថា* **ន កម្បតិ** *បានដល់*

មិនញាប់ញ័រ មិនកម្រើក ។ បទថា **អសោកំ** បានដល់ មិនមានសេចក្ដីសោក ដកនូវសេចក្ដីសោកចេញហើយ ។ បទថា **វិរជំ** បានដល់ ប្រាសចាកធូលី គឺកិលេស កម្ចាត់ធូលី គឺកិលេសហើយ ។ បទថា **ខេមំ** បានដល់ មិនមានភ័យ មិនមានឧបទ្រវ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។ នេះជាពណ៌នាបទ ។

ឯពណ៌នាសេចក្ដី គប្បីជ្រាបដូច្នេះថា ចិត្តនៃបុគ្គលណាដែលលោកធម៌ ៨ មានលាភ មិនមានលាភជាដើមពាល់ត្រូវគ្របសង្កត់ហើយ រមែងមិនញាប់ញ័រ មិនកម្រើក មិនរង្គោះ ឈ្មោះថា ចិត្តនៃបុគ្គលណាដែលលោកធម៌ប៉ះខ្ទប់ហើយមិនកម្រើក ចិត្តនោះនៃបុគ្គលនោះ គប្បីជ្រាបថាជាមង្គល ព្រោះនាំមកនូវភាពប្រសើរលើសលោក ដែលធម៌ណាមួយឲ្យកម្រើកមិនបាន ។

សួរថា ចិត្តនៃបុគ្គលណា ត្រូវលោកធម៌ទាំងនោះប៉ះខ្ទប់ហើយមិនកម្រើក ឆ្លើយថា ចិត្តនៃព្រះអរហន្តខីណាស្រព មិនមែនចិត្តរបស់បុគ្គលដទៃ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ដូច្នេះថា

**សេលោ យថា ឯកគ្ឃនោ វាតេន ន សមីរតិ**
**ឯវំ រូបា រសា សទ្ទា គន្ធា ផស្សា ច កេវលា**
**ឥដ្ឋា ធម្មា អនិដ្ឋា ច នប្បវេធេន្តិ តាទិនោ**
**ឋិតំ ចិត្តំ វិប្បមុត្តំ វយញ្ចស្សានុបស្សតិ ។**

ថ្មដែលតាន់ស៊ុប មិនបានរញ្ជួយដោយខ្យល់ យ៉ាងណាមិញ
រូប សំឡេង ក្លិន រស ផស្សៈ និងធម្មារម្មណ៍ទាំងអស់

ដែលជាទីគាប់ចិត្តក្តី មិនជាទីគាប់ចិត្តក្តី ក៏ញុំាងចិត្តរបស់ភិក្ខុជាតាទិបុគ្គលឲ្យញាប់ញ័រមិនបាន យ៉ាងនោះដែរ ចិត្តរបស់ភិក្ខុនោះជាចិត្តឋិតនៅខ្ជាប់ខ្ជួន ជាចិត្តផុតស្រឡះចាកកិលេសហើយ លោកពិចារណានូវសេចក្តីកើត និងសេចក្តីរលត់នៃចិត្តនោះ ។

ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោក** ។ ពិតហើយ ចិត្តនៃព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោក** ព្រោះមិនមានការសោកដែលលោកពោលដោយន័យជាដើមថា សេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោច សេចក្តីសោយសោក សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្ត ។ អាចារ្យពួកខ្លះពោលដល់ព្រះនិព្វាន ពាក្យនោះ ភ្ជាប់សេចក្តីមិនបាន ជាមួយនឹងបទខាងដើម ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះឈ្មោះថា **អសោក** យ៉ាងណា ក៏ឈ្មោះថា **វិរជ ខេម** ដូច្នោះ ។ ពិតហើយ ចិត្តនៃព្រះខីណាស្រពនោះ ឈ្មោះថា **វិរជ** ព្រោះប្រាសចាកធូលី មានរាគៈទោសៈ មោហៈជាដើម និងឈ្មោះថា **ខេម** ព្រោះផុតចាកយោគៈទាំង ៤ ព្រោះថា ចិត្តទាំង ៣ យ៉ាងនោះ លោកកាន់យកហើយក្នុងខណៈចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងនោះ ដោយអាការនោះៗ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវភាពជាបុគ្គលឧត្តុង្គឧត្តមលើសលោក មានភាពជាបុគ្គល ដែលមានខន្ធមិនប្រព្រឹត្តទៅហើយ និងព្រោះនាំមកនូវភាពជាអាហុនេយ្យបុគ្គលជាដើម ។

ព្រះមានព្រះភាគ ត្រាស់មង្គលនៃគាថានេះ ៤ មង្គល គឺចិត្តដែលមិនញាប់ញ័រដោយលោកធម៌ប្រាំបី ១ ចិត្តមិនសោយសោក ១ ចិត្តប្រាសចាកលម្អងធូលី គឺកិលេស ១ ចិត្តក្សេម ១ ដោយប្រការដូច្នេះ ។ ភាពដែលមង្គលទាំងនេះ ជាមង្គល ក៏បានចង្អុលបង្ហាញហើយ ក្នុងមង្គលទាំងអស់នោះឯង ។

**អធិប្បាយបទថា ផុដ្ឋស្ស លោកធម្មេហិ ចប់**

## អធិប្បាយបទថា ឯតាទិសានិ

ព្រះមានព្រះភាគ កាលត្រាស់មហាមង្គល ៣៨ ប្រការ ដោយគាថា ១០ មានពាក្យថា **អសេវនា ច ពាលានំ** ការមិនសេពគប់បុគ្គលពាលជាដើម យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសរសើរមង្គល ដែលទ្រង់ត្រាស់ទាំងនេះហើយ ទើបត្រាស់គាថាចុងក្រោយថា **ឯតាទិសានិ កត្វាន** ជាដើម ។

ពណ៌នាអត្ថនៃគាថាចុងក្រោយនោះ ដូច្នេះថា បទថា **ឯតាទិសានិ** ប្រែថា ដូច្នេះ ឬទាំងនេះ គឺមានការមិនសេពគប់បុគ្គលពាលជាដើម មានប្រការដែលខ្ញុំពោលមកហើយ ។ បទថា **កត្វាន** ប្រែថា ធ្វើ ។ សេចក្តីពិត ពាក្យនេះ មិនក្រៅអត្ថអំពីអត្ថថា **កត្វាន កត្វា ការិត្វា** គឺប្រែថា ធ្វើដូចគ្នា ។ បទថា **សព្វត្ថមបរាជិតា** សេចក្តីថា សត្វទាំងឡាយធ្វើមង្គលទាំងនេះ ដែលជាសត្រូវ ៤ ប្រភេទ គឺខន្ធមារ កិលេសមារ អភិសង្ខារមារ និងទេវ-

*បុត្តមារ សូម្បីតែមួយ ក៏ធ្វើឲ្យចាញ់មិនបាន ក្នុងទីទាំងពួង លោកអធិប្បាយថា ញុំាងមារទាំង ៤ នោះ ឲ្យចាលចាញ់ដោយខ្លួនឯង ។* **ម** *អក្ខរៈ ក្នុងពាក្យថា* **សព្វត្ថមបរាជិតា** *នេះ គប្បីជ្រាបថា ត្រឹមតែធ្វើការតបទ ។*

*បទថា* **សព្វត្ថ សោត្ថឹ គច្ឆន្តិ** *សេចក្តីថា សត្វទាំងឡាយ ធ្វើមង្គលដូចពោលមកនេះ ដែលមារទាំង ៤ ធ្វើឲ្យចាញ់មិនបានហើយ រមែងដល់នូវសួស្តីក្នុងទីទាំងពួង គឺក្នុងលោកនេះ និងលោកខាងមុខ ទោះឈរក្តី ដើរក្តី អាសវៈពួកណា ដែលធ្វើនូវការចង្អៀតចង្អល់ និងក្តៅក្រហាយ គប្បីកើតឡើង ព្រោះការសេពគប់បុគ្គលពាលជាដើម ព្រោះមិនមានអាសវៈ ទាំងនោះ ទើបដល់នូវសួស្តី លោកអធិប្បាយថា ជាបុគ្គលដែលឧបទ្វវមិនរារាំង ដែលឧបសគ្គមិនរារាំង ក្សេមទូលាយ មិនមានភ័យចំពោះមុខ ។ ឯនិគ្គហិតក្នុងពាក្យថា* **សព្វត្ថ សោត្ថឹ គច្ឆន្តិ** *នេះ គប្បីជ្រាបថា ត្រាស់ដើម្បីងាយស្រួលដល់ការចងគាថា ទ្រង់បញ្ចប់ទេសនា ដោយបទនៃគាថាថា* **តំ តេសំ មង្គលមុត្តមំ** *។ ទ្រង់បញ្ចប់ដូចម្តេច ទ្រង់បញ្ចប់ថា ម្នាលទេវបុត្រ ព្រោះហេតុដែលជនធ្វើ មង្គលដូចពោលមកនេះ រមែងដល់នូវសួស្តី ក្នុងទីទាំងពួងយ៉ាងនេះ ដូច្នោះ ទើបលោកកាន់យកថា មង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់បុគ្គលពាលជាដើម ជាមង្គលឧត្តម ប្រសើរបំផុត ល្អបំផុត សម្រាប់ជនទាំងនោះ ដែលធ្វើមង្គលដូចពោលមកនេះ ។*

*ចុងក្រោយ ទេសនាដែលព្រះមានព្រះភាគទ្រង់បញ្ចប់យ៉ាងនេះ ទេវតាសែនកោដិសម្រេចអរហត្ត ទេវតាដែលសម្រេចសោតាបត្តិផល សកទាគា-*

មិផល អនាគាមិផល រាប់ប្រមាណមិនបាន ។ គ្រានោះ ព្រឹកឡើង ព្រះដ៏មានព្រះភាគត្រាស់ហៅព្រះអានន្ទមក ត្រាស់ថា ម្នាលអានន្ទ កាលអំពីយប់មិញនេះ ទេវតាមួយរូប ចូលមកសួរមង្គលបញ្ហា កាលនោះ តថាគតបានពោលមង្គល ៣៨ ប្រការដល់ទេវតារូបនោះ ម្នាលអានន្ទ អ្នកចូររៀនមង្គលបរិយាយនេះ កាលរៀនហើយ ចូរបង្រៀនដល់ភិក្ខុទាំងឡាយ ព្រះថេរៈរៀនហើយ ក៏បង្រៀនដល់ភិក្ខុទាំងឡាយ ។ មង្គលសូត្រនេះ អាចារ្យនាំបន្តៗ គ្នាមក ប្រព្រឹត្តទៅដរាបដល់សព្វថ្ងៃនេះ គប្បីជ្រាបថា សាសនព្រហ្មចរិយៈនេះចម្រើនមាំទាំ ផ្សាយទៅ ជនទាំងឡាយដ៏ច្រើន ចេះដឹង ដរាបណាទេវតា និងមនុស្សប្រកាសល្អហើយ ។

ដើម្បីការឈ្លាសក្នុងការសន្សំការចេះដឹង ក្នុងមង្គលទាំងនេះឯង ឥឡូវនេះ នឹងប្រកបសេចក្តីតាំងអំពីដើម ដូច្នេះ ។

សត្វទាំងឡាយដែលប្រាថ្នាសុខក្នុងលោកនេះ និងលោកខាងមុខ និងលោកុត្តរសុខទាំងនេះ លះនូវការសេពគប់បុគ្គលពាល អាស្រ័យតែបណ្ឌិតបូជាបុគ្គលដែលគួរបូជា នៅក្នុងបដិរូបទេស និងភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុនដាស់តឿន ក្នុងការបំពេញកុសល តាំងខ្លួនប្រពៃ មានអត្តភាពប្រដាប់ដោយពាហុសច្ចៈ សិប្បៈ និងវិន័យ ពោលសុភាសិតដែលសមគួរដល់វិន័យ មិនទាន់លះភេទគ្រហស្ថដរាបណា ក៏ជម្រះនូវមូលបំណុលចាស់ដោយទំនុកបម្រុងមាតាបិតា ប្រកបមូលបំណុលថ្មី ដោយការសង្គ្រោះបុត្រនិងភរិយា ដល់នូវការតាំងមាំដោយទ្រព្យ និងស្រូវ ដោយភាពជាបុគ្គលមាន

ការងារមិនច្របូកច្របល់ ទាញយកនូវសារៈនៃភោគៈ ដោយការឲ្យទាន និង សារៈនៃជីវិត ដោយការប្រព្រឹត្តធម៌ ធ្វើប្រយោជន៍ដល់ជនរបស់ខ្លួន ដោយ ការសង្គ្រោះញាតិ និងប្រយោជន៍ដល់ជនដទៃៗ ដោយការងារដែលមិនមាន ទោស វៀរការប្រទូស្តអ្នកដទៃ ដោយការវៀរចាកបាប វៀរចាកការប្រទូស្ត ខ្លួនឯង ដោយសង្រួមក្នុងការផឹកទឹកស្រវឹង ចម្រើននូវកុសល ដោយសេចក្តី មិនប្រមាទក្នុងធម៌ទាំងឡាយ លះភេទគ្រហស្ថ ដល់ភាពជាបុគ្គលចម្រើននូវ កុសល បើនៅក្នុងភាវៈជាបព្វជិត ក៏ញុំាងវត្តសម្បទាឲ្យសម្រេចដោយសេចក្តី គោរពក្នុងព្រះពុទ្ធ សាវករបស់ព្រះពុទ្ធ និងឧបជ្ឈាយ៍យាចារ្យជាដើម និង ដោយការប្រព្រឹត្តបន្ទាបខ្លួន លះនូវការចង់បាននូវបច្ច័យ ដោយសន្តោស តាំងនៅក្នុងសប្បុរសភូមិ ដោយភាពជាកតញ្ញូ លះនូវភាពជាបុគ្គលមាន ចិត្តរួញរា ដោយការស្តាប់ធម៌ គ្រប់សព្វកាលអន្តរាយគ្រប់យ៉ាង ដោយខន្តី ។ ធ្វើខ្លួនឲ្យមានទីពឹង ដោយភាពជាអ្នកប្រដៅងាយ មើលការប្រកបបដិបទា ដោយការឃើញសមណៈបន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយជាទី តាំងនៃសេចក្តីសង្ស័យ ដោយការសន្ទនាធម៌ ដល់នូវសីលវិសុទ្ធិ ដោយ តបៈ គឺឥន្ទ្រិយសំវរៈ ដល់នូវចិត្តវិសុទ្ធិ ដោយព្រហ្មចរិយៈ គឺសមណធម៌ និងញុំាងវិសុទ្ធិ ៤ ក្រៅអំពីនោះឲ្យដល់ព្រម ដល់នូវញាណទស្សនវិសុទ្ធិ ដែលជាបរិយាយនៃការឃើញអរិយសច្ច ដោយបដិបទានេះ ធ្វើឲ្យជាក់ ច្បាស់នូវព្រះនិព្វាន ដែលរាប់បានថា អរហត្តផល កាលធ្វើឲ្យជាក់ច្បាស់ ហើយ ជាអ្នកមានចិត្តមិនញាប់ញ័រដោយលោកធម៌ ៨ ដូចសិនេរុបព៌ត មិន

*ញាប់ញ័រដោយខ្យល់ និងភ្លៀង រមែងជាអ្នកមិនសោយសោក ប្រាសចាក លម្អងកិលេស មានការក្សេម ទូលាយ រមែងជាបុគ្គលដែលសត្រូវណាម្នាក់ ឲ្យចុះចាញ់មិនបាន ក្នុងទីទាំងពួងផង ដល់នូវសួស្តី ក្នុងទីគ្រប់អន្លើផង ។ ដោយប្រការដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ថា ទេវតា និងមនុស្សទាំង-ឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តី ក្នុងទីទាំងពួង នេះជាមង្គលដ៏ឧត្តម របស់ទេវតា នឹងមនុស្សទាំងឡាយនោះ ។៚*

## អធិប្បាយមង្គលសូត្រ ចប់

# សុត្តន្តបិដក

## ខុទ្ទកបាឋៈ រតនសូត្រ

[ ៧ ] ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឯអាកាសក្តី ដែលមកជួបជុំក្នុងទីនេះ ពួកភូតទាំងអស់នោះ ចូរមានចិត្តល្អមួយទៀត ចូរស្តាប់នូវភាសិតដោយគោរព ព្រោះហេតុនោះ អ្នកទាំងឡាយជាភូតទាំងអស់ ចូរស្តាប់ ( នូវព្រះបរិត្ត ) ចូរធ្វើនូវមេត្តាចិត្តដល់ពពួកសត្វជាមនុស្សជាតិ មនុស្សទាំងឡាយណា តែងនាំមកនូវពលី ក្នុងពេលថ្ងៃ និងពេលយប់ ព្រោះហេតុនោះ សូមអ្នកទាំងឡាយ កុំប្រហែសធ្វេសរក្សានូវមនុស្សទាំងនោះ ។ ទ្រព្យណាមួយក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី រតនវត្ថុដ៏ឧត្តមណា ក្នុងឋានសួគ៌ក្តី ទ្រព្យ និងរតនវត្ថុទាំងនោះឯងស្មើដោយព្រះតថាគតមិនមានឡើយ រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះសក្យមុនី ទ្រង់មានព្រះហឫទ័យតម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ណា ជាទីក្ស័យទៅនៃកិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់ជាធម៌ឧត្តម រតនៈនីមួយស្មើដោយព្រះធម៌នោះមិនមាន រតនៈ គឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះពុទ្ធជាបុគ្គលប្រសើរ ទ្រង់សរសើរនូវសមាធិណា ថាជាធម៌ដ៏ស្អាតបណ្ឌិតទាំងឡាយ ពោលហើយនូវសមាធិណា ថាជាធម៌ឲ្យផលដោយលំដាប់ សមាធិឯទៀតស្មើដោយសមាធិនោះមិនមានឡើយ រតនៈ គឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

បុគ្គលទាំងឡាយណា ៨ ពួក ដែលពួកសប្បុរសសរសើរហើយ រាប់ជាគូមាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវ័ករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយដែលបុគ្គលឲ្យហើយ ចំពោះទក្ខិណេយ្យ-បុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

អរិយបុគ្គលទាំងឡាយណា ក្នុងសាសនានៃព្រះសម្ពុទ្ធព្រះនាមគោតមប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានសេចក្តីប្រាថ្នាឡើយ អរិយ-បុគ្គលទាំងឡាយនោះ ដល់ហើយនូវអរហត្តផល សម្រេចហើយនូវព្រះនិព្វានបាននូវការរលត់កិលេសដោយទទេ ( ឥតមានទិញដូរឡើយ ) ហើយទទួលនូវផល រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះសូមមានសិរីសួស្តី ។

សសរគោល ដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ អ្នកណាពិចារណាឃើញ នូវអរិយសច្ចទាំងឡាយ តថាគតហៅអ្នកនោះ ថាជាសប្បុរស ( មិនញាប់ញ័រដោយលោកធម៌ទាំងឡាយ ) ដូចសសរគោលដូច្នោះឯង រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះសូមមានសិរីសួស្តី ។

អរិយបុគ្គលទាំងឡាយណា ធ្វើឲ្យជាក់ច្បាស់នូវអរិយសច្ចទាំងឡាយដែលព្រះតថាគត ព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅ សម្តែងប្រពៃហើយ

អរិយបុគ្គលទាំងនោះ ទុកជាប្រមាទដ៏លើសលប់ក៏ដោយ អរិយបុគ្គលទាំងនោះ គង់មិនកាន់យកកពជាគម្រប់ ៨ គឺ មិនកើតទៀតហួសពី ៧ ជាតិឡើយ រតនៈ គឺ ព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

( សំយោជនក្កិលេស ៣ យ៉ាង គឺ ) សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាស ណាមួយ ធម៌ទាំងឡាយ ៣ នោះ សោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្បទា គឺសោតាបត្តិមគ្គ មួយទៀត សោតាបន្នបុគ្គល រួចស្រឡះចាកអបាយទាំង ៤ ផង មិនអាចធ្វើនូវអភិដ្ឋាន ទាំងឡាយ ៦ ផង រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសេចក្តីសួស្តី ។ ប្រសិនបើសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មដោយកាយវាចា ឬដោយចិត្តក៏ដោយ ( ព្រោះសេចក្តីភ្លាំងភ្លាត់ ) សោតាបន្នបុគ្គលនោះ មិនដែលបិទបាំងនូវបាបកម្មនោះឡើយ ភាវៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វានឃើញហើយ ជាបុគ្គលមិនដែលបិទបាំងបាបកម្ម ព្រះពុទ្ធទាំងឡាយ បានត្រាស់សម្តែងហើយ រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

គុម្ពឈើក្នុងព្រៃ មានត្រួយលូតលាស់ ក្នុងខាងដើមគិម្ហរដូវ គឺខែក្តៅ យ៉ាងណាមិញ ព្រះពុទ្ធបានត្រាស់សម្តែងហើយ នូវធម៌ដ៏ប្រសើរ ជាធម៌អាចញ៉ាំងសត្វទាំងឡាយ ឲ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ដូចជាគុម្ពឈើមានក្នុងព្រៃដូច្នោះឯង រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម

ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ ព្រះអង្គប្រសើរ ឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្តែងហើយ នូវធម៌ដ៏ប្រសើរ រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

កម្មចាស់ ( របស់អរិយបុគ្គលណា ) អស់ហើយ កម្មថ្មី រមែងមិនកើតប្រាកដ អរិយបុគ្គលទាំងឡាយណា មានចិត្តនឿយណាយហើយក្នុងភពតទៅ អរិយបុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈ គឺសេចក្តីប៉ុនប៉ងក្នុងចិត្ត មិនដុះចម្រើនឡើង ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចប្រទីបដែលរលត់ទៅនេះ រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយសូមនមស្ការ នូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការ នូវព្រះធម៌ដែលមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅឰដ៏អាកាសក្តី

*ដែលមកប្រជុំគ្នាក្នុងទីនេះ យើងទាំងឡាយសូមនមស្ការ នូវព្រះសង្ឃដែលមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមមានសិរីសួស្តី ។*

*រតនសូត្រ ចប់*

# អដ្ឋកថា

# រតនសូត្រ

## ប្រយោជន៍នៃនិក្ខេបបទ

*[ ៧ ] ឥឡូវនេះ ដល់លំដាប់ពណ៌នានៃរតនសូត្រ ដែលលើកឡើងក្នុងលំដាប់បន្ទាប់អំពីមង្គលសូត្រនោះ ដោយន័យជាដើមថា* **យានីធ ភូតានិ** *ខ្ញុំនឹងពោលប្រយោជន៍នៃការតាំងរតនសូត្រនោះ ក្នុងទីនេះ បន្ទាប់អំពីនោះកាលសម្តែងការឈមចុះនូវអត្ថនៃសូត្រនេះ តាមនិទានវចនៈដ៏បរិសុទ្ធិ ដូចការចុះទឹកក្នុងស្ទឹង និងអូរជាដើម តាមកំពង់ទឹកដ៏បរិសុទ្ធិ ប្រកាសន័យនេះថា សូត្រនេះ បុគ្គលណាពោល ពោលក្នុងកាលណា ពោលទីណា ពោលព្រោះហេតុអ្វី ហើយទើបធ្វើនូវកិច្ចពណ៌នាសេចក្តីនៃរតនសូត្រនេះ ។*

*ក្នុង ២ សូត្រនោះ ព្រោះព្រះមានព្រះភាគ ទ្រង់សម្តែងការរក្សាខ្លួនឯង និងការកម្ចាត់អាសវៈទាំងឡាយ ដែលមានការធ្វើមិនល្អ និងការធ្វើមិនល្អជាបច្ច័យដោយមង្គលសូត្រ ចំណែកសូត្រនេះ ឲ្យសម្រេចការរក្សាអ្នកដទៃ*

និងការកម្ចាត់អាសវៈទាំងឡាយ ដែលមានអមនុស្សជាដើមជាបច្ច័យ ដូច្នោះ ទើបសូត្រនេះ ជាការតាំងទុកក្នុងលំដាប់ បន្ទាប់អំពីមង្គលសូត្រនោះឯង ។

ប្រយោជន៍នៃការតាំងរតនសូត្រ ក្នុងទីនេះមានប្រមាណប៉ុណ្ណេះសិន

# រឿងក្រុងវេសាលី

ឥឡូវនេះ ក្នុងពាក្យថា **យេន វុត្តំ យទា យត្ថ យស្មា ចេតំ** នេះ អ្នកចោទសួរពោលថា សូត្រនេះអ្នកណាពោល ពោលកាលណា ពោលទីណា ពោលព្រោះហេតុអ្វី នឹងចង្អុលបង្ហាញ ដូច្នេះថា សេចក្តីពិត សូត្រនេះ ព្រះមានព្រះភាគមួយអង្គត្រាស់ សាវកជាដើមមិនបានពោលឡើយ ។ សួរថា ត្រាស់ក្នុងកាលណា ឆ្លើយថា ត្រាស់កាលក្រុងវេសាលីត្រូវឧបទ្ទវទាំងឡាយ មានទុព្ភិក្ខភ័យជាដើមចូលរាពាំង ព្រះមានព្រះភាគ កាលពួកស្តេចលិច្ឆវីទូលអារាធនា នាំទ្រង់មកអំពីក្រុងរាជគ្រឹះ កាលនោះ រតនសូត្រនោះ ទ្រង់ក៏ត្រាស់ដើម្បីបំបាត់ឧបទ្រពទាំងនោះក្នុងក្រុងវេសាលី ។ ការវិសជ្ជនាបញ្ហាទាំងនោះមានប៉ុណ្ណេះសិន ។ ឯពិស្តារ បុរាណាចារ្យទាំងឡាយ ពណ៌នារាប់តាំងអំពីក្រុងវេសាលីជាដើមទៅ ។

បានឮមកថា អគ្គមហេសីរបស់ស្តេចក្រុងពារាណសីទ្រង់ព្រះគភ៌ ។ ព្រះនាងទ្រង់ជ្រាបហើយ ក៏បានក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាក៏ទ្រង់ព្រះរាជទានគ្រឿងបរិហារព្រះគភ៌ ។ ព្រះនាងបានទទួលបរិហារព្រះគភ៌

យ៉ាងល្អ ក៏យាងចូលកាន់មន្ទីរប្រសូត ក្នុងកាលព្រះគភ៌គ្រប់ខែ ។ ពួកសត្វដែលមានបុណ្យរមែងប្រសូតចាកគភ៌ក្នុងពេលទៀបភ្លឺ ។ ក្នុងបណ្តាអ្នកមានបុណ្យទាំងនោះ អគ្គមហេសីនោះក៏ជាអ្នកមានបុណ្យមួយអង្គ ដោយហេតុនោះក្នុងពេលទៀបភ្លឺ ព្រះនាងក៏ប្រសូតដុំសាច់ដូចផ្កាច្បា ដែលមានត្របកក្រហមដូចល័ក្ត បន្ទាប់អំពីនោះ ទេវីអង្គដទៃ ក៏ប្រសូតព្រះឱរសដូចរូបមាស អគ្គ-មហេសី ទ្រង់ប្រសូតដុំសាច់ ដូច្នោះ ព្រះនាងទ្រង់ព្រះតម្រិះថា សំឡេងតិះដៀលគប្បីកើតដល់អញ ក្នុងទីចំពោះមុខនៃព្រះរាជា ព្រះនាងខ្លាចការតិះដៀលនោះ ទើបបញ្ជាឲ្យដាក់ដុំសាច់នោះក្នុងភាជនៈមួយ យកភាជនៈមួយទៀតគ្រប ប្រថាប់ព្រះរាជត្រា ហើយឲ្យបណ្តែតទៅតាមក្រសែស្ទឹងគង្គាគ្រាន់តែភ្នាក់ងារទាំងឡាយបណ្តែតទៅ ទេវតាទាំងឡាយ ក៏រៀបចំធ្វើនូវការរក្សា យកជ័រមហាហិង្គុចារឹកផែនមាស ចងនៅត្រង់ភាជនៈនោះថា ព្រះរាជ-ឱរសព្រះរាជធីតារបស់អគ្គមហេសីនៃព្រះបាទក្រុងពារាណសី ។ បន្ទាប់អំពីនោះ ភាជនៈនោះមិនត្រូវបានភ័យ គឺរលកបៀតបៀន ក៏អណ្តែតទៅតាមក្រសែស្ទឹងគង្គា ។

សម័យនោះ តាបសមួយរូបអាស្រ័យត្រកូលអ្នកចិញ្ចឹមគោនៅប្រេះច្រាំងស្ទឹងគង្គានោះ ។ ក្នុងពេលព្រឹក តាបសនោះក៏ចុះកាន់ស្ទឹងគង្គា ក្រឡេកឃើញភាជនៈអណ្តែតមក ក៏កាន់យកដោយបង្សុកូលសញ្ញា ដោយយល់ថា ជារបស់ដែលគេចោលហើយ ។ បន្ទាប់មក ក៏ឃើញបន្ទះមាសចារឹកអក្សរ និងត្រាក៏ស្រាយចេញ ឃើញដុំសាច់នោះ លុះឃើញហើយ តាបសរូបនោះក៏គិតថានេះប្រហែលជាសត្វដែលកើតក្នុងគភ៌ ដូច្នោះ ទើបមិនស្អុយរលួយ ក៏នាំដុំសាច់

ទៅកាន់ទីអាស្រ័យ ទុកក្នុងទីស្អាត រំលងទៅកន្លះខែ ដុំសាច់ក៏បែកចេញជា ២ ចម្រៀក តាបសឃើញហើយ ក៏ទុកយ៉ាងល្អ ។ បន្ទាប់អំពីនោះ រំលងទៅកន្លះខែទៀត ដុំសាច់នីមួយៗ ក៏ចេញពក ៥ ជាដៃ ជើង និងក្បាល តាបសក៏ផ្ចិតផ្ចង់យ៉ាងល្អទៀត ។ បន្ទាប់អំពីនោះកន្លះខែទៀត ដុំសាច់ក៏ក្លាយជាទារកដូចរូបមាស មួយដុំទៀត ក៏ជាទារិកា តាបសកើតការស្រឡាញ់ដូចបុត្រក្នុងទារកទាំង ២ នោះ ទឹកដោះក៏កើតអំពីមេដៃរបស់តាបសនោះ ។ តាំងពីនោះមក តាបសបានទឹកដោះ និងអាហារមក ក៏បរិភោគអាហារ បន្តក់ទឹកដោះក្នុងមាត់ទារកទាំង ២ វត្ថុណាមួយចូលទៅក្នុងផ្ទៃរបស់ទារកនោះ វត្ថុទាំងអស់នោះ ក៏ហាក់ដូចជាចូលទៅក្នុងភាជនៈធ្វើដោយកែវមណី ។ ទារកទាំង ២ មិនមានពណ៌សម្បុរយ៉ាងនេះ ។ តែអាចារ្យពួកដទៃៗ ពោលថា ពណ៌សម្បុរទារកទាំង ២ នោះ ជាក់ដល់គ្នានិងគ្នា ដូចត្រូវអំបោះដោត ទើបទារកទាំងនោះប្រាកដឈ្មោះថា លិច្ឆវី ព្រោះមិនមានពណ៌សម្បុរ ឬព្រោះមានស្បែកថ្លា ដោយប្រការដូច្នេះ ។

តាបសចិញ្ចឹមទារក លុះថ្ងៃរះឡើង ក៏ចូលទៅកាន់ស្រុក ហើយស្វែងរកអាហារ ពេលរសៀលក៏ត្រឡប់ ។ អ្នកចិញ្ចឹមគោទាំងឡាយ ដឹងដល់ការខ្វល់ខ្វាយនោះរបស់តាបសនោះ ក៏ពោលថា បពិត្រលោកម្ចាស់ ការចិញ្ចឹមទារក ជាបលិពោធរបស់អ្នកបួសទាំងឡាយ សូមលោកម្ចាស់ឲ្យនូវទារកដល់ពួកខ្ញុំចុះ ពួកខ្ញុំនឹងនាំគ្នាចិញ្ចឹម សូមលោកម្ចាស់ ធ្វើកិច្ចកម្មរបស់លោកម្ចាស់ចុះ ។ តាបសក៏ព្រមទទួល ។ ស្អែកឡើង ពួកអ្នកចិញ្ចឹមគោ ក៏នាំគ្នា

ធ្វើផ្លូវឲ្យរាបស្មើ ហើយពោយខ្សាច់ លើកទង់ មានតន្ត្រីបន្ទឺឡើង នាំគ្នាមក កាន់អាស្រមៗ តាបសពោលថា ទារកទាំង ២ មានបុណ្យច្រើន ពួកអ្នក ចូរនាំគ្នាចិញ្ចឹមឲ្យចម្រើនវ័យ ដោយការមិនប្រមាទ ។ កាលឲ្យចម្រើនវ័យ ហើយ ចូររៀបចំអាវាហ៍វិវាហ៍ដល់គ្នានិងគ្នា ឲ្យព្រះរាជាទ្រង់ត្រេកអរដោយ បញ្ចគោរស ចូរជ្រើសរើសភូមិប្រទេស នាំគ្នាសាងព្រះនគរឡើង ចូរអភិសេក ព្រះកុមារក្នុងទីនោះ ហើយប្រគល់ទារកឲ្យ ។ ពួកអ្នកចិញ្ចឹមគោទទួលពាក្យ ហើយ ក៏នាំទារកទៅចិញ្ចឹម ។

ទារកទាំង ២ ចម្រើនធំធាត់ ក៏លេងនូវការលេង ប្រើដៃខ្លះ ជើងខ្លះ វាយតប់កូនរបស់អ្នកចិញ្ចឹមគោដទៃៗ ក្នុងទីដែលឈ្លោះគ្នា កូនអ្នកចិញ្ចឹមគោ ទាំងនោះក៏ស្រែកយំ ត្រូវមាតាបិតាសួរថា ហេតុអ្វី ទើបយំ ក៏ប្រាប់ថា អា កូនអត់ឪអត់ម៉ែ ដែលតាបសចិញ្ចឹមទាំងនេះវាយខ្ញុំ ។ បន្ទាប់អំពីនោះ មាតា បិតារបស់ក្មេងទាំងនោះក៏ពោលថា ទារកទាំង ២ នេះ ចូលចិត្តគំរាមកំហែង ដល់ក្មេងដទៃៗ ឲ្យក្តៅក្រហាយ ពួកយើងនឹងមិនសង្គ្រោះវា លះបង់វាចោល ។ បានឮថា តាំងអំពីកាលនោះមក ទើបទីនោះ ត្រូវហៅថា វជ្ជី ដែលមានទំហំ ៣០០ យោជន៍ ។ គ្រានោះ ពួកអ្នកចិញ្ចឹមគោធ្វើព្រះរាជាឲ្យត្រេកអរ ហើយ ជ្រើសរើសយកប្រទេសនោះ សាងព្រះនគរក្នុងប្រទេសនោះ ហើយអភិសេក ព្រះរាជកុមារដែលព្រះជន្មបាន ១៦ ឆ្នាំ តែងតាំងជាព្រះរាជា បានធ្វើវិវាហ-មង្គលជាមួយទារិការបស់ព្រះអង្គ បានដាក់កតិកាថា នឹងមិននាំទារិកាមក អំពីខាងក្រៅ នឹងមិនឲ្យទារិកាអំពីទីនេះដល់បុគ្គលណាម្នាក់ឡើយ ។ ដោយ

ការនៅរួមគ្នាគ្រាដំបូងរបស់ព្រះកុមារកុមារីនោះ ក៏កើតទារក ១ គូ ជាធីតាម្នាក់ ឱរសម្នាក់ ដោយអាការយ៉ាងនេះ ក៏កើតជាគូៗ ដល់ទៅ ១៦ ដង ។ តាំងអំពីនោះ ទារកទាំងនោះ ចម្រើនវ័យដោយលំដាប់ ។ នគរនោះក៏មិនគ្រប់គ្រាន់ ដែលអាចធ្វើអារាម ឧទ្យាន លំនៅ បរិវារ និងសម្បត្តិ ទើបព័ទ្ធរបង ៣ ជាន់ ចន្លោះមួយគាវុតមួយៗ ព្រោះនគរនោះ ត្រូវពង្រីកចេញរឿយៗ ទើបកើតឈ្មោះថា វេសាលីនេះឯង ។

**រឿងក្រុងវេសាលី ចប់**

# ការនិមន្តព្រះមានព្រះភាគ

ក្រុងវេសាលីនេះ កាលព្រះមានព្រះភាគ ទ្រង់កើតឡើង ក៏មាំទាំបរិបូណ៌ ព្រោះថា ក្រុងវេសាលីនោះ មានព្រះអង្គម្ចាស់រហូតដល់ ៧៧០៧ អង្គ យុវរាជ សេនាបតី និងកណ្ឌាគារិកក៏ដូចគ្នា ដូចលោកពោលថា

សម័យនោះឯង ក្រុងវេសាលីនោះ ចម្រើនមាំទាំ មានមនុស្សច្រើន មានមនុស្សកកកុញ មានអាហាររកបានងាយ មានប្រាសាទ ៧៧០៧ ខ្នង មានផ្ទះកំពូល ៧៧០៧ ខ្នង មានអារាម ៧៧០៧ អារាម មានស្រះបោក្ខរណី ៧៧០៧ ស្រះ ។

សម័យតមក ក្រុងវេសាលីនោះកើតទុព្ភិក្ខភ័យ ភ្លៀងរាំង ស្រូវសាលីក៏ងាប់អស់ អ្នកកម្សត់ក្រីក្រស្លាប់មុន គេបោលមនុស្សទាំងនោះទៅខាងក្រៅនគរ ។ ពួកអមនុស្សបានក្លិនមនុស្ស ក៏នាំគ្នាចូលកាន់ព្រះនគរ ។ បន្ទាប់

*អំពីនោះ មនុស្សស្លាប់ក៏ច្រើនឡើង ។ ព្រោះភាពបដិកូលនោះ អហិវាត-ករោគក៏កើតដល់សត្វទាំងឡាយ ។ អ្នកក្រុងវេសាលីត្រូវភ័យ ៣ យ៉ាង គឺទុព្ភិក្ខភ័យ អមនុស្សភ័យ និងរោគភ័យបៀតបៀន ក៏ចូលទៅគាល់ព្រះរាជាក្រាបទូលថា បពិត្រតេជះ ភ័យ ៣ យ៉ាងកើតក្នុងនគរនេះហើយ តាំងអំពីមុននេះ ៧ ជួររាជត្រកូល មិនធ្លាប់កើតភ័យបែបនេះឡើយ ប្រហែលជាទ្រង់មិនតាំងនៅក្នុងធម៌ ទើបឥឡូវនេះ ភ័យកើតឡើង ។ ព្រះរាជាទ្រង់ប្រជុំស្តេចលិច្ឆវីគ្រប់អង្គ ក្នុងទីរាជការ ត្រាស់ថា សូមពិចារណាថយក្រោយ ក្នុងប្រការដែលពួកយើងមិនតាំងនៅក្នុងធម៌ចុះ ។ ស្តេចលិច្ឆវីទាំងនោះពិចារណាថយក្រោយដល់បវេណីគ្រប់យ៉ាង ក៏ទ្រង់មិនឃើញមានកំហុសធ្ងន់ណាមួយក៏មិនឃើញទោសរបស់ព្រះរាជា ទើបនាំគ្នាគិតថា ភ័យរបស់យើងនេះ រម្ងាប់បានដូចម្តេច ។ ក្នុងទីប្រជុំនោះ ស្តេចលិច្ឆវីពួកខ្លះអាងដល់សាស្តាទាំង ៦ ថា ទាល់តែសាស្តាទាំងនេះឈានជើងចុះប៉ុណ្ណោះ ភ័យក៏នឹងរម្ងាប់ទៅ ។ ពួកខ្លះត្រាស់ថា បានឮថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងធម៌ ដើម្បីជាប្រយោជន៍ដល់សត្វទាំងពួង ទ្រង់មានឫទ្ធិច្រើន មានអានុភាពច្រើន ទាល់តែទ្រង់យាងព្រះបាទចុះប៉ុណ្ណោះ ភ័យគ្រប់យ៉ាងក៏រម្ងាប់ទៅ ដោយហេតុនោះ ស្តេចលិច្ឆវីទាំងនោះ ទើបសប្បាយក្នុងព្រះហឫទ័យ ត្រាស់ថា ព្រះមានព្រះភាគអង្គនេះ ឥឡូវនេះ ទ្រង់ប្រថាប់នៅទីណាហ្ន៎ ពួកយើងបញ្ជូនមនុស្សទៅយាង ទ្រង់នឹងមិនយាងមក ។ ស្តេចលិច្ឆវីពួកខ្លះត្រាស់ថា ធម្មតាព្រះពុទ្ធ ទ្រង់ករុណាសត្វ ហេតុអ្វី ថាមិនយាង*

មក ។ ព្រះមានព្រះភាគអង្គនោះ ឥឡូវនេះ ប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ព្រះបាទពិម្ពិសារទ្រង់ឧបដ្ឋាក ក្រែងតែទ្រង់មិនឲ្យយាងមក ។ ពួកខ្លះត្រាស់ថា បើដូច្នោះ យើងទូលព្រះបាទពិម្ពិសារឲ្យទ្រង់ជ្រាប ហើយយាងព្រះមានព្រះភាគមក ហើយទ្រង់ប្រគល់គ្រឿងបណ្ណាការជាច្រើន បញ្ជូនស្តេចលិច្ឆវី ២ អង្គ មួយអន្លើដោយពលសេនាច្រើន ទៅកាន់រាជសម្នាក់នៃព្រះបាទពិម្ពិសារ ដោយត្រាស់ថា សូមអ្នកទូលព្រះបាទពិម្ពិសារឲ្យទ្រង់យល់ ហើយយាងព្រះមានព្រះភាគមក ។ ស្តេចលិច្ឆវីទាំង ២ អង្គយាងទៅថ្វាយគ្រឿងបណ្ណាការដល់ព្រះបាទពិម្ពិសារ ហើយទូលឲ្យទ្រង់ជ្រាប រួចត្រាស់ថា បពិត្រមហារាជ សូមទ្រង់មេត្តាបញ្ជូនព្រះមានព្រះភាគមកកាន់នគររបស់ទូលបង្គំផងចុះ ។ ព្រះរាជាទ្រង់មិនទទួល ដោយត្រាស់ថា ពួកអ្នកចូរដឹងខ្លួនឯង ។ ស្តេចលិច្ឆវីក៏ទូលថា សាធុ ហើយចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភ័យ ៣ យ៉ាង កើតឡើងក្នុងនគររបស់ខ្ញុំព្រះអង្គ បើទ្រង់គប្បីយាងទៅសោត សួស្តីគប្បីមានដល់ពួកខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ពិចារណាថា កាលត្រាស់រតនសូត្រក្នុងក្រុងវេសាលី ការរក្សានឹងផ្សាយទៅសែនកោដិចក្រវាល កាលសូត្រនេះចប់ សត្វ ៨៤០០០ នឹងត្រាស់ដឹងធម៌ ហើយទើបទ្រង់ទទួលនិមន្ត គ្រានោះ ព្រះបាទពិម្ពិសារទ្រង់បានដំណឹងថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្ត ហើយទ្រង់ឲ្យឃោសនាទៅក្នុងព្រះនគរថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្ត យាងទៅក្រុងវេសាលីហើយ ទ្រង់ចូលគាល់ព្រះមានព្រះភាគទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់

ទទួលនិមន្តយាងទៅក្រុងវេសាលីឬ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ។ ព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមទ្រង់បង្អង់ ទម្រាំចាត់ចែងផ្លូវថ្វាយស្រេច ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ធ្វើផ្ទៃដី ៥ យោជន៍ ចន្លោះក្រុងរាជគ្រឹះ និងស្ទឹងគង្គាឲ្យរាបស្មើហើយ បានក្រាបទូលព្រះមានព្រះភាគដល់កាល ។ ព្រះមានព្រះភាគ មានភិក្ខុ ៥០០ រូបចោមរោម ហើយទ្រង់យាងទៅ ព្រះរាជាទ្រង់យកផ្កាដែលមាន ៥ ពណ៌ រោយត្រង់ផ្លូវ ៥ យោជន៍ត្រឹមក្បាលជង្គង់ ឲ្យលើកទង់ជ្វាលា ក្អមទឹក និងដើមចេកជាដើម ឲ្យបាំងស្វេតច្ឆត្រ ២ ជាន់ សម្រាប់ព្រះមានព្រះភាគ ឆត្រមួយជាន់សម្រាប់ភិក្ខុមួយរូបៗ ទ្រង់ធ្វើការបូជាដោយផ្កា និងគ្រឿងប្រអប់ជាដើម ព្រមដោយរាជបរិវាររបស់ព្រះអង្គ ឲ្យព្រះមានព្រះភាគប្រថាប់នៅក្នុងវិហារមួយខ្នងៗ ថ្វាយមហាទាន ទ្រង់នាំព្រះមានព្រះភាគឡើងកាន់ឆ្នេរស្ទឹងគង្គាអស់កាល ៥ ថ្ងៃ ក្នុងទីនោះ ទ្រង់តាក់តែងទូកដោយគ្រឿងប្រដាប់គ្រប់យ៉ាង ហើយទ្រង់បញ្ជូនដំណឹងទៅ ថ្វាយស្តេចលិច្ឆវីក្រុងវេសាលីថា ព្រះមានព្រះភាគទ្រង់យាងមកហើយ សូមស្តេចលិច្ឆវីគ្រប់អង្គតាក់តែងផ្លូវ ទទួលព្រះមានព្រះភាគចុះ ។ ស្តេចលិច្ឆវីទាំងនោះស្រុះស្រួលគ្នាថា នឹងធ្វើការបូជាទ្វេគុណ ធ្វើផ្ទៃដី ៣ យោជន៍ ចន្លោះក្រុងវេសាលី និងស្ទឹងគង្គាឲ្យរាបស្មើ រៀបចំស្វេតច្ឆត្រ ៤ ជាន់ សម្រាប់ព្រះមានព្រះភាគ ២ ជាន់ សម្រាប់ភិក្ខុមួយរូបៗ ធ្វើការបូជា ទ្រង់យាងមករង់ចាំ ។

គ្រានោះ ព្រះបាទពិម្ពិសារទ្រង់ធ្វើទូក ២ គ្រឿង ហើយសាងមណ្ឌប

ប្រក់ដោយផ្កា ក្រាលពុទ្ធាសនៈ ធ្វើដោយរតនៈសុទ្ធក្នុងមណ្ឌបនោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ប្រថាប់លើពុទ្ធាសនៈនោះ ។ សូម្បីភិក្ខុ ៥០០ រូប ក៏ឡើងទូកអង្គុយតាមសមគួរ ព្រះរាជា ទ្រង់ជូនដំណើរព្រះមានព្រះភាគ ចុះទឹកប្រមាណត្រឹមព្រះសូរង ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅរង់ចាំត្រង់ប្រាំងគង្គានេះឯង ទម្រាំទ្រង់យាងត្រឡប់មក ហើយទ្រង់ក៏យាងត្រឡប់ ។ ទេវតាខាងលើ រហូតដល់អកនិដ្ឋភព បាននាំគ្នាធ្វើការបូជា ។ នាគរាជទាំងឡាយ មានកម្ពលនាគ និងអស្សតរនាគជាដើម អាស្រ័យនៅបាតស្ទឹងគង្គា ក៏នាំគ្នាធ្វើការបូជា ដោយការបូជាធំយ៉ាងនេះ ព្រះមានព្រះភាគយាងទៅតាមស្ទឹងគង្គា អស់ចម្ងាយផ្លូវប្រមាណមួយយោជន៍ ក៏ចូលដល់ព្រំដែនរបស់ស្ដេចលិច្ឆវី ក្រុងវេសាលី ។

បន្ទាប់អំពីនោះ ពួកស្ដេចលិច្ឆវីក៏ធ្វើការបូជា ២ ដង លើសព្រះបាទពិម្ពិសារទ្រង់ធ្វើ ចេញទៅទទួលព្រះមានព្រះភាគដល់ក្នុងទឹក ប្រមាណត្រឹមព្រះសូរង ។ ខណៈនោះឯង មហាមេឃគ្របដណ្ដប់ដោយភាពងងឹត ផ្ទេកបន្ទោរបង្ហាញខ្លួន ផ្គរលាន់គ្រហឹមក្នុងទិសទាំង ៤ ។ សម័យនោះ ព្រះសម្ពុទ្ធទ្រង់លើកព្រះបាទដំបូង ជាន់ត្រង់ឆ្នេរស្ទឹងគង្គា ភ្លៀងបោក្ខរព័ស្សក៏បាចសាចចុះមក ជនពួកណាត្រូវការសើម ជនទាំងនោះរមែងសើម ជនពួកណាមិនត្រូវការ ក៏មិនសើម ក្នុងទីគ្រប់កន្លែង មានទឹកហូរទៅត្រឹមក្បាលជង្គង់ ត្រឹមភ្លៅ ត្រឹមចង្កេះ ត្រឹម-ក សាកសពទាំងពួង ត្រូវទឹកបន្សាត់ទម្លាក់ចុះកាន់ស្ទឹងគង្គា ផ្ទៃដីក៏ស្អាតបរិសុទ្ធ ។

ពួកស្តេចលិច្ឆវីឲ្យព្រះមានព្រះភាគគង់ប្រថាប់ គ្រប់មួយយោជន៍ក្នុងផ្លូវ ថ្វាយមហាទាន ទ្រង់ធ្វើការបូជាទ្វេគុណ អស់កាល ៣ ថ្ងៃ ទើបនាំព្រះមានព្រះភាគចូលកាន់ក្រុងវេសាលី ។ កាលព្រះមានព្រះភាគ យាងដល់ក្រុងវេសាលី សក្កទេវរាជដែលមានពួកទេវតាចោមរោមយាងមកដល់ ។ ព្រះមានព្រះភាគប្រថាប់ឈរក្បែរទ្វារព្រះនគរ ទ្រង់ហៅព្រះអានន្ទមកត្រាស់ថា ម្នាលអានន្ទ អ្នកចូររៀនរតនសូត្រនេះ កាន់គ្រឿងប្រកបពលិកម្ម ដើរទៅក្នុងចន្លោះកំពែង ៣ ជាន់នៃក្រុងវេសាលី ជាមួយពួកស្តេចលិច្ឆវីរាជកុមារ ធ្វើព្រះបរិត្តហើយបានត្រាស់រតនសូត្រ ។

ការវិសជ្ជនាបញ្ហាទាំងនេះថា ព្រះសូត្រនេះអ្នកណាពោល ពោលក្នុងកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី បុរាណាចារ្យទាំងឡាយបានពណ៌នាពិស្តារ តាំងអំពីរឿងក្រុងវេសាលីជាដើម ដោយប្រការដូច្នេះ ។

ដូច្នោះ ក្នុងថ្ងៃដែលព្រះមានព្រះភាគ យាងដល់ក្រុងវេសាលីនោះឯង រតនសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ក្បែរទ្វារក្រុងវេសាលី ដើម្បីកម្ចាត់ឧបទ្រពទាំងនោះ ព្រះអានន្ទក៏រៀនយក កាលពោលដើម្បីជាបរិត្ត ទើបយកបាត្ររបស់ព្រះមានព្រះភាគមកដាក់ទឹក ដើរប្រស់ព្រំពេញព្រះនគរ គ្រាន់តែព្រះថេរៈពោលថា **យង្កិញ្ចិ** ពួកអមនុស្សដែលអាស្រ័យគំនរសំរាម និងជញ្ជាំងផ្ទះជាដើម ដែលមិនទាន់គេចទៅក្នុងគ្រាដំបូង ក៏នាំគ្នាគេចទៅតាមទ្វារធំទាំង ៤ ទ្វារទាំងឡាយក៏មិនមានចន្លោះ អមនុស្សពួកខ្លះ កាលមិនមានទីទំនេរក្នុងទ្វារទាំងឡាយ ក៏ផ្លោះកំពែងគេចទៅ ។ ពួកអមនុស្សនាំគ្នាទៅហើយ រោគនៃ

ពួកមនុស្សទាំងឡាយក៏ស្ងប់ទៅ ពួកមនុស្សទាំងឡាយ ក៏នាំគ្នាមកបូជាព្រះ-ថេរៈដោយផ្កា និងគ្រឿងក្រអូបគ្រប់យ៉ាងជាដើម មហាជនយកគ្រឿងក្រអូបគ្រប់យ៉ាងលាបសណ្ឋាគារ គឺទីប្រជុំ កណ្ដាលព្រះនគរ ធ្វើពិតានវិចិត្រដោយរតនៈ ប្រដាប់ដោយគ្រឿងអាភរណៈទាំងពួងបូជាពុទ្ធាសនៈ ក្នុងទីនោះហើយនាំព្រះមានព្រះភាគយាងមក ។

ព្រះមានព្រះភាគ យាងចូលកាន់សណ្ឋាគារ គង់ប្រថាប់លើអាសនៈដែលគេបូជា ។ ភិក្ខុសង្ឃក្ដី គណៈក្ដី មនុស្សទាំងឡាយក្ដី ក៏អង្គុយក្នុងអាសនៈដែលសមគួរ ។ សូម្បីសក្កទេវរាជស្ដេចទេវតា ក៏ប្រថាប់គង់ក្បែរទេវបរិស័ទក្នុងទេវលោកទាំង ២ មួយអន្លើដោយទេវលោកដទៃៗ ផងដែរ សូម្បីព្រះអានន្ទត្ថេរ ក៏ត្រាច់ទៅពេញក្រុងវេសាលី ធ្វើការរក្សាហើយ ក៏មកជាមួយអ្នកក្រុងវេសាលី អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ក្នុងទីនោះ ព្រះមានព្រះភាគ ក៏បានត្រាស់រតនសូត្រនោះឯង ដល់មនុស្សទាំងអស់ ។

មាតិកាណា ខ្ញុំតាំងទុកថា ខ្ញុំនឹងប្រកាសន័យនេះថា រតនសូត្រនេះ បុគ្គលណាពោល ពោលកាលណា ពោលទីណា ពោលព្រោះហេតុអ្វី មាតិកានោះខ្ញុំពោលពិស្ដារហើយ ដោយប្រការទាំងពួង ដោយពាក្យប្រមាណប៉ុណ្ណេះ ។

## អធិប្បាយបទថា យានីធ

ឥឡូវនេះ នឹងផ្ដើមពណ៌នាសេចក្ដី ព្រោះខ្ញុំបានពោលថា នឹងពណ៌នាអត្ថនៃរតនសូត្រនោះ តែអាចារ្យមួយពួកទៀតពោលថា ព្រះមានព្រះភាគត្រាស់ ៥ គាថាខាងដើម ដែលសល់អំពីព្រះអានន្ទត្ថេរពោល តែទោះជាយ៉ាង

*ណាក៏ដោយ ប្រយោជន៍អ្វីរបស់យើង ដោយគាថាតិចតួច ដែលមិនទាន់បានពិនិត្យពិច័យនេះ ខ្ញុំនឹងពណ៌នាអត្ថនៃរតនសូត្រនេះ ដោយប្រការទាំងពួង ។*

*នឹងពណ៌នាគាថាដំបូង គឺ* **យានីធ ភូតានិ** *ជាដើម ។ ក្នុងគាថាដំបូងនោះ បទថា* **យានិ** *បានដល់ បែបណា ទោះសក្តិតូច ឬសក្តិធំ ។ បទថា* **ឥធ** *ប្រែថា ក្នុងប្រទេសនេះ ព្រះមានព្រះភាគត្រាស់ដល់ទីដែលប្រជុំក្នុងខណៈនោះ ។*

*ក្នុងបទថា* **ភូតានិ ភូត** *សព្វ សំដៅដល់ មានពិត ដូចក្នុងប្រយោគជាដើមថា* **ភូតស្មឹ ចាចិត្តិយំ** *ភិក្ខុណាមួយ ប្រាប់ឧត្តរិមនុស្សធម្មដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឧត្តរិមនុស្សធម្មនោះ ភិក្ខុមានពិតមែន ។*

*ប្រើក្នុងអត្ថថា* **ខន្ធបញ្ចកៈ** *ដូចក្នុងប្រយោគជាដើមថា* **ភូតមិទន្តិ ភិក្ខវេ សមនុបស្សថ** *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញនូវខន្ធបញ្ចកៈនេះ ដែលកើតឡើងហើយឬទេ ។*

*ប្រើក្នុងអត្ថថា រូប ៤ យ៉ាង មានបឋវីធាតុជាដើម ដូចក្នុងប្រយោគជាដើមថា* **ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ** *ម្នាលភិក្ខុ មហាភូតទាំង ៤ ជាហេតុ មហាភូតទាំង ៤ ជាបច្ច័យ ដូច្នេះជាដើម ។*

*ប្រើក្នុងអត្ថថា ព្រះខីណាស្រព ដូចក្នុងប្រយោគជាដើមថា* **យោ ច កាលឃសោ ភូតោ** *បុគ្គលណា ជាអ្នកទំពាស៊ីនូវពេលវេលា ដូច្នេះ ។*

*ប្រើក្នុងអត្ថថា សត្វទាំងឡាយ ដូចក្នុងប្រយោគជាដើមថា* **សព្វេវ**

**ឆិគ្គិបិស្សន្តិ ភូតា លោកេ សមនុស្សយំ** សត្វទាំងឡាយនេះឯង តែង លះបង់រាងកាយក្នុងលោក ដូច្នេះ ។

ប្រើក្នុងអត្ថថា ដើមឈើ ដូចក្នុងប្រយោគជាដើមថា **ភូតគាមបាតព្យតាយ** ភិក្ខុធ្វើភូតគាម មានឈើ និងស្មៅជាដើមឲ្យវិនាស ត្រូវអាបត្តិ បាចិត្តិយៈ ដូច្នេះ ។

ប្រើក្នុងអត្ថថា ពួកសត្វខាងក្រោម ទេវតាជាន់ចាតុម្មហារាជ ដូចក្នុង ប្រយោគជាដើមថា **សព្វេវ ឆិគ្គិបិស្សន្តិ ភូតា លោកេ សមនុស្សយំ** សត្វ ទាំងឡាយនេះឯង តែងលះបង់រាងកាយក្នុងលោក ដូច្នេះ ។ តែ **ភូត** សព្ទ ក្នុងទីនេះ គប្បីជ្រាបថា ប្រើក្នុងអត្ថថា អមនុស្សដោយមិនផ្សេងគ្នា ។

បទថា **សមាគតានិ** ប្រែថា ប្រជុំហើយ ។ បទថា **ភុម្មានិ** បានដល់ កើតឡើងត្រង់ដែនដី ។ សព្ទថា **វា** ប្រើក្នុងអត្ថថា មិនពិតប្រាកដ ។ ដ្បិត ថា **វា** សព្ទនោះ ព្រះមានព្រះភាគទ្រង់ធ្វើវិកប្បថា **យានីធ ភុម្មានិ វា ភូតានិ សមាគតានិ** ហើយត្រាស់ថា **យានិ វ អន្តលិក្ខេ** ដើម្បីទ្រង់ធ្វើវិកប្បទី ២ ទៀត សេចក្តីថា សត្វទាំងឡាយណាដែលកើតហើយក្នុងអាកាស សត្វទាំង នោះមកប្រជុំគ្នាហើយក្នុងទីនេះ ។ ក្នុងសេចក្តីនេះ សត្វទាំងឡាយដែលកើត ហើយ ឧប្បត្តិកហើយ តាំងអំពីទេវតាជាន់យាមា រហូតដល់អកនិដ្ឋ គប្បី ជ្រាបថា កើតហើយក្នុងអាកាស ព្រោះជាសត្វកើតក្នុងវិមានដែលប្រាកដក្នុង អាកាស ។ សត្វទាំងឡាយខាងក្រោមអំពីនោះ រាប់តាំងអំពីស្តេចភ្នំសិនេរុ រហូតដល់ទេវតាដែលអាស្រ័យនៅក្នុងដើមឈើ និងវល្លិជាដើម និងពួក

ដែលកើតហើយត្រង់ផែនដី សត្វទាំងនោះ គប្បីជ្រាបថា ជាសត្វដែលកើតត្រង់ផែនដី ព្រោះជាសត្វដែលកើតត្រង់ផែនដី និងត្រង់ដើមឈើ វល្លិភ្នំជាដើម ដែលទាក់ទងដោយផែនដី ។

ព្រះមានព្រះភាគ កាលទ្រង់កំណត់ពួកសត្វ មនុស្ស គ្រប់ពួក ដោយបទថា **ភុម្មានិ វា យានិ វ អន្តលិក្ខេ** ទ្រង់សរុបមួយបទទៀត ទើបត្រាស់ថា **សព្វេវ ភូតា សុមនា ភវន្តុ** ។ បទថា **សព្វេ** បានដល់ មិនមានសេសសល់ ។ សព្ទថា **ឯវ** ចុះក្នុងអត្ថថា អវធារណៈ គឺហាមអត្ថដទៃ អធិប្បាយថា មិនវៀរសូម្បីតែមួយ ។ បទថា **ភូតា** បានដល់ ពួកអមនុស្ស បទថា **សុមនា ភវន្តុ** បានដល់ ចូរជាអ្នកកើតនូវបីតិសោមនស្ស ។ បទថា **អថោបិ** ជានិបាត ទាំង ២ ពាក្យ ចុះក្នុងអត្ថ គឺការកាន់យកនូវពាក្យដើម្បីប្រកបក្នុងកិច្ចដទៃ ។ បទថា **សក្កច្ច សុណន្តុ ភាសិតំ** បានដល់ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត រួបរួមដោយចិត្តទាំងអស់ហើយ ចូរស្តាប់ទេសនារបស់តថាគត ដែលនាំមកនូវទិព្វសម្បត្តិ និងលោកុត្តរសុខ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ប្រារព្ធពួកភូតដោយព្រះតម្រាស់ដែលមិនពិតប្រាកដថា **យានីធ ភូតានិ សមាគតានិ** ហើយទើបកំណត់ជា ២ ចំណែកទៀតថា **ភុម្មានិ វាយានិ វ អន្តលិក្ខេ** បន្ទាប់អំពីនោះ ក៏ត្រាស់សរុបទៀតថា **សព្វេវ ភូតា** ទ្រង់ប្រកបសត្វក្នុងអាសយសម្បត្តិ ដោយព្រះតម្រាស់ថា **សុមនា ភវន្តុ** ទ្រង់ប្រកបសត្វក្នុងប្រយោគសម្បត្តិ ដោយព្រះតម្រាស់ថា **សក្កច្ច សុណន្តុ ភាសិតំ** ទ្រង់ប្រកបសត្វក្នុងសម្បត្តិ គឺ

យោនិសោមនសិការ និងក្នុងសម្បត្តិ គឺការឃោសនាអំពីអ្នកដទៃ ក៏ដូចគ្នា ទ្រង់ប្រកបសត្វក្នុងសម្បត្តិ គឺការតាំងខ្លួនប្រពៃ និងការចូលរកសប្បុរស និងក្នុងសម្បត្តិ គឺហេតុនៃសមាធិ និងបញ្ញា ក៏ដូចគ្នា ទើបទ្រង់បញ្ចប់ព្រះគាថា ។

## អធិប្បាយបទថា តស្មា ហិ

នឹងពោលគាថាទី ២ ថា **តស្មា ហិ** ជាដើម ។ ក្នុងគាថានោះ បទថា **តស្មា** ជាពាក្យពោលហេតុ ។ បទថា **ភូតា** ជាពាក្យអញ្ជើញ ។ បទថា **និសាមេថ** បានដល់ ចូរស្តាប់ ។ បទថា **សព្វេ** បានដល់ មិនមានសេសសល់ សេចក្តីនេះ លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា ព្រោះហេតុអ្នកទាំងឡាយលះទិព្វស្ថាន និងការដល់ព្រមនៃគ្រឿងឧបភោគបរិភោគ ក្នុងទិព្វ-ស្ថាននោះ មកប្រជុំក្នុងទីនេះ ដើម្បីស្តាប់ធម៌ មិនមែនដើម្បីមើលការរាំច្រៀងជាដើមឡើយ ដូច្នេះឯង ចូរអ្នកទាំងឡាយដែលជាភូត តាំងចិត្តស្តាប់ ។

ម្យ៉ាងទៀត ដោយព្រះតម្រាស់ថា **សុមនា ភវន្តុ សក្កច្ច សុណន្តុ** ព្រះមានព្រះភាគទ្រង់ឃើញថា ភូតទាំងនោះ មានចិត្តល្អ ចង់ស្តាប់ដោយគោរព ទើបត្រាស់ថា ព្រោះអ្នកទាំងឡាយប្រកបដោយភាពជាអ្នកមានចិត្តល្អ ដោយអត្តសម្មាបណិធិ យោនិសោមនសិការ និងអាសយសុទ្ធិ ដោយភាពជាអ្នកប្រាថ្នានឹងស្តាប់ដោយគោរព និងដោយបយោគសុទ្ធិ ព្រោះជាបទដ្ឋាននៃការចូលរកសប្បុរស និងការឃោសនាអំពីអ្នកដទៃ ដូច្នេះឯង ចូរភូតទាំងឡាយតាំងចិត្តស្តាប់ចុះ ។

ម្យ៉ាងទៀត ពាក្យណា ត្រាស់ថា **ភាសិតំ** ខាងចុងគាថាទី ១ ទ្រង់អាង ពាក្យនោះជាតួហេតុ ទើបត្រាស់ថា ព្រោះធម្មតាភាសិតរបស់តថាគត មាន ដោយកម្រក្រៃពេក ព្រោះខណៈដែលវៀរចាកអខណៈទាំងពួង ជាការក្រ និងមានអានិសង្សច្រើន ព្រោះបដិបត្តិដោយព្រះគុណ មានបញ្ញាគុណ និង ករុណាគុណជាដើម ខ្ញុំក៏បំណាងនឹងពោលភាសិតនោះ ទើបពោលថា **សុណាថ ភាសិតំ** ដូច្នោះឯង ចូរកូតទាំងឡាយតាំងចិត្តស្តាប់ចុះ ។ ព្រះតម្រាស់នេះ ទ្រង់អធិប្បាយដោយបទនៃគាថានេះ ។

ព្រះមានព្រះភាគ កាលទ្រង់លើកហេតុយ៉ាងនេះ ទ្រង់ប្រកបកូតទាំង-ឡាយទុកក្នុងការតាំងចិត្ត ស្តាប់ភាសិតរបស់ព្រះអង្គ ទើបទ្រង់ផ្តើមត្រាស់ ភាសិតដែលគប្បីតាំងចិត្តស្តាប់ថា **មេត្តំ ករោថ មានុសិយា បជាយ ។** ភាសិតនោះ មានអត្ថថា មហាជនដែលជាមនុស្សណា ត្រូវឧបទ្រវទាំង ៣ រាក់រងហើយ ចូរអ្នកទាំងឡាយ ចូលទៅតាំងមេត្តាភាពជាមិត្រ ការមាន អធ្យាស្រ័យ ឲ្យនូវប្រយោជន៍ដល់មហាជនមនុស្សនោះចុះ ។ តែអាចារ្យពួក ខ្លះពោលថា **មានុសិកំ** ពាក្យនោះ មិនត្រឹមត្រូវ ព្រោះកូតដែលនៅត្រង់ផែន ដីមិនកើត ។ អាចារ្យពួកដទៃពណ៌នាអត្ថណា សូម្បីពណ៌នានោះ ក៏មិនត្រឹម ត្រូវ ។ ឯក្នុងទីនេះ មានអធិប្បាយថា ខ្ញុំមិនពោលដោយកម្លាំងនៃភាពជាធំ ថាជាពុទ្ធៈ ។ តែវត្ថុណាជាប្រយោជន៍ដល់ពួកអ្នក និងដល់មហាជនមនុស្ស នេះ ខ្ញុំនឹងពោលវត្ថុនោះថា **មេត្តំ ករោថ មានុសិយា បជាយ** ចូរពួកអ្នក ធ្វើមេត្តាដល់មហាជនដែលជាមនុស្សចុះ ។

ម្យ៉ាងទៀត ក្នុងសេចក្តីនេះ មេត្តា គប្បីជ្រាបថា ជាប្រយោជន៍ដល់អ្នកធ្វើមេត្តាដោយព្រះសូត្រទាំងឡាយយ៉ាងនេះថា

បើបុគ្គលមានចិត្តមិនប្រទូស្តសត្វ សូម្បីតែសត្វមួយ ចម្រើនមេត្តា ជាបុគ្គលឈ្លាសវៃ ដោយមេត្តានោះ មួយទៀត ព្រះអរិយៈ កាលអនុគ្រោះសត្វទាំងអស់ដោយចិត្តហើយ ឈ្មោះថា ធ្វើបុណ្យច្រើន ជនទាំង-ឡាយណា ឈ្នះផែនដីដ៏ដេរដាសទៅដោយសត្វ ជនទាំងឡាយនោះ ជាធម្មិករាជ ប្រហែលដោយឥសីហើយញ៉ាំងការបូជា ឲ្យប្រព្រឹត្តទៅ ( គឺទ្រង់ឈ្លាសវៃក្នុងការទំនុកបម្រុងធញ្ញាហារ គឺស្រែស្រូវ ឲ្យសម្បូណ៌ក្នុងព្រះរាជអាណាចក្រ ១ ទ្រង់ឈ្លាសវៃ ក្នុងការសង្គ្រោះរាជបុរស ១ ទ្រង់ប្រកបឧបាយ ចងចិត្តមនុស្សឲ្យបូលចិត្ត ១ ទ្រង់មានព្រះបន្ទូល ផ្អែមល្ហែម ១ ជាហេតុឲ្យស្រុកទេសរាបទាប សាន្តត្រាណ គ្មានចោរទាល់តែមិនបាច់ដាក់គន្លឹះ ចាក់សោទ្វារផ្ទះ ១ ) ការបូជាទាំងឡាយនោះ មិនដល់មួយចំណិតនៃបុគ្គលអ្នកចម្រើនមេត្តាចិត្ត ដែលចែកឲ្យជាចំណែក ១៦ៗ ជងឡើយ ដូច្នេះ ។ និងដោយអានិសង្ស ១១ ប្រការ ។

មេត្តា គប្បីជ្រាបថា ជាប្រយោជន៍ដល់សត្វទាំងឡាយដែលគេធ្វើមេត្តា

*ដោយព្រះសូត្រជាដើមយ៉ាងនេះថា* **ទេវតានុកម្បិតោ បោសោ សទា ភទ្រានិ បស្សតិ** *បុរសដែលទេវតាអនុគ្រោះហើយ តែងឃើញសេចក្ដីចម្រើនសព្វកាល ។*

*ព្រះមានព្រះភាគ កាលទ្រង់សម្ដែងមេត្តា មានប្រយោជន៍ដល់បុគ្គលទាំង ២ ចំណែកយ៉ាងនេះ ទើបត្រាស់ថា* **មេត្តំ ករោថ មានុសិយា បជាយ** *ដូច្នេះ កាលទ្រង់សម្ដែងឧបការៈ ទើបត្រាស់ថា* **ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ តស្មា ហិ នេ រក្ខថ អប្បមត្តា។** *មនុស្សទាំងឡាយណា តែងនាំមកនូវពលីក្នុងពេលថ្ងៃ និងពេលយប់ ព្រោះហេតុនោះ សូមអ្នកទាំង-ឡាយ កុំប្រហែសធ្វេស រក្សានូវមនុស្សទាំងនោះ ។*

*ភាសិតនេះ មានអត្ថថា មនុស្សពួកណាសាងទេវតាដោយរូបគំនូរ និងឆ្លាក់ដោយឈើជាដើម ហើយចូលទៅកាន់រុក្ខចេតិយជាដើម ធ្វើពលីកម្ម ក្នុងពេលថ្ងៃ និងពលីកម្មក្នុងពេលយប់ ក្នុងថ្ងៃខាងនោចជាដើម ឧទ្ទិសទេវតាទាំងឡាយ ឬប្រគេនសលាកភត្តជាដើម ធ្វើពលីកម្មឧទ្ទិសដល់អារក្ខទេវតា រហូតដល់ការឲ្យនូវបត្តិទាន គឺចំណែកបុណ្យដល់ព្រហ្ម និងទេវតាទាំងឡាយ និងធ្វើពលីកម្មក្នុងពេលយប់ ដោយការលើកឆត្រ អុជប្រទីប ប្រដាប់នូវកម្រងផ្កា និងរៀបចំឲ្យមានការស្ដាប់ធម៌មួយយប់ទល់ភ្លឺជាដើម មនុស្សទាំងនោះ ពួកអ្នកមិនគប្បីរក្សាដូចម្ដេចបាន ។ ព្រោះហេតុដែលមនុស្សពួកណាធ្វើពលីកម្មឧទ្ទិសដល់អ្នកទាំងឡាយពេលថ្ងៃក្ដី ពេលយប់ក្ដី យ៉ាងនេះ ចូរពួកអ្នករក្សាមនុស្សទាំងឡាយនោះចុះ ។ អធិប្បាយថា ដូច្នោះ ពួកអ្នកចូរ*

គ្រប់គ្រងរក្សាមនុស្សទាំងនោះ គឺបុគ្គលដែលមិនប្រមាទ ធ្វើនូវកាលជាបុគ្គលកតញ្ញូនោះទុកក្នុងចិត្ត វេលាដល់ជានិច្ច ចូរនាំវត្ថុដែលមិនជាប្រយោជន៍ដល់ពួកជនទាំងនោះចេញទៅ គប្បីនាំចូលមកតែវត្ថុជាប្រយោជន៍ ។

## អធិប្បាយបទថា យង្កិញ្ចិ

ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា មនុស្សមានឧបការៈក្នុងទេវតាទាំងឡាយយ៉ាងនេះហើយ ទើបទ្រង់ផ្តើមប្រកបសច្ចវចនៈ ដោយន័យថា **យង្កិញ្ចិ វិត្តំ** ដូច្នេះជាដើម ដើម្បីទ្រង់រម្ងាប់ឧបទ្រវរបស់មនុស្សទាំងនោះ និងដើម្បីការស្តាប់ធម៌របស់ទេវតា និងមនុស្សទាំងឡាយ ដោយការប្រកាសគុណរបស់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ក្នុងសច្ចវចនៈនោះ បទថា **យង្កិញ្ចិ** សេចក្តីថា លោកកាន់យកមិនសេសសល់ ដោយមិនកំណត់ គឺវត្ថុណាមួយដែលគួរធ្វើការផ្លាស់ប្តូរបានក្នុងទឹកដីនោះៗ ។ បទថា **វិត្តំ** បានដល់ ទ្រព្យ ។ ពិតហើយ ទ្រព្យនោះ ឈ្មោះថា **វិត្ត** ព្រោះឲ្យកើតការត្រេកអរ ។ ទ្រង់សម្តែងមនុស្សលោក ដោយបទថា **ឥធ វា** ទ្រង់សម្តែងលោកដ៏សេសក្រៅអំពីមនុស្សនោះ ដោយបទថា **ហុរំ វា**។ ដោយ ២ បទនោះ គប្បីជ្រាបថា ស៊ីសេចក្តីដល់នាគ និងគ្រុឌជាដើមដ៏សេស វៀរមនុស្ស និងទេវតាទាំងឡាយ ព្រោះកាលដែលកាន់យកលោកទាំងពួង វៀរមនុស្សទាំងឡាយ ក៏បានត្រាស់ខាងមុខថា **សគ្គេសុ វា**។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តឯណាសម្រាប់មនុស្ស គឺជាទ្រព្យប្រើផ្លាស់ប្តូរ និងដែលប្រើជាគ្រឿងប្រដាប់ គ្រឿងបរិភោគ និងគ្រឿងឧបភោគ មាន

*មាស ប្រាក់ កែវមុក្តា កែវមណី កែវពិទូរ្យ កែវប្រវាល កែវទទឹម និងកែវមានមកិតជាដើម និងទ្រព្យជាគ្រឿងត្រេកអរនៃចិត្តឯណា សម្រាប់នាគ និងគ្រុឌជាដើមដែលកើតក្នុងភពទាំងឡាយ ដែលធំទូលាយច្រើនរយយោជន៍ ក្នុងវិមានរតនៈ ក្នុងផ្ទៃដីដែលក្រាលដោយខ្សាច់ កែវមុក្តា និងកែវមណី ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ក៏ជាការសម្តែងហើយ ដោយបទទាំង ២ នេះ ដោយប្រការដូច្នេះ ។*

*បទថា* **សគ្គេសុ វា** *បានដល់ ទេវលោកដែលជាកាមាវចរ និងរូបាវចរ ទេវលោកទាំងនោះ ឈ្មោះថា* **សគ្គ** *គឺស្ថានសួគ៌ ព្រោះប្រព្រឹត្តទៅ គឺដល់បានដោយកម្មដ៏ស្អាត ។ ម្យ៉ាងទៀត ឈ្មោះថា* **សគ្គ** *ព្រោះមានអារម្មណ៍ល្អក្រៃលែង ។ បទថា* **យំ** *បានដល់ មានម្ចាស់របស់ ឬមិនមានម្ចាស់របស់ឯណា ។ បទថា* **រតនំ** *បានដល់ ឈ្មោះថា* **រតន** *ព្រោះនាំឲ្យកើត គឺចម្រើននូវសេចក្តីត្រេកអរ ពាក្យថា* **រតន** *នេះ ជាឈ្មោះរបស់វត្ថុទាំងអស់ដែលធ្វើឲ្យស្អាត មានតម្លៃច្រើន ថ្លឹងថ្លែងមិនបាន ធ្វើបានលំបាក និងជារបស់បរិភោគ ប្រើប្រាស់របស់សត្វដែលមិនថោកថយ ដូចលោកពោលថា*

**ចិត្តីកតំ មហគ្ឃញ្ច　　អតុលំ ទុល្លភទស្សនំ**
**អនោមសត្តបរិភោគំ　　រតនំ តេន វុច្ចតិ ។**

*របស់ដែលធ្វើឲ្យគេកោតក្រែង មានតម្លៃច្រើន ថ្លឹងមិនបាន*
*ឃើញបានដោយលំបាក ជាគ្រឿងប្រើបាស់របស់សត្វដែល*
*មិនថោកថយ ដោយហេតុនោះ ទើបហៅថា* **រតនៈ ។**

បទថា **បណីតំ** បានដល់ ប្រសើរបំផុត មិនតិច គួរត្រេកអរនៃចិត្ត រតនៈណាក្នុងសួគ៌ទាំងឡាយ តាំងអំពីវិមានសុធម្មសភា វេជយន្តប្រាសាទ ដែលជារតនៈ មានទំហំច្រើនរយយោជន៍ ជារបស់មានម្ចាស់ និងរតនៈណា ដែលទាក់ទងនៅក្នុងវិមានដែលទំនេរ ក្នុងស្ថានសួគ៌ទាំងឡាយ ដែលធ្វើអបាយ ប៉ុណ្ណោះឲ្យពេញ មិនមែនសម័យដែលព្រះពុទ្ធកើតឡើង មិនមានម្ចាស់ ឬ រតនៈដទៃណា ដែលអាស្រ័យនៅក្នុងផែនដី មហាសមុទ្រ និងភ្នំហិមពាន្តជា ដើមមិនមានម្ចាស់ រតនៈដទៃនោះ ក៏ឈ្មោះថា ទ្រង់សម្តែងហើយដោយបទ នៃគាថានេះ ដោយប្រការដូច្នេះ ។

សព្ទថា **ន** ក្នុងបាទគាថាថា **ន នោ សមំ អត្ថិ តថាគតេន** ចុះក្នុង ការបដិសេធ ។ សព្ទថា **នោ** ចុះក្នុងអត្ថហាមសេចក្តីដទៃ ។ បទថា **សមំ** បានដល់ ប្រៀបធៀប ។ បទថា **អត្ថិ** ប្រែថា មាន ។ បទថា **តថាគតេន** បានដល់ ដោយព្រះពុទ្ធ ។ លោកអធិប្បាយដូចម្តេច ។ លោកអធិប្បាយ ដូច្នេះ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត និងរតនៈនោះឯណា ដែលព្រះមាន ព្រះភាគទ្រង់ប្រកាសហើយ បណ្តាទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត និងរតនៈ នោះ រតនៈសូម្បីតែមួយ ដែលស្មើដោយពុទ្ធរតនៈ មិនមានឡើយ ពិតហើយ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ឈ្មោះថា **រតន** ព្រោះអត្ថថា ធ្វើឲ្យកើត នូវការកោតក្រែង ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺចក្ករ័តន៍ និងមណីរ័តន៍របស់ស្តេចចក្រពត្តិ ដែលកើតឡើងហើយ មហាជននឹងធ្វើ សេចក្តីគោរពកោតក្រែងក្នុងទីដទៃ បុគ្គលណាកាន់យកផ្កា និងគ្រឿងក្រអូប

ជាដើម ហើយមិនទៅកាន់ស្ថានរបស់យក្ស ឬស្ថានរបស់ភូត ៨ ជនគ្រប់គ្នានឹងធ្វើសេចក្តីគោរពកោតក្រែង បូជាចំពោះចក្ករ័តន៍ និងមណីរ័តន៍ប៉ុណ្ណោះ ប្រាថ្នាពរនោះៗ និងពរឯណានីមួយ ប្រាថ្នាហើយប្រាថ្នាទៀត ក៏សម្រេចផលបាន រតនៈនោះ ស្មើដោយពុទ្ធរតនៈ មិនមាន ។

បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា **រតន** ព្រោះអត្ថថា ធ្វើឲ្យកើតការគោរពកោតក្រែងព្រះតថាគតប៉ុណ្ណោះ ក៏ឈ្មោះថា **រតន** ។ ពិតហើយ កាលព្រះតថាគត ទ្រង់កើតឡើងហើយ ទេវតា និងមនុស្សដែលមានសក្តិច្រើន គ្រប់ពួក គ្រប់ត្រកូល ទេវតា និងមនុស្សទាំងនោះ រមែងមិនធ្វើសេចក្តីគោរពកោតក្រែង ក្នុងរតនៈដទៃ រមែងមិនបូជារតនៈដទៃណាមួយ ។ ពិតហើយ សហម្បតីព្រហ្មក៏បូជាព្រះតថាគត ដោយកម្រងរតនៈប៉ុនភ្នំព្រះសិនេរុ ។ ទេវតាដទៃ និងមនុស្សទាំងឡាយ មានព្រះបាទពិម្ពិសារ និងព្រះបាទកោសល និងអនាថបិណ្ឌិកជាដើម ក៏បូជាតាមកម្លាំង ព្រះបាទអសោកមហារាជ លះបង់ព្រះរាជទ្រព្យ ៩៦ កោដិ សាងវិហារ ៨៤០០០ ពេញជម្ពូទ្វីប ឧទ្ទិសចំពោះព្រះមានព្រះភាគ សូម្បីព្រះអង្គទ្រង់បរិនិព្វានហើយ ។ នឹងពោលទៅថ្វីសម្រាប់បុគ្គលដែលគោរពកោតក្រែងដទៃនោះ ។ម្យ៉ាងទៀត កាលព្រះពុទ្ធអង្គណាមួយដទៃបរិនិព្វានហើយ ធ្វើការកោតក្រែង ឧទ្ទិសទីប្រសូត ទីត្រាស់ដឹង ទីប្រកាសធម្មចក្រ និងទីបរិនិព្វាន ឬចេតិយ គឺព្រះបដិមា ក៏ប្រព្រឹត្តទៅដូចនឹងព្រះមានព្រះភាគ ។ រតនៈដែលស្មើដោយព្រះតថាគត ព្រោះអត្ថថា ធ្វើឲ្យកើតនូវការគោរពកោតក្រែង មិនមាន ដោយ

ប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ឈ្មោះថា **រតន** ព្រោះអត្ថថា មានតម្លៃច្រើនក៏ដូចគ្នា ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺសំពត់ដែនកាសីដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក ទោះចាស់ក៏មានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ស្មើដោយពុទ្ធរតនៈ មិនមាន រតនៈជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា **រតន** ព្រោះអត្ថថា មានតម្លៃច្រើន ព្រះតថាគតប៉ុណ្ណោះឈ្មោះថា **រតន** ពិតហើយ ព្រះតថាគតទ្រង់ទទួលបង្សុកូលចីវររបស់ជនពួកណា ទាននោះរបស់ជនទាំងនោះ រមែងមានផលច្រើន មានអានិសង្សច្រើន ដូច្នេះ ។ ព្រោះព្រះតថាគតនោះ មានតម្លៃច្រើន ។ ដោយពាក្យពោលដល់ប្រការដែលព្រះតថាគត ទ្រង់មានតម្លៃច្រើនយ៉ាងនេះ គប្បីជ្រាបបទនៃព្រះសូត្រដែលសាធកការមិនមានទោស ក្នុងសេចក្តីនេះ ដូច្នេះថា

ប្រសិនបើតថាគតទទួលចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនដល់ពួកជននោះ បានជាតថាគតពោលយ៉ាងនេះ ព្រោះតថាគតមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើន យ៉ាងណាមិញ ម្នាលភិក្ខុ

*ទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។*

*រតនៈស្មើដោយតថាគត ព្រោះអត្ថថា មានតម្លៃច្រើន រមែងមិនមានដោយប្រការដូច្នេះ ។*

*ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ឈ្មោះថា* **រតន** *ព្រោះអត្ថថា ថ្លឹងមិនបាន ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺចក្ករតន៍នៃស្តេចចក្រពត្តិ មានដុំជាកែវមណីឥន្ទនីល មានកាំជារតនៈ ៧ ពាន់កាំ មានខ្នងកង់ជាវិការនៃកែវប្រពាល មានទី-តជាមាសកើតឡើងរៀងរាល់ ១០ កាំទទួលខ្យល់ហើយ ធ្វើសំឡេងដូចសំឡេងតន្ត្រី ដែលមានអង្គ ៥ ដែលអ្នកជំនាញប្រគំហើយ ផ្នែកសងខាងនៃដុំ មានមុខរាជសីហ៍ ២ ខាងក្នុងកង់រថមានប្រហោង មិនមានអ្នកធ្វើ ឬអ្នកឲ្យធ្វើ រនូនោះកើតឡើងអំពីឧតុ មានកម្មជាបច្ច័យ ដែលព្រះរាជាទ្រង់បំពេញចក្កពត្តិវត្ត ១០ ប្រការហើយ ថ្ងៃឧបោសថ ១៥ កើត ១៥ រោច ទ្រង់កក់សីសៈហើយ ទ្រង់រក្សាឧបោសថ ទ្រង់ឡើងលើមហាប្រាសាទ ទ្រង់ជម្រះសីល ប្រថាប់គង់ហើយ ទតឃើញចក្ករតន៍ប្រាកដឡើង ដូចព្រះចន្ទ និងព្រះអាទិត្យពេញវង់ ទ្រង់បានឮសំឡេងមកតាំងអំពីទី ១២ យោជន៍ ឃើញពណ៌មកតាំងអំពីទី ៣ យោជន៍ ដែលមហាជនសម្លឹងឃើញ នាំគ្នាភ្ញាក់ផ្អើលថា ពន់ពេកថា ប្រហែលជាព្រះចន្ទ និងព្រះអាទិត្យដួងទី ២ កើតឡើងហើយ អណ្តែតមកខាងលើព្រះនគរ មិនខ្ពស់ពេក មិនទាបពេក តាមទិសខាងកើត ខាងក្នុងព្រះរាជនិវេសន៍ ហើយឈប់នឹងថ្កល់ ដូចបាក់ភ្ជៅ ក្នុងទីដែលមហាជនគួរបូជា ដោយគ្រឿងក្រអូប និងផ្កា*

ជាដើម ។

ហត្ថិរ័តន៍ ដំរីកែវកើតឡើងតាមចក្ករ័តន៍នោះឯង គឺដំរីសសុទ្ធ ជើងក្រហម មានកម្លាំងស្មើដំរី ៧ មានឫទ្ធិទៅក្នុងអាកាសបាន មកអំពីត្រកូលដំរីឈ្មោះឧបោសថក៏មាន មកអំពីត្រកូលឆទ្ទន្តក៏មាន បើមកអំពីត្រកូលឧបោសថ ក៏ជាដំរីច្បងគេទាំងអស់ បើមកអំពីត្រកូលឆទ្ទន្ត ក៏ជាដំរីប្អូនគេទាំងអស់ មានការសិក្សាហើយ ទូន្មានហើយ ដំរីនោះ នាំបរិស័ទប្រមាណ ១២ យោជន៍ ធ្វើលជម្ពូទ្វីប ទៅហើយត្រឡប់មកឯង មុនអាហារព្រឹកនោះឯង ។

អស្សរតរ័តន៍ ក៏កើតតាមហត្ថិរ័តន៍នោះឯង គឺជាសេះសសុទ្ធ ជើងក្រហម ក្បាលដូចក្បាលក្អែក មានសក់ដូចស្មៅជំណោកទទន្សាយ មកអំពីត្រកូលស្តេចសេះវលាហក ។ ក្នុងសេចក្តីនេះ ពាក្យដ៏សេស ដូចគ្នានឹងហត្ថិរ័តន៍នោះឯង ។

មណីរ័តន៍ ក៏កើតជាប់តាមអស្សរតរ័តន៍នោះ មណីនោះ ជាកែវពិទូរ្យស្អាតដោយធម្មជាតិ ជាកែវមានជ្រុង ៨ ដែលគេធ្វើយ៉ាងល្អ ដោយបណ្តោយក៏ដូចគ្នានឹងដុំនៃចក្រ មកអំពីវេបុលបព៌ត មណីនោះ ពេលយប់ងងឹត ដែលប្រកបដោយអង្គ ៤ ដាក់លើកំពូលទង់របស់ព្រះរាជា ក៏ផ្សាយពន្លឺទៅរាប់យោជន៍ ពួកមនុស្សសម្គាល់ថាជាពេលថ្ងៃ ប្រកបការងារ មើលឃើញដោយហោចសូម្បីស្រមោច និងស្រមោចក្រហម ។

ឥត្ថីរ័តន៍ក៏កើតឡើងតាមមណីរ័តន៍នោះឯង គឺស្ត្រីដែលជាអគ្គមហេសីដោយប្រក្រតី ឬមកអំពីឧត្តរកុរុទ្វីប ឬមកអំពីត្រកូលមទ្ទរាជ វៀរចាកទោស

៦ មានការខ្ពស់ពេកជាដើម កន្លងបង់នូវពណ៌របស់មនុស្ស តែមិនដល់វណ្ណៈទិព្វ សម្រាប់ព្រះរាជា នាងមានកាយក្ដៅក្នុងកាលត្រជាក់ មានកាយត្រជាក់ក្នុងកាលក្ដៅ មានសម្ផស្សដូចសំឡីដែលគេផ្ដួច ៧ ដង ក្លិនចន្ទន៍ផ្សាយចេញអំពីព្រះកាយ ក្លិនឧប្បលផ្សាយចេញអំពីមាត់ និងជាស្ត្រីប្រកបដោយគុណសម្បត្តិដ៏ចម្រើន មានការក្រោកមុនជាដើម ។

គហបតិរ័តន៍ ក៏កើតជាប់តាមឥត្ថីរ័តន៍នោះឯង គឺសេដ្ឋីដែលធ្វើការងារដោយប្រក្រតីរបស់ព្រះរាជា តែកាលចក្ករ័តន៍កើតឡើង ក៏ប្រាកដទិព្វចក្ខុ ឃើញនូវរណ្ដៅទ្រព្យបានប្រមាណមួយយោជន៍ដោយជុំវិញ ទោះជារបស់មានម្ចាស់និងមិនមានម្ចាស់ ក៏ចូលគាល់ព្រះរាជា ទូលនូវបំណាងថា បពិត្រទេវរាជ សូមទ្រង់ដាក់ព្រះរាជភារកិច្ចចុះ ទូលបង្គំនឹងធ្វើកិច្ចដែលគួរធ្វើ ទាក់ទងនឹងទ្រព្យរបស់ព្រះអង្គដោយខ្លួនឯង ។

បរិនាយករ័តន៍ ក៏កើតតាមគហបតិរ័តន៍នោះឯង ដោយប្រក្រតី គឺព្រះជេដ្ឋឱរសរបស់ព្រះរាជា កាលចក្ករ័តន៍កើតឡើង ក៏ជាបុគ្គលប្រកបដោយបញ្ញាឈ្លាសវៃក្រៃលែង អាចកំណត់ដឹងចិត្តរបស់បរិស័ទប្រមាណ ១២ យោជន៍ដោយចិត្តរបស់ខ្លួន ហើយធ្វើនិគ្គហៈ គឺការដាក់ទោស និងបគ្គហៈ គឺការសរសើរ បរិនាយកនោះ ក៏ចូលគាល់ព្រះរាជាទូលនូវសេចក្ដីប្រាថ្នាថា បពិត្រមហារាជ សូមទ្រង់ដាក់ព្រះរាជភារៈចុះ ខ្ញុំព្រះអង្គនឹងបរិហាររាជការផែនដីរបស់ព្រះអង្គដោយខ្លួនឯង ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តដទៃណាបែបនោះឈ្មោះថា **រតន** ព្រោះអត្ថថា ប្រើងមិនបាន ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តណា

មិនអាចពិនិត្យពិចារណា វាយតម្លៃថា មានតម្លៃ ១០០ , ១០០០ ឬ ១ កោដិ ក្នុងទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ សូម្បីរតនៈណាមួយ ស្មើដោយពុទ្ធ-រតនៈ មិនមានឡើយ ។ បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា **រតន** ព្រោះអត្ថថា ថ្លឹងមិនបាន ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា **រតន។** ពិតហើយ ព្រះតថាគត បុគ្គលណាម្នាក់ ក៏មិនអាចពិចារណាដោយសីល ដោយសមាធិ ឬដោយបណ្ដាបញ្ញាជាដើមណាមួយ ហើយកំណត់ថា ទ្រង់មាននូវព្រះគុណប៉ុណ្ណោះ ទ្រង់ស្មើ ឬប្រៀបធៀបនឹងបុគ្គលនេះ រតនៈស្មើដោយព្រះតថាគត ព្រោះអត្ថថា ថ្លឹងមិនបាននោះ រតនៈនោះមិនមានឡើយ ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តណា ឈ្មោះថា **រតន** ព្រោះអត្ថថា ឃើញបានលំបាក ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនេះ គឺភាពជារបស់ប្រាកដបានលំបាក បានដល់ ស្ដេចចក្រពត្តិ និងរតនៈ ៧ ប្រការរបស់ស្ដេចចក្រពត្តិនោះ រតនៈនោះ ស្មើដោយពុទ្ធរតនៈ មិនមាន ។ បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះថា **រតន** ព្រោះអត្ថថា ឃើញបានលំបាកសោត ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា **រតន** ភាពជារតនៈរបស់ស្ដេចចក្រពត្តិជាដើម និងឃើញបានលំបាកមកអំពីណា ពិតហើយ រតនៈទាំងនោះ រមែងកើតឡើងច្រើនក្នុងកប្ប ១ ប៉ុណ្ណោះ តែព្រោះទ្វីបលោកសូន្យចាកព្រះតថាគតរាប់អសង្ខេយ្យកប្ប ដូច្នោះ ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា ឃើញបានលំបាក ព្រោះកើតឡើងម្ដងម្កាល ។ សមដូចព្រះមានព្រះភាគ ត្រាស់ក្នុងសម័យបរិនិព្វានដូច្នេះថា

ម្នាលអានន្ទ ពួកទេវតាពោលទោសថា ពួកយើងមក
អំពីចម្ងាយ ដើម្បីឃើញព្រះតថាគតៗ ជាព្រះអរហន្ត
សម្មាសម្ពុទ្ធកើតឡើងក្នុងលោកមានម្តងៗ ក្នុងបច្ឆិម-
យាម នៃរាត្រីថ្ងៃនេះឯង បរិនិព្វានទើងមានដល់ព្រះ
តថាគត ក៏ភិក្ខុមានសក្តិធំនេះ មកឈររាំងនៅចំព្រះ
ភក្ត្រនៃព្រះមានព្រះភាគ ពួកយើងមិនបានឃើញព្រះ
តថាគត ក្នុងបច្ឆិមកាលឡើយ ។

រតនៈស្មើដោយព្រះតថាគត ព្រោះអត្ថថា ឃើញបានដោយក្រ រមែង
មិនមាន ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ បានឈ្មោះថា **រតន** ព្រោះអត្ថថា
ជាគ្រឿងបរិភោគប្រើប្រាស់របស់សត្វ ដែលមិនថោកទាប ក៏ដូចគ្នា ។ ទ្រព្យ
ជាគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺរតនៈជាដើមរបស់ស្តេចចក្រពត្តិ ។ ពិត
ហើយ រតនៈនោះ មិនមែនកើតឡើងដើម្បីជាគ្រឿងបរិភោគ សូម្បីដោយការ
យល់សប្តិរបស់បុរសថោកថយ បុគ្គលមានត្រកូលទាប ដូចជាមនុស្សចណ្ឌាល
ជាងផែង ព្រាន ជាងរថ និងអ្នកចាក់សំរាមជាដើម ដែលមានទ្រព្យរាប់សែន
កោដិក្តី នៅលើមហាប្រាសាទ ៧ ជាន់ក្តី តែជាគ្រឿងបរិភោគ របស់សត្វ
ដែលមិនថោកថយ ព្រោះកើតដើម្បីជាគ្រឿងបរិភោគ របស់ព្រះមហាក្សត្រ
ដែលជាឧភតោសុជាតិ បំពេញចក្កពត្តិវត្ត ១០ ប្រការបរិបូណ៌ រតនៈនោះ
ស្មើដោយពុទ្ធរតនៈមិនមានឡើយ ។ បើទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឈ្មោះ

ថា **រតន** ព្រោះអត្ថថា ជាគ្រឿងបរិភោគរបស់សត្វដែលមិនថោកថយសោត ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា **រតន** ។ ពិតហើយ ព្រះតថាគតមិនមែនជាគ្រឿងបរិភោគ សូម្បីត្រឹមតែការយល់សប្តិរបស់គ្រូទាំង ៦ មានបូរណកស្សបជាដើម ដែលសន្មតគ្នាថា ជាសត្វថោកថយ មិនដល់ព្រមដោយឧបនិស្ស័យ មានទស្សនវិបរិត និងរបស់សត្វដទៃបែបនោះ តែជាគ្រឿងបរិភោគរបស់ពួកបុគ្គលដែលដល់ព្រមដោយឧបនិស្ស័យ ជាអ្នកអាចសម្រេចអរហត្ត កាលចប់គាថា ៤ បទ បុគ្គលមានញាណទស្សនៈ ទម្លាយនូវកិលេស មានព្រះពាហិយ-ទារុចីរិយជាដើម និងរបស់ព្រះមហាសាវកទាំងឡាយដទៃៗ ដែលជាបុត្រនៃត្រកូលធំ ។ ពិតហើយ ពួកសត្វដែលមិនថោកថយទាំងនោះ កាលញ៉ាំងទស្សនានុត្តរិយៈ សវនានុត្តរិយៈ និងបារិចរិយានុត្តរិយៈជាដើមឲ្យសម្រេច ឈ្មោះថា បរិភោគប្រើប្រាស់ព្រះតថាគត ។ រតនៈដែលស្មើដោយព្រះតថាគត ព្រោះអត្ថថា ជាគ្រឿងបរិភោគរបស់សត្វ ដែលមិនថោកថយ មិនមានឡើយ ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងត្រេកអរនៃចិត្តនោះ ដោយមិនវិសេស ឈ្មោះថា **រតន** ព្រោះអត្ថថា ឲ្យកើតនូវការត្រេកអរ ។ ទ្រព្យ គឺគ្រឿងត្រេកអរនៃចិត្តនោះ គឺអ្វី គឺចក្ករ័តន៍របស់ស្តេចចក្រពត្តិ ពិតហើយ ស្តេចចក្រពត្តិទ្រង់ឃើញចក្ក-រ័តន៍នោះហើយ ក៏ទ្រង់សប្បាយព្រះហឫទ័យ ចក្ករ័តន៍នោះ នាំមកនូវការត្រេកអរដល់ព្រះរាជា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ស្តេចចក្រពត្តិទ្រង់ចាប់ព្រះសុវណ្ណភិង្គា ដោយព្រះហស្តឆ្វេង

ទ្រង់ប្រោះព្រំដោយព្រះហស្តស្តាំ មានព្រះរាជឱង្ការថា ចក្ករ័តន៍ចូរវិលទៅ ចក្ករ័តន៍ចូរមានជ័យជម្នះ ។ បន្ទាប់អំពីនោះ ចក្ករ័តន៍ក៏បន្លឺសំឡេងពីរោះ ដូចតន្ត្រីមានគ្រឿង ៥ ហោះទៅទិសខាងកើត ។ ស្តេចចក្រពត្តិទ្រង់លើក ចតុរង្គសេនាដែលមានទទឹង ១២ យោជន៍ជាប់តាមទៅ ដោយអានុភាពចក្ក- រ័តន៍ មិនខ្ពស់ពេក មិនទាបពេក ឆ្ងាយអំពីផែនដី យ៉ាងទាបត្រឹមដើមឈើ ទាប យ៉ាងខ្ពស់ត្រឹមដើមឈើខ្ពស់ ទ្រង់ទទួលគ្រឿងបណ្ណាការអំពីដៃរបស់ពួក ជនដែលកាន់បណ្ណាការ មានផ្កា ផ្លែឈើ និងពន្លកឈើក្នុងដើមឈើជាដើម ។

ឯព្រះរាជាដែលធ្លាប់ជាបដិបក្ខ មកគាល់ដោយសេចក្តីគោរព ឱន លំទោនយ៉ាងក្រៃលែងថា សូមទ្រង់យាងមកចុះ ព្រះមហារាជ ក៏ទ្រង់អនុ- សាសន៍ ទូន្មានដោយន័យថា កុំសម្លាប់សត្វមានជីវិត ដូច្នេះជាដើម ទើប យាងទៅ ។ ក្នុងទីណាព្រះរាជាមានបំណងសោយ ឬបំណងនឹងផ្ទំពេលថ្ងៃ ក្នុងទីនោះ ចក្ករ័តន៍ក៏ចុះអំពីអាកាស ហើយឈប់ ដូចបាក់ក្ដៅ ក្នុងទីដែល រាបស្មើ សមគួរដល់កិច្ចគ្រប់យ៉ាង មានកិច្ចដែលទាក់ទងដោយទឹកជាដើម កាលព្រះរាជាគិតយាងទៅទៀត ចក្ករ័តន៍ក៏បន្លឺសំឡេងដោយន័យមុននោះឯង ទើបរសាត់ទៅ ។ ឯបរិស័ទទំហំ ១២ យោជន៍បានឮសំឡេងនោះ ក៏នាំគ្នា ហោះទៅ ។ ចក្ករ័តន៍ចុះកាន់មហាសមុទ្រទិសខាងកើតដោយលំដាប់ កាល ចក្ករ័តន៍នោះចុះកាន់សមុទ្រ ទឹកក៏រួញខ្លួនទៅប្រមាណមួយយោជន៍ឈប់ស្ងៀម ដូចធ្វើការស្រឡាញ់រាប់អាន ។ មហាជនក៏រើសរតនៈទាំង ៧ តាមសេចក្តី ត្រូវការ ព្រះរាជាទ្រង់ចាប់ឃ្នោកមាសទៀត ទ្រង់ប្រោះព្រំដោយទឹក ត្រាស់ថា

រាជកិច្ចរបស់ខ្ញុំប្រព្រឹត្តទៅ ហើយទ្រង់យាងត្រឡប់ ។ កងទ័ពនៅខាងមុខ ចក្ករ័តន៍ នៅខាងក្រោយ ព្រះរាជានៅកណ្តាល ។ ទឹកត្រឡប់មកវិញ ពេញត្រង់ទីដែលចក្ករ័តន៍ចុះនោះ ។ ចក្ករ័តន៍ទៅក្នុងសមុទ្រទិសទក្សិណ ទិសខាងបស្ចិម និងទិសឧត្តរ ដោយឧបាយនេះឯង ។

ចក្ករ័តន៍វិលទៅ ៤ ទិសយ៉ាងនេះហើយ ក៏ឡើងកាន់អាកាសប្រមាណ ៣០០ យោជន៍ ព្រះរាជាទ្រង់ប្រថាប់ឈរលើចក្ករ័តន៍នោះ ទ្រង់ឈ្នះដោយអានុភាពចក្ករ័តន៍ ទ្រង់មើលចក្រវាលមួយ ដែលប្រដាប់ដោយទ្វីបធំ ៤ និងទ្វីបតូច ២០០០ ដូចសួនបុណ្ឌរិកដែលរីកល្អហើយយ៉ាងនេះ គឺបុព្វវិទេហទ្វីបប្រដាប់ដោយទ្វីបតូច ៥០០ មានបរិមណ្ឌល ៧០០០ យោជន៍ ឧត្តរកុរុទ្វីបក៏ដូចគ្នា មានបរិមណ្ឌល ៨០០០ យោជន៍ អាមរគោយានទ្វីប មានបរិមណ្ឌល ៧០០០ យោជន៍ដូចគ្នា និងជម្ពូទ្វីបមានបរិមណ្ឌល ១០០០០ យោជន៍ ។ ស្តេចចក្រពត្តិអង្គនោះ កំពុងពិនិត្យមើលយ៉ាងនេះ ទ្រង់ក៏ត្រេកអរក្រៃលែង ចក្ករ័តន៍នោះបានឲ្យកើតសេចក្តីត្រេកអរដល់ព្រះរាជា ដោយអាការយ៉ាងនេះ ។ ចក្ករ័តន៍នោះ មិនស្មើនឹងពុទ្ធរ័តន៍ឡើយ ។ បើឈ្មោះថា **រតន** ព្រោះអត្ថថាឲ្យកើតសេចក្តីត្រេកអរសោត ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា **រតន** ចក្ក-រ័តន៍តែម្យ៉ាង នឹងធ្វើអ្វីបាន ។

ពិតហើយ ការត្រេកអរក្នុងចក្រពត្តិ ដែលខ្លួនធ្វើឲ្យកើត រតនៈគ្រប់យ៉ាងមានចក្ករ័តន៍ជាដើម ក៏មិនទាន់រាប់ស្មើមួយចម្រៀកនៃចំណែកការត្រេកអរដែលជាទ្រព្យឯណា ព្រះតថាគតទ្រង់ធ្វើឲ្យកើតសេចក្តីត្រេកអរក្នុងបឋមជ្ឈាន

ការត្រេកអរក្នុងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន សេចក្តីត្រេកអរក្នុងអាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន និងនេវសញ្ញានាសញ្ញាយតនជ្ឈាន សេចក្តីត្រេកអរក្នុងសោតាបត្តិមគ្គ សេចក្តីត្រេកអរក្នុងសោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ និងអរហត្តផល ដល់ទេវតា និងមនុស្ស រាប់មិនអស់ ដែលទទួលឱវាទរបស់ព្រះអង្គ ។ ក្រៃលែងជាង ប្រណីតជាងការត្រេកអរនោះ រតនៈ ស្មើដោយព្រះតថាគត ព្រោះអត្ថថា ឲ្យកើតនូវការត្រេកអរ មិនមាន ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ធម្មតារតនៈនេះមាន ២ យ៉ាង គឺ **សវិញ្ញាណករតនៈ** និង **អវិញ្ញាណករតនៈ** ។ បណ្តារតនៈទាំង ២ នោះ អវិញ្ញាណករតនៈ បានដល់ចក្ករ័តន៍ និងមណីរ័តន៍ ឬរតនៈដទៃណា មានមាស និងប្រាក់ជាដើម ដែលទាក់ទងដោយអនិន្ទ្រិយ ។

សវិញ្ញាណករតនៈ បានដល់ រតនៈ មានហត្ថិរ័តន៍ជាដើម មានបរិនាយករ័តន៍ជាទីបំផុត ឬរតនៈដទៃណាបែបនោះ ដែលទាក់ទងដោយឥន្ទ្រិយ ។ កាលបើដូច្នោះ ក្នុងរតនៈទាំង ២ យ៉ាង សវិញ្ញាណករតនៈ ពោលថា ជារតនៈប្រសើរ ក្នុងសេចក្តីនេះ ។ ព្រោះហេតុអ្វី ព្រោះថា រតនៈ មានមាស ប្រាក់ កែវមណី កែវមុក្តាជាដើម ត្រូវនាំចូលទៅប្រើជាគ្រឿងអលង្ការនៃហត្ថិរ័តន៍ជាដើម ដែលជាសវិញ្ញាណករតនៈ ។

សវិញ្ញាណករតនៈមាន ២ យ៉ាង គឺរតនៈជាសត្វតិរច្ឆាន និងរតនៈជា

មនុស្ស ។ បណ្ដាសវិញ្ញាណករតនៈ ២ យ៉ាងនោះ រតនៈដែលជាមនុស្ស ពោលហើយថា ជារតនៈប្រសើរ ព្រោះហេតុអ្វី ព្រោះថា រតនៈដែលជាសត្វតិរច្ឆាន រមែងជាពាហនៈរបស់រតនៈដែលជាមនុស្ស ។ មនុស្សរតនៈមាន ២ យ៉ាង គឺឥត្ថីរ័តន៍ និងបុរិសរ័តន៍ ។ បណ្ដាមនុស្សរតនៈទាំង ២ យ៉ាងនោះ បុរិសរ័តន៍ ឈ្មោះថា របស់ប្រសើរ ។ ព្រោះហេតុអ្វី ព្រោះថា ឥត្ថីរ័តន៍ជាបារិចារិការបស់បុរិសរ័តន៍ ។ បុរិសរតនៈក៏មាន ២ យ៉ាង គឺអគារិករ័តន៍ និងអនាគារិករ័តន៍ ។ បណ្ដាបុរិសរ័តន៍ ២ យ៉ាងនោះ អនាគារិករ័តន៍ ជារតនៈប្រសើរ ព្រោះហេតុអ្វី ព្រោះថា ក្នុងអគារិករ័តន៍ ស្ដេចចក្រពត្តិដ៏ប្រសើរ ក៏គង់ថ្វាយបង្គំអនាគារិករ័តន៍ដែលប្រកបដោយគុណ មានសីលជាដើម ដោយបញ្ចង្គប្រតិស្ឋាន ទំនុកបម្រុង អង្គុយជិត ជួបនូវសម្បត្តិដែលជាទិព្វ និងមនុស្ស សម្រេចនិព្វានសម្បត្តិក្នុងទីបំផុត ។

កាលបើដូច្នោះ សូម្បីអនាគារិករ័តន៍ក៏មាន ២ យ៉ាង គឺ **អរិយរតន** និង **បុថុជ្ជនរតន** ។

អរិយរតនៈមាន ២ យ៉ាង គឺ **សេក្ខរតន** និង **អសេក្ខរតន** ។

អសេក្ខរតនៈក៏មាន ២ យ៉ាង គឺ **សុក្ខវិបស្សករតន** និង **សមថយានិករតន** ។

សមថយានិករ័តន៍ក៏មាន ២ យ៉ាង គឺដែលសម្រេចសាវកបារមី និងដែលមិនសម្រេចសាវកបារមី ។ បណ្ដាសមថយានិករ័តន៍ទាំង ២ យ៉ាងនោះ សមថយានិករ័តន៍ដែលសម្រេចសាវកបារមី ឈ្មោះថា ប្រសើរ ព្រោះ

ហេតុអ្វី ព្រោះថា មានគុណច្រើន ព្រះបច្ចេកពុទ្ធរ័តន៍ ឈ្មោះថា ជារតនៈប្រសើរជាងសាវកបារមីបត្តរ័តន៍ ។ ព្រោះហេតុអ្វី ព្រោះថា មានគុណច្រើន ។ សាវ័កច្រើនរយ ដូចជាព្រះសារីបុត្រ ព្រះមោគ្គល្លាន ក៏មិនដល់ចំណែកទី ១០០ នៃគុណទាំងឡាយរបស់ព្រះបច្ចេកពុទ្ធមួយអង្គ ។

សម្មាសម្ពុទ្ធរ័តន៍ ពោលថា ជារតនៈដ៏ប្រសើរជាងបច្ចេកពុទ្ធរ័តន៍ ព្រោះហេតុអ្វី ព្រោះថា មានគុណច្រើន ។ បើព្រះបច្ចេកពុទ្ធទាំងឡាយគង់ពត់ភ្នែនជាប់ៗ គ្នា ពេញជម្ពូទ្វីប ក៏មិនស្មើនឹងមួយចម្រៀកនៃព្រះគុណទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធមួយអង្គ ។ សមដូចព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី មានជើងពីរក្តី ។បេ។ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរ ជាងពួកសត្វទាំងនោះ ។ រតនៈដែលស្មើដោយព្រះតថាគតមិនមានឡើយ ដោយបរិយាយណាមួយ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ន នោ សមំ អត្ថិ តថាគតេន** ទ្រព្យ និងរតនវត្ថុទាំងនោះឯង ស្មើដោយព្រះតថាគតមិនមានឡើយ ។

ព្រះមានព្រះភាគ កាលត្រាស់ភាពដែលពុទ្ធរ័តន៍ ដែលរតនៈដទៃៗប្រៀបធៀបមិនបានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវដែលកើតដល់សត្វទាំងនោះ ទ្រង់មិនអាស្រ័យជាតិ ទ្រង់មិនអាស្រ័យគោត្រ ទ្រង់មិនអាស្រ័យភាពជាកុលបុត្រ ទ្រង់មិនអាស្រ័យភាពជាអ្នកមានពណ៌សម្បុរស្អាតជាដើម បើទ្រង់អាស្រ័យភាពដែលពុទ្ធរ័តន៍ មិនមានអ្វីប្រៀបធៀបបានដោយ

គុណទាំងឡាយ មានសីលក្ខន្ធ និងសមាធិក្ខន្ធជាដើមក្នុងលោក ដែលមានអវីចីជាដើម មានភវគ្គព្រហ្មជាទីបំផុត ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** រតនៈ គឺព្រះពុទ្ធនេះឯងជារតនៈដ៏ឧត្តម ដោយសច្ចៈនេះ សូមមានសិរីសួស្តី ដូច្នេះ ។

សច្ចវចនៈនោះ មានសេចក្តីដូច្នេះថា ភាពដែលព្រះពុទ្ធមិនមានបុគ្គលប្រៀបបានដោយព្រះគុណទាំងឡាយនោះៗ និងទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត ឬរតនៈគ្រប់យ៉ាង ដែលមានក្នុងលោកនេះ ឬលោកដទៃ ឬក្នុងស្ថានសួគ៌ទាំងឡាយ នេះឈ្មោះថា រតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ បើសេចក្តីនេះជាសច្ចៈសោតកាលបើដូច្នោះ ដោយសច្ចៈនេះ សូមសួស្តីកើតមាន សូមវត្ថុដែលល្អទាំងឡាយមាន ការមិនមានរោគ ការប្រាសចាកឧបទ្រវ ចូរមានដល់សត្វទាំងនេះ ក្នុងសេចក្តីនេះ គប្បីជ្រាបថា បណីតរ័តន៍ បានដល់ ភាពជារតនៈប្រណីត គឺការៈដែលព្រះពុទ្ធជារតនៈប្រណីត ដូចភាពជាខ្លួន ឬព្រោះទាក់ទងនឹងខ្លួន ក្នុងប្រយោគជាដើមយ៉ាងនេះថា **ចក្ខុំ ខោ អានន្ទ សុញ្ញំ អត្តេន វា អត្តនិយេន វា** ម្នាលអានន្ទ ចក្ខុហ្នឹងឯងសូន្យចាកខ្លួន ឬចាកបរិក្ខាររបស់ខ្លួន ។ ពិតហើយ ក្រៅអំពីនេះ ចក្ខុក៏ជាការបដិសេធមិនបានថាជាខ្លួន ឬវត្ថុដែលទាក់ទងជាមួយនឹងខ្លួន ដូច្នោះ ។ ពិតហើយ ដោយប្រការក្រៅអំពីនេះ ព្រះពុទ្ធរមែងមិនសម្រេចជារតនៈ ដ្បិតថា មិនមានក្នុងវត្ថុណា វត្ថុនោះ ក៏មិនសម្រេចជារតនៈ ។ តែបើរតនៈទាក់ទងដោយវិធីណាមួយក៏ដោយ ដែលរាប់ថាជាប្រយោជន៍មាន បុគ្គលធ្វើសេចក្តីគោរពកោតក្រែងជាដើមមានក្នុង

វត្ថុណា ព្រោះវត្ថុនោះ លោកសំដៅយកភាពជារតនៈ ទើបបញ្ញត្តថា **រតន** ដូច្នោះ ទើបព្រះពុទ្ធសម្រេចថា ជារតនៈ ព្រោះរតនៈនោះមាន ។ មួយទៀត បទថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ** គប្បីជ្រាបអត្ថយ៉ាងនេះថា ព្រះពុទ្ធ ជារតនៈ ដោយប្រការដូច្នេះ ។ លុះព្រះដ៏មានព្រះភាគត្រាស់ព្រះគាថា សួស្តី ក៏កើតដល់រាជត្រកូល ភ័យក៏រម្ងាប់ទៅ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នា ព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

ព្រះមានព្រះភាគ កាលត្រាស់វចនៈយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់បទថា **ខយំ វិរាគំ** ជាដើម ។ ក្នុងពាក្យនោះ ព្រោះកិលេសទាំងឡាយ មានរាគៈជាដើមអស់ទៅ ព្រោះធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឬព្រោះហេតុដែលព្រះនិព្វាននោះ លុះកិលេសទាំងនោះអស់ទៅ ដោយរលត់មិនកើត និងព្រោះហេតុដែលព្រះនិព្វាននោះ មិនប្រកបដោយកិលេស មានរាគៈជាដើម ដោយការជួប និងដោយអារម្មណ៍ ឬព្រោះកាលបុគ្គលធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះហើយ កិលេសទាំងឡាយ មានរាគៈជាដើម ក៏អស់ទៅដោយឥតសេសសល់ ប្រាសទៅ ត្រូវកម្ចាត់ទៅ ដូច្នោះ ទើបព្រះនិព្វាន លោកហៅថា **ខយ** ហៅថា **វិរាគ** តែព្រោះនិព្វាននោះ ការកើតមិនប្រាកដ ការវិនាសមិនប្រាកដ ភាពដែលចិត្តប្រែប្រួលមិនមាន ដូច្នោះ ទើបព្រះនិព្វាននោះ លោកពោលថា មិនកើត មិនចាស់ មិនស្លាប់ ហៅថា អមតៈ តែក្នុងទីនេះ លោកហៅថា បណីត ព្រោះអត្ថថា ឧត្តម និងព្រោះអត្ថថា មិនឆ្អែត ។ បទថា **យទជ្ឈគា** បានដល់ សម្រេច ជួប បានធ្វើឲ្យ

ជាក់ច្បាស់ដោយកម្លាំងញាណ របស់ខ្លួននូវព្រះនិព្វាននោះ ។ បទថា **សក្យ-មុនី** បានដល់ ឈ្មោះថា **សក្យ** ព្រោះទ្រង់ជាឱរសរបស់សក្យត្រកូល ។ ឈ្មោះថា **មុនី** ព្រោះប្រកបដោយមោនេយ្យធម៌ មុនី គឺសក្យៈ ឈ្មោះថា **សក្យមុនី** ។ បទថា **សមាហិតោ** បានដល់ ដែលមានចិត្តតាំងមាំហើយក្នុងសមាធិ ដែលជាអរិយមគ្គ ។ បទថា **ន តេន ធម្មេន សមត្ថិ កិញ្ចិ** សេចក្តីថា ធម្មជាតណាមួយដែលស្មើដោយធម៌ ដែលព្រះសក្យមុនីទ្រង់សម្រេចហើយ មានឈ្មោះថា **១យ** ជាដើមនោះ មិនមាន ។ ព្រោះហេតុនោះ ក្នុងព្រះសូត្រដទៃ ព្រះមានព្រះភាគក៏ត្រាស់ជាដើមថា

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌ ( ធម៌ដែលមានបច្ច័យប្រជុំតាក់តែង ) ក្តី ជាអសង្ខតធម៌ ( ធម៌ដែលមិនមានបច្ច័យប្រជុំតាក់តែង ) ក្តី វិរាគៈ ( ការប្រាសចាកតម្រេក ) ដែលជាគ្រឿងញាំញីនូវសេចក្តីស្រវឹង នាំចេញនូវសេចក្តីស្រេកឃ្លាន ដកឡើងនូវសេចក្តីអាល័យ កាត់ផ្តាច់នូវវដ្តៈ អស់តណ្ហា ប្រាសចាកតម្រេក រលត់មិនសេសសល់ មិនមានតណ្ហានេះ ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ។

ព្រះមានព្រះភាគ កាលត្រាស់ភាពដែលព្រះនិព្វានធម៌ ដែលធម៌ដទៃណាមួយប្រៀបធៀបមិនបានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវដែលកើតដល់សត្វទាំងនោះ ទ្រង់អាស្រ័យភាពដែលរតនៈ គឺនិព្វានធម៌ មិន

*មានធម៌ដទៃដូច ដោយគុណទាំងឡាយ គឺភាពជាធម៌ដែលអស់កិលេស ខ្ជាក់ចោលនូវកិលេស ជាអមតធម៌ និងជាបណីតធម៌ ទើបទ្រង់ប្រកបសច្ចវចនៈថា* **ឥទម្បិ ធម្មេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** *រតនៈ គឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងគាថាដើមនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាព្រមទទួលអាជ្ញានៃព្រះគាថានេះឯង ។*

## អធិប្បាយបទថា យម្ពុទ្ធសេដ្ឋោ

*ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដោយគុណនៃនិព្វានធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយព្រះគុណនៃមគ្គធម៌ថា* **យម្ពុទ្ធសេដ្ឋោ** *ជាដើម ។ ក្នុងពាក្យនោះ ឈ្មោះថា* **ពុទ្ធ** *ដោយន័យជាដើមថា ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា* **សេដ្ឋ** *ព្រោះជាបុគ្គលឧត្តម និងគួរសរសើរ ឈ្មោះថា* **ពុទ្ធសេដ្ឋ** *ព្រោះជាអ្នកត្រាស់ដឹង ជាបុគ្គលឧត្តម និងគួរសរសើរ ម្យ៉ាងទៀត ឈ្មោះថា* **ពុទ្ធសេដ្ឋ** *ព្រោះជាបុគ្គលប្រសើរបំផុតក្នុងព្រះពុទ្ធទាំងឡាយ ដែលហៅថា* **អនុពុទ្ធ បច្ចេកពុទ្ធ** *និង* **សុតពុទ្ធ** *។ ព្រះពុទ្ធប្រសើរបំផុតអង្គនោះ ទ្រង់សរសើរ ទ្រង់លើកតម្កើង ប្រកាសសមាធិធម៌ណា ក្នុងបាលីទាំងនោះ ដោយន័យជាដើមថា មគ្គដែលប្រកបដោយអង្គ ៨ ដ៏ក្សេមក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដើរទៅកាន់ព្រះនិព្វាន ឈ្មោះអមតៈ និងដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវ*

សម្មាសមាធិ ដែលឥតទោស ព្រមទាំងបច្ច័យ ព្រមទាំងបរិវារ ... ឈ្មោះថា **សុចិ** បានដល់ ផូរផង់ក្រៃលែង ព្រោះធ្វើនូវការកាត់មន្ទិល គឺកិលេសបានជាសមុច្ឆេទ ។ បទថា **សមាធិមានន្តរិកញ្ញមាហុ** សេចក្តីថា បណ្ឌិតទាំង-ឡាយពោលដល់សមាធិឯណាថា អានន្តរិកសមាធិ គឺសមាធិកើតក្នុងលំដាប់ ព្រោះអោយផលពិតប្រាកដ ក្នុងលំដាប់នៃការបដិបត្តិរបស់ខ្លួន ។ ដរាបណាហាមបង់នូវការកើតផលនៃអានន្តរិកសមាធិនោះ កាលសមាធិដែលជាតួមគ្គកើតឡើងហើយ មិនមាន ដូចលោកពោលថា

> បុគ្គលនេះ ជាអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ
> សោតាបត្តិផល ទុកជាវេលាភ្លើងឆេះកប្បនឹងមាន បើ
> បុគ្គលនេះ មិនទាន់ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល
> ដរាបណា ភ្លើងក៏មិនគប្បីឆេះកប្បដរាបនោះដែរដូច្នេះ ។

បទថា **សមាធិនា តេន សមោ ន វិជ្ជតិ** សេចក្តីថា រូបាវចរសមាធិ ឬអរូបាវចរសមាធិឯណាមួយ ដែលស្មើដោយអនន្តរិកសមាធិដ៏ស្អាត ដែលព្រះសម្ពុទ្ធដ៏ប្រសើរសរសើរហើយនោះ មិនមានឡើយ ព្រោះហេតុអ្វី ព្រោះសត្វកើតក្នុងព្រហ្មលោកនោះៗ ព្រោះអប់រំសមាធិទាំងនោះហើយ ក៏នៅមានការកើតក្នុងអបាយ មាននរកជាដើមទៀតបាន និងព្រោះព្រះអរិយបុគ្គលកាត់នូវការកើតគ្រប់យ៉ាងបានជាសមុច្ឆេទ ព្រោះអប់រំសមាធិ ដែលជាតួអរហត្តនេះហើយ ព្រោះហេតុនោះ ក្នុងសូត្រដទៃ ព្រះមានព្រះភាគក៏ត្រាស់ថា

> ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងប៉ុន្មាន ដែលជាសង្ខតធម៌

មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ គឺការឃើញត្រូវ ១ ។បេ។ តាំងចិត្តមាំត្រូវ ១ នេះ ប្រាកដជាប្រសើរជាង ធម៌ទាំងនោះ ។

ព្រះមានព្រះភាគ កាលត្រាស់កាពដែលអានន្តរិកសមាធិ ដែលសមាធិដទៃៗ ប្រៀបផ្ទឹមមិនបានដូច្នេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យកាពដែលរតនៈ គឺមគ្គធម៌ដែលមិនមានរតនៈដទៃស្មើ ដោយន័យមុននោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ធម្មេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ** រតនៈ គឺព្រះធម៌នេះឯងជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមមានសិរីសួស្តី ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបដោយន័យដែលពោលមកអំពីមុនហើយ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានោះឯង ។

## អធិប្បាយបទថា យេ បុគ្គលា

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈដោយគុណនៃមគ្គធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយសង្ឃគុណថា **យេ បុគ្គលា** ជាដើម ។ ក្នុងពាក្យនោះ សព្ទថា **យេ** ជានិទ្ទេសមិនពិតប្រាកដ ។ បទថា **បុគ្គលា** បានដល់ សត្វទាំងឡាយ ។ សព្ទថា **អដ្ឋ** ជាការកំណត់ចំនួនសត្វទាំងនោះ ។ ពិតហើយ សត្វទាំងនោះមាន ៨ គឺអ្នកបដិបត្តិ ( មគ្គ ) ៤ និងអ្នកតាំងនៅក្នុងផល ៤ ។ បទថា **សតំ បសដ្ឋា** បានដល់ ដែលសប្បុរសគឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ទេវតា និងមនុស្សដទៃសរសើរ

ហើយ ។ ព្រោះហេតុអ្វី ព្រោះប្រកបដោយគុណ មានសីលដែលកើតរួមគ្នាជាដើម ។ សេចក្តីពិត គុណទាំងឡាយរបស់សប្បុរសទាំងនោះ មានសីលសមាធិជាដើមកើតរួមគ្នា ដូចពណ៌ និងក្លិន ជាដើមដែលកើតរួមគ្នារបស់ផ្កាចម្ប៉ា និងផ្កាពិកុលជាដើម ។ ដោយហេតុនោះ ទើបបុគ្គលទាំងនោះ ជាទីស្រឡាញ់ ជាទីពេញចិត្ត គួរសរសើរ របស់សប្បុរសទាំងឡាយ ដូចផ្កាទាំងឡាយដែលដល់ព្រមដោយពណ៌ និងក្លិនជាដើម ជាទីស្រឡាញ់ពេញចិត្តគួរសរសើរនៃទេវតា និងមនុស្សទាំងឡាយ ទើបព្រះមានព្រះភាគត្រាស់ថា

**យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា។**

ម្យ៉ាងទៀត សព្ទថា **យេ** ជានិទ្ទេសមិនពិតប្រាកដ ។ បទថា **បុគ្គលា** បានដល់ សត្វទាំងឡាយ ។ សព្ទថា **អដ្ឋសតំ** ជាការកំណត់ចំនួនសត្វទាំងនោះ ។ ពិតហើយ សត្វទាំងនោះ បានដល់ ព្រះសោតាបន្ន ៣ ពួក គឺឯកពីជី កោលំកោលៈ និងសត្តក្ខត្តុបរមៈ ព្រះសកទាគាមី ៣ ពួក ដែលសម្រេចផលក្នុងកាមភព រូបភព និងអរូបភព ។ ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ មាន ២៤ ពួក ដោយបដិបទា ៤ ។ ព្រះអនាគាមីក្នុងទេវតាជាន់អវិហាមាន ៥ ពួក គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី សសង្ខារបរិនិព្វាយី អសង្ខារបរិនិព្វាយី ឧទ្ធំសោតោអកនិដ្ឋគាមី ។ ព្រះអនាគាមីក្នុងទេវតាជាន់អតប្បា សុទស្សា សុទស្សី ក៏មានមួយជាន់ ៥ ពួកដូចគ្នា ។ ឯក្នុងអកនិដ្ឋកភពមាន ៤ វៀរឧទ្ធំសោតោ រួមជាព្រះអនាគាមី ២៤ ពួក ។ ព្រះអរហន្ត មាន ២ ពួក គឺសុក្ខវិបស្សកៈ និងសមថយានិក ។ ព្រះអរិយ-

បុគ្គលតាំងនៅក្នុងមគ្គ មាន ៤ ពួក រួមជាព្រះអរិយបុគ្គល ៥៤ ពួក ។ ព្រះអរិយបុគ្គលទាំងនោះ គុណនឹងធុរៈ ២ គឺសទ្ធាធុរៈ និងបញ្ញាធុរៈ ជា ១០៨ ពួក ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

បទថា **ចត្តារិ ឯតានិ យុគានិ ហោន្តិ** សេចក្តីថា បុគ្គលដែលទ្រង់លើកឧទ្ទេសដោយពិស្តារថា ព្រះអរិយបុគ្គលទាំងអស់មាន ៨ ពួកក្តី ១០៨ ពួកក្តី ដោយសង្ខេប បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ សោតាបត្តិផល ជា ១ គូយ៉ាងនេះ រហូតដល់ដែលតាំងនៅក្នុងអរហត្តមគ្គ កិត្តិដែលតាំងនៅក្នុងអរហត្តផល រួមជា ១ គូ សរុបទាំងអស់ ៤ គូ ។ សព្ទថា **តេ** ក្នុងបទថា **តេ ទក្ខិណេយ្យា** ជាសព្ទនិទ្ទេស អធិប្បាយកំណត់ពិតប្រាកដនូវបទឧទ្ទេសដែលលើកឡើងមិនពិតប្រាកដ បុគ្គលដែលព្រះមានព្រះភាគត្រាស់ពិស្តារថា មាន ៨ ពួក ឬ ១០៨ ពួក ដោយសង្ខេបមាន ៤ គូ រមែងគួរដល់ទក្ខិណា ហេតុនោះ ទើបឈ្មោះថា **ទក្ខិណេយ្យ** ។ ទេយ្យធម៌ដែលបុគ្គលជឿកម្ម និងផលនៃកម្ម មិនពិចារណាដល់ថា កិត្តិរូបនេះនឹងធ្វើកិច្ចកម្មដែលជាគ្រូពេទ្យ ឬកិច្ចកម្មទទួលបម្រើនេះដល់អញ ដូច្នេះជាដើម ហើយប្រគេន ឈ្មោះថា **ទក្ខិណា** ។ បុគ្គលប្រកបដោយសីលគុណជាដើម និងបុគ្គលទាំងនេះដែលមានសភាពដូច្នោះ ឈ្មោះថា រមែងគួរដល់ទក្ខិណានោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **តេ ទក្ខិណេយ្យា** ។

បទថា **សុគតស្ស សាវកា** សេចក្តីថា ព្រះមានព្រះភាគ ឈ្មោះថា **សុគត** ព្រោះប្រកបដោយការយាងទៅល្អ ព្រោះយាងទៅកាន់ទីដែលល្អ ព្រោះ

យាងទៅដោយល្អ និងព្រោះត្រាស់ល្អ ។ ជាសាវករបស់ព្រះសុគតអង្គនោះ ។ លោកទាំងអស់នោះ ឈ្មោះថា សាវក ព្រោះស្តាប់ព្រះតម្រាស់ ។ បុគ្គលដទៃៗ គប្បីស្តាប់ក៏ពិត តែបុគ្គលនោះស្តាប់ហើយ ក៏មិនធ្វើកិច្ចដែលគួរធ្វើ ។ ឯសាវកទាំងនេះ ស្តាប់ហើយ ធ្វើកិច្ចដែលគួរធ្វើ គឺបដិបត្តិធម៌សមគួរដល់ធម៌ សម្រេចមគ្គផល ព្រោះហេតុនោះ ទើបលោកទាំងនេះត្រាស់ថា សាវក ។

បទថា **ឯតេសុ ទិន្នានិ មហប្ផលានិ** សេចក្តីថា ទានទាំងឡាយសូម្បីតិចតួច ដែលប្រគេនក្នុងសាវករបស់ព្រះតថាគតទាំងនេះ ឈ្មោះថា មានផលច្រើន ព្រោះជាទានដែលចូលដល់ទក្ខិណាវិសុទ្ធិខាងបដិគ្គាហក ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសូត្រដទៃថា

> ម្នាលភិក្ខុទាំងឡាយ សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃជាសាវក របស់ព្រះតថាគត ដែលចាត់ជាគូនៃបុរសមាន ៤ គូ ចាត់ជាបុរសបុគ្គល ( រៀងគ្នា ) មាន ៨ នេះប្រាកដជាប្រសើរជាង សង្ឃ និងគណៈទាំងនោះ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយភិក្ខុដែលតាំងនៅក្នុងមគ្គ តាំងនៅក្នុងផលយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដូចពោលមកមុននោះឯង ។ ពួកអមនុស្សក្នុងសែនកោដិ នាំគ្នាទទួលពុទ្ធ-

អាជ្ញានៃព្រះគាថានេះឯង ។

## អធិប្បាយបទថា យេ សុប្បយុត្តា

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដោយគុណរបស់សង្ឃរតនៈ ដោយភិក្ខុដែលតាំងនៅក្នុងមគ្គ និងតាំងនៅក្នុងផលយ៉ាងនេះហើយ ឥឡូវនេះ ទើបផ្តើមត្រាស់ដោយគុណរបស់ព្រះខីណាសវបុគ្គលទាំងឡាយ ដែលសោយសុខក្នុងផលសមាបត្តិប៉ុណ្ណោះថា **យេ សុប្បយុត្តា** ជាដើម ។ ក្នុងពាក្យនោះ ពាក្យថា **យេ** ជាពាក្យឧទ្ទេសមិនពិតប្រាកដ ។

បទថា **សុប្បយុត្តា** ប្រែថា ប្រកបល្អហើយ អធិប្បាយថា លះអនេសនា គឺការស្វែងរកមិនសមគួរច្រើនយ៉ាង ហើយអាស្រ័យការចិញ្ចឹមជីវិតដោយបរិសុទ្ធ ផ្តើមប្រកបខ្លួនក្នុងវិបស្សនា ។ម្យ៉ាងទៀត បទថា **សុប្បយុត្តា** បានដល់ ប្រកបដោយកាយបយោគ និងវចីបយោគ ដែលបរិសុទ្ធល្អ ។ ទ្រង់សម្តែងសីលក្ខន្ធរបស់ព្រះខីណាសវបុគ្គលទាំងនោះដោយបទថា **សុប្បយុត្តា** នោះ ។ បទថា **មនសា ទឡ្ហេន** បានដល់ ដោយចិត្តដែលធ្ងន់ អធិប្បាយថា ដោយចិត្តដែលប្រកបដោយសមាធិដែលមាំទាំ ។ ទ្រង់សម្តែងសមាធិក្ខន្ធនៃខីណាសវបុគ្គលទាំងនោះដោយបទថា **មនសា ទឡ្ហេន** នោះ ។ បទថា **និក្កាមិនោ** បានដល់ ជាអ្នកមិនអាល័យក្នុងកាយ និងជីវិត មានព្យាយាមចេញចាកកិលេសទាំងពួង ដែលបុគ្គលមានបញ្ញា គឺធុរៈធ្វើហើយ ដោយសេចក្តីព្យាយាម ។ ទ្រង់សម្តែងបញ្ញាក្ខន្ធដែលប្របកបដោយសេចក្តីព្យាយាមរបស់ព្រះខីណាសវបុគ្គលទាំងនោះ ដោយបទថា **និក្កាមិនោ**

នោះ ។ បទថា **គោតមសាសនម្ហិ** បានដល់ ក្នុងសាសនារបស់ព្រះតថាគត ព្រះនាមថាគោតម ដោយគោត្រនោះឯង ។ បទថា **គោតមសាសនម្ហិ** នោះ ទ្រង់សម្តែងថា ពួកបុគ្គលក្រៅសាសនានេះ ដែលធ្វើតបៈដើម្បីបានជាទេវតា មានប្រការផ្សេងៗ ក៏មិនមានសេចក្តីព្យាយាមចេញចាកកិលេសទាំងឡាយ ព្រោះមិនមានគុណ មានការប្រកបយ៉ាងល្អជាដើម ។ ពាក្យថា **តេ** ជាពាក្យអធិប្បាយឧទ្ទេសដែលតាំងទុកមុន ។ ក្នុងពាក្យថា **បត្តិបត្តា** នេះ គុណគួរសម្រេច ហេតុនោះ ទើបឈ្មោះថា **បត្តិ** ។ នូវបុគ្គលដែលសម្រេចហើយ ជាបុគ្គលក្សេម ផុតចាកយោគៈដោយឥតសេសសល់ ឈ្មោះថា **បត្តញ្ញា** នោះ ។ ពាក្យនេះ ជាឈ្មោះនៃអរហត្តផល ។ បុគ្គលសម្រេចគុណ ដែលគួរសម្រេចនោះ ហេតុនោះ ទើបឈ្មោះថា **បត្តិបត្តា** ។ បទថា **អមតំ** បានដល់ ព្រះនិព្វាន ។ បទថា **វិគយ្ហ** បានដល់ ចូលដល់ដោយអារម្មណ៍ ។ បទថា **លទ្ធា** ប្រែថា បានហើយ ។ បទថា **មុធា** បានដល់ ដោយមិនមានតម្លៃ គឺមិនធ្វើតម្លៃត្រឹមតែមួយកាកណិក ។ បទថា **និព្វុតឹ** បានដល់ ផលសមាបត្តិដែលរម្ងាប់សេចក្តីក្រវល់ក្រវាយដោយអំណាចកិលេសហើយ ។ បទថា **ភុញ្ជមានា** បានដល់ សោយ ។ លោកអធិប្បាយដូចម្តេច ។ លោកអធិប្បាយថា ពួកជនណា ក្នុងសាសនា របស់ព្រះគោតមនេះ ឈ្មោះថា ប្រកបល្អហើយ ព្រោះដល់ព្រមដោយសីល ឈ្មោះថា មានចិត្តធ្ងន់ ព្រោះដល់ព្រមដោយសមាធិ ឈ្មោះថា មិនមានសេចក្តីអាល័យ ព្រោះដល់ព្រមដោយបញ្ញា ជនទាំងនោះក៏ចូលដល់អមតៈ ដោយសម្មាបដិបត្តិនេះ ជាបុគ្គល

បានទទេ សោយ នូវការរលត់ ដែលយល់បានថាជាផលសមាបត្តិ ឈ្មោះថាជាបុគ្គលសម្រេចគុណដែលគួរសម្រេច ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយព្រះខីណាសវបុគ្គលដែលសោយផលសមាបត្តិយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ សេចក្តីនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលអំពីមុនហើយ ពួកអមនុស្សក្នុងសែនកោដិចក្រវាលក៏នាំគ្នាព្រមទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## អធិប្បាយបទថា យថិន្ទខីលោ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ដោយខីណាសវបុគ្គលយ៉ាងនេះហើយ ទ្រង់ផ្តើមត្រាស់ដោយគុណនៃព្រះសោតាបន្នប៉ុណ្ណោះថា **យថិន្ទខីលោ** ជាដើម ។ ក្នុងពាក្យនោះ បទថា **យថា** ជាពាក្យឧបមា ។ ពាក្យថា **ឥន្ទខីលោ** នេះ ជាឈ្មោះរបស់សសរខឿម ដែលគេបោះចូលដី ៨ ហត្ថ ឬ ១០ ហត្ថ ខាងក្នុងធរណីទ្វារ ដើម្បីការពារទ្វារព្រះនគរ ។ បទថា **បឋវឹ** ប្រែថា ផែនដី ។ បទថា **សិតោ** បានដល់ចូលទៅអាស្រ័យខាងក្នុង ។ បទថា **សិយា** ប្រែថា គប្បីកើត ។ បទថា **ចតុព្ភិ វាតេហិ** ប្រែថា ដែលខ្យល់បក់មកអំពីទិសទាំង ៤ ។ បទថា **អសម្បកម្បិយោ** បានដល់ មិនអាចឲ្យញាប់ញ័រ គឺមិនអាចឲ្យកម្រើកបាន ។ បទថា **តថូបមំ** ប្រែថា ដូច្នោះ ដូចគ្នា ។ បទថា **សប្បុរិសំ** បានដល់

បុរសឧត្តម ។ បទថា **វទាមិ** ប្រែថា ពោល ។ បទថា **យោ អរិយសច្ចានិ អវេច្ច បស្សតិ** ប្រែថា បុគ្គលណាពិចារណាឃើញអរិយសច្ច ៤ ដោយបញ្ញា ។ ក្នុងសេចក្តីនោះ អរិយសច្ចទាំងឡាយ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងកុមារបញ្ហា និងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

ឯសេចក្តីសង្ខេបក្នុងសេចក្តីនេះ មានដូច្នេះ ដូចសសរខឿន ដែលលិចចូលទៅក្នុងដីដ៏ជ្រៅ ខ្យល់បក់មកអំពីទិសទាំង ៤ គប្បីឲ្យញាប់ញ័រមិនបានយ៉ាងណា សប្បុរសណា ឃើញអរិយសច្ច តថាគតពោលសប្បុរសនេះឧបមាដូច្នោះដូចគ្នា ព្រោះហេតុអ្វី ព្រោះសប្បុរសនោះ ជាបុគ្គលដែលខ្យល់គឺវាទៈរបស់តិរ្ថិយទាំងពួងធ្វើឲ្យកម្រើកមិនបាន គឺបុគ្គលណាក៏មិនអាចឲ្យកម្រើក ឬឃាតចាកទស្សនៈនោះបាន ដូចសសរខឿនដែលខ្យល់បក់មកអំពីទិសទាំង ៤ ធ្វើឲ្យញាប់ញ័រមិនបាន ដូច្នោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងសូត្រដទៃថា

> ម្នាលភិក្ខុទាំងឡាយ ដូចសសរដែកក្តី សសរគោលក្តី ដែលមានរណ្តៅដ៏ជ្រៅ គេដាំស៊ប់សួនល្អឥតមានកម្រើក ឥតមានញាប់ញ័រ បើទុកជាភ្លៀងលាយដោយខ្យល់ដ៏ខ្លាំងមកអំពីទិសខាងកើត ក៏មិនធ្វើសសរនោះឲ្យកម្រើក មិនធ្វើឲ្យរញ្ជួយ មិនធ្វើឲ្យញាប់ញ័រ បើទុកជាខ្យល់បក់មកអំពីទិសខាងលិចក្តី ។បេ។ អំពីខាងជើងក្តី ភ្លៀងដែលលាយដោយខ្យល់ដ៏ខ្លាំងមកអំពីទិសខាងត្បូងក្តី ក៏មិនធ្វើ

ឲ្យសសរនោះ កម្រើករញ្ជួយញាប់ញ័រឡើយ ។ ដំណើរ
នោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះរណ្តៅ
ជ្រៅ ព្រោះសសរគេដាំស៊ប់សួនល្អ យ៉ាងណាមិញ ។
ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ឯណា
នីមួយ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។
ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទា ជាដំណើរទៅ
កាន់ទីរម្ងត់ទុក្ខ សមណៈ ឬព្រាហ្មណ៍ទាំងនោះ មិន
ក្រឡេកមើលមុខសមណៈ ឬព្រាហ្មណ៍ដទៃថា លោក
ដ៏ចម្រើននេះ កាលបើដឹង ក៏ដឹងដោយពិត កាលបើ
ឃើញ ក៏ឃើញដោយពិត ។ ដំណើរនោះ ព្រោះហេតុ
អ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបានឃើញនូវអរិយ-
សច្ច ៤ ដោយប្រពៃ ។

ព្រះមានព្រះភាគ កាលត្រាស់គុណនៃសង្ឃរតនៈ ដោយអំណាចព្រះ-សោតាបន្នដែលប្រចក្សដល់មនុស្សជាច្រើនយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ ។ អត្ថនៃសច្ចវចនៈនោះគប្បីជ្រាបតាមន័យដែលពោលមកមុនហើយនោះឯង ពួកអមនុស្សក្នុងសែនកោដិចក្រ-វាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

# អធិប្បាយបទថា យេ អរិយសច្ចានិ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដែលមានសង្ឃរតនៈជាទីតាំង ដោយគុណរបស់ព្រះសោតាបន្ន ដោយមិនប្លែកគ្នាយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្ដើមត្រាស់ថា **យេ អរិយសច្ចានិ** ជាដើម ដោយគុណរបស់ព្រះ-សោតាបន្នសត្តក្ខត្តុបរមៈ និងចូឡសោតាបន្នទាំងអស់ បណ្ដាព្រះសោតាបន្ន ៣ ប្រភេទ គឺឯកពីជី កោលំកោលៈ សត្តក្ខត្តុបរមៈ ដូចព្រះតម្រាស់ថា

បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ បុគ្គលនោះកើតក្នុងភព ជារបស់មនុស្សតែម្ដងទៀត ហើយធ្វើនូវទីបំផុតនៃវដ្ដទុក្ខ នេះហៅថា បុគ្គលជាឯកពីជី ។

បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ ស្ទុះទៅ អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ហើយធ្វើនូវទីបំផុតនៃវដ្ដទុក្ខ នេះហៅថា បុគ្គលជាកោលំកោល ។

បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ ស្ទុះទៅ អន្ទោលទៅក្នុង ទេវតា និងមនុស្សអស់វារៈ

៧ ជាតិ ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គល
ជាសត្តក្ខត្តុំបរមៈ[១] ។

ក្នុងពាក្យនោះ ពាក្យថា **យេ អរិយសច្ចានិ** នេះ មានន័យដូចពោលមក
ហើយនោះឯង ។ បទថា **វិភាវយន្តិ** បានដល់ កម្ចាត់ងងឹត គឺកិលេស
ដែលបិទបាំងសច្ចៈហើយ ធ្វើឲ្យជាក់ច្បាស់ប្រាកដដល់ខ្លួនដោយពន្លឺនៃបញ្ញា ។
បទថា **គម្ភីរបញ្ញេន** បានដល់ ដែលព្រះមានព្រះភាគអ្នកមានបញ្ញា មាន
កម្លាំង ដែលបុគ្គលណាម្នាក់ មិនបានដោយញាណនៃលោកនេះ មួយអន្លើ
ដោយទេវលោក ដោយព្រះបញ្ញាមិនមានប្រមាណ លោកអធិប្បាយថា
បុគ្គលដែលជាសព្វញ្ញូ ។

បទថា **សុទេសិតានិ** បានដល់ ទ្រង់សម្តែងដោយល្អ ដោយន័យនោះៗ
មានសមាសន័យ អព្យាសន័យ សាកល្យន័យ វេកល្យន័យជាដើម ។ បទ
ថា **កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា** សេចក្តីថា បុគ្គលទាំងឡាយ ដែល
អប់រំអរិយសច្ចហើយយ៉ាងនោះ អាស្រ័យឋានៈនៃសេចក្តីប្រមាទ មានភាព
ជាទេវរាជ និងភាពជាស្តេចចក្រពត្តិជាដើម ជាអ្នកប្រមាទពេញបន្ទុកក៏ពិត តែ
នាមរូបណាគប្បីតាំងនៅ ព្រោះវិញ្ញាណដែលសោតាបត្តិមគ្គញាណតាក់តែង
រលត់ទៅ ហើយកើតក្នុងសង្សារវដ្តដែលមិនមានទីបំផុតខាងដើម កើតតែ ៧
ភព ក៏មិនកាន់យកភពទី ៨ ព្រោះនាមរូបនោះរលត់ទៅ ព្រោះតាំងនៅមិនបាន

---

១- បិដកខ្មែរ លោកសម្តែងសត្តក្ខត្តុំបរមបុគ្គលនេះមុនហើយ ទើបសម្តែងកោលំកោល-
បុគ្គល និងឯកពីជីបុគ្គលឯក្រោយ ។

*តែក្នុងភពទី ៧ នោះឯង ក៏នឹងផ្ដើមវិបស្សនា ហើយសម្រេចអរហត្ត ។*

*ព្រះមានព្រះភាគ កាលត្រាស់គុណសង្ឃរតនៈ ដោយព្រះសោតាបន្ន ដែលជាសត្តក្ខត្តុបរមៈយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា* **ឥទម្បិ សង្ឃេ រតនំ បណីតំ** *នេះ ក៏ជារតនៈ ដ៏ប្រណីតក្នុងព្រះសង្ឃ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោល មកអំពីមុនហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំ គ្នាទទួលព្រះពុទ្ធអាជ្ញានៃគាថានេះឯង ។*

# អធិប្បាយ បទថា សហាវស្ស

*ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ដោយ គុណ គឺការមិនកាន់យកភពទី ៨ របស់ព្រះសោតាបន្នសត្តក្ខត្តុបរមយ៉ាងនេះ ហើយ ឥឡូវនេះ នឹងផ្ដើមត្រាស់ថា* **សហាវស្ស** *ជាដើម ដោយគុណរបស់ ព្រះសោតាបន្នសត្តក្ខត្តុបរមៈនោះឯង សូម្បីដល់ ៧ ភពដែលប្លែកពីបុគ្គល ដទៃៗ ដែលមិនទាន់លះការកាន់យកភពបាន ។ ក្នុងពាក្យនោះ បទថា* **សហាវ** *ប្រែថា ព្រមជាមួយ ។ បទថា* **អស្ស** *បានដល់ បណ្ដាព្រះសោតាបន្នដែល ត្រាស់ថា ព្រះសោតាបន្នទាំងនោះ មិនកាន់យកភពទី ៨ ភពណាមួយ ។ បទ ថា* **ទស្សនសម្បទាយ** *បានដល់ ដោយការដល់ព្រមនៃសោតាបត្តិមគ្គ ។ ពិតហើយ សោតាបត្តិមគ្គ ឃើញព្រះនិព្វានហើយ ទើបលោកហៅថា ទស្សនៈ ព្រោះឃើញព្រះនិព្វានមុនធម៌ទាំងពួង ដោយការដល់ព្រមនៃកិច្ចដែលគួរធ្វើ ។ ការប្រាកដនៃសោតាបត្តិមគ្គនោះក្នុងខ្លួន ឈ្មោះថា* **ទស្សនសម្បទា** *។ មួយ*

*អន្ទើដោយទស្សនសម្បទានោះឯង ។ សព្ទថា* **សុ** *ក្នុងពាក្យថា* **តយស្សុ ធម្មា ជហិតា ភវន្តិ** *នេះ ជានិបាត ចុះក្នុងអត្ថថា គ្រាន់តែធ្វើបទឲ្យពេញ ដូចក្នុងប្រយោគជាដើមថា* **ឥទំ សុ មេ សារិបុត្ត មហាវិកដភោជនស្មឹ ហោតិ** *ម្នាលសារីបុត្ត នេះឯងជាវត្តខាងភោជនយ៉ាងចម្លែកធំរបស់តថាគត ។ ក្នុងសេចក្តីនេះ មានអត្ថយ៉ាងនេះថា ព្រោះធម្មតាសំយោជនៈ ៣ ខាងក្រោម ឈ្មោះថា ព្រះសោតាបន្ន លះបានហើយ ឈ្មោះថា លះហើយ មួយអន្ទើ ដោយទស្សនសម្បទារបស់ព្រះសោតាបន្ននោះ ។*

*ឥឡូវនេះ ដើម្បីទ្រង់សម្តែងធម៌ដែលព្រះសោតាបន្នលះបានហើយ ទើបត្រាស់ថា* **សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច សីលព្វតំ វាបិ យទត្ថិ កិញ្ចិ** *ក្នុងធម៌ ៣ យ៉ាងនោះ កាលកាយនៅមានទិដ្ឋិ មានវត្ថុ ២០ ក្នុងកាយដែលហៅថា ឧបាទានក្ខន្ធ ៥ ដែលមានឈ្មោះថា សក្កាយទិដ្ឋិ ឬថា កាលកាយនៅមាន ទិដ្ឋិ គឺការឃើញក្នុងកាយនោះ ( ក៏មាន ) ព្រោះហេតុនោះ ឈ្មោះថា សក្កាយទិដ្ឋិ អធិប្បាយថា ទិដ្ឋិដែលមាននៅក្នុងកាយ តាមដែលពោលមកហើយ ឬទិដ្ឋិ ការឃើញក្នុងកាយដែលមាននោះឯង ព្រោះហេតុនោះ ឈ្មោះថា សក្កាយទិដ្ឋិ អធិប្បាយថា ទិដ្ឋិក្នុងកាយតាមដែលពោលមកហើយ ដែលប្រព្រឹត្តទៅយ៉ាងនេះថា* **អត្តា** *ពោល គឺរូបជាដើម ។ ទិដ្ឋិទាំងពួងនោះ ឈ្មោះថា ព្រះសោតាបន្នលះទាំងអស់ហើយ ព្រោះលះសក្កាយទិដ្ឋិនោះបាន ហើយ ដ្បិតថា សក្កាយទិដ្ឋិនោះជាមូលរបស់ធម៌ គឺកិលេសទាំងនោះ បញ្ញា លោកហៅថា* **ចិកិច្ឆិត** *ព្រោះរម្ងាប់ព្យាធិ គឺកិលេសទាំងពួង ។* **បញ្ញា–**

**ចិកិច្ឆិត** គឺបញ្ហាដោះស្រាយនោះទៅប្រាសហើយចាកវត្ថុនេះ ឬវត្ថុនេះទៅប្រាសហើយចាកបញ្ហាចិកិច្ឆិតនោះ ហេតុនោះ ទើបឈ្មោះថា **វិចិកិច្ឆិត** ។ ពាក្យនេះ ជាឈ្មោះនៃសេចក្ដីសង្ស័យដែលមានវត្ថុ ៨ ដែលត្រាស់ដោយន័យជាដើមថា សង្ស័យក្នុងព្រះសាស្ដា ។ ការសង្ស័យទាំងអស់ ឈ្មោះថា លះបានហើយ ព្រោះលះវិចិកិច្ឆានោះបានហើយ ។ ពិតហើយ ការសង្ស័យនោះជាមូលនៃកិលេសទាំងនោះ ។ សីលផ្សេងៗ មានគោសីល កុក្កុរសីល និងវត្ត មានគោវត្ត និងកុក្កុរវត្តជាដើម ដែលមកក្នុងបាលីបទេសជាដើមយ៉ាងនេះថា សមណព្រាហ្មណ៍ខាងក្រៅព្រះសាសនានេះ ប្រកាន់នូវការបរិសុទ្ធដោយសីល បរិសុទ្ធដោយវត្ត ហៅថា **សីលវត្ត** ។ តបៈដើម្បីបានជាទេវតា មានការអាក្រាតកាយ មានក្បាលត្រងោលជាដើមគ្រប់យ៉ាងក៏ឈ្មោះថា លះបានហើយ ព្រោះលះសីលវត្តនោះ ។ ពិតហើយ សីលវត្តនោះ ជាមូលរបស់តបៈនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ខាងចុងគាថាទាំងអស់ថា **យទត្ថិ កិញ្ចិ** ដែលប្រែថា ឯណាមួយមាន ។ គប្បីជ្រាបថា បណ្ដាសំយោជនៈខាងក្រោម ៣ នោះ សក្កាយទិដ្ឋិ លះបានក៏ដោយការដល់ព្រមដោយការឃើញទុក្ខ វិចិកិច្ឆា លះបានដោយការដល់ព្រមនៃការឃើញសមុទយៈ សីលព្វត លះបានដោយការដល់ព្រមនៃការឃើញមគ្គ និងការឃើញព្រះនិព្វាន ។

## អធិប្បាយបទថា ចតូហបាយេហិ

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការលះកិលេសវដ្ដរបស់ព្រះសោតា-

បន្ទនោះយ៉ាងនេះហើយ ឥឡូវនេះ កាលកិលេសវដ្តនោះមាន វិបាកវដ្តណា គប្បីមាន កាលទ្រង់សម្តែងការលះវិបាកវដ្តនោះ ព្រោះលះកិលេសវដ្តនោះបាន ទើបត្រាស់ថា **ចតូហបាយេហិ ច វិប្បមុត្តោ** ក្នុងពាក្យនោះ ឈ្មោះថា អបាយ មាន ៤ គឺនិរយៈ តិរច្ឆាន បិត្តិវិស័យ និងអសុរកាយ អធិប្បាយថា ព្រះសោតាបន្ននោះ សូម្បីរស់ ៧ ភព ក៏ផុតចាកអបាយទាំង ៤ នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការលះវិបាកវដ្តរបស់ព្រះសោតាបន្ននោះយ៉ាងនេះហើយ ឥឡូវនេះ កម្មវដ្តណា ជាឫសគល់នៃវិបាកវដ្តនោះ កាលទ្រង់សម្តែងការលះកម្មវដ្តនោះ ទើបត្រាស់ថា **ច ឆាភិឋានានិ អភព្វោ កាតុំ** និងមិនគួរធ្វើអភិដ្ឋាន ៦ ។ ក្នុងពាក្យនោះ បទថា **អភិឋានានិ** បានដល់ឋានៈដែលគ្រោតគ្រាត ។ ព្រះសោតាបន្ននោះ មិនគួរធ្វើអភិដ្ឋាននោះ ។ អភិដ្ឋានទាំងនោះ គប្បីជ្រាបថា ជាកម្ម គឺមាតុឃាត បិតុឃាត អរហន្តឃាត លោហិតុប្បាទ សង្ឃភេទ និងអញ្ញសត្ថារុទ្ទេស គឺរាប់អានសាស្តាដទៃ មានបូលតិរិយជាដើម ដែលព្រះមានព្រះភាគត្រាស់នៅក្នុងឯកនិបាត អង្គុត្តរ-និកាយ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីផ្តាច់បង់ជីវិតមាតា ដោយហេតុឯណា ហេតុនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ។ ពិតហើយ អរិយសាវកដែលដល់ព្រមដោយទិដ្ឋិ មិនគប្បីផ្តាច់ជីវិតសូម្បីតែស្រមោចខ្មៅ ស្រមោចក្រហមក៏ពិត តែអភិដ្ឋាន ៦ នោះ ព្រះមានព្រះភាគត្រាស់ ក៏ដើម្បីតិះដៀលភាវៈនៃបុថុជ្ជន ។ ពិតហើយ បុថុជ្ជនរមែងធ្វើអភិដ្ឋានដែលមានទោសច្រើនយ៉ាងនេះបាន ក៏ព្រោះ

មិនដល់ព្រមដោយទិដ្ឋិ ឯព្រះសោតាបន្ន ដែលដល់ព្រមដោយទិដ្ឋិ មិនគួរធ្វើអភិដ្ឋានទាំងនោះ ។ ឯការប្រើ **អភព្វ** សព្ទ ក្នុងទីនេះ ក៏ដើម្បីសម្ដែងថា ព្រះសោតាបន្នមិនធ្វើសូម្បីក្នុងភពដទៃ ។ សេចក្ដីពិត ក្នុងភពដទៃ ព្រះសោតាបន្នសូម្បីមិនដឹងថា ខ្លួនជាអរិយសាវក ដោយធម្មតានោះ ក៏មិនធ្វើបាប ៦ យ៉ាងនោះ ឬធ្វើវៀរ ៥ មានបាណាតិបាតជាដើម ឬដល់នូវឋានៈ ៦ មួយអន្ទើដោយការរាប់អានសាសនាដទៃ ដែលអាចារ្យពួកខ្លះសំដៅដល់ ហើយពោលថា **ឆ ចាភិឋានានិ** ដូច្នេះក៏មាន ព្រះអរិយសាវក និងក្មេងអ្នកស្រុកដែលចាប់ត្រីជាដើម ក៏ជាឧបមាក្នុងសេចក្ដីនេះ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់អរិយសាវកដែលនៅមានភព ៧ ដែលជាសង្ឃរតនៈ ដោយគុណប្លែកពីបុគ្គលដទៃៗ ដែលលះការកាន់យកនូវភពមិនទាន់បាន យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃនោះ ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបដោយន័យដែលពោលមកអំពីមុនហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## អធិប្បាយ បទថា កិញ្ចាបិ សោ

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាដើមជាទីតាំង ដោយប្លែកពីបុគ្គលដទៃ ដែលមិនទាន់លះការកាន់យកភពបាននៃព្រះសោតាបន្ន សូម្បីសល់ ៧ ភព យ៉ាងនេះហើយ ឥឡូវនេះ ព្រះសោតា-

បន្នដែលដល់ព្រមដោយទស្សនៈ មិនមែនមិនគួរធ្វើអភិដ្ឋាន ៦ យ៉ាងប៉ុណ្ណោះទេ សូម្បីបាបកម្មតិចតួចណាមួយ ក៏មិនគួរធ្វើដែរ ហើយបិទបាំងបាបកម្មនោះដូច្នោះ ទើបទ្រង់ផ្តើមត្រាស់ដោយគុណ គឺព្រះសោតាបន្នដែលដល់ព្រមដោយទស្សនៈ សូម្បីនៅដោយសេចក្តីប្រមាទ ក៏មិនមានការបិទបាំងកម្មដែលធ្វើមកហើយថា **កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ** ប្រសិនបើសោតាបន្នបុគ្គលនោះ ធ្វើបាបកម្ម ... ដូច្នេះ ។

ព្រះតម្រាស់នោះ មានអត្ថដូច្នេះ សូម្បីព្រះសោតាបន្ននោះដល់ព្រមដោយទស្សនៈ អាស្រ័យការនៅដោយសេចក្តីប្រមាទ មិនមានស្មារតី វៀរសិក្ខាបទដែលជាលោកវជ្ជ ដែលព្រះមានព្រះភាគ ទ្រង់សំដៅដល់ការតាំងចិត្តកន្លងល្មើស ត្រាស់ថា សិក្ខាបទណា តថាគតបញ្ញត្តដល់សាវកទាំងឡាយ សាវកទាំងឡាយ រមែងមិនកន្លងល្មើសសិក្ខាបទនោះរបស់តថាគត ព្រោះហេតុនៃជីវិត ដូច្នេះ រមែងធ្វើបាបកម្មដទៃ ផ្លូវកាយ ដែលព្រះពុទ្ធទ្រង់រង្កៀស ពោលគឺការកន្លងល្មើសសិក្ខាបទដែលជាបណ្ណត្តិវជ្ជ មានកុដិការសិក្ខាបទ និងសហសេយ្យសិក្ខាបទជាដើមក្តី ធ្វើបាបកម្មផ្លូវវាចា មានបង្រៀនធម៌ដល់អនុបសម្បន្នដែលពោលព្រមគ្នាក្តី សម្តែងធម៌ដល់មាតុគ្រាមលើស ៥-៦ ម៉ាត់ក្តី ការពោលរាយមាយក្តី ពោលពាក្យគ្រោតគ្រាតជាដើមក្តី ឬធ្វើបាបកម្មផ្លូវចិត្ត មិនថា ក្នុងទីណា គឺការធ្វើឲ្យកើត លោភៈ ទោសៈ ការត្រេកអរក្នុងមាសជាដើម ការមិនពិចារណាក្នុងការបរិភោគចីវរជាដើមក្តី ព្រះសោតាបន្ននោះ ក៏មិនបិទបាំងបាបកម្មនោះ គឺព្រះសោតាបន្ននោះដឹងថា កម្មនេះមិន

សមគួរ មិនគួរធ្វើ មិនបិទបាំងបាបកម្មនោះសូម្បីតែមួយរំពេច ក្នុងរំពេចនោះឯង ក៏ធ្វើឲ្យជាក់ច្បាស់ គឺបើកផ្ទារក្នុងព្រះសាស្តា ឬក្នុងសព្រហ្មចារីដែលជាវិញ្ញូជន ហើយសម្តែងតាមធម៌ ឬរាំងប្រយ័ត្នក្នុងសិក្ខាបទដែលគួរសង្រួមយ៉ាងនេះថា ខ្ញុំនឹងមិនធ្វើទៀតឡើយ ។ ព្រោះហេតុអ្វី ព្រោះថា ព្រះមានព្រះភាគ ត្រាស់ដល់ភាពដែលព្រះសោតាបន្នដែលឃើញបទ គឺព្រះនិព្វានហើយ មិនគួរបិទបាំងបាបកម្ម អធិប្បាយថា ព្រះមានព្រះភាគត្រាស់ដល់ភាពដែលបុគ្គលអ្នកឃើញបទ គឺព្រះនិព្វាន ដែលដល់ព្រមដោយទស្សនៈដែលមិនគួរធ្វើបាបកម្មបែបនោះ ហើយបិទបាំងនូវបាបកម្មនោះ សេចក្តីនេះទ្រង់ត្រាស់ដូចម្តេច ទ្រង់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ដូចជាកុមារក្មេង ជាកូនខ្ចីនៅដេកផ្ងារនៅឡើយ ប៉ះពាល់រងើកភ្លើងដោយដៃក្តី ដោយជើងក្តី ក៏ដកមកវិញជាប្រញាប់ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ធម្មតារបស់បុគ្គល ដែលប្រកបដោយទិដ្ឋិ គឺការចេញចាកអាបត្តិមានសភាពយ៉ាងណា ភិក្ខុក៏គង់ត្រូវអាបត្តិមានសភាពយ៉ាងនោះខ្លះដែរ តែថា ភិក្ខុនោះសម្តែង បើក ធ្វើឲ្យច្បាស់ឡើង នូវអាបត្តិនោះ ក្នុងសម្នាក់សាស្តា ឬក្នុងពួកសព្រហ្មចារីបុគ្គល ជាអ្នកប្រាជ្ញដោយឆាប់រហ័ស លុះសម្តែង បើក ធ្វើឲ្យច្បាស់ឡើងហើយ ក៏ដល់នូវកិរិយាសង្រួមតទៅ យ៉ាងនោះដែរ ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយគុណរបស់ព្រះសោតាបន្ន សូម្បីទៅដោយសេចក្តីប្រមាទ តែក៏ដល់ព្រមដោយទស្សនៈ មិនមានការបិទបាំងបាបកម្ម ដែលធ្វើហើយយ៉ាងនេះ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ សង្ឃេ រតនំ បណីតំ** ដូច្នេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកអំពីមុនហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាលក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## អធិប្បាយបទថា វនប្បគុម្ពេ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងដោយប្រការនៃគុណទាំងនោះរបស់បុគ្គលទាំងឡាយ ទាក់ទងក្នុងព្រះសង្ឃយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគកាលទ្រង់សម្តែងគុណព្រះរតនត្រ័យ ដែលទ្រង់សម្តែងយ៉ាងសង្ខេបក្នុងទីនេះ និងទ្រង់សម្តែងពិស្តារក្នុងទីដទៃ ទើបទ្រង់ផ្តើមត្រាស់សច្ចវចនៈ មានព្រះពុទ្ធវចនៈជាទីតាំងទៀតថា **វនប្បគុម្ពេ យថា ផុស្សិតគ្គេ** ក្នុងសច្ចវចនៈនោះ ក្រុមដើមឈើដែលកំណត់ទីតាំងនៅប្រចាំជិតៗ គ្នា ឈ្មោះថា **វន** ។ គុម្ពឈើដែលរីកចម្រើនដោយឫស ខ្លឹម ក្រមរ មែក និងស្លឹក ឈ្មោះថា **បគុម្ព** ។ គុម្ពឈើដែលរីកចម្រើនរបស់ព្រៃ ឬក្នុងព្រៃ ឈ្មោះថា **វនប្បគុម្ពោ** ។ គុម្ពឈើដែលដុះដាលក្នុងព្រៃនោះ លោកហៅថា **វនប្បគុម្ពេ** កាលបើដូច្នោះ ក៏ហៅបានថា **វនសណ្ឌ** ប្រែថា ដងព្រៃ ដូចក្នុងប្រយោគជាដើមថា **អត្ថិ សវិតក្ក**

**សវិចារេ អត្ថិ អវិតក្កវិចារមត្តេ សុខេ ទុក្ខេ ជីវេ** ប្រកបដោយវិតក្កក៏មាន ប្រកបដោយវិចារៈក៏មាន មិនមានវិតក្ក មានវិចារៈក៏មាន សុខ ទុក្ខ ជីវៈ ដូច្នេះ ។ ពាក្យថា **យថា** ជាពាក្យឧបមា ។ ត្រួយរបស់គុម្ពឈើនោះ ត្រសុំត្រសាយហើយ ហេតុនោះ ទើបគុម្ពឈើនោះ ឈ្មោះថា មានត្រួយរីកហើយ ។ អធិប្បាយថា ផ្កាដែលកើតឯង ត្រង់មែកធំ-តូច ។ ផ្កានោះ លោកពោលថា មានត្រួយរីកហើយ តាមន័យដែលពោលមកអំពីមុនហើយនោះឯង ។ បទថា **គិម្ហានមាសេ បឋមស្មឹ គិម្ហេ** សេចក្ដីថា ក្នុងខែ ១ នៃខែក្នុងគិម្ហរដូវ ៤ ខែ បើសួរថា ក្នុងខែណា ឆ្លើយថា ក្នុងខែខាងដើមនៃគិម្ហន្តរដូវ អធិប្បាយថា ក្នុងខែចេត្រ ។ ពិតហើយ ចិត្ត មាសានោះ លោកហៅថា ដើមគិម្ហន្តរដូវ និងហៅថា **ពាលវស្សានោ** គឺវស្សានរដូវយ៉ាងទន់ ។ ពាក្យក្រៅអំពីនោះ ប្រាកដច្បាស់ដោយអត្ថនៃបទហើយនោះឯង ។

ឯការសេរុបសេចក្ដីក្នុងទីនេះ មានដូច្នេះថា គុម្ពឈើដែលដុះដាល លូតលាស់ ហៅថា គុម្ពឈើជំទង់ ត្រួយ មែក មានផ្ការីកស្គុសស្គាយ រមែងស្រស់ត្រកាលពន់ពេក ក្នុងព្រៃដែលក្រាស់ដោយដើមឈើច្រើនប្រភេទ ក្នុងពាល-វស្សាន ដែលឈ្មោះថា ខែខាងដើមនៃគិម្ហរដូវ យ៉ាងណា ព្រះមានព្រះភាគទ្រង់មិនមែនសម្ដែងព្រោះឃើញដល់លាភ មិនមែនទ្រង់សម្ដែងព្រោះឃើញដល់សក្ការៈជាដើមឡើយ តែបើមានព្រះហឫទ័យដែលព្រះមហាករុណា ឲ្យទ្រង់មានឧស្សាហ៍តែម្យ៉ាង ទ្រង់បានសម្ដែងព្រះបរិយត្តិធម៌ដ៏ប្រសើរ ដែលឈ្មោះថា មានឧបមាយ៉ាងនោះ ព្រោះស្រស់ត្រកាលក្រៃលែងដោយផ្កា គឺ

ប្រភេទនៃអត្ថច្រើនប្រការ មានខន្ធ អាយតនៈជាដើមក៏មាន មានសតិប្បដ្ឋាន និងសម្មប្បធានជាដើមក៏មាន មានសីលក្ខន្ធ សមាធិក្ខន្ធជាដើមក៏មាន ឈ្មោះថា ឲ្យដល់នូវព្រះនិព្វាន ព្រោះសម្តែងមគ្គដែលឲ្យដល់ព្រះនិព្វាន ដើម្បីជាប្រយោជន៍ក្រៃលែងដល់សត្វទាំងឡាយដូច្នោះដូចគ្នា ។ ឯក្នុងពាក្យថា **បរមំ ហិតាយ** លោកចុះនិគ្គហិតដើម្បីងាយស្រួលដល់ការចងគាថា ។ ឯអត្ថមានដូច្នេះថា ទ្រង់បានសម្តែងដើម្បីជាប្រយោជន៍ក្រៃលែង គឺដើម្បីព្រះនិព្វាន ។

ព្រះមានព្រះភាគ កាលត្រាស់ព្រះបរិយត្តិធម៌ ដែលដូចគុម្ពឈើដ៏ស្រស់ស្អាតក្នុងព្រៃ មានត្រួយ មែក ផ្ការីកស្គុសស្គាយយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យព្រះបរិយត្តិធម៌នេះឯង ទើបទ្រង់ប្រកបសច្ចវចនៈ ដែលមានពុទ្ធរតនៈជាទីតាំងថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ** នេះ ក៏ជារតនៈដ៏ប្រសើរក្នុងព្រះសម្ពុទ្ធ ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលអំពីមុនហើយនោះឯង ។ តែគប្បីប្រកបអត្ថតែម្យ៉ាងយ៉ាងនេះថា គុណជាត ពោល គឺព្រះបរិយត្តិធម៌ មានប្រការតាមដែលពោលមកហើយនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះសម្មាសម្ពុទ្ធ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលព្រះពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## អធិប្បាយបទថា វរោ វរញ្ញូ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដែលមានព្រះពុទ្ធរតនៈជាទីតាំងដោយបរិយត្តិធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយលោកុត្តរធម៌ថា **វរោ វរញ្ញូ** ។ ក្នុងពាក្យនោះ បទថា **វរោ** សេចក្តីថា ព្រះពុទ្ធ

ទ្រង់មានអធ្យាស្រ័យបង្អោនចិត្តជឿ ដែលប្រណីត ប្រាថ្នាថា ឱហ្ន៎ ! សូម្បីអាត្មាអញ ក៏គប្បីមានសភាពដូច្នេះ ។ ឬព្រះពុទ្ធដ៏ប្រសើរឧត្តម ប្រសើរបំផុត ព្រោះប្រកបដោយព្រះគុណដ៏ប្រសើរ ។ បទថា **វរញ្ញូ** បានដល់ ទ្រង់ដឹងព្រះនិព្វាន ។ ពិតហើយ ព្រះនិព្វាន ឈ្មោះថា ប្រសើរ ព្រោះអត្ថថាឧត្តមជាងធម៌ទាំងពួង ។ ព្រះពុទ្ធអង្គនោះ ត្រាស់ដឹងនូវព្រះនិព្វាននោះ ត្រង់មណ្ឌលពោធិព្រឹក្សដោយព្រះអង្គឯង ។ បទថា **វរទោ** សេចក្តីថា ប្រទានធម៌ដ៏ប្រសើរ ដែលជាចំណែកត្រាស់ដឹង និងចំណែកដែលអប់រំបន្ទំបារមីដល់សាវកទាំងឡាយ មានបញ្ចវគ្គិយ ភទ្ទវគ្គិយ និងជដិលជាដើមដល់ទេវតា និងមនុស្សដទៃ ។ បទថា **វរាហរោ** បានដល់ ដែលហៅថា **វរាហរោ** ព្រោះទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់បំពេញបារមី ៣០ មកតាំងអំពីព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់នាំនូវបុរាណមគ្គដ៏ប្រសើរ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គមុនៗ ទ្រង់ដើរមកហើយ ។ ដោយហេតុនោះ ទើបទ្រង់ត្រូវហៅថា **វរាហរោ** ដែលនាំមកនូវមគ្គដ៏ប្រសើរ ។

ម្យ៉ាងទៀត ព្រះសម្ពុទ្ធ ឈ្មោះថា **វរោ** គឺបុគ្គលប្រសើរ ព្រោះទ្រង់បាននូវព្រះសព្វញ្ញុតញ្ញាណ ឈ្មោះថា **វរញ្ញូ** គឺបុគ្គលដឹងធម៌ដ៏ប្រសើរ ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា **វរទោ** ព្រោះទ្រង់ប្រទានធម៌ដ៏ប្រសើរ ព្រោះទ្រង់ប្រទានវិមុត្តិសុខដល់សត្វទាំងឡាយ ឈ្មោះថា **វរាហរោ** គឺទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ព្រោះទ្រង់នាំមកនូវបដិបទាដ៏ឧត្តម ឈ្មោះថា **អនុត្តរោ** ព្រោះមិនមានគុណណាមួយ ដែលក្រៃលែងជាងលោកុត្តរគុណ

ទាំងនោះ ។

មានន័យដទៃទៀតថា ឈ្មោះថា **វរោ** ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋាន-ធម៌ គឺឧបសមៈ ។ ឈ្មោះថា **វរញ្ញូ** ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋានធម៌ គឺបញ្ញាដឹងដោយជុំវិញ ។ ឈ្មោះថា **វរទោ** ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋាន-ធម៌ គឺចាគៈ ។ ឈ្មោះថា **វរាហរោ** ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋាន គឺសច្ចៈ ។ ទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ។ ម្យ៉ាងទៀត ឈ្មោះថា **វរោ** ព្រោះទ្រង់អាស្រ័យបុណ្យ ។ ឈ្មោះថា **វរញ្ញូ** ក៏ព្រោះទ្រង់អាស្រ័យបុណ្យ ។ ឈ្មោះថា **វរទោ** ព្រោះទ្រង់ប្រគល់ឧបាយនៃបុណ្យនោះដល់បុគ្គលដែលត្រូវការជាព្រះពុទ្ធ ។ ឈ្មោះថា **វរាហរោ** ព្រោះទ្រង់នាំមកនូវឧបាយនៃបុណ្យនោះដល់បុគ្គលដែលត្រូវការជាព្រះបច្ចេកពុទ្ធ ។ ឈ្មោះថា **អនុត្តរោ** ព្រោះមិនមានបុគ្គលស្មើដូចក្នុងធម៌នោះៗ ឬព្រោះជាបុគ្គលមិនមានអាចារ្យ តែក៏បានជាអាចារ្យរបស់បុគ្គលដទៃៗ ដោយព្រះអង្គឯង ទ្រង់បានសម្ដែងធម៌ដ៏ប្រសើរ ព្រោះទ្រង់សម្ដែងធម៌ដ៏ប្រសើរ ដែលប្រកបដោយគុណ មានធម៌ដែលត្រាស់សម្ដែងល្អហើយជាដើម ដើម្បីផលនោះដល់បុគ្គលត្រូវការជាសាវក ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់ទ្រង់ដោយលោកុត្តរធម៌ ៩ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ពុទ្ធេ** ជាដើម អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលអំពីមុនហើយនោះឯង តែគប្បីប្រកបសេចក្ដីតែមួយ

យ៉ាងនេះថា ព្រះសម្ពុទ្ធអង្គនោះ បានត្រាស់ដឹងលោកុត្តរធម៌ដ៏ប្រសើរបានផង បានប្រទានលោកុត្តរធម៌បានផង ទ្រង់នាំមកនូវលោកុត្តរធម៌បានផង ទ្រង់សម្ដែងលោកុត្តរធម៌បានផង នេះក៏ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានោះ ។

## អធិប្បាយបទថា ខីណំ

ព្រះមានព្រះភាគ ទ្រង់អាស្រ័យបរិយត្តិធម៌ និងលោកុត្តរធម៌ហើយ ត្រាស់វចនៈ មានពុទ្ធរតនៈជាទីតាំង ដោយ ២ គាថា យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណ គឺការសម្រេចអនុបាទិសេសនិព្វាននៃសាវ័កទាំងឡាយដែលបានស្ដាប់បរិយត្តិធម៌នោះ និងបដិបត្តិតាមគន្លងដែលបានស្ដាប់មកហើយ បានសម្រេចលោកុត្តរធម៌ទាំង ៩ ប្រការ ទើបទ្រង់ផ្ដើមត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងទៀតថា **ខីណំ បុរាណំ** ។ ក្នុងសច្ចវចនៈនោះ បទថា **ខីណំ** បានដល់ កាត់ផ្ដាច់ ។ បទថា **បុរាណំ** ប្រែថា ចាស់ ។ បទថា **នវំ** បានដល់ ក្នុងឥឡូវនេះដែលកំពុងប្រព្រឹត្តទៅ គឺបច្ចុប្បន្ន ។ បទថា **នត្ថិ សម្ភវំ** បានដល់ ការប្រាកដមិនមាន ។ បទថា **វិរត្តចិត្តា** បានដល់ មានចិត្តប្រាសចាករាគៈ ។ បទថា **អាយតិកេ ភវស្មឹ** បានដល់ ក្នុងភពថ្មី ក្នុងអនាគតកាល ។ បទថា **តេ** បានដល់ ភិក្ខុខីណាស្រពដែលអស់កម្មភពចាស់ មិនមានកម្មភពថ្មី និងមានចិត្តប្រាសចាកតម្រេកក្នុងភពតទៅ ។ បទថា **ខីណា-ពីជា** បានដល់ ជាអ្នកមានពូជដកហើយ ។ បទថា **អវិរុឡ្ហិឆន្ទា** បានដល់ ជាអ្នកវៀរចាកឆន្ទៈដែលដុះបាន ។ បទថា **និព្វន្តិ** បានដល់ អស់ទៅ ។ បទថា

**ធីរា** បានដល់ បុគ្គលដល់ព្រមដោយបញ្ញា ឈ្មោះធិតិ ។ បទថា **យថា-យម្បទីបោ** ប្រែថា ដូចប្រទីបនេះ ។

លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា កម្មនោះ នៃសត្វទាំង-ឡាយកើតហើយរលត់ទៅ ជាកម្មចាស់ ជាអតីតកាល រមែងមិនទាន់អស់ទៅ ព្រោះអាចនាំមកនូវបដិសន្ធិ ព្រោះលះសិនេហៈ គឺតណ្ហាមិនទាន់បាន កម្មចាស់នោះរបស់ព្រះខីណាស្រពទាំងឡាយណា ឈ្មោះថា អស់ទៅ ក៏ព្រោះមិនអាចឲ្យវិបាកតទៅ ដូចពូជដែលភ្លើងឆេះហើយ ព្រោះសិនេហៈ គឺតណ្ហារីងស្ងួតទៅដោយអរហត្តមគ្គ និងកម្មណារបស់ភិក្ខុខីណាស្រពពួកណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដោយអំណាចពុទ្ធបូជាជាដើម ហៅថា កម្មថ្មី ។ កម្មថ្មីនោះរបស់ភិក្ខុខីណាស្រពណា ក៏បង្កនូវភពបាន ព្រោះមិនអាចឲ្យផលតទៅ ដូចផ្កានៃដើមឈើដែលមានឫសដាច់ហើយ ព្រោះលះតណ្ហាបាននោះឯង ។

ម្យ៉ាងទៀត ភិក្ខុខីណាស្រពពួកណា មានចិត្តនឿយណាយហើយ ក្នុងភពតទៅ ព្រោះលះតណ្ហាបាននោះឯង ភិក្ខុខីណាស្រពទាំងនោះ ឈ្មោះថា មានពូជអស់ហើយ ព្រោះបដិសន្ធិវិញ្ញាណ ដែលលោកពោលហើយ ក្នុងពាក្យនេះថា កម្ម គឺស្រែ វិញ្ញាណ គឺពូជ អស់ទៅ ព្រោះអស់កម្មនោះឯង ឆន្ទៈឯណានៃការកើត ពោល គឺភពថ្មី មានមកហើយអំពីកាលមុន ។ ភិក្ខុខីណាស្រពទាំងឡាយ ឈ្មោះថា មានឆន្ទៈមិនដុះ ព្រោះមិនកើតក្នុងពេលចុតិដូចក្នុងកាលមុន ព្រោះឆន្ទៈនោះលះបានហើយ ព្រោះលះសមុទយៈនោះឯង ឈ្មោះថា អ្នកប្រាជ្ញ ព្រោះដល់ព្រមដោយធិតិប្បញ្ញា រមែងរលត់ទៅ ដូច

ប្រទីបដួងនេះរលត់ទៅ ដូច្នោះ ព្រោះចរិមវិញ្ញាណរលត់ទៅ រមែងកន្លងបង់នូវផ្លូវនៃបញ្ញត្តិជាដើមយ៉ាងនេះថា មានរូប ឬមិនមានរូបទៀត ។

បានឮថា បណ្តាប្រទីបច្រើនដួង ដែលគេដុតដើម្បីបូជាទេវតាប្រចាំក្រុងក្នុងសម័យនោះ ប្រទីប ១ រលត់ទៅហើយ ព្រះមានព្រះភាគ កាលទ្រង់ចង្អុលបង្ហាញប្រទីបដួងនោះ ទើបត្រាស់ថា **យថាយម្បទីបោ** ដូចប្រទីបដួងនេះ ។

ព្រះមានព្រះភាគ កាលត្រាស់គុណ គឺការសម្រេចអនុបាទិសេសនិព្វាន របស់ព្រះខីណាស្រព ដែលស្តាប់បរិយត្តិធម៌ ដែលត្រាស់ដោយ ២ គាថាមុននោះផង បដិបត្តិតាមគន្លងបរិយត្តិដែលស្តាប់ហើយផង សម្រេចលោកុត្តរធម៌ទាំង ៩ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង កាលទ្រង់ប្រកបសច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ទើបទ្រង់បញ្ចប់ទេសនាថា **ឥទម្បិ សង្ឃេ** ជាដើម អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកមុនហើយនោះឯង ។ តែគប្បីប្រកបសេចក្តីតែមួយ យ៉ាងនេះថា គុណជាត ពោល គឺព្រះនិព្វានរបស់ភិក្ខុខីណាស្រព ដោយប្រការតាមដែលពោលមកហើយ នេះក៏ជារតនៈដែលប្រណីតក្នុងសង្ឃ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

ចប់ទេសនា សួស្តីក៏មានដល់រាជត្រកូល ឧបទ្រព្យទាំងពួង ក៏រម្ងាប់ទៅ សត្វ ៨៤០០០ ក៏បានត្រាស់ដឹងធម៌ ។

## អធិប្បាយគាថា ៣ មានយានីធជាដើម

គ្រានោះ សក្កទេវរាជទ្រង់ព្រះតម្រិះថា ព្រះមានព្រះភាគ ទ្រង់អាស្រ័យ

គុណព្រះរតនត្រ័យ ប្រកបសច្ចវចនៈ ទ្រង់ធ្វើសួស្តីដល់អ្នកនគរ ។ សូម្បីអញ ក៏គប្បីពោលពាក្យណានីមួយ អាស្រ័យគុណព្រះរតនត្រ័យ ដើម្បីសួស្តីដល់អ្នកនគរ ដូច្នេះហើយ ទើបត្រាស់ ៣ គាថាខាងចុងថា **យានីធ ភូតានិ** ជាដើម ។ ក្នុង ៣ គាថានោះ ព្រោះហេតុដែលព្រះពុទ្ធ លោកហៅថា តថាគត ព្រោះយាងមក ដូចដែលមនុស្សទាំងឡាយ ត្រូវខ្វល់ខ្វាយ នាំគ្នាមកដើម្បីជាប្រយោជន៍ដល់សត្វលោក ព្រោះយាងទៅ ដូចដែលមនុស្សទាំងនោះគប្បីទៅ ព្រោះទ្រង់ដឹងទូទៅ ដូចដែលមនុស្សទាំងនោះគប្បីដឹងទូទៅ ព្រោះទ្រង់ដឹងដូចដែលមនុស្សទាំងនោះគប្បីដឹង ព្រោះទ្រង់ជួបនូវវត្ថុ ដែលមានយ៉ាងនោះ ម្យ៉ាងទៀត ព្រោះព្រះពុទ្ធអង្គនោះ ដែលទេវតា និងមនុស្សទាំងឡាយបូជា ដោយឥតសេសសល់ ដោយផ្កា និងគ្រឿងក្រអូបជាដើម ដែលកើតខាងក្រៅជាឧបករណ៍ និងដែលកើតក្នុងខ្លួន មានកិច្ចបដិបត្តិធម៌សមគួរដល់ធម៌ជាដើមដូច្នោះ ។ សក្កទេវរាជទ្រង់ប្រមូលទេវបរិស័ទ មួយអន្លើនឹងព្រះអង្គ ហើយត្រាស់ថា **តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ** យើងខ្ញុំទាំងឡាយ សូមនមស្ការព្រះពុទ្ធ ដែលទេវតា និងមនុស្សបូជាហើយ សូមសួស្តីកើតមាន ។

ម្យ៉ាងទៀត ព្រោះក្នុងព្រះធម៌ មគ្គធម៌ប្រព្រឹត្តទៅហើយ ដែលគប្បីប្រព្រឹត្តទៅ ដោយការដកនូវបក្ខពួកកិលេស ដោយកម្លាំងសមថៈ និងវិបស្សនា ដែលជាធម៌គូគ្នា សូម្បីនិព្វានធម៌ ដែលព្រះពុទ្ធជាដើម ទ្រង់សម្រេចហើយ ដូចដែលទ្រង់ត្រាស់ដឹង គឺចាក់ធ្លុះដោយបញ្ញា មួយអន្លើ

ដែលនឹងកម្ចាត់ទុក្ខទាំងពួង ដូច្នោះ ទើបលោកហៅថា តថាគត ។ ម្យ៉ាង ទៀត ព្រោះព្រះសង្ឃប្រព្រឹត្តទៅហើយ ដូចដែលលោកបដិបត្តិ ដើម្បីជាប្រយោជន៍ដល់ខ្លួន គប្បីប្រព្រឹត្តទៅដោយមគ្គនោះៗ ហេតុនោះ ទើបលោកហៅថា តថាគត ។ ដូច្នោះ សូម្បីក្នុង ២ គាថាដ៏សេស ទើបសក្កទេវរាជត្រាស់ថា យើងខ្ញុំទាំងឡាយ សូមនមស្ការតថាគតធម៌ សូមសួស្តីកើតមាន យើងខ្ញុំសូមនមស្ការតថាគតសង្ឃ សូមសួស្តីកើតមាន ដូច្នេះ ។ ពាក្យដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

សក្កទេវរាជកាលត្រាស់ ៣ គាថាយ៉ាងនេះហើយ ទ្រង់ធ្វើប្រទក្សិណព្រះមានព្រះភាគ ទ្រង់យាងត្រឡប់ទៅកាន់ទេវបុរី មួយអន្លើដោយទេវបរិស័ទ ។ ចំណែកព្រះមានព្រះភាគ ទ្រង់សម្តែងរតនសូត្រនោះឯង ។ ក្នុងថ្ងៃទី ២ សត្វប្រមាណ ៨៤០០០ ក៏ត្រាស់ដឹងធម៌ ។ ទ្រង់សម្តែងយ៉ាងនេះដល់ថ្ងៃទី ៧ ។ ការត្រាស់ដឹងធម៌ មានហើយយ៉ាងនោះឯង រាល់ៗ ថ្ងៃ ។ ព្រះមានព្រះភាគនៅប្រថាប់ក្នុងក្រុងវេសាលីកន្លះខែហើយ ទើបទ្រង់ប្រាប់ដល់ពួកស្តេចលិច្ឆវីថា នឹងត្រឡប់ បន្ទាប់អំពីនោះ ពួកស្តេចលិច្ឆវី ក៏នាំព្រះមានព្រះភាគចូលកាន់ច្រាំងស្ទឹងគង្គា ដោយសក្ការៈជាទ្វេគុណ ៣ ថ្ងៃទៀត ពួកស្តេចនាគដែលកើតនៅក្នុងស្ទឹងគង្គាគិតគ្នាថា ពួកមនុស្សធ្វើសក្ការៈ ដល់ព្រះតថាគត ពួកយើងនឹងមិននាំគ្នាធ្វើខ្លះឬ ទើបសាងផ្ទះច្រើនខ្នង ជាវិការនៃមាស ប្រាក់ និងកែវមណី ក្រាលបល្ល័ង្ក ធ្វើដោយមាស ប្រាក់ និងកែវមណី ធ្វើទឹកឲ្យគ្របដណ្តប់ដោយឈូក ៥ ពណ៌ ទូលអារាធនាព្រះមានព្រះភាគថា សូមទ្រង់

មេត្តាធ្វើនូវសេចក្តីអនុគ្រោះពួកខ្ញុំព្រះអង្គផងចុះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលទ្រង់ឡើងកាន់ផ្ទះកែវ ឯភិក្ខុ ៥០០ ក៏ឡើងកាន់ទូកវៀងៗ ខ្លួន ។ ពួកស្តេចនាគនាំព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ចូលទៅកាន់នាគ-ពិភព ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់នាគ-បរិស័ទមួយយប់ទល់ភ្លឺ ថ្ងៃទី ២ ពួកស្តេចនាគនាំគ្នាថ្វាយមហាទាន ដោយរបស់ទំពា របស់ឆាន់ដែលជាទិព្វ ។ ព្រះមានព្រះភាគ ទ្រង់អនុមោទនាហើយ ទ្រង់ចេញអំពីនាគពិភព ។

ពួកភុម្មទេវតានាំគ្នាគិតថា ពួកមនុស្ស និងនាគនាំគ្នាធ្វើសក្ការៈដល់ព្រះតថាគត ពួកយើងមិនធ្វើខ្លះឬ ទើបនាំគ្នាលើកស្វេតច្ឆត្រធំតូច លើគុមឈើ ប្រគាបឈើ ដើមឈើ និងភ្នំ ។ ដោយឧបាយនោះឯង សក្ការៈវិសេសដ៏ធំក៏កើត ដរាបដល់ភពអកនិដ្ឋព្រហ្ម ។ សូម្បីព្រះបាទពិម្ពិសារ ក៏ទ្រង់បានធ្វើទ្វេគុណ ជាងសក្ការៈដែលពួកស្តេចលិច្ឆវីធ្វើ កាលព្រះមានព្រះភាគយាងមក ទ្រង់នាំព្រះមានព្រះភាគ ៥ ថ្ងៃ ទើបដល់ក្រុងរាជគ្រឹះ ដោយន័យដូចពោលមកអំពីមុនហើយ ។

ព្រះមានព្រះភាគ យាងដល់ក្រុងរាជគ្រឹះហើយ ខាងក្រោយអាហារ ពួកភិក្ខុដែលអង្គុយប្រជុំគ្នាក្នុងសាលាមូល ពោលក្នុងរវាងគ្នានិងគ្នាយ៉ាងនេះថា ឱ ! អានុភាពរបស់ព្រះមានព្រះភាគ ក្នុងទីភូមិភាគ ៨ យោជន៍ ទាំងត្រើយអាយ និងត្រើយនាយនៃស្ទឹងគង្គា ត្រូវពង្រាបទីទំនាប និងទីទួលឲ្យរាបហើយ ដោយខ្សាច់ គ្របដណ្តប់ដោយផ្កាទាំងឡាយ ស្ទឹងគង្គាប្រមាណមួយយោជន៍

ក៏ត្រូវគ្របដណ្តប់ដោយផ្កាឈូកពណ៌ផ្សេងៗ ឆត្រតូច-ធំត្រូវលើកឡើងដរាប ដល់អកនិដ្ឋព្រហ្ម ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបរឿងនោះហើយ ចេញអំពី ព្រះគន្ធកុដិ យាងទៅកាន់សាលាមូលដោយបាដិហារ្យ សមគួរដល់ខណៈនោះ គង់ប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេបានរៀបចំក្នុងសាលាមូលនោះ ។ កាលគង់ប្រថាប់ហើយ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាល ភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នា និយាយរឿងអ្វី ភិក្ខុ ទាំងឡាយក្រាបទូលរឿងទាំងអស់នោះ ។ ព្រះមានព្រះភាគ ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បូជាវិសេសនេះ មិនបានកើតព្រោះពុទ្ធានុភាពរបស់ តថាគត ទាំងមិនមែនព្រោះអានុភាពរបស់នាគ ទេវតា និងព្រហ្មឡើយ ដោយពិត កើតព្រោះអានុភាពនៃការបរិច្ចាគបន្តិចបន្តួចទេតើ ។ ទើបភិក្ខុ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹងការបរិច្ចាគតិចតួច នោះ សូមព្រះមានព្រះភាគ មេត្តាប្រាប់ពួកខ្ញុំព្រះអង្គ ដូចដែលពួកខ្ញុំព្រះអង្គ ដឹងការបរិច្ចាគតិចតួចនោះផងចុះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ រឿងធ្លាប់មានមកហើយ ក្នុងនគរតក្កសិលា មានព្រាហ្មណ៍ម្នាក់ ឈ្មោះសង្ខៈ គាត់មានកូនប្រុសម្នាក់ ឈ្មោះសុសិមមាណព ។ មាណពនោះ អាយុបាន ១៦ ឆ្នាំ ដោយវ័យ ថ្ងៃមួយ ចូលទៅរកបិតា ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ។ បិតាសួរថា នែ សុសិមៈ អ្នកមានរឿង អ្វី សុសិមៈឆ្លើយថា ខ្ញុំចង់ទៅក្រុងពារាណសី រៀនសិប្បៈ ព្រាហ្មណ៍ពោល ថា នែ សុសិមៈ បើដូច្នោះ ឪពុកមានសម្លាញ់ជាព្រាហ្មណ៍ឈ្មោះនោះ ចូរបា

ទៅរកអាចារ្យនោះរៀនសូត្រចុះ ហើយប្រគល់ទ្រព្យ ១០០០ កហាបណៈ ។ សុសិមមាណពនោះទទួលទ្រព្យហើយ ក៏សំពះមាតាបិតា ធ្វើដំណើរទៅក្រុងពារាណសីដោយលំដាប់ គាត់ចូលទៅរកអាចារ្យដោយវិធី ប្រកបដោយភាពទន់ភ្លន់ ថ្វាយបង្គំហើយ ប្រាប់ការងាររបស់ខ្លួន អាចារ្យដឹងថា ជាកូនរបស់សម្លាញ់ ក៏ទទួលមាណព បានធ្វើការទទួលយ៉ាងល្អគ្រប់យ៉ាង មាណពនោះប្រាសចាកការនឿយហត់ក្នុងការធ្វើដំណើរផ្លូវឆ្ងាយហើយ ក៏ដាក់កហាបណៈនោះ ទៀបបាតជើងអាចារ្យ សូមឱកាសរៀនសិប្បៈ ។ អាចារ្យក៏បើកឱកាសឲ្យរៀនសូត្រ មាណពរៀនបានរហ័ស និងបានច្រើនផង ព្រមទាំងទ្រទ្រង់នូវសិប្បៈដែលរៀនបានហើយ មិនឲ្យសាបសូន្យផង ដូចប្រេងថ្លាដាក់ក្នុងភាជនៈមាស គាត់រៀនសិប្បៈដែលគួររៀនអស់ ១២ ឆ្នាំ ឲ្យចប់សព្វគ្រប់ត្រឹម ២-៣ ខែប៉ុណ្ណោះ ។ មាណពស្វាធ្យាយតាំងអំពីខាងដើម និងកណ្ដាលប៉ុណ្ណោះ មិនឃើញខាងចុង ទើបចូលទៅរកអាចារ្យសួរថា លោកអាចារ្យ ខ្ញុំឃើញតែខាងដើម និងកណ្ដាលរបស់សិប្បៈនេះប៉ុណ្ណោះ មិនឃើញខាងចុងឡើយ អាចារ្យក៏ពោលថា ឯខ្ញុំក៏ឃើញយ៉ាងនោះដូចគ្នានោះឯង ។ ទើបមាណពសួរថា បពិត្រលោកអាចារ្យ បើដូច្នោះ អ្នកណាដឹងខាងចុងរបស់សិប្បៈនេះ ។ អាចារ្យពោលថា នែបា នៅឯព្រៃឥសិបតនៈ មានឥសីច្រើនអង្គ ឥសីទាំងនោះគង់នឹងដឹង ។ មាណពប្រាប់ថា បពិត្រលោកអាចារ្យ ខ្ញុំនឹងចូលទៅសួរឥសីទាំងនោះឯង ។ អាចារ្យក៏ប្រាប់ថា នែបា អ្នកចូរទៅសួរតាមសប្បាយចុះ ។ មាណពទៅកាន់ព្រៃឥសិបតនៈ ចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយ

សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ដឹងខាងចុងនៃសិប្បៈខ្លះដែរឬទេ ។ ព្រះបច្ចេកពុទ្ធពោលថា អើ អាត្មាដឹង ។ មាណពអារាធនាថា សូមឲ្យខ្ញុំសិក្សាខាងចុងសិប្បៈនោះផងចុះ ។ ព្រះបច្ចេកពុទ្ធពោលថា បើដូច្នោះ ចូរបួសចុះ បុគ្គលដែលមិនបួស សិក្សាមិនបានទេ ។ មាណពទទួលថា សាធុ សូមឲ្យខ្ញុំបួសចុះ ។ សូមលោកម្ចាស់ ធ្វើតែទីដែលលោកម្ចាស់ប្រាថ្នាហើយឲ្យខ្ញុំសិក្សាខាងចុងសិប្បៈ ក៏ជាការស្រេច ។ ព្រះបច្ចេកពុទ្ធទាំងនោះឲ្យមាណពបួសហើយ ក៏មិនអាចប្រកបមាណពក្នុងកម្មដ្ឋាន ឲ្យសិក្សាតែអភិសមាចារ ដោយន័យជាដើមថា អ្នកគប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ។ មាណពសិក្សាក្នុងសិក្ខាបទនោះ តែព្រោះជាអ្នកដល់ព្រមដោយឧបនិស្ស័យ មិនយូរប៉ុន្មានក៏ត្រាស់ដឹងបច្ចេកពោធិញ្ញាណ ។ ព្រះបច្ចេកពុទ្ធសុសិមៈដល់នូវលាភយសដ៏ក្រៃលែង កុះករដោយបរិវារ ប្រាកដទូទៅក្នុងក្រុងពារាណសីថា ជាព្រះបច្ចេកពុទ្ធ តែមិនយូរប៉ុន្មាន លោកក៏បរិនិព្វានព្រោះបានធ្វើកម្មដែលជាហេតុឲ្យអាយុខ្លី ។ ព្រះបច្ចេកពុទ្ធទាំងឡាយ និងពួកមហាជន នាំគ្នាធ្វើឈាបនកិច្ចសរីរៈរបស់លោក រក្សាធាតុ សាងព្រះស្តូបក្បែរទ្វារព្រះនគរ ។

ឯសង្ខព្រាហ្មណ៍ គិតថា កូនរបស់អញទៅយូរហើយ មិនមានដំណឹងម្តងសោះឡើយ បំណងនឹងជួបកូន ទើបចេញអំពីតក្កសិលា ធ្វើដំណើរទៅតាមលំដាប់ ក៏ដល់ក្រុងពារាណសី ឃើញពួកមហាជនប្រជុំគ្នា គិតថា ក្នុងពួកជនជាច្រើន គង់មានម្នាក់ ដឹងដំណឹងកូនរបស់អញពិត ទើបចូលទៅត្រង់

ប្រជុំជន សួរថា មាណពឈ្មោះសុសិមៈមកក្នុងទីនេះ មានដែរឬទេ អ្នកធ្លាប់ឮដំណឹងរបស់សុសិមមាណពខ្លះដែរឬ ។ ជនទាំងនោះពោលថា អើព្រាហ្មណ៍ពួកខ្ញុំដឹង លោករៀនចប់ត្រៃវេទក្នុងសម្នាក់ព្រាហ្មណ៍ នាទនគរនេះហើយ បួសក្នុងសម្នាក់ព្រះបច្ចេកពុទ្ធទាំងឡាយ បានត្រាស់ជាព្រះបច្ចេកពុទ្ធ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុហើយ នេះព្រះស្តូប ពួកយើងសាងឡើងសម្រាប់លោក ។ សង្ខព្រាហ្មណ៍យកដៃវាយផែនដី ទ្រហោយំ ទៅកាន់លានចេតិយនោះ ដកស្មៅហើយ យកសំពត់ដណ្តប់វេចខ្សាច់ នាំទៅរោយត្រង់លានព្រះចេតិយរបស់ព្រះបច្ចេកពុទ្ធ យកទឹកក្នុងកុណ្ឌីប្រោះព្រំ ធ្វើការបូជាដោយផ្កាព្រៃ យកសំពត់ដណ្តប់លើកឡើង ធ្វើជាទង់ ចងឆត្រ គឺឆត្ររបស់ខ្លួនដាក់លើស្តូប ហើយត្រឡប់ទៅ ។

ព្រះមានព្រះភាគ កាលទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់បន្តអនុសន្ធិជាតកនោះជាមួយបច្ចុប្បន្ន ទើបត្រាស់ធម៌ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីមានការគិតថា អ្នកដទៃជាសង្ខព្រាហ្មណ៍ សម័យនោះពិត តែពួកអ្នកមិនគប្បីឃើញយ៉ាងនេះ សម័យនោះ តថាគតជាសង្ខ-ព្រាហ្មណ៍ តថាគតដកស្មៅត្រង់លានព្រះចេតិយ របស់សុសិមព្រះបច្ចេកពុទ្ធដោយផលកម្មរបស់តថាគតនោះ ទើបជនទាំងឡាយធ្វើផ្លូវ ៨ យោជន៍ ឲ្យប្រាសចាកដង្គត់ និងបន្លា ធ្វើផ្ទៃដីឲ្យរាបស្មើស្អាត តថាគតរោយខ្សាច់ត្រង់លានព្រះចេតិយព្រះសុសិមបច្ចេកពុទ្ធនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើបជនទាំងឡាយរោយខ្សាច់ត្រង់ផ្លូវ ៨ យោជន៍ តថាគតបូជាត្រង់

ព្រះស្តូបនោះ ដោយផ្កាព្រៃ ដោយផលកម្មនៃតថាគតនោះ ទើបជនទាំងឡាយ ផ្ញើកម្រាលផ្កាច្រើនប្រភេទ ទាំងលើគោក និងក្នុងទឹក ក្នុងផ្លូវ ៩ យោជន៍ តថាគតប្រោះព្រំផែនដីដោយទឹក ក្នុងកុណ្ឌីទឹកត្រង់ព្រះស្តូបនោះ ដោយផល នៃកម្មនោះ ទើបភ្លៀងបោក្ខរព័ស្សធ្លាក់ត្រង់ក្រុងវេសាលី តថាគតលើកទង់ជ្វា លា និងឆត្រត្រង់ព្រះចេតិយនោះ ដោយផលនៃកម្មរបស់តថាគតនោះ ទើប ជនទាំងឡាយលើកទង់ជ្វាលា និងឆត្រតូចធំ រហូតដល់អកនិដ្ឋភព ។ ម្នាល ភិក្ខុទាំងឡាយ ការបូជាវិសេស មិនមែនកើតព្រោះពុទ្ធានុភាពរបស់តថាគត ឡើយ មិនមែនព្រោះអានុភាពរបស់នាគ ទេវតា និងព្រហ្មឡើយ ដោយពិត នោះ កើតព្រោះអានុភាពរបស់ការបរិច្ចាគបន្តិចបន្តួចទេតើ ។ ចប់ធម្មកថា បានត្រាស់ព្រះគាថានេះថា

**មត្តាសុខបរិច្ចាគា　　　　បស្សេ ចេ វិបុលំ សុខំ**
**ចជេ មត្តាសុខំ ធីរោ　　　　សម្បស្សំ វិបុលំ សុខំ ។**

*បើបុគ្គលឃើញសុខធំទូលាយ　　　ព្រោះលះសុខមាន*
*ប្រមាណតិចចេញ　អ្នកមានប្រាជ្ញា　កាលឃើញច្បាស់*
*សុខធំទូលាយ គប្បីលះសុខមានប្រមាណតិចចេញ ។*

**អធិប្បាយរតនសូត្រ**

**នៃ**

**អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកា ចប់**

# ខុទ្ទកបាឋៈ តិរោកុឌ្ឌកណ្ឌ

[ ៨ ] បើបុគ្គលឃើញសុខធំទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ អ្នកមានប្រាជ្ញា កាលឃើញច្បាស់សុខធំទូលាយ គប្បីលះសុខមានប្រមាណតិចចេញ ។

ប្រេតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថា ជាផ្ទះរបស់ខ្លួន ហើយឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និងទ្វារផ្ទះទាំងឡាយខ្លះ ។ កាលបើបាយទឹក បង្អែម និងចំអាបមានគ្រប់គ្រាន់ ដែលពួកញាតិតាក់តែងទុកហើយ មិនមានញាតិណាមួយ នឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។ ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំង-ឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹក និងភោជនដ៏មិនមែនកង់ ... ដ៏ប្រសើរ ជារបស់គួរតាមកាល ដល់ញាតិទាំងឡាយ យ៉ាងនេះថា ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្ដីសុខ ។ ចំណែកប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកជួបជុំគ្នាហើយ ក្នុងមន្ទីរឲ្យទាននោះ កាលបើបាយ និងទឹកមានល្មមគ្រាន់ ក៏អនុមោទនាដោយគោរពថា យើងទាំងឡាយបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំងឡាយនោះ រស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយក្ដី ញាតិទាំងឡាយ ជាអ្នកឲ្យទានក្ដី មិនមែនជាឥតផលឡើយ កសិកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ គោរក្ខកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ ពាណិជ្ជកម្មដែលជាហេតុបានសម្បត្តិបែបដូច្នោះ

ក៏មិនមាន ការលក់ទិញផ្លាស់ប្តូរដោយប្រាក់ក៏មិនមាន បុគ្គលទាំងឡាយធ្វើកាលកិរិយាលះលោកនេះទៅហើយ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិទាំងឡាយ ឧទ្ទិសឲ្យហើយអំពីលោកនេះ ។ ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទាបដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។ ផ្លូវទឹកមានទន្លេ និងស្ទឹងជាដើមដ៏ពេញ រមែងញ៉ាំងសាគរឲ្យពេញប្រៀប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះ បានឲ្យរបស់នេះដល់អញ អ្នកនេះ បានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះជាញាតិមិត្តជាសម្លាញ់របស់អញ ដូច្នេះហើយ គួរឲ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ ។ ការយំសោកសៅ និងការខ្សឹកខ្សួលដទៃណា មិនមានប្រយោជន៍ឡើយ ការយំជាដើមនោះ មិនសម្រេចប្រយោជន៍ដល់ប្រេតទាំងឡាយទេ ញាតិទាំងឡាយ រមែងឋិតនៅយ៉ាងនោះដដែល ឥតបានដឹង បានឮឡើយ ។ លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឲ្យហើយ តម្កល់ទុកប្រពៃហើយក្នុងសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ។ ញាតិធម៌នោះ ឈ្មោះថា មហាបពិត្របានសម្តែងជាបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លាចំពោះប្រេតទាំងឡាយ ឈ្មោះ

ថា បានធ្វើហើយផង កម្លាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា បានបំពេញឲ្យហើយផង បុណ្យឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយផង ។

តិរោកុឌ្ឌកណ្ឌ ចប់

# អដ្ឋកថា

# តិរោកុឌ្ឌ កណ្ឌ

## ប្រយោជន៍នៃការតាំងបទព្រះសូត្រ

[ ៨ ] ឥឡូវនេះ ដល់លំដាប់ពណ៌នានូវតិរោកុឌ្ឌសូត្រ ដែលលើកឡើងចំពោះលំដាប់ បន្ទាប់អំពីរតនសូត្រ ដោយន័យជាដើមថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ជាដើម នឹងពោលប្រយោជន៍នៃការតាំងតិរោកុឌ្ឌសូត្រនេះ ក្នុងទីនេះហើយ ទើបពណ៌នាសេចក្តី ។

ក្នុងសេចក្តីនោះ សេចក្តីពិត តិរោកុឌ្ឌសូត្រនេះ ព្រះមានព្រះភាគ ក៏មិនបានត្រាស់តាមលំដាប់នេះ តែក៏ទ្រង់សម្តែងកិច្ចបដិបត្តិកុសលកម្មនេះបាន ដោយប្រការផ្សេងៗ មុនព្រះសូត្រនេះ ព្រោះបុគ្គលប្រមាទក្នុងកិច្ចបដិបត្តិកុសលកម្មនោះ កាលកើតក្នុងឋានៈដែលសៅហ្មងជាងនរក និងកំណើតសត្វ

តិរច្ឆាន ក៏រមែងកើតក្នុងជំពូកប្រេតបែបនោះ ដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់រតនសូត្រ ដើម្បីសម្ដែងថា បុគ្គលមិនគួរធ្វើសេចក្ដីប្រមាទក្នុងកិច្ចបដិ-បត្តិកុសលកម្មនោះ និងដើម្បីរម្ងាប់ឧបទ្រវនៃក្រុងវេសាលី ដែលពួកភូតទាំង-ឡាយណា បៀតបៀនហើយ ឬត្រាស់ដើម្បីសម្ដែងថា ក្នុងពួកភូតទាំងនោះ មានភូតពួកខ្លះ មានរូបរាងបែបនោះ គប្បីជ្រាបប្រយោជន៍នៃការតាំង តិរោកុឌ្ឌសូត្រនោះ ក្នុងទីនេះ ។

## អនុមោទនាកថា

តែព្រោះតិរោកុឌ្ឌសូត្រ បុគ្គលណាប្រកាស ប្រកាសទីណា ប្រកាសក្នុង កាលណា ប្រកាសព្រោះហេតុអ្វី ពណ៌នាសេចក្ដីនៃតិរោកុឌ្ឌសូត្រនោះ ការ ប្រកាសតិរោកុឌ្ឌសូត្រនោះអស់ហើយ កាលធ្វើតាមលំដាប់ ឈ្មោះថា ធ្វើល្អ ហើយ ដូច្នោះ ខ្ញុំនឹងពណ៌នាសេចក្ដីនោះយ៉ាងនោះដូចគ្នា ។

ពាក្យថា **តិរោកុឌ្ឌសូត្រ** នេះ បុគ្គលណាប្រកាស ប្រកាសទីណា ប្រកាស ក្នុងកាលណា ប្រកាសព្រោះហេតុអ្វី សូមចង្អុលបង្ហាញថា តិរោកុឌ្ឌសូត្រ ព្រះមានព្រះភាគ ទ្រង់ប្រកាស តិរោកុឌ្ឌសូត្រនោះឯង ទ្រង់ប្រកាស ដើម្បី អនុមោទនាដល់ព្រះបាទមគធរដ្ឋក្នុងថ្ងៃស្អែក ដើម្បីធ្វើសេចក្ដីនេះឲ្យជាក់ច្បាស់ គួរពោលរឿងពិស្ដារ ក្នុងសេចក្ដីនេះ ដូច្នេះ ។

ក្នុងកប្បទី ៩២ បន្ទាប់អំពីកប្បនេះ មាននគរឈ្មោះកាសី ក្នុងនគរនោះ ព្រះរាជាឈ្មោះថា ជ័យសេន ព្រះទេវីរបស់ព្រះរាជានោះ ព្រះនាមថា សិរិមា ព្រះពោធិសត្វព្រះនាមថា ផុស្សៈ កើតក្នុងព្រះគភ៌របស់ព្រះនាង ត្រាស់ដឹង

សម្មាសម្ពោធិញ្ញាណតាមលំដាប់ ព្រះរាជាជ័យសេនទ្រង់កើតការដឹងដល់ការកើតរបស់ព្រះអង្គថា ឱរសរបស់អញចេញបួស នឹងបានជាព្រះពុទ្ធ ព្រះពុទ្ធក៏ជារបស់អញ ព្រះធម៌ក៏ជារបស់អញ ព្រះសង្ឃក៏ជារបស់អញ ទ្រង់ឧបដ្ឋាកដោយព្រះអង្គគ្រប់កាល មិនព្រមប្រទានឱកាសដល់បុគ្គលដទៃៗឡើយ ។

បងប្អូនរបស់ព្រះមានព្រះភាគ មាតាដទៃ ៣ អង្គ នាំគ្នាត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់កើតឡើងដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងពួង មិនមែនដើម្បីជាប្រយោជន៍ដល់បុគ្គលម្នាក់ប៉ុណ្ណោះឡើយ តែព្រះបិតារបស់អញ ទ្រង់មិនប្រទានឱកាសដល់អញ និងមនុស្សដទៃៗ សោះ អញនឹងបានឧបដ្ឋាកដូចម្តេចហ្ន៎ ។ ទើបព្រះរាជឱរសទាំងនោះ សម្រេចព្រះហឫទ័យថា យើងនឹងធ្វើឧបាយណាមួយ ។ ស្តេចទាំង ៣ អង្គឲ្យចៅហ្វាយស្រុកជាយដែនធ្វើហាក់បីដូចជាដណ្តើមស្រុក ។ បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ឮថា ចៅហ្វាយស្រុកជាយដែនបះបោរ ទើបទ្រង់បញ្ជូនរាជឱរសទាំង ៣ អង្គចេញទៅបង្ក្រាប ។ ព្រះឱរសទាំងនោះបង្ក្រាបស្រេចហើយ ក៏យាងត្រឡប់មក ព្រះរាជាទ្រង់សប្បាយព្រះរាជហឫទ័យ ទ្រង់ព្រះរាជទានពរថា អ្នកប្រាថ្នារបស់ណាក៏ចូរទទួលរបស់នោះ ។ ព្រះរាជឱរសទាំង ៣ ក្រាបទូលថា ខ្ញុំព្រះអង្គប្រាថ្នាឧបដ្ឋាកព្រះមានព្រះភាគ ព្រះរាជាត្រាស់ថា វៀរពរនោះចេញ ទទួលពរដទៃចុះ ។ ព្រះរាជឱរសក្រាបទូលថា ពួកទូលបង្គំមិនប្រាថ្នាពរដទៃទេ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកចូរកំណត់កាល មកហើយទទួលចុះ ។ ព្រះ

រាជឱរសសូម ៧ ឆ្នាំ ព្រះរាជាទ្រង់មិនព្រះរាជទាន ទើបព្រះរាជឱរសទូលសូមបន្ថយចុះយ៉ាងនេះ គឺ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ រហូតដល់ ៣ ខែ ទើបព្រះរាជាថា បាន ។ ព្រះរាជឱរសទាំងនោះ បានទទួលព្រះរាជទានពរហើយ ក៏ទ្រង់ត្រេកអរក្រៃលែង ចូលគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គប្រាថ្នានឹងឧបដ្ឋាកទ្រង់អស់ត្រៃមាស សូមទ្រង់មេត្តាទទួលចាំវស្សាអស់ត្រៃមាសនេះ សម្រាប់ខ្ញុំព្រះអង្គផងចុះ ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលដោយតុណ្ហីភាព ។ បន្ទាប់អំពីនោះ ព្រះរាជឱរសទាំង ៣ អង្គ ក៏បញ្ជូនហត្ថលេខា ចាត់ចែងដល់ក្មាក់ងារអ្នករក្សាសួយក្នុងជនបទរបស់ព្រះអង្គថា ខ្ញុំនឹងឧបដ្ឋាកព្រះមានព្រះភាគអស់កាល ៣ ខែនេះ អ្នកចូររៀបចំគ្រឿងប្រកបការឧបដ្ឋាកព្រះមានព្រះភាគ ឲ្យព្រមគ្រប់ប្រការ តាំងអំពីសាងវិហារជាដើមទៅ ។ ម្ចាស់ក្មាក់ងារអ្នករក្សាសួយនោះ រៀបចំចាត់ចែងគ្រប់យ៉ាងហើយ ក៏បញ្ជូនសំបុត្រឲ្យទ្រង់ជ្រាប ។ ព្រះរាជឱរសទាំងនោះ ក៏ស្លៀកដណ្តប់កាសាវពស្រ្ត ទ្រង់ឧបដ្ឋាកព្រះមានព្រះភាគដោយគោរព ដោយបុរសវេយ្យាវច្ចៈ ២៥០០ នាក់ នាំព្រះមានព្រះភាគទៅកាន់ជនបទ ថ្វាយព្រះវិហារឲ្យទ្រង់ចាំវស្សា ។

គហបតីបុត្រម្នាក់ ដែលជាក្មាក់ងាររក្សាឃ្លាំងរបស់ព្រះរាជឱរសទាំងនោះមួយអន្លើដោយភរិយា ជាអ្នកមានបសាទសទ្ធា ចូលទៅបដិបត្តិការថ្វាយទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធានដោយគោរព ។ ក្មាក់ងារអ្នករក្សាសួយ

ក្នុងជនបទ នាំកូនគហបតីនោះ ឲ្យធ្វើការថ្វាយដោយគោរព មួយអន្លើដោយបុរសអ្នកជនបទប្រមាណ ១១០០០ នាក់ ។ បណ្តាមនុស្សទាំងនោះ ជនពួកខ្លះ មានចិត្តត្រូវឥស្សា និងមច្ឆរិយៈគ្របសង្កត់ ជនទាំងនោះក៏នាំគ្នាធ្វើអន្តរាយដល់ទាន ដោយស៊ីទេយ្យធម៌ខ្លួនឯងខ្លះ ឲ្យដល់កូនរបស់ខ្លួនខ្លះ និងយកភ្លើងដុតរោងទាន ។ កាលបវារណាចេញវស្សា ព្រះរាជឱរសទាំងឡាយ ក៏ទ្រង់ធ្វើសក្ការៈក្រៃលែងដល់ព្រះមានព្រះភាគ តាមព្រះមានព្រះភាគ ចូលទៅគាល់ព្រះរាជបិតា ។ ព្រះមានព្រះភាគ យាងទៅក្នុងទីនោះហើយ ក៏បរិនិព្វាន ។ ព្រះរាជា ព្រះឱរស ក្នាក់ងារអ្នករក្សាសួយក្នុងជនបទ និងអ្នកក្នាក់ងារ អ្នករក្សាឃ្លាំង ធ្វើកាលកិរិយាទៅតាមលំដាប់ កើតក្នុងស្ថានសួគ៌ មួយអន្លើដោយបរិស័ទ និងបរិវារ ។ ពួកជនដែលមានចិត្តត្រូវឥស្សា និងមច្ឆរិយៈគ្របសង្កត់ ក៏នាំគ្នាទៅកើតក្នុងនរកទាំងឡាយ ។ ជនទាំង ២ ពួកនោះ ចេញពីស្ថានសួគ៌ ចូលដល់ស្ថានសួគ៌ ចេញអំពីនរកទៅកើតនរក ដោយប្រការដូច្នេះ ។ កប្បកន្លងទៅហើយ ៩២ កប្ប ។

តមក ក្នុងភទ្ទកប្បនេះ កាលព្រះពុទ្ធព្រះនាមថាកស្សប ជនដែលមានចិត្តត្រូវឥស្សា និងមច្ឆរិយៈគ្របសង្កត់ទាំងនោះ ក៏កើតជាប្រេត ។ កាលនោះមនុស្សទាំងឡាយថ្វាយទាន ឧទ្ទិសដើម្បីប្រយោជន៍ដល់ពួកប្រេតដែលជាញាតិរបស់ខ្លួនថា សូមទាននេះ មានដល់ពួកញាតិរបស់ខ្ញុំ ។ ប្រេតទាំងនោះក៏បានសម្បត្តិ ។ ខណៈនោះ ប្រេតទាំងនោះឃើញដូច្នោះ ក៏ចូលទៅគាល់ព្រះមានព្រះភាគកស្សបសម្ពុទ្ធ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើម្តេចហ្ន៎ ទើប

ពួកខ្ញុំបានសម្បត្តិខ្លះ ។ ព្រះមានព្រះភាគត្រាស់ថា ឥឡូវនេះ ពួកអ្នកមិនទាន់បានទេ តែក្នុងអនាគត នឹងមានព្រះពុទ្ធព្រះនាមថាគោតម ក្នុងកាលរបស់ព្រះមានព្រះភាគអង្គនោះ នឹងមានព្រះរាជាព្រះនាមថាពិម្ពិសារ ទ្រង់ជាញាតិរបស់ពួកអ្នក រាប់អំពីនេះថយទៅ ៩២ កប្ប ទ្រង់នឹងថ្វាយទានដល់ព្រះពុទ្ធឧទ្ទិសចំណែកកុសលដល់ពួកអ្នក កាលនោះ ទើបពួកអ្នកបានបរិភោគ ។ បានឮថា កាលព្រះពុទ្ធមានព្រះតម្រាស់យ៉ាងនេះហើយ ព្រះពុទ្ធតម្រាស់នោះ បានប្រាកដដល់ប្រេតទាំងនោះ ហាក់បីដូចជាត្រាស់ថា ពួកអ្នកនឹងបានក្នុងថ្ងៃស្អែកនេះ ។

ពេលវេលាកន្លងទៅមួយពុទ្ធន្តរ ព្រះមានព្រះភាគនៃយើងក៏កើតឡើងក្នុងលោក ។ ព្រះរាជឱរសទាំង ៣ អង្គនោះ ក៏ចុតិអំពីទេវលោក មួយអន្លើនឹងបុរស ២៥០០ នាក់ ជនទាំងនោះ បានកើតក្នុងត្រកូលព្រាហ្មណ៍ទាំងឡាយក្នុងដែនមគធៈ បួសជាឥសីដោយលំដាប់ បានជាជដិល ៣ នាក់បងប្អូន ក្នុងគយាសីសបទេស ។ ភ្នាក់ងាររក្សាស្បៀងក្នុងជនបទ បានជាព្រះបាទពិម្ពិសារ បុត្រគហបតីដែលជាភ្នាក់ងាររក្សាឃ្លាំង បានជាសេដ្ឋីឈ្មោះវិសាខ ករិយារបស់គាត់បានជាធីតារបស់សេដ្ឋីឈ្មោះធម្មទិន្នា បរិស័ទដ៏សេសកើតជាព្រះរាជបរិវាររបស់ព្រះបាទពិម្ពិសារទាំងអស់ ។ ព្រះមានព្រះភាគនៃយើងទ្រង់កើតឡើងក្នុងលោក កន្លងទៅ ៧ សប្តាហ៍ ក៏យាងមកកាន់ក្រុងពារាណសីដោយលំដាប់ ប្រកាសធម្មចក្រ ប្រោសបញ្ចវគ្គិយភិក្ខុជាដើមរឿយៗ ទៅ រហូតដល់ទូន្មានជដិលទាំង ៣ នាក់ ដែលមានបរិវារ ២៥០០ នាក់ ទើបយាងទៅកាន់ក្រុង

រាជគ្រឹះ ។ ក្នុងក្រុងរាជគ្រឹះនោះ ទ្រង់ប្រោសព្រះបាទពិម្ពិសារដែលយាងចូលទៅគាល់ក្នុងថ្ងៃនោះឯង ឲ្យតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយព្រាហ្មណ៍និងគហបតី អ្នកមគធៈ ដកមួយម៉ឺននាក់ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តរបស់ព្រះបាទពិម្ពិសារ ដើម្បីសោយក្នុងថ្ងៃស្អែក ។ លុះថ្ងៃស្អែកឡើង កាលសក្កទេវរាជទ្រង់សរសើរដោយគាថាទាំងឡាយ យ៉ាងនេះជាដើមថា

**ទន្តោ ទន្តេហិ សហ បុរាណជដិលេហិ វិប្បមុត្តោ វិប្បមុត្តេហិ**
**សិង្គីនិក្ខសុវណ្ណោ រាជគហំ បាវិសិ ភគវា ។**

ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ ( នូវឥន្ទ្រិយ ) មានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាស ឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលជាអ្នកទូន្មានហើយ ( នូវឥន្ទ្រិយ ) ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ទ្រង់ចូលកាន់ក្រុងរាជគ្រឹះ ដូច្នេះ ។

ទ្រង់ទទួលមហាទាន ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ ប្រេតទាំងនោះ ឈរចោមរោម ដោយទន្ទឹងថា ឥឡូវនេះ ព្រះរាជាទ្រង់នឹងឧទ្ទិសទានដល់ពួកយើង ឥឡូវនេះ ព្រះរាជាទ្រង់នឹងឧទ្ទិសទានដល់ពួកយើង ។ ឯព្រះបាទពិម្ពិសារ ថ្វាយទានហើយ ទ្រង់ព្រះតម្រិះថា ព្រះមានព្រះភាគ គប្បីប្រថាប់នៅក្នុងទីណាហ្ន៎ ទ្រង់ព្រះតម្រិះដល់រឿងទីគង់នៅ របស់ព្រះមាន

ព្រះភាគប៉ុណ្ណោះ ទ្រង់មិនបានឧទ្ទិសទាននោះដល់បុគ្គលណាឡើយ ។

ប្រេតទាំងឡាយអស់សង្ឃឹម លុះពេលរាត្រី ទើបនាំគ្នាធ្វើសំឡេងប្លែកៗ ទ្រហឹងអឺងកង គួរតក់ស្លុតក្រៃលែងក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់ស្លុតព្រះរាជហឫទ័យភ័យខ្លាច លុះព្រឹកឡើង ក៏ក្រាបទូលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮសំឡេងបែបនេះ ហេតុកេទអ្វីនឹងមានដល់ខ្ញុំព្រះអង្គឬហ្ន៎ ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្រសូមទ្រង់កុំខ្លាចឡើយ មិនមានវត្ថុអាក្រក់ណាមួយ កើតដល់មហាបពិត្រទេ តែបុរាណញាតិរបស់មហាបពិត្រ កើតជាប្រេតមាន ប្រេតទាំងនោះ ត្រាច់រង្គាត់អស់មួយពុទ្ធន្តរ ទន្ទឹងចំពោះមហាបពិត្រថា ទ្រង់នឹងថ្វាយទានដល់ព្រះពុទ្ធ ហើយឧទ្ទិសចំណែកបុណ្យដល់ពួកគេ កាលពីម្សិលមិញ មហាបពិត្រ មិនបានឧទ្ទិសចំណែកកុសលដល់ប្រេតទាំងនោះ ទើបពួកប្រេតនោះអស់សង្ឃឹម នាំគ្នាបន្លឺសំឡេងចម្លែកៗ អឺងកង ដូច្នោះ ។

ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលខ្ញុំព្រះអង្គថ្វាយទាន ពួកប្រេតទាំងនោះ គួរបានដែរឬទេ ។ ព្រះមានព្រះភាគត្រាស់ថា បាន មហាបពិត្រ ។ ព្រះបាទពិម្ពិសារក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះមានព្រះភាគទ្រង់ទទួលនិមន្ត ហើយសោយក្នុងថ្ងៃស្អែកនេះផងចុះ ខ្ញុំព្រះអង្គនឹងឧទ្ទិសទានដល់ពួកប្រេតនោះ ។ ព្រះមានព្រះភាគទ្រង់ក៏ទទួល ។ ព្រះរាជាយាងចូលព្រះរាជនិវេសន៍ ចាត់ចែងមហាទាន ហើយឲ្យក្រាបទូលកត្តកាលដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ យាង

ចូលខាងក្នុងព្រះរាជនិវេសន៍ ប្រថាប់គង់លើពុទ្ធាសនៈដែលគេរៀបចំ មួយអន្លើដោយភិក្ខុសង្ឃ ។

ប្រេតទាំងនោះ នាំគ្នាឈរខាងក្រៅជញ្ជាំងជាដើម ដោយទន្ទឹងថា ថ្ងៃនេះពួកយើងនឹងបានអ្វីខ្លះ ។ ព្រះមានព្រះភាគ ទ្រង់បានធ្វើដោយអាការដែលប្រេតទាំងនោះ ប្រាកដដល់ព្រះរាជាគ្រប់គ្នា ។

ព្រះរាជាថ្វាយទឹកទក្ខិណោទក ឧទ្ទិសថា សូមទាននេះ មានដល់ពួកញាតិរបស់ពួកខ្ញុំ ។ រំពេចនោះឯង ស្រះបោក្ខរណី ដេរដាសដោយផ្កាឈូក ក៏កើតដល់ប្រេតទាំងនោះ ប្រេតទាំងនោះក៏ងូត និងផឹកក្នុងស្រះបោក្ខរណីនោះ រម្ងាប់សេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក និងសេចក្តីស្រេកឃ្លានបាន ហើយមានពណ៌សម្បុរដូចមាស ។

លំដាប់នោះ ព្រះរាជា ថ្វាយយាគូ របស់ទំពា របស់បរិភោគជាដើម ហើយទ្រង់ឧទ្ទិស ។ ក្នុងរំពេចនោះឯង បបរ របស់ទំពា និងរបស់បរិភោគដែលជាទិព្វ ក៏កើតដល់ប្រេតទាំងនោះ ។ ប្រេតទាំងនោះ ក៏នាំគ្នាបរិភោគរបស់ទិព្វទាំងនោះ មានឥន្ទ្រិយឆ្អែតស្កប់ស្កល់ ។

លំដាប់នោះ ព្រះរាជាថ្វាយសំពត់ និងសេនាសនៈជាដើម ទ្រង់ឧទ្ទិសឲ្យនូវគ្រឿងអលង្ការផ្សេងៗ មានសំពត់ទិព្វ យានទិព្វ ប្រាសាទទិព្វ កម្រាល និងទីដេកជាដើម ក៏កើតឡើងដល់ពួកប្រេតទាំងនោះ ។ សម្បត្តិរបស់ពួកប្រេតទាំងនោះ ប្រាកដគ្រប់យ៉ាងដោយប្រការណា ព្រះមានព្រះភាគ ក៏ទ្រង់អធិដ្ឋានឲ្យព្រះរាជាឃើញដោយប្រការនោះ ។ ព្រះរាជាទ្រង់ត្រេកអរក្រៃលែង ។ បន្ត

អំពីនោះ ព្រះមានព្រះភាគទ្រង់សោយស្រេចហើយ ទ្រង់ហាមកត្តហើយ បានត្រាស់ព្រះគាថាទាំងនេះថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ជាដើម ដើម្បីទ្រង់អនុមោទនាដល់ព្រះបាទមគធរដ្ឋ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ មាតិកានេះថា **យេន យត្ថ យទា យស្មា តិរោកុឌ្ឌំ បកាសិតំ បកាសយិត្វា តំ សព្វំ** ក៏ជាការចែកហើយទាំងដោយសង្ខេប និងដោយពិស្តារ ។

ឥឡូវនេះ នឹងពណ៌នាសេចក្តីនៃតិរោកុឌ្ឌសូត្រនេះតាមលំដាប់ គឺ

## អធិប្បាយគាថាទី ១

នឹងពណ៌នាក្នុងបឋមគាថាមុន ។ ចំណែកខាងក្រៅនៃជញ្ជាំងទាំងឡាយ ហៅថា **តិរោកុឌ្ឌ** ។ ពាក្យថា **តិដ្ឋន្តិ** ជាពាក្យពោលដល់ឥរិយាបថឈរ ព្រោះហាមឥរិយាបថអង្គុយជាដើម ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ដល់ពួកប្រេត ដែលឈរត្រង់ចំណែកដទៃនៃជញ្ជាំងក្នុងទីនេះថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ឈរនៅត្រង់ខាងក្រៅជញ្ជាំង ដូចលោកពោលដល់បុគ្គលដែលសម្តែងឫទ្ធិផ្សេងៗ ដែលទៅក្នុងចំណែកដទៃនៃកំពែង និងចំណែកដទៃនៃភ្នំថា ទៅក្រៅកំពែង ក្រៅភ្នំ មិនទើសទាក់ ដូច្នោះ ។ ក្នុងពាក្យថា **សន្ធិសិង្ឃាដកេសុ ច** នោះ ផ្លូវដែលមានមុំ ៤ ឬត្រង់ទី-តនៃផ្ទះ និងទី-តនៃជញ្ជាំង និងមាត់បង្អួច លោកហៅថា **សន្ធិ** ។ ផ្លូវបែកជា ៣ លោកហៅថា **សិង្ឃាដក** ។ ព្រះមានព្រះភាគ ទ្រង់ធ្វើពាក្យនោះកន្លែងតែមួយ ភ្ជាប់ជាមួយពាក្យដើម ទើបត្រាស់ថា **សន្ធិសិង្ឃាដកេសុ ច** ។ បទថា **ទ្វារពាហាសុ**

**តិដ្ឋន្តិ** បានដល់ ឈរផ្អែកទ្វារព្រះនគរ និងទ្វារផ្ទះ ។ ផ្ទះញាតិអំពីមុនក្តី ផ្ទះរបស់ខ្លួនដែលធ្លាប់គ្រប់គ្រងក្តី ឈ្មោះថា ផ្ទះរបស់ខ្លួន ក្នុងពាក្យថា **អាគន្ត្វាន សកំ ឃរំ** នេះ ។ ព្រោះហេតុដែលប្រេតទាំងនោះ នាំគ្នាមកដោយសកសញ្ញា គឺសម្គាល់ថាជាផ្ទះរបស់ខ្លួន ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ដល់ផ្ទះទាំង ២ នោះថា **អាគន្ត្វាន សកំ ឃរំ** ប្រែថា មកកាន់ផ្ទះរបស់ខ្លួន ។

# អធិប្បាយគាថាទី ២

ព្រះមានព្រះភាគ កាលទ្រង់បង្ហាញដល់ព្រះរាជា នូវប្រេតជាច្រើនដែលនាំគ្នាមកកាន់ព្រះរាជនិវេសន៍ របស់ព្រះបាទពិម្ពិសារ ដែលជាផ្ទះញាតិក្នុងកាលមុន សូម្បីខ្លួនមិនធ្លាប់គ្រប់គ្រងមក ដោយសម្គាល់ថា ជាផ្ទះរបស់ខ្លួន ឈរនៅខាងក្រៅជញ្ជាំង ត្រង់ផ្លូវបែកជា ៤ ផ្លូវបែកជា ៣ និងត្រង់សន្ទះទ្វារ សោយផលនៃសេចក្តីប្រណែន និងសេចក្តីកំណាញ់ ពួកខ្លះមានពុកមាត់ និងសក់វែង មានមុខខ្មៅ មានអវយវៈតូចធំចង់ដោយចំណងធូរខ្លះ តឹងខ្លះ មានសក់កន្ទ្រើង ដូចដើមត្នោតត្រូវភ្លើងឆេះ ឈរបង្ហាញខ្លួនក្នុងទីនោះៗ ពួកខ្លះមានសរីរៈត្រូវភ្លើងឆេះខាងក្នុងពោះ អណ្តាតភ្លើងចេញតាមមាត់ ព្រោះការត្រដុសគ្នានៃឈើក្តួតភ្លើង គឺសេចក្តីស្រេកឃ្លានដុតរោល ពួកខ្លះ មិនបានផឹករសជាតិដទៃ ក្រៅអំពីរស គឺសេចក្តីស្រេកឃ្លាន ព្រោះសូម្បីបានបាយទឹក ក៏មិនអាចបរិភោគបានតាមត្រូវការ ព្រោះមានបំពង់កប៉ុនគូថម្ជុល និងមានពោះធំដូចភ្នំ ពួកខ្លះ មានសរីរៈមិនគួរមើល វិកល វិការ គួរឲ្យខ្លាចពន់ពេក បានទឹកខ្ទុះ ទឹកឈាម ទឹករំអិលជាដើម ដែលហូរចេញអំពីបូសដែលបែកនៃ

គ្មានិងគ្នា ឬរបស់សត្វដទៃ លិទ្ធក្រេបដូចទឹកអម្រឹត ទើបត្រាស់ថា

ប្រេតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថាជា
ផ្ទះរបស់ខ្លួន ហើយឈរនៅជិតខាងក្រៅជញ្ជាំង
ទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែបជា ៣
ទាំងឡាយខ្លះ ជិតទ្វារក្រុង និងទ្វារផ្ទះទាំងឡាយខ្លះ ។

កាលទ្រង់សម្តែងភាពដែលកម្មរបស់ប្រេតទាំងនោះធ្វើមកហើយ ជាកម្មធ្ងន់ ទើបត្រាស់គាថាទី ២ ថា **បហូតេ អន្នបានម្ហិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បហូតេ** បានដល់ មិនតិច ។ លោកអធិប្បាយថា ច្រើន រហូតល្មមត្រូវការ ។ ផ្លាស់ **ព** ជា **ប** ដូចក្នុងប្រយោគជាដើមថា **បហុសន្តោ ន ភរតិ** បុគ្គលមានច្រើនក៏មិនចិញ្ចឹម ។ តែអាចារ្យពួកខ្លះសូធ្យថា **បហូតេ** ក៏មាន **ពហូកេ** ក៏មាន ។ បាឋៈទាំងនោះ ជាបាឋៈដែលសរសេរដោយការភ្លាត់ ។ បាយផង ទឹកផង ឈ្មោះថា បាយ និងទឹករបស់ទំពាផង របស់បរិភោគផង ឈ្មោះថា របស់ទំពា និងរបស់បរិភោគ ។ ព្រះមានព្រះភាគទ្រង់សម្តែងអាហារ ៤ យ៉ាង គឺរបស់ស៊ី របស់ផឹក របស់ទំពា និងរបស់លិទ្ធភ្លក្សដោយបទនេះ ។ បទថា **ឧបដ្ឋិតេ** បានដល់ ចូលទៅតាំងទុក ។ លោកអធិប្បាយថា ចាត់ចែង តាក់តែង រួបរួម ។ បទថា **ន កោចិ តេសំ សរតិ សត្តានំ** សេចក្តីថា កាលសត្វទាំងនោះកើតក្នុងបិត្តិវិស័យ បុគ្គលណាម្នាក់ ជាមាតាក្តី បុត្រក្តី ក៏មិនរឭកដល់ ។ ព្រោះហេតុអ្វី ព្រោះកម្មជាបច្ច័យ គឺព្រោះមច្ឆរិយកម្មដែលខ្លួនធ្វើមាន ដោយបដិសេធការ

*ទទួល និងការឲ្យជាដើមជាបច្ច័យ ព្រោះកម្មរបស់សត្វទាំងនោះ មិនឲ្យញាតិនឹកឃើញ ។*

## អធិប្បាយគាថាទី ៣

*ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថា មិនមានញាតិណាមួយ ដែលលួមរឭកដល់ ព្រោះកម្មដែលមានវិបាកជាទុក្ខក្ដៅផ្សា ដែលសត្វទាំងនោះធ្វើ ទុកជាបច្ច័យដល់សត្វដែលជាប្រេតទាំងនោះ ដែលត្រាច់ទន្ទឹងចំពោះញាតិទាំងឡាយថា កាលបាយទឹកជាដើម មិនមែនតិច ដែលញាតិចូលទៅតាំងទុកក្នុងសង្ឃ គួរតែញាតិទាំងឡាយ គប្បីឲ្យអ្វីមួយ ឧទ្ទិសដល់ពួកយើងខ្លះ យ៉ាងនេះ ទើបត្រាស់ថា*

*កាលបើបាយទឹក បង្អែម និងចំអាបមានគ្រប់គ្រាន់ ដែលពួកញាតិតាក់តែងហើយ មិនមានញាតិណាមួយនឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។ កាលទ្រង់សរសើរភាពដែលព្រះរាជាថ្វាយឧទ្ទិសដល់ព្រះញាតិរបស់ព្រះរាជា ដែលកើតក្នុងបិត្តិវិស័យ ទើបត្រាស់ព្រះគាថាទី ២ ថា* **ឯវំ ទទន្តិ ញាតីនំ** *ជាដើម ។*

*បណ្ដាបទទាំងនោះ បទថា* **ឯវំ** *ជាពាក្យឧបមា ។ ពាក្យថា* **ឯវំ** *នោះសម្ពន្ធជា ២ ន័យ គឺ*

*ជនណា ជាអ្នកអាណិតអាសូរ ជនទាំងនោះ រមែងឲ្យបាយទឹកជាដើម ដើម្បីញាតិទាំងឡាយ កាលញាតិណាមួយ រឭកមិនបាន ព្រោះកម្មរបស់សត្វទាំងនោះជាបច្ច័យយ៉ាងនេះ ១ ។ ថ្វាយព្រះពរមហាបពិត្រ ជនទាំងឡាយណា*

ជាអ្នកអាណិតអាសូរ ជនទាំងនោះ រមែងឲ្យបាយទឹកដ៏ស្អាតប្រណីត ជាកប្បិយ គួរតាមកាល ដើម្បីញាតិទាំងឡាយ ដូចមហាបពិត្រថ្វាយទានដូច្នោះ ១ ។

បណ្ដាបទទាំងនោះ បទថា **ទទន្តិ** បានដល់ ឲ្យ ឧទ្ទិស ប្រគល់ឲ្យ ។ បទថា **ញាតីនំ** បានដល់ ជនដែលទាក់ទងខាងមាតា និងខាងបិតា ។ បទថា **យេ** បានដល់ ពួកណានីមួយ ជាបុត្រក្ដី ធីតាក្ដី បងប្អូនក្ដី ។ បទថា **ហោន្តិ** ប្រែថា រមែងមាន ។ បទថា **អនុកម្បកា** បានដល់ បុគ្គលបំណងប្រយោជន៍ បុគ្គលស្វែងរកប្រយោជន៍ ។ បទថា **សុចិំ** បានដល់ ឥតមន្ទិល គួរសរសើរ ត្រេកអរ កើតឡើងដោយធម៌ បានមកដោយធម៌ ។ បទថា **បណីតំ** បានដល់ ឧត្ដម ប្រសើរបំផុត ។ បទថា **កាលេន** បានដល់ តាមកាល ដែលពួកប្រេតជាញាតិមកឈរខាងក្រៅជញ្ជាំងជាដើម ។ បទថា **កប្បិយំ** បានដល់ គួរ សមគួរ គួរបរិភោគរបស់ព្រះអរិយៈទាំងឡាយ ។ បទថា **បានភោជនំ** បានដល់ ទឹកផង បាយផង ឈ្មោះថា **បានភោជនំ** ។ ក្នុងទីនេះ លោកបំណងយកទេយ្យធម៌គ្រប់យ៉ាង ដោយលើកទឹក និងបាយឡើងជាប្រធាន ។

# អធិប្បាយគាថាទី ៤ សម្ពន្ធនឹងគាថាទី ៣

ព្រះមានព្រះភាគ កាលទ្រង់សរសើរបាយ និងទឹក ដែលព្រះបាទមគធរដ្ឋទ្រង់ថ្វាយ ដើម្បីអនុគ្រោះដល់ពួកព្រះញាតិ ដែលជាប្រេតយ៉ាងនេះ ទើបត្រាស់ថា

ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹក និងភោជនដ៏ហ្មត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាល ដល់ញាតិទាំងឡាយ យ៉ាងនេះ ។ កាលទ្រង់សម្តែងប្រការដែលទានឲ្យហើយឈ្មោះថា ឲ្យដើម្បីញាតិទាំងនោះទៀត ទើបត្រាស់ពាក់កណ្តាលខាងដើមនៃគាថាទី ៤ ថា **ឥទំ វោ ញាតីនំ ហោតុ** ជាដើម គប្បីសម្ពន្ធអត្ថ និងកន្ទុះដើមគាថានៃគាថាទី ៣ ថា ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឲ្យនូវទឹក និងភោជនដ៏ហ្មត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ យ៉ាងនេះថា ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខ ។ ដោយហេតុនោះ ដូចអាការដែលគប្បីឲ្យ ជាការធ្វើហើយ ដោយ **ឯវំ** សព្ទ ដែលមានអត្ថថា អាការ ក្នុងពាក្យថា ជនទាំងនោះ រមែងឲ្យដោយអាការយ៉ាងនេះថា សូមទាននេះឯង មានដល់ញាតិទាំងឡាយ មិនមែនដោយអាការដទៃ ។

បណ្តាបទទាំងនោះ បទថា **ឥទំ** ជាបទសម្តែងគំរូនៃទេយ្យធម៌ ។ បទថា **វោ** ត្រឹមតែជានិបាតតែម្យ៉ាង មិនមែនឆដ្ឋីវិភត្តិ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា ។** និងថា **យេហិ វោ អរិយា ។** បទថា **ញាតីនំ ហោតុ** សេចក្តីថា ចូរមានដល់ញាតិទាំងឡាយ ដែលកើតក្នុងបិត្តិវិស័យ ។ បទថា **សុខិតា ហោន្តុ ញាតយោ** សេចក្តីថា សូមពួកញាតិដែលចូលដល់បិត្តិវិស័យទាំងនោះ ចូរជាអ្នកសោយផលទាននេះ មានសេចក្តីសុខចុះ ។

# អធិប្បាយចុងគាថាទី ៤ សម្ពន្ធនឹងដើមគាថាទី ៥

*ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រការដែលទាន ដែលញាតិគប្បីឲ្យដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិស័យ ទើបត្រាស់ថា សូមទាននេះឯង មានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានទូវសេចក្តីសុខ ដូច្នេះ ព្រោះហេតុដែលព្រះមានព្រះភាគត្រាស់ថា សូមទាននេះឯង មានដល់ញាតិទាំងឡាយ កម្មដែលបុគ្គលណាមួយធ្វើហើយ រមែងមិនឲ្យផលដល់បុគ្គលម្នាក់ទៀត តែវត្ថុនោះដែលញាតិឲ្យឧទ្ទិសយ៉ាងនោះតែម្យ៉ាង រមែងជាបច្ច័យដល់កុសលកម្មនៃញាតិទាំងឡាយ ដូច្នោះ កាលទ្រង់សម្តែងប្រការដែលកុសលកម្ម ដែលឲ្យកើតផលភ្លាមៗ ព្រោះវត្ថុនោះឯងទៀត ទើបត្រាស់ដល់កន្លះគាថាក្រោយនៃគាថាទី ៤ ថា* **តេ ច តត្ថ** *និងកន្លះគាថាខាងដើមនៃគាថាទី ៥ ថា* **បហូតេ អន្នបានម្ហិ** ។

*កន្លះគាថាដើម និងកន្លះគាថាក្រោយ នៃគាថាទាំងនោះ មានសេចក្តីថា លោកអធិប្បាយថា ប្រេតដែលជាញាតិទាំងនោះមកដោយជុំវិញ មកប្រជុំរួមគ្នា ក្នុងទីមួយកន្លែង ដែលញាតិឲ្យទាននោះ លោកអធិប្បាយថា ប្រេតទាំងនោះ មកដោយប្រពៃ មករួមគ្នា មកព្រមគ្នា ដើម្បីសេចក្តីត្រូវការយ៉ាងនេះថា ញាតិទាំងឡាយរបស់យើងនឹងឧទ្ទិសទាននេះ ដើម្បីជាប្រយោជន៍ដល់យើងទាំងឡាយ ។ បទថា* **បហូតេ អន្នបានម្ហិ** *សេចក្តីថា ក្នុងបាយទឹកដែលញាតិឲ្យឧទ្ទិសដើម្បីខ្លួនមានច្រើននោះ ។ បទថា* **សក្កច្ចំ អនុមោទរេ** *សេចក្តីថា ប្រេតទាំងនោះជឿមាំលើផលនៃកម្ម មិនលះបង់នូវការកោតក្រែងមានចិត្តមិនញាប់ញ័រ រមែងត្រេកអរអនុមោទនា កើតបីតិបាមោជ្ជថា ទាននេះ*

ចូរមានផល ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងទាំងឡាយ ។

# អធិប្បាយចុងគាថាទី ៥ ភ្ជាប់នឹងដើមគាថាទី ៦

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងប្រការដែលកុសលកម្ម ឲ្យផលកើតភ្លាមៗ ដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិស័យយ៉ាងនេះ ទើបត្រាស់ថា

ចំណែកប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកជួបជុំគ្នា
ហើយ ក្នុងមន្ទីរឲ្យទាននោះ កាលបើបាយ និងទឹកមានល្មម
គ្រាន់ ក៏អនុមោទនាដោយគោរព ។

កាលទ្រង់សម្ដែងអាការសរសើរ ប្រារព្ធញាតិទាំងឡាយរបស់ប្រេតទាំងនោះ ទើបសោយផលនៃកុសលកម្ម ដែលកើតព្រោះអាស្រ័យពួកញាតិទៀត ទើបត្រាស់កន្ទះគាថាក្រោយ នៃគាថាទី ៥ ថា **ចិរំ ជីវន្តុ** និងកន្ទះគាថាដើម នៃគាថាទី ៦ ថា **អម្ហាកញ្ច កតា បូជា ។**

កន្ទះគាថាក្រោយ និងកន្ទះគាថាដើម នៃគាថាទាំងនោះ មានសេចក្ដីថា បទថា **ចិរំ ជីវន្តុ** បានដល់ មានជីវិតនៅយូរ មានអាយុវែង ។ បទថា **នោ ញាតី** ប្រែថា ញាតិទាំងឡាយរបស់ពួកយើង ។ បទថា **យេសំ ហេតុ** បានដល់ ព្រោះអាស្រ័យញាតិទាំងឡាយណា ព្រោះហេតុនៃញាតិពួកណា ។ បទថា **លភាម្ហសេ** ប្រែថា បាន ។ ពួកប្រេតពោលអាងសម្បត្តិដែលខ្លួនបានក្នុងខណៈនោះ ។

ពិតហើយ ទក្ខិណា រមែងសម្រេចផល គឺកើតផលក្នុងខណៈនោះបាន ក៏ដោយអង្គ ៣ គឺដោយការអនុមោទនារបស់ប្រេតទាំងឡាយ ១ ដោយការ

ឧទ្ទិសរបស់ទាយកទាំងឡាយ ១ ដោយការដល់ព្រមនៃទក្ខិណេយ្យបុគ្គល ១ ។

បណ្តាអង្គទាំង ៣ នោះ ទាយកទាំងឡាយ ជាហេតុពិសេស ដោយហេតុនោះ ទើបប្រេតទាំងឡាយពោលថា **យេសំ ហេតុ លភាម្ហសេ** ប្រែថា រមែងបានព្រោះហេតុនៃញាតិពួកណា ។ បទថា **អម្ហាកញ្ច កតា បូជា** សេចក្តីថា និងញាតិទាំងឡាយដែលឧទ្ទិសទាននេះ យ៉ាងនេះថា សូមទាននេះ មានដល់ញាតិទាំងឡាយរបស់យើង ដូច្នេះ ឈ្មោះថា ធ្វើការបូជាពួកយើងហើយ ។ បទថា **ទាយកា ច អនិប្ផលា** សេចក្តីថា កម្មដែលសម្រេចមកអំពីការបរិច្ចាគ ដែលទាយកធ្វើហើយក្នុងសន្តានណា ទាយកទាំងឡាយឈ្មោះថា មិនឥតផល ក៏ព្រោះកម្មនោះឲ្យផលក្នុងសន្តាននោះប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះ បុគ្គលអ្នកចោទសួរពោលថា ញាតិទាំងឡាយ ចូលដល់បិត្តិវិស័យបានប៉ុណ្ណោះឬ ឬថា សូម្បីបុគ្គលដទៃៗ ក៏បាន ។ សូមចម្លើយបង្ហាញដូច្នេះ ព្រះមានព្រះភាគត្រូវព្រាហ្មណ៍ឈ្មោះជាណុស្សោណិទូលសួរហើយ ក៏ទ្រង់ព្យាករសេចក្តីនេះដូច្នេះថា ក្នុងសេចក្តីនេះ តថាគតគប្បីពោលពាក្យណា ។ សមដូចព្រះសង្គីតិកាចារ្យពោលដូច្នេះថា

> បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ តែងឲ្យទាន
> តែងធ្វើអំពើ ដែលគេគប្បីធ្វើដោយសទ្ធា ហើយឧទ្ទិសថា
> ទាននេះ សូមឲ្យសម្រេចផល ដល់ប្រេតទាំងឡាយ ជា
> ញាតិសាលោហិត ពួកប្រេតទាំងឡាយ ជាញាតិសា-
> លោហិត សូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏

ចម្រើន ចុះទាននោះ នឹងសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិតដែរឬទេ ប្រេតទាំងឡាយ ជាញាតិ-សាលោហិតនោះ នឹងបរិភោគនូវទាននោះ បានដែរឬទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ទាននេះ សម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន ទីដែលគួរ តើដូចម្តេច ទីដែលមិនគួរ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ពោល ពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅក៏ទៅកើតក្នុងនរក អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយកើតក្នុងនរក សត្វនរកនោះ តែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងនរកនោះ ដោយសារអាហារនោះ សត្វនរកនោះឋិតនៅក្នុងនរកនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយ

រាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតនៃតិរច្ឆាន អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយ ដែលកើតក្នុងកំណើតតិរច្ឆាន សត្វតិរច្ឆាននោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកឯបុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាប ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកមនុស្ស អាហារណា ជាអាហារសម្រាប់ពួកមនុស្ស បុគ្គលនោះ ក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ បុគ្គលនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នក

វៀរស្រឡះចាកបាណាតិបាត ។បេ។ មានសេចក្តីយល់ត្រូវ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងពួកទេវតា អាហារណាជាអាហារសម្រាប់ពួកទេវតា ទេវតានោះ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ទេវតានោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ មិនសម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថា ទីមិនគួរ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។បេ។ មានសេចក្តីយល់ខុស បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងបិត្តិវិស័យ អាហារណា ជាអាហារសម្រាប់សត្វទាំងឡាយ ដែលកើតក្នុងបិត្តិវិស័យ ប្រេតនោះ ក៏ញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬក៏ពួកមិត្តអាមាត្យក្តី ជនជាញាតិសាលោហិតក្តី ឧទ្ទិសឲ្យនូវទានណា ដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ ប្រេតនោះ ឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថាទីគួរ ។

ជានុស្សោណិព្រាហ្មណ៍ទូលសួរថា

បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេត ជាញាតិ-សាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ តើអ្នកណាបរិភោគទាននោះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា

អើព្រាហ្មណ៍ ពួកប្រេតដែលជាញាតិសាលោហិតដទៃទៀតរបស់គេ គង់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯងបរិភោគទាននោះ ។

ជានុស្សោណិព្រាហ្មណ៍ទូលសួរថា

បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេត ជាញាតិសាលោហិតដទៃទៀតរបស់គេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណា បរិភោគទាននោះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា

អើ ព្រាហ្មណ៍ ទីណាដែលស្ងាត់ចាកប្រេតទាំងឡាយ ជាញាតិសាលោហិត ដោយកាលជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺថា មិនធ្លាប់មានឡើយ ម្នាលព្រាហ្មណ៍ មួយទៀត ជម្មតាអ្នកឲ្យទាន មិនមែនជាគ្មានផលទេ ។

## អធិប្បាយ ចុងគាថាទី ៦ ភ្ជាប់នឹងដើមគាថាទី ៧

ព្រះមានព្រះភាគ កាលទ្រង់សរសើរព្រះរាជា ព្រោះអាស្រ័យសម្បត្តិរបស់ពួកព្រះញាតិក្នុងជាតិមុនរបស់ព្រះបាទមគធរដ្ឋ ដែលចូលដល់បិត្តិវិស័យ ទើបទ្រង់សម្តែងថា សូមថ្វាយព្រះពរ ព្រះញាតិរបស់មហាបពិត្រទាំងនោះត្រេកអរ នាំគ្នាសរសើរក្នុងទានសម្បទានេះ ទើបត្រាស់ថា

យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិរបស់យើងទាំងឡាយនោះរស់នៅយឺនយូរ ការបូជាដែលញាតិទាំងឡាយ ធ្វើហើយដល់យើងទាំងឡាយក្តី ញាតិទាំងឡាយ ជាអ្នកឲ្យទានក្តី មិនមែនជាឥតផលឡើយ ដូច្នេះ ។

កាលទ្រង់សម្តែងការមិនមានហេតុដែលឲ្យបានសម្បត្តិដទៃ មានកសិកម្មនិងគោរក្ខកម្មជាដើមរបស់ពួកប្រេត ដែលចូលដល់បិត្តិវិស័យទាំងនោះ និងភាពដែលពួកប្រេតទាំងនោះ ញុំាំងជីវិតឲ្យប្រព្រឹត្តទៅដោយទាន ដែលញាតិឲ្យអំពីមនុស្សលោកនេះ ទើបត្រាស់កន្លះគាថាក្រោយនៃគាថាទី ៦ ថា **ន ហិ តត្ថ កសី អត្ថិ** និងគាថាទី ៧ នេះថា **វណិជ្ជា តាទិសី** ជាដើម ។

ក្នុងគាថានោះ ពណ៌នាសេចក្តីដូច្នេះ សូមថ្វាយព្រះពរ ក្នុងបិត្តិវិស័យនោះ មិនមានកសិកម្ម ដែលពួកប្រេតទាំងនោះនឹងអាស្រ័យហើយ បាននូវសម្បត្តិ ។ បទថា **គោរក្ខេត្ថ ន វិជ្ជតិ** សេចក្តីថា មិនមែនមិនមានកសិកម្មតែម្យ៉ាងប៉ុណ្ណោះទេ ក្នុងបិត្តិវិស័យនោះ សូម្បីតែគោរក្ខកម្មក៏មិនមាន ដែលពួកប្រេតទាំងនោះអាស្រ័យហើយ បានសម្បត្តិ ។ បទថា **វណិជ្ជា តាទិសី**

**ឧត្ថិ** សេចក្ដីថា មិនមានការជួញដូរ ដែលជាហេតុឲ្យបានសម្បត្តិនៃពួកប្រេត ទាំងនោះ ។ បទថា **ហិរញ្ញេន កយាកយំ** សេចក្ដីថា ក្នុងបិត្តិវិស័យនោះ មិនមាន សូម្បីតែការជួញដូរដោយប្រាក់ ដែលជាហេតុឲ្យបានសម្បត្តិរបស់ពួកប្រេតទាំងនោះ ។

បទថា **ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហឹ** សេចក្ដីថា តែពួកប្រេត រមែងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយទានដែលពួកញាតិ ឬពួកមិត្តសម្លាញ់ឲ្យទៅអំពីមនុស្សលោកនេះតែម្យ៉ាង ។ បទថា **បេតា** បានដល់ ពួកសត្វដែលចូលដល់បិត្តិវិស័យ ។ បទថា **កាល-កតា** បានដល់ ទៅតាមពេលស្លាប់របស់ខ្លួន ។ អធិប្បាយថា ធ្វើកាល-កិរិយា ធ្វើមរណកាល ។ បទថា **តហឹ** បានដល់ បិត្តិវិស័យនោះ ។

## អធិប្បាយគាថាទី ៨ និងគាថាទី ៩

ព្រះមានព្រះភាគ កាលត្រាស់ថា បុគ្គលធ្វើកាលកិរិយាទៅហើយ តែង ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យនោះ ដោយទានដែលពួកញាតិ មិត្តសម្លាញ់ឲ្យហើយអំពីមនុស្សលោកនេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសសេចក្ដីនោះ ដោយឧបមាទាំងឡាយ ទើបត្រាស់ ២ គាថានេះថា **ឧន្នតេ ឧទកំ វុដ្ឋំ** ជាដើម ។

គាថានោះ មានសេចក្ដីថា ទឹកដែលធ្លាក់ពីលើមេឃ ស្រក់ចុះលើទីទួល លើទីភូមិភាគដែលខ្ពស់ រមែងហូរចុះទៅកាន់ទីទាប គឺហូរទៅដល់ភូមិភាគដែលទាប យ៉ាងណា ទានដែលពួកញាតិ មិត្តសម្លាញ់ឲ្យ អំពីមនុស្សលោក

នេះ រមែងសម្រេចផល អធិប្បាយថា កើតផល ប្រាកដផលដល់ពួកប្រេត ដូច្នោះដូចគ្នា ។ ពិតហើយ បេតលោក ឈ្មោះថា ឋានៈ គឺទីតាំងនៃសេចក្តីសម្រេចផលនៃទាន ដូចជាទីទាប ជាឋានៈដែលដក់ទឹកហូរមក ដូចព្រះតម្រាស់ត្រាស់ថា ម្នាលព្រាហ្មណ៍ ទាននោះ សម្រេចផល ដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯងហៅថា ទីគួរ ។ ឧបមាដូចទឹកដែលហូរអំពីជ្រោះ ញកភ្នំ អូរធំ អូរតូច បឹង ស្ទឹងធំ រមែងធ្វើសាគរ គឺសមុទ្រឲ្យពេញ យ៉ាងណា ទានដែលញាតិមិត្ត សម្លាញ់ ឲ្យទៅអំពីមនុស្សលោកនេះ រមែងសម្រេចផល ដល់ពួកប្រេត តាមន័យដែលពោលមកអំពីមុនហើយ ដូច្នោះ ។

## អធិប្បាយគាថាទី ១០

ព្រះមានព្រះភាគ កាលទ្រង់ប្រកាសសេចក្តីនេះថា បុគ្គលកាលធ្វើកាល-កិរិយាទៅហើយ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យ ដោយទានដែលញាតិមិត្តសម្លាញ់ឲ្យទៅអំពីមនុស្សលោកនេះ ដូច្នេះហើយ កាលទ្រង់សម្តែងគាថា ព្រោះហេតុដែលពួកប្រេតទាំងនោះ ទន្ទឹងថា ពួកយើងនឹងបានអ្វីមួយអំពីមនុស្សលោកនេះ នាំគ្នាមកដល់ផ្ទះញាតិហើយ ក៏មិនអាចសូមថា សូមអ្នកទាំងឡាយឲ្យរបស់ឈ្មោះនេះដល់ពួកខ្ញុំចុះ ដូច្នោះ កុលបុត្រកាលរឭកដល់វត្ថុដែលគួររឭកទាំងនេះ គប្បីឲ្យទក្ខិណា ដើម្បីពួកប្រេតទាំងនោះ ទើបត្រាស់គាថានេះថា **អទាសិ មេ** ជាដើម ។

គាថានោះ មានសេចក្តីថា កុលបុត្រកាលរឭកគ្រប់យ៉ាង យ៉ាងនេះថា អ្នកបានឲ្យទ្រព្យ ឬធញ្ញាហារនេះដល់អញ អ្នកបានព្យាយាមដោយខ្លួនឯង

*បានធ្វើកិច្ចឈ្មោះនេះដល់អញ បុគ្គលនោះជាញាតិ ព្រោះទាក់ទងខាងមាតា ឬខាងបិតារបស់អញ បុគ្គលនោះជាមិត្ត ព្រោះអាចជួយស្រោចស្រង់ ដោយសេចក្តីស្រឡាញ់ ហើយបុគ្គលនោះ ជាសម្លាញ់លេងដីជាមួយគ្នា របស់អញ ដូច្នេះ គប្បីឲ្យទក្ខិណា គប្បីបង្អោនទានឲ្យដល់បុគ្គលដែលស្លាប់ទៅហើយ ។*

*មានបាឋៈដទៃទៀតថា* **បេតានំ ទក្ខិណា ទជ្ជា។** *បាឋៈនោះមានអត្ថថា ឈ្មោះថា* **ទជ្ជា** *ព្រោះជារបស់ដែលគប្បីឲ្យ ។ របស់ដែលគប្បីឲ្យនោះ គឺអ្វី គឺទក្ខិណា ដើម្បីបុគ្គលដែលស្លាប់ទៅហើយ ដោយហេតុនោះ កុលបុត្រកាលរឭកដល់បុគ្គលនោះ អធិប្បាយថា កាលរឭកដល់កិច្ចដែលបុគ្គលនោះធ្វើមកអំពីមុន ដោយន័យថា បុគ្គលនោះបានឲ្យវត្ថុនោះដល់អញ ដូច្នេះជាដើម ។ ពាក្យនេះ គប្បីជ្រាបថា ជាបឋមាវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។*

## អធិប្បាយគាថាទី ១១

*ព្រះមានព្រះភាគ កាលទ្រង់សម្តែងអនុស្សរណវត្ថុ ដែលជាហេតុក្នុងការប្រគល់ឲ្យនូវទក្ខិណាដើម្បីពួកប្រេតយ៉ាងនេះ ទើបត្រាស់ថា*

*បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះបានឲ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត ជាសម្លាញ់របស់អញ ដូច្នេះហើយ គួរឲ្យទក្ខិណាទាន ចំពោះប្រេតទាំងឡាយ ។*

*កាលទ្រង់សម្តែងទៀតថា ជនទាំងឡាយណា មានការទ្រហោយំ និងការសោយសោកជាដើមជាខាងមុខ ព្រោះការស្លាប់របស់ញាតិតាំងនៅ ។ បុគ្គល*

ដែលស្លាប់ទៅហើយ រមែងមិនឲ្យប្រយោជន៍ណាមួយដល់ជនទាំងនោះ ការទ្រហោយំ និងការសោយសោកជាដើមនៃជនទាំងនោះ មានតែធ្វើខ្លួនឲ្យក្តៅក្រហាយតែម្យ៉ាងប៉ុណ្ណោះ រមែងមិនញ៉ាំងប្រយោជន៍ណាមួយឲ្យសម្រេចដល់បុគ្គលដែលស្លាប់ទៅហើយឡើយ ទើបត្រាស់គាថានេះថា **ន ហិ រុណ្ណំ វា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **រុណ្ណំ** បានដល់ ការកន្ទក់កន្ទេញ ការស្រក់ទឹកភ្នែក ការសម្តែងសេចក្តីលំបាកកាយដោយបទនេះ ។ បទថា **សោកោ** បានដល់ ការស្រុបស្រៅ ការសោកសង្រេង ។ ទ្រង់សម្តែងសេចក្តីលំបាកផ្លូវចិត្តដោយបទនេះ ។ បទថា **យាវញ្ញា** បានដល់ ឬក្រៅអំពីការយំសោកណា ។ បទថា **បរិទេវនា** បានដល់ ការយំរៀបរាប់ពណ៌នាដល់គុណដោយន័យថា ឱ ! កូនតែមួយជាទីស្រឡាញ់ ជាទីពេញចិត្ត កូនទៅឯណាដូច្នេះជាដើម របស់បុគ្គលដែលត្រូវញាតិព្យញ្ជនៈពាល់ត្រូវហើយ ។ ទ្រង់សម្តែងការលំបាកវាចាដោយបទនេះ ។

## អធិប្បាយគាថាទី ១២

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការយំជាដើម មិនជាប្រយោជន៍ថា ការយំដទៃទាំងអស់ មិនមានប្រយោជន៍ដល់អ្នកដែលស្លាប់ទៅហើយ ដែលពិតនោះ មានតែធ្វើខ្លួនឲ្យក្តៅក្រហាយតែម្យ៉ាងប៉ុណ្ណោះ ញាតិទាំងឡាយក៏គង់នៅយ៉ាងនោះ ដូច្នេះហើយ កាលទ្រង់សម្តែងភាពដែលទក្ខិណាដែលព្រះបាទមគធរដ្ឋទ្រង់ថ្វាយហើយ មានប្រយោជន៍ ទើបត្រាស់គាថានេះថា **អយញ្ច**

**៦៣ ទក្ខិណា** ដូច្នេះជាដើម ។

គាថានោះ មានសេចក្តីថា សូមថ្វាយព្រះពរ ទក្ខិណានេះឯង មហាបពិត្រថ្វាយឧទ្ទិសដល់ពួកព្រះញាតិ របស់មហាបពិត្រក្នុងថ្ងៃនេះ ព្រោះហេតុដែលព្រះសង្ឃជាស្រែបុណ្យដ៏កំពូលនៃលោក ដូច្នោះ ទក្ខិណានោះ គប្បីជាទក្ខិណាដែលទ្រង់បានតម្កល់ល្អហើយក្នុងសង្ឃ ទើបសម្រេចផល លោកអធិប្បាយថា សម្រេចផល ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់បេតជន អស់កាលយូរ ។ បទថា **ឧបកប្បតិ** បានដល់ សម្រេចផលដោយឋានៈ គឺសម្រេចផលក្នុងខណៈភ្លាមៗ មិនយូរឡើយ ។ ដូចការដែលជាក់ច្បាស់ក្នុងរំពេចនោះ ក៏ត្រាស់ថា សេចក្តីនោះជាក់ច្បាស់ដល់តថាគតដោយឋានៈ យ៉ាងណា ទក្ខិណាដែលសម្រេចផលក្នុងរំពេចនោះ ក្នុងទីនេះ ក៏ត្រាស់ថា សម្រេចផលដោយឋានៈ ដូច្នោះ ។ ឋានៈណាត្រាស់ថា ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនេះឯង ហៅថាទីគួរ ដូច្នេះ ។ ទក្ខិណាដែលសម្រេចផលក្នុងឋានៈនោះដោយប្រភេទ មានខុប្បិបាសិកប្រេត វន្តាសាប្រេត បរទត្តូជីវីប្រេត និងនិជ្ឈាមតណ្ហិកប្រេតជាដើម ក៏ត្រាស់ថា រមែងសម្រេចផលដោយឋានៈ ដូចឲ្យកហាបណៈក្នុងលោក គេក៏សន្មតថា បុគ្គលនោះឲ្យកហាបណៈ ដូច្នោះ ។ តែក្នុងអត្ថវិកប្បនេះ បទថា **ឧបកប្បតិ** បានដល់ ប្រាកដផល លោកអធិប្បាយថា កើតផល ។

## អធិប្បាយគាថាទី ១៣

ព្រះមានព្រះភាគ កាលទ្រង់សម្តែងទក្ខិណា ដែលព្រះរាជាថ្វាយហើយ

មានប្រយោជន៍យ៉ាងនេះ ទើបត្រាស់ថា

លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឲ្យហើយ តម្កល់
ទុកប្រពៃហើយក្នុងសង្ឃ ទើបសម្រេចផលដោយរួសរាន់
ដើម្បីប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង ដូច្នេះ ។

ព្រោះញាតិធម៌ដែលព្រះរាជាទ្រង់ថ្វាយទក្ខិណានេះ ទ្រង់សម្ដែងហើយ ដោយទ្រង់ធ្វើកិច្ចដែលពួកញាតិគួរធ្វើដល់ពួកញាតិ ទ្រង់ធ្វើឲ្យប្រាកដដល់ជនជាច្រើន ឬទ្រង់លើកជាគំរូថា ញាតិធម៌ អ្នកទាំងឡាយក៏គប្បីបំពេញដោយការធ្វើកិច្ចដែលពួកញាតិគប្បីធ្វើយ៉ាងនោះដូចគ្នា មិនគប្បីធ្វើខ្លួនឲ្យក្ដៅក្រហាយដោយការយំជាដើម ដែលឥតប្រយោជន៍ ការបូជាពួកប្រេត ដែលព្រះរាជាទ្រង់ញ៉ាំងពួកប្រេតទាំងនោះឲ្យជួបនូវទិព្វសម្បត្តិ ទ្រង់ធ្វើហើយយ៉ាងឱឡារ ឯកម្លាំងរបស់ភិក្ខុទាំងឡាយ ដែលព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹកជាដើម ឈ្មោះថាទ្រង់បន្ថែមឲ្យហើយ ឯបុណ្យមិនមែនតិច ដែលព្រះរាជាទ្រង់ញ៉ាំងចាគចេតនាមានគុណ គឺសេចក្ដីអនុគ្រោះជាដើម ដែលជាបរិវារឲ្យកើត ក៏ទ្រង់ជួបហើយដូច្នោះ កាលទ្រង់ញ៉ាំងព្រះរាជាឲ្យត្រេកអរដោយគុណតាមសេចក្ដីពិតទាំងនេះទៀត ទើបទ្រង់បញ្ចប់ទេសនា ដោយព្រះគាថានេះថា

ញាតិធម៌នោះ ឈ្មោះថា មហាបពិត្រ បានសម្ដែងជាបែប
យ៉ាងហើយ ការបូជាដ៏ថ្លៃថ្លាចំពោះប្រេតទាំងឡាយ ឈ្មោះ
ថា បានធ្វើហើយផង កម្លាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះ

ថា បានបំពេញឲ្យហើយផង បុណ្យ ឈ្មោះថា បានសន្សំទុក មិនមែនតិចឡើយផង ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់បង្អួលបង្ហាញព្រះរាជាដោយធម្មីកថា ដោយបទគាថានេះថា **សោ ញាតិធម្មោ ច អយំ និទស្សិតោ។** សេចក្តីពិត ការសម្តែងញាតិធម៌នេះឯង ជាការបង្អួលបង្ហាញរឿយៗ ក្នុងសេចក្តីនេះ ។ ទ្រង់ទូន្មានដោយបទគាថានេះថា **បេតានបូជា ច កតា ឧឡារា** សេចក្តីពិត ការសរសើរថា **ឧឡារា** ក៏ជាការដឹកនាំដោយការបូជារឿយៗ ក្នុងសេចក្តីនេះ ទ្រង់ឲ្យអាចហ៊ាន ដោយបទគាថានេះថា **ពលញ្ច ភិក្ខូនម-នុប្បទិន្នំ ។** សេចក្តីពិត ការបន្ថែមកម្លាំងដល់ភិក្ខុទាំងឡាយ ក៏ជាទានយ៉ាងនេះមួយបែបក្នុងសេចក្តីនេះ ។ ពាក្យថា បានបំពេញនូវកម្លាំង ជាការដាំបណ្តុះ ឲ្យអាចហ៊ាន ដោយការបន្ថែមនូវឧស្សាហ៍ដល់ព្រះរាជានោះ ។ ទ្រង់ឲ្យរីករាយ ដោយបទគាថានេះថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ។** សេចក្តីពិត ការសម្រេច ដល់ការជួបនូវបុណ្យនោះឯង គប្បីជ្រាបថា ជាការឲ្យកើតនូវសេចក្តីត្រេកអរ ដោយពណ៌នាគុណតាមសេចក្តីពិត ដល់ព្រះរាជានោះក្នុងសេចក្តីនេះ ។

ចប់ទេសនា ការសម្រេចធម៌មានដល់សត្វ ៨៤០០០ ដែលសង្វេគ ព្រោះពណ៌នាទោសនៃការចូលដល់បិត្តិវិស័យ ហើយតាំងសេចក្តីព្យាយាមដោយឧបាយប្រាជ្ញា ។ ក្នុងថ្ងៃស្អែកឡើង ព្រះមានព្រះភាគ ក៏ទ្រង់សម្តែងតិរោកុឌ្ឌសូត្រនេះឯងដល់ទេវតា និងមនុស្សទាំងឡាយ ការត្រាស់ដឹងធម៌យ៉ាងនោះ

មានរហូត ៧ ថ្ងៃ ដោយប្រការដូច្នេះ ។

## អដ្ឋកថា តិរោកុឌ្ឍសូត្រ

## នៃ

## អដ្ឋកថា តិរោកុឌ្ឍសូត្រ ចប់

# សុត្តន្តបិដក

## ខុទ្ទកបាឋៈ និធិកណ្ឌ

[ ៩ ] បុរសកប់កំណប់ទ្រព្យទុកក្នុងទីជ្រៅ ជាទីបំផុតនៃទឹក ដោយគិតថា កាលបើកិច្ចដែលត្រូវការកើតឡើងហើយ ទ្រព្យនេះនឹងបានជាប្រយោជន៍ដល់អាត្មាអញ ដែលត្រូវពួកមច្ចាមិត្តពោលបង្កាច់នឹងបានដោះខ្លួនចេញពីស្ដេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរ្ភិក្ស ឬក៏ក្នុងកាលអន្តរាយទាំងឡាយ ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។ កំណប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹក ដល់ម៉្លោះ កំណប់ទ្រព្យទាំងអស់នោះក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ ដ្បិតថា កំណប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្ដីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយរមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះកាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។ កំណប់ទ្រព្យដែលស្ត្រីឬបុរសណា បានកប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម និងដោយការទូន្មានខ្លួន ក្នុងចេតិយ ឬក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកភ្ញៀវ ឬមួយក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុស-ស្រីដែលជាច្បង កំណប់ទ្រព្យនោះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណាៗ មិនគប្បីផ្ចាញ់

បាន ជាកំណាប់ទ្រព្យដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយ ដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណាប់ទ្រព្យ គឺបុណ្យនុ៎ះទៅ កំណាប់ទ្រព្យ គឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន ។ កំណាប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គួរធ្វើនូវកំណាប់ទ្រព្យ គឺបុណ្យនោះ កំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណាៗ ផលទាំងពួងនោះៗ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះទន់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពជាស្តេចប្រទេសរាជ ឥស្សរិយយសសេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតា ក្នុងទេវនិកាយទាំងឡាយ ផលទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរ ក្នុងទេវលោកណាផង សម្បត្តិ គឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជា និងវិមុត្តិឥទ្ធ-ផលទាំងអស់ បានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ បដិសម្ភិទា វិមោក្ខសាវកបារមីញាណ បច្ចេកពោធិញាណ និងពុទ្ធភូមិណាៗ ឥទ្ធផលទាំងអស់រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។ បុញ្ញសម្បទានោះ ឲ្យសម្រេច

ប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យបានធ្វើហើយ ។

និធិកណ្ឌ ចប់

# អដ្ឋកថា

# និធិកណ្ឌ

## ហេតុនៃការតាំងព្រះសូត្រ

[ ៩ ] និធិកណ្ឌសូត្រនេះ ខ្ញុំលើកឡើងដោយន័យថា **និធឹ និធេតិ បុរិសោ** ជាដើម បន្ទាប់អំពីលំដាប់តិរោកុឌ្ឌសូត្រ ឥឡូវនេះ ខ្ញុំនឹងពោលនិក្ខេបបទ និងសម្តែងអត្ថុប្បត្តិហេតុនៃនិធិកណ្ឌសូត្រក្នុងទីនេះហើយ នឹងពណ៌នាសេចក្តីនៃនិធិកណ្ឌសូត្រនោះ ។

បណ្តាហេតុទាំង ២ នោះ ក្នុងទីនេះ គប្បីជ្រាបហេតុតាំង ( និក្ខេបបទ ) នៃនិធិកណ្ឌសូត្រនេះសិន ។ ពិតហើយ និធិកណ្ឌសូត្រនេះ ព្រះមានព្រះភាគមិនបានត្រាស់តាមលំដាប់នេះ ព្រោះជាសូត្រគូគ្នានឹងតិរោកុឌ្ឌសូត្រ ព្រោះទាក់ទងដោយការអនុមោទនា ដូច្នោះ ទើបខ្ញុំលើកឡើងក្នុងទីនេះ ។ ឬថាគប្បីជ្រាបថា ខ្ញុំកាលសម្តែងវិបត្តិនៃពួកជនដែលប្រាសចាកបុណ្យ ដោយតិរោកុឌ្ឌសូត្រហើយ ទើបលើកនិធិកណ្ឌសូត្រនេះតាំងទុកក្នុងទីនេះ ក៏ដើម្បី

សម្តែងសម្បត្តិនៃពួកជន ដែលធ្វើបុណ្យទុកដោយសូត្រនេះ ។ និក្ខេបបទនៃនិធិកណ្ឌសូត្រនោះ ទុកក្នុងទីនេះប៉ុណ្ណោះ ។

# អត្ថុប្បត្តិហេតុ

និធិកណ្ឌសូត្រនេះ កើតឡើងដោយហេតុដូច្នេះថា បានឮថា ក្នុងក្រុងសាវត្ថី កុដុម្ពិកៈម្នាក់ ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន តែបុគ្គលនោះ ជាអ្នកមានបសាទសទ្ធា មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់នៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយ គាត់ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន សម័យនោះ ព្រះរាជាមានព្រះបំណងត្រូវការទ្រព្យ ទើបបញ្ជូនរាជបុរសម្នាក់ ទៅក្នុងសម្នាក់របស់គាត់ ដោយព្រះរាជបញ្ជាថា អ្នកចូរទៅនាំកុដុម្ពិកៈឈ្មោះនេះមក ។ រាជបុរសនោះ ទៅនិយាយនឹងកុដុម្ពិកៈនោះថា នៃគហបតី ព្រះរាជាអញ្ជើញអ្នក ។ កុដុម្ពិកៈមានចិត្តប្រកបដោយគុណ មានសទ្ធាជាដើម កំពុងអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបពោលថា នៃរាជបុរស អ្នកទៅមុនចុះ ខ្ញុំទៅឯក្រោយ ខ្ញុំកំពុងកប់ទ្រព្យក្នុងខណៈនេះសិន ។ ព្រះមានព្រះភាគទ្រង់សោយស្រេច ទ្រង់ដកព្រះហស្តចេញអំពីបាត្រហើយ ។ ដើម្បីទ្រង់សម្តែងបុញ្ញសម្បទា ដោយនិធិបរមត្ថ បានត្រាស់ព្រះគាថាទាំងនេះថា **និធឹ និធេតិ បុរិសោ** ជាដើម ដើម្បីអនុមោទនាដល់កុដុម្ពិកៈនោះ ។ និធិកណ្ឌសូត្រនេះ មានអត្ថុប្បត្តិហេតុដូចពោលមក ដូច្នេះ ។

ខ្ញុំពោលនិក្ខេបបទ និងសម្តែងអត្ថុប្បត្តិហេតុនៃនិធិកណ្ឌសូត្រទុកក្នុងទីនេះហើយ នឹងពណ៌នាអត្ថនៃនិធិកណ្ឌសូត្រនោះដូចតទៅនេះ

# អធិប្បាយគាថាទី ១

បណ្តាបទទាំងនោះ បទថា **និធី និធេតិ បុរិសោ** សេចក្តីថា ឈ្មោះថា **និធិ** ព្រោះកប់ អធិប្បាយថា តាំងទុក រក្សាទុក ។ និធិនោះមាន ៤ គឺ ថាវរនិធិ ១ ជង្គមនិធិ ១ អង្គសមនិធិ ១ អនុគាមិកនិធិ ១ ។ បណ្តានិធិ ៤ នោះ ទ្រព្យដែលជាប់ផែនដីក្តី ទ្រព្យដែលតាំងនៅក្នុងអាកាសក្តី ប្រាក់ក្តី មាសក្តី ស្រែក្តី ដីភូមិក្តី ឬទ្រព្យបែបនោះដទៃណាមួយ ដែលមិនអាចកម្រើកដោយខ្លួនឯងបាន ឈ្មោះថា **ថាវរនិធិ**។ ខ្ញុំស្រី ខ្ញុំប្រុស ដំរី គោ សេះ លា ពពែ ចៀម មាន់ ជ្រូក ឬទ្រព្យដែលមានសភាពបែបនោះដទៃណាមួយ ដែលប្រកបដោយការកម្រើកបានខ្លួនឯង ឈ្មោះថា **ជង្គម** កំណាប់ទ្រព្យនេះ ឈ្មោះថា **ជង្គមនិធិ** ។ ពាហុសច្ចៈ ដែលជាប្រភពកើតការងារ ជាប្រភពកើតសិប្បៈ ជាទីតាំងនៃវិជ្ជាការ ឬពាហុសច្ចៈដែលមានសភាពបែបនោះដទៃណាមួយ ដែលសិក្សាហើយសិក្សាទៀត ជំនាញជាប់ខ្លួន ប្រៀបដូចអវយវៈតូចធំ ឈ្មោះថា **អង្គសម** គឺទ្រព្យស្មើដោយអវយវៈ ទ្រព្យនេះ ឈ្មោះថា **អង្គសមនិធិ** ។ បុណ្យដែលសម្រេចដោយទាន ដែលសម្រេចដោយសីល ដែលសម្រេចដោយភាវនា បុណ្យដែលសម្រេចដោយការស្តាប់ធម៌ ដែលសម្រេចដោយការសម្តែងធម៌ ឬបុណ្យបែបនោះដទៃណាមួយ ដែលឲ្យផលគួរជាទីប្រាថ្នា ហាក់ដូចជាជាប់តាមទៅក្នុងទីនោះៗ ឈ្មោះថា **អនុគាមិក** គឺជាប់តាមទៅបាន ។ កំណាប់ទ្រព្យនេះ ឈ្មោះថា **អនុគាមិកនិធិ**។ ចំណែកក្នុងទីនេះ ទ្រង់បំណងយកថាវរនិធិ ។

បទថា **និធេតិ** បានដល់ តាំងទុក សន្សំទុក រក្សាទុក ។ បទថា **បុរិសោ**

បានដល់ មនុស្ស ។ បុរសក្តី ស្ត្រីក្តី ខ្ទើយក្តី រមែងកប់ទ្រព្យបានក៏ពិត តែក្នុងទីនេះ ទ្រង់ធ្វើទេសនា ដោយបុរសជាសំខាន់ តែដោយអត្ថ គប្បីឃើញថា ទ្រង់ប្រមូលមនុស្សទាំងនោះទុកក្នុងទីនេះ ។ បទថា **គម្ភីរេ ឧទកន្តិកេ** សេចក្តីថា ដែលឈ្មោះថា **គម្ភីរ** ព្រោះអត្ថថា ឈមចុះបាន ឈ្មោះថា **ឧទកន្តិក** ព្រោះជាទីមានទឹកជាទីបំផុត ។ ទីជ្រៅតែមិនមានទឹកជាទីបំផុតក៏មាន ដូចគ្នានឹងអណ្តូងជម្រៅ ១០០ ជួរបុរស ក្នុងផែនដីត្រង់ទីទួល ។ ទីដែលមានទឹកជាទីបំផុត តែមិនជ្រៅក៏មាន ដូចជាអណ្តូងជម្រៅ ១-២ ហត្ថ ក្នុងទីដែលមានភក់ ។ ទីដែលជ្រៅផង មានទឹកជាបំផុតផងក៏មាន ដូចអណ្តូងដែលគេជីកក្នុងផែនដីត្រង់ទីទួល រហូតដល់ទឹកហូរមកក្នុងកាលនោះ ។ ពាក្យថា **គម្ភីរេ ឧទកន្តិកេ** នេះ ត្រាស់សំដៅដល់ទីជ្រៅដែលមានទឹកជាទីបំផុតនោះ ។

បទថា **អត្ថេ កិច្ចេ សមុប្បន្នេ** សេចក្តីថា ឈ្មោះថា **អត្ថ** ព្រោះមិនប្រាសចាកប្រយោជន៍ ។ លោកអធិប្បាយថា នាំមកនូវប្រយោជន៍ នាំមកនូវឧបការៈ ។ ឈ្មោះថា **កិច្ច** ព្រោះគួរធ្វើ ។ លោកអធិប្បាយថា ករណីណាមួយដែលកើតឡើងហើយនោះឯង ឈ្មោះថា **សមុប្បន្ន**។ លោកអធិប្បាយថា ដែលតាំងឡើងហើយ ដោយភាពជាកិច្ចដែលគួរធ្វើ ។ ពាក្យនេះ ជាការសម្តែងដល់ប្រយោជន៍នៃការកប់ទ្រព្យថា កាលកិច្ចដែលជាប្រយោជន៍នោះកើតឡើងហើយ កំណប់ទ្រព្យនឹងជាប្រយោជន៍ដល់យើង សេចក្តីពិត បុរសនោះកប់ទ្រព្យ ក៏ដើម្បីជាប្រយោជន៍យ៉ាងនេះថា កាលករណីណាមួយដែលនាំ

មកនូវប្រយោជន៍កើតឡើង កំណប់ទ្រព្យនឹងជាប្រយោជន៍ដល់យើង នឹងមានដើម្បីសេចក្តីសម្រេចនៃកិច្ចរបស់យើងនោះ ។ សេចក្តីពិត ការសម្រេចនៃកិច្ចនោះឯង គប្បីជ្រាបថា ជាប្រយោជន៍របស់កំណប់ទ្រព្យនោះ កាលកិច្ចកើតឡើង ។

## អធិប្បាយគាថាទី ២

ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រយោជន៍នៃការកប់ទ្រព្យយ៉ាងនេះ កាលទ្រង់សម្តែងបំណងនៃការជួបនូវប្រយោជន៍ ឥឡូវនេះ ដើម្បីទ្រង់សម្តែងនូវបំណងនៃការចៀសវាងនូវវត្ថុមិនជាប្រយោជន៍ ទើបត្រាស់ថា

នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរ្ភិក្ស ឬក៏ក្នុងកាលអន្តរាយទាំងឡាយ ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។

គាថានេះ គប្បីប្រកបសេចក្តីតាមកំណើតសត្វជាមួយបទថា **ភវិស្សតិ បមោក្ខាយ** ដែលត្រាស់ក្នុងពាក្យនេះថា **អត្ថាយ មេ ភវិស្សតិ** និងព្រះតម្រាស់ថា **ឥណស្ស វា បមោក្ខាយ** ទើបនឹងជ្រាបសេចក្តីបាន ក្នុងសេចក្តីនោះ ប្រកបសេចក្តីយ៉ាងនេះថា បុរសកប់កំណប់ទ្រព្យ មិនមែនដោយបំណងថា ជាប្រយោជន៍ដល់អញតែម្យ៉ាងប៉ុណ្ណោះទេ សេចក្តីនេះ គឺអ្វីទៅវិញ គឺបុរសកប់ទ្រព្យ ក៏ដោយបំណងថា នឹងជួយដោះអាត្មាអញឲ្យផុតចាករាជភ័យដែលត្រូវពួកសត្រូវ ពួកបច្ចាមិត្រប្រទូស្ត ដោយន័យជាដើមយ៉ាងនេះថា អ្នក

នេះជាចោរខ្លះ ជាប្រុសស្មន់ខ្លះ គេចទូវភាស៊ីខ្លះ ដូច្នេះជាដើម នឹងជួយដោះអាត្មាអញឲ្យផុតចាកចោរភ័យ ដែលត្រូវពួកចោរបៀតបៀនដោយការលួចទ្រព្យ ដោយរបៀបកាត់ជញ្ជាំងជាដើម ដោយការចាប់ជំរិតថា ឯងចូរឲ្យមាសប៉ុណ្ណេះៗ ជាដើម ម្ចាស់បំណុលទារឲ្យអញសងបំណុល ក៏ជួយដោះអញឲ្យផុតចាកបំណុលខ្លះ ។ សម័យដែលកើតទុព្ភិក្ខភ័យ សម្លូងវិនាសអាហាររកបានដោយលំបាក ក្នុងសម័យនោះ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយទ្រព្យបន្តិចបន្តួច ធ្វើមិនបានឆាយ កំណប់ទ្រព្យនោះ ក៏នឹងជួយបានក្នុងគ្រាទុព្ភិក្ខភ័យបែបនោះមកដល់ដូច្នេះខ្លះ នឹងជួយបានក្នុងគ្រាអន្តរាយដែលកើតអំពីអគ្គិភ័យ ឧទកភ័យ ទាយាទដែលមិនជាទីស្រឡាញ់ ដូច្នេះជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងប្រយោជន៍នៃការរក្សាទ្រព្យ ២ យ៉ាងដោយ ២ គាថា គឺការប្រាថ្នាដែលនឹងជួបប្រយោជន៍ និងការប្រាថ្នាដែលនឹងគេចចេញអំពីវត្ថុដែលមិនមែនប្រយោជន៍យ៉ាងនេះហើយ ឥឡូវនេះ កាលត្រាស់ត្រួតនូវប្រយោជន៍ទាំង ២ ដល់កុដុម្ពិកៈនោះ ទើបត្រាស់ថា **ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ** ធម្មតាកំណប់ដែលគេកប់ក្នុងលោកដើម្បីជាប្រយោជន៍នេះឯង ។

គាថានោះមានអត្ថថា ប្រយោជន៍នេះ គឺការជួបនូវប្រយោជន៍ និងការចៀសចេញអំពីវត្ថុដែលមិនជាប្រយោជន៍ ទ្រង់សម្ដែងដោយន័យជាដើមយ៉ាងនេះថា នឹងជាប្រយោជន៍ដល់អញ និងដើម្បីដោះអាត្មាអញឲ្យផុតអំពីរាជភ័យ ។ ធម្មតាកំណប់ មានប្រាក់ មាសជាដើមណាមួយ គេកប់តម្កល់

ទុក រក្សាទុកក្នុងឱកាសលោកនេះ ក៏ដើម្បីជាប្រយោជន៍នោះ គឺដើម្បីធ្វើកិច្ចទាំងនោះឲ្យសម្រេច ។

## អធិប្បាយគាថាទី ៣

ឥឡូវនេះ ព្រោះកំណប់ទ្រព្យទាំងនោះ គេកប់ល្អហើយយ៉ាងនេះ តែងឲ្យសម្រេចប្រយោជន៍ ដែលបំណងដល់អ្នកមានបុណ្យប៉ុណ្ណោះ មិនសម្រេចប្រយោជន៍ដល់អ្នកដទៃ ដូច្នោះ កាលទ្រង់សម្តែងប្រយោជន៍ ទើបត្រាស់ថា

> កំណប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹក
> ដល់ម៉្លោះ កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេច
> ដល់បុគ្គលនោះ សព្វកាលទេ ។

គាថានោះ មានអត្ថថា កំណប់ទ្រព្យនោះ គេកប់ល្អដល់ម៉្លោះ លោកអធិប្បាយថា សូម្បីកំណប់ទ្រព្យដែលគេកប់យ៉ាងល្អដល់ម៉្លោះ គេកប់ល្អដូចម្តេច គេកប់ក្នុងទីជ្រៅ មានទឹកជាទីបំផុត លោកអធិប្បាយថា ល្អដរាបស្មើនឹងការរាប់បានថា កប់ក្នុងទីជ្រៅ មានទឹកជាទីបំផុត ។ បទថា **ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ** សេចក្តីថា កំណប់ទ្រព្យរមែងមិនសម្រេចប្រយោជន៍ មិនសម្រេចផលសព្វយ៉ាង លោកអធិប្បាយថា មិនអាចធ្វើកិច្ចតាមដែលពោលមកហើយ ដល់បុរសដែលកប់ទុកបានសព្វកាល សេចក្តីនេះដូចម្តេច គឺជួនកាល សម្រេចប្រយោជន៍ ជួនកាល មិនសម្រេចប្រយោជន៍ទេ ។ សព្ទថា **តំ** ក្នុងគាថានោះ គប្បីឃើញថា ជានិបាត ចុះក្នុងអត្ថបទបូរណៈ គឺធ្វើបទឲ្យពេញ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **យថា**

**តំ អប្បមត្តស្ស អាតាបិនោ** ។ ជួនកាល លោកធ្វើលិង្គឲ្យផ្សេងគ្នា ដើម្បីគួរនឹងពោលថា **សោ** ក៏ពោលភ្ជាត់ថា **តំ** ។ ពិតហើយ កាលពោល យ៉ាងនោះ សេចក្តីនោះ ក៏ដឹងបានស្រួល ។

# អធិប្បាយគាថាទី ៤-៥

ព្រះមានព្រះភាគ កាលត្រាស់ថា **ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ** យ៉ាងនេះ ឥឡូវនេះ កាលទ្រង់សម្តែងហេតុដែលមិនសម្រេច ប្រយោជន៍ទើបត្រាស់ថា

ដ្បិតថា កំណប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គល នោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយរមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យ ទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅ ក្នុងវេលានោះ ។

គាថានេះមានអត្ថថា កំណប់ទ្រព្យនោះ ឃ្លាតចេញទៅអំពីទីដែលគេកប់ ល្អហើយ គឺមិនមានចេតនា ក៏ទៅទីដទៃបាន ដោយម្ចាស់ទ្រព្យអស់បុណ្យ ខ្លះ ។ ការចាំរបស់បុគ្គលនោះឃ្លៀងឃ្លាត គឺចាំមិនបាន ដល់ទីដែលកប់ ទ្រព្យខ្លះ ពួកនាគដែលការអស់បុណ្យរបស់បុគ្គលនោះ ជាស់តឿនហើយ ប្តូរ កន្លែងកប់ទ្រព្យនោះ យកទៅទីដទៃខ្លះ ពួកយក្ខលួចយកទៅតាមគាប់ចិត្តខ្លះ ពួកទាយាទដែលទទួលមត៌កមិនជាទីពេញចិត្ត ជីកផែនដីយកទ្រព្យនោះទៅ

ក្នុងកាលដែលបុគ្គលនោះមិនឃើញខ្វះ ។ កំណាប់ទ្រព្យមិនសម្រេចប្រយោជន៍ដល់បុគ្គលនោះ ព្រោះមានការឃ្លាតចាកទីដើមទាំងនោះ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ហេតុដែលមិនសម្រេចប្រយោជន៍ ដែលលោកសន្មត មានការធ្វើឲ្យឃ្លៀងឃ្លាតជាដើមយ៉ាងនេះហើយ ឥឡូវនេះ គ្រាទ្រង់សម្តែងហេតុ ដែលគេសន្មតថា ការអស់បុណ្យណាមួយ ដែលជាមូលនៃហេតុទាំងនោះ ទើបត្រាស់ថា **យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ ។**

គាថានោះ មានសេចក្តីថា សម័យណា បុណ្យដែលភោគសម្បត្តិឲ្យសម្រេចអស់ទៅ ក៏ធ្វើវត្ថុដែលមិនមែនបុណ្យ ដែលប្រព្រឹត្តទៅដើម្បីការវិនាសនៃភោគសម្បត្តិ មានឱកាសតាំងនៅ សម័យនោះ ធនជាតិណា មានប្រាក់ និងមាសជាដើម ដែលបុគ្គលកប់ហើយ ធនជាតិទាំងអស់នោះក៏វិនាសអស់ទៅ ។

## អធិប្បាយគាថាទី ៦

ព្រះមានព្រះភាគ កាលត្រាស់ដល់កំណាប់ទ្រព្យ ដែលបុគ្គលកប់ហើយដោយបំណងនោះៗ តែក៏មិនសម្រេចប្រយោជន៍តាមដែលបំណងដល់លោកសន្មត ក៏ត្រូវមានការវិនាសទៅជាធម្មតា ឥឡូវនេះ ដើម្បីទ្រង់សម្តែងបុញ្ញសម្បទាប៉ុណ្ណោះថា ជាកំណាប់ទ្រព្យដោយបរមត្ថ កាលទ្រង់សម្តែងនិធិកណ្ឌសូត្រនេះ ដែលទ្រង់ផ្តើមដើម្បីអនុមោទនាដល់កុដុម្ពិកៈនោះ ទើបត្រាស់ថា

កំណាប់ដែលស្ត្រី ឬបុរសណា បានកប់ទុកល្អហើយ ដោយ
ទាន សីល ដោយការសង្រួម ដោយការទូន្មានខ្លួន ។

បណ្តាបទទាំងនោះ បទថា **ធានំ** គប្បីកាន់យកតាមន័យដែលពោលមក ហើយក្នុងមង្គលថា **ធានញ្ច ធម្មរិយា** នោះ ។ បទថា **សីលំ** បានដល់ ការមិនកន្លងល្មើសតាមផ្លូវកាយ និងវាចា គឺសីល ៥ សីល ៨ សីល ១០ និងបាតិមោក្ខសំវរសីលជាដើម ។ សីលគ្រប់យ៉ាង លោកបំណងយកថា ជាសីលក្នុងទីនេះ ។ បទថា **សញ្ញមោ** បានដល់ ការសង្រួម អធិប្បាយថា ការហាមចិត្តទៅក្នុងអារម្មណ៍ផ្សេងៗ ពាក្យនេះជាឈ្មោះនៃសមាធិដែលបុគ្គលប្រកបហើយ លោកហៅថា ជាអ្នកសង្រួមដ៏ឧត្តម ក្នុងបាលីថា **ហត្ថសញ្ញតោ បាទសញ្ញតោ វាចាសញ្ញតោ សញ្ញតុត្តមោ** ប្រែថា ជាអ្នកសង្រួមដៃ សង្រួមជើង សង្រួមវាចា ឈ្មោះថា ជាអ្នកសង្រួមដ៏ឧត្តម ។ អាចារ្យមួយពួកទៀតពោលថា ការសង្រួម លោកអធិប្បាយថា ការរវាំង ការប្រយ័ត្ន ពាក្យនេះជាឈ្មោះឥន្ទ្រិយសំវរៈ ។ ការទូន្មាន ឈ្មោះថា **ទម** អធិប្បាយថា ការរម្ងាប់កិលេស ពាក្យនេះ ជាឈ្មោះនៃបញ្ញា ។ ពិតហើយ បញ្ញាក្នុងបាលីខ្លះ ហៅថា **បញ្ញា** ក្នុងប្រយោគជាដើមយ៉ាងនេះថា **សុស្សូសំ លភតេ បញ្ញំ** បុគ្គលស្តាប់ដោយល្អ រមែងបាននូវបញ្ញា ទីខ្លះ លោកហៅថា **ធម្ម** ក្នុងប្រយោគជាដើមយ៉ាងនេះថា **សច្ចំ ធម្មោ ធិតិ ចាគោ** ប្រែថា សច្ចៈ ធម្មៈ ធិតិ ចាគៈ ទីខ្លះ លោកហៅថា **ទម** ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **យទិ សច្ចា ទមា ចាគា ខន្ត្យាភិយ្យោ ន វិជ្ជតិ** បើធម៌ក្រៅលែងជាងសច្ចៈ ទមៈ ចាគៈ ខន្តី មិនមានសោត ។

បណ្ឌិតស្គាល់ទានជាដើមយ៉ាងនេះហើយ គប្បីប្រមូលមក ហើយជ្រាប

អត្ថនូវគាថានេះយ៉ាងនេះថា កំណប់ទ្រព្យដែលសម្រេចដោយបុណ្យនៃបុគ្គលណា ជាស្រ្តីក្តី បុរសក្តី ទោះគេយកធម៌ទាំង ៤ នេះ គឺទាន សីល សញ្ញមៈ ទមៈ ដែលកប់ទុកល្អហើយ ដោយការធ្វើធម៌ទាំង ៤ មានទានជាដើមទាំងនោះ ទុកដោយល្អក្នុងចិត្តសន្តាន ឬក្នុងវត្ថុមានចេតិយជាដើម ដូចកំណប់ទ្រព្យ ដែលសម្រេចដោយធនជាតិ ក៏យកប្រាក់ មាស មុក្តា មណី កប់ដោយការដាក់ប្រាក់ មាសជាដើមនោះ ក្នុងទីតែមួយដូច្នេះ ។

## អធិប្បាយគាថាទី ៧

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលបុញ្ញសម្បទាជាកំណប់ទ្រព្យដោយបរមត្ថ ដោយគាថានេះថា **យស្ស ទានេន** ជាដើមយ៉ាងនេះហើយ គ្រាទ្រង់សម្តែងវត្ថុត្រង់រណ្តៅទ្រព្យ ដែលបុគ្គលស្តាប់ហើយ ឈ្មោះថា កប់យ៉ាងល្អ ទើបត្រាស់ថា

ក្នុងចេតិយ គឺក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកភ្ញៀវ ឬមួយ
ក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុស-ស្រីដែលជាច្បង ។

ក្នុងគាថានោះ ឈ្មោះថា **ចេតិយ** ព្រោះគួរធ្វើ លោកអធិប្បាយថា គួរបូជា ។ ឈ្មោះថា **ចេតិយ** ព្រោះវិចិត្រហើយ ។ ចេតិយនោះមាន ៣ យ៉ាង គឺបរិភោគចេតិយ ១ ឧទ្ទិស្សកចេតិយ ១ ធាតុកចេតិយ ១ ។

បណ្តាចេតិយទាំង ៣ នោះ ពោធិព្រឹក្ស ឈ្មោះថា **បរិភោគចេតិយ** ព្រះបដិមា ឈ្មោះថា **ឧទ្ទិស្សកចេតិយ** ព្រះស្តូប មានបន្ទប់បញ្ចុះព្រះធាតុ ឈ្មោះថា **ធាតុកចេតិយ** ។

បទថា **សង្ឃេ** បានដល់ បុគ្គលណាម្នាក់ ក្នុងពួកសង្ឃ មានព្រះពុទ្ធជាប្រធាន ។ បទថា **បុគ្គលេ** បានដល់ បុគ្គលណាម្នាក់ ក្នុងពួកគ្រហស្ថនិងបព្វជិតជាដើម ។ ឈ្មោះថា **អតិថិ** គឺភ្ញៀវ ព្រោះបុគ្គលនោះមិនមានតិថី គឺមកថ្ងៃណាក៏បាន ពាក្យនេះជាឈ្មោះរបស់ភ្ញៀវ ដែលមកក្នុងខណៈនោះ ។ ពាក្យដ៏សេស ក៏មានន័យដែលពោលមកហើយនោះឯង ។

បណ្ឌិតស្គាល់ចេតិយជាដើមយ៉ាងនេះហើយ ឥឡូវនេះ គប្បីជ្រាបអត្ថនៃគាថានេះយ៉ាងនេះ កំណប់ទ្រព្យនោះ ត្រាស់ថា ជាការកប់ល្អហើយ កំណប់ទ្រព្យនោះដែលគេកប់ទុកក្នុងវត្ថុទាំងនោះ រមែងឈ្មោះថា កប់ល្អហើយ ។ ព្រោះហេតុអ្វី ព្រោះអាចឲ្យនូវផលដែលគួរប្រាថ្នាបានអស់កាលយូរ ។ ពិតហើយ ជនទាំងឡាយ ថ្វាយក្នុងព្រះចេតិយសូម្បីតិចតួច រមែងជាបុគ្គលបានផល ដែលប្រាថ្នាអស់កាលយូរ ដូចព្រះតម្រាស់ថា

**ឯកបុប្ផំ ចជិត្វាន អសីតិកប្បកោដិយោ**
**ទុគ្គតឹ នាភិជានាមិ បុប្ផទានស្សិទំ ផលំ ។**

ខ្ញុំបានថ្វាយផ្កា ១ ទង ក៏មិនស្គាល់ទុគ្គតិ អស់ ៨០
កោដិនៃកប្ប នេះជាផលនៃការថ្វាយផ្កា ។

និងគាថាថា

**មត្តាសុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ**

បើបុគ្គលឃើញសុខធំទូលាយ ព្រោះលះសុខមានប្រមាណតិចចេញ ។ គប្បីជ្រាបការចែកផលទានក្នុងវត្ថុ មានព្រះសង្ឃជាដើម តាមន័យដែល

ពោលមកហើយ ក្នុងទក្ខិណាវិសុទ្ធិសូត្រ និងក្នុងវេលាមសូត្រជាដើម ដោយប្រការដូច្នោះ ។ ម្យ៉ាងទៀត ទ្រង់សម្ដែងការប្រព្រឹត្តទៅ និងការចម្រើនផលនៃទាន ក្នុងវត្ថុ មានចេតិយជាដើមដោយប្រការណា ក៏គប្បីប្រារព្ធគុណនោះៗ ក្នុងទីទាំងពួងតាមការប្រកបហើយ ទើបជ្រាបការប្រព្រឹត្តទៅ និងការចម្រើនផលនៃសីល មានចារិតសីល វារិតសីល សញ្ញមៈ ពុទ្ធានុស្សតិ ទមៈ វិបស្សនា មនសិការ និងការពិចារណាវត្ថុនោះដោយប្រការនោះ ។

## អធិប្បាយគាថាទី ៨

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងវត្ថុ មានចេតិយជាដើមនៃកំណប់ទ្រព្យដែលសម្រេចដោយបុណ្យ ដែលគេកប់ដោយទានជាដើម យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងការផ្សេងគ្នារបស់កំណប់ទ្រព្យនោះ ដែលគេកប់ក្នុងវត្ថុទាំងនោះ ចាកកំណប់ទ្រព្យ ដែលគេកប់ក្នុងទីជ្រៅ មានទឹកជាទីបំផុត ទើបត្រាស់ថា

កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ
នរណាៗ មិនគប្បីផ្លាញ់បាន ជាកំណប់ទ្រព្យដែលជាប់តាមខ្លួន
ទៅ កាលភោគៈទាំងឡាយ ដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួន
រមែងកាន់យកនូវកំណប់ទ្រព្យ គឺបុណ្យនុ៎ះទៅ ។

ក្នុងគាថានោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងកំណប់ទ្រព្យដែលកប់ល្អហើយ ដោយទានជាដើមនោះ ដោយបទដើមថា កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ ។ បទថា **អជេយ្យោ** បានដល់ មនុស្ស

ដទៃៗ មិនអាចផ្ចាញ់ ហើយយកទៅបាន ។ បាឋៈថា **អជេយ្យោ** ក៏មាន ។ អធិប្បាយថា ដែលបុគ្គលណាម្នាក់ មិនគប្បីឈ្នះ មិនគួរឈ្នះ គឺបុគ្គលត្រូវការប្រយោជន៍ និងសេចក្តីសុខ គួរកសាងឯង ។ ក្នុងបាឋៈនេះ ប្រកបសេចក្តីថា កំណប់ទ្រព្យនេះ បុគ្គលណាម្នាក់ផ្ចាញ់មិនបាន ដោយសម្តែងពាក្យសួរទៀតថា ព្រោះហេតុអ្វី ទើបសម្ពន្ធសេចក្តីថា ព្រោះហេតុដែលកំណប់ទ្រព្យដែលកប់ហើយ ជាប់ទៅមិនបាន ។ តែភាពដែលកំណប់ទ្រព្យដែលកប់ល្អហើយ ដោយប្រការក្រៅអំពីនេះ ជារបស់ដែលបុគ្គលណាម្នាក់ឈ្នះបាន លោកគប្បីពោលហើយ តែលោកមិនបានពោល ។ ពិតហើយ កំណប់ទ្រព្យនោះដែលកប់ល្អហើយ ដែលបុគ្គលណាម្នាក់យកឈ្នះមិនបាន គឺមិនមានបុគ្គលណាម្នាក់យកឈ្នះបានឡើយ ។ កំណប់ទ្រព្យ ឈ្មោះថា អនុគាមិក ព្រោះជាប់តាមទៅបាន អធិប្បាយថា មិនលះបង់បុគ្គលសូម្បីកំពុងទៅបរលោក ដោយការឲ្យផលក្នុងភពនោះៗ ។

បានឮថា បទថា **បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ** នេះ មានសេចក្តីយ៉ាងនេះថា កាលមរណកាលប្រាកដឡើង បណ្តាភោគៈទាំងឡាយដែលចាំបាច់លះទៅ បុគ្គលនោះក៏នាំទៅបាននូវកំណប់ទ្រព្យ គឺបុណ្យនេះ សេចក្តីនេះមិនត្រឹមត្រូវ ព្រោះហេតុអ្វី ព្រោះភោគៈទាំងឡាយទៅមិនបាន សេចក្តីពិតភោគៈនោះៗ ដែលមច្ចៈ គឺអ្នកដែលត្រូវស្លាប់ គប្បីលះទៅប៉ុណ្ណោះ ទៅមិនបានឡើយ តែគតិវិសេសនោះៗ ទេតើ ចាំបាច់ត្រូវទៅ ។ ព្រោះបើគប្បីមានយ៉ាងនេះសោត ក៏គប្បីពោលបានថា បណ្តាគតិវិសេសទាំងឡាយ ដែលចាំ

បាច់លះភោគៈទាំងឡាយទៅ ដូច្នោះ ទើបគួរជ្រាបក្នុងសេចក្ដីនោះយ៉ាងនេះ ថា កាលភោគៈទាំងឡាយ រង់ចាំតែលះបង់អ្នកដែលត្រូវស្លាប់ដោយប្រការ ជាដើមយ៉ាងនេះថា **និធិ វា ឋានា ចវតិ** កំណាប់ទ្រព្យឃ្លាតទៅចាកទីខ្វះ មច្ចុៈ គឺអ្នកដែលត្រូវស្លាប់ ក៏នាំទៅបានចំពោះតែកំណាប់ គឺបុណ្យ ដ្បិតថា កំណាប់ទ្រព្យ គឺបុណ្យ មិនលះមច្ចុៈនោះ ព្រោះជាទ្រព្យជាប់តាមទៅបាន ។ ក្នុងគាថានោះ អ្នកចោទសួរពោលថា ក្នុងបទថា **គមនីយេសុ** នេះ គប្បី មានអត្ថថា **គន្តព្វេសុ** ក៏មិនមែន សេចក្ដីថា **គច្ឆន្តេសុ** ពាក្យនោះ មិនគប្បី កាន់យកតែមួយចំណុច ។ ដូចក្នុងពាក្យថា **អរិយា និយ្យានិកា** នេះ មាន សេចក្ដីថា **និយ្យន្តា** មិនមែនមានសេចក្ដីថា **និយ្យាតព្វា** យ៉ាងណា សូម្បី ក្នុងទីនេះ ក៏មានសេចក្ដីថា **គច្ឆន្តេសុ** មិនមែនមានសេចក្ដីថា **គន្តព្វេសុ** ដូច្នោះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលបុគ្គលទាំងនេះ បំណងនឹងឲ្យដល់បុគ្គលណា ក្នុងកាលនឹងស្លាប់ ក៏ចាប់ពាល់ភោគៈឲ្យមិនបាន ដូច្នោះ ភោគៈទាំងនោះ ដែល បុគ្គលនោះ ត្រូវលះទៅផ្លូវកាយមុន ខាងក្រោយ ទើបចាំបាច់ចេញទៅតាម ផ្លូវចិត្តដែលអស់សង្ឃឹម លោកអធិប្បាយថា គប្បីកន្លងទៅ ។ ព្រោះដូច្នោះ ទើបគួរឃើញក្នុងសេចក្ដីនេះយ៉ាងនេះថា បណ្ដាភោគៈទាំងឡាយ ដែលចាំបាច់ លះទៅផ្លូវកាយមុន ក្រោយមក ទើបលះទៅតាមផ្លូវចិត្ត ។ ក្នុងសេចក្ដីខាង ដើម សត្តមីវិភត្តិ ចុះក្នុងនិទ្ធារណៈថា បណ្ដាភោគៈទាំងឡាយដែលចាំបាច់ លះទៅ បុគ្គលនោះក៏នាំភោគៈ គឺបុញ្ញនិធិប៉ុណ្ណោះចេញអំពីភោគៈទាំងឡាយ

នាំទៅ ។ ក្នុងប្រការក្រោយ សត្តមីវិភត្តិ ចុះក្នុងការលក្ខណៈ ដោយការៈថា ដោយការៈដែលភោគៈទាំងឡាយជាប់តាមទៅ ក៏រមែងកំណត់ការៈ គឺកំណប់ទ្រព្យនោះនាំទៅបានផង ។

# អធិប្បាយគាថាទី ៩

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការផ្សេងគ្នានៃបុញ្ញនិធិនេះចាកកំណប់ទ្រព្យដែលគេកប់ទុកក្នុងទីជ្រៅ មានទឹកជាទីបំផុត កាលទ្រង់ញ៉ាំងឧស្សាហ៍ឲ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងបុញ្ញនិធិនោះ ដោយពណ៌នាគុណបុញ្ញនិធិដែលទ្រង់សម្ដែងដោយព្រះអង្គទៀត ដូចឈ្មួញអ្នកលក់ដ៏ឱឡារញ៉ាំងឧស្សាហ៍ឲ្យកើតដល់អ្នកទិញ ដោយពណ៌នាគុណនៃទំនិញរបស់ខ្លួន ដូច្នោះ ទើបត្រាស់ថា

កំណប់ទ្រព្យ គឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ជារបស់ដែល
ចោរលួចទៅមិនបាន កំណប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួន
ទៅបាន អ្នកប្រាជ្ញ គួរធ្វើនូវកំណប់ទ្រព្យ គឺបុណ្យនោះ ។

បណ្ដាបទទាំងនោះ បទថា **អសាធារណមញ្ញេសំ** ប្រែថា មិនទូទៅដល់ជនដទៃ ។ **ម** អក្ខរៈ ធ្វើបទសន្ធិ ដូចក្នុងប្រយោគជាដើមថា **អទុក្ខមសុខាយ វេទនាយ សម្បយុត្តា** ប្រកបដោយវេទនាដែលមិនមែនទុក្ខ មិនមែនសុខ ។ និធិដែលចោរទាំងឡាយលួចទៅមិនបាន ឈ្មោះថា **អចោរាហារណោ** ។ អធិប្បាយថា រមែងជានិធិដែលចោរទាំងឡាយនាំទៅមិនបាន ។ ឈ្មោះថា **និធិ** ព្រោះបុគ្គលនោះកប់ ។ ព្រះមានព្រះភាគ កាលទ្រង់ពណ៌នា

គុណនៃបុញ្ញនិធិដោយ ២ បទខាងដើមយ៉ាងនេះហើយ បន្ទាប់អំពីនោះ ក៏ទ្រង់ញ៉ាំងឧស្សាហ៍ឲ្យកើតក្នុងបុញ្ញនិធិនោះ ដោយបទក្រោយ ទើបត្រាស់ថា បុញ្ញនិធិឯណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គប្បីធ្វើបុញ្ញនិធិនោះ ។

គាថានោះមានសេចក្តីថា ព្រោះហេតុដែលធម្មតា បុញ្ញនិធិមិនសាធារណៈដល់ជនដទៃ និងជានិធិដែលចោរលួចទៅមិនបាន ។ តែមិនមែននិធិដែលមិនសាធារណៈ ហើយចោរលួចទៅមិនបានតែម្យ៉ាងប៉ុណ្ណោះទេ ពិតហើយ នៅជានិធិដែលត្រាស់យ៉ាងនេះថា និធិនោះ កប់ទុកល្អហើយ ដែលបុគ្គលណាម្នាក់ផ្លាញ់មិនបាន ជាប់តាមខ្លួនទៅបាន ។ និធិណាជាប់តាមខ្លួនទៅបាន ព្រោះហេតុដែលនិធិនោះ ជាបុញ្ញនិធិតែម្យ៉ាង ដូច្នោះ អ្នកប្រាជ្ញ គឺបុគ្គលដែលដល់ព្រមដោយពុទ្ធិ គឺការដឹង ដល់ព្រមដោយធិតិ គឺបញ្ញា គប្បីធ្វើបុណ្យ បំពេញបុណ្យទាំងឡាយ ។

## អធិប្បាយគាថាទី ១០

ព្រះមានព្រះភាគ កាលទ្រង់ញ៉ាំងឧស្សាហ៍ឲ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងបុញ្ញនិធិ ដោយពណ៌នាគុណយ៉ាងនេះហើយ ឥឡូវនេះ ជនទាំងឡាយណាឧស្សាហ៍ហើយ ធ្វើឧស្សាហ៍នោះឲ្យសម្រេចផល ដោយការធ្វើបុញ្ញនិធិ បុញ្ញនិធិរបស់ជនទាំងនោះ រមែងឲ្យផល កាលទ្រង់សម្តែងផលនោះដោយសង្ខេប ទើបត្រាស់ថា កំណាប់ទ្រព្យ គឺបុណ្យនោះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ។

ឥឡូវនេះ ព្រោះបុញ្ញនិធិទាក់ទងដោយសេចក្តីប្រាថ្នាជាគ្រឿងឲ្យនូវវត្ថុ

តាមសេចក្តីប្រាថ្នា ទើបវៀរសេចក្តីប្រាថ្នាចេញមិនបាន ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយសាលីយកសូត្រ ) ថា

ម្នាលគហបតីទាំងឡាយ បុគ្គលអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រសិនបើប្រាថ្នាថា ឱហ្ន៎ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ទៅ សូមឲ្យអាត្មាអញបានទៅកើតជាមួយនឹងពួកខត្តិយមហាសាលដូច្នេះ ហេតុនុ៎ះឯង រមែងមាន បុគ្គលនោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ មុខជានឹងបានទៅកើតជាមួយនឹងពួកខត្តិយមហាសាល បានមែន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ដោយពិត ។បេ។ ដ្បិតបុគ្គលនោះ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួន ចំពោះចេតោវិមុត្តិ និង បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ ទាំងឡាយក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ បានមែន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះតែបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើដោយពិត ។

ពិតហើយ ព្រះមានព្រះមានភាគ ក៏ត្រាស់ ( ក្នុងមជ្ឈិមនិកាយសំរូបបត្តិសូត្រ ) ថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រកបដោយ សទ្ធា ប្រកបដោយសីល ប្រកបដោយសុតៈ ប្រកបដោយ

ចាគៈ ប្រកបដោយបញ្ញា ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះ
យ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះដល់រំលាងខន្ធ បន្ទាប់អំពី
មរណៈទៅ សូមឲ្យទៅកើតជាមួយនឹងពួកខត្តិយមហាសាល ។
ភិក្ខុនោះ តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះទុក ។
ធម៌ទាំង ៥ មានសទ្ធាជាដើមនោះ ឈ្មោះថា សង្ខារផង
ឈ្មោះថា វិហារធម៌ផង ដែលភិក្ខុនោះចម្រើនហើយយ៉ាងនេះ
ធ្វើឲ្យរឿយៗ ហើយយ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីកើតជា
មួយនឹងខត្តិយមហាសាលនោះមែន ។

ព្រោះដូច្នោះ កាលទ្រង់សម្តែងបរិយាយនៃការសង្ស័យយ៉ាងនោះ ការប្រាថ្នាដែលមានអធិដ្ឋានភាវនា ដោយការតាំងចិត្តជាបរិក្ខារ ព្រោះក្នុងភាពដែលបុញ្ញនិធិនោះឲ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាងនោះ ទើបត្រាស់ថា

ពួកទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណាៗ
ផលទាំងពួងនោះៗ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

## អធិប្បាយគាថាទី ១១

ឥឡូវនេះ ផលគ្រប់យ៉ាងដែលទេវតា និងមនុស្សរមែងបានដោយបុញ្ញនិធិនោះ កាលទ្រង់សម្តែងផលនោះ ជាបែបៗ ទើបត្រាស់គាថាយ៉ាងនេះថា ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះជាដើម ។

បណ្តាគាថាទាំងនោះ នឹងវិនិច្ឆ័យក្នុងគាថាទី ១ សិន ការមានឆវីវណ្ណស្អាត មានពណ៌សម្បុរដូចមាស ឈ្មោះថា មានពណ៌សម្បុរល្អនោះ បុគ្គល

រមែងបានដោយបុញ្ញនិធិនោះ ។ ដូចព្រះតម្រាស់ដែលត្រាស់ ( ក្នុងទីឃ-និកាយលក្ខណសូត្រ ) ថា

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិនមានសេចក្តីក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត សូម្បីជនច្រើននាក់ នាំគ្នាស្តីថាឲ្យ ក៏មិនឈឺចិត្ត មិនក្រោធ មិនចងកំហឹងទុក មិនតម្កល់ទុកនូវសេចក្តីក្រោធ ទាំងមិនបានធ្វើនូវសេចក្តីក្រោធ នូវការប្រទូស្ត និងសេចក្តីតូចចិត្តឲ្យប្រាកដឡើង ( ដោយកាយវិការ ឬវចីវិការ ) ឡើយ ព្រះតថាគតជាអ្នកបានឲ្យនូវកម្រាល និងសំពត់ដណ្តប់មានសាច់ល្អិត ទន់ល្មៃ គឺសំពត់ធ្វើពីសម្បកឈើ មានសាច់ម៉ដ្ឋ សំពត់ធ្វើពីកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើពីសូត្រ មានសាច់ម៉ដ្ឋ សំពត់ធ្វើពីរោមសត្វ មានសាច់ម៉ដ្ឋ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានពណ៌សម្បុរ ( លឿងភ្លឺបំព្រង ) ដូចជាសម្បុរនៃមាស និងមានស្បែកជិតស្និទ្ធ ល្អដូចជាមាស ។

ភាពជាបុគ្គលមានសំឡេងដូចព្រហ្ម ជាអ្នកនិយាយសំឡេងដូចសត្វករវិក

ឈ្មោះថា ភាពជាអ្នកមានសំឡេងពីរោះ ព្រោះភាពជាអ្នកមានសំឡេងពីរោះនោះ ដែលបុគ្គលរមែងបាន ក៏ដោយបុញ្ញនិធិនេះ ដូចព្រះតម្រាស់ត្រាស់ ( ក្នុងលក្ខណសូត្រ ) ថា

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកលះបង់នូវផរុសវាចា វៀរស្រឡះហើយចាកផរុសវាចា ជាអ្នកនិយាយតែពាក្យដែលឥតទោស ពាក្យដែលជាសុខដល់ត្រចៀកគេ គួរឲ្យស្រឡាញ់ គួរឲ្យតាំងទុកក្នុងហឫទ័យ ជាសម្ដីអ្នកក្រុង ទាំងជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាង នូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានអណ្ដាតវែង ១ មានសូរសព្ទសំឡេងក្រាំងក្រអៅ ដូចជាសំឡេងព្រហ្ម កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងសត្វករវិក ១ ។

បទថា **សុសណ្ឋានា** បានដល់ ការមានទ្រង់ទ្រាយល្អ លោកអធិប្បាយថា ការតាំងនៅនៃអវយវៈធំ-តូច ក្នុងការដែលគួរពេញ គួរមូល ដោយភាពជាអវយវៈដែលពេញ និងមូល ដូចព្រះតម្រាស់ត្រាស់ ( ក្នុងលក្ខណសូត្រ ) ថា

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសុខ ប្រាថ្នាសេចក្តីក្សេមក្សាន្តចាកយោគៈ ដល់ពួកជនច្រើនថា ធ្វើដូចម្តេចជនទាំងនេះ នឹងបានចម្រើនដោយសទ្ធា ចម្រើនដោយសីល ចម្រើនដោយសុតៈ ចម្រើនដោយវុឌ្ឍិ ចម្រើនដោយចាគៈ ចម្រើនដោយលោកិយធម៌ ចម្រើនដោយប្រាជ្ញា ចម្រើនដោយទ្រព្យ និងធញ្ញាហារ ចម្រើនដោយស្រែនិងចម្ការ ចម្រើនដោយសត្វជើង ២ និងសត្វជើង ៤ ចម្រើនដោយកូន និងប្រពន្ធ ចម្រើនដោយពួកបុរសជាទាសៈ និងកម្មករ ចម្រើនដោយពួកញាតិ ចម្រើនដោយពួកមិត្ត ចម្រើនដោយពួកផៅពង្ស ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំង ៣ នេះ គឺ មានចំណែកកន្លះកាយខាងលើស្រដៀងនឹងចំណែកកន្លះកាយនៃរាជសីហ៍ ១ មានខ្នងពេញស្មើ ឥតមានចង្អូរផតខ្នងត្រង់កណ្តាល ១ មានកមូលសម ១ ។

បទនៃព្រះសូត្រទាំងឡាយ ដែលធ្វើឲ្យការបានសម្រេចនូវបុញ្ញនិធិនេះ សូម្បីក្នុងទីដទៃអំពីនេះ ក៏គប្បីនាំអំពីទីនោះៗ ពោលដោយន័យនេះ ។ តែ

ព្រោះខ្លាចពិស្តារ ទើបសម្ដែងដោយសង្ខេប ឥឡូវនេះ ខ្ញុំនឹងពណ៌នាបទដ៏សេស ។

សរីរៈទាំងមូល គប្បីជ្រាបថា **រូប** ក្នុងពាក្យថា **សុរូបតា** នេះ ។ ដូចក្នុងប្រយោគជាដើមថា សភាពដែលអាកាសរុំព័ទ្ធ រមែងរាប់ថា រូបទាំងអស់ ។ ភាពដែលរូបនោះល្អ ឈ្មោះថា មានរូបស្អាត លោកអធិប្បាយថា មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក ។ បទថា **អាធិបច្ចំ** បានដល់ ភាពជាធំ អធិប្បាយថា ភាពជាចៅហ្វាយ ដោយភាពជាក្សត្រមហាសាលជាដើម ។ បទថា **បរិវារោ** បានដល់ សម្រាប់គ្រហស្ថ សម្បត្តិ គឺជនរបស់ខ្លួន និងជនដោយជុំវិញ សម្រាប់បព្វជិត សម្បត្តិ គឺបរិស័ទ ។ ភាពជាធំ និងភាពមានបរិវារ ឈ្មោះថា ភាពជាធំ និងមានបរិវារ បណ្ដាឥដ្ឋផលទាំងនោះ គប្បីជ្រាបថា សម្បត្តិ គឺភោគៈត្រាស់ដោយភាពជាធំ សម្បត្តិ គឺជនរបស់ខ្លួន និងជនដោយជុំវិញ ត្រាស់ដោយភាពមានបរិវារ ។ ដោយពាក្យថា **សព្វមេតេន លព្ភតិ** ព្រះមានព្រះភាគរមែងសម្ដែងថា ពាក្យនោះបានត្រាស់ថា ទេវតា និងមនុស្សទាំងឡាយប្រាថ្នាផលណាមួយ ផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញ-និធិនេះ ក្នុងពាក្យនោះ ឥដ្ឋផល មានពណ៌សម្បុរល្អជាដើម ដែលត្រាស់ចំណែកដំបូងមុននេះ គប្បីជ្រាបថា ផលទាំងអស់នោះ បុគ្គលបានដោយបុញ្ញនិធិនេះ ។

# អធិប្បាយគាថាទី ១២

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសម្បត្តិរបស់ទេវតា និងមនុស្សដែលទាបជាងសម្បត្តិ គឺភាពជាព្រះរាជា ដែលបុគ្គលគប្បីបានដោយបុញ្ញានុភាព ដោយគាថានេះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងសម្បត្តិ គឺភាពជាព្រះរាជាទាំង ២ នោះ ទើបត្រាស់គាថានេះថា

ភាពជាស្ដេចបទេសរាជ ឥស្សរិយយស សេចក្ដីសុខ
របស់ស្ដេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្ដេចនៃ
ទេវតា ក្នុងទេពនិកាយទាំងឡាយ ផលទាំងអស់ រមែង
បានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

បណ្ដាបទទាំងនោះ បទថា **បទេសរជ្ជំ** បានដល់ ភាពជាព្រះរាជានៃប្រទេស ក្នុងប្រទេសនីមួយៗ សូម្បីតែទ្វីបមួយ មិនសោយរាជ្យក្នុងទ្វីបទាំងអស់ ។ ភាពជាព្រះរាជាដែលជាធំ ឈ្មោះថា **ឥស្សរិយ** ។ ទ្រង់សម្ដែងភាពជាស្ដេចចក្រពត្តិ ដោយបទនេះ ។ សុខរបស់ស្ដេចចក្រពត្តិ ឈ្មោះថា **ចក្កវត្តិសុខ** ។ បទថា **បិយំ** បានដល់ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ។ ទ្រង់សម្ដែងភាពជាស្ដេចចក្រពត្តិ មានមហាសមុទ្រទាំង ៤ ជាព្រំប្រទល់ដោយបទនេះ ។ ភាពជាព្រះរាជាក្នុងពួកទេវតា ឈ្មោះថា **ទេវរជ្ជំ** ។ ឈ្មោះថា ទ្រង់សម្ដែងភាពជាព្រះរាជារបស់ទេវតានៃមនុស្សទាំង-ឡាយ មានស្ដេចមន្ធាតុរាជជាដើម ដោយបទនេះ ។ ដោយបទថា **អបិ ទិព្វេសុ** នេះ ទ្រង់សម្ដែងភាពជាព្រះរាជារបស់ទេវតានៃមនុស្សទាំងឡាយ ដែលកើតក្នុងទិព្វទាំងឡាយ ដែលហៅថា **ទិព្វា** ព្រោះមានក្នុងភពទិព្វ ដោយ

បទថា **សព្វមេតេន លព្ភតិ** ទ្រង់សម្តែងថា ក្នុងពាក្យដែលត្រាស់ថា **យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ** ឥដ្ឋផល មានភាពជាបទេសរាជ ដែលត្រាស់ជាចំណែកទី ២ នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នេះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។

## អធិប្បាយគាថាទី ១៣

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសម្បត្តិ គឺភាពជាព្រះរាជានៃទេវតា និងមនុស្ស ដែលបុគ្គលគប្បីបាន ដោយបុញ្ញានុភាព ដោយគាថាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ធ្វើសម្បត្តិ ដែលត្រាស់ដោយ ២ គាថាខាងមុខ ដោយសង្ខេប និងទ្រង់សម្តែងសម្បត្តិ គឺព្រះនិព្វាន ទើបត្រាស់គាថានេះថា

*សម្បត្តិរបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវ-*
*លោកណាផង សម្បត្តិ គឺព្រះនិព្វានណាផង សម្បត្តិ*
*ទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។*

បណ្តាបទនៃគាថានោះ មានដូច្នេះ ឈ្មោះថា **មានុសី** ព្រោះជារបស់មនុស្សទាំងឡាយ **មានុសី** នោះឯង ឈ្មោះថា **មានុស្សិកា**។ ការដល់ព្រម ឈ្មោះថា **សម្បត្តិ** ។ លោកនៃទេវតាទាំងឡាយ ឈ្មោះថា **ទេវលោកេ** ។ ក្នុងទេវលោកនោះ ។ បទថា **យា** ជាការកាន់យកមិនមានសេសសល់ឡើយ ។ ឈ្មោះថា **រតិ** ព្រោះត្រេកអរដោយសម្បត្តិដែលកើតខាងក្នុង ឬជាគ្រឿងឧបករណ៍ខាងក្រៅ ។ ពាក្យនេះ ជាឈ្មោះរបស់សុខ និងវត្ថុជាគ្រឿងឲ្យមានសុខ ។ ពាក្យថា **យា** ជាពាក្យសម្តែងដែលមិនពិតប្រាកដ ។

*ច សព្វំ មានសេចក្តីថា រួមគ្នានឹងសម្បត្តិទាំងពួង ។ ព្រះនិព្វាននោះឯង ឈ្មោះថា* **និព្វានសម្បត្តិ** ។

*ពណ៌នាសេចក្តី មានដូច្នេះ ដោយបទថា* **សុវណ្ណតា** *ជាដើម សម្បត្តិ និងសេចក្តីត្រេកអរនោះ ទើបត្រាស់ថា* **មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ** *សម្បត្តិរបស់មនុស្ស និងការត្រេកអរក្នុងទេវលោក ។ សម្បត្តិ និងការត្រេកអរទាំងអស់នោះ និងសម្បត្តិ គឺព្រះនិព្វាន ដែលបុគ្គលគប្បីសម្រេចដោយភាពជាព្រះអរិយបុគ្គល ដែលជាសទ្ធានុសារីបុគ្គលជាដើម ដទៃៗ ឥដ្ឋផលដូចពោលមកនេះ ដែលត្រាស់ជាទី ៣ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។ ម្យ៉ាងទៀត សម្បត្តិរបស់មនុស្សឯណា ដែលមិនបានត្រាស់ទុកមុនដោយឥដ្ឋផល មានភាពជាអ្នកមានពណ៌សម្បុរល្អជាដើម និងដោយការចេះដឹង និងការឈ្លាសជាដើម ដែលលោកសម្តែងដោយន័យយ៉ាងនេះថា ជាអ្នកអង់អាច ជាអ្នកមានសតិការនៅប្រព្រឹត្តព្រហ្មចរិយ: ក្នុងព្រះធម្មវិន័យនេះជាដើម ការត្រេកអរក្នុងឈានជាដើម ក្នុងទេវលោកដទៃណា និងនិព្វានសម្បត្តិតាមដែលពោលហើយឯណា ឥដ្ឋផលដូចពោលមកនេះ ត្រាស់ជាចំណែកទី ៣ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ គប្បីជ្រាបពណ៌នាក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។*

## អធិប្បាយគាថាទី ១៤

*ព្រះមានព្រះភាគ កាលទ្រង់សម្តែងនិព្វានសម្បត្តិដែលគប្បីបាន ដោយ*

បុញ្ញានុភាព និងដែលគប្បីសម្រេចដោយភាពជាព្រះអរិយបុគ្គល មានសទ្ធានុសារីបុគ្គលជាដើមដោយគាថានេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងនិព្វាននោះ និងឧបាយនៃនិព្វាននោះ ដោយភាពជាអ្នកជំនាញក្នុងវិជ្ជា ៣ និងឧភតោភាគវិមុត្តិ ទើបត្រាស់គាថានេះថា

> ភាពនៃបុគ្គល កាលអាស្រ័យមិត្តសម្បទា បើប្រកប
> សេចក្តីព្យាយាមដោយឧបាយ ដែលត្រូវជាអ្នកស្ទាត់ក្នុង
> វិជ្ជា និងវិមុត្តិ ឥដ្ឋផលទាំងអស់ បានដោយកំណប់ទ្រព្យ
> គឺបុណ្យនោះ ។

ពណ៌នាបទនៃគាថានោះ មានដូច្នេះថា ឈ្មោះថា **សម្បទា** ព្រោះជាគ្រឿងសម្រេចផល គឺដល់នូវសេចក្តីចម្រើននៃគុណសម្បទា គឺមិត្ត ឈ្មោះថា មិត្តសម្បទា ។ នូវមិត្តសម្បទានោះ ។ បទថា **អាគម្ម** ប្រែថា អាស្រ័យ ។ បទថា **យោនិសោ** បានដល់ ដោយឧបាយ ។ បទថា **បយុញ្ជតោ** បានដល់ ធ្វើនូវការប្រកបឧស្សាហ៍ ។ ឈ្មោះថា **វិជ្ជា** ព្រោះជាគ្រឿងដឹងច្បាស់ ។ ឈ្មោះថា **វិមុត្តិ** ព្រោះជាគ្រឿងរួចផុត ឬរួចផុតឯង ។ វិជ្ជាផង វិមុត្តិផង ឈ្មោះថា វិជ្ជា និងវិមុត្តិ ។ ភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិ ឈ្មោះថា **វិជ្ជាវិមុត្តិវសីភាវោ**។ ឯពណ៌នាសេចក្តី មានដូចតទៅនេះ

កាលដែលបុគ្គល អាស្រ័យមិត្តសម្បទា គឺអាស្រ័យព្រះសាស្តា ឬសព្រហ្មចារី ជាទីតាំងនៃសេចក្តីគោរពណាមួយ ទទួលឱវាទ និងអនុសាសនីអំពីលោកហើយ ប្រកបដោយយោនិសោមនសិការ ដោយកិច្ចបដិបត្តិតាម

ដែលលោកប្រៀនប្រដៅ ជាអ្នកជំនាញក្នុងវិជ្ជា ៣ មានបុព្វេនិវាសញ្ញាណជាដើម និងក្នុងវិមុត្តិ មានសមាបត្តិ ៨ និងព្រះនិព្វាន ដែលមកយ៉ាងនេះថា ក្នុងធម៌ទាំងនោះ វិមុត្តិ គឺអ្វី គឺការរួចផុតដ៏ក្រៃលែងនៃចិត្ត និងព្រះនិព្វាន ដោយអត្ថថា មិនយឺតយូរដោយប្រការនេះ ផលដែលត្រាស់ជាចំណែកទី ៤ នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។

# អធិប្បាយគាថាទី ១៥

ព្រះមានព្រះភាគ កាលទ្រង់សម្តែងនិព្វានសម្បត្តិ ដែលបានដោយអានុភាពនៃបុណ្យដែលជាចំណែកនៃភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិ ដែលពោលមកអំពីមុនហើយ គប្បីសម្រេចដោយអំណាចនៃវិជ្ជា ៣ និងឧភតោភាគវិមុត្តិ ដោយគាថានេះ យ៉ាងនេះហើយ ឥឡូវនេះ ព្រោះលោកដល់នូវភាពជាបុគ្គលសម្រេចនូវភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិ ជាអ្នកមានវិជ្ជា ៣ និងរួចផុតដោយចំណែក ២ លោកទាំងនោះ មិនមែនបាននូវសេចក្តីចម្រើននៃគុណ មានបដិសម្ភិទាជាដើមឡើយ តែការចម្រើននៃគុណ ដែលបុគ្គលរមែងបានដោយបុញ្ញសម្បទានោះ ដែលធ្វើហើយ ដោយប្រការនោះៗ ដោយជាបទដ្ឋាននៃវិមុត្តិនោះ ដូច្នោះ កាលទ្រង់សម្តែងសេចក្តីចម្រើននៃគុណនោះ ទើបត្រាស់គាថានេះថា

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ
និងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់ រមែងបានដោយ

កំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ព្រោះថា បញ្ញានេះ ដល់នូវការបែកធ្លាយក្នុងធម៌ អត្ថ និរុត្តិ និងបដិ-ភាណ លោកហៅថា បដិសម្ភិទា វិមោក្ខ ៨ នេះ ដោយន័យថា បុគ្គលមានរូប រមែងឃើញរូបជាដើម ។ សាវកបារមីនេះ ដែលឲ្យសម្រេចសាវកសម្បត្តិ ដែលសាវកទាំងឡាយរបស់ព្រះមានព្រះភាគ គប្បីសម្រេច ។ ព្រះបច្ចេកពុទ្ធណា ដែលឲ្យសម្រេចភាពជាព្រះសយម្ភូ និងពុទ្ធភូមិណា ដែលឲ្យសម្រេចភាពជាអ្នកឧត្តមនៃសព្វសត្វ ឥដ្ឋផលដែលត្រាស់ជាចំណែកទី ៥ នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ដែលគេធ្វើហើយដោយប្រពៃ ។

## អធិប្បាយគាថាទី ១៦

ព្រះមានព្រះភាគ កាលទ្រង់សម្តែងផល ដែលត្រាស់ទុកថា ទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាឥដ្ឋផលណាមួយ ឥដ្ឋផលទាំងអស់នោះ បុគ្គលរមែងបានដោយបុញ្ញនិធិនេះ ដោយគាថា ៥ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សរសើរបុញ្ញសម្បទា ដែលយល់ថា ជានិធិដែលឲ្យផលគួរប្រាថ្នាគ្រប់យ៉ាង ទើបទ្រង់បញ្ចប់ទេសនា ដោយគាថានេះថា

បុញ្ញសម្បទានេះ ឲ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការ
ដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយជាធីរជន ទើប
សរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ។

ពណ៌នាបទនៃគាថានោះ មានដូច្នេះថា បទថា **ឯវំ** ជាពាក្យសម្តែងភាព

ដែលកន្ទង់ហើយ ។ ឈ្មោះថា **មហត្ថិកា** ព្រោះមានប្រយោជន៍ច្រើន លោកអធិប្បាយថា ប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ បាឋៈថា **មហទ្ធិកា** ដូច្នេះក៏មាន ។ បទថា **ឯសា** ជាពាក្យឧទ្ទេស លើកបុញ្ញសម្បទា ដែលត្រាស់តាំងអំពីដើមបទនេះថា **យស្ស ទានេន សីលេន** រហូតដល់បទថា **កយិរាថ ធីរោ បុញ្ញានិ** ដោយពាក្យឧទ្ទេសនោះ ។ សព្ទថា **យទិទំ** ជានិបាតចុះក្នុងអត្ថ ធ្វើឲ្យប្រជុំគ្នា ។ ដើម្បីទ្រង់អធិប្បាយបទឧទ្ទេស ដែលទ្រង់លើកថា **ឯសា** ទើបទ្រង់ធ្វើឲ្យប្រជុំគ្នាថា **យា ឯសា** ដោយនិបាតសព្ទថា **យទិទំ** នោះ ។ ការដល់ព្រមនៃបុណ្យទាំងឡាយ ឈ្មោះថា **បុញ្ញសម្បទា** ។ បទថា **តស្មា** ជាពាក្យសម្តែងហេតុ ។ បទថា **ធីរា** បានដល់ អ្នកមានបញ្ញា ។ បទថា **បសំសន្តិ** ប្រែថា សរសើរ ។ បទថា **បណ្ឌិតា** បានដល់ ដែលដល់ព្រមដោយបញ្ញា ។ បទថា **កតបុញ្ញតំ** ប្រែថា ភាពជាអ្នកមានបុណ្យបានធ្វើហើយ ។

ចំណែកឯពណ៌នាសេចក្តី មានដូច្នេះថា ព្រះដ៏មានព្រះភាគ កាលទ្រង់សរសើរបុញ្ញនិធិ គឺភាពជាអ្នកមានពណ៌សម្បុរល្អជាដើម មានពុទ្ធភូមិ ជាទីបំផុត ដែលល្មមបុគ្គលគប្បីសម្រេចបាន ដោយអានុភាពនៃបុញ្ញសម្បទាដូច្នេះហើយ ឥឡូវនេះ កាលទ្រង់សំដែងតាមសេចក្តីនោះឯង កាលទ្រង់លើកភាពដែលបុញ្ញសម្បទា តាមដែលពោលហើយ មានប្រយោជន៍ច្រើនដោយសេចក្តីនោះឯង ទើបត្រាស់ថា ការដែលបុញ្ញសម្បទា ដែលតថាគតសម្តែងដោយន័យថា **យស្ស ទានេន សីលេន** ដូច្នេះ ព្រោះហេតុនោះ ទើប

បណ្ឌិតអ្នកមានបញ្ញា ដូចតថាគតសរសើរ ភាពជាអ្នកមានបុណ្យបានធ្វើហើយ ដែលមានអាការ និងវាការៈ គឺខន្ធច្រើន ដោយពាក្យដែលពោលក្នុងទីនេះ មានពាក្យថា កំណប់ទ្រព្យ គឺបុណ្យមិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបានជាដើម និងដែលបានពោលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំខ្លាចបុណ្យឡើយ ពាក្យថា បុណ្យនេះ ជាឈ្មោះនៃសេចក្ដីសុខនោះឯង ដូច្នេះជាដើម ដោយគុណតាមសេចក្ដីពិត ព្រោះមិនខ្ពិលច្រអូសក្នុងការសម្ដែងធម៌ ដែលនាំមកនូវប្រយោជន៍ និងសេចក្ដីសុខដល់សត្វទាំងឡាយ មិនមែនសរសើរឲ្យចូលខាងបក្ខពួករបស់ខ្លួនឡើយ ។

លុះចប់ទេសនា ឧបាសកនោះ ក៏តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយជនជាច្រើន ឯឧបាសកនោះ ក៏ចូលទៅគាល់ ព្រះបាទបសេនទិកោសល ក្រាបទូលសេចក្ដីនោះ ។ ព្រះរាជាទ្រង់ត្រេកអរក្រៃលែង ទ្រង់សរសើរថា សាធុ គហបតី សាធុ គហបតី អ្នកកប់កំណប់ទ្រព្យ ដែលខ្ញុំនាំទៅមិនបាន ទ្រង់បានធ្វើការបូជាដ៏ច្រើនដល់ឧបាសកនោះឯង ៗ។

## អដ្ឋកថា និធិកណ្ឌសូត្រ ចប់

# សុត្តន្តបិដក

## ខុទ្ទកបាឋៈ ករណីយមេត្តសូត្រ

[ ១០ ] កិច្ចណា ( ដែលព្រះអរិយៈ ) បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន ( បានធ្វើហើយ ) កិច្ចនោះ កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍គួរធ្វើ ( កុលបុត្តនោះ ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយនិងវាចាផង ត្រង់ល្អដោយចិត្តផង គេប្រដៅងាយផង មានសភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង សន្តោសផង គេចិញ្ចឹមងាយផង មានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាលព្រម ( មានបរិក្ខារតិច ) ផង មានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង មិនឃ្នើសឃ្នងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង វិញ្ញូជនទាំងឡាយ គួរតិះដៀលជនទាំងឡាយដទៃដោយកម្មណាមិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមកសូម្បីតិចតួច ( ហើយគួរផ្សាយមេត្តាចិត្តចំពោះពពួកសត្វថា ) សត្វទាំងឡាយទាំងពួងសូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ សត្វមានជីវិតទាំងឡាយណាមួយ ឥតមានសេសសល់ ទោះសត្វមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី មាំមួន គឺឥតមានតណ្ហាក្តី សត្វទាំង-ឡាយណា មានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយស្គម ឬធាត់ក្តី សត្វទាំងឡាយណា ដែលយើងឃើញហើយក្តី មិនឃើញហើយក្តី សត្វទាំងឡាយណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី សត្វទាំងអស់ ( នោះ ) ចូរមានខ្លួនជាសុខចុះ ។ សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ មិនគួរ

មើលងាយគេតិចតួចក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានិងគ្នា ព្រោះសេចក្តីក្រេវក្រោធ និងសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ ។ មាតាថ្នមរក្សាបុត្តដែលកើតអំពីខ្លួន ជាកូនតែមួយដោយអាយុ ( ស្មើដោយជីវិត ) យ៉ាងណាមិញ បុគ្គលគួរចម្រើមេត្តាចិត្ត មិនមានប្រមាណចំពោះសត្វទាំងឡាយទាំងពួង យ៉ាងនោះឯង ។ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ គឺក្នុងទីខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង ។ ( បុគ្គលអ្នកចម្រើនមេត្តាចិត្តនោះ ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់អស់កាលត្រឹមណា គួរតម្កល់នូវសតិនោះ អស់កាលត្រឹមនោះ បណ្ឌិតទាំង-ឡាយ ពោលនូវកិរិយានុ៎ះថា ជាព្រហ្មវិហារក្នុងសាសនានេះ ។ ( បុគ្គលដែលមានមេត្តាព្រហ្មវិហារ ) មិនងប់ងល់នឹងទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ ( តទៅទៀត ) បន្ទោបង់នូវសេចក្តីជាប់ជំពាក់ក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់ គព្ភសេយ្យាទៀតឡើយ ។

មេត្តសូត្រ ចប់

ខុទ្ទកបាឋៈ ចប់

# អដ្ឋកថា

# មេត្តសូត្រ

## ប្រយោជន៍នៃការតាំងនិក្ខេបបទ

[ ១០ ] ឥឡូវនេះ ដល់លំដាប់ពណ៌នាអត្ថនៃមេត្តសូត្រ ដែលលើកឡើងក្នុងលំដាប់ បន្ទាប់អំពីនិធិកណ្ឌសូត្រ ។ ក្នុងទីនេះ ខ្ញុំនឹងពោលប្រយោជន៍នៃការតាំងមេត្តសូត្រនោះ ហើយបន្ទាប់អំពីនោះ គប្បីជ្រាបការបង្អុលបង្ហាញបទទាំងនេះថា មេត្តសូត្រនោះ បុគ្គលណាពោល ពោលក្នុងកាលណា ពោលទីណា ពោលព្រោះហេតុដូចម្ដេច ជម្រះនិទានហើយ ទើបនឹងពណ៌នាអត្ថនៃមេត្តសូត្រនោះ ។

ក្នុងមេត្តសូត្រនោះ ព្រោះទ្រង់ត្រាស់បុញ្ញសម្បទា មានទាន សីលជាដើម ដោយនិធិកណ្ឌសូត្រ ។ កាលបុគ្គលធ្វើមេត្តាក្នុងសត្វទាំងឡាយ បុញ្ញសម្បទានោះ រមែងមានផលច្រើន រហូតដល់អាចឲ្យសម្រេចពុទ្ធភូមិបាន ដូច្នោះទើបខ្ញុំលើកមេត្តសូត្រឡើងក្នុងទីនេះ ដើម្បីសម្ដែងថា មេត្តសូត្រមានឧបការៈដល់បុញ្ញសម្បទានោះ ឬព្រោះហេតុដែលខ្ញុំ កាលសម្ដែងកម្មដ្ឋានដែលអាចលះទោសៈ ដោយទ្វត្តឹសាការសម្រាប់ជនទាំងឡាយ ដែលរាប់អានព្រះសាសនាដោយសរណៈ ហើយតាំងនៅក្នុងសីល ដោយសិក្ខាបទទាំងឡាយ នឹងអាចលះមោហៈដោយកុមារបញ្ហា ទើបសម្ដែងថា ការប្រព្រឹត្តសរណៈជាដើមនោះជាមង្គល និងរក្សាខ្លួនឯងដោយមង្គលសូត្រ សម្ដែងការរក្សាអ្នកដទៃ ដែលសមគួរដល់មង្គលនោះ ដោយរតនសូត្រ សម្ដែងការឃើញកូតពួកខ្លះ ក្នុង

បណ្ដាកូតទាំងឡាយដែលពោលមកក្នុងរតនសូត្រ និងការវិបត្តិនៃជន ដែលប្រមាទក្នុងបុញ្ញសម្បត្តិ ដូចដែលពោលហើយដោយតិរោកុឌ្ឌសូត្រ និងសម្ដែងសម្បត្តិដែលជាបដិបក្ខចំពោះវិបត្តិដែលពោលក្នុងតិរោកុឌ្ឌសូត្រ ដោយនិធិ-កណ្ឌសូត្រ តែមិនទាន់បានសម្ដែងកម្មដ្ឋាន ដែលអាចលះទោសៈ ដូច្នោះ ដើម្បីសម្ដែងកម្មដ្ឋានដែលអាចលះទោសៈនោះ ទើបខ្ញុំលើកមេត្តសូត្រនេះឡើងក្នុងទីនេះ ។ កាលបើដូច្នោះ ទើបខ្ញុំទុកបាឋៈបរិបូណ៌ដោយល្អ ការពោលមកដូច្នេះ ជាប្រយោជន៍នៃការតាំងមេត្តសូត្រនោះក្នុងទីនេះ ។

## អធិប្បាយនិទាន

ឥឡូវនេះ ខ្ញុំនឹងលើកមាតិកានេះឡើងថា គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា មេត្តសូត្រនេះ បុគ្គលណាពោល ពោលកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី ខ្ញុំជម្រះនិទានហើយ នឹងពណ៌នាសេចក្ដីនៃមេត្តសូត្រនោះ ដូច្នេះ ។

ក្នុងមាតិកានោះ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះ និងការជម្រះនិទាន ដោយសង្ខេបយ៉ាងនេះមុនថា មេត្តសូត្រនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ សាវកជាដើមមិនបានពោល តែកាលណា ភិក្ខុទាំងឡាយត្រូវទេវតាទាំងឡាយបៀតបៀន ក្បែរភ្នំហិមពាន្ត ទើបនាំគ្នាមកគាល់ព្រះមានព្រះភាគ កាលនោះ ទើបព្រះមានព្រះភាគត្រាស់មេត្តសូត្រនោះ ដើម្បីការពារ និងដើម្បីជាកម្មដ្ឋានសម្រាប់ភិក្ខុទាំងនោះ ។

ចំណែកដោយពិស្ដារ គប្បីជ្រាបយ៉ាងនេះថា សម័យមួយ ក្នុងតិថីជិត

ចូលវស្សា ព្រះមានព្រះភាគ ប្រថាប់នៅក្នុងក្រុងសាវត្ថី ។ សម័យនោះ ភិក្ខុទាំងឡាយ មកអំពីនគរផ្សេងៗ ជាច្រើន ទទួលកម្មដ្ឋានក្នុងសម្នាក់ព្រះមានព្រះភាគហើយ បំណងនឹងចាំវស្សាក្នុងទីនោះៗ ទើបចូលគាល់ព្រះមានព្រះភាគ ។ បានឮថា សម័យនោះ ព្រះមានព្រះភាគ ត្រាស់កម្មដ្ឋានទាំងឡាយ ដែលសមគួរដល់ចរិត ៨៤០០០ ប្រភេទ ដោយន័យយ៉ាងនេះ គឺ អសុភកម្មដ្ឋាន ១១ យ៉ាង គឺអសុភដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ សម្រាប់បុគ្គលរាគចរិត កម្មដ្ឋាន មានមេត្តាកម្មដ្ឋានជាដើម ៤ យ៉ាង សម្រាប់បុគ្គលទោសចរិត កម្មដ្ឋាន មានមរណស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលមោហចរិត កម្មដ្ឋាន មានអានាបានស្សតិ និងបឋវីកសិណជាដើម សម្រាប់បុគ្គលវិតក្កចរិត កម្មដ្ឋាន មានពុទ្ធានុស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលសទ្ធាចរិត កម្មដ្ឋាន មានចតុធាតុវវដ្ឋានកម្មដ្ឋានជាដើម សម្រាប់បុគ្គលពុទ្ធិចរិត ។

លំដាប់នោះ ភិក្ខុប្រមាណ ៥០០ រូប រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះមានព្រះភាគ កំពុងស្វែងរកសេនាសនៈ ដែលជាសប្បាយ និងគោចរគាម ធ្វើដំណើរទៅតាមលំដាប់ បានជួបភ្នំ មានផ្ទាំងថ្មពណ៌ខៀវចាស់ដូចកែវមណីប្រដាប់ដោយដងព្រៃពណ៌ខៀវ មានម្លប់ត្រជាក់ មានផែនដីរាបស្មើ ក្រាលដោយខ្សាច់ ដូចបន្ទះប្រាក់ និងដូចសំណាញ់នៃកែវមុក្តា ព័ទ្ធដោយជលាល័យដ៏ស្អាតល្អ ជាប់គ្នានឹងព្រៃហិមពាន្ត ក្នុងបច្ចន្តប្បទេស ភិក្ខុទាំងនោះស្នាក់នៅមួយយប់ក្នុងទីនោះ កាលរាត្រីអស់ហើយ ធ្វើសរីរកិច្ច ក៏នាំគ្នាចូលទៅបិណ្ឌ-

បាត ត្រង់ភូមិមួយកន្លែងជិតទីនោះឯង ភូមិនោះប្រកបដោយត្រកូលមួយពាន់ ដែលនៅអាស្រ័យកុះករក្នុងភូមិនោះ មនុស្សទាំងឡាយមានបសាទសទ្ធា ជនទាំងនោះឃើញភិក្ខុទាំងឡាយប៉ុណ្ណោះ ក៏កើតបីតិសោមនស្ស ព្រោះការឃើញបព្វជិតក្នុងបច្ចន្តបទេស រកបានដោយកម្រ និមន្តភិក្ខុទាំងនោះឲ្យឆាន់ហើយ ក៏អារាធនាថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់គង់នៅទីនេះអស់ត្រៃមាសចុះ ហើយនាំគ្នាសង់កុដិសម្រាប់ធ្វើសេចក្ដីព្យាយាម ៥០០ ខ្នង រៀបចំគ្រឿងឧបករណ៍គ្រប់យ៉ាង មានគ្រែ តាំង ក្អមទឹកសម្រាប់ឆាន់ ទឹកប្រើប្រាស់ជាដើមក្នុងទីនោះ ។

ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយ ចូលទៅបិណ្ឌបាតក្នុងតំបន់ដទៃ ក្នុងភូមិនោះ មនុស្សទាំងឡាយ ក៏ទំនុកបម្រុងយ៉ាងនោះដូចគ្នា អារាធនាឲ្យនៅចាំវស្សា ។ ភិក្ខុទាំងឡាយទទួលនិមន្ត ដោយអាងលេសថា បើមិនមានអន្តរាយ ទើបនាំគ្នាចូលទៅកាន់ដងព្រៃនោះ ជាអ្នកប្រារព្ធសេចក្ដីព្យាយាមអស់យប់និងថ្ងៃ វាយជួងប្រាប់យាម ជាអ្នកច្រើនដោយយោនិសោមនសិការ ទើបចូលទៅអង្គុយត្រង់គល់ឈើ ។ រុក្ខទេវតាទាំងឡាយ ត្រូវតេជះរបស់ភិក្ខុអ្នកមានសីលកម្ចាត់ហើយ ក៏ចុះចាកវិមានរៀងៗ ខ្លួន នាំកូនៗ ត្រាច់ទៅរហង់ ប្រៀបដូចកាលព្រះរាជា ឬរាជអមាត្យទៅកាន់លំនៅរបស់អ្នកស្រុក កាន់យកឱកាសទំនេរក្នុងផ្ទះទាំងឡាយ របស់ពួកអ្នកស្រុកៗ ក៏ត្រូវចេញអំពីផ្ទះ ទៅកាន់ទីដទៃ បានត្រឹមតែសម្លឹងមើលក្បែរៗ ដោយបំណងថា កាលណាហ្ន៎ ទើបព្រះរាជាយាងទៅវិញ យ៉ាងណា ទេវតាទាំងឡាយ ត្រូវលះបង់វិមានរបស់ខ្លួន

រៀងៗ ខ្លួន បានត្រឹមតែសម្លឹងមើលជិតៗ ដោយបំណងថា កាលណាហ្ន៎ ទើបលោកទៅវិញ ក៏ដូច្នោះដូចគ្នា ។ បន្ទាប់អំពីនោះ ទេវតាទាំងឡាយក៏នាំគ្នាគិតយ៉ាងនេះថា ភិក្ខុទាំងឡាយ ចូលវស្សាដំបូងហើយ នឹងនៅអស់ត្រៃមាសដោយពិត ពួកយើងមិនអាចនាំកូននៅរងោករង្គយបានយូរឡើយ ណ្ហើយចុះពួកយើងនឹងបង្ហាញអារម្មណ៍ ដែលគួរខ្លាចដល់ភិក្ខុទាំងឡាយ ។ ទើបទេវតាទាំងនោះនិម្មិតរូបយក្ខដែលគួរខ្លាច ឈរនៅចំពោះមុខ ក្នុងពេលដែលភិក្ខុទាំងឡាយធ្វើសមណធម៌ នៅពេលរាត្រី និងធ្វើសំឡេងគួរខ្លាច ព្រោះឃើញរូបទាំងនោះ និងបានឮសំឡេងនោះ ហទយៈរបស់ភិក្ខុទាំងឡាយក៏កម្រើកភិក្ខុទាំងនោះមានពណ៌សម្បុរស្លេកស្លាំង និងកើតរោគស្គមលឿង ។ ដោយហេតុនោះ ទើបភិក្ខុទាំងនោះ មិនអាចធ្វើចិត្តឲ្យមានអារម្មណ៍តែមួយបាន កាលចិត្តមិនមានអារម្មណ៍តែ ១ ភិតភ័យរឿយៗ ព្រោះសេចក្ដីខ្លាច សតិរបស់ ភិក្ខុទាំងនោះក៏ប្រាសទៅ បន្ទាប់អំពីនោះ អារម្មណ៍ដែលស្អុយ ក៏ជួបដល់ភិក្ខុទាំងនោះ ដែលប្រាសចាកសតិហើយ ខួរក្បាលរបស់ភិក្ខុទាំងនោះហាក់ដូចត្រូវក្លិនស្អុយនោះបៀតបៀន រោគឈឺក្បាលក៏កើតឡើងយ៉ាងធ្ងន់ ។ ភិក្ខុទាំងនោះ ក៏មិនព្រមប្រាប់រឿងនោះដល់គ្នានិងគ្នា ។

ថ្ងៃមួយ កាលភិក្ខុគ្រប់រូបប្រជុំគ្នា ក្នុងពេលបម្រើព្រះសង្ឃត្ថេរ ។ ព្រះសង្ឃត្ថេរសួរថា អាវុសោ កាលពួកលោកចូលទៅកាន់ដងព្រៃនេះ ២-៣ ថ្ងៃ ពណ៌សម្បុរបរិសុទ្ធផូរផង់ក្រៃពេក ឥន្ទ្រិយក៏ផូរផង់ តែឥឡូវនេះ ក្នុងទីនេះពួកលោកស្គាំងស្គម ពណ៌សម្បុរស្លេកស្លាំង កើតរោគស្គមលឿង ក្នុងទីនេះ

ពួកលោកមិនសប្បាយឬ ។

លំដាប់នោះ ភិក្ខុមួយរូបពោលថា បពិត្រលោកម្ចាស់ ពេលយប់ ខ្ញុំឃើញ និងឮអារម្មណ៍ដែលគួរខ្លាចយ៉ាងនេះៗ ហិតតែក្លិនបែបនេះ ដោយហេតុនោះ ទើបចិត្តរបស់ខ្ញុំ មិនតាំងមាំជាសមាធិ ។ ភិក្ខុគ្រប់រូបក៏នាំគ្នាប្រាប់រឿងនោះដោយឧបាយនេះដូចគ្នា ព្រះសង្ឃត្ថេរពោលថា អាវុសោ ព្រះមានព្រះភាគទ្រង់បញ្ញត្តការចូលវស្សា ២ យ៉ាង សេនាសនៈនេះ មិនសប្បាយដល់ពួកយើង មកចុះអាវុសោ ពួកយើងនាំគ្នាទៅគាល់ព្រះមានព្រះភាគ ទូលសួរដល់សេនាសនៈដែលជាសប្បាយដទៃៗ ភិក្ខុទាំងនោះទទួលពាក្យព្រះថេរៈថា សាធុ គ្រប់រូបក៏ទុកដាក់សេនាសនៈ កាន់បាត្រ ចីវរ មិនប្រាប់ដល់បុគ្គលណាម្នាក់ក្នុងត្រកូលទាំងឡាយ នាំគ្នាចារិកទៅកាន់ក្រុងសាវត្ថី ដល់ក្រុងសាវត្ថីតាមលំដាប់ ហើយក៏នាំគ្នាចូលគាល់ព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ ទ្រង់ឃើញភិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ តថាគតបញ្ញត្តសិក្ខាបទថា ភិក្ខុមិនគប្បីចារិកទៅខាងក្នុងវស្សា ហេតុអ្វី ទើបពួកអ្នកនាំគ្នាចារិក ។ ទើបភិក្ខុទាំងនោះ ក្រាបទូលរឿងទាំងអស់ដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់អាវជ្ជនៈក៏មិនឃើញសេនាសនៈដែលជាសប្បាយដទៃសម្រាប់ភិក្ខុទាំងនោះ ពេញជម្ពូទ្វីប ដោយហោចសូម្បីត្រឹមតែតាំងដែលមានជើង ៤ ដូច្នោះ ទើបត្រាស់ប្រាប់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ សេនាសនៈដែលជាសប្បាយដទៃ សម្រាប់ពួកអ្នកមិនមានទេ ពួកអ្នកចូរនៅក្នុងទីនោះឯង នឹងសម្រេចធម៌ជាទីអស់អាសវៈ ទៅចុះភិក្ខុទាំង-

ឡាយ ពួកអ្នកទៅអាស្រ័យសេនាសនៈនោះជាមួយគ្នាចុះ តែបើពួកអ្នកប្រាថ្នាការមិនមានភ័យអំពីទេវតាទាំងឡាយ ក៏ចូរនាំគ្នារៀនព្រះបរិត្តនេះ ដ្បិតថាព្រះបរិត្តនេះ នឹងជាគ្រឿងការពារ និងជាកម្មដ្ឋានសម្រាប់ពួកអ្នក ដូច្នេះហើយទើបត្រាស់ព្រះសូត្រនេះ ។

តែអាចារ្យពួកដទៃទៀតពោលថា ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកចូរទៅចុះ ពួកអ្នកចូរទៅអាស្រ័យសេនាសនៈនោះឯង ជាមួយគ្នាចុះ ហើយទើបត្រាស់ថា ម្យ៉ាងទៀត ភិក្ខុនៅព្រៃ គួរស្គាល់បរិហារ ។ បរិហារដូចម្តេច បរិហារយ៉ាងនេះ គឺផ្សាយមេត្តា ២ ពេល គឺធ្វើពេលល្ងាច និងព្រឹក ធ្វើព្រះបរិត្ត ២ ពេល ចម្រើនអសុភ ២ ពេល ចម្រើនមរណស្សតិ ២ ពេល និងគិតដល់សង្វេគវត្ថុ ៨ គឺជាតិ ជរា ព្យាធិ មរណៈ អបាយទុក្ខបួន ២ ពេល ។

ម្យ៉ាងទៀត ជាតិ ជរា ព្យាធិ មរណៈ ៤ អបាយទុក្ខជាគម្រប់ ៥ អតីតវដ្តមូលទុក្ខ ១ អនាគតវដ្តមូលទុក្ខ ១ ទុក្ខព្រោះការស្វែងអាហារបច្ចុប្បន្នជាមូល ១ ។ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់ការបរិហារយ៉ាងនេះហើយទើបត្រាស់ព្រះសូត្រនេះ ដើម្បីជាមេត្តា ដើម្បីជាព្រះបរិត្ត និងដើម្បីឈានដែលជាបាទនៃវិបស្សនាដល់ភិក្ខុទាំងនោះ ។ គប្បីជ្រាបការចង្អុលបង្ហាញបទទាំងនេះថា **យេន វុត្តំ យទា យត្ថ យស្មា ចេ** និងការជម្រះនិព្វាន ដោយប្រការដូច្នេះ ។

មាតិកានោះ ខ្ញុំតាំងទុកថា **យេន វុត្តំ យទា យត្ថ យស្មា ចេតេស**

**ឌីបនា និទានំ សោធយិត្វា ។** មាតិកានោះ ខ្ញុំពោលពិស្តារហើយ ដោយអាការទាំងពួង ដោយគាថាមានប្រមាណប៉ុណ្ណេះ ។

# អធិប្បាយ គាថាទី ១

ឥឡូវនេះ នឹងផ្តើមពណ៌នាសេចក្តីនៃព្រះសូត្រនោះ ដែលធ្វើការជម្រះនិទានហើយយ៉ាងនេះ ខ្ញុំបានពោលថា នឹងពណ៌នាសេចក្តីនៃព្រះសូត្រនោះដូច្នេះ ។ ក្នុងគាថានោះ នឹងផ្តើមពណ៌នាបទនៃគាថានេះថា **ករណីយមត្ថ-កុសលេន** ដូច្នេះជាមុនសិន ។ បទថា **ករណីយំ** ប្រែថា គប្បីធ្វើ អធិប្បាយថា គួរដល់ការធ្វើ ។ បដិបទា ឈ្មោះថា អត្ថ ឬប្រយោជន៍ដល់ខ្លួនណាមួយ ប្រយោជន៍ទាំងអស់នោះ លោកហៅថា អត្ថ ព្រោះមិនមានកិលេស ដូចសត្រូវ ឈ្មោះថា **ករណី** ព្រោះដែលបុគ្គលគប្បីចូលដល់ ។ បុគ្គលឈ្លាសក្នុងប្រយោជន៍ ឈ្មោះថា **អត្ថកុសល** លោកអធិប្បាយថា ជាបុគ្គលឈ្លាសក្នុងប្រយោជន៍ ។ បទថា **យំ** ជាបឋមាវិភត្តិ សម្តែងការមិនពិតប្រាកដ ។ បទថា **តំ** ជាទុតិយាវិភត្តិ សម្តែងអត្ថពិតប្រាកដ ។ ឬថា ពាក្យថា **យំ តំ** ទាំង ២ ជាបឋមាវិភត្តិ ។ ពាក្យថា **សន្តំ បទំ** ជាទុតិយាវិភត្តិ ។ បណ្តាពាក្យទាំង ២ នោះ ឈ្មោះថា **សន្ត** ព្រោះជាលក្ខណៈ ដែលមានឈ្មោះថា **បទ** ព្រោះដែលបុគ្គលគប្បីដល់ ពាក្យនេះជាឈ្មោះនៃព្រះនិព្វាន ។ បទថា **អភិសមេច្ច** ប្រែថា សម្រេចហើយ ។ បុគ្គលណា រមែងអាច ហេតុនោះបុគ្គលនោះ ឈ្មោះថា **សក្ក** គឺជាអ្នកអាច លោកអធិប្បាយថា ជាអ្នកអាច ជាអ្នកអាចហ៊ាន ។ បទថា **ឧជុ** បានដល់ ប្រកបដោយការត្រង់ ។ បុគ្គល

ណាត្រង់ដោយល្អ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **សុហុជូ** គឺអ្នកត្រង់ដោយល្អ ។ ការប្រដៅងាយមានក្នុងបុគ្គលនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **សុវចោ** គឺជាអ្នកប្រដៅងាយ ។ បទថា **អស្ស** ប្រែថា គប្បីមាន គប្បីកើត ។ បទថា **មុទុ** បានដល់ ប្រកបដោយការទន់ភ្លន់ បុគ្គលណាមិនមានអតិមានះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **អនតិមានី**។

ឯពណ៌នាក្នុងគាថាទី ១ មានដូច្នេះថា ។

នឹងវិនិច្ឆ័យក្នុងពាក្យថា **ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច** នេះមុន ។ **ករណី** ក៏មាន **អករណី** ក៏មាន ។ ក្នុង ២ យ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា **ករណី**។ សីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ អាជីវវិបត្តិ ដូចពោលមកយ៉ាងនេះជាដើម ឈ្មោះថា **អករណី** ម្យ៉ាងទៀត **អត្ថកោសល** ក៏មាន **អនត្ថកោសល** ក៏មាន ។ ក្នុង ២ យ៉ាងនោះ បុគ្គលណាបួសក្នុងសាសនានេះ មិនប្រកបខ្លួនដោយប្រពៃ ជាអ្នកមានសីលដាច់ អាស្រ័យអានេសនា គឺការស្វែងរកដែលមិនសមគួរ ២១ យ៉ាងចិញ្ចឹមជីវិត គឺឲ្យប្ញស្សី ១ ឲ្យស្លឹកឈើ ១ ឲ្យផ្កា ១ ឲ្យផ្លែឈើ ១ ឲ្យឈើស្ទន់ ១ ឲ្យទឹកលុបមុខ ១ ឲ្យទឹកងូត ១ ឲ្យលម្អិតលាបខ្លួន ១ ឲ្យដីដុសខ្លួន ១ និយាយបញ្ចោរ ១ និយាយលេងលាយមែន ១ ចិញ្ចឹមកូនឲ្យគេ ១ ទទួលបម្រើគ្រហស្ថ ១ ធ្វើខ្លួនជាគ្រូពេទ្យ ១ ធ្វើខ្លួនជាទូត ១ ទទួលបញ្ជូនដំណឹងគ្រហស្ថ ១ យកលាភទាក់លាភ ១ ដោះដូរ ១ ធ្វើគ្រូមើលផែនដី ១ ធ្វើគ្រូមើលឫក្ស ១ ជាគ្រូមើលលក្ខណៈ ១ ។ ប្រព្រឹត្តអគោចរ ៦ គឺ

កន្លែងស្រីពេស្យា ១ សម្នាក់ស្រីមេម៉ាយ ១ សម្នាក់ក្រមុំចាស់ ១ សម្នាក់ខ្ទើយ ១ សម្នាក់ភិក្ខុនី ១ រោងសុរា ១ ។ ប្រឡូកប្រឡំដោយគ្រហស្ថ គឺ ព្រះរាជា អមាត្យ តិត្ថិយ សាវកតិត្ថិយ ដោយការប្រឡូកប្រឡំ ដែលមិនសមគួរ ។ សេពគប់បុគ្គលចូលត្រកូល ដែលមិនមានបសាទសទ្ធា មិនដូចជាអណ្តូងទឹក ជេរ និងបរិភាស ប្រាថ្នាតែវត្ថុដែលមិនជាប្រយោជន៍ មិនផាសុក មិនលែងនូវយោគៈ ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា កុលបុត្តនេះ ឈ្មោះថា ឈ្លាសក្នុងវត្ថុមិនជាប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាបួសក្នុងព្រះសាសនានេះ ប្រកបខ្លួនដោយប្រពៃ លះអនេសនា ប្រាថ្នាតែការតាំងនៅក្នុងចតុប្បារិសុទ្ធិសីល បំពេញបាតិមោក្ខ-សំវរសីលដោយសទ្ធាជាសំខាន់ បំពេញឥន្ទ្រិយសំវរសីល ដោយសតិជាសំខាន់ បំពេញអាជីវបារិសុទ្ធិសីល ដោយសេចក្តីព្យាយាមជាសំខាន់ បំពេញការសេពបច្ច័យដោយបញ្ញាជាសំខាន់ បុគ្គលនេះ ឈ្មោះថា កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណា ជម្រះបាតិមោក្ខសំវរសីល ដោយជម្រះអាបត្តិ ៧ កង ជម្រះឥន្ទ្រិយសំវរសីល ដោយមិនឲ្យអភិជ្ឈាជាដើមកើតក្នុងអារម្មណ៍ ដែលប៉ះខ្ទប់ក្នុងទ្វារ ៦ ជម្រះអាជីវបារិសុទ្ធិសីល ដោយវៀរអនេសនា និងសេពតែបច្ច័យដែលវិញ្ញូជនសរសើរ និងដែលព្រះពុទ្ធ សាវករបស់ព្រះពុទ្ធសរសើរ ជម្រះការសេពបច្ច័យ ដោយការពិចារណាបច្ច័យតាមដែលពោល និងជម្រះសម្បជញ្ញៈ ដោយការពិចារណាជាសាត្ថកសម្បជញ្ញៈជាដើម ក្នុង

ការផ្លាស់ឥរិយាបថទាំង ៤ បុគ្គលនេះ ក៏ឈ្មោះថា កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណា សំពត់ស្មោកគ្រោក អាស្រ័យទឹកប្រៃ ក៏ធ្វើឲ្យស្អាតបាន កញ្ចក់អាស្រ័យផេះ ក៏ធ្វើឲ្យស្អាតបាន មាសអាស្រ័យការលត់ ក៏ធ្វើឲ្យបរិសុទ្ធបាន យ៉ាងណា សីលអាស្រ័យញាណ ក៏ផូរផង់បាន ដូច្នោះ ។ ហើយជម្រះដោយទឹក គឺញាណ ធ្វើសីលឲ្យបរិសុទ្ធបាន ប្រៀបដូចសត្វត្រដៀវរិចរក្សានូវស៊ុត សត្វចាមរីរក្សានូវរោមកន្ទុយ នារីមានកូនតែមួយរក្សាបុត្រតែម្នាក់ជាទីស្រឡាញ់ និងដូចបុរសមានភ្នែកម្ខាង រក្សានូវភ្នែកម្ខាងនោះ យ៉ាងណា បុគ្គលមិនប្រមាទក៏រក្សាសីលក្ខន្ធរបស់ខ្លួនក៏ដូច្នោះ បុគ្គលនោះពិចារណាទាំងព្រឹក ទាំងល្ងាច ក៏មិនជួបនូវទោស មានប្រមាណតិចតួច បុគ្គលនេះ ក៏ឈ្មោះថា កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាតាំងនៅក្នុងសីល ដែលមិនធ្វើនូវការក្តៅក្រហាយរមែងផ្គងបដិបទាដែលជាគ្រឿងសង្កត់កិលេស ។ កាលផ្គងបដិបទានោះហើយ រមែងធ្វើបរិកម្មក្នុងកសិណ កាលធ្វើបរិកម្មក្នុងកសិណហើយ រមែងញ៉ាំងសមាបត្តិទាំងឡាយឲ្យកើត បុគ្គលនេះ ក៏ឈ្មោះថា កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ ។

ម្យ៉ាងទៀត បុគ្គលណាចេញចាកសមាបត្តិ ពិចារណាសង្ខារទាំងឡាយរមែងសម្រេចអរហត្ត បុគ្គលនេះជាកំពូលនៃអ្នកឈ្លាសក្នុងប្រយោជន៍ ជនទាំងនេះ ជាអ្នកឈ្លាសក្នុងប្រយោជន៍ដែលលោកសរសើរហើយ ដោយត្រឹម

*តែតាំងនៅក្នុងសីល ដែលមិនធ្វើការក្តៅក្រហាយ ឬដោយត្រឹមតែផ្គងនូវបដិបទាជាគ្រឿងសង្កត់កិលេស ជនទាំងនោះ លោកបំណងថា កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍ក្នុងអត្តនេះ ។ ភិក្ខុទាំងនោះក៏ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅដល់ភិក្ខុទាំងនោះ ទើបត្រាស់ទេសនាជាបុគ្គលាធិដ្ឋានតែម្យ៉ាងថា* **ករណីយមត្ថកុសលេន** *ដូច្នេះ ។*

*បន្ទាប់អំពីនោះ កាលភិក្ខុទាំងនោះកើតសេចក្តីសង្ស័យថា កិច្ចណាមួយដែលត្រូវធ្វើ ទើបព្រះមានព្រះភាគត្រាស់ថា* **យន្តំ សន្តំ បទំ អភិសមេច្ច** *ពាក្យនេះ មានអធិប្បាយដូច្នេះថា ព្រះពុទ្ធ និងអនុពុទ្ធទាំងឡាយសរសើរកិច្ចដែលបុគ្គលបំណងនឹងសម្រេចសន្តិបទ ដោយការចាក់ធ្លុះ ហើយគប្បីធ្វើ ។ ក្នុងពាក្យនេះ គប្បីជ្រាបថា ពាក្យថា* **យំ** *ខ្ញុំបានពោលខាងដើមបទគាថានោះហើយ រមែងប្រព្រឹត្តទៅដោយអធិការថា* **ករណីយំ** *គឺ* **តំ សន្តំ បទំ អភិសមេច្ច** ។ *តែព្រោះសេចក្តីនេះ មានបាឋៈដែលត្រូវបន្ថែមពាក្យដ៏សេស ដូច្នោះ ទើបខ្ញុំពោលថា* **វិហរិតុ កាមេន** ។

*ម្យ៉ាងទៀត ក្នុងពាក្យនេះ គប្បីជ្រាបអធិប្បាយយ៉ាងនេះថា ពាក្យថា* **សន្តំ បទំ អភិសមេច្ច** *រមែងប្រព្រឹត្តទៅដោយអធិការថា កិច្ចនោះ ដែលបុគ្គលបំណងដឹងបទ គឺព្រះនិព្វានថា* **សន្ត** *ដោយលោកិយប្បញ្ញា ដោយបានស្តាប់មកជាដើម និងសម្រេចបទ គឺព្រះនិព្វាននោះ គប្បីធ្វើ ។ ម្យ៉ាងទៀត កាលត្រាស់ថា* **ករណីយមត្ថកុសលេន** *កាលភិក្ខុទាំងឡាយនាំគ្នាគិតថា ធ្វើអ្វី ទើបត្រាស់ថា* **យន្តំ សន្តំ បទំ អភិសមេច្ច** ។ *ន័យនោះ គប្បីជ្រាបអធិប្បាយ*

យ៉ាងនេះ កិច្ចណាដែលបុគ្គលដឹងសន្តិបទ ដោយលោកិយបញ្ញាហើយ គប្បីធ្វើ គប្បីប្រកបកិច្ចនោះ ក៏គួរធ្វើលោកអធិប្បាយថា កិច្ចក៏គួរដល់ការធ្វើទាំងអស់ ។

សួរថា កិច្ចនោះ គឺអ្វី ។ ឆ្លើយថា កិច្ចអ្វីដទៃ គប្បីមាន ក្រៅអំពីឧបាយសម្រេចនិញ្វានបទនោះ ។ កិច្ចនោះ ខ្ញុំពោលហើយដោយបទដើម ដែលសម្ដែងសិក្ខា ៣ ព្រោះអត្ថថា គួរដល់ការធ្វើ សេចក្ដីពិត ទោះបីយ៉ាងនោះក្នុងកាលពណ៌នាអត្ថនៃពាក្យនោះ ខ្ញុំក៏បានពោលហើយថា **ករណី** ក៏មាន **អករណី** ក៏មាន ។ ក្នុង ២ យ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា **ករណី** ។ តែព្រោះទ្រង់សម្ដែងសង្ខេបពេក បណ្ដាភិក្ខុទាំងនោះ ពួកខ្លះក៏មិនដឹង ។ បន្ទាប់អំពីនោះ ការត្រាស់កិច្ចដោយចំពោះយ៉ាងក្រៃលែង ដែលភិក្ខុនៅព្រៃគួរធ្វើឲ្យពិស្ដារ ដើម្បីឲ្យពួកភិក្ខុដែលមិនដឹង បានដឹង ទើបត្រាស់កន្លះគាថានេះមុនថា **សក្កោ ឧជូ ច សុហុជូ ច សុវចោចស្ស មុទុ អនតិមានី** ។

លោកអធិប្បាយដូចម្ដេច លោកអធិប្បាយថា ភិក្ខុនៅព្រៃ បំណងនឹងសម្រេចសន្តិបទ ឬសម្រេចសន្តិបទនោះ ដោយលោកិយបញ្ញាហើយ បដិបត្តិដើម្បីសម្រេចសន្តិបទនោះ មិនអាល័យក្នុងកាយ និងជីវិត ដោយការប្រកបបធានិយង្គ ប្រការទី ២ និងទី ៤ គប្បីជាអ្នកអាចបដិបត្តិចាក់ធ្លុះនូវសច្ចៈ ករណីយកិច្ចដែលគួរធ្វើណាមួយ ទោះខ្ពស់ទាបនៃសព្រហ្មចារី ក្នុងការបរិកម្មកសិណ សមាទានវត្តជាដើម និងក្នុងការជួសជុលបាត្រ ចីវរជា

ដើមរបស់ខ្លួន ក៏គប្បីអាច គប្បីឧស្សាហ៍ មិនខ្ជិលច្រអូស អាចក្នុងករណីយ-កិច្ចទាំងនោះ និងក្នុងកិច្ចដទៃក៏ដូចគ្នា ។ កាលជាអ្នកអាច ក៏គប្បីជាអ្នកត្រង់ដោយការប្រកបដោយបធានិយង្គប្រការទី ៣ កាលជាអ្នកត្រង់ ក៏គប្បីជាអ្នកត្រង់ដោយល្អ ដោយជាអ្នកត្រង់តែម្យ៉ាង ឬដោយជាអ្នកត្រង់ក្នុងកាលដែលនៅជាកំលោះ ដោយមិនដល់នូវសន្តោស តែមិនរួញរារឿយៗ ដរាបដល់អស់ជីវិត ។ ឈ្មោះថា **ឧជុ** ព្រោះធ្វើដោយការមិនអួត ឈ្មោះថា **សុហុជូ** ព្រោះមិនមានមាយា ឬថា ត្រង់ ព្រោះលះនូវការវៀចវេរដោយកាយ និងវាចា ឈ្មោះថា ត្រង់ល្អ ព្រោះលះនូវការវៀចផ្លូវចិត្ត ។ ឈ្មោះថា **ឧជុ** ព្រោះមិនអួតគុណដែលមាន ឈ្មោះថា **សុហុជូ** ព្រោះមិនអត់សង្កត់ចំពោះលាភដែលកើតព្រោះគុណដែលមិនពិត ។ គប្បីឈ្មោះថា ជាអ្នកត្រង់ និងត្រង់ដោយល្អ ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ដោយសិក្ខាទី ២ ទី ៣ ខាងដើម និងដោយបយោគសុទ្ធិ និងអាសយសុទ្ធិ ដោយប្រការដូច្នេះ ។

ភិក្ខុមិនមែនជាអ្នកត្រង់ និងត្រង់ល្អតែប៉ុណ្ណោះទេ ដែលពិត គប្បីជាអ្នកប្រដៅងាយទៀតផង ។ បុគ្គលណា ត្រូវលោកស្តីប្រដៅ ពោលថា លោកមិនគួរធ្វើរឿងនេះ ក៏ពោលថា លោកម្ចាស់ឃើញអ្វី លោកម្ចាស់ឮអ្វី លោកម្ចាស់ជាអ្វីនឹងខ្ញុំ ជាឧបជ្ឈាយ៍ អាចារ្យ សម្លាញ់ធ្លាប់ជួបឬ ឬបៀតបៀនបុគ្គលនោះ ដោយការមិននិយាយតប ឬព្រមទទួលហើយ តែមិនធ្វើយ៉ាងនោះ បុគ្គលនោះ ឈ្មោះថា នៅឆ្ងាយអំពីការសម្រេចគុណវិសេស ។ ឯបុគ្គលណា ត្រូវលោកទូន្មាន ក៏ពោលថា សាធុ លោកម្ចាស់ លោកម្ចាស់

ពោលល្អហើយ ។ ឈ្មោះថា ទោសរបស់ខ្លួន ជារបស់ឃើញបានលំបាក លោកម្ចាស់ឃើញខ្ញុំយ៉ាងនេះ សូមអធ្យាស្រ័យស្តីប្រដៅទៀតចុះ ខ្ញុំនឹងទទួលឱវាទអំពីសម្នាក់លោកម្ចាស់អស់កាលយូរ នឹងបដិបត្តិតាមលោកម្ចាស់ប្រៀនប្រដៅ បុគ្គលនោះឈ្មោះថា មិនទៅឆ្ងាយពីការសម្រេចគុណវិសេស ព្រោះដូច្នោះ បុគ្គលទទួលពាក្យរបស់អ្នកដទៃ ហើយធ្វើយ៉ាងនេះ គប្បីឈ្មោះថាជាអ្នកប្រដៅងាយ ។

ម្យ៉ាងទៀត បុគ្គលអ្នកប្រដៅងាយ យ៉ាងណា ក៏គប្បីជាអ្នកទន់ភ្លន់យ៉ាងនោះ ។ បទថា **មុទុ** សេចក្តីថា កិច្ចត្រូវពួកគ្រហស្ថប្រើក្នុងភាពជាទូតបញ្ជូនដំណឹងជាដើម ក៏ជាអ្នកមិនធ្វើការទន់ភ្លន់ក្នុងកិច្ចនោះ ជាអ្នករឹងប៉ឹងនោះឯង គប្បីជាអ្នកទន់ភ្លន់ក្នុងវត្តបដិបត្តិ និងព្រហ្មចរិយៈទាំងមូល អត់ធន់ចំពោះការមិនចាំបាច់ទទួលបម្រើក្នុងកិច្ចនោះ ដូចមាសដែលជាងតាក់តែងដោយល្អ ។ ម្យ៉ាងទៀត បទថា **មុទុ** បានដល់ ជាអ្នកមិនមានមុខក្រៀមក្រំ ជាអ្នកមានមុខរីក ចរចាពាក្យដែលឲ្យកើតសុខ ទទួលភ្ញៀវ ដូចបុគ្គលដែលចុះកាន់កំពង់ទឹក ដែលល្អដោយស្រួល មិនមែនជាអ្នកទន់ភ្លន់តែម្យ៉ាងទេ គប្បីជាបុគ្គលមិនមានអតិមានះ មើលងាយអ្នកដទៃផងដែរ ។ មិនគប្បីពោលមើលងាយអ្នកដទៃ ដោយវត្ថុនៃការមើលងាយ មានជាតិ និងគោត្រជាដើម គប្បីមានចិត្តស្មើ ដូចក្មេងចណ្ឌាល ដូចព្រះសារីបុត្រ ដូច្នោះ ។

## អធិប្បាយគាថាទី ២

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់ករណីយកិច្ច ដោយចំពោះយ៉ាង

ក្រៃលែងរបស់ភិក្ខុដែលនៅព្រៃ ដែលបំណងនឹងសម្រេចសន្តិបទ ឬបដិបត្តិដើម្បីសម្រេចសន្តិបទនោះយ៉ាងនេះហើយ មានព្រះពុទ្ធបំណងនឹងត្រាស់ក្រៃលែងឡើងជាងនោះទៀត ទើបត្រាស់គាថាទី ២ ថា **សន្តុស្សកោ ច** ជាដើម ក្នុងគាថាទី ២ នោះ ភិក្ខុ ឈ្មោះថា សន្តោស ព្រោះសន្តោសដោយសន្តោស ១២ យ៉ាង មានប្រភេទដែលពោលហើយ ក្នុងមង្គលសូត្រនេះថា **សន្តុដ្ឋី ច កតញ្ញុតា** នេះ ។ ម្យ៉ាងទៀត ភិក្ខុណារមែងត្រេកអរហេតុនោះ ភិក្ខុនោះ ឈ្មោះថា **តុស្សក** ប្រែថា អ្នកត្រេកអរ ភិក្ខុអ្នកត្រេកអរដោយរបស់ខ្លួនឯង ត្រេកអរដោយរបស់ដែលមាន ត្រេកអរដោយការស្មោះស្មើ ហេតុនោះ ទើបឈ្មោះថា **សន្តុស្សក** គឺអ្នកសន្តោស ។ ក្នុងលក្ខណៈ ៣ យ៉ាងនោះ បច្ច័យ ៤ ដែលលោកលើកឡើងសម្ដែងក្នុងពេលឧបសម្បទាយ៉ាងនេះថា **បិណ្ឌិយាលោបភោជនំនិស្សាយ** អាស្រ័យភោជន គឺដុំបាយដែលរកមកដោយកម្លាំងស្មងជាដើម ហើយខ្លួនក៏ទទួលហើយ ឈ្មោះថារបស់ខ្លួន ។ ភិក្ខុមិនសម្ដែងអាការខុសប្រក្រតី ក្នុងវេលាទទួល និងវេលាបរិភោគ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យរបស់ខ្លួននោះ ល្អក្ដី មិនល្អក្ដី ដែលគេប្រគេនដោយគោរព និងមិនគោរពក្ដី ហៅថា ជាអ្នកត្រេកអរដោយរបស់ខ្លួន ។

របស់ណាបានមកហើយ មានដល់ខ្លួន របស់នោះ ឈ្មោះថា មាន ភិក្ខុត្រេកអរដោយរបស់មាននោះឯង មិនប្រាថ្នារបស់ដទៃអំពីនោះ លះភាពជាបុគ្គលប្រាថ្នាច្រើន ហៅថា ត្រេកអរដោយរបស់ដែលមាន ។

ការលះត្រេកអរក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា ប្រព្រឹត្តស្មើ ភិក្ខុត្រេកអរក្នុងអារម្មណ៍ទាំងពួង ដោយអាការស្មើនោះ ឈ្មោះថា ត្រេកអរដោយអាការស្មើ ។

ឈ្មោះថា **សុភរ** ព្រោះគេចិញ្ចឹមដោយងាយ ។ លោកអធិប្បាយថា បុគ្គលដែលគេចិញ្ចឹមងាយ ។ ភិក្ខុណា កាលមនុស្សយកបាត្រដាក់ពេញដោយបាយ សាច់ជាដើមប្រគេន ហើយសម្តែងភាវៈ មុខស្មើ អាក់អន់ចិត្ត ពោលថា ពួកអ្នកឲ្យអ្វី មើលងាយបិណ្ឌបាតចំពោះមុខបុគ្គលនោះ ឲ្យដល់សាមណេរ និងគ្រហស្ថជាដើម ភិក្ខុនោះ ឈ្មោះថា **ទុព្ភរ** គឺបុគ្គលដែលគេចិញ្ចឹមលំបាក មនុស្សទាំងឡាយឃើញភិក្ខុនោះហើយ លះបង់អំពីចម្ងាយនោះឯង ដោយពោលថា ភិក្ខុចិញ្ចឹមក្រ អ្នកណាក៏មិនអាចចិញ្ចឹមបាន ឯភិក្ខុណាបានរបស់សៅហ្មងក្តី ប្រណីតក្តីណាមួយ តិច ឬច្រើន មានចិត្តត្រេកអរ មានមុខផូរផង់ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ភិក្ខុនោះ ឈ្មោះថា **សុភរ** គឺអ្នកចិញ្ចឹមងាយ ។ មនុស្សទាំងឡាយឃើញភិក្ខុនោះ ជាអ្នកស្រេកគត់ស្រេគំ ក៏ប្តេជ្ញាទទួលចិញ្ចឹមថា លោកម្ចាស់របស់យើងចិញ្ចឹមងាយ ភិក្ខុបែបនេះ លោកបំណងថា ជា **សុភរ** គឺអ្នកចិញ្ចឹមងាយក្នុងទីនេះ ។

កិច្ចរបស់ភិក្ខុនោះតិច ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **អប្បកិច្ចោ** គឺអ្នកមានកិច្ចតិច មិនមែនខ្វល់ខ្វាយដោយកិច្ចច្រើន ដូចជា ត្រេកអរក្នុងការងារ ត្រេកអរក្នុងការនិយាយ ត្រេកអរក្នុងការប្រឡូកប្រឡំជាដើម ។ម្យ៉ាងទៀត ជាអ្នកវៀរកិច្ច មានការកសាងលំនៅរបស់សង្ឃ និងបង្រៀនសាមណេរ ឬ

ញោមវត្តជាដើម ពេញវិហារ ។ លោកអធិប្បាយថា ការកោរសក់ កាត់ក្រចក និងដុតបាត្រ ជ្រលក់ចីវរជាដើមរបស់ខ្លួន ក្រៅអំពីកិច្ច គឺសមណធម៌ៗ

ការប្រព្រឹត្តរបស់ភិក្ខុនោះស្រាល ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **សល្លហុកវុត្តិ** គឺអ្នកមានការប្រព្រឹត្តស្រាល ។ ភិក្ខុមានបរិក្ខារច្រើនរូបខ្លះ វេលាធ្វើដំណើរ ក៏ឲ្យមហាជនកាន់បាត្រ ចីវរ កម្រាល ប្រេង ទឹកអំពៅជាដើមជាច្រើន ទូលលើក្បាល កណ្ដៀតជាដើម យ៉ាងណា ភិក្ខុណាមិនមានសភាពយ៉ាងនោះ រមែងជាអ្នកមានបរិក្ខារតិច រក្សាត្រឹមតែសមណបរិក្ខារ ៨ មានបាត្រ ចីវរជាដើមប៉ុណ្ណោះ កាលដើរផ្លូវ ក៏ធ្វើដំណើរទៅ ដូចបក្សីមានតែស្លាប ភិក្ខុបែបនោះ លោកបំណងថា ជាអ្នកមានការប្រព្រឹត្តស្រាល ក្នុងទីនេះ ។ ឥន្ទ្រិយទាំងឡាយរបស់ភិក្ខុនោះស្ងប់ ហេតុនោះ ទើបភិក្ខុនោះ ឈ្មោះថា មានឥន្ទ្រិយស្រគត់ស្រគំ លោកអធិប្បាយថា ជាអ្នកមានឥន្ទ្រិយមិនរាយមាយដោយអំណាចរាគៈជាដើម ក្នុងឥដ្ឋារម្មណ៍ជាដើម ។ បទថា **និបកោ** បានដល់ដែលជាវិញ្ញូជន ជាអ្នកដឹងច្បាស់ មានបញ្ញា អធិប្បាយថា ជាអ្នកប្រកបដោយបញ្ញា គ្រឿងតាមរក្សាសីល ដោយបញ្ញាកំណត់បច្ច័យ ៤ មានចីវរជាដើម និងដោយបញ្ញាកំណត់ដឹងនូវសប្បាយ ៧ មានអាវាសសប្បាយជាដើម ។

បុគ្គលមិនគ្នាំគ្នង ហេតុនោះ ទើបឈ្មោះថា **អប្បគព្ភ** គឺអ្នកមិនគ្នាំគ្នង អធិប្បាយថា វៀរចាកការគ្នាំគ្នងផ្លូវកាយ ៨ ឋានៈ ចាកការគ្នាំគ្នងដោយវាចា ៤ ឋានៈ និងចាកការគ្នាំគ្នងផ្លូវចិត្តច្រើនឋានៈ ។

ការធ្វើមិនសមគួរផ្លូវកាយក្នុងសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ទឹក ផ្លូវបិណ្ឌបាត និងការចូលកាន់ចន្លោះស្រុក ឈ្មោះថា ការផ្តាំផ្គងផ្លូវកាយ ៨ ស្ថាន គឺភិក្ខុរបខ្វះក្នុងសាសនានេះ អង្គុយត្របោមក្បាលជង្គង់ ឬយកជើងដាក់លើជើងក្នុងកណ្តាលសង្ឃ ។ ក្នុងកណ្តាលគណៈ ក្នុងទីប្រជុំបរិស័ទ ៤ ក៏ដូចគ្នា ក្នុងបុគ្គលដែលចាស់ជាងក៏ដូចគ្នា ។ ឯក្នុងរោងឆាន់ ភិក្ខុមិនឲ្យអាសនៈដល់បុគ្គលដែលចាស់ជាង ហាមអាសនៈដល់ភិក្ខុថ្មី ក្នុងរោងភ្លើងក៏ដូចគ្នា ។ ក្នុងភ្លើង ភិក្ខុមិនសូមឱកាសភិក្ខុចាស់ជាង ធ្វើការដុតភ្លើងជាដើម ។ ឯក្នុងកំពង់ទឹក លោកពោលពាក្យថា មិនត្រូវប្រកាន់ថា ភិក្ខុកំលោះ ឬភិក្ខុចាស់ គប្បីឆ្លងបានតាមលំដាប់របស់អ្នកមកដល់ ភិក្ខុមិនកាន់យកពាក្យនោះ មកឯក្រោយ ក៏ចុះទឹក បៀតបៀនភិក្ខុចាស់ និងភិក្ខុថ្មី ។ ឯក្នុងផ្លូវបិណ្ឌបាត ភិក្ខុទៅខាងមុខ យកដៃប៉ះដៃភិក្ខុចាស់ ដើម្បីយកអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ និងអាហារដ៏ប្រសើរ ក្នុងការចូលទៅកាន់ចន្លោះស្រុកមានជាដើមយ៉ាងនេះថា ភិក្ខុចូលទៅមុនភិក្ខុចាស់ ធ្វើការលេងដោយកាយជាមួយនឹងភិក្ខុកំលោះ ។

ការបន្ទឺវាចាមិនសមគួរក្នុងសង្ឃ គណៈ បុគ្គល និងចន្លោះស្រុក ឈ្មោះថា ផ្តាំផ្គងដោយវាចា ៤ ស្ថាន យ៉ាងនេះថា ភិក្ខុរបខ្វះក្នុងសាសនានេះមិនសូមឱកាសក្នុងកណ្តាលសង្ឃ ពោលធម៌ ។ ក្នុងគណៈ ក្នុងបុគ្គលដែលចាស់ជាងដូចពោលខាងដើមក៏ដូចគ្នា ។ ក្នុងទីនោះ ភិក្ខុត្រូវមនុស្សទាំងឡាយសួរបញ្ហា មិនសូមឱកាសភិក្ខុដែលចាស់ជាង ក៏ឆ្លើយបញ្ហា ។ ឯក្នុងចន្លោះស្រុក

*ភិក្ខុពោលជាដើមយ៉ាងនេះថា ក្នុងស្រុកឈ្មោះនោះ មានអ្វី បបរ ឬរបស់ទំពា ឬរបស់បរិភោគ លោកនឹងឲ្យអ្វីដល់ខ្ញុំ ថ្ងៃនេះ ខ្ញុំនឹងទំពា បរិភោគ ផឹកនូវអ្វី ។*

*មិនដល់នូវការល្មើសផ្លូវកាយវាចាក្នុងឋានៈនោះៗ តែក៏មានវិតក្ក ដែលមិនសមគួរប្រការផ្សេងៗ មានកាមវិតក្កជាដើមផ្លូវចិត្ត ឈ្មោះថា ការផ្តាំផ្គងផ្លូវចិត្តមានច្រើនឋានៈ ។*

*បទថា* **កុលេសុ អននុគិទ្ធោ** *សេចក្តីថា ភិក្ខុចូលទៅរកត្រកូលទាំងនោះ មិនគិតដោយការចង់បានបច្ច័យ ឬដោយការច្រឡូកច្រឡំ មិនសមគួរក្នុងត្រកូលទាំងនោះ លោកអធិប្បាយថា មិនសោយសោកជាមួយផង មិនត្រេកអររួមផង មិនសុខ ដោយកាលត្រកូលទាំងនោះជួបនូវសុខ មិនទុក្ខ កាលត្រកូលទាំងនោះជួបនូវទុក្ខ កាលករណីយកិច្ចទាំងឡាយកើតឡើង ក៏មិនចូលប្រកបដោយខ្លួនឯង ។ ពាក្យណាថា* **អស្ស** *ដែលត្រាស់ក្នុងពាក្យនេះថា* **សុវចោ អស្ស** *នៃគាថានេះ ពាក្យនោះ គប្បីប្រកបចូលជាមួយបទទាំងអស់យ៉ាងនេះថា* **សន្តុស្សកោ ច អស្ស សុភរោ ច អស្ស។**

## អធិប្បាយគាថាទី ៣

*ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ករណីដែលក្រៃលែងជាងនោះ ដោយចំពោះក្រៃលែង ដល់ភិក្ខុអ្នកនៅព្រៃ ដែលបំណងនឹងសម្រេចសន្តិបទហើយ ឬបំណងនឹងបដិបត្តិ ដើម្បីសម្រេចសន្តិបទនោះយ៉ាងនេះហើយ ឥឡូវនេះ មានព្រះពុទ្ធបំណងនឹងត្រាស់ប្រាប់ករណី ទើបត្រាស់កន្លះគាថាថា* **ន ច ខុទ្ទំ-**

**សមាចរេ កិញ្ចិ យេនវិញ្ញូ បរេ ឧបវទេយ្យុំ។**

កន្ទះគាថានោះ មានសេចក្ដីដូច្នេះ ភិក្ខុកាលធ្វើករណីនេះយ៉ាងនេះ ក៏មិនគប្បីប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត ដែលហៅថា **ខុទ្ទ** គឺលាមក កាលមិនប្រព្រឹត្ត មិនមែនមិនប្រព្រឹត្តតែកម្មគ្រោតគ្រាតតែម្យ៉ាងឡើយ សូម្បីកម្មបន្តិចបន្តួចណាមួយ ក៏មិនប្រព្រឹត្ត លោកអធិប្បាយថា មិនប្រព្រឹត្តកម្មអាក្រក់ទាំងចំនួនតិច និងទំហំតូច ។

បន្ទាប់អំពីនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងទោសដែលឃើញបានឯងក្នុងការប្រព្រឹត្តលាមកកម្មនោះថា **យេន វិញ្ញូ បរេ ឧបវទេយ្យុំ។** ក្នុងពាក្យនេះ ព្រោះបុគ្គលមិនមែនវិញ្ញូជនដទៃ មិនកាន់យកជាប្រមាណ ព្រោះវិញ្ញូជនទាំងនោះ នៅធ្វើកម្ម មិនមានទោស ឬមានទោស មានទោសតិច ឬទោសច្រើន ចំណែកវិញ្ញូជនទាំងឡាយប៉ុណ្ណោះ កាន់យកជាប្រមាណបាន ព្រោះថាវិញ្ញូជនទាំងនោះប្រាជ្ញាគ្រប់គ្រាន់ហើយ រមែងតិះដៀលបុគ្គលដែលគួរតិះដៀលសរសើរបុគ្គលដែលគួរសរសើរ ដូច្នោះ ទើបត្រាស់ថា **វិញ្ញូ បរេ** ។

ព្រះមានព្រះភាគ កាលត្រាស់ឧបចារនៃកម្មដ្ឋាន មានករណី និងអករណីដោយចំពោះយ៉ាងក្រៃលែង ដល់ភិក្ខុអ្នកនៅព្រៃ ដែលបំណងនឹងសម្រេចសន្តិបទ ហើយនៅ ឬបំណងនឹងបដិបត្តិ ដើម្បីសម្រេចសន្តិបទនោះ និងដល់ពួកភិក្ខុដែលបំណងនឹងទទួលកម្មដ្ឋានគ្រប់រូប ដោយលើកភិក្ខុដែលនៅព្រៃជាសំខាន់ ដោយ ២ គាថាកន្ទះយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្ដើមត្រាស់មេត្តាកថា ដោយន័យថា **សុខិនោ វា ខេមិនោ ហោន្តុ** ជាដើម ដើម្បីជាបរិត្ត

កម្ចាត់ភ័យអំពីទេវតានោះ និងដើម្បីជាកម្មដ្ឋាន ដោយឈានជាបាទនៃវិបស្សនា ដល់ភិក្ខុទាំងនោះ ។

បណ្ដាបទទាំងនោះ បទថា **សុខិនោ** បានដល់ ជាអ្នកដល់ព្រមដោយសុខ ។ បទថា **ខេមិនោ** ប្រែថា ជាអ្នកមានសេចក្ដីក្សេម ។ លោកអធិប្បាយថា ជាបុគ្គលមិនមានភ័យ មិនមានឧបទ្រវ ។ បទថា **សព្វេ** បានដល់ មិនសេសសល់ឡើយ ។ បទថា **សត្តា** បានដល់ សត្វមានជីវិត ។ បទថា **សុខិតត្តា** បានដល់ បុគ្គលមានចិត្តដល់នូវសុខ ។ ក្នុងពាក្យនេះ គប្បីជ្រាបថា ឈ្មោះថា បុគ្គលមានសេចក្ដីសុខ ដោយសុខផ្លូវកាយ ។ ឈ្មោះថា មានចិត្តដល់នូវសុខ ដោយសុខផ្លូវចិត្ត ។ ឈ្មោះថា មានការក្សេមដោយសុខទាំង ២ នោះ ឬដោយទៅប្រាសចាកភ័យ និងឧបទ្រវទាំងពួង ។ ហេតុអ្វី ទើបត្រាស់យ៉ាងនេះ ក៏ដើម្បីសម្ដែងអាការនៃមេត្តាភាវនា ។ កាលបើដូច្នេះ ទើបគួរចម្រើនមេត្តាថា សូមសត្វទាំងពួងមានសេចក្ដីសុខ ដូច្នេះ ឬថា ចូរមានសេចក្ដីក្សេម ដូច្នេះ ឬថា ចូរជាបុគ្គលមានខ្លួនដល់នូវសុខ ដូច្នេះ ។

## អធិប្បាយគាថាទី ៤

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងមេត្តាភាវនាដោយសង្ខេប តាំងអំពីឧបចារៈដល់អប្បនាជាទីបំផុតយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងមេត្តាភាវនានោះដោយពិស្ដារ ទើបត្រាស់ ២ គាថាថា **យេ កេចិ** ជាដើម ។ម្យ៉ាងទៀត ព្រោះហេតុដែលចិត្តត្រូវសន្សំនៅក្នុងអារម្មណ៍ច្រើនៗ រមែងមិនបញ្ឈប់នៅក្នុងអារម្មណ៍ ១ ដោយខាងដើមប៉ុណ្ណោះ តែនឹងស្ទុះជាប់តាម

ប្រភេទអារម្មណ៍ដោយលំដាប់ ដូច្នោះ ទើបត្រាស់ ២ គាថាថា **យេ កេចិ** ជាដើម ដើម្បីចិត្តដែលស្ទុះតាមទៅហើយ ឈប់នៅក្នុងអារម្មណ៍ដែលជាប្រភេទនៃទុកៈរបស់សត្វ និងតិកៈនៃសត្វ មានតសថាវរទុកៈជាដើម ។ ម្យ៉ាងទៀត ព្រោះហេតុដែលអារម្មណ៍ណានៃបុគ្គលណា ជាអារម្មណ៍ដែលប្រាកដច្បាស់ហើយ ចិត្តនៃបុគ្គលនោះ រមែងតាំងនៅជាសុខក្នុងអារម្មណ៍នោះ ដូច្នោះ អារម្មណ៍របស់ភិក្ខុរូបណា ក្នុងបណ្ដាភិក្ខុទាំងនោះប្រាកដច្បាស់ហើយ ព្រះមានព្រះភាគ មានព្រះពុទ្ធបំណងនឹងឲ្យចិត្តរបស់ភិក្ខុរូបនោះ តាំងនៅក្នុងអារម្មណ៍នោះ ទើបត្រាស់ ២ គាថាថា **យេ កេចិ** ជាដើម ដែលសម្ដែងការផ្សេងគ្នានៃអារម្មណ៍ជាទុកៈ និងតិកៈ មានតសថាវរទុកៈជាដើម ។

សេចក្ដីពិត ក្នុង ២ គាថានោះ ព្រះមានព្រះភាគទ្រង់សម្ដែងទុកៈ គឺធម៌ពួក ២ នៃសត្វ ៤ ទុកៈ គឺតសថាវរទុកៈ គឺសត្វដែលតក់ស្លុត និងមាំទាំ ១ ទិដ្ឋាទិដ្ឋទុកៈ សត្វដែលឃើញហើយ និងសត្វដែលមិនទាន់ឃើញ ១ ទូរសន្តិកទុកៈ ពួកសត្វដែលនៅឆ្ងាយ និងនៅជិត ១ ភូតសម្ភវេសីទុកៈ សត្វដែលកើតហើយ និងស្វែងរកទីកើត ១ ។ ហើយទ្រង់សម្ដែងតិកៈ ៣ តិកៈ គឺទីឃរស្សមជ្ឈិមតិកៈ សត្វដែលមានអត្តភាពវែង ខ្លី និងកណ្ដាល ១ មហន្តាណុកមជ្ឈិមតិកៈ គឺសត្វដែលមានអត្តភាពធំ តូច និងកណ្ដាល ១ ។ ថូលាណុកមជ្ឈិមតិកៈ គឺសត្វដែលមានអត្តភាពធាត់ ស្គម និងកណ្ដាល ដោយមជ្ឈិមបទជាទីកើតប្រយោជន៍ក្នុង ៣ តិកៈ និងអនុកថូលបទ ជាទីកើតប្រយោជន៍ក្នុង ២ តិកៈ ដោយ ៦ បទ មានទីឃបទជាដើម ។ បណ្ដា

បទទាំងនោះ បទថា **យេ កេចិ** ជាពាក្យសម្តែងថា មិនមានចំណែកសេស សល់ ។ ពួកសត្វដែលកើតហើយ គឺបាណ ឈ្មោះថា **ចាណភូត** ម្យ៉ាង ទៀត សត្វទាំងឡាយ រមែងដកដង្ហើម ហេតុនោះ ទើបឈ្មោះថា **ចាណា** ។ ទ្រង់កាន់យកបញ្ចវោការសត្វ ដែលទាក់ទងដោយអស្សាសបស្សាសៈ ដោយ បទនេះ ។ សត្វទាំងឡាយរមែងកើត ហេតុនោះ ទើបឈ្មោះថា **ភូត** ។ ទ្រង់កាន់យកឯកវោការសត្វ និងចតុវោការសត្វ ដោយបទនេះ ។ បទថា **អត្ថិ** ប្រែថា មាន គឺមានព្រម ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងសត្វទាំងពួង ដែលទ្រង់សង្គ្រោះ ដោយទុកៈ និងតិកៈរួមគ្នា ដោយពាក្យថា **យេ កេចិ ចាណភូតត្ថិ** នេះ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសត្វទាំងនោះ សម្តែងដោយទុកៈនេះ ថា **តសា វា ថាវរា វា អនវសេសា** ។

ក្នុងទុកៈនេះ សត្វទាំងឡាយ រមែងតក់ស្លុត ហេតុនោះ ទើបឈ្មោះថា **តសា** ពាក្យនេះ ជាឈ្មោះនៃសត្វទាំងឡាយ ដែលមានតណ្ហា និងមានភ័យ ។ សត្វទាំងឡាយរមែងមាំទាំ ហេតុនោះ ទើបឈ្មោះថា **ថាវរា** ពាក្យនេះ ជា ឈ្មោះរបស់ព្រះអរហន្តទាំងឡាយ ដែលលះតណ្ហា និងភ័យបានហើយ ។ ចំណែកដែលសល់នៃសត្វទាំងនោះមិនមាន ហេតុនោះ ទើបឈ្មោះថា **អន-វសេសា** លោកអធិប្បាយថា គ្រប់ខ្ទួនសត្វ ។ ពាក្យណាត្រាស់ខាងចុងនៃ គាថាទី ២ ពាក្យនោះ គប្បីភ្ជាប់គ្រប់ទុកៈ និងតិកៈ ។ បទថា **យេ កេចិ ចាណភូតត្ថិ** សេចក្តីថា សត្វទាំងឡាយដែលតក់ស្លុតក្តី មាំទាំក្តី មិនមាន

សល់ សត្វទាំងអស់នោះ ចូរជាបុគ្គលមានខ្លួនដល់នូវសេចក្តីសុខ ពួកសត្វដែលកើតហើយក្តី ស្វែងរកទីកើតក្តី ត្រឹមណា សត្វទាំងអស់នេះ ត្រឹមនោះ ចូរជាអ្នកមានខ្លួនដល់នូវសុខចុះ ដោយប្រការដូច្នេះ ។

ឥឡូវនេះ បណ្តាបទទាំង ៦ មាន **ទីឃា វា** ជាដើម ដែលសម្តែងតិកៈ ៣ ពួក មានទីឃរស្សមជ្ឈិមតិកៈជាដើម ។ បទថា **ទីឃា** បានដល់ សត្វដែលមានអត្តភាពវែង មាននាគ ត្រី ទន្សងជាដើម ពិតហើយ អត្តភាពរបស់នាគទាំងឡាយក្នុងមហាសមុទ្រ មានប្រវែងច្រើនរយព្យាម ។ អត្តភាពរបស់ត្រី និងទន្សងជាដើម មានច្រើនយោជន៍ ។ បទថា **មហន្តា** សត្វមានអត្តភាពធំក្នុងទឹក មានត្រី និងអណ្តើក លើគោក មានស្តេចដំរីជាដើម ក្នុងចំនួនអមនុស្ស មានទានវៈ ( យក្សព្រៃ ) ជាដើម និងត្រាស់ថា រាហូ ជាកំពូលនៃសត្វដែលមានអត្តភាពជាធំទាំងឡាយ ។ ពិតហើយ អត្តភាពរបស់រាហូនោះ កម្ពស់ ៤៨០០ យោជន៍ ដៃប្រវែង ១២០០ យោជន៍ ចន្លោះចិញ្ចើម ៥០ យោជន៍ ចន្លោះថ្នាំងដៃក៏ដូចគ្នា បាតដៃមានទំហំ ២០០ យោជន៍ ។ បទថា **មជ្ឈិមា** បានដល់ អត្តភាពរបស់សេះ គោ ក្របី ជ្រូក ។ បទថា **រស្សកា** បានដល់ សត្វទាំងឡាយ មានខ្នាតខ្លី ត្រង់កណ្តាលវែង ត្រង់កណ្តាលធាត់ មានមនុស្សតឿជាដើម ក្នុងជាតិនោះៗ ។ បទថា **អណុកា** បានដល់ សត្វទាំងឡាយដែលមានអត្តភាពល្អិត ឬតូចជាដើម ដែលកើតក្នុងទឹកជាដើម មិនជាអារម្មណ៍នៃមំសចក្ខុ ជាវិស័យរបស់ទិព្វចក្ខុ ។ ម្យ៉ាងទៀត សត្វទាំងឡាយណា ទាប ត្រង់កណ្តាលធំ ត្រង់កណ្តាលធាត់ សត្វទាំងនោះ គប្បី

ជ្រាបថា តូច ។ បទថា **ថូលា** បានដល់ សត្វទាំងឡាយដែលមានអត្តភាពមូល មានត្រី អណ្តើក គ្រុំ ខ្យងជាដើម ។

# អធិប្បាយគាថាទី ៥

ព្រះមានព្រះភាគ ទ្រង់សម្តែងសត្វទាំងឡាយមិនសេសសល់ ដោយតិកៈ ៣ តិកៈ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសម្តែងដោយទុកៈ ៣ ទុកៈ ថា **ទិដ្ឋា វា យេ ច អទិដ្ឋា** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋា** បានដល់ សត្វពួកណាធ្លាប់ឃើញដោយមកប្រាកដដល់ភ្នែករបស់ខ្លួន ។ បទថា **អទិដ្ឋា** បានដល់ សត្វទាំង-ឡាយណាតាំងនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្រវាលដទៃជាដើម ។ តែព្រះមានព្រះភាគទ្រង់សម្តែងសត្វដែលនៅឆ្ងាយ និងមិនឆ្ងាយអត្តភាពរបស់ខ្លួនដោយទុកៈនេះថា **យេ ច ទូរេ វសន្តិ អវិទូរេ** ។ សត្វទាំងនោះ គប្បីជ្រាបថាជាសត្វមិនមានជើង និងជើង ២ ។ ពួកសត្វដែលនៅក្នុងកាយរបស់ខ្លួន ហៅថា **អវិទូរេ** គឺនៅមិនឆ្ងាយ សត្វដែលនៅក្រៅកាយ ហៅថា **ទូរេ** គឺនៅឆ្ងាយ ។ ម្យ៉ាងទៀត ពួកសត្វដែលនៅខាងក្នុងឧបចារៈ ហៅថា នៅមិនឆ្ងាយ ។ ដែលនៅក្រៅឧបចារៈ ហៅថា នៅឆ្ងាយ ។ ដែលនៅក្នុងព្រះវិហារតាមជនបទ ទ្វីប ចក្រវាល ហៅថា នៅមិនឆ្ងាយ ដែលនៅក្នុងចក្រវាលដទៃ ហៅថា នៅឆ្ងាយ ។ បទថា **ភូតា** បានដល់ កើតហើយ កើតឡើងហើយ ។ ព្រះខីណាស្រពពួកណា កើតហើយនោះឯង មិនរាប់ថា កើតទៀត ពាក្យនោះជាឈ្មោះនៃព្រះខីណាស្រពទាំងនោះ ។ សត្វទាំងឡាយណា ស្វែងរកទីកើត

ហេតុនោះ សត្វទាំងនោះ ឈ្មោះថា **សម្ភវេសី** ។ ពាក្យនេះជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ដែលកំពុងស្វែងរកទីកើតក្នុងអនាគត ព្រោះភវសំយោជនៈនៅមាន ។ ម្យ៉ាងទៀត បណ្ដាកំណើតទាំង ៤ សត្វដែលជាអណ្ឌជៈ និងជលាពុជៈ មិនទាន់ទម្លាយសម្បកស៊ុត និងស្បូនចេញមកដរាបណា ដរាបនោះក៏ឈ្មោះថា **សម្ភវេសី** ។ កាលទម្លាយសម្បកស៊ុត និងស្បូនចេញមកខាងក្រៅ ឈ្មោះថា **ភូតា** ។ ពួកសត្វដែលជាសំសេទជៈ និងឱបបាតិកៈ ឈ្មោះថា **សម្ភវេសី** ក្នុងខណៈបឋមចិត្ត តាំងអំពីខណៈទុតិយចិត្តទៅ ឈ្មោះថា **ភូតា** ។ ម្យ៉ាងទៀត សត្វទាំឡាយកើតក្នុងឥរិយាបថណា មិនទាន់ប្ដូរឥរិយាបថដទៃអំពីឥរិយាបថនោះដរាបណា ដរាបនោះ ឈ្មោះថា **សម្ភវេសី** ក្រៅអំពីនោះទៅ ឈ្មោះថា **ភូតា** ។

# អធិប្បាយគាថាទី ៦

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងមេត្តាភាវនាក្នុងសត្វទាំងឡាយដោយប្រាថ្នាតែឲ្យចូលដល់ប្រយោជន៍សុខរបស់ពួកសត្វទាំងនោះ ដោយប្រការផ្សេងៗ ដោយ២ គាថាកន្លះថា **សុខិនោ វា** ជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងមេត្តាភាវនានោះ សូម្បីដោយប្រាថ្នាឲ្យចេញទៅអំពីវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខ ទើបត្រាស់ថា **ន បរោ បរំ និកុព្ពេថ** ។ នេះជាបាឋៈចាស់ តែបច្ចុប្បន្នសូធ្យថា **បរំ ហិ** ដូច្នេះក៏មាន បាឋៈនេះមិនប្រពៃ ។

បណ្ដាបទទាំងនោះ បទថា **បរោ** បានដល់ ជនដទៃ ។ បទថា **ន កុព្ពេថ** បានដល់ មិនបោកបញ្ឆោត ។ បទថា **នាតិមញ្ញេថ** បានដល់ មិនសំខាន់ពេក

គឺមិនមើលងាយ ។ បទថា **កត្ថចិ** បានដល់ ក្នុងឱកាសណាមួយ គឺក្នុងស្រុក ឬក្នុងគាមក្ខេត្ត កណ្តាលពួកញាតិ ឬកណ្តាលពួកបុគ្គល ដូច្នេះជាដើម ។ បទថា **នំ** ប្រែថា នុ៎ះ ។ បទថា **កិញ្ចិ** បានដល់ បុគ្គលណាម្នាក់ គឺក្សត្រ ឬព្រាហ្មណ៍ គ្រហស្ថ ឬបព្វជិតដែលដល់នូវសេចក្តីសុខ ឬដល់នូវសេចក្តីទុក្ខ ដូច្នេះជាដើម ។ បទថា **ព្យារោសនា បដិឃសញ្ញា** បានដល់ ព្រោះការខឹងក្រោធ ដោយកាយវិការ និងវចីវិការ និងព្រោះថ្នាំងថ្នាក់ដោយមនោវិការ ។ ព្រោះកាលគួរនឹងត្រាស់ថា **ព្យារោសនាយ បដិឃសញ្ញាយ** តែក៏ត្រាស់ថា **ព្យារោសនា បដិឃសញ្ញា** ដូចកាលគួរត្រាស់ថា **សម្មទញ្ញាយ វិមុត្តា** តែក៏ត្រាស់ថា **សម្មទញ្ញា វិមុត្តា** និងដូចកាលគួរត្រាស់ថា **អនុបុព្វសិក្ខាយ អនុបុព្វកិរិយាយ អនុបុព្វបដិបទាយ** តែក៏ត្រាស់ថា **អនុបុព្វសិក្ខា អនុ-បុព្វកិរិយា អនុបុព្វបដិបទា អញ្ញារាធនា** ដូច្នោះ ។ បទថា **នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** សេចក្តីថា មិនគប្បីប្រាថ្នាទុក្ខដល់គ្នានិងគ្នា ។ លោកអធិប្បាយដូចម្តេច ។ លោកអធិប្បាយថា មិនមែនចម្រើនមេត្តាដោយមនសិការជាដើមថា ចូរសត្វទាំងឡាយមានសេចក្តីសុខ មានសេចក្តីក្សេមចុះ ដូច្នេះតែម្យ៉ាងទេ ដែលពិត គប្បីមនសិការយ៉ាងនេះថា ឱហ្ន៎ ! បុគ្គលដទៃ ទោះបុគ្គលណាក៏ដោយ មិនគប្បីគំរាមបុគ្គលដទៃណាម្នាក់ ដោយកិរិយាបន្ទំ មានការបោកបញ្ឆោតជាដើម មិនគប្បីមើលងាយបុគ្គលដទៃណាម្នាក់ ទោះជាទីកន្លែងណា ដោយមានះវត្ថុ ៩ យ៉ាង មានជាតិជាដើម មិនគប្បីប្រាថ្នានូវទុក្ខដល់គ្នានិងគ្នា ព្រោះសេចក្តីក្រោធ ឬព្រោះការចង្អៀតចង្អល់ ដូច្នេះទៀតផង ។

# អធិប្បាយគាថាទី ៧

*ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនា ដោយអត្ថ ដោយប្រាថ្នាឲ្យបុគ្គលនោះចេញទៅអំពីវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងមេត្តាភាវនានោះដោយឧបមា ទើបត្រាស់ថា* **មាតា យថា និយំ បុត្តំ** *ជាដើម ។*

*គាថានោះ មានសេចក្តីថា មាតាគប្បីអនុគ្រោះបុត្រក្នុងខ្លួន គឺបុត្រដែលកើតក្នុងខ្លួន កើតអំពីទ្រូង គប្បីថ្នាក់ថ្នមបុត្រនោះ ដែលមានតែម្នាក់ប៉ុណ្ណោះ ស្មើដោយជីវិត គឺហ៊ានលះបង់ជីវិតរបស់ខ្លួនដើម្បីរក្សាបុត្រនោះ ដើម្បីហាមទុក្ខដែលមកដល់បុត្រនោះ យ៉ាងណា ភិក្ខុគប្បីធ្វើមនសៈ ដែលប្រកបដោយមេត្តានេះឲ្យចម្រើន គឺឲ្យកើតរឿយៗ ឲ្យរីកទៅ និងញ៉ាំងមេត្តាភាវនានោះឲ្យចម្រើន មិនមានប្រមាណ ដោយកាន់យកសត្វមិនមានប្រមាណជាអារម្មណ៍ ឬដោយផ្សាយទៅមិនសេសសល់ សូម្បីតែក្នុងសត្វមួយ ។*

# អធិប្បាយគាថាទី ៨

*ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនា ដោយអាការទាំងពួងយ៉ាងនេះ ឥឡូវនេះ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនានោះ ទើបត្រាស់ថា* **មេត្តញ្ច សព្វលោកស្មឹ** *ជាដើម ។*

*ក្នុងគាថានោះ ឈ្មោះថា* **មិត្ត** *ព្រោះស្រឡាញ់ និងរក្សា អធិប្បាយថា ជាប់ជំពាក់ ព្រោះមានអធ្យាស្រ័យប្រាថ្នាប្រយោជន៍ និងរក្សាឲ្យផុតចាកការមកដល់នៃវត្ថុដែលមិនជាប្រយោជន៍ ។ ភាពជាមិត្ត ឈ្មោះថា* **មេត្តា។** *បទថា* **សព្វលោកស្មឹ** *បានដល់ ក្នុងសត្វលោក មិនមានសេសសល់ ។ មាន*

ក្នុងចិត្ត ហេតុនោះ ទើបឈ្មោះថា **មានស។** ពាក្យថា **មានសំ** នោះ លោកពោលយ៉ាងនេះ ក៏ព្រោះប្រកបជាមួយចិត្ត ។ បទថា **ភាវយេ** ប្រែថា ឲ្យចម្រើន ។ ប្រមាណរបស់មានសៈនោះមិនមាន ហេតុនោះ ទើបឈ្មោះថា **អបរិមាណា។** លោកពោលយ៉ាងនេះ ក៏ព្រោះមេត្តាមានសត្វមិនមានប្រមាណជាអារម្មណ៍ ។ បទថា **ឧទ្ធំ** ប្រែថា ខាងលើ ទ្រង់កាន់យករូបភពដោយបទនោះ ។ បទថា **អធោ** ប្រែថា ខាងក្រោម ។ ទ្រង់កាន់យកកាមភពដោយបទនោះ ។ បទថា **តិរិយំ** បានដល់ ខាងទទឹង ។ ទ្រង់កាន់យករូបភពដោយបទនោះ ។ បទថា **អសម្ពាធំ** បានដល់ វៀរចាកការចង្អៀតចង្អល់ ។ លោកអធិប្បាយថា មានព្រំដែនបែកហើយ គឺមានសិរីភាព ។ សត្រូវ លោកហៅថា ព្រំដែន អធិប្បាយថា ទៅក្នុងទីដែលមិនមានព្រំដែននោះ ។ បទថា **អវេរំ** បានដល់ វៀរចាកពៀរ អធិប្បាយថា វៀរចាកការប្រាកដនៃចេតនាដែលញ៉ាំងពៀរក្នុងចន្លោះៗ ។ បទថា **អសបត្តំ** បានដល់ ប្រាសចាកសត្រូវ ។ ពិតហើយ បុគ្គលនៅដោយមេត្តា រមែងជាទីស្រឡាញ់របស់មនុស្ស ជាទីស្រឡាញ់របស់ពួកអមនុស្ស ។ សត្រូវណាម្នាក់ របស់បុគ្គលនោះ រមែងមិនមាន ។ ដោយហេតុនោះ មានសៈរបស់បុគ្គលនោះ ទើបលោកហៅថា **អសបត្ត** ព្រោះប្រាសចាកសត្រូវ ។ ពាក្យដែលថា សត្រូវៗ ជាពាក្យដោយបរិយាយ ពណ៌នាសេចក្ដីតាមបទនេះមានប៉ុណ្ណេះ ចំណែកការសម្ដែងភាពដែលបំណងក្នុងទីនេះ មានដូច្នេះ ។

គប្បីចម្រើនពង្រីកមេត្តាដែលត្រាស់ថា **ឯវម្បិ សព្វភូតេសុ មានសំ**

**ភាវយេ អបរិមាណំ** ដូច្នេះ ផ្សាយមេត្តាដែលមាននៅក្នុងចិត្ត មិនមានប្រមាណ ឲ្យសម្រេចដល់នូវការចម្រើនដុះដាល បរិបូណ៌ក្នុងលោកទាំងពួង ។ ធ្វើដូចម្តេច គឺផ្សាយមេត្តាចិត្តនោះទៅ មិនសេសសល់ ទាំងខាងលើ ខាងក្រោម ខាងទទឹង ខាងលើ តាំងអំពីភវគ្គព្រហ្មចុះមក ខាងក្រោម តាំងអំពីអវិចីនរកឡើងមក ខាងទទឹងតាំងអំពីទិសដ៏សេស ឬខាងលើ ក៏បានដល់ អរូបធាតុ ខាងក្រោមក៏បានដល់ កាមធាតុ ខាងទទឹងក៏បានដល់ រូបធាតុ កាលចម្រើនមេត្តាយ៉ាងនេះ ធ្វើមិនឲ្យមានការចង្អៀតចង្អល់ ពៀរ និងសត្រូវ គប្បីចម្រើនមេត្តានោះ ដោយប្រការដែលមិនមានការចង្អៀតចង្អល់ មិនមានពៀរ និងមិនមានសត្រូវ ។ ឬថា មេត្តានោះដល់នូវសម្បទាភាវនា ជាគុណឈ្មោះថា មិនចង្អៀតចង្អល់ ព្រោះជាឱកាសលោកទាំងពួង គឺភូមិ ៣១ ជាគុណឈ្មោះថា មិនមានពៀរ ព្រោះកម្ចាត់អាឃាតរបស់ខ្លួន ក្នុងសត្វដទៃចោល ជាគុណឈ្មោះថា មិនមានសត្រូវ ព្រោះកម្ចាត់អាឃាតរបស់សត្វដទៃក្នុងខ្លួនចេញ ក៏គប្បីចម្រើន ពង្រីកមេត្តា ដែលមានក្នុងចិត្តនោះ ដែលមិនចង្អៀតចង្អល់ មិនមានពៀរ មិនមានសត្រូវ មិនមានប្រមាណក្នុងលោកទាំងពួង ដោយកំណត់ទិសទាំង ៣ គឺខាងលើ ខាងក្រោម នឹងខាងទទឹង ។

# អធិប្បាយគាថាទី ៩

ព្រះមានព្រះភាគ កាលទ្រង់សម្តែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ កាលទ្រង់សម្តែងការមិនមានឥរិយាបថពិតប្រាកដ នៃបុគ្គលប្រកបរឿយៗ នូវការចម្រើនមេត្តានោះ ទើបត្រាស់ថា **តិដ្ឋំ ចរំ ។បេ។ អធិដ្ឋេយ្យ** ដូច្នេះ ។

*គាថានោះមានសេចក្ដីថា បុគ្គលចម្រើនមេត្តា កាលចម្រើនមេត្តាមានក្នុងចិត្តយ៉ាងនេះ មិនចាំបាច់កំណត់ឥរិយាបថ ដូចក្នុងបាលីថា អង្គុយពត់ភ្នែនតាំងកាយឲ្យត្រង់ កាលធ្វើការបន្ទោបង់នូវការនឿយហត់ ដោយឥរិយាបថណាមួយតាមសប្បាយ ទោះឈរ ឬដើរ អង្គុយ ឬដេក គង់ជាបុគ្គលប្រាសចាកការងងុយងោកងក់ដរាបណា ក៏គប្បីតាំងសតិក្នុងមេត្តាឈាននោះដរាបនោះ ។*

*មួយវិញទៀត ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងភាពជាអ្នកជំនាញ ទើបត្រាស់ថា* **តិដ្ឋំ ចរំ** *ជាដើម ។ ពិតហើយ បុគ្គលជំនាញហើយ គង់បំណងនឹងតាំងសតិក្នុងមេត្តាឈាន ដោយឥរិយាបថដរាបណា ទោះឈរក្ដី ដើរក្ដី អង្គុយក្ដីដេកក្ដី ក៏រមែងបាន ។ មួយវិញទៀត បុគ្គលជំនាញ ទោះឈរក្ដី ដើរក្ដី អង្គុយក្ដីដេកក្ដី ព្រោះហេតុនោះ ការឈរជាដើម រមែងមិនធ្វើអន្តរាយដល់បុគ្គលនោះ ។ មួយវិញទៀត បុគ្គលជំនាញ បំណងនឹងតាំងសតិមាំក្នុងមេត្តាឈាននេះដរាបណា ក៏គង់ជាបុគ្គលប្រាសចាកការងោកងុយ ទើបតាំងនូវសតិដរាបនោះ ។ ការយឺតយូរក្នុងមេត្តាឈាននោះនៃបុគ្គលនោះ រមែងមិនមាន ដោយហេតុនោះ ទើបត្រាស់ថា ទោះឈរក្ដី ដើរក្ដី អង្គុយក្ដី ដេកក្ដី គង់ជាអ្នកប្រាសចាកការងោកងុយដរាបណា ក៏គប្បីតាំងសតិដរាបនោះ ។*

*គាថានោះ មានអធិប្បាយដូច្នេះថា បុគ្គលជំនាញគប្បីចម្រើនមេត្តា ដែលត្រាស់ថា* **មេត្តញ្ច សព្វលោកស្មិំ មានសម្ភាវយេ** *ដោយប្រការដែលបុគ្គលជំនាញ មិនចាំបាច់ជ្រើសរើសដោយឥរិយាបថ បណ្ដាឥរិយាបថ មាន*

ឈរជាដើម ឬដល់ឥរិយាបថ មានឈរជាដើម គង់បំណងនឹងតាំងសតិក្នុងមេត្តាឈាននោះដរាបណា ជាអ្នកប្រាសចាកការងងុយងោកងក់ហើយ ក៏គប្បីតាំងសតិនោះដរាបនោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពជាអ្នកជំនាញក្នុងមេត្តាភាវនាយ៉ាងនេះ ទ្រង់ប្រកបមេត្តាក្នុងមេត្តាវិហារនោះថា **ឯតំ សតឹ អធិដ្ឋេយ្យ** ដូច្នេះ ។ កាលទ្រង់សរសើរការនៅយ៉ាងនោះ ទើបត្រាស់ថា **ព្រហ្មមេតំ វិហារំ ឥធមាហុ** ។

គាថានោះមានអត្ថថា ការនៅដោយមេត្តានេះ ទ្រង់សរសើរតាំងអំពីដើម តាំងអំពីព្រះពុទ្ធត្រាស់ថា **សុខិនោ វា ខេមិនោ វា ហោន្តុ** ចូរជាអ្នកមានសេចក្តីសុខ ឬមានការក្សេម រហូតដល់ព្រះពុទ្ធត្រាស់ថា **ឯតំ សតឹ អធិដ្ឋេយ្យ** ប្រែថា គប្បីតាំងនូវសតិនោះដរាបនោះ ។ អ្នកប្រាជ្ញទាំងឡាយពោលការនៅនោះថា **ព្រហ្មវិហារ** គឺការនៅដូចព្រហ្ម ពោលការនៅនោះថា **សេដ្ឋវិហារ** គឺការនៅដ៏ប្រសើរ ក្នុងព្រះសាសនា គឺក្នុងធម្មវិន័យរបស់ព្រះ-អរិយៈនេះ ព្រោះមិនមានការនៅដូចទិព្វ នៅដូចព្រហ្ម នៅដូចព្រះអរិយៈ និងនៅដោយឥរិយាបថវិហារ និងការនៅដោយមេត្តានោះ ធ្វើប្រយោជន៍ដល់ខ្លួនផង ដល់អ្នកដទៃផង ។ ព្រោះការស្ងប់ជាប់តគ្នាមិនមានចន្លោះ ដូច្នោះ អ្នកចម្រើនមេត្តា ឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី មិនងងុយងោកងក់ដរាបណា គប្បីតាំងនូវសតិនោះដរាបនោះ ។

# អធិប្បាយគាថាទី ១០

ព្រះមានព្រះភាគ កាលទ្រង់សម្តែងមេត្តាភាវនាប្រការផ្សេងៗ ដល់ភិក្ខុទាំងនោះយ៉ាងនេះហើយ ឥឡូវនេះ ព្រោះមេត្តាជិតចំពោះអត្តទិដ្ឋិ គឺការឃើញថាជាខ្លួន ព្រោះមានសត្វជាអារម្មណ៍ ដូច្នោះ កាលទ្រង់សម្តែងការសម្រេចអរិយភូមិ ធ្វើមេត្តាឈាននោះឯងឲ្យជាបាទដល់ភិក្ខុទាំងនោះ ដោយលើកការហាម ការប្រកាន់ទិដ្ឋិឡើងជាប្រធាន ទើបទ្រង់បញ្ចប់ទេសនាដោយគាថានេះថា **ទិដ្ឋិញ្ច អនុបគម្ម** ជាដើម ។

គាថានោះ មានសេចក្តីថា ការនៅដោយមេត្តាឈាននោះ ទ្រង់សរសើរថា **ព្រហ្មមេតំ វិហារំ ឥធមាហុ** អ្នកប្រាជ្ញទាំងឡាយពោលការនៅនោះថាជាព្រហ្មវិហារក្នុងធម្មវិន័យនេះ បុគ្គលចម្រើនមេត្តា ចេញអំពីការនៅដោយមេត្តាឈាននោះហើយ កំណត់នាមធម៌ មានវិតក្ក វិចារៈជាដើមក្នុងទីនេះ និងរូបធម៌តាមគន្លងការកំណត់នាមធម៌នោះជាដើម ហើយកំណត់អរូបធម៌ និងដោយការកំណត់នាមរូបនេះ ក៏មិនប្រកាន់ដោយទិដ្ឋិយ៉ាងនេះថា នេះគំនរសង្ខារដែលបរិសុទ្ធ បុគ្គលរមែងប្រកាន់មិនបានថា ជាសត្វក្នុងសង្ខារដូច្នេះ ជាអ្នកមានសីល ដោយលោកុត្តរសីលតាមលំដាប់ ដល់ព្រមដោយទស្សនៈដែលតែងហៅថា សម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គ ដែលប្រកបដោយលោកុត្តរ-សីល បន្ទាប់អំពីនោះ ក៏នាំចេញ កម្ចាត់ រម្ងាប់នូវការរវើងក្នុងកាមទាំង-ឡាយ គឺកិលេសកាមដែលមិនទាន់លះបាន ដោយការធ្វើឲ្យស្រាលស្តើងដោយសកទាគាមិមគ្គ និងអនាគាមិមគ្គ និងដោយការលះមិនឲ្យសេសសល់ក៏មិនចូលដល់នូវការដេកក្នុងគភ៌ម្តាយទៀត គឺមិនចាំបាច់ដេកក្នុងគភ៌ទៀត

យ៉ាងពិតប្រាកដ បានដល់ កើតក្នុងពួកទេវតាជាន់សុទ្ធាវាសទាំងឡាយ សម្រេចអរហត្ត ហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់បញ្ចប់ទេសនាយ៉ាងនេះហើយ ត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកចូរទៅចុះ ពួកអ្នកចូរនៅក្នុងដងព្រៃនោះឯង ចូរវាយជួងក្នុងថ្ងៃធម្មស្សវនៈ ៨ ថ្ងៃ ក្នុង ១ ខែ ហើយចូរសូធ្យនូវព្រះសូត្រនេះ ចូរធ្វើធម្មកថា ធម្មសាកច្ឆា អនុមោទនា ចូរសេព ចម្រើនធ្វើឲ្យច្រើននូវកម្មដ្ឋាននេះឯង ពួកអមនុស្សទាំងនោះ នឹងមិនបង្ហាញអារម្មណ៍ដែលគួរខ្លាចនោះ នឹងជាអ្នកបំណងល្អ ប្រាថ្នាប្រយោជន៍ដល់ពួកអ្នកពិត ភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ហើយ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំហើយ ធ្វើប្រទក្សិណទៅក្នុងដងព្រៃនោះ ហើយធ្វើតាមព្រះតម្រាស់គ្រប់ប្រការ ។ ទេវតាទាំងឡាយកើតបីតិសោមនស្សថា លោកម្ចាស់ទាំងឡាយបំណងល្អប្រាថ្នានូវប្រយោជន៍ដល់ពួកយើង ។ ក៏នាំគ្នាបោសសេនាសនៈឯង ចាត់ចែងទឹកក្តៅ ប្របាច់ខ្នង ប្របាច់ជើង និងតាំងការរក្សា ភិក្ខុទាំងនោះក៏នាំគ្នាចម្រើនមេត្តា ធ្វើមេត្តានោះឲ្យជាបាទ ផ្តើមវិបស្សនា ក៏សម្រេចអរហត្ត ជាអគ្គផលខាងក្នុងត្រៃមាសនោះឯងគ្រប់រូប បវារណាដោយវិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណាចេញវស្សានោះឯង ។

ព្រះតថាគតជាម្ចាស់នៃធម៌ ទ្រង់ឈ្លាសក្នុងប្រយោជន៍ ត្រាស់ករណីយមេត្តសូត្រ ដែលមានប្រយោជន៍ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយ ដែលមានបញ្ញាបរិបូណ៌ បានទទួលសេចក្តីស្ងប់នៃហទយៈ

យ៉ាងក្រៃលែង ក៏សម្រេចនូវសន្តិបទ ។

ព្រោះដូច្នោះឯង វិញ្ញូជនដែលប្រាថ្នានឹងសម្រេចសន្តិបទ ដែលជាអមតៈ ដែលគួរអស្ចារ្យ ដែលព្រះអរិយៈស្រឡាញ់រាប់អាន គប្បីធ្វើករណីដែលមានប្រយោជន៍ មានសីល សមាធិ បញ្ញា ដែលមិនមានមន្ទិល អស់កាលជានិច្ច កុំឲ្យដាច់ហោង ។៚

## អដ្ឋកថាមេត្តសូត្រ

## នៃ

## អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកា ចប់

# និគមគាថា

ដោយគាថាមានប្រមាណប៉ុណ្ណេះ ខ្ញុំបានពោលពាក្យណាថា ខ្ញុំសូមនមស្ការព្រះរតនត្រ័យដ៏ឧត្តម នៃវត្ថុដែលគួរថ្វាយបង្គំ ហើយនឹងសម្ដែងអដ្ឋកថានៃខុទ្ទបាឋៈណាមួយ ។

ក្នុងពាក្យនោះ ខ្ញុំចងអដ្ឋកថានៃខុទ្ទបាឋៈ ៩ ប្រភេទ គឺសរណៈ ១ សិក្ខាបទ ១ ទ្វត្តឹសាការ ១ កុមារបញ្ហា ១ មង្គលសូត្រ ១ រតនសូត្រ ១ តិរោកុឌ្ឌសូត្រ ១ និធិកណ្ឌសូត្រ ១ និងមេត្តសូត្រ ១ ដោយហេតុនោះ ទើបខ្ញុំពោលពាក្យនេះថា

ខ្ញុំបំណងឲ្យព្រះសទ្ធម្មតាំងមាំ ទើបរចនាអដ្ឋកថានៃខុទ្ទកបាឋៈនេះ ជួបនូវកុសលឯណា ។

សូមមហាជន ចាប់រួសរាន់សម្រេចនូវសេចក្ដីចម្រើនរុងរឿង បរិបូណ៌ក្នុងធម៌ដែលព្រះអរិយៈប្រកាសហើយ ព្រោះអានុភាពនៃកុសលនោះ ។

អដ្ឋកថានៃខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកានេះ រចនាដោយព្រះថេរៈដែលគ្រូទាំងឡាយឲ្យឈ្មោះថា ពុទ្ធឃោសៈ ជាអ្នកប្រដាប់ដោយគុណ គឺបរិសុទ្ធិ ការជឿ ការដឹង និងការព្យាយាម ដែលគុណសមុទយៈ គឺសីលាចារៈ អាជ្ជវៈ និងមទ្ទវៈជាដើម បណ្ដាលហើយ ជាអ្នកអាចឈមចុះកាន់ព្រៃស្កុក គឺលទ្ធិខ្លួន និងលទ្ធិដទៃ ប្រកបដោយការឈ្លាសវៃ ដែលមានពន្លឺគឺអំណាចនៃញាណ ដែលមិនមានអ្វីរាំង ក្នុងសត្ថុសាសនៈ មានព្រះត្រៃបិដក បរិយត្តិធម៌ ព្រមទាំងអដ្ឋកថា ជាមហាកវី ប្រកបដោយលម្អនៃវចនៈដ៏ពីរោះឱឡារ ដែលបន្លឺបានស្រួលនូវសម្បត្តិ គឺករណៈ ឲ្យកើតហើយ ដោយ

មហាវេយ្យាករណ៍ ដែលមានវាទៈពាល់ត្រូវ បែកធ្លាយ មានវាទៈដ៏ប្រសើរ ជាអ្នកមានសេចក្តីបរិសុទ្ធ និងការដឹងដ៏បរិបូណ៌ ជាអលង្ការនៃវង្សរបស់ព្រះថេរៈទាំងឡាយ ដែលនៅក្នុងមហាវិហារ ជាប្រទីបនៃថេរវង្ស ជាអ្នកមានការដឹងមាំទាំហើយ ក្នុងឧត្តរិមនុស្សធម៌ ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ និងបដិសម្ភិទាជាដើម ។

**តាវ និដ្ឋតុ លោកស្មឹ លោកនិដ្ឋរណេសិនំ**
**ឧសេ្សន្តិ កុលបុត្តានំ នយំ សីលាទិវិសុទ្ធិយា ។**
**យាវ ពុទ្ធោតិ នាមម្បិ សុទ្ធចិត្តស្ស តាទិនោ**
**លោកម្ហិ លោកជេដ្ឋស្ស បវត្តិ មហេសិនោ ។**

គម្ពីរបរមត្ថជោតិកា ដែលសម្តែងន័យនៃវិសុទ្ធិ មានសីលវិសុទ្ធិជាដើម ដល់កុលបុត្រទាំងឡាយ ដែលស្វែងរកការចេញចាកលោក ចូរតាំងនៅដរាប ដែលឈ្មោះថា ពុទ្ធ របស់បុគ្គលដែលមានចិត្តបរិសុទ្ធ ជាតាទិបុគ្គល ចម្រើនបំផុតក្នុងលោក ជាអ្នកស្វែងរកគុណធំ ប្រព្រឹត្តទៅក្នុងលោកហោង ។

**អដ្ឋកថាខុទ្ទកបាឋៈ**

**នៃ**

**អដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកា ចប់**

# សុត្តន្តបិដក

## ខុទ្ទកនិកាយ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

## ធម្មបទគាថា

### យមកវគ្គទី ១

[ ១១ ] *ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត ( មានចិត្តជាធំ ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី ( នូវទុច្ចរិត ) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។ ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី ( នូវសុចរិត ) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។*

*អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នកណា ចងសេចក្តីក្រោធបែបនោះទុក ( ដូច្នេះ ) ពៀររបស់អ្នកនោះមិនរម្ងាប់ឡើយ ។*

*អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះ បានលួចយកទ្រព្យរបស់អញទៅហើយ បើអ្នក*

ណា មិនចងសេចក្តីក្រោធបែបនេះទុក ( ដូច្នេះ ) ពៀររបស់អ្នកនោះ ទើបរម្ងាប់បាន ។ ពិតមែន តាំងពីកាលណាមក ក្នុងលោកនេះ ពៀរទាំងឡាយមិនរម្ងាប់ដោយពៀរឡើយ ពៀរទាំងឡាយតែងរម្ងាប់ ដោយមិនមានពៀរ នេះជាបវេណីធម៌ ។ ជនទាំងឡាយដទៃ ( ក្រៅអំពីបណ្ឌិត ) តែងមិនដឹងខ្លួនថា យើងទាំងឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះដូច្នេះឡើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំងឡាយ នឹងវិនាសក្នុងកណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែកទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

បុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាល្អ មិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គលនោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វលដូច្នោះ ។ ឯបុគ្គលដែលយល់ឃើញនូវអារម្មណ៍ថាមិនល្អ សង្រួមប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មានសទ្ធា ប្រារព្ធព្យាយាម កិលេសមារតែងគ្របសង្កត់បុគ្គលនោះមិនបាន ដូចខ្យល់គ្របសង្កត់ថ្មភ្នំតាន់មិនបានដូច្នោះ ។

អ្នកណា នៅមានទឹកចត់ គឺរាគាទិក្កិលេស ( ក្នុងសន្តាន ) ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។ លុះតែអ្នកណាមានទឹកចត់ គឺរាគាទិក្កិលេស ខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំ

ក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន ។

ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មានខ្លឹម ថាជាធម៌មិនមានខ្លឹមផង ជាអ្នកមានតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។ ជនទាំងឡាយ ដែលយល់ឃើញនូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញនូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម ។

ផ្ទះដែលប្រក់ខ្ជីខ្ជាហើយ តំណក់ទឹកភ្លៀង រមែងលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោតយ៉ាងនោះឯង ។

ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀង រមែងមិនលេចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបានយ៉ាងនោះឯង ។ បុគ្គលអ្នកធ្វើបាប តែងសោកស្តាយក្នុងលោកទាំងពីរ គឺសោកស្តាយ ក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងសោកស្តាយ ក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំង ២ គឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។ បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំង ២ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយ

ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាប អញបានធ្វើហើយ លុះមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយ ដ៏ក្រៃលែង ។

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំង ២ គឺត្រេកអរ ក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងត្រេកអរ ដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីច្រើន តែជាអ្នក ប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផល ឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ ( ជាអ្នក មិនបានបរិភោគនូវបញ្ចគោរស ) ដូច្នោះឯង ។ បើនរជនពោលពាក្យប្រកប ដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ ដែលគួរកំណត់តាម ហេតុ មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំក្នុងលោក នេះ និងលោកខាងមុខ នរជននោះ រមែងជាអ្នកបានចំណែកសាមញ្ញផល ។

**យមកវគ្គទី ១ ចប់**

# ធម្មបទដ្ឋកថា

## អដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ

# យមកវគ្គ

## បទនមស្ការ

*ខ្ញុំដែលព្រះកុមារកស្សបត្ថេរ ជាអ្នកទូន្មានខ្លួនល្អហើយ ប្រព្រឹត្តស្មើដោយប្រក្រតី មានចិត្តមាំទាំ ប្រាថ្នានូវការតាំងមាំនៃព្រះសទ្ធម្ម បំណងថា អដ្ឋកថាដែលពណ៌នាអត្ថធម្មបទដ៏ល្អ ដែលព្រះសាស្តាទ្រង់ជាអ្នកឈ្លាស ក្នុងសភាវៈដែលជាធម៌ និងមិនមែនធម៌ មានបទ គឺព្រះសទ្ធម្មដល់ព្រមហើយ មានព្រះអធ្យាស្រ័យដ៏មានកម្លាំងនៃព្រះករុណា ឲ្យនូវឧស្សាហ៍ដោយល្អហើយ ទ្រង់អាស្រ័យហេតុនោះៗ សម្តែងហើយ ជាគ្រឿងចម្រើនបីតិ និងបាមោជ្ជរបស់ទេវតា និងមនុស្សទាំងឡាយ ជាពាក្យដ៏សុខុម នាំបន្តគ្នាមកតាំងនៅហើយក្នុងតម្ពបណ្ណិទ្វីប ដោយភាសាអ្នកកោះ មិនទាន់ធ្វើអត្ថដល់ព្រមនៃប្រយោជន៍ឲ្យសម្រេចដល់សត្វទាំងឡាយដ៏សេសបាន ហេតុដូច្នោះ អដ្ឋកថានៃធម្មបទនោះ នឹងធ្វើប្រយោជន៍ឲ្យសម្រេចដល់លោកទាំងពួងបាន ដូច្នេះ អារាធនាដោយគោរពហើយ ទើបក្រាបនមស្ការព្រះបាទានៃព្រះសម្ពុទ្ធដ៏មានសិរី ទ្រង់សម្លឹងឃើញទីបំផុតលោកបាន មានឫទ្ធិដ៏រុងរឿង ទ្រង់ញុំាងប្រទីប គឺព្រះសទ្ធម្មឲ្យភ្លឺសន្ធោសន្ធៅ ក្នុងកាលដែលលោកងងឹត គឺមោហៈជំគ្របដណ្តប់*

ហើយ បូជាព្រះសទ្ធម្មនៃព្រះសម្ពុទ្ធអង្គនោះ និងធ្វើអញ្ជលីដល់ព្រះសង្ឃ-សាវកព្រះសម្ពុទ្ធអង្គនោះ ហើយនឹងពោលអដ្ឋកថា ដែលពណ៌នាអត្ថនៃធម្មបទនោះ ដោយភាសាដទៃ ដោយអត្ថមិនឲ្យសេសសល់ លះភាសានោះនិងលំដាប់នៃពាក្យដែលដល់នូវការពិស្តារពន់ពេកចោល លើកឡើងកាន់ភាសាដ៏ពីរោះ អធិប្បាយបទ ព្យញ្ជនៈនៃគាថាទាំងឡាយ ដែលលោកមិនទាន់បានអធិប្បាយហើយ ក្នុងអដ្ឋកថានោះ មិនឲ្យសេសសល់ នាំមកនូវបីតិនិងបាមោជ្ជនៃចិត្ត អាស្រ័យអត្ថ និងធម៌ដល់អ្នកប្រាជ្ញទាំងឡាយ ។

បទនមស្ការ ចប់

# យមកវគ្គ

# រឿង ព្រះចក្ខុបាលត្ថេរ

## លំនាំដើម

មានបុច្ឆាថា ព្រះធម្មទេសនា ដែលមានពាក្យថា

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត ( មានចិត្តជាធំ ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្ត ហើយ ពោលក្តី ធ្វើក្តី ( នូវទុច្ចរិត ) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមជានជើងគោដែលកំពុងអូសទៅ ។

ដូច្នេះ តើព្រះគាថានេះ ព្រះសាស្តាទ្រង់ត្រាស់ ហើយក្នុងទីណា ។

ឆ្លើយថា ទ្រង់ត្រាស់ហើយក្នុងក្រុងសាវត្ថី ។

មានបុច្ឆាតទៅទៀតថា ទ្រង់ប្រារព្ធអ្នកណា ។

ឆ្លើយថា ទ្រង់ប្រារព្ធព្រះចក្ខុបាលត្ថេរ ។

បានឮមកថា ក្នុងក្រុងសាវត្ថី មានកុដុម្ពិកៈម្នាក់ ឈ្មោះមហាសុវណ្ណ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានសម្បត្តិច្រើន តែមិនមានកូន ។ ថ្ងៃមួយ គាត់ចូលទៅកាន់កំពង់ទឹក ងូតស្រេចហើយត្រឡប់មក ឃើញដើមឈើធំ ដែលជាធំនៃឈើទាំងឡាយ ១ ដើម បរិបូរដោយមែកក្នុងរវាងផ្លូវ គិតថា ដើមឈើនេះនឹងមានទេវតាដែលមានសក្តិធំអាស្រ័យនៅ ដូច្នេះហើយ ទើបឲ្យគេជម្រះចំណែកខាងក្រោម នៃដើមឈើនោះឲ្យស្អាត ហើយឲ្យព័ទ្ធ

របង ពោយខ្សាច់ លើកទង់ជ័យ និងទង់ផ្កាលាឡើង គាក់តែងដើមឈើធំនោះហើយ ធ្វើសេចក្ដីប្រាថ្នា គឺបន់ស្រន់ថា ខ្ញុំបានបុត្រ ឬធីតាហើយ នឹងធ្វើសក្ការៈធំដល់លោក ដូច្នេះហើយ ចៀសចេញទៅ ។

ក្នុងកាលបន្ទមក ភរិយារបស់សេដ្ឋីក៏តាំងគភ៌ ។ គាត់ក៏ឲ្យធ្វើនូវពិធីបរិហារគភ៌ដល់នាង លុះកន្លងទៅ ១០ ខែ នាងប្រសូតកូនប្រុសម្នាក់ លោកសេដ្ឋីឲ្យឈ្មោះបុត្រនោះថា បាលៈ ព្រោះទារកនោះ គាត់អាស្រ័យដើមឈើធំដែលខ្លួនរក្សា ទើបបានហើយ ។

ក្នុងកាលជាចំណែកដទៃ លោកសេដ្ឋីបានកូនប្រុសម្នាក់ទៀត គាត់ឲ្យឈ្មោះថា ចុល្លបាលៈ ហើយឲ្យឈ្មោះកូនប្រុសច្បងថា មហាបាលៈ ។ កាលកុមារពីរនាក់នោះចម្រើនវ័យ មាតាបិតាគិតដល់ចំណងដោយគ្រឿងចង គឺការគ្រប់គ្រងគេហដ្ឋាន ។

ក្នុងកាលចំណែកដទៃ មាតាបិតាបានធ្វើកាលកិរិយាទៅ ។ ពួកញាតិក៏បើកសម្បត្តិទាំងអស់ ប្រគល់ឲ្យដល់សេដ្ឋីបុត្រទាំង ២ ។

ក្នុងសម័យនោះ ព្រះសាស្ដាទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅហើយ ទ្រង់យាងទៅដោយលំដាប់ ប្រថាប់នៅនាវត្តជេតពនមហាវិហារដែលសេដ្ឋីឈ្មោះអនាថបិណ្ឌិក បរិច្ចាគទ្រព្យ ៥៤ កោដិ សាងថ្វាយ ទ្រង់ទូន្មានមហាជនឲ្យតាំងនៅក្នុងផ្លូវសួគ៌ និងក្នុងផ្លូវនិព្វាន ។

មែនពិត ព្រះតថាគតទ្រង់នៅចាំវស្សា ១ វស្សាប៉ុណ្ណោះ ក្នុងនិគ្រោធមហាវិហារ ដែលព្រះញាតិវង្សខាងព្រះមាតា ៨ ម៉ឺនត្រកូល និងខាងព្រះ

បិតា ៨ ម៉ឺនត្រកូល សរុបជា ១ សែន ៦ ម៉ឺនត្រកូលសាងថ្វាយ ទ្រង់នៅចាំវស្សានាវត្តជេតពនមហាវិហារ ដែលអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ១៩ វស្សា ។ ទ្រង់ចាំវស្សាក្នុងបុព្វារាម ដែលនាងវិសាខាមហាឧបាសិកាបរិច្ចាគទ្រព្យ ២៧ កោដិ សាងថ្វាយចំនួន ៦ វស្សា ។ ទ្រង់អាស្រ័យត្រកូលទាំង ២ ដែលជាធំដោយគុណធម៌ ទ្រង់នៅចាំវស្សាអាស្រ័យក្រុងសាវត្ថី ជាគោចរគាមអស់ ២៥ វស្សា ដោយប្រការដូច្នេះ ។

អនាថបិណ្ឌិកសេដ្ឋីក្តី នាងវិសាខាមហាឧបាសិកាក្តី រមែងទៅកាន់ទីឧបដ្ឋាកព្រះតថាគត ១ ថ្ងៃ ពីរដងជាប្រចាំ ។ កាលទៅ មិនធ្លាប់មានដៃទទេ ដោយគិតក្រែងថា ភិក្ខុកំលោះ និងសាមណេរនឹងសម្លឹងមើលដៃរបស់ខ្លួន ។ កាលទៅមុនពេលឆាន់អាហារ រមែងប្រើឲ្យមនុស្សកាន់ខាទនីយជាដើមទៅ បើទៅខាងក្រោយពេលឆាន់អាហារ ប្រើឲ្យមនុស្សកាន់ភេសជ្ជៈ និងទឹកអដ្ឋបានទៅ ហើយក្នុងគេហដ្ឋាននៃជនទាំងពីរនោះ គេក្រាលអាសនៈទុកដើម្បីភិក្ខុមួយកន្លែង ២ ពាន់រូបជានិច្ចកាល ។ ភិក្ខុរូបណាប្រាថ្នាវត្ថុណា ទោះជាបាយទឹក ឬភេសជ្ជៈ របស់នោះក៏សម្រេចដល់ភិក្ខុរូបនោះ សមតាមប្រាថ្នា ។

ក្នុងជនទាំង ២ នោះ អនាថបិណ្ឌិកសេដ្ឋីមិនធ្លាប់ទូលសួរបញ្ហាចំពោះព្រះសាស្តា រហូតដល់ថ្ងៃមួយ ។ បានឮថា គាត់គិតថា ព្រះតថាគតជាព្រះពុទ្ធ ជាបុគ្គលល្អិតល្អន់ ជាក្សត្រល្អិតល្អន់ កាលទ្រង់សម្តែងធម៌ដល់អាត្មាអញដោយទ្រង់ព្រះតម្រិះថា ពួកគហបតីមានឧបការៈដល់តថាគតច្រើនដូច្នេះ ទ្រង់នឹងលំបាក ហើយមិនទូលសួរបញ្ហា ដោយសេចក្តីស្រឡាញ់ក្នុងព្រះ

សាស្ដាដ៏ក្រៃលែង ។ ចំណែកព្រះសាស្ដា លុះសេដ្ឋីអង្គុយហើយ ទ្រង់ពុទ្ធតម្រិះថា សេដ្ឋីនេះរក្សាតថាគតក្នុងទីមិនគួររក្សា ព្រោះថាតថាគតបានកាត់ក្បាលរបស់តថាគត ដែលប្រដាប់តាក់តែងហើយ ខ្វេះនូវកែវភ្នែករបស់តថាគតចេញហើយ ពុះវះនូវសាច់បេះដូងរបស់តថាគតហើយ លះបង់កូនប្រពន្ធ ជាទីស្រឡាញ់ស្មើដោយជីវិតរបស់តថាគតហើយ បំពេញបារមី ៤ អសង្ខេយ្យ និង ១ សែនកប្ប បំពេញហើយដើម្បីសម្ដែងធម៌ដល់អ្នកដទៃប៉ុណ្ណោះ សេដ្ឋីនេះរក្សាតថាគតក្នុងទីដែលមិនគួររក្សា កាលទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ត្រាស់ព្រះធម្មទេសនា ១ កណ្ឌជានិច្ច ។

គ្រានោះ ក្នុងក្រុងសាវត្ថីមានមនុស្សរស់នៅ ៧ កោដិ ក្នុងមនុស្សទាំងនោះ អ្នកបានស្ដាប់ធម្មកថារបស់ព្រះសាស្ដាហើយ កើតជាអរិយសាវក ប្រមាណ ៥ កោដិ នូវជាបុថុជ្ជនប្រមាណ ២ កោដិ ក្នុងមនុស្សទាំងនោះ កិច្ចរបស់អរិយសាវកមានត្រឹម ២ យ៉ាងប៉ុណ្ណោះ គឺក្នុងកាលមុនពេលឆាន់អាហារ លោកថ្វាយទាន ក្នុងកាលខាងក្រោយអំពីពេលឆាន់អាហារហើយ លោកមានដៃកាន់គ្រឿងសក្ការបូជា មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ប្រើមនុស្សឲ្យកាន់ទេយ្យធម៌ មានសំពត់ ភេសជ្ជៈ និងទឹកបានជាដើម ទៅដើម្បីស្ដាប់ធម៌ ។

ក្រោយមកថ្ងៃមួយ មហាបាលកុដុម្ពិកៈឃើញពួកអរិយសាវក មានដៃកាន់គ្រឿងសក្ការបូជា មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ទៅកាន់វិហារ ទើបសួរថា មហាជននេះទៅណា កាលបានឮថា ទៅស្ដាប់ធម៌ ក៏គិតថា

អញក៏នឹងទៅដែរ កាលទៅដល់ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយនៅខាងក្រោយប្រជុំជន ។

ធម្មតាព្រះពុទ្ធទាំងឡាយ កាលទ្រង់សម្តែងធម៌ ទតឃើញឧបនិស្ស័យនៃគុណ មានសរណៈ សីល និងបព្វជ្ជាជាដើមក្នុងកាលមុន ហើយទើបទ្រង់សម្តែងធម៌តាមអំណាចអធ្យាស្រ័យ ។

ហេតុនោះ ថ្ងៃនោះ ព្រះសាស្តាទតឃើញឧបនិស្ស័យរបស់មហាបាលកុដុម្ពិកៈហើយ កាលទ្រង់សម្តែងធម៌ បានត្រាស់អនុបុព្វីកថា គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោស និងការសៅហ្មងនៃកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ។

មហាបាលកុដុម្ពិកៈបានស្តាប់ធម៌រួចហើយគិតថា បុត្ត និងធីតាក្តី ភោគសម្បត្តិក្តី រមែងមិនទៅតាមបុគ្គលដែលទៅកាន់បរលោក សូម្បីសរីរៈក៏ទៅមិនបាន ប្រយោជន៍អ្វីរបស់អញដោយការនៅគ្រប់គ្រងផ្ទះ អញនឹងបួស លុះទេសនាចប់ គាត់ក៏ចូលទៅគាល់ព្រះសាស្តាសូមបួស ។ ខណៈនោះ ព្រះសាស្តាត្រាស់សួរថា ញាតិណាមួយរបស់អ្នកដែលគួរលា មិនមានទេឬ គាត់ទូលថា បពិត្រព្រះអង្គ ប្អូនប្រុសរបស់ខ្ញុំព្រះអង្គមាន ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរអ្នកលាប្អូននោះជាមុន ។

គាត់ទទួលថា សាធុ ហើយថ្វាយបង្គំព្រះសាស្តា ទៅដល់ផ្ទះហៅប្អូនប្រុសមកប្រគល់ទ្រព្យសម្បត្តិឲ្យថា នែបា សវិញ្ញាណកទ្រព្យក្តី អវិញ្ញាណកទ្រព្យក្តីណាមួយ ដែលមានក្នុងត្រកូលនេះ ទ្រព្យនោះ ចូរធ្លាក់ជាភារៈរបស់ឯងទាំង

អស់ ឯងចូរថែរក្សាទ្រព្យនោះចុះ ។

ប្អូនប្រុសសួរថា នែបង ចុះបងវិញ ។ បងប្រុសឆ្លើយថា អញនឹងបួសក្នុងសម្នាក់របស់ព្រះសាស្ដា ។ ប្អូនប្រុសពោលថា បងនិយាយអ្វី កាលមាតារបស់យើងស្លាប់ហើយ ខ្ញុំបានបងដូចជាមាតា កាលបិតាស្លាប់ហើយ ខ្ញុំបានបងដូចជាបិតា សម្បត្តិដ៏ច្រើនមាននៅក្នុងផ្ទះរបស់យើង យើងនៅគ្រប់គ្រងផ្ទះប៉ុណ្ណោះក៏អាចធ្វើបុណ្យបាន សូមបងកុំធ្វើយ៉ាងនោះឡើយ ។ បងប្រុសពោលថា នែបា អញបានស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា ព្រោះព្រះសាស្ដាទ្រង់សម្ដែងធម៌ មានគុណពីរោះក្នុងខាងដើមផង កណ្ដាលផង និងទីបំផុតផង លើកឡើងកាន់ត្រៃលក្ខណ៍ដ៏សុខុម ធម៌នោះ បុគ្គលណាមួយ មិនអាចបំពេញឲ្យបរិបូណ៌ក្នុងចំណែកផ្ទះបានឡើយ អញនឹងបួស ប្អូនប្រុសពោលថា អើ បងនៅកំលោះដោយពិត ចាំបួសក្នុងកាលបងចាស់ចុះ បងពោលថា នែបា ដៃនិងជើងរបស់មនុស្សចាស់របស់ខ្លួនក៏ជាមិនស្ដាប់ មិនប្រព្រឹត្តទៅក្នុងអំណាចនឹងពោលទៅថ្វីដល់ញាតិទាំងឡាយ អញនឹងមិនធ្វើតាមពាក្យរបស់អ្នក អញនឹងបំពេញសមណបដិបត្តិឲ្យបរិបូរណ៌ ។

ដៃ និងជើងរបស់បុគ្គលណា ទ្រុឌទ្រោមទៅព្រោះជរាថាមិនស្ដាប់ បុគ្គលនោះមានកម្លាំង ដែលជរាកម្ចាត់ហើយ នឹងប្រព្រឹត្តធម៌បានដូចម្ដេច គឺអញនឹងបួស ។

កាលប្អូនប្រុសកំពុងទ្រហោយំនោះឯង គាត់ចូលទៅកាន់សម្នាក់ព្រះសាស្ដា ហើយទូលសូមបួស បានបព្វជ្ជាឧបសម្បទាហើយ នៅក្នុងសម្នាក់នៃអាចារ្យ

និងឧបជ្ឈាយ៍គ្រប់ ៥ វស្សាហើយ ចេញវស្សាបវារណាហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយទូលសួរថា បពិត្រព្រះអង្គ ក្នុងព្រះសាសនានេះ មានធុរៈប៉ុន្មានយ៉ាង ។

ព្រះសាស្តាត្រាស់ឆ្លើយថា ម្នាលភិក្ខុ ធុរៈមាន ២ យ៉ាង គឺគន្ថធុរៈ និងវិបស្សនាធុរៈប៉ុណ្ណោះ មហាបាលភិក្ខុទូលសួរថា បពិត្រព្រះអង្គ គន្ថធុរៈដូចម្តេច វិបស្សនាធុរៈដូចម្តេច ។ ព្រះសាស្តាត្រាស់ថា ធុរៈ គឺការរៀនមួយនិកាយក្តី ពីរនិកាយក្តី ចប់ពុទ្ធវចនៈ គឺព្រះត្រៃបិដកក្តី តាមសមគួរដល់បញ្ញារបស់ខ្លួន ហើយទ្រទ្រង់ ពោល ប្រាប់នូវពុទ្ធវចនៈនោះ ឈ្មោះថាគន្ថធុរៈ ។ ចំណែកការផ្តើមនូវការអស់ និងការសូន្យក្នុងអត្តភាព ញុំាងវិបស្សនាឲ្យចម្រើនដោយអំណាចនៃការធ្វើឲ្យជាប់តគ្នា ហើយកាន់យកអរហត្តរបស់ភិក្ខុ ដែលមានការប្រព្រឹត្តស្ងាត់ជំនាញ ត្រេកអរក្រៃលែងហើយក្នុងសេនាសនៈដ៏ស្ងាត់ ឈ្មោះថា វិបស្សនាធុរៈ ។ មហាបាលភិក្ខុពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបួសហើយក្នុងកាលខ្លួនចាស់ មិនអាចបំពេញគន្ថធុរៈឲ្យបរិបូណ៌បាន តែនឹងបំពេញវិបស្សនាធុរៈឲ្យបរិបូណ៌បាន សូមទ្រង់ត្រាស់ប្រាប់កម្មដ្ឋានដល់ខ្ញុំព្រះអង្គចុះ ។

លំដាប់នោះ ព្រះសាស្តាបានត្រាស់ប្រាប់កម្មដ្ឋាន រហូតដល់អរហត្តដល់មហាបាលភិក្ខុ លោកថ្វាយបង្គំព្រះសាស្តាហើយ ស្វែងរកភិក្ខុដែលទៅជាមួយខ្លួន បានភិក្ខុ ៦០ រូបហើយ ចេញព្រមគ្នាធ្វើដំណើរទៅជាមួយភិក្ខុទាំងនោះ អស់ចម្ងាយផ្លូវ ១២០ យោជន៍ ដល់តំបន់ជាយដែនមួយ មួយអន្លើ

ដោយអ្នករួមដំណើរចូលទៅបិណ្ឌបាតក្នុងស្រុកនោះ ។

ពួកមនុស្សឃើញភិក្ខុទាំងឡាយដល់ព្រមដោយវត្ត មានចិត្តជ្រះថ្លា រៀបចំអាសនៈហើយ និមន្តឲ្យគង់ អង្គាសដោយអាហារដ៏ប្រណីតហើយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់នឹងទៅទីណា កាលលោកទាំងឡាយពោលថា ឧបាសក និងឧបាសិកាទាំងឡាយ អាត្មាទៅកាន់ទីដែលជាផាសុក ដូច្នេះហើយ ពួកមនុស្សដែលជាបណ្ឌិតដឹងថា លោកម្ចាស់ទាំងឡាយស្វែងរកសេនាសនៈចាំវស្សា ទើបអារាធនាថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះអស់ត្រីមាស យើងខ្ញុំទាំងឡាយនឹងតាំងនៅក្នុងសរណៈ ហើយរក្សាសីល ។ ភិក្ខុទាំងឡាយក៏គិតឃើញថា យើងបានអាស្រ័យត្រកូលទាំងនេះនឹងធ្វើការចេញទៅអំពីភពបាន ដូច្នេះ ទើបទទួលនិមន្ត ។ ពួកមនុស្សទទួលប្ដេជ្ញារបស់លោកទាំងឡាយហើយ បាននាំគ្នាបោសសម្អាត រៀបចំទីលំនៅក្នុងពេលយប់ និងទីលំនៅក្នុងពេលថ្ងៃ ហើយវេរប្រគេន ។ ភិក្ខុទាំងឡាយចូលទៅបិណ្ឌបាតក្នុងស្រុកនោះជាប្រចាំ ។ កាលនោះ ពេទ្យម្នាក់ចូលទៅរកភិក្ខុទាំងឡាយ បវារណាថា បពិត្រលោកម្ចាស់ ធម្មតាក្នុងទីលំនៅរបស់មនុស្សច្រើន រមែងមិនមានផាសុកខ្លះ បើការមិនផាសុកនោះកើតឡើងហើយ លោកម្ចាស់ទាំងឡាយគប្បីប្រាប់ដល់ខ្ញុំ ខ្ញុំនឹងធ្វើភេសជ្ជៈប្រគេន ។

ក្នុងថ្ងៃចាំវស្សា ព្រះថេរៈហៅភិក្ខុទាំងនោះមកព្រមគ្នា ហើយសួរថា អាវុសោទាំងឡាយ អ្នកទាំងឡាយនឹងឲ្យត្រីមាសនេះកន្លងទៅដោយឥរិយាបថប៉ុន្មាន ។ ភិក្ខុទាំងឡាយឆ្លើយថា នឹងឲ្យកន្លងទៅដោយឥរិយាបថគ្រប់ទាំង

៤ ព្រះថេរៈពោលថា អាវុសោទាំងឡាយ សេចក្តីនោះសមគួរឬ យើងទាំង-ឡាយគួរជាបុគ្គលមិនប្រមាទមិនមែនឬ ព្រោះយើងទាំងឡាយរៀនព្រះកម្ម-ដ្ឋានមកអំពីសម្នាក់របស់ព្រះសម្ពុទ្ធ ដែលទ្រង់គង់ព្រះជន្មនៅ ធម្មតាព្រះពុទ្ធទាំងឡាយដែលបុគ្គលអួតអាង មិនអាចឲ្យទ្រង់ត្រេកអរបាន ដ្បិតថា ព្រះពុទ្ធទាំងឡាយនោះ ដែលបុគ្គលមានអធ្យាស្រ័យល្អមួយពួកប៉ុណ្ណោះ គប្បីឲ្យទ្រង់ត្រេកអរបាន ។ ឈ្មោះថា អបាយទាំង ៤ ដូចផ្ទះរបស់ខ្លួនឯងនៃបុគ្គលអ្នកប្រមាទហើយ អ្នកទាំងឡាយ ចូរជាអ្នកមិនប្រមាទចុះ ភិក្ខុទាំងឡាយសួរថា ចុះលោកម្ចាស់វិញ ។ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ខ្ញុំនឹងឲ្យត្រីមាសនេះកន្លងទៅដោយឥរិយាបថ ៣ គឺមិនសណ្តូកខ្លួន ភិក្ខុទាំងឡាយពោលថា សាធុ សូមលោកម្ចាស់មិនប្រមាទចុះ ។

កាលព្រះថេរៈមិនឈានចុះកាន់និទ្រា កាលមួយខែកន្លងទៅហើយ រោគក្នុងភ្នែកក៏កើតឡើង ទឹកហូរចេញអំពីភ្នែកទាំងពីរ ដូចទឹកដែលហូរចេញអំពីឆ្នាំងដែលធ្លុះ ។ ព្រះថេរៈបំពេញសមណធម៌អស់រាត្រីទាំងមូល ហើយក្នុងពេលអារុណរះ ចូលបន្ទប់គង់ហើយ ។ ក្នុងពេលភិក្ខាចារ ភិក្ខុទាំងឡាយទៅកាន់សម្នាក់របស់ព្រះថេរៈប្រាប់ថា ពេលនេះ ជាពេលភិក្ខាចារលោកម្ចាស់ ។ ព្រះថេរៈឆ្លើយថា អាវុសោទាំងឡាយ បើយ៉ាងនោះលោកទាំងឡាយកាន់បាត្រនិងចីវរចុះ ដូច្នេះហើយ ឲ្យភិក្ខុទាំងឡាយកាន់បាត្រ និងចីវររបស់ខ្លួនចេញទៅហើយ ។

ភិក្ខុទាំងឡាយ ឃើញភ្នែកទាំងពីររបស់ព្រះថេរៈមានខ្ទុះ ទើបសួរថា

បពិត្រលោកម្ចាស់ នុ៎ះជាអ្វី ។ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ខ្យល់ចាក់នូវក្អែករបស់ខ្ញុំ ។ ភិក្ខុទាំងឡាយពោលថា បពិត្រលោកម្ចាស់ គ្រូពេទ្យបវារណាយើងមិនមែនឬ យើងគួរប្រាប់ដល់គាត់ ព្រះថេរៈពោលថា សាធុ អាវុសោទាំងឡាយ ។

ទើបភិក្ខុទាំងឡាយ បានប្រាប់ដល់គ្រូពេទ្យ គាត់ចម្អិនប្រេងបញ្ជូនទៅប្រគេនហើយ ព្រះថេរៈដាក់តំណក់ប្រេងក្នុងច្រមុះអង្គុយបន្តក់ហើយ ចូលទៅខាងក្នុងស្រុក ។

គ្រូពេទ្យឃើញ ក៏សាកសួរថា បពិត្រលោកម្ចាស់ បានឮថា ខ្យល់ចាក់ក្អែករបស់លោកម្ចាស់ឬ ។ ព្រះថេរៈពោលថា អើ ឧបាសក ។ គ្រូពេទ្យពោលថា បពិត្រលោកម្ចាស់ ខ្ញុំចម្អិនប្រេងហើយបញ្ជូនទៅប្រគេនលោកម្ចាស់បន្តក់តាមច្រមុះហើយឬ ។ ព្រះថេរៈពោលថា អើ ឧបាសក ។ គ្រូពេទ្យពោលថា ឥឡូវនេះ ដូចម្ដេចទៅហើយលោកម្ចាស់ ។ ព្រះថេរៈពោលថា ខ្យល់នៅតែចាក់នោះឯង ឧបាសក ។

គ្រូពេទ្យឆ្ងល់ក្នុងចិត្តគិតថា អញបញ្ជូនប្រេងដើម្បីនឹងញុំាងរោគឲ្យរម្ងាប់បាន ដោយការបន្តក់ត្រឹមតែម្ដងប៉ុណ្ណោះ ទៅប្រគេនហើយ ហេតុអ្វីហ្ន៎ ទើបរោគមិនសះស្បើយ ទើបសាកសួរថា បពិត្រលោកម្ចាស់ ប្រេងនោះលោកម្ចាស់ គង់បន្តក់ ឬសិងបន្តក់ ។ ព្រះថេរៈនៅស្ងៀម សូម្បីគ្រូពេទ្យសាកសួរ ក៏មិនពោល ។

គ្រូពេទ្យគិតថា អញនឹងទៅវិហារមើលទីលំនៅឯង ដូច្នេះហើយ ពោល

ថា បើយ៉ាងនោះសូមនិមន្តទៅចុះ ។ បញ្ជូនព្រះថេរៈហើយ ទៅកាន់វិហារ មើលទីលំនៅរបស់ព្រះថេរៈ ឃើញតែទីចង្រ្កម និងទីអង្គុយ មិនឃើញទីសិង ទើបសាកសួរថា បពិត្រលោកម្ចាស់ ប្រេងនោះលោកម្ចាស់អង្គុយបន្តក់ ឬ សិងបន្តក់ ។ ព្រះថេរៈក៏នៅស្ងៀម ។ គ្រូពេទ្យអង្វរហើយអង្វរទៀតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំធ្វើយ៉ាងនោះ ធម្មតាសមណធម៌ បើរាងកាយនៅប្រព្រឹត្តទៅ ក៏អាចធ្វើបាន សូមលោកម្ចាស់សិងបន្តក់ចុះ ។

ព្រះថេរៈឆ្លើយថា ទៅចុះអ្នក អាត្មានឹងប្រឹក្សាមើលហើយទើបដឹង ។ ក្នុងទីនោះមិនមានញាតិសាលោហិតរបស់ព្រះថេរៈឡើយ តើលោកប្រឹក្សាជាមួយអ្នកណា តែទោះជាយ៉ាងនោះលោកប្រឹក្សាជាមួយករជកាយថា នែបាលិតៈ អ្នកចូរពោលមកមុន អ្នកនឹងឃើញដល់ចក្ខុ ឬនឹងឃើញដល់ព្រះពុទ្ធសាសនា ។ ក្នុងសង្សារវដ្តដែលមានទីបំផុត ដែលបុគ្គលដឹងមិនបាន ការគណនារាប់ខ្លួនរបស់អ្នកដែលខ្វាក់ភ្នែកមិនបាន ។ ព្រះពុទ្ធទាំងឡាយកន្លងទៅច្រើនរយ ច្រើនពាន់អង្គហើយ ព្រះពុទ្ធទាំងនោះ ព្រះពុទ្ធសូម្បីមួយអង្គក៏កំណត់មិនបាន អ្នកបានចងចិត្តទុកឥឡូវនេះឯងថា នឹងមិនដេកអស់កាល ៣ ខែ ក្នុងវស្សាភ្លៀងនេះ ។ ហេតុនោះ ភ្នែករបស់អ្នកវិនាស ឬបែកក៏ដោយចុះ អ្នកចូរទ្រទ្រង់តែព្រះពុទ្ធសាសនាចុះ កុំឃើញដល់ចក្ខុឡើយ កាលទូន្មានកូតកាយ បានភាសិតគាថានេះថា

ចក្ខុដែលអ្នកប្រកាន់ថារបស់ខ្លួន វិនាសក៏វិនាសចុះ ត្រចៀក
ក៏វិនាសទៅចុះ កាយក៏ដូចគ្នាយ៉ាងនោះចុះ វត្ថុទាំងអស់

អាស្រ័យកាយនេះ ក៏វិនាសទៅចុះ បាលិត: ហេតុអ្វី ទើប
អ្នកប្រមាទ ។ ចក្ខុដែលអ្នកសម្គាល់ថារបស់ខ្លួន ទ្រុឌទ្រោម
ទៅចុះ ត្រចៀកក៏ទ្រុឌទ្រោមទៅចុះ កាយក៏ដូចគ្នាយ៉ាងនោះ
ចុះ វត្ថុសព្វយ៉ាងអាស្រ័យកាយនេះ ក៏ចូរទ្រុឌទ្រោមទៅចុះ
បាលិត: ហេតុអ្វី ទើបអ្នកប្រមាទ ។ ចក្ខុដែលអ្នកប្រកាន់
ថារបស់ខ្លួន ចូរបែកទៅចុះ ត្រចៀកក៏បែកទៅចុះ រូបក៏ដូច
គ្នាយ៉ាងនោះចុះ វត្ថុសព្វយ៉ាងអាស្រ័យកាយនេះ ក៏បែកទៅ
ចុះ បាលិត: ហេតុអ្វី ទើបអ្នកប្រមាទ ។

កាលព្រះថេរៈឲ្យឱវាទដល់ខ្លួនឯងដោយ ៣ គាថាយ៉ាងនេះហើយ បាន
អង្គុយធ្វើនត្ថុកម្ម ហើយទើបចូលទៅស្រុកដើម្បីបិណ្ឌបាត គ្រូពេទ្យឃើញ
ហើយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើនត្ថុកម្មហើយឬ ។ ព្រះថេរៈ
ពោលថា អើ ឧបាសក ។ គ្រូពេទ្យពោលថា តើអាការដូចម្ដេចខ្លះ លោក
ម្ចាស់ ។ ព្រះថេរៈពោលថា នៅតែឈឺចាប់នោះឯងឧបាសក ។ គ្រូពេទ្យ
ពោលថា លោកម្ចាស់អង្គុយបន្តក់ ឬសិងបន្តក់ ។ ព្រះថេរៈក៏នៅស្ងៀម ព្រះ
ថេរៈសូម្បីគ្រូពេទ្យសួរហើយសួរទៀត ក៏មិនពោលអ្វីឡើយ ។ ខណៈនោះ
គ្រូពេទ្យពោលជាមួយលោកថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនធ្វើសេចក្ដី
សប្បាយតាំងអំពីថ្ងៃនេះ សូមលោកម្ចាស់កុំបីពោលថា គ្រូពេទ្យឈ្មោះនោះ
ចម្អិនប្រេងឲ្យអាត្មា ឯខ្ញុំក៏មិនពោលថា ខ្ញុំចម្អិនប្រេងប្រគេនលោកម្ចាស់ ។

ព្រះថេរៈត្រូវគ្រូពេទ្យបញ្ឈប់ហើយ ត្រឡប់ទៅកាន់វិហារត្រិះរិះថា អ្នក

សូម្បីគ្រូពេទ្យក៏ដកពាក្យហើយ អ្នកកុំបីលះឥរិយាបថនេះចោលឡើយ សមណៈ ហើយពោលទូន្មានខ្លួនដោយគាថាយ៉ាងនេះថា

បាលិតៈ អ្នកត្រូវគ្រូពេទ្យបោះបង់ការព្យាបាលហើយ ទៀងចំពោះមច្ចុ-រាជ ហេតុអ្វី អ្នកនៅប្រមាទ ដូច្នេះហើយ បំពេញសមណធម៌ ។

លំដាប់នោះ លុះមជ្ឈិមយាមកន្លងហើយ ភ្នែកក្តី កិលេសក្តីរបស់លោក បែកព្រមគ្នាមិនមុនមិនក្រោយ លោកជាព្រះអរហន្តសុក្ខវិបស្សកៈ ចូលទៅកាន់បន្ទប់គន្ធ៍ហើយ ។

ក្នុងពេលភិក្ខាចារ ភិក្ខុទាំងឡាយទៅប្រាប់លោកថា បពិត្រលោកម្ចាស់ កាលនេះជាកាលភិក្ខាចារ ព្រះថេរៈពោលថា កាលឬ អាវុសោទាំងឡាយ ភិក្ខុទាំងឡាយពោលថា ពិតហើយលោកម្ចាស់ ព្រះថេរៈពោលថា បើដូច្នោះ អ្នកទាំងឡាយ ចូរទៅចុះ ភិក្ខុទាំងឡាយពោលថា ចុះលោកម្ចាស់វិញ ព្រះថេរៈពោលថា អាវុសោទាំងឡាយ ភ្នែករបស់ខ្ញុំវិនាសហើយ ។

ភិក្ខុទាំងឡាយមើលភ្នែករបស់ព្រះថេរៈហើយ មានភ្នែកពេញដោយទឹកភ្នែក លួងលោមព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំគិតថ្វីឡើយ យើងខ្ញុំនឹងបដិបត្តិលោកម្ចាស់ ដូច្នេះហើយ ធ្វើវត្តដែលគួរធ្វើ ស្រេចហើយ ចូលទៅកាន់ស្រុក ។ ពួកមនុស្សមិនឃើញព្រះថេរៈ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់របស់យើងខ្ញុំទៅឯណា បានឮដំណឹងនោះហើយ ក៏ផ្ញើបបរទៅប្រគេនមុនហើយ កាន់យកបិណ្ឌបាតទៅឯង ថ្វាយបង្គំព្រះថេរៈ ហើយទ្រហោយំបម្រះនៀលទៀបបាទារបស់ព្រះថេរៈ លួងលោមថា បពិត្រ

លោកម្ចាស់ យើងខ្ញុំទាំងឡាយនឹងទទួលបដិបត្តិ សូមលោកម្ចាស់កុំគិតថ្វីឡើយ ហើយលាត្រឡប់ទៅ ។ តាំងអំពីនោះមក ជនទាំងនោះក៏បញ្ជូនបបរនិងបាយ ទៅប្រគេនឯវិហារជានិច្ច ។

ចំណែកព្រះថេរៈ ក៏ពោលទូន្មានភិក្ខុ ៦០ រូប ក្រៅអំពីនេះជានិច្ច ។ ភិក្ខុទាំងឡាយតាំងនៅក្នុងឱវាទរបស់លោក លុះដិតថ្ងៃបវារណា ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាគ្រប់រូប ។

ភិក្ខុទាំងឡាយកាលចេញវស្សាហើយ ចង់គាល់ព្រះសាស្តា ទើបប្រាប់ព្រះថេរៈថា យើងខ្ញុំចង់គាល់ព្រះសាស្តា ។

ព្រះថេរៈបានស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយហើយ គិតថា អាត្មាអញជាបុគ្គលទុព្វលភាព ហើយក្នុងរវាងផ្លូវព្រៃជ្រៅ ដែលអមនុស្សអាស្រ័យនៅក៏មាន បើអញទៅជាមួយភិក្ខុទាំងឡាយ លោកនឹងនាំគ្នាលំបាកមិនអាចបានសូម្បីភិក្ខា អញនឹងបញ្ជូនភិក្ខុទាំងនេះទៅមុន ។ លំដាប់នោះ ទើបលោកពោលនឹងភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ចូរអ្នកទាំងឡាយទៅមុនចុះ ភិក្ខុទាំងឡាយសួរថា ចុះលោកម្ចាស់វិញ ព្រះថេរៈពោលថា ខ្ញុំជាមនុស្សទុព្វលភាព ហើយក្នុងរវាងផ្លូវ ព្រៃជ្រៅដែលអមនុស្សអាស្រ័យនៅក៏មាន បើខ្ញុំទៅជាមួយអ្នកទាំងឡាយ អ្នកទាំងឡាយនឹងលំបាកទាំងអស់ អ្នកទាំង-ឡាយ ចូរទៅមុនចុះ ភិក្ខុទាំងឡាយពោលថា សូមលោកម្ចាស់កុំធ្វើយ៉ាងនេះឡើយ យើងខ្ញុំនឹងទៅជាមួយលោកម្ចាស់នោះឯង ព្រះថេរៈពោលថា អ្នកទាំងឡាយ កុំពេញចិត្តយ៉ាងនោះឡើយ បើយ៉ាងនោះការមិនមានសេចក្តី

សុខនឹងមានដល់ខ្ញុំ ប្អូនប្រុសរបស់ខ្ញុំឃើញអ្នកទាំងឡាយហើយ គង់នឹងសាកសួរ បើដូច្នោះ អ្នកទាំងឡាយ គប្បីប្រាប់កាលដែលក្អែករបស់ខ្ញុំវិនាសហើយដល់គេ ប្អូនខ្ញុំគង់នឹងបញ្ជូនអ្នកណាម្នាក់មកកាន់សម្នាក់របស់ខ្ញុំ ខ្ញុំនឹងទៅជាមួយបុគ្គលនោះ អ្នកទាំងឡាយ ចូរថ្វាយបង្គំព្រះទសពល និងព្រះអសីតិមហាថេរៈតាមពាក្យរបស់ខ្ញុំ ដូច្នេះហើយ ក៏បញ្ជូនភិក្ខុទាំងនោះទៅ ។

ភិក្ខុទាំងឡាយសូមខមាទោសព្រះថេរៈហើយ ចូលទៅខាងក្នុងស្រុក ពួកមនុស្សនិមន្តឲ្យគង់ ថ្វាយភិក្ខាហើយសួរថា បពិត្រលោកម្ចាស់ មើលអាកប្បកិរិយារបស់លោកម្ចាស់ទាំងឡាយ ហាក់ដូចជាទៅណាហ្ន៎ ។

ភិក្ខុទាំងឡាយឆ្លើយថា អើ ឧបាសកទាំងឡាយ ពួកអាត្មាចង់គាល់ព្រះសាស្តា ។ ពួកជនទាំងនោះអង្វរច្រើនលើកច្រើនសាហើយ ជ្រាបការពេញចិត្តក្នុងការដែលភិក្ខុទាំងឡាយចង់ទៅតែពីខាងបាន ទើបតាមជូនទៅ ហើយយំរៀបរាប់ត្រឡប់មក ។

ចំណែកភិក្ខុទាំងឡាយ ទៅដល់វត្តជេតពនដោយលំដាប់ ថ្វាយបង្គំព្រះសាស្តា និងព្រះមហាថេរៈទាំងឡាយតាមពាក្យរបស់ព្រះថេរៈហើយ លុះស្អែកឡើងចូលទៅកាន់ផ្លូវដែលប្អូនប្រុសរបស់ព្រះថេរៈនៅ ដើម្បីបិណ្ឌបាត កុដុម្ពិកៈចាំភិក្ខុទាំងឡាយបាន និមន្តឲ្យគង់ធ្វើបដិសណ្ឋារៈ ហើយសួរថា ព្រះថេរៈដែលជាបងប្រុសរបស់ខ្ញុំនៅឯណា ។

លំដាប់នោះ ភិក្ខុទាំងឡាយប្រាប់ដំណើរនោះដល់ចុល្លបាលហើយ ។ គាត់ទ្រហោយំ បម្រះននៀលទៀបជើងរបស់ភិក្ខុទាំងឡាយ សួរថា បពិត្រ

លោកម្ចាស់ ឥឡូវនេះ គួរធ្វើយ៉ាងណាល្អ ភិក្ខុទាំងឡាយពោលថា ព្រះថេរៈត្រូវការឲ្យបុគ្គលណាម្នាក់ទៅអំពីទីនេះ ក្នុងកាលទៅដល់ហើយ លោកនឹងមកជាមួយបុគ្គលនោះ ចុល្លបាលពោលថា បពិត្រលោកម្ចាស់ បុគ្គលនេះជាក្មួយរបស់ខ្ញុំឈ្មោះបាលិតៈ សូមលោកម្ចាស់ទាំងឡាយបញ្ជូនបុគ្គលនេះទៅចុះ ភិក្ខុទាំងឡាយពោលថា បញ្ជូនទៅយ៉ាងនេះមិនបាន អន្តរាយក្នុងផ្លូវមាន ត្រូវឲ្យបួសជាមុន ហើយបញ្ជូនទៅ ទើបគួរ ។ ចុល្លបាលពោលថា សូមលោកម្ចាស់ទាំងឡាយធ្វើយ៉ាងនោះហើយ បញ្ជូនទៅចុះ ។ គ្រានោះ ភិក្ខុទាំងឡាយឲ្យក្មួយនោះបួសហើយ បង្រៀនឲ្យសិក្សាវត្តបដិបត្តិ មានទទួលចីវរជាដើមអស់កន្លះខែហើយ ប្រាប់ផ្លូវហើយ បញ្ជូនទៅ ។

សាមណេរដល់ស្រុកនោះដោយលំដាប់ ឃើញបុរសជីងក្តីម្នាក់ត្រង់ទ្វារស្រុក ទើបសួរថា វិហារព្រៃណាមួយអាស្រ័យស្រុកនេះមានឬ ជននោះឆ្លើយថា មានលោកម្ចាស់ សាមណេរសួរថា អ្នកណានៅក្នុងទីនោះ ជននោះពោលថា ព្រះថេរៈឈ្មោះបាលិតៈលោកម្ចាស់ សាមណេរពោលថា សូមអ្នកប្រាប់ផ្លូវដល់អាត្មាបន្តិចចុះ ជននោះពោលថា លោកម្ចាស់ត្រូវជាអ្វីនឹងលោក សាមណេរពោលថា អាត្មាជាក្មួយរបស់ព្រះថេរៈ ។

ខណៈនោះ អ្នកស្រុកនោះនាំសាមណេរទៅកាន់វិហារហើយ ។ លោកថ្វាយបង្គំព្រះថេរៈ ហើយធ្វើវត្តបដិបត្តិបម្រើព្រះថេរៈដោយល្អ អស់កន្លះខែហើយ ពិតថា បពិត្រលោកម្ចាស់ កុដុម្ពិកៈជាអ៊ំរបស់ខ្ញុំត្រូវការឲ្យលោកម្ចាស់ត្រឡប់ទៅ សូមលោកម្ចាស់ទៅជាមួយខ្ញុំចុះ ។

ព្រះថេរៈពោលថា បើយ៉ាងនោះ ចូរអ្នកចាប់ចុងឈើច្រត់របស់ខ្ញុំចុះ ។ សាមណេរចាប់ចុងឈើច្រត់ ចូលទៅខាងក្នុងស្រុកជាមួយព្រះថេរៈ ។ ពួកមនុស្សនិមន្តឲ្យគង់ហើយ សាកសួរថា បពិត្រលោកម្ចាស់មើលឫកហាក់ដូចជាចង់និមន្តទៅណាទេដឹង ព្រះថេរៈឆ្លើយថា អើ ឧបាសក និងឧបាសិកាទាំងឡាយ អាត្មានឹងទៅថ្វាយបង្គំព្រះសាស្តា ពួកមនុស្សទាំងនោះអង្វរដោយប្រការផ្សេងៗ កាលមិនបានដូចបំណង ក៏ជូនព្រះថេរៈទៅដល់ពាក់កណ្តាលផ្លូវហើយ នាំគ្នាទ្រហោយំ ត្រឡប់មក ។

សាមណេរនាំព្រះថេរៈដោយចុងឈើច្រត់ទៅ ដល់ស្រុកដែលព្រះថេរៈធ្លាប់អាស្រ័យឈ្មោះសង្កដ្ឋៈ ក្នុងព្រៃវាងផ្លូវ ។ សាមណេរបានឮសំឡេងស្រីម្នាក់ ដែលចេញអំពីស្រុកនោះហើយ ច្រៀងបណ្តើរ រកឧសបណ្តើរក្នុងព្រៃ កាន់យកនិមិត្តក្នុងសំឡេងហើយ ។

មែនពិត មិនមានសំឡេងដទៃឈ្មោះថាអាចផ្សាយទៅពេញសរីរៈរបស់បុរសទាំងឡាយ តាំងនៅដូចសំឡេងស្រីឡើយ ហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា

> ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសំឡេងដទៃសូម្បីតែសំឡេង ១ ដែលគ្របសង្កត់ចិត្តបុរសហើយឋិតនៅដូចសំឡេងស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សំឡេងស្ត្រី ទើបអាចគ្របសង្កត់ចិត្តបុរស ហើយឋិតនៅ ។

សាមណេរកាន់យកនិមិត្តក្នុងសំឡេងនោះហើយ លែងចុងឈើច្រត់ចោល ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់ចាំសិនកិច្ចរបស់ខ្ញុំមាន ដូច្នេះហើយ ទៅកាន់សម្នាក់របស់ស្រីនោះ ។ នាងឃើញសាមណេរហើយ បានឈប់ស្ងៀម ។ សាមណេរដល់នូវសីលវិបត្តិជាមួយនាងហើយ ។ ព្រះថេរៈគិតថា អាត្មាអញបានឮសំឡេងច្រៀងឯណាមួយអម្បាញ់មិញនេះឯង ឯសំឡេងនោះ គង់ជាសំឡេងស្រី សូម្បីសាមណេរក៏យឺតយូរ សាមណេរនឹងដល់នូវសីលវិបត្តិដោយពិត ។ ចំណែកសាមណេរនោះធ្វើកិច្ចរបស់ខ្លួនស្រេចហើយមកដល់ ពោលថា បពិត្រលោកម្ចាស់យើងទាំងឡាយ ទៅជាមួយគ្នាចុះ ។

ខណៈនោះ ព្រះថេរៈសួរថា នែសាមណេរ អ្នកក្លាយជាមនុស្សអាក្រក់ហើយមែនឬ សាមណេរក៏ស្ងៀមនៅ ព្រះថេរៈសួរដដែលក៏មិនពោលពាក្យណាមួយឡើយ ។

លំដាប់នោះ ព្រះថេរៈពោលនឹងសាមណេរថា ធុរៈដោយការដែលមនុស្សអាក្រក់ដូចអ្នកចាប់ចុងឈើច្រត់របស់ខ្ញុំមិនមាន ។ សាមណេរដល់នូវសេចក្តីសង្វេគហើយ ដោះនូវសំពត់កាសាវៈចេញហើយ ស្លៀកដណ្តប់តាមបែបគ្រហស្ថពោលថា បពិត្រលោកម្ចាស់ កាលមុនខ្ញុំជាសាមណេរ តែឥឡូវនេះខ្ញុំជាគ្រហស្ថហើយ ។ម្យ៉ាងទៀត ខ្ញុំកាលបួសក៏មិនបានបួសដោយសទ្ធា បួសព្រោះខ្លាចចំពោះអន្តរាយក្នុងរវាងផ្លូវ សូមលោកម្ចាស់ទៅជាមួយខ្ញុំចុះ ។

ព្រះថេរៈពោលថា នែអ្នកគ្រហស្ថអាក្រក់ក្តី សាមណេរអាក្រក់ក្តី ក៏អាក្រក់ដូចតែគ្នា អ្នកសូម្បីតាំងនៅក្នុងភាពជាសមណៈហើយ មិនអាចធ្វើគុណ

ត្រឹមតែសីលឲ្យបរិសុទ្ធ ទម្រាំជាគ្រហស្ថនឹងធ្វើកល្យាណកម្មអ្វីបាន ធុរៈដោយការដែលមនុស្សអាក្រក់ដូចអ្នក ចាប់ចុងឈើប្រត់របស់អាត្មាមិនមាន ។

នាយបាលិតៈឆ្លើយថា បពិត្រលោកម្ចាស់ ផ្លូវមានអមនុស្ស លោកម្ចាស់ក៏ខ្វាក់ភ្នែកនឹងនៅទីនេះបានដូចម្តេច ។

លំដាប់នោះ ព្រះថេរៈពោលថា នែអ្នក អ្នកកុំគិតយ៉ាងនេះឡើយ អាត្មាដេកស្លាប់ក្នុងទីនេះក្តី ដេកបម្រះននៀលក្នុងទីនេះក្តី ឈ្មោះថា ការទៅជាមួយអ្នក មិនមាន ។ ហើយបានពោលគាថានេះថា

ណ្ហើយចុះ ខ្ញុំជាអ្នកមានភ្នែកខ្វាក់ហើយ មកកាន់ផ្លូវកន្តារ ដេកក្តី នឹងមិនទៅព្រោះភាពជាសម្លាញ់ក្នុងជនពាល រមែងមិនមាន ។ ណ្ហើយចុះ ខ្ញុំជាបុគ្គលមានចក្ខុវិនាសហើយ មកកាន់ផ្លូវកន្តារ ទោះស្លាប់ក៏មិនទៅ ព្រោះភាពជាសម្លាញ់ក្នុងជនពាល រមែងមិនមាន ។

នាយបាលិតៈបានឮពាក្យនោះហើយ កើតនូវសេចក្តីសង្វេគគិតថា អញធ្វើកម្មធ្ងន់ប្រព្រឹត្តទៅដោយរហ័ស មិនសមគួរហ្ន៎ ដូច្នេះហើយ ឱបដៃខ្សឹកខ្សួលរត់ចូលកាន់ព្រៃចៀសចេញទៅ ដោយប្រការនោះឯង ។

ដោយតេជះនៃសីលរបស់ព្រះថេរៈ បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជ បណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ មានពណ៌ដូចផ្កាជយព្រឹក មានប្រក្រតីទ្រុឌចុះក្នុងពេលប្រថាប់គង់ និងប៉ោងឡើងក្នុងពេលក្រោកឡើង សម្តែងអាការក្តៅហើយ ។

សក្កទេវរាជទ្រង់ព្រះតម្រិះថា នរណាហ្ន៎ ប្រាថ្នាឲ្យអាត្មាអញឃ្លាតចាកស្ថាន ដូច្នេះហើយ ទ្រង់សម្លឹងចុះមក បានឃើញព្រះថេរៈដោយទិព្វចក្ខុ ។

ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

ស្តេចសហស្សនេត្រ ជាស្តេចនៃទេវតា បញ្ជូនទិព្វចក្ខុ ទ្រង់ជ្រាបថា ព្រះបាលត្ថេរអង្គនេះ តិះដៀលបុគ្គលអាក្រក់ ជម្រះគ្រឿងចិញ្ចឹមជីវិតឲ្យបរិសុទ្ធហើយ ស្តេចសហស្សនេត្រ ជាស្តេចនៃទេវតា បញ្ជូនទិព្វចក្ខុទ្រង់ជ្រាបថា ព្រះបាលត្ថេរអង្គនេះ ជូន់ក្នុងធម៌ ត្រេកអរក្នុងសាសនាគង់នៅហើយ ។

ខណៈនោះ សក្កទេវរាជទ្រង់ព្រះតម្រិះថា បើអាត្មាអញមិនទៅកាន់សម្នាក់របស់លោកម្ចាស់ដែលជាអ្នកតិះដៀលបុគ្គលបាប ជាអ្នកជូន់ក្នុងធម៌បែបនេះ ក្បាលរបស់អញគប្បីបែកជា ៧ ភាគ អញនឹងទៅកាន់សម្នាក់របស់លោក ។

ហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

ស្តេចសហស្សនេត្រជាស្តេចនៃទេវតា ទ្រទ្រង់នូវសិរីរបស់ទេវរាជ ទ្រង់យាងមកក្នុងខណៈនោះហើយ ចូលទៅជិតព្រះចក្ខុបាលត្ថេរហើយ ។

កាលទ្រង់យាងចូលទៅជិតហើយ ទ្រង់បានធ្វើសំឡេងជើងក្នុងទីជិតព្រះថេរៈ ។ ខណៈនោះ ព្រះថេរៈសួរថា នេះជាអ្នកណាហ្ន៎ សក្កទេវរាជឆ្លើយថា ខ្ញុំជាអ្នកដំណើរលោកម្ចាស់ ព្រះថេរៈពោលថា អ្នកទៅណាឧបាសក សក្ក-

ទេវរាជពោលថា ទៅក្រុងសាវត្ថី ព្រះថេរៈពោលថា ទៅចុះអ្នក ព្រះឥន្ទ្រពោលថា ចុះលោកម្ចាស់វិញនិមន្តទៅណា ព្រះថេរៈពោលថា អាត្មាក៏ទៅក្នុងទីនោះដូចគ្នា ព្រះឥន្ទ្រពោលថា បើយ៉ាងនោះយើងទាំងឡាយទៅជាមួយគ្នាចុះ ព្រះថេរៈពោលថា អាត្មាជាមនុស្សទុព្វលភាព ការយឺតយូរនឹងមានដល់អ្នកដែលទៅជាមួយអាត្មា ។ ព្រះឥន្ទ្រពោលថា កិច្ចប្រញាប់ប្រញាល់របស់ខ្ញុំមិនមាន បើខ្ញុំទៅជាមួយលោកម្ចាស់នឹងបាននូវបុញ្ញកិរិយាវត្ថុ ១០ ណាមួយ បពិត្រលោកម្ចាស់ យើងទៅជាមួយគ្នាចុះ ។

ព្រះថេរៈគិតថា នេះប្រហែលជាសប្បុរស ទើបពោលថា បើយ៉ាងនោះចូរចាប់ចុងឈើច្រត់ចុះ ។

សក្កទេវរាជធ្វើយ៉ាងនោះហើយ បង្រួញផែនដីឲ្យដល់វត្តជេតពនក្នុងពេលល្ងាច ។

ព្រះថេរៈបានស្តាប់សំឡេងប្រគំ មានស័ង្ខ និងស្គរតូចជាដើម ហើយសួរថា នុ៎ះជាសំឡេងទីណា ព្រះឥន្ទ្រពោលថា ក្នុងក្រុងសាវត្ថីលោកម្ចាស់ ព្រះថេរៈពោលថា ក្នុងកាលទៅអាត្មាទៅអស់កាលយូរ ព្រះឥន្ទ្រពោលថា ខ្ញុំស្គាល់ផ្លូវត្រង់លោកម្ចាស់ ។

ក្នុងខណៈនោះ ព្រះថេរៈកំណត់បានថា បុគ្គលនេះមិនមែនមនុស្ស ពិតជាទេវតា ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលថា ។

ស្តេចសហស្សនេត្រ ជាស្តេចនៃទេវតា ទ្រទ្រង់នូវសិរីរបស់
ទេវរាជ បង្រួញផ្លូវនោះ ទ្រង់យាងមកដល់ក្រុងសាវត្ថីហើយ ។

ព្រះឥន្ទ្រនាំព្រះថេរៈទៅកាន់បណ្ណសាលា ដែលកុដុម្ពិកៈជាប្អូនធ្វើដើម្បីប្រយោជន៍ដល់ព្រះថេរៈនោះហើយ និមន្តឲ្យគង់លើបទ្ទុះក្តារ ហើយក្លែងខ្លួនជាសម្លាញ់ ជាទីស្រឡាញ់ទៅកាន់សម្នាក់របស់ចុល្លបាលកុដុម្ពិកៈ ត្រាស់ហៅថា នែបាលៈសម្លាញ់ បាលកុដុម្ពិកៈស្រែកសួរថា មានការអ្វីសម្លាញ់ ឥន្ទ្រនិម្មិតពោលថា ឯងដឹងភាពដែលព្រះថេរៈមកហើយឬនៅ ចុល្លបាលពោលថា ខ្ញុំមិនទាន់ដឹងទេ ព្រះថេរៈមកហើយឬ ទេវរាជត្រាស់ថា អើសម្លាញ់ខ្ញុំទៅវិហារឃើញព្រះថេរៈគង់ក្នុងបណ្ណសាលាដែលឯងធ្វើ មកហើយ អម្បាញ់មិញនេះឯង ដូច្នេះហើយ ទ្រង់ចៀសចេញទៅ ។

ចំណែកកុដុម្ពិកៈ ទៅដល់វិហារឃើញព្រះថេរៈហើយ ទ្រហោយំបម្រះនទៀលទៀបបាទជើងពោលថា បពិត្រលោកម្ចាស់ ខ្ញុំឃើញហេតុនេះហើយទើបមិនព្រមឲ្យលោកម្ចាស់បួស ដូច្នេះជាដើមហើយ ធ្វើកុមារដែលជាទាសៈពីរនាក់ឲ្យជាអ្នកជា ឲ្យបួសក្នុងសម្នាក់របស់ព្រះថេរៈហើយ ប្រាប់ថា អ្នកទាំងឡាយ ចូរនាំរបស់ធាន់ មានបបរ និងបាយជាដើម មកអំពីខាងក្នុងផ្ទះឧបដ្ឋាកព្រះថេរៈចុះ ដូច្នេះហើយ ប្រគល់ឲ្យ ។ សាមណេរទាំងឡាយធ្វើវត្តបដិបត្តិ ឧបដ្ឋាកព្រះថេរៈហើយ ។

ថ្ងៃមួយ ក្នុងកាលជាខាងក្រោយ ភិក្ខុទាំងឡាយដែលនៅក្នុងទិសដទៃមកកាន់វត្តជេតពន ដោយបំណងគាល់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តា សួរសុខទុក្ខព្រះអសីតិមហាថេរៈហើយ ត្រាច់ចារិកក្នុងវិហារដល់លំនៅរបស់ព្រះចក្ខុបាលត្ថេរហើយ មានមុខឆ្ពោះទៅកាន់ទីនោះក្នុងពេលល្ងាច ដោយបំណង

ថា នឹងមើលទីនេះ ។

ក្នុងខណៈនោះ មហាមេឃតាំងឡើង ពួកលោកគិតថា ឥឡូវនេះ ល្ងាចណាស់ហើយ មេឃក៏តាំងឡើងហើយ អញនឹងមកមើលអំពីព្រឹក ដូច្នេះហើយ ត្រឡប់ទៅ ។ ភ្លៀងធ្លាក់ក្នុងបឋមយាម រាំងក្នុងមជ្ឈិមយាម ។ ព្រះថេរៈជាអ្នកធ្លាប់ប្រារព្ធសេចក្ដីព្យាយាម និមន្តចង្រ្កមជានិច្ចកាល ហេតុនោះទើបចុះកាន់ទីចង្រ្កមហើយ ក្នុងបច្ឆិមយាម ។ ក្នុងកាលនោះ មេភ្លៀងជាច្រើន តាំងឡើងហើយលើផែនដីដែលភ្លៀងធ្លាក់ថ្មី ។ សត្វល្អិតទាំងនោះកាលព្រះថេរៈចង្រ្កម ក៏ដល់នូវសេចក្ដីវិបត្តិ គឺស្លាប់ដោយច្រើន ។

ពួកអន្តេវាសិក មិនទាន់បោសទីចង្រ្កមរបស់ព្រះថេរៈអំពីព្រលឹម ។ ឯពួកភិក្ខុក្រៅអំពីនេះ មកដោយបំណងថា នឹងមើលលំនៅរបស់ព្រះថេរៈ ឃើញសត្វល្អិតទាំងឡាយក្នុងទីចង្រ្កមហើយសួរថា លោកម្ចាស់អង្គណាចង្រ្កមក្នុងទីនេះ ។ ពួកអន្តេវាសិករបស់ព្រះថេរៈឆ្លើយថា ឧបជ្ឈាយ៍របស់ពួកខ្ញុំលោកម្ចាស់ ។ ភិក្ខុទាំងឡាយនោះតិះដៀលថា លោកទាំងឡាយចូរមើលកម្មរបស់សមណៈចុះ ក្នុងកាលមានភ្នែក លោកដេកលក់មិនធ្វើអ្វី ក្នុងកាលមានចក្ខុពិការ ឥឡូវនេះ បែរជាចង្រ្កមធ្វើសត្វមានប្រមាណដល់ម្ល៉េះឲ្យស្លាប់ហើយ លោកគិតថា នឹងធ្វើប្រយោជន៍ បែរជាធ្វើការគ្មានប្រយោជន៍ទៅវិញ ។

ភិក្ខុទាំងនោះ ទៅក្រាបទូលព្រះតថាគតហើយក្នុងខណៈនោះថា បពិត្រព្រះអង្គ ព្រះចក្ខុបាលត្ថេរយកលេសថាចង្រ្កម ធ្វើសត្វមានជីវិតជាច្រើនឲ្យស្លាប់ហើយ ។

ព្រះសាស្តាត្រាស់សួរថា អ្នកទាំងឡាយឃើញលោកកំពុងធ្វើសត្វមានជីវិតជាច្រើនឲ្យស្លាប់ហើយឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ មិនបានឃើញទេ ។ ព្រះសាស្តាត្រាស់ថា អ្នកទាំងឡាយមិនឃើញលោក យ៉ាងណា ឯលោកក៏មិនឃើញសត្វមានជីវិតទាំងនោះដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ ចេតនាជាហេតុឲ្យស្លាប់របស់ព្រះខីណាស្រពទាំងឡាយមិនមាន ។ ភិក្ខុទាំង-ឡាយទូលសួរថា បពិត្រព្រះអង្គ កាលឧបនិស្ស័យនៃអរហត្តមាន ហេតុអ្វីទើបលោកក្លាយជាបុគ្គលមានចក្ខុងងឹតហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះអំណាចកម្មដែលខ្លួនធ្វើទុកហើយ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ តើលោកបានធ្វើកម្មអ្វីមកហើយ ។

## បុព្វកម្មរបស់ព្រះចក្ខុបាលត្ថេរ

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនោះ អ្នកទាំងឡាយចូរស្តាប់ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ព្រះបាទពារាណសីគ្រងរាជ្យក្នុងក្រុងពារាណសី ។ គ្រូពេទ្យម្នាក់ត្រាច់ធ្វើវេជ្ជកម្មក្នុងស្រុក និងនិគម ឃើញស្ត្រីទុព្វលដោយចក្ខុម្នាក់ ទើបសួរថា ការមិនផាសុករបស់នាងដូចម្តេច ស្រីនោះឆ្លើយថា ខ្ញុំមិនឃើញដោយភ្នែក គ្រូពេទ្យពោលថា ខ្ញុំនឹងព្យាបាលឲ្យនាង ស្រីនោះពោលថា សូមព្យាបាលចុះ គ្រូពេទ្យពោលថា នាងនឹងឲ្យអ្វីដល់ខ្ញុំ ស្រីនោះពោលថា បើអ្នកអាចធ្វើភ្នែករបស់ខ្ញុំឲ្យដូចប្រក្រតីបាន ខ្ញុំ កូនប្រុស និងកូនស្រី នឹងព្រមធ្វើជាទាសីរបស់អ្នក គ្រូពេទ្យទទួលថា សាធុ ដូច្នេះហើយ ប្រកបថ្នាំឲ្យហើយ

ភ្នែកក៏ជាដូចប្រក្រតី ដោយថ្នាំមួយដងប៉ុណ្ណោះ ។

ស្រីនោះគិតហើយថា អញបានប្ដេជ្ញាដល់ពេទ្យនោះថា អាត្មាអញមួយអន្លើដោយកូនប្រុសកូនស្រី ព្រមធ្វើជាទាសីរបស់គាត់ គាត់នឹងមិនហៅអញដោយវាចាពីរោះ អញនឹងបោកបញ្ឆោតគាត់ ពេលគ្រូពេទ្យមកហើយសួរថា អាការដូចម្ដេចទៅហើយ នាងឆ្លើយថា ពីមុនភ្នែករបស់ខ្ញុំឈឺតិចៗ ឥឡូវនេះ ឈឺខ្លាំងពន់ពេក ។ គ្រូពេទ្យគិតថា ស្រីនេះបំណងនឹងបោកអញ ហើយមិនឲ្យវត្ថុណាមួយ សេចក្ដីត្រូវការរបស់អញដោយឈ្នួលដែលស្រីនេះឲ្យដល់អញមិនមាន អញនឹងធ្វើឲ្យស្រីនេះខ្វាក់ភ្នែកឥឡូវនេះ ហើយទៅដល់ផ្ទះប្រាប់សេចក្ដីនោះដល់ភរិយា នាងក៏នៅស្ងៀម ។ ពេទ្យនោះ ផ្សំថ្នាំមួយមុខទៀតហើយទៅកាន់សម្នាក់ស្រីនោះ ប្រាប់ឲ្យបន្តក់ថា នែនាង ចូរនាងបន្តក់ថ្នាំនេះ ។ ភ្នែកទាំងពីរបានរលត់ហើយ ដូចអណ្ដាតភ្លើង ។ គ្រូពេទ្យនោះ បានមកកើតជាចក្ខុបាលភិក្ខុហើយ ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កម្មដែលបុត្ររបស់តថាគតធ្វើហើយក្នុងកាលនោះ ជាប់តាមលោកអំពីខាងក្រោយ ។ មែនពិត ឈ្មោះថាបាបកម្មនេះ រមែងតាមបុគ្គលអ្នកធ្វើ ដូចកង់រទេះវិលតាមស្នាមជើងគោដែលនាំធុរៈទៅ ដូច្នោះ ។ កាលត្រាស់រឿងនេះហើយ ព្រះធម្មរាជាបានត្រាស់ព្រះគាថានេះបន្តអនុសន្ធិដូចប្រថាប់រាជសាសន៍ដោយត្រាស់ថា

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**

**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត ( មានចិត្តជាធំ ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្ត ហើយ ពោលក្តី ធ្វើក្តី ( នូវទុច្ចរិត ) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។

## សេចក្តីអធិប្បាយ

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ មានកាមាវចរចិត្តជាដើម ឈ្មោះថា មនោ ក្នុងព្រះគាថានេះ តែក្នុងបទនេះកាលនិយម ប៉ុន់ស្មាន់ កំណត់ចុះដោយអំណាចចិត្តដែលកើតឡើងដល់គ្រូពេទ្យនោះ ក្នុងគ្រានោះ រមែងបានចំពោះចិត្តដែលប្រព្រឹត្តទៅដោយទោមនស្ស ប្រកបដោយបដិឃៈតែម្យ៉ាង ។

បទថា **បុព្វង្គមា** គឺឈ្មោះថា មកតាមព្រមដោយចិត្តនោះ ដែលជាប្រធាន ទៅមុន ។

បទថា **ធម្មា** គឺឈ្មោះថា ធម៌ ៤ យ៉ាង ដោយអំណាចគុណធម៌ ទេសនាធម៌ បរិយត្តិធម៌ និងនិស្សត្តនិជ្ជីវធម៌ ។ ក្នុងធម៌ ៤ ប្រការនោះ ធម្ម សព្ទ ក្នុងពាក្យថា

**នហិ ធម្មោ អធម្មោ ច ឧភោ សមវិបាកិនោ**

**អធម្មោ និរយំ នេតិ ធម្មោ បាបេតិ សុគតឹ ។**

សភាវៈទាំងពីរ គឺកុសលធម៌ ១ អកុសលធម៌ ១ មិនមែន

*មានផលស្មើគ្នាទេ អកុសលធម៌ នាំសត្វទៅកាន់នរក*

*កុសលធម៌ ញុំាងសត្វឲ្យដល់ នូវសុគតិ ។*

*ដូច្នេះ ឈ្មោះថា គុណធម៌ ។* **ធម្ម** *សព្ទ ក្នុងពាក្យថា* **ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ អាទិកល្យាណំ** *ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងធម៌ ដែលមានលម្អបទដើម [illegible]ដែលមាន[illegible]ទាំងឡាយ ។ ដូច្នេះជាដើម ឈ្មោះថា ទេសនាធម៌ ។* **ធម្ម** *សព្ទ ក្នុងពាក្យថា* **ឥធ ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ** *ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ ។បេ។ ដូច្នេះជាដើម ឈ្មោះថា បរិយត្តិធម៌ ។* **ធម្ម** *សព្ទ ក្នុងពាក្យថា* **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ ខន្ធា ហោន្តិ** *ពួកធម៌កើតមានក្នុងសម័យនោះ ពួកខន្ធកើតមានក្នុងសម័យនោះ ។ ដូច្នេះជាដើម ឈ្មោះថា និស្សត្តធម៌ គឺធម៌មានសភាពមិនមែនសត្វ ន័យក្នុងបទថា និជ្ជីវធម៌ គឺធម៌មិនមែនជីវិត ក៏ដូចគ្នា ។ ក្នុងធម៌ ៤ ប្រការនោះ និស្សត្តធម៌ ឬនិជ្ជីវធម៌ ព្រះសាស្ដាទ្រង់បំណងយកក្នុងទីនេះ ។ និស្សត្តធម៌ និងនិជ្ជីវធម៌នោះ ដោយអត្ថ បានដល់អរូបក្ខន្ធ ៣ គឺវេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ ។ ព្រោះថា អរូបក្ខន្ធ ៣ ប្រការនោះ មានចិត្តជាប្រធាន ។*

*មានពាក្យសួរថា ចិត្ត មានវត្ថុដូចគ្នា មានអារម្មណ៍តែមួយ កើតក្នុងខណៈតែមួយ ជាមួយធម៌ទាំងនោះ មិនមុនមិនក្រោយ តើជាប្រធានរបស់ធម៌ទាំងនោះបានដូចម្ដេច ។*

*មានពាក្យឆ្លើយថា ចិត្ត បានឈ្មោះថា ជាប្រធាននៃធម៌ទាំងនោះ ដោយ*

អត្ថថា ជាបច្ច័យញុំាងធម៌ឲ្យកើតឡើង ឧបមាដូចពួកចោរជាច្រើន ធ្វើចោរ-កម្ម មានប្លន់ស្រុកជាដើមទាំងអស់នេះ កាលមានបុគ្គលសួរថា អ្នកណាជាមេរបស់ពួកវា អ្នកណាជាបច្ច័យរបស់ពួកវា គឺអាស្រ័យអ្នកណា ទើបធ្វើកម្មនោះបាន បុគ្គលនោះ ឈ្មោះទត្តៈក្តី មត្តៈក្តី គេហៅថា ជាមេរបស់ចោរ យ៉ាងណា ពាក្យឧបមេយ្យដែលជាគ្រឿងឲ្យអត្ថដល់ព្រមនេះ បណ្ឌិតគប្បីដឹងច្បាស់ ដូច្នោះ ។ ចិត្ត ឈ្មោះថា ជាប្រធាននៃធម៌ទាំងឡាយនោះ ដោយអត្ថថា ជាបច្ច័យ ញុំាងធម៌ឲ្យកើតឡើង ដូច្នេះ ហេតុនោះ ធម៌ទាំងឡាយនោះ ឈ្មោះថា មានចិត្តជាប្រធាន ។ ព្រោះកាលចិត្តមិនកើតឡើង ធម៌ទាំងនោះរមែងមិនអាចកើតឡើងបាន ។ ចំណែកចិត្ត ទោះចេតសិកធម៌ពួកខ្លះមិនកើតឡើង ក៏រមែងកើតឡើងបានពិត ។ ម្យ៉ាងទៀត ចិត្ត ឈ្មោះថាជាធំនៃធម៌ទាំងឡាយនោះ ដោយអំណាចជាអធិបតិ ហេតុនោះ ទើបធម៌ទាំងឡាយនោះ ឈ្មោះថា មានចិត្តជាធំ ។ ឧបមាដូចជនទាំងឡាយ មានចោរដែលជាមេជាដើមជាអធិបតិ បានឈ្មោះថា ជាធំនៃជនទាំងឡាយ មានចោរជាដើម យ៉ាងណា ចិត្តជាអធិបតិបាន ឈ្មោះថា ជាធំនៃធម៌ទាំងនោះ ដូច្នោះ ។ ហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា មានចិត្តជាធំ ។ ម្យ៉ាងទៀត វត្ថុទាំងឡាយនោះៗ សម្រេចហើយដោយវត្ថុ មានឈើជាដើម ក៏ឈ្មោះថា របស់សម្រេចហើយ ដោយឈើជាដើម យ៉ាងណា សូម្បីធម៌ទាំងឡាយនោះ បានឈ្មោះថា សម្រេចហើយដោយចិត្ត ព្រោះសម្រេចមកអំពីចិត្ត ដូច្នោះ ។

បទថា **បទុដ្ឋេន** គឺដែលទោស មានអភិជ្ឈាជាដើម ចូលមកប្រទូស្ត

ហើយ ។ មែនពិត ចិត្តប្រក្រតី ឈ្មោះថា ភវង្គចិត្ត ភវង្គចិត្តនោះ មិនត្រូវទោសប្រទូស្តហើយ ។ ឧបមាដូចទឹកថ្លាសៅហ្មងហើយ ព្រោះពណ៌ទាំង-ឡាយ មានពណ៌ខៀវជាដើមចូលមក ក៏បែរជាទឹកមានពណ៌ខៀវជាដើម ឈ្មោះថា ជាទឹកថ្មីក៏មិនមែន ឈ្មោះថា ទឹកថ្លាដូចពីដើមនោះ ក៏មិនមែន យ៉ាងណា ភវង្គចិត្តនោះ ដែលទោសមានអភិជ្ឈាជាដើម ចូលមកប្រទូស្តហើយ ឈ្មោះថា ជាចិត្តថ្មីក៏មិនមែន ឈ្មោះថា ជាភវង្គចិត្តដូចពីមុននោះក៏មិនមែន ដូច្នោះ ហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចិត្តនេះផូរផង់ តែសៅហ្មងហើយ ព្រោះឧបក្កិលេសទាំងឡាយចូលមកហើយ ដូច្នេះ ។ បើបុគ្គលមានចិត្តប្រទូស្តហើយយ៉ាងនេះ ។

បាទព្រះគាថាថា **ភាសតិ វា ករោតិ វា** គឺកាលបុគ្គលពោល រមែងពោលចំពោះតែវចីទុច្ចរិត ៤ យ៉ាង ។ កាលធ្វើ រមែងធ្វើចំពោះតែកាយទុច្ចរិត ៣ យ៉ាង កាលមិនពោល មិនធ្វើ ព្រោះភាពដែលខ្លួនជាបុគ្គលមានចិត្តដែលទោស មានអភិជ្ឈាជាដើមប្រទូស្តហើយនោះ រមែងធ្វើមនោទុច្ចរិត ៣ ឲ្យពេញ ។ អកុសលកម្មបថ ១០ របស់បុគ្គលនោះ រមែងដល់នូវការពេញដោយប្រការយ៉ាងនេះ ។

បាទព្រះគាថាថា **តតោ នំ ទុក្ខមន្វេតិ** សេចក្តីថា ទុក្ខរមែងតាមបុគ្គលនោះទៅ ព្រោះទុច្ចរិត ៣ យ៉ាងនោះ គឺទុក្ខដែលជាផលប្រព្រឹត្តទៅក្នុងកាយផង ប្រព្រឹត្តទៅក្នុងចិត្តផង ដោយបរិយាយនេះថា ទុក្ខ មានកាយជាទីតាំងខ្លះ ទុក្ខ មានចិត្តក្រៅអំពីនេះជាទីតាំងខ្លះ រមែងទៅតាមអត្តភាពនោះ បុគ្គល

ទៅក្នុងអបាយ ៤ ក្តី ក្នុងពួកមនុស្សក្តី ព្រោះអានុភាពនៃទុច្ចរិត ។

មានពាក្យសួរថា ទុក្ខរមែងជាប់តាមបុគ្គលនោះដូចអ្វី ។ មានពាក្យឆ្លើយថា ដូចកង់វិលទៅតាមស្នាមជើងរបស់គោដែលអូសរទេះទៅ អធិប្បាយថា ដូចកង់រទេះទៅតាមស្នាមជើងរបស់គោដែលគេទឹមត្រង់នឹម ហើយនាំនឹមទៅ ដូច្នោះ ទោះគោនោះអូសទៅមួយថ្ងៃក្តី ពីរថ្ងៃក្តី ដប់ថ្ងៃក្តី កន្លះខែក្តី រមែងមិនអាចឲ្យកង់រទេះវិលត្រឡប់ គឺមិនអាចលះបង់កង់ទៅបានដោយពិត កាលគោឈានជើងទៅខាងមុខ នឹមក៏ជាប់ករបស់គោ កាលគោថយក្រោយ កង់ក៏កកិតត្រង់សាច់ស្មង កង់បៀតបៀនដោយហេតុពីរប្រការនេះ វិលតាមស្នាមជើងរបស់គោទៅ យ៉ាងណា ទុក្ខប្រព្រឹត្តទៅខាងផ្លូវកាយផង ផ្លូវចិត្តផង ដែលមានទុច្ចរិតជាមូល រមែងជាប់តាមបុគ្គលដែលមានចិត្តប្រទូស្តហើយ ធ្វើទុច្ចរិត ៣ ប្រការឲ្យពេញ តាំងនៅក្នុងទីដែលបុគ្គលនោះទៅហើយ មាននរកជាដើម ដូច្នោះឯង ។

ក្នុងកាលចប់គាថា ភិក្ខុ ៣ ពាន់រូប បានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ។ ទេសនាបានជាកថាមានប្រយោជន៍ មានផលដល់បរិស័ទដែលប្រជុំគ្នាហើយ ដូច្នេះឯង ។l៚

## រឿងចក្ខុបាលត្ថេរ ចប់

# រឿង មដ្ឋកុណ្ឌលី

## លំនាំដើម

ឯគាថាទី ២ មានពាក្យថា **មនោបុព្វង្គមា** ជាដើម ព្រះមានព្រះភាគទ្រង់ប្រារព្ធមដ្ឋកុណ្ឌលីមាណព ភាសិតហើយ ក្នុងក្រុងសាវត្ថីនោះឯង ។

បានឮមកថា ក្នុងក្រុងសាវត្ថីមានព្រាហ្មណ៍ម្នាក់ ឈ្មោះអទិន្នបុព្វកៈ គាត់មិនធ្លាប់ឲ្យរបស់ណាមួយដល់បុគ្គលណាម្នាក់ឡើយ ព្រោះដូច្នោះ ប្រជុំជនទើបដាក់ឈ្មោះឲ្យគាត់ថា អទិន្នបុព្វកៈ ។ គាត់មានកូនប្រុសម្នាក់ជាទីស្រឡាញ់ពេញចិត្ត ។ ក្រោយមក គាត់ចង់ធ្វើគ្រឿងប្រដាប់ឲ្យកូន គិតថា បើអញជួលជាងមាស ក៏ត្រូវឲ្យថ្លៃឈ្នួល ដូច្នេះហើយ ទើបផែមាសធ្វើឲ្យជាកុណ្ឌលរលោងៗ ស្រេចហើយ បានឲ្យដល់កូនរបស់ខ្លួន ។ ព្រោះដូច្នោះ ទើបកូនរបស់គាត់ ប្រាកដឈ្មោះថា មដ្ឋកុណ្ឌលី ។

ក្នុងកាលកូននោះអាយុបាន ១៦ ឆ្នាំ ក៏កើតរោគលឿង ។ មាតាក្រឡេកមើលបុត្រហើយ ទើបពោលនឹងព្រាហ្មណ៍ជាប្តីថា នែព្រាហ្មណ៍ រោគកើតឡើងដល់កូនរបស់អ្នក សូមអ្នករកគ្រូពេទ្យមកព្យាបាលចុះ ។

ព្រាហ្មណ៍ឆ្លើយថា នែនាង បើខ្ញុំរកពេទ្យមក យើងនឹងត្រូវឲ្យថ្លៃព្យាបាលដល់គេ នាងប្រហែលមិនមើលកាលអស់ទ្រព្យរបស់យើងទេ ។

ព្រាហ្មណីសួរថា បើយ៉ាងនេះ អ្នកនឹងធ្វើដូចម្តេច ។ ព្រាហ្មណ៍ឆ្លើយថា ទ្រព្យរបស់យើងមិនខាតបង់ទៅបាន យ៉ាងណា យើងនឹងធ្វើយ៉ាងនោះ ។

ព្រាហ្មណ៍នោះទៅកាន់សម្នាក់គ្រូពេទ្យទាំងឡាយហើយ សួរថា ពួកអ្នកដាក់ថ្នាំប្រភេទណាដល់បុគ្គលដែលមានរោគប្រភេទនោះ ។

លំដាប់នោះ ពួកគ្រូពេទ្យក៏ប្រាប់ថ្នាំដែលស្ទែងជាដើមដល់គាត់ គាត់ទៅយកឫសឈើជាដើមដែលពួកគ្រូពេទ្យប្រាប់នោះមកហើយ ធ្វើថ្នាំឲ្យដល់កូន ។ កាលព្រាហ្មណ៍ធ្វើយ៉ាងនោះឯង រោគក៏កម្រើកខ្លាំងឡើង រហូតដល់មិនមានអ្នកណាអាចព្យាបាលបាន ។ ព្រាហ្មណ៍ដឹងថា កូនទុព្វលភាពហើយ ទើបរកគ្រូពេទ្យម្នាក់មក គ្រូពេទ្យនោះមកពិនិត្យមើលហើយ ទើបពោលថា ខ្ញុំមានកិច្ចខ្លះ ដែលត្រូវធ្វើ អ្នកចូររកមនុស្សដទៃមកព្យាបាលចុះ ដូច្នេះហើយ មិនព្យាបាល លាព្រាហ្មណ៍ត្រឡប់ទៅ ។

ព្រាហ្មណ៍ដឹងកាលថា កូនជិតស្លាប់ហើយ គិតថាពួកជនដែលមកហើយដើម្បីប្រយោជន៍សួរសុខទុក្ខកូននេះ នឹងឃើញទ្រព្យសម្បត្តិក្នុងផ្ទះ អញនឹងយកកូនអញទៅខាងក្រៅ ដូច្នេះហើយ ទើបនាំយកកូនចេញមកឲ្យដេកត្រង់យ៉មុខខាងក្រៅ ។

ក្នុងពេលបច្ចូសសម័យថ្ងៃជិតរះ ព្រះមានព្រះភាគចេញអំពីមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ កាលទតឃើញពួកសត្វដែលជាផៅពង្សល្មមទ្រង់ទូន្មានបាន ដែលមានកុសលមូលក្រាស់ហើយ មានសេចក្ដីប្រាថ្នាបានធ្វើហើយ ក្នុងព្រះពុទ្ធទាំងឡាយ អំពីកាលមុន ទ្រង់បានផ្សាយសំណាញ់ គឺព្រះញាណទៅក្នុងម៉ឺនចក្រវាល ។ មដ្ឋកុណ្ឌលីមាណពប្រាកដហើយក្នុងសំណាញ់ញាណនោះ ដោយអាការដែលដេកត្រង់យ៉មុខខាងក្រៅនោះ ។

ព្រះសាស្ដាទ្រង់ទតឃើញហើយ ទ្រង់ជ្រាបថា ព្រាហ្មណ៍ដែលជាបិតា

នាំមដ្ឋកុណ្ឌលីចេញមកខាងក្រៅផ្ទះហើយ ឲ្យដេកក្នុងទីនោះ ទ្រង់ត្រិះរិះថា នឹងមានប្រយោជន៍ខ្លះឬហ្ន៎ ដោយបច្ច័យដែលតថាគតទៅក្នុងទីនោះ លុះទ្រង់ប្រមើលមើល ក៏បានឃើញហេតុនេះថា មាណពនេះនឹងធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត ធ្វើកាលកិរិយាហើយ នឹងកើតក្នុងវិមានមាសកម្ពស់ ៣០ យោជន៍ក្នុងស្ថានតាវត្តិង្សទេវលោក មានស្រីទេពអប្សរជាបរិវារ ១ ពាន់ ។ ចំណែកព្រាហ្មណ៍នឹងធ្វើឈាបនសរីរៈនោះ ទ្រហោយំក្នុងទីបច្ឆា ។ ទេវបុត្រនឹងសម្លឹងមើលអត្តភាពខ្លួន ដែលមានកម្ពស់ប្រមាណ ៣ គាវុត តាក់តែងដោយគ្រឿងអលង្ការ ទម្ងន់ ៦០ រទេះ មានស្រីទេពអប្សរជាបរិវារ ១ ពាន់ គិតថា សិរីសម្បត្តិនេះ អញបានដោយកម្មអ្វីហ្ន៎ ដូច្នេះហើយ ក៏បានជ្រាបថា បានដោយចិត្តជ្រះថ្លាក្នុងតថាគត គិតថា បិតាមិនរកគ្រូពេទ្យមកព្យាបាលឲ្យអញ ព្រោះខ្លាចទ្រព្យអស់ទៅ ឥឡូវនេះ ទៅកាន់ឈាបនដ្ឋានទ្រហោយំ អញនឹងធ្វើបិតាឲ្យដល់នូវអាការចម្លែកដូច្នេះ ដោយអាក់អន់ក្នុងបិតា ទើបកាឡាខ្លួនដូចមដ្ឋកុណ្ឌលីមាណព មកដេកយំក្នុងទីជិតឈាបនដ្ឋាននោះ ។ ពេលនោះព្រាហ្មណ៍នឹងសួរថា អ្នកជានរណា ទេវបុត្រនោះនឹងឆ្លើយថា ខ្ញុំជាមដ្ឋកុណ្ឌលីមាណពជាកូនរបស់អ្នក ព្រាហ្មណ៍ពោលថា អ្នកទៅកើតក្នុងទីណា ទេវបុត្រពោលថា ក្នុងតាវត្តិង្សពិភព ។ កាលព្រាហ្មណ៍សួរថា ព្រោះធ្វើកម្មដូចម្តេច ទេវបុត្រនឹងប្រាប់ថា ខ្ញុំកើតព្រោះចិត្តជ្រះថ្លាក្នុងព្រះតថាគត ។ ព្រាហ្មណ៍នឹងសួរតថាគតថា ឈ្មោះថា ការធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គប៉ុណ្ណោះហើយ ទៅកើតក្នុងស្ថានសួគ៌មានឬ ពេលនោះ តថាគតនឹងប្រាប់ព្រាហ្មណ៍នោះថា មិន

មានអ្នកណាអាចកំណត់ ដោយការរាប់បានថា មានប្រមាណប៉ុណ្ណោះរយ ប៉ុណ្ណោះពាន់ ឬប៉ុណ្ណោះសែនបានឡើយ ដូច្នេះហើយ នឹងកាសិតគាថាក្នុងធម្មបទ ។ ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌នឹងមានដល់សត្វប្រមាណ ៨ ម៉ឺន ៤ ពាន់ ។ មដ្ឋកុណ្ឌលីទេវបុត្រ នឹងបានជាព្រះសោតាបន្ន សូម្បីអទិន្នបុព្វកព្រាហ្មណ៍ក៏ដូចគ្នា ។ អាស្រ័យកុលបុត្រនេះ ការបូជាធម៌ដ៏ច្រើននឹងមានដោយប្រការដូច្នេះ លុះថ្ងៃស្អែកឡើង ទ្រង់ធ្វើកិច្ចបដិបត្តិព្រះសរីរៈស្រេចហើយ ដែលមហាភិក្ខុសង្ឃចោមរោមហើយ ទ្រង់យាងចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត យាងដល់ទ្វារផ្ទះរបស់ព្រាហ្មណ៍ដោយលំដាប់ ។

ក្នុងខណៈនោះ មដ្ឋកុណ្ឌលីមាណពកំពុងដេកបែរមុខទៅឯក្នុងផ្ទះ ។ ព្រះសាស្ដាទ្រង់ជ្រាបថា មិនឃើញព្រះអង្គ ទើបទ្រង់បញ្ចេញព្រះរស្មីប្រមាណមួយព្យាម ។ មាណពគិតថា នេះពន្លឺអ្វីហ្ន៎ ទើបប្រែខ្លួនត្រឡប់មកឃើញព្រះសាស្ដាហើយគិតថា អញអាស្រ័យបិតាដែលជាបុគ្គលពាល ទើបមិនបានចូលទៅគាល់ព្រះពុទ្ធដែលមានសភាពបែបនេះ ហើយធ្វើសេចក្ដីខ្វល់ខ្វាយដោយកាយក្ដី ថ្វាយទានក្ដី ស្ដាប់ធម៌ក្ដី ។ ឥឡូវនេះ សូម្បីតែដៃទាំងពីររបស់អញក៏លើកសំពះមិនបាន កិច្ចដែលគួរធ្វើដទៃមិនមាន ដូច្នេះហើយ បានធ្វើចិត្តប៉ុណ្ណោះឲ្យជ្រះថ្លា ។

ព្រះសាស្ដាទ្រង់ព្រះតម្រិះរិះថា ដោយការដែលមាណពនេះ ធ្វើចិត្តឲ្យជ្រះថ្លាប្រមាណប៉ុណ្ណោះក៏ល្មម ហើយទ្រង់យាងចៀសចេញទៅ ។ កាលព្រះតថាគតបាត់អំពីក្រសែភ្នែកទៅ មាណពនោះក៏មានចិត្តជ្រះថ្លា ធ្វើកាល-

កិរិយាហើយ ហាក់ដូចជាដេកលក់ហើយភ្ញាក់ឡើង ទៅកើតក្នុងវិមានមាស កម្ពស់ ៣០ យោជន៍ ក្នុងទេវលោក ។

ចំណែកព្រាហ្មណ៍ ធ្វើឈាបនកិច្ចសរីរៈមាណពនោះហើយ មានតែការទ្រហោយំប្រព្រឹត្តខាងមុខ ក្នុងទីប៉ាធាពល់ៗ ថ្ងៃ យំបណ្ដើររៀបរាប់បណ្ដើរថា កូនតែមួយរបស់ឪពុក កូននៅទីណា កូនតែមួយរបស់ឪពុក កូននៅទីណា ។

ទេវបុត្រសម្លឹងមើលសម្បត្តិរបស់ខ្លួនហើយ គិតថា សម្បត្តិនេះអញបានដោយកម្មអ្វីហ្ន៎ កាលពិចារណាក៏បានដឹងថា បានដោយចិត្តជ្រះថ្លាក្នុងព្រះសាស្ដាដូច្នេះហើយ ទើបគិតតទៅថា ព្រាហ្មណ៍នេះ ក្នុងកាលអញមានជំងឺមិនបានរកគ្រូពេទ្យមកព្យាបាលឡើយ ឥឡូវនេះ បែរជាទៅព្រៃខ្មោចទ្រហោយំ អញគួរធ្វើគាត់ឲ្យដល់នូវប្រការដ៏ចម្លែក ដូច្នេះហើយ ទើបកាឡាខ្លួនដូចមដ្ឋកុណ្ឌលីមាណពមកហើយ បានផ្គងដើមដៃទ្រហោយំក្នុងទីមិនឆ្ងាយអំពីទីប៉ាធា ។

ព្រាហ្មណ៍ឃើញទេវនិមិត្តនោះហើយ ទើបគិតថា អញយំព្រោះសោយសោកដល់កូន ចុះមាណពនេះយំត្រូវការអ្វីហ្ន៎ អញនឹងសួរគេមើល ដូច្នេះហើយ កាលនឹងសួរ ទើបពោលគាថានេះថា

> អ្នកមានខ្លួនប្រដាប់ហើយ មានកុណ្ឌលរលើង ទ្រទ្រង់នូវកម្រងផ្កា មានខ្លួនប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដើមដៃកន្ទក់កន្ទេញក្នុងកណ្ដាលព្រៃស្មសាន តើអ្នកដល់នូវសេចក្ដីទុក្ខដូចម្ដេច ។ មាណពពោលថា រាងរថ ជាវិការនៃមាស

មានសេចក្ដីផ្ទេក កើតឡើងដល់ខ្ញុំ បើខ្ញុំមិនបានទូវគូនៃកង់
របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្ដីទុក្ខនោះ ។
ពេលនោះ ព្រាហ្មណ៍បានពោលនឹងមាណពថា ម្នាលមាណព
ដ៏ចម្រើន អ្នកចូរប្រាប់ ( នូវគូនៃកង់ ) មាស ឬកែវមណី
កែវទទឹម ឬប្រាក់ដល់ខ្ញុំៗ នឹងញ៉ាំងអ្នកឲ្យបាននូវគូនៃកង់
( នោះ ) ។

មាណពនោះបានស្ដាប់ពាក្យនោះ គិតថា ព្រាហ្មណ៍នេះ មិនធ្វើថ្នាំឲ្យដល់កូន កាលឃើញអញមានរូបរាងដូចកូន ក៏ទ្រហោយំ ពោលថា ខ្ញុំនឹងធ្វើកង់រថ ដែលធ្វើដោយមាសជាដើមឲ្យ ណ្ហើយចុះ អញនឹងក្លែងពោលលែងដល់ព្រាហ្មណ៍នេះ ដូច្នេះហើយ ទើបពោលថា អ្នកធ្វើគូនៃកង់ឲ្យដល់ខ្ញុំធំប៉ុនណា កាលព្រាហ្មណ៍នោះពោលថា អ្នកត្រូវការធំប៉ុនណា ទើបប្រាប់ថា

ខ្ញុំត្រូវការដោយព្រះចន្ទ និងព្រះអាទិត្យទាំងពីរវង់ ប្រាកដក្នុង
ដ៏អាកាស នុ៎ះរថរបស់ខ្ញុំ ជាវិការនៃមាស សមដោយព្រះ
អាទិត្យ និងព្រះចន្ទនោះ ជាគូនៃកង់ ។

លំដាប់នោះ ព្រាហ្មណ៍ ពោលថា

ម្នាលមាណព អ្នកណាប្រាថ្នា នូវរបស់ដែលមិនគួរប្រាថ្នា
អ្នកនោះចំជាល្ងង់មែន ខ្ញុំសម្គាល់ថា អ្នកនឹងស្លាប់ អ្នកពិតជា
មិនបានព្រះចន្ទ និងព្រះអាទិត្យឡើយ ។

លំដាប់នោះ ទើបមាណពពោលនឹងព្រាហ្មណ៍នោះថា បុគ្គលដែល

ទ្រហោយំ ចង់បាននូវវត្ថុដែលប្រាកដ ជាបុគ្គលល្ងង់ ឬបុគ្គលដែលទ្រហោយំ ចង់បានវត្ថុដែលមិនប្រាកដ ជាបុគ្គលល្ងង់ ដូច្នេះហើយ ទើបពោលគាថានេះថា

ការចរទៅ និងចរមក ( នៃព្រះចន្ទ និងព្រះអាទិត្យទាំងពីរ ) ក្តី វណ្ណធាតុ ( ការទ្រទ្រង់នៃរស្មី ) ក្តី រមែងប្រាកដក្នុងវិថីទាំងពីរ បុគ្គលអ្នកធ្វើមរណកាល ទៅកាន់លោកខាងមុខ រមែងមិនប្រាកដឡើយ បណ្តាយើងទាំងពីរ ជាអ្នកកំពុងកន្ទក់កន្ទេញក្នុងទីនេះ តើអ្នកណាល្ងង់ជាង ។

ព្រាហ្មណ៍ស្តាប់ពាក្យនោះហើយ កំណត់បានថា មាណពនេះនិយាយត្រូវ ទើបពោលថា

ម្នាលមាណព អ្នកនិយាយចំជាពិតមែនហើយ បណ្តាយើងទាំងពីរនាក់ ជាអ្នកកំពុងកន្ទក់កន្ទេញ ខ្ញុំឯងជាបុគ្គលល្ងង់ជាង ( ព្រោះ ) ខ្ញុំប្រាថ្នានូវកូនប្រុសដែលធ្វើមរណកាលទៅកាន់លោកខាងមុខហើយ ដូចជាទារកយំទារ នូវព្រះចន្ទដូច្នោះដែរ ។

ដូច្នេះហើយ ជាអ្នកប្រាសចាកសេចក្តីសោក ព្រោះពាក្យរបស់មាណពនោះ កាលធ្វើការសរសើរមាពណា បានពោលគាថាទាំងនេះថា

អ្នកបានស្រោចស្រពនូវខ្ញុំ ដែលក្តៅ គឺសេចក្តីសោកកំពុងឆេះសព្វ ឲ្យស្ងប់រម្ងាប់ ញុំាំងសេចក្តីក្រវល់ក្រវាយទាំងពួង

ឲ្យរលត់បាន ដូចបុគ្គលយកទឹកស្រោចភ្លើង កំពុងឆេះនូវផ្ទាំងខ្លាញ់ អ្នកណាបានបន្ទោបង់នូវសេចក្ដីសោក ព្រោះកូនចំពោះខ្ញុំដែលមានសោក កំពុងគ្របសង្កត់ អ្នកនោះ ឈ្មោះថា បានដកនូវកូនសរ គឺសេចក្ដីសោក ដែលអាស្រ័យនូវហឫទ័យរបស់ខ្ញុំ ខ្ញុំនោះ ជាអ្នកមានកូនសរ គឺសេចក្ដីសោកដកហើយ ខ្ញុំជាអ្នកមានចិត្តត្រជាក់ហើយ មានទុក្ខរលត់ហើយ ម្នាលមាណព ខ្ញុំលែងសោកស្ដាយ លែងយំទួញហើយ ព្រោះបានស្ដាប់នូវពាក្យរបស់អ្នក ។

ខណៈនោះព្រាហ្មណ៍ កាលសួរថាអ្នកឈ្មោះអ្វី ទើបពោលថា

អ្នកជាទេវតាឬ ឬជាគន្ធព្វ ឬមួយជាព្រះឥន្ទ្រ បានបំពេញទានក្នុងកាលមុន អ្នកជាអ្វី ជាកូនរបស់អ្នកណា យើងនឹងស្គាល់អ្នក ដូចម្ដេចបាន ។

លំដាប់នោះ មាណពប្រាប់ដល់ព្រាហ្មណ៍ថា

អ្នកបានដុតកូនណា ដោយខ្លួនឯងក្នុងទីបូជាសព ( ឈាប-នដ្ឋាន ) ហើយកន្ទក់កន្ទេញផង យំទួញផង កូននោះ គឺខ្ញុំហ្នឹងឯង ធ្វើនូវកុសលកម្ម បានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។

ព្រាហ្មណ៍បានពោលថា

កាលអ្នកឲ្យទានតិច ឬច្រើនក្នុងផ្ទះ របស់ខ្លួនក្ដី ឬក៏រក្សានូវ

ឱបោសថកម្ម ប្រាកដដូច្នោះក្តី ខ្ញុំមិនបានឃើញអ្នកទៅកាន់ទេវលោក តើដោយបុណ្យអ្វី ។

មាណពបានពោលថា

ខ្ញុំជាអ្នកមានអាពាធ ឈឺធ្ងន់ ដល់នូវសេចក្តីទុក្ខ មានរូបក្តៅក្រហាយជានិច្ច ក្នុងផ្ទះរបស់ខ្លួន ខ្ញុំបានឃើញព្រះពុទ្ធ ព្រះអង្គមានធូលី គឺកិលេសទៅប្រាសហើយ មានសេចក្តីសង្ស័យធ្លងផុតហើយ មានដំណើរល្អ មានបញ្ញាមិនថយថោក ខ្ញុំនោះមានចិត្តរីករាយ ជ្រះថ្លា បានធ្វើអញ្ជលី ចំពោះព្រះតថាគត លុះខ្ញុំបានធ្វើកុសលកម្មនោះហើយ ក៏បានទៅកើតជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។

កាលមាណពនោះ កំពុងពោលទូន្មាននោះឯង សរីរៈទាំងមូលរបស់ព្រាហ្មណ៍ ក៏ពេញហើយដោយបីតិ ។ កាលគាត់ប្រកាស់នូវបីតិនោះ ទើបពោលថា

អើហ្ន៎ អស្ចារ្យណាស់ ចម្លែកណាស់ ផលនៃអញ្ជលិកម្មដល់ម្ល៉េះតើ អើ ខ្ញុំក៏មានចិត្តរីករាយ មានចិត្តជ្រះថ្លាដែរ សូមដល់នូវព្រះពុទ្ធជាទីរឭក ក្នុងថ្ងៃនេះឯង ។

លំដាប់នោះ មាណពបានពោលទូន្មានថា

អ្នកចូរមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីរឭក ក្នុងថ្ងៃនេះចុះ អ្នកចូរសមាទាននូវ

សិក្ខាបទទាំង ៥ កុំឲ្យដាច់ កុំឲ្យធ្លុះធ្លាយដូច្នោះចុះ ចូរវៀរចាកការសម្លាប់សត្វយ៉ាងឆាប់ផង ចូរវៀរបង់នូវការកាន់យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោកផង កុំផឹកនូវទឹកស្រវឹងផង កុំពោលនូវពាក្យកុហកផង ចូរជាអ្នកសន្តោស ដោយប្រពន្ធរបស់ខ្លួនផង ។

ព្រាហ្មណ៍ទទួលថា សាធុ ហើយបានពោលនូវគាថាទាំងនេះថា

បពិត្រអ្នកដែលគេគប្បីបូជា អ្នកប្រាថ្នានូវសេចក្តីចម្រើនដល់ខ្ញុំ បពិត្រទេវតា អ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីរឭកផង សូមដល់នូវព្រះធម៌ ជាទីរឭកផង សូមដល់នូវព្រះសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់ជន និងទេវតាជាទីរឭកផង ខ្ញុំវៀរចាកការសម្លាប់សត្វ យ៉ាងឆាប់ផង វៀរបង់នូវការកាន់យកទ្រព្យ ដែលគេមិនបានឲ្យក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង សន្តោសដោយប្រពន្ធរបស់ខ្លួនផង ។

លំដាប់នោះ ទេវបុត្រពោលថា នែព្រាហ្មណ៍ ទ្រព្យក្នុងផ្ទះរបស់អ្នកមានច្រើន ចូរអ្នកទៅគាល់ព្រះសាស្តា ហើយថ្វាយទាន ចូរស្តាប់ធម៌ ចូរសួរនូវបញ្ហា ដូច្នេះហើយ ក៏អន្តរធានទៅក្នុងទីនោះឯង ។

ចំណែកព្រាហ្មណ៍ទៅផ្ទះហើយ ហៅព្រាហ្មណីមកពោលថា នែនាងដ៏

ចម្រើន ខ្ញុំនឹងនិមន្តព្រះសមណគោតម ហើយទូលសួរបញ្ហា ចូរនាងធ្វើសក្ការៈ ដូច្នេះហើយ ទៅកាន់វិហារ មិនថ្វាយបង្គំព្រះសាស្តា មិនធ្វើបដិសណ្ឋារៈ ឈរក្នុងទីម្ខាង ហើយក្រាបទូលថា បពិត្រព្រះគោតម សូមទ្រង់មួយអន្ទើ ដោយភិក្ខុសង្ឃ ទទួលភត្តាហារនៃខ្ញុំ ដើម្បីសោយក្នុងថ្ងៃនេះ ។

ព្រះសាស្តាទ្រង់ទទួលហើយ ។ គាត់បានជ្រាបថា ព្រះសាស្តាទ្រង់ទទួលហើយ ទើបមកដោយរហ័ស ប្រើមនុស្សឲ្យរៀបចំខាទនីយភោជនីយាហារក្នុងផ្ទះរបស់ខ្លួន ។ ព្រះសាស្តា មានភិក្ខុសង្ឃចោមរោមហើយ យាងទៅកាន់ផ្ទះនៃព្រាហ្មណ៍នោះ ប្រថាប់គង់លើអាសនៈដែលគេតាក់តែង ។ ព្រាហ្មណ៍អង្គាសហើយដោយគោរព ។

មហាជនប្រជុំគ្នា ។ បានឮថា កាលព្រះតថាគតដែលព្រាហ្មណ៍មិច្ឆាទិដ្ឋិនិមន្តហើយ ។ ពួកជនពីរពួកមកប្រជុំគ្នា គឺពួកជនដែលជាមិច្ឆាទិដ្ឋិប្រជុំគ្នាដោយតាំងចិត្តថា ថ្ងៃនេះ ពួកយើងនឹងឃ្មាំមើលព្រះសមណគោតមដែលត្រូវព្រាហ្មណ៍បៀតបៀន ដោយសួរបញ្ហា ។ ពួកជនដែលជាសម្មាទិដ្ឋិក៏ប្រជុំគ្នាដោយតាំងចិត្តថា ថ្ងៃនេះ ពួកយើងនឹងចាំមើលពុទ្ធវិស័យ និងពុទ្ធលីលា ។

លំដាប់នោះ ព្រាហ្មណ៍ចូលទៅគាល់ព្រះតថាគត ដែលទ្រង់ធ្វើភត្តកិច្ចស្រេចហើយ អង្គុយលើអាសនៈទាប បានទូលសួរបញ្ហាថា បពិត្រព្រះគោតម ឈ្មោះថាពួកជនដែលមិនបានថ្វាយទានដល់ព្រះអង្គ មិនបានបូជាព្រះអង្គ មិនបានស្តាប់ធម៌ មិនបានរក្សាឧបោសថ បានទៅកើតក្នុងឋានសួគ៌ដោយគ្រាន់តែមានចិត្តជ្រះថ្លាតែម្យ៉ាងប៉ុណ្ណោះមានឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍

ហេតុអ្វី អ្នកសួរតថាគត ភាពដែលបុគ្គលធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតហើយ កើតក្នុងឋានសួគ៌ ដែលមដ្ឋកុណ្ឌលីជាកូនរបស់អ្នក ប្រាប់ដល់អ្នកហើយមិនមែនឬ ព្រាហ្មណ៍ពោលថា ប្រាប់ក្នុងកាលណាព្រះគោតមដ៏ចម្រើន ព្រះសាស្ដាត្រាស់ថា ថ្ងៃនេះ អ្នកទៅកាន់ឈាបនដ្ឋាន យំខ្សឹកខ្សួល ឃើញមាណពម្នាក់ផ្គងដើមដៃកន្ទក់កន្ទេញក្នុងទីមិនឆ្ងាយហើយសួរថា

អ្នកមានខ្លួនប្រដាប់ហើយមាន កុណ្ឌលរលីង ទ្រទ្រង់នូវ
កម្រងផ្កា មានខ្លួនប្រោះព្រំដោយខ្លឹម ចន្ទន៍ក្រហម ...
ដូច្នេះជាដើម មិនមែនឬ ។

កាលទ្រង់ប្រកាសពាក្យដែលជនទាំងពីរសន្ទនាគ្នាហើយ បានត្រាស់រឿងមដ្ឋកុណ្ឌលីទាំងអស់ ។ ព្រោះដូច្នេះឯង ទើបរឿងមដ្ឋកុណ្ឌលីនោះ បានឈ្មោះថា ជាពុទ្ធភាសិត ។ កាលព្រះសាស្ដាត្រាស់រឿងមដ្ឋកុណ្ឌលីនោះហើយ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ មិនថា មានត្រឹមតែមួយរយ ឬពីររយ ដោយពិត ការដែលរាប់សត្វ ដែលធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតហើយកើតក្នុងឋានសួគ៌ រមែងមិនមាន ។ មហាជនក៏កើតសេចក្ដីសង្ស័យហើយ ។

លំដាប់នោះ ព្រះសាស្ដាទ្រង់ជ្រាបភាពដែលមហាជននោះមិនអស់សេចក្ដីសង្ស័យ ទ្រង់បានអធិដ្ឋានថា មដ្ឋកុណ្ឌលីទេវបុត្រ ចូរមកមួយអន្លើដោយវិមាននោះឯង ។ ទេវបុត្រមានអត្តភាពដែលប្រដាប់តាក់តែងហើយ ដោយគ្រឿងអករណៈទិព្វ កម្ពស់ប្រមាណ ៣ គាវុធមកហើយ ចុះអំពីវិមានថ្វាយបង្គំព្រះសាស្ដាហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាកាលត្រាស់សួរទេវបុត្រថា អ្នកធ្វើកម្មដូចម្តេច ទើបបាននូវសម្បត្តិនេះ បានត្រាស់ព្រះគាថាថា

ម្នាលទេវតា អ្នកមានសម្បុរដ៏រុងរឿង ញុំាងទិសទាំងពួង

ឲ្យភ្លឺ ដូចផ្កាយព្រឹក ... តថាគតសូមសួរអ្នក អ្នកកាលកើត

ជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច ។

ទេវបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សម្បត្តិនេះ ខ្ញុំព្រះអង្គ បានហើយ ព្រោះធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា សម្បត្តិនេះ អ្នកបានហើយ ព្រោះធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគតឬ ទេវបុត្រពោលថា ព្រះករុណា ព្រះអង្គ ។

មហាជនសម្លឹងមើលទេវបុត្រហើយ បានប្រកាសសេចក្តីត្រេកអរថា នៃបា ពុទ្ធគុណគួរអស្ចារ្យពិតហ្ន៎ កូនរបស់អទិន្នបុព្វកព្រាហ្មណ៍ មិនបានធ្វើបុណ្យណាមួយដទៃឡើយ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះសាស្តាហើយ បានសម្បត្តិបែបនេះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ដល់ជនទាំងនោះថា ក្នុងការធ្វើកម្មដែលជាកុសល និងអកុសល ចិត្តជាប្រធាន ចិត្តជាធំ ។ ព្រោះថា កម្មដែលធ្វើដោយចិត្តដែលជ្រះថ្លាហើយ រមែងមិនលះបុគ្គលដែលទៅកាន់ទេវលោក មនុស្សលោក ដូចស្រមោល ដូច្នោះ ។ កាលត្រាស់រឿងនេះហើយ ព្រះធម្មរាជាបានត្រាស់ព្រះគាថានេះ បន្តអនុសន្ធិ ដូចប្រថាប់ព្រះរាជសាសន៍ហើយ ដោយព្រះរាជលញ្ចករថា

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**

**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**

**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

*ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី ( នូវសុចរិត ) ព្រោះសុចរិតទាំងនោះ សុខ រមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។*

## សេចក្តីអធិប្បាយ

*ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ហៅថា ចិត្ត ក្នុងព្រះគាថានោះក៏ពិត ដោយមិនប្លែកគ្នា តែកាលនិយម ប៉ាន់ស្មាន កំណត់ក្នុងបទនេះ រមែងបានដល់ចិត្តជាកាមាវចរកុសល ៨ ដួង កាលពោលដោយអំណាចវត្ថុ រមែងបានដល់ចិត្តដែលប្រកបដោយញាណ ប្រព្រឹត្តទៅមួយអន្លើដោយសោមនស្ស អំពីកាមាវចរកុសលចិត្ត ៤ ដួងប៉ុណ្ណោះ ។*

*បទថា* **បុព្វង្គមា** *សេចក្តីថា ប្រកបជាមួយចិត្តដែលជាអ្នកទៅមុននោះ ។ ខន្ធ ៣ មានវេទនាជាដើម ឈ្មោះថា ធម៌ ។ មែនហើយ ចិត្តជាប្រធានរបស់អរូបក្ខន្ធទាំង ៣ មានវេទនាក្ខន្ធជាដើម ដោយអត្ថ គឺជាបច្ច័យឲ្យកើតឡើង ហេតុនោះ ទើបខន្ធទាំង ៣ ប្រការនោះ ឈ្មោះថា មានចិត្តជាប្រធាន ឧបមាដូចកាលទាយកជាច្រើន កំពុងធ្វើបុណ្យ មានប្រគេនបាត្រ និងចីវរជាដើមដល់មហាភិក្ខុសង្ឃក្តី មានបូជាដ៏ក្រៃលែង និងស្តាប់ធម៌ អុជប្រទីប និង*

*ធ្វើសក្ការៈដោយកម្រងផ្កាជាដើមក្ដីជាមួយគ្នា កាលមានបុគ្គលពោលថា អ្នកណាជាប្រធាននៃទាយកទាំងនោះ ទាយកណាជាបច្ច័យរបស់ពួកជនទាំងនោះ គឺពួកជនទាំងនោះ អាស្រ័យទាយកណា ទើបធ្វើបុណ្យទាំងនោះបាន ទាយកនោះ ឈ្មោះតិស្សៈក្ដី ឈ្មោះបុស្សៈក្ដី ប្រជុំជនរមែងហៅថា ជាប្រធានរបស់ពួកគេ យ៉ាងណា ពាក្យឧបមេយ្យដែលជាគ្រឿងឲ្យកើតអត្ថ គឺការដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។ ចិត្ត ឈ្មោះថា ជាប្រធាននៃធម៌ទាំងនេះ ដោយអត្ថថា ជាបច្ច័យឲ្យកើតឡើង ដោយប្រការដូច្នេះ ហេតុនោះ ទើបធម៌ទាំងនេះ ឈ្មោះថា មានចិត្តជាប្រធាន ។ ពិតហើយ ធម៌ទាំងនោះ កាលចិត្តមិនកើតឡើង រមែងមិនអាចកើតឡើងបាន ចំណែកចិត្ត កាលចេតសិកពួកខ្លះមិនកើតឡើង ក៏កើតឡើងបាន ។ ចិត្ត ឈ្មោះថា ជាធំជាងធម៌ទាំងនេះ ដោយអំណាចជាអធិបតី ព្រោះដូច្នោះ ទើបធម៌ទាំងនេះ ឈ្មោះថា មានចិត្តជាធំ ។ម្យ៉ាងទៀត វត្ថុទាំងឡាយនោះៗ សម្រេចហើយដោយវត្ថុ មានមាសជាដើម ក៏ឈ្មោះថា សម្រេចហើយដោយមាសជាដើម យ៉ាងណា សូម្បីធម៌ទាំងឡាយនោះ ក៏បានឈ្មោះថា សម្រេចហើយដោយចិត្ត ព្រោះជារបស់សម្រេចមកអំពីចិត្ត ដូច្នោះ ។*

*បទថា* **បសន្នេន** *សេចក្ដីថា ផូរផង់ហើយ ដោយគុណទាំងឡាយ មានការមិនសម្លឹង ( ទោស ) ជាដើម ។*

*ពីរបទថា* **ភាសតិ វា ករោតិ វា** *សេចក្ដីថា បុគ្គលមានចិត្តបែបនេះ កាលនឹងពោល រមែងពោលតែវចីសុចរិត ៤ យ៉ាង កាលធ្វើ រមែងធ្វើតែ*

កាយសុចរិត ៣ យ៉ាង កាលមិនពោល កាលមិនធ្វើ រមែងធ្វើតែមនោ-សុចរិត ៣ យ៉ាងឲ្យពេញបរិបូណ៌ ព្រោះភាពដែលខ្លួនជាអ្នកមានចិត្តផូរផង់ ហើយដោយគុណទាំងឡាយ មានការមិនសម្លឹងជាដើមនោះ ។ កុសលកម្ម-បថ ១០ របស់បុគ្គលនោះ រមែងដល់នូវការបរិបូណ៌ ដោយប្រការយ៉ាងនេះ ។

បាទព្រះគាថាថា **តតោ នំ សុខមន្វេតិ** សេចក្ដីថា សេចក្ដីសុខ រមែងតាមបុគ្គលនោះទៅ ព្រោះសុចរិត ៣ យ៉ាងនោះ ។ កុសលទាំង ៣ ភូមិ ព្រះដ៏មានព្រះភាគទ្រង់បំណងយកហើយក្នុងទីនេះ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអធិប្បាយថា សេចក្ដីសុខដែលជាផល ដែលប្រព្រឹត្តទៅក្នុងកាយនិងប្រព្រឹត្តទៅក្នុងចិត្តដោយបរិយាយនេះថា សេចក្ដីសុខមានកាយជាទីតាំងខ្លះ សេចក្ដីសុខមានចិត្តជាទីតាំងខ្លះ រមែងតាមទៅ គឺរមែងមិនលះបុគ្គលនោះដែលកើតហើយក្នុងសុគតិកពក្ដី តាំងនៅហើយក្នុងទីសោយសុខក្នុងសុគតិក្ដី ព្រោះអានុភាពនៃសុចរិត ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ មានពាក្យសួរជ្រៀតចូលមកថា សេចក្ដីនេះដូចអ្វី ឆ្លើយថា ដូចស្រមោលមានប្រក្រតីទៅតាមខ្លួន អធិប្បាយថា ធម្មតាស្រមោល ជារបស់ជាប់នឹងសរីរៈ កាលសរីរៈដើរ ស្រមោលក៏ដើរទៅ កាលសរីរៈឈប់ ស្រមោលក៏ឈប់ ។ កាលសរីរៈអង្គុយ ស្រមោលក៏អង្គុយ ។ មិនមានបុគ្គលណាអាចពោលជាមួយស្រមោលដោយពាក្យដែលល្អិតក្ដី ដោយពាក្យដែលគ្រោតគ្រាតក្ដីថា អ្នកចូរត្រឡប់ទៅ ឬដេញវាយហើយ ទើបឲ្យត្រឡប់បាននោះឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះវាជារបស់ជាប់នឹងសរីរៈ យ៉ាងណា សេចក្ដីសុខដែលប្រព្រឹត្ត

*ទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្ត មានសុខ ដោយកាមាវចរសុខជាដើម មានកុសលនៃកុសលកម្មបថ ១០ នេះ ដែលបុគ្គលប្រព្រឹត្តច្រើនហើយ និងប្រព្រឹត្តល្អហើយជាប្ញសគាល់ រមែងមិនលះបង់បុគ្គលនោះ ក្នុងទីដែលបុគ្គលនោះទៅហើយ ដូចស្រមោល អន្ទោលទៅតាមប្រាណ ដូច្នោះឯង ។*

*ក្នុងកាលចប់គាថា ការត្រាស់ដឹងធម៌មានហើយដល់សត្វ ៨ ម៉ឺន ៤ ពាន់ ។ មដ្ឋកុណ្ឌលីទេវបុត្រតាំងនៅហើយក្នុងសោតាបត្តិផល អទិន្នបុព្វកព្រាហ្មណ៍ក៏ដូចគ្នា ។ គាត់បានសាបព្រោះសម្បត្តិធំដល់ម៉្លោះ ក្នុងព្រះពុទ្ធសាសនាហើយ ដូច្នេះឯង ។៚*

**រឿង មដ្ឋកុណ្ឌលី ចប់**

# រឿង ព្រះតិស្សត្ថេរ

## លំនាំដើម

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ បានត្រាស់ព្រះធម្មទេសនានេះថា* ***អក្កោច្ឆិ មំ អវធិ មំ*** *ជាដើម ។*

*បានឮមកថា ព្រះតិស្សត្ថេរនេះ ជាឱរសព្រះបិតុច្ឆារបស់ព្រះដ៏មានព្រះភាគ បួសក្នុងកាលឯចាស់ បរិភោគលាភសក្ការៈដែលកើតឡើងហើយ ក្នុងព្រះពុទ្ធសាសនា មានរាងកាយធាត់ល្អ មានចីវរស្អាតរៀបរយហើយដោយច្រើន អង្គុយក្នុងរោងឆាន់កណ្ដាលវិហារ ។ ភិក្ខុអាគន្តុកៈទាំងឡាយមកហើយ*

ដើម្បីប្រយោជន៍ចូលគាល់ព្រះតថាគត ទៅកាន់សម្នាក់របស់លោក ដោយសម្គាល់ថា នេះជាមហាថេរៈ ដូច្នេះហើយ សួរដល់វត្ត សួរដល់កិច្ចដែលគួរធ្វើ មានប្របាច់ជើងជាដើម ព្រះតិស្សៈក៏គង់ស្ងៀមនៅ ។

លំដាប់នោះ ភិក្ខុកំលោះមួយអង្គសួរថា លោកម្ចាស់វស្សាប៉ុន្មានហើយ លោកឆ្លើយថា មិនទាន់មានវស្សាទេ ខ្ញុំបួសហើយ ក្នុងកាលជាមនុស្សចាស់ ទើបភិក្ខុកំលោះពោលថា លោកម្ចាស់តាដ៏មានអាយុ ជាអ្នកប្រដៅក្រ លោកម្ចាស់មិនស្គាល់ប្រមាណខ្លួនឯង ឃើញមហាថេរៈមានប្រមាណប៉ុណ្ណេះហើយ មិនធ្វើវត្ត សូម្បីតែសាមីចិកម្ម កាលវត្តដែលព្រះថេរៈទាំងនេះសួរដោយអើពើ លោកម្ចាស់ក៏នៅស្ងៀម សូម្បីតែសេចក្តីរង្កៀស ក៏មិនមានដល់លោកម្ចាស់ ដូច្នេះ ទើបលាដៃ ។ ព្រះតិស្សៈញុំាងខត្តិយមានះឲ្យកើតឡើងហើយ សួរថា ពួកលោកមកកាន់សម្នាក់អ្នកណា កាលអាគន្តុកៈទាំងនោះឆ្លើយថា ខ្ញុំមកកាន់សម្នាក់របស់ព្រះសាស្តា ទើបពោលថា ពួកលោកសម្គាល់ខ្ញុំថា នេះជាអ្នកណា ខ្ញុំនឹងកាត់មូលរបស់ពួកលោកចេញឲ្យបាន ដូច្នេះហើយ ស្រែកយំដល់នូវសេចក្តីទុក្ខទោមនស្ស ទៅកាន់សម្នាក់របស់ព្រះសាស្តាហើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរថា ម្នាលតិស្សៈ តើមានរឿងអ្វីហ្ន៎ ទើបអ្នកជាទុក្ខទោមនស្ស មានមុខជោកដោយទឹកភ្នែក ទ្រហោយំមកហើយ ។ចំណែកភិក្ខុទាំងនោះ គឺអាគន្តុកភិក្ខុគិតថា ភិក្ខុនេះគង់មិនធ្វើកម្មល្អក់ករណាមួយឡើយ ដូច្នេះ ទើបទៅជាមួយព្រះតិស្សៈនោះឯង ថ្វាយបង្គំព្រះសាស្តាហើយ បានអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះតិស្សៈនោះ កាល

ព្រះសាស្តាត្រាស់សួរហើយ បានក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុទាំងនេះ ជេរខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកអង្គុយហើយក្នុងទីណា ព្រះតិស្សៈ ទូលថា ត្រង់រោងឆាន់កណ្តាលវិហារ ព្រះសាស្តាត្រាស់ថា ភិក្ខុទាំងនេះមក អ្នកបានឃើញដែរឬទេ ព្រះតិស្សៈឆ្លើយថា ឃើញព្រះអង្គ ព្រះសាស្តាត្រាស់ ថា អ្នកបានក្រោកឡើងធ្វើការទទួលដែរឬ ព្រះតិស្សៈឆ្លើយថា មិនបានធ្វើទេ ព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកបានសួរដោយអើពើ ដល់ការទទួលបរិក្ខារ របស់ភិក្ខុទាំងនោះដែរឬ ព្រះតិស្សៈតបថា ខ្ញុំព្រះអង្គមិនបានសួរដោយអើពើ ឡើយព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកបានសួរដោយអើពើដើម្បីដល់នូវ ទំនៀម ឬទឹកផឹកដែរឬ ព្រះតិស្សៈតបថា ខ្ញុំព្រះអង្គមិនបានសួរដោយអើពើ ឡើយ ព្រះសាស្តាត្រាស់ថា អ្នកនាំអាសនៈមកហើយ ធ្វើការគក់ប្រេបាច់ជើង ឲ្យដែរឬ ព្រះតិស្សៈតបថា មិនបានធ្វើទេ ព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលតិស្សៈ វត្តទាំងពួងនោះ អ្នកគួរធ្វើដល់ភិក្ខុដែលជាថេរៈ ។ កាលដែល អ្នកមិនធ្វើវត្តទាំងពួងនោះ អង្គុយក្នុងកណ្តាលវិហារ មិនសមគួរ ទោសរបស់ អ្នកខ្លួនឯងមាន អ្នកចូរខមាទោសភិក្ខុទាំងឡាយនោះចុះ ព្រះតិស្សៈពោលថា បពិត្រព្រះអង្គ ភិក្ខុទាំងឡាយនេះ បានជេរខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមិនសូមខមា-ទោសឡើយ ព្រះសាស្តាត្រាស់ថា ម្នាលតិស្សៈ អ្នកកុំធ្វើយ៉ាងនេះ ទោស របស់អ្នកមាន អ្នកចូរសូមខមាទោសភិក្ខុទាំងនោះចុះ ព្រះតិស្សៈពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនព្រមសូមទោសភិក្ខុទាំងនេះទេ ។

លំដាប់នោះ ព្រះសាស្តាកាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ

ព្រះតិស្សៈនេះ ជាបុគ្គលប្រដៅក្រ ដូច្នេះហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តិស្សៈនេះមិនមែនប្រដៅក្រតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តិស្សៈនេះក៏ជាបុគ្គលប្រដៅក្រដូចគ្នា កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ជ្រាបលោកថា ជាបុគ្គលប្រដៅក្រតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ តើលោកបានធ្វើអ្វី ក្នុងអតីតកាល ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនោះ ចូរអ្នកទាំងឡាយស្តាប់ ដូច្នេះហើយ ទ្រង់បាននាំអតីតនិទានមក ។

## បុព្វកម្មរបស់ព្រះតិស្សៈ

ក្នុងអតីតកាល កាលព្រះបាទពារាណសីសោយរាជសម្បត្តិ ក្នុងនគរពារាណសី តាបសឈ្មោះទេវិលៈនៅក្នុងហិមវន្តប្បទេស ៨ ខែ ប្រាថ្នាចូលទៅអាស្រ័យនគរ ៤ ខែ ដើម្បីបរិភោគរសប្រៃ និងរសជូរ ទើបមកអំពីហិមវន្តប្បទេស ជួបពួកអ្នកយាមទ្វារនគរ ទើបសួរថា ពួកបព្វជិតដែលមកដល់នគរនេះហើយ ស្នាក់នៅក្នុងទីណា ពួកអ្នកយាមទាំងឡាយប្រាប់ថា ក្នុងរោងនាយស្មូនឆ្នាំង លោកម្ចាស់ ។ លោកទៅកាន់រោងនាយស្មូនឆ្នាំងហើយ ឈរត្រង់ទ្វារពោលថា បើអ្នកមិនយល់ទាស់ទេ អាត្មាសូមស្នាក់នៅក្នុងរោងត្រឹមមួយរាត្រី ។ ស្មូនឆ្នាំងពោលថា ពេលយប់ កិច្ចរបស់ខ្ញុំត្រង់រោងមិនមាន រោងនេះធំ និមន្តលោកម្ចាស់ស្នាក់នៅ តាមសប្បាយចុះ ដូច្នេះហើយ ប្រគល់រោងប្រគេន ។

កាលលោកចូលទៅអង្គុយហើយ ។ តាបសមួយរូបទៀត ឈ្មោះនារទៈ

មកអំពីហិមវន្តប្បទេស បានសូមស្នាក់នៅមួយរាត្រីជាមួយនាយស្ដូនផ្ទាំង ។ នាយស្ដូនផ្ទាំងគិតថា តាបសអង្គដែលមកមុនជាអ្នកប្រដៅក្រ ដូចគ្នានឹងតាបសអង្គនេះឬទេហ្ន៎ក៏មិនដឹង អញនឹងដោះខ្លួនចេញ ដូច្នេះហើយ ទើបពោលថា បើលោកម្ចាស់អង្គណាចូលទៅមុនពេញចិត្តសោត សូមលោកម្ចាស់ស្នាក់នៅតាមការពេញចិត្តរបស់តាបសអង្គមុនចុះ ។ នារទតាបសនោះ ចូលទៅរកទេវិលៈ ហើយពោលថា លោកអាចារ្យ បើលោកម្ចាស់មិនយល់ទាស់ទេ ខ្ញុំសូមស្នាក់នៅក្នុងរោងនេះមួយរាត្រីចុះ កាលលោកពោលថា រោងធំ សូមលោកម្ចាស់ចូលទៅចំណែកម្ខាងចុះ ដូច្នេះហើយ ទើបចូលអង្គុយក្នុងទីមួយកន្លែងទៀតនៃតាបសដែលចូលទៅមុន ។

តាបសទាំងពីររូប ពោលប្រាស្រ័យនាំឲ្យរឭកដល់គ្នាហើយ ក្នុងកាលសិង នារទតាបសកំណត់ទីសិងនៃតាបស និងទ្វារហើយ ទើបសិង ចំណែកទេវិលតាបសនោះកាលនឹងសិង មិនសិងក្នុងទីរបស់ខ្លួន សិងទទឹងត្រង់ទ្វារ ។ នារទតាបសកាលចេញទៅក្នុងរាត្រី បានជាន់ត្រង់ជដារបស់លោក ។ កាលលោកពោលថា អ្នកណាជាន់ខ្ញុំ នារទតាបសពោលថា ខ្ញុំលោកអាចារ្យ ទេវិលៈពោលថា នែជដិលកោង អ្នកមកអំពីព្រៃហើយ ជាន់ត្រង់ជដារបស់ខ្ញុំ នារទតាបសពោលថា លោកអាចារ្យខ្ញុំមិនដឹងថា លោកអាចារ្យសិងទីនេះ សូមលោកអាចារ្យអត់ទោសដល់ខ្ញុំចុះ ។ កាលលោកកំពុងរអ៊ូនោះឯង ចេញទៅខាងក្រៅហើយ ។ ទេវិលតាបសគិតថា តាបសនេះ ចូលមកគប្បីជាន់អញ ដូច្នេះហើយ ទើបសិងបែរក្បាលទៅខាងចុងជើង ។

ចំណែកនារទតាបស កាលនឹងចូលទៅ គិតថា ពីមុនអញបានខុសម្តង ហើយ ក្នុងលោកអាចារ្យ ឥឡូវនេះអញនឹងចូលទៅខាងចុងជើងរបស់លោក ដូច្នេះហើយ កាលមក បានជាន់ត្រង់ករបស់លោក កាលលោកពោលថា នេះអ្នកណា ទើបពោលថា លោកអាចារ្យ គឺខ្ញុំ ។ កាលលោកពោលថា នែ ជដិលកោង ដំបូងអ្នកជាន់ត្រង់ជដារបស់ខ្ញុំហើយ ឥឡូវនេះ ជាន់ត្រង់ករបស់ខ្ញុំទៀត ខ្ញុំនឹងដាក់បណ្តាសាអ្នក នារទតាបសពោលថា លោកអាចារ្យ ទោសរបស់ខ្ញុំមិនមាន ខ្ញុំមិនដឹងថា លោកម្ចាស់សិងហើយយ៉ាងនេះ ខ្ញុំចូលមកដោយគិតថា ដំបូងកំហុសរបស់ខ្ញុំមាន ឥឡូវនេះ ខ្ញុំនឹងចូលទៅខាងចុងជើង ដូច្នេះ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ ទេវិលតាបសពោលថា នែជដិលកោង ខ្ញុំនឹងដាក់បណ្តាសាលោក នារទតាបសពោលថា លោកអាចារ្យ សូមលោកកុំធ្វើយ៉ាងនេះឡើយ ។

ទេវិលៈមិនអើពើនឹងពាក្យសម្តីរបស់នារទតាបសនោះឡើយ នៅតែចចេសដាក់បណ្តាសានារទតាបសនោះដោយគាថាថា

ព្រះអាទិត្យ មានរស្មីរាប់ពាន់ មានតេជៈរាប់រយ មាន
ប្រក្រតីកម្ចាត់នូវងងឹត លុះព្រះអាទិត្យរះឡើង មកក្នុង
ពេលព្រឹក ក្បាលរបស់លោក ចូរបែកជា ៧ ភាគ ។

នារទតាបសពោលថា លោកអាចារ្យទោសរបស់ខ្ញុំមិនមាន កាលកំពុងពោលនោះឯង លោកម្ចាស់បានដាក់បណ្តាសាហើយ ទោសរបស់អ្នកណាមាន ក្បាលរបស់អ្នកនោះចូរបែកចុះ ក្បាលរបស់អ្នកមិនមានទោស កុំបីបែកឡើយ

ដូច្នេះហើយ បានដាក់បណ្តាសាដោយគាថាថា

ព្រះអាទិត្យ មានរស្មីរាប់ពាន់ មានតេជះរាប់រយ មាន
ប្រក្រតីកម្ចាត់នូវងងឹត លុះព្រះអាទិត្យរះឡើងក្នុងពេល
ព្រឹក ក្បាលរបស់លោក ចូរបែកជា ៧ ភាគចុះ ។

នារទតាបសនោះមានអានុភាពធំ អាចរឭកជាតិបាន ៨០ កប្ប គឺក្នុងអតីតកាល ៤០ កប្ប ក្នុងអនាគតកាល ៤០ កប្ប ។ ព្រោះហេតុនោះលោកពិចារណាថា បណ្តាសានឹងធ្លាក់លើអ្នកណាហ្ន៎ដូច្នេះ កាលពិចារណាក៏ដឹងថា នឹងធ្លាក់ទៅលើលោកអាចារ្យ ។ អាស្រ័យសេចក្តីករុណាក្នុងទេវិលៈទើបបានឃាត់អារុណមិនឲ្យរះដោយកម្លាំងនៃឫទ្ធិ ។

អ្នកនគរកាលអារុណមិនរះ ក៏នាំគ្នាទៅកាន់ទ្វារព្រះរាជវាំង ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព កាលព្រះអង្គទ្រង់គ្រងរាជសម្បត្តិ អារុណមិនរះ សូមទ្រង់មេត្តាឲ្យអារុណរះ ដើម្បីទូលបង្គំទាំងឡាយចុះ ។

ព្រះរាជាទ្រង់ពិចារណាចរិយានុវត្ត មានកាយកម្មជាដើមរបស់ព្រះអង្គក៏មិនបានឃើញការដែលមិនសមគួរណាមួយ ទើបទ្រង់ព្រះតម្រិះថា ហេតុអ្វីហ្ន៎ដូច្នេះ ទ្រង់សង្ស័យថា ប្រហែលជាការវិវាទរបស់ពួកបព្វជិត ដូច្នេះហើយទើបត្រាស់សួរថា ពួកបព្វជិតក្នុងនគរនេះមានដែរឬទេ កាលមានបុគ្គលក្រាបទូលថា កាលពីល្ងាចម្សិលមិញនេះ មានពួកបព្វជិតមកក្នុងរោងនាយស្មូនឆ្នាំង ។ ព្រះរាជាមានរាជបុរសកាន់គប់ភ្លើងនាំទ្រង់ទៅក្នុងទីនោះ ក្នុងវេលានោះឯង ទ្រង់អភិវាទនារទតាបសហើយ ប្រថាប់ក្នុងទីសមគួរ នាចំណែកម្ខាង

ត្រាស់សួរថា

បពិត្រលោកម្ចាស់នារទៈ ការងារទាំងឡាយ របស់ពួកអ្នកជម្ពូទ្វីប រមែងប្រព្រឹត្តទៅមិនបាន ទ្វីបលោកកើតងងឹតហើយព្រោះហេតុអ្វី លោកម្ចាស់ដែលខ្ញុំសួរហើយ សូមប្រាប់ហេតុនោះដល់ខ្ញុំ ។

នារទតាបសពោលរឿងទាំងពួងថ្វាយហើយ ថ្វាយព្រះពរថា អាត្មាភាពដែលតាបសរូបនេះផ្ដាសាហើយ ព្រោះហេតុនេះ កាលបើយ៉ាងនោះ ទើបអាត្មាបានដាក់បណ្ដាសាដែរថា ទោសរបស់ខ្ញុំមិនមាន ទោសរបស់បុគ្គលណាមានបណ្ដាសាចូរធ្លាក់លើបុគ្គលនោះឯង កាលផ្ដាសាហើយ ទើបគិតថា បណ្ដាសានឹងធ្លាក់លើអ្នកណាហ្ន៎ កាលពិចារណាទៅក៏ឃើញថា ក្នុងពេលព្រះអាទិត្យរះឡើង ក្បាលរបស់អាចារ្យនឹងបែកជា ៧ ភាគ ដូច្នេះហើយ អាស្រ័យសេចក្ដីករុណាក្នុងលោក ទើបមិនឲ្យអារុណរះឡើង ។ ព្រះរាជាត្រាស់ថា ធ្វើយ៉ាងណាកុំឲ្យអន្តរាយមានដល់លោក នារទតាបសពោលថា បើលោកសូមខមាទោសនឹងអាត្មាភាព អន្តរាយនឹងមិនមាន ព្រះរាជាត្រាស់ថា បើយ៉ាងនោះសូមលោកម្ចាស់ខមាទោសចុះ ទេវិលតាបសពោលថា ជដិលនោះជាន់អាត្មាត្រង់ជដា និងក អាត្មាមិនព្រមសូមទោសជដិលកោងនោះឡើយ ។ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ខមាទោសចុះ កុំធ្វើយ៉ាងនេះឡើយ ។

ទេវិលតាបសទូលថា អាត្មាមិនព្រមសូមទោសឡើយ កាលព្រះរាជាត្រាស់ថា ក្បាលលោកម្ចាស់នឹងបែកជា ៧ ភាគ ដូច្នេះក៏នៅតែមិនព្រមសូម

ទោសនោះឯង ។

លំដាប់នោះ ព្រះរាជាត្រាស់ថា លោកម្ចាស់មិនព្រមសូមទោសតាមគាប់ចិត្តរបស់ខ្លួនឬ ដូច្នេះហើយ ប្រាប់ឲ្យរាជបុរសចាប់ទេវិលតាបសនោះត្រង់ដៃ ត្រង់ជើង ត្រង់ពោះ ត្រង់ក ឲ្យក្រាបទៀបបាទមូលរបស់នារទតាបស ។

នារទតាបសពោលថា លោកអាចារ្យ សូមលោកម្ចាស់ក្រោកឡើងចុះ ខ្ញុំព្រមអត់ទោសឲ្យលោកម្ចាស់ ដូច្នេះហើយ ថ្វាយព្រះពរថា បពិត្រមហារាជ តាបសនេះមិនខមាទោសអាត្មាដោយស្ម័គ្រចិត្តឡើយ មានស្រះមួយក្នុងទីមិនឆ្ងាយ សូមទ្រង់ឲ្យលោកឈរទូលដុំដីស្អិតលើក្បាល ត្រាំទឹកនៅក្នុងស្រះនោះត្រឹម-ក ។ ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះហើយ ។ នារទតាបសហៅទេវិលតាបសមកថា លោកអាចារ្យកាលឫទ្ធិខ្ញុំរម្យាយហើយ កាលពន្លឺព្រះអាទិត្យតាំងឡើង លោកម្ចាស់គប្បីមុជក្នុងទឹកហើយ ផុសឡើងក្នុងទីដទៃ ។ ដុំដីស្អិតលើក្បាលរបស់ទេវិលៈនោះ គ្រាន់តែរស្មីព្រះអាទិត្យពាល់ត្រូវប៉ុណ្ណោះក៏បែកជា ៧ ចម្រៀក ។ ទេវិលតាបសនោះបានជ្រមុជទៅកាន់ទីដទៃហើយ ។

ព្រះសាស្តាកាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាក្នុងកាលនោះបានជាអានន្ទ ទេវិលតាបសបានជាតិស្សៈ នារទតាបសបានជាតថាគតនេះឯង ។ សូម្បីក្នុងគ្រានោះ តិស្សៈនេះក៏ជាបុគ្គលប្រដៅក្រយ៉ាងនេះដូចគ្នាដូច្នេះហើយ ត្រាស់ឲ្យហៅតិស្សភិក្ខុមក ហើយត្រាស់ថា ម្នាលតិស្សៈ កាលភិក្ខុគិតថា អញត្រូវបុគ្គលនោះជេរហើយ ត្រូវបុគ្គលនោះប្រហារហើយ ត្រូវបុគ្គលនោះឈ្នះហើយ បុគ្គលនោះ បានលួចទ្រព្យ

របស់អញទៅហើយ ដូច្នេះ ឈ្មោះថា ពៀររមែងមិនរម្ងាប់បាន តែកាលកិក្ខុមិនចូលទៅចង យ៉ាងនោះឯង ពៀររមែងរម្ងាប់បាន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថា ដូច្នេះថា

**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។**
**អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ**
**យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។**

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះ បានលួចយក ទ្រព្យអញទៅហើយ បើអ្នកណាចងសេចក្ដីក្រោធបែបនោះទុក ( ដូច្នេះ ) ពៀររបស់អ្នកនោះមិនរម្ងាប់ឡើយ ។

អ្នកឯណោះ បានជេរអញ អ្នកឯណោះ បានវាយអញ អ្នកឯណោះ បានផ្ចាញ់អញ អ្នកឯណោះ បានលួចយក ទ្រព្យរបស់អញទៅហើយ បើអ្នកណាមិនចងសេចក្ដីក្រោធបែបនោះទុក ( ដូច្នេះ ) ពៀររបស់អ្នកនោះ ទើបរម្ងាប់បាន ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អក្កោច្ឆិ** គឺជេរហើយ ។ បទថា **អវធិ** គឺប្រហារហើយ ។ បទថា **អជិនិ** គឺបានឈ្នះអញដោយការអាងសាក្សីកោងខ្វះ

ដោយការពោលផ្ចាញផ្ចាល់ខ្លះ ដោយការធ្វើឲ្យក្រៃលែងជាងការធ្វើខ្លះ ។

បទថា **អហាសិ** គឺបុគ្គលនោះបានលួចទ្រព្យ គឺបណ្ដាវត្ថុទាំងឡាយមានសំពត់ជាដើមណាមួយរបស់អញ ។

ពីរបទថា **យេ ច តំ** ជាដើម សេចក្ដីថា ជនពួកណាមួយ គឺទេវតាក្ដី មនុស្សក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ចូលទៅចងសេចក្ដីក្រោធនោះ គឺមានវត្ថុជាដើមថា អ្នកឯណោះបានជេរអញ ដូចមនុស្សបររទេះ មួលទូករទេះដោយកូនកំព្រា និងដូចពួកអ្នកប្រម៉ង់ចងវត្ថុ មានត្រីស្អុយជាដើម ដោយវត្ថុ មានស្បូវក្លាំងជាដើមរឿយៗ ។ ពៀររបស់ជននោះកើតឡើងហើយតែម្ដង រមែងមិនរម្ងាប់ គឺមិនស្ងប់បានឡើយ ។

បាទព្រះគាថាថា **យេ ច តំ នូបនយ្ហន្តិ** សេចក្ដីថា ជនទាំងឡាយណាមិនចូលទៅចងសេចក្ដីក្រោធនោះ គឺមានពាក្យជេរជាដើមជាទីតាំង ដោយអំណាចការមិនរឭកដល់ និងការមិនធ្វើទុកក្នុងចិត្តខ្លះ ដោយអំណាចការពិចារណាឃើញកម្មយ៉ាងនេះថា បុគ្គលណាម្នាក់ដែលមិនមានទោស សូម្បីអ្នកគង់ជេរហើយក្នុងភពមុន គង់ប្រហារហើយក្នុងភពមុន គង់នឹងជួលសាក្សីកោងឈ្នះហើយក្នុងភពមុន ទ្រព្យណាមួយរបស់បុគ្គលណាម្នាក់ អ្នកគង់នឹងសង្កត់សង្កិនដណ្ដើមយកហើយក្នុងភពមុន ។ ព្រោះដូច្នោះ អ្នកសូម្បីជាបុគ្គលមិនមានទោស ទើបបានផលដែលមិនគួរប្រាថ្នា មានពាក្យជេរជាដើមដូច្នេះខ្លះ ពៀររបស់ជនទាំងនោះ សូម្បីកើតហើយ ព្រោះសេចក្ដីប្រមាទរមែងស្ងប់បានដោយការមិនចង សេចក្ដីក្រោធនេះ ដូចភ្លើងមិនមានកំញម

កើតឡើងហើយ រលត់ទៅដូច្នេះឯង ។

ក្នុងកាលចប់ធម្មទេសនា ភិក្ខុមួយសែនរូបបានសម្រេចអរិយផលទាំង-ឡាយ មានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនាបានជាកថាមានប្រយោជន៍ដល់មហាជនហើយ ។ ព្រះតិស្សត្ថេរសូម្បីជាបុគ្គលប្រដៅក្រ ក៏ក្លាយជាបុគ្គលប្រដៅងាយហើយ ដូច្នេះឯង ។៚

**រឿង ព្រះតិស្សត្ថេរ ចប់**

# រឿង នាងកាឡីយក្ខិនី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីអារម្នាក់ ត្រាស់ធម្មទេសនានេះថា **ន ហិ វេរេន វេរានិ** ជាដើម ។

បានឮមកថា បុត្រកុដុម្ពិកៈម្នាក់ កាលបិតាធ្វើកាលកិរិយាហើយ ធ្វើការងារទាំងពួង ទាំងទីវាល ទាំងក្នុងស្រុកដោយខ្លួនឯង បដិបត្តិមាតា ។ បន្ទាប់មក មាតាបានប្រាប់ដល់បុត្រនោះថា នែបា ម៉ែនឹងនាំនាងកុមារិកាមកឲ្យឯង បុរសនោះពោលថា បពិត្រអ្នកម៉ែ សូមម៉ែកុំពោលយ៉ាងនេះឡើយ ខ្ញុំនឹងបដិបត្តិម៉ែដរាបដល់អស់ជីវិត ។ មាតាពោលថា នែបា អ្នកតែម្នាក់ឯងធ្វើការទាំងទីវាល និងក្នុងស្រុក ព្រោះហេតុនោះ ទើបម៉ែមិនមានការសប្បាយចិត្តឡើយ ម៉ែនឹងនាំកុមារិកាមកឲ្យឯង ។

បុរសនោះសូម្បីឃាត់ម្ដាយច្រើនដងហើយ ក៏បាននៅស្ងៀម ។ មាតានោះចេញអំពីផ្ទះ ដើម្បីនឹងទៅកាន់ត្រកូលមួយ ។

លំដាប់នោះ បុត្រសួរមាតាថា អ្នកម៉ែទៅកាន់ត្រកូលណា ម្ដាយតបថា ទៅកាន់ត្រកូលឈ្មោះនោះ ដូច្នេះហើយ ហាមការដែលទៅកាន់ត្រកូលនោះ ហើយប្រាប់ត្រកូលដែលខ្លួនពេញចិត្ត ។ មាតាបានទៅកាន់ត្រកូលនាងកុមារិកានោះហើយ កំណត់ថ្ងៃរៀបការ នាំកុមារិកាម្នាក់នោះមក បានធ្វើទុកក្នុងផ្ទះរបស់បុត្រ ។

កុមារិកានោះជាស្រីអារ ទើបមាតាពោលនឹងបុត្រថា នែបា អ្នកឲ្យម្ដាយនាំកុមារិកាមកតាមគាប់ចិត្តរបស់ឯងហើយ ឥឡូវនេះ កុមារិកានោះជាស្រីអារ គ្មានកូន ធម្មតាត្រកូលដែលមិនមានបុត្រ រមែងអន្តរធានបវេណី រមែងមិនបន្តគ្នាទៅ ព្រោះដូច្នេះ ម៉ែនឹងនាំកុមារិកាដទៃមក សូម្បីកូននោះពោលឃាត់ថា សូមម៉ែកុំធ្វើដូច្នេះឡើយ ក៏ម្ដាយនៅតែពោលយ៉ាងនោះរឿយៗ ។ ស្រីអារបានឮពាក្យនោះ ទើបគិតថា ធម្មតាកូនរមែងមិនអាចឃាត់ពាក្យមាតាបិតាបាន ឥឡូវនេះម៉ែក្មេកគិតនាំស្រីដទៃដែលមិនអារមកហើយ នឹងប្រើអញដូចជាទាសី បើយ៉ាងនោះអញនឹងនាំកុមារិកាម្នាក់មកដោយខ្លួនឯង ដូច្នេះហើយ ទើបទៅកាន់ត្រកូលមួយ សូមកុមារិកាដើម្បីប្រយោជន៍ដល់ប្ដី ។ ត្រូវពួកជនក្នុងត្រកូលនោះឃាត់ថា នាងពោលអ្វីដូច្នោះ ដូច្នេះហើយ ទើបលួងលោមថា ខ្ញុំជាស្រីអារ ត្រកូលដែលមិនមានកូនរមែងវិនាស កូនស្រីរបស់អ្នក មានកូនហើយ នឹងបានជាម្ចាស់របស់សម្បត្តិ សូមលោកមេត្តាលើកកូន

នោះ ឲ្យដល់ប្ដីរបស់ខ្ញុំចុះ ដូច្នេះហើយ ញុំាងត្រកូលនោះឲ្យព្រម ហើយនាំមកផ្ទះរបស់ប្ដី ។

បន្ទាប់មកស្រីអារនោះ មានបរិវិតក្កថា បើស្រីនេះបានកូនប្រុស ឬកូនស្រីសោត វានឹងជាម្ចាស់សម្បត្តិតែម្នាក់ឯង អញគួរធ្វើនាងកុំឲ្យបានកូនឡើយ។

លំដាប់នោះ ទើបស្រីអារនោះពោលនឹងនាងនោះថា គភ៌តាំងឡើងក្នុងផ្ទៃរបស់នាងកាលណា សូមនាងប្រាប់ដល់ខ្ញុំក្នុងកាលនោះ នាងទទួលថា សាធុ កាលគភ៌តាំងហើយ បានប្រាប់ដល់ស្រីអារនោះ ។ ចំណែកស្រីអារនោះ បានឲ្យបបរ និងបាយដល់ស្រីនោះជានិច្ច ។ ក្រោយមកនាងបានឲ្យថ្នាំសម្រាប់រំលូតកូន លាយជាមួយអាហារដល់នាងនោះ គភ៌ក៏ធ្លាក់ ។ កាលគភ៌តាំងជាលើកទីពីរ នាងក៏បានប្រាប់ដល់ស្រីអារនោះ ស្រីអារនោះ ក៏បានធ្វើគភ៌ឲ្យធ្លាក់ដោយឧបាយយ៉ាងនោះឯង ជាលើកទីពីរ ។

លំដាប់នោះ ពួកស្រីដែលស្និទស្នាលគ្នាបានសួរស្រីនោះថា ស្រីរួមប្ដីធ្វើអន្តរាយដល់នាងខ្លះដែរឬ នាងប្រាប់សេចក្ដីនោះហើយ ត្រូវស្រីទាំងនោះពោលថា ស្រីអន្ធពាល ហេតុអ្វី ទើបនាងធ្វើយ៉ាងនោះ ស្រីអារនេះបានប្រកបថ្នាំសម្រាប់ធ្វើគភ៌ឲ្យធ្លាក់ដល់នាង ព្រោះខ្លាចនាងជាធំ ព្រោះដូច្នោះ ទើបគភ៌របស់នាងរលូត ។ នាងកុំធ្វើយ៉ាងនេះទៀត ។ ក្នុងលើកទីបី ទើបនាងមិនប្រាប់ ។ បន្ទាប់មក ស្រីអារឃើញពោះរបស់នាងនោះហើយ ទើបពោលថា ហេតុអ្វី ទើបនាងមិនប្រាប់ការមានគភ៌ដល់ខ្ញុំ កាលស្រីនោះពោលថា នាងនាំខ្ញុំមកហើយ ធ្វើគភ៌ខ្ញុំធ្លាក់ដល់ទៅពីរដង ខ្ញុំប្រាប់នាងធ្វើអ្វី ទើបគិតថា ឥឡូវ

នេះ អញវិនាសហើយ ឃ្លាំចាំមើលការប្រមាទរបស់កុមារិកានោះ កាលគក៏ចាស់ខែហើយ ទើបបានឱកាស បានប្រកបថ្នាំមិនឲ្យសម្រាលកូន ព្រោះគក៏ចាស់ទើបដេកទទឹងទ្វារ ។ វេទនាដ៏ក្លាំងក្លាក៏កើតឡើង នាងក៏អស់ជីវិតទៅ ។

នាងតាំងសេចក្ដីប្រាថ្នាថា អញត្រូវស្រីនេះឲ្យវិនាសហើយ ហងនាំអញមក ធ្វើទារកឲ្យវិនាសដល់ទៅ ៣ នាក់ ឥឡូវនេះ ខ្លួនអញក៏វិនាស អញស្លាប់ពីអត្តភាពនេះ គប្បីកើតជាយក្ខិនីអាចទំពាស៊ីទារករបស់ហងចុះ ដូច្នេះហើយ ស្លាប់ទៅកើតជាមេឆ្មាក្នុងផ្ទះនោះឯង ។ ចំណែកស្វាមីចាប់ស្រីអារនោះហើយពោលថា ហងបានធ្វើការកាត់ត្រកូលរបស់អញឲ្យដាច់សូន្យ ដូច្នេះហើយ វាយដោយអវយវៈទាំងឡាយ មានកែង និងជង្គង់ជាដើមឲ្យដាបហើយ ស្រីអារនោះស្លាប់ព្រោះជំងឺនោះឯង ហើយកើតជាមេមាន់ក្នុងផ្ទះនោះដូចគ្នា ។

ចំណេរកាលមិនយូរ មេមាន់បានពងជាច្រើន ។ មេឆ្មាមកស៊ីពងមាន់ទាំងនោះអស់ សូម្បីលើកទីពីរ លើកទីបី ឆ្មាក៏ស៊ីដូចគ្នា ។ មេមាន់ធ្វើសេចក្ដីប្រាថ្នាថា ហងស៊ីពងរបស់អញអស់បីដងហើយ ឥឡូវនេះ ហងក៏ចង់ស៊ីខ្លួនអញទៀតដូច្នេះ អញស្លាប់ពីអត្តភាពនេះហើយ គប្បីបានស៊ីហង និងកូនរបស់ហងដូច្នេះហើយ ។ ចុតិចាកអត្តភាពនោះ បានកើតជាមេខ្លាដំបង ។ ចំណែកមេឆ្មា បានកើតជាមេម្រឹគ ។ ក្នុងកាលមេម្រឹគនោះកើតកូនហើយ មេខ្លាក៏បានមកស៊ីកូនទាំងឡាយដល់ទៅបីដង កាលដល់ពេលស្លាប់ មេម្រឹគធ្វើសេចក្ដីប្រាថ្នាថា កូនរបស់អញមេខ្លានេះស៊ីអស់បីដងហើយ ឥឡូវនេះ វានឹង

ស៊ីខ្លួនអញផង ឥឡូវនេះ អញចុតិចាកអត្តភាពនេះហើយ គប្បីបានស៊ីកូនរបស់វាចុះ ដូច្នេះហើយ បានស្លាប់ទៅកើតជាយក្ខិនី ។ ចំណែកមេខ្លាចុតិអំពីអត្តភាពនោះហើយ កើតជាកុលធីតា ក្នុងក្រុងសាវត្ថី ។ នាងដល់នូវសេចក្តីចម្រើនហើយ បានទៅកាន់ត្រកូលប្តី ក្នុងស្រុកក្បែរទ្វារក្រុង ។ ចំណេរកាលតមក នាងបានប្រសូតកូនប្រុសម្នាក់ ។ នាងយក្ខិនីកាឡាខ្លួនជាស្រីសម្លាញ់ជាទីស្រឡាញ់របស់នាងមកហើយ សួរថា ស្រីសម្លាញ់របស់ខ្ញុំនៅទីណា ពួកអ្នកស្រុកបានប្រាប់ថា នាងប្រសូតបុត្រនូវខាងក្នុងបន្ទប់ ។ នាងយក្ខិនីស្តាប់ពាក្យនោះ ធ្វើជាពោលថា សម្លាញ់របស់ខ្ញុំប្រសូតកូនជាប្រុសឬជាស្រីហ្ន៎ ខ្ញុំនឹងមើលកូននោះ ដូច្នេះហើយ ចូលទៅធ្វើជាសម្លឹងមើលទារកចាប់ស៊ីហើយក៏ចេញទៅ ។ ក្នុងលើកទីពីរក៏បានស៊ីដូចគ្នា ។ ក្នុងលើកទីបីនាងកុលធីតាមានគភ៌ចាស់ខែ ហៅប្តីមកហើយ ប្រាប់ថា នែអ្នក យក្ខិនីម្នាក់ស៊ីកូនរបស់ខ្ញុំអស់ពីរនាក់ហើយ ឥឡូវនេះ ខ្ញុំនឹងទៅកាន់ផ្ទះត្រកូលរបស់ខ្ញុំដើម្បីប្រសូតបុត្រ ដូច្នេះហើយ ទៅកាន់ផ្ទះនៃត្រកូលខ្លួន ប្រសូតបុត្រក្នុងទីនោះ ។ ក្នុងកាលនោះ យក្ខិនីនោះ ដល់នូវពេលបញ្ជូនទឹក ព្រោះថាយក្ខិនីទាំងឡាយ ត្រូវដងទឹកអំពីអនោតត្តស្រះ ទូលលើក្បាលមក ដើម្បីព្រះបាទវេស្សវ័ណ តាមវារៈ ៤ ខែខ្លះ ៥ ខែខ្លះ ទើបផុតបាន ។ យក្ខិនីដទៃមានកាយហត់នឿយ ដល់នូវការអស់ជីវិតក៏មាន ។ ចំណែកយក្ខិនីនោះលុះផុតវេនដងទឹកហើយប៉ុណ្ណោះ ក៏ប្រញាប់ទៅកាន់ផ្ទះនោះ សួរថា សម្លាញ់របស់ខ្ញុំនៅឯណា ពួកអ្នកស្រុកប្រាប់ថា អ្នកនឹងជួបគេក្នុងទីណា ព្រោះយក្ខិនី

ម្នាក់ស៊ីកូនរបស់គេ ដែលប្រសូតក្នុងទីនេះ ព្រោះដូច្នេះ ទើបនាងទៅកាន់ផ្ទះនៃត្រកូល ។ យក្ខិនីនោះគិតថា ទោះបីទៅក្នុងទីណាក៏ដោយ នឹងមិនផុតអំពីអញបានឡើយ ដូច្នេះហើយ ដោយកម្លាំងពៀរឲ្យឧស្សាហ៍ហើយ រត់បែរមុខទៅកាន់ក្រុង ។ ចំណែកនាងកុលធីតា ក្នុងថ្ងៃដាក់ឈ្មោះឲ្យទារកនោះ ងូតទឹក ដាក់ឈ្មោះ ហើយពោលនឹងប្តីថា នែអ្នក ឥឡូវនេះ យើងនាំគ្នាទៅកាន់ផ្ទះរបស់យើងចុះ ពបុត្រទៅជាមួយស្វាមីតាមផ្លូវកាត់ តម្រង់ទៅត្រង់កណ្តាលវិហារ ប្រគល់កូនឲ្យប្តីហើយ ចុះងូតទឹកក្នុងស្រះបោក្ខរណីក្បែរវិហារ ហើយឡើងមកទទួលយកកូន កាលប្តីកំពុងងូត ឈរឲ្យកូនបៅដោះ ឃើញយក្ខិនីមក ចាំបានហើយ ស្រែកដោយសំឡេងខ្លាំងថា នែអ្នកមកឲ្យឆាប់ឡើង នេះយក្ខិនីនោះ ដូច្នេះហើយ មិនអាចឈរចាំរហូតប្តីនោះមកបាន ទើបរត់ត្រឡប់បែរមុខទៅកាន់វិហារហើយ ។

ក្នុងសម័យនោះ ព្រះសាស្តាទ្រង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ នាងកុលធីតានោះឲ្យកូនដេកទៀបខ្នងព្រះបាទរបស់ព្រះសុគត ហើយក្រាបទូលថា បុត្រនេះ ខ្ញុំម្ចាស់ថ្វាយដល់ទ្រង់ហើយ សូមទ្រង់ប្រទានជីវិតដល់កូនរបស់ខ្ញុំម្ចាស់ចុះ ។ សុមនទេវបុត្រដែលអាស្រ័យនៅត្រង់ខ្លោងទ្វារ មិនអនុញ្ញាតឲ្យយក្ខិនីចូលទៅខាងក្នុង ។ ព្រះសាស្តាទ្រង់ត្រាស់ហៅព្រះអានន្ទត្ថេរមកហើយ ត្រាស់ថា ម្នាលអានន្ទ ចូរអ្នកទៅហៅយក្ខិនីនោះមក ព្រះអានន្ទទៅហៅយក្ខិនីនោះមកហើយ ។ នាងកុលធីតាក្រាបទូលថា បពិត្រព្រះអង្គ យក្ខិនីនេះមក ។ ព្រះសាស្តាត្រាស់ថា យក្ខិនីចូរមកចុះ នាងកុំយំថ្វីឡើយ ដូច្នេះ

ហើយ បានត្រាស់នឹងយក្ខិនីដែលមកឈរហើយថា ហេតុអ្វី ទើបនាងធ្វើយ៉ាង នោះ បើពួកនាងមិនមកចំពោះមុខព្រះពុទ្ធ ដូចតថាគតហើយ ពៀររបស់ពួក នាង នឹងបានជាកម្មតាំងនៅអស់មួយកប្ប ដូចពៀររបស់ពស់ និងសត្វស្ការ របស់ខ្លាឃ្មុំ និងដើមពទ្រ របស់ក្អែក និងសត្វមៀម ហេតុអ្វី ទើបពួកអ្នកធ្វើ នូវពៀរវេរាឲ្យគ្នាទៅវិញទៅមក ព្រោះពៀររម្ងាប់បានដោយការមិនមានពៀរ មិនមែនរម្ងាប់ដោយពៀរឡើយ ដូច្នេះហើយ បានត្រាស់គាថានេះថា

**ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**

**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។**

ពិតមែន តាំងពីកាលណា មកក្នុងលោកនេះ ពៀរទាំង-ឡាយ មិនរម្ងាប់ដោយពៀរឡើយ ពៀរទាំងឡាយ តែង រម្ងាប់ដោយមិនមានពៀរ នេះជាបវេណីធម៌ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន ហិ វេរេន** ជាដើម សេចក្តីថា ដូចបុគ្គល កាលលាងនូវរបស់ប្រឡាក់ហើយ ដោយរបស់មិនស្អាត មានទឹកមាត់ ទឹក សម្បោរជាដើម ដោយរបស់មិនស្អាតទាំងនោះឯង រមែងមិនអាចធ្វើឲ្យ បរិសុទ្ធ បាត់ក្លិនស្អុយបាន ។ ដោយពិតនោះ បែរជាមិនបរិសុទ្ធ និងមានក្លិន ស្អុយក្រៃលែងជាងមុនទៅទៀត យ៉ាងណា បុគ្គលកាលជេរតបបុគ្គលដែល ជេរ ប្រហារតបជនដែលប្រហារ រមែងមិនអាចញុំាងពៀរឲ្យរម្ងាប់ដោយពៀរ បានដោយពិត បុគ្គលឈ្មោះថា ធ្វើពៀរនោះឯងឲ្យក្រៃលែង ដូច្នោះនោះឯង ។

ក្នុងកាលណាៗ ឈ្មោះថា ពៀរទាំងឡាយ រមែងមិនរម្ងាប់បានដោយពៀរឡើយ ។ ដោយពិត ឈ្មោះថា រមែងចម្រើនតែម្យ៉ាង ដោយប្រការដូច្នេះ ។

ពីរបទថា **អវេរេន ច សម្មន្តិ** សេចក្តីថា ដូចរបស់មិនស្អាត មានទឹកមាត់ជាដើមនោះ ដែលបុគ្គលលាងដោយទឹកថ្លា រមែងបរិសុទ្ធបាន ទីដែលលាងនោះ រមែងជាទីបរិសុទ្ធ មិនមានក្លិនស្អុយ យ៉ាងណា ពៀរទាំងឡាយរមែងរម្ងាប់ គឺរមែងស្ងប់ បានដល់ រមែងដល់នូវការមិនមានពៀរ ដោយទឹកគឺខន្តី និងមេត្តា ដោយការធ្វើទុកក្នុងចិត្តដោយឧបាយ ដោយការពិចារណាដូច្នោះនោះឯង ។

បាទព្រះគាថាថា **ឯស ធម្មោ សនន្តនោ** សេចក្តីថា ធម៌នេះ ដែលរាប់ថាការស្ងប់ពៀរដោយការមិនមានពៀរ ជាបុរាណធម៌ គឺជាមាគ៌ានៃព្រះពុទ្ធព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយរាល់ៗ អង្គ យាងទៅហើយ ។

ក្នុងកាលចប់គាថា យក្ខិនីនោះតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ។

ព្រះសាស្តា បានត្រាស់នឹងស្រីនោះថា នាងចូរឲ្យបុត្ររបស់នាងដល់យក្ខិនីចុះ នាងកុលធីតាពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គខ្លាច ព្រះសាស្តាត្រាស់ថា នាងកុំខ្លាចឡើយ ព្រោះអាស្រ័យយក្ខិនីនេះ អន្តរាយមិនមានដល់នាងឡើយ នាងបានឲ្យបុត្រដល់យក្ខិនីនោះហើយ យក្ខិនីនោះពទារកនោះឱបថើបហើយ ឲ្យដល់នាងវិញ ហើយទ្រហោយំ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរយក្ខិនីនោះថា តើនាងកើតអ្វី យក្ខិនី

ក្រាបទូលថា បពិត្រព្រះអង្គ កាលមុនខ្ញុំម្ចាស់សម្រេចការចិញ្ចឹមជីវិត ដោយមិនជ្រើសរើស គង់មិនទាន់បានអាហារល្មមពេញពោះ ឥឡូវនេះ ខ្ញុំម្ចាស់ចិញ្ចឹមជីវិតបានដូចម្ដេច ។

លំដាប់នោះ ព្រះសាស្ដាត្រាស់លួងលោមយក្ខិនីនោះថា នាងកុំគិតឡើយ ដូច្នេះហើយ ត្រាស់នឹងស្រីនោះថា នាងចូរនាំយក្ខិនីទៅឲ្យនៅក្នុងផ្ទះរបស់ខ្លួន ហើយចូរបដិបត្តិដោយបបរ និងបាយយ៉ាងល្អ ។ ស្រីនោះនាំយក្ខិនីទៅហើយ ឲ្យស្នាក់នៅក្នុងរោងត្បាល់ក្បឿង បានបដិបត្តិដោយបបរ និងបាយយ៉ាងល្អហើយ ក្នុងកាលបុកស្រូវអង្រែប្រាកដជដល់យក្ខិនីនោះ ដូចត្រូវក្បាល ។ ទើបហៅនាងកុលធីតាដែលជាសម្លាញ់មកហើយ ពោលថា ខ្ញុំមិនអាចនៅក្នុងទីនេះបាន នាងចូរឲ្យខ្ញុំស្នាក់នៅក្នុងទីដទៃចុះ ស្រីសម្លាញ់នោះឲ្យស្នាក់នៅក្នុងទីទាំងនេះ គឺក្នុងរោងអង្រែក្បែរពាងទឹក ក្បែរចង្ក្រាន ត្រង់សំយាបផ្ទះ ក្បែរគំនរសំរាម ក្បែរទ្វារស្រុក នាងក៏ពោលថា ក្នុងរោងអង្រែនេះ អង្រែរមែងប្រាកដដូចវាយក្បាលខ្ញុំ ត្រង់ក្បែរពាងទឹកនេះ ពួកក្មេងរមែងបាចទឹកដែលសល់ទៅ ។ ក្បែរចង្ក្រាននេះ ពួកឆ្កែរមែងមកដេក ត្រង់សំយាបផ្ទះ ពួកក្មេងរមែងធ្វើស្មោកគ្រោក ក្បែរគំនរសំរាមនេះ ជនទាំងឡាយរមែងចាកសំរាម ក្បែរទ្វារស្រុកនេះ ពួកក្មេងអ្នកស្រុក រមែងលេងក្នាល់គ្នាដោយការគណនាដូច្នេះហើយ បានឃាត់ទីទាំងពួងនោះ ។

គ្រានោះ ទើបស្រីសម្លាញ់ ឲ្យនាងយក្ខិនីនោះ ស្នាក់នៅត្រង់ទីស្ងាត់ខាងក្រៅស្រុកហើយ នាំភោជនមានបបរ និងបាយជាដើមយ៉ាងល្អ ទៅដើម្បីយក្ខិនី

នោះ ហើយបដិបត្តិក្នុងទីនោះ ។ យក្ខិនីនោះគិតយ៉ាងនេះថា ឥឡូវនេះ សម្លាញ់របស់អញមានឧបការៈច្រើនដល់អញ ណ្ហើយចុះ អញនឹងតបគុណណាមួយដូច្នេះហើយ បានប្រាប់ដល់ស្រីសម្លាញ់នោះថា ក្នុងឆ្នាំនេះ នឹងមានភ្លៀងល្អនាងចូរធ្វើស្រូវក្នុងទីទួលចុះ ក្នុងឆ្នាំនេះ មានភ្លៀងរាំង នាងចូរធ្វើស្រូវត្រង់ទីទំនាបចុះ សំណាបដែលពួកជនដ៏សេសធ្វើហើយ រមែងខូចបង់ដោយទឹកច្រើនពេកខ្លះ ដោយទឹកតិចខ្លះ ចំណែកសំណាបរបស់នាងកុលធីតានោះ រមែងបរិបូណ៌ពន់ពេក ។

គ្រានោះ ពួកជនដ៏សេសទាំងនោះនាំគ្នាសួរនាងថា នែនាង សម្ទូងដែលនាងធ្វើហើយ មិនខូចខាតដោយទឹកច្រើនពេក រមែងមិនខូចខាតដោយទឹកតិចពេក នាងដឹងភ្លៀងល្អ និងភ្លៀងរាំងហើយ ទើបធ្វើការងារឬ ។ សេចក្តីនេះដូចម្តេចហ្ន៎ នាងប្រាប់ថា យក្ខិនីជាសម្លាញ់របស់ខ្ញុំប្រាប់ភាពដែលភ្លៀងល្អ និងភ្លៀងរាំងដល់ខ្ញុំ ខ្ញុំធ្វើស្រូវទាំងឡាយ ក្នុងទីទួល និងទីទំនាបតាមពាក្យរបស់យក្ខិនីនោះ ហេតុនោះ ទើបស្រូវរបស់ខ្ញុំសម្បូរល្អ ។ ពួកអ្នកមិនឃើញភោជនមានបបរ និងបាយជាដើម ដែលខ្ញុំនាំទៅអំពីផ្ទះជានិច្ចទេឬ របស់ទាំងនោះ ខ្ញុំនាំទៅឲ្យយក្ខិនីនោះ សូម្បីពួកអ្នកក៏ចូរនាំភោជន មានបបរ និងបាយជាដើមយ៉ាងល្អ ទៅឲ្យយក្ខិនីផងចុះ នាងនឹងមើលថែការងាររបស់ពួកអ្នកដែរ ។

គ្រានោះ ពួកអ្នកស្រុកទាំងអស់នាំគ្នាធ្វើសក្ការៈដល់យក្ខិនីនោះហើយ ។ ចាប់តាំងពីពេលនោះមក នាងមើលថែការងារទាំងឡាយរបស់ជនទាំងពួង ជាអ្នកបាននូវលាភដ៏ប្រសើរ មានបរិវារច្រើនហើយ ។

ក្នុងកាលតមក យក្ខិនីនោះរៀបចំសលាកភត្ត ៨ សម្រាប់ហើយ ។ សលាកភត្តនោះ ជនទាំងឡាយនៅតែប្រគេនរហូតដល់សព្វថ្ងៃនេះឯង ៕

**រឿង នាងកាឡីយក្ខិនី ចប់**

# រឿង ភិក្ខុក្រុងកោសម្ពី

## លំនាំដើម

ព្រះសាស្ដា គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុក្រុងកោសម្ពី ត្រាស់ព្រះធម្មទេសនាថា **បរេ ច ន វិជានន្តិ** ជាដើម ។

សេចក្ដីពិស្ដារថា ភិក្ខុពីររូប គឺព្រះវិនយធរមួយរូប ព្រះធម្មកថិកមួយរូប មានបរិវារមួយរូប ៥០០ បាននៅក្នុងឃោសិតារាម ក្បែរក្រុងកោសម្ពី ។ ថ្ងៃមួយ ក្នុងភិក្ខុពីររូបនោះ ធម្មកថិកទៅបន្ទន់ហើយ វៀរទឹកជម្រះដ៏សេសទុកក្នុងភាជន៍ ត្រង់អាងទឹកហើយ ចេញមក ។ ក្រោយមក ព្រះវិនយធរចូលទៅត្រង់អាងទឹកនោះ ឃើញទឹកនោះ ចេញមកសួរព្រះធម្មកថិកថា អាវុសោ លោកបន្សល់ទឹកទុកឬ ព្រះធម្មធរពោលថា ករុណាលោកម្ចាស់ ព្រះវិនយធរពោលថា លោកមិនដឹងថា អាបត្តិ ព្រោះការបន្សល់ទឹកនេះឬ ព្រះធម្មធរពោលថា ខ្ញុំព្រះករុណាមិនដឹង ព្រះវិនយធរពោលថា មិនដឹង ក៏ហីទៅចុះ អាវុសោ តែជាអាបត្តិក្នុងសេចក្ដីនេះ ព្រះធម្មធរពោលថា បើយ៉ាងនោះ ខ្ញុំ

នឹងសម្តែងអាបត្តិនោះចេញ ។ ព្រះវិនយធរពោលថា អាវុសោ បើសេចក្តីនោះ លោកមិនក្លែងព្រោះមិនមានស្មារតី អាបត្តិមិនមាន ។

ព្រះធម្មកថិកនោះ បានជាបុគ្គលមានការឃើញអាបត្តិនោះ ថាមិនមែនអាបត្តិ ។ ចំណែកព្រះវិនយធរបានប្រាប់ដល់ពួកនិស្សិតរបស់ខ្លួនថា ព្រះធម្មកថិករូបនេះ សូម្បីត្រូវអាបត្តិក៏មិនដឹង ពួកនិស្សិតព្រះវិនយធរនោះ ឃើញពួកនិស្សិតរបស់ព្រះធម្មកថិកនោះហើយ បានពោលថា ឧបជ្ឈាយ៍របស់ពួកលោកសូម្បីត្រូវអាបត្តិហើយ ក៏មិនដឹងថា ត្រូវអាបត្តិ ។ ពួកកូនសិស្សរបស់ព្រះធម្មកថិកនោះ ទៅប្រាប់ដល់ឧបជ្ឈាយ៍របស់ខ្លួនហើយ ។ ព្រះធម្មកថិកនោះពោលយ៉ាងនេះថា ព្រះវិនយធររូបនេះកាលមុនពោលថា មិនជាអាបត្តិឥឡូវនេះ ពោលថាជាអាបត្តិ ព្រះវិនយធរនោះពោលមុសា ពួកកូនសិស្សរបស់ព្រះធម្មកថិកទៅពោលថា ឧបជ្ឈាយ៍របស់ពួកលោកពោលមុសា ពួកនិស្សិតរបស់ព្រះវិនយធរ និងព្រះធម្មកថិកនោះ ធ្វើនូវជម្លោះដល់គ្នា និងគ្នាឲ្យចម្រើនហើយ ដោយប្រការយ៉ាងនេះ ។

ក្រោយមក ព្រះវិនយធរបានឱកាសហើយ ទើបបានធ្វើឧក្ខេបនីយកម្មដល់ព្រះធម្មកថិក ព្រោះទោសដែលមិនឃើញអាបត្តិ ។ ចាប់តាំងពីកាលនោះ សូម្បីពួកឧបដ្ឋាក ដែលប្រគេនបច្ច័យដល់ភិក្ខុពីររូបនោះ ក៏បែកគ្នាជាពីរចំណែក ពួកភិក្ខុនីដែលទទួលឱវាទក្តី ពួកអារក្ខទេវតាក្តីរបស់ភិក្ខុពីររូបនោះ ពួកអាកាសទេវតាដែលជាសម្លាញ់ស្និទស្នាលរបស់ពួកអារក្ខទេវតាទាំងនោះក្តី ពួកបុថុជ្ជនទាំងឡាយក្តី ក៏បែកគ្នាជាពីរចំណែក រហូតដក់ព្រហ្មលោក ក៏កោលាហលកង

រំពងដោយសំឡេងតែមួយ រហូតដល់អកនិដ្ឋភព ។

គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះតថាគត ក្រាបទូលការដែលពួកភិក្ខុលើកវត្ត ប្រកាន់ថា ព្រះធម្មកថិករូបនេះ សង្ឃលើកវត្តហើយ ដោយកម្មដែលប្រកបដោយធម៌ពិត កាលដែលពួកភិក្ខុប្រព្រឹត្តតាមព្រះធម្មកថិកដែលសង្ឃលើកវត្តហើយ ប្រកាន់ថា ព្រះឧបជ្ឈាយ៍របស់ពួកយើង សង្ឃលើកវត្តហើយ ដោយកម្មដែលមិនប្រកបដោយធម៌ ។ ការដែលពួកភិក្ខុប្រព្រឹត្តតាមព្រះធម្មកថិក បុគ្គលដែលសង្ឃលើកវត្តទាំងនោះ សូម្បីពួកភិក្ខុដែលលើកវត្តឃាត់ហើយ ក៏នៅតែចចេសតាមចោមរោមព្រះធម្មកថិកនោះ ។ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ជូនឱវាទទៅថា ភិក្ខុទាំងឡាយ ចូរព្រមព្រៀងគ្នាអស់វារៈពីរដងហើយ ទ្រង់បានឮថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយមិនប្រាថ្នាព្រមព្រៀងគ្នាឡើយ លើកទីបី ទ្រង់ឮថា ភិក្ខុសង្ឃបែកគ្នាហើយ ភិក្ខុសង្ឃបែកគ្នាហើយ ដូច្នេះ ទើបទ្រង់ទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ហើយត្រាស់ទោសក្នុងការលើកវត្តរបស់ពួកភិក្ខុដែលលើកវត្ត និងទោសក្នុងការមិនឃើញអាបត្តិរបស់ពួកភិក្ខុក្រៅអំពីនេះហើយ ទ្រង់អនុញ្ញាតសង្ឃកម្មទាំងឡាយ មានឧបោសថជាដើម ក្នុងសីមាតែមួយ ត្រង់ឃោសិតារាមនោះឯង ដល់ភិក្ខុទាំងឡាយទៀត ហើយទ្រង់បញ្ញត្តិវត្តក្នុងរោងឆាន់ថា ម្នាលភិក្ខុទាំងឡាយ គប្បីអង្គុយក្នុងជួរមានអាសនៈមួយៗ ក្នុងចន្លោះៗ ដូច្នេះជាដើម ដល់ភិក្ខុទាំងឡាយដែលកើតការប្រេះឆា ក្នុងទីទាំងឡាយ មានរោងឆាន់ជាដើម ហើយទ្រង់បានឮថា សូម្បីឥឡូវនេះ ភិក្ខុទាំងឡាយ ក៏នៅតែប្រេះឆា

និងគ្នា ទើបទ្រង់ទៅកាន់ឃោសិតារាមនោះ ហើយត្រាស់ឃាត់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំបីធ្វើការប្រេះឆាគ្នា ឡើយ ដូច្នេះជាដើមហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ការប្រេះឆា ការឈ្លោះប្រកែក ប្រណាំងប្រជែង និងការវិវាទនោះ ធ្វើនូវសេចក្ដីវិនាសមកឲ្យមែនពិត សូម្បីសត្វប្រចៀចអាស្រ័យការឈ្លោះគ្នា គង់អាចធ្វើស្ដេចដំរីឲ្យដល់នូវការអស់ជីវិត ដូច្នេះហើយ ទ្រង់ត្រាស់លដុកិកជាតក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរព្រមព្រៀងគ្នាចុះ កុំវិវាទគ្នាឡើយ ព្រោះថា សូម្បីសត្វចាបទាំង-ឡាយ អាស្រ័យការវិវាទគ្នា ដល់នូវការអស់ជីវិត ដូច្នេះហើយ ទ្រង់ត្រាស់វដ្ដកជាតក ។

ទោះបីយ៉ាងនេះ ពួកភិក្ខុនោះក៏មិនស្ដាប់ព្រះវាចា កាលភិក្ខុជាធម្មវាទីរូបណាមួយមិនពេញចិត្តឲ្យព្រះតថាគតទ្រង់លំបាក ក៏ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ដែលជាម្ចាស់នៃធម៌ ទ្រង់បង្អង់សិន បពិត្រព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទ្រង់មានសេចក្ដីខ្វល់ខ្វាយតិច ប្រកបព្យាយាមក្នុងធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ចុះ ពួកខ្ញុំព្រះអង្គនឹងប្រាកដ ព្រោះការប្រេះឆា ការទាស់ទែង ការប្រកួតប្រជែង និងការវិវាទនោះឯង ព្រះដ៏មានព្រះភាគត្រាស់និទានដល់ភាពដែលព្រះបាទទីឃីតិកោសលរាជ ត្រូវព្រះបាទព្រហ្មទត្ត រឹបជាន់យកទ្រព្យសម្បត្តិ ក្លែងភេទមិនឲ្យអ្នកណាស្គាល់ ស្ដេចនៅក្នុងក្រុងពារាណសី ត្រូវចាប់ផ្ដាច់ព្រះជន្មហើយ និងការដែលព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារនោះ ព្រមព្រៀងគ្នា ចាប់តាំងពីកាលទីឃាវុកុមារ លើកព្រះជន្មរបស់ព្រះអង្គថ្វាយ

ថា ម្នាលភិក្ខុទាំងឡាយ រឿងនេះធ្លាប់មានមកហើយក្នុងក្រុងពារាណសី មានព្រះបាទក្រុងកាសីមួយអង្គ ព្រះនាមថាព្រហ្មទត្តដូច្នេះជាដើម ។ សូម្បីត្រាស់ទូន្មានថា ម្នាលភិក្ខុទាំងឡាយ ការអត់សង្កត់ និងការស្ងប់ស្ងៀមបែបនោះគង់មានហើយដល់ព្រះរាជាទាំងនោះ ដែលមានដំបងកាន់ហើយ មានសស្ត្រាកាន់ហើយ ការដែលអ្នកទាំងឡាយបួសហើយក្នុងធម្មវិន័យ ដែលពោលប្រពៃហើយយ៉ាងនេះ គួរជាអ្នកអត់ធ្មត់ ជាអ្នកស្ងប់ស្ងៀម គប្បីស្អាតក្នុងធម្ម-វិន័យនេះឯង ដូច្នេះហើយ ក៏មិនអាចឲ្យភិក្ខុទាំងឡាយព្រមព្រៀងគ្នាបាន ។

ព្រះដ៏មានព្រះភាគ ទ្រង់រអាព្រះហឫទ័យព្រោះការនៅរង្កៀសនោះ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ តថាគតនៅរង្កៀសជាទុក្ខ ភិក្ខុទាំងនេះមិនធ្វើតាមពាក្យរបស់តថាគត បើដូច្នោះ តថាគតគប្បីចៀសចេញចាកគណៈនៅម្នាក់ឯងដូច្នេះហើយ ទ្រង់យាងបិណ្ឌបាតក្នុងក្រុងកោសម្ពី មិនត្រាស់ប្រាប់ភិក្ខុសង្ឃទ្រង់កាន់បាត្រចីវររបស់ទ្រង់ យាងទៅពាលកលោណការាមតែមួយព្រះអង្គឯងត្រាស់ឯកចារិកវត្តដល់ព្រះភគុ ត្រង់ពាលកលោណការាមនោះហើយ ត្រាស់អានិសង្សនៃសាមគ្គីរសដល់កុលបុត្រ ៣ រូប ក្នុងមិគទាយវ័ន ឈ្មោះបាចីនវំស: ហើយយាងទៅកាន់ព្រៃបាលិលេយ្យក: ។ បានឮមកថា គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់អាស្រ័យព្រៃបាលិលេយ្យក: ទ្រង់ចាំវស្សាត្រង់គល់សាល-ព្រឹក្សធំ ក្នុងដងព្រៃរក្ខិតវ័ន ដែលដំរីបាលិលេយ្យក:ឧបដ្ឋាក នៅជាសុខ ។

ចំណែកពួកឧបាសក ដែលនៅក្នុងក្រុងកោសម្ពីឯណោះ ទៅកាន់វិហារមិនឃើញព្រះសាស្តា ទើបសួរថា បពិត្រលោកម្ចាស់ ព្រះសាស្តាយាងទៅទី

ណា ភិក្ខុទាំងនោះពោលថា ទ្រង់ទៅកាន់ព្រៃបាលិលេយ្យកៈហើយ ឧបាសក សួរថា ព្រោះហេតុអ្វី ភិក្ខុទាំងឡាយប្រាប់ថា ទ្រង់ព្យាយាមធ្វើពួកអាត្មាឲ្យព្រមព្រៀងគ្នា តែពួកអាត្មាមិនបានជាអ្នកព្រមព្រៀងគ្នាឡើយ ឧបាសកពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយ បួសក្នុងសម្នាក់របស់ព្រះសាស្ដាហើយ សូម្បីទ្រង់ធ្វើសាមគ្គី ក៏មិនបានជាអ្នកសាមគ្គីគ្នាហើយឬ ភិក្ខុទាំងឡាយពោលថា អើ យ៉ាងនោះឯង ពួកមនុស្សគិតថា ពួកភិក្ខុនេះ បួសក្នុងសម្នាក់របស់ព្រះសាស្ដាហើយ សូម្បីទ្រង់ធ្វើសាមគ្គីក៏មិនសាមគ្គីគ្នា ពួកយើងមិនបានឃើញព្រះសាស្ដា ព្រោះអាស្រ័យភិក្ខុទាំងឡាយនេះ ពួកយើងមិនថ្វាយអាសនៈ នឹងមិនធ្វើសាមីចិកម្ម មានការថ្វាយបង្គំជាដើមដល់ភិក្ខុទាំង-ឡាយនេះ ។ ចាប់តាំងពីកាលនោះមក ក៏មិនធ្វើសូម្បីត្រឹមតែសាមីចិកម្មដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយស្គមស្គាំងព្រោះមានអាហារតិច ក្នុងកាលពីរបីថ្ងៃប៉ុណ្ណោះក៏ជាបុគ្គលត្រង់ សម្ដែងទោសដែលប្រព្រឹត្តកន្លងដល់គ្នានិងគ្នា សូមខមាទោសដល់គ្នានិងគ្នាហើយ ពោលថា នែឧបាសកទាំងឡាយ ពួកអាត្មាព្រមព្រៀងគ្នាហើយ ពួកអ្នកចូរឲ្យពួកអាត្មាដូចកាលមុនចុះ ។ ឧបាសកទាំងឡាយពោលថា លោកម្ចាស់ទាំងឡាយ ទូលសូមខមាទោសព្រះសាស្ដាហើយឬ ភិក្ខុទាំងឡាយប្រាប់ថា មិនទាន់បានខមាទោសទេ ឧបាសកទាំង-ឡាយពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយ ទូលសូមខមាទោសនឹងព្រះសាស្ដាចុះ ចំណែកពួកខ្ញុំ និងពួកលោកម្ចាស់ នឹងជាគ្នាដូចកាលមុនក្នុងកាលពួកលោកម្ចាស់សូមខមាទោសព្រះសាស្ដាហើយ ។

ភិក្ខុទាំងឡាយមិនអាចទៅកាន់សម្នាក់របស់ព្រះសាស្តា ព្រោះខាងក្នុងវស្សា ញ៉ាំងខាងក្នុងវស្សានោះឲ្យកន្លងទៅដោយសេចក្តីលំបាក ។

ចំណែកព្រះសាស្តាដែលដំរីនោះឧបដ្ឋាក ប្រថាប់នៅជាសុខហើយ ចំណែកដំរីនោះលះហ្វូងចូលទៅកាន់ដងព្រៃនោះ ដើម្បីការនៅជាសុខ ព្រះធម្មសង្គាហកាចារ្យពោលដូចម្តេច ព្រះធម្មសង្គាហកាចារ្យពោលថា ( គ្រានោះ សេចក្តីត្រិះរិះមានដល់ស្តេចដំរីនោះថា ) អញត្រូវរុកកួនដោយពួកដំរីញី ដំរីស្ទាវ និងកូនដំរី ទំពាស៊ីស្មៅដែលគេកាត់ចុងហើយ និងចាំស៊ីមែកឈើដែលបាក់ធ្លាក់ចុះ ហើយអញផឹកទឹកដែលល្អក់ កាលអញចុះកាន់កំពង់ហើយ ពួកដំរីញីក៏ដើរជ្រៀតបៀតទៅ បើដូច្នោះ អញនឹងចេញអំពីហ្វូងម្នាក់ឯង ។ គ្រានោះឯង ស្តេចដំរីនោះ ចៀសចេញអំពីហ្វូង ចូលទៅក្នុងព្រៃបាលិលេយ្យកៈ ដែលជាព្រៃរក្ខិតវន ត្រង់មណ្ឌលដើមសាលព្រឹក្សធំ ដែលព្រះដ៏មានព្រះភាគទ្រង់គង់ហើយ កាលចូលទៅហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ សម្លឹងមើលមិនឃើញវត្ថុណាមួយ ទើបជាន់ត្រង់គល់សាលព្រឹក្សធំដោយជើង ឈូសឲ្យរាបស្មើ កាន់មែកឈើដោយប្រមោយបោស ។ តាំងអំពីនោះមក ស្តេចដំរីនោះចាប់ក្អមដោយប្រមោយ ដងទឹកឆាន់ នាំមកតម្កល់ទុក កាលទ្រង់បំណងដោយទឹកក្តៅ ក៏រៀបចំទឹកក្តៅថ្វាយ ។ ស្តេចដំរីនោះ រៀបចំទឹកក្តៅបានដូចម្តេច ស្តេចដំរីនោះកួតឈើងាប់ដោយប្រមោយ ឲ្យភ្លើងកើតឡើង ដាក់អុសឲ្យឆេះឡើង យកថ្មដាក់ក្នុងគំនរភ្លើងនោះហើយ ឆ្កឹះដុំថ្មនោះទៅដោយកំណាត់ឈើ ប្រមៀលចុះទៅក្នុងត្រពាំងតូច ដែលខ្លួនចំណាំ លំដាប់

*នោះ លូកប្រមោយចូលទៅក្នុង ដឹងថា ទឹកក្តៅហើយ ទើបថ្វាយបង្គំព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា ម្នាលបាលិលេយ្យកៈ ទឹកអ្នកដាំហើយឬ ដូច្នេះហើយ ទ្រង់យាងទៅស្រង់ក្នុងទីនោះ ។ ក្នុងកាលនោះ ស្តេចដំរីនោះនាំផ្លែឈើជាច្រើនមកថ្វាយដល់ព្រះសាស្តា កាលព្រះសាស្តាទ្រង់ចូលស្រុកដើម្បីបិណ្ឌបាត ស្តេចដំរីនោះកាន់បាត្រ និងចីវរទុកលើពោង ដើរតាមព្រះសាស្តាទៅ ។ ព្រះសាស្តាយាងដល់ស្រុកហើយប្រាប់ថា ម្នាលបាលិលេយ្យកៈ ចាប់អំពីនេះទៅ អ្នកមិនអាចទៅបានឡើយ អ្នកចូរយកបាត្រ និងចីវររបស់តថាគតមក ដូច្នេះហើយ ឲ្យស្តេចដំរីនោះយកបាត្រ និងចីវរ មកថ្វាយហើយ ទ្រង់ចូលស្រុកដើម្បីបិណ្ឌបាត ចំណែកស្តេចដំរីនោះឈរក្នុងទីនោះឯង ទម្រាំព្រះសាស្តាទ្រង់យាងមក ក្នុងពេលព្រះសាស្តាទ្រង់យាងមក ធ្វើការទទួលហើយ កាន់បាត្រ និងចីវរដោយន័យមុន ទៅដាក់ចុះក្នុងទីប្រថាប់ហើយ ថ្វាយនូវការបក់ដោយមែកឈើ សម្តែងវត្ត ។ ក្នុងរាត្រី ស្តេចដំរីនោះកាន់កំណាត់ឈើធំដោយប្រមោយ ត្រាច់ទៅក្នុងចន្លោះៗ នៃដងព្រៃ ទម្រាំអារុណរះឡើង ដើម្បីការពារអន្តរាយដែលមានអំពីសត្វសាហាវ ដោយតាំងចិត្តថា អញនឹងរក្សាព្រះសាស្តា ។ បានឮថា ដងព្រៃនោះ ឈ្មោះថា រក្ខិតវនសណ្ឌៈ តាំងអំពីកាលនោះមក ។ កាលអរុណរះហើយ ស្តេចដំរីនោះ ធ្វើវត្តទាំងពួងដោយឧបាយនោះឯង ផ្តើមតាំងអំពីការថ្វាយទឹកលុបព្រះភក្ត្រ ។*

*ក្នុងកាលនោះ ពានរមួយឃើញដំរីនោះក្រោកឡើងហើយ ធ្វើអភិសមាចារិកវត្តដល់ព្រះតថាគតហើយគិតថា អញនឹងធ្វើអ្វីមួយថ្វាយហ្ន៎ ហើយត្រាច់*

ទៅ ថ្ងៃមួយ ឃើញសម្បុកឃ្មុំប្រាសចាកមេត្រង់មែកឈើ កាច់មែកឈើហើយ នាំសម្បុកឃ្មុំព្រមទាំងមែកឈើ ទៅកាន់សម្នាក់ព្រះសាស្តា បានកាច់ស្លឹក ចេកទ្រថ្វាយ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ ពានរកំពុងសម្លឹងមើល ដោយគិតថា ព្រះសាស្តាទ្រង់ធាន់ឬអត់ហ្ន៎ ឃើញព្រះសាស្តាទ្រង់ទទួលហើយ គង់ធ្វើព្រងើយ គិតថា ហេតុអ្វីហ្ន៎ ទើបចាប់មែកឈើប្រែឡើង ប្រែចុះ ពិចា-រណាមើល ឃើញកូនឃ្មុំតូចៗ ហើយ ទើបនាំកូនឃ្មុំនោះចេញសន្សើមៗ ហើយប្រគេនជាថ្មី ។ ព្រះសាស្តាទ្រង់សោយហើយ ។ ពានរនោះមានចិត្ត ត្រេកអរ បានចាប់មែកឈើនោះៗ ឈរសម្រាក ក្នុងកាលនោះ មែកឈើ ដែលពានរនោះចាប់ក្តី មែកឈើដែលពានរនោះឈរហើយក្តី បាក់ហើយ ។ ពានរនោះធ្លាក់ចុះចំដង្គត់ឈើមួយ មានខ្លួនត្រូវដង្គត់ទម្លុះហើយ មានចិត្តជ្រះថ្លា ធ្វើកាលកិរិយាហើយ កើតក្នុងវិមានមាសកម្ពស់ ៣០ យោជន៍ ក្នុងស្ថាន តាវត្តិង្ស មានស្រីទេពអប្សរមួយពាន់ជាបរិវារ ។

កាលដែលព្រះតថាគត ដែលដំរីឧបដ្ឋាកប្រថាប់នៅក្នុងដងព្រៃរក្ខិតវន នោះ បានប្រាកដពេញផ្ទៃជម្ពូទ្វីប ។ ត្រកូលធំៗ គឺអនាថបិណ្ឌិកសេដ្ឋី និង នាងវិសាខាមហាឧបាសិកាជាដើម បានបញ្ជូនដំណឹងអំពីនគរសាវត្ថី ទៅដល់ ព្រះអានន្ទត្ថេរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្ហាញព្រះសាស្តា ដល់ពួកខ្ញុំ ។ ចំណែកភិក្ខុ ៥០០ រូបដែលនៅក្នុងទិសចាំវស្សាហើយ ចូលទៅ រកព្រះអានន្ទត្ថេរ ស្នើថា អាវុសោអានន្ទ ធម្មីកថាក្នុងទីចំពោះព្រះភក្ត្រនៃ ព្រះដ៏មានព្រះភាគ យើងខ្ញុំខានស្តាប់មកយូរហើយ អាវុសោអានន្ទ យើងខ្ញុំ

*គប្បីបានស្តាប់ធម្មីកថា ក្នុងទីចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ។ ព្រះថេរៈនាំភិក្ខុនោះទៅក្នុងទីនោះ ហើយគិតថា ការចូលទៅកាន់សម្នាក់ព្រះតថាគតដែលទ្រង់នៅមួយព្រះអង្គឯងអស់ត្រីមាស មួយអន្លើដោយភិក្ខុមានប្រមាណប៉ុណ្ណេះ មិនគួរឡើយ ដូច្នេះហើយ ទើបបញ្ឈប់ភិក្ខុនោះខាងក្រៅហើយ ចូលទៅគាល់ព្រះសាស្តាមួយអង្គឯងប៉ុណ្ណោះ ។ ស្តេចដំរីបាលិលេយ្យកៈឃើញព្រះអានន្ទត្ថេរនោះហើយ កាន់មែកឈើស្ទុះទៅ ព្រះសាស្តាទតឃើញហើយត្រាស់ថា ចៀសចេញទៅបាលិលេយ្យកៈ កុំឃាត់លោកឡើយ ភិក្ខុនោះជាឧបដ្ឋាក ។ ស្តេចដំរីបាលិលេយ្យកៈនោះ ទម្លាក់កំណាត់ឈើក្នុងទីនោះឯងហើយបានអើពើដល់ការទទួលបាត្រ និងចីវរ ។ ព្រះថេរៈមិនបានឲ្យឡើយ ។ ស្តេចដំរីបានគិតថា បើភិក្ខុរូបនេះ មានវត្តបានរៀនហើយ លោកគង់នឹងមិនដាក់បរិក្ខាររបស់ខ្លួនលើផ្ទាំងថ្ម ដែលជាទីប្រថាប់របស់ព្រះសាស្តាឡើយ ។ ព្រះថេរៈដាក់បាត្រ និងចីវរ ត្រង់ផែនដីហើយ ។*

*ពិតហើយ ជនដែលដល់ព្រមហើយដោយវត្ត រមែងមិនដាក់បរិក្ខាររបស់ខ្លួនលើទីគង់ ឬលើទីសិងរបស់គ្រូ ។ ដំរីនោះឃើញអាការនោះ មានចិត្តជ្រះថ្លាហើយ ។ ព្រះថេរៈអភិវាទព្រះសាស្តាហើយ គង់ក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ អ្នកមកម្នាក់ឯងប៉ុណ្ណោះឬ ។ ទ្រង់ស្តាប់ភាពដែលព្រះថេរៈមកហើយជាមួយភិក្ខុ ៥០០ ទើបត្រាស់ថា ភិក្ខុទាំងនោះនៅឯណា ព្រះថេរៈទូលថា ខ្ញុំព្រះអង្គមិនជ្រាបទឹកព្រះហឫទ័យរបស់ព្រះអង្គ ទើបបញ្ឈប់ពួកលោកនៅខាងក្រៅ ហើយមកតែឯង ។ ព្រះសាស្តា*

ត្រាស់ថា ចូរអ្នកហៅភិក្ខុទាំងឡាយមកចុះ ព្រះថេរៈបានធ្វើតាមព្រះតម្រាស់ហើយ ។ ភិក្ខុទាំងនោះមកថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរ ទាចំណែកម្ខាង ។ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងឡាយហើយ កាលភិក្ខុទាំងនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ជាព្រះសម្ពុទ្ធដ៏សុខុមជាក្សត្រដ៏សុខុម ទ្រង់ឈរ និងទ្រង់ប្រថាប់គង់មួយព្រះអង្គឯង អស់ត្រីមាសធ្វើកិច្ចដែលធ្វើបានដោយលំបាក អ្នកធ្វើវត្ត និងបដិវត្តក្តី អ្នកថ្វាយទឹកលុបព្រះភក្ត្រក្តី ប្រហែលមិនមានឡើយ ។ ព្រះសព្វញ្ញូត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងពួងរបស់តថាគត គឺស្តេចដំរីបាលិលេយ្យកៈធ្វើហើយ បុគ្គលដែលបានសម្លាញ់បែបនេះនៅជាមួយគ្នាគួរហើយ បើមិនបានសម្លាញ់បែបនេះ កាលត្រាច់ទៅម្នាក់ឯងប៉ុណ្ណោះប្រសើរជាង ដូច្នេះហើយ ទ្រង់ភាសិតគាថា ៣ គាថា ក្នុងនាគវគ្គទាំងនេះថា

> បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងនៅ ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង ។ បើស្វែងរកមិនបានសម្លាញ់ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿង ញុំាងប្រយោជន៍ឲ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯកឯងវិញ ដូចព្រះរាជាលះបង់រដ្ឋ

ដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំនោះសោត ដូចដំរីឈ្មោះមាតង្គៈ ដែលលះហ្វូងត្រាច់ទៅតែឯក ឯង ក្នុងព្រៃដូច្នោះដែរ ។

កាលត្រាច់ទៅ របស់បុគ្គលឯកឯង ជាគុណជាតិប្រសើរផុត

( ព្រោះថា ) សហាយតាគុណ រមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះ គប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយ លះបង់ហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

ក្នុងកាលចប់គាថា ភិក្ខុទាំង ៥០០ រូប តាំងនៅក្នុងអរហត្តហើយ ។ ព្រះអានន្ទត្ថេរ ក្រាបទូលដំណឹងដែលត្រកូលធំៗ មានអនាថបិណ្ឌិកសេដ្ឋីជាដើម បញ្ជូនមកហើយក្រាបទូលថា បពិត្រព្រះអង្គ អរិយសាវក ៥ កោដិ មានអនាថបិណ្ឌិកសេដ្ឋីជាប្រធាន ទន្ទឹងការយាងមករបស់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ អ្នកចូលទទួលបាត្រ និងចីវរ ដូច្នេះហើយ ឲ្យព្រះថេរៈទទួលបាត្រ និងចីវរហើយ យាងចេញទៅ ។ ស្តេចដំរីបានទៅឈររាំងផ្លូវ ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ ស្តេចដំរីធ្វើអ្វី ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំរីបំណាំងនឹងប្រគេនភិក្ខាដល់អ្នកទាំងឡាយ ដំរីនេះបានធ្វើឧបការៈដល់តថាគត អស់រាត្រីដ៏យូរ ការញ៉ាំងចិត្តរបស់ដំរីនេះឲ្យអាក់អន់មិនគួរ ម្នាលភិក្ខុទាំងឡាយ អ្នក

ទាំងឡាយចូរត្រឡប់ចុះ ។ ព្រះសាស្តាទ្រង់នាំភិក្ខុទាំងឡាយត្រឡប់ហើយ ។

ចំណែកដំរីចូលទៅកាន់ដងព្រៃហើយ ប្រមូលផ្លែឈើផ្សេងៗ មានផ្លែខ្នុរ និងផ្លែចេកជាដើមមក ធ្វើឲ្យជាគំនរ ក្នុងថ្ងៃស្អែកឡើង បានប្រគេនដល់ភិក្ខុទាំងឡាយ ។ ភិក្ខុ ៥០០ រូប មិនអាចឆាន់ផ្លែឈើទាំងឡាយឲ្យអស់បានឡើយ ។ ក្នុងកាលចប់ភត្តកិច្ច ព្រះសាស្តាទ្រង់កាន់បាត្រ និងចីវរយាងចេញទៅហើយ ។ ស្តេចដំរីទៅតាមក្នុងចន្លោះៗ នៃភិក្ខុទាំងឡាយ ឈរខាំងព្រះភក្ត្រព្រះសាស្តា ។ ភិក្ខុទាំងឡាយឃើញដូច្នោះ ទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ដំរីនេះគិតធ្វើអ្វី ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំរីនេះបញ្ជូនពួកអ្នកទៅហើយ តែបបួលតថាគតឲ្យត្រឡប់ ភិក្ខុទាំងឡាយទូលថា យ៉ាងនោះឬព្រះអង្គ ព្រះសាស្តាត្រាស់ថា អើ យ៉ាងនោះឯង ភិក្ខុទាំងឡាយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងដំរីនោះថា ម្នាលបាលិលេយ្យកៈ នេះការទៅមិនត្រឡប់របស់តថាគត ឈានក្តី វិបស្សនាក្តី មគ្គ និងផលក្តី រមែងមិនមានដល់អ្នកដោយអត្តភាពនេះ អ្នកចូរឈប់ចុះ ។ ស្តេចដំរីបានស្តាប់ព្រះតម្រាស់នោះហើយ បានស៊កប្រមោយចូលក្នុងមាត់ ទ្រហោយំ ដើរតាមទៅអំពីខាងក្រោយ ។ ស្តេចដំរីនោះបើយាងព្រះសាស្តាឲ្យត្រឡប់បាន គប្បីបដិបត្តិដោយអាការយ៉ាងនោះ ដរាបដល់អស់ជីវិត ចំណែកព្រះសាស្តាយាងដល់ព្រំដែននៃស្រុកហើយត្រាស់ថា ម្នាលបាលិលេយ្យកៈ ចាប់តាំងអំពីនេះទៅ មិនមែនជាទឹកដីរបស់អ្នក ជាទឹកដីរបស់មនុស្សទាំងឡាយ ។ មានអន្តរាយ

បៀតបៀនដោយជុំវិញ អ្នកចូរឈប់បន្តន់ចុះ ដីរនោះឈរយំក្នុងទីនោះ កាលព្រះសាស្តាបាត់អំពីគន្លងចក្ខុទៅ ក៏បែកទ្រូងស្លាប់ ធ្វើកាលកិរិយាហើយ កើតក្នុងកណ្តាលស្រីទេពអប្សរមួយពាន់ ក្នុងវិមានមាស កម្ពស់ ៣០ យោជន៍ ក្នុងតាវត្តិង្សពិភព ព្រោះសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា មានឈ្មោះថាបាលិ-លេយ្យកទេវបុត្រ ។ ចំណែកព្រះសាស្តា យាងដល់វត្តជេតពនហើយដោយលំដាប់ ។

ភិក្ខុក្រុងកោសម្ពីបានដំណឹងថា ព្រះសាស្តាយាងដល់ក្រុងសាវត្ថីហើយ បានទៅក្នុងទីនោះ ដើម្បីទូលសូមខមាទោសចំពោះព្រះសាស្តា ។ ព្រះបាទកោសលទ្រង់បានដំណឹងថា ភិក្ខុក្រុងកោសម្ពីដែលជាអ្នកបង្កការប្រេះធាទាំងនោះនិមន្តមក ទើបចូលទៅគាល់ព្រះសាស្តាទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនព្រមឲ្យភិក្ខុទាំងនោះ ចូលមកកាន់ដែនដីរបស់ទូលបង្គំឡើយ ព្រះសាស្តាត្រាស់តបថា បពិត្រមហារាជ ភិក្ខុទាំងនោះជាអ្នកមានសីល តែមិនកាន់យកពាក្យរបស់តថាគត ព្រោះវិវាទគ្នានិងគ្នាប៉ុណ្ណោះ ឥឡូវនេះ ភិក្ខុទាំងឡាយនោះ មកដើម្បីសូមខមាទោសនឹងតថាគត ។ បពិត្រមហារាជ សូមឲ្យភិក្ខុទាំងឡាយនោះមកចុះ ។

ចំណែកអនាថបិណ្ឌិកសេដ្ឋីទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនព្រមឲ្យភិក្ខុទាំងនោះចូលមកក្នុងវិហារនេះឡើយ ដូច្នេះហើយ ត្រូវព្រះសាស្តាឃាត់ដូចគ្នា បានស្ងៀមហើយ ។ កាលភិក្ខុទាំងនោះដល់ក្រុងសាវត្ថីដោយលំដាប់ហើយ ព្រះដ៏មានព្រះភាគត្រាស់ឲ្យប្រទានសេនាសនៈនាចំណែកម្ខាង ធ្វើឲ្យ

ជាទីស្វាត់ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុពួកដទៃមិនគង់ មិនឈរជាមួយភិក្ខុទាំងនោះ ។

ពួកជនដែលមកហើយ ទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ភិក្ខុទាំងឡាយណាជាអ្នកក្រុងកោសម្ពី ដែលជាអ្នកបង្កនូវការប្រេះឆាទាំងនោះ ព្រះសាស្តាទ្រង់បង្ហាញថា នុ៎ះគឺពួកភិក្ខុទាំងនោះ ។ ភិក្ខុអ្នកក្រុងកោសម្ពីទាំងនោះត្រូវពួកជនដែលមកហើយ ចង្អុលដោយម្រាមដៃថា បានឮថា នុ៎ះពួកភិក្ខុក្រុងកោសម្ពី ដែលជាអ្នកបង្កនូវជម្លោះទាំងនោះ បានឮថា នុ៎ះពួកភិក្ខុក្រុងកោសម្ពីដែលបង្កជម្លោះនោះដូច្នេះ មិនអាចងើបមុខរួច ព្រោះសេចក្តីខ្មាស ជាអ្នកឱនកចុះ ក្រាបទៀបបាទមូលនៃព្រះដ៏មានព្រះភាគ ទូលសូមខមាទោសព្រះដ៏មានព្រះភាគហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្វើកម្មធ្ងន់ហើយឈ្មោះថា អ្នកទាំងឡាយ បួសហើយក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ដូចតថាគតនេះ កាលតថាគតធ្វើនូវសាមគ្គី មិនធ្វើតាមពាក្យតថាគត ចំណែកបណ្ឌិតក្នុងកាលមុន ស្តាប់ឱវាទរបស់មាតា និងបិតា ដែលត្រូវប្រហារជីវិត កាលមាតាបិតានោះត្រូវផ្តាច់ជីវិត ក៏មិនកន្លងឱវាទនោះ ខាងក្រោយបានគ្រងរាជសម្បត្តិក្នុងដែនពីរ ដូច្នេះហើយ ទ្រង់ត្រាស់ទីឃាវុកុមារជាតកទៀត ដូចមុននោះឯងហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទីឃាវុកុមារសូម្បីកាលព្រះជនក និងព្រះជននី ត្រូវប្រហារជីវិតយ៉ាងនោះ ក៏មិនឈានកន្លងឱវាទរបស់ព្រះជនក និងព្រះជននីទាំងនោះឡើយ ក្រោយមកបានធីតារបស់ព្រះបាទព្រហ្មទត្ត គ្រងរាជ-

សម្បត្តិក្នុងដែនកាសី និងដែនកោសលទាំងពីរហើយ ចំណែកអ្នកទាំងឡាយ មិនធ្វើតាមពាក្យរបស់តថាគត ធ្វើកម្មធ្ងន់ហើយ ដូច្នេះហើយ ត្រាស់គាថានេះថា

**បរេ ច ន វិជានន្តិ មយមេត្ថ យមាម្ហសេ**

**យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។**

ជនទាំងឡាយដទៃ ( ក្រៅអំពីបណ្ឌិត ) តែងមិនដឹងខ្លួនថា យើងទាំង ឡាយនឹងវិនាសក្នុងកណ្តាលនៃពួកនេះដូច្នេះឡើយ ចំណែកជនទាំងឡាយណា ក្នុងពួកនេះ ដឹងខ្លួនថា យើងទាំង- ឡាយ នឹងវិនាសកណ្តាលនៃពួកនេះ ដូច្នេះ ការឈ្លោះប្រកែក ទាំងឡាយ រមែងរម្ងាប់អំពីជនទាំងឡាយនោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បរេ** ជាដើម សេចក្តីថា ពួកជនដែលធ្វើការ ប្រេះឆា វៀរបណ្ឌិតទាំងនោះចេញ គឺពួកដទៃក្រៅពីបណ្ឌិតនោះ ឈ្មោះថា ជន ពួកដទៃ ជនពួកដទៃនោះធ្វើនូវការវឹកវរក្នុងជំនុំសង្ឃនោះ រមែងមិនដឹងខ្លួនថា យើងទាំងឡាយរមែងលំបាក គឺបែកខ្ញែក វិនាស បានដល់ ទៅកាន់ទីជិត គឺ សម្នាក់មច្ចុជានិច្ច ។

បាទព្រះគាថាថា **យេ ច តត្ថ វិជានន្តិ** សេចក្តីថា ជនទាំងឡាយណា ដែលជាបណ្ឌិតក្នុងក្រុមនោះរមែងដឹងខ្លួនថាយើងទាំងឡាយទៅកាន់ទីជិតមច្ចុ។

បាទព្រះគាថាថា **តតោ សម្មន្តិ មេធគា** សេចក្តីថា ជនទាំងនោះដឹង យ៉ាងនេះឯង ញុំាងយោនិសោមនសិការឲ្យកើតឡើងហើយ រមែងបដិបត្តិ

ដើម្បីស្ងប់នូវការប្រកួតប្រកាន់ គឺការទាស់ទែងគ្នា ។ កាលបើដូច្នោះ ការប្រកួតប្រកាន់ទាំងនោះ រមែងស្ងប់ព្រោះបដិបត្តិរបស់បណ្ឌិតទាំងនោះ ។

ម្យ៉ាងទៀត គប្បីជ្រាបអធិប្បាយក្នុងព្រះគាថានេះយ៉ាងនេះថា ពាក្យថា **បរេ ច** ជាដើម សេចក្ដីថា ជនទាំងឡាយ សូម្បីតថាគតពោលទូន្មានថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំធ្វើនូវការបែកបាក់គ្នាដូច្នេះជាដើម ក្នុងកាលមុន ក៏មិនរាប់អានព្រោះមិនទទួលឱវាទរបស់តថាគត ឈ្មោះថា ជនពួកដទៃ ។ ជនពួកដទៃនោះ រមែងមិនដឹងខ្លួនថា យើងទាំងឡាយប្រកាន់ខុសដោយអំណាចអគតិ មានឆន្ទៈជាដើម រមែងដល់នូវការលំបាក បានដល់ព្យាយាមដើម្បីសេចក្ដីចម្រើននៃហេតុដែលធ្វើនូវសេចក្ដីវិនាស មានការប្រេះឆាជាដើមក្នុងកណ្ដាលសង្ឃនេះ ។ តែឥឡូវនេះ បុរសដែលជាបណ្ឌិតទាំងឡាយណា ក្នុងរវាងនៃអ្នកទាំងឡាយនោះ ពិចារណាដឹងច្បាស់ថា កាលមុន យើងទាំងឡាយកំពុងព្យាយាមដោយអំណាចអគតិ មានឆន្ទៈជាដើម បដិបត្តិដោយមិនប្រពៃហើយ ការប្រកួតប្រកាន់ ក៏រាប់ថាជាជម្លោះក្នុងឥឡូវនេះ ទាំងនេះ រមែងស្ងប់ចាកសម្នាក់បណ្ឌិតទាំងឡាយនោះ គឺព្រោះអាស្រ័យបុរសដែលជាបណ្ឌិតទាំងនោះ ដោយប្រការដូច្នេះ ។

ក្នុងវេលាចប់គាថា ភិក្ខុដែលប្រជុំគ្នាបានតាំងនៅក្នុងអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។៚

## រឿងភិក្ខុក្រុងកោសម្ពី ចប់

# រឿង ចុល្លកាល និងមហាកាល

## លំនាំដើម

ព្រះសាស្ដា កាលទ្រង់ចូលទៅអាស្រ័យសេតព្យនគរ ប្រថាប់នៅក្នុងព្រៃធ្នង់ ទ្រង់ប្រារព្ធចុល្លកាល និងមហាកាល ត្រាស់ព្រះធម្មទេសនានេះថា **សុភានុបស្សឹង វិហរន្តំ** ជាដើម ។

សេចក្ដីពិស្ដារថា កុដុម្ពិកៈអ្នកសេតព្យនគរ ៣ នាក់បងប្អូន គឺចុល្លកាល ១ មជ្ឈិមកាល ១ មហាកាល ១ ។ បណ្ដាបងប្អូន ៣ នាក់នោះ បងប្រុសធំ និងប្អូនប្រុសពៅ ត្រាច់ទៅក្នុងទិសទាំងឡាយ នាំរបស់របរមកដោយរទេះ ៥០០ មជ្ឈិមកាលលក់របស់ដែលបងប្អូនទាំងពីរនាំមក ។

តមកសម័យនោះ បងប្អូនទាំងពីរនោះផ្ទុកវត្ថុផ្សេងៗ ដោយរទេះ ៥០០ ទៅកាន់ក្រុងសាវត្ថី ដោះរទេះទាំងឡាយត្រង់ចន្លោះក្រុងសាវត្ថី និងវត្តជេតពន។

ក្នុងបងប្អូនពីរនាក់នោះ មហាកាលឃើញអរិយសាវកអ្នកក្រុងសាវត្ថីទាំងឡាយ មានដៃកាន់កម្រងផ្កា និងគ្រឿងក្រអូបជាដើម ទៅស្ដាប់ធម៌នាពេលល្ងាច ទើបសួរថា ជនទាំងនេះទៅណា ។ បានស្ដាប់ពាក្យនោះហើយ គិតថា សូម្បីអញក៏ទៅ ហៅប្អូនប្រុសមកហើយប្រាប់ថា នែបា អ្នកចូរជាបុគ្គលមិនប្រមាទក្នុងរទេះទាំងឡាយ ។ ចំណែកខ្ញុំនឹងទៅស្ដាប់ធម៌ ដូច្នេះហើយ ទៅថ្វាយបង្គំព្រះសាស្ដា អង្គុយត្រង់ទីបំផុតនៃបរិស័ទ ។

ថ្ងៃនោះ ព្រះសាស្ដា កាលនឹងត្រាស់អនុបុព្វីកថាតាមអធ្យាស្រ័យរបស់មហាកាលនោះ ទើបត្រាស់ទោស ការថោកទាប និងការសៅហ្មង នៃកាមទាំងឡាយ ដោយបរិយាយដ៏ច្រើន ដោយអំណាចនៃសូត្រ មានទុក្ខក្ខន្ធសូត្រ

ជាដើម ។ មហាកាលបានស្តាប់ព្រះធម្មទេសនានោះហើយ គិតថា មនុស្ស យើង ត្រូវលះវត្ថុទាំងពួងទៅ ភោគៈ និងញាតិទាំងឡាយ រមែងមិនជាប់ តាមបុគ្គលដែលទៅកាន់បរលោកឡើយ អញត្រូវការអ្វីដោយការគ្រប់គ្រង ផ្ទះ អញនឹងបួស កាលមហាជនថ្វាយបង្គំ ហើយចៀសចេញទៅ ទូលសូម បព្វជ្ជានឹងព្រះសាស្តា កាលព្រះសាស្តាត្រាស់ថា បុគ្គលដែលអ្នកគួរលាណា ម្នាក់មិនមានទេឬ មហាកាលពោលថា ប្អូនប្រុសខ្ញុំព្រះអង្គមាន កាលទ្រង់ ត្រាស់ថា បើដូច្នោះ អ្នកចូរលាគេចុះ ។ មហាកាលទទួលថា សាធុ ព្រះអង្គ ត្រឡប់មកប្រាប់ប្អូនប្រុសដូច្នេះថា នែបា អ្នកចូរគ្រប់គ្រងសម្បត្តិទាំងអស់ នេះចុះ ចុល្លកាលសួរថា ចុះបងវិញ មហាកាលប្រាប់ថា បងនឹងបួសក្នុង សម្នាក់របស់ព្រះសាស្តា ។ ចុល្លកាលអង្វរបងប្រុសនោះដោយប្រការផ្សេងៗ ក៏មិនអាចឲ្យត្រឡប់បាន ទើបពោលថា សាធុ បង សូមបងធ្វើតាមអធ្យា-ស្រ័យចុះ មហាកាលទៅបួសក្នុងសម្នាក់របស់ព្រះសាស្តាហើយ ។ ចំណែក ចុល្លកាល ក៏បួសដោយតាំងចិត្តថា អញនឹងបបួលបងប្រុសសឹក ។

ក្នុងកាលតមក មហាកាលបានឧបសម្បទាហើយ ចូលទៅគាល់ព្រះ សាស្តា ទូលសួរដល់ធុរៈក្នុងព្រះសាសនា ។ កាលព្រះសាស្តាត្រាស់ប្រាប់ ធុរៈ ២ យ៉ាងហើយ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចបំពេញ គន្ថធុរៈបាន ព្រោះខ្ញុំព្រះអង្គបួសកាលឯចាស់ តែនឹងបំពេញវិបស្សនាធុរៈឲ្យ បរិបូណ៌ ទូលឲ្យព្រះអង្គត្រាស់ប្រាប់សោសានិកធុតង្គ រហូតដល់ព្រះអរហត្ត កាលកន្លងបឋមយាម កាលជនដេកលក់អស់គ្រប់គ្នាហើយ ទៅកាន់ព្រៃខ្មោច

វេលាទៀតក្តី កាលជនទាំងអស់មិនទាន់ភ្ញាក់ ត្រឡប់មកកាន់វិហារវិញ ។

គ្រានោះ ស្រីអ្នករកស៊ីរៀបចំបុណ្យខ្មោចម្នាក់ឈ្មោះកាឡី ជាអ្នកយាមព្រៃខ្មោច ឃើញទីឈរទីអង្គុយ ទីចង្រ្កមរបស់ព្រះថេរៈហើយ គិតថា អ្នកណាហ្ន៎ មកក្នុងទីនេះ អញនឹងឃ្លាំចាប់ខ្លួន កាលមិនអាចចាប់បាន ថ្ងៃមួយទើបអុជប្រទីបត្រង់ខ្ទម ក្បែរព្រៃខ្មោច នាំកូនប្រុសស្រីទៅពួនក្នុងចំណែកម្ខាង ឃើញព្រះថេរៈនិមន្តមកក្នុងមជ្ឈិមយាម ទើបទៅថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ស្នាក់នៅក្នុងទីរបស់ពួកខ្ញុំឬ ព្រះថេរៈតបថា អើ ឧបាសិកា ស្រីនោះពោលថា បពិត្រលោកម្ចាស់ធម្មតាអ្នកនៅព្រៃខ្មោចទាំងឡាយ រៀនរបៀបរបបសិន ទើបគួរ ។

ព្រះថេរៈមិនពោលថា អាត្មានឹងប្រព្រឹត្តក្នុងរបៀបដែលនាងប្រាប់ហើយយ៉ាងណា បែរជាពោលថា ធ្វើយ៉ាងណាទើបគួរឧបាសិកា ស្រីនោះពោលថា បពិត្រលោកម្ចាស់ ធម្មតាអ្នកនៅក្នុងព្រៃខ្មោចទាំងឡាយ គួរប្រាប់កាពដែលខ្លួននៅក្នុងព្រៃខ្មោច ដល់អ្នកយាមព្រៃខ្មោច ដល់ព្រះមហាថេរៈក្នុងវិហារដល់ម្ចាស់ស្រុក ។ ព្រះថេរៈពោលថា ព្រោះហេតុអ្វី ស្រីនោះពោលថា ព្រោះពួកចោរធ្វើកម្មហើយ ត្រូវពួកម្ចាស់ទ្រព្យដេញតាមស្នាមជើងទៅ ក៏ចោលកញ្ចប់កណ្ឌៈក្នុងព្រៃ ហើយលបចៀសចេញទៅ ។ កាលបើដូច្នោះពួកមនុស្សក៏នឹងចោមរោមធ្វើអន្តរាយដល់បុគ្គលដែលនៅក្នុងព្រៃខ្មោច តែបើបានប្រាប់ដល់ម្ចាស់ស្រុកនោះហើយ ម្ចាស់ស្រុកទាំងនោះ រមែងជួយការពារអន្តរាយបាន ដោយពោលធានាថា ពួកអ្នកចូរជ្រាបកាពដែលលោកម្ចាស់

អង្គនេះ នៅក្នុងទីនេះ អស់កាលប្រមាណប៉ុណ្ណោះ លោកម្ចាស់រូបនេះ មិនមែនចោរទេ ព្រោះដូច្នោះ គួរប្រាប់ដល់ម្ចាស់ស្រុកទាំងនោះ ។

ព្រះថេរៈពោលថា កិច្ចដទៃណាមួយដែលអាត្មាគួរធ្វើមានទៀតដែរឬទេ ស្រីនោះពោលថា បពិត្រលោកម្ចាស់ ធម្មតាអ្នកនៅក្នុងព្រៃខ្មោចត្រូវវៀរវត្ថុទាំងឡាយ មានត្រី សាច់ មេ្សៅ ល្ង និងទឹកអំពៅជាដើមចេញ មិនគួរសិងនៅពេលថ្ងៃ មិនជាអ្នកខ្ជិលច្រអូស គួរប្រារព្ធព្យាយាម ភាពជាអ្នកមិនអួតអាង មិនមានមាយា ជាអ្នកមានអធ្យាស្រ័យស្អាត ពេលល្ងាច ជនត្រឡប់អស់ហើយ គប្បីមកអំពីវិហារ ពេលព្រឹក កាលពួកជនមិនទាន់ក្រោកឡើងគប្បីទៅវិហារ ។ បពិត្រលោកម្ចាស់ បើលោកម្ចាស់នៅក្នុងទីនេះ ដោយអាការយ៉ាងនេះសោត នឹងអាចញ៉ាំងកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបាន បើពួកជននាំសពមកចោល ខ្ញុំនឹងលើកឡើងកាន់ផ្ទះកំពូល ដែលពាសដោយសំពត់កម្ពល ធ្វើសក្ការៈដោយវត្ថុទាំងឡាយ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ហើយ នឹងធ្វើការដាក់សព បើលោកម្ចាស់មិនអាចញ៉ាំងកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបានសោត ខ្ញុំនឹងលើកឡើងកាន់ជើងក្ករ ហើយដុតភ្លើង យកតម្តក់ទាញសពមកខាងក្រៅ ពុះដោយពូថៅ ច្រៀកជាចម្រៀកតូចធំ ហើយដាក់ក្នុងភ្លើង បង្ហាញដល់លោកម្ចាស់ហើយ ទើបដុត ។

ពេលនោះ ព្រះថេរៈប្រាប់នាងកាឡីនោះថា ល្អហើយនាង បើនាងឃើញរូបារម្មណ៍ណាមួយហើយ ចូរប្រាប់ដល់អាត្មា ។ នាងកាឡីទទួលថា ករុណាលោកម្ចាស់ ។ ព្រះថេរៈធ្វើសមណធម៌ក្នុងព្រៃខ្មោចតាមអធ្យាស្រ័យរបស់

ខ្ជួន ។ ចំណែកព្រះចុល្លកាលត្ថេរ ជូនក្រោក ជូនអង្គុយ នឹកដល់យាវាស គិតដល់បុត្រ និងភរិយា គិតថា បងប្រុសរបស់អញនេះ ធ្វើកម្មធ្ងន់ហ្ន៎ ។

លំដាប់នោះ កុលធីតាម្នាក់ធ្វើកាលកិរិយាក្នុងពេលល្ងាច ដែលមិនទាន់ក្រៀមស្ងួត ស្គមស្គាំងព្រោះព្យាធិកម្រើកឡើងក្នុងមួយរំពេចប៉ុណ្ណោះ ពួកញាតិសែងសពកុលធីតានោះ ទៅកាន់ព្រៃខ្មោចក្នុងពេលល្ងាច មួយអន្ទើដោយគ្រឿងដុតផ្សេងៗ មានអុស និងប្រេងជាដើម ឲ្យថ្លៃឈ្នួលដល់ស្រីអ្នកយាមព្រៃខ្មោច ដោយពាក្យថា ចូរនាងរៀបចំបូជាសពនេះ ដូច្នេះហើយ ប្រគល់សពឲ្យហើយ ចៀសចេញទៅ ។ នាងដោះសំពត់របស់នាងកុលធីតានោះចេញហើយ ឃើញសរីរៈស្វាប់ភ្លាមៗ នោះនៅប្រណីត មានពណ៌ដូចមាស ទើបគិតថា អារម្មណ៍នេះ គួរបង្ហាញដល់លោកម្ចាស់ ហើយទៅថ្វាយបង្គំព្រះថេរៈពោលថា បពិត្រលោកម្ចាស់ អារម្មណ៍បែបនេះមាន សូមលោកម្ចាស់ទៅពិចារណាចុះ ។

ព្រះថេរៈទទួលថា សាធុ ដូច្នេះហើយ ទៅឲ្យបើកសំពត់ដណ្តប់ចេញហើយ ពិចារណាតាំងអំពីចុងជើងដល់ចុងសក់ហើយ ពោលថា រូបនេះប្រណីតពន់ពេក មានពណ៌ដូចមាស នាងគប្បីដាក់រូបនោះក្នុងភ្លើង ក្នុងកាលដែលរូបនោះត្រូវអណ្តាតភ្លើងធំលោកហើយ សឹមប្រាប់ដល់អាត្មា ដូច្នេះហើយទៅកាន់លំនៅរបស់ខ្លួននោះឯង គង់ហើយ ។ នាងធ្វើយ៉ាងនោះហើយ ទើបប្រាប់ដល់ព្រះថេរៈៗ ក៏ទៅពិចារណាក្នុងទីដែលត្រូវអណ្តាតភ្លើងប៉ះខ្ទប់ហើយ ពណ៌នៃសរីរៈបានដូចជាមេគោពពាល ។ ជើងទាំងពីរក្រញាង សំយុងចុះ ដៃ

ទាំងពីរក្តាប់ចូល ថ្ងាស់មានស្បែករបកហើយ ។

ព្រះថេរៈពិចារណាថា សរីរៈនេះ ធម្មជាតិធ្វើឲ្យមិនអផ្សុកដល់បុគ្គល ដែលសម្លឹងមើលក្នុងឥឡូវនេះឯង អម្បាញ់មិញនោះឯង តែឥឡូវនេះ បែរជាដល់នូវការអស់ទៅ ដល់នូវការវិនាសទៅហើយ ។ ត្រឡប់ទៅកាន់ទីសម្រាកពេលយប់ អង្គុយពិចារណាដល់ការអស់ទៅ និងការសូន្យទៅ ពោលគាថាថា

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើង និងវិនាសទៅវិញជាធម្មតា រមែងកើតឡើងហើយរលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង ។

ចម្រើនវិបស្សនាបានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ កាលលោកសម្រេចអរហត្តហើយ ព្រះសាស្តាមានភិក្ខុសង្ឃចោមរោម ទ្រង់យាងចារិកទៅកាន់សេតព្យនគរហើយ ស្តេចចូលកាន់ព្រៃធ្នង់ ។ ភរិយារបស់ព្រះចុល្លកាលបានឮថា ព្រះសាស្តាយាងមកដល់ហើយ គិតថា ពួកយើង នឹងនាំគ្នាចាប់ប្តីរបស់ពួកយើង ដូច្នេះហើយ បញ្ជូនមនុស្សទៅអារាធនាព្រះសាស្តា ។

ក្នុងទីដែលព្រះពុទ្ធទាំងឡាយ ទ្រង់នឹងស្ថិតស្ថាល គួរភិក្ខុមួយរូបដែលប្រាប់ការក្រាលអាសនៈ ត្រូវនាំមុខទៅមុន ។ អាសនៈសម្រាប់ព្រះពុទ្ធទាំងឡាយ គប្បីក្រាលត្រង់កណ្តាល អាសនៈសម្រាប់ព្រះសារីបុត្តត្ថេរ គប្បីឲ្យ

ក្រាលខាងស្តាំ អាសនៈសម្រាប់ព្រះមហាមោគ្គល្លានត្ថេរ គប្បីឲ្យក្រាលខាងឆ្វេងនៃអាសនៈរបស់ព្រះសម្ពុទ្ធ អាសនៈសម្រាប់ភិក្ខុសង្ឃ គប្បីឲ្យក្រាលទាំងសងខាងបន្ទាប់អំពីនោះទៅ ។ ព្រោះដូច្នោះ ព្រះមហាកាលត្ថេរសម្រាកនៅក្នុងទីប៉ាំងចីវរ បញ្ជូនព្រះចុល្លកាលទៅថា ចូរលោកទៅមុន ប្រាប់ដល់ការក្រាលអាសនៈ ។

ពួកជនក្នុងផ្ទះធ្វើការស្និទ្ធស្នាលនឹងលោក ចាប់តាំងពីកាលដែលពួកគេឃើញលោកក្រាលអាសនៈទាប ក្នុងទីបំផុតនៃព្រះសង្ឃត្ថេរ ក្រាលអាសនៈខ្ពស់ក្នុងទីបំផុតរបស់ព្រះសង្ឃនវកៈ ។ ព្រះចុល្លកាលនេះប្រាប់ថា ពួកនាងចូរធ្វើយ៉ាងនោះ ចូរក្រាលអាសនៈខ្ពស់ក្នុងទីខ្ពស់ ចូរក្រាលអាសនៈទាបក្នុងទីទាប ។

ពួកស្រីធ្វើហាក់ដូចមិនបានឮនូវពាក្យរបស់លោក ចោមរោមគ្នាថា លោកម្ចាស់និមន្តទៅណា កិច្ចឲ្យក្រាលអាសនៈមិនសមគួរដល់លោកម្ចាស់ឬ លោកម្ចាស់លាអ្នកណាបួស អ្នកណាព្រមឲ្យលោកម្ចាស់បួស លោកម្ចាស់មកក្នុងទីនេះធ្វើអ្វី ដូច្នេះហើយ នាំគ្នាទាញស្បង់ និងចីវរចេញហើយ ឲ្យស្លៀកសំពត់ស ពាក់នូវឈ្នួតផ្កាលើក្បាល ហើយបញ្ជូនទៅដោយពាក្យថា អ្នកចូរទៅនាំព្រះសាស្តាមក ពួកខ្ញុំនឹងក្រាលអាសនៈ ។

ចុល្លកាលតាំងនៅក្នុងភាវៈនៃភិក្ខុអស់កាលមិនយូរ មិនទាន់បានវស្សាក៏សឹក ទើបមិនខ្មាស ព្រោះដូច្នោះ ទើបគាត់អស់សេចក្តីរង្កៀសដោយកិរិយាអាការនោះ ទៅថ្វាយបង្គំព្រះសាស្តាហើយ នាំភិក្ខុសង្ឃមានព្រះពុទ្ធជា

ប្រធានមក ។

ក្នុងកាលស្រេចភត្តកិច្ចរបស់ភិក្ខុសង្ឃ ពួកភរិយារបស់ព្រះមហាកាល គិតគ្នាថា ស្រីពួកនេះ ចោមរោមចាប់ប្ដីរបស់ខ្លួនបាន ពួកយើងក៏នឹងចាប់ប្ដីរបស់ពួកយើងដែរ ទើបឲ្យនិមន្តព្រះសាស្ដាដើម្បីប្រយោជន៍ដល់ការសោយក្នុងថ្ងៃស្អែក ។

ក្នុងកាលនោះ ភិក្ខុដទៃបានទៅប្រាប់ឲ្យក្រាលអាសនៈ ស្រីទាំងនោះមិនបានឱកាសក្នុងខណៈនោះ អារាធនាភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យគង់ហើយបានថ្វាយភិក្ខា ។ ចុល្លកាលមានភរិយាពីរនាក់ មជ្ឈិមកាលមានភរិយា ៤ នាក់ មហាកាលមាន ៨ នាក់ ចំណែកភិក្ខុទាំងឡាយប្រាថ្នាធ្វើកិច្ច បានអង្គុយធ្វើភត្តកិច្ចហើយ ពួកដែលប្រាថ្នាទៅខាងក្រៅ ក៏បានក្រោកទៅហើយ ចំណែកព្រះសាស្ដាប្រថាប់គង់ធ្វើភត្តកិច្ច ក្នុងកាលស្រេចភត្តកិច្ចរបស់ព្រះអង្គ ស្រីទាំងនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកាលធ្វើអនុមោទនាដល់ពួកខ្ញុំម្ចាស់ហើយ សឹមទៅ សូមទ្រង់យាងទៅមុនចុះ ។

ព្រះសាស្ដាត្រាស់ថា សាធុ បានយាងទៅមុនហើយ ។ កាលដល់ទ្វារស្រុក ភិក្ខុសង្ឃក៏លើកទោសថា ហេតុអ្វីទើបព្រះសាស្ដាទ្រង់ធ្វើបែបនេះ ព្រះអង្គទ្រង់ជ្រាបហើយធ្វើ ឬមិនជ្រាបហើយធ្វើហ្ន៎ ម្សិលមិញអន្តរាយនៃបព្វជ្ជាកើតឡើងដល់ចុល្លកាលព្រោះទៅមុនគេ ថ្ងៃនេះ អន្តរាយមិនមាន ព្រោះភិក្ខុដទៃទៅមុន ឥឡូវនេះ ព្រះសាស្ដាត្រាស់ឲ្យព្រះមហាកាលឈប់បង្អង់ ហើយទ្រង់យាងមក ភិក្ខុអ្នកមានសីលដល់ព្រមហើយដោយអាចារ ស្រីទាំងនោះ នឹង

ធ្វើអន្តរាយនៃបព្វជ្ជាដល់ព្រះមហាកាលនោះបានឬហ្ន៎ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទ្រង់ត្រឡប់មកប្រថាប់ឈរ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលអ្វី ភិក្ខុទាំងនោះទូលសេចក្តីនោះហើយ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់មហាកាលដូចចុល្លកាលឬ ភិក្ខុទាំងឡាយទូលថា យ៉ាងនោះឯងព្រះអង្គ ព្រោះចុល្លកាលនោះមានភរិយាពីរនាក់ ចំណែកព្រះមហាកាលនេះមានភរិយាដល់ទៅ ៨ នាក់ លោកត្រូវភរិយាទាំង ៨ ចោមរោមចាប់ហើយនឹងធ្វើអ្វីបាន ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំពោលយ៉ាងនោះឡើយ ។ ចុល្លកាលក្រោកឡើង ក្រោកឡើងព្រមហើយ ច្រើនទៅដោយអារម្មណ៍ថាស្អាត ដូចគ្នានឹងដើមឈើដែលមានកម្លាំងទុព្វល តាំងនៅត្រង់មាត់ជ្រោះឆាយនឹងដាច់ ចំណែកមហាកាលបុត្រតថាគត តាមឃើញអារម្មណ៍ថាមិនស្អាត ជាអ្នកមិនញាប់ញ័រឡើយ ដូចថ្មភ្នំតាន់ ដូច្នេះហើយ បានភាសិតគាថាទាំងនេះថា

សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្វលំ
អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ

**តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។**

បុគ្គលដែលយល់ឃើញ នូវអារម្មណ៍ថាល្អ មិនសង្រួមក្នុង
ឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន ខ្ជិលច្រអូស
មានព្យាយាមធូរថយ កិលេសមារ រមែងគ្របសង្កត់បុគ្គល
នោះឯង ដូចខ្យល់ដែលគ្របសង្កត់ដើមឈើទុព្វល ដូច្នោះ ។
ឯបុគ្គលដែលយល់ឃើញ នូវអារម្មណ៍ថាមិនល្អ សង្រួម
ប្រពៃក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន មាន
សទ្ធា ប្រារព្ធព្យាយាម កិលេសមារ តែងគ្របសង្កត់បុគ្គល
នោះមិនបាន ដូចខ្យល់គ្របសង្កត់ថ្មភ្នំតាន់មិនបាន ដូច្នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុភានុបស្សឹ** បានដល់ បុគ្គលតាមឃើញអារម្មណ៍ថាស្អាត អធិប្បាយថា បុគ្គលបណ្តែតបណ្តោយចិត្តទៅក្នុងអារម្មណ៍ដែលគួរប្រាថ្នា បុគ្គលណាកាលកាន់យកដោយនិមិត្ត ដោយអនុព្យញ្ជនៈ រមែងកាន់យកថា ក្រចកទាំងឡាយស្អាត កាន់យកថា ម្រាមដៃទាំងឡាយស្អាត កាន់យកថា ដៃទាំងពីរ ជើងទាំងពីរ ដើមដៃទាំងពីរ ស្មងទាំងពីរ ចង្កេះ ពោះ សុដន់ទាំងពីរ ក បបូរមាត់ ធ្មេញទាំងឡាយ មាត់ ច្រមុះ ភ្នែកទាំងគូ ត្រចៀកទាំងគូ ចិញ្ចើមទាំងគូ ថ្ងាស សក់ទាំងឡាយស្អាត ។ កាន់យកថា សក់ រោម ក្រចក ធ្មេញ ស្បែក ស្អាត ឬកាន់យកថា សម្បុរល្អ ទ្រង់ទ្រាយល្អ បុគ្គលនេះ ឈ្មោះថា តាមឃើញអារម្មណ៍ថាស្អាត បុគ្គលនោះ គឺជាអ្នក

តាមឃើញនូវអារម្មណ៍ថាស្អាត យ៉ាងនោះ ។

បទថា **ឥន្ទ្រិយេសុ** បានដល់ ក្នុងឥន្ទ្រិយទាំង ៦ មានចក្ខុជាដើម ។

បទថា **អសំវុតំ** បានដល់ ដែលមិនរក្សាទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម ។

បទថា **អមត្តញ្ញុំ** សេចក្តីថា ឈ្មោះថា បុគ្គលមិនស្គាល់ប្រមាណក្នុងភោជន ព្រោះមិនស្គាល់ប្រមាណនេះ គឺប្រមាណក្នុងការស្វែងរក ប្រមាណក្នុងការទទួល ប្រមាណក្នុងការបរិភោគ ។ ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកមិនស្គាល់ប្រមាណ ព្រោះមិនស្គាល់ប្រមាណទាំងនេះ គឺប្រមាណក្នុងការពិចារណា ប្រមាណក្នុងការលះ គឺមិនដឹងថា ភោជននេះ ប្រកបដោយធម៌ នេះមិនប្រកបដោយធម៌ ។ បទថា **កុសីតំ** សេចក្តីថា ឈ្មោះថា អ្នកខ្ជិលច្រអូស ព្រោះជាអ្នកប្រព្រឹត្តទៅក្នុងអំណាចរបស់កាមវិតក្ក ព្យាបាទវិតក្ក និងវិហឹង្សាវិតក្ក ។

បទថា **ហីនវីរិយំ** សេចក្តីថា ជាអ្នកមិនមានសេចក្តីព្យាយាម គឺវៀរចាកការធ្វើសេចក្តីព្យាយាមក្នុងឥរិយាបថទាំង ៤ ។

បទថា **បសហតិ** ប្រែថា រមែងគ្របសង្កត់ គឺញាំញី ។

បាទព្រះគាថាថា **វាតោ រុក្ខំវ ទុព្វលំ** សេចក្តីថា ដូចខ្យល់ដែលមានកម្លាំងខ្លាំង កួចនូវដើមឈើដែលមានកម្លាំងខ្សោយ ដែលដុះត្រង់មាត់ជ្រោះឲ្យដាច់ អធិប្បាយថា ខ្យល់នោះញ៉ាំងចំណែកផ្សេងៗ មានផ្កា ផ្លែ ស្លឹកខ្ចីជាដើមនៃដើមឈើនោះឲ្យជ្រុះខ្លះ កាច់បំបាក់មែកតូចខ្លះ កាច់មែកធំខ្លះ ដក

នូវដើមឈើនោះ ព្រមទាំងឫស ធ្វើឲ្យឫសឡើងលើ មែកចុះក្រោម យ៉ាងណា មារ គឺកិលេសដែលកើតខាងក្នុង រមែងក្ចបុគ្គលដែលឃើញបែបនោះបានដូច្នោះដូចគ្នា គឺកិលេសមារ រមែងធ្វើឲ្យត្រូវអាបត្តិតូចៗ ដូចខ្យល់មានកម្លាំងខ្លាំង បក់ចំណែកផ្សេងៗ មានផ្កា ផ្លែ ស្លឹកខ្ចីជាដើមនៃដើមឈើដែលមិនរឹងមាំឲ្យជ្រុះចុះខ្លះ ធ្វើឲ្យត្រូវអាបត្តិមាននិស្សគ្គិយៈជាដើម ដូចខ្យល់មានកម្លាំងខ្លាំង កាច់បំបាក់មែកឈើតូចៗ ខ្លះ ធ្វើឲ្យត្រូវអាបត្តិសង្ឃាទិសេស ១៣ ដូចខ្យល់មានកម្លាំងកាច់បំបាក់នូវមែកធំខ្លះ ធ្វើឲ្យត្រូវអាបត្តិបារាជិក នាំចេញចាកសាសនាដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយ ឲ្យដល់នូវភាពជាគ្រហស្ថក្នុងរយៈពេលពីរបីថ្ងៃប៉ុណ្ណោះ ដូចខ្យល់មានកម្លាំងខ្លាំងដកដើមឈើធ្វើឲ្យរលំមានឫសឡើងលើ មានមែកចុះក្រោមខ្លះ ។ កិលេសមារ រមែងញ៉ាំងបុគ្គលបែបនោះ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ។

បទថា **អសុភានុបស្សិំ** សេចក្តីថា ជាអ្នកឃើញអារម្មណ៍មិនល្អ ១០ យ៉ាងណាមួយថាមិនស្អាត គឺប្រកបក្នុងមនសិការ ដោយភាពជារបស់បដិកូល បានឃើញសក់ទាំងឡាយ ថាជារបស់មិនស្អាត ឃើញរោម ក្រចក ធ្មេញ ស្បែក ពណ៌សម្បុរ ទ្រង់ទ្រាយដោយភាពមិនស្អាត ។

បទថា **ឥន្ទ្រិយេសុ** បានដល់ ក្នុងឥន្ទ្រិយ ៦ ។ បទថា **សុសំវុតំ** បានដល់ ដែលវៀរចាកការកាន់យក មានកាន់យកដោយនិមិត្តជាដើម គឺជាអ្នកមានទ្វារបិទហើយ ។

បទថា **មត្តញ្ញុំ** សេចក្តីថា បុគ្គលស្គាល់ប្រមាណក្នុងភោជន ដោយផ្ទុយ

គ្នាក្នុងភាពជាបុគ្គលមិនស្គាល់ប្រមាណ ។

បទថា **សទ្ធំ** សេចក្ដីថា ជាអ្នកប្រកបដោយលោកិយសទ្ធា មានការជឿកម្ម និងផលជាលក្ខណៈមួយ និងប្រកបដោយលោកុត្តរសទ្ធា ពោល គឺការជ្រះថ្លាដែលមិនញាប់ញ័រក្នុងវត្ថុ ៣ យ៉ាងមួយ ។

បទថា **អារទ្ធវីរិយំ** បានដល់ ជាអ្នកផ្គងព្យាយាម គឺជាអ្នកមានសេចក្ដីព្យាយាមពេញលេញ ។

បទថា **តំ វេ** បានដល់ បុគ្គលនោះ គឺឃើញបែបនោះ អធិប្បាយថា ខ្យល់ដែលមានកម្លាំងខ្សោយបក់ស្រាលៗ រមែងមិនអាចឲ្យសិលាតាន់ញាប់ញ័របានយ៉ាងណា កិលេសមារដែលមានកម្លាំងខ្សោយ សូម្បីកើតឡើងខាងក្នុង រមែងក្ដួចបុគ្គលនោះមិនបាន គឺមិនអាចឲ្យញាប់ញ័រកម្រើករំពើកឃ្លាតចាកទីបាន ដូច្នោះ ។

ពួកស្រីទាំងនោះឯង ដែលជាភរិយាចាស់របស់មហាកាលនោះ ចោមរោមព្រះថេរៈហើយ ពោលពាក្យជាដើមថា លោកម្ចាស់លាអ្នកណាបួសឥឡូវនេះ លោកម្ចាស់ទៅជាគ្រហស្ថឬមិនទៅ ដូច្នេះហើយ បានជាអ្នកប្រាថ្នានឹងដោះសំពត់កាសាវពស្ត្រទាំងឡាយរបស់ព្រះថេរៈចេញ ។

ព្រះថេរៈកំណត់អាការរបស់ស្រីទាំងនោះបានហើយ ក្រោកចាកអាសនៈដែលអង្គុយ ហើយហោះទៅដោយឫទ្ធិ ទម្លាយហោជាងផ្ទះកំពូល ទៅតាមអាកាស កាលព្រះសាស្ដាត្រាស់ព្រះគាថាចប់ សរសើរព្រះសរីរៈរបស់ព្រះសាស្ដា ដែលមានពណ៌ដូចមាស ចុះមកថ្វាយបង្គំព្រះយុគលបាទរបស់

ព្រះតថាគតហើយ ។

ក្នុងកាលចប់គាថា ភិក្ខុដែលប្រជុំគ្នា តាំងនៅក្នុងអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ចុល្លកាល និងមហាកាល ចប់**

# រឿង ទេវទត្តភិក្ខុ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបានសំពត់កាសាវពស្ត្រ ដែលបុគ្គលនាំមកអំពីដែនគន្ធារៈរបស់ទេវទត្តភិក្ខុ ក្នុងក្រុងរាជគ្រឹះ ត្រាស់ព្រះធម្មទេសនានេះថា **អនិក្កសាវោ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ អគ្គសាវកទាំងពីរ នាំបរិវាររបស់ខ្លួនមួយអង្គ ៥០០ ទៅទូលលាព្រះសាស្តាហើយ បានទៅអំពីវត្តជេតពន កាន់ក្រុងរាជគ្រឹះ ។

អ្នកក្រុងរាជគ្រឹះរួមគ្នាមួយពួក ២ នាក់ខ្លះ ៣ នាក់ខ្លះ ច្រើននាក់ខ្លះ បានប្រគេនអាគន្តុកទាន ។ សម័យថ្ងៃមួយ ព្រះសារីបុត្រកាលធ្វើអនុមោទនា សម្តែងធម៌យ៉ាងនេះថា ឧបាសកឧបាសិកាទាំងឡាយ ទាយកមួយពួកថ្វាយទានដោយខ្លួនឯង តែមិនបបួលអ្នកដទៃ ទាយកនោះ រមែងបានភោគសម្បត្តិក្នុងទីដែលខ្លួនកើតហើយ តែមិនបានបរិវារសម្បត្តិ បុគ្គលមួយពួក បបួល

អ្នកដទៃតែខ្លួនឯងមិនថ្វាយ បុគ្គលនោះ រមែងបានបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ តែជាអ្នកមិនមានភោគសម្បត្តិ បុគ្គលមួយពួកខ្លួនឯង ក៏មិនបានថ្វាយ អ្នកដទៃក៏មិនបបួល បុគ្គលនោះ រមែងមិនបានវត្ថុសូម្បីត្រឹមតែបាយចុងអង្ករល្មមចម្អែតផ្ទៃ រមែងជាមនុស្សអនាថា មិនមានបច្ច័យ ក្នុងទីដែលខ្លួនកើតហើយ ជនមួយពួកខ្លួនឯងក៏ថ្វាយផង បបួលអ្នកដទៃផង បុគ្គលនោះ រមែងបានទាំងភោគសម្បត្តិ ទាំងបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ អស់រយអត្តភាពខ្លះ ពាន់អត្តភាពខ្លះ សែនអត្តភាពខ្លះ ។

បុរសបណ្ឌិតម្នាក់ ស្តាប់ធម្មទេសនានោះហើយ គិតថា ព្រះធម្មទេសនាអស្ចារ្យពន់ពេក លោកម្ចាស់សារីបុត្រពោលហេតុនៃសេចក្តីសុខ អញធ្វើកម្មញុំាងសម្បត្តិទាំងពីរនេះឲ្យសម្រេច រមែងសមគួរ ដូច្នេះហើយ ទើបនិមន្តព្រះថេរៈថា បពិត្រលោកម្ចាស់ ស្អែកនេះសូមនិមន្តលោកម្ចាស់ទាំងឡាយទទួលភិក្ខារបស់ខ្ញុំចុះ ព្រះថេរៈសួរថា អ្នកត្រូវការភិក្ខុប៉ុន្មាន ឧបាសកសួរថា ភិក្ខុដែលជាបរិវាររបស់លោកម្ចាស់មានប៉ុន្មាន ព្រះថេរៈពោលថា មានប្រមាណមួយពាន់រូប ឧបាសកពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ មួយអន្លើដោយភិក្ខុទាំងអស់ទទួលភិក្ខារបស់ខ្ញុំ ។ ព្រះថេរៈទទួលហើយ ។

ឧបាសកត្រាច់ទៅក្នុងផ្លូវនៃព្រះនគរ បបួលដោយពាក្យថា អ្នកម៉ែ លោកឪពុកទាំងឡាយ ខ្ញុំនិមន្តភិក្ខុមួយពាន់រូប អ្នកទាំងឡាយនឹងអាចប្រគេនភិក្ខាមានចំនួនប៉ុនណា អ្នកទាំងឡាយ នឹងអាចប្រគេនភិក្ខាដល់ភិក្ខុមានចំនួនប៉ុនណា ។

ពួកមនុស្សពោលដោយល្មមសមគួរដល់កម្លាំងរៀងៗ ខ្លួនថា ពួកខ្ញុំនឹងប្រគេនដល់ភិក្ខុ ១០ រូប ពួកខ្ញុំ ២០ រូប ពួកខ្ញុំ ១០០ រូប ។

ឧបាសកពោលថា បើដូច្នោះ យើងទាំងឡាយនឹងចម្អិនរួមគ្នាក្នុងទីមួយកន្លែង សូមអ្នករាល់គ្នាប្រមូលវត្ថុផ្សេងៗ មានប្រេង ល្ង អង្ករ សប្បិ ទឹកអំពៅជាដើម ដូច្នេះហើយ ឲ្យទុកដាក់ក្នុងទីមួយកន្លែង ។

ពេលនោះ កុដុម្ពិកៈម្នាក់ឲ្យសំពត់កាសាវៈ ដែលនាំមកអំពីដែនគន្ធារៈ ដែលមានតម្លៃ ១ សែនដល់ឧបាសកនោះហើយ ប្រាប់ថា បើទានវត្ថុៈ ( ទេយ្យធម៌ ) របស់អ្នកមិនទាន់គ្រប់គ្រាន់សោត អ្នកគប្បីចំណាយសំពត់នេះ ឲ្យគ្រប់ចំណែកដែលខ្វះខាត បើទានវត្ថុៈរបស់អ្នកគ្រប់គ្រាន់សោត អ្នកគប្បីប្រគេនសំពត់នេះដល់ភិក្ខុអង្គណាដែលអ្នកប្រាថ្នា ។ ក្នុងកាលនោះ ទានវត្ថុៈគ្រប់យ៉ាងរបស់ឧបាសកនោះគ្រប់គ្រាន់ហើយ វត្ថុណាមួយឈ្មោះថា ខ្វះខាតមិនមាន ទើបឧបាសកនោះសួរមនុស្សទាំងឡាយថា សំពត់កាសាវពស្ត្រដែលមានតម្លៃកាត់ថ្លៃមិនបាននេះ ដែលកុដុម្ពិកៈម្នាក់ពោលយ៉ាងនេះ ហើយប្រគល់ឲ្យ ។ ទានវត្ថុៈរបស់ពួកយើង ក៏មានគ្រប់គ្រាន់ហើយ យើងទាំងឡាយនឹងប្រគេនសំពត់កាសាវៈនេះ ដល់ភិក្ខុអង្គណាហ្ន៎ ។

មនុស្សពួកខ្លះពោលថា គួរប្រគេនដល់ព្រះសារីបុត្តត្ថេរ ពួកខ្លះពោលថា ព្រះថេរៈជាច្រើនមកក្នុងវេលាស្រូវទុំ ហើយក៏ទៅ ទេវទត្តភិក្ខុជាសម្លាញ់ក្នុងការមង្គល និងអវមង្គលទាំងឡាយរបស់ពួកយើង តាំងនៅជានិច្ច ដូចក្អមទឹក ពួកយើងនឹងប្រគេនសំពត់នោះដល់លោក កាលវាចាប្រព្រឹត្តទៅច្រើនផ្លូវ

យ៉ាងនោះ ពួកដែលពោលថា ប្រគេនដល់ទេវទត្តភិក្ខុ មានចំនួនច្រើនជាង កាលបើយ៉ាងនោះ ទើបពួកគេប្រគេនសំពត់កាសាវពស្ត្រនោះ ដល់ទេវទត្តភិក្ខុ ។

ទេវទត្តកាន់សំពត់នោះហើយ ដេរ ជ្រលក់ ស្លៀកដណ្ដប់ត្រាច់ទៅ ។ ពួកមនុស្សឃើញលោកហើយ ទើបពោលថាសំពត់នេះ មិនសមគួរដល់ទេវទត្តភិក្ខុសោះ គួរដល់ព្រះសារីបុត្តត្ថេរ ។ ទេវទត្តភិក្ខុដណ្ដប់សំពត់ដែលមិនសមគួរដល់ខ្លួន ត្រាច់ទៅហ្ន៎ ។

ខណៈនោះ ភិក្ខុដែលនៅក្នុងទិសដទៃមួយរូប ចេញអំពីនគររាជគ្រឹះទៅកាន់នគរសាវត្ថី ថ្វាយបង្គំព្រះសាស្ដា ជាបុគ្គលដែលព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈ ត្រាស់សួរដល់ការនៅជាផាសុខ របស់អគ្គសាវកទាំងពីរហើយ ទើបក្រាបទូលរឿងទាំងអស់នោះ តាំងពីដើមដល់ចប់ ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទេវទត្តនោះទ្រទ្រង់សំពត់ដែលមិនសមគួរដល់ខ្លួនក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន ក៏ទ្រទ្រង់ហើយដូចគ្នា ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តទ្រង់សោយរាជសម្បត្តិ ក្នុងនគរពារាណសី ។ នាយព្រានដំរីអ្នកនគរពារាណសីម្នាក់ ផ្ដួលដំរីហើយ នាំភ្លុកស្បែក ពោះវៀនធំ និងសាច់មកហើយ លក់ដូរចិញ្ចឹមជីវិត ។ គ្រានោះ ដំរីទាំងឡាយមួយពាន់ ដើររកស៊ីក្នុងព្រៃមួយ ជួបព្រះបច្ចេកពុទ្ធច្រើនអង្គ ចាប់តាំងអំពីកាលនោះ កាលទៅវមែងក្រាបចុះដោយជើងទាំងពីរ ហើយថ្វាយបង្គំ

ក្នុងកាលដែលទៅ និងមក ហើយទើបចូលទៅ ។ ថ្ងៃមួយ ព្រានដីរឃើញកិរិយានោះហើយ គិតថា អញសម្លាប់ដីរទាំងនេះបានដោយលំបាក ក្នុងកាលទៅ និងមក ដីរទាំងនេះរមែងថ្វាយបង្គំព្រះបច្ចេកពុទ្ធទាំងឡាយ ដីរទាំងនេះឃើញអ្វីហ្ន៎ ទើបថ្វាយបង្គំ ។ កំណត់បានថា ឃើញសំពត់កាសាវពស្ត្រដូច្នេះហើយ ត្រិះរិះថា ឥឡូវនេះ អញនឹងបានសំពត់កាសាវពស្ត្រ រមែងគួរ ។ កាលព្រះបច្ចេកពុទ្ធមួយរូប ចុះទៅកាន់ជាតស្រះស្រង់ទឹក ដាក់សំពត់កាសាវៈទាំងឡាយត្រង់មាត់ច្រាំង ទើបលួចចីវរទៅ ចាប់លំពែងអង្គុយទទួរនៅត្រង់មាត់ផ្លូវ ដែលដីរទាំងនោះទៅមក ។ ពួកដីរឃើញព្រានហើយ ទើបថ្វាយបង្គំដោយសម្គាល់ថា ព្រះបច្ចេកពុទ្ធ ហើយក៏ចូលទៅ នាយព្រានដីរនោះយកលំពែងពួយដីរដែលទៅខាងក្រោយគេបង្អស់ឲ្យធ្លាប់ហើយ កាន់យកចំណែកផ្សេងៗ មានភ្លុកជាដើម កប់ចំណែកដែលសល់ក្នុងផែនដី ហើយទៅ ។

ក្នុងកាលតមក ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតដីរ បានជាមេហ្វូង ជាប្រធាន ។ ក្នុងកាលនោះ ព្រានដីរនោះក៏នៅតែធ្វើយ៉ាងនោះ ។ ព្រះមហាបុរសជ្រាបការអស់ទៅនៃបរិស័ទរបស់ខ្លួន ទើបសួរថា ដីរទាំងនេះទៅណា ទើបរលស់អស់ កាលពួកដីរទាំងនោះឆ្លើយថា ខ្ញុំមិនដឹងទេ ព្រះពោធិសត្វក៏គិតថា ដីរទាំងឡាយទៅណាក៏មិនប្រាប់អញ ឬក៏មិនទៅណាអន្តរាយពិតជាមាននឹកសង្ស័យថា អន្តរាយគប្បីមានអំពីសម្នាក់នៃបុរស ដែលអង្គុយទទួរសំពត់កាសាវៈក្នុងទីមួយ ។ ដើម្បីចាប់បុរសនោះ ទើបបញ្ជូនដីរទាំងអស់ឲ្យដើរទៅមុន ចំណែកខ្លួនដើរមកឯក្រោយ នាយព្រានដីរនោះ កាលដីរដ៏សេសថ្វាយ

បន្តំហើយដើរទៅ ឃើញព្រះមហាបុរសកំពុងដើរមក ទើបមូរចីវរ ពួយលំពែងទៅ ។

ព្រះមហាបុរសគ្រប់គ្រងសតិដើរមក ថយក្រោយទៅគេចលំពែងហើយ ពេលនោះ ទើបស្ទុះចូលទៅដើម្បីចាប់នាយព្រាននោះ ដោយសម្គាល់ថាបុគ្គលនេះឲ្យដំរីរបស់អញវិនាសហើយ នាយព្រានដំរីនេះ ពួនកំបាំងដើមឈើមួយដើម ពេលនោះ ព្រះមហាបុរសយកប្រមោយចាប់ព្រាន ព្រមទាំងដើមឈើបំណងថា នឹងចាប់សង្កត់ចុះត្រង់ផែនដី ឃើញសំពត់កាសាវៈដែលព្រាននាំមកបង្ហាញ ទើបឈប់បង្អង់ដោយគិតឃើញថា បើអញប្រទូស្តក្នុងបុរសនេះសោត ឈ្មោះថា ការខ្មាសក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពច្រើនពាន់អង្គ ឈ្មោះថា អញទម្លាយហើយ ។ ហើយបែរជាសួរថា ញាតិរបស់យើងប្រមាណប៉ុណ្ណេះ អ្នកឯងឲ្យវិនាសហើយឬ ។

នាយព្រានដំរីសារភាពថា ពិតហើយ ព្រះមហាបុរសពោលថា ព្រោះហេតុអ្វី ទើបអ្នកធ្វើកម្មគ្រោតគ្រាតយ៉ាងនេះ អ្នកដណ្តប់សំពត់មិនគួរដល់ខ្លួនសមគួរដល់អ្នកប្រាសចាករាគៈទាំងឡាយ កាលធ្វើកម្មដ៏លាមកបែបនេះ ឈ្មោះថា ធ្វើកម្មធ្ងន់ កាលពោលយ៉ាងនោះហើយ ដើម្បីសង្កត់សង្កិនឲ្យក្រៃលែងឡើង ទើបពោលគាថា

អ្នកណា នៅមានទឹកចត់ គឺរាគាទិក្កិលេស ( ក្នុងសន្តាន )
ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ និងសច្ចៈហើយ ស្លៀក
ដណ្តប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្តប់

សំពត់កាសាវៈឡើយ ។ លុះតែអ្នកណា មានទឹកចត់ គឺ
រាគាទិក្កិលេសខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់
មាំក្នុងចតុប្បារិសុទ្ធិសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ
និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្ដប់សំពត់
កាសាវៈបាន ។ ដូច្នេះហើយ ពោលថា អ្នកធ្វើកម្មមិន
សមគួរ ហើយដោះលែងទៅ ។

ព្រះសាស្ដាកាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រានដំរីក្នុងកាលនោះ បានជាទេវទត្តក្នុងកាលឥឡូវនេះ ដំរីដ៏ប្រសើរដែលសង្កត់សង្កិននាយព្រាននោះ គឺតថាគតនេះឯង ដូច្នេះ ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ទ្រទ្រង់សំពត់មិនសមគួរដល់ខ្លួនដូចគ្នា ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា

**អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហិស្សតិ**
**អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ**
**យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ**
**ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។**

អ្នកណា នៅមានទឹកចត់ គឺរាគាទិក្កិលេស ( ក្នុងសន្ដាន )
ជាអ្នកបោះបង់ការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ ហើយស្លៀក
ដណ្ដប់សំពត់កាសាវៈ អ្នកនោះ មិនគួរនឹងស្លៀកដណ្ដប់
សំពត់កាសាវៈឡើយ ។ លុះតែអ្នកណា មានទឹកចត់ គឺ

*រាគាទិក្កិលេសខ្ជាក់ចោលអស់ហើយ ជាអ្នកមានចិត្តតម្កល់មាំក្នុងចតុប្បារិសុទ្ធសីល ប្រកបដោយការទូន្មាននូវឥន្ទ្រិយ និងសច្ចៈ អ្នកនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈបាន ។ សេចក្តីនេះ បណ្ឌិតគប្បីសម្តែងដោយឆទ្ទន្តជាតកដូច្នេះ ។*

# អធិប្បាយសេចក្តី

*បណ្តាបទទាំងនោះ បទថា* **អនិក្កសាវោ** *សេចក្តីថា បុគ្គលឈ្មោះថាមានកិលេសដូចទឹកចត់ ព្រោះកិលេសដូចទឹកចត់ទាំងឡាយ មានកាមរាគៈជាដើម ។*

*បទថា* **បរិទហេស្សតិ** *សេចក្តីថា នឹងប្រើប្រាស់ដោយអំណាចនៃការស្លៀកដណ្តប់ និងការក្រាល ។ ព្រះបាលីថា* **បរិទហិស្សតិ** *ក៏មាន ។*

*បាទព្រះគាថាថា* **អបេតោ ទមសច្ចេន** *សេចក្តីថា ប្រាសចាក អធិប្បាយថា ប្រាសទៅអំពីការទូន្មានឥន្ទ្រិយ និងវចីសច្ចៈ ដែលជាចំណែកបរមត្ថសច្ចៈ ។*

*បទថា* **ន សោ** *ជាដើម សេចក្តីថា បុគ្គលនោះ គឺបុគ្គលបែបនោះ រមែងមិនគួរស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។*

*បទថា* **វន្តកសាវស្ស** *សេចក្តីថា គប្បីជាអ្នកមានកិលេសដូចទឹកចត់ដែលខ្ជាក់ហើយ គឺមានកិលេសដូចទឹកចត់ដែលចោលហើយ បានដល់ មានកិលេសដូចទឹកចត់លះហើយដោយមគ្គ ៤ ។*

*បទថា* **សីលេសុ** *បានដល់ ក្នុងបរិសុទ្ធសីល ៤ ។ បទថា* **សុសមាហិតោ** *បានដល់ បុគ្គលតាំងមាំល្អ គឺតាំងនៅដោយល្អ ។*

បទថា **ឧបេតោ** សេចក្តីថា ប្រកបដោយការទូន្មានឥន្ទ្រិយ និងវចីសច្ចៈ មានប្រការដូចពោលហើយ ។

បទថា **ស វេ** ជាដើម សេចក្តីថា បុគ្គលនោះ គឺបែបនោះ រមែងគួរស្លៀកដណ្តប់សំពត់កាសាវពស្ត្រនោះ ។

ក្នុងកាលចប់គាថា ភិក្ខុដែលនៅក្នុងទិសផ្សេងនោះ បានជាព្រះសោតាបន្នជនដទៃមានចំនួនច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានសម្រេចប្រយោជន៍ដល់មហាជន ដូច្នេះឯង ៕

**រឿង ទេវទត្តភិក្ខុ ចប់**

# រឿង សញ្ជ័យ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការមិនមករបស់សញ្ជ័យបរិព្វាជក ដែលអគ្គសាវកទាំងពីរក្រាបទូលហើយ ត្រាស់ព្រះធម្មទេសនានេះថា **អសារេ សារមតិនោ** ជាដើម ។ អនុបុព្វីកថាក្នុងរឿងសញ្ជ័យនោះដូចតទៅនេះ

សេចក្តីពិស្តារថា ក្នុងទីបំផុត ៤ អសង្ខេយ្យ និងមួយសែនកប្បអំពីកប្បនេះទៅ ព្រះសាស្តានៃយើងទាំងឡាយ ជាកូនរបស់ព្រាហ្មណ៍ ឈ្មោះថាសុមេធ ក្នុងអមរវតីនគរ ដល់នូវការសម្រេចសិប្បៈគ្រប់យ៉ាង ដោយ

កាល ធ្វើកាលកិរិយាទៅនៃមាតា និងបិតា ទ្រង់បរិច្ចាគទ្រព្យច្រើនកោដិ បួសជាឥសីក្នុងហិមវន្តប្បទេស ធ្វើឈាន និងអភិញ្ញាឲ្យកើតហើយ ទៅដោយអាកាស ឃើញមនុស្សធ្វើផ្លូវ ដើម្បីប្រយោជន៍ដល់ការយាងអំពីសុទស្សនវិហារ ចូលកាន់ទៅអមរវតីនគរនៃព្រះទសពល ព្រះនាមថាទីបង្ករ ខ្លួនឯងក៏កាន់យកមួយចំណែក កាលចំណែកនោះមិនទាន់សម្រេច ដេកក្រាបធ្វើខ្លួនឲ្យជាស្ពាន ក្រាលស្បែកខ្លាលើភក់ ដើម្បីព្រះសាស្តាដែលយាងមកហើយដោយបំណងថា សូមព្រះសាស្តា មួយអន្លើដោយសង្ឃសាវក មិនចាំបាច់ជាន់ភក់ សូមទ្រង់ជាន់អញយាងទៅចុះ ។ លុះព្រះសាស្តាទតឃើញ ក៏ទ្រង់ព្យាករថា សត្វនេះជាពុទ្ធង្កូរ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ក្នុងទីបំផុត ៤ អសង្ខេយ្យ និងមួយសែនកប្ប ក្នុងអនាគត ។ ក្នុងសម័យតមកព្រះសាស្តាអង្គនោះ ក៏ទទួលព្យាករក្នុងសម្នាក់ព្រះពុទ្ធ ២៣ អង្គ ដែលទ្រង់កើតឡើង បំភ្លឺលោកឲ្យភ្លឺ គឺ ព្រះកោណ្ឌញ្ញៈ ១ ព្រះសុមង្គលៈ ១ ព្រះសុមនៈ ១ ព្រះរេវតៈ ១ ព្រះសោភិតៈ ព្រះអនោមទស្សី ១ ព្រះបទុមៈ ១ ព្រះនារទៈ ១ ព្រះបទុមុត្តរៈ ១ ព្រះសុមេធៈ ១ ព្រះសុជាតៈ ១ ព្រះបិយទស្សី ១ ព្រះអត្ថទស្សី ១ ព្រះធម្មទស្សី ១ ព្រះសិទ្ធត្ថៈ ១ ព្រះតិស្សៈ ១ ព្រះផុស្សៈ ១ ព្រះវិបស្សី ១ ព្រះសិខី ១ ព្រះវេស្សភូ ១ ព្រះកកុសន្ធៈ ១ ព្រះកោនាគមនៈ ១ ព្រះកស្សបៈ ១ ទ្រង់បំពេញបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ឲ្យមហាទានដែលធ្វើផែនដីឲ្យកម្រើក ៧ ដង ទ្រង់បរិច្ចាគព្រះរាជឱរស និង

ព្រះជាយាក្នុងទីបំផុតព្រះជន្មាយុ ក៏ទ្រង់កើតឡើងក្នុងតុសិតបុរី តាំងនៅក្នុងតុសិតបុរីនោះដរាបអស់ព្រះជន្មាយុ កាលទេវតាក្នុងម៉ឺនចក្រវាលប្រជុំគ្នាអារាធនាថា

បពិត្រមហាវីរៈ កាលនេះ ជាកាលរបស់ព្រះអង្គ សូមទ្រង់កើតឡើងក្នុងព្រះគភ៌នៃព្រះមាតា ត្រាស់ដឹងអមតបទ ញុំាងលោកនេះ ព្រមទាំងទេវលោកឲ្យឆ្លង ។

ទ្រង់ជ្រើសរើសនូវឋានៈធំៗ ដែលគួរជ្រើសរើស ៥ ទ្រង់ចុតិអំពីតុសិតបុរីនោះហើយ ទ្រង់បដិសន្ធិក្នុងសក្យរាជត្រកូល ដែលព្រះញាតិបម្រើដោយមហាសម្បត្តិក្នុងសក្យត្រកូលនោះ ។ ទ្រង់ដល់នូវការចម្រើនវ័យដោយលំដាប់ សោយសិរីរាជសម្បត្តិ ក្នុងប្រាសាទទាំងបីដែលសមគួរដល់រដូវទាំងបី ដូចសិរីសម្បត្តិក្នុងទេវលោក ។

ក្នុងសម័យដែលទ្រង់យាងទៅដើម្បីប្រពាតឧទ្យាន ទ្រង់ឃើញទេវទូត ៣ គឺមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ដោយលំដាប់ ទ្រង់កើតនូវសេចក្ដីសង្វេគ យាងត្រឡប់ហើយ ក្នុងថ្ងៃទី ៤ ទ្រង់ឃើញបព្វជិត ញុំាងនូវការពេញព្រះហឫទ័យក្នុងការបំពេញបព្វជ្ជាឲ្យកើតឡើងថា ការបួសជាការល្អហ្ន៎ ។ ទ្រង់ទៅកាន់ឧទ្យាន ញុំាងថ្ងៃឲ្យអស់ទៅក្នុងឧទ្យាននោះ ប្រថាប់គង់ត្រង់ឆ្នេរស្រះបោក្ខរណីជាមង្គល ដែលវិស្សកម្មទេវបុត្រ កាឡាខ្លួនជាខ្មាន់ព្រះកេសនិម្មិតតាក់តែងថ្វាយ ទ្រង់បានឮដំណឹងប្រសូតរបស់រាហុលកុមារ ទ្រង់ជ្រាបដល់សេចក្ដីស្នេហាក្នុងឱរសមានកម្លាំង ទ្រង់ត្រិះរិះថា អញនឹងកាត់ចំណងនេះ រហូតដល់ចងអញមិនបាននោះឯង ។ ពេលល្ងាច ទ្រង់ចូលទៅ

កាន់ព្រះនគរ ទ្រង់ស្តាប់គាថានេះ ដែលព្រះរាជធីតារបស់ព្រះបិតុលា ឈ្មោះកិសាគោតមីភាសិតថា

ព្រះរាជកុមារនេះ ជាព្រះរាជឱរសនៃមាតាណា មាតានោះរលត់ដោយពិត ជាឱរសនៃបិតាណា បិតានោះ រលត់ដោយពិត ជាព្រះស្វាមីរបស់នារីណា នារីនោះ រលត់ គឺត្រជាក់ចិត្តដោយពិត ។

ទ្រង់ព្រះតម្រិះថា អាត្មាអញដែលព្រះនាងកិសាគោតមីនេះឲ្យបានឮនិព្វុតបទហើយ ទើបដោះកែវមុក្តាហារអំពីព្រះសូរង បញ្ជូនទៅឲ្យដល់ព្រះនាង ហើយស្តេចចូលទៅកាន់លំនៅរបស់ព្រះអង្គ ប្រថាប់គង់លើព្រះទែនបន្ទំដ៏មានសិរី ទតឃើញប្រការដែលប្លែករបស់ពួកស្រីរបាំ ដែលនិទ្រាហើយមានព្រះហឫទ័យនឿយណាយ ទើបដាស់ឆន្នៈអមាត្យឲ្យក្រោកឡើង ឲ្យនាំសេះកណ្ឋកៈមក ។ ទ្រង់ឡើងសេះកណ្ឋកៈ មានឆន្នៈអមាត្យជាសម្លាញ់ ដែលទេវតាក្នុងម៉ឺនចក្រវាលហែហមហើយ ទ្រង់ចេញមហាភិនេស្រ្កមណ៍ ទ្រង់ព្រះផ្នួសត្រង់ឆ្នេរស្ទឹងអនោមានទី ។ ទ្រង់យាងដល់ក្រុងរាជគ្រឹះដោយលំដាប់ ទ្រង់យាងបិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះ ប្រថាប់គង់ត្រង់ញកភ្នំបណ្ឌវៈ ដែលស្តេចផែនដី នគរមគធៈអារាធនាដោយរាជសម្បត្តិ ទ្រង់បដិសេធពាក្យអារាធនានោះ ទ្រង់ទទួលបេ្តជ្ញាអំពីព្រះបាទមគធៈដើម្បីប្រយោជន៍ដល់ការបានសម្រេចសព្វញ្ញុតញ្ញាណហើយ ទ្រង់នឹងមកកាន់ដែនរបស់ព្រះអង្គមុនគេ ។ ទ្រង់ចូលទៅរកអាឡារតាបស និងឧទកតាបស ទ្រង់មិនពេញព្រះហឫទ័យ

ក្នុងគុណវិសេស ដែលទ្រង់បានសម្រេចក្នុងសម្នាក់របស់តាបសនោះ ទ្រង់តាំងមហាបធានអស់ ៦ ឆ្នាំ ។

ក្នុងថ្ងៃវិសាខបុណ្ណមីពេលព្រឹក ទ្រង់សោយបាយាសដែលនាងសុជាតាថ្វាយ ហើយទ្រង់បណ្តែតថាសមាសក្នុងស្ទឹងនេរញ្ជរា ឲ្យបំណែកនៃថ្ងៃកន្លងទៅដោយសមាបត្តិផ្សេងៗ ក្នុងដងព្រៃមហាវន្តត្រង់ឆ្នេរស្ទឹងនេរញ្ជរានោះ ពេលល្ងាច ទ្រង់ទទួលស្មៅ ដែលសោត្ថិយព្រាហ្មណ៍ថ្វាយ មានព្រះគុណដែលស្តេចកាលនាគសរសើរហើយ ទ្រង់យាងទៅកាន់មណ្ឌលពោធិព្រឹក្ស ធ្វើប្ដេជ្ញាថា អាត្មាអញនឹងមិនទម្លាយភ្នែននេះ អស់កាលដែលចិត្តរបស់អាត្មាអញ មិនរួចផុតចាកអាសវៈទាំងឡាយ ដោយការមិនចូលទៅប្រកាន់មាំ ប្រថាប់គង់បែរព្រះភក្ត្រទៅកាន់ទិសបូព៌ កាលព្រះអាទិត្យមិនទាន់អស្តង្គត ទ្រង់កម្ចាត់មារ និងពលបាន ទ្រង់សម្រេចបុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់សម្រេចចុតូបបាតញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ឈានចុះក្នុងបច្ចយាការក្នុងទីបំផុតនៃបច្ឆិមយាម ក្នុងអរុណរះឡើង ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណដែលប្រដាប់ដោយគុណគ្រប់យ៉ាង មានព្រះទសពលញាណ និងចតុវេសា-រជ្ជញ្ញាណជាដើម ទ្រង់ញ៉ាំងកាលឲ្យកន្លងទៅត្រង់មណ្ឌលពោធិព្រឹក្ស អស់ ៧ សប្តាហ៍ ក្នុងសប្តាហ៍ទី ៨ ប្រថាប់គង់ត្រង់គល់អជបាលនិគ្រោធ ទ្រង់ដល់នូវភាពជាអ្នកខ្វល់ខ្វាយតិច ដោយពិចារណាឃើញថា ជាធម៌មានសភាពជ្រាលជ្រៅ ដែលសហម្បតីព្រហ្ម មានមហាព្រហ្មមួយម៉ឺនជាបរិវារ អារាធនាឲ្យសម្តែងធម៌ ទ្រង់ពិចារណាមើលលោកដោយពុទ្ធចក្ខុហើយ ទ្រង់ទទួល

ពាក្យអារាធនារបស់ព្រហ្ម ទ្រង់ពិចារណាថា អាត្មាអញគប្បីសម្តែងធម៌ដល់នរណាមុនគេហ្ន៎ ។ ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបសធ្វើកាលកិរិយាហើយ ទ្រង់នឹកដល់ឧបការៈច្រើនរបស់បញ្ចវគ្គិយភិក្ខុ ទ្រង់ក្រោកអំពីអាសនៈទៅកាន់កាសីបុរី ក្នុងរវាងផ្លូវ បានសន្ទនាជាមួយឧបកាជីវក ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ទ្រង់ដល់លំនៅរបស់បញ្ចវគ្គិយ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ញុំាងបញ្ចវគ្គិយទាំងនោះ ដែលហៅទ្រង់ដោយពាក្យដែលមិនសមគួរឲ្យក្រាក់ខ្លួនហើយ កាលនឹងញុំាងព្រហ្ម ១៨ កោដិ មានព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាន ឲ្យផឹកនូវអមតៈ ទើបទ្រង់សម្តែងធម្មចក្រ ទ្រង់មានធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅហើយ ក្នុងតិថីទី ៥ នៃបក្ខ ទ្រង់ញុំាងភិក្ខុទាំងអស់នោះឲ្យតាំងនៅក្នុងអរហត្ត ក្នុងថ្ងៃជាមួយគ្នានោះឯង ។ ទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់យសកុលបុត្រហើយ ត្រាស់ហៅយសកុលបុត្រ ដែលនឿយណាយ លះផ្ទះចេញមកទាំងកណ្តាលយប់ថា ម្នាលយស អ្នកចូរមកនេះចុះ ធ្វើយសកុលបុត្រឲ្យសម្រេចសោតបត្តិផលទាំងយប់នោះឯង ក្នុងថ្ងៃរះឡើងឲ្យសម្រេចអរហត្ត ។ ទ្រង់ញុំាងសម្លាញ់របស់យស ៥៤ នាក់ដទៃទៀត ឲ្យបព្វជ្ជាដោយឯហិភិក្ខុឧបសម្បទាហើយ ឲ្យបានសម្រេចអរហត្ត ។

កាលព្រះអរហន្តកើតឡើងក្នុងលោក ៦១ អង្គ ដោយប្រការយ៉ាងនេះហើយ ព្រះសាស្តាទ្រង់នៅចាំវស្សាបវារណាហើយ ទ្រង់បញ្ជូនភិក្ខុ ៦០ រូបទៅក្នុងទិសទាំងឡាយដោយព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរត្រាច់ចារិកទៅចុះ ដូច្នេះជាដើម ។ ចំណែកទ្រង់ទៅកាន់ឧរុវេលាបទេស

ក្នុងរវាងផ្លូវទ្រង់បានទូន្មានភទ្ទវគ្គិយកុមារ ៣០ រូបក្នុងព្រៃកប្បាស ។ បណ្ដាភទ្ទវគ្គិយកុមារ ៣០ រូបនោះ បុគ្គលដែលទាបជាងគេបង្អស់ ជាព្រះសោតាបន្ន ខ្ពស់ជាងគេបង្អស់ ជាព្រះអនាគាមី ។ ទ្រង់ឲ្យភទ្ទវគ្គិយទាំងអស់នោះបព្វជ្ជាដោយឯហិភិក្ខុដូចគ្នាហើយ ទ្រង់បញ្ជូនទៅក្នុងទិសទាំងឡាយ ចំណែកព្រះអង្គទ្រង់ទៅកាន់ឧរុវេលាបទេស ទ្រង់សម្ដែងបាដិហារ្យ ៣៥០០ ទូន្មានជដិល ៣ នាក់បងប្អូន ដែលមានជដិលមួយពាន់នាក់ជាបរិវារ មានឧរុវេលកស្សបៈជាដើម ឲ្យបព្វជ្ជាដោយឯហិភិក្ខុភាវៈដូចគ្នាហើយ ឲ្យប្រជុំគ្នាត្រង់គយាសីសប្បទេស ឲ្យតាំងនៅក្នុងអរហត្ត ដោយអាទិត្តបរិយាយទេសនា ហែមរោមដោយព្រះអរហន្តមួយពាន់អង្គ យាងទៅកាន់ឧទ្យានលដ្ឋិវ័ន ជិតនគររាជគ្រឹះ ដោយទ្រង់ព្រះតម្រិះថា នឹងដោះបេ្តជ្ញាដែលថ្វាយដល់ព្រះបាទពិម្ពិសារ ត្រាស់ព្រះធម្មកថាដ៏ពីរោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់ឮថា ព្រះសាស្ដាយាងមកហើយ ទ្រង់មកគាល់ មួយអន្លើដោយព្រាហ្មណ៍ និងគហបតី ១២ ម៉ឺននាក់ ញ៉ាំងព្រះរាជា និងព្រាហ្មណ៍ មួយអន្លើដោយគហបតី ១១ ម៉ឺននាក់ ឲ្យតាំងនៅក្នុងសោតាបត្តិផល ១ ម៉ឺនទៀត ឲ្យតាំងនៅក្នុងសរណៈ ៣ ។ ស្អែកឡើង មានព្រះគុណដែលសក្កទេវរាជកាឡាខ្លួនជាមាណពសរសើរហើយ ទ្រង់ចូលទៅកាន់នគររាជគ្រឹះ ទ្រង់ធ្វើភត្តកិច្ចក្នុងព្រះរាជនិវេសន៍ ទ្រង់ទទួលវេឡុវនារាម ប្រថាប់នៅក្នុងវេឡុវនារាមនោះឯង ។ សារីបុត្រ និងមោគ្គល្លាន ចូលទៅគាល់ទ្រង់ក្នុងវេឡុវនារាមនោះ ។

អនុបុព្វីកថាក្នុងរឿងព្រះសារីបុត្រ និងព្រះមោគ្គល្លាននោះ មានដូចតទៅ

សេចក្តីពិស្តារថា កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើងនោះឯង មានស្រុកព្រាហ្មណ៍ពីរតំបន់ គឺឧបតិស្សគ្រាម ១ កោលិតគ្រាម ១ ក្នុងទីមិនឆ្ងាយអំពីក្រុងរាជគ្រឹះ ។ ក្នុងពីរតំបន់នោះ ក្នុងថ្ងៃដែលនាងព្រាហ្មណីឈ្មោះសារីក្នុងឧបតិស្សគ្រាមតាំងគភ៌នោះឯង នាងព្រាហ្មណីឈ្មោះមោគ្គល្លី ក្នុងកោលិត-គ្រាម ក៏តាំងគភ៌ដែរ ។ បានឮថា ត្រកូលទាំងពីរនោះ បានជាសម្លាញ់ជាប់ទាក់ទងគ្នាតមកដល់ទៅ ៧ ជួរត្រកូលនោះឯង ។ ព្រាហ្មណ៍ជាប្តីបានឲ្យពិធីបរិហារគភ៌ដល់ព្រាហ្មណីទាំងពីរនោះ ក្នុងថ្ងៃតែមួយដូចគ្នា ។ ដោយកាលកន្លងទៅ ១០ ខែ ព្រាហ្មណីទាំងពីរនោះក៏ប្រសូតបុត្រ ។ ក្នុងថ្ងៃដាក់ឈ្មោះពួកញាតិដាក់ឈ្មោះកូនរបស់សារីព្រាហ្មណីថា ឧបតិស្សៈ ព្រោះជាកូនរបស់ត្រកូលមេស្រុកក្នុងតំបន់ឧបតិស្សគ្រាម ។ តាំងឈ្មោះកូនរបស់មោគ្គល្លីព្រាហ្មណីថា កោលិតៈ ព្រោះជាកូនរបស់ត្រកូលមេស្រុក ក្នុងតំបន់កោលិតគ្រាមនេះ ។ ក្មេងទាំងពីរនោះ ដល់នូវការចម្រើនហើយ បានដល់នូវការសម្រេចនៃសិប្បៈគ្រប់យ៉ាង ក្នុងពេលទៅកាន់ស្ទឹង ឬឧទ្យាន ដើម្បីប្រយោជន៍ក្នុងការលេងឧបតិស្សមាណពមានគ្រែស្នែង ៥០០ ជាគ្រឿងហែហម កោលិតមាណពទឹមរថដោយសេះអាជានេយ្យ ៥០០ ជាគ្រឿងហែហម ជនទាំងពីរ មានមាណពជាបរិវារម្នាក់ ៥០០ ។ ក្នុងក្រុងរាជគ្រឹះ មានមហោស្រពលើកំពូលភ្នំរាល់ៗ ឆ្នាំ ។ ពួកញាតិបានលើកគ្រែត្រួតគ្នាដើម្បីកុមារទាំងពីរនោះក្នុងទីជាមួយគ្នានោះឯង ។ កុមារទាំងពីរ ក៏អង្គុយមើលមហោស្រពរួមគ្នារមែងសើចក្នុងឋានៈដែលគួរសើច រមែងដល់នូវសេចក្តីសង្វេគ ក្នុងឋានៈដែល

គួរសើចគួរសង្វេគ រមែងឲ្យរង្វាន់ក្នុងឋានៈដែលគួរឲ្យរង្វាន់ ។ ថ្ងៃមួយ កាលកុមារទាំងពីរនោះមើលមហោស្រពដោយទំនងនេះ ការសើចក្នុងឋានៈដែលគួរសើច ឬការសង្វេគក្នុងឋានៈដែលគួរសង្វេគ ឬការឲ្យរង្វាន់ក្នុងឋានៈដែលគួរឲ្យ មិនមានហើយដូចក្នុងថ្ងៃមុនៗ ព្រោះញាណដល់នូវការចាស់ក្លាដោយជុំវិញហើយ ។ ជនទាំងពីរគិតគ្នាយ៉ាងនេះថា នឹងមានប្រយោជន៍អ្វី ដែលគួរមើលក្នុងការនេះ ជនទាំងអស់នេះ កាលមិនទាន់ដល់មួយរយឆ្នាំ ក៏នឹងដល់នូវភាពជាសភាវៈមិនមានបញ្ញត្តិ យើងទាំងពីរគួរស្វែងរកធម៌ជាគ្រឿងរួចផុតយ៉ាងឯក ដូច្នេះហើយ កាន់យកជាអារម្មណ៍ អង្គុយហើយ ។ លំដាប់នោះ កោលិតៈពោលនឹងឧបតិស្សៈថា នែឧបតិស្សៈសម្លាញ់ ហេតុអ្វី ទើបអ្នកមិនសើចសប្បាយដូចក្នុងថ្ងៃដទៃៗ ថ្ងៃនេះ អ្នកមានចិត្តមិនរីករាយ អ្នកកំណត់អ្វីបានឬ ឧបតិស្សៈពោលថា កោលិតៈសម្លាញ់ ខ្ញុំអង្គុយគិតដល់ហេតុនេះថា ក្នុងការមើលមនុស្សទាំងនេះ មិនមានសារៈ ការមើលនេះ មិនមានប្រយោជន៍ អញគួរស្វែងរកមោក្ខធម៌ដើម្បីខ្លួន ចុះអ្នកវិញ ព្រោះហេតុ អ្វីទើបមិនរីករាយ សូម្បីកោលិតៈនោះក៏ប្រាប់យ៉ាងនោះដូចគ្នា ។ លំដាប់នោះ ឧបតិស្សៈជ្រាបភាពដែលកោលិតៈនោះមានអធ្យាស្រ័យដូចគ្នានឹងខ្លួនហើយ ទើបពោលថា នែសម្លាញ់ យើងទាំងពីរគិតគ្នាល្អហើយ យើងគួរស្វែងរកមោក្ខធម៌ ធម្មតាអ្នកស្វែងរក ត្រូវបានបព្វជ្ជាបែបណាមួយ ទើបគួរ យើងទាំងពីរនឹងបួសក្នុងសម្នាក់អ្នកណាហ្ន៎ ។

សម័យនោះឯង សញ្ជ័យបរិព្វាជក អាស្រ័យនៅក្នុងក្រុងរាជគ្រឹះជាមួយ

បរិព្វាជកបរិស័ទយ៉ាងច្រើន ។ សារីបុត្រ និងមោគ្គល្លានទាំងពីរនោះ ដាក់កតិកាគ្នាថា យើងនឹងបួសក្នុងសម្នាក់សញ្ជ័យនោះ ។ ហើយបញ្ជូនមាណព ៥០០ ទៅដោយពាក្យថា អ្នកទាំងឡាយ ចូរយកគ្រែស្នែង និងវថទៅចុះមួយអន្ទើដោយមាណព ៥០០ បួសហើយក្នុងសម្នាក់របស់សញ្ជ័យ ។ តាំងអំពីជនទាំងពីរបួសហើយ សញ្ជ័យក៏បាននូវភាពប្រសើរដោយលាភ យសយ៉ាងហូរហៀរ ។ ជនទាំងពីររៀនចប់លទ្ធិសម័យរបស់សញ្ជ័យ ដោយត្រឹមតែពីបីថ្ងៃប៉ុណ្ណោះ ទើបសួរថា លោកអាចារ្យ លទ្ធិដែលលោកដឹងមានត្រឹមប៉ុណ្ណោះ ឬមានក្រៃលែងជាងនេះ កាលសញ្ជ័យឆ្លើយថា មានត្រឹមប៉ុណ្ណោះឯងអ្នកទាំងពីរចេះចប់ហើយ ។ ទើបជនទាំងពីរគិតគ្នាថា បើដូច្នេះ ការនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់របស់លោក ក៏មិនមានប្រយោជន៍ យើងទាំងពីរចេញមកដើម្បីស្វែងរកមោក្ខធម៌ ។ មោក្ខធម៌នោះ យើងមិនអាចឲ្យកើតឡើងបានក្នុងសម្នាក់របស់លោកអាចារ្យនេះ ជម្ពូទ្វីបធំណាស់ យើងត្រាច់ទៅកាន់គាមនិគម ជនបទ និងរាជធានី គង់នឹងបានអាចារ្យដែលសម្តែងមោក្ខធម៌ត្រឹមតែម្នាក់ពិត ។ តាំងអំពីនោះ បុគ្គលណាម្នាក់ពោលក្នុងទីណាមួយថាសមណព្រាហ្មណ៍ដែលជាបណ្ឌិតមាន ជនទាំងពីររមែងទៅធ្វើសាកច្ឆាក្នុងទីនោះៗ បញ្ហាដែលជនទាំងពីរសួរទៅ អាចារ្យដទៃមិនអាចឆ្លើយបាន តែជនទាំងពីរអាចស្រាយប្រស្នារបស់អាចារ្យទាំងនោះបាន ។ ជនទាំងពីរ ស៊ើបរកពេញជម្ពូទ្វីបយ៉ាងនេះហើយ ត្រឡប់មកកាន់លំនៅរបស់ខ្លួន ធ្វើកតិកាគ្នាថាកោលិតៈសម្លាញ់ បណ្តាយើងពីរនាក់ អ្នកណាបានសម្រេចអមតធម៌មុន អ្នក

នោះ ចូរប្រាប់ដល់គ្នានិងគ្នា ។

កាលជនទាំងពីរធ្វើកតិកាគ្នាយ៉ាងនោះ ព្រះសាស្តាយាងដល់ក្រុងរាជគ្រឹះ ដោយលំដាប់ដូចពោលហើយ ទ្រង់ទទួលវេឡុវ័នហើយ ប្រថាប់នៅក្នុងវេឡុវ័ននោះ ។ ក្នុងកាលនោះ ព្រះអស្សជិត្ថេរក្នុងចំនួនបញ្ចវគ្គិយ រវាងព្រះអរហន្ត ៦១ អង្គ ដែលព្រះសាស្តាទ្រង់បញ្ជូនទៅដើម្បីប្រកាសគុណព្រះរតនត្រ័យ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចារិកទៅដើម្បីប្រយោជន៍ដល់ជនច្រើនចុះ ។ ត្រឡប់មកកាន់ក្រុងរាជគ្រឹះហើយ ក្នុងស្អែកឡើង លោកកាន់បាត្រ និងចីវរទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាតអំពីព្រលឹម ។

សម័យនោះ ឧបតិស្សបរិព្វាជកធ្វើភត្តកិច្ចអំពីព្រលឹមហើយ ទៅកាន់អារាមរបស់បរិព្វាជកជួបព្រះថេរៈ ទើបគិតថា អ្នកបួសបែបនេះអញមិនធ្លាប់ជួបឡើយ ភិក្ខុរូបនេះគង់ជាបុគ្គលម្នាក់ បណ្តាបុគ្គលដែលជាព្រះអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គក្នុងលោក ធ្វើម្តេចហ្ន៎ អញគប្បីចូលទៅរកភិក្ខុនេះ ហើយសួរថា លោកដ៏មានអាយុ លោកម្ចាស់បួសឧទ្ទិសចំពោះអ្នកណា អ្នកណាជាសាស្តារបស់លោកម្ចាស់ លោកម្ចាស់គាប់ចិត្តក្នុងធម៌របស់អ្នកណា ។

ពេលនោះ បរិវិតក្កនេះមានដល់គាត់ថា កាលនេះ មិនមែនកាលគួរសួរបញ្ហានឹងភិក្ខុនេះ ភិក្ខុនេះកំពុងចូលទៅកាន់ចន្លោះស្រុកត្រាច់បិណ្ឌបាត បើដូច្នោះ អញនឹងស្វែងរកមោក្ខធម៌ដែលបុគ្គលត្រូវការដឹងហើយ គួរដើរតាមភិក្ខុនេះ ទៅអំពីខាងក្រោយ ។ គាត់ឃើញព្រះថេរៈបានបិណ្ឌបាតហើយ ទៅកាន់ឱកាសណាមួយ ហើយជ្រាបសេចក្តីដែលព្រះថេរៈនោះបំណងនឹងគង់

ទើបរៀបតាំងរបស់បរិញ្វាជកសម្រាប់ខ្លួនប្រគេន ។ ក្នុងពេលដែលលោកឆាន់ស្រេចហើយ ក៏ប្រគេនទឹកក្នុងកុណ្ឌីរបស់ខ្លួនដល់ព្រះថេរៈ កាលធ្វើអាចរិយវត្តយ៉ាងនោះហើយ ទើបធ្វើបដិសណ្ឋារៈ ទាក់ចិត្តជាមួយព្រះថេរៈដែលឆាន់ស្រេចហើយ សាកសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ ឥន្ទ្រិយរបស់លោកម្ចាស់ផូរផង់ពេក ពណ៌សម្បុរបរិសុទ្ធ លោកម្ចាស់បួសឧទ្ទិសចំពោះអ្នកណា អ្នកណាជាគ្រូរបស់លោកម្ចាស់ លោកម្ចាស់គាប់ចិត្តក្នុងធម៌របស់អ្នកណា ។

ព្រះថេរៈគិតថា ធម្មតាបរិញ្វាជកទាំងនេះ រមែងជាបដិបក្ខចំពោះសាសនា អញនឹងសម្តែងជម្រៅក្នុងព្រះសាសនាដល់បរិញ្វាជកនេះ កាលសម្តែងនូវភាពដែលខ្លួនបួសថ្មី ទើបពោលថា អាវុសោ ខ្ញុំជាអ្នកបួសថ្មី បួសហើយមិនយូរ ទើបតែមកកាន់ធម្មវិន័យនេះ ខ្ញុំមិនអាចសម្តែងធម៌ដោយពិស្តារទេ ។ បរិញ្វាជកប្រាប់ថា ខ្ញុំឈ្មោះឧបតិស្សៈ សូមលោកម្ចាស់ពោលតាមសមត្ថភាពចុះ តិចក្តី ច្រើនក្តី សេចក្តីនោះ ជាភារៈរបស់ខ្ញុំ ដើម្បីចាក់ធ្លុះដោយន័យមួយរយន័យមួយពាន់ ដូច្នេះហើយ សាកសួរថា

ទោះតិចក្តី ច្រើនក្តី សូមលោកម្ចាស់ពោលមកចុះ ចូរប្រាប់ដល់ខ្ញុំតែអត្ថប៉ុណ្ណោះ ខ្ញុំត្រូវការអត្ថ មិនចាំបាច់ធ្វើព្យញ្ជនៈឲ្យច្រើនឡើយ ។ កាលគាត់ប្រាប់យ៉ាងនោះហើយ ទើបព្រះថេរៈពោលគាថាថា ធម៌ទាំងឡាយណា មានហេតុជាដែនកើត ព្រះតថាគតត្រាស់ហេតុនៃធម៌នោះ និងហេតុនៃការរលត់នៃធម៌ទាំងនោះ ព្រះមហាសមណៈមានប្រក្រតីត្រាស់យ៉ាងនេះ ។

បរិព្វាជកស្តាប់ត្រឹមពីរបទខាងដើមប៉ុណ្ណោះ ក៏តាំងនៅក្នុងសោតាបត្តិផលដល់ព្រមដោយន័យមួយពាន់ ។ ព្រះថេរៈញុំាងពីរបទក្រៅអំពីនេះឲ្យចប់ ក្នុងពេលឧបតិស្សៈជាព្រះសោតាបន្ន ។ គាត់ជាព្រះសោតបន្នហើយ កាលគុណវិសេសជាន់ខ្ពស់មិនទាន់ប្រព្រឹត្តទៅក៏ជំទាស់ថា ហេតុក្នុងវត្ថុនេះនឹងមាន ទើបសាកសួរព្រះថេរៈថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនចាំបាច់ពង្រីកព្រះធម្មទេសនាឲ្យក្រៃលែងឡើងឡើយ សេចក្តីប៉ុណ្ណោះក៏ល្មមគ្រប់គ្រាន់ ព្រះសាស្តារបស់ពួកយើងប្រថាប់នៅឯណា ។ ព្រះថេរៈឆ្លើយថា ទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ។ ឧបតិស្សៈសួរថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់និមន្តទៅមុនចុះ ខ្ញុំមានសម្លាញ់ម្នាក់ទៀត ហើយខ្ញុំទាំងពីរបានធ្វើកតិកាដល់គ្នានិងគ្នាថា អ្នកណាសម្រេចអមតៈមុន អ្នកនោះចូរប្រាប់ដល់គ្នានិងគ្នា ខ្ញុំដោះបេ្តជ្ញានោះហើយ នឹងនាំសម្លាញ់នោះទៅកាន់សម្នាក់របស់ព្រះសាស្តា តាមដែលលោកម្ចាស់ទៅហើយនោះឯង ដូច្នេះហើយ ក្រាបទៀបបាទាទាំងពីររបស់ព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណ ៣ ជុំ បញ្ជូនព្រះថេរៈទៅហើយ បានបែរមុខទៅកាន់អារាមរបស់បរិព្វាជកហើយ ។ កោលិតបរិព្វាជកឃើញឧបតិស្សៈមកអំពីចម្ងាយ គិតថា ថ្ងៃនេះ ទឹកមុខសម្លាញ់របស់អញមិនដូចក្នុងថ្ងៃដទៃៗ គេគង់បានសម្រេចអមតៈដោយពិត ទើបសួរដល់ការសម្រេចអមតៈ ។ ឧបតិស្សបរិព្វាជកនោះក៏ទទួលថា អើ អាវុសោ អមតៈខ្ញុំបានសម្រេចហើយ បានភាសិតគាថានោះឯងដល់កោលិតបរិព្វាជកនោះ ។

ក្នុងកាលចប់គាថា កោលិតៈតាំងនៅក្នុងសោតាបត្តិផលហើយ ទើប

ពោលថា សម្លាញ់ព្រះសាស្តារបស់ពួកយើងប្រថាប់នៅឯណា ឧបតិស្សៈពោលថា ប្រថាប់នៅវត្តវេឡុវ័ន ដំណឹងនេះព្រះអស្សជិត្ថេរអាចារ្យរបស់យើងប្រាប់ហើយ កោលិតៈពោលថា នែសម្លាញ់ បើដូច្នោះយើងទៅគាល់ព្រះសាស្តាចុះ ។

ធម្មតាព្រះសារីបុត្តត្ថេរនេះ រមែងជាអ្នកបូជាអាចារ្យសព្វកាល ព្រោះដូច្នោះ ទើបពោលនឹងកោលិតៈយ៉ាងនេះថា នែសម្លាញ់ យើងនឹងប្រាប់អមតៈដែលយើងទាំងពីរបាន ដល់សញ្ជ័យបរិព្វាជកដែលជាអាចារ្យរបស់យើងផង លោកដឹងក៏នឹងចាក់ធ្លុះ បើមិនចាក់ធ្លុះ ជឿពួកយើងហើយនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ធម្មទេសនារបស់ពុទ្ធបុគ្គលទាំងឡាយហើយ នឹងធ្វើនូវការចាក់ធ្លុះនូវមគ្គ និងផល ។

លំដាប់នោះ ជនទាំងពីរក៏បានទៅកាន់សម្នាក់របស់សញ្ជ័យ ។ សញ្ជ័យគ្រាន់តែឃើញទើបសួរថា បាទាំងពីរ ពួកបាបានអ្នកណាបង្ហាញផ្លូវអមតៈហើយឬ ទើបសម្លាញ់ទាំងពីរប្រាប់ថា បានហើយលោកអាចារ្យ ព្រះពុទ្ធទ្រង់កើតឡើងហើយក្នុងលោក ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ លោកអាចារ្យប្រព្រឹត្តធម៌ទទេឥតសារៈ សូមលោកអាចារ្យមកចុះយើងទាំងឡាយនឹងទៅកាន់សម្នាក់ព្រះសាស្តា ។ សញ្ជ័យពោលថា អ្នកទាំងពីរទៅចុះ ខ្ញុំមិនអាចទេ សម្លាញ់ទាំងពីរសួរថា ព្រោះហេតុអ្វី សញ្ជ័យប្រាប់ថា ខ្ញុំជាអាចារ្យរបស់មហាជនហើយ ការនៅជាអន្តេវាសិករបស់ខ្ញុំនោះ ដូចគ្មានឹងការកម្រើកនៃទឹកក្នុងពាង ខ្ញុំមិនអាចនៅជាអន្តេវាសិកបាន សម្លាញ់ទាំងពីរពោលថា កុំធ្វើយ៉ាងនោះឡើយលោកអាចារ្យ សញ្ជ័យពោលថា ណ្ហើយចុះ

បា បានាំគ្នាទៅចុះ ខ្ញុំមិនអាចទេ សម្លាញ់ទាំងពីរពោលថា លោកអាចារ្យ តាំងអំពីកាលព្រះពុទ្ធកើតឡើងក្នុងលោក មហាជនមានគ្រឿងក្រអូប កម្រង ផ្កាជាដើមក្នុងដៃទៅបូជាព្រះអគ្គបុគ្គលប៉ុណ្ណោះ ឯខ្ញុំទាំងពីរក៏នឹងទៅក្នុងទីនោះដូចគ្នា លោកអាចារ្យនឹងធ្វើដូចម្តេច ។ សញ្ជ័យពោលថា បាទាំងទ្វេរ ក្នុងលោកនេះ អ្នកល្ងង់មានច្រើន ឬអ្នកឆ្លាតមានច្រើន សម្លាញ់ទាំងពីរពោលថា អ្នកល្ងង់ មានច្រើនលោកអាចារ្យ ឯអ្នកឈ្លាសមានត្រឹមតិចតួច សញ្ជ័យពោលថា បាទាំងពីរ បើដូច្នោះ ពួកជនដែលឈ្លាសវៃ នឹងទៅកាន់សម្នាក់ព្រះគោតម ពួកជនល្ងង់ខ្លៅនឹងមកកាន់សម្នាក់ខ្ញុំ បាទៅចុះ ខ្ញុំមិនទៅទេ ។

ទើបសម្លាញ់ទាំងពីរនោះពោលថា លោកអាចារ្យ លោកនឹងប្រាកដឯង ។ ដូច្នេះហើយ ចៀសចេញទៅ កាលសម្លាញ់ទាំងពីរនោះកំពុងទៅ បរិស័ទរបស់ សញ្ជ័យបែកគ្នាហើយ ខណៈនោះអារាមបានជាទីទទេ ។ សញ្ជ័យនោះ ឃើញ អារាមទទេហើយ ក៏ក្អួតឈាមក្តៅៗ ។ ក្នុងបរិព្វាជក ៥០០ នាក់ ដែលទៅ ជាមួយសម្លាញ់ទាំងពីរនោះ បរិស័ទរបស់សញ្ជ័យ ២៥០ នាក់ ត្រឡប់ ហើយ ។ សម្លាញ់ទាំងពីរទៅកាន់វត្តវេឡុវ័ន មួយអន្លើដោយបរិព្វាជក ២៥០ ដែលជាអន្តេវាសិករបស់ខ្លួន ។

ព្រះសាស្តាប្រថាប់គង់សម្តែងធម៌ ក្នុងកណ្តាលបរិស័ទ ៤ ទតឃើញ បរិព្វាជកទាំងនោះអំពីចម្ងាយ ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្លាញ់ពីរនាក់នោះកំពុងមក គឺកោលិតៈ និងឧបតិស្សៈ ជនទាំងពីរនោះ ជាគូសាវកដ៏កំពូលរបស់តថាគត ។ សម្លាញ់ទាំងពីរនោះ

ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងចំណែកម្ខាង ជនទាំងពីរបានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា ខ្ញុំព្រះអង្គគប្បីបានទូវបព្វជ្ជា គប្បីបានទូវឧបសម្បទាក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគផងចុះ ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកទាំងឡាយចូរជាភិក្ខុចុះ ធម៌តថាគតពោលល្អហើយ ចូរប្រព្រឹត្តព្រហ្មចរិយៈដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ ។ ជនទាំងអស់ បានជាបុគ្គលទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ហាក់បីដូចព្រះថេរៈមានវស្សា ១០០ ។

គ្រានោះ ព្រះសាស្តាទ្រង់ពង្រីកព្រះធម្មទេសនា ដោយអំណាចចរិយាដល់បរិស័ទរបស់សម្លាញ់ទាំងពីរ វៀរអគ្គសាវកទាំងពីរចេញ ជនដ៏សេសសម្រេចអរហត្តហើយ ឯកិច្ចដោយមគ្គខាងលើរបស់អគ្គសាវកទាំងពីរ មិនបានសម្រេចឡើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសាវកបារមីញាណ ជារបស់ធំ ។

ក្នុងថ្ងៃទីពីរ បន្ទាប់អំពីបួសហើយ ព្រះមហាមោគ្គល្លានចូលទៅអាស្រ័យស្រុកកាល្លវាលៈ ក្នុងដែនមគធៈ កាលថីនមិទ្ធៈគ្របសង្កត់ ព្រះសាស្តាទ្រង់ធ្វើឲ្យសង្វេគហើយ បន្ទោបង់ថីនមិទ្ធៈបាន កំពុងស្តាប់ធាតុកម្មដ្ឋាន ដែលព្រះតថាគតប្រទានហើយ ញុំាងកិច្ចក្នុងមគ្គ ៣ ខាងលើឲ្យសម្រេច ដល់ទីបំផុតសាវកបារមីញាណហើយ ។

ចំណែកព្រះសារីបុត្រកន្លងទៅបានកន្លះខែអំពីថ្ងៃបួស ចូលទៅអាស្រ័យក្រុងរាជគ្រឹះនោះហើយ នៅក្នុងវិហារសូករខាតាជាមួយព្រះសាស្តា កាលព្រះ

សាស្តា ទ្រង់សម្តែងវេទនាបរិគ្គហសូត្រដល់ទីឃនខបរិព្វាជក ដែលជាក្មួយរបស់ខ្លួន បញ្ជូនញាណទៅតាមក្រសែនៃព្រះសូត្រ ក៏ដល់នូវទីបំផុតនៃសាវកបារមីញាណ ដូចបុគ្គលដែលបរិភោគកត្តដែលគេឲ្យដល់អ្នកដទៃ ។

មានពាក្យសួរថា ព្រះសារីបុត្រជាអ្នកមានបញ្ញាច្រើនមិនមែនឬ បើដូច្នោះហេតុអ្វី ទើបសម្រេចសាវកបារមីញាណក្រោយព្រះមហាមោគ្គល្លាន ឆ្លើយថា ព្រោះមានបរិកម្មច្រើន ឧបមាដូចមនុស្សក្រីក្រ បំណងនឹងទៅទីណាមួយ ក៏ចេញទៅដោយរហ័ស ចំណែកព្រះរាជាត្រូវមានការប្រុងប្រៀបច្រើន មានការត្រៀមដំរី ព្រះរាជពាហនៈជាដើម ទើបសមគួរ យ៉ាងណា ឧបមេយ្យនេះ គប្បីជ្រាបយ៉ាងនោះ ។

ក្នុងវេលាល្ងាចថ្ងៃនោះឯង ព្រះសាស្តាទ្រង់ប្រជុំសាវក ក្នុងវត្តវេឡុវនប្រទានតំណែងជាអគ្គសាវកដល់ព្រះថេរៈទាំងពីរហើយ ទ្រង់សម្តែងបាតិមោក្ខ ។ ពួកភិក្ខុលើកទោសពោលថា ព្រះសាស្តាប្រទានតំណែងដល់ភិក្ខុទាំងឡាយដោយយល់មុខ កាលទ្រង់ប្រទានតំណែងអគ្គសាវក គួរប្រទានដល់បញ្ច-វគ្គិយភិក្ខុដែលបួសមុន បើមិនឃើញបញ្ចវគ្គិយទាំងនោះ ក៏គួរប្រទានដល់ភិក្ខុ ៥៥ រូប មានព្រះយសត្ថេរជាប្រធាន បើមិនសម្លឹងមើលភិក្ខុទាំងនោះ ក៏គួរប្រទានដល់ភទ្ទវគ្គិយ បើមិនសម្លឹងមើលដល់ភទ្ទវគ្គិយៈទាំងនោះ ក៏គួរប្រទានដល់ភិក្ខុ ៣ នាក់បងប្អូន មានព្រះឧរុវេលកស្សបៈជាដើម តែព្រះសាស្តាទ្រង់រំលងភិក្ខុទាំងនោះ មានប្រមាណត្រឹមណោះ កាលប្រទានតំណែងអគ្គសាវក ក៏ទ្រង់យល់មុខប្រទានដល់អ្នកបួសក្រោយគេបង្អស់ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី កាលភិក្ខុទាំងឡាយទូលថា រឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនឲ្យតំណែងដោយយល់មុខ ដល់ពួកភិក្ខុឡើយ តែតថាគតឲ្យតំណែងដែលបុគ្គលម្នាក់ៗ ប្រាថ្នាហើយនោះឯង ដល់ភិក្ខុទាំងនោះ ឯអញ្ញាកោណ្ឌញ្ញៈកាលថ្វាយទាន ទាក់ទងដោយស្រូវដ៏ប្រសើរ ៩ ដង ក្នុងកាលស្រូវមួយរដូវក៏មិនបានប្រាថ្នាតំណែងអគ្គសាវកឡើយ តែបានប្រាថ្នាដើម្បីចាក់ធ្លុះអរហត្ត ដែលជាធម៌ដ៏ប្រសើរមុនសាវកទាំងឡាយ ហើយថ្វាយទាន ។ ភិក្ខុទាំងឡាយទូលសួរថា ថ្វាយក្នុងកាលណាព្រះអង្គ ។ ព្រះសាស្តាទ្រង់សាកសួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនឹងស្តាប់ឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងស្តាប់ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីភទ្ទកប្បនេះទៅ ៩១ កប្ប ព្រះមានព្រះភាគព្រះនាមវិបស្សី ទ្រង់កើតឡើងហើយក្នុងលោក ក្នុងកាលនោះ កុដុម្ពិកៈពីរនាក់បងប្អូន គឺមហាកាល និងចុល្លកាល បានព្រោះស្រូវសាលីច្រើន ថ្ងៃមួយ ចុល្លកាលទៅស្រែឃើញស្រូវល្អ ហែកដង្ហើមស្រូវសាលីមួយដើមហើយភ្លក្សមើល ។ មានរសឆ្ងាញ់ល្អ គាត់ប្រាថ្នានឹងថ្វាយគព្ភសាលីទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបចូលទៅរកបងប្រុស ហើយពោលថា ខ្ញុំនឹងហែកស្រូវផើមចម្អិនឲ្យជារបស់គួរដល់ព្រះពុទ្ធទាំងឡាយ ហើយថ្វាយទាន បងប្រុសពោលថា ឯងនិយាយអ្វី ការហែកស្រូវសាលីកំពុងផើមធ្វើទាន មិនធ្លាប់មានឡើយក្នុងអតីតៈ នឹងមិនមានក្នុងអនាគត ឯងកុំធ្វើ

ស្រូវសាលីឲ្យវិនាសឡើយ ចុល្លកាលអង្វររឿយៗ ដដែលៗ កាលនោះ ទើបបងប្រុសពោលថា បើដូច្នោះ យើងត្រូវបែងស្រែជាពីរចំណែក ហើយកុំប៉ះពាល់ចំណែករបស់យើង ចូរធ្វើចំណែកដែលឯងប្រាថ្នា ក្នុងស្រែដែលជាចំណែករបស់ឯងចុះ ។ ចុល្លកាលទទួលថា សាធុ ហើយចែកស្រែគ្នា បានសូមកម្លាំងមនុស្សជាច្រើន ហែកដង្ហើមស្រូវសាលីកិនជាទឹកដោះ ចម្អិនដោយសប្បិ ទឹកឃ្មុំ និងស្ករផែនថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងកាលស្រេចភត្តកិច្ចក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទានដ៏ប្រសើររបស់ខ្ញុំព្រះអង្គនេះ សូមប្រព្រឹត្តទៅដើម្បីការត្រាស់ដឹងធម៌ដ៏ប្រសើរ មុនសាវកទាំងពួង ។ ព្រះសាស្តាត្រាស់ថា ការប្រាថ្នារបស់អ្នកចូរសម្រេចយ៉ាងនោះចុះ ហើយទ្រង់ធ្វើអនុមោទនា ។ គាត់ទៅស្រែពិនិត្យមើល ឃើញស្រែកកកុញដោយកួរស្រូវសាលីដូចគេចងជាបាច់ៗ ក្នុងស្រែទាំងមូល បាននូវបីតិ ៥ យ៉ាង ហើយគិតថា ជាលាភរបស់អញហ្ន៎ លុះដល់ស្រូវល្មមធ្វើអំបុក បានថ្វាយទានដ៏ប្រសើរដោយអំបុក ។ បានថ្វាយទានដែលទាក់ទងដោយស្រូវដ៏ប្រសើរ មួយអន្លើដោយអ្នកស្រុកទាំងឡាយ មុនប្រូតបានថ្វាយទានដ៏ប្រសើរក្នុងកាលប្រូតក្នុងកាលធ្វើចំណងបានថ្វាយទានដ៏ប្រសើរក្នុងកាលធ្វើចំណង ក្នុងគ្រាបោកបែនជាដើម ក៏បានថ្វាយទានដ៏ប្រសើរក្នុងកាលបោកបែន ក្នុងកាលស្រូវមកដល់លាន ... ប្រសើរដល់ក្នុងជង្រុក បានថ្វាយទានដ៏ប្រសើរ ៩ ដង ក្នុងស្រែមួយរដូវ ដោយប្រការយ៉ាងនេះ ។ ទីដែលប្រូតកាត់យកហើយ បានពេញដូចដើមរាល់ៗ ដង ។ ស្រូវបានដុះដាលបរិបូណ៌ឡើងយ៉ាងក្រៃលែង

ឈ្មោះថា ធម៌រមែងរក្សាបុគ្គលរក្សាធម៌ សមដូចព្រះមានព្រះភាគត្រាស់ថា

ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គល
សន្សំល្អហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុង
ធម៌ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិន
ទៅកាន់ទុគ្គតិ ។

អញ្ញាកោណ្ឌញ្ញៈ ប្រាថ្នាដើម្បីត្រាស់ដឹងធម៌ដ៏ប្រសើរមុនគេ ទើបបាន
ថ្វាយទានដ៏ប្រសើរ ៩ ដង ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមថាវិបស្សី
ដោយប្រការយ៉ាងនេះឯង ។[១]

ម្យ៉ាងទៀត ក្នុងកាលនៃព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ ក្នុងហង្សវតីនគរ
ក្នុងទីបំផុតមួយសែនកប្បអំពីនេះទៅ អញ្ញាកោណ្ឌញ្ញៈថ្វាយមហាទានអស់ ៧
ថ្ងៃហើយ ក្រាបទៀបបាទមូលរបស់ព្រះដ៏មានព្រះភាគអង្គនោះ តាំងសេចក្តី
ប្រាថ្នាដើម្បីត្រាស់ដឹងធម៌ដ៏ប្រសើរមុនគេដូចគ្នា ។ តថាគតបានឲ្យផលដែល
អញ្ញាកោណ្ឌញ្ញៈនេះប្រាថ្នាហើយនោះឯង ដោយប្រការដូច្នេះ ។ មិនមែនឲ្យ
ដោយយល់មុខឡើយ ។

ភិក្ខុទាំងឡាយទូលសួរថា ជន ៥៥ នាក់ មានយសកុលបុត្រជាប្រធាន
ធ្វើកម្មអ្វី ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ជន ៥៥ នោះ ប្រាថ្នាអរហត្ត
ក្នុងសម្នាក់ព្រះពុទ្ធមួយអង្គ ធ្វើកុសលកម្មច្រើនហើយ ខាងក្រោយ កាល
ព្រះពុទ្ធមិនទាន់កើតឡើង ជាសម្លាញ់នឹងគ្នា ធ្វើបុណ្យរួមជាពួកតែមួយ ជាអ្នក

១- ក្នុងទីខ្លះថា មហាកាល ជាអ្នកធ្វើទាននេះ ។

ចាត់ចែងបុណ្យសពជនឥតទីពឹង ។ ថ្ងៃមួយ ជនទាំងនោះ ជួបស្រីស្លាប់ម្នាក់ស្រុះស្រួលថានឹងដុត ទើបនាំទៅកាន់ឈាបនដ្ឋាន ក្នុងជនទាំងនោះ ផ្ទាកក្នុងព្រៃខ្មោច ៥ នាក់ ដោយប្រាប់ថា ពួកអ្នកចូរដុត ឯមនុស្សដ៏សេស ចូលទៅក្នុងស្រុក ។ បុរសម្នាក់យកឈើសូលចាក់សពនោះ ត្រឡប់ទៅ ត្រឡប់មក បានអសុភសញ្ញាហើយ ។ គាត់សម្ដែងដល់សម្លាញ់ ៤ នាក់ក្រៅអំពីនេះថា អ្នកដ៏ចម្រើន អ្នកចូរមើលសពនេះមានស្បែករបកហើយ ក្នុងទីនោះៗ ដូចគោពពាលមិនស្អាត ស្អុយ គួរខ្ពើមរអើម ។ ជនទាំង ៤ នោះក៏បានអសុភ-សញ្ញាក្នុងសពនោះ ។ ជនទាំង ៥ ចូលទៅកាន់ស្រុកប្រាប់ដល់សម្លាញ់ដ៏សេស ចំណែកបុរសនោះបានទៅកាន់ផ្ទះ ប្រាប់ដល់មាតាបិតា និងភរិយា ។ ជនទាំងអស់នោះក៏ចម្រើនអសុភសញ្ញាហើយ នេះជាបុព្វកម្មរបស់មនុស្ស ៥៥ នាក់ មានយសកុលបុត្រជាប្រធាននោះ ។ ព្រោះហេតុនេះឯង ការសម្គាល់ក្នុងផ្ទះដែលដេរដាស់ដោយស្ត្រី ហាក់ដូចព្រៃខ្មោច ទើបកើតដល់យសកុល-បុត្រ ។ ដោយឧបនិស្ស័យសម្បត្តិនោះ ទើបការសម្រេចគុណវិសេសកើតឡើងដល់ជនទាំងអស់ ។ ជនទាំងនេះ បានទទួលផលដែលខ្លួនប្រាថ្នាហើយដូចគ្នា ដោយប្រការយ៉ាងនេះ មិនមែនតថាគតឲ្យដោយយល់មុខឡើយ ។

ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ ភទ្ទវគ្គិយដែលជាសម្លាញ់នឹងគ្នាបានធ្វើកម្មអ្វី ។

ម្នាលភិក្ខុទាំងឡាយ ពួកភទ្ទវគ្គិយនោះក៏ប្រាថ្នាអរហត្តក្នុងសម្នាក់ព្រះពុទ្ធក្នុងកាលមុន ហើយធ្វើបុណ្យ ។ ក្រោយមក កាលព្រះពុទ្ធមិនទាន់កើតឡើង

ជាអ្នកលេង ៣០ នាក់ ស្តាប់តុណ្ហិភាវៈហើយ បានរក្សាសីល ៥ អស់ ៦ ម៉ឺនឆ្នាំ កុទុវត្តិយទាំងនេះក៏បានផលដែលខ្លួនប្រាថ្នាហើយដូចគ្នា ដោយប្រការយ៉ាងនេះ មិនមែនតថាគតឲ្យដោយយល់មុខដល់ភិក្ខុទាំងឡាយនោះឡើយ ។

ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ កស្សបៈ ៣ នាក់បងប្អូនមានឧរុវេលកស្សបៈជាដើម ធ្វើកម្មអ្វីដែរ ។

ព្រះសាស្តាត្រាស់ថា ជនទាំងនោះប្រាថ្នាអរហត្តដូចគ្នា ធ្វើបុណ្យហើយ ។ ក្នុង ៩២ កប្បរាប់អំពីនេះទៅ ព្រះពុទ្ធ ២ អង្គ គឺព្រះតិស្សៈ ១ ព្រះផុស្សៈ ១ ទ្រង់កើតឡើងហើយ ។ រាជាព្រះនាមមហិន្ទៈ បានជាព្រះបិតារបស់ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ កាលទ្រង់សម្រេចសម្ពោធិហើយ ព្រះឱរសពៅរបស់ព្រះរាជាបានជាព្រះអគ្គសាវ័ក កូនបុរោហិតបានជាទុតិយសាវ័ក ។ ព្រះរាជាបានយាងទៅកាន់សម្នាក់ព្រះសាស្តា ទ្រង់ទតមើលជនទាំងនោះថា រាជឱរសច្បងរបស់អញជាព្រះពុទ្ធ រាជឱរសពៅជាអគ្គសាវ័ក បុត្របុរោហិតជាទុតិយសាវ័ក ទ្រង់បន្លឺព្រះឧទាន ៣ ដងថា ព្រះពុទ្ធជារបស់ខ្ញុំ ព្រះធម៌ជារបស់ខ្ញុំ ព្រះសង្ឃជារបស់ខ្ញុំ ខ្ញុំសូមនមស្ការដល់ព្រះដ៏មានព្រះភាគដែលជាអរហន្តទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯងនោះ ដូច្នេះហើយ ក្រាបទៀបបាទមូលរបស់ព្រះសាស្តា ទ្រង់ទូលប្តេជ្ញាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គហាក់ដូចជាអង្គុយដេកលក់ក្នុងទីបំផុតអាយុប្រមាណ ៩ ម៉ឺនឆ្នាំ សូមទ្រង់កុំយាងទៅកាន់ផ្ទះរបស់ជនដទៃ សូមទ្រង់ទទួលបច្ច័យ ៤ របស់ខ្ញុំព្រះអង្គអស់កាលដែលខ្ញុំព្រះអង្គនៅមានជីវិត ដូច្នេះហើយ ទ្រង់ធ្វើពុទ្ធឧបដ្ឋាក ជា

ប្រចាំ ។ ម្យ៉ាងទៀត ព្រះរាជាទ្រង់មានព្រះរាជឱរស ៣ ព្រះអង្គទៀត ។ បណ្ដាឱរស ៣ អង្គនោះ ព្រះរាជឱរសច្បងមានអ្នកចម្បាំងជាបរិវារ ៥០០ ព្រះរាជឱរសកណ្ដាលមាន ៣០០ ព្រះរាជឱរសពៅមាន ២០០ ព្រះរាជឱរសទាំង ៣ អង្គនោះទូលសូមឱកាសនឹងព្រះបិតាថា សូមឱ្យទូលបង្គំទាំងឡាយ ក៏នឹងនិមន្តព្រះជេដ្ឋាសោយដែរ សូមឱ្យទូលអង្វររឿយៗ ក៏មិនបាន ។ កាលបច្ចន្តជនបទបះបោរហើយ ត្រូវបញ្ជូនទៅដើម្បីប្រយោជន៍នឹងរម្ងាប់បច្ចន្តជនបទនោះ លុះបង្ក្រាបបច្ចន្តជនបទបានរាបទាបហើយ មកកាន់សម្នាក់ព្រះរាជបិតា ។ គ្រានោះ ព្រះបិតាទ្រង់ឱបព្រះឱរសទាំង ៣ នោះហើយ ថើបត្រង់សីសៈត្រាស់ថា បាទាំងឡាយបិតាឲ្យពរដល់បុត្រ ។ ឱរសទាំង ៣ នោះទូលថា សាធុ ព្រះអង្គ ។ ធ្វើពរឲ្យជាការកាន់យកហើយ ដោយកាលកន្លងទៅពីរបីថ្ងៃ ព្រះបិតាត្រាស់ទៀតថា នែបាទាំងឡាយ ពួកបាចូរទទួលពរចុះ ។ រាជបុត្រទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ការបំណាំងដោយវត្ថុណាមួយដទៃរបស់ទូលបង្គំមិនមាន ឥឡូវនេះ ទូលបង្គំនឹងនិមន្តព្រះជេដ្ឋាសោយ សូមទ្រង់ព្រះរាជទានពរនេះដល់ទូលបង្គំចុះ ព្រះរាជាត្រាស់ថា នែបា យើងឲ្យមិនបានទេ ព្រះរាជឱរសទូលថា បើមិនព្រះរាជទានជានិច្ច សូមទ្រង់ព្រះរាជទានត្រឹម ៧ ឆ្នាំ ព្រះរាជាត្រាស់ថា មិនបានទេបា ព្រះរាជឱរសទូលថា បើដូច្នេះ សូមព្រះរាជទានត្រឹម ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ ព្រះរាជាត្រាស់ថា មិនបានទេបា ព្រះរាជឱរសទូលថា ណ្ហើយចុះ សូមទ្រង់ព្រះរាជទានត្រឹមតែ ៣ ខែដល់ខ្ញុំព្រះអង្គទាំងឡាយ ម្នាក់

មួយខែៗ ចុះ ព្រះរាជាពោលថា សាធុ បើដូច្នោះ បាច្ចូរនិមន្តឲ្យទ្រង់សោយបាន ៣ ខែ ។

នាយឃ្លាំងរបស់ព្រះរាជបុត្រទាំង ៣ នោះ មានម្នាក់ នាយស្មៀន ក៏ម្នាក់ដូចគ្នា ។ ព្រះរាជបុត្រទាំង ៣ អង្គនោះ មានបុរស ១២ ម៉ឺនជាបរិវារ ។ ព្រះរាជឱរសទាំង ៣ ឲ្យហៅបរិវារទាំងនោះមកហើយ ត្រាស់ថា យើងទាំង ៣ នឹងទទួលសីល ១០ ជណ្តប់សំពត់កាសាវពស្ត្រពីរជាន់ នៅរួមជាមួយព្រះសាស្តាអស់ ៣ ខែនេះ ពួកអ្នកគប្បីទទួលតម្លៃមានប្រមាណប៉ុណ្ណោះ ញុំាំងរបស់ទំពា និងរបស់បរិភោគគ្រប់យ៉ាងឲ្យប្រព្រឹត្តទៅដល់ភិក្ខុ ៩ ម៉ឺនរូប និងអ្នកចម្បាំងរបស់យើងមួយពាន់នាក់ ព្រោះបន្ទាប់អំពីនេះទៅ ពួកយើងមិនបានពោលពាក្យណាមួយឡើយ ។

ព្រះរាជឱរសទាំង ៣ នោះ នាំបុរសបរិវារមួយពាន់សមាទានសីល ១០ ជណ្តប់សំពត់កាសាវពស្ត្រ នៅតែក្នុងវិហារ ។ នាយឃ្លាំង និងនាយស្មៀន បានរួមគ្នាបើកស្បៀងតាមវារៈៗ អំពីឃ្លាំងទាំងឡាយរបស់បងប្អូនទាំង ៣ ថ្វាយទាន ។

កូនរបស់ពួកកម្មករស្រែកយំត្រូវការបបរ និងកត្តជាដើម កម្មករទាំងនោះ កាលភិក្ខុសង្ឃមិនទាន់មក ក៏ឲ្យវត្ថុមានបបរ និងកត្តជាដើមដល់កូនទាំងនោះ ។ ក្នុងពេលដែលភិក្ខុសង្ឃឆាន់ស្រេចហើយ មិនជាប់មានរបស់អ្វីសល់ឡើយ ។

ក្នុងកាលបន្ទាប់មក ពួកកម្មករទាំងនោះពោលអាងថា ខ្ញុំឲ្យដល់កូនដូច្នេះ

ហើយ ទទួលទៅបរិភោគឯង ។ ឃើញអាហារដែលពេញចិត្ត ក៏មិនអាចអត់ធ្មត់បាន ពួកជនទាំងនោះមានប្រមាណ ៨៤០០០ នាក់ ពួកគេបរិភោគអាហារដែលថ្វាយសង្ឃហើយ ក្រោយអំពីបែកកាយ បានទៅកើតក្នុងបិត្តិវិស័យហើយ ។

ចំណែកព្រះឱរសបីនាក់បងប្អូន មួយអន្លើដោយបុរសមួយពាន់ ធ្វើកាលកិរិយាហើយ កើតក្នុងទេវលោក អន្ទោលអំពីទេវលោក កាន់ទេវលោក ញុំាងកាលឲ្យអស់ទៅ ៩២ កប្ប រាជឱរសបីនាក់បងប្អូននោះ ប្រាថ្នាអរហត្តធ្វើកល្យាណកម្មក្នុងកាលនោះ ដោយប្រការយ៉ាងនេះ ។ ជដិលបីនាក់បងប្អូននោះបានទទួលផលដែលខ្លួនប្រាថ្នាហើយដូចគ្នា តថាគតមិនមែនឲ្យដោយយល់មុខឡើយ ។

ចំណែកស្មៀនរបស់ឱរសទាំងបីអង្គនោះ ក្នុងកាលនោះបានជាព្រះបាទពិម្ពិសារ នាយឃ្លាំងបានជាវិសាខឧបាសក ។ កម្មកររបស់ជនទាំងបីនោះកើតហើយក្នុងពួកប្រេតក្នុងកាលនោះ អន្ទោលទៅមកដោយអំណាចនៃទុគ្គតិ និងសុគតិ ក្នុងកប្បនេះ កើតក្នុងបេតលោកនោះឯង អស់ ៤ ពុទ្ធន្តរ ។

ប្រេតទាំងនោះចូលគាល់ព្រះដ៏មានព្រះភាគ ព្រះនាមកកុសន្ធៈ ដែលទ្រទ្រង់ព្រះជន្មាយុបាន ៤ ម៉ឺនឆ្នាំ ទ្រង់កើតឡើងមុនព្រះពុទ្ធគ្រប់អង្គ ក្នុងកប្បនេះទូលថា សូមទ្រង់មេត្តាប្រាប់កាលដែលបានអាហារដល់ខ្ញុំព្រះអង្គទាំងឡាយ ។

ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកមិនបានអាហារក្នុងកាលរបស់តថាគត តែខាងក្រោយ កាលផែនដីដុះឡើងប្រមាណមួយយោជន៍ ព្រះពុទ្ធព្រះនាមកោនា-

គមនៈនឹងកើតឡើង ។ ពួកអ្នកគប្បីទូលសួរព្រះអង្គចុះ ។

ប្រេតទាំងនោះ ញុំាងកាលមានប្រមាណប៉ុណ្ណោះឲ្យអស់ទៅហើយ កាលព្រះពុទ្ធព្រះនាមកោនាគមនៈកើតឡើងហើយ ទើបបានទូលសួរទ្រង់ សូម្បីព្រះពុទ្ធអង្គនោះក៏ត្រាស់ថា ពួកអ្នកមិនបានអាហារក្នុងកាលរបស់តថាគត តែខាងក្រោយ កាលមហាប្រឹថពីដុះឡើងបានមួយយោជន៍ ព្រះពុទ្ធព្រះនាមកស្សបៈកើតឡើង ពួកអ្នកគប្បីទូលសួរព្រះអង្គចុះ ។

ប្រេតទាំងនោះញុំាងកាលមានប្រមាណប៉ុណ្ណោះ ឲ្យអស់ទៅហើយ កាលព្រះពុទ្ធព្រះនាមកស្សបៈកើតឡើងហើយ ទើបទូលសួរព្រះអង្គ សូម្បីព្រះពុទ្ធអង្គនោះក៏ត្រាស់ថា ពួកអ្នកមិនបានអាហារក្នុងកាលរបស់តថាគតឡើយ តែក្នុងកាលខាងក្រោយ មហាប្រឹថពីដុះឡើងប្រមាណមួយយោជន៍ ព្រះពុទ្ធព្រះនាមគោតមទ្រង់កើតឡើង ក្នុងកាលនោះញាតិរបស់ពួកអ្នក បានជាព្រះរាជាព្រះនាមពិម្ពិសារ ស្ដេចពិម្ពិសារនោះថ្វាយទានដល់ព្រះសាស្ដាហើយ នឹងឲ្យចំណែកកុសលទានដល់ពួកអ្នក ពួកអ្នកនឹងបានអាហារក្នុងគ្រានោះ ។ មួយពុទ្ធន្តរបានប្រាកដដល់ប្រេតទាំងនោះ ដូចក្នុងថ្ងៃស្អែក ។

ប្រេតទាំងនោះកាលព្រះតថាគតកើតឡើងហើយ កាលព្រះបាទពិម្ពិសារថ្វាយទានក្នុងថ្ងៃទីមួយ ប្រេតបន្លឺសំឡេងគួរខ្លាចបង្ហាញខ្លួនដល់ព្រះរាជា ក្នុងចំណែកនៃរាត្រីហើយ ។ ស្អែកឡើង ព្រះរាជាយាងមកកាន់វេឡុវ័ន ក្រាបទូលរឿងនោះ ដល់ព្រះតថាគត ។

ព្រះសាស្ដាត្រាស់ថា បពិត្រមហារាជ ក្នុងទីបំផុត ៩២ កប្បអំពីកប្ប

នេះទៅ ក្នុងកាលនៃព្រះពុទ្ធព្រះនាមផុស្សៈ ពួកប្រេតនោះ ជាព្រះញាតិរបស់ព្រះអង្គ បរិភោគអាហារដែលគេថ្វាយភិក្ខុសង្ឃ កើតក្នុងបេតលោកហើយអន្ទោលទៅ បានទូលសួរព្រះពុទ្ធទាំងឡាយដែលកើតឡើងហើយ មានព្រះពុទ្ធកកុសន្ធៈជាដើម ដែលព្រះពុទ្ធទាំងនោះ ត្រាស់ប្រាប់ពាក្យនេះៗ ហើយ ទន្ទឹងចំពោះទានរបស់ព្រះអង្គ អស់កាលមានប្រមាណប៉ុណ្ណេះ ។ ម្សិលមិញនេះកាលទ្រង់ថ្វាយទានហើយ មិនបានទទួលចំណែកបុណ្យ ទើបបានធ្វើយ៉ាងនោះ ។ ព្រះរាជាទូលសួរថា បពិត្រព្រះអង្គ បើខ្ញុំព្រះអង្គថ្វាយទានក្នុងឥឡូវនេះ ប្រេតទាំងនោះនឹងបានទទួលឬ ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ នឹងបាន ។ ព្រះរាជាទ្រង់និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានក្នុងថ្ងៃស្អែក ហើយបានព្រះរាជទានចំណែកបុណ្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមបាយទឹកដែលជាទិព្វសម្រេចដល់ពួកប្រេតទាំងនោះ អំពីមហាទាននេះ ។ បាយទឹកដែលជាទិព្វកើតហើយដល់ប្រេតទាំងនោះដូច្នោះឯង ។ ស្អែកឡើង ប្រេតទាំងនោះអាក្រាតកាយ បង្ហាញខ្លួនហើយ ។ ព្រះរាជាទូលថា ថ្ងៃនេះ ពួកប្រេតអាក្រាតកាយបង្ហាញខ្លួនដល់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ព្រោះទ្រង់មិនបានថ្វាយសំពត់ ។

ស្អែកឡើង ទើបព្រះរាជាថ្វាយចីវរទាំងឡាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ទ្រង់ឲ្យចំណែកបុណ្យថា សូមសំពត់ជាទិព្វទាំងឡាយសម្រេចដល់ប្រេតទាំងនោះ អំពីចីវរទាននេះចុះ ។ ក្នុងខណៈនោះឯង សំពត់ទិព្វកើត

ឡើងដល់ប្រេតទាំងនោះហើយ ។ ប្រេតទាំងនោះលះអត្តភាពរបស់ប្រេតតាំងនៅដោយអត្តភាពដែលជាទិព្វហើយ ។ ព្រះសាស្តាកាលទ្រង់ធ្វើអនុមោទនាទ្រង់បានធ្វើអនុមោទនាដោយតិរោកុឌ្ឍសូត្រថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** ជាដើម ។ ក្នុងទីបំផុតអនុមោទនា ធម្មាភិសម័យមានដល់សត្វ ៨៤០០០ ហើយ ។ ព្រះសាស្តាកាលត្រាស់រឿងនៃជដិល ៣ នាក់បងប្អូនហើយ ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ អគ្គសាវ័កទាំងពីរបានធ្វើកម្មអ្វី ។ ព្រះសាស្តាត្រាស់ថា អគ្គសាវ័កទាំងពីរធ្វើសេចក្តីប្រាថ្នា ដើម្បីជាអគ្គសាវ័ក ។ ពិតហើយ ក្នុងទីបំផុត ១ អសង្ខេយ្យ និង ១ សែនកប្ប រាប់អំពីកប្បនេះទៅ សារីបុត្រកើតក្នុងត្រកូលព្រាហ្មណមហាសាល មានឈ្មោះថា សរទមាណព ។ មោគ្គល្លានកើតក្នុងត្រកូលគហបតិមហាសាល មានឈ្មោះថា សិរិវឌ្ឍកុដុម្ពិកមាណព ។ មាណពទាំងពីរនោះបានជាសម្លាញ់លេងដីរួមគ្នា ។ សរទមាណពដោយអនិច្ចកម្មទៅនៃបិតា បានគ្រប់គ្រងទ្រព្យដ៏ច្រើន ដែលជាមត៌ករបស់ត្រកូល ។ ថ្ងៃមួយ នៅក្នុងទីកំបាំងគិតថា អញរមែងដឹងអត្តភាពក្នុងលោកនេះប៉ុណ្ណោះ មិនដឹងអត្តភាពក្នុងលោកខាងមុខឡើយ ធម្មតាការស្លាប់របស់សត្វដែលកើតហើយទាំងឡាយ ជារបស់ទៀង អញគួរបួសជាបព្វជិតបែបណាមួយ ធ្វើការស្វែងរកមោក្ខធម៌ ។

សរទមាណពនោះ ចូលទៅរកសម្លាញ់ហើយពោលថា សិរិវឌ្ឍសម្លាញ់ ខ្ញុំនឹងបួស ហើយស្វែងរកមោក្ខធម៌ អ្នកនឹងបួសជាមួយខ្ញុំឬ ។ សិរិវឌ្ឍតបថា

ខ្ញុំមិនអាចបួសបានទេ អ្នកបួសម្នាក់ឯងចុះ ។ សរទមាណពនោះ គិតថា ធម្មតាអ្នកទៅបរលោក នាំសម្លាញ់ ឬញាតិមិត្តទៅមិនបានឡើយ កម្មដែលខ្លួនធ្វើហើយ ជារបស់ខ្លួនឯង ។ បន្ទាប់អំពីនោះ ទើបសរទមាណពឲ្យបើកឃ្លាំងកែវចេញ ឲ្យមហាទានដល់មនុស្សកំព្រា អ្នកដើរផ្លូវ វនិព្វក និងយាចកទាំងឡាយ ចូលទៅកាន់ជើងភ្នំ បួសជាឥសីហើយ ។ ជនទាំងឡាយបួសតាមសរទៈនោះដោយអាការយ៉ាងនេះ គឺម្នាក់ ពីរនាក់ បីនាក់ រហូតមានជដិលប្រមាណ ៧ ម៉ឺន ៤ ពាន់នាក់ ។ ជដិលទាំងនោះញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ ប្រាប់កសិណបរិកម្មដល់ជដិលទាំងនោះ ។ សូម្បីជដិលទាំងនោះ ក៏ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងហើយ ។

ដោយសម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមអនោមទស្សី ទ្រង់កើតឡើងហើយក្នុងលោក ក្នុងនគរឈ្មោះចន្ទវតី ព្រះរាជាព្រះនាមយសវន្ត ជាព្រះបិតា ព្រះទេវីព្រះនាមយសោធរាជាព្រះមាតា ដើមអជ្ជុនជាទីត្រាស់ដឹង អគ្គសាវកទាំងពីរ ឈ្មោះនិសភៈ ១ ឈ្មោះអនោមៈ ១ ឧបដ្ឋាកឈ្មោះវរុណ អគ្គសាវិកាទាំងពីរ ព្រះនាមសុន្ទរា ១ សុមនា ១ ព្រះជន្មាយុមានមួយសែនឆ្នាំ ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ព្រះរស្មីនៃព្រះសរីរៈផ្សាយទៅ ១២ យោជន៍ ភិក្ខុមួយសែនជាបរិវារ ។ ថ្ងៃមួយ ក្នុងពេលទៀបភ្លឺ ព្រះពុទ្ធព្រះនាមថាអនោមទស្សីនោះ ទ្រង់ចេញអំពីមហាករុណាសមាបត្តិ ទ្រង់ពិចារណាមើលសត្វលោក ទតឃើញសរទតាបសហើយ ទ្រង់ព្រះតម្រិះថា ព្រោះតថាគតទៅកាន់សម្នាក់សរទតាបស ក្នុងថ្ងៃនោះជាបច្ច័យ ព្រះធម្មទេសនានឹងមានគុណ

ធំ សរទតាបសនេះ នឹងប្រាថ្នាតំណែងអគ្គសាវក សិរិវឌ្ឍកុដុម្ពិកៈដែលជាសម្លាញ់តាបសនោះ នឹងប្រាថ្នាតំណែងអគ្គសាវកទីពីរ ក្នុងកាលចប់ទេសនាជដិល ១ ម៉ឺន ៤ ពាន់បរិវារតាបសនោះ នឹងសម្រេចអរហត្ត តថាគតគួរទៅក្នុងទីនោះ ។ ដូច្នេះហើយ ទ្រង់កាន់បាត្រ និងចីវររបស់ព្រះអង្គមិនត្រាស់ហៅបុគ្គលដទៃ យាងទៅមួយព្រះអង្គឯង ដូចស្តេចរាជសីហ៍ កាលអន្តេវាសិកទាំងឡាយរបស់សរទតាបសទៅហើយ ដើម្បីបេះផ្លែឈើ ទ្រង់អធិដ្ឋានថា ចូរសរទតាបស ជ្រាបនូវភាពដែលតថាគតជាព្រះពុទ្ធ កាលសរទតាបសឃើញនោះឯង ទ្រង់ចុះអំពីអាកាស ប្រថាប់លើផែនដីហើយ ។

សរទតាបសឃើញពុទ្ធានុភាព និងការសម្រេចនៃព្រះសរីរៈ ពិនិត្យនូវមន្តសម្រាប់ទាយព្រះលក្ខណៈ ក៏ជ្រាបបានថា បុគ្គលដែលប្រកបដោយលក្ខណៈទាំងនេះ បើនៅគ្រប់គ្រងផ្ទះ រមែងបានជាស្តេចចក្រពត្តិ បើចេញបួស រមែងបានជាព្រះសព្វញ្ញុពុទ្ធ មានកិលេសដំបូលបើកហើយក្នុងលោក ។ បុរសនេះជាព្រះពុទ្ធដោយឥតសង្ស័យ ទើបធ្វើការទទួល ថ្វាយបង្គំដោយបញ្ចង្គប្បតិដ្ឋាន បានរៀបចំអាសនៈថ្វាយហើយ ។ ព្រះដ៏មានព្រះភាគ គង់ប្រថាប់លើអាសនៈដែលរៀបចំ សរទតាបសកាន់យកអាសនៈដែលសមគួរដល់ខ្លួនហើយ អង្គុយក្នុងចំណែកម្ខាង ។ ក្នុងសម័យនោះ ជដិល ៨៤០០០ កាន់ផ្លែឈើទាំងឡាយប្រណីតៗ មានឱជៈល្អមកដល់សម្នាក់អាចារ្យហើយ ក្រឡេកមើលអាសនៈដែលព្រះពុទ្ធប្រថាប់ និងអាចារ្យអង្គុយហើយ ទើបពោលថា បពិត្រលោកអាចារ្យ ពួកខ្ញុំត្រាច់ទៅដោយយល់ថា ក្នុងលោកនេះ

បុគ្គលជាធំជាងលោកអាចារ្យ មិនមាន បុរសនេះ ប្រហែលជាធំជាងលោកអាចារ្យហ្ន៎ ។

សរទតាបសឆ្លើយថា នែបាទាំងឡាយ ពួកបានិយាយអ្វី ពួកបាប្រាថ្នាធ្វើភ្នំសិនេរុដែលមានកម្ពស់ ៦៨ សែនយោជន៍ ឲ្យស្មើនឹងគ្រាប់ស្ពៃ នែបាពួកបាកុំធ្វើការប្រៀបធៀបខ្ញុំ នឹងព្រះសព្វញ្ញុពុទ្ធឡើយ ។

គ្រានោះ តាបសទាំងនោះគិតថា បើបុរសនេះ ជាបុគ្គលតូចតាចសោតលោកអាចារ្យរបស់យើងគង់មិនទាញវត្ថុបែបនេះមកឧបមា បុរសនេះ ធំប៉ុនណាហ្ន៎ ដូច្នេះហើយ តាបសទាំងអស់ក្រាបទៀបព្រះបាទទាំងទ្វេ ថ្វាយបង្គំដោយសិរសាហើយ ។ គ្រានោះ អាចារ្យពោលនឹងតាបសទាំងនោះថា បាទាំងឡាយ ទេយ្យធម៌ដែលសមគួរដល់ព្រះពុទ្ធទាំងឡាយរបស់យើងមិនមានព្រះសាស្តាក៏យាងមកក្នុងទីនេះ ក្នុងពេលភិក្ខាចារ ពួកយើងនឹងថ្វាយទេយ្យ-ធម៌តាមកាល តាមកម្លាំង ពួកអ្នកចូរនាំផ្លែឈើប្រណីតដែលមានមក ដូច្នេះកាលបាននាំមកហើយ លាងដៃទាំងពីរហើយ ដាក់ក្នុងបាត្ររបស់ព្រះតថាគតដោយខ្លួនឯង កាលព្រះសាស្តាទ្រង់ទទួលផលាផល ទេវតាទាំងឡាយក៏ដាក់ឱជៈដែលជាទិព្វចូល ។ តាបសនោះបានត្រងទឹកថ្វាយដោយខ្លួនឯងនោះឯង ។

បន្ទាប់មក កាលព្រះសាស្តាប្រថាប់គង់ធ្វើភត្តកិច្ចហើយ តាបសនោះហៅអន្តេវាសិកទាំងអស់មកហើយ អង្គុយពោលសារាណីយកថា ក្នុងទីជិតព្រះសាស្តា ។ ព្រះសាស្តាត្រិះរិះថា ចូរអគ្គសាវកទាំងពីរមក ព្រមដោយភិក្ខុសង្ឃចុះ ។ អគ្គសាវកទាំងពីរនោះ ជ្រាបព្រះតម្រិះរបស់ព្រះសាស្តាហើយ

មានព្រះទីណាស្រេពមួយសែនរូបជាបរិវារ មកថ្វាយបង្គំព្រះសាស្តាហើយ បាន ឈរក្នុងចំណែកម្ខាង ។

លំដាប់នោះ សរទតាបសហៅអន្តេវាសិកទាំងឡាយមកហើយ ពោលថា បាទាំងឡាយ សូម្បីអាសនៈដែលព្រះពុទ្ធប្រថាប់គង់ក៏ទាប អាសនៈសម្រាប់ សមណៈមួយសែនក៏មិនមាន ពួកអ្នកគួរធ្វើពុទ្ធសក្ការៈឲ្យឱឡារក្នុងថ្ងៃនេះ ចូរ នាំផ្កាទាំងឡាយដែលដល់ព្រមដោយពណ៌ និងក្លិន មកអំពីជើងភ្នំចុះ ។ ពេល ដែលនិយាយហាក់ដូចជាយឺតយូរ តែវិស័យរបស់ឫទ្ធិបុគ្គលមិនគួរគិត ព្រោះ ដូច្នោះ ដោយកាលត្រឹមតែមួយសម្មុះប៉ុណ្ណោះ តាបសទាំងនោះនាំផ្កាទាំង- ឡាយ ដែលដល់ព្រមដោយពណ៌ និងក្លិនមកហើយ តាក់តែងអាសនៈផ្កា សម្រាប់ព្រះពុទ្ធ ប្រមាណបានមួយយោជន៍ សម្រាប់អគ្គសាវកទាំងពីរ ប្រមាណ ៣ គាវុត សម្រាប់ភិក្ខុដ៏សេស មានប្រមាណផ្សេងៗ គ្នា គឺមាន ប្រមាណកន្លះយោជន៍ជាដើម សម្រាប់ភិក្ខុថ្មីក្នុងសង្ឃ មានប្រមាណមួយ ឧសភៈ ( ២៥ ព្យាម ) បុគ្គលណាម្នាក់មិនគប្បីគិតថា ក្នុងអាស្រមបទមួយ កន្លែង អាចតាក់តែងអាសនៈធំ មានប្រមាណត្រឹមនោះបានដូចម្តេច ព្រោះថា នេះជាវិស័យនៃឫទ្ធិ កាលតាក់តែងអាសនៈស្រេចហើយយ៉ាងនោះ សរទ- តាបសឈរផ្គងអញ្ជលីចំពោះព្រះភក្ត្ររបស់ព្រះតថាគតហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ឡើងកាន់អាសនៈផ្កានេះ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលដ៏យូរ ព្រោះហេតុនោះ ទើប បុរាណាចារ្យពោលថា

សរទតាបសយកផ្កាផ្សេងៗ និងគ្រឿងក្រអូបរួមចូលគ្នា តុបតែង ដោយអាសនៈផ្កាហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះវីរៈ អាសនៈដែលខ្ញុំព្រះអង្គតាក់តែងហើយនេះ សមគួរដល់ព្រះអង្គ ទ្រង់កាលញ៉ាំងចិត្តខ្ញុំព្រះអង្គឲ្យជ្រះថ្លា សូមទ្រង់ប្រថាប់គង់លើអាសនៈផ្កា ព្រះសម្ពុទ្ធទ្រង់បានញ៉ាំងចិត្តខ្ញុំព្រះអង្គ ឲ្យជ្រះថ្លាហើយ ញ៉ាំងលោកនេះ ព្រមទាំងទេវលោកឲ្យត្រេកអរហើយ ទើបប្រថាប់គង់លើអាសនៈផ្កា អស់ ៧ យប់ ៧ ថ្ងៃ ។

កាលព្រះសាស្តាប្រថាប់គង់ហើយយ៉ាងនោះ អគ្គសាវកទាំងពីរ និងភិក្ខុដ៏សេស ក៏គង់ហើយលើអាសនៈដែលដល់លំដាប់ខ្លួន ។ សរទតាបសបានកាន់ឆត្រផ្កាធំ ឈរបាំងលើសិរសារបស់ព្រះតថាគត ព្រះសាស្តាទ្រង់អធិដ្ឋានថា ចូរសក្ការៈរបស់ជដិលនេះមានផលធំ ដូច្នេះហើយ ទ្រង់ចូលនិរោធ-សមាបត្តិ ។ អគ្គសាវកទាំងពីរក្តី ភិក្ខុដ៏សេសក្តី ជ្រាបថា ព្រះសាស្តាទ្រង់ចូលសមាបត្តិហើយ ក៏ចូលសមាបត្តិ កាលព្រះតថាគតប្រថាប់គង់ចូលនិរោធ-សមាបត្តិ អស់ ៧ ថ្ងៃ ពួកអន្តេវាសិក កាលដល់ពេលត្រាច់ទៅរកភិក្ខាបរិភោគមូលផលាផលក្នុងព្រៃហើយ ឈរផ្គងអញ្ជលីដល់ព្រះពុទ្ធទាំងឡាយអស់កាលដ៏សេស ។ ចំណែកសរទតាបស មិនទៅកាន់ទីភិក្ខាចារ បាំងឆត្រផ្កានោះឯង ឲ្យកាលកន្លងទៅដោយបីតិ និងសុខអស់ ៧ ថ្ងៃ ។ ព្រះសាស្តាទ្រង់ចេញអំពីនិរោធហើយ ត្រាស់ហៅអគ្គសាវកឈ្មោះនិសភត្ថេរដែលគង់ខាងស្តាំ ដោយព្រះតម្រាស់ថា ម្នាលនិសភៈ អ្នកចូរធ្វើអនុមោទនា

អាសនៈផ្កាដល់តាបសទាំងឡាយ ដែលធ្វើសក្ការៈ ព្រះថេរៈមានចិត្តត្រេកអរ ហាក់ដូចមេទ័ពធំ ជួបនូវលាភធំអំពីសម្នាក់របស់ស្តេចចក្រពត្តិ តាំងនៅក្នុងសាវកបារមីញាណ ផ្តើមអនុមោទនាអាសនៈផ្កាហើយ ។ ក្នុងទីបំផុតនៃទេសនារបស់ព្រះនិសភត្ថេរនោះ ព្រះសាស្តាត្រាស់ហៅទុតិយសាវ័ក ដោយព្រះតម្រាស់ថា ម្នាលភិក្ខុ អ្នកក៏ចូរសម្តែងធម៌ ។ ព្រះអនោមត្ថេរពិចារណាព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ពោលធម៌ហើយដោយអគ្គសាវ័កទេសនា ការត្រាស់ដឹងមិនមានដល់តាបសសូម្បីមួយរូប ។

គ្រានោះ ព្រះសាស្តាតាំងនៅក្នុងពុទ្ធវិស័យមិនមានប្រមាណ ទ្រង់ផ្តើមធម្មទេសនាហើយ ក្នុងកាលចប់ទេសនា ជដិល ៧ ម៉ឺន ៤ ពាន់ វៀរសរទ-តាបសចេញ សម្រេចអរហត្តហើយ ។ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា អ្នកទាំងឡាយចូរមកជាភិក្ខុចុះ រំពេចនោះឯង សក់ និងពុកមាត់របស់ជដិលទាំងនោះ បានអន្តរធានទៅហើយ បរិក្ខារ ៨ បានជណ្តប់កាយហើយនោះឯង ។

មានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ទើបសរទតាបសមិនបានសម្រេចអរហត្ត ឆ្លើយថា ព្រោះមានចិត្តរាយមាយ ។ បានឮថា តាំងអំពីកាលសរទតាបសនោះ ផ្តើមស្តាប់ធម្មទេសនារបស់ព្រះអគ្គសាវ័ក ដែលគង់លើអាសនៈទីពីរនៃព្រះសម្ពុទ្ធ តាំងនៅក្នុងសាវកបារមីញាណ សម្តែងធម៌ កើតការគិតឡើងថា ឱហ្ន៎ សូម្បីអញគប្បីបានទទួលធុរៈដែលសាវ័ករូបនេះបានទទួលក្នុងសាសនារបស់ព្រះពុទ្ធ ដែលទ្រង់កើតឡើងក្នុងអនាគត ដោយ

បរិវិតក្កនោះ ទើបសរទតាបសនោះ មិនអាចធ្វើការចាក់ធ្លុះនូវមគ្គផលបាន ។ លោកឈរថ្វាយបង្គំព្រះតថាគតហើយ ក្នុងទីចំពោះព្រះភក្ត្រ ក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុដែលគង់លើអាសនៈ ក្នុងលំដាប់នៃទ្រង់ជាអ្វី ក្នុងសាសនារបស់ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា ភិក្ខុដែលញ៉ាំងធម្មចក្រដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាម ជាអ្នកដល់នូវទីបំផុតនៃសាវកបារមីញាណ ចាក់ធ្លុះនូវបញ្ហា ១៦ យ៉ាង តាំងនៅ បុគ្គលនេះ ឈ្មោះថា ជាអគ្គសាវកក្នុងសាសនារបស់តថាគត ។ សរទៈបានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ដោយផលនៃសក្ការៈដែលខ្ញុំព្រះអង្គបាំងឆត្រផ្កាធ្វើហើយ អស់ ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាភាពជាសក្កៈ ឬភាពជាព្រហ្មដទៃឡើយ តែខ្ញុំព្រះអង្គសូមបានជាអគ្គសាវករបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូចព្រះនិសភៈអង្គនេះ ។

ព្រះសាស្តាទ្រង់បញ្ជូនអនាគតំសញ្ញាណទៅ ពិចារណាថា ការប្រាថ្នារបស់បុរសនេះនឹងសម្រេចឬហ្ន៎ ទ្រង់បានឃើញថា កន្លងមួយអសង្ខេយ្យ និងមួយសែនកប្បហើយ នឹងបានសម្រេច កាលទ្រង់ឃើញហើយ ទើបត្រាស់នឹងតាបសថា សេចក្តីប្រាថ្នារបស់អ្នកមិនឥតប្រយោជន៍ទេឡើយ ក្នុងអនាគត កន្លងទៅមួយអសង្ខេយ្យ និងមួយសែនកប្ប ព្រះពុទ្ធព្រះនាមថា គោតម ទ្រង់កើតឡើងក្នុងលោក ព្រះមាតារបស់ទ្រង់ព្រះនាមមហាមាយា-ទេវី ព្រះបិតាព្រះនាមសុទ្ធោទនមហារាជ ព្រះឱរសព្រះនាមរាហុល ឧបដ្ឋាក

មាននាមថាអានន្ទ ទុតិយសាវកមាននាមថាមោគ្គល្លាន ចំណែកអគ្គសាវក របស់ព្រះអង្គនាមថាធម្មសេនាបតីសារីបុត្រ កាលទ្រង់ព្យាករតាបសយ៉ាង នោះហើយ ត្រាស់ធម្មកថា មានភិក្ខុចោមរោមហោះទៅហើយ ។

ចំណែកសរទតាបស ទៅកាន់សម្នាក់ព្រះថេរៈដែលជាអន្តេវាសិក ហើយ បញ្ជូនដំណឹងទៅដល់សិរិវឌ្ឍកុដុម្ពិកៈជាសម្លាញ់ថា បពិត្រលោកម្ចាស់ សូម លោកម្ចាស់ទាំងឡាយ ប្រាប់ដល់សម្លាញ់របស់ខ្ញុំថា សរទតាបសដែលជា សម្លាញ់របស់អ្នក បានប្រាថ្នាតំណែងព្រះអគ្គសាវក ក្នុងសាសនារបស់ព្រះពុទ្ធ ព្រះនាមថាគោតម ដែលទ្រង់នឹងកើតឡើងក្នុងអនាគត ទៀបបាទមូលរបស់ ព្រះពុទ្ធព្រះនាមអនោមទស្សីហើយ ចូរអ្នកប្រាថ្នាតំណែងទុតិយអគ្គសាវក ចុះ ។ កាលពោលយ៉ាងនោះហើយ បានទៅក្នុងចំណែកម្ខាងមុនព្រះថេរៈ ទាំងឡាយ បានឈរត្រង់មាត់ទ្វាររបស់សិរិវឌ្ឍហើយ ។ សិរិវឌ្ឍពោលថា យូរហើយហ្ន៎ លោកម្ចាស់របស់ខ្ញុំទើបមក ដូច្នេះហើយ និមន្តឲ្យគង់លើ អាសនៈ ខ្លួនអង្គុយលើអាសនៈទាបជាង ហើយសាកសួរថា ហេតុអ្វី អន្តេ- វាសិកបរិស័ទលោកម្ចាស់បាត់អស់ទៅ សរទតាបសពោលថា យ៉ាងនោះឯង សម្លាញ់ ព្រះសម្ពុទ្ធអនោមទស្សី ទ្រង់មកកាន់អាស្រមរបស់យើងទាំងឡាយ ពួកខ្ញុំធ្វើសក្ការៈដល់ព្រះអង្គតាមកម្លាំងរបស់ខ្លួន ព្រះសាស្តាទ្រង់សម្តែងធម៌ ប្រោសពួកយើងគ្រប់គ្នា ក្នុងកាលចប់ទេសនា វៀរតែខ្ញុំចេញ ជនដ៏សេស សម្រេចអរហត្ត ហើយបួស ។ ខ្ញុំឃើញព្រះនិសភត្ថេរ អគ្គសាវករបស់ព្រះ សាស្តា ទើបប្រាថ្នាតំណែងអគ្គសាវកក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមគោតម

*ដែលទ្រង់នឹងកើតឡើងក្នុងអនាគត ឯអ្នកក៏ចូរប្រាថ្នាតំណែងទុតិយសាវកក្នុងសាសនារបស់ព្រះអង្គចុះ ។*

*សិរិវឌ្ឍពោលថា ខ្ញុំមិនមានការស្និទ្ធស្នាលនឹងព្រះសម្ពុទ្ធឡើយ សរទតាបសពោលថា រឿងទូលព្រះសម្ពុទ្ធជាភារៈរបស់ខ្ញុំឯង អ្នកចូររៀបចំសក្ការៈធំចុះ ។*

*សិរិវឌ្ឍស្ដាប់ពាក្យរបស់តាបសនោះហើយ បានធ្វើទីប្រមាណ ៨ករីសៈ ( មួយករីសៈ ១២៥ ហត្ថ ) ដោយមាត្រាវង្វាស់ត្រង់ទ្វារផ្ទះរបស់ខ្លួន ឲ្យមានផែនដីស្មើហើយ កៀរខ្សាច់ រោយផ្កា មានលាជជាគម្រប់ ៥ ធ្វើមណ្ឌបប្រក់ដោយផ្កាឧប្បលខៀវ តាក់តែងពុទ្ធាសនៈ រៀបចំអាសនៈដល់ភិក្ខុដ៏សេសរៀបចំសក្ការៈ និងគ្រឿងទទួលដ៏ច្រើនហើយ បានឲ្យសញ្ញាដល់សរទតាបសដើម្បីប្រយោជន៍និមន្តព្រះពុទ្ធទាំងឡាយ ។*

*ព្រះតាបសបាននាំភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទៅត្រង់លំនៅរបស់សិរិវឌ្ឍកុដុម្ពិកៈនោះហើយ ។ ចំណែកសិរិវឌ្ឍកុដុម្ពិកៈ ធ្វើការទទួលបាត្រអំពីព្រះហស្តរបស់ព្រះតថាគត និមន្តឲ្យចូលទៅកាន់មណ្ឌប ថ្វាយទឹកទក្ខិណោទកដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អង្គុយលើអាសនៈដែលតាក់តែង អង្គាសដោយភោជនដ៏ប្រណីត ក្នុងពេលស្រេចភត្តកិច្ច និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន គ្រងសំពត់ដែលមានតម្លៃច្រើន ហើយក្រាបទូលថា បពិត្រព្រះអង្គ ការផ្ដួចផ្ដើមនេះ មិនបានប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់តំណែងមានប្រមាណតូចតាចឡើយ សូមទ្រង់ធ្វើសេចក្ដីអនុគ្រោះដោយទំនង*

នេះឯង អស់កាល ៧ ថ្ងៃចុះ ។

ព្រះសាស្តាទ្រង់ទទួលហើយ ។ គាត់ញុំាងមហាទានឲ្យប្រព្រឹត្តទៅដោយទំនងនោះឯងរហូត ៧ ថ្ងៃ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ឈរផ្គងនូវអញ្ជលីក្រាបទូលថា បពិត្រព្រះអង្គ សរទតាបសសម្លាញ់របស់ខ្ញុំព្រះអង្គប្រាថ្នាថា ខ្ញុំគប្បីជាអគ្គសាវករបស់ព្រះសាស្តាអង្គណា ខ្ញុំព្រះអង្គគប្បីជាទុតិយសាវករបស់ព្រះសាស្តាអង្គនោះដូចគ្នា ។ ព្រះសាស្តាទ្រង់ពិចារណាដល់អនាគតកាលទ្រង់ឃើញភាវៈ គឺកាលសម្រេចនៃសេចក្តីប្រាថ្នារបស់បុគ្គលនោះ ទើបទ្រង់ព្យាករថា កន្លងអំពីនេះទៅមួយអសង្ខេយ្យ និងមួយសែនកប្ប អ្នកក៏នឹងបានជាទុតិយសាវករបស់ព្រះពុទ្ធព្រះនាមគោតម ។

សិរិវឌ្ឍ ស្តាប់ព្យាកររបស់ព្រះសម្ពុទ្ធហើយ ជាអ្នកត្រេកអរីករាយហើយ ព្រះសាស្តាទ្រង់ធ្វើកត្តានុមោទនាហើយ ព្រមទាំងបរិវារយាងទៅកាន់វិហារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្រាថ្នាដែលបុត្ររបស់តថាគតប្រាថ្នាហើយក្នុងកាលនោះ ។ អគ្គសាវកទាំងពីរនោះបានតំណែងតាមដែលខ្លួនប្រាថ្នានោះឯង តថាគតមិនមែនឲ្យដោយយល់មុខឡើយ ។

កាលព្រះសាស្តាត្រាស់ព្រះពុទ្ធវចនៈយ៉ាងនោះឯង អគ្គសាវកទាំងពីរថ្វាយបង្គំព្រះដ៏មានព្រះភាគ ទូលរឿងដែលជាបច្ចុប្បន្នទាំងអស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គកាលនៅជាអ្នកគ្រប់គ្រងផ្ទះ ទៅមើលមហោស្រពលើកំពូលភ្នំដូច្នេះជាដើម រហូតដល់ការសម្រេចសោតាបត្តិផល អំពីសម្នាក់ព្រះអស្សជិត្ថេរ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរ

នោះទៅកាន់សម្នាក់របស់អាចារ្យសញ្ជ័យ បំណងនឹងនាំលោកឲ្យមកកាន់បាទមូលរបស់ព្រះអង្គ ប្រាប់ថាលទ្ធិរបស់លោកមិនមានសារៈ ហើយពោលអានិសង្សក្នុងការមកទីនេះ អាចារ្យសញ្ជ័យឆ្លើយថា ឥឡូវនេះ ឈ្មោះថា ការនៅជាអន្តេវាសិករបស់ខ្ញុំ ហាក់ដូចជាការដល់នូវភាពកម្រើកនៃទឹកក្នុងត្រពាំង ខ្ញុំមិនអាចនៅជាអន្តេវាសិកបាន កាលខ្ញុំព្រះអង្គប្រាប់ថា លោកអាចារ្យ ពេលនេះ មហាជនមានដៃកាន់វត្ថុ មានគ្រឿងក្រអូប និងផ្កាកម្រងជាដើម ទៅបូជាចំពោះព្រះសាស្តា លោកនឹងធ្វើដូចម្តេច គាត់ឆ្លើយថា ក្នុងលោកនេះ អ្នកឈ្លាសវៃច្រើន ឬអ្នកល្ងង់ខ្លៅច្រើន កាលខ្ញុំព្រះអង្គឆ្លើយថា អ្នកល្ងង់ខ្លៅច្រើន គាត់ក៏ពោលថា បើដូច្នោះ ពួកអ្នកឈ្លាសវៃ នឹងទៅកាន់សម្នាក់ព្រះគោតម ពួកអ្នកល្ងង់ខ្លៅនឹងមកកាន់សម្នាក់របស់ខ្ញុំ អ្នកទាំងពីរទៅចុះ មិនប្រាថ្នានឹងមក ៗ

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សញ្ជ័យកាន់យករបស់ដែលមិនមានសារៈ ថាមានសារៈ និងរបស់ដែលមានសារៈ ថាមិនមានសារៈ ព្រោះភាពដែលខ្លួនជាមិច្ឆាទិដ្ឋិ ។ ចំណែកអ្នកទាំងពីរដឹងវត្ថុជាសារៈដោយភាពជាសារៈ និងវត្ថុដែលមិនជាសារៈ ដោយភាពមិនជាសារៈ លះវត្ថុដែលមិនមានសារៈចេញ កាន់យកតែវត្ថុដែលជាសារៈប៉ុណ្ណោះ ព្រោះភាពដែលខ្លួនជាបណ្ឌិត ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថានេះថា

អសារេ សារមតិនោ សារេ ចាសារទស្សិនោ
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា ។

**សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ**
**តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។**

*ជនទាំងឡាយ ដែលយល់ឃើញក្នុងធម៌មានខ្លឹម ថាជាធម៌មិនមានខ្លឹមផង ជាអ្នកតម្រិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌ដែលមានខ្លឹមឡើយ ។ ជនទាំងឡាយ ដែលយល់ឃើញនូវធម៌មានខ្លឹម ថាជាធម៌មានខ្លឹមផង យល់ឃើញនូវធម៌គ្មានខ្លឹម ថាជាធម៌គ្មានខ្លឹមផង ជាអ្នកមានតម្រិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌ដែលមានខ្លឹម ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទព្រះគាថាថា* **អសារេ សារមតិនោ** *សេចក្តីថា សភាវៈនេះ គឺបច្ច័យ ៤ មិច្ឆាទិដ្ឋិមានវត្ថុ ១០ ធម្មទេសនាដែលជាឧបនិស្ស័យនៃមិច្ឆាទិដ្ឋិនោះ ឈ្មោះថា ជាធម៌មិនមានខ្លឹម បុគ្គលមានប្រក្រតីឃើញក្នុងធម៌ ដែលមិនមានខ្លឹមនោះ ថាជាខ្លឹម ។*

*បទព្រះគាថាថា* **សារេ ចាសារទស្សិនោ** *សេចក្តីថា សភាវៈ គឺសម្មាទិដ្ឋិមានវត្ថុ ១០ ធម្មទេសនាដែលជាឧបនិស្ស័យនៃសម្មាទិដ្ឋិនោះ ឈ្មោះថា ជាខ្លឹម បុគ្គលមានប្រក្រតីឃើញក្នុងធម៌ដែលជាខ្លឹមនោះថា នេះជាខ្លឹម ។*

*ពីរបទថា* **តេ សារំ** *ជាដើម សេចក្តីថា ជនទាំងនោះ គឺបុគ្គលដែលកាន់យកមិច្ឆាទិដ្ឋិនោះតាំងនៅ ជាអ្នកមានសេចក្តីត្រិះរិះជាគោចរ ដោយអំណាចនៃវិតក្កទាំងឡាយ មានកាមវិតក្កជាដើម រមែងមិនសម្រេចសីលសារៈ*

សមាធិសារៈ បញ្ញាសារៈ វិមុត្តិសារៈ វិមុត្តិញ្ញាណទស្សនសារៈ និងនិព្វាន ដែលជាបរមត្ថសារៈ ។

បទថា **សារតោ** សេចក្តីថា ដឹងនូវសារៈ មានសីលសារៈជាដើមនោះឯងថា នេះឈ្មោះថាសារៈ និងដឹងធម៌ដែលមិនជាសារៈ មានប្រការដូចពោលហើយថា នេះមិនជាសារៈ ។

ពីរបទថា **តេ សារំ** ជាដើម សេចក្តីថា ជនទាំងនោះ គឺបណ្ឌិតដែលប្រកាន់សម្មាទស្សនៈយ៉ាងនោះតាំងនៅ ជាអ្នកមានតម្រិះត្រូវជាគោចរ ដោយអំណាចការត្រិះរិះទាំងឡាយ មានការត្រិះរិះចេញចាកកាមជាដើម រមែងសម្រេចធម៌ដែលជាសារៈ មានប្រការដូចពោលហើយនោះ ។

ក្នុងកាលចប់គាថា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទេសនាបានជាប្រយោជន៍ដល់ជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ៕៚

## រឿង សញ្ជ័យ ចប់

# រឿង ព្រះនន្ទត្ថេរ

## លំនាំដើម

ព្រះសាស្តា គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនន្ទ ត្រាស់ព្រះធម្មទេសនានេះថា **យថា អគារំ ទុច្ឆន្នំ** ជាដើម ។

សេចក្តីពិស្តារថា ព្រះសាស្តាទ្រង់មានបវរធម្មចក្រឲ្យប្រព្រឹត្តទៅហើយ យាងទៅកាន់ក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងវត្តវេឡុវ័ន ។ បណ្តាទូត ១០ នាក់ មានបរិវារម្នាក់ ១ ពាន់ ដែលព្រះបាទសុទ្ធោទនមហារាជ ទ្រង់បញ្ជូនទៅ ដោយត្រាស់ថា អ្នកទាំងឡាយចូរនាំព្រះអយ្យបុត្រមកឲ្យខ្ញុំចុះ ព្រះកាឡុទាយត្ថេរទៅក្រោយគេបង្អស់ សម្រេចអរហត្តហើយ ជ្រាបកាលដែលទ្រង់មកហើយ ពណ៌នាផ្លូវដោយគាថា ៦០ គាថា នាំព្រះសាស្តាដែលមានព្រះខីណាស្រព ២ ម៉ឺនចោមរោមហើយ ទៅកាន់កបិលវត្ថុបុរី ទ្រង់ធ្វើភ្លៀងបោក្ខរព័ស្ស ឲ្យជាអត្ថុប្បត្តិហេតុហើយ ត្រាស់មហាវេស្សន្តរជាតកក្នុងសមាគមព្រះញាតិ ស្អែកឡើង ទ្រង់ចូលទៅបិណ្ឌបាត ប្រោសព្រះបិតាឲ្យតាំងនៅក្នុងសោតាបត្តិផល ដោយព្រះគាថាថា **ឧត្តិដ្ឋេ នប្បមជ្ជេយ្យ** ជាដើម ។ ប្រោសព្រះនាងមហាបជាបតិគោតមីឲ្យតាំងនៅក្នុងសោតាបត្តិផល និងប្រោសព្រះរាជាឲ្យតាំងនៅក្នុងសកទាគាមិផល ដោយព្រះគាថាថា **ធម្មញ្ចរេ សុចរិតំ** ជាដើម ។ ក្នុងកាលស្រេចភត្តកិច្ច ទ្រង់អាស្រ័យពណ៌នាព្រះគុណរបស់រាហុលមាតា ត្រាស់ចន្ទកិន្នរីជាតក ក្នុងថ្ងៃទី ៣ បន្ទាប់អំពីថ្ងៃនោះ កាលវិវាហមង្គលដែលយាងព្រះមានព្រះភាគចូលផ្ទះ អភិសេករបស់នន្ទកុមារប្រព្រឹត្តទៅ ។ ទ្រង់ចូលទៅបិណ្ឌបាត ប្រទានបាត្រក្នុងព្រះហស្តរបស់នន្ទកុមារ ត្រាស់មង្គល ស្តេចក្រោកអំពីអាសនៈហើយចៀសចេញទៅ ទ្រង់មិនបានទទួលបាត្រអំពីព្រះហស្តរបស់នន្ទកុមារឡើយ ។

ចំណែកនន្ទកុមារនោះ ដោយការគោរពក្នុងព្រះសាស្តា ទើបមិនអាច

ទូលថា សូមទ្រង់ទទួលបាត្រវិញចុះ តែគិតយ៉ាងនេះថា ព្រះសាស្តាទ្រង់នឹងទទួលបាត្រត្រង់ក្បាលជណ្តើរ ។ ក្នុងទីនោះព្រះសាស្តាក៏ទ្រង់មិនបានទទួល ។ នន្ទកុមារក៏គិតថា ទ្រង់គង់នឹងទទួលត្រង់មាត់ជណ្តើរ ។ ក្នុងទីនោះព្រះសាស្តាក៏មិនទទួល ។ នន្ទកុមារក៏គិតថា ទ្រង់នឹងទទួលត្រង់ព្រះលានរាជវាំង ក្នុងទីនោះព្រះសាស្តាក៏ទ្រង់មិនទទួល ។ ព្រះកុមារប្រាថ្នាយាងត្រឡប់ យាងទៅដោយការមិនពេញព្រះហឫទ័យ ដោយការគោរពក្នុងព្រះតថាគត ទើបមិនអាចទូលថា សូមទ្រង់ទទួលបាត្រចុះ ទ្រង់យាងគិតថា ព្រះអង្គនឹងទទួលក្នុងទីនេះ ព្រះអង្គនឹងទទួលក្នុងទីនេះ ក្នុងខណៈនោះ ស្រីពួកជទៃឃើញអាការនោះហើយ ទើបប្រាប់ដល់នាងជនបទកល្យាណីថា បពិត្រព្រះនាង ព្រះដ៏មានព្រះភាគទ្រង់នាំនន្ទកុមារទៅហើយ គង់នឹងពង្រាត់នន្ទកុមារអំពីព្រះនាង ។

ចំណែកនាងជនបទកល្យាណីនោះ បានឮពាក្យនោះហើយ មានតំណក់ទឹកកំពុងហូរនោះឯង មានសក់ដែលបួងបានមួយចំហៀង ប្រញាប់ទៅទូលថា បពិត្រអយ្យបុត្រ សូមព្រះអង្គប្រញាប់យាងត្រឡប់ ពាក្យរបស់នាងនោះហាក់បីដូចធ្លាក់ទៅតាំងនៅក្នុងហទយៈរបស់នន្ទកុមារ ព្រះសាស្តាទ្រង់នៅតែមិនទទួលបាត្រអំពីដៃរបស់នន្ទកុមារនោះ ទ្រង់នាំនន្ទកុមារនោះទៅកាន់វិហារហើយត្រាស់ថា នន្ទ អ្នកចង់បួសឬទេ នន្ទកុមារនោះ ដោយការគោរពក្នុងព្រះពុទ្ធ ទើបមិនទូលថា ខ្ញុំព្រះអង្គមិនបួសទេ តែទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងបួស ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរឲ្យនន្ទបួសចុះ ។

ព្រះសាស្តាយាងទៅកាន់ក្រុងកបិលវត្ថុបុរីក្នុងថ្ងៃទី ៣ ទ្រង់ញុំាងនន្ទកុមារឲ្យបួសហើយ ក្នុងថ្ងៃទី ៧ ព្រះមាតារបស់ព្រះរាហុលតាក់តែងព្រះរាជកុមារហើយ បញ្ជូនទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគ ដោយព្រះសវនីយ៍ថា នែបាចូរបាមើលសមណៈដែលមានសមណៈ ២ ម៉ឺនចោមរោម ទ្រង់មានពណ៌សម្បុរដូចមាស មានវណ្ណៈនៃព្រះរូបដូចព្រហ្មនោះ សមណៈនោះជាបិតារបស់បា កំណប់ទ្រព្យធំមានហើយ ក្នុងកាលដែលព្រះបិតារបស់បានោះប្រសូត ។ តាំងអំពីកាលទ្រង់ចេញបួស មាតាមិនធ្លាប់ឃើញឡើយ បាចូរទៅទូលសូមមត៌កជាមួយទ្រង់ថា បពិត្រព្រះបិតា ខ្ញុំជាកុមារ លុះអភិសេកហើយនឹងបានជាស្តេចចក្រពត្តិ ខ្ញុំត្រូវការដោយទ្រព្យ សូមព្រះបិតាព្រះរាជទានទ្រព្យដល់ខ្ញុំ ព្រោះបុត្រ រមែងជាម្ចាស់របស់សម្បត្តិនៃបិតា ។ ព្រះរាជកុមារយាងទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ ក៏បានទូវសេចក្តីស្រឡាញ់ក្នុងបិតាត្រេកអរហើយ ទូលថា បពិត្រសមណៈ ម្លប់របស់ព្រះអង្គ ត្រជាក់ សុខណាស់ បានឈរពោលពាក្យដទៃដ៏ច្រើន ដែលសមគួរដល់ខ្លួន ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើភត្តកិច្ចហើយ ទ្រង់អនុមោទនាហើយ ស្តេចក្រោកចាកអាសនៈ ចៀសចេញទៅ សូម្បីព្រះកុមារក៏ទូលសូមថា បពិត្រសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំចុះ បពិត្រសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំចុះ ដូច្នេះហើយ ក៏យាងតាមព្រះដ៏មានព្រះភាគទៅ ។ ព្រះដ៏មានព្រះភាគ ក៏មិនឲ្យព្រះរាជកុមារត្រឡប់ ។ ចំណែកបរិជនក៏មិនអាចយាងព្រះរាជកុមារ ដែលយាងទៅតាមព្រះដ៏មានព្រះភាគឲ្យត្រឡប់បាន ព្រះរាជកុមារនោះ បានយាង

ទៅដល់អារាមនោះឯង ជាមួយព្រះដ៏មានព្រះភាគ ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា កុមារនេះចង់បានទ្រព្យ ដែលជាសម្បត្តិរបស់បិតា ទ្រព្យនោះទៅតាមវដ្ដៈ មានការចង្អៀតចង្អល់ ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានចំពោះ ត្រង់មណ្ឌលពោធិព្រឹក្សដល់កុមារនេះ នឹងធ្វើកុមារនេះឲ្យជាម្ចាស់មត៌ក ដែលជាលោកុត្តរ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគត្រាស់ឲ្យហៅព្រះសារីបុត្រមកហើយ ត្រាស់ថា ម្នាលសារីបុត្រ បើដូច្នោះ អ្នកចូរឲ្យរាហុលកុមារបួសចុះ ព្រះថេរៈ ឲ្យកុមារនោះឲ្យបួសហើយ ។ កាលព្រះកុមារបួសហើយ ទុក្ខមានប្រមាណ ជាទម្ងន់កើតឡើងដល់ព្រះរាជា ព្រោះទ្រង់បានឮដំណឹងនោះ ។

ព្រះរាជាទ្រង់មិនអាចសង្កត់នូវសេចក្ដីទុក្ខនោះបាន យាងទៅកាន់សម្នាក់ ព្រះដ៏មានព្រះភាគ ទូលហើយ សូមប្រទានពរថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ សូមប្រទានព្រះវរោកាស លោកម្ចាស់ទាំងឡាយ មិនគប្បីញ៉ាំងបុត្រដែល មាតាបិតាមិនអនុញ្ញាតឲ្យបួសឡើយ ។

ព្រះដ៏មានព្រះភាគ ប្រទានពរនោះដល់ព្រះរាជាហើយ ស្អែកឡើងសោយ ព្រះក្រយាហារព្រឹក ក្នុងព្រះរាជនិវេសន៍ហើយ កាលព្រះរាជាប្រថាប់នៅក្នុង ចំណែកម្ខាង ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងពេលដែលព្រះអង្គទ្រង់ធ្វើ ទុក្ករកិរិយា ទេវតាមួយអង្គចូលមករកខ្ញុំព្រះអង្គប្រាប់ថា ព្រះរាជឱរសរបស់ ព្រះអង្គសោយទិវង្គតហើយ ខ្ញុំព្រះអង្គមិនជឿពាក្យរបស់ទេវតានោះ ទើប

ជំទាស់ទេវតានោះថា បុត្ររបស់ខ្ញុំ បើមិនទាន់សម្រេចពោធិញ្ញាណ មិនធ្វើកាលកិរិយាឡើយ ដូច្នេះហើយ ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ឥឡូវនេះ ព្រះអង្គនឹងជឿបានដូចម្តេច សូម្បីក្នុងកាលមុន កាលបុរសម្នាក់ បង្ហាញឆ្អឹងដល់ទ្រង់ ទូលថា កូនរបស់ព្រះអង្គសោយទិវង្គតហើយ ក៏ទ្រង់មិនជឿ បានត្រាស់មហាធម្មបាលជាតក ព្រោះអត្ថុប្បត្តិហេតុនេះឯង ។ ក្នុងកាលចប់គាថា ព្រះរាជាតាំងនៅក្នុងអនាគាមិផល ។

ព្រះដ៏មានព្រះភាគ ប្រោសព្រះបិតាឲ្យតាំងនៅក្នុងផល ៣ ដោយប្រការដូច្នេះហើយ មានភិក្ខុសង្ឃចោមរោម យាងត្រឡប់ទៅកាន់ក្រុងរាជគ្រឹះទៀត បន្ទាប់អំពីនោះ ទ្រង់ទទួលប្តេជ្ញាជាមួយអនាថបិណ្ឌិកសេដ្ឋី ដើម្បីប្រយោជន៍ដល់ការយាងមកក្រុងសាវត្ថី កាលវត្តជេតពនមហាវិហារធ្វើស្រេចហើយ ទ្រង់យាងទៅចាំវស្សាក្នុងវត្តជេតពនមហាវិហារនោះ ។

កាលព្រះសាស្តា ប្រថាប់នៅក្នុងវត្តជេតពនយ៉ាងនេះឯង ព្រះនន្ទអផ្សុកហើយ ទើបប្រាប់សេចក្តីនោះ ដល់ភិក្ខុទាំងឡាយថា អាវុសោ ខ្ញុំមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្តព្រហ្មចរិយៈទៅបាន ខ្ញុំនឹងពោលលាសិក្ខាហើយសឹក ។ ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ត្រាស់ឲ្យហៅព្រះនន្ទមកគាល់ហើយត្រាស់ថា ម្នាលនន្ទ បានឮថា អ្នកប្រាប់ដល់ភិក្ខុច្រើនរូបយ៉ាងនេះថា អាវុសោ ខ្ញុំមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្តព្រហ្មចរិយៈទៅបាន ខ្ញុំនឹងពោលលាសិក្ខាហើយសឹកពិតឬ ។ ព្រះនន្ទទូលថា បពិត្រព្រះអង្គ ពិតយ៉ាងនោះហើយ ព្រះដ៏មានព្រះភាគត្រាស់ថា

ម្នាលនន្ទ អ្នកមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្តព្រហ្ម-ចរិយៈទៅបាន នឹងពោលលាសិក្ខាសឹកទៅដើម្បីហេតុអ្វី ព្រះនន្ទពោលថា បពិត្រព្រះអង្គ កាលខ្ញុំព្រះអង្គចេញចាកផ្ទះ នាងជនបទកល្យាណីសាកិយៈ មានសក់មូរបានពាក់កណ្តាល បានផ្តាំពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រអយ្យ-បុត្រ សូមអយ្យបុត្រប្រញាប់យាងមក បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនោះឯងរឭក ដល់ពាក្យនោះ ទើបមិនត្រេកអរក្នុងការប្រព្រឹត្តព្រហ្មចរិយៈ មិនអាចបន្ត ព្រហ្មចរិយៈទៅបាន នឹងពោលលាសិក្ខា សឹកទៅ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ចាប់ព្រះនន្ទត្រង់ដើមដៃហើយ នាំទៅកាន់តាវត្តិង្សទេវលោកដោយកម្លាំងឫទ្ធិ ក្នុងរវាងផ្លូវ ទ្រង់បង្ហាញស្វាញីមួយដែលមានត្រចៀក ច្រមុះ កន្ទុយដាច់អស់ អង្គុយត្របោមក្បាលជន្ទន់លើជន្តត់ឈើ ដែលភ្លើងឆេះ ត្រង់ស្រែដែលភ្លើងឆេះមួយកន្លែង ហើយទ្រង់បង្ហាញស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ដែលមកកាន់ទីបម្រើរបស់សក្កទេវរាជ ក្នុងតាវត្តិង្សពិភព ។

កាលទ្រង់បង្ហាញហើយ ត្រាស់យ៉ាងនេះថា ម្នាលនន្ទ អ្នកសម្គាល់សេចក្តីនេះដូចម្តេច ចំណែកមួយណាមានរូបស្អាតជាង គួរមើលជាង គួរជ្រះថ្លាជាង នាងជនបទកល្យាណីសាកិយៈ ឬស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាបនេះ ។ នន្ទបានស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្វាញីមានត្រចៀក ច្រមុះ និងកន្ទុយកំបុតនោះយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន នាងជនបទកល្យាណីសាកិយៈក៏ដូចគ្នាដូច្នោះ

ព្រោះការប្រៀបធៀបគ្នា នាងរមែងមិនដល់នូវការរាប់ខ្លះ មិនដល់នូវមួយចម្រៀកខ្លះ មិនដល់ចំណែកមួយខ្លះនៃស្រីទេពអប្សរ ៥០០ នេះដោយពិត ស្រីទេពអប្សរ ៥០០ នេះឯងមានរូបស្អាតជាង គួរមើលជាង និងគួរជ្រះថ្លាជាង ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនន្ទ ចូរអ្នកត្រេកអរ ម្នាលនន្ទ ចូរអ្នកត្រេកអរ តថាគតនឹងជាទីជានារបស់អ្នក ដើម្បីបានចំពោះស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ព្រះនន្ទទូលថា បពិត្រព្រះអង្គ បើទ្រង់ជានាដល់ខ្ញុំព្រះអង្គដើម្បីបានចំពោះនូវទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាបសោត បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងត្រេកអរក្នុងព្រហ្មចរិយៈ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់នាំនន្ទទៅបាត់អំពីទីនោះ ទៅប្រាកដក្នុងវត្តជេតពនវិញ ។

ភិក្ខុទាំងឡាយបានស្តាប់ហើយថា ព្រះនន្ទជាព្រះភាតារបស់ព្រះដ៏មានព្រះភាគ ឱរសរបស់ព្រះមាតុច្ឆា ប្រព្រឹត្តព្រហ្មចរិយៈ ព្រោះស្រីទេពអប្សរទាំងឡាយ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់ជាអ្នកជានារបស់ព្រះនន្ទនោះ ដើម្បីបានចំពោះស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ។

គ្រានោះឯង ពួកភិក្ខុដែលជាសម្លាញ់របស់ព្រះនន្ទ ហៅព្រះនន្ទដោយវាទៈថា ជាអ្នកស៊ីឈ្នួលខ្លះ ដោយវាទៈថា ជាបុគ្គលដែលព្រះដ៏មានព្រះភាគទ្រង់ជានាខ្លះថា បានឮថា ព្រះនន្ទជាកូនឈ្នួល បានឮថា ព្រះនន្ទ ព្រះសាស្តាទ្រង់ជានា ព្រះនន្ទប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុនៃស្រីទេពអប្សរ ៥០០

បានឮថា ព្រះដ៏មានព្រះភាគទ្រង់ជាបុគ្គលធានារបស់លោក ដើម្បីបានចំពោះនូវស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ។

គ្រានោះឯង ព្រះនន្ទមានការខ្មាសអៀន រង្កៀសដោយវាទៈថា ជាអ្នកស៊ីឈ្នួលខ្លះ ជាអ្នកដែលព្រះសាស្តាកក់ឲ្យខ្លះ របស់ពួកភិក្ខុទាំងឡាយ ជាបុគ្គលម្នាក់ឯងចៀសចេញទៅហើយ ជាអ្នកមិនប្រមាទ មានព្យាយាម មានខ្លួនបញ្ជូនទៅ ។ ចំណេរកាលមិនយូរឡើយ បានធ្វើឲ្យជាក់ច្បាស់នូវទីបំផុតនៃអគ្គព្រហ្មចរិយៈ ដែលកុលបុត្រអ្នកចេញចាកផ្ទះទាំងឡាយ បួសមិនមានផ្ទះដោយប្រពៃ ត្រូវការដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅចប់ហើយ កិច្ចដែលគួរធ្វើ អាត្មាអញធ្វើស្រេចហើយ កិច្ចដទៃដើម្បីភាពយ៉ាងនេះមិនមាន ។ ឈ្មោះថា ព្រះនន្ទបានជាព្រះអរហន្តមួយអង្គ ក្នុងបណ្តាព្រះអរហន្តទាំងឡាយ ។

គ្រានោះ ទេវតាមួយអង្គញុំាងវត្តជេតពនទាំងមូលឲ្យភ្លឺស្វាង ក្នុងចំណែកនៃរាត្រីហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គ ព្រះនន្ទជាព្រះភាតារបស់ព្រះអង្គ ជាឱរសរបស់ម្តាយមីង ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ជាអ្នកមិនមានអាសវៈព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងនេះឯង សម្រេចហើយក្នុងទិដ្ឋធម៌ ។ ញាណបានកើតឡើងដល់ព្រះដ៏មានព្រះភាគដូចគ្នាថា នន្ទធ្វើឲ្យជាក់ច្បាស់នូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ ព្រះនន្ទនោះ ដោយ

កន្លងទៅនៃរាត្រីនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ជាអ្នកធានារបស់ខ្ញុំព្រះអង្គ ដើម្បីបានចំពោះនូវស្រីទេពអប្សរ ៥០០ ដែលមានជើងដូចជើងព្រាប ដោយការធានាណា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គដោះព្រះដ៏មានព្រះភាគអំពីការធានានោះ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនន្ទ សូម្បីតថាគតក៏កំណត់ចិត្តអ្នកដោយចិត្តរបស់តថាគត ដឹងហើយថា នន្ទធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ សូម្បីទេវតាក៏ប្រាប់សេចក្តីនេះដល់តថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនន្ទធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយការដឹងក្រៃលែងឯង សម្រេចហើយក្នុងទិដ្ឋធម៌ ។ ម្នាលនន្ទ កាលណាចិត្តរបស់អ្នក ផុតហើយចាកអាសវៈទាំង-ឡាយ ព្រោះមានការមិនប្រកាន់មាំ កាលនោះ តថាគតក៏ផុតចាកការធានានោះ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់ជ្រាបសេចក្តីនេះហើយ ទ្រង់បន្លឺឧទាននេះក្នុងពេលនោះថា

ភិក្ខុណា បានឆ្លងភក់ គឺកាម បានញាំញីបន្លា គឺកាម
ភិក្ខុនោះ បានដល់នូវការអស់មោហៈ រមែងមិនញាប់ញ័រ
ព្រោះសុខ និងទុក្ខឡើយ ។

សម័យថ្ងៃមួយ ភិក្ខុទាំងឡាយសួរព្រះនន្ទថា អាវុសោនន្ទ កាលមុន

លោកម្ចាស់ពោលថា ខ្ញុំអផ្សុកហើយ ឥឡូវនេះ ចិត្តរបស់លោកម្ចាស់ដូចម្តេច ព្រះនន្ទឆ្លើយថា អាវុសោ ការជាប់ជំពាក់ក្នុងភាពជាគ្រហស្ថរបស់ខ្ញុំមិនមាន ។ ពួកភិក្ខុបានស្តាប់ពាក្យនោះហើយ ពោលថា លោកម្ចាស់នន្ទពោលមិនពិត រមែងព្យាករអរហត្តផលក្នុងថ្ងៃដែលកន្លងមកហើយថា ខ្ញុំជាអ្នកអផ្សុកហើយ តែឥឡូវនេះពោលថា ការជាប់ជំពាក់ក្នុងភាពជាគ្រហស្ថរបស់ខ្ញុំមិនមាន ដូច្នេះហើយ ក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃមុនអត្តភាពរបស់នន្ទដូចគ្នានឹងផ្ទះដែលគេប្រក់មិនល្អ តែឥឡូវនេះដូចផ្ទះដែលគេប្រក់ល្អហើយ ព្រោះថា នន្ទនេះតាំងអំពីកាលដែលខ្លួនឃើញស្រីទេពអប្សរហើយ ព្យាយាមដើម្បីសម្រេចទីបំផុតនៃកិច្ចរបស់បព្វជិត បានសម្រេចកិច្ចនោះហើយ ទ្រង់បានភាសិតព្រះគាថានេះថា

**យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ**
**ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។**
**យថា អគារំ សុឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ**
**ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។**

ផ្ទះដែលប្រក់ខ្ជីខ្ជាហើយ តំណក់ទឹកភ្លៀងរមែងលិចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលមិនបានអប់រំទុកហើយ រាគៈរមែងចាក់ដោតយ៉ាងនោះឯង ។ ផ្ទះដែលប្រក់ល្អហើយ តំណក់ទឹកភ្លៀងមិនលិចរហូត យ៉ាងណាមិញ ចិត្តដែលបុគ្គលបានអប់រំទុកល្អហើយ រាគៈរមែងមិនចាក់ដោតបាន យ៉ាងនោះឯង ។

បណ្ដាបទទាំងនោះ បទថា **អគារំ** គឺនូវផ្ទះប្រភេទណាមួយ ។

បទថា **ទុច្ឆន្នំ** គឺដែលប្រក់រង្វើលៗ មានប្រហោងតូចប្រហោងធំ ។

បទថា **សមតិវិជ្ឈតិ** គឺគ្រាប់ភ្លៀងរមែងលិចស្រោចបាន ។

បទថា **អភាវិតំ** ជាដើម សេចក្ដីថា រាគៈរមែងចាក់ដោតចិត្ត ដែលឈ្មោះថា មិនបានអប់រំ ព្រោះជាធម្មជាតឆ្ងាយអំពីភាវនា ប្រៀបដូចភ្លៀងលិចស្រោចផ្ទះនោះបាន ដូច្នោះ មិនមែនតែរាគៈតែម្យ៉ាងប៉ុណ្ណោះទេ កិលេសទាំងពួង មានទោសៈ មោហៈ និងមានះជាដើម ក៏ចាក់ទម្លុះចិត្តបែបនោះដូចគ្នា ។

បទថា **សុភាវិតំ** បានដល់ ដែលអប់រំល្អហើយ ដោយសមថភាវនា និងវិបស្សនាភាវនា កិលេសទាំងឡាយ មានរាគៈជាដើម រមែងមិនអាចចាក់ដោតចិត្តបែបនោះបាន ដូចភ្លៀងមិនអាចលិចស្រោចផ្ទះដែលប្រក់ល្អហើយបាន ដូច្នោះ ។

ក្នុងកាលចប់គាថា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ទេសនាបានសម្រេចប្រយោជន៍ដល់មហាជនហើយ ។

សម័យតមក ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ ឈ្មោះថា ព្រះពុទ្ធទាំងឡាយជាអច្ឆរិយបុគ្គល ។ ព្រះនន្ទ ឈ្មោះថា អាស្រ័យនាងជនបទកល្យាណីអផ្សុកហើយ ព្រះសាស្ដាទ្រង់ធ្វើពួកនាងទេពអប្សរ ឲ្យជាអាមិសដឹកនាំបានហើយ ។ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំង

នោះក្រាបទូលថា ដោយកថាឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុន ននូនេះ តថាគតបានបញ្ឆោតដោយមាតុគ្រាមទូន្មានហើយដូចគ្នា ដូច្នេះហើយ កាលភិក្ខុនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងក្រុងពារាណសី មានឈ្មួញអ្នកក្រុងពារាណសីម្នាក់ឈ្មោះកប្បកៈ ។ លារបស់ឈ្មួញនាំភារៈបានមួយកុម្ភៈ លានោះដើរទៅបានមួយថ្ងៃ ៧ យោជន៍ ។ គ្រាមួយ ឈ្មួញនោះទៅកាន់នគរតក្កសិលា នាំភារៈទៅដោយលា លែងលាឲ្យត្រាច់ទៅទម្រាំលក់ទ្រព្យរបស់អស់ ។ គ្រានោះ លារបស់ឈ្មួញនោះត្រាច់ទៅលើខ្នងប្រឡាយ ជួបលាញីមួយ ទើបចូលទៅរក លាញីកាលធ្វើបដិសណ្ឋារៈជាមួយលាឈ្មោលនោះ ទើបពោលថា អ្នកមកអំពីណា លាឈ្មោលឆ្លើយថា ខ្ញុំមកពីនគរពារាណសី លាញីពោលថា អ្នកមកដោយកម្មអ្វី លាឈ្មោលឆ្លើយថា ដោយកម្មរបស់ឈ្មួញ លាញីពោលថា អ្នកនាំភារៈទៅបានប៉ុន្មាន លាឈ្មោលឆ្លើយថា ប្រមាណមួយកុម្ភៈ លាញីពោលថា កាលនាំភារៈប្រមាណប៉ុណ្ណោះទៅក្នុងទីប៉ុន្មានយោជន៍ លាឈ្មោលឆ្លើយថា បាន ៧ យោជន៍ លាញីពោលថា ក្នុងទីដែលអ្នកទៅហើយ លាញីណាមួយធ្វើការគក់ប្រេបាច់ជើងឬបម្រើអ្នក មានដែរឬ លាឈ្មោលឆ្លើយថា មិនមានឡើយ លាញីពោលថា បើដូច្នោះ អ្នកប្រហែលជាបានទទួលសេចក្តីទុក្ខច្រើន ។

ពិតហើយ ឈ្មោះថា កម្មមានការគក់ជើងជាដើម សម្រាប់សត្វតិរច្ឆាន

ទាំងឡាយ រមែងមិនមានដោយពិត តែលាញីពោលពាក្យបែបនោះ ដើម្បីអាស្រ័យដល់កាមសំយោជនៈ ។ លានោះ អផ្សុកដោយពាក្យរបស់លាញីនោះហើយ ។

ចំណែកកប្បកពាណិជ្ជលក់កណ្ឌៈអស់ហើយ ទៅកាន់ទីដែលលាស្នាក់នៅ ពោលថា នែបា អ្នកចូរមកចុះ យើងនឹងទៅ លាឈ្មោលនោះឆ្លើយថា ចូរលោកទៅចុះ ខ្ញុំមិនទាន់ទៅឡើយ លំដាប់នោះ នាយកប្បកៈអង្វរលានោះហើយអង្វរទៀត គិតថា អញនឹងញ៉ាំងលានោះ ដែលមិនប្រាថ្នាទៅឲ្យខ្លាចហើយ នឹងនាំទៅ ដូច្នេះហើយ ពោលនូវគាថានេះថា

ខ្ញុំនឹងធ្វើជន្លួញមានមុខស្រួច ប្រវែង ១៦ ធ្នាប់ដល់អ្នក ហើយចាក់ទម្លុះកាយរបស់អ្នក នែលា ឯងចូរដឹងយ៉ាងនេះ លាបានស្តាប់ពាក្យនោះហើយឆ្លើយថា កាលបើដូច្នោះ ខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើដល់អ្នកដែរ ដូច្នេះហើយពោលគាថានេះថា

> បើអ្នកធ្វើជន្លួញមានមុខស្រួចប្រវែង ១៦ ធ្នាប់ដល់ខ្ញុំ ខ្ញុំនឹង
> សង្កត់ខាងមុខ លើកខាងក្រោយឡើងហើយ ធ្វើកណ្ឌៈរបស់អ្នក
> ឲ្យធ្លាក់ទៅ នែកប្បកៈ អ្នកចូរដឹងយ៉ាងនេះ ។

ឈ្មួញបានស្តាប់ពាក្យនោះ ទើបត្រិះរិះថា ដោយហេតុអ្វីហ្ន៎ ទើបលានេះពោលយ៉ាងនេះដាក់អញ ដូច្នេះហើយ កាលក្រឡេកមើលឆ្វេង-ស្តាំ ឃើញលាញីនោះហើយ គិតថា លានេះ គង់ត្រូវលាញីនេះឲ្យសិក្សាហើយយ៉ាងនេះ អញត្រូវបញ្ឆោតលានេះ ដោយមាតុគ្រាមថា ខ្ញុំនឹងនាំលាមានរូប

យ៉ាងនេះមកឲ្យអ្នក ហើយនឹងនាំទៅ ដូច្នេះហើយ ទើបពោលគាថានេះថា

ខ្ញុំនឹងនាំលាក្រមុំមានជើងបួន មានមុខដូចស័ង្ខ មានកាយសព្វអន្ទើស្អាត មកជាភរិយាអ្នក នែលា អ្នកចូរដឹងយ៉ាងនេះ ។ លាបានស្តាប់ពាក្យនោះមានចិត្តត្រេកអរ ពោលគាថានេះថា

> អ្នកនឹងនាំលាញីក្រមុំមានជើងបួន មានមុខដូចស័ង្ខ មានសរីរៈ
> ស្អាត មកជាប្រពន្ធរបស់ខ្ញុំ នែកប្បកៈ អ្នកចូរដឹងយ៉ាងនេះ
> ខ្ញុំនឹងទៅឲ្យរហ័ស រហូត ១៤ យោជន៍ ។

ពេលនោះ ទើបនាយកប្បកៈពោលនឹងលានោះថា បើដូច្នោះ អ្នកចូរមកចុះ ដូច្នេះហើយ បានដឹកទៅកាន់ទីរបស់ខ្លួន ។ លានោះ ដោយកាលកន្លងទៅ ២-៣ ថ្ងៃទើបពោលនឹងនាយកប្បកៈថា អ្នកបានពោលនឹងខ្ញុំថា នឹងនាំភរិយាមកឲ្យខ្ញុំ ដូច្នេះ មិនមែនឬ នាយកប្បកៈឆ្លើយថា អើ ខ្ញុំពោលហើយ ខ្ញុំនឹងមិនទម្លាយពាក្យរបស់ខ្លួន នឹងនាំភរិយាមកឲ្យអ្នក តែខ្ញុំឲ្យអាហារដល់អ្នកមួយចំណែក អាហារនោះចូរគ្រប់គ្រាន់ដល់អ្នក ដែលមានខ្លួនជាគម្រប់ពីរ ឬមិនគ្រប់គ្រាន់ក្តី អ្នកគប្បីដឹងខ្លួនឯងចុះ សូម្បីកូនទាំងឡាយអាស្រ័យសង្វាសរបស់អ្នកទាំងពីរក៏នឹងកើតឡើង អាហារនោះ ចូរគ្រប់គ្រាន់ដល់អ្នក និងកូនជាច្រើននោះ ឬមិនគ្រប់ក្តី អ្នកគប្បីដឹងឯងចុះ ។ លាកាលនាយកប្បកៈនោះ ពោលយ៉ាងនោះ បានជាអ្នកអស់សេចក្តីប្រាថ្នាហើយ ។

ព្រះសាស្តា កាលនាំព្រះធម្មទេសនានេះមកហើយ ទ្រង់ញ៉ាំងជាតកឲ្យចប់ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាញីក្នុងកាលនោះ បានជា

នាងជនបទកល្យាណី លាឈ្មោលបានជានន្ទ ចំណែកឈ្មួញ បានជាតថាគត នេះឯង ។ ក្នុងកាលមុន នន្ទនេះ តថាគតក៏បានបញ្ឆោតដោយមាតុគ្រាមទូន្មាន ហើយ ដោយប្រការយ៉ាងនេះ ៕

**រឿង ព្រះនន្ទត្ថេរ ចប់**

# រឿង នាយចុន្ទសូករិកៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរស ឈ្មោះចុន្ទ-សូករិកៈ ត្រាស់ធម្មទេសនានេះថា **ឥធ សោចតិ បេច្ច សោចតិ** ជាដើម ។

បានឮថា នាយចុន្ទសូករិកៈនោះ សម្លាប់ជ្រូកទាំងឡាយបរិភោគខ្លះ លក់ដូរខ្លះ ចិញ្ចឹមជីវិតអស់ ៥៥ ឆ្នាំ ។ ក្នុងពេលស្រូវថ្លៃ គាត់យករទេះដឹកស្រូវទៅកាន់ជនបទ ដូរកូនជ្រូកស្រុកដោយស្រូវប្រមាណមួយនាឡិ ឬពីរនាឡិ ដាក់ពេញរទេះហើយត្រឡប់មក ព័ទ្ធទីមួយកន្លែងដូចក្រោល ខាងក្រោយលំនៅហើយដាំបន្លែក្នុងទីនោះឯង ដើម្បីកូនជ្រូកទាំងនោះ ។ កាលកូនជ្រូកទាំងនោះស៊ីបន្លែផ្សេងៗ ខ្លះ សរីរវលជ្ជៈ គឺលាមកខ្លះ ក៏ធំចម្រើនឡើង ។ គាត់ប្រាថ្នាសម្លាប់ជ្រូកណាក៏ចងជ្រូកនោះឲ្យណែន ក្នុងទីដែលសម្លាប់ ហើយវាយដោយដំបងបួនជ្រុង ដើម្បីឲ្យសាច់ជ្រូកប៉ោងធំឡើង ដឹងថា សាច់ប៉ោងក្រាស់ហើយ ក៏ខ្ទាស់មាត់ដោយឈើទៅក្នុងចន្លោះធ្មេញ ប្រកទឹកក្តៅដែលក្តៅខ្លាំង ចូលទៅ

ក្នុងមាត់ដោយនាឡិលោហៈ ។ ទឹកក្តៅនោះចូលទៅក្នុងពោះ ក៏ហូរចេញមកដោយចំណែកខាងក្រោម គឺតាមទ្វារធំ ករីសៈតូចមួយ នៅមានដរាបណា រមែងជាទឹកល្អក់ដរាបនោះ កាលពោះស្អាតហើយ ទើបចេញទឹកថ្លាមិនល្អក់ ពេលនោះ ទើបគាត់ស្រោចទឹកក្តៅដែលសល់លើស្បែកជ្រូកនោះ ទឹកនោះក៏បកយកស្បែកខ្មៅចេញទៅ បន្ទាប់អំពីនោះ ទើបរោលរោមដោយគប់ស្មៅ ហើយកាត់ក្បាលដោយដាវដ៏មុត ត្រងឈាមដែលហូរចេញដោយភាជន៍ លាបសាច់ដោយឈាមហើយ អាំងអង្គុយបរិភោគក្នុងកណ្តាលបុត្រ និងភរិយា លក់ចំណែកដែលសល់ ។ គាត់ចិញ្ចឹមជីវិតដោយទំនងនេះឯង អស់កាលកន្លងទៅ ៥៥ ឆ្នាំ ។ កាលព្រះតថាគតប្រថាប់នៅក្នុងធុរវិហារ ការបូជាដោយផ្កាត្រឹមតែមួយក្តាប់ក្តី ការថ្វាយភិក្ខាត្រឹមតែមួយវែកក្តី ឈ្មោះថា បុណ្យដទៃតិចតួចក្តី មិនមានហើយ ត្រឹមមួយថ្ងៃ ។

គ្រានោះ រោគកើតឡើងក្នុងសរីរៈរបស់គាត់ ការក្តៅក្រហាយអំពីអវីចីមហានរកប្រាកដដល់គាត់ទាំងរស់នោះឯង ។

ឈ្មោះថា កម្តៅក្នុងអវីចី រមែងជាកម្តៅដែលអាចទម្លាយភ្នែករបស់បុគ្គលដែលឈរមើលក្នុងទីប្រមាណ ១០០ យោជន៍បាន សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ដូច្នេះថា មានភ្លើងឆេះប្រាលរន្ទាល ផ្សាយទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វៗ កាល ។

ព្រោះហេតុដែលកម្តៅក្នុងអវីចីនោះ មានប្រមាណក្រៃលែងជាងកម្តៅរបស់ភ្លើងដោយប្រក្រតី ទើបព្រះនាគសេនត្ថេរពោលឧបមានេះថា បពិត្រ

មហារាជ ដុំថ្មប្រមាណប៉ុនផ្ទះកំពូលដែលបុគ្គលទម្លាក់ទៅក្នុងភ្លើងនរក រមែងដល់នូវការរលាយបាន ដោយខណៈមួយ យ៉ាងណា ចំណែកសត្វដែលកើតក្នុងនរកនោះ ប្រៀបដូចនៅក្នុងគភ៌មាតា នឹងរលួយទៅ ព្រោះកម្លាំងនៃកម្មដូច្នោះ ក៏មិនមែន ។

កាលការក្តៅក្រហាយនោះ ប្រាកដដល់នាយចុន្ទសូករិកៈនោះហើយ អាការដែលសមគួរដល់កម្មក៏កើតឡើង គាត់ស្រែកសំឡេងដូចជ្រូក វារជើង ៤ ទៅក្នុងផ្ទះនោះឯង ទៅកាន់ទិសខាងកើតខ្លះ ទៅកាន់ទិសខាងលិចខ្លះ ។

លំដាប់នោះ ពួកមនុស្សក្នុងផ្ទះចាប់គាត់ ហើយបិទមាត់ ធម្មតាផលនៃកម្ម បុគ្គលណាម្នាក់មិនអាចនឹងហាមបាន គាត់នៅត្រាច់ស្រែកទៅខាងនោះខ្លះ ខាងនេះខ្លះ មនុស្សក្នុងផ្ទះ ៧ ខ្នងដោយជុំវិញ មិនបានដេកលក់ ម្យ៉ាងទៀត មនុស្សក្នុងផ្ទះទាំងអស់ កាលមិនអាចហាមការចេញទៅខាងក្រៅរបស់គាត់ ដែលត្រូវមរណភ័យគំរាមហើយបាន ទើបបិទទ្វារផ្ទះ រក្សានៅក្នុងផ្ទះដោយប្រការដែលគាត់នៅខាងក្នុង មិនអាចត្រាច់ទៅខាងក្រៅបាន ។

នាយចុន្ទសូករិកៈ ត្រាច់ស្រែកទៅខាងនោះខ្លះ ខាងនេះខ្លះ ខាងក្នុងផ្ទះនោះឯង ដោយកម្តៅក្នុងនរក គាត់ត្រាច់ទៅយ៉ាងនោះអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ធ្វើកាលកិរិយាហើយ ទៅកើតក្នុងអវីចិមហានរក ។ អវីចិមហានរក អ្នកប្រាជ្ញ គប្បីពណ៌នាតាមទេវទូតសូត្រ ។

ភិក្ខុនិមន្តទៅតាមទ្វារផ្ទះរបស់គាត់ បានឮសំឡេងនោះហើយ ជាអ្នកមានសេចក្តីសម្គាល់ថាសំឡេងជ្រូក ទៅកាន់វិហារ អង្គុយក្នុងសម្នាក់ព្រះសាស្តា

ហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលសូករៈទាំងឡាយ ដែលនាយចុន្ទសូករិកៈបិទទ្វារផ្ទះសម្លាប់ ថ្ងៃនេះជាថ្ងៃទី ៧ មង្គលកិរិយាណា មួយប្រហែលនឹងមានក្នុងផ្ទះរបស់គាត់ ។ បពិត្រព្រះអង្គដ៏ចម្រើន មេត្តាចិត្ត ឬសេចក្ដីករុណាណាមួយរបស់គាត់ ដែលសម្លាប់ជ្រូកទាំងឡាយមានប្រមាណ ប៉ុណ្ណេះ រមែងមិនមាន សត្វដែលកាចសាហាវបែបនេះ ខ្ញុំព្រះអង្គទាំងឡាយ មិនធ្លាប់ឃើញឡើយ ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គាត់មិនមែនសម្លាប់ជ្រូកអស់ ៧ ថ្ងៃនេះឡើយ ផលដែលសមគួរដោយកម្មកើតឡើងហើយដល់បុគ្គលនោះ ការក្ដៅក្រហាយក្នុងអវិចីមហានរក ប្រាកដដល់គាត់ទាំងរស់នោះឯង ដោយ ការក្ដៅក្រហាយនោះ គាត់ស្រែកដូចជ្រូក ត្រាច់ទៅខាងក្នុងនិវេសន៍អស់ ៧ ថ្ងៃ ថ្ងៃនេះធ្វើកាលកិរិយាទៅកើតក្នុងអវិចី ។ កាលភិក្ខុក្រាបទូលថា បពិត្រ ព្រះអង្គ កាលគាត់សោយសោកយ៉ាងនេះ ក្នុងលោកនេះហើយ នឹងទៅកើត ក្នុងឋានៈដែលជាទីសោយសោកដូច្នេះទៀតឬ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ យ៉ាងនោះឯង ឈ្មោះថា បុគ្គលប្រមាទហើយ ជាគ្រហស្ថក្ដី បព្វជិតក្ដី រមែងសោយសោកក្នុងលោកទាំងពីរពិត ដូច្នេះហើយ ត្រាស់ព្រះ គាថានេះថា

**ឥធ សោចតិ បេច្ច សោចតិ ។ បាបការី ឧភយត្ថ សោចតិ**
**សោ សោចតិ សោ វិហញ្ញតិ ។ ទិស្វា កម្មកិលិដ្ឋមត្តនោ ។**

បុគ្គលអ្នកធ្វើបាប តែងសោកស្ដាយក្នុងលោកទាំងពីរ គឺសោក

ស្តាយក្នុងលោកនេះ ១ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែង
សោកស្តាយក្តៅក្រហាយ ព្រោះឃើញអំពើសៅហ្មងរបស់ខ្លួន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បាបការី** ជាដើម សេចក្តីថា បុគ្គលធ្វើបាប មានប្រការផ្សេងៗ រមែងសោកស្តាយក្នុងលោកនេះ ក្នុងសម័យជិតស្លាប់ ដោយចំណែកមួយពិត ដោយគិតថា កម្មល្អអញមិនបានធ្វើហ្ន៎ កម្មអាក្រក់ អញបានធ្វើហើយ នេះជាការសោកស្តាយព្រោះកម្មរបស់បុគ្គលនោះ កាល បុគ្គលនោះសោយផល ស្លាប់ទៅហើយ រមែងសោកស្តាយ នេះជាការសោក ស្តាយ ព្រោះវិបាកក្នុងលោកខាងមុខរបស់បុគ្គលនោះ បុគ្គលនោះ រមែង សោកស្តាយ ក្នុងលោកទាំងពីរយ៉ាងនេះឯង ដោយហេតុនោះឯង នាយចុន្ទ-សូករិកៈនោះ ឈ្មោះថា សោកស្តាយទាំងរស់នោះឯង ។

បាទព្រះគាថាថា **ទិស្វា កម្មកិលិដ្ឋមត្តនោ** សេចក្តីថា បុគ្គលនោះ ឃើញកម្មសៅហ្មងរបស់ខ្លួនហើយ តែងសោកស្តាយ រវើរវាយមានប្រការ ផ្សេងៗ ឈ្មោះថា រមែងក្តៅក្រហាយ គឺរមែងលំបាក ។

ក្នុងកាលចប់ទេសនា ភិក្ខុដ៏ច្រើន បានជាព្រះសោតាបន្នជាដើម ហើយ ទេសនាមានប្រយោជន៍ ដល់មហាជនហើយ ដូច្នេះឯង ។៚

**រឿង នាយចុន្ទសូករិកៈ ចប់**

# រឿង ធម្មិកឧបាសក

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធធម្មិកឧបាសក ត្រាស់ធម្មទេសនានេះថា **ឥធ មោទតិ បេច្ច មោទតិ** ជាដើម ។

បានឮថា ក្នុងនគរសាវត្ថី មានឧបាសកអ្នកបដិបត្តិធម៌ប្រមាណ ៥០០ នាក់ បណ្តាឧបាសកទាំងនោះ ម្នាក់ៗ មានឧបាសក ៥០០ ជាបរិវារ ។ ឧបាសក ដែលជាប្រធាននៃឧបាសកទាំងនោះ មានកូនប្រុស ៧ នាក់ កូនស្រី ៧ នាក់ ។ បណ្តាកូនប្រុស និងកូនស្រីទាំងនោះ ម្នាក់ៗ មានសលាកយាគូ សលាកភត្ត បក្ខិកភត្ត សង្ឃភត្ត ឧបោសថិកភត្ត អាគន្តុកភត្ត វស្សាវាសិក-ភត្ត មួយមុខមួយសម្រាប់ ។ ជនទាំងនោះ បានជាបុគ្គលឈ្មោះថា អនុ-ជាតបុត្រទាំងអស់នោះឯង សលាកយាគូជាដើមមួយសម្រាប់ គឺរបស់កូន ១៤ នាក់ របស់ភរិយាមួយ របស់ឧបាសកមួយ រមែងប្រព្រឹត្តទៅ ដោយប្រការដូច្នេះ ។ គាត់ មួយអន្លើដោយបុត្រ និងភរិយា បានជាអ្នកមានសីល មានកល្យាណធម៌ មានការត្រេកអរក្នុងការឲ្យទាន ដោយប្រការដូច្នេះ ។ចំណេរកាលតមក រោគកើតឡើងដល់ឧបាសក អាយុសង្ខារអស់ទៅ ដោយជុំវិញហើយ ។

គាត់ប្រាថ្នានឹងស្តាប់ធម៌ ទើបបញ្ជូនមនុស្សទៅកាន់សម្នាក់ព្រះសាស្តា ដោយក្រាបទូលថា សូមទ្រង់បញ្ជូនភិក្ខុ ៨ រូប ឬ ១៦ រូប ដល់ខ្ញុំព្រះអង្គ ។

ព្រះសាស្តាទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ភិក្ខុទាំងនោះទៅហើយ អង្គុយ

លើអាសនៈ ដែលគេតាក់តែងជុំវិញគ្រែរបស់គាត់ កាលគាត់ពោលថា បពិត្រលោកម្ចាស់ ការឃើញលោកម្ចាស់ទាំងឡាយ របស់ខ្ញុំបានដោយលំបាក ខ្ញុំជាបុគ្គលទុព្វលភាព សូមលោកម្ចាស់ទាំងឡាយ ស្វាធ្យាយព្រះសូត្រមួយប្រោសខ្ញុំចុះ ។

ទើបភិក្ខុទាំងឡាយសួរថា អ្នកបំណងនឹងស្តាប់សូត្រណា កាលគាត់ប្រាប់ថា សតិប្បដ្ឋានសូត្រដែលព្រះពុទ្ធគ្រប់អង្គទ្រង់មិនលះបង់ ។ ទើបផ្តើមសូធ្យព្រះសូត្រថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា** ជាដើម ។

ខណៈនោះ រថ ៦ គ្រឿង ប្រដាប់ដោយអលង្ការគ្រប់យ៉ាង ទឹមដោយសេះសិន្ធពមួយពាន់ ទំហំប្រមាណ ១៥០ យោជន៍ មកអំពីទេវលោក ៦ ជាន់ ។ ទេវតាឈរនៅលើរថទាំងនោះ អញ្ជើញថា ខ្ញុំនឹងនាំទៅកាន់ទេវលោករបស់ខ្ញុំ ខ្ញុំនឹងនាំទៅកាន់ទេវលោករបស់ខ្ញុំ អ្នកដ៏ចម្រើន ចូរកើតក្នុងទីនេះ ដើម្បីការត្រេកអរក្នុងទេវលោករបស់ខ្ញុំ ដូចបុគ្គលទម្លាយនូវភាជន៍ដី ហើយកាន់យកភាជន៍មាស ។

ឧបាសកមិនប្រាថ្នាឲ្យអន្តរាយដល់ការស្តាប់ធម៌ ទើបពោលថា អ្នកទាំងឡាយ ចូរបង្អង់សិន អ្នកទាំងឡាយ ចូរបង្អង់សិន ។

ភិក្ខុឈប់ស្ងៀមព្រោះយល់ថា ឧបាសកនិយាយជាមួយពួកលោក គ្រានោះ កូនប្រុស និងកូនស្រីរបស់គាត់គិតថា ឪពុករបស់ពួកយើង ក្នុងកាលមុន ជាអ្នកមិនឆ្អែតដោយការស្តាប់ធម៌ តែឥឡូវនេះ ឲ្យនិមន្តភិក្ខុមកធ្វើការ

ស្វាធ្យាយហើយ ហាមឃាត់ដោយខ្លួនឯង ឈ្មោះថា សត្វដែលមិនខ្លាច ចំពោះមរណៈ មិនមានឡើយ ដូច្នេះហើយ ទើបទ្រហោយំ ពួកភិក្ខុប្រឹក្សាគ្នាថា ឥឡូវនេះ មិនជាឱកាសហើយ ទើបក្រោកចាកអាសនៈចៀសចេញទៅ ឧបាសកញុំាងកាលបន្តិចឲ្យកន្លងទៅហើយ ក៏បាននូវស្មារតី សួរកូនទាំង-ឡាយថា ព្រោះហេតុអ្វី ទើបពួកអ្នកយំសោក ទើបពួកកូនប្រាប់ថា ពុកឲ្យនិមន្តភិក្ខុមកហើយស្តាប់ធម៌ បែរជាហាមឃាត់ដោយខ្លួនឯង កាលបើដូច្នោះ ទើបពួកខ្ញុំគិតថា ឈ្មោះថា សត្វមិនខ្លាចចំពោះមរណៈមិនមាន ដូច្នេះ ទើបយំសោក ។ ឧបាសកសួរថា ចុះលោកម្ចាស់ទាំងឡាយនិមន្តទៅឯណា កូនទាំងឡាយឆ្លើយថា បពិត្រលោកឪពុក ពួកលោកម្ចាស់ទាំងឡាយនិយាយគ្នាថា មិនជាឱកាស ក្រោកចាកអាសនៈ ចៀសចេញទៅហើយ ។ ឧបាសកពោលថា ឪពុកមិនបានពោលជាមួយលោកម្ចាស់ទាំងឡាយឡើយ កូនសួរថា បើដូច្នោះ លោកឪពុកនិយាយជាមួយអ្នកណា ។ ឧបាសកពោលថា ទេវតាតាក់តែងរថ ៦ គ្រឿង នាំមកអំពីទេវលោក ៦ ជាន់ ឈប់នៅក្នុងអាកាសបន្លឺសំឡេងថា ចូរអ្នកត្រេកអរក្នុងទេវលោករបស់ខ្ញុំ ចូរអ្នកត្រេកអរក្នុងទេវលោករបស់ខ្ញុំ ឪពុកនិយាយជាមួយទេវតាទាំងនោះទេតើ ។ កូនពោលថា បពិត្រលោកឪពុក តើរថនៅឯណា ពួកខ្ញុំមើលមិនឃើញឡើយ ឧបាសកពោលថា តើកម្រងផ្កាដែលដោតជាកម្រងដើម្បីពុក មានដែរឬទេ កូនពោលថា មាន ឧបាសកពោលថា ទេវលោកជាន់ណាគួរ ជាទីត្រេកអរ កូនពោលថា តុសិតពិភព ជាទីប្រថាប់នៅរបស់ព្រះពោធិសត្វគ្រប់អង្គ របស់ព្រះពុទ្ធ-

មាតា និងរបស់ព្រះពុទ្ធបិតា ជាទីត្រេកអរ ។

ឧបាសកពោលថា បើដូច្នោះ ពួកអ្នកចូរបន្ទឺសំឡេងថា សូមកម្រងផ្កាជាប់ត្រង់រថដែលមកអំពីស្ថានតុសិត ដូច្នេះហើយ បោះកម្រងផ្កាទៅចុះ ។

កូនទាំងនោះ បានបោះទៅហើយ កម្រងផ្កានោះ បានទើរត្រង់ចន្ទោលសំយុងចុះក្នុងអាកាស ។ មហាជនឃើញតែកម្រងផ្កានោះមិនឃើញរថឡើយ ។ ឧបាសកពោលថា អ្នកទាំងឡាយឃើញកម្រងផ្កានោះទេ កាលបុត្រឆ្លើយថាឃើញ ទើបពោលថា កម្រងផ្កានោះជាប់ត្រង់រថដែលមកអំពីតុសិត ឪពុកនឹងទៅកាន់ស្ថានតុសិត ពួកអ្នកកុំត្រិះរិះថ្វីឡើយ ពួកអ្នកមានសេចក្តីប្រាថ្នាកើតក្នុងសម្នាក់ឪពុក ក៏ចូរធ្វើបុណ្យទាំងឡាយ តាមទំនងដែលឪពុកធ្វើហើយចុះ ដូច្នេះហើយ ធ្វើកាលកិរិយាតាំងនៅលើរថដែលមកអំពីស្ថានតុសិត ។ អត្តភាពរបស់គាត់ កម្ពស់ប្រមាណ ៣ គាវុត ប្រដាប់ដោយអលង្ការទម្ងន់ ៦០ រទេះ កើតក្នុងរំពេចនោះឯង ស្រីទេពអប្សរមួយពាន់ចោមរោមហើយវិមានប្រមាណ ២៥ យោជន៍ប្រាកដហើយ ។

ព្រះសាស្តាត្រាស់សួរភិក្ខុទាំងនោះ ដែលមកដល់វិហារហើយ ដោយលំដាប់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកបានស្តាប់ធម្មទេសនាហើយឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ស្តាប់ហើយ តែឧបាសកបានឃាត់ក្នុងចន្លោះនោះឯងថា សូមអ្នកឈប់បង្អង់សិន លំដាប់នោះ បុត្រ និងធីតារបស់ឧបាសកនោះកន្ទក់កន្ទេញហើយ ពួកខ្ញុំព្រះអង្គប្រឹក្សាគ្នាថា ឥឡូវនេះមិនជាឱកាស ទើបក្រោកចាកអាសនៈចេញមក ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកនោះមិនពោលជាមួយអ្នកឡើយ តែទេវតាតាក់តែងរថ ៦ គ្រឿងនាំមកអំពីទេវលោក ៦ ជាន់ អញ្ជើញឧបាសកនោះហើយ គាត់មិនប្រាថ្នានឹងធ្វើអន្តរាយដល់ការសម្តែងធម៌ ទើបពោលនឹងទេវតាទាំងនោះ ភិក្ខុទាំងឡាយទូលថា យ៉ាងនោះឬព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ភិក្ខុទាំងឡាយក្រាបទូលថា ឥឡូវនេះ តើគាត់កើតហើយក្នុងទីណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ក្នុងស្ថានតុសិត ភិក្ខុទាំងឡាយសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសកនោះ ត្រេកអរក្នុងកណ្តាលជុំនុំញាតិក្នុងលោកនេះហើយ កើតក្នុងស្ថានដែលជាទីត្រេកអរនោះទៀតឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ព្រោះបុគ្គលមិនប្រមាទហើយទាំងឡាយ ជាគ្រហស្ថក្តី ជាបព្វជិតក្តី រមែងត្រេកអរក្នុងទីទាំងពួងនោះឯង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**៩៨ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ**
**សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរគឺរីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងរីករាយស្រស់ស្រាយ ព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កតបុញ្ញោ** ជាដើម សេចក្តីថា បុគ្គលធ្វើ

*កុសលមានប្រការផ្សេងៗ រមែងត្រេកអរដោយការត្រេកអរ ព្រោះកម្មក្នុងលោកនេះថា កម្មអាក្រក់អញមិនបានធ្វើឡើយ កម្មល្អ អញធ្វើហើយហ្ន៎ ។ លះលោកនេះទៅហើយ រមែងត្រេកអរដោយការត្រេកអរព្រោះវិបាក ឈ្មោះថា រមែងត្រេកអរក្នុងលោកទាំងពីរយ៉ាងនេះ ។*

*បទថា* **កម្មវិសុទ្ធឹ** *ជាដើម សេចក្តីថា ធម្មិកឧបាសកឃើញកម្មដែលបរិសុទ្ធ គឺការដល់ព្រមនៃបុញ្ញកម្មរបស់ខ្លួនហើយ មុនធ្វើកាលកិរិយា រមែងត្រេកអរក្នុងលោកនេះ ធ្វើកាលកិរិយាហើយ ឥឡូវនេះ ក៏រមែងត្រេកអរ គឺត្រេកអរក្រៃលែងក្នុងលោកខាងមុខ ។*

*ក្នុងកាលចប់គាថា ជនទាំងឡាយដ៏ច្រើនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ព្រះធម្មទេសនា មានប្រយោជន៍ដល់មហាជនដូច្នេះឯង ។៚*

**រឿង ធម្មិកឧបាសក ចប់**

# រឿង ភិក្ខុទេវទត្ត

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ត្រាស់ធម្មទេសនានេះថា* **ឥធ តប្បតិ បេច្ច តប្បតិ** *ជាដើម ។*

*រឿងទេវទត្តភិក្ខុ ព្រះសាស្តាត្រាស់ជាតកទាំងអស់ ដែលទ្រង់ប្រារព្ធ*

ទេវទត្តឲ្យពិស្តារហើយ តាំងអំពីពេលបួសរហូតដល់ផែនដីស្រូប ឯសេចក្តីសង្ខេបក្នុងរឿងទេវទត្តភិក្ខុនេះ ដូចតទៅនេះ

កាលព្រះសាស្តាទ្រង់អាស្រ័យនិគម ឈ្មោះអនុបិយនៃមល្លក្សត្រ ប្រថាប់នៅក្នុងអនុបិយអម្ពវ័ននោះឯង ។ ក្នុងថ្ងៃទទួលព្រះលក្ខណៈនៃព្រះតថាគតនោះឯង ត្រកូលព្រះញាតិ ៨ ម៉ឺន ប្រគាល់ព្រះឱរស ៨ ម៉ឺនឲ្យដោយពាក្យថា សុទ្ធត្ថកុមារ ទោះជាព្រះរាជាក៏ដោយ ជាព្រះពុទ្ធក៏ដោយ នឹងមានស្តេចជាបរិវារត្រាច់ទៅ កាលព្រះឱរសទាំងនោះបួសហើយដោយច្រើន ពួកព្រះញាតិឃើញសក្យៈ ៦ អង្គ គឺភទ្ទិយៈ អនុរុទ្ធ អានន្ទ ភគុ កិម្ពិលៈ ទេវទត្តមិនទាន់បានបួសទើបសន្ទនាគ្នាថា ពួកយើងគង់ឲ្យកូនរបស់ខ្លួនបួស បានសក្យៈទាំង ៦ នេះប្រហែលមិនមែនព្រះញាតិទេដឹង ព្រោះដូច្នោះទើបមិនបានបួស ។

គ្រានោះ មហានាមសក្យៈចូលទៅរកអនុរុទ្ធត្រាស់ថា នែបា បុគ្គលចេញចាកត្រកូលបួសក្នុងត្រកូលរបស់យើងមិនមាន ប្អូនបួស ឬបងនឹងបួស ។ អនុរុទ្ធកុមារនោះជាស្តេចសុខុមាលជាតិ មានភោគៈសម្បូរ សូម្បីពាក្យថាមិនមាន ទ្រង់ក៏មិនធ្លាប់ឮ ។ ពិតហើយ ថ្ងៃមួយ កាលក្សត្រ ៦ អង្គនោះទ្រង់លេងកីឡាបោះឡូ អនុរុទ្ធទ្រង់ចាញ់ដោយនំហើយ បញ្ជូនមនុស្សទៅដើម្បីត្រូវការនំ គ្រានោះ ព្រះមាតារបស់លោក ទ្រង់បញ្ជូននំទៅ ក្សត្រទាំងឡាយសោយហើយនាំគ្នាលេងទៀត អនុរុទ្ធនោះឯងជាអ្នកចាញ់រហូតទៅចំណែកព្រះមាតា កាលទ្រង់បញ្ជូនមនុស្សទៅក៏បញ្ជូននំទៅអស់បីដង ក្នុងវារៈទី ៤ បញ្ជូនទៅថា នំមិនមាន ព្រះកុមារទ្រង់សម្គាល់ថា នំនេះប្រហែល

*ជានំប្រភេទណាមួយ ព្រោះមិនធ្លាប់បានឮពាក្យថា មិនមាន ទើបទ្រង់បញ្ជូនមនុស្សទៅថា ចូរនាំនំមិនមាននោះមកចុះ ។*

*ចំណែកព្រះមាតារបស់លោក កាលមនុស្សទូលថា បពិត្រព្រះនាង បានឮថា ព្រះនាងទ្រង់ប្រទាននំមិនមាន ។ ទើបព្រះនាងព្រះតម្រិះរិះថា កូនរបស់អញមិនធ្លាប់បានឮពាក្យថាមិនមាន តែអញនឹងឲ្យដឹងសេចក្តីនោះដោយឧបាយនេះ ទើបទ្រង់គ្របថាសមាសទទេដោយថាសមាសដទៃ ហើយបញ្ជូនទៅ ។*

*ពួកទេវតាដែលរក្សាព្រះនគរគិតថា អនុរុទ្ធសក្យៈបានថ្វាយភត្តជាចំណែកខ្លួន ដល់ព្រះបច្ចេកពុទ្ធឈ្មោះឧបរិដ្ឋៈ ក្នុងកាលដែលខ្លួននៅជាអន្នភារៈ ទ្រង់ធ្វើសេចក្តីប្រាថ្នាថា ព្រះអង្គកុំបីឮពាក្យថាមិនមាន កុំដឹងទីដែលកើតនៃភោជន បើស្តេចអនុរុទ្ធនេះទ្រង់ឃើញថាសទទេសោត ពួកយើងក៏មិនបាន ចូរទៅកាន់ទេវសមាគមផង ក្បាលរបស់ពួកយើងនឹងបែក ៧ ភាគផង ពេលនោះ ទើបធ្វើថាសមាសនោះឲ្យពេញដោយនំទិព្វ កាលថាសនោះ គ្រាន់តែអ្នកបម្រើដាក់ចុះត្រង់ទីសម្រាប់លេង ហើយបើកឡើង ក្លិននំក៏ផ្សាយទូទៅពេញព្រះនគរ ដុំនំគ្រាន់តែក្សត្រទាំង ៦ ដាក់ចូរទៅក្នុងព្រះឱស្ឋប៉ុណ្ណោះ ក៏ផ្សាយទៅ ពេញបសាទដែលទទួលរសទាំង ៧ ពាន់ ។*

*ព្រះកុមារនោះទ្រង់ព្រះតម្រិះថា អាត្មាអញប្រហែលមិនជាទីស្រឡាញ់របស់ព្រះមាតា ទើបព្រះមាតាទ្រង់មិនចម្អិននំឈ្មោះនំមិនមាននេះឲ្យដល់អញអស់កាលមានប្រមាណប៉ុណ្ណេះ ។ តាំងអំពីនេះទៅ អញមិនបរិភោគនំដទៃឡើយ ដូច្នេះហើយ យាងទៅកាន់ដំណាក់ ទូលសួរព្រះមាតាថា បពិត្រព្រះ*

មាតា ទូលបង្គំជាទីស្រឡាញ់របស់មាតា ឬមិនជាទីស្រឡាញ់ ព្រះមាតាពោលថា នែបា បាជាទីស្រឡាញ់ក្រៃលែងរបស់មាតា ដូចភ្នែករបស់បុគ្គលមានតែម្ខាង និងដូចហទយៈរបស់មាតាដូច្នោះ ព្រះអនុរុទ្ធពោលថា បើដូច្នោះហេតុអ្វី ទើបព្រះមាតា ទ្រង់មិនចម្អិននំមិនមានឲ្យដល់ទូលបង្គំ អស់កាលមានប្រមាណប៉ុណ្ណោះ ។

ព្រះនាងសួរក្មេងស្និទ្ធស្នាលថា នំណាមួយមាននៅក្នុងថាសឬ អ្នកបម្រើពោលថា បពិត្រព្រះនាង ថាសពេញទៅដោយនំ ឈ្មោះថានំបែបនេះទូលបង្គំក៏មិនធ្លាប់ឃើញដែរ ។ ព្រះនាងទ្រង់ព្រះតម្រិះថា កូនរបស់អញជាអ្នកមានបុណ្យ មានអភិនីហារបានធ្វើហើយ ទេវតាទាំងឡាយដាក់នំឲ្យពេញថាសបញ្ជូនទៅហើយ ។ លំដាប់នោះ ទើបព្រះអនុរុទ្ធទូលនឹងព្រះមាតាថា បពិត្រព្រះមាតា តាំងអំពីនេះទៅទូលបង្គំមិនសោយនំដទៃ សូមព្រះមាតាចម្អិនតែនំមិនមានតែម្យ៉ាង ។ តាំងអំពីនោះមក សូម្បីព្រះនាងកាលព្រះកុមារនោះទូលថា ទូលបង្គំត្រូវការសោយនំ ព្រះនាងក៏គ្របថាសទទេនោះឯង ដោយថាសដទៃ បញ្ជូនទៅឲ្យព្រះកុមារនោះ ទេវតាទាំងឡាយបញ្ជូននំទិព្វថ្វាយព្រះកុមារនោះអស់កាលដែលលោកនៅជាយរាវាស ។

ព្រះកុមារនោះ កាលទ្រង់មិនជ្រាបសូម្បីត្រឹមតែពាក្យ មានប្រមាណប៉ុណ្ណោះ ទ្រង់នឹងជ្រាបដល់ការបួសបានដូចម្តេច ព្រោះដូច្នោះ ទើបកុមារទូលសួរព្រះភាតាថា ការបួសនេះដូចម្តេច កាលស្តេចមហានាមត្រាស់ថា អ្នកបួសត្រូវកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ត្រូវដេក

លើកម្រាលដែលធ្វើដោយឈើ ឬលើគ្រែដែលត្បាញដោយផ្តៅ ត្រាច់បិណ្ឌបាត នេះឈ្មោះថា ការបួស ។ ទើបទូលថា ព្រះជេដ្ឋា ខ្ញុំជាសុខុមាលជាតិ ខ្ញុំមិនអាចបួសបានទេ ។ ព្រះបាទមហានាមត្រាស់ថា នែបា បើដូច្នោះ ចូរបារៀននូវកិច្ចដែលជាឃរាវាសចុះ ។ ក្នុងយើងទាំងពីរ បើម្នាក់មិនបួស មិនគួរ ។

ខណៈនោះ អនុរុទ្ធកុមារសួរបងថា ឈ្មោះថា ការងារនេះដូចម្តេច កុលបុត្រដែលមិនដឹងសូម្បីតែទីកើតនៃភត្ត នឹងស្គាល់ការងារបានដូចម្តេច ។

ថ្ងៃមួយ ការសន្ទនាកើតឡើងដល់ក្សត្រ ៣ អង្គថា ឈ្មោះថា ភត្ត កើតឡើងក្នុងទីណា កិម្ពិលកុមារប្រាប់ថា កើតឡើងក្នុងជង្រុក គ្រានោះ ភទ្ទិយ-កុមារជំទាស់កិម្ពិលកុមារនោះថា ព្រះអង្គមិនជ្រាបទីកើតនៃភត្ត ឈ្មោះថា ភត្ត រមែងកើងឡើងត្រង់ឆ្នាំងបាយ អនុរុទ្ធជំទាស់ថា ទោះបីអ្នកទាំងពីរ ក៏នូវមិនដឹង ធម្មតា ភត្ត រមែងកើតក្នុងថាសមាស ប្រមាណមួយហត្ថក្តាប់ ។

បានឮថា ក្សត្រ ៣ អង្គនោះ ថ្ងៃមួយ កិម្ពិលកុមារទ្រង់ឃើញគេជញ្ជូនស្រូវចុះអំពីជង្រុក ក៏យល់ថាស្រូវទាំងនេះកើតឡើងហើយក្នុងជង្រុកនោះឯង ។

ចំណែកភទ្ទិយកុមារ ថ្ងៃមួយ ទ្រង់ឃើញគេដួសភត្តចេញអំពីឆ្នាំងបាយ ក៏យល់ថា ភត្តកើតឡើងក្នុងឆ្នាំងបាយនោះឯង ។

ចំណែកអនុរុទ្ធកុមារ មិនធ្លាប់ឃើញសូម្បីមនុស្សបុកអង្ករ ដាំបាយ ឬដួសបាយ ទ្រង់ឃើញតែបាយដែលគេដួសហើយតម្កល់ទុកចំពោះមុខប៉ុណ្ណោះ ទើបទ្រង់យល់ថា ភត្តកើតក្នុងថាសក្នុងពេលដែលត្រូវការបរិភោគ ។ ស្តេចទាំង ៣ អង្គនោះ ទ្រង់មិនជ្រាបសូម្បីទីកើតនៃភត្ត ដោយប្រការយ៉ាងនេះ

ព្រោះដូច្នោះ ទើបព្រះអនុរុទ្ធទូលសួរថា ឈ្មោះថា ការងារនេះដូចម្ដេច កាលទ្រង់បានស្ដាប់កិច្ចការដែលយកវាសគប្បីធ្វើប្រចាំឆ្នាំ មានខាងដើមត្រូវភ្ជួរស្រែ ។ ទើបសួរថា កាលណាទីបំផុតនៃការងារទាំងឡាយនឹងប្រាកដ ។ កាលណា ទើបទូលបង្គំមានសេចក្ដីខ្វល់ខ្វាយតិច ប្រើប្រាស់កោគៈបាន ។ កាលព្រះបាទមហានាមត្រាស់ប្រាប់ការមិនមានទីបំផុតនៃការងារទាំងឡាយហើយ ទូលថា បើយ៉ាងនោះ ម្ចាស់បងនោះឯងជាអ្នកគ្រប់គ្រងយកវាសចុះ ទូលបង្គំមិនត្រូវការដោយយកវាសនោះឡើយ ដូច្នេះហើយ ចូលគាល់ព្រះមាតាក្រាបទូលថា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតដល់ទូលបង្គំចុះ ទូលបង្គំនឹងបួស កាលព្រះនាងទ្រង់ឃាត់អស់វារៈពីរដង ត្រាស់ថា បើកទ្ទិយកុមារជាសម្លាញ់របស់បុត្របួសសោត ចូរកូនបួសជាមួយទ្រង់ចុះ ទើបចូលទៅរកព្រះភទ្ទិយៈនោះទូលថា នែសម្លាញ់ ការបួសរបស់ខ្ញុំជាប់ទាក់ទងជាមួយទ្រង់ ដូច្នេះហើយ បានញ៉ាំងភទ្ទិយៈនោះឲ្យយល់ព្រមដោយប្រការផ្សេងៗ ក្នុងថ្ងៃទី ៧ ទ្រង់ទទួលបេ្ដជ្ញាដើម្បីប្រយោជន៍នឹងបួសជាមួយព្រះអង្គ ។

បន្ទាប់អំពីនោះ ក្សត្រទាំង ៦ អង្គ គឺភទ្ទិយសក្យរាជ អនុរុទ្ធ អានន្ទ ភគុ កិម្ពិលៈ និងទេវទត្ត មានឧបាលីដែលជាកូសាមាលាជាគម្រប់ ៧ ទ្រង់សោយមហាសម្បត្តិអស់ ៧ ថ្ងៃ ដូចទេវតាសោយទិព្វសម្បត្តិ ហើយយាងចេញដោយចតុរង្គសេនា ហាក់ដូចយាងទៅប្រពាតឧទ្យាន ដល់ដែនក្សត្រអង្គដទៃហើយ ទ្រង់បញ្ជូនកងទ័ពទាំងអស់ឲ្យត្រឡប់ដោយព្រះរាជអាជ្ញា ទ្រង់យាងចូលកាន់ដែនក្សត្រអង្គដទៃ ។ ក្នុងជន ៧ នាក់នោះ ក្សត្រ ៦ អង្គ

ទ្រង់ ដោះអករណៈរៀងៗ ខ្លួន ធ្វើជាបង្វេចហើយប្រាប់ថា នែឧបាលី ចូរអ្នកត្រឡប់ទៅចុះ ទ្រព្យប៉ុណ្ណេះល្មមចិញ្ចឹមជីវិតរបស់អ្នក ដូច្នេះហើយ ប្រទានដល់ឧបាលី ។ ឧបាលីយំបម្រះនៀលទៀបបាទារបស់ក្សត្រ ៦ អង្គនោះ កាលមិនអាចកន្លងអាជ្ញារបស់ស្តេចទាំងនោះ ទើបក្រោកឡើងកាន់បង្វេចនោះត្រឡប់ទៅ ។ ក្នុងកាលនៃជនទាំងនោះកើតជាពីរពួក ព្រៃ ហាក់ដូចជាដល់នូវការទ្រហោយំ ផែនដី ហាក់ដូចជាដល់នូវការញាប់ញ័រ ។ ចំណែកឧបាលីកូសាមាលា ទៅបានបន្តិច ក៏ត្រឡប់គិតយ៉ាងនេះថា ស្តេចសក្យៈ កាចណាស់ គប្បីសម្លាប់អញបង់ ដោយយល់ថារាជកុមារទាំងឡាយត្រូវអញផ្តាច់ព្រះជន្មហើយ ដូច្នេះក៏ថាបាន ធម្មតាសក្យកុមារទាំងនេះ ទ្រង់លះសម្បត្តិបែបនេះ បោលអករណៈដែលមានតម្លៃ កាត់ថ្លៃមិនបានទាំងនេះដូចដុំទឹកមាត់ ហើយបួស នឹងពោលថ្វីដល់អញ កាលគិតដូច្នេះហើយ ទើបស្រាយបង្វេចចេញ យកអករណៈទាំងនោះព្យួរលើដើមឈើហើយ ពោលថា អ្នកណាត្រូវការ ចូរកាន់យកចុះ ដូច្នេះហើយ ទៅកាន់សម្នាក់របស់សក្យកុមារទាំងនោះ សក្យកុមារទាំងនោះត្រាស់សួរថា ព្រោះហេតុអ្វី ទើបអ្នកត្រឡប់មក ក៏ក្រាបទូលសេចក្តីនោះហើយ ។

គ្រានោះ សក្យកុមារទាំងនោះ ទ្រង់នាំគ្នាចូលទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយឈ្មោះថាជាសក្យៈ មានការប្រកាន់ខ្លួនប្រចាំសន្តាន ។ បុគ្គលនេះជាអ្នកបម្រើរបស់ខ្ញុំព្រះអង្គអស់រាត្រីយូរ សូមទ្រង់ឲ្យបុគ្គលនេះបួសមុន

ខ្ញុំព្រះអង្គទាំងឡាយនឹងធ្វើសាមីចិកម្ម មានការអភិវាទជាដើមដល់បុគ្គលនេះ ការប្រកាន់ខ្លួនរបស់ខ្ញុំព្រះអង្គ នឹងសាបរលាបទៅដោយអាការយ៉ាងនេះ ។ ដូច្នេះហើយ ឲ្យឧបាលីនោះបួសមុន ឯខ្លួនបួសខាងក្រោយ ។ បណ្តាសក្យៈ ៦ អង្គនោះ ព្រះភទ្ទិយៈបានជាព្រះអរហន្តតេវិជ្ជោ ក្នុងរវាងវស្សានោះឯង ។ ឯព្រះអនុរុទ្ធជាអ្នកមានទិព្វចក្ខុ ក្រោយមកទ្រង់ស្តាប់មហាបុរិសវិតក្កសូត្រ បានសម្រេចអរហត្តហើយ ព្រះអានន្ទតាំងនៅក្នុងសោតាបត្តិផលហើយ ។ ព្រះកគុត្ថេរ និងព្រះកិម្ពិលត្ថេរ ក្នុងកាលខាងក្រោយមក ចម្រើនវិបស្សនាសម្រេចអរហត្ត ទេវទត្តកិត្តិបានសម្រេចឫទ្ធិដែលជារបស់បុថុជ្ជន ។

ក្នុងកាលបន្ទាប់មក កាលព្រះសាស្តាប្រថាប់នៅក្នុងក្រុងកោសម្ពី លាភនិងសក្ការៈជាច្រើន កើតឡើងដល់ព្រះតថាគត មួយអន្លើដោយសង្ឃសាវក មនុស្សទាំងឡាយក្នុងក្រុងកោសម្ពីនោះ មានដៃកាន់សំពត់ និងភេសជ្ជៈជាដើម ចូលទៅកាន់វិហារហើយ សួរគ្នាថា ព្រះសាស្តាប្រថាប់នៅក្នុងទីណាហ្ន៎ ព្រះសារីបុត្តត្ថេរនៅក្នុងទីណាហ្ន៎ ព្រះមហាមោគ្គល្លានត្ថេរនៅទីណាហ្ន៎ ព្រះមហាកស្សបត្ថេរនៅទីណាហ្ន៎ ព្រះភទ្ទិយត្ថេរនៅទីណាហ្ន៎ ព្រះអនុរុទ្ធត្ថេរនៅទីណាហ្ន៎ ព្រះអានន្ទត្ថេរនៅទីណាហ្ន៎ ព្រះកគុត្ថេរនៅទីណាហ្ន៎ ព្រះកិម្ពិលត្ថេរនៅទីណាហ្ន៎ ដូច្នេះហើយ ដើរមើលទីគង់នៃអសីតិមហាសាវក ឈ្មោះថា បុគ្គលសួរថា ទេវទត្តគង់ ឬឈរទីណាហ្ន៎ដូច្នេះ មិនមាន ទើបទេវទត្តគិតថា អញបួសជាមួយសក្យរាជទាំងនោះដូចគ្នា សក្យៈទាំងនោះជាខត្តិយបព្វជិត សូម្បីអាត្មាអញក៏ជាខត្តិយបព្វជិត ពួកមនុស្សក៏មានដៃកាន់លាភសក្ការៈ ស្វែងរក

លោកទាំងនោះ អ្នកហារមាត់សួរដល់ឈ្មោះរបស់អញ មិនមាន អញនឹងសេពគប់ជាមួយអ្នកណាហ្ន៎ គប្បីញុំាងអ្នកណាឲ្យជ្រះថ្លា ហើយញុំាងលាភសក្ការៈឲ្យកើតដល់អញបាន ។

ពេលនោះ ការសម្រេចចិត្តនេះមានដល់លោកថា ព្រះបាទពិម្ពិសារមួយអន្លើដោយបរិវារ ១១ ម៉ឺន ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ ដោយការឃើញគ្រាដំបូងនោះឯង អញមិនអាចសេពគប់ជាមួយព្រះរាជានោះបាន សូម្បីព្រះបាទកោសល អញក៏មិនអាចសេពគប់បាន ឯអជាតសត្តុកុមារព្រះឱរសរបស់ព្រះរាជានេះឯង នៅមិនទាន់ដឹងគុណ និងទោសរបស់បុគ្គលណា អញសេពគប់ជាមួយកុមារនោះ ។ ទេវទត្តនោះ ចេញអំពីក្រុងកោសម្ពីទៅកាន់ក្រុងរាជគ្រឹះ និមិត្តភេទជាកុមារតូច រុំអសិរពិស ៤ ត្រង់ដៃ និងជើងទាំង ៤ ពស់ ១ ទៀតរុំត្រង់ក ពស់ ១ ទៀត ធ្វើជាឈ្នួតក្បាល ពស់មួយទៀត ធ្វើជាខ្សែស្មារ ចុះពីលើអាកាស ដោយសង្វារពស់នេះ អង្គុយលើភ្លៅរបស់អជាតសត្តុកុមារ កាលកុមារនោះ ទ្រង់ខ្លាចហើយ ត្រាស់ថា អ្នកជានរណា ទើបថ្វាយព្រះពរថា អាត្មា គឺទេវទត្ត ដើម្បីបន្ទោបង់នូវការខ្លាចរបស់ព្រះរាជកុមារ ទើបត្រឡប់អត្តភាពនោះជាភិក្ខុ ទ្រទ្រង់សង្ឃាដីបាត្រ និងចីវរឈរនៅចំពោះព្រះភក្ត្រ ញុំាងរាជកុមារនោះឲ្យជ្រះថ្លា ញុំាងលាភ និងសក្ការៈឲ្យកើតហើយ ។

ទេវទត្តភិក្ខុនោះ កាលលាភ និងសក្ការៈគ្របសង្កត់ហើយ ញុំាងការគិតដ៏លាមកឲ្យកើតឡើងថា អញនឹងគ្រប់គ្រងភិក្ខុសង្ឃជួច្នេះហើយ ក៏សាបសូន្យ

ចាកឫទ្ធិដំណាលគ្នានឹងចិត្តុប្បាទនោះឯង ហើយថ្វាយបង្គំព្រះសាស្តា ដែលកំពុងសម្តែងធម៌ដល់បរិស័ទ មួយអន្លើដោយព្រះរាជាក្នុងវត្តវេឡុវ័នវិហារ ក្រោកចាកអាសនៈហើយ ផ្គងអញ្ជលីក្រាបទូលថា បពិត្រព្រះអង្គ ពេលនេះ ទ្រង់ចាស់ជរាហើយ សូមទ្រង់ខ្វល់ខ្វាយតិច ប្រកបរឿយៗ នូវវិហារធម៌ដែលជាទីសប្បាយក្នុងទិដ្ឋធម៌ចុះ ខ្ញុំព្រះអង្គនឹងគ្រប់គ្រងភិក្ខុសង្ឃ សូមទ្រង់ប្រគល់ភិក្ខុសង្ឃដល់ខ្ញុំព្រះអង្គចុះ ដូច្នេះហើយ ត្រូវព្រះសាស្តាសង្កត់សង្កិនដោយខេឡាសិកវាទ ទ្រង់ឃាត់ហើយ មិនពេញចិត្ត បានចងអាឃាតនេះ ក្នុងព្រះតថាគតជាគ្រាដំបូង ហើយចៀសចេញទៅ ។

គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ឲ្យធ្វើបកាសនីយកម្ម ក្នុងក្រុងរាជគ្រឹះដល់ទេវទត្តហើយ ។ លោកគិតថា ឥឡូវនេះ អញត្រូវព្រះសមណគោតមកម្ចាត់ហើយ ឥឡូវនេះ អញនឹងធ្វើសេចក្តីវិនាសដល់ព្រះសមណគោតមនេះ ដូច្នេះហើយ ទើបទៅគាល់ព្រះបាទអជាតសត្តុកុមារទូលថា បពិត្រព្រះរាជកុមារ កាលមុនមនុស្សទាំងឡាយមានអាយុវែង ឥឡូវនេះអាយុខ្លី ការដែលទ្រង់គប្បីទិវង្គតតាំងអំពីក្មេង នុ៎ះជាឋានៈមាននៅ បើដូច្នោះ សូមទ្រង់សម្រេចទោសព្រះបិតាជាព្រះរាជាចុះ អាត្មាសម្រេចទោសព្រះដ៏មានព្រះភាគ ហើយធ្វើជាព្រះពុទ្ធ កាលព្រះកុមារតាំងនៅក្នុងរាជសម្បត្តិហើយ បានតែងតាំងបុរសទាំងឡាយ ដើម្បីសម្លាប់ព្រះតថាគត កាលបុរសទាំងនោះសម្រេចសោតាបត្តិផលត្រឡប់ទៅហើយ ទើបឡើងភ្នំគិជ្ឈកូដឯង ប្រមៀលថ្មដោយបំណងថា អញខ្លួនឯងនឹងផ្តាច់ជីវិតព្រះសមណគោតម បានធ្វើកម្ម គឺលោហិតឲ្យពុះពងឡើង

កាលមិនអាចសម្លាប់ដោយឧបាយនេះ ទើបឲ្យលែងដំរីនាឡាគិរីទៅទៀត កាលដំរីនោះកំពុងដើរមក ព្រះអានន្ទត្ថេរលះបង់ជីវិតរបស់ខ្លួន ថ្វាយព្រះសាស្តា បានឈររាំងខាងមុនហើយ ។

ព្រះសាស្តាទ្រង់ទូន្មានដំរីហើយ ទ្រង់ចេញអំពីនគរមកកាន់វិហារ សោយមហាទាន ដែលពួកឧបាសកច្រើនពាន់នាំមកហើយ ទ្រង់សម្តែងអនុបុព្វីកថា ប្រោសអ្នកក្រុងរាជគ្រឹះ ១៨ កោដិ ដែលប្រជុំគ្នាក្នុងថ្ងៃនោះ ធម្មាភិសម័យកើតមានដល់សត្វប្រមាណ ៨៤០០០ ។

ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់កថាពណ៌នាគុណរបស់ព្រះថេរៈថា ឱ ! ព្រះអានន្ទមានគុណច្រើន កាលស្តេចដំរីបែបនោះមក បានលះបង់ជីវិតរបស់ខ្លួន ឈររាំងមុខព្រះសាស្តា ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អានន្ទនេះក៏លះបង់ជីវិតដើម្បីប្រយោជន៍ដល់តថាគតហើយដូចគ្នា កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទើបត្រាស់ចុល្លហង្សជាតក មហាហង្សជាតក និងកក្កដជាតក ។

កម្មរបស់ទេវទត្ត ព្រោះញុំាងព្រះបាទអជាតសត្តុកុមារ ឲ្យសម្រេចទោសព្រះរាជាក្តី រៀបចំនាយខ្មាន់ធ្នូក្តី ព្រោះប្រមៀលថ្មក្តី មិនបានប្រាកដដូចព្រោះលែងដំរីនាឡាគិរីឡើយ ។ គ្រានោះឯង មហាជនបានចោទគ្នាឡើងថា សូម្បីព្រះរាជាក៏ទេវទត្តនោះឯងជាអ្នកឲ្យសម្រេចទោស នាយខ្មាន់ធ្នូក៏ទេវទត្តនោះឯងរៀបចំឡើង ដុំថ្មក៏ទេវទត្តជាអ្នកប្រមៀលដូចគ្នា ឥឡូវនេះលោកក៏បានលែងដំរីនាឡាគិរី ព្រះរាជាទ្រង់សេពគប់បុគ្គលលាមកបែបនេះហ្ន៎ ព្រះរាជាទ្រង់ឮ

ពាក្យរបស់មហាជនហើយ ទើបឲ្យនាំកត្ត ៥០០ សម្រាប់មក មិនបានយាង ទៅឧបដ្ឋាកទេវទត្តនោះទៀតឡើយ សូម្បីអ្នកនគរមិនបានប្រគេនវត្ថុត្រឹមតែ ភិក្ខាដល់លោកដែលចូលទៅកាន់ត្រកូល ។

ទេវទត្តនោះសាបសូន្យចាកលាភ និងសក្ការៈហើយ បំណងនឹងចិញ្ចឹម ជីវិតដោយការបោកបញ្ឆោត ទើបចូលទៅគាល់ព្រះសាស្ដា ទូលសូមវត្ថុ ៥ ប្រការ ត្រូវព្រះដ៏មានព្រះភាគទ្រង់ហាមថា ម្នាលទេវទត្ត អ្នកកុំធ្វើដូច្នោះឡើយ បុគ្គលណាប្រាថ្នា បុគ្គលនោះក៏ចូលជាអ្នកនៅព្រៃចុះ ដូច្នេះហើយ ទូលថា នែអាវុសោទាំងឡាយ ពាក្យសម្ដីរបស់អ្នកណាស្អាត របស់ព្រះតថាគត ឬ របស់ខ្ញុំ ខ្ញុំនឹងពោលដោយអំណាចបដិបទាយ៉ាងឧក្រិដ្ឋយ៉ាងនេះថា បពិត្រ ព្រះអង្គ ខ្ញុំព្រះអង្គសូមព្រះរាជទានព្រះវរោកាស សូមភិក្ខុទាំងឡាយជាអ្នក នៅព្រៃ ត្រាច់បិណ្ឌបាត ទ្រទ្រង់សំពត់បង្សុកូល នៅដោយគល់ឈើ មិន គប្បីឆាន់ត្រី និងសាច់ដរាបដល់អស់ជីវិត ហើយពោលថា បុគ្គលណាប្រាថ្នា ផុតចាកទុក្ខ បុគ្គលនោះ ចូរមកជាមួយខ្ញុំ ដូច្នេះហើយ ចៀសចេញទៅ ភិក្ខុ ពួកខ្លះជាអ្នកបួសថ្មី មានការចេះដឹងតិច បានស្ដាប់ពាក្យរបស់ទេវទត្តនោះ ហើយ បបួលគ្នាថា ព្រះទេវទត្តនិយាយត្រូវ ពួកយើងនឹងទៅជាមួយទេវទត្ត នោះ ដូច្នេះហើយ បានសេពគប់ជាមួយលោក ។

ទេវទត្តនោះញ៉ាំងជនដែលជ្រះថ្លាក្នុងរបស់សៅហ្មងឲ្យយល់ ដោយវត្ថុ ៥ ប្រការនោះ មួយអន្លើដោយភិក្ខុ ៥០០ រូប ឲ្យត្រាច់សូម្បីបច្ច័យក្នុងត្រកូល ទាំងឡាយមកបរិភោគ ព្យាយាមដើម្បីបំបែកសង្ឃហើយ ។ ទេវទត្តកាល

ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលទេវទត្ត បានឮថា អ្នកព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីទម្លាយចក្កពិតឬ ទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនេះពិតហើយ សូម្បីទ្រង់ប្រទានឱវាទ ដោយព្រះពុទ្ធវចនៈជាដើមថា ម្នាលទេវទត្ត ការបំបែកសង្ឃមានទោសធ្ងន់ ក៏មិនបានកាន់យកព្រះវាចារបស់ព្រះសាស្តាឡើយ ហើយចៀសចេញទៅ ជួបព្រះអានន្ទដែលកំពុងត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទើបពោលថា អាវុសោអានន្ទ តាំងអំពីថ្ងៃនេះជាដើមទៅ ខ្ញុំនឹងធ្វើឧបោសថ ធ្វើសង្ឃកម្មវៀរចាកព្រះដ៏មានព្រះភាគ វៀរចាកភិក្ខុសង្ឃ ។

ព្រះថេរៈក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះសាស្តាទ្រង់ជ្រាបសេចក្តីនោះហើយ កើតធម្មសង្វេគ ទ្រង់បរិវិតក្កថា ទេវទត្តធ្វើកម្មជាហេតុឲ្យខ្លួនឆេះក្នុងអវីចិ ដែលទាក់ទងដល់សេចក្តីវិនាសដល់សត្វលោក និងទេវលោក ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

អំពើល្អ មនុស្សស្របុរស ធ្វើបានដោយងាយ
អំពើល្អ មនុស្សបាប ធ្វើបានដោយក្រ ។

ទ្រង់បន្លឺព្រះឧទានទៀតថា

អំពើបាប មនុស្សបាប ធ្វើបានដោយងាយ អំពើ
បាប ព្រះអរិយៈទាំងឡាយ ធ្វើបានដោយក្រ ។

គ្រានោះឯង ទេវទត្តអង្គុយក្នុងចំណែកម្ខាង មួយអន្លើដោយបរិស័ទរបស់ខ្លួនក្នុងថ្ងៃឧបោសថ ពោលថា វត្ថុ ៥ ប្រការនេះ គាប់ចិត្តដល់បុគ្គលណា បុគ្គលនោះចូរចាប់ស្លាក កាលភិក្ខុវជ្ជីបុត្រ ៥០០ រូប ជាអ្នកបួសថ្មី

មិនស្គាល់ធម៌វិន័យ ដែលព្រះដ៏មានព្រះភាគទ្រង់ធ្វើ ចាប់ស្វាកហើយ បាន ទម្លាយសង្ឃ នាំភិក្ខុទាំងនោះ ទៅកាន់គយាសីសប្បទេស ។

ព្រះសាស្តា ទ្រង់ឮដំណឹងដែលទេវទត្តនោះទៅហើយក្នុងទីនោះ ទើប បញ្ជូនអគ្គសាវកទាំងពីរទៅ ដើម្បីប្រយោជន៍ដល់ការនាំភិក្ខុទាំងនោះមកវិញ អគ្គសាវកទាំងពីរនោះទៅក្នុងទីនោះហើយ ទូន្មានដោយអនុសាសនី ទាក់ទង ក្នុងអាទេសនាបាដិហារ្យ និងអនុសាសនីដែលទាក់ទងក្នុងឥទ្ធិប្បាដិហារ្យ ញ៉ាំងភិក្ខុទាំងនោះ ឲ្យផឹកអមតធម៌ហើយ នាំមកតាមអាកាស ។

ចំណែកកោកាលិកភិក្ខុពោលថា អាវុសោទេវទត្តក្រោកឡើង សារីបុត្រ និងមោគ្គល្លាននាំភិក្ខុទាំងនោះទៅអស់ហើយ ខ្ញុំប្រាប់លោកហើយ មិនមែនឬ ថា អាវុសោ លោកកុំទុកចិត្តសារីបុត្រ និងមោគ្គល្លាន ព្រោះសារីបុត្រ និង មោគ្គល្លាន មានការប្រាថ្នាលាមក លុះនៅក្នុងអំណាចសេចក្តីប្រាថ្នាលាមក ដូច្នេះហើយ យកក្បាលជង្គង់ឧកត្រង់ដើមទ្រូង ។ ឈាមក្តៅៗ បានខ្ពុរចេញ តាមមាត់ទេវទត្តក្នុងទីនោះឯង ។

ចំណែកពួកភិក្ខុឃើញព្រះសារីបុត្រ មានភិក្ខុសង្ឃចោមរោមមកតាម អាកាសហើយ ក្រាបទូលថា បពិត្រព្រះអង្គ ព្រះសារីបុត្តត្ថេរក្នុងកាលទៅ មានពីររូបប៉ុណ្ណោះ ឥឡូវនេះ មានបរិវារមក រុងរឿងពិតហ្ន៎ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះ ទេ សូម្បីក្នុងកាលទេវទត្តកើតក្នុងកំណើតតិរច្ឆាន បុត្ររបស់តថាគតមកកាន់ សម្នាក់តថាគត ក៏រមែងរុងរឿងដូចគ្នា ដូច្នេះហើយ ត្រាស់ជាតកនេះថា

សេចក្តីចម្រើន តែងមានដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្ត បដិសណ្ឋារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈ កំពុងដើរ មក ដែលពួកញាតិហែហមហើយ នាងឃើញម្រឹគឈ្មោះ កាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ ( កំពុងដើរមក ) ឬទេ ដូច្នេះជាដើម ។

កាលពួកភិក្ខុក្រាបទូលទៀតថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ទេវទត្ត ឲ្យអគ្គសាវកពីរអង្គ គង់សងខាងហើយ ពោលថា ខ្ញុំនឹងសម្តែងធម៌ដោយ ពុទ្ធលីលា ធ្វើកិរិយាតាមព្រះអង្គហើយ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ មិនមែនតែឥឡូវប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តនេះ ក៏ធ្វើតាមលីលារបស់តថាគត តែមិនអាច ដូច្នេះហើយ ត្រាស់នទីចរកាក-ជាតកថា[១]

ប្រពន្ធក្អែកគោកសួរថា

នែក្អែកទឹកឈ្មោះវីរកៈ អ្នកឃើញសត្វស្លាបដែលពោល ពាក្យពីរោះ មានផ្ទួតកដូចជាផ្ទួតកនៃក្ងោក ជាក្អែកគោក ឈ្មោះសវិដ្ឋកៈ ជាប្តីរបស់ខ្ញុំដែរឬ ។

ក្អែកទឹកពោធិសត្វពោលថា

ក្អែកសវិដ្ឋកៈ កាលធ្វើតាមសត្វស្លាបអ្នកត្រាច់ទៅក្នុងទឹក និងលើគោក បានបរិភោគត្រីស្រស់ជានិច្ចនោះ ត្រូវសារាយ

១- បិដកខ្មែរ ជាវីរកជាតក ។

ព័ន្ធព័ទ្ធស្លាប់ទៅហើយ ដូច្នេះជាដើម ។

សូម្បីថ្ងៃដទៃៗ ទៀត ទ្រង់ប្រារព្ធកថាដូច្នោះដូចគ្នា ត្រាស់ជាតកទាំង-ឡាយជាដើមយ៉ាងនេះថា

ខទិរវនិយបក្សីពោលថា

ឱហ្ន៎ ត្រសេះនេះ កាលចោះនូវឈើក្នុងព្រៃទាំងឡាយ បានហើរទៅក្នុងពួកឈើមិនមានខ្លឹម ជាចំណែកនៃឈើស្ងួតក្នុង កាលជាខាងក្រោយមកត្រសេះ ( នេះ ) បានហើរ មកទម្លាយ អំបែងក្បាល ( របស់ខ្លួន ) និងដើមស្តែ្កជាឈើមានខ្លឹមអំពីកំណើត ។

កេសរសីហពោធិសត្វពោលថា ខួរក្បាលរបស់អ្នកធ្លាយចេញផង លលាដ៍ក្បាលរបស់អ្នកបែកធ្លាយផង ឆ្អឹងជំនីរទាំងអស់ របស់អ្នក ដ៏របំបាក់ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងអ្វីទៀត ។

ទ្រង់ប្រារព្ធកថាថា ទេវទត្តជាបុគ្គលអកតញ្ញូ ទើបត្រាស់ជាតកទាំងឡាយជាដើមទៀតថា

សត្វត្រសេះពោលថា កម្លាំងណារបស់យើងមានហើយ យើងធ្វើកិច្ចដល់អ្នកតាមកម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក យើងត្រូវបានសាច់បន្តិចបន្តួចខ្លះ ។

រាជសីហ៍ឆ្លើយតបថា អ្នកឯងចូលទៅតាមចន្លោះនៃធ្មេញ របស់ខ្ញុំដែលជាអ្នកស៊ី ( សាច់ ) និងឈាម ធ្វើនូវអំពើអាក្រក់ទាំង-ឡាយជានិច្ច រស់នៅ ដោយសាច់ណា សាច់នោះមានច្រើន ។

ទ្រង់ប្រារព្ធការខ្វល់ខ្វាយដើម្បីសម្លាប់ព្រះអង្គ របស់ទេវទត្តភិក្ខុនោះទៀត ត្រាស់ជាតកទាំងឡាយជាដើមថា

ប្រើសពោធិសត្វពោលថា ម្នាលដើមចំបក់ អ្នកជម្រុះផ្លែមក
ដោយហេតុណា ហេតុនុ៎ះ អញជាប្រើសបានដឹងហើយ អញនឹង
ទៅកាន់ដើមចំបក់ឯទៀត ផ្លែរបស់អ្នកអញមិនពេញចិត្តទេ ។

កាលកថានៅប្រព្រឹត្តទៅទៀតថា ទេវទត្តវិនាសចាកផលពីរប្រការ គឺចាកលាភ និងសក្ការៈ ១ ចាកសមញ្ញផល ១ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីកាលមុនទេវទត្តក៏វិនាសហើយដូចគ្នា ដូច្នេះហើយ ត្រាស់ជាតកទាំងឡាយជាដើមថា

រុក្ខទេវតាពោធិសត្វពោលថា ក្អែកទាំងឡាយបែកធ្លាយហើយ
សំពត់បាត់ហើយ ការឈ្លោះក៏មានក្នុងផ្ទះនៃស្ត្រីជាសម្លាញ់ ការងារ
ទាំងឡាយខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង ។

ព្រះសាស្តាកាលប្រថាប់នៅក្រុងរាជគ្រឹះ ទ្រង់ប្រារព្ធទេវទត្តត្រាស់ជាតកជាច្រើនដោយប្រការយ៉ាងនេះហើយ ទ្រង់ចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងសាវត្ថី ប្រថាប់នៅក្នុងជេតពនមហាវិហារ ។

ចំណែកទេវទត្ត មានជំងឺអស់ ៩ ខែ ក្នុងកាលចុងក្រោយ ប្រាថ្នានឹងគាល់ព្រះសាស្តា ទើបប្រាប់សាវ័ករបស់ខ្លួនថា ខ្ញុំនឹងគាល់ព្រះសាស្តា អ្នកទាំងឡាយ ចូរបង្ហាញព្រះសាស្តានោះដល់ខ្ញុំចុះ កាលសាវ័កទាំងនោះឆ្លើយថា លោកម្ចាស់ក្នុងកាលដែលអាចប្រព្រឹត្តជាបុគ្គលមានពៀរ ជាមួយព្រះសាស្តា

យើងខ្ញុំមិនអាចនាំលោកម្ចាស់ ទៅក្នុងទីដែលព្រះសាស្តាគង់នៅបានឡើយ ទើបពោលថា អ្នកទាំងឡាយ កុំធ្វើឲ្យខ្ញុំវិនាសឡើយ ខ្ញុំធ្វើអាឃាតក្នុងព្រះសាស្តា តែសម្រាប់ព្រះសាស្តា មិនមានការអាឃាតក្នុងខ្ញុំ សូម្បីមានប្រមាណប៉ុនចុងសក់ឡើយ ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះ

ទ្រង់មានព្រះហឫទ័យស្មើ ក្នុងបុគ្គលទូទៅ គឺក្នុងនាយខ្មាន់ធ្នូ ក្នុង
ទេវទត្ត ក្នុងអង្គុលិមាលចោរ ក្នុងដំរីធនបាល និងក្នុងព្រះរាហុល ។

ព្រោះដូច្នោះ ទើបទេវទត្តអង្វរហើយអង្វរទៀតថា សូមអ្នកទាំងឡាយបង្ហាញព្រះដ៏មានព្រះភាគដល់ខ្ញុំ ។ ពេលនោះ សាវ័កទាំងនោះ នាំទេវទត្តនោះចេញទៅដោយគ្រែតូច ភិក្ខុទាំងឡាយ បានដំណឹងអំពីការមក របស់ទេវទត្តនោះ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ បានឮថា ទេវទត្តមកដើម្បីប្រយោជន៍គាល់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តនោះមិនបានឃើញតថាគតដោយអត្តភាពនោះ បានឮថា ទេវទត្តរមែងមិនបានឃើញព្រះពុទ្ធអង្គទៀត ចាប់តាំងអំពីកាលដែលសូមវត្ថុ ៥ ប្រការ សេចក្តីនេះរមែងជាធម្មតា ពួកភិក្ខុក្រាបទូលថា ទេវទត្តមកដល់ទីនោះ និងទីនោះហើយ ព្រះសាស្តាត្រាស់ថា ទេវទត្តចូរធ្វើវត្ថុដែលខ្លួនប្រាថ្នាចុះ តែទោះជាយ៉ាងណា ក៏ទេវទត្តមិនបានឃើញតថាគត ភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ទេវទត្តមកដល់ទីប្រមាណមួយប្រយោជន៍អំពីទីនេះហើយ ហើយទូលបន្តៗ ទៀតថា មកដល់កន្លះយោជន៍ហើយ មួយគាវុតហើយ មកដល់ជិតស្រះបោក្ខរណីហើយ ព្រះសាស្តាត្រាស់ថា សូម្បីទេវទត្តចូលមកខាងក្នុងវត្ត

ជេតពន ក៏មិនបានឃើញតថាគតពិត ។

ពួកសាវកនាំទេវទត្តមក ដាក់គ្រែត្រង់ប្រាំងស្រះបោក្ខរណីជិតវត្តជេតពន ហើយក៏ចុះទៅដើម្បីងូតទឹកក្នុងស្រះបោក្ខរណី សូម្បីទេវទត្តក្រោកអំពីគ្រែ ហើយអង្គុយដាក់ជើងទាំងពីលើផែនដី ជើងទាំងពីរនោះក៏លិចចុះក្នុងផែនដី លោកលិចចុះហើយដោយលំដាប់ត្រឹមកជើង ត្រឹមជង្គង់ ត្រឹមចង្កេះ ត្រឹមដោះ រហូតត្រឹម-ក ក្នុងកាលដែលឆ្អឹងចង្កាប៉ះផែនដី បានពោលគាថានេះថា

**ឥមេហិ អដ្ឋីហិ តមគ្គបុគ្គលំ ទេវាតិទេវំ នរទម្មសារថឹ**
**សមន្តចក្ខុំ សតបុញ្ញលក្ខណំ បាណេហិ ពុទ្ធំ សរណំ គតោស្មីតិ ។**

ខ្ញុំសូមដល់ព្រះពុទ្ធ ជាបុគ្គលដ៏ប្រសើរ ជាទេវតានៃទេវតា ជាសារថីនៃបុគ្គលដែលគួរទូន្មាន មានព្រះចក្ខុឃើញដោយជុំវិញ ទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយ ថាជាទីពឹងដោយឆ្អឹងទាំងឡាយ និងខ្យល់ដង្ហើមនេះ ដូច្នេះ ។

បានឮថា ព្រះតថាគតទ្រង់ឃើញឋានៈនេះ ទើបឲ្យទេវទត្តបួស បើទេវទត្តនោះមិនបានបួសសោត ជាគ្រហស្ថនឹងធ្វើកម្មដ៏ធ្ងន់ មិនអាចធ្វើបច្ច័យនៃភពតទៅ កាលបួសហើយ ទោះធ្វើកម្មធ្ងន់ក៏ពិត ក៏អាចធ្វើបច្ច័យនៃភពតទៅបាន ព្រោះដូច្នោះ ទើបព្រះសាស្តាឲ្យទេវទត្តបួសហើយ ។

ពិតហើយ ទេវទត្តនោះ នឹងបានជាព្រះបច្ចេកពុទ្ធ ព្រះនាមអដ្ឋិស្សរៈ ក្នុងទីបំផុតនៃមួយសែនកប្បអំពីកប្បនេះ ទេវទត្តនោះ លិចក្នុងដីទៅហើយ កើតក្នុងអវីចី លោកជាអ្នកកម្រើកមិនបាន ត្រូវភ្លើងឆេះព្រោះជាអ្នកខុសក្នុង

ព្រះពុទ្ធដែលមិនញាប់ញ័រ សរីរៈរបស់លោកកម្ពស់ប្រមាណមួយរយយោជន៍ កើតក្នុងរណ្ដៅអវិចីដែលមានប្រមាណ ៣០០ យោជន៍ ក្បាលស៊កចូលទៅក្នុងផែនដីដែក ខាងលើដល់គុម្ពត្រចៀក ជើងទាំងពីរលិចក្នុងផែនដីដែក ខាងក្រោមត្រឹមកជើង ដែកស្រួចមានប្រមាណប៉ុនដើមត្នោតធំ ចេញអំពីជញ្ជាំងខាងក្រោយ ចាក់ទម្លុះខ្នងធ្លុះទៅខាងមុខ ដោតជាប់នឹងជញ្ជាំងខាងមុខ ដែកស្រួចមួយទៀត ចេញអំពីជញ្ជាំងខាងស្ដាំ ទម្លុះឆ្អឹងជំនីរស្ដាំធ្លុះទៅឆ្អឹងជំនីរឆ្វេង ដោតជាប់ជញ្ជាំងខាងឆ្វេង ដែកស្រួចមួយទៀត ចេញអំពីជញ្ជាំងខាងលើទម្លុះក្បាល ធ្លុះចេញទៅខាងក្រោម ដោតជាប់នឹងផែនដីដែក ទេវទត្តនោះជាអ្នកកម្រើកមិនបាន ត្រូវភ្លើងឆេះក្នុងអវិចីនោះ ដោយប្រការយ៉ាងនេះ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាថា ទេវទត្តដល់នូវឋានៈមានប្រមាណប៉ុណ្ណោះ មិនទាន់បានគាល់ព្រះសាស្ដា ត្រូវលិចចុះកាន់ផែនដីហើយ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តប្រព្រឹត្តខុសក្នុងតថាគតរហូតលិចចុះក្នុងដីក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន ក្នុងកាលមុនទេវទត្តក៏លិចចុះហើយដូចគ្នា ដើម្បីទ្រង់សម្ដែងភាពដែលបុរសវង្វេងផ្លូវ ត្រូវព្រះអង្គលួងលោមហើយ លើកឡើងដាក់លើខ្នងរបស់ខ្លួន នាំដល់ទីក្សេមហើយ បែរជាកាត់ភ្លុកទាំងឡាយអស់ ៣ ដងយ៉ាងនេះ គឺត្រង់ចុង ត្រង់កណ្ដាល ត្រង់គល់ ក្នុងវារៈទីបីកាលដើរផុតគន្លងចក្ខុនៃមហាបុរសហើយ ក៏លិចចុះក្នុងផែនដីក្នុងកាលដែលទ្រង់ជាស្ដេចដំរី ទើបត្រាស់ជាតកនេះជាដើមថា

រុក្ខទេវតាពោលថា ប្រសិនបើគេឲ្យផែនដីទាំងមូល ដល់បុរស

អកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញុំាងបុរសអកតញ្ញូ នោះ ឲ្យត្រេកអរបានឡើយ ។

កាលកថាតាំងឡើងហើយដូច្នោះឯងទៀត ទើបត្រាស់ខន្តិវាទិជាតកដើម្បីសម្តែងភាពដែលទេវទត្តនោះ កាលនៅជាព្រះបាទកលាបុ ប្រព្រឹត្តខុសក្នុងព្រះអង្គដែលជាខន្តិវាទីតាបស ហើយលិចចុះកាន់ផែនដី និងចុល្លធម្មបាល-ជាតក ដើម្បីទ្រង់សម្តែងភាពដែលទេវទត្តនោះ កាលជាព្រះបាទមហាបតាបៈ ប្រព្រឹត្តខុសក្នុងព្រះអង្គជាចុល្លធម្មបាល ហើយលិចចុះក្នុងផែនដី កាលទេវទត្តធរណីស្រូបហើយ មហាជនត្រេកអរ លើកទង់ជ័យ ទង់ជ្វាលា និងដើមចេកតម្កល់ក្អមទឹកពេញហើយ ប្រគំមហោស្រពធំ ដោយប្រាថ្នាថា ជាលាភរបស់ពួកយើងហ្ន៎ ។ ពួកភិក្ខុក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលទេវទត្តស្លាប់ហើយ មហាជនត្រេកអរមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ក្នុងកាលមុន ក៏ត្រេកអរហើយដូចគ្នា ។ ដើម្បីសម្តែងភាពដែលមហាជនត្រេកអរក្នុងកាលព្រះរាជាព្រះនាមបិង្គលៈ ក្នុងនគរពារាណសី ដែលជាស្តេចកាចឃោរឃៅ មិនជាទីស្រឡាញ់របស់ជនទូទៅសោយទិវង្គតហើយ ទើបត្រាស់បិង្គលជាតកនេះថា

ព្រះពោធិសត្វពោលថា ជនទាំងអស់ត្រូវស្តេចបិង្គលៈបៀតបៀនហើយ កាលស្តេចនោះ សោយទិវង្គតហើយ ជនទាំងឡាយ រមែងបាននូវសេចក្តីត្រេកអរ ម្នាលទ្វារបាល ស្តេចអកណ្ហនេត្រ ជាទីស្រឡាញ់របស់អ្នកឬ ព្រោះហេតុអ្វី បានជាអ្នកយំ ។

ទ្វារបាលបុរសពោលថា ស្តេចអកណ្ហនេត្រ មិនមែនជាទីស្រឡាញ់របស់ខ្ញុំទេ ខ្ញុំខ្លាចស្តេចនោះត្រឡប់មកវិញ ( ព្រោះស្តេចនោះ ) ទៅអំពីមនុស្សលោកនេះ គប្បីបៀតបៀនទូវមច្ចុរាជ មច្ចុរាជនោះក្រែងត្រូវស្តេចបិត្តលៈបៀតបៀនហើយ គប្បីនាំមកទុកក្នុងមនុស្សលោកនេះវិញ ។

ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះទេវទត្តកើតហើយក្នុងទីណា ព្រះសាស្តាត្រាស់ថា ក្នុងអវីចីមហានរក ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តប្រព្រឹត្តក្តៅក្រហាយក្នុងលោកនេះហើយ ទៅកើតក្នុងទីដែលក្តៅក្រហាយនោះទៀតឬ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ជនទាំងឡាយជាបព្វជិតក្តី ជាគ្រហស្ថក្តី មានប្រក្រតីនៅដោយសេចក្តីប្រមាទ រមែងក្តៅក្រហាយក្នុងលោកទាំងពីរនោះឯង ដូច្នេះហើយ ត្រាស់គាថានេះថា

**៩៨ តប្បតិ បេច្ច តប្បតិ ចាបការី ឧភយត្ថ តប្បតិ**
**ចាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។**

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្តៅក្រហាយ ក្នុងលោកនេះ ១ ក្តៅក្រហាយ ក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយដោយគិតឃើញថា បាបអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់ទុគ្គតិ ក៏រឹងរឹតតែក្តៅក្រហាយដ៏ក្រៃលែង ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ឥធ តប្បតិ** សេចក្តីថា រមែងក្តៅក្រហាយក្នុងលោកនេះ ដោយហេតុត្រឹមតែទោមនស្ស ដោយការក្តៅក្រហាយព្រោះកម្ម ។

បទថា **បេច្ច** សេចក្តីថា ចំណែកក្នុងលោកខាងមុខ រមែងក្តៅក្រហាយព្រោះទុក្ខក្នុងអបាយដ៏ខ្លាំងក្លាក្រៃលែង ដោយការក្តៅក្រហាយព្រោះវិបាក ។

បទថា **បាបការី** សេចក្តីថា អ្នកធ្វើបាបមានប្រការផ្សេងៗ ។

បទថា **ឧភយត្ថ** សេចក្តីថា ឈ្មោះថា រមែងក្តៅក្រហាយក្នុងលោកទាំងពីរ ដោយការក្តៅក្រហាយ មានប្រការដូចពោលហើយ ។

ពីរបទថា **បាបំ មេ** សេចក្តីថា អ្នកមានប្រក្រតីធ្វើបាបនោះ កាលក្តៅក្រហាយដោយការក្តៅក្រហាយព្រោះកម្ម ឈ្មោះថា រមែងក្តៅក្រហាយដោយគិតថា កម្មអាក្រក់អញធ្វើហើយ នោះជាការក្តៅក្រហាយមានប្រមាណតិចតួច តែកាលក្តៅក្រហាយដោយការក្តៅក្រហាយព្រោះវិបាក ឈ្មោះថាទៅកាន់ទុគ្គតិ រមែងក្តៅក្រហាយក្រៃលែងឡើង គឺរមែងក្តៅក្រហាយពន់ពេកដោយការក្តៅក្រហាយដ៏ទារុណក្រៃលែង ។

ក្នុងកាលចប់គាថា មហាជនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើមហើយ ទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។៙

**រឿងទេវទត្ត ចប់**

# រឿង នាងសុមនាទេវី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងសុមនាទេវី ត្រាស់ព្រះធម្មទេសនានេះថា **ឥធ នន្ទតិ បេច្ច នន្ទតិ** ជាដើម ។

សេចក្ដីពិស្ដារថា ភិក្ខុ ២ ពាន់រូប តែងឆាន់ក្នុងផ្ទះរបស់អនាថបិណ្ឌិក-សេដ្ឋី ក្នុងក្រុងសាវត្ថីរាល់ថ្ងៃ ក្នុងផ្ទះរបស់នាងវិសាខាមហាឧបាសិកា ក៏ដូចគ្នា ។ បុគ្គលណាម្នាក់ក្នុងក្រុងសាវត្ថី ជាអ្នកបំណងនឹងថ្វាយទាន បុគ្គលនោះៗ ត្រូវបានឱកាសរបស់ជនទាំងពីរនោះមុនហើយ ទើបធ្វើបាន ។

សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះបុគ្គលដទៃៗ សួរថា អនាថ-បិណ្ឌិកសេដ្ឋី ឬនាងវិសាខាមកកាន់រោងទានរបស់អ្នកហើយឬ កាលជននោះឆ្លើយថា មិនបានមក រមែងតិះដៀល ទោះបីបុគ្គលនោះលះទ្រព្យរាប់សែនហើយធ្វើ ក៏អ្នកស្រុកនៅតែពោលថា នេះឈ្មោះថា ទានអ្វី ព្រោះលោកទាំងពីរនោះ រមែងដឹងការគាប់ចិត្តរបស់ភិក្ខុសង្ឃ និងកិច្ចដែលសមគួរដល់ភិក្ខុសង្ឃ ។ កាលលោកទាំងពីរនោះ នៅក្នុងទីនោះ ពួកភិក្ខុរមែងឆាន់បានតាមពេញចិត្តនោះឯង ព្រោះដូច្នោះបុគ្គលគ្រប់គ្នា បំណងនឹងថ្វាយទាន ទើបអញ្ជើញជនទាំងពីរនោះទៅ ។ ជនទាំងពីរនោះរមែងមិនបានអង្គាសភិក្ខុទាំងឡាយក្នុងផ្ទះរបស់ខ្លួនដោយហេតុនេះ ព្រោះហេតុនោះ នាងវិសាខា កាលពិចារណាថា នរណាហ្ន៎នឹងតាំងនៅក្នុងកិច្ចរបស់អញ អង្គាសភិក្ខុសង្ឃ ឃើញចៅស្រីហើយទើបតាំងទុកក្នុងនាទីរបស់ខ្លួន នាងអង្គាសភិក្ខុសង្ឃក្នុងផ្ទះរបស់នាងវិសាខានោះ ។

សូម្បីអនាថបិណ្ឌិកសេដ្ឋី ក៏តាំងកូនស្រីច្បងឈ្មោះមហាសុភទ្ទា ។ នាងមហាសុភទ្ទានោះ ធ្វើការខ្វល់ខ្វាយដល់ភិក្ខុទាំងឡាយ និងស្តាប់ធម៌បានជាព្រះសោតាបន្នហើយ ទៅកាន់ត្រកូលស្វាមី ។

បន្ទាប់អំពីនោះ អនាថបិណ្ឌិកក៏តាំងនាងចូឡសុភទ្ទាជំនួស ។ សូម្បីនាងចូឡសុភទ្ទានោះ ក៏ធ្វើយ៉ាងនោះដូចគ្នា ជាព្រះសោតាបន្នហើយ ក៏ទៅកាន់ត្រកូលនៃស្វាមី ។ លំដាប់នោះ ទើបអនាថបិណ្ឌិកតាំងធីតាពៅឈ្មោះសុមនាទេវីជំនួស ។

នាងសុមនាទេវីនោះ ស្តាប់ធម៌ហើយសម្រេចសកទាគាមិផល ទាំងនៅជាកុមារិកានោះឯង រសាប់រសល់ដោយការមិនផាសុកបែបនោះ កាត់អាហារមានបំណងនឹងឃើញបិតា ទើបឲ្យអញ្ជើញមក ។ លោកសេដ្ឋី លុះបានឮដំណឹងរបស់កូនស្រីក្នុងរោងទានមួយកន្លែង ក៏មករកហើយនិយាយថា នែសុមនា នាងកើតអ្វីឬ នាងសុមនាឆ្លើយថា មិនជាការប្តីទេប្អូនប្រុស បិតាសួរថា នាងវង្វេងវង្វាយហើយឬ សុមនាឆ្លើយថា មិនវង្វេងវង្វាយទេប្អូនប្រុស បិតាពោលថា នាងខ្លាចឬ ធីតាឆ្លើយថា មិនខ្លាចទេប្អូនប្រុស លុះនាងសុមនាទេវីពោលបានប៉ុណ្ណេះ ក៏ធ្វើកាលកិរិយាហើយ ។

លោកសេដ្ឋីនោះ សូម្បីជាព្រះសោតាបន្ន ក៏មិនអាចអត់សង្កត់សេចក្តីសោកដែលកើតក្នុងធីតាបាន ធ្វើការបូជាសពធីតាស្រេចហើយ ទ្រហោយំទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលគហបតី ហេតុអ្វីទើបអ្នកជាទុក្ខទោមនស្ស មានមុខជោកដោយទឹកភ្នែកមកហើយ ទើប

ក្រាបទូលថា បពិត្រព្រះអង្គ នាងសុមនាទេវីកូនស្រីរបស់ខ្ញុំព្រះអង្គ ធ្វើកាលកិរិយាហើយ ។ ព្រះសាស្តាត្រាស់ថា បើដូច្នោះ ហេតុអ្វីទើបអ្នកសោយសោក សេចក្តីស្លាប់រមែងប្រព្រឹត្តទៅដោយចំណែកមួយ ដល់សព្វសត្វមិនមែនឬ ។ អនាថបិណ្ឌិកឆ្លើយថា បពិត្រព្រះអង្គ សេចក្តីនោះខ្ញុំព្រះអង្គជ្រាបហើយ តែធីតារបស់ខ្ញុំព្រះអង្គដល់ព្រមដោយហិរិ និងឱត្តប្បៈបែបនេះ ក្នុងវេលាទៀបស្លាប់ នាងមិនអាចគ្រប់គ្រងសតិបានឡើយ រវើរវាយស្លាប់ទៅហើយ ដោយហេតុនោះ ទោមនស្សមិនមែនតិច កើតដល់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី នាងនិយាយអ្វីខ្លះ ។ អនាថបិណ្ឌិកសេដ្ឋីពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គហៅនាងថា នាងកើតអ្វីឬ ពេលនោះនាងក៏ពោលនឹងខ្ញុំព្រះអង្គថា មិនជាការប៉ើឡើយប្អូនប្រុស បន្ទាប់អំពីនោះ កាលខ្ញុំព្រះអង្គពោលថា នាងរវើរវាយឬ ក៏ឆ្លើយថា មិនរវើរវាយទេប្អូនប្រុស កាលខ្ញុំព្រះអង្គសួរថា នាងខ្លាចឬ ក៏ឆ្លើយថា មិនខ្លាចទេប្អូនប្រុស លុះពោលបានត្រឹមណេះ ក៏ធ្វើកាលកិរិយាហើយ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់នឹងសេដ្ឋីនោះថា ម្នាលគហបតី កូនស្រីរបស់អ្នកមិនមែនរវើរវាយឡើយ ។ អនាថបិណ្ឌិកសេដ្ឋីពោលថា ហេតុអ្វីទើបនាងពោលយ៉ាងនោះ ។ ព្រះសាស្តាត្រាស់ថា ព្រោះអ្នកជាប្អូនប្រុសរបស់នាងពិត ។ ម្នាលគហបតី កូនស្រីរបស់អ្នកជាធំជាងអ្នកដោយមគ្គ និងផល ព្រោះអ្នកត្រឹមតែជាសោតាបន្ន ចំណែកធីតារបស់អ្នក ជាសកទាគាមី ព្រោះនាងជាធំដោយមគ្គ និងផល ទើបនាងពោលយ៉ាងនោះ ។ អនាថបិណ្ឌិក-

សេដ្ឋីពោលថា យ៉ាងនោះឬព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលគហបតី យ៉ាងនោះឯង ។ អនាថបិណ្ឌិកសេដ្ឋីពោលថា ពេលនេះ នាងកើតក្នុងទីណា ព្រះអង្គ ។ កាលព្រះសាស្តាត្រាស់ថា ម្នាលគហបតី ក្នុងស្ថានតុសិត ទើបលោកសេដ្ឋីទូលថា កូនស្រីរបស់ខ្ញុំព្រះអង្គត្រេកអរក្នុងពួកញាតិ ក្នុងលោកនេះ សូម្បីទៅអំពីលោកនេះហើយ កើតក្នុងទីដែលត្រេកអរដូចគ្នាឬ ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងសេដ្ឋីនោះថា ម្នាលគហបតី ធម្មតាបុគ្គលមិនប្រមាទ ជាគ្រហស្ថក្តី ជាបព្វជិតក្តី រមែងត្រេកអរក្នុងលោកនេះ និងលោកខាងមុខពិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**៩៨ ឥធ នន្ទតិ បេច្ច នន្ទតិ កតបុញ្ញោ ឧភយត្ថ នន្ទតិ**
**បុញ្ញំ មេ កតន្តិ នន្ទតិ ភិយ្យោ នន្ទតិ សុគតឹ គតោ ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងត្រេកអរក្នុងលោកទាំងពីរ គឺត្រេកអរក្នុងលោកនេះ ១ ត្រេកអរក្នុងលោកខាងមុខ ១ បុគ្គលនោះរមែងត្រេកអរដោយគិតឃើញថា បុណ្យអញបានធ្វើហើយ លុះធ្វើមរណកាលទៅកាន់សុគតិ ក៏រឹងរឹតតែត្រេកអរដ៏ក្រៃលែង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឥធ** សេចក្តីថា រមែងត្រេកអរក្នុងលោកនេះ ដោយការត្រេកអរព្រោះកម្ម ។

បទថា **បេច្ច** សេចក្តីថា រមែងត្រេកអរក្នុងលោកខាងមុខ ដោយការត្រេកអរព្រោះវិបាក ។

បទថា **កតបុញ្ញោ** គឺធ្វើបុណ្យ មានប្រការផ្សេងៗ ។

បទថា **ឧភយត្ថ** សេចក្តីថា រមែងត្រេកអរក្នុងលោកនេះ ដោយគិតថា កុសលអញធ្វើហើយ បាបអញមិនបានធ្វើ កាលសោយវិបាក ឈ្មោះថា រមែងត្រេកអរក្នុងលោកខាងមុខ ។

ពីរបទថា **បុញ្ញំ មេ** សេចក្តីថា កាលត្រេកអរក្នុងលោកនេះ ឈ្មោះថា រមែងត្រេកអរ ព្រោះអាស្រ័យការត្រេកអរព្រោះកម្ម ដោយហេតុត្រឹមសោមនស្សប៉ុណ្ណោះថា បុណ្យអញធ្វើហើយ ។

បទថា **ភិយ្យោ** ជាដើម សេចក្តីថា បុគ្គលនោះទៅកាន់សុគតិហើយ កាលសោយទិព្វសម្បត្តិអស់ ៥៧ កោដិ ៦០ សែនឆ្នាំខ្លះ ឈ្មោះថា ត្រេកអរយ៉ាងក្រៃលែងក្នុងតុសិតបុរី ដោយការត្រេកអរ ព្រោះវិបាក ។

ក្នុងកាលចប់គាថា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្ន ជាដើម ហើយព្រះធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។៚

**រឿង នាងសុមនាទេវី ចប់**

# រឿង ភិក្ខុជាសម្លាញ់នឹងគ្នាពីរនាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុពីររូបដែលជាសម្លាញ់នឹងគ្នា ត្រាស់ព្រះធម្មទេសនានេះថា **ពហុម្បិ ចេ ហសិតំ**

**ភាសមានោ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា កុលបុត្រពីរនាក់ដែលជាអ្នកក្រុងសាវត្ថី ជាសម្លាញ់នឹងគ្នាទៅកាន់វិហារ ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ហើយលះកាមទាំងឡាយ ថ្វាយជីវិតក្នុងព្រះសាសនារបស់ព្រះសាស្ដា បួសហើយនៅក្នុងសម្នាក់អាចារ្យ និងឧបជ្ឈាយ៍គ្រប់ ៥ ឆ្នាំហើយ ចូលទៅគាល់ព្រះសាស្ដាទូលសួរដល់ធុរៈក្នុងសាសនា បានស្ដាប់វិបស្សនាធុរៈ និងគន្ថធុរៈដោយពិស្ដារហើយ ១ រូបក្រាបទូលមុនថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបួសហើយ ក្នុងកាលឯចាស់ មិនអាចបំពេញធុរៈបាន តែបំពេញវិបស្សនាធុរៈបាន ដូច្នេះហើយ ទូលឲ្យព្រះសាស្ដាត្រាស់ប្រាប់វិបស្សនារហូតដល់អរហត្ត ហើយព្យាយាមសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។

ចំណែកសម្លាញ់មួយអង្គទៀតគិតថា អញនឹងបំពេញគន្ថធុរៈ ដូច្នេះហើយរៀនព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដោយលំដាប់ ពោលធម៌សូធ្យសរភញ្ញក្នុងទីដែលខ្លួនទៅហើយ ប្រាប់ធម៌ដល់ភិក្ខុ ៥០០ បានជាអាចារ្យរបស់មហាគណៈ ១៨ គណៈ ។

ភិក្ខុទាំងឡាយ រៀនព្រះកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាហើយ ទៅកាន់លំនៅរបស់ព្រះថេរៈក្រៅអំពីនេះ គឺព្រះថេរៈដែលបំពេញវិបស្សនា តាំងនៅក្នុងឱវាទរបស់លោក សម្រេចអរហត្តហើយ នមស្ការព្រះថេរៈ ប្រាប់ថាយើងខ្ញុំប្រាថ្នានឹងគាល់ព្រះសាស្ដា ។

ព្រះថេរៈពោលថា នែអាវុសោ អ្នកទាំងឡាយចូរទៅចុះ ចូរថ្វាយបង្គំ

ព្រះសាស្ដា នមស្ការព្រះមហាថេរៈទាំង ៨០ រូប តាមពាក្យរបស់ខ្ញុំ ចូរប្រាប់សម្លាញ់របស់ខ្ញុំថា លោកអាចារ្យរបស់យើងខ្ញុំនមស្ការលោកម្ចាស់ ដូច្នេះហើយបញ្ជូនទៅ ។ ភិក្ខុទាំងនោះទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្ដា នមស្ការព្រះអសីតិមហាថេរៈហើយ ទៅកាន់សម្នាក់ព្រះគន្ថិកត្ថេរប្រាប់ថា បពិត្រលោកម្ចាស់ លោកអាចារ្យរបស់ពួកខ្ញុំនមស្ការដល់លោកម្ចាស់ កាលព្រះថេរៈសួរថា លោកអាចារ្យរបស់ពួកអ្នកនោះជាអ្នកណា ភិក្ខុទាំងនោះប្រាប់ថា ជាសម្លាញ់របស់លោកម្ចាស់ ។

កាលព្រះថេរៈបញ្ជូនដំណឹងសួរសុខទុក្ខនេះរឿយៗ ភិក្ខុនោះអត់ធន់បានអស់កាលតិចតួច ក្រោយមកមិនអាចអត់ធន់បាន កាលពួកអាគន្តុកភិក្ខុប្រាប់ថា លោកអាចារ្យរបស់ពួកខ្ញុំនមស្ការលោកម្ចាស់ ដូច្នេះហើយ ទើបពោលថា អាចារ្យរបស់ពួកអ្នកជាអ្នកណា ភិក្ខុទាំងឡាយប្រាប់ថា ជាសម្លាញ់របស់លោកម្ចាស់ ទើបពោលថា នេះអ្វីហ្ន៎ ដែលពួកអ្នករៀនក្នុងសម្នាក់របស់ភិក្ខុនោះ បណ្ដានិកាយ មានទីឃនិកាយជាដើម និកាយណាមួយលោកចេះឬ បណ្ដាបិដក ៣ បិដកណាមួយ លោកចេះឬ ពួកអ្នកបានហើយឬ ដូច្នេះហើយ គិតថា សម្លាញ់របស់អញរមែងមិនចេះសូម្បីគាថា ប្រកបដោយបទ ៤ សមាទានបង្សុកូលក្នុងព្រៃ តាំងអំពីបួសហើយ គង់បានអន្តេវាសិកច្រើនហ្ន៎ ក្នុងកាលដែលលោកមក អញគួរសួរបញ្ហាល្បងមើល ។

សម័យក្រោយមក ព្រះថេរៈវិបស្សកៈ បានមកគាល់ព្រះសាស្ដា ទុកដាក់បាត្រ និងចីវរក្នុងសម្នាក់ព្រះថេរៈជាសម្លាញ់ហើយ ទៅថ្វាយបង្គំព្រះ

សាស្តា និងនមស្ការព្រះអសីតិ និងមហាថេរៈហើយ ក៏ត្រឡប់មកលំនៅរបស់ព្រះថេរៈដែលជាសម្លាញ់ លំដាប់នោះ ព្រះគន្ថិកត្ថេរឲ្យភិក្ខុទាំងឡាយធ្វើវត្តដល់លោក ហើយកាន់យកអាសនៈសមគួរប៉ុណ្ណោះ អង្គុយហើយដោយតាំងចិត្តថា នឹងសួរប្រស្នា ។

ខណៈនោះ ព្រះសាស្តាទ្រង់ជ្រាបថា គន្ថិកភិក្ខុនេះគប្បីបៀតបៀនបុត្រតថាគត ដែលមានសភាពបែបនេះ ហើយកើតក្នុងនរក ដោយទ្រង់ករុណាទ្រង់ធ្វើហាក់ដូចចារិកទៅក្នុងវិហារ យាងដល់ទីដែលភិក្ខុទាំងពីរគង់ហើយប្រថាប់គង់លើពុទ្ធាសនៈដែលគេរៀបចំ ។ ពិតហើយ ភិក្ខុទាំងឡាយកាលអង្គុយក្នុងទីនោះៗ រៀបចំអាសនៈសម្រាប់ព្រះពុទ្ធមុនហើយទើបគង់ ។ ព្រោះហេតុនោះ ទើបព្រះសាស្តាប្រថាប់គង់លើអាសនៈដែលព្រះគន្ថិកភិក្ខុនោះរៀបចំដោយប្រក្រតីនោះឯង ។ កាលប្រថាប់គង់ហើយ ទើបត្រាស់សួរបញ្ហាក្នុងបឋមជ្ឈានដល់ព្រះគន្ថិកភិក្ខុ កាលលោកទូលតបមិនបាន ទើបត្រាស់សួរបញ្ហាក្នុងរូបសមាបត្តិ និងអរូបសមាបត្តិទាំង ៨ តាំងអំពីទុតិយជ្ឈានជាដើមទៅ ព្រះគន្ថិកត្ថេរក៏មិនអាចឆ្លើយបាន សូម្បីត្រឹមតែមួយប្រស្នា ។ ព្រះវិបស្សកត្ថេរទូលតបបញ្ហានោះបានទាំងអស់ ។

ពេលនោះ ព្រះសាស្តាត្រាស់សួរបញ្ហាក្នុងសោតាបត្តិមគ្គ ព្រះគន្ថិកត្ថេរក៏មិនអាចទូលឆ្លើយបាន បន្ទាប់អំពីនោះ ទើបត្រាស់សួរព្រះខីណាស្រព ព្រះថេរៈក៏ឆ្លើយបាន ។

ព្រះសាស្តាទ្រង់សរសើរថា សាធុ សាធុ ហើយត្រាស់សួរបញ្ហាក្នុងមគ្គ

ដ៏សេសទាំងឡាយដោយលំដាប់ ព្រះគន្ថិកត្ថេរក៏មិនអាចទូលឆ្លើយបញ្ហាបាន សូម្បីត្រឹមតែមួយ ចំណែកព្រះវិណាស្រេតឆ្លើយបញ្ហាដែលត្រាស់សួរហើយបានទាំងអស់ ។ ព្រះសាស្តាបានប្រទានសាធុការដល់ព្រះវិណាស្រេតនោះក្នុងឋានៈទាំង ៤ ។ ទេវតាទាំងឡាយ តាំងអំពីភុម្មទេវតា រហូតដល់ព្រហ្មលោក នាគក្តី គ្រុឌក្តី បានស្តាប់សាធុការនោះហើយ ក៏បានឲ្យសាធុការ ។

ពួកអន្តេវាសិក និងសទ្ធិវិហារិករបស់ព្រះគន្ថិកត្ថេរ បានស្តាប់សាធុការនោះហើយ ទើបពោលទោសព្រះសាស្តាថា ព្រះសាស្តាទ្រង់ធ្វើកម្មអ្វីដូច្នេះ ទ្រង់បានប្រទានសាធុការដល់ព្រះមហល្លកត្ថេរ ដែលមិនចេះដឹងអ្វីសោះក្នុងឋានៈទាំង ៤ ចំណែកលោកអាចារ្យរបស់ពួកយើង ដែលទ្រទ្រង់នូវព្រះបរិយត្តិធម៌បានទាំងអស់ ជាប្រធាននៃភិក្ខុប្រមាណ ៥០០ រូប ព្រះអង្គមិនបានធ្វើ សូម្បីត្រឹមតែការសរសើរ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលអ្វី កាលភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាចារ្យរបស់ពួកអ្នក ដូចអ្នករក្សាគោទាំង-ឡាយ ដើម្បីថ្លៃឈ្នួលក្នុងសាសនារបស់តថាគត ចំណែកបុត្ររបស់តថាគត ដូចម្ចាស់បរិភោគបញ្ចគោរសតាមគាប់ចិត្ត ដូច្នេះហើយ បានភាសិតព្រះគាថាទាំងឡាយថា

**ពហុម្បិ ចេ សហិតំ ភាសមានោ ន តក្ករោ ហោតិ នរោ បមត្តោ**
**គោវោវ គាវោ គណយំ បរេសំ ន ភាគវា សាមញ្ញស្ស ហោតិ**

**អប្បម្បិ ចេ សហិតំ ភាសមានោ ធម្មស្ស ហោតិ អនុធម្មចារី**
**រាគញ្ច ទោសញ្ច បហាយ មោហំ សម្មប្បជានោ សុវិមុត្តចិត្តោ**
**អនុបាទិយានោ ឥធ វា ហុរំ វា ស ភាគវា សាមញ្ញស្ស ហោតិ ។**

*បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីច្រើន តែជាអ្នកប្រមាទ មិនធ្វើតាមពាក្យនោះ រមែងជាអ្នកមិនមានចំណែកសាមញ្ញផលឡើយ ដូចអ្នករក្សាគោ កាលរាប់គោប្រគល់ឲ្យអ្នកដទៃហើយ ( ជាអ្នកមិនបានបរិភោគនូវបញ្ចគោរស ) ដូច្នោះឯង ។ បើនរជនពោលពាក្យប្រកបដោយប្រយោជន៍ សូម្បីបន្តិចបន្តួច តែជាអ្នកប្រព្រឹត្តនូវធម៌សមគួរដល់ធម៌ បានលះបង់រាគៈ ទោសៈ និងមោហៈ ជាអ្នកដឹងនូវធម៌ដែលគួរកំណត់តាមហេតុ មានចិត្តដកផុតអំពីសេចក្តីសៅហ្មង មិនមានសេចក្តីប្រកាន់មាំក្នុងលោកនេះ និងលោកខាងមុខ នរជននោះ រមែងជាអ្នកបាននូវចំណែកសាមញ្ញផល ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **សហិតំ** *នេះ ជាឈ្មោះនៃព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក នរជនចូលទៅរកអាចារ្យទាំងឡាយ រៀននូវពុទ្ធវចនៈនោះហើយ ពោល គឺប្រាប់ បានដល់ សម្តែងនូវព្រះពុទ្ធវចនៈ សូម្បីច្រើនដល់ជនដទៃ តែជាបុគ្គលដែលមិនធ្វើកិច្ច ដែលការកបុគ្គលស្តាប់ធម៌នោះហើយ គប្បីធ្វើ គឺមិនញុំាងការធ្វើទុកក្នុងចិត្តឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម សូម្បីត្រឹមតែមួយខណៈមាន់ទទេះស្លាប នរជននោះ*

រមែងជាបុគ្គលមានចំណែកនៃផល ត្រឹមតែការធ្វើវត្ត បដិវត្តអំពីសម្នាក់នៃអន្តេវាសិកទាំងឡាយតែម្យ៉ាង តែមិនជាបុគ្គលមានចំណែកនៃគុណរបស់សមណៈឡើយ ដូចអ្នកឃ្វាលគោ រក្សាគោទាំងឡាយដើម្បីថ្លៃឈ្នួលប្រចាំថ្ងៃ ទទួលទៅអំពីព្រឹក វេលាល្ងាចរាប់ប្រគល់ឲ្យដល់ម្ចាស់ទាំងឡាយ ហើយទទួលយកត្រឹមតែថ្លៃឈ្នួលប្រចាំថ្ងៃ តែមិនបានបរិភោគបញ្ចគោរសតាមគាប់ចិត្ត ដូច្នោះឯង ។

ម្ចាស់គោពួកខ្លះ រមែងបរិភោគបញ្ចគោរសនៃគោទាំងឡាយ ដែលនាយគោបាលប្រគល់ឲ្យហើយ យ៉ាងណា ការកបុគ្គលទាំងឡាយ ស្តាប់ធម៌ដែលនរជននោះពោលហើយ បដិបត្តិតាមនរជននោះប្រៀនប្រដៅហើយ ក៏ដូច្នោះ ពួកខ្លះសម្រេចបឋមជ្ឈានជាដើម ពួកខ្លះចម្រើនវិបស្សនាហើយ សម្រេចមគ្គផល រាប់ថាជាចំណែកនៃគុណរបស់សមណៈ ដូចម្ចាស់គោទាំងឡាយ រមែងជាអ្នកមានចំណែកនៃគោរស ដូច្នោះ ។ ព្រះសាស្តាត្រាស់គាថាទី ១ ដោយអំណាចនៃភិក្ខុសម្បូរដោយសីល ជាអ្នកមានសុតៈច្រើន តែមានប្រក្រតីនៅដោយការប្រមាទ មិនប្រព្រឹត្តហើយក្នុងយោនិសោមនសិការ ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម មិនមែនត្រាស់ដោយអំណាចនៃភិក្ខុទ្រុស្តសីលឡើយ ដោយប្រការដូច្នេះ ។

ចំណែកគាថាទី ២ ទ្រង់ត្រាស់ដោយអំណាចនៃការកបុគ្គល ដែលមានសុតៈតិច តែធ្វើកម្មក្នុងយោនិសោមនសិការ ។

ក្នុងបទទាំងនោះ បទថា **អប្បម្បិ** ចេ សេចក្តីថា តិច គឺសូម្បីត្រឹមមួយ

វគ្គ ឬក៏ពីរវគ្គ ។

បាទព្រះគាថាថា **ធម្មស្ស ហោតិ អនុធម្មចារី** ជាដើម សេចក្ដីថា នរជនដឹងអត្ថ ដឹងធម៌ហើយ ប្រព្រឹត្តធម៌សមគួរដល់លោកុត្តរធម៌ ៩ គឺប្រភេទនៃធម៌ មានបារិសុទ្ធិសីល ៤ ធុតង្គគុណ និងអសុភកម្មដ្ឋានជាដើម ក៏រាប់ថាជាបដិបត្តិនៃចំណែកខាងដើម រមែងជាបុគ្គលឈ្មោះថា មានប្រក្រតីប្រព្រឹត្តធម៌សមគួរ គឺសង្ឃឹមបានទូវការចាក់ធ្លុះថា អាត្មាអញនឹងចាក់ធ្លុះក្នុងថ្ងៃនេះ អាត្មាអញនឹងចាក់ធ្លុះក្នុងថ្ងៃនេះ នោះឯងឈ្មោះថា រមែងប្រព្រឹត្ត ។ នរជននោះលះរាគៈ ទោសៈ និងមោហៈដោយសម្មាបដិបទានេះហើយ កំណត់ដឹងធម៌ដែលគួរកំណត់ដឹងដោយប្រពៃ ដោយហេតុ ដោយន័យ មានចិត្តរួចផុតល្អហើយ ដោយអំណាចនៃតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិ-វិមុត្តិ និងនិស្សរណវិមុត្តិ ។ អស់ទូវការប្រកាន់មាំក្នុងលោកនេះ ឬក្នុងលោកដទៃ គឺមិនចូលទៅប្រកាន់ខន្ធ អាយតនៈ និងធាតុទាំងឡាយដែលទាក់ទងក្នុងលោកនេះ និងលោកដទៃ ឬដែលជាខាងក្នុង និងខាងក្រៅដោយ ឧបាទាន ៤ ឈ្មោះថា ជាមហាខីណាស្រព រមែងជាអ្នកមានចំណែកនៃគុណរបស់សមណៈ គឺផលដែលមកហើយដោយអំណាចនៃគុណរបស់សមណៈ ពោលគឺមគ្គ និងគុណរបស់សមណៈ គឺគំនរនៃអសេក្ខធម៌ ៥ ( គឺសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធ ) ។

*ព្រះសាស្ដាទ្រង់រួបរួមកំពូលនៃទេសនា ដោយអរហត្ត ដូចមេជាងកាន់យកកំពូលនៃផ្ទះ ដោយកំពូលកែវ ដូច្នោះ ។*

*ក្នុងកាលចប់ទេសនា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។l๛*

## រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីរនាក់ ចប់

## យមកវគ្គទី ១ ចប់

# សុត្តន្តបិដក

## ធម្មបទគាថា អប្បមាទវគ្គទី ២

[ ១២ ] សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ( ទើបស្ថិតនៅ ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម៌ជាគោចរ នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។ យសតែងចម្រើនកុះករ ដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត ( ឥតទោស ) ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។ អ្នកប្រាជ្ញគប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺកិលេសជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយការទូន្មានឥន្ទ្រិយផង ។ ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញរមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗ នូវសេចក្តីរីករាយ

ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្ដីសុខដ៏ទូលាយ ។

កាលណាបណ្ឌិត បន្ទោបង់នូវសេចក្ដីប្រមាទ ដោយសេចក្ដីមិនប្រមាទ កាលនោះ លោកនឹងឡើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ធីរជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលស្ថិតនៅលើផែនដី ដូច្នោះឯង ។

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿនដែលទៅចោលនូវសេះ មានកម្លាំងទន់ទាប ដូច្នោះឯង ។

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាងទេវតាទាំងឡាយ ព្រោះតែសេចក្ដីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយតែងសរសើរនូវសេចក្ដីមិនប្រមាទ ត្មះតិះដៀលនូវសេចក្ដីប្រមាទ សព្វៗ កាល ។ ភិក្ខុអ្នកត្រេកអរក្នុងសេចក្ដីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្ដីប្រមាទ តែងដុតចោលសំយោជនៈ ទាំងតូចទាំងធំ ដូចភ្លើងឆេះ ( រាលនូវកម្ទេចទាំងតូចទាំងធំ ) ដូច្នោះឯង ។

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្ដីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្ដីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ស្ថិតនៅក្នុងទី

ជិតនៃព្រះនិព្វាន ។

អប្បមាទវគ្គទី ២ ចប់

# អដ្ឋកថា

# អប្បមាទវគ្គ

## រឿង ព្រះនាងសាមាវតី

### លំនាំដើម

ព្រះសាស្តា កាលអាស្រ័យក្រុងកោសម្ពី ប្រថាប់នៅឃោសិតារាម ទ្រង់ប្រារព្ធមរណៈរបស់ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន និងនៃញាតិ ៥០០ របស់នាងមាគន្ទិយានោះ ដែលមាននាងមាគន្ទិយាជាប្រធាន ទើបត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទោ អមតំ បទំ** ជាដើម ក្នុងរឿងនោះ មានអនុបុព្វីកថាដូចតទៅនេះ

ក្នុងកាលកន្លងមកហើយ ព្រះរាជាពីរអង្គ គឺព្រះរាជាដែនអល្លកប្ប: ទ្រង់ព្រះនាមអល្លកប្ប: ក្នុងដែនវេដ្ឋទីបក: ព្រះនាមវេដ្ឋទីបក: ជាសម្លាញ់នឹងគ្នាតាំងអំពីកំលោះ ទ្រង់សិក្សាសិប្ប: ក្នុងសម្នាក់អាចារ្យតែមួយ ដោយព្រះរាជបិតាសោយទិវង្គតទៅរៀងៗ ខ្លួន បានលើកស្វេតឆត្រឡើងហើយ

គ្រងរាជ្យជាព្រះរាជាក្នុងដែន ក្នុងមួយដែនប្រមាណ ១០ យោជន៍ ។ ព្រះរាជាពីរអង្គនោះ យាងមកប្រជុំគ្នាសព្វកាលតាមកាល ទ្រង់ឈរ ទ្រង់អង្គុយ ទ្រង់ផ្ទំរួមគ្នា ទតមហាជនដែលកើត និងស្លាប់ ទ្រង់ប្រឹក្សាគ្នាថា ឈ្មោះថាបុគ្គល តាមគ្នាទៅកាន់បរលោកមិនមាន ដោយទីបំផុត សូម្បីសរីរៈរបស់ខ្លួនក៏យកទៅមិនបាន ត្រូវលះវត្ថុទាំងពួងទៅ ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់យើង យើងនឹងបួស ដូច្នេះហើយ ទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ព្រះរាជឱរស និងអគ្គមហេសី ចេញបួសជាឥសី នៅក្នុងហេមវន្តប្បទេស ទ្រង់ប្រឹក្សាគ្នាថា ពួកយើងមិនអាចរស់នៅ ទើបលះរាជសម្បត្តិចេញបួស ក៏មិនមែន ពួកយើងកាលនៅក្នុងទីតែមួយ ក៏ដូចអ្នកមិនបានបួសនោះឯង ព្រោះដូច្នោះ យើងនឹងបែកគ្នា អ្នកចូរនៅត្រង់ភ្នំនោះ ខ្ញុំនឹងនៅត្រង់ភ្នំនេះ តែជួបគ្នាក្នុងថ្ងៃឧបោសថ រាល់កន្លះខែ កាលនោះតាបសទាំងពីរនោះកើតសេចក្ដីត្រិះរិះឡើងយ៉ាងនេះថា កាលបើដូច្នេះ ការប្រឡូកប្រឡំដោយគណៈនឹងមានដល់យើងទាំងឡាយ អ្នកគប្បីដុតភ្លើងឲ្យឆេះឡើងត្រង់ភ្នំរបស់អ្នក ខ្ញុំក៏អុជភ្លើងឲ្យឆេះឡើងត្រង់ភ្នំរបស់ខ្ញុំ ដោយគ្រឿងសញ្ញានោះ យើងទាំងឡាយនឹងដឹងភាពដែលនៅមានជីវិត តាបសទាំងពីរនោះធ្វើយ៉ាងនោះហើយ ។

ក្នុងកាលជាខាងក្រោយ វេដ្ឋទីបកតាបសធ្វើកាលកិរិយា កើតជាទេវតាដែលមានសក្តិធំបន្ទាប់អំពីនោះ កាលដល់កន្លះខែ អល្លកប្បតាបសកាលមិនឃើញភ្លើងក៏ជ្រាបបានថា សម្លាញ់របស់អញធ្វើកាលកិរិយាហើយ ។ សូម្បីវេដ្ឋទីបក

តាបស ក្រឡេកមើលទិព្វសិរីរបស់ខ្លួនក្នុងខណៈដែលកើត ពិចារណាដល់កម្ម ឃើញកិរិយាដែលខ្លួនធ្វើតាំងអំពីចេញបួសហើយ គិតថា ឥឡូវនេះអញនឹងទៅសួរសុខទុក្ខសម្លាញ់របស់អញ ។ ក្នុងខណៈនោះ ទើបលះអត្តភាពនោះហើយ ធ្វើហាក់ដូចមនុស្សវង្វេងផ្លូវ ទៅកាន់សម្នាក់របស់អល្លកប្បតាបសនោះ ថ្វាយបង្គំហើយ បានឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង ។ លំដាប់នោះ អល្លកប្បតាបសនោះសួរបុរសនោះថា អ្នកមកអំពីណា ។ បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំជាមនុស្សវង្វេងផ្លូវ ដើរមកអំពីទីឆ្ងាយពន់ពេក ចុះលោកម្ចាស់តែមួយរូបប៉ុណ្ណោះនៅក្នុងទីនេះឬ ឬមានអ្នកណាដទៃខ្លះដែរទេ ។ តាបសពោលថា មានសម្លាញ់របស់ខ្ញុំម្នាក់ដែរ បុរសនោះសួរថា ចុះគាត់នៅឯណា ។ តាបសពោលថា គេនៅត្រង់ក្នុំនោះ តែថ្ងៃឧបោសថ គេមិនដុតភ្លើងឲ្យឆេះសោះ គេប្រហែលជាស្លាប់ហើយដោយពិត បុរសនោះឆ្លើយថា យ៉ាងនោះឬ លោកម្ចាស់ ។ តាបសពោលថា អើអ្នកយ៉ាងនោះឯង ។ បុរសនោះពោលថា ខ្ញុំគឺតាបសនោះលោកម្ចាស់ តាបសពោលថា ចុះអ្នកកើតក្នុងទីណា ។ បុរសនោះប្រាប់ថា ខ្ញុំកើតជាទេវតាមានសក្តិធំក្នុងទេវលោក មកនេះដោយបំណងថានឹងសួរសុខទុក្ខលោកម្ចាស់ តើលោកម្ចាស់នៅក្នុងទីនេះ ហេតុអាក្រក់ណាមួយ មានខ្លះដែរឬ ។ តាបសពោលថា អើ អាវុសោ ខ្ញុំលំបាកព្រោះដំរី ។ បុរសនោះពោលថា បពិត្រលោកម្ចាស់ ដំរីធ្វើអ្វីដល់លោកម្ចាស់ ។ តាបសពោលថា ដំរីបន្ទោបង់លាមកក្នុងទីដែលបោស យកជើងឈូសដីឲ្យហុយឡើង ខ្ញុំចាំជញ្ជូនអាចម៍ដំរីចោល ចាំកៀរដីឲ្យស្មើ ក៏

រមែងលំបាក ។ បុរសនោះពោលថា តើលោកម្ចាស់ប្រាថ្នាមិនឲ្យដំរីទាំងនោះមកដែរឬទេ តាបសពោលថា អើអាវុសោ ។ បុរសនោះពោលថា បើដូច្នោះខ្ញុំនឹងធ្វើមិនឲ្យដំរីទាំងនោះមក ។ បានប្រគេនពិសសម្រាប់ឲ្យដំរីស្រឡាញ់ និងបង្រៀនមន្តសម្រាប់ឲ្យដំរីស្រឡាញ់ដល់តាបសហើយ កាលនឹងឲ្យ បានចង្អុលបង្ហាញខ្សែពិន ៣ ខ្សែ ឲ្យរៀនមន្ត ៣ បទ ហើយប្រាប់ថា កាលដេញខ្សែពិននេះ រាយមន្តបទនេះហើយ ដំរីមិនអាចបែរក្រោយក្រឡេកមើល រមែងគេចទៅ កាលដេញពិនខ្សែនេះ រាយមន្តបទនេះហើយ ដំរីនឹងបែរមើលក្រោយបណ្តើរ គេចទៅបណ្តើរ កាលដេញពិនខ្សែនេះ រាយមន្តបទនេះហើយ ដំរីមេហ្វូងរមែងបង្អោនខ្នងចូលមក ហើយពោលថា វត្ថុណាដែលលោកម្ចាស់គាប់ចិត្ត លោកម្ចាស់គប្បីធ្វើវត្ថុនោះចុះ ថ្វាយបង្គំតាបសហើយ ក៏ចៀសចេញទៅ ។

តាបសរាយមន្តសម្រាប់ដេញដំរី ផ្ចាត់ខ្សែពិនសម្រាប់ដេញដំរី ញុំាងដំរីឲ្យគេចទៅហើយ ។

ក្នុងសម័យនោះ ក្នុងក្រុងកោសម្ពី មានព្រះរាជាព្រះនាមបរន្តបៈ ។ ថ្ងៃមួយ ព្រះបាទបរន្តបៈគង់អាំងកម្តៅថ្ងៃត្រង់ទីវាល ជាមួយព្រះរាជទេវី ដែលទ្រទ្រង់គភ៌ ព្រះរាជទេវីទ្រង់ដណ្តប់សំពត់កម្ពលក្រហម ដែលមានតម្លៃមួយសែន ដែលជាព្រះភូសារបស់ព្រះរាជា ព្រះនាងគង់ប្រាស្រ័យជាមួយព្រះរាជាដោះព្រះទម្រង់ដែលមានតម្លៃមួយសែន អំពីព្រះអង្គុលីរបស់ព្រះរាជា មកពាក់ក្នុងដៃរបស់ព្រះនាង ។

ក្នុងសម័យនោះ បក្សីហត្ថីលិង្គហើរមកតាមអាកាស ឃើញព្រះរាជទេវី ទើបសម្គបស្ទាប បោះពួយចុះដោយសម្គាល់ថាជាដុំសាច់ ព្រះរាជាទ្រង់កិតភ័យដោយសន្ទឹករបស់បក្សីនោះ ទើបទ្រង់ក្រោកចូលទៅខាងក្នុងព្រះរាជនិវេសន៍ ព្រះរាជទេវីមិនអាចទៅដោយរហ័សបាន ព្រោះទ្រង់គភ៌ចាស់ផង និងព្រោះជាអ្នកមានជាតិនៃអ្នកមានជាតិជាអ្នកខ្លាច ។ គ្រានោះ ទើបបក្សីនោះឆាបព្រះនាងនោះឲ្យគង់ក្នុងក្រចក ហើរទៅកាន់អាកាសហើយ ។ បានឮថា បក្សីទាំងនោះមានកម្លាំងស្មើនឹងដំរី ៥ ព្រោះដូច្នោះ ទើបនាំចំណីទៅតាមអាកាស ទុំក្នុងទីដែលពេញចិត្តហើយ រមែងទំពាស៊ីនូវមំសៈ ។ ព្រះនាងកាលបក្សីនោះនាំទៅ ព្រះនាងភ័យខ្លាចចំពោះមរណភ័យ ទើបត្រិះរិះថា បើអញស្រែក ធម្មតាសំឡេងមនុស្សជាទីភ័យខ្លាចសម្រាប់សត្វតិរច្ឆាន សត្វនេះស្តាប់សំឡេងនេះហើយ នឹងទម្លាក់អញចោល កាលបើដូច្នោះ អញនឹងដល់នូវការអស់ជីវិតព្រមទាំងកូនក្នុងផ្ទៃ តែកាលសត្វនេះទុំក្នុងទីណាហើយ ចាប់ផ្តើមស៊ីអញក្នុងទីនោះ អញនឹងស្រែក ហើយដេញឲ្យសត្វនេះគេចទៅ ព្រះនាងអត់ធ្មត់ ទប់បាន ព្រោះភាពជាបណ្ឌិត ។ ក្នុងកាលនោះ ត្រង់ហេមវន្តប្បទេស មានដើមជ្រៃធំមួយ ចម្រើនឡើងបន្តិចម្តងៗ ហើយតាំងនៅដោយអាការដូចមណ្ឌប ។ បក្សីនោះនាំចំណី មានម្រឹគជាដើមទៅហើយ រមែងទំពាស៊ីត្រង់ដើមជ្រៃនោះ ព្រោះដូច្នោះ សត្វហត្ថីលិង្គនោះ នាំព្រះរាជទេវីទៅត្រង់ដើមជ្រៃនោះឯង ដាក់ក្នុងវាងប្រគាបឈើ សម្លឹងមើលផ្លូវដែលខ្លួនហើរមកហើយ បានឮថា ការសម្លឹងមើលផ្លូវដែលហើរមកហើយ ជាធម្មតារបស់សត្វទាំងនោះ ក្នុងខណៈ

នោះ ព្រះទេវីព្រះតម្រិះថា ឥឡូវនេះ គួរបង្អើលបក្សីនេះឲ្យហើរទៅ ទើបព្រះនាងលើកព្រះហស្តទាំងពីរឡើង ទះផង ស្រែកផង បក្សីនោះក៏ហើរទៅហើយ ។ គ្រានោះ ជាពេលព្រះអាទិត្យអស្តង្គត ខ្យល់កម្មជវាតបានតាំងឡើងហើយក្នុងព្រះគភ៌របស់ព្រះទេវីនោះ មហាមេឃក៏គ្រហឹមគ្រប់ទិស ឈ្មោះថាការដេកលក់មិនមាន អស់រាត្រីរហូតក្ដីដល់ព្រះទេវីដែលតាំងនៅក្នុងសេចក្ដីសុខ មិនបានសូម្បីត្រឹមតែពាក្យថា កុំខ្លាចឡើយព្រះនាង កាលសេចក្ដីទុក្ខគ្របសង្កត់ហើយ កាលរាត្រីអស់ហើយ ការស្រឡះអំពីវលាហកក្ដី ការរះឡើងនៃអរុណក្ដី ការប្រសូតិនៃសត្វដែលនៅក្នុងគភ៌របស់ព្រះនាងក្ដី មានហើយ ក្នុងខណៈតែមួយ ។ ព្រះនាងបានដាក់ឈ្មោះព្រះរាជឱរសថា ឧទេនព្រោះកាន់យករដូវពពក និងរដូវអរុណរះប្រសូតហើយ ។

លំនៅរបស់អល្លកប្បតាបស ក៏នៅមិនឆ្ងាយអំពីទីនោះ ។ ដោយប្រក្រតីក្នុងថ្ងៃមានភ្លៀង តាបសនោះរមែងមិនទៅព្រៃដើម្បីប្រយោជន៍ដល់ផលាផលព្រោះចាញ់រងា ទៅកាន់គល់ឈើនោះ រើសឆ្អឹងម្រឹគដែលបក្សីស៊ីហើយ ស្ងោរឲ្យមានរសហើយក៏បរិភោគ ព្រោះដូច្នោះក្នុងថ្ងៃនោះ តាបសក៏គិតថា នឹងរើសឆ្អឹង ទើបទៅត្រង់គល់ឈើនោះ ហើយស្វែងរកឆ្អឹងត្រង់គល់ឈើ បានឮសំឡេងទារកខាងលើ ទើបធ្មៀងមើល ឃើញព្រះទេវី ទើបសួរថា នាងជាអ្នកណា ព្រះទេវីឆ្លើយថា ខ្ញុំជាស្រីមនុស្ស ។ តាបសសួរថា នាងមកបានដូចម្ដេច កាលនាងពោលថា សត្វហត្ថិលិង្គនាំខ្ញុំមក ទើបពោលថា នាងចូរចុះមក ។ ព្រះទេវីពោលថា ខ្ញុំខ្លាចមកអំពីកំណើត តាបសពោលថា នាងជានរណា

ព្រះទេវីពោលថា ខ្ញុំជាម្ចាស់ក្សត្រិយ៍ តាបសពោលថា សូម្បីខ្ញុំក៏ជាស្តេចដូចគ្នា ព្រះទេវីពោលថា បើដូច្នោះ សូមអ្នកបង្ហាញនូវមាយាក្សត្រ តាបសនោះក៏បង្ហាញហើយ ព្រះទេវីពោលថា បើដូច្នោះ សូមលោកម្ចាស់ឡើងមក នាំកូនតូចរបស់ខ្ញុំចុះ ។ ព្រះតាបសនោះធ្វើផ្លូវឡើងដោយចំណែកម្ខាង ឡើងទៅហើយ ទទួលទារក កាលព្រះទេវីពោលថា កុំយកដៃពាល់ខ្ញុំ ក៏មិនពាល់ព្រះនាង បីទារកចុះមក សូម្បីព្រះរាជទេវីក៏ចុះហើយ ។ គ្រានោះ តាបសនាំនាងទៅកាន់អាស្រមបទ មិនធ្វើសីលភេទឡើយ ទំនុកបម្រុងហើយដោយសេចក្តីអនុគ្រោះ នាំទឹកឃ្មុំដែលមិនមានមេមក នាំស្រូវសាលីដែលកើតឯងមក បានស្ងោរជាបបរឲ្យហើយ ។ កាលតាបសនោះកំពុងទំនុកបម្រុងយ៉ាងនោះ ក្នុងកាលដទៃ ទើបព្រះទេវីគិតថា អញមិនស្គាល់ផ្លូវមកតាមណាឡើយ សូម្បីត្រឹមតែការស្និទ្ធស្នាលរបស់អញនឹងតាបសនេះក៏មិនមាន បើតាបសនេះបោះបង់អញចោល អញទៅណាហ្ន៎ យើងទាំងពីរនាក់ក៏នឹងស្លាប់ ក្នុងទីនេះឯង គួរធ្វើឧបាយណាមួយទម្លាយសីលរបស់តាបសរូបនេះ ធ្វើដោយអាការដែលតាបសរូបនេះ មិនបោះបង់អញទៅបាន ។ ពេលនោះ ទើបព្រះរាជទេវីលួងលោមតាបស ដោយការបង្ហាញសំពត់ស្លៀក សំពត់ដណ្តប់ឲ្យរបូត ឲ្យដល់នូវការវិនាសនៃសីលហើយ តាំងអំពីថ្ងៃនោះ ជនទាំងពីរ ក៏នៅស្និទ្ធស្នាលនឹងគ្នាហើយ ។

ក្នុងថ្ងៃមួយ តាបសសង្កេតមើលការប្រកបនៃផ្កាយនក្ខត្តឫក្ស ឃើញភាពសៅហ្មងនៃផ្កាយនក្ខត្តឫក្សរបស់ព្រះបាទបរន្តបៈ ទើបត្រាស់ថា នែនាង

ដ៏ចម្រើន ព្រះបាទបរន្តបៈក្នុងក្រុងកោសម្ពី សោយទិវង្គតហើយ ។

ព្រះរាជទេវីត្រាស់ថា ព្រោះហេតុអ្វី ទើបលោកម្ចាស់ត្រាស់យ៉ាងនេះ លោកម្ចាស់មានការអាឃាតជាមួយព្រះបាទបរន្តបៈនោះឬ តាបសពោលថា នែនាង ខ្ញុំមិនមានសេចក្តីអាឃាតជាមួយទ្រង់ឡើយ ខ្ញុំឃើញការសៅហ្មងរបស់ផ្កាយនក្ខត្តឫក្សរបស់ព្រះបាទបរន្តបៈ ទើបពោលយ៉ាងនេះ ។ ព្រះរាជទេវីទ្រង់កន្សែងហើយ ។ គ្រានោះ ទើបតាបសត្រាស់សួរព្រះទេវីនោះថា ព្រោះហេតុអ្វី ទើបនាងយំ កាលព្រះទេវីត្រាស់ប្រាប់ភាពដែលព្រះបាទបរន្តបៈនោះជាព្រះស្វាមីរបស់ព្រះនាងហើយ ទើបតាបសត្រាស់ថា នែនាង នាងកុំយំឡើយ ធម្មតាសត្វកើតហើយ រមែងស្លាប់ពិត ។ ព្រះទេវីត្រាស់ថា ខ្ញុំជ្រាបលោកម្ចាស់ តាបសពោលថា បើដូច្នេះ ហេតុអ្វី ទើបនាងយំ ព្រះទេវីពោលថា កូនរបស់ខ្ញុំជាបុគ្គលគួរដល់រាជសម្បត្តិ ដែលជារបស់ត្រកូល បើកូននេះនៅក្នុងក្រុងនោះ គេនឹងឲ្យលើកស្វេតឆត្រឡើង ឥឡូវនេះ បុត្រនេះជាបុគ្គលវិនាសធំហើយ ដោយសេចក្តីសោកយ៉ាងនេះ ទើបខ្ញុំយំ ។ តាបសពោលថា ណ្ហើយចុះ នាងកុំគិតថ្វីឡើយ បើប្រាថ្នារាជសម្បត្តិឲ្យបុត្រ ខ្ញុំនឹងធ្វើអាការឲ្យកុមារនេះបានរាជសម្បត្តិតាមប្រាថ្នា ។

គ្រានោះ តាបសបានឲ្យពិន និងមន្តញុំាងដំរីឲ្យស្រឡាញ់ដល់បុត្ររបស់នាងហើយ ។ ក្នុងកាលនោះ ដំរីច្រើនសែនមកស្ទាក់នៅត្រង់គល់ជ្រៃសាខានោះ លំដាប់នោះ ទើបតាបសត្រាស់នឹងកុមារនោះថា កាលដំរីទាំងឡាយមិនទាន់មកដល់នោះឯង ចូរអ្នកឡើងដើមឈើ កាលដំរីទាំងឡាយមកដល់ហើយ

ចូររាយមន្តបទនេះ ដេញពិនខ្សែនេះ ដំរីទាំងអស់មិនអាចបែរមើលក្រោយគេចទៅ ពេលនោះ អ្នកគប្បីចុះមក កុមារនោះធ្វើតាមនោះហើយ ត្រឡប់មកប្រាប់ការប្រព្រឹត្តទៅហើយ ។ ដល់ថ្ងៃទី ២ ទើបតាបសប្រាប់កុមារនោះថា ក្នុងថ្ងៃនេះ ចូរអ្នករាយមន្តបទនេះ ដេញពិនខ្សែនេះ ដំរីត្រឡប់មើលក្រោយបណ្តើរ រត់ទៅបណ្តើរ ក្នុងកាលនោះ កុមារក៏ទ្រង់ធ្វើតាមនោះហើយ ត្រឡប់មកប្រាប់ការប្រព្រឹត្តទៅនោះ ។ គ្រានោះ តាបសហៅមាតារបស់កុមារនោះមកហើយ ប្រាប់ថា នែនាង ចូរនាងឲ្យរាជសាសន៍ដល់បុត្ររបស់នាង បុត្រនេះទៅអំពីទីនេះឯង នឹងបានជាស្តេចផែនដី ។ ព្រះរាជទេវីត្រាស់ហៅព្រះរាជឱរសមកហើយ ត្រាស់ថា កូនជារាជបុត្ររបស់ព្រះបាទបរន្តប: ក្នុងក្រុងកោសម្ពី សត្វហត្ថិលិង្គនាំយើងមក ទាំងដែលមានគភ៌ ដូច្នេះហើយត្រាស់ប្រាប់ឈ្មោះសេនាបតីជាដើម ត្រាស់ថា កាលជនទាំងនោះមិនជឿ បុត្រគប្បីយកសំពត់កម្ពលដែលជាព្រះភូសាជណ្តប់ និងព្រះទម្រង់ដែលជាគ្រឿងប្រដាប់របស់ព្រះបិតានេះ បង្ហាញចុះ ដូច្នេះ ទើបបញ្ជូនទៅហើយ ។

ទើបព្រះកុមារសួរតាបសថា ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេច តាបសពោលថា អ្នកចូរអង្គុយខាងក្រោមដើមឈើ រាយមន្តបទនេះ ដេញពិនខ្សែនេះ ដំរីមេហ្វូងនឹងបង្អោនខ្នងចូលមករកអ្នក អ្នកគប្បីអង្គុយលើខ្នងរបស់ដំរី ហើយចូរទៅដណ្តើមយករាជសម្បត្តិ ។

ព្រះរាជកុមារនោះ ថ្វាយបង្គំតាបស និងមាតាហើយ ទ្រង់ធ្វើតាមនោះហើយអង្គុយលើខ្នងដំរីដែលចូលមកហើយ ខ្សឹបប្រាប់ដំរីថា ខ្ញុំជាបុត្ររបស់

ព្រះបាទបរន្តបៈ ក្នុងក្រុងកោសម្ពី ចូរអ្នកដណ្តើមយករាជសម្បត្តិ ដែលជារបស់បិតាឲ្យដល់ខ្ញុំចុះ ។ ដំរីមេហ្វូងស្តាប់ពាក្យនោះហើយ ទើបស្រែកដោយសំឡេងដំរីថា ដំរីទាំងឡាយចូរមកប្រជុំគ្នាឲ្យបានច្រើនពាន់ ។ ដំរីច្រើនពាន់មកប្រជុំគ្នាហើយ ក៏ប្រាប់ទៀតថា ដំរីចាស់ៗ ចូរថយចេញទៅ ដំរីចាស់ៗនាំគ្នាថយទៅហើយ ដំរីនោះក៏ស្រែកទៀតថា ដំរីតូចៗ ចូរត្រឡប់ទៅ ។ ដំរីទាំងនោះក៏នាំគ្នាត្រឡប់ហើយ ។ ព្រះរាជកុមារនោះ កាលដំរីចម្បាំងទាំងឡាយនាំគ្នាចោមរោមហើយ ដល់ស្រុកជាយដែនហើយ ប្រកាសថា ខ្ញុំជារាជបុត្រស្តេចផែនដី អ្នកដែលប្រាថ្នាសម្បត្តិ ចូរមកជាមួយយើង តាំងអំពីនោះទៅក៏ទ្រង់ធ្វើការប្រមូលមនុស្សទៅព័ទ្ធព្រះនគរហើយ បញ្ជូនព្រះរាជសាសន៍ទៅថា តើឲ្យយើងច្បាំង ឬឲ្យរាជសម្បត្តិ ។ អ្នកក្រុងទាំងឡាយពោលថា យើងមិនឲ្យទាំងពីរយ៉ាង ពិតហើយ ព្រះរាជទេវីរបស់យើងមានគភ៌ចាស់ ត្រូវសត្វហត្ថិលិង្គនាំទៅហើយ យើងទាំងឡាយមិនដឹងថា ព្រះនាងនៅមានព្រះជន្មឬក៏មិនមានហើយ ដរាបណាដែលពួកយើងមិនជ្រាបរឿងរាវរបស់ព្រះនាងយើងនឹងមិនឲ្យទាំងការច្បាំង និងរាជសម្បត្តិ ។ បានឮថា ភាពជាស្តេចផែនដីដោយពូជពង្ស មានហើយក្នុងកាលនោះ លំដាប់នោះ ទើបព្រះរាជកុមារត្រាស់ថា យើងជាបុត្ររបស់ព្រះនាង ហើយអាងដល់សេនាបតីជាដើម កាលជនទាំងនោះមិនជឿយ៉ាងនោះ ទើបបង្ហាញសំពត់កម្ពល និងព្រះទម្រង់ ។ ពួកអ្នកនគរចាំសំពត់កម្ពលក្រហម និងព្រះទម្រង់នោះបាន អស់សន្ទិះសង្ស័យ ទើបបើកទ្វារ អភិសេកកុមារនោះក្នុងរាជសម្បត្តិហើយ ។

នេះជារឿងនៃការកើតឡើងរបស់ព្រះបាទឧទេនជាបឋម ។

កាលទុព្ភិក្ខភ័យកើតហើយក្នុងដែនអល្លកប្បៈ បុរសម្នាក់ឈ្មោះកោតុ-ហលិកៈ មិនអាចរស់នៅបាន ទើបនាំកិរិយាដែលមានកូនខ្ចីឈ្មោះកាឡីរៀបចំស្បៀងចេញទៅហើយ ដោយបំណងថា នឹងទៅរកស៊ីឯក្រុងកោសម្ពី អាចារ្យពួកខ្លះពោលថា ប្តីប្រពន្ធនោះចេញទៅហើយ ក្នុងកាលមហាជនកំពុងស្លាប់ដោយអហិវាតរោគក៏មាន ។ ប្តីប្រពន្ធពីរនាក់នោះ ធ្វើដំណើរទៅ កាលស្បៀងអស់ហើយ កាលសេចក្តីឃ្លានគ្របសង្កត់ហើយ មិនអាចនាំកុមារទៅបាន កាលនោះ ទើបប្តីពោលនឹងកិរិយាថា នែនាង បើយើងនៅមានជីវិតក៏នឹងបានកូនទៀត គេចោលកូនហើយក៏ទៅ ។ ធម្មតាថា ទឹកចិត្តរបស់មាតាទន់ភ្លន់ព្រោះដូច្នោះ ទើបពោលថា ខ្ញុំមិនអាចចោលកូនទាំងដែលនៅមានជីវិតបានទេ ។ ប្តីពោលថា បើដូច្នោះ យើងគិតធ្វើដូចម្តេច កិរិយាពោលថា យើងប្តូរគ្នានាំទៅ ។ មាតាលើកកូនឡើង ដូចកម្រងផ្កាក្នុងវារៈរបស់ខ្លួន ផ្អិបត្រង់ទ្រូងបីទៅហើយក៏ឲ្យដល់ឪពុក ។ វេទនាមានកម្លាំងជាងការស្រេកឃ្លានកើតដល់បុរសជាប្តីនោះ ក្នុងទីដែលគាត់ទទួលកូននោះហើយដាក់ចុះ ក៏ពោលនឹងកិរិយានោះ ដដែលហើយដដែលទៀតថា នែនាង បើយើងនៅមានជីវិត យើងនឹងបានកូនទៀត យើងចោលកូននេះចុះ ។ កិរិយាក៏ឃាត់ជាច្រើនដង ហើយក៏នៅស្ងៀម ។ កុមារត្រូវផ្លាស់ប្តូរតាមវារៈ នឿយហត់ទន់ខ្សោយ ដេកលក់ក្នុងដៃរបស់ឪពុក ។ បុរសជាប្តីដឹងថា កូនប្រុសដេកលក់ ទើបបណ្តោយឲ្យម្តាយដើរទៅមុន ហើយយកកុមារនោះ ផ្តេកលើកម្រាលស្លឹកឈើ ក្រោម

ដើមឈើមួយកន្លែង ហើយដើរទៅ ។ មាតាក្រឡេកមើលមិនឃើញកូន ទើបសួរថា នែអ្នក កូនយើងទៅណា ប្តីពោលថា ខ្ញុំឲ្យវាដេកក្រោមគុម្ពឈើមួយកន្លែង ភរិយាពោលថា នែអ្នក អ្នកកុំញ៉ាំងខ្ញុំឲ្យវិនាសឡើយ ខ្ញុំវៀរកូនហើយមិនអាចរស់នៅបានទេ សូមអ្នកនាំកូនខ្ញុំមកចុះ គក់ទ្រូងយំរៀបរាប់ហើយ ។ គ្រានោះ ទើបបុរសជាប្តីត្រឡប់ទៅយកកុមារនោះមក កូននោះក៏ស្លាប់ហើយក្នុងរវាងផ្លូវ ។ នាយកោតុហលិកៈ បោលកូនក្នុងឋានៈមានប្រមាណប៉ុណ្ណោះ ទើបត្រូវគេបោះចោលអស់ ៧ ដង ក្នុងអន្តរភព ដោយផលនៃកម្មនោះ ដោយប្រការដូច្នេះ ។ ឈ្មោះថា បាបកម្មនេះ បុគ្គលមិនគួរមើលងាយថា មានប្រមាណតិចឡើយ ស្វាមីភរិយាពីរនាក់នោះ ធ្វើដំណើរទៅដល់ត្រកូលរបស់អ្នកចិញ្ចឹមគោមួយកន្លែងហើយ ។

ក្នុងថ្ងៃនោះ មានការធ្វើពិធីដល់មេគោទឹកដោះរបស់នាយគោបាល ក្នុងផ្ទះរបស់នាយគោបាល ព្រះបច្ចេកពុទ្ធមួយរូបឆាន់ជានិច្ច ។ នាយគោបាលនោះ និមន្តព្រះបច្ចេកពុទ្ធឆាន់ស្រេចហើយ ទើបបានធ្វើការមង្គល ។ បាយាសគេរៀបចំជាច្រើន នាយគោបាលឃើញប្តីប្រពន្ធពីរនាក់នោះមក ទើបសួរថា អ្នកមកអំពីណា ដឹងរឿងនោះហើយ ជាកុលបុត្រមានចិត្តទន់ភ្លន់ ទើបធ្វើសេចក្តីសង្គ្រោះក្នុងជនទាំងពីរនោះ ឲ្យបាយាស និងសប្បិដ៏ច្រើន ។

ភរិយាពោលនឹងស្វាមីថា នែអ្នក បើអ្នកមានជីវិត ខ្ញុំក៏ឈ្មោះថា មានជីវិត អ្នកស្រេកឃ្លានមកអស់កាលយូរ ចូរបរិភោគតាមសេចក្តីត្រូវការ ដូច្នេះហើយ ទើបដាក់បាយាសខាងមុខ មួយអន្លើដោយសប្បិ ខ្លួនឯងបរិភោគសប្បិ

រាវតែបន្តិចប៉ុណ្ណោះ ចំណែកនាយកោតុហលិកៈបរិភោគច្រើនពេក មិនអាចអស់ចំណាន់ក្នុងអាហារបាន ព្រោះខ្លួនស្រេកឃ្លានមក ៧-៨ ថ្ងៃហើយ ។ នាយគោបាលកាលឲ្យបាយាសដល់ប្តីប្រពន្ធពីរនាក់នោះហើយ ទើបខ្លួនឯង ផ្តើមបរិភោគ ។ នាយកោតុហលិកៈ អង្គុយមើលបុរសនោះហើយ ឃើញបាយាសដែលនាយគោបាលពូតឲ្យដល់ឆ្កែញី ដែលដេកហើយក្រោមតាំង គិតថា ឆ្កែញីនេះមានបុណ្យ ទើបបានភោជនបែបនេះជានិច្ច ។ លុះដល់កណ្តាលយប់ នាយកោតុហលិកៈនោះ មិនអាចញ៉ាំងបាយាសនោះឲ្យរលួយបាន ទើបធ្វើកាលកិរិយា ទៅកើតក្នុងផ្ទៃឆ្កែញីនោះ ។ គ្រានោះ ភរិយារបស់គាត់ធ្វើសរីរ-កិច្ចហើយ ក៏ធ្វើការស៊ីឈ្នួលក្នុងផ្ទះនោះឯង បានអង្ករមួយនាឡិ ចម្អិនហើយដាក់បាត្រព្រះបច្ចេកពុទ្ធ ហើយពោលថា បពិត្រលោកម្ចាស់ ដោយកុសល-កម្មនេះ ខ្ញុំព្រះអង្គសូមដល់នូវភាពជាទាសៈរបស់លោកម្ចាស់ចុះ ដូច្នេះហើយទើបគិតថា អាត្មាអញគួរនៅក្នុងទីនេះឯង លោកម្ចាស់រមែងមកក្នុងទីនេះជានិច្ច ទេយ្យធម៌ ទោះមាន ឬមិនមានក៏ដោយចុះ អញនឹងថ្វាយបង្គំ ធ្វើនូវសេចក្តីខ្វល់ខ្វាយ ញ៉ាំងចិត្តឲ្យជ្រះថ្លារាល់ថ្ងៃ នឹងជួបនូវបុណ្យច្រើន គិតដូច្នេះហើយ ទើបនាងធ្វើការស៊ីឈ្នួលនៅក្នុងផ្ទះនោះឯង ។

ក្នុងខែទី ៦ ឬទី ៧ ឆ្កែនោះឯងក៏កើតកូនមកតែមួយ ទើបនាយគោបាលឲ្យនាំយកទឹកដោះរបស់មេគោមួយ ឲ្យដល់កូនឆ្កែនោះ ។ មិនយូរប៉ុន្មាន កូនឆ្កែនោះក៏ធំធាត់ ។ គ្រានោះ ព្រះបច្ចេកពុទ្ធកាលឆាន់ រមែងឲ្យដុំបាយដល់កូនឆ្កែនោះមួយដុំជានិច្ច អាស្រ័យដុំបាយ ទើបឆ្កែនោះមានសេចក្តីស្រឡាញ់ក្នុង

ព្រះបច្ចេកពុទ្ធ ។ នាយគោបាលរមែងទៅកាន់ទីបម្រើរបស់ព្រះបច្ចេកពុទ្ធ មួយថ្ងៃពីរដងជានិច្ច ។ នាយគោបាលនោះកាលដើរទៅ ក៏យកដំបងវាយគុម្ពឈើនិងដីក្នុងទីដែលមានសត្វកាច ត្រង់រវាងផ្លូវ ហើយបន្លឺសំឡេងថា សុសុ ៣ ដង ញ៉ាំងសត្វសាហាវឲ្យគេចទៅហើយ ឯឆ្កែក៏ទៅជាមួយនាយគោបាលនោះ ។ ថ្ងៃមួយ នាយគោបាលនោះ ពោលនឹងព្រះបច្ចេកពុទ្ធថា បពិត្រលោកម្ចាស់ កាលណាខ្ញុំមិនមានឱកាសទំនេរ កាលនោះខ្ញុំនឹងបញ្ជូនឆ្កែនេះមក សូមលោកម្ចាស់មកដោយសញ្ញានៃឆ្កែនេះ ដែលខ្ញុំបញ្ជូនមកហើយ ។ តាំងអំពីនោះមកក្នុងថ្ងៃដែលមិនមានឱកាស នាយគោបាលនោះ ក៏បញ្ជូនឆ្កែទៅដោយពាក្យថា នែបា ចូរបាទៅនាំព្រះបច្ចេកពុទ្ធមក ដោយពាក្យប្រើត្រឹមតែម្តងប៉ុណ្ណោះ ឆ្កែនោះក៏រត់ទៅដល់ទីដែលម្ចាស់វាយគុម្ពឈើ និងផែនដី ក៏ព្រុសបីដង ដឹងថាសត្វកាចគេចទៅហើយ ដោយសំឡេងនោះ ទៅដល់លំនៅរបស់ព្រះបច្ចេក-ពុទ្ធដែលធ្វើសរីរកិច្ចអំពីព្រលឹម ចូលទៅកាន់បណ្ណសាលាគង់ហើយ ។ ឆ្កែដល់ទ្វារបណ្ណសាលា ទើបព្រុស ៣ ដង ឲ្យព្រះបច្ចេកពុទ្ធដឹងថា ខ្ញុំមកហើយ ក៏ដេកក្រាបនៅត្រង់ចំណែកម្ខាង កាលព្រះបច្ចេកពុទ្ធកំណត់កាលចេញទៅហើយ ឆ្កែនោះក៏ដើរព្រុសទៅខាងមុខនោះឯង ។ ព្រះបច្ចេកពុទ្ធកាលសាកល្បងឆ្កែនោះ ទើបនិមន្តទៅផ្លូវដទៃ ពេលនោះ ទើបឆ្កែនោះ ឈរព្រុសរាំងខាងមុខព្រះបច្ចេកពុទ្ធនោះ ហើយនាំលោកត្រឡប់មកកាន់ផ្លូវក្រៅអំពីនេះ ។ សម័យថ្ងៃមួយ ព្រះបច្ចេកពុទ្ធកាលសាកល្បងឆ្កែនោះ ទើបនិមន្តទៅកាន់ផ្លូវដទៃ សូម្បីឆ្កែនោះឈររាំងឃាត់នៅខាងមុខក៏មិនត្រឡប់ យកជើង

ធ្ងះក្អែកនោះហើយនិមន្តទៅ ក្អែកដឹងថា ព្រះបច្ចេកពុទ្ធមិនត្រឡប់ ទើបទៅនាំជាយស្បង់ទាញមក នាំលោកមកកាន់ផ្លូវក្រៅអំពីនេះ ។ ក្អែកនោះ បានញ៉ាំងសេចក្តីស្រឡាញ់ដ៏មានកម្លាំង ឲ្យកើតឡើងហើយ ក្នុងព្រះបច្ចេកពុទ្ធនោះដោយប្រការយ៉ាងនេះ ។

ក្នុងកាលដទៃ ចីវររបស់ព្រះបច្ចេកពុទ្ធចាស់ហើយ កាលនោះ ទើបនាយគោបាលប្រគេនចីវរសម្រាប់ធ្វើចីវរដល់លោក ទើបព្រះបច្ចេកពុទ្ធពោលនឹងនាយគោបាលនោះថា នែអ្នក ឈ្មោះថា ការធ្វើចីវរ បុគ្គលម្នាក់ឯងធ្វើបានលំបាក ។ អាត្មាទៅកាន់ទីដែលសប្បាយហើយនឹងធ្វើ ។ នាយគោបាលពោលថា បពិត្រលោកម្ចាស់ សូមនិមន្តលោកម្ចាស់ធ្វើទីនេះចុះ ព្រះបច្ចេកពុទ្ធពោលថា នែអ្នក អាត្មាមិនអាចធ្វើក្នុងទីនេះបានទេ ។ នាយគោបាលពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់កុំទៅខាងក្រៅយូរពេក ។ ក្អែកបានឈរស្តាប់ពាក្យរបស់ជនទាំងពីរនោះដូចគ្នា ។ ព្រះបច្ចេកពុទ្ធពោលនឹងនាយគោបាលនោះថា ចូរឈប់ទីនេះចុះឧបាសក ។ ឲ្យនាយគោបាលត្រឡប់ហើយ ហោះឡើងទៅកាន់អាកាស មានមុខឆ្ពោះទៅកាន់ភ្នំគន្ធមាទន៍ ចៀសចេញទៅហើយ ។ ក្អែកសម្លឹងមើលព្រះបច្ចេកពុទ្ធដែលរសាត់ទៅក្នុងអាកាសឈរព្រួសហើយ កាលព្រះបច្ចេកពុទ្ធនោះផុតពីគន្លងចក្ខុ ហទយៈក៏បែកស្លាប់ទៅ ។

ឈ្មោះថា សត្វតិរច្ឆានទាំងឡាយ ជាសត្វមានជាតិស្មោះត្រង់ មិនវៀចវេរ ចំណែកមនុស្សចិត្តគិតផ្សេង មាត់និយាយផ្សេង ព្រោះហេតុនោះឯង

ទើបនាយបេស្ស:ជាកូនរបស់ហ្មដំរី ពោលថា

បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សមានចិត្តសាំញាំ បពិត្រព្រះអង្គដ៏ចម្រើន ពួកសត្វចិញ្ចឹម មានចិត្តងាយយល់ ។

ឆ្កែនោះធ្វើកាលកិរិយាហើយ ទៅកើតក្នុងស្ថានតាវត្តិង្ស មានស្រីទេពអប្សរមួយពាន់ចោមរោម បានសោយនូវសម្បត្តិធំ ព្រោះជាសត្វស្មោះត្រង់មិនវៀចវេរ ដោយប្រការដូច្នេះ ។

កាលទេវបុត្រនោះខ្សឹបត្រង់ត្រចៀករបស់បុគ្គលណាមួយ សំឡេងរមែងលាន់ឮទៅឆ្ងាយ រហូត ១៦ យោជន៍ ចំណែកសំឡេងពោលដោយប្រក្រតីរមែងឮពេញទេវនគរទាំងមូល ដែលមានប្រមាណមួយម៉ឺនយោជន៍ ព្រោះហេតុនោះឯង ទើបទេវបុត្រនោះមានឈ្មោះថា ឃោសកទេវបុត្រ ។ នេះជាអានិសង្ស ជាផលនៃការព្រុសដោយសេចក្ដីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ។ ឃោសកទេវបុត្រនោះ តាំងនៅក្នុងទេវនគរនោះ មិនយូរក៏ចុតិហើយ ។

ពិតហើយ ទេវបុត្រទាំងឡាយរមែងឃ្លាតចាកទេវលោកដោយហេតុ ៤ យ៉ាង គឺដោយអស់អាយុ ១ ដោយអស់បុណ្យ ១ ដោយការអត់អាហារ ១ ដោយសេចក្ដីក្រោធ ១ ។

ក្នុងហេតុ ៤ យ៉ាងនោះ ទេវបុត្រអង្គណាធ្វើបុញ្ញកម្មច្រើន ទេវបុត្រអង្គនោះ កើតក្នុងទេវលោកតាំងនៅដរាបដល់អស់អាយុ ហើយក៏កើតក្នុងទេវលោកជាន់ខ្ពស់បន្តៗ ទៅ យ៉ាងនេះឈ្មោះថា ចុតិដោយការអស់អាយុ ។ ទេវបុត្រអង្គណាធ្វើបុណ្យតិច ទេវបុត្រអង្គនោះអស់ទៅក្នុងចន្លោះដូចធុញ្ញជាតិ

ដែលបុគ្គលដាក់ក្នុងជង្រុកធំ ត្រឹមតែ ៤-៥ នាឡិដូច្នោះ ។ ទេវបុត្រនោះរមែង ធ្វើកាលកិរិយាក្នុងវេលានោះឯង យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអស់បុណ្យ ។ ទេវបុត្រអង្គខ្លះជាអ្នកបរិភោគកាមគុណ មិនបរិភោគអាហារព្រោះភ្លេចស្មារតី មានកាយទន់ខ្សោយក៏ធ្វើកាលកិរិយា យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអត់អាហារ ។ ទេវបុត្រអង្គខ្លះ មិនអត់ធន់ក្នុងសម្បត្តិអ្នកដទៃ អាក់អន់ហើយ ទើបកាលកិរិយា យ៉ាងនេះឈ្មោះថាចុតិដោយសេចក្តីក្រោធ ។

ឃោសកទេវបុត្រនេះ រវល់តែបរិភោគកាមគុណ ភ្លេចស្មារតី ទើបចុតិដោយការអត់អាហារ ។ កាលចុតិស្រេចហើយ បដិសន្ធិក្នុងផ្ទៃនៃស្រីនគរសោភិនី ក្នុងក្រុងកោសម្ពី ។ ក្នុងថ្ងៃប្រសូតនាងសួរទាសីថា កូនយើងប្រុសឬស្រី កាលនាងទាសីឆ្លើយថា កូនប្រុសអ្នកនាង ទើបប្រាប់ឲ្យនាងទាសីយកទៅចោលដោយពាក្យថា ចូរនាងយកទារកនេះដាក់ក្នុងចង្អេរ ហើយយកទៅចោលត្រង់គំនរសំរាម ។ ពិតហើយ ស្រីនគរសោភិនីទាំងឡាយ រមែងចិញ្ចឹមកូនស្រី មិនចិញ្ចឹមកូនប្រុស ព្រោះពូជពង្សរបស់ពួកនាងបន្តទៅបានក៏ដោយកូនស្រី ។ ក្អែកខ្លះ ឆ្កែខ្លះ នាំគ្នាចោមរោមកុមារនោះ ។ ដោយផលនៃការព្រុស ដែលកើតអំពីសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ សត្វសូម្បីតែមួយក៏មិនអាចចូលជិតបាន ។ ក្នុងខណៈនោះ បុរសម្នាក់ចេញទៅខាងក្រៅស្រុក ឃើញការចោមរោមរបស់ក្អែក និងឆ្កែនោះ គិតថា នុ៎ះមានហេតុអ្វីហ្ន៎ ទើបដើរទៅទីនោះ ឃើញទារក ក៏កើតសេចក្តីស្រឡាញ់ដូចកូន ទើបនាំទៅកាន់ផ្ទះដោយត្រេកអរថា អញបានកូនប្រុសហើយ ។

ក្នុងកាលនោះ សេដ្ឋីអ្នកក្រុងកោសម្ពីទៅកាន់រាជត្រកូល ជួបបុរោហិត ដើរមកអំពីព្រះរាជវាំង ទើបសួរថា លោកអាចារ្យ ថ្ងៃនេះលោកបានពិនិត្យមើលការប្រកបរបស់ផ្កាយនក្ខត្តឫក្ស ដែលជាគ្រោះល្អ គ្រោះអាក្រក់ហើយឬ បុរោហិតឆ្លើយថា នែលោកសេដ្ឋី កិច្ចដទៃរបស់ពួកយើងមិនមាន សេដ្ឋីពោលថា នឹងមានអ្វីកើតឡើងដល់ជនបទឬ បុរោហិតពោលថា ហេតុដទៃមិនមាន តែក្មេងដែលកើតក្នុងថ្ងៃនេះ នឹងបានជាសេដ្ឋីដ៏ប្រសើរក្នុងក្រុងនេះ ។

គ្រានោះ ភរិយារបស់សេដ្ឋីមានគភ៌ចាស់ ព្រោះដូច្នោះ ទើបសេដ្ឋីនោះបញ្ជូនអ្នកបម្រើទៅកាន់ផ្ទះយ៉ាងរហ័ស ដោយពាក្យថា អ្នកចូរទៅ ហើយចូរដឹងភរិយារបស់ខ្ញុំថា តើប្រសូតបុត្រហើយឬនៅ លុះជ្រាបថាមិនទាន់ប្រសូតចូលគាល់ព្រះរាជាស្រេចហើយ ប្រញាប់ត្រឡប់ទៅផ្ទះ ហៅស្រីបម្រើឈ្មោះកាឡីមកហើយ ឲ្យទ្រព្យមួយពាន់ពោលថា ចូរនាងទៅពិនិត្យមើលក្នុងក្រុងនេះ ឲ្យទ្រព្យមួយពាន់នាំក្មេងដែលកើតក្នុងថ្ងៃនេះមក ។ នាងកាឡីនោះ កាលពិនិត្យមើលទៅដល់ផ្ទះនោះ ឃើញកុមារហើយ ទើបសួរស្រីមេផ្ទះថា កុមារនេះកើតក្នុងកាលណា កាលស្រីនោះឆ្លើយថា កើតថ្ងៃនេះ ទើបពោលថា ចូរឲ្យក្មេងនេះដល់ខ្ញុំ ទើបប្រមូលតម្លៃតាំងអំពីមួយកហាបណៈជាដើម រហូតដល់ឲ្យទ្រព្យមួយពាន់ ហើយនាំក្មេងនោះទៅបង្ហាញដល់សេដ្ឋី ។ សេដ្ឋីគិតថា បើកូនរបស់ខ្ញុំកើតមកជាស្រី អ្នកចូរឲ្យកុមារនេះ រួមជាមួយកូនស្រីរបស់យើងនោះ ហើយធ្វើគេឲ្យជាម្ចាស់នៃតំណែងសេដ្ឋី បើកូនរបស់យើងកើតមកជាកូនប្រុស យើងនឹងសម្លាប់វាចោល ដូច្នេះហើយ ទើបទទួលក្មេងនោះទុកក្នុង

ផ្ទះ ។ ក្នុងកាលតមក ភរិយារបស់សេដ្ឋីនោះប្រសូតបុត្រប្រុស ដោយកន្លងទៅ ២-៣ ថ្ងៃ ទើបសេដ្ឋីគិតថា បើមិនមានក្មេងនេះ កូនប្រុសរបស់អញក៏នឹងបានតំណែងសេដ្ឋី ។ ឥឡូវនេះ អញគួរតែសម្លាប់វាចោល ដូច្នេះហើយ ទើបហៅនាងកាឡីមក ពោលថា ហងចូរទៅក្នុងកាលដែលពួកគោចេញអំពីក្រោល ហងចូរដាក់ក្មេងនេះឲ្យដេកទទឹង ត្រង់កណ្ដាលទ្វារក្រោល មេគោទាំងឡាយនឹងជាន់វាស្លាប់ តែចូរដឹងថា មេគោជាន់ឬមិនជាន់ហើយសឹមមក ។ នាងកាឡីនោះទៅហើយ លុះនាយគោបាលបើកទ្វារក្រោលប៉ុណ្ណោះ ក៏យកក្មេងនោះឲ្យដេកតាមនោះ គឺដូចសេដ្ឋីបញ្ជា ។ គោឧសភៈមួយក្បាលជាមេហ្វូង ចេញខាងក្រោយគោទាំងពួងក្នុងកាលដទៃ តែក្នុងថ្ងៃនោះ ចេញមកមុនគោដទៃទាំងអស់ បានឈរក្រុងទារកក្នុងរវាងជើងទាំងបួន ។ មេគោច្រើនរយក៏នាំគ្នាប្រច្រៀតសងខាងគោឧសភៈចេញទៅ ។ សូម្បីនាយគោបាលក៏គិតថា គោឧសភៈនេះ កាលមុន ចេញក្រោយគោទាំងអស់ តែថ្ងៃនេះចេញមកមុនគេ ហើយឈរស្ងៀមត្រង់ទ្វារក្រោល តើមានហេតុអ្វីហ្ន៎ ទើបដើរទៅកាលឃើញទារកដេកនៅក្រោមពោះគោនោះ ក៏បានទូវសេចក្ដីស្រឡាញ់ដូចកូន ទើបនាំទៅផ្ទះ ដោយគិតថា អញបានកូនប្រុសហើយ ។ នាងកាឡីទៅហើយ ត្រូវសេដ្ឋីសួរ ទើបប្រាប់រឿងនោះ សេដ្ឋីពោលថា ហងចូរទៅ ចូរឲ្យទ្រព្យគេមួយពាន់ ហើយនាំក្មេងនោះមក ដូច្នេះហើយ ឲ្យទ្រព្យមួយពាន់បាននាំត្រឡប់មកឲ្យជាថ្មីទៀត ។

គ្រានោះ សេដ្ឋីពោលនឹងនាងកាឡីថា នែកាឡី ក្នុងក្រុងនេះមានពួករទេះ

៥០០ ក្រោកឡើងអំពីព្រលឹម រមែងទៅលក់ដូរ នាងចូរយកក្មេងនេះ ទៅឲ្យដេកត្រង់ផ្លូវរទេះ ពួកគោនឹងជាន់ ឬកង់រទេះនឹងកិនវា លុះដឹងរឿងរបស់វាហើយ សឹមត្រឡប់មក ។ នាងកាឡីនោះ នាំក្មេងនោះទៅហើយ ឲ្យដេកត្រង់ផ្លូវរទេះ ក្នុងកាលនោះ ប្រធានក្រុមរទេះបានទៅខាងមុខ ។ គ្រានោះពួកគោរបស់គាត់ដល់ទីនោះហើយ នាំគ្នាទម្លាក់នឹមចោល សូម្បីគាត់លើកឡើងហើយ ដេញទៅច្រើនដង ក៏មិនដើរទៅខាងមុខ ។ កាលគាត់ព្យាយាមជាមួយគោទាំងពីរនោះយ៉ាងនេះឯង អរុណក៏រះឡើង ។ ទើបគាត់គិតថា គោទាំងពីរនាំគ្នាធ្វើហេតុនេះព្រោះអ្វី ទើបពិនិត្យមើលផ្លូវ ឃើញទារកហើយក៏គិតថា កម្មរបស់អញធ្ងន់ហ្ន៎ មានសេចក្ដីត្រេកអរថា អញបានកូនប្រុសហើយ ទើបនាំក្មេងនោះទៅកាន់ផ្ទះ ។ នាងកាឡីទៅហើយ កាលសេដ្ឋីសួរ ទើបប្រាប់ការប្រព្រឹត្តទៅនោះ កាលសេដ្ឋីប្រាប់ថា ហែងចូរទៅឲ្យទ្រព្យមួយពាន់ ហើយចូរនាំក្មេងនោះត្រឡប់មក ដូច្នេះហើយ បានធ្វើតាមនោះ ។

កាលនោះ សេដ្ឋីពោលនឹងនាងកាឡីនោះថា ឥឡូវនេះ ហែងចូរនាំវាទៅកាន់ព្រៃខ្មោច ហើយឲ្យដេកក្នុងចន្លោះគុម្ពឈើ វានឹងត្រូវសត្វ មានឆ្កែព្រៃជាដើមខាំ ឬត្រូវអមនុស្សប្រហារឲ្យស្លាប់ក្នុងទីនោះ ហែងដឹងថា វាស្លាប់ហើយ ឬមិនទាន់ស្លាប់សឹមត្រឡប់មក ។ នាងកាឡីនោះ នាំក្មេងនោះទៅឲ្យដេកក្នុងព្រៃខ្មោចហើយ បានឈរនៅក្នុងទីមួយកន្លែង ។ ឆ្កែខ្លះ ក្អែកខ្លះ អមនុស្សខ្លះ មិនអាចចូលជិតក្មេងនោះបាន ។ មានពាក្យសួរជ្រៀតចូលមកថា មាតាបិតា និងបណ្ដាបងប្អូនជាដើម បុគ្គលណាម្នាក់ ឈ្មោះថា រក្សាក្មេងនោះ មិន

មានមិនមែនឬ អ្នកណារក្សាក្មេងនោះ ឆ្លើយថា កម្មគ្រាន់តែការព្រុសប៉ុណ្ណោះ ដែលក្មេងឲ្យប្រព្រឹត្តទៅហើយ ដោយការស្រឡាញ់ក្នុងព្រះបច្ចេកពុទ្ធ ក្នុងកាលកើតជាឆ្កែ ជាអ្នករក្សាក្មេង ។ គ្រានោះ នាយអជបាលម្នាក់ គៀងមេពពែទាំងឡាយមួយសែនក្បាលទៅរកស៊ី ដើរទៅក្បែរព្រៃខ្មោចនោះ ។ មេពពែមួយស៊ីស្លឹកឈើជាដើម ចូលទៅកាន់គុម្ពឈើ ឃើញទារកហើយ ទើបលុតជង្គង់ឲ្យទឹកដោះដល់ទារក ។ សូម្បីនាយអជបាលធ្វើសំឡេងថា ហេ ហេ ក៏មិនចេញទៅឡើយ បុរសនោះគិតថា នឹងយករំពាត់វាយវាឲ្យចេញ ទើបចូលទៅកាន់គុម្ពឈើ ឃើញមេពពែលុតជង្គង់ឲ្យទារកតូចបៅដោះ ក៏បានទនូវសេចក្តីស្រឡាញ់ក្នុងទារកដូចកូន ទើបនាំទារកនោះទៅដោយគិតថា អញបានកូនប្រុសហើយ នាងកាឡីឃើញហេតុនោះហើយ ទើបទៅ ត្រូវសេដ្ឋីសួរហើយ ទើបប្រាប់ការប្រព្រឹត្តទៅនោះ ដែលសេដ្ឋីពោលថា ហាងចូរទៅឲ្យទ្រព្យមួយពាន់ ហើយនាំវាត្រឡប់មកទៀត នាងកាឡីបានធ្វើតាមហើយ ។

គ្រានោះ សេដ្ឋីពោលនឹងនាងទាសីនោះថា នែកាឡី ហាងចូរយកក្មេងនេះឡើងភ្នំដែលជាទីទម្លាក់ចោរ ចូរបោះវាទៅក្នុងជ្រោះ វាប៉ះនឹងបាតជ្រោះនឹងដាច់ជាកំណាត់តូចធំ ធ្លាក់ចុះត្រង់ផែនដី ហាងដឹងថា វាស្លាប់ហើយ ឬមិនស្លាប់សឹមត្រឡប់មក នាងកាឡីនោះ នាំក្មេងនោះទៅទីនោះហើយ ឈរនៅលើកំពូលភ្នំ បោះទម្លាក់ទៅហើយ ។ គុម្ពឫស្សីធំអាស្រ័យបាតជ្រោះនោះឯងចម្រើនក្នុងបាតជ្រោះនោះឯង វល្លិទំពាំងបាយជូរមានស្លឹកក្រាស់បានចាក់ស្រេះលើគុម្ពឫស្សីនោះ ទារកកាលធ្លាក់ ក៏ធ្លាក់លើវល្លិនោះ ដូចគេដាក់លើសំពត់

រោមសត្វក្នុងថ្ងៃនោះ មេជាងផែងត្រូវការដោយឫស្សី ចូលទៅជាមួយកូនប្រុស ផ្ដើមកាប់គុម្ពឫស្សីនោះ កាលដើមឫស្សីរង្គើទារកក៏យំឡើង ។ ទើបពោលថា ដូចសំឡេងក្មេង ទើបឡើងទៅតាមផ្លូវមួយ ឃើញទារកនោះ មានចិត្តត្រេកអរ ទើបនាំទៅដោយគិតថា អញបានកូនប្រុសហើយ ។ នាងកាឡីទៅកាន់សម្នាក់របស់សេដ្ឋី ត្រូវសេដ្ឋីនោះសួរហើយ ទើបប្រាប់រឿងនោះ កាលសេដ្ឋីពោលថា ហងចូរទៅ ឲ្យទ្រព្យគេមួយពាន់ ហើយនាំវាមក នាងបានធ្វើយ៉ាងនោះហើយ ។

កាលសេដ្ឋីធ្វើកម្មនោះៗ ទារកចម្រើនធំធាត់ហើយ ។ ទារកនោះមានឈ្មោះថា ឃោសកៈ ។ ឃោសកកុមារនោះប្រាកដដល់សេដ្ឋីដូចបន្ទាក្នុងភ្នែក សេដ្ឋីមិនអាចសម្លឹងមើលដោយត្រង់ៗ បាន ។ គ្រានោះ សេដ្ឋីត្រិះរិះរកឧបាយសម្លាប់ឃោសកកុមារនោះ ទើបទៅកាន់សម្នាក់របស់នាយស្មូនឆ្នាំង ដែលជាសម្លាញ់របស់ខ្លួន ហើយសួរថា ក្នុងកាលណា ទើបអ្នកដុត-ឡ ។ កាលបុរសនោះឆ្លើយថា ស្អែកនេះ ទើបពោលថា បើដូច្នោះ អ្នកចូរយកទ្រព្យមួយពាន់នេះ ហើយចូរធ្វើការងារឲ្យខ្ញុំមួយ ស្មូនឆ្នាំងពោលថា ការងារអ្វី ។ សេដ្ឋីពោលថា ខ្ញុំមានកូនជាតិអាក្រក់ម្នាក់ ខ្ញុំនឹងបញ្ជូនវាមកកាន់សម្នាក់របស់អ្នក បើដូច្នោះ អ្នកចូរឲ្យវាចូលកាន់បន្ទប់ យកកាំបិតដែលមុតកាត់ឲ្យជាកំណាត់តូចធំ ដាក់ក្នុងថាំង ហើយដុតក្នុង-ឡ ទ្រព្យមួយពាន់នេះជារង្វាន់សម្រាប់អ្នក ។ ក្នុងកាលក្រោយ ខ្ញុំនឹងធ្វើវត្ថុដែលគួរធ្វើដល់អ្នកឲ្យក្រៃលែងឡើង ។ ស្មូនឆ្នាំងពោលថា បានលោកម្ចាស់ ។

ស្អែកឡើង សេដ្ឋីហៅឃោសកកុមារមកហើយពោលថា នែបា ម្សិល មិញនេះ អញប្រាប់ការងារដល់នាយស្ទូនផ្ទាំងម្យ៉ាង ឯងចូរមក ហើយចូរទៅ កាន់សម្នាក់របស់គាត់ ពោលយ៉ាងនេះថា បានឮថា អ្នកចូរញុំាងការងារ ដែលឪពុករបស់ខ្ញុំប្រាប់កាលពីម្សិលមិញនេះឲ្យសម្រេចចុះ ដូច្នេះហើយ បាន បញ្ជូនទៅហើយ ។ ឃោសកៈនោះទទួលថា បាទ បានទៅហើយ ។ ឯកូន ប្រុសរបស់សេដ្ឋី កំពុងលេងកូនឃ្លីជាមួយពួកក្មេង កាលឃោសកកុមារនោះ ដើរទៅក្នុងទីនោះ ទើបហៅឃោសកៈនោះហើយសួរថា បងទៅណា កាល នាយឃោសកៈពោលថា យកដំណឹងរបស់លោកឪពុកទៅកាន់សម្នាក់របស់ នាយស្ទូនផ្ទាំង ទើបពោលថា ខ្ញុំនឹងទៅក្នុងទីនោះ ក្មេងទាំងនេះឈ្នះខ្ញុំច្រើន ពិន្ទុហើយ សូម្បីបងឈ្នះយកពិន្ទុសងឲ្យខ្ញុំវិញ ឃោសកកុមារពោលថា បង ខ្លាចលោកឪពុក ។ កូនសេដ្ឋីប្រាប់ថា សូមបងកុំខ្លាចឡើយ ខ្ញុំនឹងនាំដំណឹង នោះទៅឯង ពួកក្មេងច្រើននាក់ឈ្នះខ្ញុំហើយ សូមបងឈ្នះយកពិន្ទុឲ្យខ្ញុំ ទម្រាំ ខ្ញុំត្រឡប់មក ។ បានឮថា ឃោសកៈជាអ្នកឈ្លាសក្នុងការលេងឃ្លី ព្រោះ ដូច្នោះ ទើបកូនប្រុសរបស់សេដ្ឋី បានទាក់ទាញឃោសកៈនោះយ៉ាងនោះ ។

ចំណែកឃោសកៈនោះពោលនឹងកូនសេដ្ឋីនោះថា បើដូច្នោះ ចូរឯងទៅ ប្រាប់នាយស្ទូនផ្ទាំងថា បានឮថា កាលពីម្សិលមិញនេះ ឪពុករបស់ខ្ញុំប្រាប់ ឲ្យអ្នកធ្វើការងារមួយ សូមអ្នកញុំាងការងារនោះឲ្យសម្រេចចុះ ដូច្នេះហើយ បញ្ជូនកូនសេដ្ឋីនោះទៅហើយ ។ កូនប្រុសរបស់សេដ្ឋីនោះ ទៅកាន់សម្នាក់ របស់នាយស្ទូនផ្ទាំងនោះ បានពោលតាមពាក្យនោះ ។ គ្រានោះ នាយស្ទូន

ផ្ទាំងបានសម្លាប់កូនប្រុសសេដ្ឋីនោះ តាមពាក្យសេដ្ឋីប្រាប់នោះឯង ហើយបោះទៅក្នុង-ឡ ។

ចំណែកឃោសកកុមារលេងអស់ភាគនៃថ្ងៃ លុះល្ងាចក៏ត្រឡប់ទៅផ្ទះសេដ្ឋីឃើញហើយ ទើបសួរថា នែបា ឯងមិនបានទៅឬ ក៏ប្រាប់ដល់ហេតុដែលខ្លួនមិនទៅ និងហេតុដែលប្អូនប្រុសទៅឲ្យជ្រាប ។ សេដ្ឋីស្តាប់ពាក្យនោះហើយ ទើបស្រែកយំពោលថា កុំសម្លាប់ឡើយ ហាក់បីដូចមានឈាមពុះក្នុងសរីរៈទាំងមូល ផ្គងដើមដៃកន្ទក់កន្ទេញថា ស្ងួនផ្ទាំងដ៏ចម្រើន កុំឲ្យខ្ញុំវិនាសឡើយ កុំឲ្យខ្ញុំវិនាសឡើយ ដូច្នេះ បានទៅកាន់សម្នាក់របស់នាយស្ងួនផ្ទាំងនោះហើយ ។

នាយស្ងួនផ្ទាំងឃើញសេដ្ឋីនោះមកដោយអាការយ៉ាងនោះ ទើបពោលថា នែលោកម្ចាស់ លោកម្ចាស់កុំធ្វើសំឡេងខ្លាំងឡើយ ការងាររបស់លោកម្ចាស់សម្រេចហើយ ។ សេដ្ឋីនោះត្រូវសេចក្តីសោកប្រៀបដូចភ្នំសង្កត់ហើយ សោយទោមនស្ស មានប្រមាណមិនមែនតិច ដូចបុគ្គលមានចិត្តប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្ត ដូច្នោះ ។

ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយក្នុងហេតុ ១០ យ៉ាង ដោយឆាប់រហ័ស គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១

អាពាធជាទម្ងន់ ១ ក្រឡុកចិត្ត ( ឆ្កួត ) ១ របជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានអាជ្ញានោះ លុះបែកធ្លាយរាងកាយរមែងទៅកើតក្នុងនរក ។

ទោះបីដូច្នោះ សេដ្ឋីក៏មិនអាចសម្លឹងមើលនាយឃោសកៈនោះត្រង់ៗ បានត្រិះរិះរកឧបាយថា ធ្វើម្តេចហ្ន៎ ទើបសម្លាប់វាបាន ក៏ឃើញឧបាយថា អញនឹងបញ្ជូនវាទៅកាន់សម្នាក់របស់នាយស្មៀន អ្នកទារពន្ធក្នុង ១០០ ស្រុករបស់អញឲ្យវាស្លាប់ ដូច្នោះហើយ ទើបសរសេរលិខិតទៅដល់មនុស្សនាយស្មៀននោះថា ជននេះជាកូនដែលមានជាតិអាក្រក់របស់ខ្ញុំ ចូរអ្នកសម្លាប់វាហើយបោះទៅក្នុងរណ្តៅលាមក កាលធ្វើការងារយ៉ាងនេះស្រេចហើយ ខ្ញុំនឹងដឹងវត្ថុដែលតបស្នងដល់អ្នកក្នុងកាលខាងក្រោយ ដូច្នេះហើយ ទើបពោលថា នែបាឃោសកៈ អ្នកហូតព័ន្ធរបស់ឪពុកមាននៅត្រង់ស្រុកសួយ ១០០ ស្រុក អ្នកចូរនាំយកសំបុត្រនេះទៅឲ្យជននោះ ដូច្នេះ ទើបយកសំបុត្រចងត្រង់ជាយសំពត់របស់ឃោសកកុមារ ។

នាយឃោសកៈនោះ មិនចេះអក្ខរសម័យឡើយ ព្រោះតាំងពីកុមារសេដ្ឋីគិតសម្លាប់គេរហូត តែមិនអាចសម្លាប់បាន តើនឹងឲ្យគេសិក្សាអក្សរដូចម្តេចបាន ។ នាយឃោសកៈនោះ ចងសំបុត្រសម្លាប់ខ្លួនឯងត្រង់ជាយសំពត់ដោយប្រការដូច្នេះ កាលនឹងចេញដំណើរ ទើបពោលថា បពិត្រលោកឪពុក

ខ្ញុំមិនមានស្បៀងសម្រាប់ដើរផ្លូវ ។ សេដ្ឋីពោលថា ឯងមិនចាំបាច់មានកិច្ច កង្វល់ដោយស្បៀងដើរផ្លូវឡើយ ក្នុងស្រុកឈ្មោះនោះ ក្នុងរវាងផ្លូវ សេដ្ឋី ជាសម្លាញ់របស់អញមាន ឯងចូរទៅបរិភោគអាហារព្រឹកត្រង់ផ្ទះរបស់គេ ហើយសឹមចេញដំណើរទៅ ។

ឃោសកៈនោះទទួលថា បាទ ថ្វាយបង្គំបិតាហើយ ចេញដំណើរទៅ ដល់ស្រុកនោះ សួររកផ្ទះសេដ្ឋី ជួបនឹងភរិយារបស់សេដ្ឋី កាលនាងពោល ថា អ្នកមកពីណា ទើបឆ្លើយថា ខ្ញុំមកពីក្នុងក្រុង ភរិយាសេដ្ឋីពោលថា អ្នក ជាកូនរបស់អ្នកណា ឃោសកៈពោលថា បពិត្រអ្នកម៉ែ ខ្ញុំជាកូនរបស់សេដ្ឋី ដែលជាសម្លាញ់របស់អ្នកម៉ែ ភរិយាសេដ្ឋីពោលថា ឯងឈ្មោះឃោសកៈឬ ឃោសកៈឆ្លើយថា បាទ អ្នកម៉ែ ។

ព្រមគ្នានឹងការបានឃើញប៉ុណ្ណោះ សេចក្ដីស្រឡាញ់ដូចកូនក្នុងឃោសកៈ នោះ កើតឡើងដល់នាងហើយ ។

សេដ្ឋីមានកូនក្រមុំម្នាក់ នាងមានអាយុ ១៥-១៦ ឆ្នាំ រូបរាងស្រស់ ស្អាតគួរជ្រះថ្លា សេដ្ឋីឲ្យស្រីបម្រើម្នាក់ដើម្បីរក្សានាងហើយ ឲ្យនៅក្នុងបន្ទប់ ដ៏មានសិរី ត្រង់ជាន់ខាងលើនៃប្រាសាទ ៧ ជាន់ ។ ក្នុងខណៈនោះ កូនក្រមុំ សេដ្ឋីបានប្រើឲ្យស្រីបម្រើទៅផ្សារ ។ គ្រានោះ ភរិយាសេដ្ឋីឃើញទាសីនោះ ហើយ សួរថា តើនាងទៅណា កាលនាងឆ្លើយថា បពិត្រអ្នកស្រី ខ្ញុំទៅ ដោយកិច្ចបម្រើរបស់ធីតានៃអ្នកស្រី ទើបពោលថា ចូរនាងមកខាងណេះសិន វៀរការបម្រើនោះ ចូររៀបចំគ្រែ លាងជើង លាបប្រេង ក្រាលទីដេកឲ្យកូន

របស់យើង សឹមធ្វើការបម្រើឯក្រោយ ។ នាងបានធ្វើតាមពាក្យប្រាប់ហើយ ។ គ្រានោះ កូនស្រីរបស់សេដ្ឋីបានសម្គុតស្រីបម្រើនោះដែលមកយឺត ។ ពេលនោះ ស្រីបម្រើនោះប្រាប់ថា បពិត្រអ្នកនាង កុំអាលខឹងខ្ញុំឡើយ កូនសេដ្ឋីឈ្មោះឃោសកៈមកហើយ ខ្ញុំធ្វើវត្តនេះ វត្តនេះដល់គាត់ហើយ ទើបទៅផ្សារហើយមក ។ គ្រាន់តែបានស្តាប់ពាក្យថា ឃោសកៈជាកូនសេដ្ឋីនោះ សេចក្តីស្រឡាញ់ជ្រាបចូលតាំងអំពីស្បែក រហូតដល់ខួរក្នុងឆ្អឹង តាំងឡើងដល់កូនស្រីសេដ្ឋីហើយ ។

ពិតហើយ កូនស្រីសេដ្ឋីនោះ ជាកិរិយារបស់នាយឃោសកៈនោះ ក្នុងកាលនៅជានាយកោតុហលិកៈ បានប្រគេនបាយ ១ នាឡិដល់ព្រះបច្ចេកពុទ្ធ ដោយអានុភាពនៃផលទាននោះ ទើបនាងមកកើតក្នុងត្រកូលសេដ្ឋីនោះ ។ សេចក្តីស្រឡាញ់ក្នុងកាលមុន បានលិចលង់ គ្របដណ្តប់កូនស្រីសេដ្ឋីនោះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា

> សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុពីរយ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុ ២ យ៉ាង គឺទឹក ១ ភក់ ១ ដូច្នេះ ។

ពេលនោះ ទើបសួរស្រីបម្រើនោះថា ឥឡូវនេះ បុរសនោះនៅឯណា ។ ស្រីបម្រើពោលថា គាត់ដេកលក់ក្នុងដំណេក ។ ធីតាសេដ្ឋីពោលថា ក្នុងដៃរបស់គាត់មានអ្វីខ្លះឬ ស្រីបម្រើពោលថា មានសំបុត្រត្រង់ជាយសំពត់ ។

ទើបកូនស្រីសេដ្ឋីនោះគិតថា នុ៎ះជាសំបុត្រអ្វីហ្ន៎ កាលនាយឃោសកៈកំពុងដេកលក់ កាលមាតាបិតាមិនឃើញ ព្រោះរវល់បញ្ជូនចិត្តទៅក្នុងរឿងដទៃ ចុះទៅកាន់សម្នាក់ហើយ ស្រាយយកសំបុត្រនោះ ចូលទៅកាន់បន្ទប់របស់ខ្លួន បិទទ្វារបើកបង្អួចអានសំបុត្រ ព្រោះនាងឈ្លាសក្នុងអក្ខរសម័យហើយគិតថា ឱមនុស្សល្ងង់ខ្លៅ ចងសំបុត្រសម្រាប់សម្លាប់ត្រង់ជាយសំពត់ហើយក៏ត្រាច់ទៅ បើអញមិនឃើញសំបុត្រហើយ គង់មិនមានជីវិត ដូច្នេះហើយ ទើបហែកសំបុត្រនោះចោល សរសេរសំបុត្រមួយច្បាប់ទៀត តាមពាក្យរបស់សេដ្ឋីថា កូនប្រុសរបស់ខ្ញុំនេះ ឈ្មោះឃោសកៈ ចូរនាំគ្រឿងបណ្ណាការមកអំពីស្រុកទាំង ១០០ ធ្វើមង្គលជាមួយកូនស្រីសេដ្ឋីក្នុងជនបទនេះ ហើយធ្វើផ្ទះពីរជាន់ត្រង់កណ្ដាលស្រុកជាលំនៅរបស់ខ្លួន ធ្វើការរក្សាឲ្យរឹងមាំដោយរបង គឺកំពែង និងរបង គឺបុរសហើយ ចូរបញ្ជូនដំណឹងមកឲ្យខ្ញុំថា ការនេះ ការនេះ ខ្ញុំធ្វើស្រេចហើយ កាលកម្មយ៉ាងនេះអ្នកធ្វើហើយ ខ្ញុំនឹងដឹងវត្តដែលគួរធ្វើដល់អ្នកក្នុងកាលខាងក្រោយ ។ លុះសរសេរស្រេចហើយ ទើបនាងរួសរាន់ ចុះទៅចងត្រង់ជាយសំពត់របស់នាយឃោសកៈនោះវិញ ។

ឃោសកៈនោះ ដេកលក់ពេញមួយថ្ងៃ ក្រោកឡើងបរិភោគហើយ ក៏ចៀសចេញទៅ ក្នុងថ្ងៃស្អែកឡើង ទៅកាន់ស្រុកនោះអំពីព្រលឹម ក្រឡេកឃើញនាយស្មៀនធ្វើកិច្ចក្នុងផ្ទះនោះឯង ។ នាយស្មៀននោះឃើញនាយឃោសកៈនោះហើយ ទើបសួរថា មានការអ្វីបា នាយឃោសកៈនោះពោលថា លោកឪពុករបស់ខ្ញុំបញ្ជូនសំបុត្រមកដល់លោក ទើបស្មៀនសួរថា សំបុត្រដើម្បី

កិច្ចអ្វី ចូរបាប្រាប់មកចុះ ទទួលសំបុត្រហើយអាន ក៏មានការពេញចិត្ត ទើបពោលនឹងគហបតីទាំងឡាយថា នែអ្នកទាំងឡាយ សូមអ្នកទាំងឡាយមើលការស្រឡាញ់ក្នុងខ្ញុំរបស់ចៅហ្វាយយើងចុះ លោកសេដ្ឋីបញ្ជូនកូនមកកាន់សម្នាក់ខ្ញុំ ដោយប្រាប់ថា ចូរធ្វើមង្គលដល់កូនប្រុសច្បងរបស់ខ្ញុំ ពួកអ្នកចូរប្រញាប់យកឈើជាដើមមកឲ្យរហ័ស ដូច្នេះហើយ ឲ្យសង់ផ្ទះមានប្រការដូចពោលហើយ ត្រង់កណ្ដាលស្រុក ឲ្យនាំបណ្ណាការមកអំពីស្រុក ១០០ នាំកូនស្រីរបស់សេដ្ឋីក្នុងជនបទ មកធ្វើមង្គលហើយ ទើបបញ្ជូនដំណឹងទៅដល់សេដ្ឋីថា ការនេះ ការនេះ ខ្ញុំធ្វើស្រេចហើយ ។

ព្រោះបានស្ដាប់ដំណឹងនោះ ទោមនស្សដ៏ធំកើតឡើងដល់សេដ្ឋីហើយថា អញឲ្យធ្វើវត្ថុណា វត្ថុនោះមិនសម្រេច វត្ថុណាមិនឲ្យធ្វើ វត្ថុនោះក៏បែរជាសម្រេច ការសោយសោកនោះ ផ្សំគ្នានឹងការសោយសោកដល់បុត្ររួមចូលគ្នាតែមួយ ញុំាងការក្ដៅក្រហាយក្នុងពោះឲ្យកើតឡើង ឲ្យកើតរោគអតិសារៈហើយ គឺរោគចុះឈាមហើយ ។ កូនក្រមុំរបស់សេដ្ឋីប្រាប់ពួកមនុស្សថា បើអ្នកណាមួយមកអំពីសម្នាក់របស់សេដ្ឋី អ្នកមិនប្រាប់ដល់ខ្ញុំហើយ កុំប្រាប់ដល់សេដ្ឋីបុត្រមុនឡើយ សូម្បីសេដ្ឋីសោតក៏គិតថា ឥឡូវនេះ អញមិនធ្វើបុត្រអាក្រក់នោះ ឲ្យជាម្ចាស់ទ្រព្យសម្បត្តិរបស់អញឡើយ ដូច្នេះហើយទើបប្រាប់នាយស្មៀនម្នាក់ថា នែអ៊ំ ខ្ញុំប្រាថ្នានឹងជួបកូនរបស់ខ្ញុំ ចូរអ៊ំបញ្ជូនអ្នកបម្រើម្នាក់ទៅហៅកូនរបស់ខ្ញុំមក បុរសនោះទទួលថា បាទ ឲ្យសំបុត្រហើយ បញ្ជូនមនុស្សម្នាក់ទៅ ។ ចំណែកកូនស្រីរបស់សេដ្ឋី ដឹងថាបុរសនោះ

មកឈរត្រង់ទ្វារ ឲ្យហៅមកហើយសួរថា នែបា តើបាមានការអ្វី អ្នកបម្រើពោលថា លោកសេដ្ឋីមានជំងឺត្រូវការជួបកូនប្រុស ទើបឲ្យហៅ ។ សេដ្ឋីធីតាពោលថា នែបា សេដ្ឋីនោះនៅមានកម្លាំង ឬថមថយកម្លាំងហើយ អ្នកបម្រើពោលថា នៅមានកម្លាំងនៅឡើយ នៅបរិភោគអាហារបាន ។

កូនស្រីសេដ្ឋីនោះ មិនឲ្យបុត្រសេដ្ឋីដឹងនោះឡើយ ឲ្យទីលំនៅនឹងស្បៀងសម្រាប់ដើរផ្លូវដល់បុរសនោះហើយពោលថា គាត់នឹងទៅបានក្នុងកាលដែលខ្ញុំបញ្ជូនទៅ ចូរស្នាក់នៅសិនចុះ ។

មហាសេដ្ឋីបានពោលនឹងនាយស្មៀនទៀតថា នែអ៊ំ អ្នកមិនទាន់បានបញ្ជូនសំបុត្រទៅកាន់សម្នាក់របស់កូនខ្ញុំទេឬ ។

នាយស្មៀនពោលថា បពិត្រលោកម្ចាស់ ខ្ញុំបញ្ជូនមនុស្សទៅហើយ តែមិនទាន់មក សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកបញ្ជូនមនុស្សទៅទៀត ។ នាយស្មៀននោះបញ្ជូនទៅហើយ ។

កូនស្រីរបស់សេដ្ឋី បដិបត្តិក្នុងបុរសនោះយ៉ាងនោះដូចគ្នា ក្នុងកាលនោះ រោគរបស់សេដ្ឋីធ្ងន់ហើយ ភាជនៈមួយចូល ភាជនៈមួយចេញ ។

ទើបសេដ្ឋីសួរនាយស្មៀនទៀតថា នែអ៊ំ អ្នកមិនទាន់បានបញ្ជូនសំបុត្រទៅកាន់សម្នាក់កូនរបស់ខ្ញុំទេឬ ។ នាយស្មៀនពោលថា បពិត្រលោកម្ចាស់ ខ្ញុំបញ្ជូនទៅហើយ តែមនុស្សដែលទៅមិនទាន់ត្រឡប់ ។ សេដ្ឋីពោលថា បើដូច្នោះ ចូរអ្នកបញ្ជូនមនុស្សទៅទៀត ។

នាយស្មៀននោះ បញ្ជូនទៅហើយ ត្រូវកូនស្រីសេដ្ឋីសួរអំពីបវត្តិហេតុ

នោះ ដល់បុរសដែលមកក្នុងវារៈទីបីហើយ បុរសនោះប្រាប់ថា បពិត្រអ្នកនាង សេដ្ឋីឈឺធ្ងន់ដាច់អាហារហើយ មានការស្លាប់ជាទីទៅខាងមុខ ភាជនៈមួយចេញ ភាជនៈមួយចូល ។ កូនស្រីសេដ្ឋីគិតថា ឥឡូវនេះ ជាកាលដែលសេដ្ឋីបុត្រគួរទៅបាន ទើបប្រាប់ដល់សេដ្ឋីបុត្រថា បានឮថា ឪពុករបស់លោកមានជំងឺ ។ កាលសេដ្ឋីបុត្រពោលថា នែនាង នាងនិយាយអ្វី ទើបពោលថា ការមិនសុខមានដល់ឪពុករបស់លោក ឃោសកៈពោលថា ឥឡូវនេះ ខ្ញុំគួរធ្វើដូចម្តេច សេដ្ឋីធីតាពោលថា លោក យើងនឹងកាន់គ្រឿងបណ្ណាការអំពីស្រុកសួយ ១០០ ស្រុក ទៅសួរសុខទុក្ខលោក ។ ឃោសកៈនោះទទួលថា ពិតហើយ ទើបឲ្យមនុស្សនាំគ្រឿងបណ្ណាការមក យករទេះដឹកចៀសចេញទៅ ។

គ្រានោះ កូនស្រីរបស់សេដ្ឋីនោះ និយាយនឹងឃោសកៈនោះថា ឪពុករបស់លោកថយកម្លាំង បើយើងកាន់គ្រឿងបណ្ណាការ មានប្រមាណប៉ុណ្ណោះទៅ នឹងជាការយឺតយូរ សូមលោកឲ្យបញ្ជូនបណ្ណាការនេះត្រឡប់ចុះ ដូច្នេះហើយ ទើបបញ្ជូនបណ្ណាការទាំងអស់នោះ ទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ហើយពោលទៀតថា នែលោក លោកគប្បីឈរខាងចុងជើងនៃបិតារបស់លោក ខ្ញុំនឹងឈរខាងក្បាល ។ កាលចូលទៅកាន់ផ្ទះនោះហើយ នាងក៏ប្រាប់ពួកមនុស្សរបស់ខ្លួនថា ពួកអ្នកចូរកាន់យកការរក្សាទាំងខាងមុខផ្ទះ ទាំងខាងក្រោយផ្ទះ ។ ក្នុងកាលដែលជនទាំងពីរចូលទៅ សេដ្ឋីបុត្របានឈរហើយខាងចុងជើងបិតា ចំណែកកកិរិយា បានឈរខាងក្បាល ។

ក្នុងខណៈនោះ សេដ្ឋីដេកផ្ងារហើយ ចំណែកនាយស្មៀន កាលប្របាច់

ជើងរបស់សេដ្ឋីនោះ ទើបពោលថា បពិត្រលោកម្ចាស់ កូនប្រុសរបស់លោកម្ចាស់មកហើយ ។ សេដ្ឋីពោលថា គេនៅឯណា នាយស្មៀនប្រាប់ថា គេឈរត្រង់ចុងជើង ។

គ្រានោះ សេដ្ឋីឃើញកូនប្រុសនោះហើយ ទើបហៅនាយស្មៀនមកហើយសួរថា ក្នុងផ្ទះរបស់ខ្ញុំមានទ្រព្យប៉ុន្មាន កាលនាយស្មៀនប្រាប់ថា មាន ៤០ កោដិប៉ុណ្ណោះ តែគ្រឿងឧបភោគបរិភោគ ស្រុក ស្រែ សត្វជើង ២ ជើង ៤ យាន ពាហនៈ មានចំនួនប៉ុណ្ណេះៗ ប្រាថ្នានឹងពោលថា ខ្ញុំមិនឲ្យទ្រព្យមានប្រមាណប៉ុណ្ណេះ ដល់ឃោសកៈជាកូនរបស់ខ្ញុំឡើយ បែរជាពោលថា ខ្ញុំឲ្យ ។ កូនស្រីសេដ្ឋីស្តាប់ពាក្យនោះហើយ គិតថា សេដ្ឋីនេះ កាលពោលគប្បីពោលពាក្យអ្វីដទៃ ធ្វើដូចក្តៅក្រហាយដោយសេចក្តីសោក រំសាយសក់ទ្រហោយំពោលថា លោកឪពុកពោលអ្វីនេះ ពួកខ្ញុំស្តាប់ពាក្យរបស់លោក ពួកខ្ញុំមិនមានបុណ្យហ្ន៎ ដូច្នេះហើយ ទើបយកក្បាលប្រហារសេដ្ឋីនោះ ត្រង់កណ្តាលដើមទ្រូង ក៏យកក្បាលបោកត្រង់ដើមទ្រូងសេដ្ឋីនោះ សម្តែងអាការសោយសោក រហូតសេដ្ឋីមិនអាចពោលបានទៀត សេដ្ឋីក៏បានធ្វើមរណកាលក្នុងខណៈនោះឯង ។

ជនទាំងឡាយបានឮថា សេដ្ឋីធ្វើអនិច្ចកម្មហើយ ទើបទៅក្រាបទូលព្រះបាទឧទេន ។ ព្រះបាទឧទេនទ្រង់ឲ្យធ្វើឈាបនកិច្ចសរីរៈរបស់សេដ្ឋីនោះហើយត្រាស់សួរថា កូនប្រុស ឬកូនស្រីរបស់សេដ្ឋីនោះមានដែរឬទេ ជនទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ មាន កូនប្រុសរបស់សេដ្ឋីនោះឈ្មោះ

ឃោសកៈ សេដ្ឋីនោះប្រគល់ទ្រព្យសម្បត្តិទាំងអស់ ឲ្យដល់ឃោសកៈនោះហើយ ក៏ដល់នូវអនិច្ចកម្ម ។ ព្រះរាជាទ្រង់ឲ្យហៅសេដ្ឋីបុត្រមកហើយក្នុងកាលដទៃ ក្នុងថ្ងៃដែលមានភ្លៀងធ្លាក់ ។ ត្រង់លានព្រះរាជវាំង មានទឹកដក់ក្នុងទីនោះៗ សេដ្ឋីបុត្រទៅហើយដោយបំណងថា នឹងគាល់ព្រះរាជា ។ ព្រះរាជាទ្រង់បើកបង្អួចទតមើលនាយឃោសកៈនោះ កំពុងដើរមក ទ្រង់ឃើញលោតរំលងទឹកត្រង់លានព្រះរាជវាំងដើរមក ទើបត្រាស់សួរឃោសកៈដែលមកថ្វាយបង្គំ ហើយឈរថា នែបា បាឈ្មោះឃោសកៈឬ កាលឃោសកៈទូលថា ត្រូវហើយព្រះអង្គ ទ្រង់លួងលោមឃោសកៈថា បាកុំទោមនស្សឡើយថា បិតារបស់អញអនិច្ចកម្មហើយ យើងនឹងឲ្យតំណែងសេដ្ឋី ដែលជារបស់ឪពុកបាដល់បានោះឯង ដូច្នេះហើយ ទ្រង់បញ្ជូនឃោសកៈទៅថា ចូរបាទៅចុះ ។ ព្រះរាជាបានប្រថាប់ឈរមើលឃោសកៈ ដែលកំពុងទៅនោះឯង ឃោសកៈមិនលោតរំលងទឹក ដែលគេលោតក្នុងកាលមក បានចុះទៅសន្សឹមៗ នោះឯង ។

កាលនោះ ព្រះរាជាត្រាស់ឲ្យហៅឃោសកៈនោះមកអំពីទីនោះឯង រួចត្រាស់សួរថា នែបា ព្រោះហេតុអ្វីហ្ន៎ កាលអ្នកមកកាន់សម្នាក់យើង លោតរំលងទឹកមក កាលទៅ ក៏ចុះទៅសន្សឹមៗ ដើរទៅ ។ នាយឃោសកៈទូលថា យ៉ាងនោះឯងព្រះអង្គ កាលនោះទូលបង្គំនៅជាកុមារ នេះឈ្មោះថា ជាកាលដែលត្រូវលេង ក្នុងកាលនេះ ទូលបង្គំបានទទួលតំណែងអំពីព្រះអង្គហើយ ព្រោះដូច្នោះ កាលដែលទូលបង្គំមិនគ្រាប់ទៅដូចក្នុងកាលមុន ហើយ

ដើរសន្សឹមៗ ទៅ ទើបគួរក្នុងកាលឥឡូវនេះ ។

ព្រះរាជាស្តាប់ពាក្យនោះហើយ ទ្រង់ត្រិះរិះថា បុរសនេះជាអ្នកមានបញ្ញា អញនឹងឲ្យតំណែងជាសេដ្ឋីដល់គេក្នុងកាលឥឡូវនេះចុះ ដូច្នេះហើយ ប្រទានភោគៈដែលបិតាបរិភោគហើយ បានប្រទានតំណែងសេដ្ឋី មួយអន្លើដោយវត្ថុមួយមុខៗ ១០០ ។

ឃោសកៈនោះ ឈរនៅលើរថ បានធ្វើប្រទក្សិណព្រះនគរហើយ ទីដែលនាយឃោសកៈនោះសម្លឹងមើលហើយ រមែងញាប់ញ័រ ។ កូនស្រីរបស់សេដ្ឋីអង្គុយប្រឹក្សាជាមួយកាឡីស្រីបម្រើថា នែកាឡី សម្បត្តិមានប្រមាណប៉ុណ្ណេះ សម្រេចហើយដល់សេដ្ឋីបុត្រ ក៏ព្រោះអាស្រ័យខ្ញុំ ។ នាងកាឡីពោលថា ព្រោះហេតុអ្វី ។ សេដ្ឋីធីតាពោលថា ព្រោះឃោសកៈនេះចងសំបុត្រសម្លាប់ខ្លួនត្រង់ជាយសំពត់ មកកាន់ផ្ទះរបស់ខ្ញុំ ។ កាលនោះ ខ្ញុំហែកសំបុត្រនោះចោល សរសេរសំបុត្រដទៃដើម្បីធ្វើការមង្គលជាមួយខ្ញុំ ខ្ញុំរក្សាគាត់អស់កាល មានប្រមាណប៉ុណ្ណេះ ។

នាងកាឡីពោលថា អ្នកនាងដឹងត្រឹមតែប៉ុណ្ណេះ តែសេដ្ឋីបំណងនឹងសម្លាប់សេដ្ឋីបុត្រ តាំងអំពីនៅជាកុមារ ក៏មិនអាចសម្លាប់បាន អាស្រ័យលោកម្ចាស់ឃោសកៈនេះតែម្យ៉ាង អស់ទ្រព្យសន្ធឹកសន្ធាប់ ។ សេដ្ឋីធីតាពោលថា លោកសេដ្ឋីធ្វើកម្មធ្ងន់ហ្ន៎ ។ សេដ្ឋីធីតានោះ ឃើញនាយឃោសកៈនោះធ្វើប្រទក្សិណនគរ ចូលទៅកាន់ផ្ទះ ទើបអស់សំណើចដោយគិតថា សម្បត្តិមានប្រមាណប៉ុណ្ណេះ សម្រេចហើយព្រោះអាស្រ័យអញ ។

គ្រានោះ សេដ្ឋីបុត្រឃើញអាការនោះ ទើបសួរថា នាងសើចអ្វី សេដ្ឋីធីតាពោលថា ព្រោះអាស្រ័យហេតុមួយ សេដ្ឋីបុត្រពោលថា ចូរប្រាប់ហេតុនោះមកចុះ សេដ្ឋីធីតានោះពោលថា មិនប្រាប់ ទើបសេដ្ឋីបុត្រនោះសម្លុតថា បើមិនប្រាប់ ខ្ញុំនឹងកាប់ជាពីរកំណាត់ ដូច្នេះ ទើបដកដាវចេញហើយ ។

ទើបសេដ្ឋីធីតានោះប្រាប់ថា ខ្ញុំសើចក៏ព្រោះគិតថា សម្បត្តិមានប្រមាណប៉ុណ្ណេះ លោកបានហើយក៏ព្រោះអាស្រ័យខ្ញុំ ។ សេដ្ឋីពោលថា បើឪពុករបស់ខ្ញុំប្រគល់មត៌ករបស់ខ្លួនឲ្យដល់ខ្ញុំហើយ នាងនឹងទាក់ទិនអ្វីក្នុងទ្រព្យនេះ ។ បានឮថា សេដ្ឋីមិនដឹងរឿងអ្វីសោះ អស់កាលមានប្រមាណប៉ុណ្ណេះ ព្រោះដូច្នោះ ទើបមិនជឿពាក្យរបស់សេដ្ឋីធីតានោះ គ្រានោះ សេដ្ឋីធីតានោះបាននិទានរឿងទាំងអស់នោះដល់សេដ្ឋីបុត្រនោះថា បិតារបស់លោកឲ្យសំបុត្រសម្លាប់លោកបញ្ជូនលោកមកហើយ ខ្ញុំធ្វើកម្មយ៉ាងនេះៗ រក្សាលោកហើយ ។ សេដ្ឋីបុត្រពោលថា នាងនិយាយមិនពិត ទើបគិតថា អញនឹងសួរនាងកាឡី ដូច្នោះហើយ ទើបពោលថា នែនាងកាឡី បានឮថា សេចក្តីនេះយ៉ាងនោះឬ ទើបនាងកាឡីពោលថា បពិត្រលោកម្ចាស់ តាំងអំពីលោកម្ចាស់នៅជាកុមារ សេដ្ឋីបំណងនឹងសម្លាប់លោកម្ចាស់ តែមិនអាចសម្លាប់បាន អាស្រ័យលោកម្ចាស់អស់ទ្រព្យសន្ធឹកសន្ធាប់ លោកម្ចាស់រួចផុតហើយអំពីសេចក្តីស្លាប់ក្នុងទី ៧ កន្លែង ឥឡូវនេះ មកហើយ អំពីស្រុកសួយ សូម្បីដំណែងសេដ្ឋីនេះ មួយអន្លើដោយវត្ថុសព្វយ៉ាង មួយមុខៗ ១០០ ។

សេដ្ឋីស្តាប់ពាក្យនោះហើយគិតថា អញធ្វើកម្មធ្ងន់ហ្ន៎ អញផុតអំពីសេចក្តី

ស្ដាប់បែបនេះ ហើយរស់នៅដោយសេចក្ដីប្រមាទមិនសមគួរឡើយ អញនឹងមិនប្រមាទដូច្នេះ លះទ្រព្យមួយថ្ងៃមួយពាន់ ផ្ដើមធ្វើនូវទាន ដើម្បីអ្នកដើរផ្លូវឆ្ងាយ និងមនុស្សកំព្រាជាដើមហើយ ។

កុដុម្ពិកៈឈ្មោះមិត្តៈ បានជាអ្នកខ្វល់ខ្វាយ ក្នុងទានរបស់សេដ្ឋីនោះឯងការកើតឡើងរបស់ឃោសកសេដ្ឋីដូច្នេះ ។

ក្នុងកាលនោះ សេដ្ឋីឈ្មោះភទ្ទវតិយៈ ក្នុងភទ្ទវតីនគរ បានជាអទិដ្ឋ-បុព្វសហាយ គឺសម្លាញ់ដែលមិនដែលឃើញគ្នារបស់ឃោសកសេដ្ឋីហើយ ។ ឃោសកសេដ្ឋីបានស្ដាប់សម្បត្តិ វ័យ និងប្រទេសរបស់ភទ្ទវតិយសេដ្ឋី ក្នុងសម្នាក់របស់ពួកឈ្មួញ ដែលមកហើយអំពីភទ្ទវតីនគរ ប្រាថ្នានូវភាពជាសម្លាញ់ជាមួយសេដ្ឋីនោះ ទើបបញ្ជូនបណ្ណាការទៅហើយ ។ ភទ្ទវតិយសេដ្ឋីបានស្ដាប់សម្បត្តិ វ័យ និងប្រទេសរបស់ឃោសកសេដ្ឋី ក្នុងសម្នាក់របស់ពួកឈ្មួញដែលមកហើយអំពីក្រុងកោសម្ពី ប្រាថ្នាភាពជាសម្លាញ់ជាមួយសេដ្ឋី ទើបបញ្ជូនគ្រឿងបណ្ណាការទៅហើយ សេដ្ឋីទាំងពីរនោះ បានជាអទិដ្ឋបុព្វសហាយនៃគ្នានិងគ្នាហើយយ៉ាងនេះ ។

ក្នុងកាលដទៃ អហិវាតករោគធ្លាក់ចុះហើយក្នុងផ្ទះរបស់ភទ្ទវតិយសេដ្ឋី កាលអហិវាតករោគនោះធ្លាក់ចុះហើយ រុយស្លាប់មុន បន្ទាប់អំពីនោះ កណ្ដូប កណ្ដុរ មាន់ ជ្រូក ឆ្កែ ឆ្មា គោ អ្នកបម្រើស្រី អ្នកបម្រើប្រុស ស្លាប់ទៅដោយលំដាប់នោះឯង មនុស្សម្ចាស់ផ្ទះ ស្លាប់ក្រោយគេ ។ ក្នុងជនទាំងនោះ ពួកជនណាទម្លាយជញ្ជាំងផ្ទះគេចទៅ ជននោះរមែងបានរួចជីវិត ។ កាលនោះ

សេដ្ឋី ភរិយា និងកូនស្រីក៏គេចទៅដោយវិធីនោះ ប្រាថ្នានឹងឃើញឃោសកសេដ្ឋី ទើបធ្វើដំណើរទៅកាន់ក្រុងកោសម្ពី ។ ជន ៣ នាក់នោះ មានស្បៀងអស់ក្នុងរវាងផ្លូវ មានសរីរៈទាន់ខ្សោយ ដោយខ្យល់ និងកម្តៅថ្ងៃ និងដោយការស្រេកឃ្លាន ដល់ក្រុងកោសម្ពីដោយលំបាក ងូតទឹកក្នុងទីដែលសប្បាយដោយទឹកហើយ ក៏ចូលទៅកាន់សាលាមួយ ត្រង់ទ្វារក្រុង ។

ក្នុងកាលនោះ សេដ្ឋីពោលនឹងភរិយាថា នែនាង បុគ្គលមកដោយទំនងនេះ រមែងមិនត្រូវចិត្តសូម្បីម្តាយបង្កើត បានឮថាសម្លាញ់របស់យើងលះទ្រព្យមួយថ្ងៃមួយពាន់ ឲ្យទានដល់អ្នកដំណើរ មនុស្សកំព្រាជាដើម យើងបញ្ជូនកូនស្រីទៅក្នុងទីនោះ ឲ្យនាំអាហារមកទំនុកបម្រុងសរីរៈក្នុងទីនេះឯង ១ ថ្ងៃ ២ ថ្ងៃហើយ សឹមសួរសុខទុក្ខសម្លាញ់ នាងទទួលថា សាធុ ។ ជនទាំងពីរនាំគ្នាស្នាក់នៅក្នុងសាលានោះឯង ។ ក្នុងថ្ងៃស្អែកឡើង កាលមហាជនប្រាប់កាលហើយ មនុស្សកំព្រា អ្នកដើរផ្លូវជាដើម កំពុងទៅដើម្បីអាហារ ទើបមាតា និងបិតា បញ្ជូនកូនស្រីទៅដោយពាក្យថា នែនាង ចូរនាងទៅនាំអាហារដើម្បីពួកយើង ។ ធីតារបស់ត្រកូលដែលមានភោគៈច្រើន មិនខ្មាស ព្រោះភាពដែលខ្លួនមានការខ្មាសដែលការវិបត្តិកាត់ផ្តាច់ហើយ កាន់ថាសទៅដើម្បីអាហារជាមួយមនុស្សអនាថា កាលមិត្តកុដុម្ពិកៈសួរថា នាងនឹងទទួលប៉ុន្មានចំណែក ក៏ប្រាប់ថា ៣ ចំណែក ពោលនោះ មិត្តកុដុម្ពិកៈឲ្យភត្តាហារ ៣ ចំណែកដល់នាង ។ កាលនាងនាំភត្តមកហើយ ជនទាំង ៣ ក៏អង្គុយដើម្បីបរិភោគរួមគ្នា ទើបមាតា និងកូនស្រី ពោលនឹងសេដ្ឋីថា បពិត្រលោកម្ចាស់

ការវិបត្តិតែងកើតឡើងសូម្បីត្រកូលធំ កុំគិតពួកខ្ញុំឡើយ សូមបរិភោគចុះ ។ អង្វរដោយប្រការផ្សេងៗ ញុំាងសេដ្ឋីនោះឲ្យបរិភោគហើយ ដោយប្រការយ៉ាងនេះ ។

សេដ្ឋីនោះបរិភោគហើយ មិនអាចឲ្យអាហាររលាយបាន កាលអរុណរះឡើង ក៏ធ្វើកាលកិរិយាហើយ មាតា និងកូនស្រីយំសោកដោយប្រការផ្សេងៗ ក្នុងថ្ងៃស្អែកឡើង កុមារិកាដើរយំទៅដើម្បីអាហារ មិត្តកុដុម្ពិកៈនោះឃើញហើយ សួរថា នាងទទួលប៉ុន្មានចំណែក ទើបប្រាប់ថា ពីរចំណែក ។ មិត្តកុដុម្ពិកៈនោះក៏ឲ្យ ២ ចំណែក ។ នាងនាំមកហើយ ក៏អង្វរឲ្យមាតាបរិភោគ មាតាកាលធីតារបស់ខ្លួនអង្វរហើយ ក៏បរិភោគ ហើយមិនអាចឲ្យអាហាររលាយបានក្នុងថ្ងៃនោះ ក៏ធ្វើកាលកិរិយាហើយ ។ ក្មេងស្រីម្នាក់ឯងប៉ុណ្ណោះយំរៀបរាប់ ជាអ្នកមានសេចក្តីទុក្ខ ព្រោះសេចក្តីឃ្លានដែលកើតឡើងហើយដ៏ខ្លាំងក្លា ព្រោះការកើតឡើងនៃសេចក្តីទុក្ខនោះ ថ្ងៃស្អែកឡើង ក៏ដើរយំទៅដើម្បីអាហារ ជាមួយពួកជនក្រីក្រ មិត្តកុដុម្ពិកៈសួរថា នាងទទួលប៉ុន្មានចំណែក ទើបប្រាប់ថា មួយចំណែក ។ មិត្តកុដុម្ពិកៈចាំនាងដែលទទួលភត្តបានទាំងបីថ្ងៃ ព្រោះហេតុនោះ ទើបពោលទឹងនាងថា ចូរវិនាសចុះ ស្រីថោកទាប ថ្ងៃនេះ នាងស្គាល់ប្រមាណក្នុងពោះរបស់នាងឬ ។ ធីតាមានត្រកូល បរិបូណ៌ដោយហិរិឱត្តប្បៈ ដូចត្រូវប្រហារដោយលំពែងត្រង់ទ្រូង និងដូចស្រោចដោយទឹកក្បុងត្រង់ដំបៅ សួរថា តើលោកនិយាយអ្វី ។ មិត្តកុដុម្ពិកៈពោលថា ថ្ងៃមុន នាងទទួលយកទៅបីចំណែក ម្សិលមិញពីរចំណែក ថ្ងៃនេះ

ទទួលមួយចំណែក ថ្ងៃនេះ នាងដឹងប្រមាណក្នុងពោះរបស់នាងហើយឬ ។ កុលធីតាពោលថា នែលោក លោកកុំយល់ថា ខ្ញុំទទួលទៅដើម្បីបរិភោគម្នាក់ឯង ។ មិត្តកុដុម្ពិកៈពោលថា បើយ៉ាងនោះ ហេតុអ្វី ទើបទទួលបីចំណែក ។ កុលធីតាពោលថា ថ្ងៃមុន ពួកខ្ញុំមានគ្នាបីនាក់ ម្សិលមិញ មានពីរនាក់ ថ្ងៃនេះមានតែខ្ញុំម្នាក់ឯងប៉ុណ្ណោះ ។ ទើបមិត្តកុដុម្ពិកៈសួរថា សេចក្តីនេះដូចម្តេច ។ បានស្តាប់រឿងទាំងអស់ដែលនាងប្រាប់ហើយ តាំងអំពីដើមមិនអាចទប់ទឹកភ្នែកបាន កើតនូវទោមនស្សដ៏ខ្លាំងពន់ប្រមាណ ទើបប្រាប់ថា នែនាង បើមានហេតុយ៉ាងនេះ កុំគិតថ្វីឡើយ នាងជាធីតារបស់កទុវតិយសេដ្ឋីចាប់អំពីថ្ងៃនេះទៅ ចូរនាងជាធីតារបស់ខ្ញុំចុះ ដូច្នេះហើយ ថើបត្រង់ក្បាលនាំទៅកាន់ផ្ទះ ទុកក្នុងតំណែងជាកូនស្រីច្បងរបស់ខ្លួនហើយ ។

សេដ្ឋីធីតានោះស្តាប់សំឡេងខ្ញៀវខ្ញារក្នុងរោងទាន ទើបសួរថា លោកឪពុក ហេតុអ្វី ទើបមិនធ្វើជនទាំងនេះឲ្យស្ងាត់ស្ងៀម ហើយឲ្យទាន ទើបមិត្តកុដុម្ពិកៈពោលថា នែនាង មិនអាចធ្វើបានទេ សេដ្ឋីធីតាពោលថា បពិត្រលោកឪពុក អាចធ្វើបាន មិត្តកុដុម្ពិកៈពោលថា នែនាង តើធ្វើដូចម្តេច សេដ្ឋីធីតាពោលថា បពិត្រលោកឪពុក សូមលោកឪពុកព័ទ្ធរោងទាន ទុកទ្វារពីរកន្លែង ល្មមប្រមាណបុគ្គលម្នាក់ចូលទៅបានប៉ុណ្ណោះ ហើយប្រាប់ថា ពួកអ្នកចូលតាមទ្វារមួយ ចេញតាមទ្វារមួយ ដោយអាការយ៉ាងនេះ ជនទាំងឡាយ នឹងស្ងាត់ស្ងៀម ហើយទទួលទាន ។

មិត្តកុដុម្ពិកៈនោះស្តាប់ពាក្យនោះហើយ ទើបពោលថា នែនាង ឧបាយ

នេះល្អ ដូច្នេះ ឲ្យធ្វើដូច្នោះហើយ ។ សូម្បីសេដ្ឋីធីតានោះ ក្នុងកាលមុន ឈ្មោះសាមា តែព្រោះនាងឲ្យធ្វើរបង ទើបឈ្មោះថា សាមាវតី តាំងអំពីកាលនោះ ការកោលាហលក្នុងរោងទានក៏បាត់អស់ទៅ ។ ឃោសកសេដ្ឋីបានស្តាប់សំឡេងនោះក្នុងកាលមុន ក៏ពេញចិត្តថា នេះជាសំឡេងក្នុងរោងទានរបស់អញ តែកាលមិនបានឮសំឡេង ២-៣ ថ្ងៃ ទើបសួរមិត្តកុដុម្ពិកៈ ដែលមកកាន់កន្លែងរបស់ខ្លួនថា នែអ្នក ទានដើម្បីមនុស្សកំព្រា និងមនុស្សធ្វើដំណើរឆ្ងាយជាដើម អ្នកនៅតែឲ្យឬ មិត្តកុដុម្ពិកៈឆ្លើយថា បាទ លោកម្ចាស់ ។ ឃោសកសេដ្ឋីពោលថា បើយ៉ាងនេះ ហេតុអ្វី ទើបខានឮសំឡេង ២-៣ ថ្ងៃ មិត្តកុដុម្ពិកៈឆ្លើយថា ខ្ញុំធ្វើឧបាយដោយអាការដែលពួកគេមិនមានសំឡេង ហើយទទួល ។ ឃោសកសេដ្ឋីពោលថា បើយ៉ាងនេះ ព្រោះហេតុអ្វី ទើបអ្នកមិនធ្វើក្នុងកាលមុន មិត្តកុដុម្ពិកៈពោលថា ព្រោះខ្ញុំមិនដឹង ។ ឃោសកសេដ្ឋីសួរថា ចុះឥឡូវនេះ អ្នកដឹងបានដូចម្តេច មិត្តកុដុម្ពិកៈពោលថា កូនស្រីរបស់ខ្ញុំជាអ្នកប្រាប់ ។ ឃោសកសេដ្ឋីពោលថា កូនស្រីរបស់អ្នកដែលខ្ញុំមិនស្គាល់មានឬ ។ មិត្ត-កុដុម្ពិកៈនោះ និទានរឿងរបស់កទូវតិយសេដ្ឋីទាំងអស់ ចាប់តាំងអំពីកើតអហិវាតករោគហើយ ក៏ប្រាប់ភាពដែលខ្លួនតាំងធីតារបស់សេដ្ឋីនោះ ក្នុងតំណែងជាកូនស្រីច្បងរបស់ខ្លួន ។

គ្រានោះ សេដ្ឋីពោលនឹងមិត្តកុដុម្ពិកៈនោះថា កាលបើដូច្នេះ ព្រោះហេតុអ្វីទើបអ្នកមិនប្រាប់ដល់ខ្ញុំ ធីតារបស់សម្លាញ់ខ្ញុំ ក៏ឈ្មោះថាជាធីតារបស់ខ្ញុំដែរ ដូច្នេះហើយ ឲ្យហៅនាងសាមាវតីនោះមកសួរថា នែនាង នាងជាកូនស្រីសេដ្ឋី

ឬ នាងសាមាវតីឆ្លើយ ពិតហើយលោកឪពុក ។ ឃោសកសេដ្ឋីពោលថា បើដូច្នោះ នាងកុំគិតថ្វីឡើយ នាងជាធីតារបស់ខ្ញុំដូច្នេះ បើបនាងសមាវតីនោះ ត្រង់ក្បាល ឲ្យស្រី ៥០០ ដល់នាងសាមាវតីនោះ ដើម្បីប្រយោជន៍ដល់ភាព ជាបរិវារ តាំងនាងសាមាវតីនោះក្នុងតំណែងធីតាច្បងរបស់ខ្លួនហើយ ។

សម័យថ្ងៃមួយ ក្នុងនគរនោះប្រកាសនក្ខត្តឫក្សហើយ ក្នុងបុណ្យនក្ខត្តឫក្សនោះ កុលធីតាទាំងឡាយ ដែលមិនបានចេញទៅខាងក្រៅ ក៏ត្រូវនាំគ្នា ដើរទៅកាន់ស្ទឹង ងូតទឹកជាមួយបរិវាររៀងៗ ខ្លួន ។ ព្រោះហេតុនោះ ក្នុងថ្ងៃ នោះនាងសាមាវតីដែលស្រី ៥០០ ចោមរោមហើយ ក៏បានទៅងូតទឹក កាត់ តាមលានព្រះរាជវាំងដូចគ្នា ។ ចំណែកព្រះបាទឧទេន ប្រថាប់ត្រង់សីហបញ្ជរ ទតឃើញនាងសាមាវតីនោះ ទើបត្រាស់សួរថា ស្រីទាំងនេះជាស្រីបម្រើរបស់ អ្នកណា រាជបុរសទូលថា បពិត្រព្រះអង្គ មិនជាស្រីបម្រើរបស់អ្នកណាឡើយ ។ ព្រះបាទឧទេនត្រាស់ថា បើយ៉ាងនោះជាកូនស្រីរបស់អ្នកណា រាជបុរសពិត ថា បពិត្រព្រះអង្គ ជាកូនស្រីរបស់ឃោសកសេដ្ឋី នាងឈ្មោះសាមាវតី ។

ព្រះបាទឧទេនទតឃើញ ទ្រង់ក៏កើតស្នេហា ទើបត្រាស់ឲ្យបញ្ជូនរាជសាសន៍ទៅឲ្យសេដ្ឋីថា លោកសេដ្ឋី ចូរបញ្ជូនធីតាមកឲ្យខ្ញុំចុះ សេដ្ឋីប្រាប់ថា បពិត្រព្រះអង្គ បញ្ជូនមិនបានទេ ។ ព្រះបាទឧទេនត្រាស់ថា សូមលោកសេដ្ឋី កុំធ្វើយ៉ាងនេះឡើយ លោកសេដ្ឋី ចូរបញ្ជូនមកឲ្យខាងតែបាន សេដ្ឋីពោល ថា ពួកទូលបង្គំជាគហបតីឲ្យមិនបាន ព្រោះខ្លាចភ័យដោយការវាយតប រុញ ច្រានទាងកុមារិកា ។

ព្រះរាជាទ្រង់ពិរោធ ទើបត្រាស់ឲ្យរឹបយត្រាផ្ទះចាប់សេដ្ឋី និងកិរិយារបស់សេដ្ឋីទុកខាងក្រៅ នាងសាមាវតីងូតទឹកហើយត្រឡប់មក មិនបានឱកាសចូលកាន់ផ្ទះ ទើបសួរថា បពិត្រលោកឪពុក តើមានរឿងអ្វី សេដ្ឋីឆ្លើយថា នែនាង ព្រះរាជាបញ្ជូនរាជសាសន៍មក ព្រោះហេតុតែនាង កាលពួកយើងពោលថា មិនឲ្យ ទើបទ្រង់បញ្ជាឲ្យរឹបយត្រាផ្ទះ ហើយបញ្ជាឲ្យធ្វើពួកយើងនៅខាងក្រៅ ទើបនាងសាមាវតីពោលថា បពិត្រលោកឪពុក លោកឪពុកធ្វើកម្មធ្ងន់ហើយ ធម្មតាព្រះរាជាកាលបញ្ជូនរាជសាសន៍មកហើយ មិនគួរទូលថា មិនឲ្យ គួរទូលថា បើព្រះអង្គទ្រង់ទទួលធីតារបស់ទូលបង្គំ ព្រមទាំងបរិវារ ក៏នឹងថ្វាយ សេដ្ឋីពោលថា សាធុ បើនាងពេញចិត្ត ឪពុកនឹងធ្វើយ៉ាងនោះ ដូច្នេះហើយ ទើបបញ្ជូនដំណឹងទៅថ្វាយព្រះរាជាតាមនោះ ។

ព្រះរាជាទទួលថា សាធុ ទ្រង់នាំនាងសាមាវតីនោះមក មួយអន្លើដោយបរិវារ ទ្រង់អភិសេកតាំងទុកក្នុងតំណែងអគ្គមហេសីហើយ ។ ស្រីដ៏សេសក៏បានជាបរិវាររបស់នាងដូចគ្នា ។ នេះជារឿងរបស់នាងសាមាវតី ។

ចំណែកព្រះបាទឧទេន មានព្រះទេវីមួយអង្គទៀត ព្រះនាមថា ព្រះនាងវាសុលទត្តា ជាព្រះរាជធីតារបស់ព្រះបាទចណ្ឌប្បជ្ជោត ។ សេចក្ដីពិស្ដារថា ក្នុងក្រុងឧជ្ជេនី មានព្រះរាជាទ្រង់ព្រះនាមចណ្ឌប្បជោត ។ ថ្ងៃមួយ ទ្រង់យាងមកអំពីព្រះរាជឧទ្យាន ទតមើលសម្បត្តិរបស់ព្រះអង្គហើយ ត្រាស់ថា សម្បត្តិបែបនេះ បុគ្គលដទៃណាម្នាក់មានដែរឬហ្ន៎ កាលអមាត្យក្រាបទូលថា ឈ្មោះថា សម្បត្តិណាមួយ សម្បត្តិរបស់ព្រះបាទឧទេន ក្នុងក្រុងកោសម្ពី

ច្រើនពេកណាស់ ដូច្នេះហើយ ត្រាស់ថា បើយ៉ាងនោះ យើងនឹងចាប់ស្តេចឧទេននោះ អមាត្យពោលថា បុគ្គលណាម្នាក់ក៏មិនអាចចាប់ទ្រង់បានដែរ ។ ព្រះរាជាត្រាស់ថា យើងនឹងធ្វើឧបាយណាមួយចាប់ឲ្យបាន ។ អមាត្យទូលថា មិនអាចទេ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី អមាត្យទាំងនោះពោលថា ព្រោះព្រះបាទឧទេននោះចេះសិប្បៈឈ្មោះហត្ថិកន្តៈ ទ្រង់រាយមន្តហើយ ដេញពិណហត្ថិកន្តៈ នឹងឲ្យដំរីគេចទៅក៏បាន នឹងចាប់យកក៏បាន បុគ្គលដែលដល់ព្រមដោយពាហនៈ គឺដំរីដូចទ្រង់ មិនមានឡើយ ។ ព្រះរាជាត្រាស់ថា យើងមិនអាចចាប់ស្តេចអង្គនោះបានឬ អមាត្យទូលថា បពិត្រព្រះអង្គ បើទ្រង់មានព្រះហឫទ័យដូច្នេះ ដោយចំណែកមួយហើយ បើដូច្នោះ សូមទ្រង់បញ្ជាឲ្យជាងធ្វើដំរីឈើ ហើយបញ្ជូនទៅកាន់លំនៅរបស់ព្រះបាទឧទេននោះ ព្រះរាជាទ្រង់ឮដល់ពាហនដំរី ឬពាហនសេះហើយ រមែងយាងទៅ សូម្បីនៅឆ្ងាយ យើងអាចចាប់ទ្រង់ ដែលយាងមកក្នុងទីនោះបាន ។

ព្រះរាជាត្រាស់ថា ឧបាយនេះប្រើការបាន ដូច្នេះហើយ ទើបប្រាប់ឲ្យជាងឈើធ្វើដំរីយន្តសម្រេចដោយឈើ យកសំពត់ចាស់ស្រោបខាងក្រៅ ធ្វើឲ្យស្អាត ឲ្យលែងទៅត្រង់មាត់ស្រះមួយកន្លែង ក្នុងទីជិតដែនរបស់ព្រះបាទឧទេននោះ ។ បុរស ៦០ នាក់ដើរទៅមកក្នុងពោះដំរី ពួកគេនាំមូលដំរីមកចោលក្នុងទីនោះៗ ។ ព្រានព្រៃម្នាក់ឃើញដំរីហើយក៏គិតថា ដំរីនេះគួរដល់ស្តេចផែនដីរបស់យើង ដូច្នេះហើយ ទើបទៅក្រាបទូលព្រះបាទឧទេនថា បពិត្រព្រះអង្គ ទូលបង្គំជួបដំរីដ៏ប្រសើរ មានពណ៌សសុទ្ធ មានចំណែកប្រៀបដោយ

កំពូលភ្នំកៃលាស គួរដល់ព្រះអង្គនោះឯង ។ ព្រះបាទឧទេនឲ្យព្រានទោះឯង នាំផ្លូវ ឡើងលើដំរី ព្រមដោយបរិវារ ទ្រង់ចេញទៅហើយ ។ ពួកចារបុរស ជ្រាបការយាងមករបស់ទ្រង់ ទើបទៅក្រាបទូលដល់ព្រះបាទចណ្ឌប្បជ្ជោត ។ ព្រះបាទចណ្ឌប្បជ្ជោតនោះយាងមកហើយ បង្កប់ពលនិកាយទាំងពីរខាង បើក ផ្លូវត្រង់កណ្តាល ព្រះបាទឧទេនមិនបានជ្រាបដល់ការយាងមករបស់ទ្រង់ ទើប ដេញតាមដំរីទៅ ។ មនុស្សដែលនៅខាងក្នុង ប្រញាប់នាំដំរីឈើគេចទៅដោយ រហ័ស កាលព្រះរាជាទ្រង់រាយមន្តដេញពិណ ដំរីឈើធ្វើហាក់ដូចមិនបានឮ សំឡេងខ្សែពិណ គេចទៅតែម្យ៉ាង ។ ព្រះរាជាមិនអាចដេញទាន់ដំរីបាន ទើប ទ្រង់ផែលសេះដេញតាមទៅ ។ កាលទ្រង់ប្រញាប់តាមទៅដោយរហ័ស ពល-និកាយក៏នៅខាងក្រោយ ព្រះរាជាទ្រង់ដាច់អំពីគេមួយអង្គឯងប៉ុណ្ណោះ កាល នោះ ពួកបុរសរបស់ព្រះបាទចណ្ឌប្បជ្ជោត ដែលបង្កប់កម្លាំងហើយទាំងសង ខាងផ្លូវ ទើបចាប់ព្រះរាជា ថ្វាយស្តេចផែនដីរបស់ខ្លួន លុះពលនិកាយរបស់ ទ្រង់ជ្រាបថា ព្រះរាជារបស់ខ្លួនធ្លាក់ក្នុងអំណាចរបស់សត្រូវហើយ ក៏បោះ បន្ទាយនៅខាងក្រៅ ។

ចំណែកព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បញ្ជាឲ្យចាប់ព្រះបាទឧទេន ហើយ ខាំងក្នុងគុកសម្រាប់ដាក់ចោរមួយកន្លែង ឲ្យបិទទ្វារ ទ្រង់ផឹកនូវទឹកជយបាន: អស់ ៣ ថ្ងៃ ក្នុងថ្ងៃទី ៤ ព្រះបាទឧទេនសួរអ្នកយាមថា នៃបាទាំងឡាយ ស្តេច ផែនដីរបស់ពួកអ្នកទៅណា ពួកអ្នកយាមទូលថា ស្តេចផែនដីទ្រង់សោយ ទឹកជយបាន: ទ្រង់ត្រេកអរថា យើងចាប់បច្ចាមិត្របានហើយ ។

ព្រះបាទឧទេនត្រាស់ថា ស្តេចផែនដីរបស់ពួកអ្នក មានកិរិយាដូចមនុស្សស្រី ការចាប់ស្តេចផែនដីដែលជាសត្រូវបានហើយ ដោះលែង ឬសម្លាប់ ទើបគួរ មិនមែនឬ តែនេះបែរជាយកយើងមកឲ្យជាទុក្ខ ហើយទៅអង្គុយផឹកទឹកជយបានៈ ។

អ្នកយាមទាំងនោះ ក៏នាំគ្នាទូលសេចក្តីនោះដល់ព្រះរាជា ព្រះរាជាយាងទៅត្រាស់សួរថា បានឮថា ទ្រង់ពោលយ៉ាងនេះមែនឬ ព្រះបាទឧទេនទូលថា មែនហើយមហារាជ ព្រះបាទចណ្ឌប្បជ្ជោតពោលថា សាធុ ខ្ញុំនឹងដោះលែងទ្រង់ តែបានឮថា ទ្រង់មានមន្តដូច្នេះ ទ្រង់ឲ្យមន្តនោះដល់ខ្ញុំដែរឬទេ ព្រះបាទឧទេនពោលថា យល់ព្រម ខ្ញុំនឹងឲ្យ តែក្នុងពេលរៀនត្រូវថ្វាយបង្គំខ្ញុំ ហើយរៀនមន្តនោះ តើទ្រង់ថ្វាយបង្គំខ្ញុំដែរឬទេ ។ ព្រះបាទចណ្ឌប្បជ្ជោតពោលថា ខ្ញុំថ្វាយបង្គំទ្រង់ដូចម្តេចបាន ព្រះឧទេនពោលថា ទ្រង់មិនថ្វាយបង្គំឬ ព្រះបាទចណ្ឌប្បជ្ជោតពោលថា ខ្ញុំមិនថ្វាយបង្គំឡើយ ព្រះបាទឧទេនពោលថា បើដូច្នោះ ខ្ញុំមិនឲ្យ ព្រះបាទចណ្ឌប្បជ្ជោតពោលថា បើដូច្នោះខ្ញុំនឹងដាក់រាជអាជ្ញាដល់ទ្រង់ ព្រះបាទឧទេនពោលថា សូមយាងចុះ ទ្រង់ជាឥស្សរៈដល់រាងកាយរបស់ខ្ញុំ តែមិនជាឥស្សរៈដល់ចិត្តឡើយ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យដ៏អង់អាចរបស់ព្រះបាទឧទេនហើយ ទើបទ្រង់ត្រិះរិះថា អញនឹងរៀនមន្តរបស់ស្តេចឧទេននេះបានដូចម្តេចហ្ន៎ ហើយទ្រង់គិតបានថា អញមិនអាចឲ្យអ្នកដទៃចេះមន្តនេះ អញនឹងឲ្យធីតារបស់អញរៀនក្នុងសម្នាក់ព្រះបាទឧទេននេះ ហើយសឹមរៀនបន្តក្នុងសម្នាក់របស់នាង ។ លំដាប់

នោះ ទើបព្រះរាជាត្រាស់នឹងព្រះបាទឧទេននោះថា តើទ្រង់ឲ្យដល់បុគ្គលដទៃ ដែលថ្វាយបង្គំហើយ រៀនដែរឬទេ ព្រះបាទឧទេនពោលថា បើយ៉ាងនោះបាន មហារាជ ។ បើដូច្នោះ ក្នុងផ្ទះខ្ញុំមានស្រីគមម្នាក់ ទ្រង់ឈរខាងក្រៅវាំងនន ចូរប្រាប់មន្តដល់ស្រីនោះ ដែលអង្គុយខាងក្នុងវាំងននចុះ ។ ព្រះបាទឧទេន ពោលថា សាធុ មហារាជ ទោះនាងជាស្រីគម ឬខ្វិនក៏ដោយចុះ កាលនាង ថ្វាយបង្គំ ខ្ញុំនឹងឲ្យ ។

លំដាប់នោះ ព្រះរាជាក៏យាងទៅត្រាស់ប្រាប់ព្រះនាងវាសុលទត្តាព្រះរាជ-ធីតាថា កូនស្រី បុរសរោគឃ្លង់ល្មៅម្នាក់ ចេះមន្តមានតម្លៃកាត់ថ្លៃមិនបាន បិតាមិនអាចឲ្យអ្នកដទៃចេះមន្តនោះបាន ។ ចូរនាងអង្គុយខាងក្នុងវាំងននថ្វាយ បង្គំបុរសនោះ ហើយរៀនមន្ត បុរសនោះឈរខាងក្រៅវាំងនន នឹងប្រាប់ដល់ នាង បិតានឹងរៀនអំពីសម្នាក់របស់នាង ។ ព្រះបាទចណ្ឌប្បជ្ជោតនោះត្រាស់ ឲ្យព្រះរាជធីតាធ្វើជាស្រីគម ចំណែកព្រះបាទឧទេន ឲ្យជាបុរសឃ្លង់ល្មៅយ៉ាង នេះ ព្រោះទ្រង់ខ្លាចជនទាំងពីរនោះ ធ្វើសន្ថវៈគ្នានិងគ្នា ។ ព្រះបាទឧទេននោះ ប្រថាប់ឈរខាងក្រៅវាំងននហើយ បានត្រាស់ប្រាប់មន្តដល់ព្រះនាង ដែល ថ្វាយបង្គំ ហើយអង្គុយខាងក្នុងវាំងនន ។

សម័យតមក ព្រះបាទឧទេនត្រាស់នឹងព្រះនាង សូម្បីទ្រង់ត្រាស់ប្រាប់ រឿយៗ ក៏មិនអាចពោលបទនៃមន្តបានថា វ៉ុយ ស្រីគម មាត់របស់នាងមិន មានបបូរ ហើយថ្ពាល់របស់នាងក្រាស់ពេក ហងចូរថាទៅយ៉ាងនេះ ។ ព្រះ នាងទ្រង់ពិរោធ ទើបត្រាស់ថា វ៉ុយ អាឃ្លង់ជួជាតិ អានិយាយអ្វី មនុស្ស

ដូចអញនេះឬ ឈ្មោះថាស្រីគម ដូច្នេះហើយ ព្រះនាងបើកជ្រុងវាំងននឡើង កាលព្រះបាទឧទេនសួរថា នាងជានរណា ទើបត្រាស់ប្រាប់ថា យើងឈ្មោះ វាសុលទត្តា ធីតារបស់ស្តេចផែនដី ព្រះបាទឧទេនពោលថា បិតារបស់នាង ប្រាប់នាងដល់ខ្ញុំថាជាស្រីគម ។ នាងវាសុលទត្តាពោលថា កាលត្រាស់ប្រាប់ ដល់ខ្ញុំ ព្រះបិតាក៏ពោលថា អ្នកជាមនុស្សឃ្លង់ល្ពៅ ជនទាំងពីរនោះត្រិះរិះថា ពាក្យនោះ ព្រះរាជាគង់ត្រាស់ដោយខ្លាចក្រែងយើងធ្វើសន្ថវៈគ្នា ហើយទ្រង់ ក៏ធ្វើសន្ថវៈគ្នាក្នុងវាំងននោះឯង ។

ចាប់តាំងអំពីនោះ ទើបការរៀនមន្ត ឬការរៀនសិប្បៈ មិនមាន ។ ព្រះ រាជាទ្រង់សួរព្រះធីតាជានិច្ចថា នាងរៀនសិប្បៈឬ ព្រះនាងត្រាស់ថា បពិត្រ ព្រះបិតា ខ្ញុំម្ចាស់នៅរៀន ។ ថ្ងៃមួយ ព្រះបាទឧទេនត្រាស់នឹងព្រះនាងថា នែ នាងដ៏ចម្រើន ឈ្មោះថា កិច្ចដែលប្តីគប្បីធ្វើ មាតាបិតា បងប្អូនប្រុស និងបង ប្អូនស្រី មិនអាចធ្វើបានឡើយ បើនាងឲ្យជីវិតដល់យើង យើងនឹងឲ្យស្រី ៥០០ ជាបរិវារ ហើយឲ្យតំណែងអគ្គមហេសីដល់នាង ព្រះនាងត្រាស់ថា បើ ទ្រង់អាចតាំងនៅក្នុងព្រះតម្រាស់នេះ ខ្ញុំម្ចាស់នឹងថ្វាយជីវិតទាននេះដល់ព្រះ អង្គ ។ ព្រះបាទឧទេនត្រាស់ថា នែប្អូនស្រី យើងនឹងអាច ព្រះនាងទទួល ព្រះតម្រាស់ថា យល់ព្រម ដូច្នេះហើយ ក៏យាងទៅកាន់សម្នាក់ព្រះបិតា ថ្វាយ បង្គំហើយ បានឈរក្នុងចំណែកម្ខាង ។ លំដាប់នោះ ព្រះរាជាត្រាស់សួរថា សិប្បៈសម្រេចហើយឬ នាងវាសុលទត្តាត្រាស់ថា បពិត្រព្រះបិតា សិប្បៈ មិនទាន់សម្រេចទេ ។ លំដាប់នោះ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់សួរព្រះនាង ថា ហេតុអ្វី ទើបមិនសម្រេច នាងវាសុលទត្តាពោលថា បពិត្រព្រះបិតា ខ្ញុំ

ម្ចាស់គួរបានទ្វារមួយ និងពាហនៈមួយ ព្រះបាទចណ្ឌប្បជ្ជោតពោលថា ហេតុអ្វី ក៏ដូច្នេះទៅវិញ នាងវាសុលទត្តាពោលថា បពិត្របិតា បានឮថា មានឱសថមួយប្រភេទ ត្រូវយកក្នុងពេលយប់ ដោយសញ្ញាដួងតារា ដើម្បីប្រយោជន៍ ជាឧបការៈនៃមន្ត ព្រោះដូច្នោះ ក្នុងកាលដែលខ្ញុំម្ចាស់ចេញទៅក្នុងកាល ឬមិនមែនកាល ទើបគួរបានទ្វារមួយ និងពាហនៈមួយ ។ ព្រះរាជាត្រាស់ថា បាន ។ ព្រះបាទឧទេន និងព្រះនាងវាសុលទត្តានោះ ទ្រង់បានទ្វារមួយដែលខ្លួនពេញចិត្ត ក្នុងកណ្ដាប់ដៃហើយ ។

ព្រះរាជាមានពាហនៈ ៥ គឺដំរីញី ១ ឈ្មោះភទ្ទវតី ដើរបានមួយថ្ងៃ ៥០ យោជន៍ ទាសៈឈ្មោះកាកៈ ដើរបានមួយថ្ងៃ ៦០ យោជន៍ សេះពីរ គឺសេះវេលកំសិ និងសេះឈ្មោះមុញ្ជកេសិ ទៅបានមួយថ្ងៃ ១០០ យោជន៍ និងដំរីនាឡាគិរីទៅបានមួយថ្ងៃ ១២០ យោជន៍ ។

បានឮមកថា ព្រះរាជាអង្គនោះ ក្នុងកាលព្រះពុទ្ធមិនទាន់កើតឡើង ជាអ្នកបម្រើរបស់ឥស្សរជនម្នាក់ ។ ក្នុងសម័យថ្ងៃមួយ កាលឥស្សរជននោះទៅក្រៅព្រះនគរងូតទឹកហើយមក ព្រះបច្ចេកពុទ្ធមួយអង្គ ចូលកាន់ព្រះនគរដើម្បីបិណ្ឌបាត មិនបានភិក្ខាសូម្បីមួយវែក ព្រោះអ្នកក្រុងទាំងមូល ត្រូវមារបណ្ដាលចិត្ត មានបាត្រដែលលាងហើយ គឺបាត្រទទេចេញទៅ ។ គ្រានោះមារចូលទៅរកព្រះបច្ចេកពុទ្ធនោះ ដោយភេទដែលមិនមានអ្នកណាស្គាល់ ហើយសួរក្នុងខណៈដែលលោកនិមន្តដល់ទ្វារនគរថា បពិត្រលោកម្ចាស់ លោកម្ចាស់ បានអ្វីខ្លះឬ ព្រះបច្ចេកពុទ្ធត្រាស់ថា អ្នកធ្វើអាការ គឺការដែល

មិនបានដល់អាត្មាហើយ មិនមែនឬ មារពោលថា បើដូច្នោះ សូមលោកម្ចាស់ត្រឡប់ទៅវិញ គ្រានេះ ខ្ញុំនឹងមិនធ្វើ ។ ព្រះបច្ចេកពុទ្ធពោលថា អាត្មាមិនត្រឡប់ឡើយ ។

បើព្រះបច្ចេកពុទ្ធគប្បីត្រឡប់សោត មារនោះគប្បីចូលសណ្ឋិតក្នុងសរីរៈរបស់អ្នកនគរទាំងមូល ហើយទះដៃធ្វើការសើចចំអកទៀត កាលព្រះបច្ចេក-ពុទ្ធមិនត្រឡប់ មារក៏អន្តរធានទៅក្នុងទីនោះឯង ។ ខណៈនោះ ឥស្សរជននោះឃើញព្រះបច្ចេកពុទ្ធនិមន្តមក ដោយបាត្រដែលលាងហើយ ទើបថ្វាយបង្គំសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានអ្វីខ្លះឬ ព្រះបច្ចេកពុទ្ធត្រាស់ថាអ្នកមានអាយុ អាត្មាត្រាច់ទៅហើយ ចេញមកហើយ បុរសនោះគិតថា លោកម្ចាស់មិនឆ្លើយពាក្យដែលអញសួរ បែរជាពោលពាក្យដទៃ គង់មិនបានអ្វីឡើយក្នុងវេលានោះ គាត់ក្រឡេងមើលបាត្ររបស់លោក ឃើញបាត្រទទេ ក៏ជាអ្នកក្តៅក្រហាយ តែមិនអាចទទួលបាត្រ ព្រោះមិនទាន់ដឹងថា ភត្តក្នុងផ្ទះរបស់ខ្លួនសម្រេចហើយ ឬមិនសម្រេច ទើបពោលថា បពិត្រលោកម្ចាស់ សូមបង្អង់បន្តិចសិនចុះ ដូច្នេះហើយ ក៏ទៅកាន់ផ្ទះដោយរហ័ស សួរថា ភត្តសម្រាប់ខ្ញុំសម្រេចហើយឬ កាលអ្នកបម្រើឆ្លើយថា ស្រេចហើយ ទើបពោលនឹងអ្នកបម្រើនោះថា នែបា អ្នកដទៃដែលសម្បូរដោយសម្ទុះជាងអ្នក មិនមាន ។ ដោយសម្ទុះដើនដ៏រហ័ស អ្នកចូរទៅដល់លោកម្ចាស់អង្គនោះ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យបាត្រមកចុះ ហើយទទួលបាត្រមកដោយរហ័ស ។ បុរសនោះរត់ទៅដោយពាក្យប្រើត្រឹមតែមួយមាត់ប៉ុណ្ណោះ ទទួលបាត្រនាំមក

ហើយ ឥស្សរជនធ្វើបាត្រឲ្យពេញដោយភោជនរបស់ខ្លួន ហើយពោលថា ឯង ចូរប្រញាប់ទៅប្រគេនបាត្រនេះដល់លោកម្ចាស់ ខ្ញុំនឹងឲ្យចំណែកបុណ្យដែលសម្រេចអំពីទាននេះដល់អ្នក ។ បុរសនោះទទួលបាត្រហើយ ទៅដោយកម្លាំងជើងដ៏រហ័ស ប្រគេនបាត្រដល់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា បពិត្រលោកម្ចាស់ កាលវេលាជិតហួសហើយ ខ្ញុំទៅនិងមកដោយសម្ទុះជើងដ៏រហ័សក្រៃលែង ដោយផលនៃសម្ទុះជើងរបស់ខ្ញុំនេះ សូមពាហនៈទាំងឡាយ ៥ ដែលអាចទៅបានមួយថ្ងៃ ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ កើតឡើងដល់ខ្ញុំ រាងកាយរបស់ខ្ញុំ មក និងទៅ ត្រូវកម្ដៅព្រះអាទិត្យដុតរោលហើយ ដោយផលនៃរាងកាយត្រូវកម្ដៅព្រះអាទិត្យនោះ សូមអាជ្ញារបស់ខ្ញុំផ្សាយទៅដូចពន្លឺនៃព្រះអាទិត្យ ក្នុងទីដែលខ្ញុំកើតហើយ ចំណែកបុណ្យព្រោះបិណ្ឌបាតនេះ ដែលចៅហ្វាយឲ្យហើយដល់ខ្ញុំ ដោយអានិសង្សនៃបុណ្យនោះ សូមឲ្យខ្ញុំជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ ព្រះបច្ចេកពុទ្ធត្រាស់ថា សេចក្ដីប្រាថ្នាដែលអ្នកតម្កល់តាំងទុកនេះ ចូរសម្រេចចុះ ហើយបានធ្វើអនុមោទនាថា សូមឥដ្ឋផល គឺផលជាទីគប្បីចិត្តដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរសម្រេចដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នកដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ។ សូមឥដ្ឋផល គឺផលជាទីគប្បីចិត្តដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរសម្រេចដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចកែវមណី មានរស្មីដ៏រុងរឿងជាកែវវិសេស អាចញ៉ាំងសេចក្ដីប្រាថ្នាទាំងពួងឲ្យសម្រេចបាន ។

បានឮថា គាថាពីរនេះឯង ឈ្មោះថា គាថាអនុមោទនារបស់ព្រះបច្ចេកពុទ្ធទាំងឡាយ រតនៈ គឺកែវមណី ដែលឲ្យបំណងប្រាថ្នាទាំងពួងសម្រេច ហៅថា កែវមណីជោតិរស ក្នុងគាថានោះ ។ នេះជាបុព្វចរិតរបស់អ្នកបម្រើនោះ ។ បុរសនោះ បានជាព្រះបាទចណ្ឌប្បជ្ជោតក្នុងកាលឥឡូវនេះ ។ និងដោយផលដែលហូរចេញអំពីកម្មនោះ ទើបពាហនៈទាំង ៥ នេះកើតឡើង ។

ថ្ងៃមួយ ព្រះរាជាយាងចេញដើម្បីលេងកីឡាក្នុងព្រះរាជឧទ្យាន ។ ព្រះបាទឧទេនទ្រង់ត្រិះរិះថា អញគួរគេចទៅក្នុងថ្ងៃនេះ ទើបទ្រង់ដាក់ថង់ស្បែកធំៗ ឲ្យពេញដោយមាស និងប្រាក់ ដាក់លើខ្នងដំរីញី ហើយនាំព្រះនាងវាសុលទត្តាភៀសខ្លួនទៅ ។ ទាហានរក្សាវាំងទាំងឡាយ ឃើញព្រះបាទឧទេនកំពុងគេចទៅ ទើបក្រាបទូលដល់ព្រះរាជា ព្រះរាជាទ្រង់បញ្ជូនពលទៅដោយព្រះតម្រាស់ថា ពួកអ្នកចូរទៅឲ្យរហ័ស ។ ព្រះបាទឧទេនទ្រង់ជ្រាបថា ពលនិកាយដេញតាម ទើបទ្រង់ស្រាយថង់កហាបណៈ ធ្វើកហាបណៈឲ្យធ្លាក់ចុះ ។ ពួកមនុស្សរើសកហាបណៈហើយដេញតាមទៅទៀត ។ ចំណែកព្រះបាទឧទេន ទ្រង់ស្រាយថង់មាសនោះ ហើយធ្វើឲ្យធ្លាក់ ពួកមនុស្សទាំងនោះរវល់តែយឺតយូរ ព្រោះចង់បានក្នុងមាស ទ្រង់ក៏យាងដល់បន្ទាយរបស់ព្រះអង្គ ដែលតាំងនៅខាងក្រៅ ។ ខណៈនោះ ពលនិកាយគ្រាន់តែឃើញទ្រង់យាងមក ក៏ចោមរោមដង្ហែចូលទៅកាន់ព្រះនគររបស់ខ្លួន ។ ព្រះរាជាកាលយាងទៅហើយ ក៏អភិសេកនាងវាសុលទត្តា តាំងទុកក្នុងតំណែងអគ្គមហេសី ។

នេះជារឿងរបស់ព្រះនាងវាសុលទត្តា

ថ្ងៃមួយ ស្រីជទៃទៀត ឈ្មោះនាងមាគន្ទិយា ក៏បានតំណែងនៃអគ្គមហេសី អំពីសម្នាក់របស់ព្រះរាជា ។ បានឮថា នាងជាកូនស្រីរបស់ព្រាហ្មណ៍ ឈ្មោះមាគន្ទិយៈក្នុងដែនកុរុ សូម្បីមាតារបស់នាង ក៏ឈ្មោះថា មាគន្ទិយាដូចគ្នា ។ សូម្បីឪពុកមារបស់នាងក៏ឈ្មោះថា មាគន្ទិយៈដែរ នាងជាមនុស្សមានរូបស្អាតប្រៀបដូចទេពអប្សរ ។ ឪពុករបស់នាង កាលមិនបានប្តីដែលសមគួរដល់នាង ទោះជាត្រូវត្រកូលធំៗ អង្វរ ក៏ទ្រគោះបោះបោកថា ពួកអ្នកមិនផ្គួផ្គងដល់កូនស្រីរបស់ខ្ញុំ ហើយដេញទៅ ។ សម័យថ្ងៃមួយ ព្រះសាស្តា ទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃអនាគាមិផលរបស់មាគន្ទិយព្រាហ្មណ៍ មួយអន្លើដោយបជាបតី គឺប្រពន្ធរបស់គាត់ ទ្រង់កាន់បាត្រ និងចីវរ ហើយបានយាងទៅកាន់ទីបម្រើភ្លើងរបស់ព្រាហ្មណ៍នោះ ខាងក្រៅនិគម ។ ព្រាហ្មណ៍នោះ ក្រឡេកឃើញអត្តភាពដ៏ប្រសើរដោយលម្អនៃព្រះរូបរបស់ព្រះតថាគតហើយ ក៏គិតថា ឈ្មោះថាបុរសដទៃដូចបុរសនេះ រមែងមិនមាន ក្នុងលោកនេះ បុរសនេះសមដល់ធីតារបស់អញៗ នឹងឲ្យធីតារបស់អញដល់បុរសនេះ ដើម្បីប្រយោជន៍បានមើលថែគ្នា ដូច្នេះហើយ ទើបពោលថា បពិត្រសមណៈ កូនស្រីរបស់ខ្ញុំមានម្នាក់ ខ្ញុំមិនទាន់ឃើញបុរសដែលសមនឹងនាង អស់កាលមានប្រមាណប៉ុណ្ណោះ អ្នកជាបុគ្គលសមដល់នាងហើយនាង ក៏ជាបុគ្គលសមនឹងអ្នកពិត គួរអ្នកបាននាងទុកជាបាទបរិចារិកា នាងក៏គួរបានអ្នកជាកស្តា ខ្ញុំនឹងឲ្យនាងដល់អ្នក អ្នកចូរឈរក្នុងទីនេះឯង ទម្រាំខ្ញុំទៅ ហើយត្រឡប់មក ។ ព្រះសាស្តា មិនត្រាស់ពាក្យណា

មួយ ទ្រង់បានធ្វើតុណ្ហីភាព ។ ព្រាហ្មណ៍ទៅកាន់ផ្ទះដោយរហ័ស ពោលនឹងព្រាហ្មណីថា នែនាង ខ្ញុំឃើញបុគ្គលដែលសមនឹងកូនស្រីរបស់យើងហើយ ។ ចូរនាងតែងខ្លួនកូនឲ្យរហ័ស ឲ្យធីតានោះតែងខ្លួនហើយនាំទៅ មួយអន្លើដោយព្រាហ្មណី បានទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ពួកអ្នកនគរក៏ភ្ញាក់ផ្អើលថា ព្រាហ្មណ៍នេះ មិនឲ្យកូនស្រីដល់បុគ្គលណា ដោយអាងថា ជាបុរសមិនសមដល់កូនស្រីខ្លួនអស់កាលមានប្រមាណប៉ុណ្ណោះ ។ បានឮថា ថ្ងៃនេះគាត់ឃើញបុរសសមនឹងកូនស្រីរបស់គាត់ហើយ បុរសនោះជានរណាហ្ន៎ ពួកយើងនឹងមើលបុរសនោះ ។ ទើបមហាជនចេញទៅជាមួយព្រាហ្មណ៍នោះដែរ កាលព្រាហ្មណ៍នោះនាំធីតាមក ព្រះសាស្តាមិនបានប្រថាប់ក្នុងទីដែលព្រាហ្មណ៍នោះពោលទេ ទ្រង់បង្ហាញចេតិយ គឺស្នាមព្រះបាទក្នុងទីនោះ ហើយបានយាងទៅប្រថាប់ឈរក្នុងទីដទៃ ។ ពិតហើយ ចេតិយ គឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលទ្រង់អធិដ្ឋានហើយ ជាន់ទុកប៉ុណ្ណោះ រមែងមិនប្រាកដក្នុងទីដទៃ ។ ម្យ៉ាងទៀត ចេតិយ គឺស្នាមព្រះបាទជាវត្ថុដែលទ្រង់អធិដ្ឋាន ដើម្បីបំណងដល់បុគ្គលណា បុគ្គលទាំងនោះប៉ុណ្ណោះ រមែងឃើញចេតិយ គឺស្នាមព្រះបាទនោះ ។ ឯសត្វ មានដំរីជាដើម ទោះជាន់ក្តី មហាមេឃគឺភ្លៀងទោះធ្លាក់ក្តី ខ្យល់កំបុតត្បូង ទោះបក់ក្តី កាលនឹងឲ្យបុគ្គលទាំងនោះមិនឃើញបុគ្គលណាម្នាក់ ក៏មិនអាចលុបចេតិយ គឺស្នាមព្រះបាទនោះបានឡើយ ។ លំដាប់នោះ ព្រាហ្មណីពោលនឹងព្រាហ្មណ៍ថា បុរសនោះនៅឯណា ព្រាហ្មណ៍គិតថា ខ្ញុំនិយាយនឹងគេថា អ្នកចូរឈរក្នុងទីនេះ គេទៅក្នុងទីណា

ហ្ន៎ ក្រឡេកមើលក៏ឃើញចេតិយ គឺស្នាមព្រះបាទ ទើបពោលថា នេះជាស្នាមជើងរបស់បុគ្គលនោះ ។ ព្រាហ្មណីរាយលក្ខណមន្ត ហើយពិនិត្យមើលលក្ខណៈនៃស្នាមព្រះបាទ ព្រោះភាពជាអ្នកជំនាញក្នុងវេទទាំង ៣ ព្រមទាំងមន្តសម្រាប់ទាយលក្ខណៈ ពោលថា នែព្រាហ្មណ៍ នេះមិនមែនស្នាមជើងរបស់អ្នកលេងកាមគុណ ៥ ហើយពោលគាថា

បុគ្គលដែលច្រើនដោយរាគៈ មានស្នាមជើងកំពុងកណ្តាល
បុគ្គលដែលប្រកបដោយទោសៈ រមែងមានស្នាមជើងស្រុត
ខាងក្រោយ បុគ្គលដែលជាមោហៈ រមែងមានស្នាមជើងជ្រៅ
ខាងមុខ បុគ្គលដែលមានកិលេស ជាគ្រឿងប្រកបើកហើយ
មានស្នាមជើងយ៉ាងនេះ ។

លំដាប់នោះ ព្រាហ្មណ៍ពោលនឹងនាងថា នែនាង នាងជាអ្នកមានប្រក្រតីឃើញមន្ត ដូចក្រពើក្នុងពាងទឹក ដូចចោរនៅក្នុងកណ្តាលផ្ទះ ចូរស្ងៀមចុះ ។ ព្រាហ្មណីពោលថា នែព្រាហ្មណ៍ អ្នកចង់ពោលពាក្យណា ចូរពោលពាក្យនោះចុះ ស្នាមជើងនេះមិនមែនស្នាមជើងអ្នកសេពកាមគុណ ៥ ទេ ។ ព្រាហ្មណ៍ក្រឡេកមើលឆ្វេងស្តាំ ឃើញព្រះសាស្តាហើយពោលថា ន៎ះ គឺបុរសនោះ ទើបចូលទៅពោលថា បពិត្រសមណៈ ខ្ញុំនឹងឲ្យធីតាដើម្បីបានចិញ្ចឹមគ្នា ព្រះសាស្តាមិនត្រាស់ថា តថាគតមានសេចក្តីត្រូវការដោយធីតារបស់អ្នក ឬក៏មិនត្រូវការ តែត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតពោលហេតុមួយដល់អ្នក ។ ព្រាហ្មណ៍ពោលថា សូមសមណៈពោលមកចុះ ទើបត្រាស់ប្រាប់ការដែល

ព្រះអង្គត្រូវមារជាប់តាមតាំងអំពីចេញបួស រហូតដល់គល់អជបាលនិគ្រោធ និងការប្រលោម ដែលមារធីតាទាំងឡាយមក ដើម្បីរម្ងាប់សេចក្ដីសោក របស់មារនោះ ដែលសោកសៅថា ឥឡូវនេះ សមណគោតមនេះ កន្លងបង់នូវវិស័យរបស់អញហើយ ប្រកបឡើងដោយអំណាចនៃភេទកុមារិកាជាដើម ត្រង់គល់អជបាលនិគ្រោធ ហើយត្រាស់ព្រះគាថានេះថា

តថាគត មិនមានការពេញចិត្តក្នុងមេថុន ព្រោះឃើញនាង
តណ្ហា នាងអរតី និងនាងរាគាផង ទីងមានសេចក្ដីញញចិត្ត
ព្រោះឃើញកូនស្រីរបស់អ្នក ដែលពេញទៅដោយមូត្រ និង
ករីសដូចម្ដេចបាន តថាគតមិនប្រាថ្នាពាល់ត្រូវធីតារបស់អ្នក
សូម្បីដោយជើង ។

ក្នុងទីបំផុតនៃគាថា ព្រាហ្មណ៍ និងព្រាហ្មណីតាំងនៅក្នុងអនាគាមិផល ។ ចំណែកនាងមាគន្ទិយាជាធីតា ចងអាឃាតក្នុងព្រះសាស្ដាថា បើសមណៈនេះមិនត្រូវការអញទេ ក៏គួរពោលថា មិនត្រូវការ តែសមណៈនេះ បែរជាធ្វើឲ្យអញពេញទៅដោយមូត្រ និងលាមក ណ្ហើយចុះ អញអាស្រ័យការដល់ព្រមដោយជាតិ ត្រកូល ប្រទេស ភោគៈ យស និងវ័យ បានកស្ដាំបែបនោះហើយ អញនឹងដឹងកម្មដែលគួរធ្វើដល់សមណគោតម ។

សួរថា តើព្រះសាស្ដា ទ្រង់ជ្រាបការកើតឡើងនៃអាឃាតក្នុងព្រះអង្គរបស់នាង ឬមិនជ្រាប ឆ្លើយថា ទ្រង់ជ្រាបដូចគ្នា សួរថា កាលទ្រង់ជ្រាបហេតុអ្វីទើបត្រាស់ព្រះគាថា ឆ្លើយថា ទ្រង់ត្រាស់គាថា ដោយអំណាចនៃ

ព្រាហ្មណ៍ និងព្រាហ្មណី ។

ធម្មតា ព្រះពុទ្ធទាំងឡាយទ្រង់មិនពិចារណាដល់ការអាឃាត ទ្រង់សម្តែងធម៌ ដោយអំណាចនៃបុគ្គលដែលគួរសម្រេចមគ្គផលប៉ុណ្ណោះ ។ មាតាបិតានាំនាងមាគន្ទិយានោះ ទៅផ្ញើនឹងនាយចូឡមាគន្ទិយៈ ដែលជាប្អូនប្រុស ហើយទៅកាន់សម្នាក់ព្រះសាស្តា ជនទាំងពីរបួសហើយ ក៏សម្រេចអរហត្ត ។

ចំណែកនាយចូឡមាគន្ទិយៈគិតថា កូនស្រីរបស់អញមិនគួរដល់បុគ្គលថោកទាប គួរដល់ព្រះរាជាតែម្យ៉ាង ទើបនាំនាងទៅកាន់ក្រុងកោសម្ពី តែងខ្លួនដោយគ្រឿងអលង្ការទាំងពួង បានថ្វាយដល់ព្រះបាទឧទេន ដោយពាក្យថា ឥត្ថីរតនៈនេះ គួរដល់ព្រះសម្មតិទេព ។ ព្រះបាទឧទេន គ្រាន់តែទតឃើញ ក៏កើតស្នេហាដ៏ខ្លាំងក្លា ទើបប្រទានការអភិសេក ធ្វើមាតុគ្រាម ៥០០ ឲ្យជាបរិវាររបស់នាង តាំងក្នុងតំណែងនៃអគ្គមហេសីហើយ ។

**នេះជារឿងរបស់នាងមាគន្ទិយា**

ព្រះបាទឧទេននោះ មានអគ្គមហេសី ៣ អង្គ មានស្រីស្នំ ១៥០០ ជាបរិវារ ដោយប្រការដូច្នេះ ។

ក្នុងសម័យនោះឯង ក្រុងកោសម្ពីមានសេដ្ឋី ៣ នាក់ គឺឃោសកសេដ្ឋី ១ កុក្កុដសេដ្ឋី ១ បាវារិកសេដ្ឋី ១ ។ សេដ្ឋីទាំងនោះ កាលវស្សូបនាយិកាជិតចូលមកហើយ ឃើញតាបស ៥០០ មកអំពីហិមវន្តប្បទេស កំពុងត្រាច់ទៅដើម្បីភិក្ខាក្នុងព្រះនគរក៏ជ្រះថ្លា ទើបនិមន្តឲ្យគង់ឲ្យឆាន់ហើយ ទទួល

បព្វជាឲ្យនៅក្នុងសម្នាក់របស់ខ្លួនអស់កាល ៤ ខែ ឲ្យបព្វជាដល់ការមកទៀត ក្នុងសម័យដែលជោកជាំដោយភ្លៀង ហើយបញ្ជូនទៅ ។ ចាប់តាំងអំពីកាលនោះ សូម្បីតាបសទាំងឡាយ នៅក្នុងហិមវន្តប្បទេសអស់ ៨ ខែហើយ ទើបមកនៅក្នុងសម្នាក់របស់សេដ្ឋីទាំងនោះ អស់កាល ៤ ខែ ។ តាបសទាំងនោះ កាលមកអំពីហិមវន្តប្បទេស ក្នុងកាលដទៃ ឃើញដើមជ្រៃធំមួយ ក្នុងដែនអរញ្ញ ទើបអង្គុយត្រង់គល់ជ្រៃនោះ ។ បណ្ដាតាបសទាំងនោះ តាបសដែលជាប្រធានគិតថា ទេវតាដែលអាស្រ័យនៅត្រង់ដើមឈើនេះ នឹងមិនមែនជាទេវតាតូចតាចឡើយ ទេវរាជដែលមានសក្តិធំនោះឯង គប្បីនៅត្រង់ដើមជ្រៃនេះ ជាការល្អហ្ន៎ បើទេវរាជនេះគប្បីឲ្យទឹកដែលគួរផឹកដល់ពួកឥសី ។ ទេវរាជនោះបានប្រគេនទឹកផឹកហើយ ។ តាបសគិតដល់ទឹកងូត ទេវរាជក៏បានប្រគេនទឹកងូតនោះ ។ បន្ទាប់អំពីនោះ តាបសដែលជាប្រធាន ក៏គិតដល់ភោជន ទេវរាជក៏ប្រគេនភោជននោះ ។ លំដាប់នោះ តាបសក៏មានបរិវិតក្កថា ទេវរាជនេះឲ្យវត្ថុសព្វយ៉ាងដែលអញគិតហើយ អើហ្ន៎ អញគប្បីឃើញទេវរាជនោះ ទេវរាជនោះ ជ្រែកដើមឈើបង្ហាញខ្លួនហើយ ។ ខណៈនោះតាបសទាំងឡាយសួរទេវរាជនោះថា នែ ទេវរាជ អ្នកមានសម្បត្តិច្រើន សម្បត្តិនេះអ្នកបានហើយ ព្រោះធ្វើកម្មអ្វីហ្ន៎ ។ ទេវរាជពោលថា សូមលោកម្ចាស់កុំសាកសួរឡើយ តាបសពោលថា ចូរប្រាប់មកចុះ ។ ទេវរាជនោះខ្មាសអៀន ព្រោះកម្មដែលខ្លួនធ្វើជាកម្មតិចតួច ទើបមិនហ៊ានប្រាប់ តែកាលតាបសនោះអង្វររឿយៗ ក៏ពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយស្តាប់ ដូច្នេះ

ហើយ ទើបតំណាលរឿងរបស់ខ្លួនថា

បានឮថា ទេវរាជនោះ ជាអ្នកក្រីក្រម្នាក់ ស្វែងរកការងារស៊ីឈ្នួល បានការងារក្នុងសម្នាក់របស់អនាថបិណ្ឌិកសេដ្ឋីហើយ ក៏អាស្រ័យការងារនោះ ចិញ្ចឹមជីវិត ។ សម័យតមក កាលដល់ថ្ងៃឧបោសថ អនាថបិណ្ឌិកសេដ្ឋីមក អំពីវិហារហើយសួរថា ក្នុងថ្ងៃនេះ បុគ្គលណាបានប្រាប់ភាពជាថ្ងៃឧបោសថ ដល់កូនឈ្នួលនោះហើយឬ មនុស្សក្នុងផ្ទះឆ្លើយថា បពិត្រលោកម្ចាស់ មិន ទាន់បានប្រាប់ទេ ។ អនាថបិណ្ឌិកពោលថា បើដូច្នោះ ពួកអ្នកចូរចម្អិនអាហារ ល្ងាចសម្រាប់គេផង ។ គ្រានោះ មនុស្សទាំងនោះ ក៏ចម្អិនបាយមួយចំណែក ដើម្បីបុរសនោះ ។ បុរសនោះ ធ្វើការងារក្នុងព្រៃពេញមួយថ្ងៃ មកក្នុងវេលា ល្ងាច កាលគេដួសបាយឲ្យ ក៏មិនប្រញាប់បរិភោគ ដោយគិតថា អញជា អ្នកឃ្លាន ហើយគិតថា ក្នុងថ្ងៃទាំងឡាយដទៃ កោលាហលធំរមែងមានក្នុង ផ្ទះនេះថា អ្នកចូរឲ្យបាយ អ្នកចូរឲ្យសម្ល អ្នកចូរឲ្យម្ហូប ក្នុងថ្ងៃនេះ មនុស្ស គ្រប់គ្នា ជាអ្នកស្ងប់ស្ងៀម ដេកហើយ នាំគ្នាអត់អាហារ ទុកដើម្បីអញតែ ម្នាក់ប៉ុណ្ណោះ សេចក្ដីនេះដូចម្ដេចហ្ន៎ ទើបសួរថា មនុស្សដ៏សេស បរិភោគ ហើយឬ មនុស្សទាំងឡាយឆ្លើយថា មិនបរិភោគទេអ្នក អ្នកស៊ីឈ្នួលសួរថា ព្រោះហេតុអ្វីហ្ន៎ មនុស្សទាំងឡាយពោលថា ក្នុងផ្ទះនេះ គេមិនចម្អិនអាហារ ក្នុងពេលល្ងាចថ្ងៃឧបោសថទាំងឡាយឡើយ មនុស្សគ្រប់គ្នា ជាអ្នករក្សា ឧបោសថ ដោយហោច សូម្បីទារកដែលនៅបៅដោះ លោកមហាសេដ្ឋីក៏ឲ្យ ខ្ពុរមាត់ ឲ្យដាក់របស់មានមធុរស ៤ យ៉ាង ចូលក្នុងមាត់ ធ្វើឲ្យជាអ្នករក្សា

ឧបោសថហើយ កាលប្រទីបដែលលាយដោយទឹកប្រអូបកំពុងភ្លឺ កុមារតូចធំទាំងឡាយទៅកាន់ទីដេកហើយ ស្វាធ្យាយអាការ ៣២ តែពួកយើងមិនបានធ្វើសតិ ដើម្បីប្រាប់កាលដែលថ្ងៃនេះជាថ្ងៃឧបោសថដល់អ្នក ព្រោះហេតុនោះទើបពួកខ្ញុំចម្អិនបាយដើម្បីអ្នកម្នាក់ឯង អ្នកចូរបរិភោគអាហារនោះចុះ ។

អ្នកស៊ីឈ្នួលពោលថា បើការដែលខ្ញុំជាអ្នករក្សាឧបោសថក្នុងឥឡូវនេះគួរសោត ខ្ញុំក៏គប្បីជាអ្នករក្សាឧបោសថដែរ ។ មនុស្សទាំងឡាយពោលថា លោកសេដ្ឋីរមែងដឹងរឿងនេះ អ្នកស៊ីឈ្នួលពោលថា បើដូច្នោះ សូមពួកអ្នកសួរលោកសេដ្ឋីនោះ ។ មនុស្សទាំងនោះទៅសួរសេដ្ឋីហើយ សេដ្ឋីពោលយ៉ាងនេះថា បុរសនោះមិនបរិភោគក្នុងឥឡូវនេះ ខ្ពុរមាត់ហើយ អធិដ្ឋានអង្គឧបោសថទាំងឡាយ នឹងបានឧបោសថកម្មពាក់កណ្តាល ។ ចំណែកអ្នកស៊ីឈ្នួលស្តាប់ពាក្យនោះ បានធ្វើតាមនោះហើយ កាលគាត់ស្រេចឃ្លានហើយព្រោះធ្វើការងារពេញមួយថ្ងៃ ខ្យល់កម្រើកហើយក្នុងសរីរៈ គាត់យកខ្សែចងពោះ ចាប់ត្រង់ចុងខ្សែហើយ បម្រះនទៀល សេដ្ឋីស្តាប់ព្រឹត្តហេតុនោះហើយ មានមនុស្សកាន់គប់ភ្លើង ឲ្យមនុស្សកាន់យកមធុរស ៤ ប្រភេទ មកកាន់សម្នាក់របស់បុរសនោះ សួរថា តើអ្នកកើតអ្វី អ្នកស៊ីឈ្នួលប្រាប់ថា បពិត្រលោកម្ចាស់ ខ្យល់កម្រើដល់ខ្ញុំ សេដ្ឋីពោលថា បើយ៉ាងនោះ អ្នកចូរក្រោកឡើង បរិភោគភេសជ្ជៈនេះ អ្នកស៊ីឈ្នួលពោលថា បពិត្រលោកម្ចាស់សូម្បីអ្នកទាំងឡាយទទួលទានហើយឬ សេដ្ឋីពោលថា ជំងឺរបស់ពួកយើងមិនមាន អ្នកបរិភោគចុះ បុរសនោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំកាលធ្វើ

ឧបោសថកម្ម មិនអាចធ្វើឧបោសថកម្មទាំងមូលបាន សូម្បីក្នុងឧបោសថកម្មពាក់កណ្ដាលរបស់ខ្ញុំ កុំបីជារបស់ខ្វះខាតឡើយ ដូច្នេះហើយ ក៏មិនប្រាថ្នានឹងបរិភោគ ។ បុរសនោះ ដែលសេដ្ឋីពោលថា អ្នកកុំធ្វើយ៉ាងនេះ ក៏មិនប្រាថ្នាហើយ កាលអរុណរះ ធ្វើកាលកិរិយាហើយ ដូចផ្កាដែលស្រពោន ដូច្នោះកើតជាទេវតាត្រង់ដើមជ្រៃនោះ ព្រោះហេតុនោះ ទេវតាកាលពោលសេចក្ដីនេះហើយ ទើបពោលថា សេដ្ឋីនោះជាអ្នករាប់អានព្រះពុទ្ធថា ជារបស់យើងរាប់អានព្រះធម៌ថា ជារបស់យើង រាប់អានព្រះសង្ឃថា ជារបស់យើងសម្បត្តិនោះ ខ្ញុំបានហើយ ដោយអានិសង្សនៃឧបោសថកម្មពាក់កណ្ដាលដែលខ្ញុំអាស្រ័យសេដ្ឋីនោះធ្វើហើយ ។

តាបស ៥០០ គ្រាន់តែស្ដាប់ពាក្យថាព្រះពុទ្ធ ក៏ក្រោកឡើងផ្គងអញ្ជលីចំពោះទេវតាពោលថា អ្នកនិយាយថាព្រះពុទ្ធ ដូច្នោះហើយ ឲ្យទេវតានោះប្ដេជ្ញា ៣ ដងថា ខ្ញុំពោលថាព្រះពុទ្ធ ហើយបន្លឺឧទានថា ឃោសៈនេះឯងរកបានកម្រក្នុងលោក ហើយពោលថា នែទេវតា ពួកខ្ញុំដែលអ្នកឲ្យស្ដាប់សំឡេងដែលមិនធ្លាប់ឮហើយ អស់សែនកប្បជាអនេក ។ ក្នុងលំដាប់នោះ ពួកតាបសដែលជាអន្តេវាសិក បានពោលពាក្យនេះនឹងអាចារ្យថា បើដូច្នោះ ពួកយើងនឹងនាំគ្នាទៅកាន់សម្នាក់របស់ព្រះសាស្ដា ។ អាចារ្យពោលថា នែបាទាំងឡាយ សេដ្ឋីបីនាក់ ជាអ្នកមានឧបការៈច្រើនដល់ពួកយើង ។ ស្អែកនេះពួកយើងទទួលភិក្ខា ក្នុងលំនៅរបស់សេដ្ឋីទាំងនោះ ប្រាប់ដល់សេដ្ឋីទាំងនោះហើយ សឹមទៅ បាទាំងឡាយ ពួកបាចូរឈប់បង្អង់សិន ។ តាបសទាំងនោះ

បន្អន់ហើយ ។ ស្អែកឡើង ពួកសេដ្ឋី ត្រៀមបបរ និងកត្តហើយ ក្រាលអាសនៈ ដឹងថា ថ្ងៃនេះជាថ្ងៃមករបស់លោកម្ចាស់នៃយើងទាំងឡាយ ធ្វើការទទួលតាបសទាំងនោះទៅកាន់លំនៅ និមន្តឲ្យអង្គុយ បានថ្វាយភិក្ខាហើយ ។ តាបសទាំងនោះ ធ្វើភត្តកិច្ចស្រេចហើយពោលថា លោកសេដ្ឋីទាំងឡាយ ពួកអាត្មានឹងទៅ ។ សេដ្ឋីពោលថា លោកម្ចាស់ទាំងឡាយទទួលបេ្តជ្ញារបស់ពួកខ្ញុំអស់ ៤ ខែ ក្នុងរដូវភ្លៀងហើយ មិនមែនឬ ឥឡូវនេះលោកម្ចាស់ទាំង-ឡាយ នឹងទៅណា តាបសពោលថា បានឮថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះធម៌ក៏កើតឡើងហើយ ព្រះសង្ឃក៏កើតឡើងហើយ ព្រោះដូច្នោះ យើងទាំងឡាយនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ។ សេដ្ឋីពោលថា ការទៅក្នុងសម្នាក់ព្រះសាស្តាអង្គនោះ គួរដល់លោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ តាបសឆ្លើយថា សូម្បីមនុស្សដទៃក៏គួរ មិនហាមឃាត់ឡើយ អាវុសោ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយបន្អង់សិន ពួកខ្ញុំនឹងធ្វើការប្រុងប្រៀបហើយក៏ទៅ ។

តាបសទាំងនោះពោលថា បើអ្នកទាំងឡាយធ្វើការប្រុងប្រៀប ការយឺតយូរមែងមានដល់ពួកយើង ពួកយើងទៅមុន អ្នកទាំងឡាយគប្បីមកឯក្រោយ ដូច្នេះហើយ ក៏ទៅមុន គាល់ព្រះសម្មាសម្ពុទ្ធ សរសើរហើយ ថ្វាយបង្គំ អង្គុយក្នុងចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់តាបសទាំងនោះ ។ ក្នុងទីបំផុតនៃទេសនា តាបសទាំងពួងសម្រេចអរហត្ត មួយអន្លើដោយ

បដិសម្ភិទាទាំងឡាយហើយ ទូលសូមបព្វជ្ជា បានជាបុគ្គលទ្រទ្រង់នូវបាត្រ និងចីវរ សម្រេចដោយឫទ្ធិ ដូចព្រះថេរៈមានវស្សាមួយរយ ក្នុងលំដាប់នៃព្រះតម្រាស់ថា អ្នកទាំងឡាយ ចូរជាភិក្ខុចុះ ។

សេដ្ឋីទាំងឡាយនោះឯង រៀបចំរទេះម្នាក់ ៥០០ ផ្ទុកគ្រឿងឧបករណ៍ដល់ទាន មានសំពត់ គ្រឿងស្លៀកដណ្តប់ សប្បិ ទឹកឃ្មុំ និងទឹកអំពៅជាដើម ទៅដល់ក្រុងសាវត្ថីហើយ ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា ស្តាប់ធម្មកថាហើយ ក្នុងទីបំផុតនៃកថា ក៏តាំងនៅក្នុងសោតាបត្តិផល ថ្វាយទានក្នុងសម្នាក់របស់ព្រះសាស្តា ប្រមាណកន្លះខែហើយ អារាធនាព្រះសាស្តាដើម្បីប្រយោជន៍យាងទៅកាន់ក្រុងកោសម្ពី កាលព្រះសាស្តាប្រទានបដិញ្ញា ដោយត្រាស់ថា ម្នាលគហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុងផ្ទះស្ងាត់ ទើបសេដ្ឋីទូលថា បពិត្រព្រះអង្គ សេចក្តីនោះខ្ញុំព្រះអង្គជ្រាបហើយ ការដែលព្រះអង្គយាងមកដោយដំណឹង ដែលពួកខ្ញុំព្រះអង្គបញ្ជូនមក រមែងគួរ ដូច្នេះហើយ ទៅកាន់ក្រុងកោសម្ពី ឲ្យសាងវិហារបីកន្លែង គឺឃោសកសេដ្ឋី សាងឃោសិតារាម កុក្កុដសេដ្ឋី សាងកុក្កុដារាម បាវារិកសេដ្ឋី សាងបាវារិការាម ហើយបញ្ជូនដំណឹងទៅ ដើម្បីជាប្រយោជន៍ដល់ការយាងមករបស់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ស្តាប់ដំណឹងរបស់សេដ្ឋីទាំងនោះ ក៏យាងទៅក្នុងទីនោះហើយ ។ សេដ្ឋីទាំងនោះទទួល ទូលអារាធនាព្រះសាស្តាឲ្យយាងចូលទៅក្នុងវិហារហើយ វេរថ្វាយ ៣ ដងថា ខ្ញុំព្រះអង្គសូមថ្វាយវិហារនេះ ដល់ភិក្ខុ-

សង្ឃ ដែលមកអំពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ដូច្នេះហើយ បដិបត្តិតាមវារៈ ។ ព្រះសាស្តាប្រថាប់នៅក្នុងវិហារនីមួយៗ រាល់ៗ ថ្ងៃ ប្រថាប់នៅក្នុងវិហាររបស់សេដ្ឋីណា ទ្រង់ក៏យាងទៅបិណ្ឌបាត ត្រង់ទ្វារផ្ទះរបស់សេដ្ឋីនោះ ។

សេដ្ឋីទាំង ៣ នាក់នោះ មានមាលាការឈ្មោះសុមនៈជាអ្នកឧបដ្ឋាក សុមនមាលាការនោះ ពោលនឹងសេដ្ឋីទាំងនោះយ៉ាងនេះថា ខ្ញុំជាអ្នកធ្វើការឧបដ្ឋាកលោកទាំងឡាយអស់កាលដ៏យូរ ជាអ្នកប្រាថ្នាដើម្បីញ៉ាំងព្រះសាស្តាឲ្យសោយ សូមលោកទាំងឡាយឲ្យព្រះសាស្តាដល់ខ្ញុំមួយថ្ងៃ ។

សេដ្ឋីទាំង ៣ នោះពោលថា នែអ្នក បើដូច្នោះ ចូរនិមន្តព្រះសាស្តាសោយក្នុងថ្ងៃស្អែកចុះ សុមនមាលាការនោះទទួលថា សាធុ ដូច្នោះ ទើបនិមន្តព្រះសាស្តា ត្រៀមគ្រឿងសក្ការៈ ។ ក្នុងកាលនោះ ព្រះរាជាព្រះរាជទានកហាបណៈ ៨ ឲ្យជាតម្លៃផ្កា ឲ្យនាងសាមាវតី រាល់ៗ ថ្ងៃ ទាសីរបស់នាងសាមាវតីនោះ ឈ្មោះនាងខុជ្ជុត្តរាទៅកាន់សម្នាក់របស់សុមនមាលាការទទួលផ្កាទាំងឡាយជានិច្ច ។ បន្ទាប់មក មាលាការពោលនឹងនាងខុជ្ជុត្តរានោះ ដែលមកក្នុងថ្ងៃនោះថា ខ្ញុំនិមន្តព្រះសាស្តាហើយ ថ្ងៃនេះ ខ្ញុំនឹងបូជាព្រះសាស្តាដោយផ្កាដ៏ប្រសើរ ចូរនាងបន្អង់ជួយក្នុងការអង្គាសភិក្ខុ ស្តាប់ធម៌សិន ហើយសឹមទទួលផ្កាទៅ នាងទទួលថា សាធុ ។

សុមនៈអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ បានទទួលបាត្រដើម្បីប្រយោជន៍ដល់ការធ្វើអនុមោទនា ។ ព្រះសាស្តា ទ្រង់ផ្តើមធម្មទេសនា

ជាគ្រឿងអនុមោទនាហើយ ចំណែកនាងខុជ្ជុត្តរាស្តាប់ធម្មកថារបស់ព្រះសាស្តា នោះឯង តាំងនៅក្នុងសោតាបត្តិផលហើយ ។ ក្នុងថ្ងៃទាំងឡាយដទៃ នាងកាន់យក ៤ កហាបណៈសម្រាប់ខ្លួន ទិញផ្កាទៅដោយ ៤ កហាបណៈ ។ ក្នុងថ្ងៃនោះ នាងទទួលផ្កាទៅ ទាំង ៨ កហាបណៈ ។

លំដាប់នោះ នាងសាមាវតីពោលនឹងនាងខុជ្ជុត្តរានោះថា នែនាង ព្រះរាជាប្រទានតម្លៃផ្កាដល់ខ្ញុំបន្ថែមឡើងពីរដងឬ នាងខុជ្ជុត្តរាពោលថា បពិត្រព្រះនាង មិនមែនដូច្នោះឡើយ ។ នាងសាមាវតីពោលថា បើយ៉ាងនេះ ព្រោះហេតុអ្វី ទើបផ្កាច្រើនជាងមុន នាងខុជ្ជុត្តរាពោលថា ក្នុងថ្ងៃទាំងឡាយដទៃ ខ្ញុំម្ចាស់កាន់យក ៤ កហាបណៈសម្រាប់ខ្លួនឯង នាំផ្កាមក ៤ កហាបណៈប៉ុណ្ណោះ ។ នាងសាមាវតីពោលថា ក្នុងថ្ងៃនេះ ព្រោះហេតុអ្វី ទើបមិនកាន់យក នាងខុជ្ជុត្តរាពោលថា ព្រោះខ្ញុំម្ចាស់ស្តាប់ធម្មកថារបស់ព្រះសម្មាសម្ពុទ្ធហើយសម្រេចធម៌ ។

លំដាប់នោះ នាងសាមាវតីមិនបានគំរាមនាងខុជ្ជុត្តរានោះ ដោយពាក្យថា វ៉ុយ ទាសីអាក្រក់ ហងចូរឲ្យកហាបណៈដែលកាន់យកហើយអស់កាលមានប្រមាណប៉ុណ្ណោះដល់អញ បែរជាពោលថា នែនាង ចូរនាងផ្ញើយើងទាំង-ឡាយឲ្យផឹកអមតរស ដែលនាងផឹកហើយ ។ កាលនាងពោលថា បើយ៉ាងនោះ សូមព្រះនាងញ៉ាំងខ្ញុំឲ្យងូតទឹក ទើបឲ្យនាងងូតទឹកដោយក្អមទាំង ១៦ ហើយ ប្រើឲ្យប្រទានសាដកសាច់ល្អ ២ ផ្ទាំង នាងខុជ្ជុត្តរានោះ ស្លៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ឲ្យក្រាលអាសនៈហើយ ឲ្យនាំផ្ចិតមកមួយ អង្គុយលើ

*អាសនៈចាប់ផ្ចិតដ៏វិចិត្រ ហៅមាតុគ្រាម ៥០០ មកហើយ សម្ដែងធម៌ដល់ស្រីទាំងនោះ ដោយទំនងដែលព្រះសាស្ដាទ្រង់សម្ដែងហើយនោះឯង ។ ស្រីទាំងឡាយនោះ ស្ដាប់ធម្មកថារបស់នាងហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ស្រីទាំងឡាយនោះ ថ្វាយបង្គំនាងខុជ្ជុត្តរាហើយ ពោលថា នែនាង តាំងអំពីថ្ងៃនេះទៅ នាងកុំធ្វើការងារដែលសៅហ្មង ចូរតាំងនៅក្នុងឋានៈនៃមាតា និងឋានៈនៃអាចារ្យរបស់ពួកខ្ញុំ ទៅកាន់សម្នាក់ព្រះសាស្ដា ស្ដាប់ធម៌ដែលព្រះសាស្ដាទ្រង់សម្ដែងហើយ ចូរពោលដល់ពួកខ្ញុំ ។ នាងខុជ្ជុត្តរាធ្វើយ៉ាងនោះ ក្នុងកាលដទៃ ក៏ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកហើយ ។*

*សម័យតមក ព្រះសាស្ដា ទ្រង់តាំងនាងខុជ្ជុត្តរានោះ ក្នុងតំណែងជាឯតទគ្គថា ម្នាលភិក្ខុទាំងឡាយ ខុជ្ជុត្តរាជាកំពូលជាងបណ្ដាឧបាសិកាសាវិការបស់តថាគតខាងធម្មកថិក ។ ស្រី ៥០០ នោះឯង ពោលនឹងនាងខុជ្ជុត្តរាយ៉ាងនេះថា នែនាង ពួកខ្ញុំប្រាថ្នាដើម្បីគាល់ព្រះសាស្ដា សូមនាងបង្ហាញព្រះសាស្ដាដល់យើងខ្ញុំទាំងឡាយ ពួកខ្ញុំនឹងបូជាព្រះសាស្ដានោះ ដោយគ្រឿងសក្ការបូជា មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ។ នាងខុជ្ជុត្តរាពោលថា ព្រះនាងទាំងឡាយ ឈ្មោះថា រាជត្រកូលជាភារៈធ្ងន់ ខ្ញុំមិនអាចនាំព្រះនាងទាំងឡាយទៅខាងក្រៅបានទេ ។ ស្រីទាំងនោះពោលថា នែនាង នាងកុំឲ្យពួកខ្ញុំវិនាសឡើយ សូមនាងបង្ហាញព្រះសាស្ដាដល់ពួកខ្ញុំចុះ នាងខុជ្ជុត្តរាពោលថា បើយ៉ាងនោះ ការសម្លឹងមើល ជាការដែលព្រះនាងអាចធ្វើបាន ដោយប្រហោងមានប្រមាណប៉ុណ្ណា ចូរចោះប្រហោង មានប្រមាណប៉ុណ្ណោះ*

ត្រង់ជញ្ជាំងបន្ទប់ដែលជាលំនៅរបស់ពួកព្រះនាង ឲ្យនាំគ្រឿងក្រអូប និង កម្រងផ្កាជាដើមមកហើយ ឈរខាងក្នុងទីនោះៗ ចូរសម្លឹងមើល ចូរលាព្រះហស្តទាំងពីរចេញ ថ្វាយបង្គំ និងចូរបូជាព្រះសាស្តា ដែលទ្រង់យាងទៅកាន់ផ្ទះរបស់សេដ្ឋីទាំងបី ។

ស្រីទាំងនោះ ធ្វើយ៉ាងនោះហើយ សម្លឹងមើលព្រះសាស្តាដែលយាងទៅ និងយាងមក ថ្វាយបង្គំ និងបូជាហើយ ។

សម័យថ្ងៃមួយ ព្រះនាងមាគន្ទិយាយាងចេញអំពីផ្ទៃប្រាសាទរបស់ខ្លួន ទៅកាន់លំនៅរបស់ស្រីទាំងនោះ ឃើញប្រហោងក្នុងបន្ទប់ទាំងឡាយហើយ ទើបសួរថា នេះជាប្រហោងអ្វី កាលស្រីទាំងនោះ មិនដឹងនូវការអាឃាតដែលព្រះនាងនោះចងក្នុងព្រះសាស្តា ទើបឆ្លើយថា ព្រះសាស្តាយាងមកនគរយើង ពួកខ្ញុំម្ចាស់ឈរក្នុងទីនេះ រមែងថ្វាយបង្គំ និងបូជាព្រះសាស្តា ដូច្នេះហើយ គិតថា ព្រះសមណគោតមមកហើយកាន់នគរនេះ ឥឡូវនេះ អញនឹងធ្វើកម្មដែលគួរដល់ព្រះសមណគោតមនេះ សូម្បីស្រីទាំងនោះ ក៏ជាឧបដ្ឋាយិការបស់ព្រះគោតមនោះ អញនឹងដឹងកម្មដែលគប្បីធ្វើដល់ស្រីទាំងនេះ ទើបទៅក្រាបទូលដល់ព្រះរាជាថា បពិត្រមហារាជ ស្រី ៥០០ មួយអន្លើដោយនាងសាមាវតី មានការប្រាថ្នាខាងក្រៅ ព្រះអង្គនឹងមិនមានព្រះជន្មក្នុងរយៈ ២-៣ ថ្ងៃពិត ។ ព្រះរាជាទ្រង់មិនជឿ ដោយទ្រង់ព្រះតម្រិះថា ស្រីទាំងនេះនឹងមិនធ្វើកម្មបែបនេះ ។ កាលព្រះនាងមាគន្ទិយាក្រាបទូលទៀត ក៏ទ្រង់មិនជឿនោះឯង ។

លំដាប់នោះ ទើបព្រះនាងមាគន្ទិយាក្រាបទូលព្រះរាជានោះ កាលក្រាបទូលយ៉ាងនេះអស់ ៣ ដង ទ្រង់ក៏នៅតែមិនជឿ ទើបពោលថា បើព្រះអង្គមិនជឿខ្ញុំម្ចាស់សោត បពិត្រមហារាជ សូមទ្រង់យាងទៅកាន់លំនៅរបស់ស្រីទាំងនោះហើយ ទ្រង់ពិចារណាចុះ ។ ព្រះរាជាយាងទៅទតឃើញប្រហោងក្នុងបន្ទប់ទាំងឡាយ ទើបត្រាស់សួរថា នេះប្រហោងអ្វី កាលស្រីទាំងនោះក្រាបទូលសេចក្ដីនោះហើយ ទ្រង់មិនពិរោធចំពោះស្រីទាំងនោះ មិនត្រាស់ពាក្យឯណានីមួយឡើយ បញ្ជាឲ្យបិទប្រហោងទាំងឡាយចេញ ហើយឲ្យធ្វើបង្អួចមានប្រហោងតូចក្នុងបន្ទប់ទាំងពួង ។ បានឮថា បង្អួចមានប្រហោងតូចទាំងឡាយកើតឡើង ហើយក្នុងកាលនោះ ។

ព្រះនាងមាគន្ទិយាមិនអាចធ្វើអ្វីដល់ស្រីទាំងនោះបាន ក៏ត្រិះរិះថា អញនឹងធ្វើកម្មដែលគួរធ្វើដល់ព្រះសមណគោតមឲ្យបាន ទើបឲ្យឈ្នួលដល់អ្នកស្រុក ហើយពោលថា ពួកអ្នកមួយអន្លើដោយពួកបុរសដែលជាទាសៈ និងកម្មករ ចូរជេរបរិភាសព្រះសមណគោតម ដែលចូលទៅខាងក្នុងព្រះនគរ ឲ្យគេចទៅ ។ ពួកមិច្ឆាទិដ្ឋិមិនជ្រះថ្លាក្នុងរតនៈ ៣ ក៏ជាប់តាមព្រះសាស្ដា ដែលយាងទៅខាងក្នុងព្រះនគរ ហើយជេរបរិភាស ដោយអក្កោសវត្ថុ ១០ យ៉ាងថា អ្នកជាចោរ អ្នកជាបុគ្គលពាល អ្នកជាមនុស្សឆ្កួត អ្នកជាសត្វអូដ្ឋ អ្នកជាគោ អ្នកជាលា អ្នកជាសត្វនរក អ្នកជាសត្វតិរច្ឆាន សុគតិរបស់អ្នកមិនមាន អ្នកមានតែទុគ្គតិតែម្យ៉ាង ។ ព្រះអានន្ទស្ដាប់ពាក្យនោះហើយ ក្រាបទូលពាក្យនេះដល់ព្រះសាស្ដាថា បពិត្រព្រះអង្គ អ្នកក្រុងទាំងនេះ ជេរ បរិភាស

ពួកយើង ពួកយើងនឹងទៅក្នុងទីដទៃអំពីទីនេះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ យើងនឹងទៅទីណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់ក្រុងដទៃ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលពួកមនុស្សក្នុងក្រុងនោះជេរទៀត យើងនឹងទៅក្នុងទីណាទៀត ព្រះអានន្ទពោលថា បពិត្រព្រះអង្គ ទៅកាន់ក្រុងដទៃអំពីក្រុងនោះទៀត ។ ព្រះសាស្តាត្រាស់ថា បើពួកមនុស្សក្នុងក្រុងនោះជេរទៀត យើងនឹងទៅទីណាវិញ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ទៅកាន់ក្រុងដទៃអំពីក្រុងនោះទៀត ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ កាលធ្វើយ៉ាងនេះមិនគួរ អធិករណ៍កើតឡើងក្នុងទីណា កាលអធិករណ៍នោះរម្ងាប់ហើយក្នុងទីនោះឯង ទើបគួរទៅក្នុងទីដទៃ ម្នាលអានន្ទ ឯពួកជនដែលជេរនោះជានរណា ព្រះអានន្ទត្រាស់ថា បពិត្រព្រះអង្គ ជនទាំងនោះជាអ្នកក្រ មួយអន្លើដោយទាសៈ និងកម្មករ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតដូចស្តេចដំរីចុះកាន់សង្គ្រាម ការអត់ធន់នឹងព្រួញដែលមកអំពីទិសទាំង ៤ រមែងជាភារៈរបស់ដំរីដែលចុះកាន់សង្គ្រាម យ៉ាងណា ឈ្មោះថា ការអត់ធន់ចំពោះពាក្យសម្តី ដែលបុគ្គលទ្រុស្តសីលជាច្រើនពោលហើយ ក៏ជាភារៈរបស់យើងដូច្នោះដូចគ្នា ដូច្នេះហើយ កាលទ្រង់ប្រារព្ធព្រះអង្គសម្តែងធម្មភាសិតទាំង ៣ នេះ ក្នុងនាគវគ្គថា

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីកាលអត់ទ្រាំចំពោះព្រួញ ដែលរបូតចេញអំពីធ្នូក្នុងសង្គ្រាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈដែលទូន្មានហើយ ទៅកាន់ទីប្រជុំ ព្រះរាជាស្តេចតែង

ឡើងកាន់វាហនៈដែលទូន្មានហើយ បណ្ដាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា បុគ្គលប្រសើរបំផុត ។ ពួកសេះអស្សតរក្ដី សេះអាជានេយ្យក្ដី សេះសិន្ធពក្ដី ដំរីកុញ្ជរដ៏ប្រសើរក្ដី ដែលបុគ្គលប្រៀនប្រដៅបានបទហើយ រាប់ថាជាសត្វប្រសើរ បុគ្គលដែលមានខ្លួនទូន្មានបានបទហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

ធម្មកថាបានជាប្រយោជន៍ដល់មហាជន ដែលដល់ព្រមហើយ ព្រះសាស្ដាកាលទ្រង់សម្ដែងធម៌យ៉ាងនោះហើយ ត្រាស់ថា ម្នាលអានន្ទ អ្នកកុំគិតឡើយ ជនទាំងនោះ នឹងជេរបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃទី ៧ នឹងជាអ្នកស្ងៀម ព្រោះថា អធិករណ៍ដែលកើតឡើងដល់ព្រះពុទ្ធទាំងឡាយ រមែងមិនលើស ៧ ថ្ងៃ ។

ព្រះនាងមាគន្ទិយា ឲ្យមនុស្សជេរព្រះសាស្ដាហើយ តែមិនអាចឲ្យគេចទៅបាន ទើបគិតថា អញនឹងធ្វើដូចម្ដេចហ្ន៎ ដូច្នេះហើយ គិតថា ស្រីទាំងនេះជាអ្នកឧបត្ថម្ភព្រះសមណគោតមនោះ អញនឹងធ្វើការវិនាសឲ្យដល់ស្រីទាំងនោះ ថ្ងៃមួយ កាលធ្វើនូវការបម្រើក្នុងទីសោយទឹកចណ្ឌនៃព្រះរាជា បញ្ជូនដំណឹងទៅឲ្យឪពុកមាថា សូមជ្រាបថា ខ្ញុំត្រូវការមាន់ទាំងឡាយ សូមឪពុកមានាំយកមាន់ស្លាប់៨ មាន់រស់ ៨ មក កាលបញ្ជូនមាន់មកហើយ ចូរឈរត្រង់ជណ្ដើរ ប្រាប់ភាពដែលខ្លួនមកហើយ កាលប្រាប់ថា ចូរចូលមក ក៏កុំចូលទៅ ចូរបញ្ជូនមាន់រស់ ៨ ទៅមុន បញ្ជូនមាន់ស្លាប់ ៨ ក្រៅអំពីនេះទៅក្រោយ

ព្រះនាងបានប្រទានថ្លៃឈ្នួលដល់អ្នកបម្រើ ដោយប្រាប់ថា អ្នកគប្បីធ្វើតាមពាក្យរបស់យើង ។

នាយមាគន្ទិយៈមកហើយ ទូលដល់ព្រះរាជាឲ្យទ្រង់ជ្រាប កាលប្រាប់ថា ចូរចូលមក ក៏ពោលថា ខ្ញុំនឹងមិនចូលទៅកាន់ទីសោយទឹកចណ្ឌរបស់ព្រះរាជា ចំណែកនាងមាគន្ទិយា បញ្ជូនអ្នកបម្រើទៅដោយពាក្យថា នែបា បាចូរទៅកាន់សម្នាក់របស់ឪពុកមាយើង ចូលទៅហើយ នាំមាន់រស់ ៨ ដែលនាយមាគន្ទិយៈនោះឲ្យហើយមក ក្រាបទូលថា បពិត្រសម្មតិទេព បុរោហិតបញ្ជូនគ្រឿងបណ្ណាការមកហើយ ។ ព្រះរាជាត្រាស់ថា ល្អហើយ សម្ងុឧត្តរិកង្គកើតឡើងដល់ពួកយើងហើយ អ្នកណាហ្នុំគួរស្ងួ ។ ព្រះនាងមាគន្ទិយាក្រាបទូលថា បពិត្រមហារាជ ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន ជាអ្នកមិនមានការងារ ដើរចុះឡើង សូមទ្រង់បញ្ជូនទៅឲ្យស្រីទាំងនោះៗ ស្ងួហើយ នឹងនាំមក ។ ព្រះរាជាទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា អ្នកចូរទៅឲ្យដល់ស្រីទាំងនោះ បានឮថា ស្រីទាំងនោះ ចូរកុំឲ្យក្នុងដៃអ្នកដទៃ ចូរសម្លាប់ស្ងួខ្លួនឯងនោះឯង ។ អ្នកបម្រើទទួលព្រះតម្រាស់ថា សាធុ ព្រះអង្គ ហើយទៅប្រាប់យ៉ាងនោះ ស្រីទាំងនោះជំទាស់ហើយថា ពួកខ្ញុំមិនធ្វើបាណាតិបាត ទើបមកក្រាបទូលសេចក្តីនោះដល់ព្រះរាជា ព្រះនាងមាគន្ទិយាក្រាបទូលថា បពិត្រមហារាជ ទ្រង់ឃើញទេ ឥឡូវនេះ ព្រះអង្គទ្រង់នឹងជ្រាបការធ្វើឬមិនធ្វើបាណាតិបាតនៃស្រីទាំងនោះ សូមទ្រង់ត្រាស់ថា ស្រីទាំងនោះ ចូរស្ងួបញ្ជូនទៅថ្វាយដល់ព្រះសមណគោតមដូច្នេះចុះ ព្រះរាជាត្រាស់យ៉ាងនោះហើយបញ្ជូនទៅ ។ អ្នក

បម្រើ កាន់មាន់ធ្វើជាដើរចេញទៅហើយ ឲ្យមាន់ទាំងនោះដល់បុរោហិត ទទួលមាន់ស្លាប់ទៅកាន់សម្នាក់របស់ស្រីទាំងនោះ ពោលថា បានឮថា ពួកព្រះនាងចូរស្ងួមាន់នេះហើយ បញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា ។ ស្រីទាំងនោះទទួលថា នែអ្នក ចូរនាំមកចុះ ឈ្មោះថា ការស្ងួមាន់ស្លាប់នេះ ជាកិច្ចរបស់ពួកយើងដូច្នេះហើយ ក៏ទទួល ។ អ្នកបម្រើនោះ មកកាន់សម្នាក់របស់ព្រះរាជា កាលព្រះរាជាសួរថា សេចក្តីនេះដូចម្តេច ទើបក្រាបទូលថា ខ្ញុំព្រះអង្គគ្រាន់តែពោលថា សូមពួកព្រះនាងស្ងួបញ្ជូនទៅថ្វាយព្រះសមណគោតមប៉ុណ្ណោះ ស្រីទាំងនោះក៏ស្ទុះមកទទួលយកហើយ ។ ព្រះនាងមាគន្ទិយាក្រាបទូលថា បពិត្រមហារាជ សូមមើលចុះ ស្រីទាំងនោះ មិនធ្វើដល់បុគ្គលដូចព្រះអង្គឡើយ កាលខ្ញុំម្ចាស់ទូលថា ស្រីទាំងនោះមានសេចក្តីប្រាថ្នាខាងក្រៅ ទ្រង់ក៏មិនជឿ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះ ទ្រង់ក៏អត់សង្កត់នៅស្ងៀមដូចមុន ។ ព្រះនាងមាគន្ទិយាគិតថា យើងនឹងធ្វើដូចម្តេចហ្ន៎ ។

ក្នុងកាលនោះ ព្រះរាជាទ្រង់រមែងឈប់សម្រាកអស់ ៧ ថ្ងៃ តាមវារៈ គឺក្នុងប្រាសាទនៃស្រីទាំង ៣ នោះ គឺព្រះនាងសាមាវតី ព្រះនាងវាសុលទត្តា និងព្រះនាងមាគន្ទិយា ។ លំដាប់នោះ ព្រះនាងមាគន្ទិយាដឹងថា ស្អែកនេះ ឬខានស្អែក ព្រះរាជានឹងយាងទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតី ទើបបញ្ជូនដំណឹងទៅដល់ឪពុកមាថា សូមជ្រាបថា ខ្ញុំត្រូវការដោយពស់ សូមឪពុកមាដកចង្កូមពស់ទាំងឡាយ ហើយបញ្ជូនពស់មកមួយក្បាល ។ នាយមាគន្ទិយៈធ្វើយ៉ាងនោះ ហើយបញ្ជូនទៅ ។ ព្រះរាជាទ្រង់កាន់យកពិនហត្ថិកន្តៈ

យានទៅកាន់ទីដែលទ្រង់យានទៅ ។ ក្នុងស្នូកពិណានោះ មានប្រហោងមួយ ព្រះនាងមាគន្ទិយា លែងពស់ចូលក្នុងប្រហោងនោះ ហើយបិទប្រហោង ដោយផ្កា ។ ពស់បាននៅក្នុងពិណានោះឯង អស់ ២-៣ ថ្ងៃ ។ ក្នុងថ្ងៃយាន ទៅនៃព្រះរាជា ព្រះនាងមាគន្ទិយាទូលសួរថា បពិត្រព្រះសម្មតិទេព ថ្ងៃនេះ ទ្រង់យានទៅប្រាសាទរបស់មហេសីអង្គណា កាលត្រាស់ថា របស់នាង សាមាវតី ទើបក្រាបទូលថា បពិត្រមហារាជ ថ្ងៃនេះ ខ្ញុំម្ចាស់សុបិនឃើញ ហេតុមិនជាទីពេញចិត្ត បពិត្រព្រះសម្មតិទេព ទ្រង់មិនអាចយានទៅក្នុងថ្ងៃ នោះបានទេ ។ ព្រះរាជាត្រាស់ថា យើងនឹងទៅឲ្យបាន ព្រះនាងឃាត់ដល់ ៣ ដង ហើយទូលថា បើដូច្នោះ ខ្ញុំម្ចាស់នឹងទៅជាមួយទ្រង់ដែរ ព្រះរាជាឲ្យ ត្រឡប់ក៏មិនត្រឡប់ ក្រាបទូលថា ខ្ញុំម្ចាស់មិនជ្រាបថា នឹងមានហេតុអ្វី ដូច្នោះ ហើយ ក៏បានទៅជាមួយព្រះរាជាទាល់តែបាន ។ ព្រះរាជាទ្រង់សំពត់ផ្កា គ្រឿង ក្រអូប និងគ្រឿងអាភរណៈដែលពួកញាតិ មួយអន្លើដោយព្រះនាងសាមាវតី ថ្វាយ សោយភោជនដ៏ល្អ ដាក់ពិណាខាងលើសីសៈ ហើយផ្ទំលើទីបន្ទំ ។ ព្រះនាងមាគន្ទិយា ធ្វើជាដើរទៅមក បាននាំផ្កាចេញអំពីប្រហោងពិន ។ ពស់ អត់អាហារ ២-៣ ថ្ងៃ លូនចេញអំពីប្រហោងនោះ ព្រោះពិសបើកពពារ ដេកលើទីបន្ទំហើយ ។ ព្រះនាងមាគន្ទិយាឃើញពស់នោះ ក៏ស្រែកឡើងថា ពស់ ព្រះអង្គ កាលជេរព្រះរាជា និងស្រីទាំងនោះ ទើបពោលថា ស្តេច ផែនដីល្ងង់អគ្គនេះ មិនមានវាសនា មិនស្តាប់ពាក្យរបស់អញ សូម្បីស្រីទាំង នេះ ក៏ជាមនុស្សមិនមានសិរី ក្បាលរឹង ពួកវា មិនបានអ្វីអំពីសម្នាក់របស់

ស្តេចផែនដីឬ ពួកនាងកាលស្តេចផែនដីអង្គនេះសោយទិវង្គតហើយ នឹងជាអ្នកនៅសប្បាយឬ កាលស្តេចផែនដីនៅមានព្រះជន្ម ពួកនាងនៅលំបាកឬ ថ្ងៃនេះ យើងឃើញសុបិនអាក្រក់ហើយ បពិត្រព្រះអង្គ ព្រះអង្គមិនស្តាប់សំឡេងរបស់ខ្ញុំម្ចាស់ដែលអង្វរថា មិនគួរយាងទៅប្រាសាទរបស់ព្រះនាងសាមាវតីទេ ។

ព្រះរាជាទតឃើញពស់ ក៏ទ្រង់ស្លុតព្រះហឫទ័យ ខ្លាចចំពោះមរណៈ បានឆេះសន្ធោសន្ធៅដោយសេចក្តីពិរោធថា ស្រីទាំងនេះធ្វើកម្មបែបនេះ ហ៊ឺះ អញក៏អាក្រក់ មិនជឿពាក្យរបស់នាងមាគន្ទិយា ដែលប្រាប់ភាពដែលស្រីទាំងនេះជាមនុស្សលាមក ក្នុងកាលមុន វាចោះប្រហោងក្នុងបន្ទប់ទាំងឡាយរបស់ខ្លួន អង្គុយហើយ កាលអញបញ្ជូនមាន់ទៅឲ្យ ក៏បញ្ជូនត្រឡប់មកវិញ ថ្ងៃនេះ លែងពស់លើទីដេក ។

ចំណែកនាងសាមាវតី ក៏បានឲ្យឱវាទដល់ស្រី ៥០០ ថា នែនាងទាំង-ឡាយ ទីពឹងរបស់ពួកយើងមិនមាន ចូរនាងញ៉ាំងមេត្តាចិត្តដ៏ស្មើនោះឯង ឲ្យប្រព្រឹត្តទៅក្នុងព្រះរាជា ដែលជាកំពូលនៃនរជន ក្នុងព្រះទេវី និងក្នុងខ្លួននាងទាំងឡាយ កុំធ្វើសេចក្តីក្រោធចំពោះបុគ្គលណាម្នាក់ឡើយ ព្រះរាជាទ្រង់កាន់ធ្នូ មានសណ្ឋានដូចក្អកដ៏រឹ ដែលមានកម្លាំងរបស់មនុស្ស ១ ពាន់ ទ្រង់ទាញខ្សែហើយ ផ្គាប់ព្រួញដែលលាបដោយពិស ធ្វើនាងសាមាវតីឲ្យនៅខាងមុខឲ្យស្រីទាំងនោះឈរតាមលំដាប់គ្នាហើយ ទើបលែងព្រួញទៅត្រង់ព្រះឱរៈរបស់ព្រះនាងសាមាវតី ។ ព្រួញនោះបែរមុខមករកព្រះរាជាហើយ ហាក់ដូច

ចូលទៅកាន់ហទយៈរបស់ព្រះរាជា បានតាំងនៅហើយ ដោយមេត្តានុភាពរបស់ព្រះនាងសាមាវតីនោះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រួញដែលអញបាញ់ទៅ រមែងទម្លុះបានសូម្បីថ្ម សូម្បីឋានៈដែលប៉ះក្នុងអាកាស ក៏មិនមាន បើដូច្នេះ ព្រួញនេះបែរមុខមករកបេះដូងរបស់អញដូចម្ដេចហ្ន៎ ពិតហើយ ព្រួញនេះមិនមានចិត្ត មិនមែនសត្វ មិនមែនរបស់មានជីវិត គង់ដឹងគុណរបស់នាងសាមាវតី ឯអញជាមនុស្ស ហេតុអ្វីក៏មិនដឹងគុណ ។

ព្រះរាជាបោះធ្នូចោល ទ្រង់ផ្គងអញ្ជលី អង្គុយប្រហោងទៀបបាទារបស់ព្រះនាងសាមាវតី ត្រាស់ព្រះគាថានេះថា

ខ្ញុំញាប់ញ័រ វង្វេង ទិសទាំងពួងងងឹតដល់ខ្ញុំ នៃសាមាវតី
ចូរនាងជាទីអាស្រ័យ ចូរនាងជាទីពឹងរបស់ខ្ញុំ ។

ព្រះនាងសាមាវតី ស្ដាប់ព្រះតម្រាស់ព្រះរាជាហើយ ក៏មិនបានក្រាបទូលថា សាធុ សម្មតិទេព ទ្រង់ដល់នូវខ្ញុំម្ចាស់ជាទីពឹងចុះ តែក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ដល់បុគ្គលណាជាទីពឹង សូមព្រះអង្គដល់បុគ្គលនោះឯងជាទីពឹងចុះ ។

ព្រះនាងសាមាវតី ដែលជាសាវិការបស់ព្រះសម្មាសម្ពុទ្ធ កាលពោលពាក្យនេះហើយ ក៏ពោលថា

សូមទ្រង់កុំដល់ខ្ញុំម្ចាស់ជាទីពឹងឡើយ ខ្ញុំម្ចាស់ដល់បុគ្គលណាជាទីពឹង បពិត្រមហារាជ បុគ្គលនោះ គឺព្រះពុទ្ធ ព្រះពុទ្ធអង្គនោះជាកំពូល សូមទ្រង់ដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងផង ទ្រង់ជា

ទីពឹង របស់ខ្ញុំម្ចាស់ផង ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់នាងសាមាវតីនោះហើយ ទើបត្រាស់ថា ឥឡូវនេះ យើងរឹងរឹតតែខ្វាចខ្វាំងឡើង ហើយត្រាស់គាថានេះថា ខ្ញុំវង្វេងក្រៃលែងឡើង ទិសទាំងពួងងងឹតដល់ខ្ញុំ នែសាមាវតី ចូរនាងជាទីអាស្រ័យនៃខ្ញុំ និងជាទីពឹងរបស់ខ្ញុំ ។

លំដាប់នោះ ព្រះនាងសាមាវតីក៏ទូលសួរព្រះរាជាទៀត ដោយន័យមុននោះឯង កាលព្រះរាជាត្រាស់ថា បើដូច្នោះ ខ្ញុំសូមដល់នាង និងព្រះសាស្តាជាទីពឹង ហើយខ្ញុំនឹងឲ្យពរដល់នាង ដូច្នេះហើយ ទើបក្រាបទូលថា បពិត្រមហារាជ ពរសូមជារបស់ដែលខ្ញុំម្ចាស់បានទទួលចុះ ។ ព្រះរាជាយាងចូលទៅគាល់ព្រះសាស្តា ទ្រង់ដល់ព្រះពុទ្ធជាសរណៈហើយ ទ្រង់និមន្តព្រះសាស្តា ថ្វាយទានដល់ភិក្ខុសង្ឃអស់ ៧ ថ្ងៃ ទ្រង់ហៅព្រះនាងសាមាវតីមកត្រាស់ថា នាងចូរក្រោកឡើងទទួលពរ ។ ព្រះនាងសាមាវតីក្រាបទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ត្រូវការដោយវត្ថុទាំងឡាយ មានប្រាក់ជាដើមឡើយ បពិត្រព្រះអង្គ សូមទ្រង់ព្រះរាជទានពរនេះដល់ខ្ញុំម្ចាស់ គឺព្រះសាស្តា មួយអន្លើដោយភិក្ខុ ៥០០ រូប នឹងយាងមកក្នុងទីនេះជានិច្ច បានដោយប្រការណា សូមទ្រង់ធ្វើដោយប្រការនោះចុះ ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ។ ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ ទូលថា បពិត្រព្រះអង្គ សូមទ្រង់យាងមកក្នុងទីនេះជានិច្ចព្រមដោយភិក្ខុ ៥០០ ។ ពួកស្រីដែលរួមទាំងព្រះនាងសាមាវតីចូលផងពោលថា ខ្ញុំម្ចាស់នឹងស្តាប់ធម៌ ។

ព្រះសាស្តាត្រាស់ថា បពិត្រមហារាជ ធម្មតាការទៅក្នុងទីតែមួយជានិច្ច រមែងមិនគួរដល់ព្រះពុទ្ធទាំងឡាយ ព្រោះមហាជនទន្ទឹងចំពោះព្រះពុទ្ធ ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើយ៉ាងនោះ សូមទ្រង់បញ្ជូនភិក្ខុមួយរូបចុះ ។

ព្រះសាស្តា ទ្រង់ប្រគល់នាទីដល់ព្រះអានន្ទត្ថេរហើយ ។ ចាប់តាំងអំពីកាលនោះ ព្រះអានន្ទត្ថេរក៏នាំភិក្ខុ ៥០០ ទៅកាន់រាជត្រកូលជានិច្ច ព្រះទេវីទាំងនោះ អង្គាសព្រះថេរៈ មួយអន្លើដោយបរិវារស្តាប់ធម៌ជានិច្ចកាល ។

ថ្ងៃមួយ ស្រីទាំងនោះ ស្តាប់ព្រះធម្មកថារបស់ព្រះអានន្ទត្ថេរហើយ ជ្រះថ្លា បានធ្វើការបូជាធម៌ដោយសំពត់ឧត្តរាសង្គៈ ៥០០ ផ្ទាំង ។ ឧត្តរាសង្គៈនីមួយៗ មានតម្លៃ ៥០០ ។ ព្រះរាជាទ្រង់មិនឃើញសំពត់មួយផ្ទាំងរបស់ស្រីទាំងនោះ ទើបត្រាស់សួរថា សំពត់ឧត្តរាសង្គៈនៅឯណា ស្រីទាំងនោះក្រាបទូលថា ខ្ញុំម្ចាស់ប្រគេនដល់លោកម្ចាស់ ។ ព្រះរាជាត្រាស់ថា លោកម្ចាស់អង្គនោះទទួលទាំងអស់ឬ ស្រីទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ លោកទទួលទាំងអស់ ។

ព្រះរាជាយាងចូលទៅរកព្រះអានន្ទត្ថេរហើយ ត្រាស់សួរភាពដែលស្រីទាំងនោះប្រគេនសំពត់ឧត្តរាសង្គៈ ទ្រង់ស្តាប់ភាពដែលសំពត់ ដែលស្រីទាំងនោះ ប្រគេនហើយ និងភាពដែលព្រះថេរៈទទួលហើយ ទើបត្រាស់សួរថា បពិត្រលោកម្ចាស់ សំពត់ទាំងឡាយច្រើនពេកមិនមែនឬ លោកម្ចាស់នឹងធ្វើអ្វីដោយសំពត់មានប្រមាណប៉ុណ្ណេះ ព្រះអានន្ទត្ថេរពោលថា បពិត្រមហារាជ

អាត្មាទទួលសំពត់ល្មមដល់អាត្មាភាពហើយ នឹងប្រគេនសំពត់ដ៏សេសដល់ភិក្ខុទាំងឡាយ ដែលមានចីវរចាស់ ។ ព្រះរាជាត្រាស់ថា ភិក្ខុទាំងឡាយនឹងធ្វើចីវរចាស់របស់ខ្លួនឲ្យជាអ្វី ព្រះថេរៈពោលថា នឹងឲ្យដល់ភិក្ខុដែលមានចីវរចាស់ជាងទាំងឡាយ ។ ព្រះរាជាត្រាស់ថា ភិក្ខុទាំងនោះនឹងធ្វើចីវរចាស់របស់ខ្លួនឲ្យជាអ្វី ព្រះថេរៈពោលថា លោកនឹងធ្វើឲ្យជាសំពត់ក្រាលដេក ។ ព្រះរាជាត្រាស់ថា លោកនឹងធ្វើសំពត់ក្រាលដេកចាស់ឲ្យជាអ្វី ព្រះថេរៈពោលថា លោកធ្វើឲ្យជាសំពត់កម្រាលផ្ទៃ ។ ព្រះរាជាត្រាស់ថា លោកនឹងធ្វើសំពត់កម្រាលផ្ទៃចាស់ឲ្យជាអ្វី ព្រះថេរៈពោលថា សូមថ្វាយព្រះពរ លោកនឹងធ្វើឲ្យជាសំពត់ជូតជើង ។ ព្រះរាជាត្រាស់ថា លោកនឹងធ្វើសំពត់ជូតជើងចាស់ឲ្យជាអ្វី ព្រះថេរៈពោលថា លោកនឹងជាន់ឲ្យល្អិត ហើយផ្សំជាមួយដីឥដ្ឋបូកជញ្ជាំង ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ សំពត់ទាំងឡាយដែលប្រគេនដល់លោកម្ចាស់ នឹងមិនវិនាស ព្រោះធ្វើកម្មមានប្រមាណប៉ុណ្ណោះឬ ព្រះថេរៈពោលថា យ៉ាងនោះឯងមហាបពិត្រ ។ ព្រះរាជាទ្រង់ជ្រះថ្លាហើយ ទ្រង់ត្រាស់ឲ្យនាំសំពត់ ៥០០ ដទៃទៀត ឲ្យតាំងទុកទៀបបាទមូលរបស់ព្រះថេរៈហើយ ។

បានឮថា ព្រះថេរៈបានសំពត់មានតម្លៃ ៥០០ ដែលព្រះរាជាទ្រង់ដាក់ត្រង់ទៀបបាទមូល ដោយចំណែក ៥០០ ដល់ទៅ ៥០០ ដង បានសំពត់មានតម្លៃមួយពាន់ ដែលព្រះរាជាទ្រង់ដាក់ទៀបបាទមូល ប្រគេនដោយចំណែកមួយពាន់ ដល់ទៅ ១ ពាន់ដង បានសំពត់មានតម្លៃមួយសែន ដែលព្រះរាជា

ទ្រង់ដាក់ទៀបបាទមូល ប្រគេនដោយចំណែកមួយសែន ដល់ទៅមួយសែនដង ឈ្មោះថា ការរាប់សំពត់ដែលព្រះអានន្ទបានហើយ ដោយន័យជាដើមថា ១-២-៣-៤-៥-១០ ដូច្នេះ មិនមាន ។ បានឮថា កាលព្រះតថាគតបរិនិព្វានហើយ ព្រះថេរៈត្រាច់ទៅពេញជម្ពូទ្វីប បានប្រគេនបាត្រ និងចីវរទាំងឡាយ ដែលជារបស់ខ្លួននោះឯង ដល់ភិក្ខុទាំងឡាយក្នុងវិហារទាំងពួងហើយ ។

ព្រះនាងមាគន្ទិយាគិតថា អញធ្វើវត្ថុណា វត្ថុនោះមិនបានយ៉ាងនោះ បែរជាបានដទៃទៅវិញ អញនឹងធ្វើដូចម្តេចហ្ន៎ ដូច្នេះហើយ គិតថា ឧបាយនេះប្រើការបាន កាលព្រះរាជាយាងទៅកាន់ទីកីឡា ក្នុងព្រះរាជឧទ្យាន ទើបបញ្ជូនដំណឹងដល់ឪពុកមាថា សូមឪពុកមាទៅកាន់ប្រាសាទរបស់នាងសាមាវតី ឲ្យបើកឃ្លាំងសំពត់ និងឃ្លាំងប្រេង ហើយជ្រលក់សំពត់ក្នុងពាងប្រេង រួចរុំសសរ ធ្វើស្រីទាំងនោះទុកជាមួយគ្នា បិទទ្វារ ដាក់គន្លឹះខាងក្រៅ យកគប់ភ្លើងមានដងដុតដំណាក់ហើយ ចូរទៅចុះ ។ នាយមាគន្ទិយៈនោះ ឡើងកាន់ប្រាសាទ ឲ្យបើកឃ្លាំងទាំងឡាយ ជ្រលក់សំពត់ក្នុងពាងប្រេងហើយរុំសសរ ។

លំដាប់នោះ ស្រីទាំងឡាយ មានព្រះនាងសាមាវតីជាប្រធាន ពោលនឹងនាយមាគន្ទិយៈថា លោកមាធ្វើអ្វី ចូលទៅរកហើយ នាយមាគន្ទិយៈពោលយ៉ាងនេះថា ព្រះនាងទាំងឡាយ ព្រះរាជាប្រាប់ឲ្យរុំសសរទាំងនេះដោយសំពត់ ជ្រលក់ប្រេង ដើម្បីប្រយោជន៍ធ្វើឲ្យរឹងមាំ ធម្មតាក្នុងព្រះរាជវាំង

កម្មដែលប្រកបល្អ និងអាក្រក់ ជារបស់ដឹងបានដោយលំបាក កុំនៅក្នុងទីជិតខ្ញុំឡើយ ដូច្នេះហើយ ឲ្យស្រីទាំងនោះមកហើយ ចូលទៅខាងក្នុងបន្ទប់ បិទទ្វារហើយ ដាក់គន្ទឹះខាងក្រៅ ដុតភ្លើង តាំងអំពីដើមចុះមកហើយ ។

ព្រះនាងសាមាវតី បានឲ្យឱវាទដល់ស្រីទាំងនោះថា ការកំណត់អត្តភាពដែលត្រូវភ្លើងឆេះយ៉ាងនេះរបស់ពួកយើង ដែលអន្ទោលទៅក្នុងសង្សារ មិនមានទីបំផុតខាងដើម សូម្បីពុទ្ធញ្ញាណ ក៏ធ្វើមិនបានដោយងាយ អ្នកទាំងឡាយចូរជាអ្នកមិនប្រមាទចុះ ។ ស្រីទាំងនោះ កាលដំណាក់ត្រូវភ្លើងឆេះ មនសិការដល់វេទនាបរិគ្គហកម្មដ្ឋាន ជនពួកខ្លះសម្រេចផលទី ២ ជនពួកខ្លះសម្រេចផលទី ៣ ។

ព្រោះដូច្នោះ ទើបធម្មសង្គាហកាចារ្យពោលថា គ្រានោះឯង ភិក្ខុជាច្រើនត្រឡប់អំពីបិណ្ឌបាតខាងក្រោយភត្ត ព្រះដ៏មានព្រះភាគ ប្រថាប់នៅទីណាចូលទៅគាល់ដោយទីនោះ កាលចូលទៅគាល់ហើយ ធ្វើអភិវាទព្រះដ៏មានព្រះភាគអង្គុយហើយក្នុងចំណែកម្ខាង ភិក្ខុទាំងនោះ ដែលអង្គុយហើយក្នុងចំណែកម្ខាងបានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រទានព្រះវរោកាស ខាងក្នុងបុរីរបស់ព្រះបាទឧទេន ដែលទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ត្រូវភ្លើងឆេះហើយ ស្រី ៥០០ មាននាងសាមាវតីជាប្រធានធ្វើកាលកិរិយាហើយ បពិត្រព្រះអង្គដ៏ចម្រើន គតិរបស់ឧបាសិកាទាំងនោះដូចម្តេច សម្បរាយភពចំពោះមុខដូចម្តេច ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងឧបាសិកាទាំងនេះ ឧបាសិកាដែលជាសោតបន្នក៏មាន ជា

ព្រះសកទាគាមីក៏មាន ជាអនាគាមីក៏មាន ឧបាសិកាទាំងអស់នោះ ជាអ្នកមិនឥតផល ធ្វើកាលកិរិយាទេ ។

លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ជ្រាបសេចក្តីនោះហើយ ទ្រង់បន្លឺព្រះឧទាននេះ ក្នុងពេលនោះថា

សត្វលោក មានមោហៈជាចំណង ប្រាកដដូចជាមានរូបចម្រើន
បុគ្គលពាល មានឧបធិក្កិលេសជាចំណង ត្រូវងងឹត គឺអវិជ្ជាចោម
រោមហើយ ប្រាកដដូចជាទៀងទាត់ សេចក្តីកង្វល់មានរាគៈជាដើម
របស់បុគ្គលអ្នកពិចារណា ឃើញច្បាស់ មិនមានទេ ។

កាលត្រាស់យ៉ាងនោះហើយ ទ្រង់សម្តែងធម៌ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វទាំងឡាយ អន្ទោលទៅក្នុងវដ្តៈ ជាអ្នកមិនប្រមាទអស់កាលជានិច្ច ធ្វើបុញ្ញកម្មក៏មាន ជាបុគ្គលមានសេចក្តីប្រមាទ ធ្វើបាបកម្មក៏មាន ហេតុនោះ សត្វដែលត្រាច់ទៅក្នុងវដ្តៈ ទើបសោយសុខខ្លះ ទុក្ខខ្លះ ។

ព្រះរាជាទ្រង់ឮថា ដំណាក់របស់ព្រះនាងសាមាវតីត្រូវភ្លើងឆេះ ទ្រង់ក៏យាងមកដោយរហ័ស ក៏មិនអាចទាន់ដំណាក់ដែលភ្លើងមិនទាន់ឆេះបាន កាលយាងមកហើយ ទ្រង់ញុំាងដំណាក់ឲ្យរលត់ហើយ ទ្រង់កើតទោមនស្សដ៏មានកម្លាំង ចោមរោមដោយពួកអមាត្យ ប្រថាប់គង់អនុស្សរណៈដល់គុណរបស់ព្រះនាងសាមាវតី ទ្រង់ព្រះតម្រិះថា នេះជាការធ្វើរបស់អ្នកណាហ្ន៎ ដូច្នេះហើយ ទ្រង់ជ្រាបថា កម្មនេះ នឹងជាកម្មដែលនាងមាគន្ទិយាឲ្យធ្វើហើយ ទ្រង់ព្រះតម្រិះថា នាងមាគន្ទិយានោះ បើអញធ្វើឲ្យភ័យខ្លាចហើយសួរ គង់មិនប្រាប់ អញ

នឹងសួរដោយឧបាយសន្សំមៗ ទើបត្រាស់នឹងអាមាត្យទាំងឡាយថា នែអ្នកទាំងឡាយ ក្នុងកាលមុន យើងក្រោកឡើងហើយ ជាអ្នកសង្ស័យដោយជុំវិញនោះឯង នាងសាមាវតីស្វែងរកទោសយើងជានិច្ច នាងក៏ស្លាប់ទៅហើយ ឥឡូវនេះ យើងនឹងត្រជាក់ចិត្តបាន យើងនឹងបានទៅដោយសេចក្ដីសុខ ។ ពួកអមាត្យក្រាបទូលថា បពិត្រសម្មតិទេព កម្មនេះ អ្នកណាហ្ន៎ធ្វើហើយ ព្រះរាជាត្រាស់តបថា នឹងដែលបុគ្គលណាម្នាក់ធ្វើហើយ ដោយការស្រឡាញ់យើង ។ ព្រះនាងមាគន្ទិយាឈរគាល់ក្នុងទីជិត ស្ដាប់ព្រះតម្រាស់នោះហើយ ទើបក្រាបទូលថា អ្នកដទៃនឹងធ្វើ មិនអាចធ្វើបាន បពិត្រព្រះអង្គ កម្មនេះ ខ្ញុំម្ចាស់ធ្វើហើយ ខ្ញុំម្ចាស់ប្រើឪពុកមាឲ្យធ្វើ ។ ព្រះរាជាត្រាស់ថា ឈ្មោះថា សត្វមានសេចក្ដីស្រឡាញ់ក្នុងយើងដទៃលើកទុកចុះ ក្រៅអំពីនាងរមែងមិនមាន យើងពេញចិត្តព្រះទេវី យើងនឹងឲ្យពរដល់នាង នាងចូរហៅពួកញាតិរបស់ខ្លួនមក ។ បញ្ជូនដំណឹងទៅដល់ពួកញាតិថា ព្រះរាជាទ្រង់ពេញព្រះហឫទ័យ នឹងព្រះរាជទានពរដល់ខ្ញុំ ចូរមកឲ្យរហ័ស ។

ព្រះរាជា បញ្ជាឲ្យធ្វើសក្ការៈធំដល់ញាតិទាំងឡាយ របស់ព្រះនាងមាគន្ទិយាដែលមកហើយ សូម្បីពួកជនដែលមិនមែនញាតិរបស់ព្រះនាងមាគន្ទិយា ឃើញសក្ការៈនោះហើយ ក៏ឲ្យសំណូកពោលថា ពួកយើងខ្ញុំជាញាតិរបស់ព្រះនាងមាគន្ទិយា នាំគ្នាមកហើយ ។ ព្រះរាជាបញ្ជាឲ្យចាប់មនុស្សទាំងនោះ ហើយឲ្យជីករណ្ដៅទាំងឡាយ ប្រមាណត្រឹមផ្ចិត ត្រង់លានព្រះរាជវាំងហើយ ឲ្យមនុស្សទាំងនោះអង្គុយក្នុងរណ្ដៅទាំងនោះ យកដីលុប

ឲ្យដាក់ចំបើងអំពីខាងលើ ហើយដុតភ្លើង ក្នុងពេលដែលស្បែកត្រូវភ្លើងឆេះហើយ បញ្ជាឲ្យក្អួរដោយទន្ទ័លដែកទាំងឡាយ ធ្វើឲ្យជាកំណាត់ និងមិនមានកំណាត់ ឬធ្វើឲ្យជាចម្រៀក និងមិនជាចម្រៀក ។ ព្រះរាជាទ្រង់បញ្ជាឲ្យឆូតសាច់អំពីសរីរៈរបស់នាងមាគន្ទិយា ត្រង់ទីដែលមានសាច់នៅ ដោយកាំបិតដ៏មុតហើយ ឲ្យលើកឡើងកាន់ចង្ក្រានដែលក្តៅដោយខ្លាញ់ ឲ្យចៀនដូចនំហើយឲ្យទំពាស៊ីសាច់ទាំងនោះឯង ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាក្នុងរោងធម្មសភាថា ការស្លាប់បែបនេះរបស់ឧបាសិកាដែលដល់ព្រមដោយសទ្ធាបែបនេះ មិនសមគួរសោះហ្ន៎អាវុសោទាំងឡាយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ។ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់របស់ស្រីទាំងឡាយនោះ មាននាងសាមាវតីជាប្រធាន មិនគួរហើយក្នុងអត្តភាពនេះ តែការស្លាប់របស់ស្រីទាំងនោះ សមគួរដល់កម្មដែលនាងធ្វើក្នុងកាលមុន ។ ភិក្ខុទាំងនោះ ទូលអារាធនាថា បពិត្រព្រះអង្គ កម្មអ្វីដែលស្រីទាំងនោះធ្វើក្នុងកាលមុន សូមទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល កាលស្តេចព្រហ្មទត្តគ្រងរាជ្យក្នុងក្រុងពារាណសី ព្រះបច្ចេកពុទ្ធ ៨ អង្គ ឆាន់ក្នុងព្រះរាជវាំងជានិច្ច ស្រី ៥០០ នាក់ រមែងទំនុក

បម្រុងព្រះបច្ចេកពុទ្ធទាំងនោះ ។ បណ្តាព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធ ៧ អង្គ ទៅកាន់ហិមវន្តប្បទេស មួយអង្គទៀត ចូលឈានត្រង់ទីស៊ុមទ្រុមដោយស្មៅមួយកន្លែង ក្បែរមាត់ស្ទឹង ។ ថ្ងៃមួយ កាលព្រះបច្ចេកពុទ្ធទាំងឡាយទៅហើយ ព្រះរាជានាំស្រីទាំងនោះទៅ ដើម្បីលេងទឹកក្នុងស្ទឹង ។ ក្នុងទីនោះ ស្រីទាំងនោះលេងទឹក រហូតអស់ចំណែកនៃថ្ងៃ ឡើងមកហើយ ត្រូវរងាបៀតបៀន ប្រាថ្នានឹងអាំងភ្លើង ពោលថា អ្នកទាំងឡាយគប្បីរកទីសម្រាប់បង្កាត់ភ្លើងរបស់ពួកយើង ដើរទៅមកៗ ឃើញទីស៊ុមទ្រុមដោយស្មៅនោះ ទើបឈរជុំវិញ បង្កាត់ភ្លើងហើយ ដោយសម្គាល់ថាជាគំនរស្មៅ កាលស្មៅទាំង-ឡាយឆេះហើយ ក៏រលត់ ស្រីទាំងនោះឃើញព្រះបច្ចេកពុទ្ធ ទើបពោលថា ពួកយើងវិនាសហើយ ពួកយើងវិនាសហើយ ព្រះបច្ចេកពុទ្ធរបស់ព្រះរាជាត្រូវភ្លើងឆាបឆេះ ព្រះរាជាទ្រង់នឹងធ្វើពួកយើងឲ្យអន្តរធាន យើងនឹងធ្វើលោកឲ្យឆេះទាំងអស់ ជនទាំងនោះ នាំឧសមកអំពីទិសផ្សេងៗ ធ្វើឲ្យជាគំនរខាងលើនៃព្រះបច្ចេកពុទ្ធនោះ គំនរឧសធំបានកើតមានហើយ ។ គ្រានោះ ស្រីទាំងនោះដុតគំនរឧសនោះហើយចៀសចេញទៅ ដោយសម្គាល់ថា ឥឡូវនេះ នឹងឆេះអស់ ។ កាលមុនស្រីទាំងនោះ ជាអ្នកមិនមានចេតនា ត្រូវកម្មជាប់តាមហើយក្នុងឥឡូវនេះ ។ មនុស្សទាំងឡាយ នាំឧសមួយពាន់រទេះ មកដុតក៏មិនអាចធ្វើព្រះបច្ចេកពុទ្ធដែលនៅក្នុងសមាបត្តិ ឲ្យមានអាការត្រឹមតែក្តៅបាន ។ ព្រោះដូច្នោះ ព្រះបច្ចេកពុទ្ធនោះ ក្នុងថ្ងៃទី ៧ ទើបក្រោកឡើង ទៅតាមសប្បាយហើយ ។ ស្រីទាំងនោះ ឆេះក្នុងនរកអស់ច្រើនពាន់ឆ្នាំ ព្រោះកម្ម

ដែលធ្វើហើយ ឆេះហើយក្នុងផ្ទះដែលត្រូវភ្លើងឆេះ ដោយទំនងនេះឯង អស់មួយរយអត្តភាព ដោយវិបាកដ៏សេសនៃកម្មនោះឯង ។ នេះជាបុព្វកម្មរបស់ស្រីទាំងនោះ ដោយប្រការដូច្នេះ ។

កាលព្រះសាស្ដា ត្រាស់យ៉ាងនោះហើយ ភិក្ខុទាំងឡាយទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គ ចុះនាងខុជ្ជុត្តរាព្រោះកម្មដូចម្ដេច ទើបកើតជាស្រីគម ព្រោះកម្មដូចម្ដេច ទើបមានបញ្ញាច្រើន ព្រោះកម្មដូចម្ដេច ទើបសម្រេចសោតាបត្តិផល ព្រោះកម្មដូចម្ដេច ទើបកើតជាអ្នកបម្រើរបស់អ្នកដទៃ ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលព្រះរាជាអង្គនោះឯង គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ព្រះបច្ចេកពុទ្ធអង្គនោះដូចគ្នា បានជាបុគ្គលមានធាតុនៃមនុស្សគមបន្តិច ។ លំដាប់នោះ ស្រីឧបដ្ឋាយិកាម្នាក់ដណ្ដប់សំពត់កម្ពល កាន់ផ្ដិលមាស ធ្វើជាមនុស្សគម សម្ដែងអកប្បកិរិយា ត្រាច់ទៅនៃព្រះបច្ចេកពុទ្ធអង្គនោះ ដោយពោលថា ព្រះបច្ចេកពុទ្ធរបស់ពួកយើងរមែងត្រាច់ទៅយ៉ាងនេះ និងយ៉ាងនេះ ព្រោះផលដែលហូរចេញនៃកម្មនោះ ទើបនាងជាស្រីគម ។

ម្យ៉ាងទៀត ក្នុងថ្ងៃដំបូង ព្រះរាជាទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យគង់ក្នុងព្រះរាជមន្ទីរហើយ ឲ្យរាជបុរសទទួលបាត្រ ដាក់បាត្រឲ្យពេញដោយបាយាស ហើយប្រគេន ។ ព្រះបច្ចេកពុទ្ធទាំងឡាយ កាន់បាត្រដែលពេញដោយបាយាសក្ដៅ ត្រូវផ្លាស់ប្ដូរដៃរឿយៗ ស្រីនោះ ឃើញលោកធ្វើយ៉ាងនោះ ក៏ប្រគេនកងដៃភ្លុក ៨ ដែលជារបស់ផ្ទាល់ខ្លួន ពោលថា សូមលោក

ម្ចាស់ដាក់លើកងដៃនេះ ហើយកាន់យក ។ ព្រះបច្ចេកពុទ្ធទាំងនោះ ធ្វើយ៉ាងនោះ ហើយសម្លឹងមើលស្រីនោះ ។ នាងជ្រាបបំណងរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនត្រូវការកងទាំងនេះឡើយ ខ្ញុំបរិច្ចាគកងទាំងនោះហើយ ដល់លោកម្ចាស់ទាំងឡាយនោះឯង សូមលោកម្ចាស់ទទួលចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ទទួលហើយ បានទៅកាន់ញកភ្នំឈ្មោះនន្ទមូលកៈ ។ សូម្បីសព្វថ្ងៃនេះ កងទាំងនោះក៏នៅល្អនោះឯង ។ ព្រោះផលដែលហូរចេញនៃកម្មនោះ ក្នុងឥឡូវនេះ ទើបនាងជាអ្នកទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាច្រើន ។ ព្រោះផលដែលហូរចេញនៃការឧបដ្ឋាកដែលនាងធ្វើដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ទើបនាងសម្រេចសោតាបត្តិផល ។ នេះជាបុព្វកម្ម ក្នុងសម័យពុទ្ធន្តររបស់នាង ។

ចំណែកក្នុងកាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈ កូនស្រីសេដ្ឋីក្រុងពារាណសីម្នាក់ចាប់កញ្ចក់ អង្គុយតែងខ្លួនក្នុងកាលមានស្រមោលចម្រើន គឺពេលរសៀល ។ លំដាប់នោះ ភិក្ខុនីជាខីណាស្រពមួយរូប ជាអ្នកស្និទ្ធស្នាលរបស់នាង បានទៅដើម្បីសួរសុខទុក្ខ ពិតហើយ ភិក្ខុនីសូម្បីជាខីណាស្រព ក៏ជាអ្នកប្រាថ្នាដើម្បីឃើញត្រកូលឧបដ្ឋាក ក្នុងពេលល្ងាច ។ ក្នុងខណៈនោះ ស្រីបម្រើណាមួយក្នុងសម្នាក់របស់ធីតារបស់សេដ្ឋីនោះមិនមានឡើយ ទើបនាងពោលថា ខ្ញុំថ្វាយបង្គំព្រះនាង សូមហុចកំប្រោងគ្រឿងប្រដាប់នោះ ឲ្យដល់ខ្ញុំបន្តិច ។ ព្រះថេរីគិតថា បើអញមិនហុចកំប្រោងនេះឲ្យដល់នាងសោត នាងនឹងធ្វើអាឃាតក្នុងអាត្មាអញ ហើយកើតក្នុងនរក តែបើអញហុចឲ្យ នាងគង់

កើតជាស្រីបម្រើរបស់អ្នកដទៃ ណ្ហើយចុះ ភាពជាអ្នកបម្រើរបស់អ្នកដទៃ ប្រសើរជាងការក្តៅក្រហាយក្នុងនរក ។ ព្រះថេរីនោះអាស្រ័យករុណា ទើបហុចកំប្រោងគ្រឿងប្រដាប់នោះឲ្យដល់នាង ។ ព្រោះអានិសង្សនៃកម្មនោះ ទើបនាងបានជាអ្នកបម្រើរបស់អ្នកដទៃ ។

ថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា ស្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន ត្រូវភ្លើងឆេះហើយក្នុងដំណាក់ ពួកញាតិរបស់ព្រះនាងមាគន្ទិយា ត្រូវដុតដោយចំបើងដែលគ្របខាងលើ ហើយទម្លាយដោយនង្គ័លដែក ព្រះនាងមាគន្ទិយា ត្រូវចៀនដោយខ្លាញ់ដ៏ក្តៅ ក្នុងមនុស្សទាំងនោះ អ្នកណាហ្ន៎ ឈ្មោះថា រស់នៅ អ្នកណាហ្ន៎ ឈ្មោះថា ស្លាប់ហើយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកជនឯណាមួយប្រមាទហើយ ជនទាំងនោះ សូម្បីរស់នៅមួយរយឆ្នាំ ក៏ឈ្មោះថា ស្លាប់ហើយពិត បុគ្គលពួកណាមិនប្រមាទ បុគ្គលនោះស្លាប់ហើយ ក៏ឈ្មោះថារស់នៅ ព្រោះដូច្នោះ នាងមាគន្ទិយា ទោះបីរស់នៅក្តី ស្លាប់ក្តី ក៏ឈ្មោះថាស្លាប់ហើយនោះឯង ស្រី ៥០០ មាននាងសាមាវតីជាប្រធាន សូម្បីស្លាប់ហើយ ក៏ឈ្មោះថា រស់នៅនោះឯង ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមិនប្រមាទ ឈ្មោះថា មិនស្លាប់ ដូច្នេះហើយ ទ្រង់ភាសិតគាថាទាំងឡាយថា

**អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ**

អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។
ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា ។
តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត បានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ( ទើបឋិតនៅ ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាគោចរ នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញាតែងប៉ះពាល់នូវព្រះនិព្វាន ជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាត ដ៏ប្រសើរបំផុត ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមាទោ** រមែងសម្តែងអត្ថទូលំទូលាយ កាន់យកអត្ថទូលាយតាំងនៅ ។ ពិតហើយ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងមូល ដែលអាចារ្យទាំងឡាយនាំមកពោល រមែងឈមចុះកាន់ការមិនប្រមាទ

នោះឯង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្នាមជើងណាមួយ របស់សត្វទាំងឡាយ ដែលត្រាច់ទៅលើផែនដី ស្នាមជើងទាំងពួងនោះ រមែងដល់នូវការប្រជុំចុះក្នុងស្នាមជើងដំរី ស្នាមជើងដំរីដែលសត្វលោកហៅថា ជាកំពូលនៃស្នាមជើងទាំងនោះ ព្រោះស្នាមជើងដំរីនេះជារបស់ធំយ៉ាងណា ម្នាលភិក្ខុទាំងឡាយ កុលសធម៌ណាមួយ កុសលធម៌ទាំងអស់នោះ មានការមិនប្រមាទជាឫសគល់ មានការមិនប្រមាទជាទីប្រជុំចុះ ការមិនប្រមាទដែលតថាគតពោលថា ជាកំពូលនៃធម៌ទាំងនោះដូច្នោះដូចគ្នា ។

ការមិនប្រមាទនោះដោយអត្ថ ឈ្មោះថាការមិននៅប្រាសចាកសតិ ព្រោះពាក្យថា ការមិនប្រមាទនោះ ជាឈ្មោះរបស់សតិដែលតាំងមាំជានិច្ច ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អមតំ បទំ** ព្រះនិព្វាន ព្រះមានព្រះភាគត្រាស់ហៅថា **អមត** ព្រោះព្រះនិព្វាននោះ ឈ្មោះថា មិនចាស់ មិនស្លាប់ ព្រោះជាធម្មជាតមិនកើត ហេតុនោះ ទើបទ្រង់ត្រាស់ហៅព្រះនិព្វានថា អមតៈ សត្វទាំងឡាយរមែងដល់ អធិប្បាយថា រមែងសម្រេចអមតៈ ដោយការមិនប្រមាទនេះ ហេតុនោះ ទើបការមិនប្រមាទនេះ ឈ្មោះថា ជាគ្រឿងដល់ លោកអធិប្បាយថា ជាឧបាយគ្រឿងសម្រេចអមតៈ ទើបឈ្មោះថា **អមតំ បទំ** ។

ភាវៈ គឺការស្រវឹង ឈ្មោះថា ការប្រមាទ ។ ពាក្យថា ការប្រមាទនោះ ជាឈ្មោះរបស់ការបណ្តែតបណ្តោយសតិ ពោល គឺការមិនមានស្មារតី ។

បទថា **មច្ចុនោ** ប្រែថា នៃសេចក្តីស្លាប់ ។ បទថា **បទំ** គឺជាឧបាយ

បានដល់ ជាផ្លូវ ។ ពិតហើយ ជនដែលប្រមាទហើយ រមែងមិនប្រព្រឹត្តទៅកន្លងនូវជាតិបាន សូម្បីកើតហើយ ក៏រមែងចាស់ រមែងស្លាប់ ហេតុនោះទើបការប្រមាទ ឈ្មោះថា ជាផ្លូវនៃមច្ចុ គឺរមែងនាំចូលរកសេចក្តីស្លាប់ ។

បាទព្រះគាថាថា **អប្បមត្តា ន មីយន្តិ** សេចក្តីថា បុគ្គលប្រកបដោយសតិ ឈ្មោះថា បុគ្គលមិនប្រមាទហើយ ។ បុគ្គលណាម្នាក់មិនគប្បីកំណត់ថា បុគ្គលមិនប្រមាទហើយរមែងមិនស្លាប់ គឺជាបុគ្គលមិនចាស់ មិនស្លាប់ ដូច្នេះ ព្រោះថា សត្វណាមួយ ឈ្មោះថា មិនចាស់ និងមិនស្លាប់ រមែងមិនមាន ។ តែឈ្មោះថាវដ្តៈរបស់សត្វដែលប្រមាទហើយ កំណត់មិនបាន វដ្តៈរបស់បុគ្គលមិនប្រមាទកំណត់បាន ហេតុនោះ សត្វដែលប្រមាទហើយ ទោះរស់នៅ ក៏ឈ្មោះថា ស្លាប់ហើយដោយពិត ព្រោះភាពជាបុគ្គលមិនផុតចាកទុក្ខ មានជាតិជាដើម ចំណែកបុគ្គលមិនប្រមាទ ចម្រើនអប្បមាទលក្ខណៈហើយ ធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផលដោយឆាប់រួសរាន់ រមែងមិនកើតក្នុងអត្តភាពទី ២ និងទី ៣ ហេតុនោះ សត្វមិនប្រមាទទាំងនោះ រស់នៅក្តី ស្លាប់ហើយក្តី ឈ្មោះថា មិនស្លាប់ដោយពិត ។

បាទព្រះគាថាថា **យេ បមត្តា យថា មតា** សេចក្តីថា ចំណែកសត្វឯណាប្រមាទហើយ សត្វទាំងនោះរមែងដូចសត្វដែលស្លាប់ហើយ ដោយការផ្តាច់ជីវិតិន្ទ្រិយ មានវិញ្ញាណទៅប្រាសហើយ ដូចគ្នានឹងអង្កត់ឧសដូច្នោះឯង ព្រោះភាពដែលមនុស្សស្លាប់ហើយ ដោយសេចក្តីស្លាប់ គឺការប្រមាទ មែនពិត ចិត្តមួយដួងដែលកើតឡើងថា អញនឹងឲ្យទាន អញនឹងរក្សាសីល អញនឹង

ធ្វើឧបោសថកម្មដូច្នេះ រមែងមិនកើតឡើងដល់បុគ្គលទាំងឡាយដែលជាគ្រហស្ថ ចិត្តមួយដួងដែលកើតឡើងថា អញនឹងបំពេញវត្តទាំងឡាយ មានអាចរិយវត្ត និងឧបជ្ឈាយវត្តជាដើម អញនឹងសមាទានធុតង្គ ចម្រើនភាវនាដូច្នេះ រមែងមិនកើតឡើងដល់សត្វទាំងនោះ សូម្បីជាបព្វជិត ដូចចិត្តមួយដួងមិនកើតឡើងដល់សត្វដែលស្លាប់ហើយដូច្នោះ សត្វដែលប្រមាទហើយនោះ ទោះរស់ បុគ្គលមានអ្វីជាគ្រឿងធ្វើឲ្យផ្សេងអំពីសត្វ ដែលស្លាប់ហើយនោះ ព្រោះដូច្នោះ ក៏ដូចជាបុគ្គលដែលស្លាប់ហើយ ។

បាទព្រះគាថាថា **ឯតំ វិសេសតោ ញត្វា** សេចក្តីថា ដឹងសេចក្តីនោះដោយប្លែកគ្នាថា ការស្រុះចេញចាកវដ្តៈរបស់បុគ្គលដែលប្រមាទហើយ រមែងមិនមាន របស់បុគ្គលមិនប្រមាទហើយ មាន ។

មានបុច្ឆាថា បុគ្គលណារមែងដឹងសេចក្តីប្លែកគ្នានោះ មានវិសជ្ជនាថា បណ្ឌិតទាំងឡាយ តាំងនៅក្នុងសេចក្តីមិនប្រមាទ រមែងដឹង អធិប្បាយថា បណ្ឌិត គឺបុគ្គលដែលមានមេធា បានដល់ជាអ្នកមានប្រាជ្ញាពួកណា តាំងនៅក្នុងការមិនប្រមាទរបស់ខ្លួនហើយ ចម្រើននូវការមិនប្រមាទ បណ្ឌិតទាំងនោះ រមែងដឹងហេតុដែលប្លែកគ្នានោះ ។

បាទព្រះគាថាថា **អប្បមាទេ បមោទន្តិ** សេចក្តីថា បណ្ឌិតទាំងនោះកាលដឹងយ៉ាងនេះហើយ រមែងត្រេកអរ គឺជាអ្នកមានមុខញញឹមញញែម បានដល់ ត្រេកអររីករាយក្នុងការមិនប្រមាទរបស់ខ្លួននោះ ។

បាទព្រះគាថាថា **អរិយានំ គោចរេ រតា** សេចក្តីថា បណ្ឌិតទាំងនោះ

ត្រេកអរក្នុងការមិនប្រមាទយ៉ាងនោះ ចម្រើននូវការមិនប្រមាទនោះហើយ រមែងជាអ្នកត្រេកអរ គឺត្រេកអរក្នុងពោធិបក្ខិយធម៌ ៣៧ ចែកចេញជាសតិប្បដ្ឋាន ៤ ជាដើម និងក្នុងលោកុត្តរធម៌ ៩ ប្រការ ដែលរាប់ថា ធម៌ជាគ្រឿងគោចររបស់ព្រះអរិយៈទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះពុទ្ធទាំងឡាយ ។

ពីរបទថា **តេ ឈាយិនោ** សេចក្តីថា បណ្ឌិតជាអ្នកមិនប្រមាទទាំងនោះ ជាបុគ្គលមានការសម្លឹងដោយឈានទាំង ២ យ៉ាង គឺដោយអារម្មណូបនិជ្ឈានពោល គឺសមាបត្តិ ៨ និងដោយលក្ខណូបនិជ្ឈាន ពោល គឺវិបស្សនាមគ្គនិងផល ។

បទថា **សាតតិកា** សេចក្តីថា ជាបុគ្គលមានសេចក្តីព្យាយាម ដែលប្រព្រឹត្តទៅដោយកាយ និងចិត្ត ប្រព្រឹត្តទៅហើយជាប់ត ចាប់តាំងអំពីកាលដែលចេញបួស រហូតដល់សម្រេចអរហត្ត ។

បាទព្រះគាថាថា **និច្ចំ ទឡ្ហបរក្កមា** សេចក្តីថា បុគ្គលប្រកបដោយសេចក្តីព្យាយាមបែបនេះថា គុណជាតណា ដែលបុគ្គលគប្បីដល់ ដោយកម្លាំងរបស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស បើមិនទាន់ដល់នូវគុណជាតនោះទេ នឹងមិនបញ្ឈប់នូវសេចក្តីព្យាយាមរបស់បុរសឡើយ ។ ដូច្នេះ ឈ្មោះថា ព្យាយាម ឈ្មោះថាប្រព្រឹត្តទៅហើយជានិច្ច ព្រោះមិនរួញរាក្នុងចន្លោះ ។

ក្នុងពាក្យថា **ផុសន្តិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ការពាល់

ត្រូវមាន ២ គឺញាណផុសនា គឺការពាល់ត្រូវដោយបញ្ញា ១ វិបាកផុសនា គឺការពាល់ត្រូវដោយវិបាក ១ ។ ក្នុងផុសនា ២ យ៉ាងនោះ មគ្គ ៤ ឈ្មោះថា **ញាណផុសនា** ផល ៤ ឈ្មោះថា **វិបាកផុសនា** ។ ក្នុងផុសនា ២ យ៉ាងនោះ វិបាកផុសនា ព្រះមានព្រះភាគទ្រង់បំណងយកក្នុងបទថា **ផុសន្តិ** នេះ ។ បណ្ឌិតដែលជាអ្នកប្រាជ្ញ កាលធ្វើនិព្វានឲ្យជាក់ច្បាស់ដោយអរិយផល ឈ្មោះថា រមែងធ្វើនិព្វានឲ្យជាក់ច្បាស់ដោយវិបាកផុសនា ។

បាទព្រះគាថាថា **យោគក្ខេមំ អនុត្តរំ** សេចក្ដីថា នូវព្រះនិព្វាន ដែលជាដែនក្សេម គឺមិនមានភ័យអំពីយោគៈ ៤ ដែលញុំាងមហាជនឲ្យលិចចុះក្នុងវដ្ដៈ ឈ្មោះថា ជាកំពូល ព្រោះជាវត្ថុដែលប្រសើរជាងលោកិយធម៌ និងលោកុត្តរធម៌ទាំងពួង ។

ក្នុងទីបំផុតនៃទេសនា ជនជាច្រើនបានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ទេសនាជាកថាមានប្រយោជន៍ដល់មហាជន ដូច្នេះ ។ល។

**រឿងព្រះនាងសាមាវតី ចប់**

# រឿង កុម្ភឃោសកៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះ កុម្ភឃោសកៈ ត្រាស់ព្រះធម្មទេសនានេះថា **ឧដ្ឋានវតោ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងនគររាជគ្រឹះ អហិវាតករោគកើតឡើងក្នុងផ្ទះរបស់រាជគហសេដ្ឋី កាលអហិវាតករោគនោះកើតឡើងហើយ សត្វតិរច្ឆាន ចាប់តាំងអំពីរុយរហូតដល់គោ រមែងស្លាប់មុន បន្ទាប់អំពីនោះមក ក៏ស្លាប់ទាសៈនិងកម្មករ ខាងក្រោយបង្អស់ ទើបស្លាប់ម្ចាស់ផ្ទះ ព្រោះដូច្នេះ ទើបរោគនោះកើតលើលោកសេដ្ឋី និងភរិយាក្រោយគេបង្អស់ ។ ស្វាមីភរិយានោះ រោគពាល់ត្រូវហើយ សម្លឹងមើលបុត្រដែលឈរក្នុងទីមិនឆ្ងាយ នេត្រាទាំងគូជាមដោយទឹកភ្នែក និយាយនឹងកូនថា នែបា បានឮថា កាលរោគប្រភេទនេះកើតឡើង ជនទាំងឡាយទម្លាយជញ្ជាំងផ្ទះគេចទៅ រមែងរួចផុតជីវិត ខ្លួនបាកុំបីជាប់ជំពាក់ក្នុងយើងទាំងពីរឡើយ គប្បីគេចទៅ បើមានជីវិត សឹមត្រឡប់មកវិញ គប្បីជីកយកទ្រព្យ ៤០ កោដិ ដែលយើងទាំងពីរកប់ក្នុងទីឈ្មោះនោះ ចិញ្ចឹមជីវិតចុះ ។

កុមារស្តាប់ពាក្យរបស់មាតា និងបិតានោះហើយ ទ្រហោយំ ថ្វាយបង្គំមាតាបិតា ខ្លាចចំពោះភ័យ គឺសេចក្តីស្លាប់ ទម្លាយជញ្ជាំងគេចទៅកាន់ព្រៃស្តុកនៃភ្នំ នៅក្នុងទីនោះអស់ ១២ ឆ្នាំ ទើបត្រឡប់មកកាន់លំនៅរបស់មាតាបិតា ។

គ្រានោះ បុគ្គលណាម្នាក់ក៏មិនស្គាល់គេ ព្រោះកាលទៅ នៅជាកុមារ

ត្រឡប់មកក្នុងកាលមានសក់ និងពុកមាត់ពុកចង្កាស្រមូម ។

បុរសនោះទៅកាន់ទីកប់ទ្រព្យដោយអំណាចនៃសញ្ញា ដែលមាតា និងបិតាទុកឲ្យ ដឹងថាទ្រព្យមិនវិនាសទើបគិតថា បុគ្គលណាម្នាក់ចាំអាត្មាអញមិនបាន បើអញជីកទ្រព្យប្រើប្រាស់សោត ជនទាំងឡាយគប្បីគិតថា បុគ្គលក្រីក្រម្នាក់ជីកទ្រព្យឡើងហើយ គប្បីចាប់អញ បៀតបៀន បើដូច្នោះ អញគប្បីធ្វើការស៊ីឈ្នួល រស់នៅក្នុងទីនេះ ។ គាត់ស្លៀកសំពត់ចាស់មួយផ្ទាំង ដើរសួរថា មានអ្នកណាត្រូវការ ដោយអ្នកស៊ីឈ្នួលដែរឬទេ ទៅដល់វិថីដែលជាលំនៅរបស់បុគ្គលម្នាក់ស៊ីឈ្នួលហើយ ។

ខណៈនោះ ពួកថៅកែឃើញគាត់ហើយពោលថា បើអ្នកធ្វើការងាររបស់ពួកយើងបានត្រឹមតែមួយសោត ពួកយើងនឹងឲ្យថ្លៃឈ្នួលសម្រាប់ទិញកត្ត ។ បុរសនោះសួរថា ឈ្មោះថា ការងារអ្វីដែលពួកអ្នកនឹងធ្វើ ពួកថៅកែឆ្លើយថា ការងារ គឺការក្រោក និងការដាស់តឿន បើអ្នកអាចធ្វើបានសោត ចូរក្រោកឡើងអំពីព្រលឹម ដើរប្រាប់ថា នែអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរក្រោកឡើង ចូរត្រៀមរទេះទាំងឡាយ ចូរទឹមគោក្នុងពេលដែលសត្វពាហនៈផ្សេងៗមានដំរី និងសេះជាដើម ទៅដើម្បីស៊ីស្មៅ នែនាងទាំងឡាយ ពួកនាង ចូរក្រោកឡើង ដាំបបរ ដាំបាយ គាត់ទទួលថា បាន ។

លំដាប់នោះ ពួកអ្នកជួលបានឲ្យផ្ទះមួយខ្នងដល់គេ ដើម្បីជាប្រយោជន៍ដល់ការនៅក្នុងទីជិត គេបានធ្វើការងារនោះរាល់ថ្ងៃ ។

ថ្ងៃមួយ ព្រះរាជាព្រះនាមពិម្ពិសារ បានស្តាប់សំឡេងរបស់គេហើយ ។

*បានឮថា ព្រះរាជាទ្រង់ជ្រាបក្នុងសំឡេងរបស់សត្វទាំងពួង ព្រោះដូច្នោះ ទើបត្រាស់ថា នោះជាសំឡេងរបស់អ្នកមានទ្រព្យច្រើន ។*

*ខណៈនោះ នាងស្នំរបស់ព្រះរាជាម្នាក់ឈរក្នុងទីជិត គិតថា ព្រះរាជាមិនត្រាស់ពាក្យផ្ដេសផ្ដាស អញគួរស្គាល់បុរសនេះ ទើបបញ្ជូនបុរសម្នាក់ទៅស៊ើបមើលដោយពាក្យថា នែបា ចូរបាទៅចុះ ចូរជ្រាបបុរសនោះហើយត្រឡប់មក ។*

*បុរសនោះរូតរះទៅ ជួបកុម្ភឃោសកៈនោះហើយ ក៏ត្រឡប់មកប្រាប់ថា នុ៎ះជាមនុស្សកំព្រាម្នាក់ ដែលធ្វើការស៊ីឈ្នួលរបស់ថៅកែទាំងឡាយ ។*

*ព្រះរាជាទ្រង់ស្ដាប់ពាក្យបុរសនោះហើយ ក៏ទ្រង់តុណ្ហីភាព ។ ក្នុងថ្ងៃទី ២ ក្ដី ទី ៣ ក្ដី កាលទ្រង់ស្ដាប់សំឡេងរបស់កុម្ភឃោសកៈនោះហើយ ក៏ត្រាស់យ៉ាងនោះដូចគ្នា ។*

*ស្រីស្នំនោះ ក៏គិតយ៉ាងនោះដូចគ្នា បញ្ជូនបុរសទៅច្រើនដង កាលបុរសនោះប្រាប់ថា ជាមនុស្សកំព្រា ទើបគិតថា ព្រះរាជាទ្រង់ស្ដាប់ពាក្យថា នុ៎ះជាមនុស្សកំព្រា ក៏ទ្រង់មិនជឿ នៅតែត្រាស់ថា នុ៎ះសំឡេងបុរសមានទ្រព្យច្រើន ក្នុងសេចក្ដីនេះពិតជាមានហេតុ អញគួរតែស្គាល់បុរសនោះតាមសេចក្ដីពិត ។ ស្នំនោះក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់កាលបានទ្រព្យ ១ ពាន់ នឹងនាំធីតាទៅ រកឧបាយឲ្យទ្រព្យនោះចូរកាន់រាជត្រកូលឲ្យបាន ។*

*ព្រះរាជាត្រាស់ឲ្យព្រះរាជទានទ្រព្យ ១ ពាន់ ដល់នាងហើយ ។ នាងទទួលទ្រព្យនោះហើយ បានឲ្យធីតាស្លៀកសំពត់ចាស់មួយផ្ទាំង ចេញអំពីព្រះ*

រាជមន្ទីរ មួយអន្ទើដោយធីតានោះ ធ្វើហាក់ដូចជាអ្នកដំណើរ ទៅកាន់វិថីដែលជាលំនៅថៅកែនោះ ចូលទៅកាន់ផ្ទះមួយខ្ទង់ពោលថា បពិត្រអ្នកស្រី ខ្ញុំទាំងពីរធ្វើដំណើរមកហត់នឿយ សូមសម្រាកក្នុងផ្ទះនេះ ត្រឹមតែពីរថ្ងៃហើយនឹងទៅ ។

ស្រីម្ចាស់ផ្ទះពោលថា នែនាង មនុស្សក្នុងផ្ទះមានច្រើន នាងមិនអាចស្នាក់នៅក្នុងផ្ទះនេះបានទេ ផ្ទះរបស់កុម្ភឃោសកៈនោះទំនេរ សូមនាងទៅក្នុងផ្ទះនោះចុះ នាងទៅត្រង់ផ្ទះកុម្ភឃោសកៈនោះហើយពោលថា នែអ្នក ខ្ញុំទាំងពីរជាអ្នកដំណើរ សូមសម្រាកក្នុងផ្ទះនេះត្រឹមតែពីរថ្ងៃ ។ ទោះត្រូវបុរសនោះហាមហើយច្រើនដង ក៏ពោលអង្វរថា នែអ្នក ខ្ញុំទាំងពីរនឹងសូមសម្រាកត្រឹមតែមួយថ្ងៃ លុះព្រលឹមក៏នឹងចេញទៅ ។ មិនប្រាថ្នានឹងចេញទៅហើយ ។ នាងសម្រាកនៅក្នុងផ្ទះរបស់កុម្ភឃោសកៈនោះឯង ស្អែកឡើងក្នុងវេលានឹងចូលព្រៃ ទើបពោលថា នែអ្នក សូមអ្នកប្រគល់តម្លៃអាហារសម្រាប់អ្នកទុក ហើយសឹមទៅ ខ្ញុំនឹងចាត់ចែងដាំស្លទុកដើម្បីអ្នក កាលបុរសនោះពោលថា កុំឡើយខ្ញុំដាំខ្លួនឯងក៏បាន ទើបអង្វររឿយៗ រហូតសម្រេច ធ្វើទ្រព្យដែលគេឲ្យ ឲ្យហាក់ដូចជាខ្លួនបានទទួលហើយនោះឯង នាំភោជន និងវត្ថុផ្សេងៗ មានអង្ករដែលបរិសុទ្ធជាដើម មកអំពីផ្សារដាំឲ្យទន់ល្អ និងធ្វើម្ហូបពីរបីមុខដែលមានរសឆ្ងាញ់ដូចចម្អិនក្នុងរាជត្រកូល ឲ្យដល់កុម្ភឃោសកៈដែលមកអំពីព្រៃ កាលដឹងថាបុរសនោះបរិភោគហើយ ដល់នូវភាពជាអ្នកមានចិត្តត្រេកអរ ទើបពោលថា នែអ្នក ខ្ញុំទាំងពីរជាអ្នកហត់នឿយ សូមសម្រាកក្នុងផ្ទះនេះឯងត្រឹមពីរថ្ងៃចុះ

បុរសនោះទទួលថា បាន ។

ពេលនោះ នាងក៏ចម្អិនកត្តយ៉ាងឆ្ងាញ់ទាំងពេលល្ងាច និងពេលព្រឹក ហើយឲ្យដល់កុម្ភឃោសកៈ ។ កាលជ្រាបភាពដែលបុរសនោះ ជាអ្នកមានចិត្តត្រេកអរហើយ ក៏អង្វរថា នែអ្នក ខ្ញុំទាំងពីរសុំនៅផ្ទះត្រឹមពីរបីថ្ងៃ ដូច្នេះ ហើយនៅក្នុងផ្ទះនោះ យកសស្ត្រាដ៏មុត កាត់ជើងគ្រែរបស់បុរសនោះខាងក្រោម មេគ្រែក្នុងទីនោះៗ ។ កាលបុរសនោះមក គ្រាន់តែអង្គុយប៉ុណ្ណោះ គ្រែក៏បាក់ ធ្លាក់ទៅខាងក្រោម បុរសនោះពោលថា ហេតុអ្វីគ្រែនេះបាក់ទៅយ៉ាងនេះ ស្រីស្នំពោលថា ឱអ្នក ខ្ញុំមិនអាចហាមពួកក្មេងកំលោះៗ បាន ពួកគេមកប្រជុំគ្នា លេងក្នុងទីនេះ ។ កុម្ភឃោសកៈពោលថា ព្រោះអាស្រ័យបុគ្គលពីរនាក់ ទើបទុក្ខនេះកើតដល់ខ្ញុំ ក្នុងកាលមុនខ្ញុំទៅក្នុងទីណាៗ ក៏បិទទ្វារហើយទៅ ។ ស្រីស្នំពោលថា តើយើងនឹងធ្វើដូចម្តេចបាន នែអ្នក ខ្ញុំមិនអាចឃាត់បាន ។

នាងកាត់ជើងគ្រែដោយទំនងនេះឯង អស់ ២-៣ ថ្ងៃ សូម្បីត្រូវបុរសនោះតិះដៀលស្តីថា ក៏នៅតែពោលដោះស្រាយយ៉ាងនោះហើយ កាត់ខ្សែដែលសល់ ខ្សែតូចៗ ២-៣ សរសៃ ។

ថ្ងៃនោះ កាលគាត់អង្គុយចុះប៉ុណ្ណោះ គ្រែទាំងអស់ក៏បាក់ធ្លាក់ចុះត្រង់ផែនដី ក្បាលរបស់គាត់ទង្គិច មួយអន្ទើនឹងក្បាលជង្គង់ទាំងពីរ គាត់ក្រោកឡើង ក៏បានពោលថា ខ្ញុំនឹងធ្វើអ្វីបាន ឥឡូវនេះ នឹងទៅណាបាន ខ្ញុំជាបុគ្គលត្រូវពួកនាងធ្វើមិនឲ្យជាម្ចាស់របស់គ្រែដេកនេះ ។

*ស្រីស្នំលួងលោមថា ធ្វើដូចម្ដេចហ្ន៎ បើខ្ញុំមិនអាចហាមក្មេងៗ ដែលស្និទ្ធស្នាលបាន ណ្ហើយចុះ កុំខ្វល់ឡើយ អ្នកកុំទៅណាក្នុងពេលនេះ ដូច្នេះហើយ ហៅធីតាប្រាប់ថា នែនាង នាងចូរធ្វើឱកាសសម្រាប់ជាទីដេករបស់បងប្រុសនាង ។*

*ធីតានោះដេកម្ខាងហើយពោលថា នែអ្នក សូមមកដេកទីនេះ សូម្បីនាងស្នំក៏ពោលនឹងកុម្ភឃោសកៈនោះថា សូមអ្នកទៅដេកជាមួយប្អូនស្រីចុះ បុរសនោះដេកលើគ្រែជាមួយធីតាស្រីស្នំនោះ បានធ្វើការជិតស្និទ្ធគ្នាក្នុងថ្ងៃនោះឯង ។*

*នាងកុមារិកាយំហើយ ពេលនោះ ទើបមាតាសួរថា នាងយំធ្វើអ្វី ធីតាពោលថា កម្មឈ្មោះនេះកើតឡើងហើយ មាតាពោលថា ណ្ហើយចុះ យើងអាចធ្វើអ្វីបាន បើនាងមានប្ដីម្នាក់ក៏ល្អ កុម្ភឃោសកៈនេះបានបាទបរិចារិកាម្នាក់ក៏ល្អ រមែងសមគួរ ដូច្នេះហើយ បានធ្វើកុម្ភឃោសកៈនោះឲ្យជាកូនប្រសាជនទាំងពីរនាក់នៅរួមគ្នាហើយ ។*

*ក្នុងកាលកន្លងទៅ ២-៣ ថ្ងៃ ស្រីស្នំនោះក៏បញ្ជូនដំណឹងដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់បញ្ជាឲ្យធ្វើការឃោសនាថា សូមពួកប្រជានុរាស្ត្រ ធ្វើមហោស្រព ក្នុងវិថីនៃជនស៊ីឈ្នួល ជនណាមិនធ្វើមហោស្រពក្នុងផ្ទះ ពិន័យប្រមាណប៉ុណ្ណេះ រមែងមានដល់បុគ្គលនោះ ។*

*ព្រះរាជាត្រាស់ឲ្យធ្វើយ៉ាងនោះ ។ គ្រានោះ ម្ដាយក្មេកពោលនឹងកុម្ភឃោសកៈថា នែបា យើងត្រូវធ្វើមហោស្រពក្នុងវិថីនៃអ្នកស៊ីឈ្នួល តាមព្រះរាជាទត្តិ តើយើងនឹងធ្វើដូចម្ដេច ។*

កុម្ភឃោសកៈពោលថា អ្នកម៉ែ ខ្ញុំធ្វើការស៊ីឈ្នួលស៊ើរតែមិនអាចរស់បាន នឹងធ្វើមហោស្រពបានដូចម្តេច ម្តាយក្មេកពោលថា នែបា ធម្មតាបុគ្គលដែលនៅគ្រប់គ្រងផ្ទះទាំងឡាយ រមែងទទួលយកបំណុល ព្រះករុណាជីវិតតម្កល់លើត្បូងទ្រង់បញ្ជា មិនធ្វើមិនបាន យើងអាចផុតចាកពិន័យបានដោយឧបាយណាមួយ នែបា ចូរបាទាំ ១ កហាបណៈ ឬ ២ កហាបណៈ អំពីទីណាក៏បាន ។

កុម្ភឃោសកៈត្រិះរិះបណ្តើរ ទៅនាំកហាបណៈមួយកហាបណៈ អំពីទីកប់ទ្រព្យ ៤០ កោដិ នាងក៏បញ្ជូនកហាបណៈទៅ ថ្វាយដល់ព្រះរាជាហើយធ្វើមហោស្រពដោយកហាបណៈរបស់ខ្លួន ក្នុងកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនដំណឹងយ៉ាងនោះទៀត ។

ព្រះរាជាទ្រង់បញ្ជាទៀតថា ប្រជានុរាស្ត្រចូរធ្វើមហោស្រព កាលបុគ្គលណាមិនធ្វើ នឹងពិន័យទ្រព្យមានប្រមាណប៉ុណ្ណេះ ។ កុម្ភឃោសកៈនោះ ត្រូវម្តាយក្មេករំអុកដូចមុននោះឯង ទើបទៅនាំកហាបណៈមួយកហាបណៈមកទៀត នាងក៏បញ្ជូនកហាបណៈនោះទៅថ្វាយដល់ព្រះរាជា ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនទៅថ្វាយទៀតថា ឥឡូវនេះ សូមទ្រង់បញ្ជូនបុរសមក ឲ្យហៅកុម្ភឃោសកៈនេះទៅ ។ ព្រះរាជាទ្រង់បញ្ជូនបុរសទៅហើយ ។

ពួកបុរសទៅកាន់វិថីដែលអ្នកស៊ីឈ្នួលនោះនៅហើយ សួរថា អ្នកណាឈ្មោះកុម្ភឃោសកៈ ដើរតាមរកក៏ជួប ប្រាប់ថា នែអ្នក ចូរមកចុះ ព្រះរាជាត្រាស់ឲ្យហៅអ្នក ។

កុម្ភឃោសកៈខ្លាចហើយ ពោលពាក្យដោះខ្លួនថា ព្រះរាជាទ្រង់មិនស្គាល់ខ្ញុំទេ ហើយមិនប្រាថ្នានឹងទៅ ។ ពេលនោះ ទើបពួកបុរសចាប់ត្រង់អវយវៈទាំងឡាយ មានដៃជាដើម ទាញមកដោយកម្លាំង ។

ស្រីនោះឃើញបុរសទាំងនោះហើយ ទើបធ្វើជាសម្គុតថា អើ អ្នកក្បាលរឹង ពួកអ្នកមិនសមគួរចាប់កូនប្រសារបស់ខ្ញុំ ត្រង់អវយវៈទាំងឡាយ មានដៃជាដើម ហើយលួងលោមថា នែបា សូមបាកុំខ្លាចឡើយ ខ្ញុំគាល់ព្រះរាជាហើយ នឹងទូលឲ្យកាត់ដៃរបស់អ្នកដែលចាប់អវយវៈជាដើម របស់កូននោះឯង ហើយនាំកូនស្រីទៅមុន ដល់ព្រះរាជមន្ទីរហើយ ប្តូរភេទ តែងគ្រឿងអលង្ការសព្វយ៉ាង បានឈរគាល់ក្នុងចំណែកម្ខាង ចំណែកកុម្ភឃោសកៈត្រូវគេអូសនាំមករហូតបាន ។

ខណៈនោះ ព្រះរាជាត្រាស់នឹងកុម្ភឃោសកៈនោះ ដែលថ្វាយបង្គំហើយឈរគាល់ថា អ្នកឬឈ្មោះកុម្ភឃោសកៈ កុម្ភឃោសកៈពោលថា បពិត្រព្រះសម្មតិទេព ពិតហើយ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកបិទបាំងទ្រព្យជាច្រើនប្រើប្រាស់ កុម្ភឃោសកៈពោលថា ទ្រព្យរបស់ខ្ញុំព្រះអង្គមានអំពីណា ខ្ញុំព្រះអង្គស៊ីឈ្នួលគេចិញ្ចឹមជីវិត ព្រះរាជាត្រាស់ថា បើយ៉ាងនោះ កុំធ្វើយ៉ាងនោះ អ្នកបោកបញ្ឆោតយើងធ្វើអ្វី កុម្ភឃោសកៈពោលថា ខ្ញុំព្រះអង្គ មិនបោកបញ្ឆោតទេ ទ្រព្យរបស់ខ្ញុំព្រះអង្គ មិនមាន ។

ពេលនោះ ព្រះរាជាទ្រង់បង្ហាញកហាបណៈទាំងនោះ ដល់កុម្ភឃោសកៈហើយត្រាស់ថា កហាបណៈទាំងនេះជារបស់អ្នកណា ។ កុម្ភឃោសកៈចាំ

កហាបណៈបានគិតថា អញវិនាសហើយ ហេតុអ្វីហ្ន៎ទើបកហាបណៈទាំងនេះ ធ្លាក់ដល់ដៃរបស់ព្រះរាជា ក្រឡេកមើលឆ្វេងស្តាំ ក៏ឃើញស្រីទាំងពីរនោះ ប្រដាប់គ្រឿងអលង្ការ ឈរគាល់ត្រង់មាត់ទ្វារបន្ទប់ ទើបគិតថា កម្មនេះសំខាន់ណាស់ ប្រហែលព្រះរាជាក្លែងស្រីទាំងនេះ ទៅបញ្ឆោតពិតប្រាកដ ។

ខណៈនោះ ព្រះរាជាត្រាស់ថា និយាយចុះអ្នក ហេតុអ្វី ទើបអ្នកធ្វើយ៉ាងនោះ កុម្ភឃោសកៈពោលថា ព្រោះទីពឹងរបស់ទូលបង្គំមិនមាន ព្រះរាជាត្រាស់ថា មនុស្សដូចយើងមិនគួរជាទីពឹងរបស់អ្នកឬ កុម្ភឃោសកៈពោលថា បពិត្រព្រះសម្មតិទេព បើទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គ ក៏ជាការសមគួរ ។ ព្រះរាជាត្រាស់ថា បាន ទ្រព្យរបស់អ្នកមានប៉ុនណា កុម្ភឃោសកៈពោលថា បពិត្រព្រះអង្គ មាន ៤០ កោដិ ព្រះរាជាត្រាស់ថា បានអ្វីជញ្ជូនទើបគួរ កុម្ភឃោសកៈ ពោលថា បពិត្រព្រះអង្គ រទេះច្រើនគ្រឿង ។

ព្រះរាជាបញ្ជាឲ្យរៀបចំរទេះច្រើនរយបញ្ជូនទៅ ឲ្យជញ្ជូនទ្រព្យនោះមកធ្វើជាគំនរទុកត្រង់លានព្រះរាជវាំងហើយ បញ្ជាឲ្យអ្នកក្រុងរាជគ្រឹះមកប្រជុំគ្នាហើយ ត្រាស់សួរថា ក្នុងនគរនេះអ្នកណាមានទ្រព្យប្រមាណប៉ុណ្ណេះខ្លះ កាលប្រជានុរាស្ត្រក្រាបទូលថា មិនមានទេព្រះអង្គ ក៏ត្រាស់សួរថា យើងគប្បីធ្វើអ្វីដល់គេទើបគួរ កាលជនទាំងនោះក្រាបទូលថា ទ្រង់ធ្វើការលើកតម្កើងដល់គេទើបគួរ ។ ទើបទ្រង់តាំងកុម្ភឃោសកៈនោះក្នុងតំណែងសេដ្ឋី ដោយសក្ការៈដ៏ច្រើន ព្រះរាជទានបុត្រីរបស់ស្រីនោះ ដល់កុម្ភឃោសកៈហើយ យាងទៅកាន់សម្នាក់ព្រះសាស្តាជាមួយកុម្ភឃោសកៈ ថ្វាយបង្គំហើយ ក្រាបទូលថា

បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទតបុរសនេះ ឈ្មោះថាបុគ្គលមានបញ្ញាបែបនេះមិនមាន បុរសនេះមានសម្បត្តិ ៤០ កោដិ ក៏មិនធ្វើការលើកតម្កើង ឬអាការត្រឹមតែតម្កើងខ្លួន ធ្វើដូចមនុស្សកំព្រា ស្លៀកសំពត់ចាស់ៗ ធ្វើការស៊ីឈ្នួលត្រង់វិថីរបស់អ្នកស៊ីឈ្នួល ចិញ្ចឹមជីវិត ខ្ញុំព្រះអង្គដឹងបានដោយឧបាយឈ្មោះនេះ ។ កាលដឹងហើយ ឲ្យហៅមកដេញដោលឲ្យទទួលថា មានទ្រព្យហើយ ឲ្យជញ្ជូនទ្រព្យនោះមក តែងតាំងក្នុងតំណែងសេដ្ឋី មិនតែប៉ុណ្ណោះ ខ្ញុំព្រះអង្គឲ្យបុត្រីដល់គេទៀតផង បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមានបញ្ញាបែបនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ ។

ព្រះសាស្តាស្តាប់រឿងនោះហើយ ត្រាស់ថា បពិត្រមហារាជ ជីវិតរបស់បុគ្គលដែលរស់នៅយ៉ាងនោះ ឈ្មោះថា រស់នៅប្រកបដោយធម៌ កម្មមានចោរកម្មជាដើម រមែងបៀតបៀនអ្នកធ្វើក្នុងលោកនេះផង ក្នុងលោកខាងមុខផង ឈ្មោះថា សេចក្តីសុខ ដែលមានកម្មនោះជាហេតុក៏មិនមាន បុរសធ្វើការស៊ីឈ្នួលក្តី ធ្វើស្រែក្តី ចិញ្ចឹមជីវិតក្នុងកាលវិនាសទ្រព្យនោះឯង ឈ្មោះថា ជីវិតប្រកបដោយធម៌ ភាពជាធំរមែងចម្រើនឡើងតែម្យ៉ាង ដល់បុគ្គលដែលដល់ព្រមដោយសេចក្តីព្យាយាម បរិបូណ៌ដោយសតិ មានការងារបរិសុទ្ធតាមទ្វារទាំងឡាយ មានកាយ និងវាចាជាដើម មានប្រក្រតីពិចារណាដោយបញ្ញាហើយ ទើបធ្វើ ជាអ្នកសង្រួមក្នុងទ្វារទាំងបី មានកាយទ្វារជាដើម ចិញ្ចឹមជីវិតដោយធម៌ តាំងនៅក្នុងការមិនប្រាសចាកសតិបែបនោះ ដូច្នេះហើយ ត្រាស់គាថានេះថា

**ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**

**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។**

*យសតែងចម្រើនកុះករដល់បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត ( ឥតទោស ) ជាអ្នកពិចារណា រួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ឧដ្ឋានវតោ** *គឺជាអ្នកមានសេចក្តីព្យាយាមជាហេតុក្រោកឡើង ។ បទថា* **សតីមតោ** *គឺសម្បូរដោយសតិ ។*

*បទថា* **សុចិកម្មស្ស** *គឺប្រកបដោយការងារទាំងឡាយ មានការងារតាមផ្លូវកាយជាដើម ដែលមិនមានទោស គឺមិនមានកំហុស ។*

*បទថា* **និសម្មការិនោ** *បានដល់ ពិចារណា គឺត្រិះរិះយ៉ាងនេះថា បើផលយ៉ាងនេះមាន អញនឹងធ្វើយ៉ាងនេះ ឬថា កាលការងារនេះ ដែលអញធ្វើហើយយ៉ាងនេះ ផលនេះនឹងមាន ដូច្នេះហើយ ធ្វើការងារទាំងពួង ដូចគ្រូពេទ្យពិនិត្យមើលហេតុហើយ ទើបព្យាបាល ដូច្នោះ ។*

*បទថា* **សញ្ញតស្ស** *បានដល់ សង្រួមហើយ គឺមិនមានចន្លោះដោយទ្វារទាំងឡាយ មានកាយទ្វារជាដើម ។*

*បទថា* **ធម្មជីវិនោ** *គឺបុគ្គលជាគ្រហស្ថ វៀរការកោងផ្សេងៗ មានកោងដោយជញ្ជីងជាដើម ចិញ្ចឹមជីវិតដោយការងារដ៏ប្រពៃទាំងឡាយ មានធ្វើស្រែនិងចិញ្ចឹមគោជាដើម បើជាបព្វជិត វៀរអនេសនាកម្មទាំងឡាយ មានវេជ្ជកម្ម*

និងទូតកម្មជាដើម ចិញ្ចឹមជីវិតដោយភិក្ខាចារដោយធម៌ គឺដោយប្រពៃ ។

បទថា **អប្បមត្តស្ស** គឺមានសតិមិនធ្លោយ ។ បទថា **យសោភិវឌ្ឍតិ** សេចក្តីថា យស បានដល់ ភាពជាធំ ការមានភោគសម្បត្តិ និងការរាប់អាន និងបានដល់កាលមានកិត្តិយស និងការពោលសរសើរ រមែងចម្រើន ។

ក្នុងកាលចប់ព្រះគាថា កុម្ភឃោសកៈតាំងនៅក្នុងសោតាបត្តិផល ជនដទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ទេសនាសម្រេចជាប្រយោជន៍ដល់មហាជនយ៉ាងនេះឯង ៕

**រឿង កុម្ភឃោសកៈ ចប់**

# រឿង ចូឡបន្ថកត្ថេរ

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះចូឡបន្ថកៈ ត្រាស់ធម្មទេសនានេះថា **ឧដ្ឋានេនប្បមាទេន** ជាដើម ។

បានឮមកថា ធីតានៃត្រកូលរបស់សេដ្ឋីក្នុងនគររាជគ្រឹះ ក្នុងកាលចម្រើនវ័យ មាតាបិតារក្សាយ៉ាងតឹងរ៉ឹង ត្រង់ជាន់លើនៃប្រាសាទ ៧ ជាន់ តែនាងជាស្រីឡេះឡោះក្នុងបុរស ព្រោះជាអ្នកស្រេវឹងក្នុងភាពជាក្រមុំ ទើបធ្វើសន្ថវៈជាមួយទាសៈរបស់ខ្លួនឯង ខ្លាចក្រែងអ្នកដទៃដឹងកម្មរបស់ខ្លួន ទើបពោលយ៉ាងនេះថា យើងទាំងពីរមិនអាចនៅទីនេះបានទេ បើមាតាបិតារបស់ខ្ញុំដឹង ការវិនាសនេះ នឹងធ្វើឲ្យយើងដាច់ជាកំណាត់តូចធំ យើងនឹងទៅកាន់ទីកដីដទៃ

ហើយរស់នៅ ។ ជនទាំងពីរនោះ កាន់យកទ្រព្យក្នុងផ្ទះដែលជាសារៈ ដែលគប្បីនាំទៅបានដោយដៃ ចេញទៅតាមទ្វារខាងជើងហើយ បបួលគ្នាថា យើងទាំងពីរត្រូវទៅនៅក្នុងទីណាមួយ ដែលជនដទៃមិនស្គាល់ ដូច្នេះហើយ ទាំងពីរនាក់ ក៏ធ្វើដំណើរទៅ ។

កាលជនទាំងពីរនៅក្នុងទីមួយកន្លែង នាងតាំងគភ៌ហើយ ព្រោះអាស្រ័យការនៅរួមគ្នា ។

នាងអាស្រ័យភាពដែលគភ៌ចាស់ ទើបប្រឹក្សានឹងប្តីនោះថា គភ៌របស់ខ្ញុំចាស់ហើយ ធម្មតាការប្រសូតិបុត្រក្នុងទីឆ្ងាយអំពីពួកញាតិ រមែងជាហេតុនាំសេចក្តីទុក្ខមកឲ្យដល់យើងទាំងពីរ យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូលចុះ ស្វាមីពោលពន្យារថា ថ្ងៃនេះសឹមទៅ ស្អែកនេះសឹមទៅចុះ ញ៉ាំងថ្ងៃទាំងឡាយឲ្យកន្លងទៅហើយព្រោះខ្លាចថា បើយើងទៅទីនោះ ជីវិតរបស់យើងរមែងមិនមាន នាងគិតថា បុរសនេះល្ងង់ មិនអាចទៅព្រោះភាពដែលខ្លួនមានទោសច្រើន ធម្មតាឪពុកម្តាយ មានការឧបការៈដោយចំណែកមួយប៉ុណ្ណោះ បុរសនេះទៅក្តី មិនទៅក្តី អញនឹងទៅ ។ កាលនាងចេញអំពីផ្ទះទៅហើយ នាងទុកដាក់ផ្ទះសម្បែង ប្រាប់ភាពដែលខ្លួនទៅកាន់ត្រកូល ប្រាប់អ្នកកូមិផងរបងជាមួយហើយធ្វើដំណើរទៅ ។ ចំណែកស្វាមីត្រឡប់មកផ្ទះ មិនឃើញភរិយា សួរអ្នកស្និទ្ធស្នាល ដឹងថាទៅផ្ទះនៃត្រកូល ទើបប្រញាប់រត់តាមទៅទាន់ក្នុងរវាងផ្លូវ ។ សូម្បីភរិយានោះ ក៏ប្រសូតបុត្រក្នុងរវាងផ្លូវនោះឯង ។ បុរសនោះសួរថា នៃនាង នេះជាអ្វី ភរិយាឆ្លើយថា កូនប្រុសម្នាក់ប្រសូតហើយ ។ ស្វាមីពោល

ថា ឥឡូវនេះ យើងនឹងធ្វើដូចម្តេច ។ ជនទាំងពីរគិតឃើញរួមគ្នាថា យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូល ដើម្បីប្រយោជន៍ដល់កម្មណា កម្មនោះសម្រេចហើយ ក្នុងរវាងផ្លូវនោះឯង យើងនឹងទៅទីនោះធ្វើអ្វី នាំគ្នាត្រឡប់ចុះ ដូច្នេះហើយ ក៏នាំគ្នាត្រឡប់ ។

ជនទាំងពីរបានដាក់ឈ្មោះកូននោះថា បន្ថក: ព្រោះកើតក្នុងផ្លូវ ។ ចំណេរកាលមិនយូរប៉ុន្មាន នាងក៏មានគភ៌ទៀត ។ ព្រឹត្តិការណ៍ទាំងពួងគប្បីឲ្យពិស្តារដោយន័យមុននោះឯង ។

ព្រោះក្មេងនោះកើតក្នុងផ្លូវ ទើបមាតាបិតាដាក់ឈ្មោះបុត្រដែលកើតមុនថា មហាបន្ថក: តាំងឈ្មោះកូនដែលកើតក្រោយថា ចូឡបន្ថក: ។

ស្វាមីភរិយានោះ ក៏នាំក្មេងទាំងពីរទៅលំនៅរបស់ខ្លួនវិញ ។ កាលប្តីប្រពន្ធពីរនាក់នៅក្នុងទីនោះ កុមារមហាបន្ថក: បានឮក្មេងប្រុសដទៃៗ ហៅថា មា អ៊ំ និងហៅថា តា យាយ ទើបសួរម្តាយថា បពិត្រអ្នកម៉ែ កុមារដទៃ ហៅបុគ្គលនោះថា តា ហៅបុគ្គលនោះថា យាយ ពួកញាតិរបស់យើង មិនមានទេឬ ។

មាតាពោលថា អើបា ពួកញាតិរបស់យើងក្នុងទីនេះ មិនមានទេ តែតារបស់ពួកឯង ឈ្មោះធនសេដ្ឋីមាននៅក្នុងនគររាជគ្រឹះ ពួកញាតិរបស់យើងជាច្រើន មាននៅក្នុងនគរនោះ ។ មហាបន្ថក:ពោលថា ហេតុអ្វីទើបពួកយើងមិនទៅក្នុងទីនោះ ។ នាងប្រាប់ហេតុដែលខ្លួនមកដល់បុត្រ កាលបុត្រទាំងពីរពោលរំអុកពេក ទើបប្រាប់ដល់ប្តីថា កូនទាំងនេះរំអុកខ្ញុំពន់ពេក មាតាបិតា

ឃើញពួកយើងហើយ នឹងស៊ីសាច់ឬ មក ឥឡូវនេះ យើងទាំងពីរនឹងបង្ហាញត្រកូលតាយាយដល់កូនទាំងឡាយ ។ ស្វាមីពោលថា ខ្ញុំមិនអាចជួបមុខបាន តែអាចនាំពួកនាងទៅបាន ។ ភរិយាពោលថា សាធុ ក្មេងទាំងពីរគួរឃើញត្រកូលរបស់ជីតា ដោយឧបាយណាមួយពិត ។

ជនទាំងពីរនាំកុមារ ទៅដល់នគររាជគ្រឹះដោយលំដាប់ ស្នាក់នៅត្រង់សាលាមួយខាងក្បែរទ្វារនគរ ។ ម្ដាយកុមារទាំងពីរ នាំក្មេងទាំងពីរទៅហើយប្រាប់ភាពដែលខ្លួនមកដល់មាតាបិតា ។

មាតាបិតាទាំងពីរនោះ បានឮដំណឹងនោះហើយពោលថា ធម្មតាជនទាំងឡាយ ដែលនៅអន្ទោលទៅក្នុងសង្សារ ឈ្មោះថា មិនធ្លាប់ជាកូនប្រុស មិនធ្លាប់ជាកូនស្រីមិនមាន មនុស្សទាំងនោះធ្វើខុសចំពោះយើងដ៏ធំ ពួកគេមិនអាចតាំងនៅក្នុងគន្លងចក្ខុរបស់យើងបានទេ ជនទាំងពីរចូរយកទ្រព្យប្រមាណប៉ុណ្ណេះទៅកាន់ទីផាសុកចិញ្ចឹមជីវិតចុះ តែចូរបញ្ជូនក្មេងទាំងពីរមកក្នុងទីនេះ ។

ស្វាមីភរិយានោះ ទទួលទ្រព្យដែលជនទាំងពីរនោះ បញ្ជូនមកហើយប្រគល់ជនទាំងពីរក្នុងដៃអ្នកបម្រើ ដែលមកហើយនោះឯង បញ្ជូនទៅហើយក្មេងទាំងពីរបម្រើនវ័យក្នុងត្រកូលរបស់តាយាយនោះឯង ។

ក្នុងកុមារទាំងពីរនោះ ចូឡបន្ថកៈនៅក្មេងពេក ។ ចំណែកមហាបន្ថកៈទៅស្ដាប់ធម្មកថា របស់ព្រះទសពលជាមួយជីតា ។ កាលចូលទៅកាន់សម្នាក់របស់ព្រះសាស្ដាជានិច្ច ចិត្តក៏បង្អោនទៅហើយក្នុងបព្វជ្ជា ។ កុមារនិយាយនឹងជីតាថា បើលោកតាអនុញ្ញាតខ្ញុំសោត ខ្ញុំគប្បីបួស ។

លោកសេដ្ឋីពោលថា បានិយាយអ្វី ការបួសរបស់ចៅជាការល្អដល់តា ជាងការបួសរបស់មនុស្សទូទៅក្នុងលោក បើចៅអាចសោត ក៏ចូរបួសចុះ ដូច្នេះហើយ នាំទៅកាន់សម្នាក់ព្រះសាស្ដា កាលទ្រង់ត្រាស់សួរថា ម្នាល គហបតី អ្នកមានកូនឬ ក៏ក្រាបទូលថា បពិត្រព្រះអង្គ កុមារនេះជាចៅ របស់ខ្ញុំព្រះអង្គ បំណងនឹងបួសក្នុងសម្នាក់របស់ព្រះអង្គ ។

ព្រះសាស្ដា ត្រាស់បញ្ជាភិក្ខុដែលសមាទានបិណ្ឌបាតជាវត្តរូបណាមួយ ថា អ្នកចូរឲ្យកុមារនេះបួស ។ ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់កុមារ ហើយឲ្យបព្វជ្ជា ។

លោករៀនព្រះពុទ្ធវចនៈបានច្រើន មានអាយុគ្រប់បានឧបសម្បទាហើយ ធ្វើកម្មក្នុងយោនិសោមនសិការ សម្រេចអរហត្តហើយ ។

លោកញ៉ាំងកាលឲ្យកន្លងទៅ ដោយសុខក្នុងឈាន និងសុខដែលកើត អំពីផល គិតថា អញអាចឲ្យសុខនេះដល់ចូឡបន្ថកៈឬហ្ន៎ ខាងក្រោយបាន ទៅកាន់សម្នាក់របស់សេដ្ឋីជាជីតា ហើយពោលយ៉ាងនេះថា លោកមហា-សេដ្ឋី បើអ្នកអនុញ្ញាតសោត អាត្មាគប្បីឲ្យចូឡបន្ថកៈបួស សេដ្ឋីពោលថា សូមលោកម្ចាស់ឲ្យគេបួសចុះ ។ បានឮថា សេដ្ឋីជ្រះថ្លាល្អហើយ ក្នុងព្រះ សាសនា តែកាលត្រូវសួរថា កុមារនេះជាបុត្ររបស់ធីតាណារបស់អ្នក នឹង ឆ្លើយថា របស់កូនស្រីដែលគេចទៅក៏ខ្មាស ព្រោះដូច្នោះ ទើបអនុញ្ញាតការ បួសដល់ចៅទាំងពីរនោះ បានដោយងាយ ។

ព្រះថេរៈបានឲ្យចូឡបន្ថកៈបួសហើយ ឲ្យតាំងនៅក្នុងសីលទាំងឡាយ ។

សូម្បីចូឡបន្ថកៈនោះបួសហើយ បានជាបុគ្គលល្ងង់ខ្លៅ ។

ព្រះថេរៈកាលទូន្មាន ពោលគាថានេះថា

ផ្កាឈូកឈ្មោះកោកនុទៈ មានក្លិនក្រអូប រីកអំពីព្រឹក មានក្លិនមិនបានទៅប្រាស យ៉ាងណាមិញ អ្នកចូរមើលព្រះដ៏មានព្រះភាគ មានរស្មីផ្សាយចេញពីព្រះអង្គដ៏រុងរឿង ដូចព្រះអាទិត្យ ដែលរុងរឿង ក្នុងកណ្តាលពពក ក៏យ៉ាងនោះឯង ។

មួយគាថាប៉ុណ្ណោះ ដោយ ៤ ខែ លោកក៏មិនអាចរៀនចាំ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា បានឮថា លោកបួសក្នុងកាលព្រះកស្សបសម្មាសម្ពុទ្ធ ជាអ្នកមានបញ្ញា បានធ្វើការសើចចំអកក្នុងកាលដែលភិក្ខុល្ងង់មួយរូប រៀនឧទ្ទេស ភិក្ខុនោះខ្មាសព្រោះការសើចនោះ ក៏ឈប់រៀនឧទ្ទេស មិនធ្វើការស្វាធ្យាយ ។

ព្រោះកម្មនោះ ចូឡបន្ថកៈនេះលុះបួសហើយ ទើបជាបុគ្គលល្ងង់ ។ បទដែលរៀនហើយ កាលដែលលោករៀនតទៅក៏ភ្លេចអស់ទៅ កាលលោកព្យាយាមរៀនគាថានេះឯង ៤ ខែកន្លងទៅហើយ ។

ពេលនោះ ព្រះមហាបន្ថកៈបានពោលនឹងលោកថា ចូឡបន្ថកៈ អ្នកជាមនុស្សអភព្វក្នុងសាសនានេះ ព្រោះ ៤ ខែ សូម្បីមួយគាថាក៏មិនអាចរៀនបាន អ្នកនឹងធ្វើកិច្ចនៃបព្វជិតឲ្យដល់ទីបំផុតបានដូចម្តេច ចូរចេញអំពីនេះចុះ ដូច្នេះហើយ ក៏បណ្តេញចេញអំពីវិហារ ។

ព្រះចូឡបន្ថកៈ មិនប្រាថ្នាភាពជាគ្រហស្ថ ព្រោះការជាប់ជំពាក់ក្នុងព្រះ

ពុទ្ធសាសនា ។ ក្នុងកាលនោះ ព្រះមហាបន្ថកៈជាភត្តុទ្ទេសកៈ ។ ពេទ្យជីវកកោមារភច្ច កាន់កម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបដ៏ច្រើន ទៅកាន់អម្ពវ័ន បូជាព្រះសាស្ដា ស្ដាប់ធម៌ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះទសពលហើយ ចូលទៅរកព្រះមហាបន្ថកៈ សួរថា ភិក្ខុក្នុងសម្នាក់របស់ព្រះសាស្ដាមានចំនួនប៉ុន្មាន ព្រះមហាបន្ថកៈពោលថា ភិក្ខុមានប្រមាណ ៥០០ រូប ពេទ្យជីវកពោលថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់នាំភិក្ខុ ៥០០ រូប មានព្រះពុទ្ធជាប្រធាន ទៅទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំ ។ ព្រះមហាបន្ថកៈពោលថា ឧបាសក ភិក្ខុល្ងង់មួយរូប ឈ្មោះចូឡបន្ថកៈ មានធម៌មិនរីកចម្រើន អាត្មាវៀរលោកចេញ ហើយនិមន្តភិក្ខុទាំងឡាយដ៏សេស ។

ព្រះចូឡបន្ថកៈស្ដាប់ពាក្យនោះហើយ គិតថា ព្រះថេរៈកាលទទួលនិមន្តដើម្បីភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណោះ ក៏វៀរអញហើយ ទើបទទួល ចិត្តរបស់បងប្រុសអញនឹងញែក មិនជាប់ជំពាក់ក្នុងអញហើយ ដោយឥតសង្ស័យ ឥឡូវនេះ អញត្រូវការអ្វីដោយសាសនានេះ អញនឹងទៅជាគ្រហស្ថធ្វើបុណ្យផ្សេងៗ មានទានជាដើម ចិញ្ចឹមជីវិតវិញ ។ ស្អែកឡើងលោកទៅដើម្បីសឹកអំពីព្រលឹម ព្រះសាស្ដាទ្រង់ប្រមើលមើលសត្វលោក ចំពោះក្នុងពេលជិតភ្លឺ ឃើញហេតុនេះហើយ ទើបទ្រង់យាងទៅមុន ទ្រង់បានឈប់ចង្ក្រមត្រង់ខ្លោងទ្វារ ដែលព្រះចូឡបន្ថកៈទៅ ។ ព្រះចូឡបន្ថកៈនិមន្តទៅជួបព្រះសាស្ដា ទើបចូលទៅគាល់ថ្វាយបង្គំ ។

ខណៈនោះ ព្រះសាស្ដាត្រាស់នឹងលោកថា ចូឡបន្ថកៈ តើអ្នកនឹងទៅ

ទីណាក្នុងកាលនេះ ព្រះចូឡបន្ថកៈទូលថា បងប្រុសបណ្តេញខ្ញុំព្រះអង្គ ព្រោះហេតុនោះ ខ្ញុំព្រះអង្គទៅដើម្បីសឹក ។ ព្រះសាស្តាត្រាស់ថា ម្នាលចូឡបន្ថកៈ ឈ្មោះថា បព្វជ្ជាក្នុងសម្នាក់របស់តថាគត បងប្រុសបណ្តេញ ហេតុអ្វីមិនមកកាន់សម្នាក់របស់តថាគត មកចុះ អ្នកនឹងត្រូវការអ្វីដោយភាពជាគ្រហស្ថ អ្នកត្រូវនៅក្នុងសម្នាក់របស់តថាគត ដូច្នេះហើយ ទ្រង់យកព្រះហស្តដែលមានស្បែកដ៏វិចិត្រទៅដោយចក្រ ស្ទាបត្រង់សីសៈ ហើយនាំទៅគង់ត្រង់មុខព្រះគន្ធកុដិ ប្រទានកំណាត់សំពត់ស្អាត ដែលទ្រង់និម្មិតឡើងដោយឫទ្ធិដោយព្រះតម្រាស់ថា ចូឡបន្ថកៈ អ្នកចូរបែរមុខទៅទិសខាងកើត ស្ទាបកំណាត់សំពត់នេះ ដោយបរិកម្មថា **រជោហរណំ រជោហរណំ** សំពត់ជូតធូលី សំពត់ជូតធូលីនោះឯង កាលបុរសក្រាបទូលកាលហើយ មានភិក្ខុសង្ឃចោមរោម យាងទៅផ្ទះរបស់ជីវក ប្រថាប់គង់លើអាសនៈដែលគេតាក់តែង ។

ចំណែកព្រះចូឡបន្ថកៈ អង្គុយសម្លឹងមើលព្រះអាទិត្យបណ្តើរ ស្ទាបសំពត់នោះបណ្តើរ បរិកម្មថា **រជោហរណំ រជោហរណំ** កាលលោកអង្អែលកំណាត់សំពត់នោះ កំណាត់សំពត់បានសៅហ្មងហើយ ។ គ្រានោះ ទើបគិតថា កំណាត់សំពត់នេះស្អាតពិត តែអាស្រ័យអត្តភាពនេះ ទើបលះប្រក្រតីដើមក្លាយជារបស់សៅហ្មងយ៉ាងនេះបាន ។ សង្ខារទាំងឡាយមិនទៀងហ្ន៎ ដូច្នេះហើយផ្តើមតាំងការអស់ និងការសូន្យ ចម្រើនវិបស្សនា ។

ព្រះសាស្តា ទ្រង់ជ្រាបថា ចិត្តរបស់ព្រះចូឡបន្ថកៈឡើងកាន់វិបស្សនា

ហើយ ទើបត្រាស់ថា ចូឡបន្ថក: អ្នកកុំធ្វើការសម្គាល់កំណាត់សំពត់នោះថា សៅហ្មងហើយ ជាប់ធូលី ធូលីទាំងឡាយ មានរាគធូលីជាដើម មាននៅខាងក្នុងរបស់អ្នក អ្នកចូរនាំ គឺកម្ចាត់ចេញ ដូច្នេះហើយ ទ្រង់បញ្ចេញព្រះរស្មី ជាអ្នកមានរូបប្រាកដដូចប្រថាប់គង់ចំពោះមុខ ទ្រង់បានភាសិតគាថាទាំងនេះថា

ធូលី គឺរាគ: មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីទុំះ ជាឈ្មោះនៃរាគ: បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីទុំះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺទោស: មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីទុំះ ជាឈ្មោះនៃទោស: បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីទុំះហើយ សម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។ ធូលី គឺមោហ: មិនមែនសំដៅយកលម្អងទេ ពាក្យថា ធូលីទុំះ ជាឈ្មោះនៃមោហ: បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីទុំះ ហើយសម្រាកសម្រាន្តនៅក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

ក្នុងកាលចប់គាថា ចូឡបន្ថក:សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ បិដក ៣ មកដល់លោក មួយអន្លើដោយបដិសម្ភិទានោះឯង ។

បានឮថា ក្នុងកាលកន្លងទៅហើយ លោកជាស្តេចផែនដី ទ្រង់ធ្វើប្រទក្សិណព្រះនគរ កាលព្រះសេទោហូរចេញអំពីព្រះនលាដ ទ្រង់យកសំពត់សស្អាត

ជូតព្រះនលាដ ។ សំពត់បានសៅហ្មងហើយ ព្រះរាជាត្រឡប់បានអនិច្ចសញ្ញា ថា សំពត់ស្អាតនេះ អាស្រ័យសរីរៈនេះ លះប្រក្រតីប្រែជាសៅហ្មងទៅបាន សង្ខារទាំងឡាយមិនទៀងហ្ន៎ ព្រោះហេតុនោះ ទើបសំពត់សម្រាប់ជូតធូលី នោះឯង ជាបច្ច័យរបស់លោកហើយ ។

ចំណែកពេទ្យជីវកកោមារភច្ច បានបង្អោនទឹកទក្ខិណោទកចូលទៅថ្វាយ ព្រះទសពល ព្រះសាស្ដាទ្រង់បិទបាត្រដោយព្រះហស្ដ ត្រាស់ថា ម្នាលជីវក ភិក្ខុក្នុងវិហារ នៅមានមិនមែនឬ ។

ព្រះមហាបន្ថកៈក្រាបទូលថា ក្នុងវិហារភិក្ខុមិនមានមិនមែនឬ ព្រះសាស្ដា ត្រាស់ថា មានជីវក ពេទ្យជីវកបញ្ជូនបុរសទៅដោយប្រាប់ថា នែអ្នក បើ ដូច្នោះ អ្នកចូរទៅ ចូរដឹងថា ភិក្ខុក្នុងវិហារមាន ឬមិនមាន ។

ក្នុងខណៈនោះ ព្រះចូឡបន្ថកៈគិតថា បងប្រុសរបស់អញពោលថា ភិក្ខុក្នុងវិហារមិនមាន អញនឹងប្រកាសការដែលភិក្ខុក្នុងវិហារមានដល់លោក ដូច្នេះហើយ ទើបនិម្មិតឲ្យអម្ពវ័នទាំងមូល ពេញដោយភិក្ខុទាំងអស់ ភិក្ខុពួក ខ្លះដេរចីវរ ពួកខ្លះជ្រលក់ចីវរ ពួកខ្លះធ្វើការស្វាធ្យាយ និម្មិតភិក្ខុមួយពាន់មិន ដូចគ្នានិងគ្នា យ៉ាងនេះ ។

បុរសនោះឃើញភិក្ខុជាច្រើនក្នុងវិហារ ទើបត្រឡប់មកប្រាប់ដល់ជីវក ថា លោកម្ចាស់ អម្ពវ័នទាំងមូល ពេញដោយភិក្ខុទាំងឡាយ ។

ព្រះធម្មសង្គាហិកាចារ្យពោលថា ចំណែកព្រះថេរៈ ឈ្មោះចូឡបន្ថកៈ និម្មិតខ្លួនមួយពាន់ដង គឺជាភិក្ខុមួយពាន់រូបក្នុងអម្ពវ័ននោះឯង ហើយគង់ក្នុង

អម្ពវ័នដ៏ជាទីមនោរម្យ រហូតដល់បុរសមកប្រាប់កាល ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងបុរសនោះថា អ្នកចូរទៅវិហារប្រាប់ថា ព្រះសាស្តាហៅរកភិក្ខុឈ្មោះចូឡបន្ថកៈ ។

កាលបុរសនោះទៅប្រាប់តាមបញ្ជាហើយ សំឡេងរាប់ពាន់ក៏លាន់ឮថា អាត្មាឈ្មោះចូឡបន្ថកៈ អាត្មាឈ្មោះចូឡបន្ថកៈ ។

បុរសនោះត្រឡប់ទៅក្រាបទូលទៀតថា បពិត្រព្រះអង្គ ភិក្ខុគ្រប់រូបឈ្មោះចូឡបន្ថកៈទាំងអស់ ព្រះសាស្តាត្រាស់ថា បើដូច្នោះ អ្នកចូរទៅ បុគ្គលណានិយាយមុនថា អាត្មាឈ្មោះចូឡបន្ថកៈ ចូរចាប់ដៃភិក្ខុនោះ ភិក្ខុដទៃក៏នឹងអន្តរធានទៅ ។

បុរសនោះបានធ្វើតាមពាក្យបញ្ជា ភិក្ខុប្រមាណមួយពាន់រូប បាត់ទៅហើយមួយរំពេចនោះឯង ព្រះថេរៈបានទៅជាមួយបុរសនោះ ។

ក្នុងកាលស្រេចភត្តកិច្ច ព្រះសាស្តាត្រាស់ហៅពេទ្យជីវកមក ប្រាប់ថា ម្នាលជីវក អ្នកចូរទទួលបាត្ររបស់ចូឡបន្ថកៈចុះ ចូឡបន្ថកៈនេះ នឹងធ្វើអនុមោទនាដល់អ្នក ។ ពេទ្យជីវកបានធ្វើយ៉ាងនោះហើយ ។ ព្រះថេរៈបន្លឺសីហនាទ ដូចសីហៈជំទន់ដែលកំពុងសម្តែងឫក បានធ្វើអនុមោទនា ញុំាងព្រះត្រៃបិដកឲ្យខ្ចរខ្ចារហើយ ។

ព្រះសាស្តាទ្រង់ក្រោកអំពីអាសនៈ មានភិក្ខុសង្ឃចោមរោម យាងទៅកាន់វិហារ កាលភិក្ខុទាំងឡាយសម្តែងវត្តហើយ ទ្រង់ក្រោកអំពីអាសនៈ ទ្រង់ឈរត្រង់យ៉មុខនៃព្រះគន្ធកុដិ ប្រទានសុគតោវាទ ត្រាស់កម្មដ្ឋានដល់ភិក្ខុសង្ឃ

ទ្រង់បញ្ជូនភិក្ខុសង្ឃទៅហើយ ទ្រង់ចូលកាន់ព្រះគន្ធកុដិ ដែលអប់ដោយក្លិនក្រអូបឈ្ងុយឈ្ងប់ ទ្រង់ផ្ទំសីហសេយ្យាដោយព្រះបន្ទៀងស្តាំ ។

ក្នុងពេលល្ងាច ភិក្ខុទាំងឡាយគង់ប្រជុំគ្នាខាងនេះ និងខាងនោះ ដូចព័ទ្ធវាំងននសំពត់កម្ពល ប្រារព្ធដល់រឿងព្រះគុណរបស់ព្រះសាស្តាថា អាវុសោ ព្រះមហាបន្ថកៈមិនជ្រាបអធ្យាស្រ័យរបស់ព្រះចូឡបន្ថកៈ ទើបមិនអាចឲ្យរៀនគាថាមួយបទ អស់កាល ៤ ខែបាន បណ្តេញចេញអំពីវិហារ ដោយយល់ថា ភិក្ខុរូបនេះល្ងង់ តែព្រះសាស្តាសម្មាសម្ពុទ្ធ បានប្រទានព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទា ក្នុងរវាងឆាន់អាហារមួយពេលប៉ុណ្ណោះ ព្រោះទ្រង់ជាព្រះធម្មរាជដ៏កំពូល មិនមានបុគ្គលប្រៀប ព្រះត្រៃបិដកមានមកព្រមជាមួយបដិសម្ភិទានោះឯង គួរសរសើរ ឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធទាំងឡាយមានច្រើន ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបរឿងរ៉ាវនេះ ក្នុងរោងធម្មសភាហើយ ទ្រង់ត្រិះរិះថា ថ្ងៃនេះតថាគតទៅ គួរទ្រង់ក្រោកចាកពុទ្ធសេយ្យាសនៈ ទ្រង់ស្លៀកសំពត់ពីរជាន់ ដែលជ្រលក់ល្អហើយ ចងវត្ថពន្ធចង្កេះ ដូចផ្លេកបន្ទោរ ទ្រង់ដណ្តប់មហាបង្សុកូលចីវរ ត្រូវនឹងទំហំសុគតប្រមាណ ប្រៀបដូចសំពត់រត្តកម្ពល ទ្រង់ចេញចាកព្រះគន្ធកុដិដែលមានក្លិនក្រអូប ទៅកាន់រោងធម្មសភាដោយលីលា នៃអកប្បកិរិយាដែលទ្រង់យាងទៅហើយ ដូចស្តេចគជសារចុះប្រេង និងដូចសីហៈដោយព្រះពុទ្ធលីលាមិនមានទីបំផុត ទ្រង់ឡើងកាន់បវរពុទ្ធាសនៈដែលបានគេរៀបចំ ត្រង់កណ្តាលនៃមណ្ឌបដែលបុគ្គលប្រដាប់ហើយ

ប្រថាប់គង់ត្រង់កណ្តាលអាសនៈ ទ្រង់បញ្ចេញព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការ ប្រៀបដូចទេវតាដ៏វិសេស បណ្តាលផ្ទៃមហាសមុទ្រឲ្យរញ្ជួយ និងដូចសុរិយោ-ទ័យ បញ្ចេញពន្លឺស្រទន់លើកំពូលយុគន្ធរ ដូច្នោះ ។ កាលព្រះសម្មាសម្ពុទ្ធយាង មកដល់ ភិក្ខុសង្ឃក៏ឈប់សន្ទនា អង្គុយស្ងៀម ។

ព្រះសាស្តាទ្រង់ពិចារណាមើលបរិស័ទ ដោយព្រះហឫទ័យដ៏ស្រទន់ ទ្រង់អាវជ្ជនៈថា បរិស័ទនេះស្រស់ត្រកាលពន់ពេក ការគ្គាំគ្គងដោយដៃក្តី គ្គាំគ្គងដោយជើងក្តី សំឡេងក្អកក្តី សំឡេងកណ្តាស់ក្តី របស់ភិក្ខុមួយរូប រមែងមិនមាន ភិក្ខុទាំងអស់នេះ មានការគោរពដោយពុទ្ធគារវៈ ដែលតេជះ នៃព្រះពុទ្ធគ្រំរាមហើយ កាលតថាគតនៅស្ងៀម មិនពោលដរាបអស់អាយុ ក៏ភិក្ខុរូបណាមួយ មិនអាចលើករឿងណាមួយពោលមុនបាន ឈ្មោះថា ទំនៀម របស់ការលើករឿងឡើង តថាគតគួរដឹង តថាគតនឹងពោលឡើងមុន ដូច្នេះ ហើយ ត្រាស់ហៅភិក្ខុទាំងឡាយដោយព្រះសូរសៀងដ៏ពីរោះ ដូចសំឡេង ព្រហ្ម សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នា ដោយ រឿងអ្វី រឿងអ្វីដែលពួកអ្នកផ្អាកក្នុងចន្លោះ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូឡបន្ថកៈ មិន មែនល្ងង់តែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏បានជាបុគ្គលល្ងង់ ហើយដូចគ្នា មួយវិញទៀត តថាគតជាទីពំនាក់អាស្រ័យរបស់លោក តែក្នុង ឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពំនាក់អាស្រ័យ ហើយដូចគ្នា ។ ក្នុងកាលមុន តថាគតបានធ្វើចូឡបន្ថកៈនេះ ឲ្យជាម្ចាស់នៃ

លោកិយទ្រព្យហើយ ឥឡូវនេះ បានធ្វើឲ្យជាម្ចាស់នៃលោកុត្តរទ្រព្យ កាលភិក្ខុទាំងឡាយ ប្រាថ្នានឹងស្តាប់សេចក្តីនោះដោយពិស្តារ ទូលស្នើហើយ ទ្រង់នាំអតីតនិទានមកពោលថា

ក្នុងអតីតកាល មាណពអ្នកនគរពារាណសីម្នាក់ ទៅកាន់ក្រុងតក្កសិលា ជាធម្មន្តេវាសិករបស់អាចារ្យទិសាបាមោក្ខ ដើម្បីបំណងរៀនសិប្ប: បានជាអ្នកឧបការៈដល់អាចារ្យក្រៃលែង ក្នុងរវាងមាណព ៥០០ ធ្វើកិច្ចគ្រប់យ៉ាង មានប្រចាប់ជើងជាដើម តែព្រោះជាបុគ្គលល្ងង់ ទើបមិនអាចរៀនអ្វីបាន អាចារ្យសូម្បីព្យាយាមដោយគិតឃើញថា សិស្សនេះ មានឧបការៈដល់អញច្រើន នឹងឲ្យគេសិក្សាឲ្យបាន ក៏មិនអាចឲ្យសិក្សាអ្វីមួយបាន ។

បុរសនោះនៅអស់កាលដ៏យូរ សូម្បីមួយគាថាក៏មិនអាចរៀនបាន នឹករអែងចិត្ត លាអាចារ្យថានឹងទៅ ។ អាចារ្យគិតថា សិស្សនេះមានឧបការៈច្រើនដល់អញ អញក៏បំណងភាពជាបណ្ឌិតដល់សិស្សនេះ តែមិនអាចធ្វើភាពជាបណ្ឌិតនោះបាន អញចាំបាច់ត្រូវធ្វើឧបការៈតបដល់សិស្សនេះឲ្យបាន អញនឹងចងមន្តឲ្យគេបានមួយបទ នាំសិស្សនោះចូលទៅកាន់ព្រៃ ចងមន្តនេះថា **ឃដេសិ ឃដេសិ កឹការណា ឃដេសិ អហំបិ តំ ជានាមិ ជានាមិ** ដូច្នេះហើយ ឲ្យរៀនប្រាស់ទៅប្រាស់មកច្រើនរយដង ហើយសួរថា អ្នកចាំបានហើយឬ កាលគាត់ឆ្លើយថា ខ្ញុំចាំបានហើយ ក៏ប្រាប់ថា ធម្មតាសិប្ប: ដែលបុគ្គលល្ងង់ធ្វើព្យាយាមឲ្យស្ទាត់ហើយ រមែងមិនភ្លេចភ្លាំង រួចឲ្យស្បៀងធ្វើដំណើរ ដោយប្រាប់ថា អ្នកចូរទៅអាស្រ័យមន្តនេះចិញ្ចឹមជីវិតចុះ តែដើម្បី

ប្រយោជន៍មិនឲ្យមន្តវិនាសទៅ អ្នកគប្បីស្វាធ្យាយមន្តនោះជានិច្ច ដូច្នេះហើយ ក៏បញ្ជូនទៅ ។

ក្នុងកាលបុរសនោះដល់នគរពារាណសី មាតាបិតាបានធ្វើសក្ការៈសន្និទ្ធ-ស្នាលដ៏ធំ ដោយត្រេកអរថា កូនរបស់អញសិក្សាសិប្បៈត្រឡប់មកហើយ ។

ក្នុងកាលនោះ ព្រះបាទពារាណសីទ្រង់ពិចារណាថា ទោសប្រការខ្លះ ព្រោះកម្មទាំងឡាយ មានកាយកម្មជាដើមមានឬហ្ន៎ ទ្រង់មិនឃើញកម្មណាមួយ ដែលមិនជាទីពេញព្រះហឫទ័យរបស់ព្រះអង្គ ក៏ទ្រង់ត្រិះរិះថា ធម្មតាទោស របស់ខ្លួនមិនប្រាកដដល់ខ្លួនឡើយ រមែងប្រាកដដល់អ្នកដទៃ អញនឹងកំណត់ ការប្រព្រឹត្តទៅរបស់ពួកអ្នកស្រុក ដូច្នេះហើយ ទើបទ្រង់ក្លែងភេទយាងចេញ ទៅក្នុងពេលល្ងាច ទ្រង់ត្រិះរិះថា ធម្មតាការសន្ទនា ប្រាស្រ័យរបស់ពួក មនុស្ស ដែលអង្គុយបរិភោគអាហារក្នុងពេលល្ងាច រមែងមានប្រការផ្សេងៗ គ្នា បើអញគ្រងរាជ្យដោយអធម៌ ជនទាំងឡាយគង់នឹងពោលថា ពួកយើង ត្រូវស្តេចផែនដីមិនតាំងនៅដោយធម៌ ជាមនុស្សអាក្រក់ បៀតបៀនដោយ ពន្ធអាករ និងពលីជាដើម បើអញគ្រងរាជ្យដោយធម៌ ជនទាំងឡាយនឹង ពោលពាក្យជាដើមថា ព្រះរាជានៃយើងទាំងឡាយ សូមទ្រង់មានព្រះជន្មាយុ យឺតយូរចុះ ហើយក៏សរសើរគុណរបស់អញ ដូច្នេះហើយ ទើបទ្រង់ត្រាច់ ទៅតាមលំដាប់ ជញ្ជាំងផ្ទះនោះៗ ។

ក្នុងខណៈនោះ ពួកចោរដែលរកស៊ីជីកឧម្មង្គ កំពុងជីកឧម្មង្គក្នុងរវាងផ្ទះ ពីរខ្នង ដើម្បីចូលផ្ទះទាំងពីរដោយឧម្មង្គតែមួយ ព្រះរាជាទតឃើញចោរ

ហើយ ទ្រង់ពួនក្នុងស្រមោលផ្ទះ ក្នុងកាលពួកចោរជីកឧម្មង្គចូលផ្ទះបាន ហើយ ពិនិត្យមើលទ្រព្យ មាណពភ្ញាក់ឡើងហើយ ក៏ស្វាធ្យាយមន្តនោះថា **ឃដេសិ ឃដេសិ កឹការណា ឃដេសិ អហំបិ តំ ជានាមិ ជានាមិ ។**

ចោរទាំងនោះ បានស្តាប់ពាក្យនោះហើយ កិតភ័យតក្កមា បោះសំពត់ សូម្បីដែលខ្លួនស្លៀកចោល គេចទៅដោយជណ្តើមគ្នាខាងមុខនោះឯង ដោយ ប្រាប់គ្នាថា បានឮថា បុរសម្នាក់នេះស្គាល់ពួកយើង វានឹងធ្វើឲ្យពួកយើង វិនាសក្នុងកាលឥឡូវនេះ ។

ព្រះរាជាទតឃើញចោរទាំងនោះកំពុងគេចទៅ ទ្រង់ស្តាប់សំឡេងមាណព នេះស្វាធ្យាយមន្ត ទ្រង់កំណត់ការប្រព្រឹត្តទៅ របស់ពួកអ្នកក្រុងបានហើយ ទើបយាងចូលព្រះរាជនិវេសន៍ តែកាលរាត្រីភ្លឺហើយ ក៏បញ្ជាឲ្យហៅបុរស ម្នាក់មកគាល់ ត្រាស់ថា នែអ្នក ចូរអ្នកទៅ ពួកចោរជីកឧម្មង្គក្នុងផ្ទះឈ្មោះ នោះ ក្នុងថ្នល់នោះ ក្នុងផ្ទះនោះ មានមាណពរៀនសិប្បៈមកអំពីនគរតក្ក- សិលា ចូរអ្នកនាំបុរសនោះមក ។ បុរសទៅប្រាប់ថា នែអ្នក ព្រះរាជាទ្រង់ ឲ្យហៅអ្នក ហើយនាំមាណពមក លំដាប់នោះ ព្រះរាជាត្រាស់សួរថា នែអ្នក អ្នកជាមាណពដែលរៀនសិប្បៈ មកអំពីនគរតក្កសិលាឬ ។ មាណពពោល ថា បពិត្រព្រះអង្គ គឺទូលបង្គំនេះឯង ។ ព្រះរាជាត្រាស់ថា អ្នកឲ្យសិប្បៈដល់ យើងបានដែរឬទេ មាណពទូលថា សាធុ សូមទ្រង់ប្រថាប់លើអាសនៈស្មើគ្នា ហើយរៀនចុះ ។

លំដាប់នោះ ព្រះរាជាទ្រង់ធ្វើយ៉ាងនោះ ទ្រង់រៀនមន្តនោះអំពីបុរសហើយ

បានព្រះរាជទានទ្រព្យមួយពាន់ ដោយព្រះតម្រាស់ថា នេះជាចំណែកបូជាអាចារ្យរបស់អ្នក ។

ក្នុងកាលនោះ សេនាបតីពោលនឹងកូសាមាលារបស់ស្តេចផែនដីថា អ្នកតាក់តែងព្រះមស្សុរបស់ព្រះរាជាក្នុងកាលណា កូសាមាលាពោលថា ស្អែកនេះ ឬខាន់ស្អែកនេះឯង ។ សេនាបតីនោះ ឲ្យទ្រព្យមួយពាន់ដល់បុរសនោះហើយពោលថា ខ្ញុំមានកិច្ចមួយ កាលបុរសនោះសួរថា កិច្ចអ្វីលោកម្ចាស់ ក៏ប្រាប់ថា ចូរអ្នកធ្វើដូចជាកោរព្រះមស្សុឲ្យព្រះរាជា សំលៀងកាំបិតកោរឲ្យមុតកាត់បំពង់កទ្រង់ចុះ អ្នកនឹងបានជាសេនាបតី ខ្ញុំនឹងធ្វើស្តេចផែនដី បុរសនោះទទួលថា បាន ។ ក្នុងថ្ងៃកោរព្រះមស្សុថ្វាយព្រះរាជា យកទឹកក្រអូបស្រន់ព្រះមស្សុឲ្យសើម សំលៀងកាំបិតកោរ ចាប់ត្រង់ជាយព្រះនលាដ គិតថា កាំបិតកោរមានមុខមុត អញគួរកាត់បំពង់កដោយឆាប់ប៉ុណ្ណោះ ដូច្នេះហើយទើបឈរក្នុងទីម្ខាងសំលៀកកាំបិតទៀត ។

ក្នុងខណៈនោះ ព្រះរាជាទ្រង់រឭកដល់មន្តរបស់ទ្រង់បាន កាលទ្រង់ធ្វើការស្វាធ្យាយ ក៏ត្រាស់ថា **ឃដេសិ ឃដេសិ កិំការណា ឃដេសិ អហំបិ តំ ជានាមិ ជានាមិ** អ្នកព្យាយាមទៅចុះ ព្យាយាមទៅចុះ ព្រោះហេតុអ្វីទើបអ្នកព្យាយាម អញក៏ដឹងហេតុនោះ អញក៏ដឹងហេតុនោះ ។

ញើសហូរស្រោក ចេញអំពីថ្ងាសរបស់កូសាមាលាហើយ គាត់យល់ថា ព្រះរាជាទ្រង់ជ្រាបអញ ភ័យខ្លាចហើយ ទើបបោះកាំបិតកោរចោលត្រង់ផែនដីហើយក្រាបទៀបបាទានោះឯង ។

ធម្មតាព្រះរាជាទាំងឡាយ រមែងជាបុគ្គលឈ្លាស ព្រោះដូច្នោះ ទើបទ្រង់ត្រាស់នឹងបុរសនោះថា វ៉ឺយ នាយកូសាមាលាកំណាច អាយល់ថា ស្តេចផែនដីមិនដឹងអាឬ កូសាមាលាពោលថា សូមទ្រង់ព្រះរាជទានអភ័យដល់ខ្ញុំព្រះអង្គចុះ ព្រះរាជាត្រាស់ថា ណ្ហើយចុះ កុំខ្លាចឡើយ ចូរប្រាប់មកចុះ ។ នាយកូសាមាលាពោលថា បពិត្រព្រះអង្គ សេនាបតីឲ្យទ្រព្យមួយពាន់ដល់ទូលបង្គំប្រាប់ថា ចូរអ្នកធ្វើជាកោរព្រះមស្សុរបស់ព្រះរាជា កាត់បំពង់កទ្រង់ចុះ កាលទ្រង់សោយទិវង្គតហើយ ខ្ញុំនឹងធ្វើជាស្តេចផែនដី តែងតាំងឯងឲ្យជាសេនាបតី ។

ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ត្រិះរិះថា អញបានជីវិតព្រោះអាស្រ័យអាចារ្យ ដូច្នេះហើយ ទើបត្រាស់ឲ្យហៅសេនាបតីមក ត្រាស់ថា នែសេនាបតី ឈ្មោះថា អ្វីដែលអ្នកមិនបានហើយអំពីសម្នាក់របស់យើង ឥឡូវនេះ យើងមិនអាចសម្លឹងមើលអ្នកបាន ចូរអ្នកចេញទៅអំពីដែនរបស់យើង បញ្ជាឲ្យនិរទេសចាកដែនហើយ ក៏ប្រើឲ្យហៅមាណព ដែលជាអាចារ្យចូលគាល់ ត្រាស់ថា លោកអាចារ្យខ្ញុំមានជីវិតព្រោះអាស្រ័យលោក ដូច្នេះហើយទ្រង់ធ្វើសក្ការៈធំ បានព្រះរាជទានតំណែងសេនាបតីដល់អាចារ្យនោះហើយ ។ មាណពក្នុងកាលនោះ បានជាចូឡបន្ថកៈ ព្រះសាស្តាជាអាចារ្យទិសាបាមោក្ខ ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន ចូឡបន្ថកៈក៏ល្ងង់យ៉ាងនេះដូចគ្នា ក្នុងកាលនោះតថាគតក៏បានជាទីពឹងពំនាក់របស់លោក ញុំាងលោកឲ្យតាំងនៅក្នុងលោកិយ-

ទ្រព្យហើយ ។ ស្អែកឡើង កាលកថាតាំងឡើងថា គួរសរសើរហ្ន៎ ព្រះសាស្តាជាទីពឹងពំនាក់របស់ចូឡបន្ថកៈហើយ ត្រាស់និទានរឿងអតីត ក្នុងចូឡសេដ្ឋិជាតក ហើយត្រាស់គាថាថា

អ្នកប្រាជ្ញឈ្លាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យ
ជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់
ភ្លើងដ៏តូច ។

ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងពំនាក់របស់ចូឡ-បន្ថកៈនេះ ចំពោះតែក្នុងឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុន ក៏បានជាទីពឹងពំនាក់ហើយ តែក្នុងកាលមុនតថាគតបានធ្វើចូឡបន្ថកៈនេះ ឲ្យជាម្ចាស់របស់លោកិយទ្រព្យ ឥឡូវនេះ ធ្វើឲ្យជាម្ចាស់លោកុត្តរទ្រព្យ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ចូឡកន្តេវាសិកក្នុងកាលនោះ បានជាចូឡបន្ថកៈ ក្នុងឥឡូវនេះ ។ ចំណែកចូឡកសេដ្ឋី ដែលជាអ្នកឈ្លាសយល់ក្នុងព្យាករនក្ខត្តឫក្ស ក្នុងកាលនោះ គឺតថាគតនោះឯង ។

ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោ ព្រះចូឡ-បន្ថកៈមិនអាចរៀនគាថា ៤ បទ ក្នុង ៤ ខែបាន ក៏មិនលះសេចក្តីព្យាយាមតាំងនៅក្នុងអរហត្តហើយ ឥឡូវនេះបានជាម្ចាស់ទ្រព្យ គឺលោកុត្តរធម៌ហើយ ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនារបស់

*តថាគត ប្រារព្ធសេចក្តីព្យាយាមហើយ រមែងជាម្ចាស់នៃលោកុត្តរធម៌បាន នោះឯង ដូច្នេះ ត្រាស់គាថានេះថា*

**ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច**
**ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។**

*អ្នកប្រាជ្ញគប្បីសាងកោះ គឺ អរហត្តផលជាកោះដែល ជំនន់ គឺ កិលេសជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹង ប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួម ក្នុងចតុប្បារិសុទ្ធសីលផង ដោយការទូន្មានឥន្ទ្រិយផង ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ ពីរបទថា* **ទីបំ កយិរាថ** *សេចក្តីថា បុគ្គលមាន បញ្ញា ប្រកបព្រមហើយដោយបញ្ញាដ៏រុងរឿងក្នុងធម៌ គប្បីធ្វើ គឺគប្បីធ្វើ បានដល់ អាចធ្វើកោះ គឺអរហត្តផល ដែលជាទីពឹងពំនាក់របស់ខ្លួនក្នុង សាគរ គឺសង្សារដ៏ជ្រៅក្រៃលែង ដោយភាពជាទីពឹង ដែលបានដោយលំបាក ក្រៃលែងនេះ ដោយធម៌ជាហេតុ ៤ ប្រការ គឺដោយការប្រឹងប្រែង ពោល គឺសេចក្តីព្យាយាម ១ ដោយការមិនប្រមាទ ពោល គឺការនៅប្រាសចាក សតិ ១ ដោយការសង្រួម ពោល គឺចតុប្បារិសុទ្ធសីល ១ ដោយ ការទូន្មានឥន្ទ្រិយ ១ ។*

*សួរថា គប្បីធ្វើកោះដូចម្តេច ឆ្លើយថា គប្បីធ្វើកោះដែលអន្លង់ទឹកជន់ លិចមិនបាន អធិប្បាយថា គប្បីធ្វើកោះដែលអន្លង់ទឹក គឺកិលេសទាំង ៤*

យ៉ាង មិនអាចលិច គឺកម្ចាត់បាន ។ ពិតហើយ អរហត្ត គឺឱឃៈ មិនអាចជន់លិចបានឡើយ ។

ក្នុងកាលចប់គាថា មហាជនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម ។ ទេសនាមានប្រយោជន៍ ដល់បុគ្គលដែលប្រជុំគ្នាហើយដូច្នេះឯង ។៙

**រឿង ព្រះចូឡបន្ថកត្ថេរ ចប់**

# រឿង ពាលនក្ខត្តឫក្ស

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនក្ខត្តឫក្សរបស់បុគ្គលពាល ត្រាស់ព្រះធម្មទេសនានេះថា **បមាទមនុយុញ្ជន្តិ** ជាដើម ។

សេចក្តីពិស្តារថា បានឮមកថា សម័យមួយ គេប្រកាសពាលនក្ខត្តឫក្សក្នុងនគរសាវត្ថី ។ ក្នុងនក្ខត្តឫក្សនោះ ពួកជនពាលអ្នកមានប្រាជ្ញាថោកថយយកធ្យូង និងគោម័យ គឺលាមកគោ លាបរាងកាយ ត្រាច់ពោលវាចារបស់អសប្បុរសរហូត ៧ ថ្ងៃ ។ ឃើញបុគ្គលណាម្នាក់ជាញាតិក្តី ជាសម្លាញ់ក្តី ជាបព្វជិតក្តី ឈ្មោះថា ខ្មាសមិនមាន ឈរពោលវាចារបស់អសប្បុរស ត្រង់ទ្វារគ្រប់ៗ ទ្វារ មនុស្សទាំងឡាយ មិនអាចស្តាប់អសប្បុរិសវាទរបស់បុគ្គលនោះបាន ទើបបញ្ជូនទ្រព្យកន្លះបាទខ្លះ ១ បាទខ្លះ ១ កហាបណៈខ្លះ តាម

កម្លាំង ពួកជនទាំងនោះកាន់យកទ្រព្យដែលបានហើយ ត្រង់ទ្វារផ្ទះរបស់មនុស្សទាំងនោះហើយ ក៏ចៀសចេញទៅ ។

ក្នុងកាលនោះ នគរសាវត្ថីមានអរិយសាវកប្រមាណ ៥ កោដិ លោកទាំងនោះបញ្ជូនដំណឹងទៅថ្វាយព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ មួយអន្ទើដោយភិក្ខុសង្ឃ កុំចូលទៅកាន់នគរ សូមប្រថាប់នៅតែក្នុងវិហារ ៧ ថ្ងៃចុះ ។ ក្នុង ៧ ថ្ងៃនោះ នឹងបញ្ជូនបបរ កត្តជាដើមទៅកាន់វិហារនោះឯង ដើម្បីភិក្ខុសង្ឃ សូម្បីខ្ញុំឯងក៏មិនអាចចេញអំពីផ្ទះ ។

កាលនក្ខត្តឫក្សស្ងប់ហើយ ក្នុងថ្ងៃទី ៨ អរិយសាវកទាំងនោះនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យយាងចូលទៅកាន់ព្រះនគរ ថ្វាយមាហទានហើយ អង្គុយក្នុងចំណែកម្ខាង ក្រាបទូលថា បពិត្រព្រះអង្គ ៧ ថ្ងៃ របស់ខ្ញុំព្រះអង្គ កន្លងទៅដោយលំបាកក្រៃលែង កាលពួកខ្ញុំព្រះអង្គបានឮវាចា មិនមែនរបស់សប្បុរសរបស់ពួកបុគ្គលពាល ត្រចៀកទាំងពីរ ហាក់បីដូចដល់នូវអាការបែកធ្លាយ ។ បុគ្គលណាម្នាក់ក៏មិនខ្មាសដល់បុគ្គលណា ព្រោះដូច្នោះទើបពួកខ្ញុំព្រះអង្គ មិនឲ្យទ្រង់យាងចូលខាងក្នុងព្រះនគរ សូម្បីពួកខ្ញុំព្រះអង្គក៏មិនអាចចេញអំពីផ្ទះ ។

ព្រះសាស្តាទ្រង់ស្តាប់វាចារបស់អរិយសាវកទាំងនោះហើយ ត្រាស់ថា កិរិយារបស់ពួកអ្នកមានប្រាជ្ញាថោកថយ រមែងដូច្នេះ ចំណែកអ្នកមានបញ្ញាទាំងឡាយ រក្សាសេចក្តីមិនប្រមាណ ដូចទ្រព្យដែលជាសារៈ រមែងសម្រេចសម្បត្តិ គឺអមតមហានិព្វាន ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**
**អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។**
**មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ**
**អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។**

*ពួកជនពាល អប្បឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចទ្រព្យយ៉ាងប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗ នូវសេចក្តីរីករាយ ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្តីសុខដ៏ទូលាយ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ពាលា** *បានដល់ ដែលប្រកបដោយភាពជាជនពាល គឺដែលមិនស្គាល់ប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ។*

*បទថា* **ទុម្មេធិនោ** *គឺឥតប្រាជ្ញា ។ ពួកជនពាលនោះ កាលមិនឃើញទោសក្នុងសេចក្តីប្រមាទ ឈ្មោះថា រមែងប្រកបរឿយៗ នូវសេចក្តីប្រមាទ គឺរមែងឲ្យកាលកន្លងទៅដោយសេចក្តីប្រមាទ ។*

*បទថា* **មេធាវី** *ជាដើម សេចក្តីថា ចំណែកបណ្ឌិតប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ រមែងរក្សាការមិនប្រមាទ ដូចទ្រព្យ គឺរតនៈ ៧ ប្រការដ៏ប្រសើរ គឺឧត្តម បន្តជាប់គ្នាមកអំពីវង្សត្រកូល ។ អធិប្បាយថា ឧបមាដូច*

*ជនទាំងឡាយ កាលឃើញអានិសង្សក្នុងទ្រព្យថា យើងទាំងឡាយអាស្រ័យទ្រព្យដ៏ឧត្តម នឹងដល់សម្បត្តិ គឺកាមគុណ នឹងធ្វើផ្លូវជាទីទៅកាន់បរលោកឲ្យបរិសុទ្ធបាន រមែងរក្សាទ្រព្យនោះ យ៉ាងណា សូម្បីបណ្ឌិតក៏ដូច្នោះ ឃើញអានិសង្សក្នុងការមិនប្រមាទថា បុគ្គលមិនប្រមាទហើយ រមែងបានចំពោះនូវឈានទាំងឡាយ មានបឋមជ្ឈានជាដើម រមែងសម្រេចលោកុត្តរធម៌ មានមគ្គនិងផលជាដើម រមែងញ៉ាំងវិជ្ជា ៣ អភិញ្ញា ៦ ឲ្យដល់ព្រមបាន រមែងរក្សាការមិនប្រមាទ ដូចទ្រព្យដ៏ប្រសើរ ។*

*បទថា* **មា បមាទំ** *សេចក្ដីថា ព្រោះដូច្នោះ អ្នកទាំងឡាយកុំតាមប្រកបនូវសេចក្ដីប្រមាទ គឺកុំឲ្យកាលកន្លងទៅដោយសេចក្ដីប្រមាទ ។*

*បាទគាថាថា* **មា កាមរតិសន្ថវំ** *សេចក្ដីថា កុំតាមប្រកប គឺកុំគិតបានដល់ កុំបានចំពោះនូវការស្និទ្ធស្នាលដោយអំណាចនៃតណ្ហា ពោល គឺការត្រេកអរក្នុងវត្ថុកាម និងកិលេសកាម ។*

*បទថា* **អប្បមត្តោ ហិ** *ជាដើម សេចក្ដីថា ព្រោះថា បុគ្គលមិនប្រមាទហើយ ដោយភាពជាបុគ្គលមានសតិតាំងមាំ សម្លឹងពិចារណា រមែងសម្រេចនិព្វានសុខដ៏បរិបូណ៌ គឺឧឡារ ។*

*ក្នុងកាលចប់គាថា ជនជាច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។៚*

**រឿងពាលនក្ខត្តឫក្ស ចប់**

# រឿង ព្រះមហាកស្សបត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **បមាទំ អប្បមាទេន** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈនៅក្នុងបិប្ផលិគុហា ត្រាច់ទៅបិណ្ឌ-បាត ខាងក្រោយភត្ត អង្គុយចម្រើនអាលោកកសិណ ប្រមើលមើលសត្វទាំងឡាយ ដែលប្រមាទហើយ និងមិនប្រមាទហើយ ដែលចុតិ និងកើតក្នុងទីទាំងឡាយ មានទឹក ផែនដី និងភ្នំជាដើម ដោយទិព្វចក្ខុ ។

ព្រះសាស្តា ប្រថាប់គង់ក្នុងវត្តជេតពននោះឯង ទ្រង់ប្រមើលមើលដោយទិព្វចក្ខុថា ថ្ងៃនេះកស្សបៈដែលជាបុត្ររបស់តថាគត នៅដោយវិហារណាហ្ន៎ ទ្រង់ជ្រាបថា កំពុងប្រមើលមើលចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ទើបត្រាស់ថា ឈ្មោះថា ចុតិ និងការកើតនៃសត្វទាំងឡាយ សូម្បីពុទ្ធញាណទ្រង់មិនកំណត់ បុគ្គលណាម្នាក់ក៏មិនអាចធ្វើការកំណត់សត្វទាំងឡាយ ដែលបដិសន្ធិក្នុងផ្ទៃរបស់មាតា ដែលមាតាបិតាមិនទាន់ស្គាល់ ក៏ចុតិហើយបាន ។ ការដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងនោះ មិនមែនវិស័យរបស់អ្នក វិស័យរបស់អ្នកមានប្រមាណតិច ចំណែកការដឹង ការឃើញសត្វទាំងឡាយដែលចុតិ និងកើត ដោយប្រការទាំងពួង ជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ដូច្នេះហើយ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់បីដូចប្រថាប់គង់នៅក្នុងទីចំពោះមុខ ត្រាស់ព្រះគាថានេះថា

**បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ**
**បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ**
**បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។**

*កាលណាបណ្ឌិតបន្ទោបង់នូវសេចក្ដីប្រមាទ ដោយសេចក្ដីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញពួកសត្វដែលមានសោក ធីរជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលឋិតនៅលើផែនដី ដូច្នោះឯង ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **នុទតិ** *ជាដើម សេចក្ដីថា កាលណាបណ្ឌិតកពូនទូវធម៌ មានការមិនប្រមាទជាលក្ខណៈ មិនឲ្យឱកាសដល់ការប្រមាទ ឈ្មោះថា រមែងបន្ទោបង់ គឺរមែងបណ្ដេញនូវសេចក្ដីប្រមាទនោះ ។ ដោយកម្លាំងនៃសេចក្ដីមិនប្រមាទ ដូចទឹកថ្មីហូរចូលស្រះបោក្ខរណី ញុំាងទឹកចាស់ឲ្យរញ្ជួយហើយ មិនឲ្យឱកាសដល់ទឹកចាស់នោះ រមែងរុញ គឺប្រានទឹកចាស់នោះឲ្យហូរចេញទៅ ដោយទីបំផុតរបស់ខ្លួនដូច្នោះឯង ។ កាលនោះ បណ្ឌិតនោះ មានសេចក្ដីប្រមាទដែលបន្ទោបង់ហើយ បំពេញបដិបទាដែលសមគួរដល់ការមិនប្រមាទនោះ ។ ឡើងកាន់បញ្ញា ប្រៀបដូចប្រាសាទ ពោល គឺទិព្វចក្ខុដ៏បរិសុទ្ធ ដោយអត្ថថា ខ្ពង់ខ្ពស់ ដោយបដិបទានោះ ដូចបុគ្គលឡើងកាន់ប្រាសាទតាមជណ្ដើរ ដូច្នោះ ឈ្មោះថា មិនសោយសោក ព្រោះភាពជា*

បុគ្គលលះនូវបង់ព្រួញ គឺសេចក្ដីសោកចេញបានហើយ ។ រមែងពិចារណាឃើញ គឺរមែងមើលឃើញប្រជា គឺពួកសត្វ ដែលឈ្មោះថា មានសេចក្ដីសោក ព្រោះភាពជាបុគ្គលមិនទាន់បានលះសរ គឺសេចក្ដីសោក ដែលចុតិ និងបដិសន្ធិដោយទិព្វចក្ខុ ។

សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា ដូចបុគ្គលឈរលើកំពូលភ្នំ រមែងសម្លឹងឃើញជនដែលឈរលើផែនដីបានដូច្នោះ អធិប្បាយថា បុគ្គលឈរលើកំពូលភ្នំ រមែងមើលឃើញជនដែលឈរត្រង់ផែនដីបាន ឬឈរលើប្រាសាទខាងលើ រមែងមើលឃើញជនដែលឈរក្នុងបរិវេណនៃប្រាសាទបាន ដោយមិនលំបាក យ៉ាងណា អ្នកប្រាជ្ញ គឺបណ្ឌិត បានដល់ ព្រះមហាខីណាស្រព នោះ ក៏រមែងពិចារណាឃើញបុគ្គលពាលទាំងឡាយ ដែលមិនទាន់ដកពូជ គឺវដ្ដៈបាន ចុតិ និងបដិសន្ធិ ដោយមិនលំបាក ដូច្នោះ ។

ក្នុងកាលចប់គាថា មហាជនធ្វើឲ្យជាក់ច្បាស់ហើយ នូវព្រះអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងមហាកស្សបត្ថេរ ចប់**

# រឿង ភិក្ខុ ២ អង្គជាសម្លាញ់នឹងគ្នា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុពីររូប ជាសម្លាញ់នឹងគ្នា ត្រាស់ព្រះធម្មទេសនានេះថា **អប្បមត្តោ បមត្តេសុ** ជាដើម ។

បានឮថា ភិក្ខុពីររូបនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ ចូលទៅកាន់វិហារ ដែលតាំងនៅក្នុងព្រៃ ។ ក្នុងភិក្ខុពីររូបនោះ ភិក្ខុមួយរូបរកឧសមកអស់កាលមួយថ្ងៃហើយ រៀបដើងក្រាន អង្គុយអាំងភ្លើង សន្ទនានឹងពួកភិក្ខុកំលោះ និងសាមណេរអស់បឋមយាម ។ មួយរូបទៀត មិនប្រមាទ ធ្វើសមណធម៌ ដាស់តឿនភិក្ខុនោះថា អាវុសោ អ្នកកុំធ្វើយ៉ាងនោះ ព្រោះអបាយ ៤ ជាផ្ទះ ជាទីដេកនៃពួកជនដែលប្រមាទហើយ ។ ធម្មតាព្រះពុទ្ធទាំងឡាយ ដែលបុគ្គលអួតអាង មិនអាចឲ្យត្រេកអរបាន ។ លោកមិនស្តាប់ពាក្យដាស់តឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះគិតថា ភិក្ខុនេះមិនជឿពាក្យអាត្មាអញ ទើបមិនប្រាប់នឹងដាស់តឿន លោកមិនប្រមាទហើយ បានធ្វើសមណធម៌ ។ ចំណែកព្រះថេរៈដែលខ្ជិលច្រអូស អាំងភ្លើងក្នុងបឋមយាមហើយ ក្នុងកាលដែលភិក្ខុ ១ អង្គទៀតដើរចង្រ្កមហើយ ចូលទៅកាន់បន្ទប់ ទើបចូលទៅពោលថា អ្នកខ្ជិលច្រអូសច្រើន អ្នកចូលមកកាន់ព្រៃដើម្បីការដេកឬ បុគ្គលរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធហើយ ក្រោកឡើងធ្វើសមណធម៌ អស់កាលយប់ និងថ្ងៃមិនគួរឬ ដូច្នេះហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួនហើយដេក ចំណែកភិក្ខុក្រៅអំពីនេះ សម្រាកក្នុងមជ្ឈិមយាមហើយ ត្រឡប់ក្រោក

ឡើង ធ្វើសមណធម៌ក្នុងបច្ឆិមយាម លោកមិនប្រមាទយ៉ាងនោះ អស់កាលមិនយូរ ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ ភិក្ខុខិលប្រអូសក្រៅអំពីនេះ ឲ្យកាលកន្លងទៅដោយសេចក្តីប្រមាទតែម្យ៉ាង ។ ភិក្ខុពីររូបនោះ ចេញវស្សាហើយ ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុពីររូបនោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនប្រមាទ ធ្វើសមណធម៌ហើយឬ កិច្ចនៃបព្វជិតរបស់ពួកអ្នក ដល់ទីបំផុតហើយឬ ភិក្ខុអ្នកប្រមាទក្រាបទូលថា បពិត្រព្រះអង្គ ការមិនប្រមាទរបស់ភិក្ខុនោះ នឹងមានមកអំពីណា តាំងអំពីទៅលោកដេកលក់ ឲ្យកាលវេលាកន្លងទៅហើយ ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ ចុះអ្នកវិញ ភិក្ខុខិលប្រអូសក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរកឧសមកក្នុងពេលថ្ងៃ រៀបដើងក្រានហើយ អង្គុយអាំងភ្លើងអស់បឋមយាម មិនដេកលក់ ឲ្យកាលវេលាកន្លងទៅហើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា អ្នកប្រមាទហើយ ឲ្យកាលកន្លងទៅទទេ នៅមកពោលថា ខ្លួនមិនប្រមាទ ហើយធ្វើបុគ្គលមិនប្រមាទឲ្យជាអ្នកប្រមាទ ។ អ្នកដូចជាសេះដែលមានខ្លួនទុព្វល មានជ្វីជើងអន់ថយហើយ ក្នុងសម្នាក់នៃបុត្រតថាគត ចំណែកបុត្ររបស់តថាគតនេះ ដូចជាសេះដែលមានជ្វីជើងរហ័ស ក្នុងសម្នាក់របស់អ្នក ដូច្នេះហើយ ទើបត្រាស់គាថានេះថា

**អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ**
**អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។**

បណ្ឌិតមានប្រាជ្ញាមុះមុត កាលបុគ្គលកំពុងប្រមាទ លោកមិនប្រមាទ កាលបុគ្គលកំពុងដេកលក់ លោកភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែបនោះ ដូចសេះលឿនដែលទៅចោលនូវសេះមានកម្លាំងទន់ទាប ដូច្នោះឯង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមត្តោ** សេចក្តីថា ឈ្មោះថា បុគ្គលដល់ព្រមដោយការមិនប្រមាទ ព្រោះជាអ្នកដល់នូវការបរិបូណ៌នៃសតិ បានដល់ព្រះខីណាស្រព ។

បទថា **បមត្តេសុ** សេចក្តីថា កាលសត្វទាំងឡាយ តាំងនៅហើយក្នុងការបណ្តែតបណ្តោយសតិ ។ បទថា **សុត្តេសុ** គឺកាលសត្វទាំងឡាយ ឈ្មោះថា ប្រព្រឹត្តដេកលក់ គ្រប់ឥរិយាបថនោះឯង ព្រោះមិនមានធម៌ជាគ្រឿងភ្ញាក់រឭក គឺសតិ ។ បទថា **ពហុជាគរោ** បានដល់ តាំងនៅក្នុងធម៌ជាគ្រឿងភ្ញាក់រឭក គឺបរិបូណ៌នៃសតិដ៏ច្រើន ។ បទថា **អពលស្សំវ** សេចក្តីថា ដូចសេះសន្ធពអាជានេយ្យ មានសម្ទុះជើងរហ័ស រត់ចោលសេះដែលមានកម្លាំងខ្សោយ មានសម្ទុះអន់ហើយ ដោយភាពជាសេះមានជើងដាច់ទៅ ដូច្នោះ ។

បទថា **សុមេធសោ** ជាដើម សេចក្តីថា បុគ្គលមានបញ្ញាដ៏កំពូល រមែងលះបុគ្គលបែបនោះទៅ ដោយអាគមន គឺបរិយត្តិខ្វះ ដោយអធិគមន គឺការ

សម្រេចមគ្គផលខ្លះ អធិប្បាយថា កាលបុគ្គលមានបញ្ញាទន់ខ្សោយ ព្យាយាមរៀនព្រះសូត្រ មួយសូត្រនោះឯង ។ បុគ្គលមានបញ្ញាល្អ រមែងរៀនបានមួយវគ្គ រមែងលះទៅដោយអាគមន គឺបរិយត្តិយ៉ាងនេះមុន ។ ម្យ៉ាងទៀត កាលបុគ្គលមានបញ្ញាអន់ខ្សោយ កំពុងព្យាយាមធ្វើទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃនោះឯង នឹងរៀនកម្មដ្ឋាន ស្វាធ្យាយនុ៎ះឯង ក្នុងកាលជាចំណែកខាងដើម បុគ្គលដែលមានបញ្ញាល្អ ចូលទៅកាន់ទីសម្រាកពេលយប់ ឬទីសម្រាកពេលថ្ងៃ ដែលអ្នកដទៃធ្វើ ពិចារណាកម្មដ្ឋាន ញុំាងកិលេសសព្វយ៉ាងឲ្យអស់ទៅ ធ្វើនវលោកុត្តរធម៌ ៩ ប្រការ ឲ្យតាំងនៅក្នុងកណ្ដាប់ដៃបាន បុគ្គលមានបញ្ញាល្អ រមែងលះទៅបានដោយអធិគមន គឺការសម្រេចមគ្គផលយ៉ាងនេះ ។ ម្យ៉ាងទៀត បុគ្គលមានបញ្ញាល្អ លះ គឺចោលបុគ្គលមានបញ្ញាអាក្រក់នោះនៅក្នុងវដ្ដៈ ដកខ្លួនចេញអំពីវដ្ដៈទៅដោយពិត ។

ក្នុងកាលចប់គាថា មហាជនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

## រឿង ភិក្ខុ ២ អង្គជាសម្លាញ់នឹងគ្នា ចប់

# រឿង សក្កទេវរាជ

## លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យក្រុងវេសាលី គង់នៅក្នុងកូដាគារសាលា ទ្រង់ប្រារព្ធសក្កទេវរាជ ត្រាស់ធម្មទេសនានេះថា **អប្បមាទេន មឃវា** ជាដើម ។

សេចក្តីពិស្តារថា ស្តេចលិច្ឆវីព្រះនាមថាមហាលិ នៅក្នុងក្រុងវេសាលី ។ ទ្រង់ស្តាប់ទេសនាក្នុងសក្កបញ្ហសូត្រ របស់ព្រះតថាគតហើយ ទ្រង់ត្រិះរិះថា ព្រះសម្មាសម្ពុទ្ធ ត្រាស់សម្បត្តិរបស់សក្កទេវរាជជាច្រើន ព្រះអង្គទ្រង់ឃើញហើយ ទើបត្រាស់ ឬទ្រង់មិនឃើញហើយត្រាស់ហ្ន៎ ទ្រង់ស្គាល់ស្តេចសក្កឬហ្ន៎ អញនឹងទូលសួរព្រះអង្គ ។

គ្រានោះឯង ស្តេចលិច្ឆវី ព្រះនាមមហាលិ ចូលទៅគាល់ដល់ទីដែលព្រះដ៏មានព្រះភាគគង់នៅ កាលចូលទៅគាល់ហើយ ទើបថ្វាយបង្គំព្រះដ៏មានព្រះភាគ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ស្តេចមហាលិលិច្ឆវី កាលអង្គុយក្នុងទីសមគួរនាចំណែកម្ខាងហើយ បានក្រាបទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវរាជជាស្តេចនៃទេវតាទាំងឡាយ ព្រះអង្គឃើញហើយឬ ។

ព្រះដ៏មានព្រះភាគត្រាស់ថា មហាលិ សក្កទេវរាជជាស្តេចនៃទេវតាទាំងឡាយ តថាគតឃើញហើយ ។ មហាលិពោលថា បពិត្រព្រះអង្គ សក្កទេវរាជនោះ ជាសក្កៈក្លែងក្លាយពិត ព្រោះថា សក្កទេវរាជទាំងឡាយ បុគ្គល

ឃើញបានដោយលំបាក ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលមហាលិ តថាគតស្គាល់សក្កៈផង ស្គាល់ធម៌ដែលធ្វើឲ្យជាសក្កៈផង សក្កទេវរាជ ដល់នូវភាពជាសក្កៈ ព្រោះសមាទាននូវធម៌ណា តថាគតស្គាល់ធម៌ទាំងនោះឯង ។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុនជាមនុស្សបានជាមាណពឈ្មោះមឃៈ ព្រោះដូច្នោះ ទើបគេហៅថា **ស្តេចមឃវា** ។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុន ជាមនុស្ស បានឲ្យទានមុនគេ ព្រោះដូច្នោះ ទើបគេហៅថា **ស្តេចបុរិន្ទទៈ** ។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុន ជាមនុស្ស បានឲ្យទានដោយគោរព ព្រោះដូច្នោះ ទើបគេហៅថា **ស្តេចសក្កៈ** ។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ក្នុងកាលមុន ជាមនុស្ស បានឲ្យទីស្នាក់អាស្រ័យ ព្រោះដូច្នោះ ទើបគេហៅថា **ស្តេចវាសវៈ** ។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ ទ្រង់ត្រិះរិះនូវន័យមួយពាន់បានមួយរំពេច ព្រោះដូច្នោះ ទើបគេហៅថា **សហស្សក្ខ** ។ ម្នាលមហាលិ នាងអសុរកញ្ញា ឈ្មោះសុជាតា ជាបជាបតីរបស់សក្កៈ ជាស្តេចនៃទេវតាទាំងឡាយ ព្រោះដូច្នោះ ទើបគេហៅថា **ស្តេចសុជម្បតី** ។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចនៃទេវតាទាំងឡាយ សោយរាជសម្បត្តិជាឥស្សរិយាធិបតិ នៃទេវតាទាំងឡាយ ជាន់តាវត្តិង្ស ព្រោះដូច្នោះ ទើបគេហៅថា **ទេវានមិន្ទៈ** ។ ម្នាលមហាលិ សក្កទេវរាជ ជាស្តេចសក្កៈហើយ ព្រោះបានសមាទានវត្តបទ ៧ ណា វត្តបទ ៧ នោះ ឈ្មោះថា ស្តេចសក្កៈ

ជាកំពូលនៃទេវតាទាំងឡាយ ក្នុងកាលមុន ជាមនុស្ស សមាទានឲ្យបរិបូណ៌ហើយ ។ វត្តបទ ៧ ប្រការដូចម្ដេច ។ គឺអាត្មាអញ គប្បីជាអ្នកចិញ្ចឹមមាតាបិតាអស់មួយជីវិត ១ គប្បីជាអ្នកមានប្រក្រតីប្រព្រឹត្តឱនលំទោនចំពោះអ្នកជំក្នុងត្រកូលអស់មួយជីវិត ១ គប្បីជាអ្នកពោលពាក្យផ្អែមល្ហែមអស់មួយជីវិត ១ គប្បីជាអ្នកមិនពោលញុះញង់អស់មួយជីវិត ១ មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ ១ មានគ្រឿងបរិច្ចាគលះបង់ហើយ មានបាតដៃលាងហើយ ត្រេកអរហើយក្នុងការលះ គួរដល់ការសូម ត្រេកអរក្នុងការចែកទាន គប្បីគ្រប់គ្រងផ្ទះអស់មួយជីវិត ១ ជាអ្នកពោលពាក្យសច្ចៈអស់មួយជីវិត ១ ជាអ្នកមិនក្រោធអស់មួយជីវិត ១ ។ បើសេចក្ដីក្រោធ គប្បីកើតដល់អញសោត អញនឹងកាច់បំបាក់ចោលមួយរំពេច ដូច្នេះ ម្នាលមហាលិ ស្ដេចសក្កៈដល់នូវភាពជាសក្កៈ ព្រោះបានសមាទានវត្តបទ ៧ ណា វត្តបទ ៧ នោះ បានជារបស់ស្ដេចសក្កៈ ដែលជាស្ដេចនៃទេវតាទាំងឡាយ កាលកើតជាមនុស្សក្នុងកាលមុន សមាទាន ឲ្យបរិបូណ៌ហើយ ដូច្នេះឯង ។

ព្រះដ៏មានព្រះភាគ កាលត្រាស់វេយ្យាករណ៍នេះហើយ បានត្រាស់ព្រះពុទ្ធវចនៈខាងក្រោយថា

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា អ្នក
កោតក្រែងបុគ្គលជាច្បងក្នុងត្រកូល មានវាចាល្អិតទន់ និយាយតែ
ពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបក្នុងការលះបង់
សេចក្ដីកំណាញ់ មានសម្ដីទៀងទាត់ ជាជនគ្របសង្កត់សេចក្ដី

ក្រោធនោះឯង ថាជាសប្បុរស ។

ព្រះដ៏មានព្រះភាគត្រាស់ថា មហាលិ កម្មនេះ សក្កៈធ្វើក្នុងគ្រាជាមឃ-មាណព ដូច្នេះហើយ កាលមហាលិលិច្ឆវី ប្រាថ្នានឹងស្ដាប់កិច្ចបដិបត្តិរបស់សក្កៈនោះដោយពិស្ដារ ទើបទូលសួរទៀតថា បពិត្រព្រះអង្គ មឃមាណពបដិបត្តិដូចម្ដេច ទើបត្រាស់ថា ម្នាលមហាលិ បើដូច្នោះ ចូរស្ដាប់ចុះ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល មាណពឈ្មោះមឃៈ ក្នុងអចលគាម ដែនមគធៈ ទៅកាន់ទីធ្វើការងារក្នុងស្រុក ឈូសធូលីដោយចុងម្រាមជើងក្នុងទីដែលខ្លួនឈរហើយ បានធ្វើឲ្យជាទីរមណីយដ្ឋាន ហើយស្នាក់នៅ ។ បុគ្គលម្នាក់ទៀតយកដៃប្រានទាំចេញអំពីទីនោះហើយ បានស្នាក់នៅក្នុងទីនោះខ្លួនឯង គាត់មិនក្រោធចំពោះបុគ្គលនោះ បានធ្វើទីដទៃឲ្យជារមណីយដ្ឋានហើយស្នាក់នៅ អ្នកដទៃក៏យកដៃប្រានគាត់ចេញអំពីទីនោះហើយ បានស្នាក់នៅក្នុងទីនោះខ្លួនឯង ។ គាត់មិនក្រោធចំពោះបុគ្គលនោះ បានធ្វើទីដទៃឲ្យជារមណីយដ្ឋាន ហើយស្នាក់នៅ ។ បុរសទាំងឡាយដែលចេញទៅហើយអំពីផ្ទះ ក៏យកដៃប្រានគាត់ចេញអំពីទីដែលគាត់ជម្រះហើយ ដោយប្រការដូច្នេះ ។ គាត់គិតថា ជនទាំងអស់នោះ ជាអ្នកបានទទួលសេចក្ដីសុខហើយ កម្មនេះ គប្បីជាកម្មឲ្យសេចក្ដីសុខដល់អញ ដូច្នេះហើយ ស្អែកឡើង កាន់យកចបទៅធ្វើទីប៉ុនមណ្ឌលនៃលានឲ្យជារមណីយដ្ឋានហើយ ។ ពពួកជនបានទៅស្នាក់នៅក្នុងទីនោះឯង ។

ក្នុងរដូវរងា គាត់បានបង្កាត់ភ្លើងឲ្យជនទាំងនោះ ក្នុងរដូវក្ដៅ បានឲ្យទឹក

បន្ទាប់មក គាត់គិតថា ឈ្មោះថា រមណីយដ្ឋាន ជាទីស្រឡាញ់របស់ជនទាំងពួង ឈ្មោះថា មិនជាទីស្រឡាញ់របស់បុគ្គលណាម្នាក់មិនមាន តាំងអំពីនេះទៅ អញគួរធ្វើផ្លូវឲ្យរាបស្មើ ដូច្នេះហើយ ទើបចេញទៅអំពីស្រុកទាំងព្រលឹម ធ្វើផ្លូវឲ្យរាបស្មើ កាប់មែកឈើដែលគួរកាប់ ។

ក្រោយមក បុរសម្នាក់ទៀតឃើញគាត់ហើយពោលថា នែសម្លាញ់ តើអ្នកធ្វើអ្វី មឃមាណពពោលថា ខ្ញុំធ្វើផ្លូវជាទីទៅឋានសួគ៌របស់ខ្ញុំ បុរសនោះពោលថា បើដូច្នោះ ខ្ញុំក៏ជាសម្លាញ់របស់អ្នក មឃមាណពពោលថា ចូរជាសម្លាញ់របស់ខ្ញុំចុះ ធម្មតាឋានសួគ៌រមែងជាស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ។

បន្ទាប់អំពីនោះមក ក៏បានគ្នាពីរនាក់ ។ ចំណែកបុរសដទៃទៀត ឃើញជនទាំងពីរហើយ សួរយ៉ាងនោះឯង លុះជ្រាបហើយ ក៏ជាសម្លាញ់របស់ជនទាំងពីរ មនុស្សដទៃៗ ទៀត ក៏បានធ្វើយ៉ាងនោះ រួមមនុស្សទាំងអស់ ទើបជា ៣៣ នាក់ ដោយប្រការដូច្នេះ ។

ជនទាំងអស់មានដៃកាន់វត្ថុ មានចបជាដើម ធ្វើផ្លូវឲ្យរាបស្មើបានចម្ងាយប្រមាណមួយយោជន៍ និងពីរយោជន៍ ។

មេស្រុកឃើញបុរសទាំងនោះហើយ គិតថា មនុស្សទាំងនេះប្រកបហើយ ក្នុងឋានៈដែលមិនគួរប្រកប បើជនទាំងនេះគប្បីនាំវត្ថុទាំងឡាយ មានត្រី និងសាច់ជាដើមមកអំពីព្រៃ ឬធ្វើស្រាហើយផឹក ឬធ្វើកម្មបែបនោះដទៃអញ គប្បីបានចំណែកខ្លះណាមួយ ។

លំដាប់នោះ ទើបមេស្រុកហៅជនទាំងនោះមកសួរថា ពួកឯងធ្វើអ្វី ជនទាំងនោះពោលថា ធ្វើផ្លូវទៅឋានសួគ៌ ។ មេស្រុកពោលថា ធម្មតាអ្នកគ្រប់គ្រងផ្ទះទាំងឡាយ ធ្វើយ៉ាងនោះមិនគួរ គួរនាំវត្ថុទាំងឡាយ មានត្រី និងសាច់ជាដើមមកអំពីព្រៃ គួរធ្វើស្រាផឹក និងគួរធ្វើការងារទាំងឡាយ មានប្រការផ្សេងៗ ។

ជនទាំងនោះ ជំទាស់ពាក្យរបស់មេស្រុកនោះ ។ សូម្បីត្រូវមេស្រុកពោលដដែលៗ ក៏ជំទាស់រឿយៗ ទៅ ។ មេស្រុកក្រោធហើយ គិតថា អញនឹងឲ្យពួកវាវិនាស ទើបទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គទូលបង្គំឃើញពួកចោរត្រាច់ទៅដោយចងគ្នាជាពួក កាលព្រះរាជាត្រាស់ថា អ្នក ចូរទៅ ចូរចាប់ពួកវា ហើយនាំមក ។ មេស្រុកបានធ្វើតាមបញ្ជា ហើយបង្ហាញដល់ព្រះរាជា ។ ព្រះរាជាទ្រង់មិនទាន់ពិចារណា ទ្រង់បង្គាប់ថា ពួកអ្នក ចូរឲ្យដំរីជាន់ ។

មឃមាណពបានឲ្យឱវាទដល់ជនទាំងឡាយថា សម្លាញ់ទាំងឡាយ វៀរមេត្តាហើយ ទីពឹងរបស់ពួកយើងមិនមាន អ្នកទាំងឡាយមិនត្រូវធ្វើសេចក្ដីក្រោធក្នុងបុគ្គលណាឡើយ ចូរជាអ្នកមានចិត្តស្មើដោយមេត្តាចិត្ត ក្នុងព្រះរាជាក្នុងមេស្រុក ក្នុងដំរី និងក្នុងមនុស្សជនទាំងនោះ ក៏បានធ្វើយ៉ាងនោះ ។

លំដាប់នោះ ដំរីមិនអាចចូលជិតបាន ព្រោះអានុភាពនៃមេត្តារបស់ជនទាំងនោះ ។ ព្រះរាជាទ្រង់ស្ដាប់សេចក្ដីនោះហើយត្រាស់ថា ដំរីវាឃើញមនុស្សច្រើន ទើបមិនអាចជាន់បាន អ្នកទាំងឡាយចូរទៅយកកន្ទេលផែងគ្រប ហើយ

សីមឲ្យជាន់ ។ ដីរ ទោះគេយកកន្ទេលផែងគ្របជនទាំងនោះ ចូលទៅជាន់ក៏ថយក្រោយ ឈរអំពីចម្ងាយនោះឯង ។ ព្រះរាជាទ្រង់ស្តាប់ព្រឹត្តិហេតុនោះហើយ ទ្រង់ត្រិះរិះថា ក្នុងរឿងនេះពិតជាមានហេតុ ហើយបញ្ជាឲ្យហៅជនទាំងនោះមក ត្រាស់សួរថា នែបាទាំងឡាយ ពួកអ្នកអាស្រ័យយើង មិនបានអ្វីឬ ជនទាំងនោះពោលថា បពិត្រព្រះអង្គ តើមានរឿងអ្វី ព្រះរាជាត្រាស់ថា បានឮថា ពួកអ្នកជាចោរ ត្រាច់ទៅក្នុងព្រៃដោយការចងគ្នាជាពួក ជនទាំងនោះពោលថា បពិត្រព្រះអង្គ អ្នកណាក្រាបទូលយ៉ាងនោះ ព្រះរាជាត្រាស់ថា មេស្រុក ជនទាំងនោះពោលថា បពិត្រព្រះអង្គ ពួកទូលបង្គំមិនមែនជាចោរ តែពួកទូលបង្គំជម្រះផ្លូវទៅកាន់ស្ថានសួគ៌ រៀងៗ ខ្លួន ទើបធ្វើកម្មនេះ និងកម្មនេះ ។ មេស្រុកដឹកនាំពួកទូលបង្គំក្នុងការធ្វើអកុសល បំណងឲ្យពួកខ្ញុំព្រះអង្គ ដែលមិនធ្វើតាមពាក្យរបស់ខ្លួនឲ្យវិនាស ក្រោធហើយ ទើបក្រាបទូលយ៉ាងនោះ ។

លំដាប់នោះ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ជនទាំងនោះ ជាបុគ្គលដល់នូវសោមនស្សត្រាស់ថា បាទាំងឡាយ សត្វតិរច្ឆាននេះគង់ស្គាល់គុណរបស់ពួកអ្នក យើងជាមនុស្សក៏មិនអាចស្គាល់ ចូរអ្នកអត់ទោសដល់យើងចុះ កាលត្រាស់យ៉ាងនោះហើយ បានព្រះរាជទានមេស្រុក មួយអន្លើដោយបុត្រ និងភរិយា ឲ្យធ្វើជាទាសៈ ដីរនោះឲ្យជាពាហនៈសម្រាប់ជិះ និងស្រុកនោះឲ្យជាគ្រឿងប្រើប្រាស់តាមសប្បាយ ដល់ជនទាំងនោះ ។

ជនទាំងនោះពោលថា ពួកយើងឃើញអានិសង្សនៃបុណ្យក្នុងបច្ចុប្បន្ន

នេះឯង ក៏មានចិត្តផូរផង់ដោយប្រមាណក្រៃលែង ផ្លាស់វេណាគ្នាជិះដីរនោះ ទៅប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងគួរធ្វើបុណ្យឲ្យក្រៃលែងឡើង សាកសួរគ្នាថា ពួកយើងនឹងធ្វើអ្វីហ្ន៎ ក៏ស្រុះស្រួលគ្នាថា នឹងសាងសាលាជាទីសម្រាករបស់មហាជនឲ្យមាំទាំ ក្នុងផ្លូវធំដែលមានមុំ ៤ ទើបពួកគេបញ្ជាឲ្យរកជាងឈើមកហើយ ចាប់ផ្តើមធ្វើសាលា តែព្រោះប្រាសចាកការពេញចិត្តក្នុងមាតុគ្រាម ទើបមិនបានឲ្យចំណែកបុណ្យ ក្នុងសាលានោះដល់មាតុគ្រាមទាំងឡាយ ។

ក្នុងផ្ទះរបស់មឃមាណពមានស្រី ៤ នាក់ គឺនាងសុនន្ទា សុចិត្រា សុធម្មា និងសុជាតា ។ បណ្តាស្រី ៤ នាក់នោះ នាងសុធម្មារួមគំនិតនឹងជាងឈើពោលថា នែបង សូមធ្វើខ្ញុំឲ្យជាធំក្នុងសាលានេះចុះ ដូច្នេះហើយ បានឲ្យថ្លៃឈ្នួលដល់មេជាង ជាងឈើទទួលពាក្យថា បាន ហើយហាលឈើសម្រាប់ធ្វើហោជាង ឲ្យស្ងួតមុនវត្ថុដទៃ ហើយចាំងធ្វើហោជាងឲ្យសម្រេច ហើយឆ្លាក់អក្សរថា សាលាសុធម្មា ដូច្នេះហើយ យកសំពត់រុំរក្សាទុក ។

កាលជាងឈើសាងសាលាស្រេចហើយ ក្នុងថ្ងៃលើកហោជាង ទើបពោលនឹងជន ៣៣ នាក់នោះថា នែអ្នក ខ្ញុំនឹកកិច្ចដែលគួរធ្វើម្យ៉ាងមិនបាន ជនទាំងនោះពោលថា នែអ្នក កិច្ចនោះឈ្មោះអ្វី មេជាងពោលថា គឺហោជាង ។ ពួកជនទាំងនោះពោលថា ណើ្ហយចុះ ពួកយើងនឹងនាំហោជាងនោះមកឯង មេជាងពោលថា ខ្ញុំមិនអាចធ្វើដោយឈើដែលកាត់ឥឡូវនេះបាន ត្រូវបានឈើហោជាងដែលគេកាត់ ចាំងហើយរក្សាទុកអំពីមុននោះឯង ទើបប្រើបាន ជនទាំងនោះពោលថា ឥឡូវនេះ ពួកយើងគួរធ្វើដូចម្តេច ជាងឈើពោលថា បើ

ក្នុងផ្ទះរបស់បុគ្គលណា មានហោជាងដែលធ្វើទុកលក់ ដែលគេធ្វើសម្រេចហើយ រក្សាទុកសោត គួរស្វែងរកហោជាងនោះ ។

ពួកជនទាំងនោះស្វែងរក ឃើញក្នុងផ្ទះរបស់នាងសុធម្មា ហើយឲ្យទ្រព្យមួយពាន់ ក៏មិនបានដោយទ្រព្យដែលជាតម្លៃ កាលនាងសុធម្មាពោលថា បើពួកអ្នកធ្វើខ្ញុំឲ្យមានចំណែកបុណ្យ ក្នុងសាលាផងសោតខ្ញុំនឹងឲ្យ ជនទាំងនោះឆ្លើយថា ពួកខ្ញុំមិនឲ្យចំណែកបុណ្យដល់ពួកមាតុគ្រាម ។ លំដាប់នោះ ជាងឈើពោលនឹងមនុស្សទាំងនោះថា នែអ្នក ពួកអ្នកនិយាយអ្វី វៀរតែព្រហ្មលោកទីដទៃឈ្មោះថាមិនមានមាតុគ្រាម រមែងមិនមាន ពួកអ្នកចូរទទួលយកហោជាងចុះ កាលបើដូច្នោះ ការងាររបស់ពួកយើងក៏នឹងដល់នូវការសម្រេច ។ ពួកជនទាំងនោះទទួលថា សាធុ ហើយទទួលយកហោជាងនោះ សាងសាលាឲ្យសម្រេចហើយ ចែកជា ៣ ចំណែក គឺក្នុងចំណែកមួយ សាងជាទីសម្រាប់នៅរបស់ពួកឥស្សរជន ចំណែកមួយសម្រាប់បុគ្គលក្រីក្រ ចំណែកមួយសម្រាប់អ្នកមានជំងឺ ។

ជន ៣៣ នាក់ ឲ្យក្រាលក្តារ ៣៣ បន្ទះ ហើយឲ្យសញ្ញាដល់ដំរីថា បុគ្គលជាភ្ញៀវមកអង្គុយលើបន្ទះក្តារ ដែលបុគ្គលណាក្រាល ចូរនាំភ្ញៀវនោះទៅឲ្យសម្រាកនៅត្រង់ផ្ទះរបស់បុគ្គលនោះ ដែលជាម្ចាស់របស់បន្ទះក្តារនោះឯង ។ ការប្រេបាច់ជើង ការប្រេបាច់ខ្នង របស់គួរទំពា គួរបរិភោគ ទីដេកគ្រប់យ៉ាង និងជានាទីរបស់បុគ្គលនោះ ដែលជាម្ចាស់របស់បន្ទះក្តារនោះឯង ។

ដំរីទទួលបុគ្គលដែលមកហើយ នាំទៅកាន់ផ្ទះរបស់ម្ចាស់បន្ទះក្តារនោះ

ឯង ។ ក្នុងថ្ងៃនោះម្ចាស់របស់បន្ទះក្តារនោះ រមែងធ្វើកិច្ចដែលគួរធ្វើដល់បុគ្គលដែលដឹកនាំទៅនោះ ។ មឃមាណព ដាំដើមរលួសផ្កាមួយដើមទុកមិនឆ្ងាយអំពីសាលា ហើយក្រាលបន្ទះថ្មត្រង់គល់រលួសផ្កានោះ ។ ពួកជនដែលចូលទៅហើយកាន់សាលា សម្លឹងមើលហោជាង អានអក្សរហើយ រមែងប្រាប់គ្នាថា សាលាសុធម្មា ឈ្មោះរបស់ជន ៣៣ នាក់មិនប្រាកដ ។ នាងសុនន្ទាគិតថា ជនទាំងនេះកាលធ្វើសាលា ធ្វើពួកយើងមិនឲ្យមានចំណែកបុណ្យ តែនាងសុធម្មា ក៏ធ្វើហោជាងរួមចំណែកទាល់តែបាន ព្រោះភាពជាបុគ្គលឈ្លាសអញក៏គួរធ្វើអ្វីមួយ តើនឹងធ្វើអ្វីហ្ន៎ ក្នុងវេលានោះ នាងក៏គិតដូច្នេះថា បុគ្គលដែលមកកាន់សាលា គួរបានទឹកផឹក និងទឹកងូត ។ អញនឹងឲ្យជីកស្រះបោក្ខ-រណី នាងឲ្យគេជីកស្រះបោក្ខរណីហើយ នាងសុចិត្រាគិតថា នាងសុធម្មាបានឲ្យហោជាង នាងសុនន្ទាបានឲ្យស្រះបោក្ខរណី អញគួរធ្វើអ្វីមួយ តើនឹងធ្វើអ្វីហ្ន៎ ពេលនោះ នាងដូច្នេះថា ក្នុងកាលដែលពួកជនមកកាន់សាលា ផឹកទឹក ងូតទឹកហើយទៅ គួរប្រដាប់កម្រងផ្កា ហើយទៅ អញនឹងធ្វើសួនផ្កា ។ នាងបានឲ្យគេសាងសួនផ្កា ដែលគួរជាទីមនោរម្យហើយ ។ បុគ្គលដែលហាមាត់ថា ក្នុងសួននោះមិនមានដើមឈើ ដែលចេញផ្កា ចេញផ្លែ ឈ្មោះនោះដូច្នេះ មិនមាន ។

ចំណែកនាងសុជាតាគិតថា អញជាកូនរបស់អាំនៃមឃមាណពផង ជាបាទបរិចារិកាផង កម្មដែលមឃមាណពនោះធ្វើហើយ ក៏ឈ្មោះថា អញធ្វើដូចគ្នា កម្មដែលអញធ្វើហើយ ក៏ឈ្មោះថាមឃមាណពនោះធ្វើដូចគ្នា ដូច្នេះហើយ

មិនបានធ្វើអ្វីមួយ រវល់តែតែងខ្លួនប៉ុណ្ណោះ ឲ្យកាលកន្លងទៅហើយ ។

ចំណែកមឃមាណព បំពេញវត្តបទទាំង ៧ គឺទំនុកបម្រុងមាតាបិតា ១ ប្រព្រឹត្តឱនលំទោនចំពោះបុគ្គលចម្រើនក្នុងត្រកូល ១ ពោលពាក្យសច្ចៈ ១ មិនពោលពាក្យគ្រោតគ្រាត ១ មិនពោលពាក្យញុះញង់ ១ កម្ចាត់សេចក្តីកំណាញ់ ១ មិនក្រោធ ១ ដល់នូវភាពជាបុគ្គលគួរសរសើរយ៉ាងនេះថា

ពួកទេវតានៅស្ថានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា អ្នកកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល មានវាចាល្អិតទន់ និយាយតែពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបក្នុងការលះបង់សេចក្តីកំណាញ់ មានសម្តីទៀងទាត់ ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯង ថាជាសប្បុរស ។

ក្នុងកាលអស់ជីវិត បានកើតជាសក្កទេវរាជក្នុងស្ថានតាវត្តិង្ស ។ សម្លាញ់របស់ជនទាំងនោះ ក៏កើតក្នុងទីនោះដូចគ្នា ។ ជាងឈើកើតជាវិស្សកម្មទេវបុត្រ ។

ក្នុងកាលនោះ ពួកអសុរនៅក្នុងភពតាវត្តិង្ស អសុរទាំងនោះគិតថា ទេវបុត្រថ្មីៗ កើតហើយ ទើបត្រៀមពិធីលៀងដោយទឹកទិព្វ ។ សក្កទេវរាជទ្រង់ឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គ បំណងមិនឲ្យបុគ្គលមួយណាផឹក ពួកអសុរផឹកទឹកទិព្វស្រវឹងគ្រប់គ្នាហើយ ។ សក្កទេវរាជទ្រង់ត្រិះរិះថា អាត្មាអញនឹងត្រូវការអ្វីដោយភាពជាស្តេច ដែលទូទៅដោយជនទាំងនេះ ទ្រង់ឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គហើយ នាំគ្នាចាប់អសុរទាំងនោះត្រង់ជើងទាំងពីរ

គ្រវែងធ្លាក់ទៅក្នុងមហាសមុទ្រ ។ អសុរទាំងនោះ មានក្បាលសំយុងចុះទៅក្នុងសមុទ្រហើយ ។ ខណៈនោះ អសុរវិមានបានកើតត្រង់ផ្ទៃខាងក្រោយនៃជើងភ្នំសិនេរុ ដោយអានុភាពនៃបុណ្យរបស់ពួកគេ ។ ឈើឈ្មោះចិត្តបាដលិ គឺដើមប្រទៀង ក៏កើតហើយ ។

កាលសង្គ្រាមទេវតា និងអសុរប្រកៀកគ្នា កាលពួកអសុរបរាជ័យហើយ ឈ្មោះថា ទេវនគរក្នុងជាន់តាវត្តិង្ស ប្រមាណមួយម៉ឺនយោជន៍កើតឡើងហើយ ។ ក្នុងរវាងទ្វារទិសខាងកើត និងទិសខាងលិចនៃព្រះនគរនោះ មានផ្ទៃប្រមាណមួយម៉ឺនយោជន៍ ចន្លោះទ្វារទិសខាងត្បូង និងទិសខាងជើងក៏ស្មើគ្នា ។ ម្យ៉ាងទៀត ព្រះនគរនោះប្រកបដោយទ្វារមួយពាន់ ប្រដាប់ដោយឧទ្យាន និងស្រះបោក្ខរណី ។ ប្រាសាទឈ្មោះថា វេជយន្ត កម្ពស់ ៧០០ យោជន៍ ប្រដាប់ដោយកែវ ៧ ប្រការ និងទង់ទាំងឡាយកម្ពស់ ៣០០ យោជន៍ ផុសឡើង ដោយផលនៃសាលាត្រង់កណ្តាលព្រះនគរនោះ ។ មានដងជាមាស មានទង់ជាកែវមណី ត្រង់ដងជាកែវមណី មានទង់ជាមាស ត្រង់ដងជាកែវប្រពាល មានទង់ជាកែវមុក្តា ត្រង់ដងជាកែវមុក្តា មានទង់ជាកែវប្រពាល ត្រង់ដងជាកែវ ៧ ប្រការ មានទង់ជាកែវ ៧ ប្រការ ទង់ដែលតាំងនៅកណ្តាល មានកម្ពស់ ៣០០ យោជន៍ ប្រាសាទកម្ពស់មួយពាន់យោជន៍ សម្រេចហើយដោយកែវ ៧ ប្រការ កើតហើយដោយផលនៃសាលា ដោយប្រការដូច្នេះ ។

ដើមបារិច្ឆត្តកៈ មានបរិមណ្ឌលផ្សាយទៅ ៣០០ យោជន៍ ដោយជុំវិញ

កើតឡើងដោយផលនៃការដាំដើមរលួសផ្អុង ។ បណ្ឌុកម្ពលសិលា មានពណ៌ដូចផ្កាជយព្រឹក្ស មានពណ៌ស្រគាំ និងពណ៌ឈូករោយ ដោយបណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្ពស់ ១៥ យោជន៍ ពាក់កណ្ដាលនៃព្រះវរកាយ លិចចុះក្នុងវេលាអង្គុយ ប៉ោងឡើងក្នុងវេលាក្រោកឡើង កើតឡើងត្រង់គល់បារិច្ឆត្តកៈ ដោយផលនៃការក្រាលបន្ទះថ្ម ។

ចំណែកដំរី កើតជាទេវបុត្រឈ្មោះឯរាវ័ណ ពិតហើយ សត្វតិរច្ឆានទាំងឡាយ រមែងមិនមានក្នុងទេវលោក ព្រោះដូច្នោះ ក្នុងវេលាសក្កទេវរាជទ្រង់ចេញដើម្បីប្រពាតព្រះឧទ្យាន ទើបទេវបុត្រនោះកាឡាខ្លួនជាដំរី ឈ្មោះឯរាវ័ណ កម្ពស់ប្រមាណ ១៥០ យោជន៍ ។ ហត្ថីទេវបុត្រនោះ និម្មិតពោង ៣៣ ដើម្បីជាប្រយោជន៍ដល់ជន ៣៣ នាក់ ក្នុងពោងទាំងនោះ ពោងនីមួយៗ វង្វង់ប្រមាណ ៣ គាវុត បណ្ដោយប្រមាណកន្លះយោជន៍ ហត្ថីទេវបុត្រនោះ និម្មិតពោងឈ្មោះសុទស្សនៈ ប្រមាណ ៣០ យោជន៍ ត្រង់កណ្ដាលពោងទាំងនោះ ដើម្បីជាប្រយោជន៍ដល់សក្កទេវរាជ ខាងលើនៃពោងនោះមានមណ្ឌបកែវប្រមាណ ១២ យោជន៍ មានទង់រចនាដោយកែវ ៧ ប្រការ កម្ពស់មួយយោជន៍ តាំងឡើងក្នុងចន្លោះៗ ក្នុងមណ្ឌបកែវនោះ ។ បណ្ដាញកណ្ដឹង ដែលត្រូវខ្យល់ស្រទន់បក់ហើយ មានសំឡេងដូចតន្ត្រីទិព្វ អមដោយសំឡេងតន្ត្រីមានអង្គ ៥ សំយុងចុះត្រង់ជាយដោយជុំវិញ ។ បល្ល័ង្កកែវមណីប្រមាណមួយយោជន៍ជាព្រះទែន ដែលគេរៀបចំល្អហើយ ដើម្បីសក្កទេវរាជ ត្រង់កណ្ដាលមណ្ឌប សក្កៈរមែងគង់លើបល្ល័ង្កនោះ ។ ទេវបុត្រ

៣៣ អង្គ អង្គុយលើរតនបល្ល័ង្ក ក្នុងពោងរបស់ខ្លួន ។ បណ្ដាពោង ៣៣ ពោងនីមួយៗ ហត្ថីទេវបុត្រនោះនិម្មិតក្ពុក ៧ ក្នុងក្ពុកទាំងនោះ ក្ពុកនីមួយៗ ប្រវែង ៥០ យោជន៍ ក្នុងក្ពុកនីមួយៗ មានស្រះបោក្ខរណី ៧ ក្នុងស្រះបោក្ខរណីមួយ មានគុម្ពឈូក ៧ គុម្ព ក្នុងគុម្ពនីមួយៗ មានផ្កា ៧ ក្នុងផ្កានីមួយៗ មានត្របក ៧ ត្របកនីមួយៗ មានទេពធីតារាំ ៧ អង្គ មហោស្រពរមែងមានលើក្ពុកដំរី ក្នុងទី ៥០ យោជន៍ ដោយជុំវិញយ៉ាងនេះឯង ។ សក្កទេវរាជសោយយសធំ ទ្រង់ត្រាច់ទៅ ដោយប្រការដូច្នេះ ។

នាងសុធម្មា លុះអស់អាយុហើយ បានទៅកើតក្នុងភពតាវត្តិង្សនោះដូចគ្នា ទេវសភាឈ្មោះសុធម្មាមានប្រមាណ ៥០០ យោជន៍ បានកើតហើយដល់នាង ។ បានឮថា ឈ្មោះថាទីដទៃដែលគួរត្រេកអរជាងនោះ រមែងមិនមានក្នុងអដ្ឋមីនៃខែ មានការស្ដាប់ធម៌ក្នុងទីនោះឯង ។ រហូតដល់ថ្ងៃនេះ ជនទាំងឡាយឃើញទីដែលគួរត្រេកអរណាមួយហើយ ក៏គង់ពោលថា ដូចទេវសភាឈ្មោះសុធម្មា ។

នាងសុនន្ទា អស់អាយុហើយ បានទៅកើតក្នុងភពតាវត្តិង្សនោះដូចគ្នា ស្រះបោក្ខរណីឈ្មោះសុនន្ទា មានប្រមាណ ៥០០ យោជន៍ កើតហើយដល់នាង ។

សូម្បីនាងសុចិត្រា អស់អាយុហើយ ក៏បានទៅកើតក្នុងភពតាវត្តិង្សនោះដូចគ្នា សួនឈ្មោះចិត្តលតា មានប្រមាណ ៥០០ យោជន៍ ដែលពួកទេវបុត្រនាំពួកទេវបុត្រដែលមានបុព្វនិមិត្តកើតហើយ ឲ្យវង្វេងត្រាច់ទៅ កើតហើយ

ដល់នាង ។

ចំណែកនាងសុជាតា អស់អាយុហើយ កើតជាកុកញីក្នុងញកភ្នំមួយកន្លែង សក្កទេវរាជទ្រង់ប្រមើលមើលបារិចារិការបស់ព្រះអង្គ ទ្រង់ជ្រាបថា នាងសុធម្មា កើតហើយក្នុងទីនេះដូចគ្នា ។ នាងសុនន្ទា និងនាងសុចិត្រាក៏យ៉ាងនោះ ទ្រង់ត្រិះរិះថា នាងសុជាតាកើតទីណាហ្ន៎ ឃើញនាងកើតក្នុងញកភ្នំនោះហើយ ទ្រង់ត្រិះរិះថា នាងសុជាតានេះល្ងង់ខ្លៅ មិនធ្វើបុណ្យណាមួយ ឥឡូវនេះកើតក្នុងកំណើតតិរច្ឆាន ឥឡូវនេះគួរអាត្មាអញ ឲ្យនាងធ្វើបុណ្យហើយនាំមកទីនេះ ដូច្នេះហើយ ទើបទ្រង់កាឡាអត្តភាពយាងទៅកាន់សម្នាក់របស់នាង ដោយភេទដែលគេមិនស្គាល់ត្រាស់សួរថា នាងត្រាច់ធ្វើអ្វីនៅទីនេះ កុកញីឆ្លើយថា នែអ្នក អ្នកគឺនរណា សក្កៈពោលថា ខ្ញុំឈ្មោះមឃៈជាប្តីរបស់នាង កុកពោលថា អ្នកកើតក្នុងទីណា សក្កៈពោលថា ខ្ញុំកើតក្នុងតាវត្តិង្សទេវលោក នាងដឹងទីកើតនៃស្រីជាសម្លាញ់របស់នាងហើយឬ កុកញីពោលថា មិនដឹងទេ សក្កៈពោលថា ស្រីទាំងនោះ កើតក្នុងសម្នាក់ខ្ញុំដូចគ្នា នាងនឹងសួរសុខទុក្ខស្រីសម្លាញ់របស់នាងឬទេ កុកញីពោលថា ខ្ញុំនឹងទៅទីនោះបានដូចម្តេច សក្កៈត្រាស់ថា ខ្ញុំនឹងនាំទៅក្នុងទីនោះ ដូច្នេះហើយ នាំទៅកាន់ទេវលោក លែងត្រង់មាត់ស្រះបោក្ខរណីឈ្មោះនន្ទា ត្រាស់ប្រាប់ដល់មហេសីទាំង ៣ ក្រៅអំពីនេះថា ពួកនាងនឹងមើលនាងសុជាតាសម្លាញ់របស់ពួកនាងឬទេ មហេសីពោលថា បពិត្រព្រះអង្គ នាងនៅទីណា សក្កទេវរាជពោលថា នៅត្រង់ច្រាំងស្រះបោក្ខរណី ឈ្មោះនន្ទា ។

ព្រះមហេសីទាំង ៣ នោះ យាងទៅទីនោះធ្វើការចំអកថា ឱ រូបរបស់នាង ឱផលនៃការតែងខ្លួន គ្រានេះអ្នកទាំងឡាយ ចូរមើលចំពុះ មើលស្មង មើលជើងរបស់នាង អត្តភាពរបស់នាងប្រហែលជាស្អាតពិត ដូច្នេះហើយ ក៏ជៀសចេញទៅ ។

សក្កទេវរាជ យាងទៅសម្នាក់របស់នាងទៀត ត្រាស់សួរថា នាងជួបសម្លាញ់ហើយឬ កាលនាងទូលថា ព្រះមហេសីទាំង ៣ នោះ ខ្ញុំម្ចាស់បានជួបហើយ គេនាំគ្នាចំអកខ្ញុំម្ចាស់ហើយក៏ទៅ សូមទ្រង់នាំខ្ញុំម្ចាស់ទៅត្រង់ញកភ្នំនោះវិញចុះ ដូច្នេះហើយ ទ្រង់នាំកុកញីនោះទៅកាន់ញកភ្នំវិញ លែងក្នុងទីនោះហើយ ត្រាស់សួរថា នាងឃើញសម្បត្តិរបស់ស្រីទាំង ៣ នោះហើយឬ កុកញីពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ឃើញហើយ សក្កទេវរាជពោលថា នាងក៏គួរធ្វើឧបាយដែលជាហេតុឲ្យកើតក្នុងទីនោះ ។ កុកញីពោលថា បពិត្រព្រះអង្គ ខ្ញុំនឹងធ្វើដូចម្តេច សក្កទេវរាជត្រាស់ថា នាងនឹងរក្សាឱវាទដែលខ្ញុំឲ្យបានទេ កុកញីពោលថា បពិត្រព្រះអង្គ រក្សាបាន ។

លំដាប់នោះ សក្កទេវរាជក៏ប្រទានសីល ៥ ដល់នាង ហើយត្រាស់ថា ចូរនាងជាបុគ្គលកុំប្រមាទ រក្សាចុះ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ចាប់ពីកាលនោះមក នាងត្រាច់រកស៊ីតែត្រីដែលស្លាប់ឯងប៉ុណ្ណោះ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ សក្កទេវរាជយាងទៅដើម្បីបំណងពិសោធចិត្តរបស់នាង ទើបកាឡាខ្លួនជាត្រីស្លាប់ ដេកផ្ងារត្រង់ឆ្នេរខ្សាច់ ។ កុកញីឃើញត្រីនោះហើយ បានពាំយកដោយសម្គាល់ថាជាត្រីស្លាប់ ក្នុងកាលនឹងលេប ត្រីក៏កម្រើក

កន្ទុយឡើង កុកញីដឹងថាត្រីរស់ ទើបលែងក្នុងទឹក សក្កទេវរាជទ្រង់បណ្ដោយឲ្យកាលកន្ទុងទៅបន្តិចហើយ ទើបទ្រង់ធ្វើជាដេកផ្ងារខាងមុខកុកទៀត កុកញីក៏ពាំទៀត ដោយសម្គាល់ថាត្រីស្លាប់ ក្នុងកាលនឹងលេប ឃើញត្រីកម្រើកកន្ទុយ ទើបលែងដោយដឹងថា ត្រីរស់ ។ សក្កទេវរាជទ្រង់សាកល្បងយ៉ាងនោះគ្រប់ ៣ ដងហើយត្រាស់ថា នាងរក្សាសីលបានល្អ ឲ្យកុកស្គាល់ព្រះអង្គហើយត្រាស់ថា ខ្ញុំមកដើម្បីប្រយោជន៍សាកល្បងនាង នាងរក្សាសីលបានល្អ កាលរក្សាបានយ៉ាងនោះមិនយូរប៉ុន្មាន ក៏នឹងកើតក្នុងសម្នាក់របស់ខ្ញុំពិត ចូរនាងជាបុគ្គលមិនប្រមាទចុះ ដូច្នេះហើយ ទ្រង់ចៀសចេញទៅ ។

ចាប់តាំងពីកាលនោះមក នាងបានត្រីដែលស្លាប់ឯងខ្លះ មិនបានខ្លះ កាលមិនបាន ដោយកាលកន្លងទៅ ២-៣ ថ្ងៃប៉ុណ្ណោះក៏ស្គាំងស្គម ធ្វើកាលកិរិយាហើយ កើតជាធីតារបស់នាយស្មូនឆ្នាំងក្នុងក្រុងពារាណសី ដោយផលនៃសីលនោះ ។

បន្ទាប់មក ក្នុងកាលដែលនាងមានអាយុ ១៥-១៦ ឆ្នាំ សក្កទេវរាជទ្រង់ពិចារណាថា នាងកើតទីណាហ្ន៎ បានឃើញហើយទ្រង់ព្រះតម្រិះថា ឥឡូវនេះ គួរអញទៅទីនោះ ដូច្នេះហើយ ទើបទ្រង់យកកែវ ៧ ប្រការដែលប្រាកដដោយពណ៌ដូចផ្លែល្ពៅ ដាក់ពេញរទេះតូច បរចូលទៅកាត់ក្រុងពារាណសីយាងទៅកាន់ថ្នល់ស្រែកប្រកាសថា អ្នកទាំងឡាយមកយកល្ពៅចុះ តែត្រាស់នឹងបុគ្គលដែលយកសណ្ដែកបាយ និងសណ្ដែករាជមាសជាដើមថា ខ្ញុំមិនឲ្យដោយតម្លៃ កាលទូលសួរថា អ្នកនឹងឲ្យដូចម្ដេច ត្រាស់ថា ខ្ញុំឲ្យដល់ស្ត្រីអ្នក

រក្សាសីល ពួកអ្នកក្រុងពោលថា នែអ្នក ឈ្មោះថា សីលដូចម្ដេច ពណ៌ខ្មៅ ឬពណ៌ខៀវជាដើម សក្កទេវរាជពោលថា ពួកអ្នកមិនស្គាល់សីល ថាដូចម្ដេច នឹងរក្សាសីលនោះបានយ៉ាងណា តែខ្ញុំនឹងឲ្យដល់ស្ត្រីអ្នករក្សាសីល ពួកអ្នកស្រុកពោលថា នែអ្នក កូនស្រីរបស់នាយស្មូនឆ្នាំងនោះត្រាច់ពោលថា ខ្ញុំរក្សាសីល ចូរឲ្យដល់ស្ត្រីនោះចុះ ។

សូម្បីធីតារបស់នាយស្មូនឆ្នាំងនោះ ក៏ទូលព្រះអង្គថា បើដូច្នោះ ក៏ឲ្យដល់ខ្ញុំចុះ សក្កទេវរាជពោលថា នាង គឺនរណា កូនស្រីនាយស្មូនឆ្នាំងពោលថា ខ្ញុំ គឺស្ត្រីមិនលះបង់សីល ៥ ។

សក្កទេវរាជពោលថា ល្ពៅទាំងនោះខ្ញុំក៏នាំមកឲ្យចំពោះនាង ។ សក្កទេវរាជទ្រង់បរយានតូចទៅកាន់ផ្ទះនាងហើយ ប្រទានទ្រព្យដែលទេវតាគប្បីឲ្យដោយពណ៌ដូចផ្លែល្ពៅ ធ្វើមិនឲ្យអ្នកដទៃលួចយកទៅបាន បង្ហាញខ្លួនព្រះអង្គឲ្យស្គាល់ ហើយត្រាស់ថា នេះទ្រព្យសម្រាប់ចិញ្ចឹមជីវិតរបស់នាង ចូរនាងរក្សាសីល ៥ កុំឲ្យដាច់ ហើយចៀសចេញទៅ ។

ចំណែកធីតានាយស្មូនឆ្នាំងនោះ ចុតិអំពីអត្តភាពនោះហើយ កើតក្នុងផ្ទះរបស់បុគ្គលដែលមានពៀរចំពោះសក្កទេវរាជ ជាធីតារបស់អសុរ ដែលជាប្រធានក្នុងភពអសុរ ព្រោះភាពដែលនាងរក្សាសីលល្អហើយពីរអត្តភាព ទើបនាងជាអ្នកមានរូបស្អាត មានពណ៌សម្បុរដូចមាស ប្រកបដោយរូបសិរីដែលមិនសាធារណៈ គឺមិនទូទៅដល់ស្រីទាំងពួង ។ ស្ដេចអសុរឈ្មោះថា វេបចិត្តិ ពោលនឹងបុគ្គលដែលមកហើយថា ពួកអ្នកមិនសមគួរដល់ធីតារបស់

ខ្ញុំ ហើយក៏មិនឲ្យធីតានោះដល់បុគ្គលណាមួយ គិតថា ធីតារបស់យើងនឹងជ្រើសរើសស្វាមីដែលសមគួរ ដល់ខ្លួនដោយខ្លួនឯង ដូច្នេះហើយ ទើបឲ្យពួកពលដែលជាអសុរប្រជុំគ្នា ហើយបានឲ្យកម្រងផ្កាក្នុងដៃរបស់ធីតានោះ ដោយប្រាប់ថា ចូរនាងទទួលបុគ្គលសមគួរជាប្ដីដល់នាង ។

ក្នុងខណៈនោះ សក្កទេវរាជទ្រង់ប្រមើលមើលទីដែលនាងកើត ជ្រាបព្រឹត្តិហេតុនោះហើយ ទ្រង់ត្រិះរិះថា ឥឡូវនេះសមគួរដែលអញនឹងនាំយកនាងមក ដូច្នេះហើយ ទ្រង់បាននិម្មិតភេទជាអសុរចាស់ ទៅឈរខាងចុងបរិស័ទ ។ នាងអសុរកញ្ញានោះ កាលសម្លឹងមើលឆ្វេងស្ដាំ លុះឃើញសក្កទេវរាជនោះ ក៏ជាអ្នកមានហឫទ័យស្រឡាញ់កើតឡើង ដោយអំណាចបុព្វេសន្និវាសគ្របសង្កត់ហើយដូចអន្លង់ទឹកធំ ក៏ដាក់ចិត្តថា នុ៎ះប្ដីរបស់អញ ទើបបោះកម្រងផ្កាទៅខាងលើសក្កទេវរាជនោះ ពួកអសុរទឹកខ្មាសថា ព្រះរាជារបស់ពួកយើងមិនបានបុគ្គលដែលសមគួរ ដល់ព្រះធីតាអស់កាលប្រមាណប៉ុណ្ណោះ ឥឡូវនេះបានហើយ បុគ្គលដែលចាស់ជាងតានេះឯង សមគួរដល់ធីតារបស់ទ្រង់ ដូច្នេះហើយ ទើបចៀសចេញទៅ ។

ចំណែកសក្កទេវរាជ ទ្រង់ចាប់អសុរកញ្ញានោះត្រង់ដៃហើយ ទ្រង់ប្រកាសថា យើងជាសក្កទេវរាជ ហើយទ្រង់ហោះទៅកាន់អាកាស ។ ពួកអសុរដឹងថា ពួកយើងត្រូវសក្កទេវរាជបោកប្រាសហើយ ទើបនាំគ្នាដេញតាមសក្កទេវរាជនោះទៅ ទេវបុត្រដែលជាសារថី ឈ្មោះមាតលិនាំវេជយន្តរថមកបញ្ឈរក្នុងរវាងផ្លូវ ។ សក្កទេវរាជទ្រង់បីនាងឡើងក្នុងរថនោះហើយ បែរព្រះ

កក្រ្កទៅកាន់ព្រះនគរ យានទៅហើយ ។ ក្នុងកាលដែលសក្កទេវរាជនោះ យានដល់សិម្ពលិវ័ន កូនគ្រុឌបានឮសំឡេងរថ ភិតភ័យស្រែកយំហើយ ។ សក្កទេវរាជ ទ្រង់បានស្តាប់សំឡេងកូនគ្រុឌទាំងនោះហើយ ត្រាស់សួរមាតលិថា នុ៎ះសំឡេងសត្វអ្វីស្រែក មាតលិទូលថា បពិត្រព្រះអង្គ នុ៎ះជាសំឡេងកូនគ្រុឌ សក្កទេវរាជពោលថា ព្រោះហេតុអ្វី ទើបសត្វនោះយំ មាតលិពោលថា ព្រោះបានឮសំឡេងរថហើយខ្លាចស្លាប់ សក្កទេវរាជត្រាស់ថា អាស្រ័យយើងម្នាក់ឯង បក្សីប្រមាណប៉ុណ្ណេះ ត្រូវសម្ពុះរបស់រថឲ្យលំបាកហើយ សត្វទាំងនេះ កុំបីវិនាសឡើយ ចូរអ្នកបររថត្រឡប់ចុះ ។ មាតលិ-ទេវបុត្រនោះឲ្យសញ្ញាដល់សេះសន្ធពមួយពាន់ ដោយខ្សែតីត្រឡប់រថហើយ ។ ពួកអសុរឃើញកិរិយានោះ គិតថា សក្កទេវរាជគេចទៅតាំងអំពីអសុរបុរីឥឡូវនេះ ត្រឡប់រថហើយ លោកនឹងបានអ្នកជំនួយដោយពិត ទើបត្រឡប់ចូលទៅកាន់អសុរបុរី តាមផ្លូវដែលមកហើយនោះឯង មិនអើតសីសៈឡើងទៀត ។

ចំណែកសក្កទេវរាជ ទ្រង់នាំនាងអសុរកញ្ញា ឈ្មោះសុជាតាទៅកាន់ទេវនគរហើយ ទ្រង់ស្ថាបនាក្នុងតំណែងជាប្រធាននៃស្រីទេពអប្សរពីរកោដិកន្លះ ។ នាងទូលសូមពរនឹងសក្កទេវរាជថា បពិត្រមហារាជ មាតាបិតាឬបងប្រុស បងស្រីរបស់ខ្ញុំម្ចាស់ក្នុងទេវលោកនេះមិនមាន ទ្រង់ទៅទីណាមួយ គប្បីនាំខ្ញុំម្ចាស់ទៅទីទាំងនោះ សក្កទេវរាជបានប្រទានបេ្តជ្ញាដល់នាងថា សាធុ ។

តាំងអំពីកាលនោះមក កាលផ្កាចិត្តបាដលិរីក ពួកអសុរបំណាងនឹងច្បាំង

ជាមួយសក្កទេវរាជ ឡើងមកដើម្បីបំណាំងនឹងច្បាំង ដោយសម្គាល់ថាជាកាល ដែលផ្កាបារិច្ឆត្តកទិព្វរបស់ពួកយើងរីក សក្កទេវរាជបានប្រទានការរក្សាដល់ពួកនាគខាងក្នុងបាតសមុទ្រ បន្ទាប់អំពីនោះពួកគ្រុឌ បន្ទាប់អំពីនោះពួកកុម្ភណ្ឌ បន្ទាប់អំពីនោះពួកយក្ខ បន្ទាប់អំពីនោះពួកចាតុម្មហារាជ ចំណែកជាន់លើបង្អស់ ទ្រង់ប្រតិស្ឋានរូបឥន្ទសិប្បនិមិត្ត ដែលមានវជិរាវុធក្នុងដៃ ត្រង់ទ្វារព្រះនគរ ។ ពួកអសុរ សូម្បីឈ្នះពួកនាគជាដើមហើយ ឃើញរូបឥន្ទសិប្បនិមិត្តអំពីចម្ងាយ រមែងគេចទៅដោយយល់ថា សក្កទេវរាជយាងមកហើយ ។

ព្រះសាស្តាត្រាស់ថា មហាលិ មឃមាណពបដិបត្តិអប្បមាទបដិបទាយ៉ាងនេះ មឃមាណពនោះមិនប្រមាទយ៉ាងនេះ ទើបដល់នូវភាពជាធំបែបនេះ ទ្រង់សោយរាជ្យក្នុងទេវលោកទាំងពីរ ឈ្មោះថា ការមិនប្រមាទនោះ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ព្រោះថា ការសម្រេចគុណវិសេសដែលជាលោកិយ និងលោកុត្តរទាំងអស់ រមែងមានព្រោះអាស្រ័យសេចក្តីមិនប្រមាទ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាងទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវសេចក្តីមិនប្រមាទ ត្មះតិះដៀលនូវសេចក្តីប្រមាទ សព្វៗ កាល ។

# សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អប្បមាទេន** គឺព្រោះការមិនប្រមាទ ដែលធ្វើទុកតាំងអំពីដើម ក្ការផ្លូវ ភូមិ ប្រទេសក្នុងអចលគ្រាម ។

បទថា **មឃវា** ជាដើម សេចក្ដីថា មឃមាណពដែលប្រាកដឈ្មោះថា មឃវៈ ក្នុងឥឡូវនេះ ឈ្មោះថា ដល់នូវភាពជាបុគ្គលប្រសើរជាងទេវតាទាំងឡាយ ព្រោះភាពជាព្រះរាជានៃទេវលោកទាំងពីរ ។

បទថា **បសំសន្តិ** សេចក្ដីថា បណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម រមែងសរសើរសេចក្ដីមិនប្រមាទតែម្យ៉ាង ។ សួរថា ព្រោះហេតុអ្វី វិសជ្ជនាថា ព្រោះសេចក្ដីមិនប្រមាទជាហេតុឲ្យបានគុណវិសេស ដែលជាលោកិយ និងលោកុត្តរទាំងអស់ ។

បាទព្រះគាថាថា **បមាទោ គរហិតោ សទា** សេចក្ដីថា ចំណែកការប្រមាទដែលព្រះអរិយៈទាំងនោះតិះដៀល គឺនិន្ទាហើយជានិច្ច ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការប្រមាទជាឫសគល់នៃវិបត្តិគ្រប់យ៉ាង ។ ពិតមែន ភាពជាបុគ្គលមានជោគអាក្រក់ក្នុងមនុស្សគ្តី ចូលដល់អបាយគ្តី សុទ្ធតែមានសេចក្ដីប្រមាទជាមូលទាំងអស់ ដូច្នេះ ។

ក្នុងវេលាចប់គាថា ស្ដេចលិច្ឆវី ព្រះនាមថាមហាលិ ទ្រង់តាំងនៅក្នុងសោតាបត្តិផលហើយ សូម្បីបរិស័ទដែលប្រជុំគ្នាជាច្រើន ក៏បានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ដូច្នេះឯង ៕

**រឿងសក្កទេវរាជ ចប់**

# រឿង អញ្ញតរភិក្ខុ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុរូបណាមួយ ត្រាស់ព្រះធម្មទេសនានេះថា **អប្បមាទរតោ ភិក្ខុ** ជាដើម ។

បានឮមកថា ភិក្ខុរូបនោះញុំាងព្រះសាស្ដាឲ្យប្រាប់ហើយនូវកម្មដ្ឋាន អំពីភាពជាព្រះអរហន្ត ចូលព្រៃបំពេញព្យាយាម ក៏មិនអាចសម្រេចអរហត្តបាន លោកគិតថា អញនឹងទៅទូលព្រះសាស្ដាឲ្យត្រាស់ប្រាប់កម្មដ្ឋាន ឲ្យវិសេសក្រៃលែងឡើង ដូច្នេះហើយ ចេញអំពីព្រៃនោះ កំពុងនិមន្តមកកាន់សម្នាក់ព្រះសាស្ដា ឃើញភ្លើងព្រៃតាំងឡើងជាច្រើនក្នុងវាងផ្លូវ ប្រញាប់ប្រញាល់ឡើងលើភ្នំមួយ អង្គុយមើលភ្លើងដែលកំពុងឆេះ កាន់យកជាអារម្មណ៍ថា ភ្លើងនេះ ដុតនូវពូជទាំងឡាយ ច្រើន និងតិច យ៉ាងណា សូម្បីភ្លើង គឺអរិយ-មគ្គញ្ញាណ ក៏នឹងដុតនូវសំយោជនៈទាំងឡាយ ច្រើន និងតិចទៅក៏ដូច្នោះ ។

ព្រះសាស្ដា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបវារចិត្តរបស់លោកហើយ ត្រាស់ថា ម្នាលភិក្ខុយ៉ាងនោះឯង សំយោជនៈទាំងឡាយល្អិតនិងគ្រោតគ្រាត ដែលកើតខាងក្នុងនៃសត្វទាំងនេះ ដូចពូជច្រើនខ្លះ តិចខ្លះ ដូច្នោះ ការដុតសំយោជនៈទាំងនោះដោយភ្លើង គឺញាណហើយ ធ្វើឲ្យជារបស់មិនគួរកើតទៀត ដូច្នេះហើយ ទ្រង់បញ្ចេញព្រះរស្មីប្រាកដបីដូចប្រថាប់គង់ក្នុងទីចំពោះមុខរបស់ភិក្ខុនោះ ត្រាស់គាថានេះថា

**អប្បមាទរតោ ភិក្ខុ    បមាទេ ភយទស្សិ វា**
**សញ្ញោជនំ អណុំ ថូលំ    ឌហំ អគ្គីវ គច្ឆតិ ។**

ភិក្ខុអ្នកត្រេកអរ ក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុង
សេចក្តីប្រមាទ តែងដុតបោលនូវសំយោជនៈ ទាំងតូចទាំងធំ
ដូចភ្លើងឆេះ ( រាលនូវកម្មេច ទាំងតូចទាំងធំ ) ដូច្នោះឯង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមាទរតោ** សេចក្តីថា ត្រេកអរ គឺអភិរម្យហើយក្នុងសេចក្តីមិនប្រមាទ បានដល់ ញុំាំងកាលឲ្យកន្លងទៅដោយសេចក្តីមិនប្រមាទ ។

បាទព្រះគាថាថា **បមាទេ ភយទស្សិ វា** សេចក្តីថា បុគ្គលឃើញភ័យក្នុងសេចក្តីប្រមាទ មានការចូលដល់នរកជាដើម ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកឃើញនូវសេចក្តីប្រមាទ ដោយភាពជាភ័យព្រោះសេចក្តីប្រមាទនោះ ជាឫសគល់នៃការកើតឡើងទាំងនោះ ។

បទថា **សញ្ញោជនំ** សេចក្តីថា សំយោជនៈ ១០ យ៉ាង ជាគ្រឿងប្រកបគ្រឿងចងពួកសត្វក្នុងវដ្តទុក្ខ អាចញុំាំងសត្វឲ្យលិចចុះក្នុងវដ្តៈបាន ។

បទថា **អណុំ ថូលំ** គឺតូចនិង ធំ ។

បាទព្រះគាថាថា **ឌហំ អគ្គីវ គច្ឆតិ** សេចក្តីថា ភិក្ខុនោះត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ រមែងដុតសំយោជនៈនោះដោយភ្លើង គឺញាណ ដែលខ្ទួនសម្រេចហើយ ដោយសេចក្តីមិនប្រមាទ គឺធ្វើឲ្យជារបស់មិនគួរកើតឡើងតទៅទៀត ដូចភ្លើងឆេះពូជ នៃភ្លើងច្រើន និងតិចនោះឯងទៅ ដូច្នោះ ។

ក្នុងកាលចប់គាថា ភិក្ខុនោះអង្គុយដូចមុននោះឯង ដុតសំយោជនៈទាំង

អស់ហើយ សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ មកតាមអាកាស សរសើរព្រះសរីរៈរបស់ព្រះតថាគត ដែលមានពណ៌ដូចមាសហើយ ថ្វាយបង្គំចៀសចេញទៅ ដូច្នេះឯង ។៙

**រឿង អញ្ញតរភិក្ខុ ចប់**

# រឿង ព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងនិគម

## លំនាំដើម

ព្រះសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ អ្នកមានប្រក្រតីនៅក្នុងនិគម ត្រាស់ធម្មទេសនានេះថា **អប្បមាទរតោ** ជាដើម ។

សេចក្តីពិស្តារថា កុលបុត្រម្នាក់កើតចម្រើនឡើងក្នុងស្រុក ដែលតាំងនៅក្នុងនិគមមួយកន្លែងមិនឆ្ងាយអំពីក្រុងសាវត្ថី បព្វជ្ជាហើយ បានឧបសម្បទាក្នុងសាសនារបស់ព្រះសាស្តាហើយ ប្រាកដឈ្មោះថា និគមតិស្សត្ថេរ ជាអ្នកប្រាថ្នាតិច សន្តោស ស្ងាត់ ប្រារព្ធព្យាយាម លោកត្រាច់បិណ្ឌបាតតែក្នុងផ្ទះរបស់ញាតិជានិច្ច ។ កាលមនុស្សទាំងឡាយ មានអនាថបិណ្ឌិកសេដ្ឋីជាដើម ធ្វើមហាទានក្តី កាលព្រះបាទបសេនទិកោសលទ្រង់បំពេញអសទិសទានក្តី ក៏មិនមកក្រុងសាវត្ថី ។

ទើបពួកភិក្ខុសន្ទនាគ្នាថា ព្រះនិគមតិស្សត្ថេរនេះ ក្រោកឡើងស្រួលបួល

ហើយ ក៏ប្រឡូកប្រឡំដោយញាតិ កាលជនទាំងឡាយ មានអនាថបិណ្ឌិកសេដ្ឋីជាដើមធ្វើមហាទានក្តី កាលព្រះបាទបសេនទិកោសល ទ្រង់បំពេញអសទិសទានក្តី លោកមិនមកឡើយ ដូច្នេះហើយ ទើបក្រាបទូលព្រះសាស្តា ។

ព្រះសាស្តា ត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ កាលលោកក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនមានការប្រឡូកប្រឡំដោយញាតិ ខ្ញុំព្រះអង្គអាស្រ័យពួកមនុស្សដែលជាញាតិទាំងនោះ រមែងបានអាហារល្មមទំពាបាន ខ្ញុំព្រះអង្គគិតថា កាលអាត្មាអញបានអាហារអាក្រក់ក្តី ប្រណីតក្តី ល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានហើយ ប្រយោជន៍អ្វីដោយការស្វែងរកអាហារទៀត ដូច្នេះហើយ ទើបមិនមក ឈ្មោះថា ការប្រឡូកប្រឡំដោយពួកញាតិ មិនមានដល់ខ្ញុំព្រះអង្គ តាមប្រក្រតីព្រះអង្គក៏ទ្រង់ជ្រាបអធ្យាស្រ័យរបស់លោក ទើបប្រទានសាធុការថា សាធុ សាធុ ភិក្ខុ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុ ការដែលអ្នកបានអាចារ្យដូចតថាគតហើយ បានជាអ្នកប្រាថ្នាតិចមិនអស្ចារ្យឡើយ ព្រោះថា ឈ្មោះថាភាពជាអ្នកប្រាថ្នាតិចនេះ ជាលំអានរបស់តថាគត ជាបវេណីរបស់តថាគត ដូច្នេះហើយ កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល សត្វសេកច្រើនពាន់ នៅក្នុងព្រៃល្វាមួយកន្លែង ជិតច្រាំងស្ទឹងគង្គា ក្នុងព្រៃហិមពាន្ត ។ បណ្តាសេកទាំងនោះ ស្តេចសេកមួយ កាលផ្លែឈើដែលខ្លួនអាស្រ័យអស់ហើយ ចឹកស៊ីដែលពន្លកស្ទឹក ឬសម្បកដែលនៅសល់ ផឹកទឹកក្នុងស្ទឹងគង្គា ជាសត្វមានសេចក្តីប្រាថ្នាតិចក្រៃលែង សន្តោស

មិនទៅក្នុងទីដទៃ ដោយគុណ គឺសេចក្ដីប្រាថ្នាតិច និងសន្ដោសរបស់ស្ដេចសេកនោះ សក្កពិភពញាប់ញ័រហើយ ។

សក្កទេវរាជ ទ្រង់ធ្វើអាវជ្ជនៈឃើញហេតុនោះហើយ ទ្រង់បណ្ដាលឲ្យដើមឈើនោះក្រៀមស្ងួត ដោយអានុភាពរបស់ខ្លួន ដើម្បីសាកល្បងស្ដេចសេកនោះ ដើមឈើបាក់ហើយ សល់នៅត្រឹមតែដង្គត់ប៉ុណ្ណោះ ជាប្រហោងតូចប្រហោងធំ គឺពុក ។ កាលខ្យល់បក់មក ក៏ឮសំឡេងដូចត្រូវបុគ្គលគោះ តាំងនៅហើយ ខ្ទូតទាំងឡាយហើរចេញអំពីប្រហោងរបស់ដើមឈើនោះ ។ ស្ដេចសេកចឹកស៊ីលម្អិតខ្ទូតទាំងនោះ ហើយផឹកទឹកក្នុងស្ទឹងគង្គា មិនទៅក្នុងទីដទៃមិនជ្រកខ្យល់ និងកម្ដៅថ្ងៃ ទំត្រង់ចុងដង្គត់ល្វានោះឯង ។ សក្កទេវរាជ ទ្រង់ជ្រាបភាពដែលស្ដេចសេកនោះ មានការប្រាថ្នាតិចក្រៃលែង ទ្រង់ត្រិះរិះថា អញនឹងឲ្យស្ដេចសេកនោះ ពោលគុណនៃមិត្តធម៌ ហើយឲ្យពរដល់បក្សីនោះ ធ្វើដើមល្វាឲ្យមានផ្លែមិនចេះអស់ហើយ ដូច្នេះហើយ និម្មិតព្រះកាយជាស្ដេចហង្សមួយ នាំនាងអសុរកញ្ញាឈ្មោះសុជាតាខាងមុខ យាងទៅព្រៃល្វានោះ ទំត្រង់មែកនៃដើមឈើមួយ ក្នុងទីមិនឆ្ងាយ កាលសន្ទនាជាមួយស្ដេចសេកនោះត្រាស់គាថានេះថា

ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ មានផ្លែជា
អនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះមានចិត្តរីករាយជានិច្ច
តែនឹងដង្គត់ឈើពុកស្ងួត ។

សុវជាតកទាំងអស់ បណ្ឌិតគប្បីឲ្យពិស្ដារតាមន័យ ដែលពោលមក

ហើយ ក្នុងនវកនិបាតនោះឯង តែការកើតឡើងនៃរឿងប៉ុណ្ណោះ ក្នុងនវកនិបាត និងក្នុងទីនេះផ្សេងគ្នា ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា សក្កទេវរាជក្នុងកាលនោះ បានជាអានន្ទ ស្តេចសេកបានជាតថាគត ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថាភាពជាបុគ្គលមានការប្រាថ្នាតិច នេះជាបែបផែន ជាបវេណីរបស់តថាគត ការដែលតិស្សៈអ្នកមានប្រក្រតីនៅក្នុងនិគម បុត្ររបស់តថាគតបានអាចារ្យដូចតថាគតហើយ ជាអ្នកមានការប្រាថ្នាតិច មិនគួរអស្ចារ្យឡើយ ធម្មតាភិក្ខុគប្បីជាអ្នកមានការប្រាថ្នាតិច ដូចតិស្សៈដែលមានប្រក្រតីនៅក្នុងនិគម ព្រោះថា ភិក្ខុបែបនេះ ជាអ្នកមិនគួរវិនាសចាកមគ្គ និងផល រមែងជាអ្នកនៅជិតព្រះនិព្វានដោយពិតនោះឯង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា**
**អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។**

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុង
សេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌
ឈ្មោះថា ស្ថិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **អភព្វោ បរិហានាយ** សេចក្តីថា ភិក្ខុបែបនោះ មិនគួរដើម្បីវិនាសចាកធម៌ គឺសមថៈ និងវិបស្សនា ឬចាកមគ្គ

*និងផល គឺវិនាសចាកគុណធម៌ដែលខ្លួនសម្រេចហើយ ក៏មិនមែន នឹងមិនសម្រេចគុណធម៌ដែលខ្លួនមិនបានសម្រេច ក៏មិនមែន ។*

*បាទព្រះគាថាថា* **និព្វានស្សេវ សន្តិកេ** *សេចក្តីថា តាំងនៅក្នុងទីជិតនៃកិលេសបរិនិព្វានក៏មាន អនុបាទាបរិនិព្វានក៏មាន ។*

*ក្នុងកាលចប់ព្រះគាថា ព្រះតិស្សត្ថេរ ជាអ្នកមានប្រក្រតីនៅក្នុងនិគម សម្រេចអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយហើយ ។ ជនដទៃជាច្រើនបានជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ទេសនាមានផលច្រើនដល់មហាជនដូច្នេះឯង ។៚*

**រឿង ព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងនិគម ចប់**

**អប្បមាទវគ្គទី ២ ចប់**

# ក្បាលទី ៣២

# សុត្តន្តបិដក បាលីប្រែ -៥២

## សន្ទឹកចង្អុលប្រាប់មាតិកា

| មាតិកា | លេខទំព័រ |
|---|---|
| ខុទ្ទកបាឋសរណគមន៍ ....... ....... ...... ...... | ២ |
| ពាក្យប្រារព្ធ ....... ....... ...... ...... | ៣ |
| ពណ៌នាត្រៃសរណៈ ....... ....... ...... ...... | ៩ |
| ខុទ្ទកបាឋសិក្ខាបទ ១០ ....... ....... ...... ...... | ២៧ |
| អដ្ឋកថាសិក្ខាបទ ១០ ....... ....... ...... ...... | ២៨ |
| ខុទ្ទកបាឋអាការ ៣២ ....... ....... ...... ...... | ៥៩ |
| អដ្ឋកថាទ្វត្តឹសាការ ....... ....... ...... ...... | ៥៩ |
| ខុទ្ទកបាឋសាមណេរបញ្ហា ....... ....... ...... ...... | ១២៣ |
| អដ្ឋកថាកុមារបញ្ហា ....... ....... ...... ...... | ១២៤ |
| ខុទ្ទកបាឋមង្គលសូត្រ ....... ....... ...... ...... | ១៥០ |
| អដ្ឋកថាមង្គលសូត្រ ....... ....... ...... ...... | ១៥៣ |
| ខុទ្ទកបាឋរតនសូត្រ ....... ....... ...... ...... | ២៧៦ |
| អដ្ឋកថារតនសូត្រ ....... ....... ...... ...... | ២៨០ |
| ខុទ្ទកបាឋតិរោកុឌ្ឌកណ្ឌ ....... ....... ...... ...... | ៣៥៤ |
| អដ្ឋកថាតិរោកុឌ្ឌកណ្ឌ ....... ....... ...... ...... | ៣៥៦ |
| ខុទ្ទកបាឋនិធិកណ្ឌ ....... ....... ...... ...... | ៣៨៧ |
| អដ្ឋកថានិធិកណ្ឌ ....... ....... ...... ...... | ៣៨៩ |
| ខុទ្ទកបាឋករណីយមេត្តសូត្រ ....... ....... ...... ...... | ៤២០ |
| អដ្ឋកថាមេត្តសូត្រ ....... ....... ...... ...... | ៤២២ |

# ធម្មបទគាថា

## យមកវគ្គទី ១ ( ៤៦០ )


រឿងព្រះចក្ខុបាលត្ថេរ ....... ....... ...... ...... ៤៦៦

រឿងមដ្ឋកុណ្ឌលី ....... ....... ...... ...... ៤៩៦

រឿងព្រះតិស្សត្ថេរ ....... ....... ...... ...... ៥១២

រឿងនាងកាឡីយក្ខិនី ....... ....... ...... ...... ៥២៣

រឿងភិក្ខុក្នុងក្រុងកោសម្ពី ....... ....... ...... ...... ៥៣៣

រឿងចុល្លកាល និងមហាកាល ....... ....... ...... ...... ៥៥០

រឿងទេវទត្តភិក្ខុ ....... ....... ...... ...... ៥៦៣

រឿងសញ្ជ័យ ....... ....... ...... ...... ៥៧១

រឿងព្រះនន្ទត្ថេរ ....... ....... ...... ...... ៦១១

រឿងនាយចុន្ទសូករិកៈ ....... ....... ...... ...... ៦២៦

រឿងធម្មិកឧបាសក ....... ....... ...... ...... ៦៣១

រឿងទេវទត្តភិក្ខុ ....... ....... ...... ...... ៦៣៦

រឿងនាងសុមនាទេវី ....... ....... ...... ...... ៦៥៩

រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីរនាក់ ....... ....... ...... ...... ៦៦៣


# ធម្មបទគាថា

## អប្បមាទវគ្គទី ២ ( ៦៧២ )


រឿងព្រះនាងសាមាវតី ....... ....... ...... ...... ៦៧៤

រឿងកុម្ភឃោសកៈ ....... ....... ...... ...... ៧៦៦

រឿងចូឡបន្ថកត្ថេរ ....... ....... ...... ...... ៧៧៧

រឿងពាលនក្ខត្តឫក្ស ....... ....... ...... ...... ៧៩៧

រឿងព្រះមហាកស្សបត្ថេរ ....... ....... ...... ...... ៨០១

រឿងភិក្ខុ ២ អង្គជាសម្លាញ់នឹងគ្នា ....... ....... ...... ...... ៨០៤
រឿងសក្កទេវរាជ ....... ....... ...... ...... ៨០៨
រឿងអញ្ញត្រភិក្ខុ ....... ....... ...... ...... ៨៣០
រឿងព្រះតិស្សត្ថេរអ្នកមានប្រក្រតីនៅក្នុងនិគម ....... ....... ...... ...... ៨៣២